# ឯកទេស

# ប្រវត្តិវិទ្យា



សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២)

២០២៦

# បុព្វកថា

ទស្សនៈវិស័យអប់រំនាសតវត្សរ៍ទី២១ បានផ្ដោតលើការរីកចម្រើនខ្លាំងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងឌីជីថល (Digital) ដែលជាមូលដ្ឋានគ្រឹះរឹងមាំមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសគឺការអភិវឌ្ឍធនធានមនុស្សដើម្បីឆ្ពោះទៅរកគំនិតនវានុវត្តន៍ថ្មីៗ សម្រាប់បម្រើឱ្យសេចក្ដីត្រូវការរបស់សង្គមជាតិទាំងមូល។ ដោយសារនិន្នាការពិភពលោក ដែលមានការអភិវឌ្ឍឥតឈប់ឈរ ទើបរាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបណ្ដុះបណ្ដាល និងអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព។

ឈរលើស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ បានដាក់ចេញនូវគោលដៅជាអាទិភាពសម្រាប់ការធ្វើកំណែទម្រង់វិស័យអប់រំដោយផ្អែកលើ សសរស្ដម្ភទាំងប្រាំរួមមាន៖ ១. ការអនុវត្តគោលនយោបាយគ្រូបង្រៀន ២.ការវាយតម្លៃ ៣.ការងារអធិការកិច្ច ៤. កម្មវិធីសិក្សា និងបរិស្ថាន ៥.ឧត្ដមសិក្សា។ ដោយឡែក កំណែទម្រង់គ្រូបង្រៀន និងកម្មវិធីសិក្សាធានាឱ្យកម្ពុជាមានធនធានមនុស្ស ដែលមានសមត្ថភាពសម្រាប់ដំណើរការអភិវឌ្ឍលើគ្រប់វិស័យ។ ក្រសួងអប់រំ យុវជន និងកីឡាបានកែលម្អកម្មវិធីសិក្សាគ្រប់មុខវិជ្ជា នៅគ្រប់កម្រិតគ្រប់ភូមិសិក្សារហូតដល់កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀន ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា និងកាន់តែធ្វើឱ្យប្រសើរឡើង នូវគុណភាពអប់រំ ក្នុងគោលបំណងឆ្លើយតបទៅនឹងការវិវឌ្ឍរបស់ពិភពលោក និងគោលដៅយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

សៀវភៅសិក្សាគោលនេះ ត្រូវបានកសាងឡើងដោយគ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ ដើម្បីកសាងឧត្ដមភាពគុណវុឌ្ឍគ្រូបង្រៀន ទៅតាមទស្សនៈ និងចក្ខុវិស័យថ្មី ជាមួយនឹងខ្លឹមសារបែបវិទ្យាសាស្ត្រ បែបបញ្ញត្តិសិក្សា និងបញ្ចូលគុណសម្បទាសតវត្សរ៍ទី២១ បន្ថែមទៅលើគុណសម្បទាពលរដ្ឋសកល។

វិទ្យាស្ថានជាតិអប់រំសង្ឃឹមថា គ្រប់ស្ថាប័នអប់រំ ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណាប់អារម្មណ៍ទាំងអស់ចូលរួមគាំទ្រ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តលើ កម្មវិធីបណ្ដុះបណ្ដាលនេះ ដើម្បីពង្រឹងសក្ដានុពលរបស់គ្រូបង្រៀននៅគ្រប់កម្រិតសិក្សាទាំងអស់ ដើម្បីអភិវឌ្ឍជំនាញវិជ្ជាជីវៈជាគ្រូបង្រៀនឱ្យកាន់តែល្អប្រសើរឡើង។

វិទ្យាស្ថានជាតិអប់រំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះ គណៈកម្មការអភិវឌ្ឍកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម (បរិញ្ញាបត្រ+២) ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាធ្វើឱ្យស្នាដៃដ៏មានសារៈសំខាន់នេះ សម្រេចបានដើម្បីជាប្រយោជន៍ដល់សង្គមជាតិយើង។

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥

**នាយកវិទ្យាស្ថានជាតិអប់រំ**

## អារម្ភកថា

ប្រវត្តិសាស្ត្រ គឺជាផ្នែកមួយនៃអត្តសញ្ញាណ និងមោទនភាពនៃជាតិមួយ និងពិភពលោកដែលប្រជាជនត្រូវមានកាតព្វកិច្ចសិក្សាឈ្វេងយល់ វិភាគ វាយតម្លៃ ពិចារណា និងទាញយកបទពិសោធពីប្រវត្តិសាស្ត្រ។ ការទទួលស្គាល់ការពិតនៃប្រវត្តិសាស្ត្រ ការចងចាំ ការចង់ដឹង និងឈ្វេងយល់ពីប្រវត្តិសាស្ត្រជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ ការធានាចីរភាពអភិវឌ្ឍន៍ និងសន្តិភាព ជាពិសេសសម្រាប់ប្រទេសដែលទើបរួចផុតពីជម្លោះដូចជាប្រទេសកម្ពុជា។ បេសកកម្មនៃការសិក្សាប្រវត្តិសាស្ត្រគឺសំដៅយល់ដឹងឱ្យបានច្បាស់អំពីខ្លួនឯង វាយតម្លៃអំពីផលប៉ះពាល់ និងផលវិបាកនៃប្រវត្តិសាស្ត្រ រួមទាំងប្រើប្រាស់ប្រវត្តិសាស្ត្រដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមទទួលខុសត្រូវនៅក្នុងកិច្ចការសង្គម។ ចំណេះដឹងប្រវត្តិសាស្ត្រប្រកបដោយការត្រិះរិះពិចារណា និងការទទួលខុសត្រូវនឹងប្រែក្លាយសិស្សឱ្យទៅជាពលរដ្ឋសកម្ម ប្រកបដោយសមត្ថភាព និងមនសិការជាតិ។ អតីតកាលគឺជាប្រទីបបំភ្លឺបច្ចុប្បន្នកាល និងបង្ហាញផ្លូវទៅកាន់អនាគតកាល ហើយមានទំនាក់ទំនងរវាងគ្នាដែលមិនអាចកាត់ផ្តាច់បាន។ បើអ្នកដឹងអតីតកាលកាន់តែច្រើន អ្នកនឹងរៀបចំអនាគតកាលបានកាន់តែល្អប្រសើរ។ ប្រជាជាតិមួយដែលគ្មានចំណេះដឹងអំពីអតីតកាលគឺគ្មានអត្តសញ្ញាណ។ ដូចច្នេះ អ្នកប្រវត្តិសាស្ត្រត្រូវតែរក្សាទុកនូវកាលដែលកន្លងហួសទៅហើយ ពោលគឺអ្នកប្រវត្តិវិទ្យាមិនត្រូវបញ្ចេញការរំភើបចិត្ត ការស្រលាញ់ចូលចិត្តរបស់ខ្លួនទៅក្នុងការសិក្សានោះឡើយ ពីព្រោះពុំមែនជាការសរសេរប្រលោមលោកនោះទេ។ ប្រវត្តិវិទូមិនមែនជាមនុស្សដែលចេះអស់នោះទេ ពីព្រោះមានពីព្រឹត្តិការណ៍ច្រើនណាស់ ដែលយើងមិនបានដឹង ហើយប្រវត្តិវិទូ ឬអ្នកប្រវត្តិសាស្ត្រគួរតែនាំគ្នាធ្វើការជាក្រុម ដើម្បីងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ។ ជាពិសេសនោះ រាល់ការបកស្រាយរបស់អ្នកប្រវត្តិសាស្ត្រត្រូវបង្ហាញគំនិតប្រកបដោយទស្សនសម្ភារៈនិយម និងមានភស្តុតាងច្បាស់លាស់។

សៀវភៅនេះត្រូវបានរៀបចំជាបីផ្នែកគឺប្រវត្តិសាស្ត្រខ្មែរ តំបន់ និងសកលលោក។ ឯកសារនេះជាសៀវភៅជំនួយនៃការបង្រៀន និងរៀន ដែលកើតចេញពីការដកស្រង់ពីឯកសារនានាដែលអ្នករៀបរៀងបានប្រាប់ពីប្រភពសម្រាប់ឱ្យគរុនិស្សិតស្រាវជ្រាវបន្ថែម និងដើម្បីឱ្យឯកសារនេះមានលក្ខណៈវិទ្យាសាស្ត្រផងដែរ។ ដោយសារតែអ្នករៀបរៀង បង្រៀនសិស្សដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល វិធីសាស្ត្រសិក្សាបញ្ញត្តិ បែបរិះរក ដូចច្នេះទាមទារឱ្យគរុនិស្សិតត្រូវមានសៀវភៅផ្សេងៗសម្រាប់ស្រាវជ្រាវបន្ថែម។

គណៈកម្មការរៀបចំសៀវភៅឯកទេសប្រវត្តិវិទ្យា សង្ឃឹមថាសៀវភៅនេះនឹងផ្តល់មូលដ្ឋានគ្រឹះ ដ៏មានប្រយោជន៍សម្រាប់អ្នកអនុវត្ត ជាពិសេសគ្រូបង្រៀន គរុនិស្សិត ដែលទទួលបានការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំយកទៅអនុវត្ត និងជាចំណែកមួយបន្ថែមក្នុងការស្រាវជ្រាវ ទោះបីខ្លឹមសារក្នុងសៀវភៅនេះពុំទាន់មានលក្ខណៈល្អប្រសើរក៏ដោយ។

គណៈកម្មការរៀបចំសៀវភៅឯកទេសប្រវត្តិវិទ្យា សូមរង់ចាំទទួលនូវការរិះគន់ស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ អ្នកសិក្សាដើម្បីយកមកកែសម្រួលនៅពេលបោះពុម្ពក្រោយៗទៀត។

**គណៈកម្មការរៀបចំសៀវភៅ**

ចងក្រង និងបោះពុម្ពដោយៈ វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២៦
គាំទ្រថវិកាដោយវិទ្យាស្ថានជាតិអប់រំ
© វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៦

## គណៈកម្មការនិពន្ធ

-លោក ទី សុផល

-លោកប៉ូ សុខា

## គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

-បណ្ឌិត សោន វណ្ណៈ

-លោក ប៊ុនលី ម៉ារឌី

-លោកស្រី វ៉ា ចំណាន

-បណ្ឌិត ទៀង សោភទ្រា

-លោកស្រី ជា កល្យាណ

## គណៈកម្មការរចនា

-លោក ប៊ុនលី ម៉ារឌី

-លោកស្រី វ៉ា ចំណាន

-លោកស្រី វីរៈ ខេងឡា

-កញ្ញា ជា សូដាភា

-កញ្ញា កែវ កញ្ញា

## គណៈកម្មការគ្រប់គ្រង

-ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

-លោក ម៉ៅ សារឿន

-បណ្ឌិត អាន រ៉ូប្រាវ

# មាតិកា


បុព្វកថា ........................................................................................................ I

អារម្ភកថា ...................................................................................................... II

គណៈកម្មការនិពន្ធ ......................................................................................... III

មាតិកា.......................................................................................................... IV

**មេរៀនទី១ សំណេរឧត្តមសិក្សា ........................................................................ 2**

១-ការអាន....................................................................................................... 2

២-អ្នកនិពន្ធ និងរៀបរៀង ................................................................................... 2

៣-ប្រភពបណ្ណសារ ............................................................................................ 3

៤-យោង និងឧបសម្ព័ន្ធ ........................................................................................ 4

**មេរៀនទី២ សញ្ញាណទូទៅនៃការសិក្សាប្រវត្តិសាស្ត្រ ................................................. 5**

១-អ្វីជាប្រវត្តិវិទ្យា/ ប្រវត្តិសាស្ត្រ? ........................................................................... 5

២-កាលវិទ្យា ..................................................................................................... 6

**មេរៀនទី៣ បុរេប្រវត្តិសាស្ត្រកម្ពុជា........................................................................ 9**

១-ស្ថានីយបុរេប្រវត្តិសាស្ត្រ ..................................................................................... 9

២-ជីវភាពរស់នៅ.............................................................................................. 10

៣-អរិយធម៌ .................................................................................................... 11

**មេរៀនទី៤ រាជាណាចក្រហ្វូណាន(ពីឆ្នាំ៥០ ដល់៥៥០) ............................................ 13**

១-អត្ថន័យនៃពាក្យហ្វូណាន និងទីតាំងភូមិសាស្ត្រ...................................................... 13

២-ឥទ្ធិពលឥណ្ឌាលើអាណាចក្រហ្វូណាន ............................................................... 15

៣-ព្រះនាមព្រះរាជាល្បីៗសម័យហ្វូណាន ................................................................. 17

៤-រដ្ឋបាល និងសេដ្ឋកិច្ច....................................................................................... 17

៥-ការដួលរលំ .................................................................................................. 18

**មេរៀនទី៥ សម័យចេនឡា (ពីឆ្នាំ៥៥០ ដល់៨០២)................................................... 20**

១-ទីតាំងភូមិសាស្ត្រ............................................................................................ 20

២-បញ្ហាឈ្មោះចេនឡា ........................................................................................ 20

៤-ចេនឡា និងការបែកបាក់.................................................................................. 23

៥-អរិយធម៌ ..................................................................................................... 25

**មេរៀនទី៦ ប្រទេសកម្ពុជាសម័យអង្គរ(ពីឆ្នាំ៨០២ ដល់១៤៣១) ..................................... 27**

១-ព្រះបាទជយវម៌្មទី២(៨០២-៨៣៤)និងការចាប់ផ្តើមសម័យអង្គរ.................................. 27

២-ព្រះរាជាល្បីៗ និងសមិទ្ធិផល ............................................................................. 28

៣-សង្គមខ្មែរសម័យអង្គ ....................................................................................................30
៤-ស្ថាប័នដឹកនាំសម័យអង្គរ......................................................................................................31
**មេរៀនទី៧ ប្រទេសកម្ពុជាសម័យចតុមុខ(ចាប់ពី១៤៣១ ដល់១៥២៩)...........................................37**
១-ការប្រជែងអំណាចក្នុងតំបន់...............................................................................................37
២-បញ្ហាប្រព័ន្ធជាវាសាស្ត្រ និងរបត់ថ្មីនៃពាណិជ្ជកម្ម ..................................................................37
៣-រាជធានីថ្មី.........................................................................................................................37
៤-ព្រះរាជា និងអាណាចក្រទាំង៣ .............................................................................................38
៥-វិបត្តិរាជវង្ស និងការកសាងសង្គមជាតិ ..................................................................................40
**មេរៀនទី៦ សម័យលង្វែក និងការលើកតម្កើងវប្បធម៌ជាតិ(១៥២៩ ដល់១៦១៩).............................43**
១-ព្រះបាទចន្ទរាជា និងការកសាងរាជធានីលង្វែក ......................................................................43
២-ការអភិវឌ្ឍប្រទេស..............................................................................................................43
៣-លង្វែក និងមជ្ឈមណ្ឌលវប្បធម៌...........................................................................................45
៤-ការទំនាក់ទំនងរវាងកម្ពុជា-អឺរ៉ុប..........................................................................................45
៥-ការបែកបាក់ក្រុងលង្វែក និងផលវិបាក...................................................................................46
**មេរៀនទី៩ សម័យឧដុង្គ(ពីឆ្នាំ១៦១៨/១៦២០ ដល់១៨៦៣)............................................................51**
១-ស្ថានភាពខ្មែរក្រោយបែកលង្វែក ..........................................................................................51
២-ព្រះបាទស្រីសុរិយោពម៌ និងការកសាងអធិបតេយ្យភាព ..........................................................51
៣-ខ្មែរ និងការបែកបាក់ផ្ទៃក្នុង(ការដណ្តើមអំណាចរវាងអង្គនន់ និងអង្គតន់)...................................54
៤-ការដណ្តើមឥទ្ធិពលគ្នារវាងមន្ត្រីរបស់ព្រះអង្គអេង ក្នុងឆ្នាំ១៧៩៤ ដល់១៧៩៦..................................56
៥-ដំណោះស្រាយបញ្ចប់សង្គ្រាមសតវត្សរ៍ទី១៨ និង១៩ ...............................................................58
៦-ព្រះបាទអង្គដួង និងទំនាក់ទំនងបារាំង-ខ្មែរ(១៨៤៧-១៨៥៦) ....................................................65
៧-សំណួរត្រិះរិះ ......................................................................................................................66
**មេរៀនទី១០ ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង(១៨៦៣ ដល់១៩៥៣).................................67**
១-កម្ពុជានាសម័យដំបូងនៃអាណាព្យាបាល..................................................................................68
២-សន្ធិសញ្ញា អនុសញ្ញា និងប្រកាស .......................................................................................69
៣-កំណែទម្រង់ និងអភិក្រមទំនើបកម្ម.........................................................................................76
៤-ចលនាតស៊ូដើម្បីទាមទារឯករាជ្យ...........................................................................................78
៥-ផលវិជ្ជមាន និងផលអវិជ្ជមាននៃរបបអាណាព្យាបាលបារាំងនៅកម្ពុជា...........................................79
ផលវិជ្ជមាន...........................................................................................................................79
**មេរៀនទី១០ ប្រទេសកម្ពុជាសម័យសង្គមរាស្ត្រនិយម(ពីឆ្នាំ១៩៥៥ ដល់១៩៧០) .................................81**
១-ស្ថានភាពសង្គមខ្មែរឆ្នាំ១៩៤៦-១៩៥៥ ....................................................................................81
២-ការបង្កើតចលនាសង្គមរាស្ត្រនិយម និងការបោះឆ្នោត...............................................................83
៣-សភាប្រជារាស្ត្រប្រចាំខេត្ត និងរាជធានី...................................................................................88

៤-សមាជជាតិ ........ 89
៥- នយោបាយអព្យាក្រឹត និងចលនាមិនចូលបក្សសម្ព័ន្ធ ........ 92
៦-សម្តេចព្រះនរោត្តម សីហនុ និងជាប្រមុខរដ្ឋឆ្នាំ ១៩៦០ ........ 93
៧-កម្ពុជា និងទំនាក់ទំនងជាមួយប្រទេសសេរី និងកុម្មុយនីស្ត ........ 93
៨-ស្ថានភាពសង្គមខ្មែរ និងការអភិវឌ្ឍជនបទ ........ 99
៩-សមិទ្ធផល និងស្ថានភាពសង្គមខ្មែរចុងសម័យសង្គមរាស្ត្រនិយម ........ 99
**មេរៀនទី១១ សម័យសាធារណរដ្ឋខ្មែរ(ពីឆ្នាំ១៩៧០ ដល់១៩៧៥) ........ 101**
១-ការលេចឡើងនៃរបបសាធារណរដ្ឋខ្មែរ ........ 101
២-សង្គម សេដ្ឋកិច្ច នយោបាយ និងវប្បធម៌សម័យសាធារណរដ្ឋខ្មែរ ........ 104
៣-សង្គ្រាមឆ្នាំ១៩៧០ ដល់១៩៧៥ (ភ្នំពេញជាដង្ហើមចុងក្រោយ) ........ 105
៤-ដំណាក់កាលចុងក្រោយនៃរបបសាធារណរដ្ឋខ្មែរ ........ 107
៥-ការខូចខាត និងផលវិបាក ........ 110
**មេរៀនទី១២ របបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ........ 112**
១-តើខ្មែរក្រហមកើតឡើងដោយរបៀបណា? ........ 112
២-កម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយជ្រុលនិយម ........ 115
៣-ប្រព័ន្ធសន្តិសុខ និងអំពើប្រល័យពូជសាសន៍ ........ 120
៤-ខ្មែរក្រហម និងការធ្វើបដិវត្តន៍ ........ 123
៥-ប្រជាជន និងជីវភាពប្រចាំថ្ងៃ ........ 124
៦-ចលនាប្រឆាំង និងការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ........ 125
**មេរៀនទី១៣ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩ ដល់១៩៩៣) ........ 131**
១-ស្ថានភាពសង្គមខ្មែរក្រោយឆ្នាំ១៩៧៩ ........ 131
២-ការទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហម ........ 137
៣-ដំណើរស្វែងរកកិច្ចចរចាសន្តិភាពនៅកម្ពុជា(១៩៨១-១៩៩១) ........ 138
**មេរៀនទី១៤ ព្រះរាជាណាចក្រកម្ពុជាទី២ ........ 144**
១-វត្តមានរបស់អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា(អ៊ុនតាក់) ........ 144
២-មាតុភូមិនិវត្តន៍ ........ 145
៣-ការបោះឆ្នោតឆ្នាំ១៩៩៣ ........ 145
៤-ស្ថានភាពនយោបាយក្រោយឆ្នាំ១៩៩៣ និងនយោបាយឈ្នះ ឈ្នះ ........ 149
៥-ផលលាភនៃសន្តិភាព និងការអភិវឌ្ឍ ........ 150
៦-ការកាត់ទោសខ្មែរក្រហមៈ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) ........ 151
៧-យុទ្ធសាស្ត្របញ្ចកោណ ........ 152
៨-សំណួរត្រិះរិះ ........ 154
**មេរៀនទី១ ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍សម័យបុរាណ ........ 156**

១-អាស៊ីអាគ្នេយ៍ជាអ្វី?....156
២-ភាសា នៃប្រជាជនអាស៊ីអាគ្នេយ៍ ....158
**៣-ប្រភពសំណេរប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ ....161**
៤-បុរេប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ .... 161
៥-សារតារ និងកំណាក់កំណើតរដ្ឋអាស៊ីអាគ្នេយ៍ពីស.វ.ទី១ដល់ស.វ.ទី៩ ....164
**មេរៀនទី២ ការពង្រីងអំណាចរបស់ពួកអឺរ៉ុប មកលើបណ្តារដ្ឋអាស៊ីអាគ្នេយ៍ ....170**
១-ការដាក់អាណានិគមរបស់ពួកអឺរ៉ុបនៅអាស៊ីអាគ្នេយ៍ ....170
២-អាណានិគមរបស់អង់គ្លេស....170
៣-អាណានិគមបារាំង....174
**៤-អាណានិគមហូឡង់នៅឥណ្ឌូណេស៊ី....179**
**៥-អាណានិគមព័រទុយហ្កាល់ ....180**
**៦-អាណានិគមអេស្ប៉ាញនៅប្រទេសហ្វីលីពីន.... 181**
**៧-ការប្រែប្រួលផ្នែកសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ ....182**
**មេរៀនទី៣ អាស៊ីអាគ្នេយ៍ និងឯករាជ្យ....185**
១-ប្រទេសវៀតណាមក្រោយសង្គ្រាមលោកលើកទី២....185
២-ប្រទេសឥណ្ឌូណេស៊ីក្រោយសង្គ្រាមលោកលើកទី២ ....197
២.៣.២-ស្ថានភាពសេដ្ឋកិច្ច....207
**មេរៀនទី៤ មជ្ឈិមបូព៌ាសម័យសង្គ្រាមត្រជាក់....208**
១-បញ្ហាចម្រុះជាតិសាសន៍ និងសាសនា....208
២-មជ្ឈិមបូព៌ាក្រោយសង្គ្រាមលោកលើកទី១....208
៣-ការប្រជែងឥទ្ធិពលនៃមហាអំណាច....209
**មេរៀនទី៥ សមាគមអាស៊ាន ....220**
១-អង្គការក្នុងតំបន់មុនការបង្កើតអាស៊ាន ....220
២-បុព្វហេតុនៃការបង្កើតអាស៊ាន ....224
៣-កំណើតអាស៊ាន ....225
៤-ដំណើរការវិវត្តនៃអាស៊ាន....228
៥-លក្ខខណ្ឌសម្រាប់សមាជិកភាពក្នុងអាស៊ាន ....228
៦-អត្ថន័យទង់អាស៊ាន....229
**មេរៀនទី៦ អាស៊ាន និងសកលភាវូបនីយកម្ម .... 230**
១-អាស៊ានក្នុងបរបទសង្គ្រាមត្រជាក់....230
២-ការបង្កើត តំបន់ពាណិជ្ជកម្មសេរី អាស៊ាន ....245

៣-កិច្ចសហប្រតិបត្តិការអាស៊ាន ....................................................................................................246
៤-ការបង្កើតសហគមន៍អាស៊ាន ..................................................................................................252

**មេរៀនទី១ អរិយធម៌ពិភពលោកបុរាណ......................................................................................254**

១.អរិយធម៌អេហ្ស៊ីប មេសូប៉ូតាមី ឥណ្ឌា និងចិន ......................................................................254
២.អរិយធម៌ផេនីស៊ី.......................................................................................................................256
៣-អរិយធម៌ហេប្រឺ .......................................................................................................................258
៣.២-សម័យកាលសំខាន់ៗ ............................................................................................................259
៤-ក្រិកបុរាណ...............................................................................................................................260
៤.២-រដ្ឋបុរីនានា ...........................................................................................................................261
៤.៤-ការធ្លាក់ចុះដុនដាប់នៃក្រិកបុរាណ ........................................................................................262
៥.អរិយធម៌រ៉ូម...............................................................................................................................265

**សំណួរត្រិះរិះ...............................................................................................................................268**

**មេរៀនទី២ ទ្វីបអឺរ៉ុបក្នុងមជ្ឈិមសម័យ និងនវសម័យ ...........................................................269**

១-មជ្ឈិមសម័យនៅអឺរ៉ុប ................................................................................................................269
២-ការរស់ឡើងវិញនៃអរិយធម៌អឺរ៉ុប...............................................................................................272
៣-ការរុករកដីថ្មី និងការបែងចែកទឹកដីរវាងអេស្ប៉ាញ និងព័រទុយហ្គាល់ ........................................275
៣.២-ការច្បាំងដណ្ដើមយកដី .........................................................................................................280
៤.បដិវត្តន៍គហបតីនៅអឺរ៉ុប និងអាម៉េរិក ........................................................................................282

**៤.១-បដិវត្តន៍គហបតីនៅអង់គ្លេស ...................................................................................................282**

**៤.១.១-របបរាជានិយមផ្ដាច់ការនៅអង់គ្លេស....................................................................................282**

**៤.១.២-បដិវត្តន៍គហបតី និងសង្គ្រាមស៊ីវិល ......................................................................................283**

**៤.១.៣-របបរាជធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ...................................................................................284**

៥-បដិវត្តន៍ឧស្សាហកម្ម និងការផ្លាស់ប្ដូរសង្គមអឺរ៉ុប ......................................................................291

**មេរៀនទី៣ ស្ថានភាពពិភពលោកមុនសង្គ្រាមលោកលើកទី១ .....................................................299**

១-ប្រទេសមហាអំណាចនៅត្រឹមដើមសតវត្សទី២០ ........................................................................299
២-ការប្រណាំងប្រជែងខាងកម្លាំង សេដ្ឋកិច្ច និងអាណានិគម..........................................................326
៣-ការបង្កើតប្លុកយោធា ..................................................................................................................330

**មេរៀនទី៤ ពិភពលោកដំណាក់កាលសង្គ្រាមលោកលើកទី១(១៩១៤-១៩១៨)............................... 333**

១-ព្រឹត្តិការណ៍សំខាន់ៗនាំទៅរកសង្គ្រាមលោកលើកទី១ ...............................................................333
២-បុព្វហេតុនៃសង្គ្រាម...................................................................................................................336
៣-ប្លុកដែលចូលរួមប្រយុទ្ធនៅក្នុងសង្គ្រាមលោកលើកទី១ .............................................................341
៤-ដំណើរប្រព្រឹត្តទៅនៃសង្គ្រាម......................................................................................................343

៥-សន្ធិសញ្ញាបញ្ចប់សង្គ្រាមលោកលើកទី១ ....................346
៦-វិនាសកម្ម និងផលវិបាកនៃសង្គ្រាមលោកលើកទី១ ....................347

**មេរៀនទី៥ ពិភពលោកដំណាក់កាលសង្គ្រាមលោកលើកទី២(១៩៣៩-១៩៤៥) ....................352**

១-បុព្វហេតុនៃសង្គ្រាម ....................352
២-ដំណើរប្រព្រឹត្តទៅនៃសង្គ្រាម ....................356
៣-ផលវិបាកដែលបន្សល់ទុកដោយសង្គ្រាមលោកលើកទី២ ....................377
៤-ដំណោះស្រាយសង្គ្រាម ....................380

**មេរៀនទី៦ អង្គការសហប្រជាជាតិ (UNITED NATION) ....................383**

១-ការបង្កើតអង្គការសហប្រជាជាតិ ....................383
២-គោលបំណង និងគោលការណ៍របស់អង្គការសហប្រជាជាតិ ....................385
៣-សមាជិកភាព ....................388
៤-ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ និងតួនាទី ....................389

**មេរៀនទី៧ ពិភពលោកដំណាក់កាលសង្គ្រាមត្រជាក់ ....................396**

១-និយមន័យ ....................396
២-ការចាប់ផ្តើមនៃសង្គ្រាមត្រជាក់ ....................396
៣-វិបត្តិនានាក្នុងដំណាក់ដំបូងនៃសង្គ្រាមត្រជាក់ ....................404
៤-សន្តិសហវិជ្ជមាន១៩៥៣-១៩៦២ និងការលេចឡើងនូវវិបត្តិនានា ....................412
៤.១-និយមន័យ ....................412
**៤.២-បុព្វហេតុខ្លះៗមុននឹងឈានដល់សន្តិសហវិជ្ជមាន** ....................412
៥-ភាពធូរស្រាល ១៩៦៣-១៩៧៥ ....................420
៦-សង្គ្រាមត្រជាក់ល្មម ១៩៧៥-១៩៨៥ ....................424
៧-ទីបញ្ចប់នៃសង្គ្រាមត្រជាក់ និងការរលំរលាយនៃប្លុកសូវៀត ....................427

**ឯកសារយោង ....................437**

# ផ្នែកទី១

# ប្រវត្តិសាស្ត្រខ្មែរ

# មេរៀនទី១ សំណេរឧត្តមសិក្សា

## ១-ការអាន

ការអាន គឺជាមូលដ្ឋានគ្រឹះសំខាន់បំផុតសម្រាប់អ្នកសិក្សា និងគ្រូបង្រៀន ដើម្បីទទួលបានពុទ្ធិសម្រាប់ធ្វើការពិចារណា វិភាគ និងវាយតម្លៃគ្រប់ជ្រុងជ្រោយ។ ចំពោះការសិក្សាមុខវិជ្ជាប្រវត្តិវិទ្យាត្រូវតែអានឱ្យបានច្រើនដើម្បីមានមូលដ្ឋានគ្រឹះផ្នែកប្រវត្តិសាស្ត្រ ដែលនាំឱ្យអ្នក ងាយរៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គមផ្សេងៗ ឬ យល់ស្ថានភាពពេលបច្ចុប្បន្នបានលឿន និងច្បាស់លាស់។

មូលដ្ឋានគ្រឹះនៃការសិក្សាប្រវត្តិសាស្ត្រក៏ជាមេរៀនមួយ ដែលសំខាន់សម្រាប់អ្នកឯកទេសប្រវត្តិវិទ្យា និងអ្នកអានយល់កាន់តែច្បាស់ពីនិយមន័យ និងលក្ខណៈវិច្ឆ័យពីអព្យាក្រឹតនៃឯកសារ និងភស្តុតាងក្នុងការសិក្សាប្រវត្តិសាស្ត្រខ្មែរជាដើម។ ប្រវត្តិសាស្ត្រ គឺជាព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងសង្គមមនុស្ស។ ប្រវត្តិសាស្ត្រគេរាប់បញ្ចូលទាំងព្រឹត្តិការណ៍ដ៏យូរលង់មកហើយ និងព្រឹត្តិការណ៍ដែលទើបតែកើតឡើងសូម្បីតែម្សិលមិញ។ ប៉ុន្តែប្រវត្តិវិទ្យានៃបច្ចុប្បន្នកាល[1]ត្រូវមានលក្ខណៈជាអត្ថបទស៊ីជម្រៅ ដែលសរសេរដោយ អ្នកសារព័ត៌មានឈានមុខ និងអ្នកប្រាជ្ញ ដែលបានសរសេរអំពីក្រុង ឬរាជធានីដែលកំពុងឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅ។ បញ្ញវន្តដែលសរសេរអំពីប្រវត្តិសាស្ត្រហៅថាប្រវត្តិវិទូ[2]។

ចំណែកអ្នកដែលអានឯកសារបានច្រើនមិនមែនជាប្រវត្តិវិទូនោះទេ ប៉ុន្តែប្រវត្តិវិទូគឺត្រូវតែជាអ្នកអានឯកសារបានច្រើន។ យើងមិនអាចក្លាយជាប្រវត្តិវិទូស្វ័យប្រកាស ដោយសារតែខ្លួនអានឯកសារ ឬ សៀវភៅបានច្រើនប្រភេទឬច្រើនក្បាលឡើយ គឺបុគ្គលត្រូវមានការណែនាំអំពីវិធីសាស្ត្រសិក្សាស្រាវជ្រាវ, ការសរសេរលក្ខណៈវិទ្យាសាស្ត្រពីគ្រូ និងការស្រាវជ្រាវឯកសារសម្រាប់បញ្ចប់កិច្ចការបណ្ឌិតស្រាវជ្រាវរបស់ខ្លួនជាដើម។

ក្នុងការស្រាវជ្រាវឯកសារ នាំមកនូវព័ត៌មានយ៉ាងសំខាន់២លេចឡើងគឺឯកសារមានយ៉ាងច្រើននិងមានគុណភាព និងឯកសារមិនអត់ប៉ុន្តែក៏មានមិនច្រើន។ ប្រវត្តិវិទូទាំងឡាយមិនអាចបកស្រាយពិភពលោកតាមរយៈ អេក្រង់នៃទ្រឹស្តីនោះទេ។ ពួកគេព្យាយាមមើលឃើញវា និងយល់ដឹងពីវាដោយផ្ទាល់[3] ហើយតាមរយៈការប្រៀបធៀបប្រវត្តិវិទូគឺប្រៀបដូចជាតារាមួយដួង[4]។ ការសិក្សាឯកសារមានគោលបំណងសំខាន់ចំនួន៤គឺ[5]រំឭកអំពីការវិវត្តន៍ជាប្រវត្តិសាស្ត្រ, ឆ្លុះបញ្ចាំងនូវបណ្តាទស្សនៈបច្ចុប្បន្ន, ធ្វើសំយោគលើចំណេះដឹងទាំងនោះ និងរកឱ្យឃើញនូវប្រព័ន្ធនៃការពន្យល់បែបថ្មីសន្លាងឱ្យហួសពីការពន្យល់ជាច់ៗ ឬ មានភាព លំអៀង។

## ២-អ្នកនិពន្ធ និងរៀបរៀង

អ្នកនិពន្ធត្រូវធ្វើយ៉ាងណាឱ្យឯកសាររបស់ខ្លួនមានរបៀបរៀងគ្នា, ដាក់រៀងតាមរបៀប ដោយស្រង់សេចក្តីពីនេះខ្លះ ពីនោះខ្លះ មកចងក្រងរៀបជារបៀប ដោយតាមលំដាប់កាល ឬ ជាការសិក្សាបញ្ញត្តិ ដោយមានប្រភពឯកសារយោងច្បាស់លាស់។ គេអាចឈ្វេងយល់ពីអតីតកាលបានដោយផ្អែកលើសិលាចារឹក, របាយការណ៍, កំណត់ហេតុប្រចាំថ្ងៃ, ឯកសារសហសម័យ, ស្នាដៃនិពន្ធ និងការនិយាយប្រាប់ពីមនុស្សជំនាន់មុននូវអ្វីដែល

---

[1] ប្រវត្តិវិទ្យានៃបច្ចុប្បន្នកាលមានន័យថាការសរសេរប្រវត្តិសាស្ត្រថ្មីៗក្នុងពេលបច្ចុប្បន្ន។ សូមមើលនិយមន័យនៃពាក្យ History of Present។

[2] ស៊ន សំណាង: *បឋកថាសម្រាប់គរុនិស្សិតប្រវត្តិវិទ្យាកម្រិតឧត្តម នៅវិទ្យាស្ថានជាតិអប់រំ*, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៥។

[3] ម៉យ ស៊ីណាន, *សញ្ញាណទស្សនវិជ្ជាប្រវត្តិសាស្ត្រ(សៀវភៅបកប្រែ)*, ភ្នំពេញ, ២០២៣, ទំព័រ៣៣។

[4] -ដ- ទំព័រ៤២។

[5] ស៊ន សំណាង, *វិធីសាស្ត្រស្រាវជ្រាវ និងសរសេរសារណា ឬ និក្ខេបបទ*, ប្រើប្រាស់ផ្ទៃ, ឆ្នាំសិក្សា២០២២-២០២៣, ទំព័រ១២។

ពួកគាត់បានដឹង ឃើញផ្ទាល់ និងតឹកតាងដ៏ជាក់លាក់។ អ្វីដែលសំខាន់ទៅទៀតនោះ គឺត្រូវសិក្សាពិនិត្យមើលថាតើតឹកតាងទាំងនោះគួរឱ្យទុកចិត្តបានកម្រិតណា?

ក្នុងការសរសេរឯកសារអ្នកស្រាវជ្រាវ អ្នកសិក្សាឧត្តមសិក្សាត្រូវតែស្វែងរកប្រភពឯកសារបានច្រើននៅក្នុងដៃ មុននិងនិយាយ ឬ និពន្ធ។ ចំណែកឯកសារប្រវត្តិសាស្ត្រសម័យទំនើប ត្រូវតែជាឯកសារដែលនិពន្ធឡើងដោយយោងពីប្រភពមួយច្បាស់លាស់, ជាក់លាក់ និងអាចទទួលយកបាន។ អ្នកឯកទេសប្រវត្តិវិទ្យា ត្រូវចេះសរសេរសំណេរឧត្តមសិក្សា[6] ហើយក៏ត្រូវចេះជ្រើសរើសស្នាដៃនិពន្ធ ទាំងឡាយណា ដែលជាប្រភេទសំណេរឧត្តមសិក្សា ឬ ការស្រាវជ្រាវបែបវិទ្យាសាស្ត្រផងដែរ។ សំណេរឧត្តមសិក្សា(Academic Writing) ត្រូវផ្អែកលើភស្តុតាងគឺមានឯកសារយោង (Reference) ដែលអាចជា«បណ្ណសារ[7]»(Archives) គឺឯកសារប្រភពទី១ (Primary Sources) ឬជា «ស្នាដៃនិពន្ធ[8]» (Books, articles...) គឺឯកសារប្រភពទី២ (Secondary Sources)[9]។ អ្នកស្រាវជ្រាវអាចសម្ភាសអ្នកជំនាញក្នុងប្រធានបទ ដែលគាត់ធ្លាប់គ្រប់គ្រង និងធ្លាប់អនុវត្តផ្ទាល់ជាដើម។ លើសពីនេះទៅទៀត ហើយអ្នកសិក្សាអាចធ្វើការស្រាវជ្រាវដល់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានជាមួយប្រភពឯកសារដែលប្រមូលបានផងដែរ។

អ្នកនិពន្ធត្រូវការផ្ទៀងផ្ទាត់អត្ថបទបោះពុម្ពថ្មីៗ ជាមួយអត្ថបទបោះពុម្ពពីមុន ឬជាមួយឯកសារដើមគឺជាការពិបាកណាស់។ នៅពេលអង្កេតដល់ទីកន្លែងតម្កល់ឯកសារ អ្នកស្រាវជ្រាវមានការខកចិត្ត ប្រសិនបើអត្ថបទ ថ្មីនោះ ខុសពីឯកសារដើម[10]។

## ៣-ប្រភពបណ្ណសារ

អ្នកសិក្សាត្រូវចេះស្រាវជ្រាវតាមប្រភពផ្សេងគ្នាតាមបណ្ណាគារ, បណ្ណាល័យ និងបណ្ណសារដ្ឋានជាតិជាដើម។ សម្រាប់ការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរចាប់ពីឆ្នាំ១៨៦៣ មកអ្នកសិក្សាស្រាវជ្រាវត្រូវស្វែងរកឯកសារបណ្ណសារ ឬឯកសារប្រភពទីមួយពីកន្លែងសំខាន់ៗដូចជាបណ្ណាល័យក្រសួងព័ត៌មាន, បណ្ណាល័យព្រឹទ្ធសភា, បណ្ណាល័យជាតិ, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងបណ្ណសារដ្ឋានជាតិ ជាដើម។ ប៉ុន្តែកន្លែងដែលមានផ្ទុកឯកសារប្រភពទី១ ច្រើនជាងគេនោះគឺបណ្ណសារដ្ឋានជាតិ។ បណ្ណសារដ្ឋានជាតិនៃកម្ពុជាគឺជាកន្លែងផ្ទុកឯកសារដើមដ៏ចំណាស់ជាងគេនៅកម្ពុជា ដែលសម្ភោធឱ្យប្រើប្រាស់តាំងពីឆ្នាំ១៩២៦មកម្ល៉េះ។ អ្នកសិក្សាអាចទៅស្រាវជ្រាវរកឯកសារប្រភពទី១នៅកន្លែងនេះ ដែលមានដូចជា កាសែត,ទស្សនាវដ្តី... និងប្រភេទឯកសារសំខាន់ៗ ជាច្រើនសម្រាប់ស្រាវជាវ។ បើយោងតាមការផ្តល់ទិន្នន័យជូនដោយអ្នកជំនាញរក្សាឯកសារ នៅបណ្ណសារដ្ឋានជាតិ នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ បានបញ្ជាក់ថា ឯកសារសំខាន់ដែលត្រូវរកនៅទីនេះមានដូចជា៖

---

[6] ក្នុងទិដ្ឋភាពទូទៅគឺអ្នកនយោបាយ ស្វែងរកការឈ្នះ, អ្នកវិទ្យាសាស្ត្រស្វែងរកការពិត, តុលាការត្រូវធ្វើយ៉ាងណាឱ្យយុត្តិធម៌បំផុត។ ចំណែកអ្នកស្រាវជ្រាវឧត្តមសិក្សា ត្រូវធ្វើយ៉ាងណាឱ្យសច្ចៈ។

[7] បណ្ណសារ»(Archives) ជាឯកសារប្រភពទី១ (Primary Sources) មាននៅក្នុងមណ្ឌលឯកសារនៃក្រសួង មន្ទីរ ស្ថាប័ន សាលារៀន...ឬ នៅក្នុងបណ្ណសារដ្ឋានជាតិ។ «បណ្ណសារ» អាចជាព្រះរាជក្រឹត្យ, អនុក្រឹត្យ, សេចក្តីសម្រេច, ប្រកាស, សារាចរណែនាំ, របាយការណ៍, កំណត់ហេតុអង្គប្រជុំ។

[8] ស្នាដៃនិពន្ធ» (Works: Books, articles) ជាឯកសារប្រភពទី២ (Secondary Sources) មាននៅក្នុងបណ្ណាល័យជាតិ បណ្ណាល័យនានា មណ្ឌលឯកសារនៃក្រសួង, មន្ទីរ និងស្ថាប័ន ដែលអាចជានិក្ខេបបទ, សារណា, អត្ថបទទស្សនាវដ្តី, អត្ថបទសិក្ខាសាលា, អត្ថបទអេឡិចត្រូនិក, សៀវភៅ និពន្ធដោយបុគ្គលម្នាក់ ឬ ជាក្រុម ឬជាស្នាដៃរបស់ស្ថាប័ន។

[9] ស៊ន សំណាង, *វិធីសាស្ត្រស្រាវជ្រាវ និងសរសេរសារណា ឬ និក្ខេបបទ*, ជ.ឯ.ម., ទំព័រ១០។

[10]-ដ- ទំព័រ១២។

- ព្រឹត្តិបត្ររដ្ឋបាលឥណ្ឌូចិនបារាំង : ចាប់ពីឆ្នាំ១៨៩៥ (ដាច់ៗ)ដល់១៩៥១)
- ព្រឹត្តិបត្ររដ្ឋបាលប្រទេសកម្ពុជា : ចាប់ពី១៩០២(ដាច់ៗ)
- រាជកិច្ចរាជការ ជាភាសាខ្មែរ : ពីឆ្នាំ១៩១១(ដាច់) ដល់១៩៣៥ (បាត់ពីឆ្នាំ១៩៣៦ រហូតដល់ឆ្នាំ ១៩៤៧ អាចមកពីបារាំងមិនបានទុកដាក់ឱ្យ ព្រោះបារាំងជាប់នឹងសង្គ្រាមលោកផងដែរ)
- រដ្ឋកិច្ចសម័យលន់ នល់: ១៩៧០ ដល់១៩៧៣
- ហ្មុង ឬ មូលឯកសាររសៀដង់ជាន់ខ្ពស់ ជាភាសាបារាំង ចាប់ពីឆ្នាំ១៨៦៣ ដល់១៩៥៣
- ហ្មុងឧត្តមនាវីពីឆ្នាំ១៨៥៩ ដល់១៨៨៧ (អាចមានមួយចំនួន)
- រដ្ឋកិច្ចពីឆ្នាំ១៩៨៥ ដល់១៩៩៣
- រាជកិច្ចពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ន។
- ផ្សេងៗ

នៅពេលទៅដល់ទីកន្លែងស្រាវជ្រាវ អ្នកស្រាវជ្រាវត្រូវយកចិត្តទុកដាក់លើចំណុចពីរគឺខំរកឯកសារដែលមិនអាចរំលងបាន សម្រាប់ជួយពង្រឹងសារណា ឬ និក្ខេបបទរបស់អ្នក និងការរុករកឯកសារ មិនត្រូវឱ្យស្រូបយកពេលវេលាច្រើនហួសពេកនោះទេ។ ក្នុងពេលរកឯកសារអ្នកសិក្សាត្រូវ៖

- បើរកបានឯកសារហើយ ត្រូវបង្កើនការអានឱ្យរហ័ស។
- ឯកសារទាំងឡាយ ទោះមានសារៈសំខាន់តិចតួចក៏ដោយ ក៏ត្រូវកត់ត្រានៅលើ Fiche ដែលត្រូវ៖ បង្ហាញតាមក្បួនខ្នាតនៃឯកសារគន្ថនិទ្ទេស និងកត់ឈ្មោះមជ្ឈមណ្ឌលឯកសារកត់លេខ Coteឯកសារ ក្រែងត្រូវការមើលម្តងទៀត
- កត់ខ្លឹមសារមួយចំនួនដែលមានលក្ខណៈទូទៅ ,ឃ្លាដកស្រង់ ,ទំព័រទាក់ទង សេចក្តីសង្ខេប ជាដើម។

## ៤-យោង និងឧបសម្ព័ន្ធ

ការតែងនិពន្ធ ដែលមានឯកសារយោង និងឧបសម្ព័ន្ធដែលអាចទទួលយកបានពីប្រភពផ្សេងៗគ្នា ដែលជាឯកសារដើម នោះបង្ហាញថាអ្នកនិពន្ធមានសមត្ថភាពខ្ពស់ក្នុងការតែងនិពន្ធ។ នៅក្នុងឯកសារយោងមានដាក់ បណ្ណសារ, គន្ថនិទ្ទេស, ឧបសម្ព័ន្ធ និងការពន្យល់ពាក្យ។

# មេរៀនទី២ សញ្ញាណទូទៅនៃការសិក្សាប្រវត្តិសាស្ត្រ

## ១-អ្វីជាប្រវត្តិវិទ្យា/ ប្រវត្តិសាស្ត្រ?

នៅក្នុងសៀវភៅខេមរយានកម្ម ចាប់ផ្តើមមានការបែងចែកពាក្យ«ប្រវត្តិវិទ្យា និងប្រវត្តិសាស្ត្រ» ដោយសារតែមុខវិជ្ជានេះ ជាមុខវិជ្ជាវិទ្យាសាស្ត្រ ទើបគេបានកំណត់បែបនោះ។ ក្នុងការសិក្សាប្រវត្តិសាស្ត្រគឺគេត្រូវយល់ឱ្យច្បាស់អំពីពាក្យប្រវត្តិ, ប្រវត្តិសាស្ត្រ, ប្រវត្តិវិទ្យា, ហេតុការណ៍ និងព្រឹត្តិការណ៍ ជាដើម។ ទោះបីជាភាសាបារាំង និងអង់គ្លេសមិនបានបែងចែកពាក្យប្រវត្តិសាស្ត្រ និងប្រវត្តិវិទ្យា(History/ Histoire) ក៏ដោយ ប៉ុន្តែប្រវត្តិវិទូខ្មែរនាសម័យសាធារណរដ្ឋខ្មែរបានបែងចែកពាក្យទាំងនេះ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ផងដែរ។ ប្រវត្តិ គឺជាកម្រងព្រឹត្តិការណ៍, ហេតុការណ៍ និងដំណាក់កាល ដែលកំណត់នូវការវិវត្តនៃមនុស្សមួយក្រុម តំបន់ណាមួយ ឬ ក្រុងណាមួយ។ ប្រវត្តិសាស្ត្រគឺជាកម្រងហេតុការណ៍ និងព្រឹត្តិការណ៍ អតីតកាលរបស់មនុស្សជាតិ និងជាចំណេះដឹងអំពីអតីតកាលនៃមនុស្សជាតិ និងសង្គមមនុស្ស[11]។

ចំណែក ប្រវត្តិវិទ្យា គឺជាការសិក្សាអំពីហេតុការណ៍, ព្រឹត្តិការណ៍ និងបទពិសោធអតីតកាលរបស់មនុស្សជាតិដោយពឹងផ្អែកលើកំណត់ត្រា និងសក្ខីកម្មសម្រាប់សហសម័យ។ មុខវិជ្ជានេះសិក្សាអំពីអតីតកាលនៃមនុស្សជាតិ, សង្គមមនុស្សដែលប្រវត្តិវិទូព្យាយាមកសាងឡើងវិញ, ការបកស្រាយឡើងវិញដោយពឹងផ្អែកទៅលើកំណត់ត្រាប្រវត្តិសាស្ត្រ និងសក្ខីកម្មសម្រាប់សហសម័យ[12] ។

ប្រវត្តិវិទូជនជាតិអាម៉េរិកាំងមួយរូប ដែលបានឱ្យតម្លៃខ្លាំងលើប្រវត្តិសាស្ត្របានមានប្រសាសន៍ថា« អ្នកមិនស្គាល់ប្រវត្តិសាស្ត្ររបស់ខ្លួនគឺជាសត្វ»។ ចំណែកឯព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ាសិរីវុឌ្ឍន៍ បានមានព្រះរាជបន្ទូលថា *អ្នកមិនស្គាល់ពីប្រវត្តិសាស្ត្ររបស់ខ្លួន គឺដូចជាដើមឈើងាប់មួយដើម*[13]។ ការយកចិត្តទុកដាក់ទៅលើមេរៀនប្រវត្តិសាស្ត្រ គឺជាការចូលរួមលើកកម្ពស់វប្បធម៌អត្តសញ្ញាណជាតិ និងអន្តរជាតិ។ ជាពិសេសនោះគឺនាំយុវជនឱ្យក្លាយជាពលរដ្ឋរបស់ជាតិពិតប្រាកដ និងជាពលរដ្ឋសកលដែលជាតម្រូវការរបស់ពិភពលោកនាពេលបច្ចុប្បន្ន។ នៅឆ្នាំ២០១៤ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ក្នុងនាមជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាបានមានប្រសាសន៍ជាមួយគ្រូសារអ្នកប្រវត្តិសាស្ត្រកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤ នៅភោជនីយដ្ឋានបឹងមាសថា*«...ប្រជាពលរដ្ឋខ្មែរត្រូវតែស្គាល់ប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ហើយខ្ញុំនឹងជំរុញឱ្យមានការយក ចិត្តទុកដាក់ទៅលើមុខវិជ្ជានេះ...»*[14]។ ទាក់ទងនឹងនិយមន័យនៃពាក្យប្រវត្តិសាស្ត្រនេះគឺមានមតិយល់ឃើញផ្សេងគ្នាជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រ តែទោះបីជាយ៉ាងណាក៏ការយល់ឃើញទាំងអស់នោះសុទ្ធតែបានបង្ហាញឱ្យឃើញពីលក្ខណៈវិទ្យាសាស្ត្រនៃមុខវិជ្ជា ប្រវត្តិវិទ្យាផងដែរ។ លោកបណ្ឌិត ម៉ាយឃើល វិកឃើរី បានរៀបរាប់ថា ប្រវត្តិវិទ្យាជាអត្តសញ្ញាណជាតិមួយដែលមានលក្ខណៈទោលបំផុតសម្រាប់ប្រជាជាតិនីមួយៗ និងជាដួងព្រលឹងនៃប្រទេសជាតិមួយ និងដែលមិនអាចមានប្រទេសដូចបាន[15]។

សរុបសេចក្តីមក យើងអាចកំណត់និយមន័យជារួមបានថា**ប្រវត្តិសាស្ត្រ**ជាព្រឹត្តិការណ៍ជាក់លាក់មួយក្នុងអតីតកាល ដែលបានបង្ហាញពីមូលហេតុដែលនាំឱ្យមានភាពជោគជ័យ និងបរាជ័យ។ មេរៀនប្រវត្តិសាស្ត្របាន

---

[11] ក្រសួងអប់រំ យុវជន និងកីឡា, *ប្រវត្តិវិទ្យា(សម័យអាណាព្យាបាលបារាំង-ព្រះរាជាណាចក្រទី២)*, ឆ្នាំ២០១៧, ទំព័រ១។

[12] -ដ- ទំព័រ១។

[13] ការពិភាក្សារវាងម្ចាស់អ៊ំ និង ទីសុផល ឆ្នាំ២០១៥ នៅហាងកាហ្វេមួយ ជិតគេហដ្ឋានរបស់ទ្រង់។

[14] អ្នកសំណេរនៅក្នុងកម្មវិធីនោះ ។

[15] ម៉ាឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, បកប្រែដោយប្រាក់ សុវណ្ណារ៉ា, ភ្នំពេញ, ឆ្នាំ២០១២-២០១៣ ទំព័រ២។

បង្ហាញឱ្យយើងបានដឹងពីអតីតកាលកាន់តែឆ្ងាយ ដែលនាំយើងឱ្យរៀបចំផែនការបច្ចុប្បន្នកាលដើម្បីសម្លឹងមើលអនាគតកាលកាន់តែឆ្ងាយ។ ជាពិសេស មេរៀនប្រវត្តិសាស្ត្រ អាចនាំឱ្យយើងជៀសផុតពីមរតកប្រវត្តិសាស្ត្រអាក្រក់នៃអតីតកាល និងទទួលបានមេរៀនល្អៗពីមរតកល្អនៃប្រវត្តិសាស្ត្រជាតិ, តំបន់, និងអន្តរជាតិ។ សម្រាប់គ្រូប្រវត្តិវិទ្យា មិនត្រូវចាត់ទុកសៀវភៅសិក្សាគោលជាគម្ពីរសាសនាដែលមិនអាចកែបាន ឬ សូត្រតាមទាំងស្រុងបានឡើយ ពីព្រោះសៀវភៅសិក្សាគោលគឺជាសៀវភៅជំនួយកម្រិតថ្នាក់ជាតិ មិនមែនជាសៀវភៅជំនួសគ្រូទាំងស្រុងឡើយ[16]។ បន្ថែមពីសៀវភៅសិក្សាគោលគឺគ្រូប្រវត្តិវិទ្យា អាចបង្រៀនដោយផ្តោតលើប្រវត្តិខេត្ត ឬ តំបន់ដែលនៅជិតសាលារៀន, ព្រឹត្តិការណ៍, រឿងព្រេង, ស្ថានីយ ឬ ប្រាសាទនានានៅមូលដ្ឋាន[17]។

## ២-កាលវិទ្យា[18]

កាលវិទ្យា(chronology)គឺជាការសិក្សាអំពីលំដាប់នៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដើម្បីឱ្យអ្នកសិក្សាដឹងពីរយៈពេលនៃព្រឹត្តិការណ៍ទាំងនោះ។ រាល់អត្ថបទប្រវត្តិសាស្ត្រមិនអាចខ្វះកាលវិទ្យាបានឡើយព្រោះ បើខ្វះអត្ថបទនោះហាក់ដូចជា ប្រលោមលោក ឬ រឿងព្រេង។

### ១-សករាជ(ère)

សករាជគឺការរាប់ថ្ងៃ ខែ ឆ្នាំ ឬ ការរាប់ត្រឹមតែឆ្នាំ តាមកាលកំណត់ដែលតាំងទុកពីមួយរៀងមកដោយមានបុគ្គលអស្ចារ្យ ឬ ដោយមានហេតុអស្ចារ្យណាមួយដែលពួកជនានុជនអ្នកគោរពត្រូវកត់ត្រាទុកមិនឱ្យបាត់ ឬ ត្រូវប្រើក្នុងសំបុត្រចុតហ្មាយជាដើម។ សករាជទាំងអស់ត្រូវមានដើមទីមួយ ដែលដើមទីនោះគេយកព្រឹត្តិការណ៍ណាមួយយ៉ាងសំខាន់ជាគោល។

| ល.រ | សករាជ | ខ្លឹមសារ |
|---|---|---|
| ១ | **មហាសករាជ ឬ សក** | មហាសករាជ មានដើមទីចាប់ផ្តើមឆ្នាំថ្មីនៅថ្ងៃ១កើត ខែចេត្រ ក្រោយគ្រិស្តសករាជ៧៨ឆ្នាំគឺនៅវាងខែមីនា ឬ មេសា ទើបត្រូវបញ្ចប់នៅខែមីនា ឬ មេសា គ្រិស្តសករាជ៧៩(មានន័យថាកើតក្រោយគ.ស.៧៨/៧៩ឆ្នាំ)។ |
| ២ | **ពុទ្ធសករាជ** | ពុទ្ធសករាជមានដើមទីនៅឆ្នាំ៥៤៣មុនគ.ស.។ ប្រទេសកម្ពុជាបានចាប់ប្រើព្រះពុទ្ធសករាជ ជាគោលនៅចុងសតវត្សរ៍ទី១៦ ហើយគេក៏ឃើញសិលាចារឹកដែលប្រើពុទ្ធសករាជចាស់ជាងគេគឺវត្តរំលក(K.27) ឆ្នាំ១៥៩១ផងដែរ។ |
| ៣ | **ចុល្លសករាជ** | ចុល្លសករាជ ចាប់រាប់ពីថ្ងៃ១២កើត ខែចេត្រ ក្រោយគ្រិស្តសករាជ ៦៣៨ឆ្នាំ។ សករាជពីរចុងក្រោយនេះត្រូវបានខ្មែរចាប់ផ្តើមប្រើនៅចុងសតវត្សរ៍ទី១៦ បើយោងតាមសិលាចារឹកវត្តរំលក(K.27)[19] ។ |

[16] សៀវភៅសិក្សាគោលគឺជា«សៀវភៅជំនួយ» មិនមែនជា«សៀវភៅជំនួសគ្រូទាំងស្រុងឡើយ»។

[17] Sorn Samnang, L'évolution de la société cambodgienne entre les deux guerres mondiales, 1919-1939 (ការវិវត្តនៃសង្គមកម្ពុជានៅចន្លោះសង្គ្រាមលោកទាំងពីរ១៩១៩-១៩៣៩), Thèse d'Histoire, Université Paris 7, 1995, p.242.

[18] ទី សុផល, *ប្រវត្តិវិទ្យា: ប្រវត្តិសាស្ត្រខ្មែរសង្ខេប*, ឆ្នាំ២០២៤, ទំព័រ៥-៩។

[19] វង់ សុធារ៉ា, *សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល,* នគរវត្ត, ភ្នំពេញ, ឆ្នាំ២០១២, ទំព័រ១៥៨។

| | | |
|---|---|---|
| ៤ | **ក្រិកសករាជ** | ក្រិកសករាជមានដើមទីនៅឆ្នាំ៧៧៦មុនគ.ស.គឺជាឆ្នាំកំណើតនៃល្បែងអូឡាំពិកនៅក្រិក។ |
| ៥ | **រ៉ូមសករាជ** | រ៉ូមសករាជ មានដើមទីនៅឆ្នាំកំណើតនៃក្រុងរ៉ូមគឺឆ្នាំ៧៥៣មុនគ.ស.។ |
| ៦ | **មហាម៉ាត់សករាជ** | មហាម៉ាត់សករាជមានដើមទីហៅថាអេស្សៀគឺជាការរត់របស់មហាម៉ាត់ក្នុងឆ្នាំ៦២២គ.ស. ពីក្រុងឡាម៉ិចដោយមានការប្រឆាំងពីសត្រូវ។ |
| ៧ | **គ្រិស្តសករាជ** | គ្រិស្តសករាជមានដើមទីនៅឆ្នាំកំណើតព្រះយេស៊ូ។ គ្រិស្តសករាជបានចាប់រាប់ឆ្នាំថ្មី ពីថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃ៣១ ខែធ្នូ។ |
| ៨ | **សាធារណរដ្ឋសករាជ** | សាធារណរដ្ឋសករាជមានដើមទីនៅថ្ងៃប្រកាសថាប្រទេសបារាំងជាសាធារណរដ្ឋ គឺថ្ងៃទី២២ខែកញ្ញា ឆ្នាំ១៧៩២។ នៅប្រទេសចិន និងឥណ្ឌាបុរាណ គេបានរើសយកព្រឹត្តិការណ៍របស់ស្ដេចនីមួយៗជាដើមទីសករាជ ហើយទើបយកសន្តតិវង្សនោះជាឈ្មោះសករាជ។ |

សម្រាប់ប្រទេសកម្ពុជា ស្ថិតក្រោមរបបអាណាព្យាបាលបារាំង គឺបានប្តូរមកប្រើគ្រិស្តសករាជ ជាគោលវិញ។ ប៉ុន្តែដោយសារការត្រូវថែរក្សាអត្តសញ្ញាណជាតិផងនោះ នៅឆ្នាំ២០១៧ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ឱ្យប្រើជាផ្លូវការនៅពុទ្ធសករាជ និងគ្រិស្តសករាជ។ ចំណែកឯការរាប់ចូលពុទ្ធសករាជថ្មីនៅកម្ពុជា ក្រសួងធម្មការ និងសាសនា បានកំណត់យកថ្ងៃ១រោច ខែពិសាខជាថ្ងៃឆ្លងសករាជ ខណៈពេលដែលប្រទេសកាន់ពុទ្ធសាសនា បានកំណត់យកថ្ងៃផ្សេងពីគ្នា ជាថ្ងៃឆ្លងចូលពុទ្ធសករាជថ្មីដូចជានៅប្រទេសថៃគេកំណត់យកថ្ងៃទី១ ខែមករាជាថ្ងៃឆ្លងពុទ្ធសករាជថ្មី។

### ២.២-រង្វាស់នៃពេល

ក្នុងការសិក្សារង្វាស់នៃពេល អ្នកសិក្សាត្រូវចាំអំពី៖

- សហស្សវត្សរ៍(Millennium) : ១ ០០០ឆ្នាំ
- សតវត្សរ៍(Century) : ១០០ឆ្នាំ
- ទសវត្សរ៍( Decade) : ១០ឆ្នាំ
- ជំនាន់(Generation): ជាចំនួនឆ្នាំចន្លោះអាយុកូន និងអាយុឪពុកគឺរយៈពេលប្រមាណ២៥ ឬ ៣០ឆ្នាំ។ ពាក្យជំនាន់នេះមានន័យទូទៅម៉្យាងទៀតគឺមនុស្សទាំងឡាយណាដែលកើតនៅក្នុងកាលបរិច្ឆេទប្រហែលៗគ្នា ដែលបានដឹងឮព្រឹត្តិការណ៍ដូចគ្នា។ ឧទារណ៍៖ ដូចជាជំនាន់ឆ្នាំ ១៩៤៥ ថាមនុស្សទាំងឡាយដែលមានអាយុបានប្រមាណ២០ឆ្នាំ ក្នុងឆ្នាំ១៩៤៥ ហើយដែលបានដឹងឮនូវព្រឹត្តិការណ៍សង្គ្រាមលោកលើកទី២ទាំងអស់គ្នា។
- កាលសម័យ(Period): មានន័យខុសគ្នាពីសម័យ។ កាលសម័យមានរយៈពេលវែងជាង ហើយបញ្ជាក់នូវចលនា និងវិវត្តន៍ក្នុងប្រវត្តិវិទ្យា។
- សម័យ( Era, Epoch ): សម្រាប់ប្រើសម្គាល់រយៈពេល ដែលមានជីវភាពប្លែក មានរចនាបថសិល្បៈ ដូចជា សម័យអង្គរ សម័យឡាបែលអេប៉ូក (La Belle Eqoque) ជាដើម។
- របប(Regime) : សម្រាប់ប្រើដោយផ្តោតលើរបបនយោបាយ ឬ របៀបនៃការដឹកនាំគ្រប់គ្រងរដ្ឋ។
- របបនយោបាយ : របៀបនៃការដឹកនាំ និងគ្រប់គ្រងរដ្ឋទៅតាមច្បាប់នៃប្រទេសភូមិសាស្ត្រនយោបាយ, មនោគមវិជ្ជា និងតួនាទីបុគ្គលអ្នកដឹកនាំរដ្ឋជាដើម។

**សរុបសេចក្តីមក ប្រវត្តិវិទ្យាផ្តល់នូវគុណតម្លៃយ៉ាងច្រើនសម្រាប់មនុស្សជាតិ៖**[20]

- ចំណេះដឹងខាងប្រវត្តិវិទ្យាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំសីលធម៌
- ផ្តល់ចំណេះដឹងដល់អ្នកសិក្សាឱ្យប្រកាន់យកគំរូល្អ
- បណ្តុះនូវឧត្តមគតិជាតិនិយម ស្នេហាជាតិ និងឆន្ទៈចូលរួមការពារជាតិមាតុភូមិ
- បានផ្តល់ចំណេះវិជ្ជាដល់អ្នកគ្រប់គ្រងប្រទេសដើម្បីកុំឱ្យជាន់ដានអាក្រក់
- ចេះសម្របសម្រួលតាមការប្រែប្រួលថ្មីៗបរិបទតំបន់ និងពិភពលោក
- យល់ដឹងពីអត្តសញ្ញាណអរិយធម៌ជាតិ និងអន្តរជាតិ
- បណ្តុះស្មារតីស្នេហាបេតិកភណ្ឌជាតិ និងអន្តរជាតិ
- បណ្តុះស្មារតីទទួលខុសត្រូវចំពោះរាល់ការប្រព្រឹត្តរបស់ខ្លួន
- បង្កើនការយល់ដឹងអំពីអតីតកាលដើម្បីរៀបចំអនាគតកាលឱ្យកាន់តែប្រសើរឡើង និងចៀសវាងកំហុសច្រំដែល
- បង្កើតស្មារតី ជាពលរដ្ឋសកល និងបណ្តុះនូវមនោសញ្ចេតនាស្រលាញ់មាតុភូមិ
- បណ្តុះស្មារតីកតញ្ញូកតវេទី កោតសរសើរ និងយកគំរូល្អតាមបុព្វបុរសដើម្បីជានានិរន្តរភាព និងសុខដុមភាពនៃប្រជាជាតិរបស់ខ្លួន
- លើកកម្ពស់តម្លៃនៃសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ
- បណ្តុះគំនិតត្រិះរិះពីចំណុចខុសឆ្គង និងខ្វះខាតរបស់បុព្វបុរស ដើម្បីពិចារណារកផ្លូវវិជ្ជមានសម្រាប់ជាតិ និងក្លាយជាពលរដ្ឋល្អប្រកបដោយការទទួលខុសត្រូវ
- រក្សាតម្លៃជាពលរដ្ឋកម្ពុជា និងមានសាមគ្គីជាតិក្នុងស្មារតីជាបងប្អូនក្នុងសង្គមជាតិ ដោយជៀសវាងពាក្យកាយវិការ ពាក្យសំដីមិនថ្លៃថ្នូរ
- បង្កប់នូវបញ្ញត្តិជាតិនិយម និងអត្តសញ្ញាណជាតិ ជាដើម។

**៣-សំណួរត្រិះរិះ**

១-ដូចម្តេចដែលហៅថាទស្សនវិជ្ជានៃប្រវត្តិវិទ្យា?

២-តើមេរៀនប្រវត្តិវិទ្យាបានផ្តល់សារៈសំខាន់អ្វីខ្លះសម្រាប់អ្នកសិក្សា?

៣-តាមគំនិតរបស់អ្នកប្រសិនបើអ្នកនយោបាយមិនបានសិក្សាស្រាវជ្រាវឱ្យស៊ីជម្រៅទៅលើមេរៀនប្រវត្តិសាស្ត្រ តើពួកគាត់អាចជួបនូវបញ្ហាអ្វីខ្លះ? ចូរពន្យល់។

៤-តើអ្នកឯកទេសប្រវត្តិវិទ្យាមានករណីយកិច្ចសំខាន់ៗអ្វីខ្លះក្នុងការសិក្សាពីប្រវត្តិសាស្ត្រ?

៥-មតិមួយពោលថា«ភ្នែកទាំងគូនៃប្រវត្តិវិទ្យាគឺកាលវិទ្យា និងភូមិវិទ្យា»។ ចូរពន្យល់។

[20] ទី សុផល, *ប្រវត្តិវិទ្យា*, ជ.ឯ.ម., ទំព័រ១៨-១៩។

# មេរៀនទី៣ បុរេប្រវត្តិសាស្ត្រកម្ពុជា

ផែនទីស្ថានីយបុរេប្រវត្តិសាស្ត្រ




**ប្រភព** : ក្រសួងអប់រំ យុវជន និងកីឡា, *សិក្សាសង្គមថ្នាក់ទី១០*, ឆ្នាំ២០២៥, ទំព័រ១០៦។

បុរេប្រវត្តិសាស្ត្រ ជាស្បង់មួយសិក្សាអំពីកាលសម័យចន្លោះដើមកំណើតមនុស្ស និងដើមកំណើតអក្សរ ដែលជនជាតិបារាំង ប៊ូសេដឺពែ (Boucher de Perthe) បានបង្កើតឡើងនៅសតវត្សរ៍ទី១៩ នៃគ្រិស្តសករាជ។ ការសិក្សាពីបុរេប្រវត្តិសាស្ត្រគេអាចប្រើប្រាស់គ្រោងឆ្អឹងមនុស្ស, អាវុធ, ប្រដាប់ប្រដា, កម្ទេច និងសំណល់គ្រប់បែបយ៉ាង។ គេក៏ពឹងផ្អែកទៅលើស្បង់ដទៃទៀតដូចជាធរណីវិទ្យា, ផូស៊ីលវិទ្យា និងជាតិពន្ធុជាដើម[21]។

## ១-ស្ថានីយបុរេប្រវត្តិសាស្ត្រ

ស្ថានីយបុរេប្រវត្តិសាស្ត្រ ដែលគេឃើញទាំងអស់នោះគឺស្ថិតនៅក្នុងយុគផ្សេងៗគ្នា។ ចំណែកការកំណត់ពីអាយុកាលនៃយុគនីមួយៗ មានគម្លាតគ្នាតិចតួចអាស្រ័យដោយការស្រាវជ្រាវ ឬ របកគំឃើញថ្មីៗ ហើយការ

[21] ក្រសួងអប់រំជាតិ, *ខេមរយោកម្មសិក្សា:ថ្នាក់ទី៦*, ផ.ឯ.ម., ទំព័រ១១។

កំណត់អាយុកាលអាច ខុសគ្នាតាមតំបន់ និងស្ថានីយផ្សេងៗគ្នាផងដែរ។ បើយោងតាមសៀវភៅសិក្សាសង្គម ថ្នាក់ទី១០ បានបែងចែកអាយុកាលនៃស្ថានីយនីមួយៗដូចខាងក្រោម[22]៖

| ស្ថានីយយុគថ្មបំបែក | ស្ថានីយយុគថ្មរំលីង | ស្ថានីយយុគលោហៈ |
|---|---|---|
| (៦០០ ០០០ឆ្នាំ-១២ ០០០ ឆ្នាំមុនគ.ស.) | (៨ ០០០ឆ្នាំ-២ ០០០ឆ្នាំ មុនគ.ស.) | (២ ០០០ឆ្នាំ-១០០ឆ្នាំមុនគ.ស.) |

ស្ថានីយទាំងនោះមាននៅតំបន់ភ្នំ, ខ្ពង់រាប និងទំនាប ដែលមានដូចជាស្ថានីយស្រែស្បូវ, ស្ថានីយល្អាងស្ពាន-បាត់ដំបង, ស្ថានីយល្អាងភ្នំ-កំពត, ស្ថានីយក្បាលរមាស-ខេត្តកែប, ស្ថានីយសំរោងសែន-កំពង់ឆ្នាំង, ស្ថានីយតំបន់អង្គរ-សៀមរាប, ស្ថានីយភូមិមូល-មេម៉ត់,ស្ថានីយ អង្គរបុរី-តាកែវ, ស្ថានីយម្លូព្រៃ-ព្រះវិហារ, ស្ថានីយអន្លង់ផ្ដៅ-កំពង់ឆ្នាំង, ស្ថានីយស្នាយ-បន្ទាយមានជ័យ, ស្ថានីយអូកែវ-កម្ពុជាក្រោម និងស្ថានីយយុគថ្មបំបែក ជាច្រើនកន្លែងផ្សេងទៀត។

**២-ជីវភាពរស់នៅ**

ចំពោះការគិតរយៈពេលនៃយុគនីមួយៗមិនដូចគ្នាទេ ហើយបុរាណវិទូមួយចំនួនក៏បានបង្ហាញដែរថា ការការកំណត់រយៈពេលច្រើនឆ្នាំបែបនេះគឺ មិនយកគ្រិស្តសករាជជាគោលទេគឺគេប្រើ BP(Before Present ដែលសំដៅលើមុនបច្ចុប្បន្ន)គឺយកឆ្នាំ១៩៥០ ជាគោលដែលជាឆ្នាំបង្កើតវិទ្យាសាស្ត្រកំណត់អាយុកាលតាមបច្ចេកទេសវិទ្យាសកម្មកាបូន១៤។ បើតាមការស្រាវជ្រាវរបស់បុរាណវត្ថុវិទូនាសតវត្សរ៍ទី២១ នេះយើងអាចកំណត់ពីកាលនៃបុរេប្រវត្តិសាស្ត្រខ្មែរបានថា[23]៖

| យុគថ្មបំបែក | យុគថ្មរំលីង | យុគលោហៈ |
|---|---|---|
| **៧១ ០០០ឆ្នាំមុន-៥ ០០០ ឆ្នាំមុន** | **៣៥០០-២៥០០ឆ្នាំមុន** | **៨០០ឆ្នាំមុនគ.ស. ត្រូវនឹង ២៧៥០ឆ្នាំមុន**[24] |
| មនុស្សរស់នៅអាស្រ័យដោយការបរបាញ់សត្វ និងប្រមូលរុក្ខផលព្រៃឈើ ហើយផ្លាស់ប្ដូរទីលំនៅញឹកញាប់ពីកន្លែងមួយទៅកន្លែងមួយ។ | មនុស្សរស់នៅតាមតំបន់ខ្ពង់រាបដីក្រហម និងតំបន់ទំនាប។ ពួកគេចាប់ផ្ដើមធ្វើកសិកម្ម ចាប់សត្វព្រៃយកមកចិញ្ចឹម និងចេះផលិតសម្ភារធ្វើពីដីដុត និងឧបករណ៍ថ្មរំលីង។ | មនុស្សរស់នៅតាមវាលទំនាប មាត់ទន្លេ ស្ទឹង បឹង។ |

---

[22] ក្រសួងអប់រំ យុវជន និងកីឡា, *សិក្សាសង្គម ថ្នាក់ទី១០,* ភ្នំពេញ, ឆ្នាំ២០១៨, ទំព័រ១២៦-១២៧។ បើយោងតាមក្រសួងអប់រំជាតិ, *ប្រវត្តិវិទ្យា ថ្នាក់ទី៦,* ឆ្នាំ១៩៧៣, ទំព័រ១១-១៥ មិនបានកំណត់ជាក់លាក់ពីអាយុកាលនេះឡើយ ហើយជាទូទៅសៀវភៅនេះបានបង្ហាញពីជីវភាពរស់នៅ និងជំនឿ របស់មនុស្សសម័យបុរេប្រវត្តិ និងការរកឃើញវត្ថុផ្សេងៗក្នុងស្ថានីយបុរេប្រវត្តិសាស្ត្រតែប៉ុណ្ណោះ។

[23] ក្រសួងអប់រំ យុវជន និងកីឡា, *ខ្មែរ និងដំណើរឆ្ពោះទៅសម័យអង្គរដ៏រុងរឿង,* ថ្នាក់ទី៥, ឆ្នាំ២០២១, ទំព័រ២៦។

[24] -ដ- ទំព័រ២២៤។

**ការរស់នៅរបស់មនុស្សបុរេប្រវត្តិ**

| | រូងភ្នំ | ខ្ពង់រាប | វាលទំនាប |
|---|---|---|---|
| ប្រភេទ២ | **ស្ថានីយល្អាងស្ពាន** | **ស្ថានីយភូមិមូល** | **ស្ថានីយនៅតំបន់វាលទំនាប** |
| | មនុស្សប្រើឧបករណ៍ថ្មបំបែកសម្រាប់អារសាច់ និងបំបែកឆ្អឹងសត្វយកខួរឆ្អឹងធ្វើជាអាហារ | មនុស្សរស់នៅជាភូមិមូល | មនុស្សរស់នៅផ្តុំគ្នាជាសហគមន៍តាមតំបន់ទំនាប |

**៣-អរិយធម៌**

ដោយយោងតាមស្ថានីយបុរេប្រវត្តិសាស្ត្រខាងលើ យើងឃើញថាមនុស្សបុរេប្រវត្តិសាស្ត្រចេះរស់នៅក្នុងសង្គមកសិកម្មដែលប្រមាណ១ ៣០០ ឆ្នាំមុនគ.ស. បុព្វបុរសខ្មែរលែងជាចរកជន[25]គឺពួកគាត់ចាប់ផ្តើមធ្វើកសិកម្ម និងការច្នៃសម្ភារៈប្រើប្រាស់អំពីថ្ម និងដីដុត ហើយពួកគាត់នាំគ្នាមករស់នៅតាមមាត់ទន្លេ ស្ទឹង បឹង រហូតដល់សមុទ្ទ។ ក្រៅពីនេះពួកគាត់បានចាប់ផ្តើមធ្វើសិប្បកម្មដែលមនុស្សក្នុងយុគថ្មរំលីងចាប់ផ្តើមរិះគិតពីពិធីក្នុងការផលិតសម្ភារៈប្រើប្រាស់ពីដីដុត។ ពួកគាត់បានស្មូនភាជន៍ដោយដៃទទេ និងដុតនៅទីវាល។ ចំពោះការរស់នៅជាសហគមន៍របស់ពួកគាត់មានការវិវត្តដោយផ្លាស់ប្តូរចេញពីរូងភ្នំ ទៅកាន់ខ្ពង់រាបដីក្រហម និងក្រោយមកបន្តមករស់នៅតំបន់ទំនាបក្បែរប្រភពទឹក។ មនុស្សនៅសម័យបុរេប្រវត្តិសាស្ត្រមានជំនឿលើធម្មជាតិ, វត្ថុនានា, ទីកន្លែងនិងអ្វីៗ ដែលនៅជុំវិញខ្លួនមនុស្ស។ នេះគឺជាជំនឿបែបជីវចលនិយម«Animism»)។ ចំពោះការកប់សពគេច្រើនឃើញមានការដាក់តង្វាយផ្សេងៗមានវត្ថុប្រើប្រាស់ ក្អម ហើយមានការសែនព្រេនក្បាលជ្រូក មានដាក់កាក់មាសមួយសន្លឹកនៅក្នុងមាត់ ហើយសពខ្លះត្រូវបានគេបំពាក់គ្រឿងអលង្ការឱ្យ សពខ្លះទៀតគេដាក់ក្នុងក្តារមឈូសកប់។ យោងតាមស្ថានីយបុរេប្រវត្តិនីមួយៗ គេឃើញថាខ្មែរមានការវិវត្តផ្នត់គំនិតរបស់ខ្លួនដូចជា៖

– ចេះប្រើទូក ចេះប្រើគោ ក្របី សម្រាប់របរកសិកម្ម
– ផ្លាស់ប្តូរកន្លែងរស់នៅពីតំបន់ភ្នំ មកខ្ពង់រាប តំបន់វាលទំនាប
– មានការផ្សាំងសត្វ មានការសង់ផ្ទះលើជន្ទល់
– ចេះគូរគំនូរលម្អដោយប្រើពណ៌ នៅលើកុលាលភាជន៍ និងរូងភ្នំជាដើម។

សរុបសេចក្តីមក ដោយយោងតាមសិលាចារឹកលេខK.1247 មានពាក្យជនជាតិ«ក្មេរ»(=ខ្មែរ<ខ្មេរ<ក្មេរ) ដំបូងបំផុតនៅលើសិលាចារឹករបស់ព្រះបាទភវវម៌្មទី២ នៅទួលប្រាសាទភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ដែលនេះបង្ហាញថាកម្ពុជាជាប្រទេសមួយដែលមានប្រវត្តិសាស្ត្ររបស់ខ្លួនច្បាស់លាស់ និងការបង្ហាញនៃកំណាយបុរេប្រវត្តិនោះក៏ដូចគ្នាដែរ។ ការឆ្លងពីសម័យបុរេប្រវត្តិសាស្ត្រមកក្នុងសម័យប្រវត្តិសាស្ត្រ ឥតធ្វើឱ្យមនុស្សជាតិ បាត់បង់នូវវឌ្ឍនភាពរបស់ខ្លួនឡើយ។ ប៉ុន្តែ វឌ្ឍនភាពនៃអរិយធម៌ពុំមែនកើតឡើងព្រមៗគ្នានៅពាសពេញក្នុងពិភពលោកនោះទេ។ នៅលើទឹកដីរបស់ខ្មែរមានវត្តមានជាតិដើមមករស់នៅតាំងពីយូរយារណាស់មកហើយ ដែលមានអាយុយ៉ាងហោច៤២៩០ឆ្នាំមុនគ.ស.[26]។ ប៉ុន្តែ ក៏មានការសន្និដ្ឋានផ្សេងទៀត

[25] បុរាណវិទូ ហេង សុផាឌី បានបញ្ជាក់ថា អ្នកបុរាណវិទ្យាមិនប្រើពាក្យថា«ចរកជន» ទេគឺប្រើ«ជនពនេចរ»។

[26] ម៉ាយឃើល វីឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់* : សម្រាប់និស្សិតសិក្សាថ្នាក់ឆ្នាំមូលដ្ឋាននៅវិទ្យាស្ថានភាសាបរទេស (បកប្រែ ប្រាក់ សុវណ្ណារ៉ា និងកែសម្រួលដោយ វង់ សុធារ៉ា), សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ឆ្នាំ ២០១២-២០១៣, ទំព័រ២០។

តាមការពិនិត្យសិក្សាឆ្អឹងសំណល់ ហើយពិសេសទៀតតាមរបៀបរាស់វែងកម្រាស់ល្បាប់គ្រង់ភូមិបុរេប្រវត្តិសាស្ត្រ អ្នកឯកទេសបានយល់ឃើញថាប្រវត្តិសាស្ត្រខ្មែរមានចំណាស់ប្រហែល៣០០ ឬ ២០០ឆ្នាំមុនគ.ស.[27]។ ទោះបីជាយ៉ាងណាក៏ដោយបុរាណវិទូ នាពេលបច្ចុប្បន្នបញ្ជាក់ថាអាយុកាលនៃយុគ ឬ ដើមកំណើតមនុស្សក្នុងទឹកដីកម្ពុជាអាចមានការផ្លាស់ប្តូរដោយយោងតាមកំណាយបុរាណវិទ្យាផងដែរ។

**៤-សំណួរត្រិះរិះ**

១-ហេតុអ្វីបានជាមនុស្សខ្មែរបុរេប្រវត្តិត្រូវផ្លាស់ប្តូរទីកន្លែងរស់នៅ?

២-តើជំនឿរបស់មនុស្សក្នុងបុរេប្រវត្តិកើតឡើង និងវិវត្តដោយរបៀបណា?

៣-ចូរពន្យល់ពីការវិវត្តផ្នត់គំនិតរបស់មនុស្សនាសម័យបុរេប្រវត្តិ។

៤- ចូររៀបរាប់ពីជីវភាពរស់នៅរបស់មនុស្សបុរេប្រវត្តិ។

៥-ចូរធ្វើផែនទីគំនិតអំពីស្ថានីយបុរេប្រវត្តសាស្ត្រនៅកម្ពុជា។

[27] ក្រសួងអប់រំជាតិ, *ខេមរយោកម្ម (ប្រវត្តិវិទ្យាថ្នាក់ទី៦)*, ជ.ឯ.ម., ទំព័រ៨៦។

## មេរៀនទី៤ រាជាណាចក្រហ្វូណាន(ពីឆ្នាំ៥០ ដល់៥៥០)

### ១-អត្ថន័យនៃពាក្យហ្វូណាន និងទីតាំងភូមិសាស្រ្ត

ហ្វូណាន ជាសុវណ្ណភូមិ[28]ដែលមានន័យថាដីមាស ឬ ដែនសម្បូរសប្បាយ។ ហ្វូណាន ជាប្រទេសមួយមានដីខ្ពស់ទាបមិនរាបស្មើ មានជ្រលងភ្នំ និងវាលរាប។ នៅទីនោះគេឃើញមានក្រុងនានាមានកំពែងការពារវិមាននានា និងគេហដ្ឋានជាច្រើន។ អ្នកស្រុកហ្វូណានធ្វើកសិកម្ម គេសាបព្រោះ១ឆ្នាំ ប្រមូលផល៣ឆ្នាំ។ ពួកគេចូលចិត្តឆ្លាក់ក្បាច់លម្អ និងជាប់ដោយពន្លាក។ឧបករណ៍ប្រើប្រាស់ក្នុងចង្ក្រានភាគច្រើនធ្វើអំពីមាស។ គេច្នៃត្បូងបៃតង ដោយត្បូងពេជ្រម្យ៉ាង។ ពួកគេបង់ពន្ធដារជាមាស, ប្រាក់ ឬ ជាគជ់ និងគ្រឿងក្រអូប។ ពួកគេមានសៀវភៅឃ្លាំងតម្កល់បណ្ណសារ និងវត្ថុផ្សេងៗទៀត[29]។ បើតាមសំណេរមួយចំនួន និងប្រសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ន សំណាង ដែលបានដកស្រង់ចេញពីនិក្ខេបបទរបស់លោក Alain Forest នៅទំព័រ៨-៩បានរៀបរាប់ថាពួកអាណាព្យាបាលដំបូងៗ ដែលចូលមកកម្ពុជាសង្ឃឹមថាបានជួបនឹង«សុវណ្ណភូមិ(Eldorado)» មួយបែប។ នៅខែតុលា ឆ្នាំ១៨៦៥ លោក Doudart de Lagrée បានសរសេរថា ក្នុងទិដ្ឋភាពទូទៅខ្ញុំសូមឆ្លើយនឹងលោកថា អ្វីៗទាំងអស់ធ្វើឱ្យយើងសង្ឃឹមថានឹងមានអនាគតល្អ ប្រសិនបើយើងចេះទាញយកផលពីធនធានដ៏សម្បើមនៃប្រទេសនេះ។

ប្រវត្តិសាស្រ្តផ្លូវការមានឈ្មោះថាហ្វូណាន (Fou-nan)បានសរសេរនៅចុងសតវត្សរ៍ទី៣។ ចិនបានពង្រីកអរិយធម៌មកទិសខាងត្បូង ហើយស្តេចហ្វូណាន និងលីនយី(ចម្ប៉ា)បានបញ្ជូនទូត និងសួយសារអាកររៀងៗខ្លួនទៅស្រុកចិន។ ប្រវត្តិសាស្រ្តស្តីពីរាជវង្សមានកថាខណ្ឌមួយពិសេសស្តីពីហ្វូណាន ហើយក្នុងប្រវត្តិសាស្រ្តរាជវង្សស៊ុនដែលសោយរាជ្យពីឆ្នាំ២៦៥ ដល់៤១៩[30]។ ចិនបានហៅថាហ្វូណាន។ ពាក្យហ្វូណាន[31]នេះ ចិនបុរាណអានថាប៊ីយូណាម ដែលជាពាក្យគ្មានន័យអ្វីឱ្យប្រាកដក្នុងភាសាចិនទេ។ តើពាក្យនេះត្រូវបានអ្នកស្រុកអាយហៅថាដូចម្តេច?

បើតាមលោក ហ្សក សឺដេស(George Coedès) បានពន្យល់ថា ចិនរាយការណ៍ថា ស្តេចហ្វូណានមានគោរមងារថាគូឡុង ដែលចូលចិត្តទៅធ្វើពិធីបូជាចំពោះព្រះផូតូលីនៅលើភ្នំមូតាន។ ព្រះស្តេចធ្លាប់ជួបទេពនោះនៅលើភ្នំនោះឯង។ គាត់គិតថាពាក្យចិនហៅគូឡុង គឺគ្មានអ្វីក្រៅពី កុរុង ដែលមានន័យថាស្តេចរបស់ខ្មែរតាំងពីបុរាណរហូតដល់សព្វថ្ងៃនោះទេ(កុរុង-ក្រុង)។ រីឯភ្នំនោះហើយដែលអាចក្លាយជាឈ្មោះរបស់ស្តេចពេលនោះ ដែលគេហៅថាកុរុងវ្នំ ឬ ស្តេចភ្នំ[32]។ យោងតាមសាស្រ្តាចារ្យបណ្ឌិត វង់ សុធារ៉ា ជាសិលាចារឹកវិទូ បានប្រើពាក្យថា ហ្វូណាន (Funan/Fou-nan)។ លោកបានសន្និដ្ឋានទៀតថា **ហ្វូណាន** មិនគួរមកពីពាក្យចិនគ្រាប់ថាវ្នំឬភ្នំ ដូចលោក ហ្ស៊ី ដេស ធ្លាប់ស្មាននោះទេ។ គឺ វាមកពីខ្មែរនៅខាងត្បូងចិន ទើបមានពាក្យណាន។ ចំណែកពាក្យហ្វូ(Fu) មានន័យថាមហាសាល។ ពីព្រោះចិនតាំងពីដើមមកយល់ថាខ្មែរជាអ្នកមានភោគទ្រព្យច្រើន

---

[28] ដោយផ្អែកលើខ្លឹមសារនៃសិលាចារឹកស្តីពី «សុវណ្ណភូមិ» ដែលបកប្រែដោយលោកបណ្ឌិត វង់ សុធារ៉ាគឺ«សិលាចារឹកនេះមានអាយុកាលពីសតវត្សរ៍ទី៧ (ឆ្នាំ៦៣៣) នៅសម័យចេនឡា និងបានរកឃើញពីជាង២០ឆ្នាំមុន នៅក្នុងស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ គឺជាភស្តុតាងប្រវត្តិសាស្រ្តតែមួយគត់ ដែលបញ្ជាក់ថាប្រទេសកម្ពុជាពិតជាទីតាំងនៃដែនដី«សុវណ្ណភូមិ»។ ប្រទេសដទៃនៃតំបន់អាស៊ីអាគ្នេយ៍នេះមិនមានអ្វីជាភស្តុតាងស្តីពី«សុវណ្ណភូមិ»ទាល់តែសោះ។

[29] Paul Pelliot, *le Fou-nan*, BEFEO, 1903, p.254.

[30] Ibid., p.251.

[31] ក្នុងអត្ថបទដើមរបស់ត្រឹង ងា សរសេរថាហ្វូណាន។

[32] ត្រឹង ងា, *ប្រវត្តិសាស្រ្តខ្មែរ(សម្រាប់មធ្យមសិក្សា និងឧត្តមសិក្សា)*, ភាគ១, ឆ្នាំ១៩៧៣, ទំព័រទី៧៩-៨០ ។

ហើយឃួនក៏យល់ដូច្នេះដែរទើបហៅខ្មែរថា កៅមៀនរហូត មក។ ដូច្នេះពាក្យហ្វូណាន(Fou-nan) ដើមគួរមានន័យថា *អ្នកមាននៅខាងត្បូង* (Rich South)។

ព្រះរាជាណាចក្រហ្វូណានស្ថិតនៅជាង៣ ០០០លី ខាងលិច[33]លិនយីក្នុងតំបន់មាត់សមុទ្ធដ៏ធំមួយ[34]។ សម្រាប់ លោក ត្រឹង ងា ក៏បានរៀបរាប់ថា ចិនកត់ត្រាថារដ្ឋនេះស្ថិតនៅចម្ងាយ៣ ០០០លី (ស្មើប្រហែល១៧៣០ គីឡូម៉ែត្រ)[35] ដែលស្ថិតក្នុងឈូងសមុទ្ធធំមួយ និងមានទន្លេធំមួយហូរពីលិច (ឯកសារខ្លះថាពាយ័ព្យ) ហើយចាក់ទៅសមុទ្ធ[36]។ បើយោងតាមភូមិសាស្ត្របច្ចុប្បន្នហ្វូណានលាតសន្ធឹងតាមបណ្តោយទន្លេមេគង្គ រហូតដល់ឈូងសមុទ្ធខ្មែរ និងឧបទ្វីបម៉ាឡាយូ ខាងលិចជាប់នឹងប្រទេសភូមា។ នៅក្នុងបេសកកម្មផ្លូវការមួយនាឆ្នាំ១៨៨០ ដល់១៨៨១ លោក Edgar Boulangier បានមកដល់កម្ពុជានឹងរៀបរាប់ថាជនជាតិខ្មែរបានបង្កើតឡើងនៅដើមគ្រិស្តសករាជ នូវប្រជាជាតិមួយដែលមានប្រជាជនច្រើន និងមានអានុភាព ដែលបានកាន់កាប់តំបន់ឥណ្ឌូចិនភាគកណ្តាល និងភាគខាងត្បូង ចាប់ពីភាគខាងត្បូងនៃកូសាំងស៊ីន រហូតទៅដល់រយៈទទឹងខាងជើងទី២០អង្សា[37]។ ចំពោះលោក អេដេម៉ារ ឡឺក្លែរ បានរៀបរាប់ថាពាក្យ ហ្វូណាន សម្រាប់ហៅទឹកដីទាំងមូលដែលលាតសន្ធឹងពីសមុទ្ធខាងត្បូង និងពាមនៃទន្លេមេគង្គ រហូតដល់ល្បាក់ខោននៅខាងជើង និងចាប់ពីជួរភ្នំអាណ្ណាមនៅខាងកើត ដែលរួមមានទាំងទឹកដីប៊ិញធន់សព្វថ្ងៃផង រហូតទៅដល់ឈូងសមុទ្ធសៀម និងជួរភ្នំតេណាស់សេរីម នៅខាងលិច ហើយអាចបញ្ចូលទាំងដែនដីចំណុះហិណ្ឌូមាននៅ តេណាស់សេរីម សមុទ្ធមែរហ្គុយ, តាវ៉យ និងម៉ាតាផងដែរ[38]។ ហ្វូណាន មានកំពង់ផែអន្តរជាតិរបស់ខ្លួនឈ្មោះអូរកែវ ដែលអាចជាអតីតរាជធានី នរវរនគរ[39]។

នៅស្រុកអង្គរបុរី[40]គេបានរកឃើញនូវកេស្តុតាងជាច្រើនដូចជា រចនាសម្ពន្ធរាជធានី, ទីទួល, ប្រាសាទ, បដិមា, សិលាចារឹក, កន្លែងកប់សព, កំពែងក្រុង ព្រមទាំងសំណង់ផ្លូវក្នុងក្រុងដែលរួមមានកម្រាលឥដ្ឋជាដើម។ ហ្វូណានគឺជាប្រទេសដែលមានព្រំប្រទល់ជាប់នឹងសមុទ្ធ និងមានទន្លេ ស្ទឹង បឹងបួរ ហូរខ្វាត់ខ្វែងទើបការរៀបចំប្រព័ន្ធធារាសាស្ត្រដើម្បីយកទឹកប្រើប្រាស់នៅក្នុងវិស័យកសិកម្មផងដែរ។ សរុបមករាជធានីរបស់ ហ្វូណានមានឈ្មោះថាវ្យាធបុរ[41] ស្ថិតនៅក្នុងស្រុកអង្គរបុរី ខេត្តតាកែវ សព្វថ្ងៃ។

---

33 បើយើងមើលតាមផែនទីបច្ចុប្បន្ន គឺនៅភាគនិរតី។

34 Paul Pelliot, *le Fou-nan*, op.cit., p.254.

35 ១លី=៥៧៦មែត្រ។

36 ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ(សម្រាប់មធ្យមសិក្សា និងឧត្តមសិក្សា)*, ភាគ១, ដ.ឯ.ម., ទំព័រទី៨១ ។

37 Edgar Boulangier, *Un hiver au Cambodge : chasses au tigre, à l'éléphant et au buffle sauvage,* souvenirs d'une mission officielle remplie en 1880-1881 ( 2e édition, revue et augmentée ), 1888, p.38.

38 អាដេម៉ារ ឡឺក្លែ, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា,* ប្រែសម្រួលដោយ ទី ឃាឃុ, បោះពុម្ពលើកទី១, ឆ្នាំ២០០៥, ទំព័រ៣១។

39 បើតាមការស្រាវជ្រាវចំពោះឈ្មោះ និងទីតាំង ពុំទាន់បានឃើញមានឯកសារអ្នកស្រាវជ្រាវណាមួយកំណត់ច្បាស់ឡើយ។

40 សម្រាប់ពេលបច្ចុប្បន្ន តាមក្រសួងមហាផ្ទៃសរសេរថា«អង្គរបូរី»។

41 វ្យាធបុរ [-បុ-រ៉ៈ]។ សម្រាប់ក្នុងឯកសារនេះ ឈ្មោះរាជធានីទាំងអស់ដែលបញ្ចប់ដោយ«-បុរ៉ៈ» គឺអ្នកនិពន្ធសរសេរ ដោយមិនមានចុចពីរ ឬយុគលពិន្ទុឡើយដូចជាវ្យាធបុរ, យសោធបុរ ជាដើម។ ចំណែកក្នុងសៀវភៅលោក ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ(ភាគ១)*, ឆ្នាំ១៩៧៣ គឺរាជធានីដែលបញ្ចប់ដោយ«បុរៈ» ក៏សរសេរមិនមានយុគលពិន្ទុផងដែរ។

## ២-ឥទ្ធិពលឥណ្ឌាលើអាណាចក្រហ្វូណាន

ឥណ្ឌា ជាប្រទេសដែលមានអរិយធម៌បុរាណមួយ។ កេរដំណែលរបស់ឥណ្ឌាបុរាណ ចំពោះពិភពលោក គឺជាគំរូនៃរបៀបអប់រំ, នយោបាយ, សាសនា និងសិល្បៈ ជាដើម។ ប្រវត្តិវិទូខ្មែរ និងបរទេស បានបកស្រាយពីមូលហេតុផ្សេងៗគ្នា នូវរបៀបដែលអាណាចក្រហ្វូណានទទួលឥទ្ធិពលពីឥណ្ឌា។

អ្នកស្រុកអាស៊ីអាគ្នេយ៍ធ្លាប់បានស្គាល់ជនជាតិឥណ្ឌាបន្តិចបន្តួចខ្លះមកហើយពី៤០០ ឬ ៣០០ឆ្នាំមុន គ.ស. តាមរយៈសាសនា។ ព្រះចៅអធិរាជឥណ្ឌាបានចាត់បញ្ជូនគណៈប្រតិភូបព្វជិតពុទ្ធសាសនាឱ្យផ្សព្វផ្សាយលទ្ធិព្រះពុទ្ធនៅតំបន់ក្តៅ មានលង្កាទ្វីប និងអាស៊ីអាគ្នេយ៍ជាដើម[42]។ ក្នុងវិស័យជំនឿសាសនា មនុស្សនៅហ្វូណាន បានកាន់សាសនាធំៗទាំងពីររបស់ឥណ្ឌា គឺព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា តែគេមិនដឹងច្បាស់ថាសាសនាណាមួយបានចូលមកស្រុកខ្មែរមុនគេទេ។ តែទោះបីជាយ៉ាងណា ក៏គេអាចដឹងថាព្រះពុទ្ធសាសនាដែលហូរចូលដំបូងគឺព្រះពុទ្ធសាសនាហីនយាន ប្រើភាសាសំស្ក្រឹត[43] ដែលឥណ្ឌានៅអមរវតី រាប់អាននៅសតវត្សរ៍ទី២-៣ ហើយព្រះពុទ្ធសាសនា ដែលគេបានរកឃើញនៅអាស៊ីអាគ្នេយ៍ មានអាយុកាលនៅសតវត្សរ៍ទី៣-៤[44]តែប៉ុណ្ណោះ[45]។ ចំណែកខាងសាសនាព្រាហ្មណ៍ គេឃើញមានគោរពចំពោះព្រះឥសូរ, ព្រះហរិហរ (វិស្ណុ និងឥសូររួមគ្នា) និងព្រះព្រហ្ម។ នៅខាងដើមសម័យហ្វូណាន គណៈឥសូរនិយម ទំនងជាសាសនាផ្លូវការផង ព្រោះព្រះរាជាតែងតែឡើងលើ ភ្នំម៉ូតាន់ ដើម្បីធ្វើសក្ការបូជា ចំពោះព្រះមហេស្វរៈ ប៉ុន្តែក្រោយមកមានអធិរាជខ្លះ បានផ្លាស់ពីឥសូរនិយម មកកាន់ពុទ្ធសាសនាវិញ ដូចជាព្រះបាទកៅណ្ឌិន្យ ជយវម្ម័ ជាដើម។ ខាងគណៈវិស្ណុនិយម ឃើញមានបដិមាវិស្ណុ និងអវតា របស់ទ្រង់ជាច្រើននៅតំបន់ភ្នំដា[46]។ ចំពោះលោក ម៉ាយឃើល វិកឃើរីយល់ថា ទោះបីរឿងដែល ស្តេចអសោក បញ្ជូនសាសនទូតខាងពុទ្ធសាសនាមកកាន់អាស៊ីអាគ្នេយ៍នេះជារឿងពិតដែលប្រវត្តិវិទូភាគច្រើននៅមានមន្ទិលសង្ស័យនៅពេលបច្ចុប្បន្ននេះ មែនរឿងនោះមិនអាចពន្យល់អំពីការកកើតនូវភស្តុតាងនៃឥទ្ធិពលឥណ្ឌា ដែលភាគច្រើនមិនមែនជាព្រះពុទ្ធនោះទេ[47]។

នៅដើមគ្រិស្តសករាជ គេឃើញមានពួកឈ្មួញឥណ្ឌាជាច្រើនបានចូលមករកស៊ីនៅអាស៊ីអាគ្នេយ៍កាន់តែច្រើនឡើងៗ[48]។ ចំណែកកំពង់ផែអូកែវ កាន់តែមមាញឹក ដោយពួកឈ្មួញទិញដូរឧបករណ៍ប្រើប្រាស់គ្រឿងមាស, ប្រាក់ និងគ្រឿងអលង្ការផ្សេងៗ ហើយលក់ក្រណាត់, គ្រឿងក្រអូប និងគ្រឿងទេសផ្សេងៗ ឱ្យអ្នកស្រុកអាណាចក្រហ្វូណាន។ ពួកគេបានរៀបការជាមួយនារីក្នុងស្រុក និងបង្កើតសង្គមគ្រួសារ ដែលប្រតិបត្តិតាមប្រពៃណីឥណ្ឌានៅក្នុងគ្រួសារ និងមានឥទ្ធិពលក្នុងសហគមន៍។ សរុបមកគេឃើញថាអ្នកស្រុកនេះមិនគ្រាន់តែធ្វើជំនួញជាមួយប្រទេសជិតខាងប៉ុណ្ណោះទេ គឺបានទាក់ទងផ្លូវជំនួញនេះជាមួយនឹងចិន, ឥណ្ឌា, រ៉ូម៉ាំង និងពែរ្សទៀតផង[49]។

---

[42] ក្រសួងអប់រំជាតិ, *ខេមរយោកម្ម (ប្រវត្តិវិទ្យាថ្នាក់ទី៦)*, ដ.ឯ.ម., ទំព័រ៩៣។

[43] សំស្ក្រឹតអត់មានអក្សរទេ។

[44] ត្រង់ចំណុចនេះ ត្រូវបានលោក ត្រឹង ងា បានលើកជាសំណួរថា បើព្រះពុទ្ធសាសនា ផ្សាយចាប់ពីស.វទី៣មុនគ.ស ហេតុអ្វីបានជាផ្លែផ្កានៅ ស.វទី៣-៤នៃគ.ស ទៅវិញ?

[45] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ(សម្រាប់មធ្យមសិក្សា និងឧត្តមសិក្សា)*, ភាគ១, ដ.ឯ.ម., ទំព័រ១០៥។

[46] -ដ- ទំព័រ១០៦។

[47] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម.,ទំព័រ៣៤។

[48] ក្រសួងអប់រំជាតិ, *ខេមរយោកម្ម (ប្រវត្តិវិទ្យាថ្នាក់ទី៦)*, ដ.ឯ.ម.,ទំព័រ៩៣។

[49] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ(សម្រាប់មធ្យមសិក្សា និងឧត្តមសិក្សា)*, ភាគ១, ដ.ឯ.ម., ទំព័រ៦០។

ទ្រឹស្តីអំពីឥទ្ធិពលឥណ្ឌាបានអះអាងថាវាមកពីពាណិជ្ជករឥណ្ឌា ដែលបានធ្វើដំណើរតាមកប៉ាល់មកកាន់តំបន់អាស៊ីអាគ្នេយ៍ ហើយនឹងបានបង្កើតឡើងនូវការតាំងទីពាណិជ្ជកម្មដោយបានរៀបអភិសេកជាមួយស្ត្រីក្នុងស្រុក ហើយបានផ្សព្វផ្សាយឥទ្ធិពលវប្បធម៌ឥណ្ឌាតាមរយៈសង្គមចម្រុះដែលបានចម្រើនលូតលាស់ឡើង។ ទ្រឹស្តីនេះត្រូវបានលោក ហ្សក សឺដេស យល់ស្រប ហើយបានប្រទះឃើញក្នុងសៀវភៅជាច្រើនដែលស្របតាមលោក។ កង្វះខាតនៃទ្រឹស្តីនេះ ត្រូវបានបង្ហាញជាពិសេសដោយលោក Van Leur។ ដំបូងគឺជាបញ្ហានៃភាសា។ ឈ្មួញឥណ្ឌាមិនបានចេះដឹងខាងភាសាសំស្ក្រឹតទេ ហើយបើសិនគេបានបង្កើតសង្គមចម្រុះមួយភាសានិយាយឥណ្ឌាគួរតែបានផ្សព្វផ្សាយនៅអាស៊ីអាគ្នេយ៍ មិនមែនសំស្ក្រឹតទេ។ ម្យ៉ាងទៀត មិនបានចេះដឹងរបៀបកសាងប្រាសាទបែបឥណ្ឌ ឬ ក៏រូបចម្លាក់ដែលជាសញ្ញាដ៏ច្បាស់លាស់បំផុតនៃលទ្ធិឥណ្ឌាទេ។ ម្យ៉ាងទៀត ការតាំងទីពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងនៅជិតកំពង់ផែសមុទ្ទ នៅខណៈពេលដែលមជ្ឈមណ្ឌលធំបំផុតទាំងអស់ មានប្រាសាទបែបឥណ្ឌា និងសិលាចារឹកជាច្រើនស្ថិតនៅតំបន់ដីគោក ជាកន្លែងដែលពាណិជ្ជករបរទេសមិនបានតាំងទីលំនៅនោះទេ[50]។

ចំពោះការភៀសខ្លួនពីសង្គ្រាមវិញ មានឯកសារមួយចំនួនសរសេរថានៅសតវត្សរ៍ទី១ រាជវង្សកុសាណៈមកពីអ៊ីរ៉ង់ បានចូលមកវាយត្រួតត្រាប្រទេសឥណ្ឌាភាគកណ្ដាលនិងខាងលិច។ នៅសតវត្សរ៍ទី២ រាជវង្សកុសាណៈដួលរលំ រាជវង្សគុប្តៈបានបង្កើតឡើង។ ភាពវឹកវរក្នុងប្រទេសបានកើតឡើងដោយជម្លោះរាជវង្ស ធ្វើឱ្យប្រជាជនឥណ្ឌាភៀសខ្លួនមករស់នៅអាស៊ីអាគ្នេយ៍ ពិសេសអាណាចក្រហ្វូណាន។ ជាក់ស្ដែង សិលាចារឹកវ៉ូកាញ់របស់គ្រួសារព្រះបាទស្រីមារៈ នៃរាជវង្សឥណ្ឌាកាលពីសតវត្សរ៍ទី១ គឺជាភស្តុតាងបញ្ជាក់ថាមាន ក្សត្រឥណ្ឌាដែលច្បាំងចាញ់គេ មកនៅអាស៊ីអាគ្នេយ៍។ នៅឥណ្ឌាក៏ដោយ ក៏គ្មានការពន្យល់ជាប្រពៃណីអំពីឥទ្ធិពលឥណ្ឌានៅអាស៊ីអាគ្នេយ៍ទេ។ ប៉ុន្តែចំពោះរឿងសង្គ្រាមនេះ គ្មានកំណត់ហេតុណាមួយនៅក្នុង ប្រទេសឥណ្ឌា ដែលបានរៀបរាប់អំពីការច្បាំងដណ្ដើម ឬ ការតាំងទីលំនៅរបស់ឥណ្ឌានៅតំបន់អាស៊ីអាគ្នេយ៍ទាល់តែសោះ[51]។

ប៉ុន្តែចំពោះការទទួលឥទ្ធិពលនេះ មានការយល់ស្របគ្នាច្រើនថា ព្រះមហាក្សត្រខ្មែរបានបញ្ជូន រាជវង្សមន្ត្រី និងអ្នកប្រាជ្ញទៅដល់ស្រុកឥណ្ឌា។ ពួកគេបានរៀនសូត្រ និងយកបទពិសោធល្អៗមកច្នៃប្រតិដ្ឋឱ្យសមស្របតាមគំនិតខ្មែរ។ ចំពោះរឿងនេះត្រូវបានលោក Van Leur សន្និដ្ឋានថាគេបានដឹកនាំទំនាក់ទំនងផ្លូវសមុទ្ទជាមួយឥណ្ឌាមុនសម័យ ដែលមានកំណត់ហេតុជាលាយលក្ខណ៍អក្សរដំបូង ហើយនឹងការផ្ដល់សញ្ញាណដំបូងអំពីឥទ្ធិពលឥណ្ឌា។ ដូច្នេះ អ្នកកាន់អំណាចអាស៊ីអាគ្នេយ៍ប្រហែលជាបានអញ្ជើញព្រាហ្មណ៍ឥណ្ឌាខ្លះ ប៉ុន្តែពួកគេបានដឹងអំពីឥណ្ឌាពីនាវិកផ្ទាល់ ដែលបានទៅកាន់ទីនោះ ដែលប្រហែលជាបាននាំយកសមាជិកនៃក្រុមអ្នកកាន់អំណាចអាស៊ីអាគ្នេយ៍ ដែលចង់ដឹងចង់ឃើញអំពីឥណ្ឌា។ មនុស្សខ្លះក្នុងចំណោមមនុស្សទាំងអស់នេះ បានស្នាក់នៅរៀនសូត្រភាសាសំស្ក្រឹត បានអង្កេតសំណង់ប្រាសាទ និងបដិមា ហើយនៅពេលដែលគេត្រឡប់មកវិញ គេបានអនុវត្ត និងបានកែច្នៃសម្រាប់ទស្សនៈរបស់ខ្លួនគេ[52]។

---

[50] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ(សម្រាប់មធ្យមសិក្សា និងឧត្តមសិក្សា)*, ភាគ១, ដ.ឯ.ម., ទំព័រ៣៥-៣៦។

[51] -ដ- ទំព័រ៣៤។

[52] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ៣៧។

## ៣-ព្រះនាមព្រះរាជាល្បីៗសម័យហ្វូណាន[53]

| ល.រ | សតវត្សរ៍ | ព្រះរាជាល្បី |
|---|---|---|
| ១ | សតវត្សរ៍ទី១ | លីវ យី, ហ៊ុន ទៀន |
| ២ | សតវត្សរ៍ទី២ | ហ៊ុន ប៉ានហួង, ហ្វាន់ ចេម៉ាន់ |
| ៣ | សតវត្សរ៍ទី៣ | ហ្វាន់ ស៊ីយុន, ហ្វាន់ ចាន់ |
| ៤ | សតវត្សរ៍ទី៤ | ធៀនឈូ ឆានតាន |
| ៥ | សតវត្សរ៍ទី៥ | កៅណ្ឌិន្យទី២, ស្រីន្រ្ទវម៌្ម, (កៅណ្ឌិន្យ)ជយវម៌្ម |
| ៦ | សតវត្សរ៍ទី៦ | រុទ្រវម៌្ម |

## ៤-រដ្ឋបាល និងសេដ្ឋកិច្ច

ព្រះរាជាអាណាចក្រហ្វូណានមានគោរមងារជា«ស្តេចភ្នំ»។ ព្រះអង្គជាមហារាជមានសិទ្ធិអំណាចលើអ្វីៗទាំងអស់លើផែនដី។ សាមន្តរាជទាំងអស់ត្រូវស្បថថា ស្មោះត្រង់នឹងមហារាជ ហើយនាំសួយសារអាករថ្វាយព្រះអង្គរាល់ឆ្នាំ។ ព្រះរាជា និងនាម៉ឺនមន្ត្រីគោរពសាសនាព្រាហ្មណ៍គណៈឥសូរ, វិណ្ណុ + ព្រះឥសូរ (ហរិហរៈ) រីឯប្រជារាស្ត្រគោរពព្រះពុទ្ធសាសនាហីនយាន គោរពដូនតា បុព្វបុរសនិងអារុក្ខអារក្សអ្នកតា។ នៅសម័យអាណាចក្រហ្វូណាន ពុំមានតុលាការច្បាស់លាស់ទេ។ អ្នកស្រុកហ្វូណាន បានចូលចិត្តប្រើវិធីដ៏អស្ចារ្យដើម្បីរកសេចក្តីពិត។ កាលណាមានបាត់របស់អ្វីមួយ គេក៏យកបាយមួយពំនូកទៅដាក់ព្រះភក្ត្រទេព្តា រួចគេអង្វរឱ្យព្រះអង្គជួយបង្ហាញមុខជនទុច្ចរិត។ ស្អែកឡើងគេយកបាយនោះ ទៅឱ្យខ្ញុំនៅក្នុងផ្ទះបរិភោគ នោះក្នុងមាត់ចោរនឹងមានឈាមហូរចេញយ៉ាងជាក់ស្តែងហើយ វាមិនអាចទំពារបាយផង។ ចំណែកក្នុងមាត់ជនទៀងត្រង់ បាយនោះអាចអិលទៅក្នុងមាត់បានយ៉ាងស្រួល។ ម៉្យាងទៀត បើកាលណាមាន ជនជាប់ចោទ គេឱ្យជននោះអត់បាយបីថ្ងៃ រួចគេតម្រូវឱ្យលូកយកវត្ថុផ្សេងៗ ក្នុងទឹកកំពុងពុះ ឬ កាន់ពូថៅ ឬ ច្រវ៉ាក់ ដុតក្រហមដើរ៧ជំហាន បើមានកំហុសមែនដៃរបស់ជននោះនឹងត្រូវរលួយ[54] ហើយគេមិននិយមដាក់គុក ជនទុច្ចរិតទេ។ បើកាលណាមានកំហុសស្រាលគេពិន័យជនមានទោស ប៉ុន្តែបើមានកំហុសធ្ងន់វិញគេយកអ្នកទោសទៅឱ្យក្រពើ ឬសត្វសាហាវស៊ីតែម្តង។ ក្នុងបីថ្ងៃបើសត្វទាំងនោះអត់ស៊ីទេ គេចាត់ទុកថាគ្មានកំហុស ហើយលែងឱ្យរួចខ្លួន[55]។ សរុបសេចក្តីមកឃើញថាតុលាការសម័យហ្វូណានគឺជាការកាត់ក្តីដែលមានលក្ខណៈពិសោធនិយម។

ហ្វូណាន ជាអាណាចក្រដែលមានឈ្មោះល្បីបំផុតនៅអាស៊ីអាគ្នេយ៍ នាសតវត្សរ៍ទី៣ ដែលអ្នកប្រវត្តិសាស្ត្រជាច្រើនចាត់ទុកថា ជាប្រទេសមហាអំណាចសេដ្ឋកិច្ច។ការគ្រប់គ្រងនៅសម័យហ្វូណាន គឺមានទម្រង់បែបមណ្ឌលអំណាច។ នយោបាយក្នុងប្រទេសវិញ គឺវាយពង្រីកទឹកដីត្រួតត្រាលើរដ្ឋតូចៗ ដើម្បីបង្រួបបង្រួមជាតិជុំវិញមហារាជ។ ផលិតផលនាំចេញមាន មាស, ប្រាក់, គ្រឿងអលង្ការ, កែវ, ក្រវាញ, ភ្លុកដំរី, កុយរមាស, ឈើក្រអូប, ក្រមួន និងគុជ ជាដើម។ ចំណែកឯផលិតផលនាំចូលមាន សំពត់ព្រែ សូត្រ ជាដើម។ រហូតមកដល់សម័យចេនឡា នយោបាយក្រៅប្រទេស គឺចងមិត្តភាព ជាមួយប្រទេសធំៗដូចជាចិន ឥណ្ឌា។ ព្រះរាជា

---

[53] ទី សុផល, ប្រវត្តិវិទ្យា, ជ.ឯ.ម., ទំព័រ៥៨។

[54] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ*, ភាគ១, ជ.ឯ.ម.,ទំព័រ៥៩។

[55] -ដ- ទំព័រ១០១។

ចេនឡាកសាងក្រុងនៅតាមមាត់ទឹក ដែលបង្ហាញពីចក្ខុវិស័យ ច្បាស់លាស់ និងគិតពីប្រយោជន៍ នៃជីវភាពប្រចាំថ្ងៃប្រជាជន ការធ្វើពាណិជ្ជកម្ម និងទាក់ទងនឹងសាសនាផងដែរ។

## ៥-ការដួលរលំ

### ៥.១-វិបត្តិនយោបាយផ្ទៃក្នុង

ព្រះបាទភវវរ្ម័ទី១ ត្រូវជាចៅរបស់ព្រះបាទរុទ្រវរ្ម័ និងជាស្តេចសោយរាជ្យនៅចេនឡា បានលើកទ័ពមកវាយក្រុមបះបោរប្រឆាំងនឹងអយ្យកោ និងដើម្បីដណ្តើមត្រួតត្រាលើអាណាចក្រហ្វូណាន។ ចាប់ពីពេលនោះមក អាណាចក្រភ្នំបានប្រែឈ្មោះមកជាអាណាចក្រចេនឡា ដែលគ្រប់គ្រងដោយព្រះបាទភវវរ្ម័ទី១[56]។ អ្នកស្រុកអាណាចក្រហ្វូណានភាគច្រើនពុំពេញចិត្តនឹងព្រះបាទរុទ្រវរ្ម័ ដែលបានសម្លាប់ព្រះអង្គម្ចាស់គុណវរ្ម័ត្រូវជាប្អូនប្រុស ដើម្បីដណ្តើមរាជ្យសម្បត្តិ ក៏ធ្វើការបះបោរប្រឆាំងនឹងអំណាចរុទ្រវរ្ម័។

### ៥.២-វិបត្តិសេដ្ឋកិច្ច

ប្រទេសកម្ពុជា មានការផ្លាស់ប្តូរខាងនយោបាយ និងសេដ្ឋកិច្ចដ៏សំខាន់បំផុតនៅសម័យហ្វូណាន។ ហេតុផលដំបូងចំពោះការផ្លាស់ប្តូរឈ្មោះពីហ្វូណាន ទៅចេនឡាគឺការធ្លាក់ចុះនៅក្នុងសេដ្ឋកិច្ចហ្វូណាន នៅពេលដែលពាណិជ្ជកម្មសំខាន់ភាគច្រើនពីអាស៊ីអាគ្នេយ៍ទៅចិន បានផ្លាស់ប្តូរពីបណ្តោយផ្លូវតាមឆ្នេរសមុទ្រ ឆ្លងកាត់កម្ពុជាទៅកាន់ផ្លូវថ្មីមួយដោយផ្ទាល់ពីឥណ្ឌូណេស៊ី (កោះជ្វា និងស៊ូម៉ាត្រា) កាត់តាមមហាសមុទ្រទៅចិនដោយគ្មានឈប់នៅតាមកំពង់ផែឆ្នេរសមុទ្រកម្ពុជា[57]។

### ៥.៣-ទំនាស់សាសនា

អ្នកស្រុកចេនឡាត្រកូលសូរ្យវង្សកាន់សាសនាព្រាហ្មណ៍ គណៈព្រះឥសូរៈ រីឯអ្នកស្រុកហ្វូណានត្រកូលសោមវង្សកាន់សាសនាព្រះពុទ្ធហីនយាន។ ក្រោយពីអាណាចក្រភ្នំទន់ខ្សោយ នគរចេនឡាបង្ខំឱ្យអ្នកស្រុកហ្វូណានកាន់សាសនាព្រាហ្មណ៍ដែរ[58]។

### ៥.៤-គ្រោះធម្មជាតិ

ចំពោះវិស័យកសិកម្មមានការរីកចម្រើនណាស់ ពីព្រោះនយោបាយទឹកមានការលូតលាស់[59] ហើយទីតាំងភូមិសាស្ត្រស្ថិតនៅដីសណ្តទន្លេមេគង្គ[60] ដែលជាតំបន់មួយប្រឈមនឹងទឹកជំនន់ផងដែរ។ ប៉ុន្តែចំពោះបញ្ហាទឹកជំនន់នេះ មិនសូវឃើញមានឯកសារប្រវត្តិសាស្ត្រជាភាសាបរទេស និងអ្នកនិពន្ធខ្មែរសរសេរឡើយដូចជាសៀវភៅត្រឹង ងា, អាដេម៉ារ ឡឺក្លែរ និងឯកសារខេមរយានកម្មជាដើម។ ប៉ុន្តែនៅក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី១០ បានរៀបរាប់ថាកាលនោះនៅដើមសតវត្សរ៍ទី៦មានគ្រោះទឹកជំនន់យ៉ាងធំ បានលិចលង់អាណាចក្រភ្នំ ធ្វើឱ្យអ្នកស្រុកមិនអាចទ្រាំរស់នៅតំបន់លិចទឹកទៀត ក៏នាំកូនចៅទៅរស់នៅតំបន់ដីគោក (ខាងជើង) គឺចេនឡា រួចលែងមកតំបន់ខាងត្បូងវិញ[61]។

---

[56] លោកបណ្ឌិត វង់ សុធា រ៉ា បានបង្ហាញថា សិលាចារឹកមួយបាននិយាយពីរាជទាយាទមួយព្រះអង្គឈ្មោះគុណវរ្ម័ ដែលគេជឿថាបុត្រារបស់ព្រះនាងកុលប្រភាវតីជាមួយព្រះបាទកៅឌិណ្ឌជយវរ្ម័ ដែលត្រូវឡើងស្នងរាជ ប៉ុន្តែ ត្រូវបងប្រុសឈ្មោះ រុទ្រវរ្ម័ ដណ្តើមរាជទៅ។ (Sabay NewsSocia: ផ្សាយថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨)។

[57] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ៦២។

[58] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ(សម្រាប់មធ្យមសិក្សា និងឧត្តមសិក្សា)*, ភាគ១, ដ.ឯ.ម., ១០៥-១០៦។

[59] ក្រសួងអប់រំជាតិ, *ខេមរយាកម្ម (ប្រវត្តិវិទ្យាថ្នាក់ទី៦)*, ដ.ឯ.ម., ទំព័រ៩៩។

[60] -ដ- ទំព័រ៩៤។

[61] ក្រសួងអប់រំ យុវជន និងកីឡា, *សិក្សាសង្គមថ្នាក់ទី១០*, ឆ្នាំ២០១៩, ទំព័រ១៣៥។

## ៦-សំណួរត្រិះរិះ

១-ចូររៀបរាប់ទីតាំងភូមិសាស្ត្រ និងកំណើតអាណាចក្រភ្នំ។

២-តើអាណាចក្រភ្នំបានទទួលឥទ្ធិឥណ្ឌាដោយរបៀបណា?

៣-មូលហេតុអ្វីខ្លះដែលធ្វើឱ្យអាណាចក្រភ្នំដួលរលំ?

៤-តើប្អូនយល់យ៉ាងណាចំពោះរបៀបកាត់ទោសសម័យអាណាចក្រភ្នំ? ហេតុអ្វី?

៥-តើកូនខ្មែរត្រូវធ្វើអ្វីខ្លះក្នុងការថែរក្សាមរតកប្រវត្តិសាស្ត្រដែលបន្សល់ទុកពីសម័យហ្វូណាន?

## មេរៀនទី៥ សម័យចេនឡា (ពីឆ្នាំ៥៥០ ដល់៨០២)

### ១-ទីតាំងភូមិសាស្ត្រ[62]

ចេនឡាគឺស្ថិតនៅនិរតីនៃនគរលើនយី ពីដើមជាសាមន្តរដ្ឋរបស់អាណាចក្រភ្នំ។ ចេនឡា មានទីតាំងស្ថិតនៅវាលទំនាបភាគកណ្ដាលនៃទន្លេមេគង្គក្នុងតំបន់ចំប៉ាសាក់ និងភាគខាងត្បូងខ្ពង់រាបកូរ៉ាត និងវាលទំនាបទន្លេមេគង្គខាងជើងត្រង់តំបន់ប៉ាក់សេនៃប្រទេសឡាវសព្វថ្ងៃ[63]។ ចំពោះទីតាំងរបស់ចេនឡាត្រូវបានអ្នកសិក្សាស្រាវជ្រាវលើកមកបង្ហាញជាច្រើនលើក ច្រើនសាដែលមានសម្មតិកម្មផ្សេងៗគ្នាដូចជា៖

១-កាលពីដំបូងលោក ហ្សិក សឺដែស ពន្យល់ថាទីតាំងចេនឡាគួរតែស្ថិតនៅជិតវត្តភូដែលជាអតីតក្រុង កុរុងក្សេត្រ របស់ស្ដេចទេវានីក នៅសតវត្សរ៍ទី៥ និងបន្ទាប់មកជាក្រុងរបស់ស្ដេចស្រុតវម៌្ម និងស្រេស្ឋវម៌្ម ជាមច្ឆាជនរបស់ឥសីកម្ពុ និងអប្សរមេរាដែលបានបង្កើតក្រុងឈ្មោះ ស្រេស្ឋបុរ នៅក្នុងតំបន់ជាមួយគ្នានោះដែរ។ តែក្រោយមកទៀតលោកសន្និដ្ឋានថា ក្រុងភវបុររបស់ស្ដេចចេនឡា គួរតែនៅក្បែរតំបន់អំពិលរលើង ឃុំចំណារលើ ស្រុកស្ទោង វិញ[64]។

២-លោក ប៉ូល ឡេវី បានសន្និដ្ឋានថានៅថលាបរីវ៉ាត់ជាក្រុង ភវបុរ របស់ស្ដេចចេនឡានាម ភវវម៌្មទី១។

៣-លោក ក្លូដ ហ្សាក់(Claude Jacqes) និងលោក ម៉ាយឃើល វិកឃឺរី(Michael Vickery) : លោកទាំងពីរបានសន្និដ្ឋានថា ក្រុងរបស់ចេនឡាគួរតែត្រូវនឹងអតីតទីតាំងសំបូរព្រៃគុក។

ចំពោះរឿងនេះ បើយោងតាមការបកស្រាយរបស់លោក ម៉ាយឃើល វិកឃឺរី គឺលោកជឿថាចេនឡាអាចមានតំបន់ពីរ គឺនៅភាគខាងលើមានមជ្ឈមណ្ឌលនៅសម្ភុបុរ ក្នុងខេត្តក្រចេះអាចមានអំណាចគ្រប់គ្រងនៅភាគខាងជើង ដែលមានបង្អែកសេដ្ឋកិច្ច លើវិស័យពាណិជ្ជកម្ម។ ចំណែកមួយផ្នែកលោកជឿជាក់ថាមានមណ្ឌលសំខាន់ស្ថិតនៅអតីតរាជធានីវ្យាធបុរ ស្រុកអង្គរបូរី។

### ២-បញ្ហាឈ្មោះចេនឡា[65]

ចំពោះឈ្មោះ«ចេនឡា» ក៏ដូច «ហ្វូណាន» ដែរ ត្រូវបានគេស្គាល់តែពីរបាយការណ៍ចិន[66]អំពីកម្ពុជាតែប៉ុណ្ណោះ។ ប្រហែលជាហេតុផលនេះហើយទើបអ្នកស្រាវជ្រាវនាំគ្នាសន្និដ្ឋានពីប្រភពផ្សេងៗ និងអត្ថន័យនៃពាក្យនេះ ដែលការបង្ហាញទាំងអស់នោះគឺជាសម្មតិកម្ម។ អ្នកស្រាវជ្រាវខ្មែរ និងអន្តរជាតិមួយចំនួនបានបញ្ចេញទស្សនៈផ្សេងៗគ្នាដូចខាងក្រោម៖

| ល.រ | ឈ្មោះ | ទស្សនៈ |
|---|---|---|
| ១ | **ប៉ូល ប៉េល្លីយ៉ូត៍**<br>(Paul Pelliot) | ឈ្មោះ«ចេនឡា»មកពីពាក្យ«ចិនរាប» ព្រោះនគរចេនឡាមានទីតាំងជាប់នឹងប្រទេសចិន។ ឥណ្ឌូចិនខាងជើងប្រហែលជាធ្លាប់មានជម្លោះនឹងគ្នា ហើយធ្លាប់ទទួលជោគជ័យលើជនជាតិទាំងនេះផង។<br>**ចិន + រាប > ចេនឡា**<br>(ចិនដែលខ្មែរពង្រាបបាន) |

[62] ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៧០-៧១។

[63] ក្រសួងអប់រំ យុវជន និងកីឡា, *សិក្សាសង្គមថ្នាក់ទី១០,* ដ.ឯ.ម., ទំព័រ១៣៨។

[64] បើយោងតាមសិលាចារឹក K.162។

[65] ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៦៨-៧០។

[66] របាយការណ៍ចិនភាគច្រើនដែលសរសេរនៅសតវត្សរ៍ទី៦, ៧, ៨ ត្រូវបានចម្លងឡើងវិញ ដោយមន្ត្រីផ្នែកប្រវត្តិសាស្ត្រចិនចាប់ពីសតវត្សរ៍ទី១១-១៥។

| | | |
|---|---|---|
| ២ | **កេង វ៉ាន់សាក់** | ឈ្មោះ«ចេនឡា» មកពីពាក្យ«ចិនលា» ពីព្រោះចិនមានបំណងវាត្រួតត្រាមកលើនគរចេនឡា។ ប៉ុន្តែត្រួតត្រារដ្ឋនេះមិនបានក៏លាទៅស្រុកវិញ។<br>**ចិន + លា > ចេនឡា**<br>(ចិនដកថយ ឬ លាទៅស្រុកវិញ) |
| ៣ | **លី ធាមតេង** | រដ្ឋចេនឡាសម្បូរព្រៃក្រាស់ និងសម្បូរឃ្មុំ។ ពួកចិនតែងតែមកស្រុកចេនឡា ដើម្បីទិញក្រមួនឃ្មុំរបស់អ្នកស្រុកនេះសុទ្ធល្អ ទើបពួកឈ្មួញចិនសន្មតហៅ ស្រុកនេះថា«ស្រុកក្រមួនសុទ្ធ(ចេនឡា ឬ ចេងឡាក់)គឺ(pure+Bee Wax)»។<br>**ចេន ឬ ចេង+ឡា ឬ ឡាក់ →ចេនឡា+ចេងឡាក់** (ចេន = សុទ្ធ, ឡា = ក្រមួន)[67]។ |
| ៤ | **ឆត្រាប្រេម ឬឌី** | កាលពីសម័យបុរាណ ប្រទេសខ្មែរចែកជាពីរផ្នែកគឺជាន់លើ(ខាងជើង) និងពូជក្រោម ឬ ក្រោមពូជ (ខាងត្បូង)។ ពាក្យជាន់លើនេះ ចិនហៅត្រាប់មិនច្បាស់ទៅជាចេនឡា។<br>**ជាន់លើ > ចេនឡា** |
| ៥ | **ហ្គោស**(Ghoh) | **ចន្ទ្របុរ(Chandrabura) > ចន្ទ្រា> ចេនឡា**<br>តាមសម្មតិកម្មរបស់លោក លី ធាមតេង គឺជាឈ្មោះដែលចិនដាក់ឱ្យទៅតាមការកត់សម្គាល់របស់ខ្លួន ដែលប្រហែលជាពាក់ព័ន្ធនឹងពាណិជ្ជកម្មចិន ហើយកន្លែងផ្ទុកទំនិញក្រមួននោះគឺនៅខេត្តក្រមួន-ស។ |

## ៣-ព្រះរាជា និងស្នាព្រះហស្ត

### ៣.១-ព្រះបាទឥសានវរ្ម័នទី១(៦១៦-៦៣៧) និងវិសាលភាពទឹកដី

ប្រទេសកម្ពុជា កើតឡើងដោយសារការបញ្ចូលគ្នារវាងរដ្ឋដែលមានអានុភាពពីរគឺនគរភ្នំ (ខាងត្បូងភ្នំដងរែក) និងចេនឡា(ខាងជើងភ្នំដងរែក)[68] នៅពាក់កណ្ដាលគ្រិស្តសតវត្សរ៍ទី៦។ នៅឆ្នាំ៥៥០ ព្រះបាទភវវរ្ម័ទី១ (ឆ្នាំ៥៥០-៦០០) ដែលជាស្ដេចនគរចេនឡា បានបង្រួបបង្រួមទឹកដីខ្មែរ ដែលស្ថិតនៅខាងជើង និងខាងត្បូងភ្នំដងរែក ឱ្យក្លាយជា «រដ្ឋឯកភាព»តែមួយ តាមរយៈការធ្វើសង្គ្រាម។ នៅឆ្នាំ៦០០ ព្រះបាទ មហេន្ទ្រវរ្ម័ (ឆ្នាំ៦០០-៦១៦) ជាប្អូនជីដូនមួយដែលបានឡើងស្នងរាជ្យនោះបានធ្វើសង្គ្រាមជាបន្តទៅទិសខាងលិច និងខាងត្បូង។ សុខដុមនីយកម្មខាងទឹកដីនៅសម័យចេនឡា បាននាំឱ្យមានសុខដុមនីយកម្មខាងជាតិ សាសន៍ខ្មែរផងដែរ។ ប្រជាពលរដ្ឋនៃចេនឡានិងនគរភ្នំ សុទ្ធតែជាជាតិសាសន៍ខ្មែរ។ «ខ្មែរលើ» រស់នៅចេនឡា ដែល

[67] ភស្តុតាងដែលបង្ហាញថាប្រទេសកម្ពុជាសម្បូរឃ្មុំ និងធ្វើក្រមួនពីព្រោះរហូតដល់សម័យអាណាព្យាបាលបារាំងគឺត្រូវបានលោក ហ្សង់ ម្វ៉ា លើកឡើងថាប្រទេសកម្ពុជា សត្វឃ្មុំធ្វើសំបុកធំៗនៅតាមដើមឈើធំនានា។ ប្រជារាស្ត្រខ្មែរ ឬ កុលសម្ព័ន្ធដែលរស់នៅក្នុងខេត្តពោធិ៍សាត់ ពិសេសពួកព័រមានវិធីយកឃ្មុំតាមបែបបុរាណរបស់ពួកគេ ដើម្បីធ្វើជាក្រមួន។ ក្រមួន នោះគេលក់ក្នុងតម្លៃ៤៥០ហ្វ្រង់ ក្នុងបរិមាណក្រមួនទម្ងន់៦៥គីឡូក្រាម។

[68] Norodom Sihanouk, *La monarchie cambodgienne et la croisade royale pour l'independence (រាជាធិបតេយ្យកម្ពុជា និងរាជបូជនីយកិច្ចដើម្បីឯករាជ្យ)*, Ministère de l'Education Nationale, Direction des Services Péagogiques, 1958, p.1។

ជាតំបន់ដីខ្ពស់ នៅខាងជើងជួរភ្នំដងរែក ចំណែកឯ «ខ្មែរក្រោម» រស់នៅហ្វូណាន ដែលជាតំបន់ដីទំនាប នៅខាងត្បូងជួរភ្នំដងរែក[69]។

ព្រះបាទឥសានវរ្ម័ទី១ បានតាំងរាជធានីនៅឥសានបុរ។ ប្រាសាទសម្បូណ៌ព្រៃគុក ដែលត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពីឆ្នាំ២០១៧។ ដោយសារនេះជា សង្គ្រាមបង្រួបបង្រួមទឹកដីខ្មែរ និងប្រជាជាតិខ្មែរនោះ ព្រះបាទឥសានវរ្ម័ទី១ សក្តិសមនឹងមាននាមថា «ស្តេចសឹកសាងសង់» ក្នុងប្រវត្តិសាស្ត្រជាតិខ្មែរផងដែរ[70] ហើយទ្រង់ជាមហារាជ ឬរាជាធិរាជដ៏ល្បីមួយអង្គនៅសម័យចេនឡា។

ព្រះបាទឥសានវរ្ម័ទី១ បានបន្សល់ទុកសិលាចារឹកជាច្រើននៅអតីតរាជានីឥសាបុរ[71] និងនៅតាម ខេត្តនានាក្នុងប្រទេសកម្ពុជា។ ជាពិសេសនោះគឺភស្តុតាងប្រវត្តិសាស្ត្រដ៏មានតម្លៃបំផុតមួយ គឺសិលាចារឹកដែលមានពាក្យថា«សុវណ្ណភូមិ» មានអាយុកាលពីក្នុងរជ្ជកាលព្រះអង្គ នៅឆ្នាំ៦៣៣ នៃគ្រិស្តសករាជ ដែលបង្ហាញពីការគ្រប់គ្រងទឹកដីសុវណ្ណភូមិទាំងមូលទៅទល់នឹងដែនសមុទ្ទ[72]។

### ៣.២-ព្រះមហារាជិនីជយទេវី(៦៨១-៧១៧[73])និងឯកភាពូបនីយកម្មទឹកដី

ព្រះនាងជយទេវី ជាបុត្រីរបស់ព្រះបាទជយវរ្ម័ទី១។ ទ្រង់បានឡើងសោយរាជ្យសម្បត្តិនៅឆ្នាំ៧១៣[74] តែគេពុំបានដឹងថាតើមានអ្នកកាន់អំណាចផ្សេងទៀតដែរ ឬ ទេនៅចន្លោះ ព្រះនាង និង ព្រះបិតា[75]។ អំណាចរបស់ព្រះនាងពុំមានមូលដ្ឋានមាំទាំឡើយ ព្រោះក្នុងអត្ថបទសិលាចារឹកមួយនៅក្នុងបារាយណ៍ទឹកថ្លា ព្រះនាងបានត្អូញត្អែពីភាពប្រឫកប្របល់ក្នុងចិត្តគំនិត និងពីទុក្ខវេទនាក្នុងគ្រាកើតកលិយុគ[76]។ ចំណែកការចាប់ផ្តើមពីសតវត្សរ៍ទី៨វិញ ព័ត៌មានសិលាចារឹកបានបង្ហាញដានហាក់ផ្ទុយពីប្រភពឯកសារចិន ត្រង់ឯកភាវូបនីយកម្មទឹកដីនៅក្រោមអំណាចរបស់អធិរាជនីតែមួយបានកាន់តែជោគជ័យនៅពាក់កណ្តាលទី១ នៃសតវត្សរ៍ទី៨។ នោះគឺការតម្កើងឋានៈកាន់តែខ្ពស់ជាងព្រះរាជាមុនៗរបស់ព្រះមហាក្សត្រិយានីជយទេវី ដែលមាននៅលើសិលាចារឹកបារាយណ៍ទឹកថ្លាហៅ ថាធូលីជេងវ្រះកម្រតាងអញ ស្រី ជយទេវី។ ឋានន្តរនាមកាន់តែខ្ពង់ខ្ពស់ជាងព្រះរាជាមុនៗបែបនេះសម្គាល់ថាព្រះនាងមានអំណាចធំជាងស្តេចប្រុសមុនៗ និងគ្រប់គ្រងដែនដីកាន់តែធំជាងមុន។ ឋានន្តរនាមបែបនេះ ត្រូវបានស្តេចចក្រពត្តិនៅសម័យអង្គរបានបន្តប្រើយ៉ាងហោចណាស់រហូតដល់រជ្ជកាលព្រះបាទយសោវរ្ម័ទី១ដែរ[77]។ ព្រះនាងជាក្សត្រី ដែលបានគ្រប់គ្រងក្សត្របុរីមុនសម័យចេនឡា។ ទ្រង់ជាអ្នកដឹកនាំ និងបង្រួបបង្រួមរដ្ឋជាច្រើនឱ្យនៅឯកភាពគ្នា។ ព្រះនាងគ្រប់គ្រងចេនឡាទាំងមូល ហើយមណ្ឌល

[69] ស៊ន សំណាង, សិក្ខាសាលាប្រចាំសប្តាហ៍ ថ្នាក់ក្រោយបរិញ្ញាបត្រ ឆ្នាំសិក្សា២០១៩-២០០០, ថ្ងៃសុក្រទី២២ ខែឧសភា ឆ្នាំ២០២០។

[70] -ដ-។

[71] ឥសានបុរ ត្រូវនឹងតំបន់សំបូរព្រៃគុក ។

[72] សិលាចារឹកនេះរកឃើញដោយលោកបណ្ឌិត វង់ សុធារ៉ា នៅថ្ងៃសុក្រទី២២ ខែធ្នូ ឆ្នាំ២០១៧ ក្នុងដំណើរត្រឡប់ពីការប្រជុំការងារនៅខេត្តកំពត។ សិលាចារឹកនេះរកឃើញនៅវត្តស្តេចគង់(វត្តបឹង)នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

[73] ក្រសួងអប់រំ យុវជន និងកីឡា, *ខ្មែរ និងដំណើរឆ្ពោះទៅសម័យអង្គរដ៏រុងរឿង*, ឆ្នាំ២០២១, ទំព័រ៤១។

[74] តើអាចទេថាព្រះនាមគ្រប់គ្រងប្រទេសតាំងពីឆ្នាំ៦៨១ ក្រោយការយាងចូលទិវង្គតរបស់ព្រះបាទ ជយវរ្ម័ទី១ បើសិនបើពុំទាន់មានសិលាចារឹកណាបញ្ជាក់ច្បាស់ពីអ្នកស្នងរាជ្យបន្ទាប់ពីទ្រង់នោះ?

[75] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា*, ដ.ឯ.ម., ទំព័រ៥៣។

[76] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ*, ភាគ១, ដ.ឯ.ម., ទំព័រ១១៩។ នេះប្រហែលជារឿងធម្មតានៃការគ្រងគ្រង ដែលរដ្ឋមួយមានរដ្ឋបុរីតូចៗជាច្រើននៅក្រោមចំណុះ គឺតែងតែជួបបញ្ហា ដោយសារតែរដ្ឋបុរីទាំងនោះពង្រឹងខ្លួន ដើម្បីឯករាជ្យរបស់ខ្លួន។

[77] វង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ(សម្រាប់ឆ្នាំមូលដ្ឋាន)*, ២០១៣, ទំព័រ៣៤។

អំណាចរបស់ចេនឡាគឺបុរន្ទរបុរ ស្ថិតនៅបារាយណ៍ទឹកថ្លា ក្នុងស្រុកពួក ខេត្តសៀមរាបសព្វថ្ងៃ[78]។ ទោះបីជាគ្មានភស្តុតាងច្បាស់លាស់ទេ ពីទំហំផ្ទៃដីក្រោមអំណាចព្រះនាង ប៉ុន្តែក្នុងសិលាចារឹក ព្រះនាងមានបញ្ជីឈ្មោះទីកន្លែង ដែលព្រះនាងប្រមូលប្រជារាស្ត្រមកធ្វើការគេឃើញមានឈ្មោះ**ចរន្ត** គឺឈ្មោះដែលប្រើមុននោះក្នុងសតវត្សរ៍ទី៧ ស្ថិតនៅខេត្តតាកែវ[79]។

## ៤-ចេនឡា និងការបែកបាក់

ចេនឡា ដែលគេដឹងតាមឯកសារចិនថា Zhenla នោះ គឺជារាជាណាចក្រខ្មែរដំបូងមួយ។ មុនដំបូងជារដ្ឋចំណុះរបស់ហ្វូណាន ប្រហែលនៅឆ្នាំ៥៥០។ បន្ទាប់មកទទួលបានឯករាជ្យ ហើយដណ្តើមយកបានហ្វូណានទាំងមូលវិញ ដោយស្រូបយកទាំងប្រជាជនទាំងវប្បធម៌ (People and Culture)។ ការចុះខ្សោយនៃរដ្ឋហ្វូណាននាសម័យនោះ អាចពន្យល់បានដោយ «ព្រឹត្តិការណ៍មិនផ្ទាល់»៖ នោះគឺការដួលរលំចក្រភពរ៉ូម៉ាំង និងផ្លូវពាណិជ្ជកម្មរវាងសមុទ្រមេឌីទែរ៉ានេ និងចិន (the collapse of the Roman Empire and subsequently trade routes between the Mediterranean  and China)។

នៅឆ្នាំ៦១៣ ឥសានបុរ បានក្លាយជារាជធានីដំបូងនៃចក្រភពថ្មី។ ក្រោយមកចេនឡាបានបែកជា២ផ្នែកជារដ្ឋខាងជើង និងខាងត្បូងដែលគេស្គាល់ថាជា«ចេនឡាគោក» និង«ចេនឡាទឹក»។ ខេត្តចម្ប៉ាសាក់នៅក្នុងប្រទេសឡាវបច្ចុប្បន្នជាមជ្ឈមណ្ឌលនៃផ្នែកខាងជើង ចំណែកទឹកដីសណ្តទន្លេមេគង្គ និងតំបន់ឆ្នេរសមុទ្រជាទឹកដីរបស់ផ្នែកខាងត្បូង[80]។ ប្រភពផ្សេងទៀត បានបង្ហាញថាប្រហែលជានៅ ឆ្នាំ៥៥០ ចេនឡាជារដ្ឋចំណុះរបស់ហ្វូណានដណ្តើមបានឯករាជ្យ។ ដោយសារការធ្វើសង្គ្រាម ចេនឡាបានពង្រីកទឹកដីមកលើហ្វូណានដីសណ្តទន្លេមេគង្គ ភាគខាងត្បូងថៃ និងភាគនានានៃប្រទេសឡាវ។ នៅឆ្នាំ៦១៣ រាជធានីត្រូវបានស្ថាបនាឡើងនៅ ឥសានបុរ។ ខ្មែរគោរពសាសនាហិណ្ឌូ។

នៅឆ្នាំ៧០៦ ចេនឡាត្រូវបែកជាពីរគឺ ចេនឡាគោក ដែលមានចម្ប៉ាសាក់ ជាមជ្ឈមណ្ឌល(ឡាវទំនើប) និងចេនឡាទឹក[81]។ នៅឆ្នាំ៧១៥ និងឆ្នាំបន្តមករាជាណាចក្រទាំងពីរបានបែកបាក់ជាបន្តមកទៀត។ ចេនឡាទឹកទទួលការវាយលុកពីពួកចោរម៉ាឡេ និងក្លាយជារដ្ឋចំណុះរបស់សន្តតិវង្ស សៃលេន្ទ្រនៃកោះជ្វា(Water Chenla, the latter, subject to Malay pirate raids,become a vassal of the Javanese Sailendra Dynasty)[82]។

បើតាមសាស្ត្រាចារ្យបណ្ឌិត វង់ សុធារ៉ា ដែលបានរៀបរាប់ក្នុងសៀវភៅប្រវត្តិសាស្ត្រខ្មែរឆ្នាំមូលដ្ឋានលោកបានពន្យល់ថាសារៈសំខាន់របស់ចេនឡា បានលេចឡើងដោយសារក្នុងសៀវភៅប្រវត្តិសាស្ត្រ របស់លោក សឺដេស និងត្រឹង ងា ដោយសារ ចិនបានចាប់ផ្តើមសរសេរក្នុងរបាយការណ៍របស់ខ្លួននៅដើមសតវត្សរ៍ទី៧ នោះថាបានវាយប្រហារហ្វូណាន នៅពេលនោះហើយដែលហ្វូណានបញ្ជូនបេសកទូតសុំជំនួយទ័ពពីចិន

[78] ក្រសួងអប់រំ យុវជន និងកីឡា, *ខ្មែរ និងដំណើរឆ្ពោះទៅសម័យអង្គរដ៏រុងរឿង*, ដ.ឯ.ម., ទំព័រ៤១។

[79] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា*, ដ.ឯ.ម., ទំព័រ៦១។

[80] http://www.worldlingo.com/ma/enwiki/en/Chenla.

[81] រឿងនេះ ប្រហែលជាការបែងចែកជាតំបន់ភូមិសាស្ត្រ។

[82] http://www.zum.de/whkmla/region/seasia/chenla.html.

៣ដងបន្តបន្ទាប់គ្នានៅឆ្នាំ៥២៣-៥៤០។ ចំណែកលោក វីកឃើរី បញ្ជាក់ថាវាមិនពិតទេពីបញ្ហាស្តីពីការប្រយុទ្ធគ្នារបស់ចេនឡាជាមួយអាណាចក្រហ្វូណានព្រោះលោកផ្អែកលើភស្តុតាងពីរៈ

**១-ព្រះបាទភវវរ្ម័ទី១** ដែលគេនាំគ្នាថា ជាស្តេចនៃប្រទេសចេនឡានៅពេលនោះ។ ដូចជាសិលាចារឹកប្រាសាទជ្រៃK.149 បានឱ្យដឹងថាព្រះអង្គធ្លាប់ធ្វើអំណោយដល់ប្រាសាទនោះ ដែលជាភស្តុតាងថា ព្រះអង្គបានគ្រប់គ្រងភាគកណ្តាលនៃកម្ពុជារួចស្រេចហើយ មុនដំណាច់សតវត្សរ៍ទី៦។ មានសិលាចារឹកជាច្រើនបញ្ជាក់ថា ព្រះអង្គជាក្សត្រនៃរាជវង្សសោមវង្ស និងប្រហែលជាចៅ (នត្តា) របស់ព្រះបាទរុទ្រវរ្ម័។ ដូច្នេះបើមានសង្គ្រាមគឺជារឿងស្របច្បាប់ ដែលក្សត្រអង្គនេះធ្វើឡើងដើម្បីផ្តួលរំលំក្សត្រមួយអង្គទៀត ដែលជាសត្រូវព្រះអយ្យកោរបស់ខ្លួន។ ចំណែករឿងរ៉ាវបានពីសិលាចារឹកប្រាសាទតាព្រហ្ម ដែលគេបានបកប្រែថាព្រះបាទ ភវវរ្ម័ទី១ ឡើងសោយរាជ្យបានដោយសារព្រះមហេសីនាម កម្ពុជរាជលក្ស្មី ដែលជាស្តេចនៃចេនឡានោះ ត្រូវបានបដិសេធដោយលោក ក្លូត ហ្សាក់ នៅពេលគាត់អាន និងផ្ទៀងផ្ទាត់ការបកប្រែនោះឡើងវិញ។ ម្លោះហើយភវវរ្ម័ទី១ ជាបុត្រាព្រះបាទវីរវរ្ម័ និងជាចៅនៃស្តេចចក្រពត្តិនៃប្រទេសហ្វូណាន។

**២-គេសង្កេតឃើញសិលាចារឹកមួយនៅក្តីអង្គ ឬ អង្គជំនីក (K:53)** បានរៀបរាប់ពីក្រុមគ្រួសារមួយដែលជាមន្ត្រីជំនិតបម្រើព្រះរាជាអស់៥ជំនាន់ ចាប់តាំងពីរាជ្យព្រះបាទរុទ្រវរ្ម័ រហូតមកដល់រាជ្យ ជយវរ្ម័ទី១។ ព្រឹត្តិការណ៍បែបនេះគឺជារឿងកម្រនឹងកើតមានណាស់នៅសម័យបុរាណ។ ព្រោះអ្នកឈ្នះ ឬ អ្នកស្នងតំណែងមិនស្របច្បាប់មិនដែលទុកចិត្ត និងយកមន្ត្រីរបស់ស្តេចដែលជាសត្រូវមកប្រើប្រាស់ឡើយ។

នៅសតវត្សរ៍ទី៨ ពួកចោរសមុទ្ទជាតិជ្វា បានជិះសំពៅធំៗ មករាតត្បាតឆ្នេរសមុទ្ទ និងតាមទន្លេនៃអាស៊ីអាគ្នេយ៍ដីគោកនៅពេលដែលរាជវង្សសៃលេន្ទ្រ[83]ដែលសោយរាជ្យនៅកោះជ្វាមានឥទ្ធិពលលើអាស៊ីអាគ្នេយ៍ទាំងមូល។ នៅឆ្នាំ៧៧៤ និង៧៨៧[84] ពួកចោរជ្វាក្រោយពីវាយបានកោះត្រឡាចហើយ តាំងមូលដ្ឋានបានរាតត្បាតឆ្នេរសមុទ្ទប្រទេសចម្ប៉ា និងចេនឡាទឹក ឡើងតាមទន្លេមេគង្គដល់សម្ភុបុរផុតបំផ្លាញក្រុង និងចាប់បានព្រះរាជាព្រះនាមមហីតិវរ្ម័ ដែលជាបុត្ររបស់ព្រះបាទរាជេន្ទ្រវរ្ម័ កាត់ព្រះសិរយកទៅប្រទេសជ្វា។ ចំពោះការតាំងអំណាច អធិរាជភាពរបស់ពួកសៃលេន្ទ្រលើប្រទេសខ្មែរនោះនៅសតវត្សរ៍ទី១០ ឈ្មួញអារ៉ាប់ម្នាក់ឈ្មោះសូឡៃម៉ាន់បានតំណាលថាៈ ថ្ងៃមួយព្រះរាជាខ្មែរមានបំណងចង់ឃើញព្រះសិរនៃមហារាជក្រុង Zabag កាត់ដាក់លើថាសមួយ។ ដំណឹងនេះឮដល់មហារាជព្រះអង្គក៏លើកទ័ពជើងទឹកចូលមកវាយប្រទេសខ្មែរ ចាប់បានព្រះរាជាខ្មែរហើយបញ្ជាឱ្យកាត់ព្រះសិរ។ លុះ ត្រឡប់ទៅដល់នគរវិញហើយ មហារាជបានយកព្រះសិរនោះទៅលាងឱ្យស្អាតយកអប់ទុកក្នុងភាជន៍មួយ រួចបញ្ជូនមកថ្វាយព្រះរាជាខ្មែរដែលសោយរាជ្យបន្ត។ ចាប់ពីពេលនោះមក រៀងរាល់ព្រឹកព្រះរាជាខ្មែរត្រូវបែរព្រះភក្ត្រឆ្ពោះទៅក្រុងZabag ដើម្បីសម្តែងការគោរពចំពោះព្រះរាជាក្រុងនោះ[85]។ ចំពោះលោក ហ្សកសឺដេស បានឱ្យសារៈសំខាន់យ៉ាងខ្លាំងដល់រាជវង្សជ្វា ហៅសៃលេន្ទ្រថាជារាជវង្សមួយខ្លាំងនៅដើមសតវត្សរ៍ទី៨ បានឃ្លានពានកម្ពុជា ហើយលោកបន្តសន្និដ្ឋានថា ប្រហែលដោយសារការចុះខ្សោយនៃរាជវង្សសៃលេន្ទ្រនៅកោះជ្វា(ជវា) ទើបជំរុញឱ្យ ស្តេចជយវរ្ម័ទី២ ត្រឡប់មកពីជ្វាវិញប្រហែល

---

[83] រាជវង្សនេះបានកសាងប្រាសាទ បូរ៉ូប៊ូឌួ។

[84] បើយោងតាមកំណត់របស់ចិនស្តីពីប្រទេសយួន និងចាម្ប ដែលត្រូវរងការវាយលុកច្រើនដងដោយកប៉ាល់លើឆ្នេរសមុទ្ទប្រទេសដីកោះទាំងនោះ ក្នុងករណីមួយនោះគេថាជា«កប៉ាល់ពួកជ្វា»។ ការវាយប្រហារទាំងនេះកើតឡើងនៅឆ្នាំ៧៦៧ទៅលើប្រទេសយួន, ឆ្នាំ៧៧៤ និង៧៨៧ ទៅលើប្រទេសចាម្ប(វង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម, ទំព័រ៣៥។

[85] តាមអត្ថបទរបស់អ្នកនិពន្ធអារ៉ាប់ Abou Zayd Hassan នៅឆ្នាំ៩២៦ (ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ* , ភាគ១, ដ.ឯ.ម., ទំព័រ១២៤)។

នៅឆ្នាំ៨០០ ដែលយើងមានភស្តុតាងជាច្រើនពាក់ព័ន្ធនឹងរាជព្រះអង្គដំបូងថា ទ្រង់គ្រងរាជ្យនៅឆ្នាំ៨០២។ ចំណែកលោក វិកឃើរីអេះអាងថា *នោះជាព័ត៌មានផ្អែកលើប្រភពរឿងព្រេងរបស់ជនជាតិអារ៉ាប់កាលពីសតវត្សរ៍ទី១០ហើយត្រូវប្រវត្តិវិទូឥណ្ឌូណេស៊ីយកមកពន្លាត និងបកស្រាយដើម្បីលើកកិត្យានុភាពប្រទេសជ្វាបុរាណ។ យោងតាមកំណត់ហេតុរបស់ចិនស្តីពីប្រទេសយួន និង ចាម្ប ដែលត្រូវរងការវាយលុកច្រើនដងដោយកប៉ាល់លើឆ្នេរសមុទ្រប្រទេសជីកោះទាំងនោះ ដែលក្នុងករណីនោះគេហៅថា «កប៉ាល់ពួកជ្វា»។ ការវាយប្រហារទាំងនោះ កើតឡើងនៅឆ្នាំ៧៦៧ ទៅលើប្រទេសយួន និងឆ្នាំ៧៧៤, ៧៨៧ ទៅលើប្រទេសចាម្ប (ប្រហែលនេះជាមូលហេតុដែលលោក ហ្សក សឺដេស ភ្ជាប់ព្រឹត្តិការណ៍នេះមកកម្ពុជា)*[86]។

ចំពោះរឿងកាត់ព្រះសិរស្តេចខ្មែរនេះ ប្រវត្តិវិទូឥណ្ឌូណេស៊ី បានបញ្ជាក់ថា នៅសតវត្សរ៍ទី៨ទាំងកោះជ្វា និងកោះស៊ូម៉ាត្រា (ស្រីវិជ័យ) គ្មានអំណាចគ្រប់គ្រាន់ ដើម្បីមកគ្របដណ្តប់មកលើកម្ពុជា និងចាប់ខ្លួនគ្រួសាររាជវង្សមួយចំនួន ដូចជាព្រះបាទជយវម៌្មទី២នោះទេ ហើយប្រទេសនេះក៏មិនទាន់ខ្លាំងពូកែផ្នែកសមុទ្រដែរ ជាវិសេសនោះគឺគេជាប់ធ្វើពាណិជ្ជកម្មផ្លូវគោក[87]។

សរុបសេចក្តីមក រឿងជ្វាលុកលុយចេនឡា កាត់ក្បាលស្តេចខ្មែរ និងចាប់រាជវង្សានុវង្សខ្មែរយកទៅស្រុកជ្វា នៅសតវត្សរ៍ទី៨ គឺគ្រាន់តែជារឿងប្រតិដ្ឋមួយដែលគេពន្លាតចេញពីរឿងព្រេងនិទានរបស់ពួកអារ៉ាប់ដែលបានរំឭកឡើងវិញកាលសតវត្សរ៍ទី១០ប៉ុណ្ណោះ។ ប្រទេសដែលអាចបង្កបញ្ហាដល់កម្ពុជាក្នុងសតវត្សរ៍ទី៨គឺចាម្បដែលមជ្ឈមណ្ឌលអំណាចកណ្តាលចាម្បផ្លាស់ពីជើង ទៅត្បូងនៅបាណ្ឌុរង្គ រវាងឆ្នាំ៧៥០ ដល់ឆ្នាំ៨៧០។ មជ្ឈមណ្ឌល កណ្តាលថ្មីរបស់ចាម្បបានខិតជិតមជ្ឈមណ្ឌលកណ្តាលកម្ពុជាពីមុន ពិសេសតំបន់ដែលគេប្រទះឃើញសិលាចារឹកដំបូងរបស់ព្រះបាទជយវម៌្មទី២គឺ K.១៣៤[88]។

**៥-អរិយធម៌**

គេឃើញមានកាសមាស គឺជាកាក់ (ធ្វើអំពីមាស) ដែលមានចារព្រះនាមព្រះបាទស្រីឥសានវម៌្ម[89] ដែលជាមហាក្សត្រដ៏ខ្លាំងពូកែនាសម័យចេនឡា (សតវត្សរ៍ទី៧)។ ព្រះបាទឥសានវម៌្ម សោយរាជ្យពីឆ្នាំ៦១៦ ដល់ឆ្នាំ៦៣៧ នៅរាជធានីឈ្មោះឥសានបុរ(សំបូរព្រៃគុក ខេត្តកំពង់ធំ)។ ព្រះអង្គគឺជាបុត្ររបស់ព្រះបាទមហេន្ទ្រវម៌្ម ដែលក្សត្រដ៏ខ្លាំងពូកែ បានវាយឈ្នះសត្រូវគ្រប់ទិសទី ដើម្បីបង្រួបបង្រួមទឹកដីឱ្យស្ថិតនៅក្រោមអំណាចនៃអាណាចក្រចេនឡាតែមួយ។ យោងតាមការសិក្សាផ្នែកស្ថាបត្យកម្ម និងសិល្បៈ ប្រាសាទនៅតំបន់សំបូរព្រៃគុកដែលចាស់ជាងគេគឺស្ថិតនៅក្នុងក្រុមខាងជើង (ក្រុមប្រាសាទសំបូរ) ដែលប្រហែលកសាងឡើងនៅចុងសតវត្សរ៍ទី៦និងដើមសតវត្សរ៍ទី៧។ ចំពោះការគោរពចំពោះសាសនាគឺ ព្រហ្មញ្ញសាសាសនា និងព្រះពុទ្ធសាសនា។ យោងតាមឯកសារចិនក្នុងរាជវង្សស៊ុ (Sui Dynasty) ដែល សរសេរឡើងនៅឆ្នាំ៦៣៦ បានរៀបរាប់ថាព្រះបាទឥសានវម៌្ម បានកសាងប្រាសាទសំខាន់ជាច្រើននៅក្នុងរាជធានីរបស់ព្រះអង្គ ដែលមានប្រជាជន២ម៉ឺនគ្រួសារ។ នៅកណ្តាលក្រុងមានសាលធំមួយជាទីដែលព្រះរាជាទ្រង់មានប្រទានសវនាការ និងប្រជុំពួកមន្ត្រីសេនាបតី។ ក្រៅពីរាជធានី នៅមានក្រុងចំនួន៣០ទៀត ដែលក្រុងនីមួយៗមានច្រើនពាន់គ្រួសារ

---

86 សូមមើល: វង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ៣៥។

87 តាមការសម្ភាសរវាងនិស្សិតទី សុផល និងលោកគ្រូ ប៊ុន ធឿន ក្នុងឆ្នាំ២០១១ នៅសាកលវិទ្យាល័យខេមរៈ សាខាភ្នំពេញ។

88 វង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ៣៨។

89 នាមព្រះរាជាសរសេរថា« ឥសានវម៌្ម» មិនមែន «ឦសានវម៌្ម» ដែល ដូចនឹង ឦសាន ទិសនោះទេ។

ហើយត្រួតត្រាដោយអភិបាលម្នាក់[90]។ ការគ្រប់គ្រងបែបមណ្ឌលអំណាចអាស៊ីអាគ្នេយ៍នាគ្រានោះ គឺចេនឡាមានអំណាចលើក្សត្របុរីជាច្រើនក្នុងតំបន់ផងដែរ។

បើយោងតាមលោកបណ្ឌិត វង់ សុធារ៉ា លោកសន្និដ្ឋានថា ប្រទេសកម្ពុជាសម័យមុនអង្គរ ប្រហែលជាមានឈ្មោះថា «សុវណ្ណភូមិ» ព្រោះសិលាចារឹកមួយរបស់លោកព្រៅឯត្តនៅម្តុំភ្នំស្រង់ខេត្តកំពង់ស្ពឺនៅដើមខែចេត្រ ឆ្នាំ៦៣៣ ក្នុងរាជ្យព្រះបាទឥសានវម៌្មទី១ អះអាងថា ព្រះអង្គជាស្ដេចអធិរាជមួយអង្គគត់ដែលគ្រប់គ្រងលើដែនសុវណ្ណភូមិទាំងមូលទៅទល់នឹងសមុទ្ទ។ សម្រាប់ការបកប្រែសិលាចារឹកនោះ ដោយមានន័យសង្ខេបថា «ព្រះមហាក្សត្រដ៏ខ្ពង់ខ្ពស់ជាញជ័យ ព្រះនាមស្រីឥសានវម៌្ម(ទី១) ដ៏មានសិរី ដ៏អង់អាច ក្លៀវក្លា ដ៏ជាស្ដេចកំពូលមួយអង្គនៃស្ដេចទាំងឡាយលើផ្ទៃសុវណ្ណភូមិរហូត ដល់សមុទ្ទជាព្រំដែន មានស្ដេចសាមន្តរដ្ឋជាច្រើនទទួលយករាជបញ្ជារបស់ព្រះអង្គដាក់លើព្រះសិរសា»។

**៦-សំណួរត្រិះរិះ**

១-ចូររៀបរាប់ពីទីតាំងភូមិសាស្ត្រអាណាចក្រចេនឡា។

២-តើភស្តុតាងអ្វីខ្លះដែលបញ្ជាក់ពីការរីកចម្រើននៃវប្បធម៌សិល្បៈសម័យចេនឡា?

៣-តើការគ្រប់គ្រងរដ្ឋសម័យចេនឡាមានទម្រង់បែបណា? និងមានចំណុចខ្លាំង និងខ្សោយអ្វីខ្លះ?

៤-ចូរបង្ហាញពីការវិវត្តផ្នត់គំនិតនៃជំនឿរបស់អ្នកស្រុកចេនឡា។

---

[90] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ,* ភាគ១, ជ.ឯ.ម., ទំព័រ១២៧។

# មេរៀនទី៦ ប្រទេសកម្ពុជាសម័យអង្គរ( ពីឆ្នាំ៨០២ ដល់១៤៣១ )

សម័យអង្គរ ត្រូវបានអ្នកស្រាវជ្រាវភាគច្រើន បានកំណត់ថាចាប់ផ្ដើមនៅឆ្នាំ៨០២។ ពាក្យ«អង្គរ» ជាពាក្យក្លាយពីពាក្យសំស្ក្រឹត«នគរ» ដែលមានន័យថា «ក្រុង, រាជធានី»[91]។ អង្គរ គឺជាពាក្យដែលគេសំដៅហៅឈ្មោះអតីតរាជធានីខ្មែរដែលចាប់កសាងដំបូងដោយព្រះបាទយសោវរ្ម័នទី១ នៅឆ្នាំ៨៨៩ ដល់៩០០។ ឆ្លងតាមរយៈការស្រាវជ្រាវខ្ញុំ( ទី សុផល ) សន្និដ្ឋានថារាជធានីនៃចក្រភពអង្គរមិនមែនជារាជធានីដែលគេបោះបង់ចោលនៅសតវត្សរ៍ទី១៥ឡើយ។ ដោយសារតែភស្តុតាងបញ្ជាក់ថានៅប្រទេសកម្ពុជា នាសតវត្សរ៍ទី១៦ គឺមានក្រុងធំៗ ដូចជាក្រុងអង្គរ, ក្រុងចតុមុខ និងក្រុងស្រីសន្ធរ ដែលមានន័យថា«ភូមិធំ»។ គេហៅថាក្រុងដ៏អស្ចារ្យផងដែរ ដែលមានមនុស្សប្រមាណប្រាំម៉ឺននាក់រស់នៅ, មានរាជវាំង, ក្រុមប្រឹក្សារជាតិ, សវនាការ និងអធិការបតីស្ថាន ដែលគ្រប់គ្រងប្រទេស[92]។

## ១-ព្រះបាទជយវម្ម័នទី២[93]( ៨០២-៨៣៤ )និងការចាប់ផ្ដើមសម័យអង្គរ

ព្រះបាទជយវរ្ម័នទី២ ជាញាតិវង្សរបស់ព្រះបាទបុស្ករាក្សនៃរាជវង្សសម្ភុបុរ និងបានឡើងគ្រងរាជ្យ នៅសម្ភុបុរតាំងពីឆ្នាំ៧៨១។ ព្រះអង្គបានបង្រួបបង្រួមអាណាចក្រដោយតាំងរាជធានីច្រើនកន្លែងមានឥន្ទ្របុរ, ហរិហរាល័យ, អមរេន្ទ្របុរ និងមហេន្ទ្របុរ។ នៅឆ្នាំ៨០២ ព្រះអង្គបានប្រារព្ធពិធីតាំងទេវរាជនៅមហេន្ទ្របុរលើភ្នំគូលែន និងប្រកាសខ្លួនជាស្ដេចចក្រពត្តិ។ ព្រះអង្គបានកសាងប្រាសាទជាច្រើន។ តាមសិលាចារឹកស្ដុកកក់ធំរៀបរាប់ថាសូមកុំបីឱ្យប្រទេសកម្ពុជាស្ថិតក្រោមជ្វា[94] ដែលបង្ហាញថាជាពិធីមួយដែលធ្វើឡើងដើម្បីកុំឱ្យជ្វាជណ្ដើមកាន់កាប់កម្ពុជាបាន។

តាមការស្រាវជ្រាវរបស់លោក វិកឃើរីថា ព្រះអង្គជារាជានៅក្នុងស្រុកប្រហែលជានៅវ្យាធបុរ។ ព្រះអង្គចាប់ផ្ដើមធ្វើសកម្មភាពនយោបាយតាំងពីឆ្នាំ៧៧០។ នៅឆ្នាំ៧៨១ ព្រះអង្គជាអ្នកបង្រួបបង្រួមវ្យាធបុរ និងសម្ភុបុរ។ លោក សឺដេស គិតថាអ្នកបង្កសង្គ្រាមពេលនោះជាជវា( ជ្វា )តែពេលនោះលោក វិកឃើរី បានបដិសេធរឿងនេះដោយស្របគ្នាជាមួយនឹងប្រវត្តិវិទូប្រទេសឥណ្ឌូណេស៊ី ដែរ។ លោកគិតថាអ្នកធ្វើសង្គ្រាមពេលនោះជាចាម្ប (មជ្ឈមណ្ឌលចាម្បបានផ្លាស់ពីជើងទៅត្បូងនៅបាណ្ឌុរង្គ ឬ ជិតកម្ពុជាភាគខាងត្បូងរវាងឆ្នាំ៧៥០-៨៥០។ ដោយនៅសតវត្សរ៍ទី១១ គេហៅពួកចាម្បថា*ជវា ឬ យវទ្វីប* ហេតុនេះទើបឱ្យប្រវត្តិវិទូច្រឡំទីតាំង។ ព្រះអង្គធ្វើសម្មភាពដើម្បីបង្រួបបង្រួមជាតិ ហើយព្រះអង្គតាំងមណ្ឌលសំខាន់នៅហរិហរាល័យ (រលួស) គ្រប់គ្រងក្រុង៤គឺឥន្ទ្របុរ ប្រហែលបន្ទាយព្រៃនគរ ខាងកើតកំពង់ចាម, អមរេន្ទ្របុរ (បាត់ដំបង),ហរិហរាល័យនៅស្រុករលួសប្រមាណ១៥គីឡូម៉ែត្រ ពីក្រុងសៀមរាប[95] និងមហេន្ទ្របវ៌ត( ភ្នំមហេន្ទ្រ )ត្រូវនឹងភ្នំគូលែន។ ព្រះបាទជយវរ្ម័នទី២ផ្លាស់ប្ដូររាជធានីគ្រប់កន្លែងដើម្បីបង្ក្រាបអ្នកបះបោរ ហើយនៅភ្នំគូលែនមានឧបសគ្គច្រើនទើបទ្រង់ត្រឡប់ទៅរកកន្លែងដែលមានវាលស្រែស្រាប់។ រាជកិច្ចរបស់ទ្រង់គឺឡើងសោយរាជ្យនៅរាជធានីមួយ

[91]ជួន ណាត, *វចនានុក្រមខ្មែរ(ភាគ១ និង២)*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ឆ្នាំ១៩៦៧, ទំព័រ១៥៧៣។

[92] សូមមើល: San Antonio, Gabriel de, *Breue y verdadera relacion de los succesos del Reyno de Camboxa* , ( 1604 ), p. S II. និង Face Book: Dūc Ṃ Pūrā ចុះផ្សាយថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។

[93] សូរអាន: « ជ័យ យៈ-ឬ ដៃយាក់ វ រម្មាក់»។

[94] សូមមើលសិលាចារឹកស្ដុកកក់ធំ។

[95] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ*, ភាគ១, ដ.ឯ.ម., ទំព័រ១៣៤។

ឈ្មោះឥន្ទ្របុរ ដែលគេសន្និដ្ឋានថាប្រហែលជានៅ ក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ សព្វថ្ងៃដែលជាទឹកដីកម្មសិទ្ធិរបស់ព្រាហ្មណ៍សិវកៃវល្យ[96]។

តំបន់អង្គរ ជាពិសេសត្រើយខាងជើងបឹងទន្លេសាប ជាតំបន់មួយប្រកបដោយគុណភាពល្អសម្រាប់កសិកម្មអតិផល។ ទំហំដីល្បាប់ដ៏ធំធេង ព្រមទាំងធនធានត្រីពីទន្លេសាបក៏មិនខ្វះ ឯស្ទឹងទាំងប៉ុន្មាន ក៏សុទ្ធតែបរិបូរណ៍ដោយទឹកមិនចេះដាច់ ប្រភពពីភ្នំគូលែនដែលលាតសន្ធឹងទៅខាងកើត តាំងជាប្រភពទឹកមួយ ជាប្រចាំ[97]។ ទីស្ថានដ៏ពិសិដ្ឋនេះ ជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ក្នុងការរៀបចំរាជធានី ដែលបង្ហាញពីជ័យភូមិ និងការរៀបចំចក្ខុវិស័យយ៉ាងច្បាស់លាស់របស់ព្រះបាទជយវម៌្មទី២។ ព្រះបាទជយវម៌្មទី២ ទ្រង់សោយទិវង្គត ព្រះអង្គមានមរណនាមថាបរមេស្វរៈ ដែលមានន័យថា ព្រះអង្គយាងទៅគង់នៅក្នុងស្ថានរបស់ព្រះឥសូរ ក្នុងឋានៈជាអាទិទេព។ ប្រវត្តិវិទូបានចាត់ទុកព្រះអង្គជាក្សត្រស្ថាបនិកសម័យអង្គរ។

## ២-ព្រះរាជាល្បីៗ និងសមិទ្ធិផល

### ២.១- ព្រះបាទយសោវម៌្មទី១(ឆ្នាំ៨៨៩-៩០០) និងក្រុងអង្គរទី១

ព្រះបាទយសោវម៌្មទី១ ពីឆ្នាំ៨៨៩ ដល់៩១០ ជាបុត្ររបស់ព្រះបាទឥន្ទ្រវម៌្មទី១។ ព្រះអង្គបានកសាងរាជធានីយសោធរបុរ ដែលមានប្រាសាទភ្នំបាខែងជាស្នូលរាជធានី។ ក្រៅពីនេះព្រះអង្គបានកសាងអាស្រមចំនួន១០០(យសោធរាស្រម) ជីកបារាយណ៍យសោធរតដាក, កសាងប្រាសាទលលៃនៅចំកណ្ដាលបារាយណ៍យសោធរតដាក ដើម្បីឧទ្ទិសដល់បុព្វការី ហើយទ្រង់បានកសាងប្រាសាទជាច្រើនដូចជា ព្រះវិហារ, ប្រាសាទភ្នំក្រោម, ប្រាសាទភ្នំបូក និងប្រាសាទភ្នំដីជាដើម។ ទ្រង់បានពង្រីកវិសាលភាពទឹកដី, រៀបចំរដ្ឋបាល និងវណ្ណៈសង្គម។ ទ្រង់ចូលចិត្តសិល្បៈ និងឱ្យតម្លៃអ្នកចេះដឹង ដោយប្រមូលអ្នកប្រាជ្ញបណ្ឌិតនៅជុំវិញព្រះអង្គ ហើយព្រះអង្គមានមរណនាមថា បរមសិវលោក។

### ២.២-ព្រះបាទជយវម៌្មទី៤(៩២៨-៩៤២)និងរាជធានីកោះកេរ[98]

ព្រះអង្គជាប្អូនថ្លៃរបស់ព្រះបាទយសោវម៌្មទី១។ ព្រះអង្គកសាងរាជធានីកោះកេរ(ឆោកគរគ្យរ)[99]។ ក្រៅពីការកសាងរាជធានី ព្រះអង្គបានកសាងប្រាសាទជាច្រើនដែលប្រកបដោយក្បាច់រចនាខុសប្លែកពីរចនាបថនៃស្ថាបត្យកម្មមុនៗ ជាពិសេសប្រាសាទធំ ឬប្រាសាទប្រាង្គ៧ជាន់ និងប្រាសាទជាច្រើន។ ព្រះអង្គ ជីកបារាយណ៍ហោលសម្រាប់តម្កល់ទឹក និងកសាងសិវលិង្គស្វយម្ភូ[100](ពីធម្មជាតិ) នៅស្រុកសាមគ្គីមានជ័យខេត្តកំពង់ឆ្នាំង។ នៅឆ្នាំ៩៤១ បុត្រារបស់ព្រះអង្គព្រះនាម ហ៌សវម៌្មទី២ បានឡើងសោយរាជ្យបាន២ ឬ ៣វស្សាក៏សោយទិវង្គត។

---

[96] សូមមើល: វង់ សុធារ៉ា និង ណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ(សម្រាប់ថ្នាំមូលដ្ឋាន)*, ដ.ឯ.ម., ទំព័រ៤៣។

[97] ប៉ែលាហ្វីលីប ហ្គ្រោលីយេ, *ទីក្រុងទឹកអង្គរ ជំហរអារ្យធម៌ខ្មែរ*, ប្រែសម្រួលដោយ នុត ណារ៉ាង, មជ្ឈមណ្ឌលស្រាវជ្រាវអារ្យធម៌ខ្មែរ, ឆ្នាំ២០០៣។, ទំព័រ១០៥។

[98] រមណីយដ្ឋានប្រាសាទកោះកេរ ត្រូវបានដាក់បញ្ចូលក្នុងបេតិកភណ្ឌវប្បធម៌ពិភពលោក នាថ្ងៃ១៧ កញ្ញា ២០២៣។

[99] សូរអាន: ឆោកគរគីរ។

[100] សូមអានសិលាចារឹក K.441.

## ២.៣-ព្រះបាទឧទយាទិត្យវម៌្ម[101]ទី២(១០៥០-១០៦៦) និងក្រុងអង្គរទី២

ព្រះបាទសូរ្យវម៌្មទី១ (ឆ្នាំ១០១០-១០៥០) ជាប់ញាតិវង្សជាមួយព្រះបាទឥន្ទ្រវម៌្មទី១ និងយសោវម៌្មទី១ បានបញ្ជាឱ្យព្រាហ្មណ៍យោគីស្វរបណ្ឌិត ជាកូនប្រសារកសាងបង្ហើយប្រាសាទតាកែវ ដែលជាស្នូលនៃរាជធានីជយេន្ទ្រនគរី របស់ព្រះបាទជយវម៌្មទី៥។ ប៉ុន្តែក្រោយពីរៀបចំលើកបន្ទុបថ្មរួចរាល់ ប្រាសាទនេះត្រូវរន្ទះបាញ់ ទើបព្រះអង្គមិនបានរចនាបង្ហើយដូចប្រាសាទដទៃទៀត ហើយរាជបុត្ររបស់ទ្រង់ព្រះនាម ឧទយាទិត្យវម៌្មទី២ ទ្រង់បានស្នងរាជ្យបន្ត[102]។ ព្រះរាជាអង្គនេះ ជាស្តេចស្ថាបនិកក្រុងអង្គរទី២ដោយបានកសាងប្រាសាទបាពួនជាផ្ចិត បន្តកសាងកំពែងព័ទ្ធជុំវិញរាជធានីពីបិតា ជីកពង្រីកបារាយណ៍ទឹកថ្លា, កសាងប្រាសាទមេបុណ្យខាងលិច នៅចំកណ្តាលបារាយណ៍ខាងលិច ដែលមានរូបព្រះវិស្ណុផ្ទុំនៅកណ្តាលស្រះនៃប្រាសាទ, ប្រាសាទភ្នំជីសូរ, តាក្របី, ប្រាសាទតាមាន់តូច និងតាមាន់ធំ ជាដើម។ ព្រះអង្គបានបង្ក្រាបចលនាបះបោរចំនួនបីលើកគឺលើកទី១នៅឆ្នាំ១០៥១, លើកទី២ នៅឆ្នាំ១០៦៥ និងលើកទី៣ (មិនដឹងកាលបរិច្ឆេទ)ដែលដឹកនាំដោយបងប្អូន២នាក់គឺស្លូត និងសិទ្ធិការ។ ព្រះអង្គសោយទិវង្គតនៅឆ្នាំ១០៦៦ ប៉ុន្តែគេពុំស្គាល់មរណនាមរបស់ព្រះអង្គទេ។ បុត្ររបស់ព្រះអង្គព្រះនាមហស៌វម៌្មទី៣បានឡើង សោយរាជ្យបន្តរហូតដល់ឆ្នាំ១០៨០។ បន្ទាប់មកព្រះបាទន្ទ្របតិន្ទ្រវម៌្ម[103] បានឡើងសោយរាជ្យនៅអង្គររហូតដល់ឆ្នាំ១១១៣ គឺពីឆ្នាំ១០៨៥ ដល់១១១៣[104]។

## ២.៤-ព្រះបាទសូរ្យវម៌្មទី២(១១១៣-១១៥០)និងក្រុងអង្គរទី៣

ព្រះបាទសូរ្យវម៌្មទី២ ជាចៅមីងរបស់ព្រះបាទធរណីន្ទ្រវម៌្មទី១ និងជយវម៌្មទី៦ ព្រះអង្គបាន បង្រួបបង្រួមអាណាចក្រខាងជើង និងចក្រភពអង្គរ កសាងរាជធានីយសោធរបុរទី៣ ដោយយកប្រាសាទអង្គរវត្តជាផ្ចិត។ ប្រាសាទនេះត្រូវបានប្រជាជនខ្មែរចាត់ទុកជាតំណាងនៃអត្តសញ្ញាណជាតិខ្មែរដ៏សំខាន់បំផុត គ្រប់ជំនាន់រៀងមក។ ព្រះអង្គបានពង្រីកទឹកដីទៅលើនគរជិតខាងមានមន និងដាយវៀត ព្រមទាំងវាយយកនគរចម្ប៉ាដាក់ជានគរចំណុះពីឆ្នាំ១១៤៥ដល់១១៤៩។ ព្រះអង្គបានបន្តកសាងប្រាសាទភ្នំជីសូរ,ភ្នំសណ្តក, វត្តភូ, ព្រះវិហារ ព្រះពិធូរ, ចៅសាយទេវតា, ធម្មានន្ទ, បន្ទាយសំរ៉ែ, បឹងមាលា និងព្រះខ័នកំពង់ស្វាយជាដើម។ នៅឆ្នាំ១១៥០ ព្រះអង្គបានសោយទិវង្គតដោយមានមរណនាមថា ព្រះបរមវិស្ណុលោក។

## ២.៥- អធិរាជជយវម៌្មទី៧(១១៨១-១២១៨) និង ក្រុងអង្គរទី៤

អធិរាជ[105]ជយវម៌្មទី៧ មាននាមដើមជយវធ៌នជាបុត្ររបស់ព្រះបាទធរណិន្ទ្រវម៌្មទី២ និងម្ចាស់ក្សត្រីយ៍ជយរាជចូឌាមណី។ ព្រះអង្គបានរំដោះរាជធានីអង្គរពីស្តេចចាម្បនៅឆ្នាំ១១៨១។ ព្រះអង្គបានកសាងរាជធានីដែលមានប្រាសាទបាយ័នជាផ្ចិតក្រុងអង្គរទី៤ និងបានកសាងប្រាសាទតាព្រហ្ម, បន្ទាយក្តី, ព្រះខ័ន, នាគព័ន្ធ, តាសោម, ក្រោលគោ, បន្ទាយឆ្មារ, វត្តនគរ, សាកលវិទ្យាល័យ, រោងព្យាបាលរោគចំនួន១០២[106], សាលាសំណាក់

[101] សូរអានៈ ឧ-ទៃ-យា-ទិត-ត្យាក់-វ-ភ្នក់។

[102] ក្រុងអង្គរទី២ ដែលមានប្រាសាទតាកែវ ជាផ្ចិតត្រូវបរាជ័យ ហើយក្រុងអង្គរទី៣ ដែលមានប្រាសាទបាពួន ជាផ្ចិតក្លាយជាក្រុងអង្គរទី២វិញ (សូមមើលៈ វង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ៤០ ដល់៤១)។

[103] ន-រិប-ប៉ាក់-តិន-ទ្រាក់-វ-ភ្នក់។

[104] វង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ២៩៩។

[105] ព្រះរាជាជាធំចម្បងជាងព្រះរាជាទាំងឡាយក្នុងប្រទេសជិតខាង។

[106] ស៊ក សឺដេស, *ជ័យវរ្ម័នទី៧*, ប្រែជាភាសាខ្មែរ ដោយជុំ ម៉ៅ, ភ្នំពេញ, ការផ្សាយរបស់ព្រះរាជបណ្ណាល័យ,ឆ្នាំ១៩៣៥, ទំព័រ២៨។

ចំនួន១២១[107], ស្ពាន, ផ្លូវថ្នល់, ជីកបារាយណ៍ជយតដាកជាដើម[108]។ ក្រៅពីការកសាងប្រាសាទ ព្រះអង្គបានគិតពីសេដ្ឋកិច្ចជាតិខ្លាំងណាស់ ដោយទ្រង់បានប្រើប្រាស់បារាយណ៍ដែលមានស្រាប់ពីរ គឺបារាយណ៍ខាងលិច និង បារាយណ៍ខាងកើតនៅក្នុងតំបន់អង្គរសម្រាប់វិស័យកសិកម្ម ដែលជាបច្ចេកទេសខ្ពស់ក្នុងវិស័យកសិកម្ម ដោយបង្ហូរទឹកនោះបញ្ចូលស្រែ ហើយស្រូវដែលទទួលបានគឺសម្រាប់ចិញ្ចឹម ប្រជាពលរដ្ឋ និងកងទ័ព។ ព្រះអង្គបានវាយយកចាម្បជាក់ជាចំណុះវិញនៅឆ្នាំ១១៩៤។ អធិរាជជយវម៌្មទី៧ មានមហេសីដ៏ឆ្លាតវៃ គឺព្រះនាងជយរាជទេវី និងព្រះនាងឥន្រ្ទទេវី ដែលជួយរាជកិច្ចព្រះអង្គជាច្រើន។ ពេលសោយទិវង្គតព្រះអង្គមានមរណនាមថា មហាបរមសៅគតបទ[109]។

## ៣-សង្គមខ្មែរសម័យអង្គ

នៅសម័យអង្គរខេត្តទាំងអស់មានចំនួន៩០ ដែលខេត្តនីមួយៗសុទ្ធតែមានមន្រ្តីធំនៅកាន់កាប់ ហើយមានឈ្មោះបន្ទាយឈើជារបាំងផង។ ចំណែកនៅក្នុងភូមិនីមួយៗជួនកាលមានវត្ត និងជួនកាលមានប្រាសាទ ហើយមន្រ្តីម្នាក់នៅត្រួតត្រាយ៉ាងហ្មត់ចត់។ មន្រ្តីនោះគេហៅថាបួយស៊ី។ នៅតាមផ្លូវធំ តែងតាំមានសាលាមួយសម្រាប់ឈប់សម្រាកគេ ស៊ិមប៉ាក់។ ប៉ុន្តែ នៅពេលកើតចម្បាំងជាមួយសៀមភូមិទាំងនេះក៏ប្រែក្លាយជាជីវាល។ ប្រជារាស្រ្តទូទៅប្រកបរបរកសិកម្មជាធំ ចេះធ្វើស្រែចម្ការ យ៉ាងប៉ិនប្រសប់ទាញភោគផលបានច្រើនដោយសារនយោបាយទឹក។ ក្រៅពីកសិកម្មនៅអង្គរក៏មានការរីកចម្រើនផ្នែកពាណិជ្ជកម្មផងដែរ។ អ្នកស្រុកនេះពួកស្រីៗប៉ិនជួញដូរណាស់ ហេតុនេះពួកចិនៗគេត្រូវរកប្រពន្ធមួយជាមុនសិន ហើយនឹងចំណេញច្រើនដោយប៉ិនប្រសព្វរកស៊ី។ រាល់ថ្ងៃគេលក់តាំងភ្លឺព្រាងៗ ដល់ពេលថ្ងៃត្រង់ទើបឈប់ ហើយពួកគេគ្មានគ្រែ ឬ ផ្ទះសម្រាប់លក់ឥវ៉ាន់ទេ គេច្រើនតែក្រាលវត្ថុហាក់ដូចជាកន្ទេលផ្ទាល់ទៅនឹងដីតម្រៀបគ្នា។ សាសនាមានតួនាទីសំខាន់ណាស់ក្នុងនយោបាយប្រទេសជាតិ។ លោក ជីវតាក្វាន់បានរៀបរាប់ថាមនុស្សសម័យអង្គរគោរពចំពោះតែថ្មមួយដុំធំ ដូចថ្មរូបអ្នកតាលើបូជនីយស្ថាននៃព្រះវិហារចិន ឧទ្ទិសដល់ព្រះធរណី។ ក្នុងក្នុងព្រះពុទ្ធសាសនាវិញ គេតែងតែយកក្មេងៗ កូនចៅអ្នកស្រុកដែកត្រូវការរៀនសូត្រ ទៅទុកដាក់រៀនជាមួយព្រះសង្ឃ ហើយបួសជាសង្ឃខ្លួនឯង រហូតដល់មានអាយុច្រើន ទើបចាកសិក្ខាបទ ត្រឡប់ជាពលរដ្ឋធម្មតាវិញ ។

នៅសតវត្សរ៍ទី១២ គណៈវិស្ណុត្រូវបានព្រះបាទសូរ្យវម៌្មទី២គោរពយ៉ាងខ្លាំង។ អ្នកស្រាវជ្រាវបានធ្វើការប៉ាន់ប្រមាណពីទំហំកម្លាំងពលកម្ម គំនិតច្នៃប្រតិដ្ឋ និងធនធានសេដ្ឋកិច្ចរបស់ដូនតាខ្មែរ សម្រាប់ប្រើនៅក្នុងការងារកសាង ទើបស្មានថាសំណង់ទាំងនោះត្រូវការកម្លាំងមនុស្សរាប់សែនលាននាក់ រួមទាំងជាងចម្លាក់, មេការ, វិស្វករ និងស្ថាបត្យករ រាប់ពាន់រាប់ម៉ឺននាក់ និងត្រូវការអង្ករ, ត្រី និងសាច់រាប់តោនប្រចាំថ្ងៃសម្រាប់ហូបចុកប្រចាំថ្ងៃជាដើម។

ផ្លូវគមនាគមន៍ មានតួនាទីសំខាន់មួយសម្រាប់បម្រើវិស័យពាណិជ្ជកម្ម ដែលកាត់តាមចំណុចប្រសព្វនៅរាជធានីអង្គរ។ ក្រៅពីផ្លូវពីអង្គរទៅក្រុងវិជ័យរបស់ចាម្ប លោក អ៊ីស៊ីហ្សាវ៉ា បានបង្ហាញពីផ្លូវថ្នល់ពីអង្គរទៅភិម៉ៃនៅភាគឦសានប្រទេសថៃ និងបន្តទៅសុខោទ័យ នៅឯនាយខាងជើងប្រទេសថៃសព្វថ្ងៃ110។ ចំណែកក្រុងប៉េ

---

[107] ក្រសួងអប់រំជាតិ, *ខេមរយានកម្ម(ប្រវត្តិវិទ្យាថ្នាក់ទី៥)*, ភ្នំពេញ, ឆ្នាំ១៩៧២, ទំព័រ១០៧។

[108] បារាយណ៍ជយតដាក ត្រូវបានកសាងដោយអធិរាជជយវម៌្មទី៧ ស្ថិតនៅប្រាសាទនាគព័ន្ធសព្វថ្ងៃ។

[109] វង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្រ្តខ្មែរ*, ដ.ឯ.ម., ទំព័រ៣០០។

[110] សូមមើល: Yoshiaki Ishizawa, *Challenging the Mystery of the Angkor Empire-realizing the mission of Sophia University in the Asian World*, Tokyo Sohia University Press, 2012.

ហ្វូនៃប្រទេសមន ចាប់ពីចុងសតវត្សរ៍ទី១៣ មានការរីកចម្រើនដោយសារតែសកម្មភាពពាណិជ្ជកម្មផ្លូវសមុទ្រជាមួយឥណ្ឌា និងពួក អារ៉ាប់ដែលមករកស៊ីជាមួយពួកអាស៊ីអាគ្នេយ៍។ ចំពោះអាណាចក្រស្រីវិជ័យ និងម៉ាឡាយូដែលល្បីល្បាញខាងពាណិជ្ជកម្មជាមួយចិន ឥណ្ឌា និងអារ៉ាប់នៅកោះស៊ូម៉ាត្រា កោះជ្វា និងជ្រោយម៉ាឡេស៊្យាត្រូវបានកាន់កាប់ដោយចោរសមុទ្រចាប់ពីចុងសតវត្សរ៍ទី១១ និងកាន់តែមានអសន្តិសុខសម្រាប់ឈ្មួញនៅសតវត្សរ៍ទី១២ រហូតដល់ភាគទី១នៃសតវត្សរ៍ទី១៤។ ដូច្នេះ ឈ្មួញភាគច្រើនមកពីភាគខាងលិច បាននាំគ្នារកស៊ីជាមួយចិន តាមរយៈមន សុខោទ័យ អង្គរ និងវិជ័យរបស់ចាម្ប។ ដោយសារជំនួញផ្លូវគោកកាត់តាមអង្គរបែបនោះទើបធ្វើឱ្យកម្ពុជាយកប្រយោជន៍សេដ្ឋកិច្ចច្រើន និងអាចឱ្យព្រះរាជាមានទ្រព្យ ស្តុកស្តម្ភ អាចកសាងសំណង់ទាំងអស់នោះបាន។ សិល្បៈខ្មែរ មានការវិវត្តឥតឈប់ឈរពីសម័យមួយទៅសម័យមួយទៀត។ ការវិវត្តនេះ បានបង្ហាញឱ្យឃើញថា បុព្វបុរសខ្មែរមានទេព្យកោសល្យខាងការច្នៃ រចនា ផ្សំផ្សំសិល្បៈបរទេស ជាមួយនឹងសិល្បៈរបស់ខ្លួនកើតបានជាសិល្បៈមួយ មានរូបរាង និងលក្ខណៈពិសេសជាខ្មែរសុទ្ធ ហើយសឱ្យឃើញម្យ៉ាងទៀតថា បុព្វបុរសខ្មែរមានទេព្យកោសល្យខាងការបង្កើតថ្មី (génie de création)[111]។

## ៤-ស្ថាប័នដឹកនាំសម័យអង្គរ[112]

នៅក្នុងស្ថាប័ននយោបាយសម័យអង្គរ អធិរាជគឺជាអ្នកគ្រប់គ្រងកំពូល ហើយនៅក្រោមអធិរាជមានខេត្តក្នុង, រាជធានី, ស្តេចត្រាញ់ និងទេពព្រះប្រាសាទ។ ចំណែកចៅហ្វាយខេត្តគឺស្ថិតផ្ទាល់ខាងក្រោមស្តេចត្រាញ់ និងទេពព្រះប្រាសាទ។

### ៤.១-ព្រះមហាក្សត្រ និងរាជរដ្ឋាភិបាល

ព្រះរាជាជាម្ចាស់ផែនដី និងជាបង្គោលនៃការគ្រប់គ្រងប្រទេសជាតិ ទាំងផ្នែកនយោបាយ ទាំងខាងផ្នែកតុលាការ។ ព្រះមហាក្សត្រ ជាអ្នកកាន់អំណាចតុលាការរកយុត្តិធម៌ឱ្យប្រជាជន[113]។ ទ្រង់គឺជាស្តេចនៃស្តេចទាំងឡាយ[114] ដោយសារទ្រង់រក្សាទុកឋានៈជាស្តេចរបស់ម្ចាស់ទឹកដីធំៗ ដែលនៅចំណុះព្រះអង្គ។

ចំណែកនៅក្នុងការគ្រប់គ្រងប្រទេស ព្រះអង្គមាននាម៉ឺនសព្វមុខមន្ត្រីមួយមុខបួននាក់ៗ ជាយន្តការលើកិច្ចការរដ្ឋទាំងមូល។ ស្តេចត្រាញ់ដែនដីនីមួយៗ នៅក្រោមចំណុះរបស់អធិរាជមានភារៈនាំសួយសារអាករថ្វាយអធិរាជជាប្រចាំ និងមានភារៈផ្តល់កម្លាំងពលកម្ម កំណែនតាមតម្រូវការរបស់អធិរាជ។ ប៉ុន្តែ ស្តេចត្រាញ់មានសិទ្ធិធ្វើអ្វីគ្រប់យ៉ាងលើដែនដីរបស់ខ្លួន និងមានរចនាសម្ព័ន្ធរដ្ឋបាលដូចគ្នា និងអធិរាជដែរ លើកលែងតែបញ្ហាប្រទានដីធ្លីធំៗ និងការកសាងសំណង់ធំៗ ទើបត្រូវទូលអធិរាជសុំព្រះរាជានុគ្រោះ ឬ រាជានុញ្ញាត។ នយោបាយបែបនេះហើយ ដែលនាំឱ្យមានកើតចលាចលក្នុងប្រទេសជាញឹកញាប់នៅពេលអធិរាជចូលទិវង្គត ដោយសារស្តេចត្រាញ់នីមួយៗ ដែលសុទ្ធសឹងជាសាច់ញាតិរបស់អធិរាជ ឬ ជាអ្នកដែលមានអំណាចខាងយោធានាំគ្នាធ្វើការប្រជែងដណ្តើមអំណាចកណ្តាលធ្វើជាអធិរាជរៀងៗខ្លួន។

- ស្ថាប័នព្រាហ្មណ៍បុរោហិតឬអាចារ្យប្រធានដែលមានគ្នាបួនរូប និងទីប្រឹក្សា
- ស្ថាប័នតុលាការ (ព្រះសភា) មានសមាជិកបួនរូប
- ស្ថាប័នសន្តិសុខ មានសមាជិកបួនរូប

---

[111] ក្រសួងអប់រំជាតិ, *ខេមរយានកម្ម(ប្រវត្តិវិទ្យាថ្នាក់ទី៥)*, ដ.ឯ.ម., ទំព័រ១៤២។

[112] ទី សុផល, ប្រវត្តិវិទ្យា, ដ.ឯ.ម., ទំព័រ៩០-៩៥។

[113] ក្រសួងអប់រំជាតិ, *ខេមរយានកម្ម(ប្រវត្តិវិទ្យាថ្នាក់ទី៥)*, ដ.ឯ.ម., ទំព័រ១០៩។

[114] រាជាធិរាជ។

– ស្ថាប័នព្រះឃ្លាំង មានសមាជិកបួនរូប

– ស្ថាប័នមន្ត្រីវាំង

ព្រះរាជាសម័យអង្គរមិនប្រព្រឹត្តអំពើអយុត្តិធម៌ដោយសារតែមនោសញ្ចេតនា និងប្រយោជន៍ឡើយ...។ ជាក់ស្តែងអធិរាជជ័យវរ្ម័ទី៧ ដែលកាន់ព្រះពុទ្ធសាសនាទ្រង់បានលើកតម្កើងច្បាប់ជានិច្ច។ ព្រះមហាក្សត្រជាអ្នកកាន់កាប់អំណាចតុលាការកំពូល ដែលផ្តន្ទាទោសដល់អ្នកប្រព្រឹត្តល្មើសទាំងឡាយដែលកាត់ក្តីនៅស្ថាននរក។ ការកាត់ក្តីរបស់យមរាជមានលក្ខណៈឃោរឃៅ។ ការកាត់ក្តីរបស់ព្រះមហាក្សត្រមានលក្ខណៈប្រកបដោយគុណធម៌ជាម្ចាស់ និងជាអ្នកការពារប្រជារាស្ត្រ គេប្រដូចព្រះមហាក្សត្រទៅនឹងប្រជាបតី។ ព្រះអង្គបានរៀបចំសណ្តាប់ធ្នាប់សង្គម តាមញាណយល់ដឹងគឺស្រុតិ និងច្បាប់ប្រពៃណី ហើយគេចាត់ទុកព្រះមហាក្សត្រជាអវតារបស់ហរិហរៈ។ ក្រៅពីឈ្មោះបញ្ចប់ដោយពាក្យ«ទេវៈ»ព្រះមហាក្សត្រភាគច្រើននៅសម័យអង្គរត្រូវឧទ្ទិសមរណនាមឱ្យ ដើម្បីបញ្ជាក់ពីស្ថានសួគ៌ ដែលព្រះអង្គត្រូវទៅសោយសុខបន្ទាប់ពីបញ្ចប់ភារកិច្ចនៅលើផែនដី។

លុះមកដល់ចុងសតវត្សរ៍ទី១២ ទស្សនៈទេវភាព ត្រូវជំនួសដោយទស្សនៈពុទ្ធសាសនាវិញ។ គេលើកតម្កើងអធិរាជជ័យវរ្ម័ទី៧ជាព្រះពុទ្ធសក្យមុនី ព្រះមាតារបស់ព្រះអង្គខាងប្រាជ្ញាបារមីតា ហើយព្រះបិតាជាពោធិសត្វលោកេស្វរៈ។

ព្រះមហាក្សត្រនាសម័យអង្គរ មានឋានៈខ្ពង់ខ្ពស់ដូច«ទេវៈ» នានាលើផែនដី។ ភាពឧដុង្គឧត្តមនេះទទួលឥទ្ធិពលពីសាសនាព្រាហ្មណ៍។ ដោយការប្រកាសខ្លួនជាតំណាងទេវលើផែនដី ព្រះមហាក្សត្រខ្មែរមានលក្ខណៈជាម្ចាស់លើប្រជារាស្ត្ររបស់ខ្លួន។ ទ្រង់បានបង្ហាញខ្លួនតាមបង្អួចប្រាសាទ ស្ថិតនៅពីលើស្រទាប់ខ្ពស់លើប្រជារាស្ត្រ ដែលបានក្រាបថ្វាយបង្គំក្រាបក្បាលដល់ដី ដោយមិនអនុញ្ញាតឱ្យងើបមើលព្រះភក្ត្រព្រះអង្គឡើយ។ សិលាចារឹកជាច្រើនបានបញ្ជាក់ថា ព្រះមហាក្សត្រជាព្រះបិតាប្រជារាស្ត្រហើយមានអំណាចជាគ្រូលើប្រជារាស្ត្រស្ថិតខ្ពស់ដាច់ចេញពីប្រជារាស្ត្រ។ អ្នកណាមិនគោរពព្រះអង្គដែលជាគ្រូលើលោកទាំងមូល អ្នកនោះនឹងគ្មានបានទទួលផលពីការធ្វើអំណោយ ការបូជា ឬ តង្វាយផ្សេងៗសោះឡើយ។ លុះមកដល់រជ្ជកាលរបស់អធិរាជជ័យវរ្ម័ទី៧ ដែលលើកតម្កើងទស្សនពុទ្ធនិយម ទើបមានការវិវត្តដ៏សំខាន់ដែលធ្វើឱ្យព្រះមហាក្សត្រខិតមកជិតប្រជារាស្ត្ររបស់ខ្លួន។ ទ្រង់បានបង្ហាញពីការយកចិត្តទុកដាក់ប្រតិបត្តិតាមការប្រៀនប្រដៅរបស់ព្រះពុទ្ធ ដោយអនុវត្តនយោបាយយកចិត្តទុកដាក់ចំពោះប្រជារាស្ត្រខ្មែរដែលគេពុំធ្លាប់ឃើញមាននៅក្នុងរជ្ជកាលមុនៗ។ អំណាចរបស់ទ្រង់ស្ថិតនៅលើការប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការគោរពធម៌ ឬ ច្បាប់ដែលនាំឱ្យមានការចូលរួមផ្តល់ថាមពលនៃអំណាចព្រះអង្គ ក្នុងការរៀបចំលើកស្ទួយការគ្រប់គ្រងកម្ពុជទេសឱ្យមានកិត្យានុភាពឡើងវិញ។

ព្រះមហាក្សត្រ មានមន្ត្រីជំនួយការរដ្ឋបាលយ៉ាងច្រើន ដែលគេអាចចែកចេញជាបួនប្រភេទគឺឯក, ទោ, ត្រី, ចត្វា។ ក្នុងការចាត់ចែងកិច្ចការរដ្ឋព្រះមហាក្សត្របានត្រាស់បង្គាប់ទៅកាន់មន្ត្រីទាំងបួនប្រភេទ ឱ្យអនុវត្តនូវសេចក្តីសម្រេចគ្រប់បែបយ៉ាងរបស់ព្រះមហាក្សត្រ។ នៅក្នុងការគ្រប់គ្រងរដ្ឋ ព្រះរាជា មហេសី ព្រះរជ្ជទាយាទ និងព្រះរាជវង្សានុវង្ស តែងបានទទួលនូវឋានៈសំខាន់នៅក្នុងរដ្ឋបាលមជ្ឈិម។

### ៤.២-ព្រះមហេសី

ព្រះមហាក្សត្រខ្មែរសម័យអង្គរ មានមហេសីដែលគេពុំអាចកំណត់បានចំនួនច្បាស់លាស់ទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ព្រះមហាក្សត្រត្រូវតែងតាំងព្រះរាជអគ្គមហេសីដែលជួនកាលមានតួនាទីសំខាន់ក្នុង

កិច្ចការប្រទេសជាតិ និងទទួលបានកិត្តិយសដោយមានពិធីអភិសេកផង ដូចសិលាចារឹកភិមានអាកាស បានបញ្ជាក់ថា អធិរាជជយវម៌្មទី៧ បានអភិសេកព្រះនាងជ័យរាជទេវីជាអគ្គមហេសី។ មន្ត្រីមួយចំនួន មានការទាក់ទងយ៉ាងជិតស្និតជាមួយព្រះមហាក្សត្រ ដោយលើកបុត្រីរបស់ខ្លួនឱ្យធ្វើជា មហេសី ទេពី ឬ ស្រីស្នំ។ បុត្រីនៃបុរោហិតអធិរាជជយវម៌្មទី៧ បានធ្វើជាមហេសីរបស់ព្រះបាទជយវម៌្មទី៨។ ដោយសារការអនុវត្តគោលការណ៍យុទ្ធសាស្ត្រអាពាហ៍ពិពាហ៍នយោបាយជាធម្មតាមហេសី ឬ អគ្គមហេសីរបស់ព្រះមហាក្សត្រភាគច្រើនជាកូនស្រី ឬ ប្អូនស្រីនៃស្តេចត្រាញ់ដែលគ្រប់គ្រងភូមិភាគសំខាន់ៗទាំងឡាយនៃចក្រភព។

## ៤.៣-ព្រះរាជវង្សានុវង្ស

បន្ទាប់ពីព្រះមហាក្សត្រ ព្រះរាជបុត្រា បុត្រីមានឋានៈខ្ពស់ជាងមន្ត្រីដទៃទៀត។ ព្រះរាជបុត្រអាចចូលទៅក្នុងប្រាសាទតាមទ្វារធំ។ ចំណែកពួកព្រាហ្មណ៍ បុរោហិត និងមេទ័ពត្រូវដោះគ្រឿងអលង្ការចេញមុនចូលក្នុងប្រាសាទ។ ព្រះរាជបុត្រតែងទទួលមុខងារដ៏ខ្ពង់ខ្ពស់របស់រដ្ឋ។ រាល់ការប្រជុំសំខាន់ៗ សុទ្ធសឹងមានសេចក្តីបញ្ជាក់ថា មានការចូលរួមពីរាជបុត្រ។ ក៏ប៉ុន្តែរាជបុត្រទាំងអស់ មិនប្រាកដថានឹងបានឡើងសោយរាជ្យស្នងបិតាខ្លួននោះទេ ដូចជា រាជបុត្ររបស់ព្រះបាទជយវម៌្មទី៣ និងជយវម៌្មទី៥ ជាដើម មិនបានស្នងរាជពីបិតាខ្លួនឡើយ។ ក្នុងរជ្ជកាលអធិរាជជយវម៌្មទី៧ ព្រះរាជបុត្រមួយអង្គបានទទួលមុខងារជាអភិបាលក្រុង«ល្វោ»។ នៅក្នុងសិលាចារឹកបន្ទាយឆ្មារបានរំឭកពីការបំពេញតួនាទីយោធារបស់រាជបុត្រមួយអង្គឈ្មោះស្រីន្ទ្រកុមារ ដែលប្រយុទ្ធជាមួយ«ភរតរាហុ» ដែលបានបះបោរដណ្តើមរាជ្យព្រះបាទយសោវម៌្មទី២ និង«កងទ័ពចាម្ប» ដែលទំនងជាក្នុងបេសកកម្មឈ្លានពានប្រទេសចាម្ប។ ក្នុងពិធីការខ្មែរអង្គរ ព្រះរាជបុត្រមានគោរមងារជាវ្រះកម្រតេងអញ ឬ វ្រះកំស្តេងអញ។ ជួនកាលគេធ្វើរូបបដិមាតំណាងឱ្យ ឬ គេឧទ្ទិសរូបបដិមាតាងព្រះរាជបុត្រ និងរាជវង្សានុវង្សដូចជានៅប្រាសាទបន្ទាយឆ្មារ, បាយ័ន, ព្រះខ័ន, តាព្រហ្ម និងបន្ទាយក្តី។

## ៤.៤-ប្រភេទ, ឋានានុក្រម និងលក្ខណៈជ្រើសរើសមន្ត្រី

តាមសិលាចារឹកមួយចំនួនរបស់ព្រះបាទជយវម៌្មទី៥ បានបញ្ជាក់ពីការបង្កើតវណ្ណៈពីរគឺ«ខ្មុកវ្រះក្រលាអច៌្ចនៈ» និង«កម្មាន្តរៈ» ដោយសមាជិកមូលដ្ឋានជ្រើសរើសចេញពីក្រុមគ្រួសាររបស់អាចារ្យប្រធាន ហើយអ្នកទាំងនោះត្រូវព្រះអង្គបញ្ញត្តិទុកថា នឹងក្លាយទៅជាប្រកពធនជានមនុស្សតែមួយគត់ សម្រាប់ជ្រើសរើសឱ្យចេញទៅធ្វើជាមន្ត្រីរាជការចាប់ពីពេលនោះមក។ ព្រះបាទសូរ្យវម៌្មទី១បានជ្រើសរើសមន្ត្រី ដោយគិតពីពូជពង្ស អាយុ ការងារបំពេញភារកិច្ច និងគុណសម្បត្តិផ្ទាល់។ តាមលោក ជីវ តាក្វាន់ មន្ត្រីព្រះរាជាណាចក្រកម្ពុជាមានឋានៈ៥យ៉ាង៖

១-មន្ត្រីមានអង្រឹងស្នែងធ្វើពីមាសមួយ និងក្លស់ដងមាសចំនួនបួន

២-មន្ត្រីមានអង្រឹងស្នែងធ្វើពីមាសមួយ និងក្លស់ដងមាសចំនួនពីរ

៣-មន្ត្រីមានអង្រឹងស្នែងធ្វើពីមាសមួយ និងក្លស់ដងមាសចំនួនមួយ

៤-ក្លស់ដងមាសមួយ

៥-ក្លស់ដងប្រាក់មួយ

នៅសម័យអង្គរ គេរកឃើញគ្រឿងឥស្សរយសជាច្រើនបែបដែលត្រូវប្រទានទៅឱ្យមន្ត្រីតាមលំដាប់ឋានានុក្រម។ តាមជីវតាក្វាន់ មន្ត្រីដែលមានឋានានុក្រមថ្នាក់ទីបួនទទួលបានក្លស់មាសមួយ។ បើយោងតាមព័ត៌មានពីសិលាចារឹក នៅសម័យអង្គរគ្រឿងឥស្សរិយយសជាច្រើនដូចជា អង្រឹងស្នែងមាសចុងដងក្បាលនាគដែលមានកំពូលប្រាំ,កំពូលបី, កំពូលមួយ, មានក្លស់ដងមាស, ក្លស់ដងប្រាក់ ក្នុងចំនួនខុសៗគ្នា, ក្លស់ពណ៌

ស, ក្លស់ធ្វើពីស្លាបក្ងោកត្បូងមួយ, ពានរង្វាន់មាសរចនារំលេចដោយផ្កាឈូកដាក់ក្នុងប្រអប់ផ្កាឈូកស្រី, ឆ្មិត ស្លាបក្ងោក និងថូមួយ។ គេសង្កេតឃើញថាក្នុងរជ្ជកាលព្រះបាទសូរ្យវម៌្មទី១ មន្ត្រីជាច្រើនទទួលបានគ្រឿងឥស្សរិយយសជាអគ្រឹងស្នែង រចនាដោយក្បាលពស់។

គោរមងាររជាភាសាខ្មែរសម្រាប់មន្ត្រី ដែលបញ្ជាក់ក្នុងសិលាចារឹកមានដូចជា វាប, ឆ្លោញ, លោញ, ម្រតេញ, ម្រតាញ ឬ ម្រតាញខ្លោញ, ស្តេញ-ស្តេង ឬ ស្តេងអញ, កំស្តេងអញ, វ្រះកំស្តេង អញ, ធូលីជេងកំស្តេងអញ, កម្រតេងអញ, វ្រញកម្រតេងអញ,ភគវ ត បាទកម្រតេងអញ, ធូលីជេងវ្រះកម្រតេងអញ...។ សម្រាប់ព្រះរាជគ្រូរបស់អធិរាជជយវម៌្មទី៧ឈ្មោះជយកិត្តិបណ្ឌិតក៏បានទទួលគោរមងារជា«ធូលីជេងវ្រះកម្រតេញអញ»។

## ៤.៥-ការដួលរលំនៃចក្រភពអង្គរ

អាណាចក្រខ្មែរ បានពង្រីកខ្លួន ជារដ្ឋកសិកម្ម ដែលនៅឆ្ងាយពីសមុទ្ទ ដោយផ្អែក លើដីសណ្តរ។ វាលទំនាបក្នុងតំបន់អង្គរត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ ជាដីកសិកម្មតាំងពីចុងសតវត្សរ៍ទី៩ ដែលនាំឱ្យមាន ការកើនឡើងនៃចំនួនប្រជាជន និងការកសាងប្រាសាទ។ ទីក្រុងអង្គរកាលពីមុន មានប្រជាជនច្រើនជាងគេលំដាប់ទីបួននៃទីក្រុងនានាក្នុងពិភពលោកដែលមានប្រជាជនប្រមាណពី៤០០ ០០០ ទៅ៥០០ ០០០នាក់។ បន្ទាប់មក ប្រាសាទអង្គរវត្តត្រូវបានសាងសង់ ហើយដើម្បីរក្សាបាននូវទីក្រុងនៃវិស័យកសិកម្មប្រមូលផ្តុំទ្រង់ទ្រាយធំនោះ គឺជាការចាំបាច់។ អាងស្តុកទឹកដ៏ធំត្រូវបានសាងសង់នៅជុំវិញក្រុង ដែលបានផ្គត់ផ្គង់ទឹកដល់វាលស្រែដ៏ធំល្វឹងល្វើយ ដែលផលត្រូវការផ្គត់ផ្គង់ដល់អ្នកដែលកំពុងសាងសង់ប្រាសាទអង្គរវត្ត។ អាងស្តុកទឹកទាំងនេះក៏បានផ្តល់ទឹកសម្រាប់ ការប្រើប្រាស់ប្រចាំថ្ងៃផងដែរ។ ប្រហែលជាចាប់ពីសតវត្សរ៍ទី១៤ មកគេមិនអាចគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ នៅអង្គរបានតទៅទៀត ដូច្នេះទឹកក៏បានស្ទះស្អុយ ហើយក៏បានក្លាយជាកន្លែងមូសដែកគោល ដែលចម្លងគ្រុនចាញ់ ម្លោះហើយក្រោយមកធ្វើឱ្យចំនួនមនុស្សថយចុះ[115]។ គ្រោះរាំងស្ងួតរយៈពេលពីរនៅចន្លោះចុងទសវត្សរ៍ឆ្នាំ១៣០០ ដើមទសវត្សរ៍ឆ្នាំ១៤០០គឺនៅជុំវិញពេលដែលអរិយធម៌អង្គរដ៏ធំសម្បើម និងសម្បូរបែបក្នុងប្រទេសកម្ពុជាសម័យទំនើបបានដួលរលំ។ ប្រាសាទជាច្រើនមានភាពលេចធ្លោឡើង គឺជាសក្ខីកម្ម បង្ហាញអំពីព្រះចេស្តារបស់ព្រះរាជា ហើយព្រះរាជាទ្រង់បានស្វែងរកប្រភពធនធាន ដើម្បីគាំទ្រក្នុងគម្រោងសាងសង់ទាំងនេះ។ អំណាចកំពូលរបស់ព្រះរាជា មិនត្រូវបានធានាក្នុង លក្ខណៈជាប្រព័ន្ធ ឬ មានរបៀបរៀបរយទេ។ ជាជាងការពឹងផ្អែកលើមូលដ្ឋានអំណាចដ៏ទន់ខ្សោយនោះ ដូច្នេះហើយគាត់ត្រូវតែសង់ប្រាសាទ ឬជាវិមានដ៏ធំសម្បើមជាមធ្យោបាយបង្ហាញពីកម្លាំងអំណាច និង ការគ្រប់គ្រងរបស់គាត់។ នេះអាចធ្វើទៅបានលុះត្រាតែទិន្នផលកសិកម្មមានស្ថិរភាពនៃអាណាចក្រខ្មែរបានអនុញ្ញាតឱ្យសាងសង់ប្រាសាទដ៏ធំទាំងនេះ[116]។ ការកសាងសមិទ្ធិផលក្នុងសម័យអង្គរ ដែលចំណាយធនធាន កម្លាំងពលកម្មហួសប្រមាណ អាចជាមូលហេតុដែលនាំឱ្យប្រជាជននឿយណាស់ និងការចំណាយរបស់រដ្ឋច្រើនសន្ធឹកនាំឱ្យមានវិបត្តិសេដ្ឋកិច្ចផងដែរ។

ការធ្វើសង្គ្រាមច្រើនដងគឺជាកត្តាអវិជ្ជមានមួយ ដែលនាំឱ្យអង្គរធ្លាក់ចុះ។ នៅចុងសតវត្សរ៍ទី១១ ខ្មែរតែងបានស្គាល់នូវអសន្តិសុខខ្លះ និងការជ្រែករាជ្យខ្លះទៀតផង។ លុះមកដល់ដើមសតវត្សរ៍ទី១២ ទើបមានព្រះរាជាមួយអង្គយ៉ាងចំណាននាម សូរ្យវម៌្មទី២ មកគ្រប់គ្រងប្រទេសជាតិ ហើយធ្វើឱ្យមានរបៀបរៀបរយឡើង

---

[115] ដេវិឌ ឆាណ្ឌលរ័, *ប្រវត្តិសាស្ត្រខ្មែរ,* បកប្រែជាភាសាអង់គ្លេសដោយ ជិន ចន្ទា, ប្រាក់ សុវណ្ណារ៉ា, ម៉ម វណ្ណារី, សេង សោត, ចេញផ្សាយលើទី៣, ឆ្នាំ២០០៩, ទំព័រ៩០-៩១។

[116] Yoshiaki Ishizawa, *Challenging the Mystery of the Angkor Empire*-realizing the mission of Sophia University in the Asian World-, Tokyo Sohia University Press, 2012, p.114.

វិញ។ ចាប់ពីឆ្នាំ១១១៣ ជាឆ្នាំដែលទ្រង់ឡើងគ្រងរាជ្យ ព្រះអង្គបាននាំទ័ពទៅច្បាំងជាមួយនឹងប្រទេសជិតខាង បានចងស្ពានមេត្រីភាពជាមួយនឹងចិន។ ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័ទី២ ប្រទេសខ្មែរមានជ័យជម្នះ លើពួកដាយវៀត ពួកមនព្រមទាំងបានយកប្រទេសចាម្បមកដាក់ជាចំណុះទៀតផង។ មកដល់ឆ្នាំ១១៧៧ ចាម្បបានលើកទ័ពចូលមកដល់អង្គរ ព្រមទាំងត្រួតត្រាអស់រយៈពេល៥ឆ្នាំផង។ អធិរាជជយវរ្ម័ទី៧ បានវាយកំចាត់ទ័ពចាម្ប ឱ្យចេញពីអង្គរទៅវិញនៅឆ្នាំ១១៨១[117]។ លើសពីនោះទៅទៀតនៅឆ្នាំ១២០៦ សង់ស៊ីខាន់ (King Song Si Khan) ប្រកាសខ្លួនជា«មេកន្ទ្រាញកំពូល»នៃកុលសម្ពន្ធទួក៍-ម៉ុងហ្គោល ដែលមានមូលដ្ឋាន នៅ ខាងត្បូងបឹងបៃកាល់(Baikal)។ រហូតដល់ឆ្នាំ១២៣០ ទឹកដីនេះ បានពង្រីកខ្លួន ហើយលាតសន្ធឹងពីព្រំដែនមហាសុងនៃចក្រភពចិន ទៅដល់ទន្លេវ៉ុលហ្គា(Volga)។ នៅឆ្នាំ១២៦០ គូប៊ីឡៃ ខាន់(Kublai Khan) បានធ្វើសញ្ជ័យយកប្រទេសចិនទាំងមូលនៅឆ្នាំ១២៧៩ ហើយនៅឆ្នាំ១២៨០ គូប៊ីឡៃ ខាន់ ប្រកាសខ្លួនជាអធិរាជនៃមហាយន់នៃចក្រភពចិន[118]។ យុទ្ធនាការសឹកថ្មីនៅឆ្នាំ១២៨២ មានគោលបំណងឱ្យអាណាចក្រចាម្បចុះចូលជាចំណុះ។ អាណាចក្រចាម្បបានប្រកាសឯករាជ្យ និងជួសជុលប្រាសាទខ្លួនឡើងវិញ ក្រោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរនៅក្នុងរាជ្យព្រះបាទជយវរ្ម័ទី៧អស់រយៈពេល៣០ឆ្នាំ(១១៩០-១២២០)។ នៅឆ្នាំ១២៦៦ ស្តេចចាម្បមួយអង្គនាមឥន្ទ្រវរ្ម័ទី៥ បានឡើងសោយរាជ្យ។ ចំណុចគួរឱ្យកត់សម្គាល់មួយក្នុងរាជ្យនេះគឺចំណងមិត្តភាពជាមួយសត្រូវចាស់អាណាចក្រដាយវៀតដែលស្តេចអង្គនេះបានបញ្ជូនទូតទៅយ៉ាងតិច៤ដងនៅចន្លោះឆ្នាំ១២៦៦ ដល់១២៧០។ យើងសង្កេតឃើញថានៅក្នុងសង្គ្រាមបន្ទាប់ទប់ទល់នឹងការលុកលុយនៃកងទ័ពម៉ុងហ្គោល នយោបាយការទូតនេះ បានជួយអាណាចក្រចាម្ប[119]។

បើនិយាយពីប្រទេសកម្ពុជាវិញ នៅពេលនោះក៏ទទួលរងសម្ពាធពីកងទ័ពម៉ុងហ្គោលដែរ ប៉ុន្តែនៅអាចដោះខ្លួនរួចដោយមិនចាំបាច់ចំណាយធនធានអស់ច្រើន។ នៅឆ្នាំ១២៨២ នៅពេលដែលមេទ័ពសោហ្គាតូ ចាប់ផ្តើមយុទ្ធនាការសឹកនៅអាណាចក្រចាម្ប គាត់ក៏បានបញ្ជូនទ័ពមួយក្រុមតូច ក្រោមការដឹកនាំនៃមេទ័ព២នាក់សំដៅមកកម្ពុជាដែរ ប្រហែលជាប្រើប្រាស់ផ្លូវក្វាំងជើ(Quảng Trị) ហើយកាត់តាមសុវណ្ណខេត្ត។ បើតាមកំណត់ត្រាជីវ តាក្វាន់ ដែលសរសេរជាង១០ឆ្នាំក្រោយបញ្ជាក់ថាពួកគេត្រូវបានចាប់ខ្លួន ហើយមិនឃើញត្រឡប់មកវិញទេ។ ព្រះរាជាខ្មែរដោយមិនត្រេកអរនឹងជ័យជម្នះតូចនេះ ព្រមទាំងបានសម្លឹងឃើញ វែងឆ្ងាយ បានផ្ញើជាសួយសារអាករទៅកាន់មហាខាន់ នៅឆ្នាំ១២៨៥[120]។ សន្តិវង្សថ្មីមួយនេះ បានព្យាយាម ដណ្តើមយកប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ ប៉ុន្តែបានបរាជ័យ។ អស់រយៈពេលជាច្រើនឆ្នាំគេបានបញ្ជូនកងទ័ពទៅវាយទាំងដាយវៀត និងទាំងចាម្ប ហើយក្នុងអំឡុងពេលនេះ វៀតណាម និងចាម្បបានសហការគ្នាប្រឆាំងនឹងម៉ុងហ្គោល រហូតដល់ម៉ុងហ្គោលត្រូវបរាជ័យក្នុងឆ្នាំ១២៨៥[121]។

ចាប់តាំងពីពាក់កណ្តាលទី១នៃសតវត្សរ៍ទី១៣ មានការលេចឡើងជាបណ្តើរៗនៃក្សត្របុរីតូចៗ នៅភាគខាងត្បូងតំបន់យុនណាន។ ក្សត្របុរីទាំងនោះក្រោយមកក្លាយជាអាណាចក្រសាន (នៅភាគឦសានប្រទេស

---

117 ក្រសួងអប់រំជាតិ, *ខេមរយានកម្ម(ប្រវត្តិវិទ្យាថ្នាក់ទី៥)*, ដ.ឯ.ម., ទំព័រ១០៧។

118 ព្រឹត្តិបត្រ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, *កម្រងអត្ថបទស្រាវជ្រាវវប្បធម៌ខ្មែរៈ កាលវេលាដ៏សំខាន់នៅអាស៊ីអាគ្នេយ៍៖សតវត្សរ៍ទី១៣ ដោយ ហ៊្សែក សីដែស,* ប្រែសម្រួលដោយ សួន សុភ័ក្ត្រា, លេខ៥ ខែធ្នូ ឆ្នាំ២០២២, ទំព័រ៥១។

119 -ដ- ទំព័រ៥៣។

120 -ដ- ទំព័រ៥៥។

121 ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, បកប្រែដោយប្រាក់ សុវណ្ណារ៉ា, កែសម្រួលដោយ វង់ សុធារ៉ា, ឆ្នាំ២០១២-២០១៣, ទំព័រ៨១។

ភូមា)នៅពេលវេលាជាមួយគ្នានោះដែរ ក៏មានការលេចឡើងនៃអាណាចក្រសុខោទ័យ និងអាណាចក្រតៃនៅលួងប្រាបាងតាមដងទន្លេណាមអ៊ូ(Nam Ou) ដែលមិនទំនងជាការបម្លាស់ប្តូរដោយគំហុក នៃប្រជាជននោះទេ តែជាបម្លាស់ប្តូរក្រុមអ្នកកាន់អំណាចចាស់ ដោយក្រុមអ្នកកាន់អំណាចថ្មីដែលមាន ប្រភពដើម តៃ[122]។

ម្យ៉ាងវិញទៀត យើងឃើញថា អយុធ្យាបានក្លាយជារដ្ឋចាប់ពីពាក់កណ្ដាលសតវត្សរ៍ទី១៤។ ដោយឡែកចាប់ពីចុងសតវត្សរ៍ទី១៣ ដល់ពាក់កណ្ដាលសតវត្សរ៍ទី១៤ ខ្មែរ និងចិនហៅតំបន់នេះថាសៀម ហើយជារដ្ឋផ្សេងគ្នាពីសុខោទ័យដែលនៅភាគខាងជើង។ ចាប់ពីចុងសតវត្សរ៍ទី១៤ អាណាចក្រជាច្រើនមានការរីកចម្រើនប្រណាំងប្រជែងគ្នាជាមួយចក្រភពអង្គរ។ ក្នុងពេលដែលរដ្ឋចំណុះមួយចំនួនបានប្រកាសខ្លួនជារដ្ឋឯករាជ្យលែងចំណុះឱ្យចក្រភពអង្គរ ក៏មានរដ្ឋចំណុះមួយចំនួនទៀតបានងាកទៅចំណុះអាណាចក្រផ្សេងដើម្បីប្រែក្លាយខ្លួនជាចក្រភពថ្មីក្នុងតំបន់។ អយុធ្យា ដែលធ្លាប់ជារដ្ឋខ្មែរមួយចំណុះឱ្យអង្គរ និងដឹកនាំដោយសែស្រឡាយរបស់រាជាធិរាជនៅអង្គរដែរនោះ បានដឹកនាំទ័ពវាយលុក និងប៉ុនប៉ងកាន់កាប់អង្គរជាច្រើនដង។ នៅឆ្នាំ១៤៣១ ដល់១៤៤៥ មានសង្គ្រាមរបស់អយុធ្យាប្រឆាំងនឹងអង្គរ។ នេះប្រហែលជាមិនមែនជាសង្គ្រាមរវាងថៃ និងខ្មែរទេ ប៉ុន្តែជាសង្គ្រាមរវាងអាណាចក្រពីរក្រុមដែលគេជឿថាជារាជធានីប្រពៃណីរបស់គេដែរ[123]។

## ៦-សំណួរត្រិះរិះ

១- តើព្រះរាជាអង្គណាជាស្តេចស្ថាបនិកទីក្រុងអង្គរទី១?

២-ចូរប្រៀបធៀបលទ្ធិទេវរាជ ជាមួយលទ្ធិកតញ្ញូនិយម។

៣-ចូររៀបរាប់ពីស្នាព្រះហស្តព្រះរាជាស្ថាបនិកក្រុងអង្គរនីមួយៗ។

៤-តើបារាយណ៍ និងប្រាសាទផ្តល់ប្រយោជន៍យ៉ាងដូចម្តេច ចំពោះមនុស្សសម័យអង្គរ និងបច្ចុប្បន្ន?

៥-ចូរពន្យល់ពីមូលហេតុដែលនាំឱ្យអរិយធម៌អង្គររីកចម្រើន។

---

[122] ព្រឹត្តិបត្រ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ដ.ឯ.ម., ទំព័រ៥៦។

[123] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ១០៥។

# មេរៀនទី៧ ប្រទេសកម្ពុជាសម័យចតុមុខ(ចាប់ពី១៤៣១ ដល់១៥២៩)

## ១-ការប្រជែងអំណាចក្នុងតំបន់

ចាប់ពីចុងសតវត្សរ៍ទី១៤ អាណាចក្រជាច្រើនមានការរីកចម្រើនប្រណាំងប្រជែងគ្នាជាមួយចក្រភពអង្គរ ហើយបានប្រកាសខ្លួនជារដ្ឋឯករាជ្យ។ ចំពោះអយុធ្យាក៏យកអង្គរមកដាក់ក្រោមចំណុះរបស់ខ្លួនបានសម្រេចលើកទីមួយនៅចុងសតវត្សរ៍ទី១៤ និងលើកទីពីរនៅដើមសតវត្សរ៍ទី១៥ ដែលជាហេតុធ្វើឱ្យអង្គរលែងជាមជ្ឈមណ្ឌលអំណាចក្នុងតំបន់។ ទោះជាក្នុងកំណត់ហេតុជនជាតិអេស្ប៉ាញ ដែលទៅដល់ស្រុកខ្មែរក្នុងឆ្នាំ១៥៩៥ បានរៀបរាប់ពីក្រុងធំៗ ដែលមានក្រុងអង្គរ ដែលត្រង់ចំណុចនេះបង្ហាញថាខ្មែរមិនបានបោះបង់ចោលក្រុងអង្គរនៅសតវត្សរ៍ទី១៥ក៏ដោយ ប៉ុន្តែមជ្ឈមណ្ឌលពាណិជ្ជកម្ម នៅតំបន់អង្គរលែងសំខាន់ទៀតហើយ។

## ២-បញ្ហាប្រព័ន្ធធារាសាស្ត្រ និងរបត់ថ្មីនៃពាណិជ្ជកម្ម

នៅចុងសតវត្សរ៍ទី១៥ ការរៀបចំសង្គម ការិយាល័យធិបតេយ្យ និងអាទិភាពសេដ្ឋកិច្ច ដែលធ្លាប់មាននៅសម័យអង្គរ ទំនងជាលែងមានភាពខ្លាំងក្លា តទៅទៀតហើយ។ ម្យ៉ាងទៀតការរៀបចំរចនាសម្ព័ន្ធថ្មី ទីតាំងថ្មី និងអាទិភាពថ្មី ដែលពឹងផ្អែក មួយផ្អែកលើការធ្វើជំនួញក្រៅប្រទេស អាចដំណើរការទៅបាន និងមានការទាក់ទាញផង[124]។ ចន្លោះឆ្នាំ១៣៧០ និង១៤២០ មានបេសកកម្មជាច្រើនដែលបានកត់ត្រាទុកពីប្រទេសកម្ពុជាទៅចិន ប្រហែលមកពីកំពង់ផែទន្លេមេគង្គខាងត្បូងទីក្រុងភ្នំពេញ។ នៅចន្លោះឆ្នាំ១៤៣១ និង១៤៤៥ ក្រុងអង្គរដែលជាមជ្ឈមណ្ឌលនយោបាយរបស់កម្ពុជា ក៏ត្រូវបានគេបោះបង់ចោល ហើយបានផ្លាស់ទៅកន្លែងថ្មីនៅប្រទេសកម្ពុជាភាគខាងត្បូង[125]។

ទួលប៉ាសាន (Pa-Shan)ធ្លាប់ជាក្រុងមួយនៃចក្រភពអង្គរ ដែលចាប់ផ្តើមទាក់ទាញការចាប់អារម្មណ៍ពីបេសកជនចិនតាំងពីទសវត្សរ៍ឆ្នាំ១៣៧០-១៣៨០[126]។ ទួលប៉ាសានជាតំបន់មានសក្តានុពលកសិកម្ម ដែលអាចផលិតស្រូវបានច្រើន ដោយមានប្រព័ន្ធផ្លូវទឹកធម្មជាតិច្រើនខ្វាត់ខ្វែង។ ព្រះបាទពញាយ៉ាតបានអភិវឌ្ឍទួលប៉ាសានជាបន្ទប់ពិសេសផ្នែកជំនឿ កសិកម្ម និងពាណិជ្ជកម្ម។ ព្រះបាទពញាយ៉ាតបានហៅរាជធានីនេះថា ស្រីយសោធរបុរ ដូចរាជធានីអង្គរដែរ ហើយប្រជារាស្ត្របានហៅកាត់ខ្លីថា ស្រីសន្ធរ ឬ ស៊ីធរ (ស្រីធរ)។ ការតាំងរាជធានីនៅទួលប៉ាសានមានរយៈពេលប្រមាណ៣ឆ្នាំប៉ុណ្ណោះ។ នៅពេលឃើញថាអយុធ្យាមិនបានលើកទ័ពតាមមក ហើយទួលប៉ាសានក៏មានទឹកជំនន់ ព្រះបាទពញាយ៉ាតបានសម្រេចចិត្តប្តូររាជធានីមកស្រុកកំណើតឯចតុមុខវិញនៅឆ្នាំ១៤៣៤។

## ៣-រាជធានីថ្មី

នៅឆ្នាំ១៤៣៤ ព្រះបាទពញាយ៉ាតបានផ្លាស់រាជធានីពីទួលប៉ាសានមកចតុមុខ ដែលស្ថិតនៅ រាជធានីភ្នំពេញបច្ចុប្បន្ន ត្រង់កន្លែងប្រសព្វគ្នារវាងទន្លេសំខាន់ៗ៤។ ទីតាំងដ៏ល្អនៃភ្នំពេញ ដែលស្ថិតនៅ ត្រង់ទីប្រសព្វទន្លេធំ និងទន្លេសាបគឺនៅត្រង់ទន្លេចតុមុខ អនុញ្ញាតឱ្យទីក្រុងមួយដែលមានកំពែងព័ទ្ធជុំវិញ អាចត្រួតពិនិត្យជំនួញដែលមកពីប្រទេសលាវ តាមដងទន្លេ ក៏ដូចជាជំនួញក្អម, ថ្នាំង, ត្រីងៀត និងទឹកត្រី មកពីតំបន់ទន្លេសាប ព្រមទាំងទំនិញនាំចូល ជាពិសេសទំនិញមកពីចិន តាមដែនដីសណ្តទន្លេមេគង្គដែលមានប្រជាជន

---

124 ដេវិឌ ឆាណ្ឌល័រ, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ៩២-៩៣។

125 ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ៨៨។

126 សូមមើល: O. W. Wolters, *The Khmer King at Basan (1371-1373) and the Restoration of the Cambodian Chronology During the 14th and 15th Centuries*, 1965, p.46.

ខ្មែររស់នៅយ៉ាងច្រើននៅពេលនោះ[127]។ ដោយសារក្នុងជំនឿព្រហ្មញ្ញសាសនា ទីណាដែលជាប្រសព្វនៃទន្លេពីរ ទីនោះ គឺជាទឹកដីពិសិដ្ឋជ័យភូមិ ទើបនៅចតុមុខមានកន្លែងបូជនីយដ្ឋាន តាំងពី សម័យបុរាណ ជាពិសេស នៅវត្តឧណ្ណាលោម ដែលមានប្រាសាទថ្មសតវត្សរ៍ទី១០ មួយត្រូវបានគេសង់ពីលើខឿនប្រាសាទឥដ្ឋកាលពីសតវត្សរ៍ទី៧។ នៅជុំវិញជាយរាជធានីនេះ ក៏មានកេរដំណែលប្រាសាទបាក់បែក ជាច្រើនទៀត នៅសម័យកាលដូចគ្នាដូចជានៅវត្តសំបួរ, វត្តជើងឯក[128], វត្តព្រៃស, វត្តអង្គតាមិញ, ទួលអស់លោក និងប្រាសាទសែនសុខ ជាដើម។ ដូច្នេះ ទីនេះគឺជាទីប្រជុំជនសំខាន់មួយដែលមានប្រជាជនរស់នៅកុះកររួចជាស្រេច។ បើយោងតាមវិសាលភាពនៃទឹកដីកម្ពុជានៅសម័យនោះ ក្រុងចតុមុខដែលមានវត្តភ្នំជាទីសក្ការៈស្ទួល អាចចាត់ទុកថា មានទីតាំងនៅចំកណ្ដាលប្រទេស ដែលឆ្លើយតបនឹងទ្រឹស្ដីលោកធាតុ (ពិភពលោកព័ទ្ធជុំវិញដោយទឹកសមុទ្រដែលមានទ្វីប៤ និងភ្នំព្រះសុមេរុនៅចំកណ្ដាល។ ស្ទួលនៃរាជធានីប្រៀបដូចជាភ្នំព្រះសុមេរុ) របស់ឥណ្ឌាដែលដូនតាខ្មែរបានយក មកអនុវត្តតាំងពីសម័យមុនអង្គររៀងមក[129]។

## ៤-ព្រះរាជា និងអាណាចក្រទាំង៣

សម័យចតុមុខ នៅពេលព្រះបាទស្រីរាជា និងអ្នកស្នេហាជាតិកំពុងធ្វើពលិកម្ម ដើម្បីរំដោះទឹកដីប៉ែកខាងលិច ដែលពួកសៀមបានឈ្លានពានយកនៅក្នុងរជ្ជកាលមុនៗ។ ទ្រង់បានស្ដារវិសាលភាពទឹកដីខ្មែរ និងដើម្បីភាពរុងរឿងរបស់ប្រទេសជាតិឡើងវិញ នៅសមរភូមិក្រោយ បានលេចឡើងនូវវិបត្តិរាជវង្សបំផ្លាញផែនការនេះ។ បញ្ហានេះបានក្លាយជាគំរូអាក្រក់សម្រាប់ព្រះមហាក្សត្រខ្មែរមិនឱ្យមានគំនិតចង់បង្រួបបង្រួម ប្រទេសកម្ពុជាបុរាណ ដែលរួមមានទឹកដីអយុធ្យាទាំងមូល ឬ ខេត្តមួយចំនួនដែលអយុធ្យាវាតយក តមកទៀត។

ក្មួយប្រុសរបស់ព្រះបាទស្រីរាជា ព្រះនាមស្រីសុរិយោទ័យ ដែលមានភារកិច្ចប្រមូលស្បៀង សម្រាប់បញ្ជូនទៅផ្គត់ផ្គង់សមរភូមិមុខ បានគាបសង្កត់យកខេត្តទាំងឡាយនៅភាគខាងកើតទន្លេមេគង្គឱ្យចុះចូលគាំទ្រអំពើក្បត់របស់ទ្រង់ និងតាំងរាជធានីនៅបាសាននៅពេលព្រះបាទ ស្រីរាជាលើកទ័ពត្រឡប់ មកវិញ បានមកបោះទីតាំងនៅខេត្តកំពង់សៀម បន្ទាប់ពីវាយប្រហារកងទ័ពក្បត់ ក្រោមបញ្ជារបស់ស្រីសុរិយោទ័យបានមួយឆាក។ ព្រះអង្គបានដឹងថាព្រះអនុជនាមស្រីធម្មរាជាក្បត់ចង់ដណ្ដើមរាជបល្ល័ង្ក ដោយព្រះធម្មរាជាបានហាមឃាត់ព្រះអង្គមិនឱ្យវិលចូលមករាជវាំងចតុមុខ ដោយបានបញ្ជូនសាច់ញាតិផ្ទាល់ និងទ្រព្យសម្បត្តិមួយចំនួនរបស់ព្រះអង្គទៅឱ្យព្រះអង្គនៅកំពង់សៀម លើកលែងតែគ្រឿងបរិក្ខារពិសិដ្ឋសម្រាប់ឡើងសោយរាជ្យ។

ព្រះធម្មរាជាបានចាត់ការពង្រឹងកម្លាំងការពារបន្ទាយយ៉ាងរឹងមាំ ដើម្បីទប់ទល់ចំពោះ ការវាយប្រហាររបស់ព្រះរៀម និងព្រះភាគិនេយ្យ។ ដូច្នោះហើយប្រទេសកម្ពុជាពេលនោះត្រូវចែកជាបី អាណាចក្រ។ ព្រះបាទស្រីរាជា គ្រប់គ្រងទឹកដីខាងលិចនិងខាងជើងទន្លេមេគង្គ ដោយតាំងរាជធានីនៅខេត្តកំពង់សៀម[130]។ ចំណែកព្រះស្រីធម្មរាជា គ្រប់គ្រងនៅត្រើយខាងលិចទន្លេសាប និងមេគង្គក្រោមដែលមានរាជវាំងនៅចតុមុខចាប់ពីឆ្នាំ

---

[127] ដេវិឌ ឆាណ្ឌល័រ, *ប្រវត្តិសាស្ត្រខ្មែរ,* ដ.ឯ.ម., ទំព័រ៩១។

[128] សូមបញ្ជាក់ថា : ទីតាំងស្ថានីយ៍ប្រវត្តិសាស្ត្រ ឬ ទីទួលបុរាណជាច្រើនត្រូវមន្ត្រីផ្នែកបុរាណវិទ្យានៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជាស្រាវជ្រាវ រកឃើញនៅក្នុងភូមិស្រុកចេក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយសុទ្ធសឹងតែជាទីតាំងឡផលិតកុលាលភាជន៍ (ក្អម, ឆ្នាំង, ចាន ធ្វើពីដី) ពីសម័យបុរាណ មានអាយុកាលរាប់រយឆ្នាំមុន។

[129] បើយោងតាមការពន្យល់បកស្រាយរបស់លោកបណ្ឌិត វង់ សុធារ៉ានៅក្នុងអនុគណកម្មការប្រវត្តិវិទ្យា។

[130] សព្វថ្ងៃគឺស្ថិតនៅក្នុង ឃុំស្រងែ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

១៤៧៨ និងស្រីសុរិយោទ័យត្រួតត្រាទឹកដីត្រើយខាងកើតទន្លេមេគង្គ ដែលមានរាជវាំងនៅទួលបាសានដែលនៅត្រង់ទីតាំងវត្តស៊ីធរ ចាប់ពីឆ្នាំ១៤៧៧។

ការច្បាំងគ្នាឯងបានអូសបន្លាយអស់រយៈពេល១០ឆ្នាំ ពីឆ្នាំ១៤៧៥ ដល់ឆ្នាំ១៤៨៥ និងបានសម្លាប់ខ្មែរគ្នាឯងអស់រាប់ម៉ឺននាក់។ ដើម្បីកុំឱ្យជីវភាពប្រជាជនជួបគ្រោះទុរ្ភិក្សព្រះបាទស្រីរាជា បបួលមេដឹកនាំពីរទៀតផ្អាកសង្គ្រាមនៅរដូវបង្កបង្កើនផល និងសន្យាច្បាំងគ្នាជាថ្មីបន្ទាប់ពីប្រជាជនប្រមូលផលកសិកម្មរួច។ ដូច្នេះប្រហែលគ្រោះមហន្តរាយធ្ងន់ធ្ងរនៃចម្បាំងនោះគឺការបំផ្លិចបំផ្លាញសម្ភារៈ និងជីវិតមនុស្សនៅរៀងរាល់រដូវប្រាំង។

នៅឆ្នាំ១៤៨៥ ព្រះធម្មរាជាទៅពឹងសៀម ដើម្បីបញ្ចប់សង្គ្រាមផង និងដើម្បីសោយរាជ្យតែមួយអង្គឯងផង។ ព្រះធម្មរាជា បានចាត់រាជទូតដឹកនាំបណ្ណាការសុទ្ធសឹងជាទ្រព្យមានតម្លៃទៅសុំចងមេត្រីភាពជាមួយព្រះចៅមហាចក្រពត្រាធិរាជ ស្ដេចក្រុងអយុធ្យា ដែលបានឆ្លើយតបជាវិជ្ជមាន និងបញ្ជូនទ័ពហែក្បួនយ៉ាងគគ្រឹកគគ្រេងមកក្រុងចតុមុខ[131]។

បន្ទាប់មកសេនាបតីខ្មែរ-សៀម បានរៀបចំក្បួនទ័ព ដើម្បីកម្ចាស់ព្រះបាទស្រីរាជា និងព្រះស្រីសុរិយោទ័យ។ ដំបូងពួកគេលើកទ័ពទៅព័ទ្ធបន្ទាយកំពង់សៀម។ ឧកញ៉ាក្រឡាហោមម៉ឹង បានចេញពីបន្ទាយមកជួបស្ដេចសៀម និងព្រះធម្មរាជា ទូលអំពីបំណងព្រះបាទស្រីរាជា ដែលសុំចងមេត្រីភាព និងជានានឹងគ្នាវិញ។ ស្ដេចទាំងពីរអង្គនោះត្រេកអរយ៉ាងខ្លាំង ក៏លើករបើពលមកតាំងបន្ទាយនៅឧដុង្គក្នុងខេត្តសំរោងទងវិញ។ ស្ដេចទាំងបីអង្គបានបញ្ជូនសារសូមយាងព្រះស្រីសុរិយោទ័យចូលទៅចរចាគ្នានៅបន្ទាយឧដុង្គ។ ព្រះអង្គមានបំណងបដិសេធ តែកូនចៅរបស់ព្រះអង្គមិនព្រមចេញច្បាំងតទៅទៀត ទើបបង្ខំព្រះទ័យឱ្យ ព្រះអង្គយល់ព្រមធ្វើតាមសំណើ។ ស្ដេចអយុធ្យាធ្វើជាចៅក្រមសម្របសម្រួលកិច្ចការចរចា។

ទំនាស់ត្រូវបានបញ្ចប់ តែស្ដេចសៀមបានទាមទារយកវិញនូវទឹកដីទាំងឡាយដែលព្រះបាទស្រីរាជាដណ្ដើមយកបានមុននោះ និងនាំខ្លួនព្រះបាទស្រីរាជា និងព្រះស្រីសុរិយោទ័យព្រមជាមួយសាច់ញាតិជិតដិតរបស់ព្រះអង្គយកទៅទុកនៅអយុធ្យា។ ដោយសារមានជំងឺឈឺចិត្តរួមរឹត ព្រះបាទស្រីរាជាបានសុគតនៅ ឆ្នាំ១៤៨៥ ហើយព្រះស្រីសុរិយោទ័យសុគតនៅឆ្នាំបន្ទាប់។ នៅកម្ពុជាព្រះស្រីធម្មរាជា បានធ្វើរាជាភិសេកឡើងសោយរាជ្យតែមួយអង្គឯង[132]។ បើយោងតាម អេង សុត, *ឯកសារមហាបុរសខ្មែរៈ ព្រះរាជពង្សាវតារខ្មែរ តាមសាស្ត្រាស្លឹករឹតពិតឥតក្លែងក្លាយ*, ភាគ១ ដល់៧, ឆ្នាំ១៩៦៩, ទំព័រ៧៧ ដល់៧៩ បានបង្ហាញពីដែនដីនៃការគ្រប់គ្រងនៅពេលនោះគឺៈ

**១-ព្រះស្រីរាជា** គង់នៅអម្រាគគិរិន្ទបូណ៌(បរិបូណ៌) គ្រប់គ្រង២៨ខេត្ត ទិសខាងជើងៈខេត្តលង្វែក, រលាប្អៀរ, អម្រាគគិរិន្ទបូណ៌, ក្រគរ, គ្រង, ពោធិ៍សាត់, បាត់ដំបង, ឫស្សីសាញ, ពាមសីមា, មង្គលបូរី, រយ៉ង, សុរិន្ទ, សង្គារ, កំពង់សៀម, ស្ទឹងត្រែង, ជើងព្រៃ, គោកសេះ, អន្លង់រាជ, ព្រំទេព, ព្រៃក្ដី, ស្មោង, ជីក្រែង, រលួស, សៀមរាប, ម្លូព្រៃ, ជាំក្សាន្ត, ត្នោត, ទឹកជោរ រៀងទៅទល់នឹងដែនសៀម ។

**២-ព្រះស្រីសុរិយោទ័យ**(បុត្រព្រះនារាយណ៍រាជា)គង់នៅបាសាន គ្រប់គ្រង១៥ខេត្តត្រើយខាងកើត ៖ ខេត្តបាសាន (ស្រីសន្ធរ), សៀមបូក, សម្បុកសម្បូណ៌, ក្រចេះ, ឆ្លូង, ត្បូង, ទទឹងថ្ងៃ, ព្រៃវែង, បាភ្នំ, រំដួល, ស្វាយទាប, រោងដំរី, ព្រៃនគរ, លង់ហោ, ជើងបាដែង រៀងទៅទល់នឹងនគរចាម្ប ។

[131] បណ្ឌិត វង់ សុធារ៉ា, *ពន្យល់ក្នុងអនុគណកម្មការប្រវត្តិវិទ្យា,* ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៨(ទី សុផល ជាសមាជិកចូលរួម)។

[132] នេះជាយុទ្ធសាស្ត្រនៃការគ្រប់គ្រងមួយរបស់សៀមដែលអាចបញ្ជាព្រះបាទស្រីធម្មរាជាឱ្យធ្វើតាមខ្លួនបាន។

**៣-ព្រះធម្មរាជា** គង់នៅចតុមុខស្រុកភ្នំពេញ គ្រប់គ្រង១៥ខេត្តខាងត្បូង ឬខាងលិច៖ ខេត្តសំរោងទង, បាទី, លើកដែក, ទ្រាំង, បន្ទាយមាស, ថ្លង, បាសាក់, បារៀ, ពាម, កោះស្លាកែត, កំពត, កំពង់សោម, ព្រះត្រពាំង, ក្រមួនស, ដូនណៃ រៀងទៅទល់នឹងសមុទ្ទ។

សរុបសម័យចតុមុខ ពេលខ្មែរបែកជា៣ បញ្ហាចោទគឺដោយសារក្មួយរបស់ព្រះបាទស្រីរាជា គឺព្រះបាទស្រីសុរិយោទ័យចង់ដណ្ដើមអំណាច។ ព្រះបាទស្រីធម្មរាជាប្រមូលអ្នកគាំទ្រខ្លួន ដើម្បីបង្កើតមណ្ឌលអំណាចរបស់ខ្លួន រួចក្រោយពេលបញ្ហាបានកើតទ្រង់បានទៅសុំអន្តរាគមន៍ពីស្ដេចសៀម គឺដើម្បីបញ្ចប់ជម្លោះ។ ពេលសៀមចូលមក ក៏យកធម្មរាជាដែលមានខ្សែលោហិតមកគ្រប់គ្រងនៅកម្ពុជា។ ចាប់ពីពេលនោះជាដំណាក់កាលអន្តរាគមន៍លើទឹកដីខ្មែរជាលើកដំបូង ដែលនាំឱ្យខ្មែរបាត់បង់ឥស្សរភាព។ រហូតមកដល់សតវត្សរ៍ទី១៨ ការអន្តរាគមន៍លើកម្ពុជាចាប់កាន់តែធ្ងន់ធ្ងរទៅដោយសារនៅពេលនោះមានទាំងសៀម និងអាណ្ណាម។

## ៥-វិបត្តិរាជវង្ស និងការកសាងសង្គមជាតិ[133]

នៅពេលព្រះបាទស្រីរាជា និងអ្នកស្នេហាជាតិកំពុងធ្វើពលិកម្មដើម្បីរំដោះទឹកដីប៉ែកខាងលិចដែលពួកសៀមបានឈ្លានពានយកក្នុងរជ្ជកាលនៃព្រះមហាក្សត្រមុនៗ, ស្ដារវិសាលភាពទឹកដីខ្មែរ និងដើម្បីភាពរុងរឿងរបស់ប្រទេសជាតិឡើងវិញនោះ នៅសមរភូមិក្រោយបានលេចនូវវិបត្តិរាជវង្ស និងបានបំផ្លាញផែនការនេះ។ បញ្ហានេះបានក្លាយជាគំរូអាក្រក់សម្រាប់ព្រះមហាក្សត្រខ្មែរ មិនឱ្យមានគំនិតចង់បង្រួបបង្រួមជាតិដែលរួមមានទឹកដីអយុធ្យាទាំងមូល ឬ ខេត្តមួយចំនួនដែលអយុធ្យាវាតយកតមកទៀត។ ចំណែកព្រះស្រីសុរិយោទ័យដែលមានភារកិច្ចប្រមូលស្បៀងសម្រាប់បញ្ជូនទៅផ្គត់ផ្គង់ដល់សមរភូមិមុខបានសង្កត់យកខេត្តទាំងឡាយ នៅភាគខាងកើតទន្លេមេគង្គឱ្យចុះចូលគាំទ្រអំពើក្បត់របស់ទ្រង់ និងតាំងរាជធានីនៅប៉ាសាន។ នៅពេលព្រះបាទស្រីរាជាលើកទ័ពត្រឡប់មកវិញ បានមកបោះទីតាំងនៅខេត្តកំពង់សៀម បន្ទាប់ពីវាយប្រហារកងទ័ពក្បត់ ក្រោមបញ្ជារបស់ព្រះអង្គម្ចាស់ស្រីសុរិយោទ័យបានមួយធាក។ នៅទីនោះហើយដែលព្រះអង្គបានដឹងថាព្រះអនុជក្បត់ចង់ដណ្ដើមរាជបល្ល័ង្កផង ពីព្រោះព្រះធម្មរាជាបានហាមឃាត់ព្រះអង្គមិនឱ្យវិលចូលមករាជវាំងចតុមុខ ដោយបានបញ្ជូនសាច់ញាតិផ្ទាល់ និងទ្រព្យសម្បត្តិមួយចំនួនរបស់ព្រះអង្គទៅឱ្យព្រះអង្គនៅកំពង់សៀម លើកលែងតែគ្រឿងបរិក្ខារពិសិដ្ឋសម្រាប់ឡើងសោយរាជ្យ។ ព្រះធម្មរាជាបានចាត់ការពង្រឹងកម្លាំងការពារបន្ទាយយ៉ាងរឹងមាំ ដើម្បីទប់ទល់ចំពោះការវាយប្រហាររបស់ព្រះរៀម និងក្មួយ។ ដូច្នោះហើយ ប្រទេសកម្ពុជាពេលនោះត្រូវចែកជាបីអាណាចក្រ។ ព្រះស្រីរាជាគ្រប់គ្រងទឹកដីខាងលិច និងខាងជើងទន្លេមេគង្គ ដោយតាំងរាជធានីនៅខេត្តកំពង់សៀម។ ព្រះស្រីធម្មរាជា គ្រប់គ្រងនៅត្រើយខាងលិចទន្លេសាប និងមេគង្គក្រោមដែលមានរាជវាំងនៅចតុមុខចាប់ពីឆ្នាំ១៤៧៨ និងព្រះស្រីសុរិយោទ័យត្រួតត្រាទឹកដីត្រើយខាងកើតទន្លេមេគង្គ ដែលមានរាជវាំងនៅទួលប៉ាសាន ត្រង់ទីតាំងវត្តស៊ីធរចាប់ពីឆ្នាំ១៤៧៧។ ការច្បាំងគ្នាឯងអូសបន្លាយតាំងពីឆ្នាំ១៤៧៥ ដល់១៤៨៥ និងបានសម្លាប់ខ្មែរគ្នាឯងអស់រាប់ម៉ឺននាក់។ ដើម្បីកុំឱ្យជីវភាពប្រជាជនជួបគ្រោះទុរ្ភិក្ស ព្រះបាទស្រីរាជាបបួលមេដឹកនាំពីរទៀតឱ្យផ្អាកសង្គ្រាមនៅរដូវបង្កបង្កើនផល និងសន្យាច្បាំងគ្នាជាថ្មីបន្ទាប់ពីប្រជាជនប្រមូលផលកសិកម្មរួច។ ប្រហែលគ្រោះមហន្តរាយធ្ងន់ធ្ងរនៃចម្បាំងនោះគឺការបំផ្លិចបំផ្លាញសម្ភារៈ និងជីវិតមនុស្សនៅរៀងរាល់រដូវប្រាំង។ នៅឆ្នាំ១៤៨៥ព្រះធម្មរាជាទៅពឹងសៀម ដើម្បីបញ្ចប់សង្គ្រាម និងដើម្បីសោយរាជ្យតែមួយអង្គឯងផង។ ព្រះធម្មរាជាបានចាត់រាជទូតដឹកនាំបណ្ណាការ

[133] ទី សុផល, ប្រវត្តិវិទ្យា, ដ.ឯ.ម., ទំព័រ១២១-១២៦។

សុទ្ធសឹងជាទ្រព្យមានតម្លៃ ទៅសុំចងមេត្រីភាពជាមួយព្រះចៅមហាចក្រពត្រាធិរាជស្ដេចក្រុងអយុធ្យា ដែលបានឆ្លើយតបជាវិជ្ជមាន និងបញ្ជូនទ័ពហែរក្បួនយ៉ាងគគ្រឹកគគ្រេងមកក្រុងចតុមុខ។

បន្ទាប់មកសេនាបតីខ្មែរ-សៀម បានរៀបចំក្បួនទ័ព ដើម្បីកម្ចាត់ព្រះស្រីរាជា និងព្រះស្រីសុរិយោទ័យ ដែលដំបូងពួកគេបានលើកទ័ពទៅព័ទ្ធបន្ទាយកំពង់សៀម។ ឧកញ៉ាក្រឡាហោមម៉ឹងបានចេញពីបន្ទាយ មកជួបស្ដេចសៀមនិងព្រះធម្មរាជាទូលអំពីបំណងព្រះបាទស្រីរាជាដែលសុំចងមេត្រីភាព និងជានានឹងគ្នាវិញ។ ស្ដេចទាំងពីរអង្គត្រេកអរយ៉ាងខ្លាំងក៏លើករេហ៍ពលមកតាំងបន្ទាយនៅឧដុង្គក្នុងខេត្តសំរោងទងវិញ។ ស្ដេចទាំងបីអង្គបានបញ្ជូនសារសូមយាងព្រះស្រីសុរិយោទ័យ ចូលទៅចរចាគ្នានៅបន្ទាយឧដុង្គ។ ព្រះអង្គមានបំណងបដិសេធ តែកូនចៅរបស់ទ្រង់មិនព្រមចេញច្បាំងតទៅទៀត ទើបបង្ខំព្រះទ័យឱ្យព្រះអង្គយល់ព្រមធ្វើតាមសំណើ។ ស្ដេចអយុធ្យាធ្វើជាចៅក្រមសម្របសម្រួលកិច្ចការចរចា។ ទំនាស់ត្រូវបានបញ្ចប់ តែស្ដេចសៀមបានទាមទារយកវិញនូវទឹកដីទាំងឡាយ ដែលព្រះបាទស្រីរាជាដណ្ដើមយកបានពេលមុន និងនាំព្រះបាទស្រីរាជានិងព្រះស្រីសុរិយោទ័យព្រមជាមួយសាច់ញាតិជិតដិតរបស់ព្រះអង្គយកទៅទុកនៅអយុធ្យា។ ដោយសារមានជំងឺឈឺចិត្តរួមរឹតព្រះបាទស្រីរាជាបានសុគតនៅឆ្នាំ១៤៨៥ ហើយព្រះស្រីសុរិយោទ័យក៏បានសុគតនៅឆ្នាំបន្ទាប់។ នៅកម្ពុជាព្រះស្រីធម្មរាជាបានធ្វើរាជាភិសេកឡើងសោយរាជ្យតែមួយអង្គឯង។

ក្រោយពីព្រះស្រីធម្មរាជាចូលទិវង្គតទៅ ព្រះស្រីសុគន្ធបទ ជាបុត្រាច្បងរបស់ព្រះបាទមហាធម្មរាជា បានឡើងសោយរាជ្យស្នងបិតាព្រះអង្គនៅឆ្នាំ១៥០៤។ ព្រះអង្គ បានលើករាជធានីមកតាំងនៅទួលប៉ាសាន ត្រង់វត្តស៊ីធរ ក្នុងឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលសព្វថ្ងៃ។ ក្រោយមកព្រះអង្គ តែងតាំងព្រះអនុជនាម ចន្ទរាជា ធ្វើជាឧបរាជតាំងមូលដ្ឋាននៅក្រុងចតុមុខមង្គលនាឆ្នាំ១៥០៨។ ដល់ចំណុចត្រង់នេះ យើងក្រឡេកទៅមើលពីប្រវត្តិសាស្ត្រដែលទាក់ទងនឹងកូនខ្មែរ មានកំណើតក្នុងត្រកូលវណ្ណៈពលរតនត្រ័យវិញម្ដង។

ក្នុងពង្សាវតារ និងស្នាដៃនិពន្ធជាច្រើនដែលបានរៀបរាប់ព្រះស្ដេចកន។ ដែលប្រភពព័ត៌មានទាំងនោះទាមទារឱ្យអ្នកសិក្សាស្វែងយល់ព័ត៌មានបន្ថែម ដើម្បីសិក្សាប្រៀបធៀបទៅលើប្រភពឯកសារទាំងនោះផងដែរ។ ឯកសារដែលរៀបរាប់ទាក់ទងនឹងរឿងនេះមានដូចជាពង្សាវតារP.3, ពង្សាវតារវត្តសិត្បូរ, ពង្សាវតារនុប្បរ័ត្ន, ឯកសារមហាបុរសខ្មែរ, ព្រះស្ដេចកន(ដោយរស់ចន្ត្រាបុត្រ), អាដឺម៉ាឡឺក្លែរ, សូរ អឿ និងលោក ឱម ណាគ្រី ក្នុងឆ្នាំ១៩៥៥ ជាដើម។ ការកត់ត្រាជាហូរហែរក្នុងពង្សាវតារខ្មែរថាកនគឺជាជនក្បត់ស្ដេច ឬ ជាព្រះមហាក្សត្រជ្រែករាជ្យ។ ប៉ុន្តែ បើតាមសៀវភៅព្រះស្ដេច កន របស់បណ្ឌិតសភាចារ្យ រស់ ចន្ត្រាបុត្រ អាចសម្គាល់បានថាព្រះស្ដេចកន គឺជាកូនខ្មែរមានដើមកំណើតក្នុងត្រកូលវណ្ណៈព្រះរតនត្រ័យ មិនមែនជាជនក្បត់ស្ដេច ឬ ព្រះមហាក្សត្រជ្រែករាជ្យ ដូចដែលគេតែងតែនិយាយពីមាត់មួយ ទៅមាត់មួយនោះទេ។ ចំពោះការលើកឡើងក្នុងចំណុចនេះ គឺបង្ហាញថាសង្គ្រាមក្នុងស្រុកដែលកើតពីការមិនទុកចិត្តគ្នាក្នុងរឿងរាជ្យសម្បត្តិ បានចំណាយធនធានមនុស្សដើម្បីធ្វើសង្គ្រាមដែលនាំឱ្យប្រទេសចុះទន់ខ្សោយ និងបង្ហាញពីការខិតខំកសាងជាតិឡើងវិញដើម្បីឱ្យមានសម្បូរសប្បាយរុងរឿង។

ក្នុងប្រវត្តិសាស្ត្រខ្មែរសង្គ្រាមផ្ទៃក្នុងនៃការដណ្ដើមរាជ្យបានកើតឡើងក្រោយឆ្នាំ១៤៧៥ រហូតដល់ ១៥២៥។ នៅឆ្នាំ១៥០៤ ព្រះបាទស្រីសុគន្ធបទដែលជាបុត្រច្បងរបស់ព្រះបាទធម្មរាជាបានឡើងគ្រងរាជ្យបន្ត ដែលរាជធានីតាំងនៅស្រីសន្ធរ។ ចំណែក ចន្ទរាជាជាសម្ដេចព្រះអនុជ ស្ដេចគង់នៅព្រះបរមរាជវាំងចតុមុខ។ នៅវាំងទួលប៉ាសាន ព្រះបាទស្រីសុគន្ធបទបានសព្វហឫទ័យជាមួយនាងពៅ ឬ ស ដែលក្រោយមកនាងក្លាយជាស្នំឯក។ ចំណែកឯ ឪពុកនាងពៅ ព្រះរាជាបានតម្លើងបុណ្យប្រទានងារជាព្រះពិជ័យនាគ។ ឯ

ម្តាយគឺនាងបាន ទទួលឋានៈជាអ្នកម៉ែបាន ហើយប្អូនប្រុស ឈ្មោះកន ព្រះរាជាប្រទានតំណែងជាមន្ត្រីរាជការឱ្យមកបម្រើព្រះអង្គ។ នាយកន ជាយុវជនដែលមានចំណេះដឹង និងជំនាញយុទ្ធសាស្ត្រ ត្រូវបានព្រះរាជាតែងតាំងជាមេទ័ពនិងបានឡើងឋានន្តរស័ក្តិរហូតជាឃុនហ្លួងព្រះស្តេច។ ប៉ុន្តែឯកសារពង្សាវតារផ្សេងទៀតបានបញ្ជាក់ថាបុណ្យស័ក្តិ និងអំណាចថ្មីថ្មោងនេះ បានធ្វើឱ្យឃុនហ្លួងព្រះស្តេចកន មានចិត្តព្រហើនកោងកាច មិនកោតក្រែងនាហ្មឺនមន្ត្រីចាស់ទុំ តូចធំ។ គ្រានោះ ព្រះស្រីសុគន្ធបទសុបិនឃើញនាគធំមួយមានឫទ្ធិមហិមា មកដេញព្រះអង្គ និងមនុស្សម្នារត់ចេញអស់ពីព្រះរាជវាំងហើយព្រួសពិសដាក់ព្រះនគរ។ អំណាចភ្លើងនោះក្តៅពន់ប្រមាណ ឃើញហាក់ដូចជានាគនោះស្ទុះចូលមកខាំស្វេតច្ឆ័ត្រ នាំទៅកាន់ទិសបូណ៌។ ជាមួយគ្នានោះថៅហ្វាយស្រុកបាត់ដំបង, ថៅហ្វាយស្រុកពោធិ៍សាត់, ថៅហ្វាយស្រុកបាទី, ថៅហ្វាយស្រុកបាភ្នំ សុទ្ធតែបានផ្ញើសំបុត្រមកកាន់ព្រះរាជវាំងបង្ហាញពីគ្រោះ និងប្រផ្នូលមិនល្អផងដែរ។ ដោយការព្រួយព្រះទ័យ ព្រះរាជាក៏រកឧបាយដើម្បីសម្លាប់ហ្លួនព្រះស្តេច។

ដើម្បីការពារខ្លួនផងនោះហ្លួងព្រះស្តេចត្រូវតែក្បត់ជាមួយព្រះរាជា។ ក្រោយមកហ្លួងព្រះស្តេច ក៏បានប្រើឧបាយប្រមូលការគាំទ្រខ្លួនគឺប្រើប្រាស់សកម្មភាពការទូតរបស់ព្រះបាទស្រីសុគន្ធបទជាមួយខ្លួន សម្រាប់បំភ័ន្តភ្នែកសាធារណមតិ និងបញ្ឆោតព្រះរាជា។ ហ្លួងព្រះស្តេចកន បញ្ជាក់ថាខ្លួនទទួលបញ្ជាពីព្រះរាជាដើម្បីកម្ចាត់ចន្ទរាជា ដែលមានចិត្តក្បត់។ ដំណឹងនេះបានឮដល់ព្រះចន្ទរាជា ទ្រង់ក៏បានភៀសព្រះកាយទៅស្រុកសៀមបាត់ទៅ។ បន្ទាប់មកហ្លួងព្រះស្តេចក៏បានវាយចូលទួលប៉ាសាន។ ចុងក្រោយព្រះស្រីសុគន្ធបទ ត្រូវក្រុមហ្លួងព្រះស្តេចធ្វើគុតនៅបន្ទាយស្ទឹងសែននាឆ្នាំ១៥១២។

ចំណែកហ្លួងព្រះស្តេចកនក៏បានឡើងសោយរាជ្យនៅទួលប៉ាសានដោយទទួលព្រះបរមនាមថា «ព្រះស្រីជេដ្ឋាធិរាជរាមាធិបតី»។ រហូតមកដល់ឆ្នាំ១៥១៤ ទ្រង់ក៏បានលើករាជធានីមកកាន់ក្រុងស្រឡប់ពិជ័យព្រៃនគរ វិញ[134]។ នៅក្នុងរជ្ជកាលព្រះអង្គគឺមានការបោះប្រាក់ស្លឹង[135]ប្រើប្រាស់ ហើយប្រទេសជាតិក៏មានភាពសម្បូរសប្បាយ។ ចំណែកព្រះបាទចន្ទរាជា ដែលរត់ទៅស្រុកសៀម ក៏បានរកឧបាយត្រឡប់មកស្រុកវិញដើម្បីសងសឹកជាមួយហ្លួងព្រះស្តេច។ ក្រោយមកធាកប្រយុទ្ធរវាងចន្ទរាជា និងហ្លួងព្រះស្តេចបានកើតឡើងហើយត្រូវបញ្ចប់នៅឆ្នាំ១៥២៥ដោយព្រះចន្ទរាជាអាចយកជ័យជម្នះលើហ្លួងព្រះស្តេច។ ពង្សាវតារជាច្រើនច្បាប់បានអះអាងពីជោគវាសនារបស់ស្តេចកនខុសៗពីគ្នា។ ច្បាប់ខ្លះបានបញ្ជាក់ថាហ្លួងព្រះស្តេចកនត្រូវបានសម្លាប់នៅក្នុងសង្គ្រាម។

## ៦-សំណួរត្រិះរិះ

១-តើមានភស្តុតាងអ្វីខ្លះបញ្ជាក់ពីការរស់នៅរបស់មនុស្សក្នុងតំបន់នេះ មុនសម័យចតុមុខ ?

២-តើខ្មែរសម័យចតុមុខបានធ្វើអ្វីខ្លះ ដើម្បីបន្តវិភាពពីសម័យអង្គរ ?

៣-ហេតុអ្វីបានជាព្រះស្រីរាជាមិនអាចរំដោះខេត្តខាងលិចពីសៀមមកវិញបាន ?

៤-ហេតុអ្វីបានជាប្រទេសខ្មែរសម័យចតុមុខចែកជាបីអាណាចក្រ ?

៥-តើវិបត្តិរាជវង្សបានផ្តល់ផលវិបាកអ្វីខ្លះដល់សង្គម និងប្រជារាស្ត្រខ្មែរ ?

---

134 ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ(សម្រាប់មធ្យមសិក្សា និងឧត្តមសិក្សា)*, ភាគ២, ដ.ឯ.ម., ទំព័រ១៥-១៦។

135 សិលាចារឹកប្រាសាទព្រះគោឆ្នាំ៨៩១គ.ស.(K.314) គេរៀបរាប់តង្វាយចំពោះព្រះអម្ចាស់អញដ៏បរមេស្វរៈ(ព្រះបាទជយវម៌្មទី២) រៀងរាល់ថ្ងៃមានអង្ករ៤លិះ ភាជន៍មួយទម្ងន់៤ជញ្ជីង ១៣តំលិង(សរុប៩៣តំលឹង) ១បាទ(និង) ១«ស្លិង» (និង) ក្អមមួយទម្ងន់១០ជញ្ជីង(២០០តំលឹង)។

# មេរៀនទី៦ សម័យលង្វែក និងការលើកតម្កើងវប្បធម៌ជាតិ(១៥២៩ ដល់១៦១៩)

## ១-ព្រះបាទចន្ទរាជា និងការកសាងរាជធានីលង្វែក

ព្រះបាទចន្ទរាជា[136] បានកសាងបន្ទាយក្រុងលង្វែករួចរាល់នៅឆ្នាំ១៥២៩។ បន្ទាយ ឬ ក្រុងលង្វែកជាចំណុចយុទ្ធសាស្ត្រ មានទន្លេ បឹង និងព្រៃឈើជារបាំង។ បន្ទាយនេះមានរាង៤ជ្រុង បណ្តោយ៣គីឡូម៉ែត្រ និងទទឹង២គីឡូម៉ែត្រ កំពែងដីកម្ពស់១៥ហត្ថ (៧.៥ម៉ែត្រ)ដែលហ៊ុមព័ទ្ធដោយគូទឹក និងដាំដើមឫស្សីកម្រាស់៨០ម៉ែត្រនៅពីក្រៅ។ បន្ទាយលង្វែកមានទ្វារធំ៤នៅទិសធំទាំង៤ និងទ្វារតូច៤ នៅចំជ្រុងនៃទិសតូចទាំង៤ មានជីកស្រះធំៗ៤ នៅគ្រប់ទិស ហើយមានចិញ្ចឹមត្រី និងមានសង់ឃ្លាំង១៥ខ្នងសម្រាប់ដាក់ស្រូវ, អង្ករ, ត្រីងៀត ត្រីឆ្អើរ និងប្រហុកជាដើម។ ព្រះចន្ទរាជាបានបញ្ជាឱ្យកសាងព្រះត្រឡែងកែង (ព្រះបែរភ័ក្ត្រទៅទិសទាំង៤ទល់ខ្នងគ្នា) និងវត្តអារាមមួយចំនួនក្នុងក្រុងលង្វែក។ ចំណែកនៅក្នុងបន្ទាយនោះ មានព្រះគោ ព្រះកែវដែលផ្ទុកដោយក្បួនតម្រារបស់ខ្មែរ ផងដែរ[137]។ បន្ទាយនេះសង់នៅលើរចនាសម្ពន្ធក្រុងចាស់ ហើយនៅជាប់ទន្លេចតុមុខ[138] ដែលជាភូមិសាស្ត្រដ៏ពិសិដ្ឋសម្រាប់រាជធានី។ នៅក្នុងសិលាចារឹកវត្តរំលក(K.27) នៅស្រុកអង្គរបុរីខេត្តតាកែវបានបង្ហាញពីឈ្មោះក្រុង«លង្វែក»ដំបូងគេក្នុងសហសម័យតាមអក្ខរាវិរុទ្ធមួយ ដែលអ្នកស្រាវជ្រាវជនជាតិបារាំងបានទទួលយកមកសរសេរដំបូងគឺ«លវែក(Lovek)»[139]។

## ២-ការអភិវឌ្ឍប្រទេស

នៅក្នុងសម័យលង្វែក អតីតរាជធានីចតុមុខនៅបន្តតួនាទីជាមជ្ឈមណ្ឌលជំនួញ និងជាទីប្រជុំជនដែលមានមនុស្សរស់នៅច្រើនកុះករ ដែលជាកម្លាំងជំរុញផ្នែកសេដ្ឋកិច្ចសម័យលង្វែក។ ចំណែក សៀន[140] និងអយុធ្យាបានលូតលាស់ ជាមជ្ឈមណ្ឌលពាណិជ្ជកម្មតាមសមុទ្រអន្តរជាតិ គេបានប្រកួតប្រជែងគ្នាជាមួយភូមា និងកម្ពុជា។ វីរបុរសខាងយោធានៃសន្តតិវង្សសុខោទ័យថ្មីនៅអយុធ្យាគឺនរេសូរ បានចាប់អារម្មណ៍នៅក្នុងធានីថ្មី លង្វែក និងការត្រួតត្រាផ្លូវទន្លេខាងត្បូងទៅសមុទ្ទ[141]។ នៅក្នុងសតវត្សរ៍ទី១៧ អង់គ្លេស និងហូឡង់ កាន់តែមានការចាប់អារម្មណ៍នៅក្នុងប្រទេសជីគោក។ ដំបូងពួកគេបានទៅកាន់ ប៉ាតានី[142] ហើយបន្ទាប់មកបានបង្កើតការិយាល័យពាណិជ្ជកម្មនៅអយុធ្យា។ នៅក្នុងទស្សវត្សរ៍ឆ្នាំ១៦២០ ជនជាតិហូឡង់ដំបូងគេបានមកកាន់កម្ពុជា ហើយពួកគេជាពាណិជ្ជករដ៏សំខាន់នៅកម្ពុជា នៅពាក់កណ្តាលសតវត្សរ៍ទី១៧[143]។

វិស័យពាណិជ្ជកម្មទន្លេមេគង្គជាផ្លូវទឹកដ៏សំខាន់សម្រាប់ដឹកនាំទំនិញ យកទៅលក់ឯបរទេស។ វិស័យពាណិជ្ជកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ព្រះបាទបរមរាជាបានធ្វើទំនាក់ទំនងជាមួយ ពួកអឺរ៉ុប, ជប៉ុន, ចិន

---

[136] ព្រះបាទចន្ទរាជា មានជំនឿទៅលើព្រះពុទ្ធសាសនាយ៉ាងមុតមាំ។ ទេពរ័ក្សទាំងអស់ត្រូវបានព្រះបាទចន្ទរាជា ព្រះឱ្យមានជីវិតឡើងវិញ ដើម្បីជាវត្ថុស័ក្តិសិទ្ធិក្នុងព្រះនគរ ហើយទ្រង់ជាព្រះរាជាដំបូងក្រោយសង្គមអង្គរដែលបានយកចិត្តទុកដាក់ថែរក្សាវប្បធម៌ ជាតិ និងក្បួនច្បាប់នោះ។

[137] G.Janneau, *Manue de Langue cambodgienne(ក្បួនសំណេរខ្មែរ),* Sigion, 1874, p.243.

[138] បើយើងមើលនឹងភ្នែកពេលបច្ចុប្បន្ន នឹងឃើញជាត្រីមុខ។

[139] សូមមើលៈ វង់ សុធារ៉ា, *សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល,* ដ.ឯ.ម.,ទំព័រ១៥៨។

[140] ក្នុងកំណត់ហេតុចិនដំបូងទាក់ទងនឹង សៀន គឺចិនបានប្រើប្រាស់ឈ្មោះ សៀន ដើម្បីសម្គាល់តំបន់ទឹកដីថៃ ចាប់ពីអយុធ្យា ទៅដល់ពាមទន្លេមេណាម ជាឈ្មោះសម្រាប់រដ្ឋដែលស្ថិតនៅចំកណ្តាលក្រុងអយុធ្យា និងបាងកក។ សៀន មិនមែនជាថៃ នៅពេលនោះទេ(សូមមើលៈ ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ៩៦)។

[141] សូមមើលៈ ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ១០៥។

[142] នៅតាមឆ្នេរសមុទ្រខាងកើតឧបទ្វីបថៃ។

[143] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ១០៩។

និងថ្លា ជាដើមឱ្យមកធ្វើជំនួញនៅស្រុកខ្មែរយ៉ាងច្រើនសន្ធឹកសន្ធាប់។ ពួកនេះបាននាំទំនិញដូចជាកំណាត់សំពត់ ឧបករណ៍ប្រើប្រាស់ផ្សេងៗ ហើយនាំចេញទៅវិញនូវគ្រឿងទេស ភ្លុកដំរី ស្នែង ជ័រ ស្បែក ជាដើម។ បើយោង ទៅតាមលទ្ធផលកំណាយដំបូងៗនៅលង្វែក គេបានឃើញបំណែកកុលាលភាជន៍យ៉ាងសន្ធឹកសន្ធាប់ ដែលមានប្រភពមកពីចិន, ជប៉ុន និងអាស៊ីអាគ្នេយ៍[144]។ បើយោងតាមអ្នកបុរាណវិទូ និងអ្នកស្រាវជ្រាវកម្ពុជា អន្តរជាតិមកពីប្រទេសអូស្ត្រាលី និងជប៉ុន បានរកឃើញថាកម្ពុជានៅដើមសម័យកណ្តាល មានទំនាក់ទំនងស៊ីជម្រៅជាមួយពាណិជ្ជកម្មប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអឺរ៉ុប។ គេបានរកឃើញអ្វីដែលសំខាន់ និងលើសពីឯកសារពង្សាវតារខ្មែរកន្លងមក គឺទាក់ទងនឹងជំនួញ កុលាលភាជន៍ (ភាជន៍ដី, ចាន, ផ្តាំង ឬ ក្អមដែលធ្វើដោយដី)។ តាមរយៈបំណែកភាជន៍ទាំងនោះធ្វើឱ្យយល់កាន់តែច្បាស់អំពី ពាណិជ្ជកម្មរបស់អាស៊ីអាគ្នេយ៍នៅលង្វែក។ បន្ទាប់ពីការឈប់ធ្វើសិប្បកម្ម ក៏ដូចជាភាជន៍នៅសម័យអង្គរ និងលង្វែក ទទួលបានរំហូរពាណិជ្ជកម្មពីក្នុងតំបន់ផង និងពីប្រទេសផ្សេងៗ ពិសេសប្រទេសជិតខាង។ ចំពោះការប្រើប្រាស់គឺមនុស្សធម្មតា ក៏ប្រើភាជន៍ចិនដែរ ប៉ុន្តែនៅសម័យលង្វែក អ្នកប្រើភាជន៍ចិន ភាគច្រើនជាអ្នកមានបណ្តាយសសក្តិ ឬ មន្ត្រីធំៗ ហើយមិនមែនរកឃើញតែភាជន៍មកពីចិនទេ ក៏មានភាគមកពី ថៃ វៀតណាម ជប៉ុនផងដែរ។ យើងក៏បានដឹងតាមរយៈកំណត់ត្រាឯកសាររបស់ចិន, ជប៉ុន, ម៉ាឡេស៊ី, ខាងអឺរ៉ុប, អេស្ប៉ាញ, អង់គ្លេស និង បារាំងជាដើម ថាធ្លាប់មានទំនាក់ទំនង និងបានរស់នៅ នៅលង្វែក។ ភាជន៍មានលក្ខណៈពិសេសឱ្យដឹងពីការប្រមូលផ្តុំអាស៊ីអាគ្នេយ៍ បង្ហាញថាលង្វែកមានតួនាទីសំខាន់ក្នុងការភ្ជាប់ពាណិជ្ជកម្មក្នុងតំបន់។ ជំនួញសមុទ្រនៅសម័យកណ្តាល ជាឱកាសសេដ្ឋកិច្ចភ្ជាប់ជំនួញអន្តរជាតិដែលអាចកំណត់ថាកម្ពុជាជាមជ្ឈដ្ឋានពាណិជ្ជកម្មពិភពលោក[145]។

វិស័យកសិកម្ម គឺសំខាន់ណាស់សម្រាប់សេដ្ឋកិច្ចជាតិ ដែលមានការយកចិត្តទុកដាក់តាំងពីសម័យអង្គរមកម្ល៉េះ។ នៅក្នុងសម័យលង្វែកក៏បានការយកចិត្តទុកដាក់ទៅលើការជីកអូរ, ប្រឡាយ, ព្រែក និងការ ផ្គត់ផ្គង់ទឹកសម្រាប់វិស័យកសិកម្ម។ សិប្បកម្មនៅមានការអន់ថយនៅឡើយ ហើយសកម្មភាពសំខាន់ក្នុងសម័យនោះ គឺការស្លដែកដែលមានសន្ទុះខ្លាំងក្លាចាប់ពីរជ្ជកាលព្រះបាទចន្ទរាជា ព្រោះព្រះអង្គបានយកព្រះទ័យទុកដាក់នឹងបញ្ហានេះណាស់។ ចំណែកពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរ ហើយសិល្បៈខ្មែរច្រើនមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសាសនា។ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ហើយព្រះសង្ឃមានវេនាសម្ពន្ធ និងច្បាប់ដោយឡែកមួយសម្រាប់ព្រះសង្ឃ។ សង្គមខ្មែរលែងងាកទៅរកព្រាហ្មណ៍ ហើយវត្តអារាមមានការកើនឡើងជាលំដាប់។ ព្រះមហាថេរដែលមាននាទីមើលការខុសត្រូវលើការរៀបចំសាសនា និងលើវត្តអារាមនៅក្នុងខេត្តនីមួយៗលែងមានលទ្ធភាពគ្រប់គ្រងបន្តទៅទៀតហើយ។ ដោយហេតុនោះសម្តេចព្រះសង្ឃរាជ ដោយមានការព្រមព្រៀងជាមួយរាជាគណៈ និងឋានានុក្រម ដូចជា មេគណៈ, រាជាគណៈ និងសម្តេចព្រះសង្ឃរាជ។ ចំពោះសាសនាគ្រិស្តដែលបានផ្សព្វផ្សាយដោយពួកព័រទុយហ្គាល់ និងអេស្ប៉ាញ[146]ក្នុងប្រទេសខ្មែរត្រូវបានបរាជ័យគ្រប់ពេលវេលា។ ត្រង់ចំណុចនេះបង្ហាញថាអ្នកស្រុកមានភក្តីភាពចំពោះព្រះរាជា និងព្រះសង្ឃ។

---

[144] បាប់កថា: *ស្រាវជ្រាវរកទេ្វង់ទ្រាយលង្វែកដោយសិក្សាតាមលទ្ធផលកំណាយដំបូង* មហាវិទ្យាល័យបុរាណវិទ្យា នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨។

[145] កម្ពុជាថ្មី: *រាជធានីលង្វែកមានទំនាក់ទំនងស៊ីជម្រៅជាមួយពាណិជ្ជកម្មពិភពលោក*, ចុះផ្សាយថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ ( https://www.kampucheathmey.com/belief/461889 )។

[146] លោកផ្សព្វផ្សាយសាសនាគ្រិសជនជាតិព័រទុយហ្គេ(ព័រទុហ្កាល់) គឺលោក ប៉ាទ្រី (បព្វជិតកាតូលិក) និងហ្គាស្ប៉ារ ដាគ្រុស(Gaspar da Cruz) បានមកទស្សនារាជធានីលង្វែក នៅចុងរាជ្យនៃព្រះចន្ទរាជាឆ្នាំ១៥៥៦។

នៅសម័យលង្វែក ព្រះពុទ្ធសាសនាធំៗជាច្រើន ដែលត្រូវបានគេជឿថា ជាស្នាព្រះហស្តរបស់ព្រះបាទចន្ទរាជា ដែលមួយនៅឧដុង្គ និងមួយទៀតនៅវត្តត្រឡែងកែង ព្រះពុទ្ធផ្ទុំនៅអង្គរ និងសំណង់មួយចំនួនទៀតដែលបានកសាងបន្ថែមនៅប្រាសាទវត្តនគរនៅក្នុងខេត្តកំពង់ចាម[147]។ អក្សរសិល្ប៍សម័យលង្វែក មានការរីកចម្រើនផងដែរ។ តាមការសិក្សាស្រាវជ្រាវបានបង្ហាញថា អត្ថបទអក្សរសិល្ប៍នាសម័យលង្វែកមានពីរប្រភេទគឺ សិលាចារឹក និងសាស្ត្រាល្បែង។

## ៣-លង្វែក និងមជ្ឈមណ្ឌលវប្បធម៌

ជនជាតិអឺរ៉ុបត្រូវការគ្រឿងទេសខ្លាំងឡើងៗ ហើយពួកនេះធ្លាប់ទិញបន្តពីឈ្មួញអារ៉ាប់ក្នុងតម្លៃខ្ពស់។ នៅតំបន់អាស៊ីអាគ្នេយ៍គ្រឿងទេសដែលសំខាន់មានដូចជាផ្កាក្លាំពូ និងចន្ទន៍ក្រិស្នា ដែលដុះតែតាមកោះនៅឥណ្ឌូណេស៊ី[148]។ ក្រុមអ្នកផ្សព្វផ្សាយសាសនា ក៏បានធ្វើសកម្មភាពខ្លាំងដែរនាពេលនោះ។ ពួកគេបានធ្វើដំណើរទៅតំបន់នានានៅជុំវិញពិភពលោក ដើម្បីបុព្វហេតុសាសនា ផ្សេងៗគ្នារបស់ពួកគេ (ភាគច្រើនជានិកាយផ្សេងៗ គ្នាក្នុងសាសនា គ្រិស្ត)[149]។ ចំណែកក្រុមអ្នកផ្សងព្រេងជាផ្នែកមួយនៃទាហានអឺរ៉ុបដែលបានចាកចេញពីក្រុមរបស់ពួកគេដោយសារបុព្វហេតុផ្សេងគ្នាៗ ហើយបានដើរផ្សងព្រេងជាក្រុម ឬ តែម្នាក់ឯង ទៅស៊ីឈ្នួលបម្រើស្តេចនៅតាមរដ្ឋនានានៅតំបន់អាស៊ីអាគ្នេយ៍[150]។ ក្រុមនេះឯងដែលនាំរបៀបប្រើកាំភ្លើងធំ ហើយត្រូវស្តេចតំបន់នេះទុកជាអ្នកជំនាញ[151]។

## ៤-ការទំនាក់ទំនងរវាងកម្ពុជា-អឺរ៉ុប

នៅសម័យលង្វែក ជាសម័យកាលមួយដែលមានវត្តមានជនជាតិអឺរ៉ុប ចូលមកកម្ពុជាជាបន្តបន្ទាប់ ហើយមានមូលហេតុជាច្រើន នៃវត្តមានដែលជនជាតិអឺរ៉ុប ដែលបានធ្វើដំណើរមកកាន់តំបន់នេះមានច្រើនរូបភាព។ ជនជាតិអឺរ៉ុបដំបូងគេដែលមកដល់ប្រទេសកម្ពុជា គឺជាស្ប៉ាជាគ្រុស នៅឆ្នាំ១៥៥៥ ដល់ឆ្នាំ១៥៥៧ ក្នុងរាជ្យព្រះអង្គចន្ទ។ ក្រោយមកមានបព្វជិតដទៃទៀតបានមកដល់ប្រទេសកម្ពុជាជាបន្តបន្ទាប់។ នៅឆ្នាំ១៥៧០ មានបព្វជិតព័រទុយហ្កាល់ ម្នាក់ប្រទះឃើញប្រាសាទអង្គរវត្ត។ ការផ្សព្វផ្សាយសាសនារបស់ពួកអឺរ៉ុបនាពេលនោះ មិនបានទទួលជោគជ័យព្រោះប្រជាជនខ្មែរមានជំនឿមុតមាំលើព្រះពុទ្ធសាសនា។ នៅឆ្នាំ១៥៨៥ មានជនជាតិព័រទុយហ្កាល់ វ័យក្មេង ឈ្មោះវេឡូសូ និងរូហ្ស មកដល់ប្រទេសកម្ពុជា។ ពួកគេបានដើរតួនាទីយ៉ាងសំខាន់មួយក្នុងរាជ្យព្រះសត្ថាទី១។ រហូតដល់សតវត្សរ៍ទី១៧ បានទើបមានជនជាតិអឺរ៉ុប ផ្សេងទៀត ជាពិសេសពួកហូឡង់ មកដល់ប្រទេសកម្ពុជាដើម្បីបុព្វហេតុសាសនា និងជំនួញ។ ប្រហែលដើម្បីបង្ហាញកិត្យានុភាពក្នុងទំនាក់ទំនងជាមួយពួកអឺរ៉ុប និងគ្រប់គ្រងលើផ្លូវនាវាចរណ៍សមុទ្ទ ដែលកាន់តែសកម្មឡើង ទើបបណ្តាស្តេចនៅភូមា, អយុធ្យា និងកម្ពុជាមានសង្គ្រាមជាមួយគ្នាកាន់តែញឹកញាប់។ ចាប់តាំងពីមានវត្តមាននៃពួកអឺរ៉ុបមកដល់អាស៊ីអាគ្នេយ៍ សម្ទុះពាណិជ្ជកម្មកើនឡើងតំណាលគ្នានឹងសង្គ្រាមក្នុងតំបន់។ គួរឱ្យកត់សម្គាល់ថា នៅពេញស.វទី១៦ ភូមា, សៀម និងកម្ពុជាមានសង្គ្រាមជាមួយគ្នាយ៉ាងញឹកញាប់។ ប្រទេសនីមួយៗខិតខំប្រឹងប្រែងវាតទីយកទឹកដី ប្រជាជន និងបំផ្លាញសត្រូវ។ នៅពេលសៀមវាយប្រហារខ្មែរ ឬ ខ្មែរវាយប្រហារសៀម តែងតែ

[147] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ១០៣។

[148] ម៉ាយឃើល វីឃើរី, *ប្រវត្តិសាស្ត្រតំបន់*, ដ.ឯ.ម., ទំព័រ១០៧។

[149] ដេវីឌ ឆាណ្ឌល័រ, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ៩៥។

[150] អាដេម៉ា ឡឺក្លែ, *ប្រវត្តិសាស្ត្រកម្ពុជា*, ដ.ឯ.ម., ទំព័រ២៧៩-២៨០។

[151] ម៉ាយឃើល វីឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា* ដ.ឯ.ម., ទំព័រ២០០-២០១។

ប្រើកងទ័ពជើងទឹក និងជើងគោក។ វត្តមានកងទ័ពជើងទឹកទាំងនេះប្រហែលប្រើក្នុងន័យគ្រប់គ្រងលើផ្លូវពាណិជ្ជកម្មសមុទ្ទ។ មុនពេលសៀមលើកទ័ពវាយក្រុងលង្វែក មានជនជាតិអឺរ៉ុបជាច្រើនមកដល់ប្រទេសកម្ពុជា និងអយុធ្យា។ ជនជាតិអឺរ៉ុបផ្សងព្រេង ឈ្មោះ វេឡូសូ និងរូហ្ស ទទួលបានការសព្វព្រះទ័យពីព្រះមហាក្សត្រខ្មែរ (ព្រះសត្ថា) ហើយគាត់បានស្វែងរកឱ្យជំនួយកងទ័ពឱ្យកម្ពុជានៅពេលសៀមវាយក្រុងលង្វែក។ ប៉ុន្តែត្រូវបរាជ័យព្រោះគាត់មកដល់យឺតពេល ក្រុងលង្វែកត្រូវសៀមវាយបែក ហើយក្សត្រថ្មីឡើងគ្រងរាជ្យ។ ពួកអឺរ៉ុបក៏បានលូកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជាផងដែរ ។ វេឡូសូ បានធ្វើគុតស្តេចរាមាជើងព្រៃ និងបានយាងព្រះអង្គចន្ទដែលជាបុត្រព្រះសត្ថាពីស្រុកឡាវមកសោយរាជ្យនៅកម្ពុជាវិញ។ វេឡូសូ និងរូហ្ស ត្រូវបានតែងតាំងជាចៅហ្វាយខេត្តបាភ្នំ និងខេត្តទ្រាំង។ ក្រោយមានគាត់ទៅបង្ក្រាបជនបះបោរក្នុងខេត្តត្បូងឃ្មុំ ហើយត្រូវក្រុមបះបោរសម្លាប់ចោលទាំងពីរនាក់ ។ នៅឆ្នាំ១៦០៣ មានជនជាតិអឺរ៉ុបដទៃទៀតដូចជា ពួកអេស្ប៉ាញ ពេលនោះមានមូលដ្ឋាននៅក្រុងម៉ានីល (ហ្វីលីពីនសព្វថ្ងៃ) ចាប់ផ្តើមទំនាក់ទំនងជាមួយខ្មែរ។ ស្តេចអង្គនេះជួយជ្រោមជ្រែងពួកគេណាស់ ទ្រង់អនុញ្ញាតពួកគេផ្សព្វផ្សាយសាសនា និងឧបត្ថម្ភពួកគេក្នុងការកសាងព្រះវិហារ។ ប្រហែលជាដោយសារទ្រង់ចង់ឱ្យពួកគេជួយ ក្នុងពេលប្រទេសកម្ពុជាមានចលាចល និងសង្គ្រាមប្រឆាំងព្រះស្រីសុរិយោពម៌ដែលមានសៀមគាំទ្រ។ តែយើងឃើញថានៅពេលព្រះស្រីសុរិយោពម៌ទទួលជ័យជម្នះ និងគ្រប់គ្រងប្រទេសទ្រង់មិនចូលចិត្តអ្នកផ្សព្វផ្សាយសាសនាទាំងនេះទេ ហើយទ្រង់បានបញ្ជូនពួកគេទៅឱ្យស្តេចសៀមនរេសូរ។ ប្រហែលជាដោយសារឥទ្ធិពលប្រទេសក្នុងតំបន់, វិបត្តិរាជវង្ស និងវិបត្តិផ្ទៃក្នុង ទើបធ្វើឱ្យក្រុងលង្វែកមិនអាចបន្តនិរន្តរភាពបាន។ យើងឃើញថាព្រះបាទសត្ថាទី១ លើករាជ្យសម្បត្តិទៅឱ្យកូននៅវ័យក្មេង (ព្រះជយជេដ្ឋាទី១) ធ្វើឱ្យបណ្តានាម៉ឺនមន្ត្រី ប្រជានុរាស្ត្រមិនពេញចិត្ត ជាហេតុនាំឱ្យបាត់បង់ស្មារតីប្រយុទ្ធទប់ទល់សត្រូវដោយសារទ្រង់ខ្លាចអំណាចបានទៅព្រះស្រីសុរិយោពម៌។ ប្រទេសខ្មែរបែកបាក់សាមគ្គី ហើយព្រះសត្ថាទី១នាំគ្រួសារភៀសព្រះកាយទៅប្រទេសឡាវ ដែលធ្វើឱ្យរាស្ត្រអស់ជំនឿចិត្ត។

## ៥-ការបែកបាក់ក្រុងលង្វែក និងផលវិបាក

ព្រះសត្ថាទី១[152]ជាក្សត្រទន់ខ្សោយ និងមានព្រះទ័យច្រណែនចំពោះព្រះស្រីសុរិយោពម៌[153]ដោយសារតែខ្លាចប្រជាប្រិយភាពរបស់ព្រះបាទស្រីសុរិយោពម៌ ដែលជាព្រះឧភយោរាជមានពលរដ្ឋស្រលាញ់គាំទ្រច្រើន។ នៅឆ្នាំ១៥៨៦ ព្រះសត្ថាបានលើកព្រះរាជបុត្ររបស់ទ្រង់ដែលមានព្រះជន្មក្មេងវស្សា(១១វស្សា) ឱ្យឡើងសោយរាជ្យសម្បត្តិ និងរាជបុត្រទី២ (ចៅ ពញាតន់) ដែលមានព្រះជន្ម៦ វស្សាធ្វើជាមហាឧបរាជ[154]។

ការដែលព្រះអង្គដាក់រាជ្យសម្បត្តិ ហើយលើកព្រះបាទជយជេដ្ឋាឱ្យឡើងសោយរាជ្យសម្បត្តិនេះបានធ្វើឱ្យព្រះឧភយោរាជ និងនាម៉ឺនសព្វមុខមន្ត្រីជាច្រើនមានការអាក់អន់ស្រពន់ចិត្តជាខ្លាំងពីព្រោះ បើតាមទំនៀមបុរាណគឺពួកនេះឯងដែលជាអ្នកមានសិទ្ធិក្នុងការជ្រើសតាំងព្រះរាជា។ ពួកគេមិនហ៊ានប្រឆាំងតវ៉ាដោយចំហទេ ក៏ប៉ុន្តែបានចាប់ព្រងើយកន្តើយ មិនយកចិត្តទុកដាក់ដល់កិច្ចការរាជការ ចាប់តាំងពីពេលនោះមកជាហេតុធ្វើឱ្យកើតមានអនាធិបតេយ្យទូទាំងប្រទេស ហើយព្រះរាជាដាក់រាជត្រូវបង្ខំព្រះទ័យលះបង់ខេត្តចន្ទបុរី និង

[152] ព្រះសត្ថាទី១ ឬ បរមរាជាទី៤ ឬ ព្រះជយជេដ្ឋាទី១? ។

[153] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ*, ភាគ២, ឆ្នាំ១៩៧៣, ទំព័រ១៥៦។

[154] បើយើងសង្កេតពីឋានានុក្រមក្នុងរាជវាំងឃើញថាមានស្តេច, ឧបយោរាជ, មហាឧបរាជ និងសម្តេចកែវហ្វា ហើយមកដល់ក្នុងរជ្ជកាលព្រះបាទអង្គដួង អត់មានងារឧបយោរាជទេ។ ប៉ុន្តែក្រោយពេលដែលសម្តេចព្រះ នរោត្តម សីហនុ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៥ គឺក៏ចាប់មានងារនេះដោយ ប្រើថាឧបយុវរាជ។ ការប្រើឧបយុវរាជនេះ ដោយទ្រង់ជាក្សត្រកំលោះ។

នគររាជសីមា ដែលទើបតែដណ្តើមបានទៅឱ្យសៀមវិញ[155]។ បញ្ហាព្រះមហាក្សត្រវ័យក្មេងនេះ ជាបញ្ហាដែលនាំឱ្យមានទំនាស់រវាងព្រះមហាក្សត្រ និងមន្ត្រីចាស់ៗ ដែលជាហេតុនាំឱ្យបែកបាក់ផ្ទៃក្នុងកម្ពុជា សាមគ្គីភាព និងការបែកបាក់រវាងខ្សែរាជវង្ស។

នៅឆ្នាំ១៥៨០ ប្រទេសភូមាបានវាយលុកចូលប្រទេសសៀមទៀត ហើយស្តេចសៀមក៏ផ្ញើសារមកថ្វាយមហាក្សត្រខ្មែរ ដើម្បីសុំកងទ័ពជួយតទល់នឹងការវាយលុករបស់ភូមា។ ព្រះសត្ថាទី១ យល់ព្រម ដោយនឹកទៅដល់សម្ពន្ធមិត្តនាឆ្នាំ១៥៧៦ ហើយព្រះអង្គបានចាត់ព្រះមហាឧភយោរាជព្រះស្រីសុរិយោពម៌ឱ្យនាំទ័ពទៅជួយសៀម។ ក្នុងការជួយធ្វើចម្បាំងនេះ ទ័ពខ្មែរបានខិតខំយកជ័យជម្នះបានលើភូមា។ ប៉ុន្តែជ័យជម្នះនេះពុំបានធ្វើឱ្យសៀម អបអរឡើយ ផ្ទុយទៅវិញ ជ័យជម្នះនេះបណ្តាលឱ្យអាប់កិត្តិយសសៀម ហើយជាពិសេសអាប់កិត្តិយសរាជបុត្រសៀម ព្រះនាមនរេសូរ។ ចាប់ពីពេលនោះមក ព្រះនរេសូរ តែងមានគំនុំចង់យកស្រុកខ្មែរ ជាចំណុះដោយរំលោភលើកិច្ចចរចាឆ្នាំ១៥៧៦។

នៅឆ្នាំ១៥៨៨ សៀមក៏ចាប់ធ្វើសង្គ្រាមទន្ទ្រានទឹកដីខ្មែរដោយគ្មានលេសអ្វីឡើយ។ នៅលើកនេះ សៀមវាយលុកប្រទេសខ្មែរចាប់តាំងពីនគររាជសីមា យកបានបាត់ដំបង ពោធិ៍សាត់ ហូតមកដល់បន្ទាយបរិបូណ៌ ដែលជាបន្ទាយរបស់ព្រះស្រីសុរិយោពម៌។ សៀមលើកទ័ពដែលមានទាហានចំនួន១០០ ០០០នាក់, ដំរី៨០០ និងសេះចំនួន១៨៥០»។ ព្រះបាទសត្ថាទី១ទ្រង់«...ចាត់សម្តេចព្រះស្រីសុរិយោពម៌ មហាឧភយោរាជឱ្យ នាំពលចំនួន២០ ០០០នាក់ លើកទៅបោះនៅបន្ទាយបរិបូរណ៌ ហើយចាត់ពញាអន ព្រះអនុជឱ្យនាំពល ចំនួន ១៥ ០០០នាក់លើកទៅទីតាំងរាំងទ័ពសៀមនៅព្រះមហានគរវត្តចាត់ព្រះជ័យចេស្តា ជាព្រះរាជបុត្រច្បងឱ្យចេញទៅកែនពាស្ត្រប្រមូលស្បៀងអាហារ...កងទ័ពដែលស្តេចឱ្យលើកទៅច្បាំង រាំងទ័ពសៀមនោះ ដោយតូចចិត្តនឹងអ្នកព្រះបាទជាអម្ចាស់ ទ្រង់ឱ្យព្រះរាជបុត្រទាំងពីរអង្គសោយរាជសម្បត្តិ ក៏ពុំសូវយកចិត្តទុកដាក់នឹងរាជការផែនដី ធ្វេសប្រហែស លើកទៅច្បាំងនឹងសៀមក៏ពុំឈ្នះ សៀមវាយបានហូតដល់ខេត្តបាត់ដំបង មហានគរពោធិ៍សាត់ ហួសមកចោមព័ទ្ធបន្ទាយ សម្តេចព្រះមហាឧភយោរាជ នៅខេត្តបរិបូរណ៌ ...»។

សៀមព័ទ្ធបន្ទាយបរិបូរណ៌ផង ហើយព័ទ្ធបន្ទាយលង្វែកផង។ ការឡោមព័ទ្ធបន្ទាយ លង្វែកនេះ ពុំបានសម្រេចផលអ្វីឡើយ។ កងទ័ពសៀមក៏អស់ស្បៀង ថែមទាំងកើតជំងឺឆ្លងផ្សេងៗទៀត។ ដោយដឹងព័ត៌មានច្បាស់អំពីចំណុចខ្សោយធំៗទាំងពីររបស់កងទ័ពសៀម កងទ័ពខ្មែរក៏នាំគ្នាវាយសៀមពីគ្រប់ទិស បណ្តាលឱ្យពួកនេះរត់ខ្ចាត់អស់ ហើយខ្មែរក៏នាំទ័ពដេញ តាមសៀមរហូតដល់ផុតព្រំប្រទល់ខ្មែរ។ សៀមបានលើកទ័ពមកវាយលង្វែកជាលើកទី២ ដោយព័ទ្ធគ្រប់ទិស ដែលជាហេតុធ្វើឱ្យព្រះបាទស្រីសុរិយោពម៌ ដែលនៅក្នុងបន្ទាយមិនអាចទប់ទល់បាន។ បន្ទាយលង្វែកបែកនៅឆ្នាំ១៥៩៣[156] បើយោងតាមលោក ប៊ែរណាដ៏ហ្វីលីព ហ្គ្រោសលីយេ[157]។

សៀម ចូលវាយយកបន្ទាយលង្វែកនោះមិនបាន ព្រោះបន្ទាយនោះមានកំពែងឫស្សីយ៉ាងក្រាស់ហើយស្នាមភ្លោះក៏ជំជ្រៅផងដែរ។ ដោយការច្បាំងមិនឈ្នះខ្មែរ សៀមបានយកប្រាក់រៀល ប្រាក់ដួង ច្រកចូលក្នុងកាំភ្លើង ហើយបាញ់បញ្ចូលទៅក្នុងបន្ទាយ រួចក៏ត្រឡប់ទៅវិញ។ ខ្មែរឃើញប្រាក់ ដែលសៀមបាញ់ចូលក្នុងបន្ទាយដែលនៅក្នុងគុម្ពឫស្សី ខ្មែរក៏កាប់ស្ការយកប្រាក់នោះ។ សៀមបានលើកទ័ពចូលមកច្បាំងម្តងទៀតឈ្នះ

[155] អាដេម៉ារ ឡឺក្លែ, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, ដ.ឯ.ម., ទំព័រ២៤៤។
[156] ឯកសារមួយចំនួនទៀត ដូចជាសៀវភៅខេមរយានកម្ម បញ្ជាក់ថាបែកលង្វែកនៅឆ្នាំ១៥៩៤។
[157] វង់ សុធារ៉ា, *សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល*, ដ.ឯ.ម.,ទំព័រ១៥៩។

ខ្មែរ[158] ក៏យកព្រះគោ ព្រះកែវ និងក្បួនរបស់ខ្មែរទៅស្រុកសៀមអស់[159]។ ប្រជារាស្ត្រខ្មែរមានស្ថានភាពក្រីក្រ និងមិនបានដឹងពីផលវិបាក ដើម្បីបានប្រាក់ដួង[160] ក៏នាំគ្នាកាប់ផ្ការព្រៃឫស្សី ដែលជារបងធម្មជាតិដ៏រឹងមាំសម្រាប់ការពារក្រុងលង្វែក។ ប្រជារាស្ត្រខ្មែរ ជឿជាក់លើអំណាចព្រះពុទ្ធរូបត្រឡែងកែង ហួសហេតុពេក។ នៅពេលដែលព្រះរាជាខ្មែរ តម្លើងព្រះពុទ្ធរូបនេះ នាំឱ្យបាក់ស្មារតី តស៊ូប្រយុទ្ធប្រឆាំងជាមួយសៀម។

សរុបមក សម័យលង្វែកហាក់ដូចជាកំពុងតែស្ថិតក្នុងអាថ៌កំបាំង សម្រាប់អ្នកសិក្សាស្រាវជ្រាវដោយសារតែ សម័យនេះមានឯកសារតិចតួចណាស់ ដែលបាននិយាយរៀបរាប់ ដែលយើងពឹងផ្អែកតែលើពង្សាវតារ។ ថ្មីៗនេះក្រុមបុរាណវត្ថុវិទូមួយក្រុម បានរកឃើញរោង ស្លលោហៈសម័យលង្វែក ហើយពួកគេសង្ឃឹមថារោងស្មិតលង្ហិន (រោងស្លលោហធាតុ)ដែលទើបរកឃើញនៅក្បែរតំបន់ក្រុងលង្វែកនឹងក្លាយជា ភស្តុតាងច្បាស់អំពីរដ្ឋកាលដែលបាត់បង់ពីកំណត់ហេតុប្រវត្តិសាស្ត្រ[161] ហើយមានការសិក្សាជាច្រើនពីប្រវត្តិសាស្ត្រខ្មែរ ក្រោយការបាត់បង់លង្វែកមក ក៏ប៉ុន្តែមានការខ្វែងគំនិតគ្នាក្នុងពិភពផ្សេងៗ បានលើកសំណួរជាច្រើនទាក់ទងនឹងព្រឹត្តិការណ៍មុន និងក្រោយការសោយទិវង្គត និងក្នុងពេលសោយរាជ្យ របស់ព្រះរាមជើងព្រៃ។ ប៉ុន្តែគេក៏បានឯកភាពគ្នាថាព្រះរាជាដែលឡើងសោយរាជ្យបន្តពីព្រះរាមជើងព្រៃ គឺព្រះបរមរាជាទី៥(ចៅពញាតន់[162]) ដែលទ្រង់បានភៀសព្រះកាយទៅរស់នៅស្រុកលាវ[163]។ ម្យ៉ាងទៀត លង្វែកជាឃ្លាំង វប្បធម៌មួយក្រោយសម័យអង្គរ ហើយរាជធានីលង្វែកស្ថិតក្នុងរចនាសម្ព័ន្ធក្រុងចាស់ដែលមានគូរទឹកព័ទ្ធជុំវិញដូចរាជធានីនោះអង្គរដែរ។ យើងគួរចោទជាសំណួរមួយថាតើលង្វែកបែកបាក់ដោយសារតែការបាក់ព្រៃឫស្សីមែនឬទេ? តើសម័យកាលមួយនេះមានការរីកចម្រើនកម្រិតណាដែរ?

ចំពោះផលវិបាកក្រោយបែកលង្វែកគឺនៅក្រោយបែកលង្វែករហូតដល់ឆ្នាំ១៦០២ មានព្រះរាជាសោយរាជ្យជាបន្តបន្ទាប់ចំនួន៤អង្គ[164]៖

| | |
|---|---|
| **រាមាជើងព្រៃ ឬ រាមទី១ (១៥៩៤-១៥៩៦)** | រាមាជើងព្រៃ ជាស្តេចត្រាញ់ ដែលមានអំណាចជាងគេ។ ក្រោយពីកងទ័ពសៀមបានចេញពីបន្ទាយលង្វែកឆ្នាំ១៥៩៤ គាត់អាចបង្រួបបង្រួមទឹកដីមួយផ្នែកធំ ហើយក៏បានឡើងសោយរាជ្យ។ |
| **ពញាតន់ (ព្រះបរមរាជាទី៥) (១៥៩៧-១៥៩៩)** (រាជ្យទី២) | ពញាតន់ ឡើងសោយរាជ្យក្រោមការគាំទ្ររបស់ពួកអេស្ប៉ាញ។ ដូច្នេះទ្រង់ក៏តែងតាំងជនជាតិអេស្ប៉ាញជាចៅហ្វាយខេត្តធ្វើឱ្យប្រជារាស្ត្រងើបឡើងបះបោរ។ ព្រះអង្គសោយទិវង្គតក្នុងពេលបង្ក្រាបក្រុមបះបោរចាម្ប។ |

[158] នៅឆ្នាំ១៥៨៩ នរេសូរ(នរេសួន) បានវាយយកលង្វែកលើកទី១ ហើយលើកទី២ នៅឆ្នាំ១៥៩៣។

[159] G.Janneau, *Manue de Langue cambodgienne(ក្បួនសំណេរខ្មែរ)*, Sigion, 1874, p.243-244.

[160] នៅត្រង់ចំណុចនេះគឺជាតម្រុយសម្រាប់អ្នកសិក្សាពិចារណា និងវិភាគ។

[161] ភ្នំពេញប៉ុស្តិ៍, Publication date 20 December 2016.

[162] ព្រះរាជបុត្រទី២ របស់ព្រះបាទសត្ថា។

[163] Mak Phoeun, *Histoire du Cambodge de la fin du XVIe siècle au début du XVIIIe (ប្រវត្តិសាស្ត្រប្រទេសកម្ពុជាពីចុងសតវត្សទី១៦ដល់ដើមសតវត្សទី១៨)*, Presses de l'École française d'Extrême-Orient, Paris, 1995, p.47.

[164] ទី សុផល, *ប្រវត្តិវិទ្យា*, ជ.ឯ.ម., ទំព័រ១៥៦។

| | |
|---|---|
| ពញាអន (ព្រះបរមរាជាទី៦) (១៥៩៩-១៦០០) | ពញាអន ទ្រង់មិនបានគិតពីរាជកិច្ច ហើយប្រព្រឹត្តអំពើអបាយមុខ រហូត ធ្វើឱ្យមេស្រុកចុះចូលជាមួយក្រុមបះបោរធ្វើគុតព្រះអង្គ។ |
| ពញាញោម (ព្រះកែវហ្វាទី១) (១៦០០-១៦០២) | ពញាញោម បានកម្ចាត់ពួកបះបោរបានសម្រេច និងបានឡើងសោយរាជ្យបន្ត។ ទ្រង់មិនអាចគ្រប់គ្រងពួកចៅហ្វាយខេត្តនានា បណ្តោយឱ្យមានការចាប់ប្រជារាស្ត្រធ្វើជាទាសករ។ នៅទីបំផុតព្រះអង្គក៏ត្រូវព្រះបាទស្រីសុរិយោពម៌សម្លាប់។ |

លង្វែក គឺជាដៃគូប្រជែងជាមួយអយុធ្យានៅក្នុងពាណិជ្ជកម្មសមុទ្ទអន្តរជាតិ[165] ដូច្នេះការបែកលង្វែកឆ្នាំ១៥៩៣ ដែលដណ្តើមបានដោយស្តេច នរេសួរ[166] បានធ្វើឱ្យកម្ពុជាជួបនូវវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ និងនាំឱ្យបាត់បង់នូវអត្តសញ្ញាណជាតិផងដែរ។ ការបែកលង្វែក ធ្វើឱ្យប្រទេសកម្ពុជាអស់ឫទ្ធានុភាព ធ្លាក់ចុះទៅជារដ្ឋតូចតាច ក្នុងភូមិភាគអាស៊ីអាគ្នេយ៍។ ខ្មែរបានបាត់បង់ទ្រព្យសម្បត្តិ, ក្បួនច្បាប់, អ្នកប្រាជ្ញបណ្ឌិត ហើយវប្បធម៌ខ្មែរក៏ហូរចូលទៅក្នុងប្រទេសសៀមអស់ ជាហេតុបណ្តាលឱ្យខ្មែរ ចូលទៅសិក្សានៅប្រទេសសៀមវិញ ក្នុងសតវត្សរ៍ក្រោយៗមក[167]។ ផលវិបាកអំពីរឿងនេះ ពង្សាវតារបានសរសេរថាថៃ បានលួចគម្ពីរពីខ្មែរ ហើយបានខ្លាំងពូកែដោយសារគម្ពីរទាំងនេះ[168]។ ចំពោះការបាត់បង់អត្តសញ្ញាណជាតិនេះ ធ្វើឱ្យខ្មែរកាន់តែទទួលឥទ្ធិពលវប្បធម៌,ភាសា,ការគ្រប់គ្រងពីសៀម ចាប់ពីរជ្ជកាលព្រះអង្គអេង(ឆ្នាំ១៧៧៩ ដល់១៧៩៦)មក។

ចំពោះស្ថានភាពសង្គមគឺក្រោយបែកលង្វែកភ្លាម ប្រទេសកម្ពុជាធ្លាក់ចូលក្នុងសភាពអនាធិបតេយ្យប្របូកប្របល់ ដែលក្នុងឱកាសនោះ គេឃើញជនជាតិអេស្ប៉ាញ និងព័រទុយហ្កាល់ខ្លះ បានចូលរួមព្រឹត្តិការណ៍ខ្លះៗផង។ ព្រះសត្ថាទី១ ព្រមទាំងព្រះរាជបុត្រ និងព្រះរាជវង្សានុវង្ស បានភៀសព្រះអង្គ ទៅគង់នៅលាវ ហើយទ្រង់ និងព្រះរាជបុត្រនាមជ័យចេស្តា[169] បានចូលទិវង្គតនៅប្រទេសលាវ ក្នុងឆ្នាំ១៥៩២[170]។ បើយោងតាមសិលាចារឹកវត្តរំលក(K.27) គឺបង្ហាញឱ្យឃើញពីការបែកបាក់ និងការរត់ភៀសខ្លួនរបស់សមាជិករាជវង្ស មន្ត្រីសំខាន់ និងប្រជាជនទៅគ្រប់ទីកន្លែង។

ព្រះរាជវង្សានុវង្ស ភៀសខ្លួនចេញពីបន្ទាយលង្វែក បែកគ្នាដោយសារការគេចពីមុខសឹក រួចមកស្នាក់នៅបណ្តោះអាសន្ន ក្នុងតំបន់វត្តរំលកនៃស្រុកព្រៃក្របាស(ក្លាយជាស្រុកព្រៃកប្បាសចាប់ពីឆ្នាំ១៩២១) នៅឆ្នាំ១៥៨៧ និងនាំឱ្យពួកគេនាំគ្នាកសាងវិហារទុកសម្រាប់គោរពបូជា និងធ្វើជាអនុស្សាវរីយ៍នៅទីនោះ នាឆ្នាំ១៥៨៩[171] គឺត្រូវគ្នានឹងកាលបរិច្ឆេទនៃការវាយប្រហារដណ្តើមយកបន្ទាយលង្វែក ដោយស្តេចសៀម នរេសួរ

[165] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ១០៥។

[166] ស្តេច នរេសួរ មិនបានវាយយកអង្គរទេ ហើយទ្រង់គឺជាជនជាតិថៃ មកពីសុខោទ័យ។

[167] ក្រសួងអប់រំជាតិ, *ប្រវត្តិវិទ្យាថ្នាក់ទី១(ភាគ១)*, ភ្នំពេញ, ១៩៧២,ទំព័រ៤០។

[168] យ.យ. មីហេយេវ, *ប្រវត្តិសាស្ត្រសង្ខេប នៃប្រទេសកម្ពុជា*, ប្រែសម្រួលដោយ ឡុង សៀម, អង្គការបោះពុម្ពផ្សាយ«ប្រូហ្គ្រេស្ស» ម៉ូស្គូ, ឆ្នាំ១៩៨១, ទំព័រ១៦៥-១៦៦។

[169] ព្រះរាជបុត្រច្បង សត្ថា/សដ្ឋា(Sattha) ឬ បរមរាជាទី៤( ១៥៧៦-១៥៩៤) ព្រះនាមជយជេស្ឋា ឬជយជេដ្ឋាទី១។

[170] ក្រសួងអប់រំជាតិ, *ខេមរយានកម្ម(ប្រវត្តិវិទ្យាថ្នាក់ទី១)*, ភាគ១, ឆ្នាំ១៩៧២, ទំព័រ៤០។

[171] ប្រហែលជាពួកគាត់រត់គេចពីមុខសឹក តាំងពីឆ្នាំ១៥៨៧ មិនមែនបែកលង្វែកឆ្នាំ១៥៩៣ ទេ។

ជាលើកទី១[172]។ ចម្បាំងនៅលើទឹកដីខ្មែរកាន់តែធ្ងន់ធ្ងរទៅ ដែលធ្វើឱ្យប្រជារាស្ត្រត្រូវចូលរួមធ្វើទ័ព មិនបានធ្វើស្រែចម្ការ ដែលនាំឱ្យកសិករធ្លាក់ខ្លួនក្រលំបាកតោកយ៉ាកផងដែរ។ នៅក្នុងប្រទេសពោរពេញទៅដោយភាពច្របូកច្របល់ កើតមកពីវិបត្តិបង្ហូរឈាមគ្នា ដើម្បីដណ្តើមរាជសម្បត្តិរវាងសមាជិកនៃរាជវង្ស និងការឈឺចាប់ចំពោះអំពើរំលោភ និងការវាយលុករបស់ពួកថៃ កំហឹងរបស់ប្រជាជនក៏បានធ្លុះធ្លាយ ដោយហេតុថាពួកអ្នកដឹកនាំពុំមានសមត្ថភាពក្នុងការរៀបចំសណ្តាប់ធ្នាប់នៅក្នុងប្រទេស ហើយចៅហ្វាយខេត្តទាំងឡាយក៏បានគ្រប់គ្រងខេត្តតាមតែការយល់ឃើញរបស់ខ្លួន[173]។

**៦-សំណួរត្រិះរិះ**

១-ចូររៀបរាប់ពីមូលហេតុនៃការកសាង និងស្ថានភាពបន្ទាយលង្វែក។

២-តើអ្នកយល់បែបណាចំពោះមតិមួយដែលពោលថា«ដោយសារតែសៀមចាប់យកព្រះគោ ព្រះកែវ ទៅស្រុកសៀមទើបនាំឱ្យស្រុកខ្មែរមិនរីកចម្រើន»។ ចូរពន្យល់។

៣-តើឃ្លាដែលនិយាយថាបន្ទាយលង្វែកដួលរលំដោយសារតែប្រជាជនកាប់បំផ្លាញព្រៃឫស្សីយកប្រាក់ដួងនោះត្រឹមត្រូវឬទេ? ចូរបង្ហាញគំនិតរបស់អ្នកតាមលក្ខណៈប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រ។

៤-មូលហេតុអ្វីខ្លះបានជាបែកបាក់បន្ទាយលង្វែក?

៥-តើការបែកបន្ទាយលង្វែកផ្តល់ផលវិបាកអ្វីខ្លះចំពោះប្រទេសកម្ពុជានាពេលនោះ?

---

[172] វង់ សុធារ៉, *សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល*, ដ.ឯ.ម., ទំព័រ១៦០។

[173] យ.យ. មីហេយេវ, *ប្រវត្តិសាស្ត្រសង្ខេប នៃប្រទេសកម្ពុជា*, ដ.ឯ.ម., ទំព័រ១៦៨។

## មេរៀនទី៩ សម័យឧដុង្គ(ពីឆ្នាំ១៦១៨/១៦២០ ដល់១៨៦៣)

### ១-ស្ថានភាពខ្មែរក្រោយបែកលង្វែក

បន្ទាប់ពីសៀមវាយបែកក្រុងលង្វែកនៅឆ្នាំ១៥៩៤ រួចសៀមក៏បាននិរទេសព្រះបាទស្រីសុរិយោពម៌ទៅកាន់ប្រទេសសៀម។ ក្រោយមកព្រះបាទរាមាជើងព្រៃរំដោះក្រុងលង្វែកនៅឆ្នាំ១៥៩៥។ ក្រោយការបែកលង្វែកទៅព្រះរាជាខ្មែរត្រូវផ្លាស់ប្តូររាជវាំងជាច្រើនកន្លែង ដើម្បីការពារខ្លួនពីការវាយលុករបស់សៀមគឺរាជវាំងត្រូវបានផ្លាស់ប្តូរទៅកាន់ផ្នែកខាងកើតនៅទន្លេមេគង្គ និងខាងលិចទន្លេមេគង្គដែលមានទីតាំងរាជធានី ជាច្រើនកន្លែងដូចជា៖

- ទួលប៉ាសាន(១៥៩៤-១៦០៣) ដែលជាកន្លែងយុទ្ធសាស្ត្រមួយយ៉ាងសំខាន់ និងជារាជធានីរបស់ព្រះរាមរាមាជើងព្រៃ ,ពញាតន់, ពញាអន និងពញាញោម។
- កោះស្លាកែត[174] ល្វាឯម(១៦០៣-១៦១៨) ជារាជធានីរបស់ស្រីសុរិយោពម៌្ម។
- ឧដុង្គ(១៦១៨-១៦២៨) ជារាជធានីរបស់ជយជេដ្ឋាទី២
- កោះឃ្លោក[175](១៦២៩-១៦៣៤)ជារាជធានីរបស់ធម្មរាជា(រាជសម្ភារ)។

ក្រោយមកព្រះបាទស្រីសុរិយោពម៌ត្រលប់មកឡើងសោយរាជ្យវិញ ហើយទ្រង់បានភ្ជាប់ទំនាក់ទំនងជាមួយអាណ្ណាម[176]។ ព្រះបាទជយជេដ្ឋាទី២បានឡើងគ្រងរាជ្យបន្តពីព្រះបិតា(១៦១៨) និងបានតាំង រាជធានីថ្មីមួយមានឈ្មោះថា ឧដុង្គមានជ័យ នៅឆ្នាំ១៦២០[177]។ ក្រោយមកព្រះមហាក្សត្របានបញ្ជាឱ្យកសាងវត្តអារាមមួយចំនួនដែលសេសសល់រហូតដល់សព្វថ្ងៃ ដែលចាប់ពីពេលនោះមកប្រទេសកម្ពុជាក្រោយសម័យលង្វែកមានឈ្មោះថាសម័យឧដុង្គ[178]។

### ២-ព្រះបាទស្រីសុរិយោពម៌ និងការកសាងអធិបតេយ្យភាព

ទំនាក់ទំនងជាមួយអឺរ៉ុប បានបន្តពីសម័យលង្វែកមក ប៉ុន្តែចាប់ពីរជ្ជកាលព្រះស្រីសុរិយោពម៌ ទ្រង់មិនសូវពេញចិត្តជាមួយជនជាតិអឺរ៉ុបទេ។ គួសបញ្ជាក់ផងដែរថា ទ្រង់ជាក្សត្រដែលសៀមជួយទំនុកបម្រុងឱ្យឡើងសោយរាជ្យ។ ចាប់ពីឆ្នាំ១៦២០ ជនជាតិហូឡង់ក្លាយជាឈ្មួញអឺរ៉ុបដ៏សំខាន់នៅក្នុងប្រទេសកម្ពុជាលើ វិស័យជំនួញ។ ជនជាតិអឺរ៉ុបបានមកដល់ប្រទេសខ្មែរនៅអំឡុងសតវត្សរ៍ទី១៦ដែលមានបព្វជិត ហ្គាស្ប៉ាជាគ្រុស[179] ក្នុងគោលបំណងផ្សាយសាសនាគ្រិស្តនៅឆ្នាំ១៥៥៥។ បន្ទាប់មកទៀតមានអ្នកផ្សងព្រេងជាតិអេស្ប៉ាញ, អង់គ្លេស, ហូឡង់ មកដល់ភ្នំពេញនៅឆ្នាំ១៦២០ និងនៅឆ្នាំ១៦២៣ បានបង្កើតគ្រឹះស្ថានជំនួញជាលើកដំបូងនៅកំពង់ហ្លួង។ នៅអំឡុងប្រហែលឆ្នាំ១៨៥៥ ទើបខ្មែរមានទំនាក់ទំនងជាមួយបារាំង ដែលជាគណៈបេសកទូតកាតូលិកឈ្មោះមីស។ នៅចុងរជ្ជកាលព្រះបាទអង្គចន្ទទី១ជនជាតិព័រទុយហ្គាល់ និងអេស្ប៉ាញមានទំនាក់ទំនងជាមួយកម្ពុជាក្នុងគោលបំណងសំខាន់របស់ពួកគេគឺផ្សាយគ្រិស្តសាសនា និងធ្វើជំនួញ។ នៅក្នុងរជ្ជកាលព្រះ

---

[174] ទីតាំងនៅទល់មុខរាជធានីចតុមុខដែលជាកន្លែងកោះនរា សព្វថ្ងៃ។

[175] កោះឃ្លោក ជាទីតាំងរាជធានីខ្មែរកាលពី៣៩០ឆ្នាំមុន សព្វថ្ងៃនេះមានឈ្មោះថាកោះឧកញាតី ស្ថិតក្នុងនៅវត្តចុងកោះ(វត្តទីបាវសាន) ឃុំឧកញាតី នៅស្រុកខ្សាច់កណ្តាល ដែលនៅក្នុងវត្តនេះមានចេតិយព្រះអង្គម្ចាស់សំរិទ្ធវង្ស។

[176] វង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ,* ជ.ឯ.ម., ទំព័រ១០៩។

[177] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ (ភាគ២)* ជ.ឯ.ម., ទំព័រ១៩៩។

[178] ការដាក់ឈ្មោះសម័យនីមួយៗគឺអាស្រ័យទៅតាមឈ្មោះរាជធានីនៅទីនោះ។

[179] បព្វជិតផ្សាយគ្រឹស្តសាសនានិកាយដូមីនីកាំង ជនជាតិព័រទុយហ្កាល់ ។

សត្តា ទ្រង់បានសព្វព្រះរាជហឫទ័យនឹងព័រទុយហ្គាល់ ម្នាក់ឈ្មោះ វេឡូសូ និង ជនជាតិ អេស្ប៉ាញម្នាក់ឈ្មោះ រ៉ូស។ ព្រះអង្គបានលើកក្សត្រិយ៍មួយអង្គ ឱ្យធ្វើជាភរិយារបស់វេឡូសូ និងលើកលោករ៉ូសឱ្យធ្វើជាព្រះអង្គរក្ស។ ជនជាតិទាំងពីរនេះបានជួយយកអាសារព្រះរាជាខ្មែរ ក្នុងការទប់ទល់នឹងសៀម រហូតសៀមចាប់បានធ្វើជាឈ្លើយសឹកនាំយកទៅក្រុងអយុធ្យា។ ក្នុងរជ្ជកាលព្រះបាទរាមាជើងព្រៃ អ្នកទាំងពីរត្រូវបានសៀមដោះលែងវិញ ហើយពួកគេបានវិលត្រឡប់មកកម្ពុជាវិញ ហើយនៅថ្ងៃមួយពួកគេមានវិវាទរវាងពួកខ្លួន និងពួកចិន វេឡូសូបានទទួចសុំចូលគាល់ព្រះរាជាដើម្បីធ្វើយុត្តិកម្ម តែត្រូវព្រះរាជាមិនអនុញ្ញាតពួកគេទាំងពីរក៏នាំទាហានទៅវាយប្រហារព្រះរាជវាំងនៅស្រីសន្ធរ រួចធ្វើគុតព្រះបាទរាមាជើងព្រៃសុគតទៅ។

ដូច្នេះ ពួកបរទេសជាពិសេសពួកព័រទុយហ្គាល់ នៅក្រោយមកទៀតពួកនេះមានតួនាទីសំខាន់ផងដែរនៅក្នុងដំណោះស្រាយជម្លោះក្នុងរាជវង្សានុវង្សខ្មែរ។ ដូចក្នុងរាជ្យព្រះពញាតូក្នុងជម្លោះ ដណ្តើមព្រះនាងបុប្ផាវតីជាមួយមារបស់ព្រះអង្គគឺព្រះឧទ័យ[180] គេសង្កេតឃើញថាក្នុងជម្លោះនេះពួកព័រទុយហ្គាល់បានជួយយកអាសារព្រះឧទ័យរហូតធ្វើឃាតព្រះពញាតូបានសម្រេច។ នៅឆ្នាំ១៦១៨ ព្រះបាទជយជេដ្ឋាទី២ បានឡើងគ្រងរាជ្យ[181]។ បន្ទាប់មកនៅឆ្នាំ១៦២០ព្រះអង្គបានយាងចេញពីរាជវាំងល្វាឯម ទៅគង់នៅក្រុងឧដុង្គ។ តែមួយឆ្នាំក្រោយមកប៉ុណ្ណោះគឺនៅឆ្នាំ១៦២១ ស្តេចសៀមព្រះនាមសុងធម្ម[182]ឬ ព្រះពុទ្ធចៅថៃណា[183]បាននាំទ័ពសៀមដោយផ្ទាល់ព្រះអង្គ មកវាយខេត្តបាត់ដំបងដើម្បី «ផ្តល់មេរៀនមួយ»ដល់ព្រះបាទជយជេដ្ឋាទី២ដែលលែងទទួលស្គាល់អំណាចរបស់សៀមមកលើខ្មែរ។ ប៉ុន្តែផ្ទុយទៅវិញស្តេចសៀមអង្គនេះបានទទួល មេរៀនមួយពីស្តេចខ្មែរ ដោយសារតែកងទ័ពរបស់ព្រះអង្គបានទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ នៅខេត្តពោធិ៍សាត់ដែលនៅទីនោះ កងទ័ពខ្មែរបានវាយទ័ពសៀមឱ្យបែកខ្ចាត់ខ្ចាយអស់ ចំណែកឯស្តេចសៀមបានរត់រួចខ្លួន ត្រឡប់ទៅសៀមវិញ។ នៅឆ្នាំ១៦២២ ព្រះចៅថៃណា (ស្តេចសៀម) បន្ទាប់ពីបានច្បាំងចាញ់ខ្មែរនៅឯដែនដីគោក ភាគខាងជើងនៃប្រទេសកម្ពុជា (ខេត្តបាត់ដំបង និងពោធិ៍សាត់)នោះ ក៏មានគំនុំគុំគួនសងសឹកវិញ ដោយចាត់ឱ្យ «ព្រះចៅវាំងណាម» ជាមហាឧបរាជសៀម លើកទ័ពជើងទឹក៥០ ០០០នាក់ មកវាយស្រុកខ្មែរភាគខាងត្បូង[184]។

និយាយជារួមមកឃើញថា ក្រៅពីបំពេញមុខងារជាគណៈបេសកទូតបព្វជិត និងជាអ្នកជំនួញពួកព័រទុយហ្គាល់ ក៏បានជ្រៀតចូលក្នុងកិច្ចការរាជវង្សដែលធ្វើឱ្យមហាក្សត្រទុកព្រះទ័យលើពួកគេ និងរាប់អានពួកគេដោយស្មោះស្ម័គ្រ[185]។

នៅឆ្នាំ១៦២២ ព្រះចៅសៀមបានលើកទ័ពមកវាយប្រទេសខ្មែរ នៅភ្នំចុង្កាង(បរិបូរណ៍) ដោយ ហេតុថាព្រះបាទជយជេដ្ឋាទី២ ពុំព្រមទទួលស្គាល់អំណាចរបស់សៀមមកលើប្រទេសខ្មែរ។ សៀមបានបាក់ទ័ព និងត្រូវខ្មែរចាប់ជាឈ្លើយសឹកជាច្រើននាក់ ហើយព្រះបាទជយជេដ្ឋាទី២ហៅឈ្លើយសៀមទាំងនោះថា សៀមចុង្កាង។

---

180 តើទំនាស់រវាងព្រះបាទពញាតូ (ព្រះបាទសម្តេចព្រះរាជឱង្ការព្រះស្រីធម្មោរាជាធិរាជរាមាធិបតី ដែលពង្សាវតារកំណត់ព្រះនាមទ្រង់ត្រឹមតែ «ព្រះស្រីធម្មោរាជា»,ព្រះរាជសម្ភារបរមពិសេសដែលឈ្មោះនេះទ្រង់បង្គាប់ឱ្យគេហៅនៅពេលដែលទ្រង់គង់នៅកោះឃ្លោក)និងព្រះឧទ័យដោយសារតែការចង់បានអំណាចរបស់ព្រះបាទឧទ័យ ឬ ដោយសារតែការដណ្តើមគ្នាយកម៉ែយួរវត្តី?

181 រជ្ជកាលព្រះបាទជយជេដ្ឋាទី២ពីឆ្នាំ១៦១៨ ដល់១៦២៨។

182 Khin Sok, *Le Cambodge entre le Siam et le Vietnam (de 1775 à 1860) (ប្រទេសកម្ពុជានៅចន្លោះសៀមនិងវៀតណាម (ពីឆ្នាំ ១៧៧៥ ដល់១៨៦០)*, Ecole Française d'Extrême-Orient, Paris, 1991, p. 33-34.

183 អេង សុត, ព្រះរាជពង្សាវតារខ្មែរ, ឯកសារមហាបុរសខ្មែរៈ ព្រះរាជពង្សាវតារខ្មែរ តាមសាស្រ្តាស្លឹករឹតពិតឥតក្លែងក្លាយ, ភាគ១-៧, ទំព័រ៦៥១។

184 មានខេត្តកំពង់សោម, កំពត, ពាម និងបន្ទាយមាស។

185 វង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ១២០-១២១។

នៅឆ្នាំ១៦២៣ សៀមលើកទ័ពមកវាយខ្មែរម្តងទៀត ក្រោមបញ្ជារបស់ព្រះថៅស្រីរាជា កងទ័ពជើងទឹកសៀមបានប្រយុទ្ធនឹងទ័ពរបស់ព្រះឧទ័យនៅត្រង់ស្រុកពាម តែត្រូវបាក់ទ័ព[186]ដកថយទៅប្រទេសសៀមវិញ[187]។ បន្ទាប់ពីគេចចេញពីឥទ្ធិពលសៀមបន្តិចម្តងៗ ព្រះរាជាខ្មែរហាក់គិតគូរស្វែងរកមហាអំណាចណាដែលអាចរក្សាសុខសុវត្ថិភាពកម្ពុជាពីការទន្ទ្រានរបស់សៀម។ អាពាហ៍ពិពាហ៍នេះ ហាក់បីដូចជាការបង្កើតការទំនាក់ទំនងការទូតច្រើនជាងទំនាក់ទំនងស្នេហានៃក្សត្រា ក្សត្រិយ៍ទាំងពីរ ស្របពេលដែលប្រទេសកម្ពុជាត្រូវការកម្លាំងគាំទ្រពីខាងក្រៅ ដើម្បីទប់ទល់នឹងសៀម។

នៅឆ្នាំ១៦២៣ គណៈបេសកទូតយួនមួយត្រូវបានបញ្ជូនមកក្រុងឧដុង្គ ក្នុងគោលបំណងសូម ព្រះរាជាខ្មែរអនុញ្ញាតឱ្យយួនបង្កើតគ្រឹះស្ថានជំនួញ នៅភាគខាងត្បូងប្រទេសខ្មែរ គឺស្ថិតនៅត្រង់តំបន់ព្រៃនគរ និងកំពង់ក្របី ព្រមទាំងសូមអនុញ្ញាតឱ្យមានសិទ្ធិកាន់កាប់គយនៅតំបន់នោះផង។ សំណើនេះធ្វើឡើង តាមរយៈអន្តរាគមន៍មហេសីរបស់ព្រះបាទជយជេដ្ឋាទី២ ដែលជាជនជាតិយួន។ តែតាមឯកសារខ្លះថាយួនខ្ចីដីនេះ ដើម្បីធ្វើការហ្វឹកហាត់ទ័ព ច្បាំងជាមួយចិនតែរយៈពេល៥ឆ្នាំ ហើយនឹងបង្វិលមកឱ្យខ្មែរវិញ។ ប៉ុន្តែក្រោយមកប្រជារាស្ត្រយួនបានចូលទៅរស់នៅក្នុងតំបន់ខាងលើបន្តិចម្តងៗ។ ក្រោយមកព្រះចៅក្រុងវេ ដែលជាស្តេចនៅអាណ្ណាមបានយកលេសថា ដើម្បីជួយអាជ្ញាធរខ្មែររក្សាសន្តិសុខឱ្យមានប្រសិទ្ធភាពរវាងជនជាតិយួន និងខ្មែរ ហើយបានបញ្ជូនកងទ័ពយួនមកកាន់ខេត្តកំពង់ក្របីបន្តិចម្តងៗ និងពាសពេញខេត្តតែម្តង។

នៅឆ្នាំ១៦២៨ ព្រះបាទជយជេដ្ឋាទី២សោយទិវង្គត ហើយទឹកដីខ្មែរស្ថិតនៅភូមិភាគចាប់ពី ព្រៃនគរ បារៀ និងដូនណៃ (កំពង់ស្រកាត្រី) រហូតដល់អតីតរាជាណាចក្រចម្ប៉ា មានសុទ្ធតែជនជាតិយួនរស់នៅពេញទី ចំណែកប្រជារាស្ត្រខ្មែរវិញបានចាកចេញបន្តិចម្តងៗ ដោយសារតែមិនអាចរស់នៅជាមួយជនចំណូលថ្មីដែលមានទំនៀមទម្លាប់ការរស់នៅខុសពីខ្លួន។ ក្នុងរាជ្យព្រះរាមាធិបតីទី១ ទ្រង់បានទាមទារយកទឹកដីព្រៃនគរ និងកំពង់ក្របីពីមហេសីយួនរបស់ព្រះជយជេដ្ឋាទី២វិញ ប៉ុន្តែទ្រង់បានស្នើសុំពន្យារពេលសិន។ ក្រោយមកស្តេចអង្គនេះប្តូរទៅកាន់សាសនាឥស្លាម ដើម្បីធ្វើពាណិជ្ជកម្មជាមួយឈ្មួញម៉ាឡេ និងត្រូវបានគេហៅថា«ព្រះរាមចោលសាសន៍»[188] ហើយទ្រង់បានជួបប្រទះការបះបោរពីព្រះអង្គសូរ និងព្រះអង្គតន់ដែលមានជំនួយពីយួន។ ចុងក្រោយស្តេចរាមាធិបតីត្រូវបរាជ័យ និងត្រូវយួនចាប់ទៅបាត់។ ប៉ុន្តែក្រោយមកទៀត ព្រះអង្គសូរ និងព្រះអង្គតន់ដែលជាអ្នកទទួលជោគជ័យបែរជាបណ្តេញកងទ័ពយួនឱ្យត្រឡប់ទៅស្រុកវិញ។

គេសង្កេតឃើញថា ចាប់ពីពេលនេះតទៅប្រទេសមានវិបត្តិធ្ងន់ធ្ងរកើតឡើង គឺការដណ្តើមរាជបល្ល័ង្ក ឬជម្លោះរាជវង្ស[189]។ ការពឹងពាក់បរទេសធ្វើឱ្យប្រទេសបាត់បង់ឥស្សរភាព និងទឹកដីបន្តិចម្តងៗ ជាពិសេសសៀម និងយួន កាន់តែមានឱកាសលូកដៃចូលកក្កូរកិច្ចការផ្ទៃក្នុងខ្មែរកាន់តែខ្លាំងឡើងៗ។ សៀម និងយួនរួមគ្នាធ្វើការគាបសង្កត់លើខ្មែរ និងដណ្តើមយកទឹកដីបន្តិចម្តងៗរហូតស្ទើរតែអស់។ ក្រៅពីនោះបរទេសក៏តែងតែចិញ្ចឹម រាជវង្សខ្មែរមួយចំនួន ដើម្បីទុកប្រជែងរាជ្យចំពោះក្សត្រណាដែលមិនស្មោះត្រង់នឹងខ្លួន។ ដូចក្នុងករណី

---

[186] បាក់ទ័ព មានន័យថាពួកកងទ័ពច្បាំងចាញ់គេរត់ប៉ាត់ប៉ាយថយចេញ។

[187] គួរកត់សម្គាល់ថា ចាប់តាំងពីសម័យលង្វែកមក ការឈ្លានពានពីសៀមតាមផ្លូវទឹកភាគច្រើនធ្វើឡើងនៅមុំខេត្តពាម។ ប្រហែលជាការត្រួតត្រាផ្លូវទឹកនាពេលនោះ សំដៅលើការគ្រប់គ្រងពាណិជ្ជកម្មតាមផ្លូវសមុទ្រដែលកាន់តែផុសផុលខ្លាំង។ ចំពោះការវាយបែកបន្ទាយលង្វែកក៏ចំណុចផ្លូវទឹកសំខាន់ដែរគឺដែលច្រក៣ មកតាមផ្លូវទឹក និងច្រក១ផ្លូវគោក មកតាមផ្លូវជាតិលេខ៥សព្វថ្ងៃ។

[188] ម៉ាយឃើល វីកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ១១៩-១២០។

[189] វង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ១១០។

យួនចិញ្ចឹមព្រះអង្គអិម ក្រោយមកយួននាំទ្រង់មកឡើងសោយរាជ្យ[190]។ មានករណីខ្លះទៀតសៀម និងយួនបានប្រជែងគ្នាត្រួតត្រាទឹកដីខ្មែរដោយផ្ទាល់តែម្តង។ ដូចក្នុងករណីស្តេចអង្គអេង, ក្សត្រីអង្គមី៉ និងអង្គដួង។ នៅដំណាក់កាលនេះ សៀមលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងខ្មែរកាន់តែខ្លាំង។ សៀមបានរៀបចំក្សត្រ ឬ តែងតាំង មន្ត្រីឱ្យកាន់អំណាចក្នុងប្រទេសខ្មែរ។ នាពេលនោះសៀមមានការព្រួយបារម្ភខ្លាចខ្មែរបានទៅយួន។ ក្នុងរជ្ជកាលព្រះអង្គអេង (១៧៩៤-១៧៩៦) សៀមតែងតាំង មន្ត្រីម្នាក់ឈ្មោះ ប៉ែន ដែលស្និទ្ធជាមួយ ជាចៅហ្វាយខេត្តបាត់ដំបង និងសៀមរាប។ ក្រោយមក ប៉ែន បានថ្វាយដែនដីនេះទៅស្តេចសៀម ព្រោះសៀមមានអំណាចជាង។ ក្នុងឆ្នាំ១៧៩៥ ព្រះអង្គអេងបានទាមទារទឹកដីនេះពីស្តេចសៀមវិញដែរ ប៉ុន្តែប្រហែលដោយសារស្តេចសៀមស្នើសុំពន្យារពេល ឬ គំរាមផង ទើបទឹកដីនេះស្ថិតក្រោមការគ្រប់គ្រងរបស់សៀមហូតដល់ព្រះអង្គអេងចូលទីវង្គត។ ក្រោយមកដែនដីបាត់ដំបង សៀមរាប និងមួយផ្នែកនៃកំពង់ធំត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់សៀមរហូតដល់សម័យអាណាព្យាបាលបារាំង។ រហូតមកដល់ឆ្នាំ១៨១៤ សៀមរំលោភទឹកដីខ្មែរត្រង់ៗ នៅបណ្តាខេត្តម្លូព្រៃ ទន្លេរពៅ និងស្ទឹងត្រែង[191]។

### ៣-ខ្មែរ និងការបែកបាក់ផ្ទៃក្នុង(ការដណ្តើមអំណាចរវាងអង្គនន់[192] និងអង្គតន់[193])

នៅសតវត្សទី១៨ គេសង្កេតឃើញថានៅក្នុងរាជវង្សខ្មែរ ត្រូវបានប្រទេសជិតខាងបានលូកដៃមកអន្តរាគមន៍ ដែលនាំឱ្យខ្មែរបាត់បង់នូវឯស្សរភាពរបស់ខ្លួន ជាពិសេសនោះក្នុងវិស័យនយោបាយ ដែលបញ្ហានេះកើតចេញពីការដណ្តើមអំណាចរវាងអង្គនន់ និងអង្គតន់ នៅក្រោយព្រះឧបរាជព្រះឧទ័យ។ បញ្ហានេះនាំឱ្យព្រះរាជាបាត់បង់នូវឯស្សរភាព និងប្រជាប្រិយភាពដោយសារតែក្សត្រអង្គខ្លះទៅពឹងសៀម និងក្សត្រអង្គខ្លះរត់ទៅពឹងពាក់អាណ្ណាម។

ក្រោយមរណភាពរបស់ព្រះឧបរាជព្រះឧទ័យនៅឆ្នាំ១៧៥៣ ព្រះបាទអង្គតន់ ដែលជាបុត្រ និងជាកូនចិញ្ចឹមរបស់ម៉ាក់តុង បានឡើងសោយរាជ្យក្រោយព្រះនាមថា *ព្រះបាទសម្តេចព្រះរាជឱង្ការព្រះនារាយណ៍រាជាធិរាជរាមាធិបតីព្រះស្រីសូរិយោពម្ពបរមសុរេន្ទ*[194]។ ក្នុងរាជ្យរបស់ទ្រង់គឺមានការទទួលស្គាល់ដោយអាណ្ណាម។ ទ្រង់បានប្រគល់ទឹកដីខេត្តពីរគឺសុកត្រាំង និងត្រាវិញទៅឱ្យពួកអាណ្ណាម។ ដោយបែបនេះហើយ ដែលរដ្ឋាភិបាលក្រុងវេបានឆ្លៀតយកឱកាសដែលប្រទេសកម្ពុជាជួបប្រទះនឹងការលំបាក ដណ្តើមយកទឹកដី កូសាំងស៊ីនដាក់បញ្ចូលមកក្នុងការគ្រប់គ្រងរបស់ខ្លួនបន្តិចម្តងៗ ហើយពួកអាណ្ណាម នេះលោភលន់ មិនចេះស្កប់ស្កល់ទេ។ រៀបចំខេត្តទាំងពីរមិនទាន់បានស្រួលបួលផង ពួកនេះក៏ចាប់តាំងកសាងបន្ទាយនៅសាដែក(ផ្សារដែក) នៅគូឡាវយាង(កោះតេង) និងនៅចូវដុក(មាត់ជ្រូក) ថែមទៀត[195]។ រហូតដល់ឆ្នាំ១៧៥៨ យួនបានមកតាំងនៅគ្រប់ខេត្តនៃដែនដីកម្ពុជាក្រោម[196]។ នៅឆ្នាំ១៧៦៣ ក្រោយពីបានប្រគល់កិច្ចការរាជការឱ្យមន្ត្រីសេនាបតីទាំងពួងរក្សាហើយ ព្រះអង្គទ្រង់ចេញសាងព្រះផ្នួស គង់ចាំព្រះវស្សាក្នុងវត្តកោះអន្លង់ ចិន[197]។ ព្រះអង្គទ្រង់ខិតខំចម្រើន

---

[190] វង់ សុជាា៉ និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ១២៣។

[191] -ដ- ទំព័រ.១២៦។

[192] អង្គនន់-រាមាធិបតីទី៣ ជាបុត្រអង្គស្ងួន-ស្រីជយជេដ្ឋ(១៧៧៥-១៧៧៩)។

[193] អង្គតន់-ឧទ័យរាជាទី៣ ឬ នារាយរាជាទី២ ជាចៅអង្គទង-រាមាធិបតីទី២(១៧៥៨-១៧៧៥)។

[194] អាដេម៉ារ ឡឺក្លែរ, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, ដ.ឯ.ម., ទំព័រ៣៣៦។

[195] -ដ- ទំព័រ៣៣៦។

[196] វង់ សុជាា៉ និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ* , ដ.ឯ.ម., ទំព័រ១១០។

[197] បើតាមការចុះស្រាវជ្រាវ អាចជាវត្តក្បាលកោះ នាពេលបច្ចុប្បន្ន។

សមណធម៌អស់រយៈបីខែ ទើបទ្រង់ចាកសិក្ខាបទយាងត្រឡប់មក សោយរាជ្យវិញ[198]។ ចំណែកឯព្រះអង្គនន់ដែលជាបងប្អូនជីដូនមួយរបស់ទ្រង់ បានរត់ទៅស្រុកសៀម។ តែសៀមមិនបានអើពើចំពោះអង្គនន់ឡើយ ព្រោះសៀមបានទទួលប្រយោជន៍ពីខ្មែរ ដោយសារតែសួយសារអាករដែលខ្មែរបានថ្វាយ។

ដោយការរំអុកខ្លាំងរបស់អង្គនន់ និងការប្ដេជ្ញារបស់ក្សាតាក ឬចៅពញាតាក[199]ថានឹងទម្លាក់ព្រះរាជាខ្មែរចេញពីព្រះរាជបល្ល័ង្កឱ្យបានផងនោះ។ ក្សាតាកបានឱ្យទ័ពសៀមមួយកងជូនព្រះអង្គនន់រាមា ធ្វើដំណើរមកកាន់ឧដុង្គកាត់តាមផ្លូវនគរវត្ត ដើម្បីស្នើប្រគល់ឱ្យនាម៉ឺនសព្វមុខមន្ត្រីនៅក្នុងព្រះរាជាណាចក្រដែលមិនសូវជាពេញចិត្តនឹងអង្គតន់ប៉ុន្មាននោះសម្រេច[200]។ទំនាស់បានកើតឡើងរវាងអង្គតន់ និងអង្គនន់ដោយសារតែ ការជួយអន្តរាគមន៍ពីសៀម និងអាណ្ណាម។ ក្នុងសភាពការសឹកនៅពេលនោះព្រះចៅអាណ្ណាមនាម យ៉ាឡុងបានទ្រង់សម្រេចជួយបញ្ជូន ទ័ពចំនួន១០ ០០០នាក់ ឱ្យមកជួយខ្មែរហើយអង្គតន់ក៏ភៀសខ្លួនទៅស្រុកយួន។ ចំណែកសៀមបានរៀបចំព្រះអង្គនន់ គង់នៅរាជធានីឧដុង្គមានជ័យ គ្រប់គ្រងនគរកម្ពុជាដោយទុកទ័ព៥០០នាក់តាមរក្សាព្រះអង្គនន់។ អំពីទ័ពជំនួយរបស់ព្រះចៅអាណ្ណាម វិញគឺបានលើកក្បួនឡើងមករួមនឹងទ័ពខ្មែរហើយប្រយុទ្ធតាំងនឹងទ័ពសៀម។ នៅទីបំផុតទ័ពសៀមទន់ដៃដកថយអស់ទៅខេត្តពាម។ ចំណែកឯព្រះអង្គនន់ ក៏ទ្រង់ភៀសទៅកាន់ខេត្តកំពត[201]។ ព្រះអង្គបានឱ្យទ័ពត្រួតត្រារក្សាខេត្តបន្ទាយមាស, ពាម, កំពត, កំពង់សោម, ថ្កូង[202] ឱ្យនៅក្រោមអំណាចព្រះអង្គ។ ក្រោយមកព្រះអង្គតន់ បានយាងត្រឡប់មកកម្ពុជាវិញ ប៉ុន្តែទ្រង់គង់នៅឯ «ព្រៃកមាត់កណ្ដុរ[203]»។ នៅពេលនោះមានមន្ត្រីយួនជួយសម្រេចកិច្ចការផែនដី ហើយនៅឆ្នាំ១៧៧២ ទ្រង់បានគង់នៅ«ព្រៃកពាក់ព្រ័ត»[204] រហូតមកដល់ឆ្នាំ១៧៧៤ ស្ដេចព្រមទាំងអគ្គមហេសី ព្រះម្នាងព្រះស្នំ ស្រីង្គារសេនាបតី នាម៉ឺនសព្វមុខមន្ត្រីហែស្ដេចយាងចេញពីព្រៃកមានលាភ ទៅគង់នៅព្រះរាជវាំងកោះចិន[205]។ ទើបទ្រង់ត្រាស់ឱ្យហៅអុងយួន មេកងទាំងពីរចូលគាល់។ ទ្រង់ព្រះរាជទានរង្វាន់តាមការគួរ ហើយទ្រង់ព្រះតម្រិះថាឱ្យអុងលើកទ័ពត្រឡប់ទៅស្រុកយួនវិញចុះ។ ទ្រង់មានបណ្ដាំថា ឱ្យក្រាបបង្គំទូលព្រះចៅក្រុងអាណ្ណាម ឱ្យបានល្អផង[206]។

ចំពោះអង្គតន់ ត្រូវបានលោក អាដេម៉ារឡឺក្លែរ បានបង្ហាញថាទ្រង់មិនត្រឹមតែជាជនឧក្រិដ្ឋចំពោះ រាជវង្សានុវង្សប៉ុណ្ណោះទេ ប៉ុន្តែបានក្បត់ប្រទេសជាតិថែមទៀតផង[207]។ តែការស្រាវជ្រាវបានបដិសេដចំពោះការយល់ឃើញរបស់លោកផងដែរ ព្រោះអង្គតន់ក៏ជាអ្នកដែលស្នេហាជាតិសំខាន់មួយរូបដែរ ទោះបីទំនាស់របស់ទ្រង់ជាមួយអង្គនន់ ជាការធ្វើសង្គ្រាមយូរឆ្នាំមកហើយនោះ ប្រាថ្នាតែរាជ្យសម្បត្តិក៏ដោយ។ តែដោយទ្រង់បានទតឃើញថាប្រជារាស្ត្រខ្មែរ វេទនាខ្លោចផ្សា ធ្លាក់ក្នុងចម្បាំង ស្លាប់នឹងជំងឺ ព្រះពុទ្ធសាសនាក៏សៅហ្មង

---

[198] សូរ អឿ, *ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និង សៀម ចាប់ពីសតវត្សរ៍ទី១៦*, ឆ្នាំ១៩៩៨, ទំព័រ៨៥។

[199] ក្សាតាកជាកូនកាត់ចិនក្នុងសហគមន៍ហៃហុង ជាចៅហ្វាយខេត្តមួយនៅទិសខាងជើងនៃប្រទេសសៀម។

[200] អាដេម៉ារ ឡឺក្លែរ, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា,* ដ.ឯ.ម., ទំព័រ៣៣៨។

[201] សូរ អឿ, *ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និងសៀម ចាប់ពីសតវត្សរ៍ទី១៦*, ដ.ឯ.ម., ទំព័រ៨៩។

[202] ថ្កូង ជាស្រុកមួយរបស់ខេត្តកំពង់ស្ពឺនាពេលបច្ចុប្បន្ន។

[203] ព្រៃកមាត់កណ្ដុរគឺប្រហែលជាស្ថិតនៅជិតព្រៃកលៀប តែអ្នកស្រាវជ្រាវរកទីតាំងមិនឃើញ។

[204] សូរ អឿ, *ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និងសៀម ចាប់ពីសតវត្សរ៍ទី១៦*, ដ.ឯ.ម., ទំព័រ៩០។

[205] កោះចិន ជាកោះមួយនៅក្នុងទន្លេសាប ស្ថិននៅទល់មុខកំពង់ហ្លួង។

[206] អេង សុត, *ឯកសារមហាបុរស ខ្មែរ(លេខ៥៩)*, ដ.ឯ.ម., ទំព័រ៩៣១។

[207] អាដេម៉ារ ឡឺក្លែរ, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, ដ.ឯ.ម., ទំព័រ៣៣៦។

សមណៈជី ព្រាហ្មណ៍ ប្រជាជន កើតវិនាសព្រាត់ប្រាសប្រពន្ធ កូន ចៅ ចោលលំនៅឋានជាច្រើន នោះព្រះអង្គក៏សុខព្រះទ័យលះបង់រាជ្យសម្បត្តិថ្វាយដល់ព្រះអង្គនន់ ដែលជាគូប្រកួតនិងជាសត្រូវនៅអំឡុងទសវត្សរ៍ឆ្នាំ ១៧៦០ ដល់១៧៧០។

បើតាមរាជពង្សាវតារបានរៀបរាប់ថា ទ្រង់បានប្រើឱ្យខ្ញុំមកអញ្ជើញអង្គនន់ព្រះរាម ចូលទៅទទួលរាជសម្បត្តិ ស្តេចនឹងបង្វែររាជ្យថ្វាយ ហើយគង់នៅជាឧបយោរាជវិញ។ ក្រោយពីអង្គនន់ព្រះរាម យល់ព្រមហើយ ទ្រង់បានត្រាស់បង្គាប់ឱ្យរៀបចំទឹកពិតទូសច្ចា ស្បថស្បាន់ និមន្តព្រះពុទ្ធបដិមាមកតាំងភ្ញីផ្កាបូជា កូរសាស្ត្រាវុធរួចឱ្យថ្វាយព្រះអង្គនន់សោយ ព្រមទាំងមន្ត្រីទទួលទានតាមទំនៀម។

ក្រោយនោះ អង្គនន់ចូលគាល់ក្នុងព្រះបរមរាជវាំង ស្តេចបានចេញទទួលដឹកព្រះហស្តឡើងគង់លើគ្រែទែនជាមួយហើយទ្រង់បានរៀបរាជដំណាក់ថ្វាយគង់តាមការគួរ។ រួចថ្ងៃបន្ទាប់ទ្រង់ព្រះរាជបញ្ជាមន្ត្រីរាជការរៀបចំព្រះរាជពិធីរាជាអភិសេកតាមក្បួនយ៉ាងកណ្តាលតាមប្រពៃណី[208]។

ព្រះអង្គនន់ព្រះរៀមដែលជាបុត្រាព្រះស្រីជ័យជេដ្ឋា និងជាព្រះរាជនត្តារបស់ព្រះធម្មរាជាទី១[209]ទ្រង់បានឡើងសោយរាជ្យនៅរាជធានីឧដុង្គ ក្នុងឆ្នាំ១៧៧៥ បន្ទាប់ពីព្រះឧទ័យរាជាអង្គតន់ ដាក់រាជ្យថ្វាយព្រះអង្គមក ដោយមានព្រះនាមក្នុងរាជ្យថា ព្រះបាទសម្តេចស្តេចព្រះរាជឱង្ការ ព្រះរាមាធិបតីរាជាធិរាជ។ ក្នុងរាជ្យព្រះអង្គប្រទេសកម្ពុជា បានធ្លាក់ពីការត្រួតត្រារបស់អាណ្ណាម ចូលទៅនៅក្រោមការត្រួតត្រារបស់សៀមវិញម្តង។

សរុបមក សង្គ្រាមដែលកើតឡើងរវាងព្រះនារាយណ៍រាជាអង្គតន់[210]ជាព្រះបិតាស្តេចអង្គអេង បានពឹងកងទ័ពយួន ដើម្បីប្រយុទ្ធជាមួយរាមាធិបតីអង្គនន់ ដែលទៅពឹងសៀមនៅអំឡុងទសវត្សរ៍ឆ្នាំ១៧៦០ ដល់ឆ្នាំ ១៧៧០ ជាដំណាក់កាល ដែលប្រទេសខ្មែរស្ថិតក្នុងយុទ្ធសាស្ត្ររបស់យួនក្នុងការច្បាំងយកអំណាចឱ្យស្តេចខ្មែរ ដើម្បីបង្កើតគុណសម្បត្តិលើរាជវង្សខ្មែរ និងយុទ្ធសាស្ត្ររបស់សៀម ដើម្បីបំបាត់នៅឥស្សរភាពរបស់ស្តេចខ្មែរក៏ត្រូវបញ្ចប់ ដោយការចូលចរចារវាងរាជាខ្មែរភាគីទំនាស់ ដើម្បីរកសន្តិភាព ជូនប្រជាជន និងប្រទេសខ្មែរ។ តែព្រះរាមាធិបតីអង្គនន់ ឡើងសោយរាជ្យនៅឧដុង្គដោយសារតែការជួយជ្រោមជ្រែងពី សៀម។ ដូច្នេះហើយ ក្នុងពេលដែលសៀមច្បាំងនឹងលាវ ក្នុងឆ្នាំ១៧៧៨ ព្រះអង្គខំកែនប្រុសខ្មែរឱ្យទៅជួយសៀម និងស្ត្រីខ្មែរឱ្យទៅបុកអង្ករ រៀបចំស្បៀងសម្រាប់ជួយឧបត្ថម្ភកងទ័ពខ្មែរផង សៀមផង។

## ៤-ការដណ្តើមឥទ្ធិពលគ្នារវាងមន្ត្រីរបស់ព្រះអង្គអេង ក្នុងឆ្នាំ១៧៩៤ ដល់១៧៩៦[211]

នៅចុងសតវត្សរ៍ទី១៨ សៀម បានចាប់ផ្តើមជួយច្បាំងក្សត្រខ្មែរឱ្យបានឡើងសោយរាជ្យដើម្បីក្លាយជាចំណុះរបស់ខ្លួន។ ក្រោយមក ពួកគេធ្វើយ៉ាងណាដើម្បីឱ្យក្សត្រខ្មែរ និងមន្ត្រីខ្មែរដែលនិយមសៀមនោះបានកាន់អំណាច ដែលក្នុងនោះគេឃើញមានដូចជាព្រះរាមាធិបតីអង្គនន់, ព្រះអង្គអេង, ចៅហ្វាបែន ជាដើម។ ជាពិសេសនោះក្នុងរជ្ជកាលព្រះបាទអង្គអេង គឺជាដំណាក់កាលនៃការដណ្តើមអំណាចគ្នារបស់មន្ត្រីរបស់ទ្រង់ និងជាដំណាក់កាលធ្លាក់កាន់តែជ្រៅនៃការទទួលយកវប្បធម៌របស់សៀមក្នុងប្រវត្តិសាស្ត្រខ្មែរ។ ប្រទេសខ្មែរក្នុងរយៈកាលចន្លោះរាជ្យនាឆ្នាំ១៧៧៩ មុំ ដណ្តើមអំណាចបានរួចប្រកាសខ្លួនថាហ្វា គឺជាថ្នាក់នាយករដ្ឋមន្ត្រី។ គាត់ បានលើកឧកញ៉ាអធិវង្សាប៉ុក ឪពុកចិញ្ចឹមរបស់អ្នកអង្គម្ចាស់អង្គអេងឱ្យឡើងធ្វើជាឧកញ៉ាវាំង។ ចំណែក

---

[208] អេង សុត, *ឯកសារមហាបុរស ខ្មែរ (លេខ៥៩)*, ដ.ឯ.ម., ទំព័រ៩៣៨។

[209] អាដេម៉ារ ឡឺក្លែរ, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, ដ.ឯ.ម., ទំព័រ៣៤១។

[210] ព្រះរាជបិតា ព្រះអង្គអេង។

[211] ទី សុផល, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម.,ទំព័រ១៩០-១៩៣។

ឯព្រះអង្គអេងផ្ទាល់ជាមហាឧបរាជ។ វិបុលរាជសួស បានឡើងជាឧកញ៉ាក្រឡាហោម គឺរដ្ឋមន្ត្រីទ័ពជើងទឹក។ ពាម ប្អូនរបស់គាត់ឱ្យឡើងជាឧកញ៉ាចក្រីជារដ្ឋមន្ត្រីសង្គ្រាម។ ក៏ប៉ុន្តែ ប្រជានុរាស្ត្រ និងនាម៉ឺនសព្វមុខមន្ត្រីចង់ឱ្យមានស្តេចសោយរាជ្យមួយអង្គ។ ដោយបញ្ហាចែកអំណាចគ្នារបស់មន្ត្រីរបស់ព្រះអង្គអេងនេះហើយ ទើបនាំឱ្យប្រទេសខ្មែរធ្លាក់ក្រោមការបញ្ជាពីសៀម។ តើអំណាចពិតប្រាកដស្ថិតនៅស្រុកខ្មែរ ឬ នៅស្រុកសៀម ក្នុងការដឹកនាំប្រទេសខ្មែរនាពេលនោះ?

នៅឆ្នាំ១៧៧៩ ព្រះអង្គអេងដែលមានព្រះជន្មត្រឹមតែ៧វស្សាឡើងគ្រងរាជ្យតែរាជការក្នុងព្រះនគរស្រេចលើថៅហ្វា ម៉ូ។ ចំណែកឧកញ៉ាយមរាជ បែន ដែលជានាម៉ឺនមន្ត្រីនៃព្រះអង្គតន់នោះ សម្តេចថៅហ្វាម៉ូមិនទុកចិត្តឱ្យចាត់ទៅធ្វើជារាជការជាមួយឧកញ៉ា ទែន ជាប្អូន ឯខេត្តកំពង់ស្វាយ និងដោយរង្កៀសចិត្តថាឧកញ៉ាយមរាជ បែន និងឧកញ៉ាក្រឡាហោម ស៊ូ ជាក្លើនឹងគ្នាផង ហើយសុទ្ធតែជាអ្នកមានតម្រិះប្រាជ្ញា និងថ្វីដៃដូចគ្នាទៀត ក្រែងនាំគ្នាសត្រូវនឹងខ្លួន ក៏បំបែកឱ្យនៅដោយខ្លួន ដើម្បីឱ្យឧកញ៉ាតេជោ ទែន មើលគំនិតឱ្យ។ ហេតុដែលកើតកលិយុគក្នុងព្រះនគរនោះពុំស្ងប់ស្ងាត់ដោយខ្ញុំរាជការចាស់ខ្លះ ដែលនៅមានចិត្តកត្តញ្ញូនឹងសម្តេចព្រះរាមរាមាធិបតីអង្គតន់ នាំគ្នារត់ទៅក្រុងអយុធ្យាទូលព្រះចៅតាកថា ឥឡូវក្រុងកម្ពុជាកើតចលាចលជាខ្លាំងគឺថៅហ្វា ម៉ូ ជាមេនាំបះបោរធ្វើគុតសម្តេចព្រះរាមាធិបតី កើតកលិយុគទៀតហើយ រួចលើកខ្លួនឯងជាធំសម្រេចរាជការក្នុងក្រុងកម្ពុជាធិបតី។ លុះឮដំណឹង ពីការរត់ទៅស្រុកសៀមរបស់មន្ត្រីចាស់តាំងពីរាជ្យអង្គតន់ បានធ្វើឱ្យថៅហ្វា ម៉ូ គ្រេកអរយ៉ាងខ្លាំង ព្រោះត្រូវតាមបំណងរបស់ខ្លួនដែលចង់កម្ចាត់ឧកញ៉ាយមរាជ បែន។

ចំណែកឯ ឧកញ៉ាក្រឡាហោម ស៊ូ ក៏នឹកអរដែរព្រោះគិតថា«បើថ្ងៃក្រោយអញកម្ចាត់ថៅហ្វា ម៉ូ បានអំណាចនឹងធ្លាក់មកលើអញតែម្នាក់ មិនមានក្លើម្រាក់ណាបែងចែកជាមួយឡើយ»។ ចំណែក បែន ត្រូវបានស្តេចសៀមបន្ទោសអំពីបទរួមគំនិតធ្វើគុត ព្រះអង្គនន់ និងបញ្ជាឱ្យគេវាយ១០០រំពាត់ ចៀរស្លឹកត្រចៀកទាំងសងខាង និងដាក់គុកជាទម្ងន់។ លុះដាក់ទោសឧកញ៉ាយមរាជ បែន រួចហើយ ស្តេចសៀមប្រឹក្សាជាមួយមន្ត្រីសេនាបតី ដើម្បីលើកមកវាយដណ្តើមកម្ពុជាពីឥទ្ធិពលយួន និងមានបំណងយកក្សត្រខ្មែរតវង្សឱ្យអស់តែម្តង។ នេះហើយជាដំណាក់កាលដែលសៀមត្រូវត្រៀមយុទ្ធសាស្ត្រគ្រប់គ្រងដែនកម្ពុជាពីចម្ងាយដោយត្រូវជួយមន្ត្រីខ្មែរ ដែលចុះចូលជាមួយសៀម ដើម្បីគ្រប់គ្រងកម្ពុជាហើយសៀមជាអ្នកកាន់ខ្សែញាក់។

ដោយឧបាយកលរបស់ បែន និងស៊ូ បានសម្លាប់ក្រុមរបស់ថៅហ្វាម៉ូ។ ចំណែកថៅហ្វា មូ និងចក្រី ពាង បានរត់ទៅពួននៅព្រៃប្របមាត់ស្ទឹងក្រាំងពន្លៃ ហើយថៅហ្វាម៉ូ បានរត់ទៅលាក់ខ្លួននៅខេត្តបាសាក់។ ជាចុងក្រោយឧកញ៉ាអធិវង្សាសួស ចាត់សេនាទាហានឱ្យលើកទ័ពទៅព័ទ្ធចាប់ថៅហ្វា ម៉ូ បានហើយឱ្យនាំមកក្រុងឧដុង្គ រួចក៏ប្រហារជីវិតនៅទីវាំងក្ការ។ ចំណែកឧកញ៉ាទែនក៏មិនហ៊ានលើកទ័ពទៅជួយដែរ ហើយក្រោយមកសម្តេចថៅពញា ស៊ូ និងយមរាជ បែន កាប់សម្លាប់ពួកសត្រូវអស់ហើយក៏ចាត់សេនាទាហានឱ្យប្រមូលមន្ត្រីខ្ញុំរាជការ ដែលមិនចូលជាមួយពួកថៅហ្វាម៉ូ, ចក្រី ពាង និងបណ្តារាស្ត្រមិនឱ្យចលាចល ហើយសម្តេចថៅពញា ស៊ូ លើកខ្លួនជាធំ ស្រដីការរាជការក្នុងក្រុងឧដុង្គជាមួយយមរាជបែន។ ឧកញ៉ាអភ័យធិបេស បែន ត្រូវបានសៀមឱ្យមកត្រួតត្រាលើខ្មែរ ដែលក្រោយមកត្រួតត្រានៅពាយព្យ និងខាងជើង។

នៅឆ្នាំ១៧៨១ ក្នុងការគ្រប់គ្រងរបស់ឧកញ៉ាអភ័យធិបេសបែន បានកែនខ្មែរយកទៅធ្វើការឱ្យសៀម គឺជួយជីកព្រែក ជីកស្រះ ដុតឥដ្ឋនៅវត្តស្រះកែវ។ លុះដឹងថាខ្មែរក្តៅក្រហាយជាមួយបែន សៀមបានបញ្ជូនព្រះអង្គអេងយាងមកសោយរាជ្យនៅឧដុង្គ វិញ។ ព្រះចៅសៀមទ្រង់តាំងឧកញ៉ាក្រឡាហោម ប៉ុក ជាថៅហ្វាទឡ្ហៈ

ជំនួស ចៅហ្វាទឡ្ហៈបែន។ នៅក្នុងឆ្នាំ១៧៩៤ ព្រះអង្គអេងត្រូវសៀមរៀបអភិសេកនៅបាងកកជាព្រះចៅនគរកម្ពុជា។ ការលើកព្រះអង្គអេងដែលមានព្រះជន្ម២១វស្សា ឱ្យឡើងគ្រងរាជ្យសម្បត្តិនេះ វាស្របតាមបំណងប្រជារាស្ត្រឧដុង្គ ដែលនឿយណាយនឹងការខ្វះស្តេចសោយរាជ្យយូរមកហើយ ព្រោះលោក អរជូន ជាស្តេចត្រាញ់ខេត្តត្បូងឃ្មុំមិនអាចធ្វើឱ្យគេគោរពបាន មិនចេះដឹងចាត់ចែងការងារ។ នៅក្នុងរដ្ឋបាលនៃការគ្រប់គ្រងទឹកដីរបស់បែន បានភ្ជាប់ទៅស្តេចសៀមផ្ទាល់ចាប់តាំងពីពេលនោះមករហូតដល់ឆ្នាំ១៩០៧ ដីនោះរួមទាំងខេត្តខ្មែរអង្គរផងដែលបានភ្ជាប់ទៅនឹងបាត់ដំបង នៅក្រោមការត្រួតត្រារបស់ចៅហ្វ៊ា បែន នេះឯងគ្មានទំនាក់ទំនងរដ្ឋបាលអ្វីជាមួយនឹងព្រះរាជាណាចក្រកម្ពុជាទេ។

ចំណែកបណ្តាខេត្តដែលស្ថិតនៅខាងជើងបាត់ដំបងដែលមានដូចជាមង្គលបុរី, សិរីសោភ័ណ និងកូរ៉ាត់ គេមិនចាំបាច់សង្ស័យអ្វីឡើយ ពួកសៀមបានយកដាក់ធ្វើជាទឹកដីរបស់គេយ៉ាងស្ងាត់ស្ងៀមក្នុងឆ្នាំ១៧៩៥។ យើងឃើញថា ក្នុងរាជ្យរបស់ព្រះអង្គអេងមិនបានបង្ហាញពីស្នាដៃធំៗអ្វីនោះឡើយ ប៉ុន្តែ ក្នុងរាជ្យរបស់ទ្រង់បានបង្ហាញឱ្យឃើញពីការបែកបាក់របស់មន្ត្រីរបស់ទ្រង់។ ជាពិសេសនោះ ចៅហ្វ៊ាបែន បានគោរពតាមតែបញ្ជាសៀម មិនមែនក្នុងនាមជាចៅហ្វាយខេត្តទេ តែក្នុងនាមជាមេទ័ពសៀម។ និយាយជារួមនៅឆ្នាំ១៧៨០ សង្គ្រាមបានកើតឡើងនៅលើទឹកដីខ្មែរ ដោយមានការជួយច្បាំងគ្នាពីភាគីអាណ្ណាម និងសៀម ដើម្បីទទួលប្រយោជន៍រៀងៗខ្លួន។

## ៥-ដំណោះស្រាយបញ្ចប់សង្គ្រាមសតវត្សរ៍ទី១៨ និង១៩

### ៥.១-ដំណោះស្រាយក្រោយបញ្ចប់សង្គ្រាម (សៀមយកខេត្តខ្មែរ)

សង្គ្រាមនៅលើទឹកដីខ្មែរ បានអូសបន្លាយអស់រយៈពេលជាច្រើនសតវត្សរ៍ ទោះបីជាមានការចរចា ជាច្រើនលើកច្រើនសារក៏ដោយចាប់តាំងពីឆ្នាំ១៦១៩ ក្នុងរាជ្យជ័យជេដ្ឋាទី២ រហូតដល់ឆ្នាំ១៧៩៦ ក្នុងការយាងចូលទិវង្គតរបស់ព្រះអង្គអេង។ ការស្រាវជ្រាវបានបង្ហាញថាខ្មែរ និងសៀម សុទ្ធតែបានទទួល ផលចំណេញពីការចរចា គឺខ្មែរទទួលបានការគ្រប់គ្រងប្រទេសកម្ពុជាតែអំណាចពិតប្រាកដស្ថិតនៅ ប្រទេសសៀម។ ចំណែកសៀមបានទទួលនូវទឹកដីជាច្រើនតាមរយៈយុទ្ធវិធីជាអ្នកចរចាដើម្បីចាត់ចែងកម្ពុជាមានដូចជាៈ

១-ខេត្តអង្គរ និងបាត់ដំបង ស្ថិតក្រោមការគ្រប់គ្រងរបស់ បែន តាំងពីឆ្នាំ១៧៧៩ បានធ្លាក់ក្រោមការគ្រប់គ្រងរបស់សៀមរហូតដល់ឆ្នាំ១៩០៧។

២- បណ្តាខេត្តដែលស្ថិតនៅខាងជើងបាត់ដំបងមានដូចជា មង្គលបុរី សិរីសោភ័ណ និងកូរ៉ាត់ ពួកសៀមបានយកដាក់ធ្វើជាទឹកដីរបស់គេយ៉ាងស្ងាត់ស្ងៀមក្នុងឆ្នាំ១៧៩៥។

៣- រួមទាំងទឹកដីខ្មែរចំនួន១២ ខេត្តទៀតដែលគេពុំបានដឹងឆ្នាំច្បាស់ដែលមានទំហំ៦០ ០០០គីឡូម៉ែត្រការ៉េ មានដូចជា នគររាជសីមា, បុរីរម្យ, សុរិន្ទ, ធនបុរី, សិរីសាកេត, ស្ទឹងជ្រៅ, ចន្ទបុរី, គោកខណ្ឌ, បស្ចិមបុរី, ក្រាត, សង្កិត, អ៊ូប៊ុន[212]។

### ៥.២-បងប្អូនបង្កើតដណ្តើមអំណាចគ្នា ពីឆ្នាំ១៨១០-១៨៣៤

នៅសតវត្សរ៍ទី១៩ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងខ្មែរកាន់តែខ្លាំងឡើងពីសំណាក់សៀម និងអាណ្ណាម។ នេះក៏ជាដំណាក់កាលថ្មីក្នុងប្រវត្តិសាស្ត្រសម័យកណ្តាល ដែលបង្ហាញពីការចាប់ដៃគ្នាដើម្បីចរចារកដំណោះស្រាយដោយខ្មែរ និងខ្មែរ ដើម្បីប្រទេសជាតិរបស់ខ្លួនផងដែរ។ នៅមុនពេលសោយទិវង្គតនា ឆ្នាំ១៧៩៦ ក្នុង

---

[212] វង់ សុជាវ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ជ.ឯ.ម., ទំព័រ១២៥។

ព្រះជន្ម២៥វស្សាព្រះអង្គអេងមានបុត្រ៥អង្គ និងក្រោយមកមានព្រះរាជនត្តាក្សត្រី[213]ចំនួន៤អង្គ ដែលជាបុត្រព្រះបាទអង្គចន្ទ។ បុត្រទាំងប្រាំអង្គនោះមាន ព្រះអង្គចន្ទ ព្រះអង្គស្ងួន ព្រះអង្គអិម ព្រះអង្គភិម និងព្រះអង្គដួង។ ព្រះបាទអង្គចន្ទមានបុត្រីដែលមានព្រះនាម អង្គប៉ែន, អង្គម៉ី, អង្គពៅ និងអង្គស្ងួន។ ជម្លោះដណ្ដើមអំណាចគ្នាដោយគ្មានចរចានេះបានកើតឡើងពីឆ្នាំ១៨១០ ដល់ឆ្នាំ១៨៣៤ ។

ក្រោយ សម្តេចចៅហ្វ៊ាប៉ុក ទទួលមរណភាព ព្រះអង្គចន្ទក៏បានទទួលរាជាភិសេក។ នៅខែសីហា ឆ្នាំ១៨០៦ ព្រះអង្គចន្ទ ដែលមានព្រះជន្ម១៦វស្សា ទ្រង់ទទួលនូវរាជាភិសេកឯក្រុងបាងកក ដោយមានព្រះនាមថា *ព្រះបាទសម្តេចព្រះឧទ័យរាជារាមាធិបតីព្រះស្រីសុរិយោពម៌* រួចទ្រង់យាងមកសោយរាជ្យនៅឧដុង្គវិញ[214]។ នៅពេលដែលទ្រង់យាងមកដល់ក្រុងឧដុង្គមន្ត្រីទាំងពួង និងចៅហ្វាយស្រុកខេត្តក្រៅនាំគ្នាមកថ្វាយបង្គំគាល់ព្រះអង្គគ្រប់គ្នា សល់តែឧកញ៉ាតេជោម៉ឹង ចៅហ្វាយស្រុកខេត្តកំពង់ស្វាយ ពុំបានចូលមក។

ការឡើងសោយរាជ្យរបស់ព្រះបាទអង្គចន្ទបុត្រច្បង របស់អង្គអេងនេះទោះបីជា ត្រូវបានសៀមអភិសេកព្រះអង្គ ហើយបងប្អូនរបស់ទ្រង់ដូចជា អង្គស្ងួន[215] អង្គអិម[216] ត្រូវបានសៀមផ្តល់តួនាទី និងបានឱ្យស្តេចទាំងពីរអង្គត្រឡប់មកកម្ពុជាវិញជាមួយនាម៉ឺន៣នាក់។ ចំណែកឧកញ៉ាតេជោម៉ឹង ស្តេចសៀមបានឱ្យមកជាមួយដែរ។

ចំពោះឧកញ៉ាក្រឡាហោមមឿង និងឧកញ៉ាចក្រី មានចរិតគិតក្បត់។ ព្រះឧទ័យរាជាអង្គចន្ទ ទ្រង់ជ្រាបក៏ចាត់ឱ្យចាប់សេនាបតីទាំងពីរនោះមកប្រហារជីវិត ដែលធ្វើឱ្យដំណឹងនេះឮដល់គ្រប់ខេត្ត។ ចំពោះឧកញ៉ាម៉ឹង ព្រួយបារម្ភណាស់ក្រែងស្តេចចាប់ទោសរាលដាលដល់ខ្លួនផង ព្រោះខ្លួនធ្លាប់មានស្នាមកំហុសពីមុនមកស្រាប់ ម្ល៉ោះហើយ កែនរាស្ត្រមកប្រជុំជាទ័ពក្នុងខេត្តកំពង់ស្វាយ។ ចំណែកពញាអភ័យធិបេសបែន បានដឹងក៏ធ្វើបន្ទាយនៅស្រុកបាត់ដំបង ប្រុងជើងការរក្សាខ្លួនឱ្យមាំមួន[217]។ នៅឆ្នាំ១៨១០ ជាចំណុចចាប់ផ្តើមនៃទំនាស់របស់បងប្អូនឯង នៃបុត្រាអង្គអេង។ ដោយដឹងពីដំណើរក្បត់របស់ឧកញ៉ាតេជោម៉ឹងខេត្ត កំពង់ស្វាយ ក្បត់នឹងព្រះអង្គ ទ្រង់បានបញ្ជាឱ្យចក្រីតី ឱ្យលើកទ័ពទៅតាមចាប់ឧកញ៉ាតេជោម៉ឹងនៅខេត្ត កំពង់ស្វាយ។ តេជោម៉ឹងដឹងខ្លួនទាន់ក៏ពុំហ៊ានទទួលច្បាំង នាំប្រពន្ធកូនរត់ទៅស្រុកសៀម។ នៅឆ្នាំ១៨១១ មហាឧបរាជអង្គស្ងួនបាននាំរាជការចេញពីក្រុង ដោយមានការទទួលស្វាគមន៍ពីអ្នកឧកញ៉ាសួគ៌ាលោក ប៉ុក ចៅហ្វាយស្រុកខេត្តពោធិ៍សាត់ ដែលជាហេតុធ្វើឱ្យព្រះឧទ័យរាជាអង្គចន្ទព្រួយបារម្ភយ៉ាងខ្លាំង ហើយទ្រង់ក៏បានអញ្ជើញអង្គស្ងួនមកវិញតែទ្រង់មិនព្រម ហើយបានឃាត់ខ្លួនមន្ត្រីដែលទៅយាងទ្រង់នោះទុកនៅជាមួយព្រះអង្គ។

ដោយការព្រួយព្រះទ័យចំពោះព្រះអនុជពុំព្រមយាងមក ទើបព្រះឧទ័យរាជាអង្គចន្ទ ទ្រង់ចាត់ឧកញ៉ាបរមរាជាអុង និងខ្ញុំរាជការ ឱ្យទៅសុំស្តេចយ៉ាឡុង មកបម្រុងការមិនបានសុខក្នុងព្រះនគរ។ រួចស្តេចយ៉ាឡុងទ្រង់ចាត់អុងឡឿង ឱញទៀង ឱ្យនាំសេនាទាហាន៥០០នាក់ ចុះទូកឡើងមកជាមួយ និងមន្ត្រីខ្មែរបោះទ័ព ចាំគាំពាររក្សាសម្តេចឧទ័យរាជា[218]។ ដោយសារតែការកាន់អំណាចបានរបស់អង្គចន្ទ មានការជួយទំនុកបម្រុងពី

---

[213] ចៅស្រី។

[214] សូរ អឿ, *ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និង សៀម ចាប់ពីសតវត្សទី១៦,* ដ.ឯ.ម., ទំព័រ១០២។

[215] សៀមបានតែងតាំងព្រះអង្គស្ងួន ជាឧភយោរាជ។(ឧបយោរាជគឺមានអំណាចដូចស្តេច ឬជាស្តេចស្ដីទី)។

[216] សៀមបានតែងតាំងព្រះអង្គអិម ជាឧបរាជ។

[217] អេង សុត, *ឯកសារមហាបុរស ខ្មែរ (លេខ២៦៥),* ដ.ឯ.ម., ទំព័រ១០៣៥។

[218] អេង សុត, *ឯកសារមហាបុរស ខ្មែរ (លេខ២៦៥),* ដ.ឯ.ម., ទំព័រ១០៣៧។

សំណាក់ប្រទេសអាណ្ណាម ព្រោះទ្រង់មិនទុកចិត្តសៀម ដោយទ្រង់បាននាំសួយសារអាករជូនអាណ្ណាម (ស្តេចយ៉ាឡុង) ៣ឆ្នាំម្តង ដែលជាហេតុធ្វើឱ្យសៀមមិនសប្បាយចិត្ត រួចបានជួយអង្គស្ងួន។

ចំណែក ព្រះវរមាតា, ព្រះអង្គអិម និងព្រះអង្គដួង ទ្រង់យាងមកជំនុំជាមួយអង្គស្ងួន នៅឧដុង្គមានជ័យ រួចទ្រង់បាននាំមន្ត្រីរាជការរបស់ទ្រង់ទៅស្រុកសៀម។ ដោយសារតែព្រះបាទអង្គចន្ទបាន ចងសម្ពន្ធមេត្រីជាមួយសៀម ហើយទៅចងសម្ពន្ធជាមួយយួន នោះហើយដែលជាដើមហេតុចម្បងនៃ ការទំនាស់រវាង បងប្អូនឯង។

ចំណែកព្រះអង្គស្ងួនបានសុគតនៅស្រុកសៀមនាឆ្នាំ១៨២២ ដោយគ្មានរាជបុត្របន្តវង្សទេ តែនៅឆ្នាំនោះដែរអ្នកម្នាងយស របស់ព្រះអង្គចន្ទ មានបុត្រីនាម «អង្គពៅ»[219]។ ត្រង់ចំណុចនេះ បង្ហាញឱ្យឃើញពីការបែកបាក់សាមគ្គីរបស់បុត្រព្រះអង្គអេង សម្ពន្ធភាពជាមួយសៀម-អាណ្ណាម និងការគោរពសាសនាផ្ទុយគ្នា ជាហេតុនាំឱ្យសៀម-អាណ្ណាម អាចលូកដៃចូលកាន់តែជ្រៅក្នុងកិច្ចការខ្មែរ។

នៅឆ្នាំ១៨៣៤ ព្រះឧទ័យរាជាអង្គចន្ទបានសុគត ហើយការដណ្តើមអំណាចរបស់បងប្អូនឯងក៏បានបញ្ចប់ ដោយជំនួសមកវិញដោយជួយជ្រោមជ្រែងស្តេចខ្មែរដើម្បីគុណបំណាច់គឺព្រះចៅមិញ ម៉ាង បានលើកអង្គម៉ី ជាស្តេចនៅឆ្នាំ១៨៣៤។ ពេលព្រះបាទឧទ័យរាជាអង្គចន្ទសោយទិវង្គតទៅ ព្រះចៅមីងម៉ាង ដែលជាបុត្រស្តេចយ៉ាឡុង ទ្រង់ចាត់ អុង ខាំម៉ាង ជារាជទូតឱ្យនាំគ្រឿងបណ្ណាការមកជួយបុណ្យព្រះបរមសព និងដើម្បីចូលរួមជ្រើសរើសក្សត្រគ្រងរាជ្យបន្ត។ ពិធីបុណ្យថ្វាយព្រះភ្លើងបានរៀបចំនៅកោះស្លាកែត ប៉ុន្តែអដ្ឋិធាតុត្រូវបានដង្ហែមកបញ្ចុះឯភ្នំព្រះរាជទ្រព្យ។ អង្គម៉ី ត្រូវបានជ្រើសរើសជាក្សត្រី ឱ្យឡើងសោយរាជ្យនៅ កោះស្លាកែត ក្នុងព្រះជន្ម២០វស្សា។ អង្គប៉ែន ជាបុត្រីច្បងមិនត្រូវបានគេជ្រើសរើសទេ ពីព្រោះអ្នកម្នាង ទេព ជាមាតាកំពុងគង់នៅស្រុកសៀម។ ក្សត្រីអង្គពៅ ត្រូវបានតែងតាំងជាឧបរាជិនី និងក្សត្រីអង្គស្ងួន ជា កែវហ្វា[220]។ ម្ចាស់ក្សត្រីអង្គម៉ី នេះហើយដែលអាណ្ណាម ចាប់ធ្វើជាចំណាប់ខ្មាំង ហើយក៏ជាក្សត្រីមួយអង្គ របស់ខ្មែរដែលក្លាហាន ហ៊ានបោះបង់ការគ្រងរាជ្យដើម្បីជាតិខ្មែរគង់វង្សដែរ។

ចំពោះប្រជារាស្ត្រហាក់ដូចជាមិនមានការភ្ញាក់ផ្អើលអ្វីទេ ចំពោះការដែលគេជ្រើសរើសព្រះក្សត្រីមួយអង្គឱ្យឡើងគង់លើរាជបល្ល័ង្កដូច្នេះ ពីព្រោះថាថ្វីបើកន្លងមកគេមិនដែលឃើញមានព្រះមហាក្សត្រីសោយរាជ្យសម្បត្តិក៏ដោយ ក៏ប៉ុន្តែគេធ្លាប់ប្រទះឃើញព្រះរាជាដាក់រាជ្យសម្បត្តិថ្វាយព្រះអគ្គមហេសី ឬ ព្រះមាតាជាញឹកញយដែរ ដើម្បីទ្រង់អាចយាងចូលសាងព្រះផ្នួសបាន។

ចំពោះ ព្រះអង្គដួង ជារាជាដែលស័ក្តិសមឡើងគ្រងរាជ្យ តែសម្រាប់អាណ្ណាម មិនយល់ស្របឡើយ។ ខណៈព្រះក្សត្រីអង្គម៉ីឡើងសោយរាជ្យ គឺព្រះអង្គដួងមិនហ៊ានមកជិតរាជបល្ល័ង្កនោះទេ ព្រោះខ្លាចអាណ្ណាមចាប់ខ្លួន។ អង្គម៉ីក្សត្រិយ៍មានឈ្មោះត្រឹមតែជារាជាប៉ុណ្ណោះ ព្រោះកិច្ចការអ្វីៗហាក់ក្រោមអាណ្ណាម ទាំងអស់។

សរុបសេចក្តីមក ស្តេចនិងមន្ត្រីយួន បានព្យាយាមប្រើឥទ្ធិពលលើស្តេចខ្មែរយ៉ាងខ្លាំង សូម្បីតែជ្រើសតាំងស្តេចសោយរាជ្យរបស់ខ្មែរក៏យួនចូលពាក់ព័ន្ធដែរ ដូចជាករណីមហាក្សត្រីអង្គម៉ី។ តែដំណោះស្រាយ ចុងក្រោយគឺសៀម និងយួនយល់ព្រមចរចា ហើយស្តេចខ្មែរ និងស្តេចខ្មែរបាននាំគ្នាបង្កើតសន្តិភាពតាមរយៈការចរចាដោយអង្គម៉ីក្សត្រិយ៍ ផ្ញើព្រះរាជសារទៅព្រះអង្គដួង ដើម្បីឱ្យទ្រង់មកគ្រប់គ្រងប្រទេស។

---

[219] សូរ អឿ, *ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និងសៀម ចាប់ពីសតវត្សរ៍ទី១៦,* ដ.ឯ.ម., ទំព័រ១០៦។

[220] -ដ- ទំព័រ១០៧។

## សន្តតិវង្សព្រះបាទអង្គអេង[221]




### ៥.៣-ការប្រជែងគ្នារបស់សៀម និងអាណ្ណាម នៅសតវត្សរ៍ទី១៩

ភាពច្របូកច្របល់ក្នុងប្រវត្តិសាស្ត្រខ្មែរនាសម័យឧដុង្គ ក្នុងការពឹងពាក់ប្រទេសជិតខាង ជាមូលហេតុដែលនាំឱ្យខ្មែរបែកបាក់សាមគ្គី ដោយមិនព្រមចរចាក្នុងឆ្នាំ១៨១០ ដល់១៨៣៤។ អំណាចរបស់សៀម-អាណ្ណាមក្នុងសតវត្សរ៍ទី១៩ បានបង្ហាញពីភាពខ្លាំងផ្នែកនយោបាយនៃប្រទេស ទាំងពីរលើកម្ពុជា ទោះបីជាការបំផ្លាញរបស់ភូមាទៅលើរាជធានីចាស់អយុធ្យា ក្នុងឆ្នាំ១៧៦៧ ដែលនាំឱ្យមានបដិវត្តន៍មួយ[222]នៅប្រទេសថៃក៏ដោយ។

ស្តេចរាមាទី១ (១៧៨២-១៨០៩) ទ្រង់បានលើករាជធានីរបស់ព្រះអង្គទៅបាងកក។ ក្នុងសម័យកាលរបស់ទ្រង់នៅតែមានសង្គ្រាមតូចៗខ្លះជាមួយភូមា ដែលថៃទទួលជ័យជម្នះ ហើយទំនាក់ទំនងជាមួយនឹងអាណ្ណាមនៅល្អដោយសារចំណងមិត្តភាពផ្ទាល់ពីមុនរវាងស្តេចរាមាទី១ និងស្តេចយ៉ាឡុង ហើយ ព្រះអង្គមានចាត់ទុកកម្ពុជាត្រូវតែស្ថិតនៅក្រោមរង្វង់អំណាចរបស់ក្រុងបាងកក ទោះបីនៅក្នុងរាជ្យរបស់ព្រះអង្គមិនមានសង្គ្រាមច្រើននៅកម្ពុជាក៏ដោយ។ ប៉ុន្តែ ទាំងស្តេចអង្គអេង និងទាំងស្តេចអង្គចន្ទ ត្រូវបាន រៀបអភិសេកជាស្តេចខ្មែរដោយសារស្តេចរាមាទី១នៅក្នុងបាងកក[223]។

ក្រោយពេលព្រះបាទឧទ័យរាជាអង្គចន្ទ ទ្រង់បានសោយរាជ្យនាឆ្នាំ១៨០៦ ទ្រង់បានជិតដិតជាមួយអាណ្ណាម ហើយបានលើកសួយសារអាករទៅថ្វាយស្តេចយ៉ាងឡុង៣ឆ្នាំម្តង។ ប៉ុន្តែជាមួយនេះ ព្រះអង្គក៏ទ្រង់នាំបណ្ណាការទៅថ្វាយស្តេចសៀមតាមទំនៀមដែរ។ ស្តេចសៀមមិនសព្វព្រះទ័យទេ ចំពោះការដែលព្រះអង្គចន្ទទ្រង់បានទាក់ទងនឹងស្តេចយួន ហើយទ្រង់បានបញ្ជាទ័ពចំនួន៥ ០០០នាក់ ឱ្យចូលមកកម្ពុជា ដោយយក

---

[221] បើយោងតាមឯកសារមហាបុរស របស់ អេង សុត នៅពេលដែលព្រះអង្គអេង យាងមកស្រុកខ្មែរ គឺអ្នកម្នាងទាំង៣របស់ទ្រង់ទុកឱ្យនៅរក្សាព្រះរាជបុត្រ ក្នុងក្រុងទេពបុរីសិន ព្រោះព្រះរាជបុត្រនៅក្មេង ហើយម្យ៉ាងទៀត អ្នកម្នាងអុត និងអ្នកម្នាងរស់ ក៏ទ្រង់គភ៌ផង។

[222] សន្តតិវង្សស្តេចចាស់ត្រូវបានបំផ្លាញ ហើយពួកមនុស្សថ្មីបានយកការដឹកនាំនយោបាយមិនចាប់អារម្មណ៍ពីព្រះអង្គម្ចាស់សន្តតិវង្សចាស់ដែលនៅមានព្រះជន្មនៅឡើយ។

[223] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ១៣១។

លេសថា មកជួយធ្វើបុណ្យសពព្រះអង្គកែវឌួង។ ប៉ុន្តែតាមការពិត សៀមលើកទ័ពតាមផ្លូវគោក (តាមខេត្តបាត់ដំបង និងតាមខេត្តស្ទឹងត្រែង) និងតាមផ្លូវទឹក គឺដើម្បីជួយសម្រេចកិច្ចផែនដីថ្វាយព្រះអង្គស្ងួន។ ទ័ពចម្រុះខ្មែរ-សៀម ប្រយុទ្ធគ្នានឹងទ័ពចម្រុះខ្មែរ-អាណ្ណាម តាមជើងគោកនិងតាមជើងទឹក។ ទ័ពចម្រុះខ្មែរ-សៀម មានប្រៀបជាង វាយបំបាក់ទ័ពខ្មែរ-អាណ្ណាម ឱ្យដកថយជាបន្តបន្ទាប់[224]។ យើងឃើញថា ទំនាក់ទំនងល្អរវាងស្តេចយ៉ាឡុង និងស្តេចរាមាទី១ ប្រហែលជាចង់និយាយថាមានជម្លោះតិចតួចលើទឹកដី កម្ពុជា[225] តែចាប់ពីឆ្នាំ១៨១១ មកបានបង្ហាញឱ្យឃើញពីការប្រជែងអំណាចគ្នារវាងសៀម យួន នៅលើ ទឹកដីកម្ពុជារហូតដល់មុនសន្ធិសញ្ញាថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣។

យើងឃើញថានៅឆ្នាំ១៨១៣ ស្តេចយ៉ាឡុង ទ្រង់បានបញ្ជាឱ្យ ឡេ វ៉ាន់យៀក ដែលមានឋានៈជាអុងតាគុន នាំក្បួនទ័ពចំនួន១០ ០០០នាក់ ដង្ហែព្រះអង្គចន្ទមកស្រុកវិញ។ ពេលទ័ពយួនបានមកដល់ កំពង់ហ្លួង មន្ត្រីសេនាបតីខ្មែរដែលមិនបានទៅតាមព្រះអង្គស្ងួន បានក្រាបថ្វាយបង្គំ ព្រះអង្គចន្ទ និងអបអរសាទរ ចំណែកឯមន្ត្រី និងមេទ័ពសៀមខ្លះ ភ័យស្រឡាំងកាំង ខ្លះទៀតថ្វាយព្រះពរចំពោះព្រះអង្គចន្ទ រួចហើយដកថយទៅស្រុកសៀមវិញ។ រហូតមកដល់ឆ្នាំ១៨១៤ សៀមបានលើកទ័ពមកបន្តទៀត ហើយម្តងនេះសៀមបានដណ្តើមយកខេត្តខ្មែរដោយត្រង់ៗតែម្តងគឺ ខេត្តមូលប្រៃ ទន្លេរពៅ និងស្ទឹងត្រែង។ នៅឆ្នាំដដែលនេះដែរ ឡេវ៉ាន់ យៀក បានអនុញ្ញាត ពីស្តេចយួនឱ្យសង់បន្ទាយនៅភ្នំពេញ និងនៅល្វាឯមហើយដាក់កងទ័ព ១ ០០០នាក់ ប្រចាំការធ្វើអាណាព្យាបាលលើកម្ពុជា។ ម្យ៉ាងទៀត ឡេវ៉ាន់ យៀក បានចាត់ឱ្យលើកដីសង់ «ដំណាក់ព្រះបារមី» មួយនៅជ្រោយចង្វាសម្រាប់មន្ត្រី យួន ខ្មែរ ទៅសំពះរំឭកគុណស្តេចយួន ដែលពេលនោះហើយព្រះរាជា និងនាម៉ឺនសព្វមុខមន្ត្រីស្លៀកពាក់តាមបែបយួន[226]។

នៅឆ្នាំ១៨៣២ មានការឈ្លានពានពីសៀម ហើយស្តេចអង្គចន្ទ បានភៀសខ្លួនព្រះអង្គម្តងទៀតទៅកាន់ប្រទេសវៀតណាម។ ឧត្តមសេនីយ៍សៀម (ឈ្មោះបូឌិន ដែលធ្លាប់ច្បាំងនៅប្រទេសឡាវ) បានយក ប្អូនប្រុសរបស់ព្រះអង្គចន្ទឈ្មោះអង្គអិម និងអង្គដួង មកភ្នំពេញ ហើយកងទ័ពសៀម បានបន្តច្បាំងជាមួយ អាណ្ណាម នៅ *ចូវដុក* ហើយវៀតណាមក៏ត្រូវទទួលបរាជ័យ។ ចំណែកការឈ្លានពានរបស់សៀមបន្តចូលមកដល់ឆ្នាំ១៨៣៣ ដល់១៨៣៤ មានការបះបោរដ៏ធំមួយនៅកម្ពុជាក្រោម[227]។

ក្នុងព្រះជន្ម៤៤វស្សាត្រូវនឹងឆ្នាំ១៨៣៤ព្រះបាទឧទ័យរាជាអង្គចន្ទបានសោយទិវង្គត[228]។ ទ្រង់មិនបានបន្សល់បុត្រាឡើយ ហើយប្អូនរបស់ទ្រង់ទាំងពីរអង្គគឺអង្គអិម និងអង្គដួងមិនបានឡើងសោយរាជ្យឡើយដោយសារតែមានទំនាក់ទំនងយ៉ាងល្អជាមួយសៀម។ ហេតុនេះហើយស្តេច មិញ ម៉ាង បានជ្រើសអង្គម៉ី ជាក្សត្រសោយរាជ្យ តែអំណាចពិតប្រាកដគឺស្ថិតក្រោមកណ្តាប់ដៃអាណ្ណាម ។

ការឡើងសោយរាជ្យសម្បត្តិរបស់ម្ចាស់ក្សត្រិយ៍អង្គម៉ី នាំឱ្យសៀមមិនសប្បាយចិត្តព្រោះកម្ពុជាត្រូវស្ថិតក្រោមអាណ្ណាម ទាំងស្រុង ហើយស្តេច មិញ ម៉ាង បានព្យាយាមអនុវត្តនយោបាយយួនតូបនីយកម្មពិតប្រាកដនៅកម្ពុជា។ ក្នុងឆ្នាំ១៨៤០ យួនបានព្យាយាមបញ្ចុះបញ្ចូលអង្គអិម, អង្គដួង មួយព្រះអង្គម្នាក់ម្តងៗបន្តបន្ទាប់

224 សូរ អឿ, *ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និង សៀម ចាប់ពីសតវត្សទី១៦,* ដ.ឯ.ម., ទំព័រ១០៣។

225 ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់,* ដ.ឯ.ម., ទំព័រ១៣៤។

226 សូរ អឿ, *ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និងសៀម ចាប់ពីសតវត្សទី១៦,* ដ.ឯ.ម., ទំព័រ១០៤-១០៥។

227 ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់,* ដ.ឯ.ម., ទំព័រ១៣៥។

228 អេង សុត, *ឯកសារមហាបុរស ខ្មែរ (លេខ២៦),* ដ.ឯ.ម., ទំព័រ១០៤៨។

គ្នាឱ្យយាងមកភ្នំពេញដើម្បីសោយរាជ្យ។ អង្គអិម បានជៀអាណ្ណាម ហើយក៏យាងមកភ្នំពេញ។ ទ្រង់បានគេនាំយកទៅអាណ្ណាម ហើយបានសោយទិវង្គតនៅទីនោះ។ សៀមបានចាប់ព្រះអង្គដួងនាំយក ព្រះអង្គត្រឡប់ទៅក្រុងបាងកកវិញ[229]។ ការប៉ះទង្គិចខ្លាំងក្លារវាងផលប្រយោជន៍សៀម និងអាណ្ណាម នៅកម្ពុជា កើតឡើងនៅពាក់កណ្តាលទី១មួយនៃសតវត្សរ៍ទី១៩។ ដោយមានជំនួយពីបារាំងជ្រើសរើសដោយសង្ឃកាតូលិក,ពីញ៉ូដឺបេអែន, អង្គម្ចាស់ត្រកូលង្វៀង, ភឹក អាញ់ មានជោគជ័យលើគូប្រជែង ហើយបានឡើងជាអធិរាជលើប្រទេសយួនទាំងមូលតាមរាជនាមយ៉ាឡុង។ ដូច្នេះនៅសតវត្សរ៍ទី១៩ យួនមាន សមត្ថភាពអាចប្រឈមមុខជាមួយសៀម នៅកម្ពុជាបាន[230]។

ជាលទ្ធផលនៅក្នុងឆ្នាំ១៨៤៧ សៀម និងអាណ្ណាម បានព្រមព្រៀងឱ្យអង្គដួងសោយរាជ្យ ហើយនឹងដកកងទ័ពចេញពីកម្ពុជា។ នោះមិនមែនមានន័យថា កម្ពុជាមានឯករាជ្យទាំងស្រុងទេ។ យោងទៅលើ ទំនាក់ទំនងអន្តរជាតិនៃសម័យនោះកម្ពុជានៅក្រោមអាណាព្យាបាលទាំងសៀម និងទាំងអាណ្ណាម។ ព្រះអង្គដួង ត្រូវតែផ្ញើសួយសារអាករទៅប្រទេសយួន ៣ឆ្នាំម្តង និងទៅសៀមរៀងរាល់ឆ្នាំ។ ព្រះអង្គមិនទាមទារយកទឹកដី ដែលត្រូវបានបាត់បង់ទៅសៀម និងអាណ្ណាម ត្រឡប់មកវិញបានទេ[231]។

## ៥.៤-ដំណោះស្រាយបញ្ចប់សង្គ្រាមនៅសតវត្សរ៍ទី១៩

ពាក្យសង្គ្រាមមានន័យថាចម្បាំង[232]។ សង្គ្រាមជាបញ្ហាចោទដែលបង្កឡើងដោយមនុស្ស ដែលខុសពីធម្មជាតិគឺមនុស្សជាអ្នកបង្កើតសង្គ្រាមដើម្បីផលប្រយោជន៍ ហើយសង្គ្រាមត្រូវបញ្ចប់ដោយមនុស្ស ព្រោះតែប្រយោជន៍។ នៅអាស៊ីដីគោកពីសតវត្សរ៍ទី១៨ ដល់ពាក់កណ្តាលទី១ សតវត្សរ៍ទី១៩ បានកើតនូវសង្គ្រាមជាញឹកញាប់រវាងប្រទេសអាណានិគម និងប្រទេសក្នុងតំបន់ និងជាសង្គ្រាមស៊ីវិល។ នៅឆ្នាំ១៧៦៧ ប្រទេសភូមាបានឈ្លានពាន និងដណ្តើមបានអយុធ្យា តែរហូតមកដល់ឆ្នាំ១៨២៤ អង់គ្លេសបានប្រកាសសង្គ្រាមជាមួយភូមា។ ចំណែកឯប្រទេសអាណ្ណាម ក្នុងរជ្ជកាលស្តេច ទឺ ឌឹក (១៨៤៨-១៨៨៣) បុត្រាស្តេច ធីវ ទ្រី គឺមានសង្គ្រាមរវាងបារាំង និងអាណ្ណាម បានកើតឡើង។ ចំណែកប្រទេសថៃគឺបានរួចផុតពីអាណានិគមរបស់បរទេសដោយគ្រាន់តែទទួលរងឥទ្ធិពលបន្តិចបន្តួចប៉ុណ្ណោះ។ សង្គ្រាមទាំងអស់គឺកើតឡើងដើម្បីបម្រើប្រយោជន៍សេដ្ឋកិច្ចការ សាសនា និងមហិច្ឆតានយោបាយប្រទេសខ្លួន ដែលសង្គ្រាមខ្លះទទួលជ័យជម្នះដោយចុងកាណុង និងការប្រឈមមុខដាក់គ្នាក្នុងសមរភូមិ តែសង្គ្រាមខ្លះក៏ត្រូវបញ្ចប់ដោយការចរចាផងដែរ។

ដោយឡែកសង្គ្រាមនៅកម្ពុជាដែលកើតឡើងចាប់ពីឆ្នាំ១៧៤៨ ដល់ឆ្នាំ១៨៤៨ គឺជាសង្គ្រាម ដណ្តើមអំណាចក្នុងស្រុកក្រោមឧបសម្ព័ន្ធសៀម-អាណ្ណាម។ សង្គ្រាមត្រូវបានដោះស្រាយដោយការចរចា និងការទទួលបានប្រយោជន៍ទាំងសងខាង។ ប៉ុន្តែប្រយោជន៍ដែលច្រើនលើសលប់នោះគឺបានទៅខាងសៀម និងអាណ្ណាម ដែលតែងតែដើរតួនាទីជាអាណាព្យាបាល ការផ្តល់ជំនួយដល់មេដឹកនាំណាដែលស្មោះស្ម័គ្រកក្តីបម្រើប្រយោជន៍គេ។

---

229 ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ១៣៥។

230 សោម សេកកុមា, *វិបត្តិកម្ពុជា និងទំនាក់ទំនងជាមួយបរទេស: កម្រងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងមេរៀននយោបាយក្រៅប្រទេសខ្មែរ សម្រាប់សតវត្សរ៍ទី២១*, ប៉ារីស៍, ឆ្នាំ២០០០, ទំព័រ១៤។

231 ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ១៣៦។

232 ជួន ណាត, *វចនានុក្រមខ្មែរ*, ដ.ឯ.ម., ទំព័រ១២៤០។

ក្រោយការឡើងសោយរាជ្យមិនបានយូរប៉ុន្មានទេ គឺនៅឆ្នាំ១៨១១ មានការឈ្លានពានពីប្រទេសសៀម ហើយព្រះឧទ័យរាជាអង្គចន្ទបាននាំគ្រួសារភៀសខ្លួនទៅអាណ្ណាម ហើយអង្គអិម, អង្គដួង បានវិលទៅក្រុងបាងកក។ រហូតមកដល់ឆ្នាំ១៨១២ ដើម្បីរក្សារាជ្យសម្បត្តិ និងនគរគឺព្រះបាទឧទ័យរាជាអង្គចន្ទបានសម្រេចចិត្តផ្តល់ប្រយោជន៍ជូនទាំងខាងសៀមផង និងអាណ្ណាម ផង។ ក្រោយពីព្រះបាទសម្តេចឧទ័យរាជា ទ្រង់ចាត់ឧកញ៉ាឯករាជ្យ ឧកញ៉ាមន្ត្រីសុរវង្ស ជារាជទូតឱ្យអញ្ជើញព្រះរាជសារ និងរាជបណ្ណាការ ទៅថ្វាយ ស្តេចសៀមដោយផ្លូវព្រះរាជមេត្រី។ ព្រះពុទ្ធឡឺតឡានកាល័យ[233] ទ្រង់មានព្រះទ័យអំណរពន់ពេក[234]។ ចំណែកខាងប្រទេសយួនវិញ ព្រះឧទ័យរាជាអង្គចន្ទ បានពេញចិត្តក្រោមរដ្ឋបាលប្រទេសយួន។ នៅឆ្នាំ១៨១៥ ត្រូវនឹងថ្ងៃទី១៣ កើត ខែមិគសិរ ឆ្នាំកុរ ស្តេចយួនត្រាស់ប្រើអុងយមរាជថាញ់ អុងប៊ិញថាញ់ អុង ផឡឹង (អុងឡឹង) នាំទ័ព ៣ ០០០នាក់ និងខ្មែរខេត្តព្រះត្រពាំង១ ០០០នាក់ឡើងទៅធ្វើបន្ទាយនៅមាត់ជ្រូក[235] ហើយប្រជាជនខ្មែរជាច្រើនត្រូវបង្ខំឱ្យទៅជីកព្រែកវិញតេ ឬហាទៀង[236] របស់អាណ្ណាម ដែលឥឡូវនេះស្ថិតនៅតាមព្រំដែនរវាងកម្ពុជា និងអាណ្ណាម [237] និងព្រែកជីកវិញអាន ប្រវែងប្រមាណ១៤គីឡូម៉ែត្រ ទទឹង២៤ម៉ែត្រតភ្ជាប់ទន្លេធំ និងទន្លេបាសាក់។ ក្រៅពីទឹកដីជាច្រើនដែលបានបាត់បង់មុនរជ្ជកាលទ្រង់ក៏ទ្រង់មិនបានទាមទារមកវិញផងដែរ។

នៅក្នុងដែនដីម្ចាស់ក្សត្រីអង្គម៉ី ទ្រង់បានថ្វាយសំបុត្រដល់ព្រះបាទអង្គដួង ដើម្បីសុំឱ្យព្រះអង្គធ្វើ យ៉ាងណាបង្កើតសន្តិភាពនៅឆ្នាំ១៨៤៣។ ដែលក្នុងខ្លឹមសារសំបុត្រនោះព្រះនាងបានបង្ហាញពីទុក្ខ ព្រះទ័យក្នុងការអាណិតអាសូររាស្ត្រខ្មែរ និងចង់ឱ្យមានការឡើងចុះជួញប្រែ រវាងរាស្ត្រខ្មែរ និងរាស្ត្រអាណ្ណាម និងសុំឱ្យសម្តេចអង្គដួង ជាព្រះបិតុលា ប្រាប់ពីចិន្តារបស់ទ្រង់អំពីរាជការបែបណា គឺសូមមានព្រះបន្ទូល ត្រឡប់តាមឧកញ៉ាមហាមន្ត្រីឈ្មោះកែ និងឧកញ៉ានាយកឈ្មោះស្រី ដើម្បីទ្រង់យកដំណឹងនៅទៅថ្វាយស្តេចយួន(ស្តេចទេព្វា)។

នៅឆ្នាំ១៨៤៣ព្រះមាតារស់ បានផ្ញើសំបុត្រមួយច្បាប់ទៅ ព្រះអង្គ។ បើតាមព្រះរាជសារនេះព្រះមាតារស់ ទ្រង់ចង់បានការសម្រេចចិត្តពីសម្តេចអង្គដួងធ្វើយ៉ាងណាបង្កើតឱ្យមានសន្តិភាពនៅប្រទេសកម្ពុជាឡើងវិញ ហើយបើសិនសព្វព្រះរាជហឫទ័យនោះ ឱ្យទូលមក ហើយឱ្យអ្នកបម្រើដែលនាំព្រះរាជសារនោះទៅនាំត្រឡប់មកវិញ ដើម្បីឱ្យព្រះមាតារស់ បានជ្រាបព័ត៌មានទៅប្រាប់ដល់អុងថុកប៉ូ ដែលជាមេទ័ពបោះបន្ទាយនៅមាត់ជ្រូកដើម្បីឱ្យគាត់ស្នើសុំស្តេចយួន[238]ធ្វើការចរចាអំពីការសម្រេចចិត្តនាំឱ្យមានសន្តិភាពនៅស្រុកខ្មែរ[239]។

ចំណែកខាងអាណ្ណាម ក៏មានសំបុត្រមួយទៀតដែលបង្ហាញពីការចរចារវាងសៀម-អាណ្ណាម ផងដែរ។ នៅក្នុងសំបុត្ររបស់មេទ័ពយួន ដែលសរសេរណែនាំប្រាប់អំពីមន្ត្រីរបស់គេ បញ្ជូនឱ្យទៅសហការជាមួយចៅហ្វាយខេត្តបាភ្នំ ដើម្បីធ្វើបន្ទាយការពារនៅទីនោះ[240] បានបង្ហាញពីខ្លឹមសារនៃការចរចារវាងមេទ័ពអាណ្ណាម-ទ័ពសៀម គឺស្តេចទាំងពីរនោះលោកចរចាគ្នាឱ្យមានសន្តិភាព ដើម្បីឱ្យប្រជារាស្ត្រទាំងអស់រកស៊ីចេញចូលក្នុងដែនដីគ្នាគ្រប់គ្រងនោះកុំឱ្យមានភ័យភិត ហើយអ្នកណាធ្លាប់បង្កការលំបាក ធ្លាប់ចាប់គេ ធ្លាប់ប្រព្រឹត្តខុសពីមុនមក ស្តេច

[233] ទ្រង់ជាព្រះរាជបុត្ររបស់ព្រះចៅថៃ «ពុទ្ធយ៉តហ្វាចុឡាលោក» ដែលបានសោយទិវង្គតនៅឆ្នាំ១៨០៩។

[234] អេង សុត, *ឯកសារមហាបុរស ខ្មែរ (លេខ៦៦)*, ដ.ឯ.ម., ទំព័រ១០៥២។

[235] -ដ- ទំព័រ១០៥២។

[236] ព្រែកវិញតេ ប្រវែងប្រមាណ៥៣គីឡូម៉ែត្រ តភ្ជាប់ពីមាត់ជ្រូកទៅនឹងសមុទ្រនៅតំបន់៣ម។

[237] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ១៣៤។

[238] ក្នុងព្រះរាជសារដាក់ថាស្តេចទេព្វា។

[239] ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ២០៤។

[240] -ដ- ២០៥។

យួន ឈប់ចាប់ទោសអូសដំណើរ ហើយលើកលែងឱ្យ និងផ្ដាំឱ្យមកស្រុកវិញ ដើម្បីប្រកបការងាររកស៊ីតាមធម្មតាឡើងវិញនៅឆ្នាំ១៨៤៣។ បែបនេះហើយបានជាក្រោយ២ឆ្នាំមកមានការចរចាគ្នារវាងមេទ័ពអាណ្ណាម និងសៀម។

សរុបមក ជម្លោះដណ្ដើមអំណាចនៅស្រុកខ្មែរ ត្រូវបានបញ្ចប់ដោយសន្តិភាព និងការចូលរួមចរចាដោយភាគីខ្មែរ សៀម អាណ្ណាម (យួន) ដោយការបែងចែកផលចំណេញរៀងៗខ្លួន ដែលសម្រេចឡើងនៅឆ្នាំ១៨៤៦ ដែលមានការប្ដូរឈ្លើយសង្គ្រាមគ្នាដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា។

## ៦-ព្រះបាទអង្គដួង និងទំនាក់ទំនងបារាំង-ខ្មែរ(១៨៤៧-១៨៥៦)

នៅឆ្នាំ១៨៤៧ ព្រះបាទអង្គដួងបានឡើងសោយរាជ្យនៅឧដុង្គ។ បន្ទាប់មក ដោយមានកង្វល់ចំពោះអនាគតមិនទៀងទាត់នៃប្រទេសកម្ពុជា ដែលកាលនោះ បានស្ថិតនៅក្រោមឥទ្ធិពលនៃប្រទេសសៀមនោះ ព្រះអង្គបានចាប់ផ្ដើមនូវទំនាក់ទំនងជាមួយប្រទេសបារាំង ដែលជាមហាអំណាចមួយនៅទ្វីបអឺរ៉ុប។ ការឡើងសោយរាជ្យរបស់ព្រះបាទអង្គដួងមានអត្ថន័យជាប្រវត្តិសាស្ត្រដ៏សំខាន់ ដោយបានបើកឡើងនូវសករាជថ្មីមួយ ជួយឱ្យកម្ពុជាផុតពីទុក្ខវេទនាបានមួយកម្រិត ហើយគឺជាឱកាសដែលមានការចាប់ផ្ដើមនូវកំណែទម្រង់ ថ្នាក់ជាតិ ជាពិសេស ក្នុងវិស័យរដ្ឋបាល តុលាការ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសាសនា។ ប៉ុន្តែវាសនាអនាគតនៃប្រទេសកម្ពុជានាពេលនោះ ស្ថិតនៅក្នុងភាពស្រពេចស្រពិលនៅឡើយ។ ដូច្នេះហើយបានជាព្រះបាទអង្គដួងបានព្យាយាមស្វែងរកនូវភាពកក់ក្ដៅ ដោយជ្រើសរើសយក"ដំណោះស្រាយបារាំង" តាំងពីឆ្នាំ១៨៤៨ ដើម្បីភាពគង់វង្សនៃរាជវង្ស និងប្រជាជាតិខ្មែរ ។

នៅឆ្នាំ១៨៥៣ ព្រះបាទអង្គដួងបានផ្ញើព្រះរាជសារទៅថ្វាយអធិរាជណាប៉ូលេអុងទី៣ នៃប្រទេសបារាំង ដើម្បីស្ថាបនាសម្ពន្ធភាពជាមួយបារាំង។ ព្រះរាជសារនេះមានខ្លឹមសារថា «ពួកបេសកបព្វជិតបារាំងបានប្រាប់ឱ្យយើងដឹងថា អធិរាជបារាំងមានចិត្តសប្បុរសចំពោះគ្រប់ប្រជាជាតិ។ ព្រះអង្គជួយការពារប្រជាជាតិទាំងនោះ ដើម្បីធានាស្ថិរភាព និងសុខុមាលភាពដោយមិនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជនម្ចាស់ស្រុក និងថា អធិរាជបារាំងល្អ និងពុំមានការប៉ុនប៉ងដូចព្រះមហាក្សត្រនានានៃទ្វីបអឺរ៉ុប ដែលគិតតែ ជិះជាន់ប្រទេសដទៃក្រៅពីប្រទេសរបស់ខ្លួន។ ដោយហេតុនេះ យើងមានសេចក្ដីរីករាយនឹងចងសម្ពន្ធភាពមួយរឹងមាំ ជាមួយព្រះចៅអធិរាជ ដែលនឹងធ្វើឱ្យប្រទេសរបស់យើងធំ និងសម្បូណ៌ ដើម្បីសេចក្ដីរុងរឿងរបស់ប្រទេសយើង» ។

នៅឆ្នាំ១៨៥៦ មានអនុសញ្ញាពាណិជ្ជកម្មនិងសាសនាថ្ងៃទី១៨ តុលា ១៨៥៦ បានកើតឡើង។ អនុសញ្ញាពាណិជ្ជកម្ម និងសាសនា រវាងព្រះបាទអង្គដួង និងលោកសាល ដឺ ម៉ុងទីញី (Charles de Montigny) អ្នកការទូតបារាំង ជាតំណាងព្រះចៅអធិរាជណាប៉ូឡេអុងទី៣។ យើងយកតែមាត្រាដែលពាក់ព័ន្ធនឹង ពាណិជ្ជកម្ម និងសាសនា ដែលមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោមស្ដីពីពាណិជ្ជកម្មថាជនជាតិបារាំងនឹងអាចទិញ និងលក់ទំនិញ នៅគ្រប់អាណាខេត្តនៃប្រទេសកម្ពុជា ដោយមានសេរីភាពពេញលេញ និងពុំមានការរារាំងពីក្រុមហ៊ុនផ្ដាច់មុខណាមួយ លើកលែងតែអាជីវកម្មអាភៀន ដែលជាអាជីវកម្មផ្ដាច់មុខរបស់រដ្ឋ (មាត្រា៣)។ ទំនិញនាំចូល ឬនាំចេញដោយនាវាបារាំង នឹងត្រូវបង់ពន្ធគយតែមួយគត់ គឺ៣%តាមមុខតម្លៃ ដែលត្រូវបង់នៅពេលដាក់ទំនិញចុះ ឬពេលផ្ទុកទំនិញ ហើយមិនត្រូវបង់ពន្ធក្នុងស្រុក ពន្ធឆ្លងកាត់ ឬពន្ធ ដទៃផ្សេងទៀតឡើយ (មាត្រា៤)។ នាវាចម្បាំង និងនាវាជំនួញបារាំងនឹងចូលមកក្នុងកំពង់ផែទាំងអស់នៃកម្ពុជាដោយសេរី ដោយមិនត្រូវបង់ពន្ធ និងត្រូវចាត់ទុកដូចជានាវាកម្ពុជា និងរបស់ព្រះរាជផ្ទាល់ព្រះអង្គ(មាត្រា៥)។ ចំពោះសាសនាវិញគឺជនជាតិបារាំងអាចធ្វើដំណើរ និងតាំងទីលំនៅដោយសេរីនៅគ្រប់អាណាខេត្តនៃព្រះរាជាណាចក្រកម្ពុជា

អាចប្រតិបត្តិសាសនារបស់គេជាសាធារណៈ អាចទិញដីធ្លីសង់វិហារ ទីលំនៅ។ល។ និងអាចប្រកបរបរជំនួញ ឬឧស្សាហកម្ម នៅលើដីធ្លីនោះ(មាត្រា២)។ បេសកបព្វជិតបារាំងនឹងមានសិទ្ធិទេសនា និងបង្រៀនអំពីសាសនាកាតូលិក មានសិទ្ធិសង់ វិហារ លំនៅដ្ឋានអ្នកបួស មន្ទីរពេទ្យ និងសំណង់ផ្សេងទៀត នៅទីណាក៏បានក្នុង ព្រះរាជាណាចក្រកម្ពុជា។ គេនឹងមានសេរីភាព ពេញលេញក្នុងការធ្វើដំណើរនៅលើផ្ទៃនៃ ប្រទេសកម្ពុជា ដោយគ្រាន់តែមានលិខិតបញ្ជាក់ពីមន្ត្រីកុងស៊ុលបារាំង ឬក្នុងករណីអវត្ត មានមន្ត្រីកុងស៊ុល ត្រូវមានលិខិតពីមន្ត្រីសង្ឃ ដែលបញ្ជាក់ពីអត្តសញ្ញាណរបស់ជនទាំងនោះ និងមានសេចក្តីបញ្ជាក់ពីចៅហ្វាយខេត្តនៃខេត្តណាមួយ ដែលគេចង់ធ្វើដំណើរទៅកាន់នោះ (មាត្រា១០)។

គួរបញ្ជាក់ថា លោក សាល ដឺ ម៉ុងទីញី បានតាក់តែងខ្លឹមសារនៃអនុសញ្ញានេះ សម្រាប់ចុះហត្ថលេខាជាមួយព្រះបាទអង្គដួង នៅកំពង់ផែកំពត។ ប៉ុន្តែ ដោយមានការគាបសង្កត់ពីសៀម ព្រះបាទអង្គដួងមិនបានយាងទៅកំពតដើម្បីឡាយព្រះហស្តលេខាលើអនុសញ្ញានេះជាមួយលោក សាល ដឺ ម៉ុងទីញី ទេ មានន័យថាអនុសញ្ញានេះគ្មានតម្លៃគតិយុត្តិសម្រាប់យកមកអនុវត្តបានឡើយ។ ទោះជាយ៉ាងនេះក្តី ក៏មានមាត្រាមួយចំនួនត្រូវបានយកប្រើនៅក្នុងសន្ធិសញ្ញាអាណាព្យាបាលនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣។ សាល ដឺ ម៉ុងទីញី (Charles de Montigny) អ្នកការទូតបារាំងបានមកដល់កំពតនៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៨៥៦ ដោយមានបំណងចុះហត្ថលេខាលើអនុសញ្ញាពាណិជ្ជកម្ម និងសាសនា ជាមួយព្រះបាទអង្គដួង។ នៅទីនោះ លោកបានតាក់តែងអត្ថបទអនុសញ្ញានេះ ដែលចុះកាលបរិច្ឆេទថ្ងៃទី១៨ ខែតុលា ឆ្នាំ១៨៥៦ ហើយបាន ចុះហត្ថលេខាមុននឹងបន្តដំណើរទៅកាន់អាណ្ណាម និងផ្ញើមកថ្វាយព្រះបាទអង្គដួង នៅរាជវាំងឧដុង្គ។ ព្រះអង្គមិនបានឡាយព្រះហស្តលេខាលើអនុសញ្ញានេះទេ ដោយសារមានការគាបសង្កត់ពីសៀម។ ដូច្នេះ ព្រះរាជបំណងចង់ស្ថាបនាសម្ពន្ធភាពជាមួយបារាំង នៅពេលនោះត្រូវទទួលបរាជ័យ[241]។

**៧-សំណួរត្រិះរិះ**

១-តើវិភាពរបស់ព្រះមហាក្សត្រខ្មែរក្នុងសម័យឧដុង្គក្នុងការរក្សាអត្តសញ្ញាណជាតិមានអ្វីខ្លះ? តើមរតកប្រវត្តិសាស្ត្របន្សល់ទុកពីសម័យឧដុង្គ ផ្តល់ប្រយោជន៍អ្វីខ្លះដល់បច្ចុប្បន្ន?

២-តើការមកដល់របស់អឺរ៉ុបបានធ្វើឱ្យនយោបាយ ពាណិជ្ជកម្ម សេដ្ឋកិច្ច អប់រំ និងសាសនាក្នុងសង្គមខ្មែរប្រែប្រួលយ៉ាងដូចម្តេចខ្លះ?

៣-តើការខិតខំប្រឹងប្រែងរបស់ព្រះបាទអង្គដួងក្នុងការបង្កើតទំនាក់ទំនងជាមួយបារាំងបន្សល់នូវអ្វីខ្លះ សម្រាប់ប្រជារាស្ត្រខ្មែរនាសម័យកាលនោះ និងពេលបច្ចុប្បន្ន?

៤-តើអ្នកយល់បែបណាចំពោះទំនាស់រវាងព្រះបាទឧទ័យ និងរាជសម្ភារដោយសារតែម៉ែឃ្លូវតី ឬ ដោយសារតែការចង់ក្តោបក្តាប់អំណាចរបស់ព្រះបាទឧទ័យ? ចូរពន្យល់ដោយបញ្ជាក់ពីហេតុផល។

៥-តើព្រះបាទអង្គដួងមានតួនាទីអ្វីខ្លះក្នុងប្រវត្តិសាស្ត្រខ្មែរ? ចូរពន្យល់។

---

[241] ស៊ន សំណាង, *សិក្ខាសាលាពង្រឹងវិធីសាស្ត្រ ថ្នាក់ក្រោយបរិញ្ញាបត្រ ឆ្នាំសិក្សា២០២១-២០២២: ព្រះបាទអង្គដួង និងទំនាក់ទំនងបារាំង-ខ្មែរ (ឆ្នាំ១៨៤៧-១៨៥៦)*, ថ្ងៃសុក្រទី១០ ខែធ្នូ ឆ្នាំ២០២១។

## មេរៀនទី១០ ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង(១៨៦៣ ដល់១៩៥៣)

ការសិក្សាស្រាវជ្រាវពីប្រទេសកម្ពុជាចាប់ពីឆ្នាំ១៨៦៣ ដល់១៩៥៣ យើងអាចបែងចែកជា៣ផ្នែកៈ

១-ប្រវត្តិសាស្ត្រប្រទេសកម្ពុជានៅដើមសម័យបារាំង(១៨៦៣-១៨៩៧)

២-ប្រវត្តិសាស្ត្រប្រទេសកម្ពុជានៅកណ្តាលសម័យបារាំង(១៨៩៧-១៩៤៥)

៣-ប្រវត្តិសាស្ត្រប្រទេសកម្ពុជានៅចុងសម័យបារាំង(១៩៤៥-១៩៥៣)

នយោបាយអាណានិគម គឺជានយោបាយដែលបម្រើឱ្យនយោបាយឧស្សាហកម្ម។ ដូច្នេះ ការដាក់អាណានិគម ឬ អាណាព្យាបាលរបស់ប្រទេសមហាអំណាចអាណានិគមមានគោលបំណងសំខាន់៣ គឺពង្រីកដែនដីអាណានិគម, ស្វែងរករូបធាតុដើម និងទីផ្សារ ដើម្បីបម្រើវិស័យសេដ្ឋកិច្ច និងការផ្សព្វផ្សាយនូវសង្គមស៊ីវិល័យរបស់ខ្លួន។ ប៉ុន្តែគោលដៅរកទីផ្សារអន្តរជាតិសម្រាប់លក់ និងទិញ ពួកគេបានប្រើវិធីសំខាន់ពីរ គឺការចរចា និងវាយយកដើម្បីសម្រេចគោលបំណងរបស់ពួកគេ។ សម្រាប់នៅឥណ្ឌូចិនក្រោមលេសធ្វើអន្តរាគមន៍លើការធ្វើទុក្ខបុកម្នេញលើ គ្រិស្តសាសនិករបស់ខ្លួននៅកូសាំងស៊ីន គឺនៅឆ្នាំ១៨៥៩ កងទ័ពបារាំងបានវាយកាន់កាប់ទីក្រុងព្រៃនគរ និងតំបន់ជិតខាង ព្រមទាំងប្រែក្លាយវៀតណាមភាគខាងត្បូងសព្វថ្ងៃ ឱ្យទៅជាដែនដីបារាំងឯនាយសមុទ្រនៅឆ្នាំ១៨៦២ដោយមានឈ្មោះថា កូសាំងស៊ីន។ បារាំងបានគ្រប់គ្រងតុងកឹងនៅឆ្នាំ១៨៨៣។ ចំណែកយួន-អាណ្ណាម(វៀតណាមកណ្តាល) ក៏បានធ្លាក់ក្រោមការគ្រប់គ្រងរបស់បារាំងនៅឆ្នាំជាមួយគ្នានោះដែរ។ ឆ្នាំ១៨៨៥ ប្រទេសវៀតណាមទាំងមូលស្ថិតក្រោមការត្រួតត្រារបស់បារាំង។ ចំណែកប្រទេសឡាវបានស្ថិតក្រោមអាណាព្យាបាលបារាំងឆ្នាំ១៨៩៣ ហើយកម្ពុជាស្ថិតក្រោមអាណាព្យាបាលនៅឆ្នាំ១៨៦៣។ អំណោយផលនៃការប្រកួតប្រជែងគ្នា រវាងមហាអំណាចអាណានិគមធំពីរនៅអាស៊ីអាគ្នេយ៍គឺអង់គ្លេស និងបារាំងបានផ្តល់ឱកាសឱ្យប្រទេសសៀមក្លាយជា «រដ្ឋទ្រនាប់(Buffer State/État tampon)» នៅចន្លោះមហាអំណាចអាណានិគមទាំងពីរនេះ។ ប៉ុន្តែ នៅផ្នែកដែលជាប់ជាមួយភូមា ជនជាតិនេះទទួលឥទ្ធិពលពីអង់គ្លេស និងផ្នែកដែលជាប់ជាមួយកម្ពុជា ពួកគេទទួលឥទ្ធិពលពីបារាំង។ ចំពោះទីក្រុងបាងកកមិនបានទទួលឥទ្ធិពលពីមហាអំណាចណាមួយឡើយ។ ទោះបីជាយ៉ាងណាក៏ដោយមានភាពវៃឆ្លាតក្នុងការសម្របសម្រួល ជាមួយមហាអំណាចអាណានិគមផងដែរ។ ប៉ុន្តែការគ្រប់គ្រងនៅឥណ្ឌូចិនគេ ហៅថា អាណានិគមអាជីវកម្ម(Colonie d'exploitation) ដែលជាអាណានិគមនៅក្រោមបារាំងសម្រាប់ទាញ យកផល[242]។ ទម្រង់នេះអាណានិគមនេះ មិនដូចគ្នានឹងអាណានិគមប្រជាជនតាំងប្រជាជន(Colonie de peuplement) ឬ អាណានិគមប្រជាសាស្ត្រ ដូចនៅប្រទេសអាល់សារី (Algeria)នោះទេ។ ចំពោះប្រទេសកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំងអស់រយៈពេល៩០ឆ្នាំ ចាប់ពីឆ្នាំ១៨៦៣ ដល់១៩៥៣ ហើយ ចាប់ពីឆ្នាំ១៨៨៤ ដល់១៩៤៥ ត្រូវបានប្រវត្តិវិទូ មួយចំនួនគិតថាជាអាណានិគមនៅកម្ពុជា។ ប៉ុន្តែបើយោងទៅតាមទម្រង់ច្បាប់ និងរដ្ឋបាលគតិយុត្តិ គឺប្រទេសកម្ពុជាស្ថិតក្រោមអាណាព្យាបាលមិនមែនអាណានិគមទេ តែយើងក៏អាចហៅបានថាក្រោមអាណានិគមកម្ម។ សម្រាប់ការគ្រប់គ្រងរបស់បារាំងនៅកម្ពុជាមាន៣ជំហានសំខាន់ៗគឺការប្រើអំណាចផ្លូវច្បាប់អន្តរជាតិ, កំណែទម្រង់រដ្ឋបាលឱ្យស្របតាមតម្រូវការរបស់មហាអំណាចអាណានិគម និងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា[243]។

[242] ទម្រង់អាណានិគមបែបនេះគេបញ្ជូនតែអ្នកជំនាញមកគ្រប់ ដើម្បីទាញយកផលតែប៉ុណ្ណោះ។

[243] ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម.,២៥១-២៥២។

**និវេសនដ្ឋាន រ៉េស៊ីដង់បារាំង ១៨៨៥**




## ១-កម្ពុជានាសម័យដំបូងនៃអាណាព្យាបាល[244]

បន្ទាប់ពីព្រះបាទអង្គដួងសោយទិវង្គតនៅឆ្នាំ១៨៦០ ក្រុមប្រឹក្សារាជបល្ល័ង្កបានលើកក្សត្រអង្គវតីឱ្យស្នងរាជ្យបន្ត។ ដោយមានការប្រឆាំងពីអនុជទាំងពីរគឺស៊ីវត្ថា និងសិរីវង្ស[245]និងការបះបោរដឹកនាំដោយ ស្នងសូរ ដែលបណ្ដាលមកពីប្រពៃណី «រាជាធិបតេយ្យជ្រើសតាំង»[246] នោះអង្គវតីបាននាំយកគ្រឿង រាជាភិសេកទៅបាងកកនាខែសីហា ឆ្នាំ១៨៦១។ ក្នុងឱកាសនោះព្រះអង្គម្ចាស់ស៊ីសុវត្ថិទទួលរ៉ាប់រងកិច្ចការប្រទេស និងរុញច្រានចលនាបះបោររបស់ស៊ីវុត្ថាឱ្យថយទៅខាងជើងប្រទេស។ អង្គវតីបានយាងពីបាងកកមកកាន់ក្រុងឧដុង្គវិញនៅខែមីនាឆ្នាំ១៨៦២។ បើតាមការរៀបរាប់របស់លោក លោកម្ញ៉ាគី ព្រះបាទនរោត្តម មិនមែនជាអ្នកគាំទ្ររបបអាណាព្យាបាលបារាំងទេ។ ព្រះបាទអង្គដួង ជាព្រះបិតា បានសុំជំនួយពីប្រទេសបារាំង ប្រឆាំងនឹងការទន្ទ្រានកាន់កាប់ពីអ្នកជិតខាងទាំងពីរ។ បារាំងមិនបានឆ្លើយតបនឹងសំណើរបស់ ព្រះអង្គទេ។ ប៉ុន្តែបន្ទាប់មក រដ្ឋាភិបាល

---

[244] បារាំងចាប់អារម្មណ៍ចំពោះកម្ពុជាផងដែរនូវ៖

- កិត្យានុភាពរបស់កម្ពុជា តាមរយៈស្នាដៃនិពន្ធរបស់លោក ហង់រី មូហូត៍[244]
- សម្បូរទៅដោយទន្លេ ដែលជាផ្លូវគមនាគមន៍យ៉ាងសំខាន់សម្រាប់ដឹកជញ្ជូន ផលិតផលកសិកម្មទៅកាន់ទីផ្សារអឺរ៉ុប
- មានផ្ទៃដីកសិកម្មច្រើន មានប្រជាជនតិច អាចបង្កើតជាដីដាំដំណាំកសិកម្ម បានផលច្រើន
- សម្បូរដោយព្រៃភ្នំប្រកបដោយឈើដែលមានគុណភាពខ្ពស់
- សម្បូរទៅដោយរ៉ែនៅក្រោមដី ដែលធ្វើឱ្យបារាំងប៉ុនប៉ងយកទៅបម្រើវិស័យឧស្សាហកម្មជាតិខ្លួន។
- នៅក្នុងតំបន់ទាំងឡាយក្បែរប្រទេសខ្មែរមានចលនាតស៊ូប្រឆាំងនឹងបារាំង ធ្វើឱ្យបារាំងចងសម្ពន្ធភាពជាមួយខ្មែរ។
- បារាំងខ្លាចបាត់បង់ប្រទេសខ្មែរ ព្រោះនៅពេលនោះចក្រភពអង់គ្លេសក៏កាន់តែមានឥទ្ធិពលខ្លាំងឡើងៗជាមួយក្រុងបាងកក[244]។
- បារាំងយល់ថាទន្លេមេគង្គអាចធ្វើដំណើរ និងធ្វើពាណិជ្ជកម្មទៅដល់ប្រទេសចិនបាន។

[245] បើតាមសៀវភៅប្រវត្តិសាស្ត្រកម្ពុជារបស់លោក Adhémard Leclère សិរីវង្ស គឺជាព្រះជាយារបស់ស៊ីវត្ថា ចំណែកព្រះរាជពង្សាវតារព្រះអង្គម្ចាស់នុប្បរតណ៍(នព្វរ័ត្ន) ឆ្នាំ១៨៧៧ ថា សិរីវង្សជាព្រះអនុជ និងជារាជបុត្រា។

[246] តាមប្រពៃណី«រាជាធិបតេយ្យជ្រើសតាំង» (Elective monarchy/ Monarchie élective) ការជ្រើសតាំងព្រះមហាក្សត្រថ្មីឱ្យស្នងរាជ្យ ធ្វើឡើងក្រោយពីពេលចូលទិវង្គតនៃព្រះមហាក្សត្រមុន ដែលជាញឹកញាប់បានបណ្ដាលឱ្យមានវិបត្តិរាជបល្ល័ង្ក ដោយសារការប្រកួតប្រជែងគ្នាពីរាជបុត្រាច្រើនអង្គដែលសុទ្ធតែជាបេក្ខជនសម្រាប់រាជបល្ល័ង្កនោះ។

បារាំងបានចាប់អារម្មណ៍លើកូសាំងស៊ីន ដែលត្រូវបានដណ្តើមយកពីអាណ្ណាម។ ដោយបានក្លាយជាអ្នកជិតខាងរបស់យើង បារាំងបានចាប់អារម្មណ៍មកលើយើង។ ពួកគេមិនបានដឹងអំពីទុក្ខព្រួយរបស់កម្ពុជាទេ។ នៅឆ្នាំ១៨៦២ ឧត្តមនាវី បូណា( Bonard )ជាទេសាភិបាល និងជាអគ្គមេបញ្ជាការកងទ័ពជើងគោក និងសមុទ្រនៅកូសាំងស៊ីន ដោយចង់វិនិច្ឆ័យដោយផ្ទាល់អំពីតម្លៃនៃ ឥស្សរជន នៅក្នុងរាជវាំងឧដុង្គ, ចង់មើលស្ថានភាពនៃព្រះរាជាណាចក្រ, សារៈសំខាន់ផ្នែកកសិកម្មនិងពាណិជ្ជកម្ម, ទំនាក់ទំនងជាមួយរដ្ឋាភិបាលសៀមនោះ បានមកប្រទេសកម្ពុជា ហើយបានចូលគាល់ ព្រះករុណាព្រះបាទនរោត្តម ដោយបានទទួលនូវការស្វាគមន៍ដ៏កក់ក្តៅពីព្រះអង្គ។ នៅឆ្នាំបន្ទាប់ ឧត្តមនាវី La Grandière បានបញ្ជាឱ្យលោកអនុសេនីយ៍ឯក ដឺឡាក្រេ ( Doudart de Lagrée ) មកប្រទេសកម្ពុជា តាមនាវា Giadinh ដើម្បីធ្វើការសង្កេតមើលវិស័យផ្សេងៗ សម្រាប់ផ្តល់ជូនលោកទេសាភិបាល នៃអាណានិគមរបស់យើងនូវព័ត៌មានច្បាស់លាស់ដែលអាចនាំទៅ ដល់ការបង្កើតឡើងនូវទំនាក់ទំនងរវាងបារាំង និងខ្មែរ[247]។ ក្រោយពីមានសន្ធិសញ្ញាអាណាព្យាបាលនៅឆ្នាំ១៨៦៣ បារាំងបានជួយឱ្យអង្គវតី បានឡើងសោយរាជ្យនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៨៦៤ ជាស្ថាពរនៅក្រុងឧដុង្គ ដោយមាននាមសម្រាប់រាជ្យថា«ព្រះបាទនរោត្តម»។

## ២-សន្ធិសញ្ញា អនុសញ្ញា និងប្រកាស

ចាប់ពីឆ្នាំ១៨៦៣ មកការវិវត្តនៃរបបអាណាព្យាបាលបារាំងនៅកម្ពុជា គឺមាន៣ដំណាក់កាល

| សន្ធិសញ្ញាបារាំង-ខ្មែរ<br>១១ សីហា ១៨៦៣<br>( ១៩មាត្រា ) | អនុសញ្ញាបារាំង-ខ្មែរ<br>១៧ មិថុនា ១៨៨៤<br>( ១១មាត្រា ) | ព្រះរាជប្រកាស<br>១១ កក្កដា ១៨៩៧<br>( ១២មាត្រា ) |
|---|---|---|
| បង្កើតរបបអាណាព្យាបាលបារាំងនៅកម្ពុជា ដែលបានចុះហត្ថលេខានៅរាជវាំងឧដុង្គ មាត្រាដែលបង្ហាញពីអធិរាជបារាំងផ្តល់នូវកិច្ចការពាររបស់ខ្លួនចំពោះព្រះរាជាកម្ពុជា ( មាត្រា១ )។ | បារាំងប៉ុនប៉ងដណ្តើមអំណាច តែមិនបានសម្រេច។ បារាំងបានបង្ខំឱ្យព្រះរាជាកម្ពុជាទទួលយកកំណែទម្រង់រដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម។ | បារាំងដណ្តើមអំណាចពីខ្មែរបាន។ ព្រះរាជប្រកាសនេះ ប្រៀបដូចជារដ្ឋធម្មនុញ្ញ។ |

### ២.១-ខ្លឹមសារសំខាន់នៃសន្ធិសញ្ញាខ្មែរ-បារាំង ១១ សីហា ១៨៦៣

ដោយមានការព្រមព្រៀងគ្នាប្រទេសទាំងពីរបានឈានដល់ការចុះសន្ធិសញ្ញា ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣។ ខ្លឹមសារនៃសន្ធិសញ្ញានេះគឺ ព្រះចៅអធិរាជបារាំង ព្រមផ្តល់នូវការការពាររបស់ព្រះអង្គចំពោះព្រះរាជានៃប្រទេសកម្ពុជា( មាត្រា១ )[248]។ ព្រះចៅអធិរាជនៃប្រទេសបារាំងនឹងតែងតាំងតំណាងមួយរូប នៅអមព្រះរាជានៃប្រទេសកម្ពុជា ដែលនឹងទទួលភារកិច្ចពិនិត្យលើការអនុវត្តឱ្យបានត្រឹមត្រូវ នូវលិខិត អាណាព្យាបាលទាំងឡាយ នៅក្រោមអំណាចដ៏ខ្ពង់ខ្ពស់នៃទេសាភិបាលកូសាំងស៊ីន។ ព្រះរាជានៃប្រទេសកម្ពុជាក៏

---

247 សូមមើល: Norodom Sihanouk, *La monarchie cambodgienne et la croisade royale pour l'independence( រាជាធិបតេយ្យកម្ពុជា និងរាជបូជនីយកិច្ចដើម្បីឯករាជ្យ )*, Ministère de l'Education Nationale, Direction des Services Péagogiques, 1958, p. 45-46.

248 មាត្រានេះបង្ហាញពីការបង្កើតរបបអាណាព្យាបាលបារាំងនៅកម្ពុជា។

អាចតែងតាំងតំណាងខ្មែរមួយរូបនៅព្រៃនគរ ដើម្បីទាក់ទងផ្ទាល់ជាមួយទេសាភិបាលកូសាំងស៊ីន(មាត្រា២)។ រេស៊ីដង់បារាំងនឹងមានឋានៈជាមន្ត្រីជាន់ខ្ពស់នៅប្រទេសកម្ពុជា ហើយត្រូវផ្តល់ឋានៈ និងកិត្តិយសនេះនៅក្នុងព្រះរាជាណាចក្រទាំងមូល(មាត្រា៣)។ កុងស៊ុលនៃប្រទេសដទៃទៀតក្រៅពីប្រទេសបារាំង នឹងមិនអាចនៅអមព្រះរាជានៃប្រទេសខ្មែរទេ ឬ ក៏នៅកន្លែងណាមួយនៅលើទឹកដីនេះ ដោយមិនបានប្រាប់ព័ត៌មាន ទៅទេសាភិបាលកូសាំងស៊ីន ហើយមិនមែនការយល់ព្រមជាមួយរដ្ឋាភិបាលកម្ពុជា(មាត្រា៤)។ ជនជាតិបារាំងនៅលើទឹកដីនៃប្រទេសកម្ពុជានឹងមានសេរីភាពពេញលេញចំពោះខ្លួនគេផ្ទាល់នឹងកម្មសិទ្ធិរបស់គេ។ គេនឹងអាចធ្វើចរាចរ អាចមានរបស់ជាកម្មសិទ្ធិ និងអាចតាំងទីលំនៅដោយសេរីនៅ គ្រប់ខេត្ត និងគ្រប់តំបន់នៃព្រះរាជាណាចក្រកម្ពុជា កាលណាគេជម្រាបដំណឹងទៅមន្ត្រីជាន់ខ្ពស់ខ្មែរណាម្នាក់ដែលនឹងចេញលិខិតអនុញ្ញាតឱ្យ(មាត្រា៥)។ ជនជាតិខ្មែរនៅលើទឹកដីនៃចក្រភពបារាំងនឹងមានសេរីភាពពេញលេញចំពោះខ្លួនគេផ្ទាល់ និងកម្មសិទ្ធិរបស់គេ។ គេនឹងអាចធ្វើចរាចរ អាចមានរបស់ជាកម្មសិទ្ធិ និងអាចតាំងទីលំនៅដោយសេរីនៅគ្រប់ខេត្ត និងគ្រប់តំបន់នៃចក្រភពនេះ កាលណាគេជម្រាបដំណឹងទៅ នាយទាហានបារាំងណាម្នាក់ដែលមានសមត្ថកិច្ចនឹងចេញលិខិតអនុញ្ញាតឱ្យ(មាត្រា៦)។ កាលណាជនជាតិបារាំងណាម្នាក់ដែលតាំងទីលំនៅ ឬ ធ្វើដំណើរឆ្លងកាត់រាជាណាចក្រកម្ពុជា មានរឿងក្តីក្តាំ ឬ ការតវ៉ាប្រឆាំងនឹងជនជាតិខ្មែរណាម្នាក់។ ដំបូងគេត្រូវដាក់ពាក្យបណ្តឹងទៅរេស៊ីដង់បារាំងដែលនៅទីនោះក្រោយពីបាន ពិនិត្យសំណុំរឿងនោះ និងព្យាយាមសម្រុះសម្រួលតាមលក្ខណៈជាមិត្តភាព។ ក្នុងករណីនីមួយៗ ប្រសិនបើគេមិនអាចដោះស្រាយរួច រេស៊ីដង់បារាំងនឹងស្នើសុំនូវជំនួយពីមន្ត្រីខ្មែរណាម្នាក់ ដែលមានសមត្ថកិច្ច ហើយមន្ត្រីទាំងពីរនេះក្រោយពីបានពិនិត្យសំណុំរឿងរួមគ្នា និងធ្វើការវិនិច្ឆ័យទៅតាមគតិយុត្តិធម៌។ រេស៊ីដង់បារាំងនឹងមិនធ្វើអន្តរាគមន៍នៅក្នុងរឿងវិវាទរវាងខ្មែរនិងខ្មែរទេ(មាត្រា៧)។

ជនជាតិបារាំង នៅក្នុងករណីណាក៏ដោយ ត្រូវទទួលការវិនិច្ឆ័យពីតុលាការបារាំង ដោយគ្មានអន្តរាគមន៍ពីអាជ្ញាធរខ្មែរ។ បទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយជនជាតិបារាំងនៅក្នុងរាជាណាចក្រកម្ពុជានឹងត្រូវយកទៅជំនុំជម្រះនៅឯក្រុងព្រៃនគរ ដោយតុលាការមានសមត្ថកិច្ច។ នៅក្នុងករណីបែបនេះ រដ្ឋាភិបាលកម្ពុជានឹងបង្កលក្ខណៈ ងាយស្រួលដល់រេស៊ីដង់បារាំងក្នុងការចាប់ជនប្រព្រឹត្តបទល្មើស រួចបញ្ជូនទៅឱ្យទេសាភិបាលកូសាំងស៊ីន។ នៅក្នុងករណីអវត្តមានរេស៊ីដង់បារាំង មេបញ្ជាការនៃកងកម្លាំងបារាំងនឹងបំពេញភារកិច្ចនេះដើម្បីអនុវត្តយុត្តិធម៌។

សរុបសេចក្តីមក នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ សន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរ ត្រូវបានចុះហត្ថលេខា នៅរាជវាំងឧដុង្គ ដោយចំណុចសំខាន់បំផុត នៅក្នុងចំណោម១៩ មាត្រា មានចែងថា ព្រះចៅអធិរាជបារាំងផ្តល់នូវកិច្ចការពាររបស់ខ្លួនចំពោះព្រះរាជាកម្ពុជា(មាត្រា១)។ ព្រះចៅអធិរាជបារាំងដែលទទួលស្គាល់អធិបតេយ្យភាពនៃព្រះរាជាកម្ពុជានោះសន្យាថានឹងជួយរក្សាសណ្តាប់ធ្នាប់ និងភាពស្ងប់ស្ងាត់នៅក្នុងប្រទេស ព្រមទាំងការពារកម្ពុជាទល់នឹងរាល់ការវាយប្រហារពីខាងក្រៅ ជួយកម្ពុជាក្នុងការទារពន្ធដារពាណិជ្ជកម្ម និងផ្តល់នូវភាពងាយស្រួលក្នុងការស្ថាបនាគមនាគមន៍រវាងកម្ពុជា និងដែនសមុទ្ទ (មាត្រា១៦)។ អត្ថន័យមាត្រា១ បង្ហាញថាបារាំងធ្វើជា «រដ្ឋអាណាព្យាល»(État protecteur) មកលើប្រទេសកម្ពុជាដែលជា «រដ្ឋក្រោមអាណាព្យាបាល»(État protégé)។ មាត្រានេះក៏មានន័យថា រដ្ឋាភិបាលបារាំងទទួលសិទ្ធិផ្តាច់មុខខាងកិច្ចការបរទេស ក្នុងការចុះកិច្ចព្រមព្រៀងជាមួយប្រទេសនានាដោយមិនចាំបាច់មានការចូលរួមពីរដ្ឋាភិបាលកម្ពុជា។ ប្រទេសកម្ពុជាជារដ្ឋក្រោមអាណាព្យាបាលមានស្វ័យភាពផ្ទៃក្នុងមួយចំនួនគឺ បន្តការគ្រប់គ្រង

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្រោមការត្រួតពិនិត្យពីបារាំង។ មន្ត្រីសៀមដែលធ្លាប់នៅអមព្រះរាជាខ្មែរត្រូវជំនួសដោយមន្ត្រីបារាំងវិញម្តង។

## ២.២-ខ្លឹមសារសំខាន់នៃសន្ធិសញ្ញាខ្មែរ-សៀម ១ ធ្នូ ១៨៦៣

ចំណែកសៀមមិនសប្បាយចិត្តទេ ក្រោយពីបានដឹងថាសម្តេច នរោត្តម[249] បានចុះព្រះហត្ថលេខាលើសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំងហើយក៏បានពន្យល់ដល់ព្រះមហាក្សត្រអំពី ភាពមិនច្បាស់លាស់របស់បារាំងមកលើកម្ពុជា។ មិនតែប៉ុណ្ណោះ ពួកមន្ត្រីសៀមបានថ្លែងគំរាមកំហែងព្រះមហាក្សត្រថា ប្រទេសសៀមនឹងអាចតែងតាំងសម្តេច នរោត្តម ឱ្យឡើងសោយរាជ្យនៅប្រទេសកម្ពុជា។ ពាក្យគំរាមកំហែងទាំងនេះបានធ្វើឱ្យព្រះមហាក្សត្រមានការភិតភ័យយ៉ាងខ្លាំង ពីព្រោះមកុដរាជ និងគ្រឿងឥស្សរិយសមហាក្សត្រកម្ពុជា ត្រូវបានថែរក្សាទុកនៅក្រុងបាងកក ព្រមទាំងច្បាប់ផ្សេងៗដែលទាក់ទងទៅនឹង ការសោយរាជ្យរបស់ មហាក្សត្រកម្ពុជាមានការជាប់ទាក់ទងទៅនឹងប្រទេសសៀម ។

ដោយសន្ធិសញ្ញារវាងខ្មែរ និងបារាំងមិនទាន់បានទទួលសច្ចាប័ននៅឡើយនោះសម្តេច នរោត្តម ទ្រង់លបលួចចងស្ពានមេត្រីជាមួយសៀមក្នុងថ្ងៃទី១ ខែធ្នូ ឆ្នាំ១៨៦៣។ សន្ធិសញ្ញារវាងប្រទេសកម្ពុជា និងប្រទេសសៀមជាសម្ងាត់នេះមាន១១មាត្រា។ ខ្លឹមសារនៅក្នុងកិច្ចព្រមព្រៀងបានបញ្ជាក់ថាសម្តេច នរោត្តម ត្រូវទទួលស្គាល់ថាជាមហាក្សត្រ និងជាប្រមុខរដ្ឋពេញច្បាប់នៃប្រទេសកម្ពុជា ហើយរាជាណាចក្រកម្ពុជាស្ថិតនៅក្នុងស្ថានភាពជាអនិស្សរភាព។

តាមរយៈសន្ធិសញ្ញានេះ ប្រមុខរដ្ឋនៃកម្ពុជាអាចតែងតាំងឡើងបាន ដោយសារមាន ការអនុញ្ញាតពីក្រុងបាងកក។ នៅក្នុងកិច្ចព្រមព្រៀងនេះដែរ ព្រះមហាក្សត្រព្រះបាទនរោត្តម ត្រូវបាត់បងសិទ្ធិទាំងអស់លើខេត្តបាត់ដំបង និងក្រុងអង្គរ មិនតែប៉ុណ្ណោះសៀមបានពង្រីកសិទ្ធិក្រសោបយកខេត្តពោធិ៍សាត់ និងកំពង់ស្ពឺទៀត ប្រសិនបើព្រះមហាក្សត្រមានការប្រព្រឹត្តមិនល្អជាមួយប្រទេសសៀម។

ក្រោយពីរដ្ឋាភិបាលបារាំង បានធ្វើសច្ចាប័នលើសន្ធិសញ្ញាស្តីពីអាណាព្យាបាលបារាំងនៅកម្ពុជានា ថ្ងៃទី៨ ខែមេសា ឆ្នាំ១៨៦៤ លោក ឡាក្រង់ឌីយែរ បានថ្វាយព័ត៌មាននេះដល់សម្តេច នរោត្តម ហើយបន្តមកពិធីប្តូរឯកសារសច្ចាប័នបានប្រព្រឹត្តទៅនៅថ្ងៃទី១២ ខែមេសាឆ្នាំ១៨៦៤។ នៅពេលជាមួយគ្នានោះ ដោយមានការសម្របសម្រួលជាមួយប្រទេសសៀម អំពីបញ្ហាដែនដីមួយភាគនៃប្រទេសកម្ពុជាដែលសម្បូរទៅដោយភោគផលដំណាំ ជាពិសេសដំណាំស្រូវដូចជាខេត្តបាត់ដំបង អង្គរ សៀមរាប ត្រូវបាត់បង់ធ្លាក់ទៅក្នុង ដៃសៀម ។

## ២.៣-ខ្លឹមសារសំខាន់នៃសន្ធិសញ្ញាបារាំង-សៀម ១៥ កក្កដា ១៨៦៧

បញ្ហាដាក់អាណាព្យាបាល លើប្រទេសខ្មែរដោយមានការប្រទាញប្រទង់រវាងសៀម និងបារាំង រដ្ឋាភិបាលបារាំងបានសុខចិត្តធ្វើការសម្រួលជាមួយប្រទេសសៀម ក្នុងការចុះហត្ថលេខាលើសន្ធិសញ្ញាមួយនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧។ ខ្លឹមសារសំខាន់នៃសន្ធិសញ្ញានេះគឺព្រះរាជានៃប្រទេសសៀមទទួលស្គាល់ជាឱឡារិករបបអាណាព្យាបាលបារាំងមកលើប្រទេសកម្ពុជា(មាត្រា១)។ សន្ធិសញ្ញាដែលបានចុះហត្ថលេខាថ្ងៃទី១ ខែធ្នូ ឆ្នាំ១៨៦៣ រវាងរាជាណាចក្រកម្ពុជា និងរាជាណាចក្រសៀមត្រូវចាត់ទុកជាមោឃៈ ហើយ រដ្ឋាភិបាលសៀមនឹងមិនអាចរំឭកសន្ធិសញ្ញានេះក្នុងកាលៈទេសៈណាក៏ដោយ(មាត្រា២)។ ព្រះរាជានៃប្រទេសសៀមលែងទទួល

---

[249] ក្នុងឯកសារនេះមុនទ្រង់ឡើងគ្រងរាជ្យនៅឆ្នាំ១៨៦៤ អ្នកនិពន្ធ និងរៀបរៀងសរសេរថា សម្តេច នរោត្តម ហើយក្រោយឆ្នាំ១៨៦៤ សរសេរថា ព្រះបាទនរោត្តម វិញ។

សួយសាអាករ ដែលជានិមិត្តរូបនៃភាពចំណុះរបស់ប្រទេសកម្ពុជា(មាត្រា៣)។ ខេត្តបាត់ដំបង[250] និងអង្គរ[251] នឹងស្ថិតក្នុងរាជាណាចក្រសៀម(មាត្រា៤)។

តាមរយៈខ្លឹមសារនៃសន្ធិសញ្ញានេះលក្ខខណ្ឌទាំងឡាយនៃកិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា និងប្រទេសសៀមត្រូវបដិសេធចោល។ ប្រទេសសៀមបានយល់ព្រមជាផ្លូវការផ្តល់សិទ្ធិដល់ប្រទេសបារាំង ចំពោះរបបអាណាព្យាបាលរបស់ខ្លួនលើប្រទេសកម្ពុជា។ ដើម្បីតបស្នងចំពោះការទទួលស្គាល់នេះ ប្រទេសសៀមបានទទួលខេត្តបាត់ដំបង និងអង្គរ។ ចំពោះផលចំណេញនៅសន្ធិសញ្ញានេះ គឺបារាំងត្រូវសៀមទទួលស្គាល់អាណាព្យាបាលបារាំងនៅកម្ពុជា។ ចំណែកសម្រាប់សៀម គឺសៀមទទួលតបមកវិញនៅពេលនោះគឺរក្សាការកាន់កាប់អាណាខេត្ត ដ៏សម្បូរទៅដោយធនធានរបស់ខ្មែរ គឺខេត្តបាត់ដំបង និងសៀមរាប ដែលពួកគេបានកាន់កាប់តាំងពីចុងសតវត្សរ៍ទី១៨ មកម្ល៉េះ[252]។ អ្នកមតិមួយចំនួនលើកឡើងថាព្រះបាទនរោត្តមមិនបានតវ៉ារឿងបារាំងកាត់ខេត្តអង្គរ(សៀមរាប) និងបាត់ដំបងឱ្យទៅនគរសៀម ក្រោមសន្ធិសញ្ញា បារាំង-សៀម ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧។ តាមពិតទ្រង់បានតវ៉ាតាមរយៈរាជសារលិខិតចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៨៦៨ ដែលមានខ្លឹមសារថា« *សម្តេចព្រះនរោត្តម ចម្រើនផ្លូវមេត្រីមកទេសាភិបាលបារាំងប្រចាំកូសាំងស៊ីនសូមជ្រាប ដោយចង់ផ្គាប់ចិត្តរបស់រដ្ឋាភិបាលបារាំង ខ្ញុំបានចាត់តាំងមន្ត្រីបីរូប ជាតំណាងឱ្យកម្ពុជា ក្នុងគណៈកម្មាធិការទទួលបន្ទុកកំណត់ព្រំដែនខេត្តអង្គរ និងខេត្តបាត់ដំបង។ បុរេចារកិច្ចដ៏ធំធេងដែលប្រជាជាតិដ៏សប្បុរសរបស់លោកផ្តល់ឱ្យរាជអាណាចក្រខ្ញុំ និងបដិការគុណរបស់ខ្ញុំ ខ្ញុំត្រូវបង្ខំចិត្តទទួលយកសំណើរបស់លោក តែទោះបីជាយ៉ាងនេះក៏ដោយ ដើម្បីរក្សាគុណប្រយោជន៍ដល់ប្រជារាស្ត្ររបស់ខ្ញុំ ថ្ងៃនេះក៏ដូចពេលកន្លងមក ខ្ញុំប្រកាសតវ៉ាចំពោះគំនិតទាំងឡាយណាដែលថាខ្ញុំបានបោះបង់ខេត្តអង្គរ និងខេត្តបាត់ដំបងទៅឱ្យព្រះរាជានគរសៀម។ ខ្ញុំមិនគោរពសន្ធិសញ្ញាណា(សំដៅសន្ធិសញ្ញាបារាំង-សៀម១៥ កក្កដា ១៨៦៧) ធ្វើឡើងដែលខ្ញុំពុំបានចូលរួម និងដឹងឮ ហើយខ្ញុំនិងទាយាទរបស់ខ្ញុំ សូមរក្សាកម្មសិទ្ធទាំងស្រុងលើខេត្តអង្គរ និងបាត់ដំបង*»[253]។

### ២.៤-ខ្លឹមសារនៃអនុសញ្ញាថ្ងៃទី១៧ មិថុនា ១៨៨៤

នៅពេលប្រទេសមានសុខសន្តិភាពគ្រាន់បើហើយនោះ សម្តេច នរោត្តម បានធ្វើទស្សនកិច្ចនៅក្រុងខ្លះដូចជាហុងកុង, ម៉ាកាវ, កង់តុង និងម៉ានីល នៅឆ្នាំ១៨៧២ ដោយជិះនាវាចម្បាំងឈ្មោះឡឺប្ល៊ីវីយ៉ាន ដែលលោកទេសាភិបាលកូសាំងស៊ីនប្រគល់ថ្វាយសម្រាប់ជូនដំណើរ[254]។ដំណើរទស្សនកិច្ចដើម្បីទ្រង់ជ្រាបពីវឌ្ឍនភាពក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចនៅភូមិភាគអាស៊ីអាគ្នេយ៍ ដោយសារបេច្ចកទេសអ្នកគ្រប់គ្រង ពួកឈ្មួញ និងពួកអ្នកជំនួញខាងហិរញ្ញវត្ថុជាតិអឺរ៉ុប និងក្រោយពីបានធ្វើការចរចាជាច្រើនលើកជាមួយ អ្នកតំណាងប្រទេសបារាំង ទើបព្រះបាទនរោត្តមទ្រង់សម្រេចព្រះទ័យថា ត្រូវតែធ្វើកំណែទម្រង់តាមព្រះរាជបញ្ញត្តិចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៨៧៧ ដើម្បីឱ្យប្រទេសជាតិរីកចម្រើនលូតលាស់ទាន់សម័យនឹងគេ[255]។

---

[250] ណាក្តាវ។

[251] សៀមរាប។

[252]សិក្សាចក្រ, *ទស្សនាវដ្តីកម្ពុជពិច័យ លេខ១២-១៣*, មជ្ឈមណ្ឌលខេមរសិក្សា, ឆ្នាំ២០១០-២០១១, ទំព័រ៧៤។

[253] https://www.icj-cij.org/sites/default/files/case-related/45/9254

[254] អាដឺម៉ារ ឡឺក្លែរ *ប្រវត្តិសាស្ត្រកម្ពុជា*, ដ.ឯ.ម. ទំព័រ ៤០៥។

[255] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ*, ភាគ២, ដ.ឯ.ម., ២៦១។

ព្រះរាជប្រកាសបានលុបបំបាត់ឋានៈឧបរាជចេញ ដូចដែលគេបានអនុវត្តរួចមកហើយនៅប្រទេសសៀម លុបឋានៈឧភយោរាជដែលអស់ន័យទៅហើយ លុបបំបាត់ឋានៈព្រះវររាជជននី(ជៈនៈនី) ព្រមទាំងលុបបំបាត់ឋានៈ និងមុខងារមន្ត្រីមួយចំនួនធំដែលគ្មានការងារអ្វីជាសំខាន់។

ការយកពន្ធដារ ឈប់ឱ្យពួកចិនប្រមូលទៀតហើយ ព្រោះពួកនេះតែងតែកាត់យកមួយចំណែកធំសម្រាប់ខ្លួនឯង។ ល្បែងស៊ីសងមួយចំនួនត្រូវហាមឃាត់។ កំណែនធ្វើការងារ៩០ថ្ងៃ អាចគេចផុតបានដោយបង់ប្រាក់ចំនួន២០ ហ្វ្រង់ស្មើនឹង៤ពៀស។ កំណែទម្រង់តុលាការ ដោយចាត់តាំងតែចៅក្រមដែលបានសិក្សាចេះចាំច្បាប់ច្បាស់លាស់។ លុបបំបាត់មិនឱ្យមានខ្ញុំបម្រើដែលមិនឱ្យរំដោះខ្លួនចេញ និងរៀបចំលុបបំបាត់ចោលទាំងស្រុង[256]។

ព្រះរាជប្រកាសខាងលើនេះ បានធ្វើឱ្យពួកមន្ត្រីភ័យខ្លាចបាត់បង់ផលប្រយោជន៍របស់ពួកគេ។ ចំពោះពួកស្រីៗនៅក្នុងព្រះរាជវាំង, ពួកអ្នកអង្គម្ចាស់ក្សត្រិយ៍, ពួកស្រីស្នំ, ពួកភីលៀង បានប្រឆាំងយ៉ាងខ្លាំងចំពោះការប្រែប្រួលទាំងឡាយ បានព្រួតគ្នាធ្វើបាតុកម្មតបមួយ ដែលបារាំងមិនដឹងតទល់យ៉ាងណា។ ដោយសារភាពពុំអើពើរបស់មន្ត្រីរាជការ ស្ដេចត្រាញ់ និងសក្ដិភូមិខ្មែរចំពោះកំណែទម្រង់បារាំងឆ្នាំ១៨៧៧ បារាំងខឹងយ៉ាងខ្លាំង។ ដោយអត់ទ្រាំពិនិត្យមើលរបាយការណ៍ស្ដីពីការយឺតយ៉ាវនេះតទៅទៀតមិនបាន លោកហ្សុលហ្វេរីដែលកាលនោះជានាយករដ្ឋមន្ត្រីបារាំងបានចាត់ឱ្យលោក សាល ថុមសុន(Charles Thomson) ជា ទេសាភិបាល និងជាតំណាងដ៏ខ្ពង់ខ្ពស់នៃប្រទេសបារាំងនៅកូសាំងស៊ីន សហការជាមួយអ្នកតំណាងអាណាព្យាបាលបារាំងនៅភ្នំពេញចូលគាល់សម្ដេចនរោត្តម ហើយយាងព្រះអង្គឱ្យឡាយព្រះហស្ដលេខាលើអនុសញ្ញាមួយ ដើម្បីប្រគល់កិច្ចដឹកនាំព្រះរាជាណាចក្រ ដែលកន្លងមកព្រះអង្គក្ដោបក្ដាប់តែមួយព្រះអង្គឯង ឱ្យអាណាព្យាបាលបារាំងចាត់ចែងជំនួសវិញម្ដង[257]។

នៅពេលនោះលោក សាល ថុមសុន(Charles Thomson) ធ្វើដំណើរតាមកប៉ាល់ពីក្រុងព្រៃនគរមកភ្នំពេញ និងបានហុចថ្វាយសម្ដេចនរោត្តម នូវច្បាប់កែទម្រង់មួយចំនួនធំក្នុងក្របខ័ណ្ឌនៃអនុសញ្ញាមួយ ដែលថែមទាំងស្ដីពីការត្រួតត្រាជាផ្លូវការរបស់បារាំងលើប្រទេសកម្ពុជា។ លោក សាល ថុមសុន បានជិះនាវាកាំភ្លើងធំមួយមកដល់រាជធានីភ្នំពេញ ដែលបានបោះយុថ្កានៅជិតព្រះបរមរាជវាំងល្មមឱ្យគេមើលឃើញ។ នៅពេលសម្ដេចនរោត្តម កំពុងទតឯកសារនោះ អង្គរក្សប្រដាប់ដោយអាវុធរបស់លោក ថុមសុន បានឈរនៅក្បែរនោះ។ ដោយមានជំនួយពីអ្នកបកប្រែកាន់ជើងបារាំងម្នាក់ឈ្មោះឧកញ៉ា សឺនដៀប ព្រះអង្គបានឡាយព្រះហស្ដលើឯកសារនោះពីព្រោះព្រះអង្គបានយល់ថាធ្វើបែបនេះទើបអាចរក្សារាជបល្ល័ង្កបាន[258]។ អនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ (១១មាត្រា) ត្រូវបានចុះហត្ថលេខា នៅរាជវាំងភ្នំពេញ។ បារាំងបានបង្ខំឱ្យព្រះរាជាកម្ពុជាទទួលយកកំណែទម្រង់រដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម។ ខ្លឹមសារសំខាន់នៃអនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤[259]៖ព្រះរាជាកម្ពុជា ទទួលយកនូវកំណែទម្រង់រដ្ឋបាល, តុលាការ, ហិរញ្ញវត្ថុ និងពាណិជ្ជកម្មសម្រាប់អនុវត្តរបបអាណាព្យាបាលរបស់ខ្លួន នៅពេលអនាគត (មាត្រា១)។ ព្រះ

---

[256] អាដឺម៉ារ ឡឺក្លែរ, *ប្រវត្តិសាស្ត្រកម្ពុជា* , ដ.ឯ.ម., ទំព័រ ៤០៦។

[257] -ដ- ទំព័រ៤០៧។

[258] ដេវិឌ ឆាន្ទល័រ, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ១៥៦។

[259] នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ វេលាម៉ោង១០ យប់ទេសាភិបាលនៅកូសាំងស៊ីនឈ្មោះ សាល ថុមសុន (Charles Thomson) ដោយមានបារាំងម្នាក់ទៀតជានាក់តំណាងអាណានិគមបារាំងទៀតឈ្មោះភូរ៉េ(Fourès) មកជាមួយផងបានចូលទៅបង្ខំព្រះបាទនរោត្តមឱ្យចុះហត្ថលេខា។

រាជាកម្ពុជានឹងបន្តគ្រប់គ្រងរដ្ឋ និងដឹកនាំរដ្ឋបាល ដូចក្នុងអតីតកាល លើកលែងតែការកែម្រិតនានា ដែលមានចែងនៅក្នុងអនុសញ្ញានេះ(មាត្រា២)។ មន្ត្រីខ្មែរនឹងនៅបន្តគ្រប់គ្រងអាណាខេត្ត ក្រោមការត្រួត ពិនិត្យពីអាជ្ញាធរបារាំង លើកលែងតែកិច្ចការណា ដែលទាក់ទងនឹងការធ្វើបញ្ជី និងការទាមទារពន្ធដារ, គយ, វិភាគទានមិនផ្ទាល់, សាធារណការ និងជាទូទៅកិច្ចការណាដែល តម្រូវឱ្យមានការដឹកនាំ តែមួយ ឬ ការប្រើប្រាស់វិស្វករឬភ្នាក់ងារអឺរ៉ុប(មាត្រា៣)។ ការចំណាយសម្រាប់រដ្ឋបាល នៃព្រះរាជាណាចក្រ និងការចំណាយសម្រាប់របបអាណាព្យាបាល នឹងជាបន្ទុករបស់កម្ពុជា(មាត្រា៦)។ ទាសភាពត្រូវលុបចោល នៅលើផ្ទៃនៃព្រះរាជាណាចក្រទាំងមូល(មាត្រា៨)។ ក្រុងភ្នំពេញនឹងគ្រប់គ្រងដោយគណៈកម្មការក្រុងមួយ ដែលមានសមាសភាពដូចជា អគ្គរ៉េស៊ីដង់ ឬអ្នកតំណាង ជាប្រធាន និងមន្ត្រី ឬ ពាណិជ្ជករបារាំង៦នាក់ តែងតាំងដោយទេសាភិបាលកូសាំងស៊ីន: ជនជាតិខ្មែរ៣នាក់, ជនជាតិអាណ្ណាម ១នាក់ ជនជាតិចិន ២នាក់, ជនជាតិឥណ្ឌា ១នាក់, ជនជាតិម៉ាឡេ ១នាក់។ ជនជាតិទាំង៥ខាងលើនេះ ត្រូវតែងតាំងដោយព្រះរាជាកម្ពុជា តាមបញ្ជីមួយដែលដាក់ជូនទេសាភិបាលកូសាំងស៊ីន។ ដូច្នេះអ្នកតំណាងជនជាតិខ្មែរមានតែ៣នាក់ក្នុងចំណោម១៥នាក់ ឬ ១/៥[260] (មាត្រា១០)។

បារាំងសាកល្បងដណ្តើមអំណាចពីព្រះរាជាខ្មែរ តាមរយៈអនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤នេះ ប៉ុន្តែមិនបានសម្រេច ដោយសារមានការបះបោរប្រឆាំងនៅឆ្នាំ១៨៨៥ និងឆ្នាំ១៨៨៦។ អត្ថន័យដ៏សំខាន់នៃកម្មវិធីកំណែទម្រង់ថ្មី គឺការដាក់កម្ពុជាក្រោមការដឹកនាំរបស់បារាំង ដោយផ្ទាល់។ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ដោយមានការគំរាមកំហែងនឹងប្រើកម្លាំងយោធាពីសំណាក់កងទ័ពបារាំងបង្ខំឱ្យព្រះបាទនរោត្តមចុះហត្ថលេខាលើកិច្ចព្រមព្រៀងដែលក្នុងនោះចំណុចទីមួយ បាននិយាយថា «ព្រះមហាក្សត្រកម្ពុជាធានាដល់ការធ្វើកំណែទម្រង់នៅលើ វិស័យរដ្ឋបាល, តុលាការ និងហិរញ្ញវត្ថុដែលសាធារណរដ្ឋបារាំងគិតថាវា មានអត្ថប្រយោជន៍ដើម្បីឱ្យមានការងាយស្រួល ក្នុងការដឹកនាំពីសំណាក់អាណាព្យាបាល» ក្នុងខណៈនេះ ព្រះមហាក្សត្រកម្ពុជាហាក់ដូចជាមានព្រះទ័យយល់ស្របរួចទៅហើយព្រោះ ព្រះអង្គក៏មានទិសដៅធ្វើទំនើបកម្មនៅក្នុងប្រទេសដែរ។ នៅក្នុងមាត្រាបន្តបន្ទាប់នៃកិច្ចព្រមព្រៀង គឺជាកម្មវិធីកំណែទម្រង់រ៉ាឌីកាល់ របស់បារាំង ដូចជានៅក្នុងវិស័យដឹកនាំរដ្ឋត្រូវបានគេមើលឃើញថាមន្ត្រីរាជការកម្ពុជា ដឹកនាំថ្នាក់ខេត្តត្រូវដាក់ក្រោមការគ្រប់គ្រងដោយផ្ទាល់ពីសំណាក់ទេសាភិបាលបារាំង។ ព្រះបាទនរោត្តម លែងមានតំណាងទូតបារាំងដូចមុនទៀតហើយ ដោយកែប្រែទៅជាទេសាភិបាលជាន់ខ្ពស់ ដែលស្ថិតនៅក្រោមការបញ្ជាដោយផ្ទាល់ពីសំណាក់ អគ្គទេសាភិបាលកូស៊ាំងស៊ីន។

គេយល់ថាកំណែទម្រង់របស់បារាំងវាគ្រាន់តែជា «ស្ថានភាពមួយដែលខ្មែរមិនត្រូវការ» ព្រោះកម្មវិធីនេះមិនចុះសម្រុងនឹងរចនាសម្ពន្ធសង្គមប្រពៃណី ទំនៀមទម្លាប់របស់ខ្មែរ ឡើយ។ ទន្ទឹមនឹងនេះដែរគេយល់យ៉ាងច្បាស់ថា មុននឹងដាក់លុយធ្វើវិនិយោគនៅក្នុងប្រទេសកម្ពុជាទាមទារឱ្យមាន ការបង្កើតឡើងនូវរចនា សម្ពន្ធសេដ្ឋកិច្ចសង្គមមួយថ្មីទាំងស្រុង ដែលអាចបង្ហាញឱ្យឃើញនូវផលប្រយោជន៍របស់ពួកនិយោជិក និងផ្តល់បរិយាកាស

[260] ចំពោះការពិនិត្យឱ្យស៊ីជម្រៅយើងឃើញថា បារាំងបានបង្ខំឱ្យព្រះរាជាកម្ពុជាទទួលយកកំណែទម្រង់រដ្ឋបាល, តុលាការ, ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម។ ប៉ុន្តែ ដោយមានចលនាបះបោរប្រឆាំងបារាំងនោះ ការប៉ុនប៉ងរបស់បារាំងក្នុងការដណ្តើមអំណាចពីព្រះរាជាខ្មែរលើកទី១នេះ មិនបានជោគជ័យទេ។ ចំពោះអនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ បានបង្ហាញនៅចំណុចចាប់អារម្មណ៍ទៅលើ២មាត្រាគឺមាត្រាទី២ ដែលបង្ហាញយ៉ាងច្បាស់ថា បារាំងនៅតែជាអាណាព្យាបាលរបស់កម្ពុជា។ មាត្រាទី៦ ដែលនាំឱ្យខ្មែរ មានការប៉ះបោរ និងមានការគាំទ្រពីព្រះបាទនរោត្តម។

ល្អដើម្បីដឹកនាំសេដ្ឋកិច្ចប្រទេស។ នៅក្នុងរាជធានីគេបានបង្កើតតុលាការកំពូល ដែលនៅក្នុងពេលជាមួយគ្នា មានតួនាទីជាសាលាក្ដីទីបីសម្រាប់ទទួលនូវពាក្យបណ្ដឹងមិនយល់ព្រមពីសាលាក្ដីថ្នាក់ក្រោម។ ក្នុងស្ថានភាព បែបនេះជាការពិតណាស់ត្រូវបានកាត់បន្ថយនូវតួនាទីកាត់ក្ដីរបស់មន្ត្រីរាជការ ។

ទោះបីជាមានការប្រឆាំងនឹងបារាំងក៏ដោយចុះ បារាំងនៅតែគិតពីបញ្ហាកំណែទម្រង់ជាធំ ដែលក្រោយ កំណែទម្រង់រដ្ឋបាលឆ្នាំ១៨៨៤ គឺនៅឆ្នាំ១៨៨៦ បារាំងបង្កើតបណ្ដា«ខេត្តជួរមុខ» ដើម្បីការពារទឹកដី កម្ពុជា។ ខេត្តទាំងនោះមានដូចជា៖

| ល.រ | ខេត្ត | ទីតាំងភូមិសាស្ត្រ |
|---|---|---|
| ១ | កំពត | ខេត្តជួរមុខ នៅតំបន់មាត់សមុទ្ទទាំងមូល |
| ២ | ក្រចេះ | ខេត្តជួរមុខនៅភូមិភាគឦសាន(ស្ទឹងត្រែងសៀមកាន់កាប់) |
| ៣ | កំពង់ធំ | ខេត្តជួរមុខនៅភូមិភាគឧត្តរ (មូលព្រៃ និងទន្លេរពៅសៀមកាន់កាប់) |
| ៤ | ពោធិ៍សាត់ | ខេត្តជួរមុខនៅភូមិភាគពាយ័ព្យ (បាត់ដំបងសៀមកាន់កាប់) |
| ៥ | ភ្នំពេញ | ទីតាំងអំណាចបារាំងថ្នាក់ជាតិ និងជាបេះដូងនៃប្រទេសកម្ពុជា |

ក្រោយកំណែទម្រង់ឆ្នាំ១៨៨៤ គឺមានការបះបោរដោយមានទិដ្ឋភាព២សំខាន់ទិដ្ឋភាពនយោបាយ ដែល បារាំងបានបន្ធូរបន្ថយ ដោយឱ្យព្រះបាទនរោត្តមគ្រប់គ្រងបន្ត។ ចំពោះទិដ្ឋភាពរដ្ឋបាល គឺប្រទេសបារាំងបាន ចុះព្រឹត្តិបត្រ ដែលមានកំណែទម្រង់រដ្ឋបាលខ្មែរដំបូងនៅឆ្នាំ១៨៨៤។ បារាំងចាប់ផ្ដើមក្ដាប់រដ្ឋបាល ថ្នាក់ជាតិ ដោយបង្រួមខេត្ត តែបារាំងមិនហ៊ានដូរឈ្មោះអ្វីឡើយ។ នៅឆ្នាំ១៨៨៦ ទើបចាប់ផ្ដើមរៀបចំ ទីរ៉េស៊ីដង់ខេត្ត (...) ដែលគ្រប់គ្រងដោយបារាំង និងមានចៅហ្វាយស្រុក(...) ខេត្ត ដែលខ្មែរជាអ្នកគ្រប់គ្រង។

### ២.៥-ព្រះរាជប្រកាស ១១ កក្កដា ១៨៩៧ [261]

បារាំងបានបោះបង់ការប៉ុនប៉ងនេះទៅវិញ ហើយបានសាកល្បងម្ដងទៀតដោយបានជោគជ័យនៅឆ្នាំ ១៨៩៧ តាមរយៈព្រះរាជប្រកាសចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៨៩៧។ ព្រះរាជប្រកាសនេះបានដកអំណាចពី ព្រះរាជាខ្មែរ ហើយប្រគល់ទៅឱ្យរេស៊ីដង់ជាន់ខ្ពស់បារាំងជំនួសវិញ តាមរយៈកិច្ចប្រជុំគណៈរដ្ឋមន្ត្រីខ្មែរ នៅ ក្រោមអធិបតីភាពរបស់រេស៊ីដង់ជាន់ខ្ពស់ ដោយមិនមានវត្តមានព្រះរាជាខ្មែរ និងការចុះហត្ថលេខាអមដោយ រេស៊ីដង់ជាន់ខ្ពស់លើលិខិតបទដ្ឋានគតិយុត្ត ដែលព្រះរាជាខ្មែរបានឡាយព្រះហស្តលេខាមុននឹងដាក់ឱ្យអនុវត្ត [262]។ ព្រះរាជប្រកាសនេះបានបង្ហាញឱ្យឃើញថាព្រះមហាក្សត្របានក្លាយជាម៉ាស៊ីនចុះហត្ថលេខា[263]។

ព្រះរាជប្រកាសខាងលើនេះមានខ្លឹមសារសំខាន់ថា ក្រុមប្រឹក្សាមួយ ដែលមានមន្ត្រីធំបំផុត៥នាក់នឹង មានភារកិច្ចពិនិត្យ និងអនុវត្តច្បាប់ ព្រមទាំងធ្វើការសិក្សាលើកំណែទម្រង់ឬ ការផ្លាស់ប្ដូរដែលអាចនឹងកើត មាន។ ក្រុមប្រឹក្សានេះដែលមានឈ្មោះថា «កុង្ស៊ីយ៍សេនាបតី[264]» មានរដ្ឋមន្ត្រី៥រូបគឺអគ្គមហាសេនា, យមរាជ, ក្រឡាហោម

---

[261] ព្រះរាជប្រកាសថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៨៩៧ ត្រូវបានចាត់ទុកថាជា រដ្ឋធម្មនុញ្ញ នៃប្រទេសកម្ពុជាចាប់ពីក្រោយឆ្នាំ១៨៩៧។ ដូច្នេះព្រះរាជ ប្រកាសដែលចេញជាបន្ទាប់មកចាប់ផ្ដើម ដោយពាក្យមួយឃ្លាថា«បានទ្រង់យល់ព្រះរាជប្រកាស...ថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៨៩៧»។

[262] បណ្ឌិតសភាចារ្យសឺន សំណាង, *របាយការណ៍សង្ខេបទី១ស្ដីពីសកម្មភាព នៃការស្រាវជ្រាវឯកសារជាតិដែលចាស់ទ្រុឌទ្រោម,* ទំព័រ២។

[263] សម្ដេចព្រះនរោត្តម សីហនុ ទ្រង់បានមានព្រះរាជបន្ទូលថាព្រះរាជាកម្ពុជាប្រៀបដូចជា«ម៉ាស៊ីនចុះហត្ថលេខា» ពីឆ្នាំ១៨៨៤ ដល់ឆ្នាំ១៩៤៥» (យោង: NORODOM SIHANOUK, L'Indochine vue de Pékin: entretiens avec Jean Lacouture, Editions du Seuil, 1972,p.27.)

[264] កុង្ស៊ីយ៍សេនាបតី ( Conseil des Ministres ) ជាគណៈរដ្ឋមន្ត្រី។

និងចក្រីវាំង។ ក្រុមប្រឹក្សានឹងធ្វើការសម្រេច ដោយមិនមានវត្តមានរបស់យើង នៅក្រោមអធិបតីភាពរបស់ រេស៊ីដង់ជាន់ខ្ពស់ បន្ទាប់មកដាក់ថ្វាយមកយើងនូវវិធានការនយោបាយ និងរដ្ឋបាលដែលមានប្រយោជន៍ចំពោះប្រទេស*(មាត្រា១)*។ យើងតែងតាំង និងដកតំណែងពួកមន្ត្រីតាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។ រាល់សេចក្តីសម្រេច ឬ ប្រកាសដែលចេញពីយើងបោះត្រា របស់យើង ត្រូវចុះហត្ថលេខាអម និងប្រកាសឱ្យប្រើដោយរេស៊ីដង់ជាន់ខ្ពស់*(មាត្រា២)*។ ជាជំនួយរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មន្ត្រី៥រូបមានភារកិច្ចជំនួសរដ្ឋមន្ត្រីនីមួយៗនៅពេលអវត្តមាន ឬ មានឧបសគ្គ និងជាជំនួយក្នុងរដ្ឋបាលទូទៅ *(មាត្រា៣)*។

បន្ទាប់ពីប្រមូលអំណាចបាន ពីព្រះរាជាខ្មែរនៅឆ្នាំ១៨៩៧ រេស៊ីដង់ជាន់ខ្ពស់ (Résident supérieur) បារាំងនៅភ្នំពេញមានអំណាចលើព្រះរាជា និងគណៈរដ្ឋមន្ត្រីខ្មែរ។បន្ទាប់មកបារាំងបានរៀបចំ រដ្ឋបាលថ្នាក់ខេត្តដែលហៅថា «ទីរេស៊ីដង់» ឬ «ទីរួមខែត្ររេស៊ីដង់» (Résidence/Circonscription résidentielle) ដែលគ្រប់គ្រងដោយ «ចៅហ្វាយខេត្តបារាំង» ហៅថា «រេស៊ីដង់ខេត្ត»។ ទោះជាយ៉ាងនេះក្តី ក៏អាជ្ញាធរបារាំងនៅតែបន្តការគ្រប់គ្រងកម្ពុជាបែប «អាណាព្យាបាល» (Protectorat) ពោលគឺឱ្យមាន កិច្ចសហការពីព្រះរាជា និងមន្ត្រីកម្ពុជានៅក្នុង «រដ្ឋបាលមិនផ្ទាល់» (Administration indirecte)[265]។ ប៉ុន្តែសម្តេចព្រះនរោត្តម សីហនុ ទ្រង់បានមានព្រះរាជបន្ទូលថាព្រះរាជាកម្ពុជា ប្រៀបដូចជា «ម៉ាស៊ីនចុះហត្ថលេខា» ពីឆ្នាំ១៨៨៤ ដល់ឆ្នាំ១៩៤៥»[266]។ ចាប់ពីឆ្នាំ១៨៧៩ ទេសាភិបាលស៊ីវិលបារាំងនៅ កូសាំងស៊ីន ឈ្មោះ ឡឺ មៀរ ដឺ វីលែរ (Le Myre de Villers) ចង់ភ្ជាប់ប្រទេសកម្ពុជា ជាមួយអាណានិគម បារាំង នៅកូសាំងស៊ីន[267]។

### ៣-កំណែទម្រង់ និងអភិក្រមធំនើបកម្ម[268]

សហភាពឥណ្ឌូចិន(Union Indochinoise)ជាឈ្មោះផ្លូវការនៃឥណ្ឌូចិនដែលត្រូវបានគ្រប់គ្រងដោយបារាំងមានរដ្ឋចំនួន៥គឺអាណានិគមមួយមានកូសាំងស៊ីន និងប្រទេសក្រោមអាណាព្យាបាលចំនួនបួនគឺកម្ពុជា, អាណ្ណាម, តុងកឹង និងឡាវ។ ឈ្មោះសហភាពឥណ្ឌូចិនដែលបានបង្កើតឆ្នាំ១៨៨៧ និងត្រូវជំនួសដោយឈ្មោះមួយថ្មីហៅថា«សហព័ន្ធឥណ្ឌូចិន(Fédération Indochinoise)» ពីឆ្នាំ១៩៤៦ ដល់ខែកក្កដា ឆ្នាំ១៩៥៤។ ឈ្មោះក្រៅផ្លូវការគឺ«ឥណ្ឌូចិនបារាំង(Indochine Française)»[269]។

ចំពោះការកែប្រែសង្គមកម្ពុជាឱ្យទៅជាសង្គមស៊ីវិល័យនោះ ហាក់មិនសូវមានសកម្មភាពផងដែរក្រោយឆ្នាំ១៩៣៩។ ចាប់ពីឆ្នាំ១៩៣៩មក បារាំងមិនបានធ្វើអ្វីជាដុំកំភួនទេ ព្រោះរដ្ឋាភិបាលបារាំងក៏ស្ថិតក្រោមការគ្រប់គ្រងរបស់អាល្លឺម៉ង់។ រហូតមកដល់ឆ្នាំ១៩៤៩ ឥទ្ធិពលរបស់បារាំងបានធ្លាក់ចុះដែលជាមូលហេតុនាំឱ្យមានការប្រគល់ឯករាជ្យឱ្យប្រទេសនៅអាស៊ីអាគ្នេយ៍ផងដែរ ប៉ុន្តែឯករាជ្យនេះមិនពេញលេញឡើយ។ ទោះបីជាប្រឈមមុខនឹងការបះបោរប្រឆាំងបារាំងពីឆ្នាំ១៨៨៥ ដល់១៨៩១, ការជួបវិបត្តិក្នុងសង្គ្រាមលោកលើកទី២ និងការដែលត្រឡប់មកវិញក្រោយសង្គ្រាមលោកលើកទី២ក្នុងឋានៈជាទីប្រឹក្សាក៏ដោយ បារាំងក៏បានចូលរួមច្រើនក្នុងការកែប្រែសង្គមកម្ពុជាឱ្យក្លាយជាសង្គមស៊ីវិល័យផងដែរ។ បើយោងតាមអត្ថន័យក្នុង

---

[265] បណ្ឌិតសភាចារ្យ ស៊ិន សំណាង, *របាយការណ៍សង្ខេបទី១ស្តីពីសកម្មភាព នៃការស្រាវជ្រាវឯកសារជាតិដែលចាស់ទ្រុឌទ្រោម*, ទំព័រ៦។

[266] NORODOM SIHANOUK, *L'Indochine vue de Pékin(ឥណ្ឌូចិនមើលពីប៉េកាំង): entretiens avec Jean Lacouture*, Editions du Seuil, 1972, p.27.

[267] Sorn Samnang, *L'évolution de la société cambodgienne entre les deux guerres mondiales, 1919-1939*, op.cit., p.13.

[268] សូមមើលៈ ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៣០៥-៤១០។

[269] ស៊ិន សំណាង, *របាយការណ៍សង្ខេបទី១ ស្តីពីសកម្មភាពនៃការស្រាវជ្រាវឯកសារជាតិដែលចាស់ទ្រុឌទ្រោម*, ទំព័រ៣។

សៀវភៅរបស់ វង់ សុធារ៉ា និងណុប សុខា បានពន្យល់ថាគឺអភិក្រមទំនើបកម្មមានន័យថាជាសកម្មភាព ឬគោលនយោបាយដែលបារាំងសាបព្រោះ ដើម្បីធ្វើឱ្យជីវភាពរស់នៅរបស់អ្នកស្រុកមានការប្រែប្រួលបែរឆ្ពោះទៅរកភាពទំនើបតាមតម្រូវនៃមហាអំណាចប្រទេសនៅអឺរ៉ុប។ ការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមួយសម័យទំនើប វាជាកិច្ចការមួយយ៉ាងលំបាកគឺបារាំងបានកែប្រែរបៀបគ្រប់គ្រងប្រទេស ទាំងផ្នែករដ្ឋបាល, សេដ្ឋកិច្ច, ពាណិជ្ជកម្ម, តុលាការ និងហិរញ្ញវត្ថុណាមួយត្រូវរក្សារបៀបរស់នៅទំនៀបទម្លាប់ប្រពៃណីខ្មែរផង។ បារាំងបានបង្ខំឱ្យខ្មែរឈានទៅរកសម័យទំនើបចាប់ផ្ដើមពីការទារពន្ធដារ ដែលខ្មែរពេលនោះចេញផុតបន្តិចម្ដងៗពីរបបសក្តិភូមិ តែធ្ងន់ធ្ងរជាមួយពន្ធអាករដែលជាហេតុនាំឱ្យមានទំនាស់ជាមួយប្រជាជន និងរដ្ឋបាលបារាំង ហើយអភិក្រមទំនើបកម្មនៅកម្ពុជាក៏នាំឱ្យមានទំនាស់រវាងវប្បធម៌ និងវប្បធម៌ដែរ។ អភិក្រមនេះ ក៏បានផ្ដល់នូវផលវិបាកជាច្រើនផងដែរសម្រាប់កម្ពុជា ក្នុងសតវត្សរ៍ទី១៩-២០ នោះផងដែរ។

អភិក្រមទំនើបកម្មរបស់បារាំងនៅកម្ពុជានាសម័យអាណាព្យាបាល គឺជាដំណើរការនៃការផ្លាស់ប្ដូររចនាសម្ពន្ធពីប្រពៃណីទៅជារបៀបទំនើបតាមបែបបស្ចិមប្រទេស ដែលនាំឱ្យមានទំនាស់វប្បធម៌រវាងខ្មែរ និងបារាំងផងដែរ។ គោលបំណងចម្បងនៃទំនើបកម្មនេះ គឺដើម្បីសម្រួលដល់ការគ្រប់គ្រងរបស់បារាំង ព្រមទាំងទាញយកផលប្រយោជន៍សេដ្ឋកិច្ចពីកម្ពុជា។ កំណែទម្រង់រដ្ឋបាល បារាំងបានបង្កើតរបបរដ្ឋបាលអាណាព្យាបាលដែលមានរេស៊ីដង់ជាន់ខ្ពស់ (Résident supérieur) ជាអ្នកតំណាងនៅអមព្រះមហាក្សត្រ ចាប់ពីឆ្នាំ១៨៨៩ ដល់១៩៤៥។ ពួកគេបានកែទម្រង់រដ្ឋបាលកម្ពុជាឡើងវិញ ដោយបង្កើតក្រុមប្រឹក្សារដ្ឋមន្ត្រី (ដោយមិនមានព្រះវត្តមានរបស់ព្រះមហាក្សត្រ) និងបានរៀបចំដែនដីខេត្តជាថ្មី ព្រមទាំងចាត់ថ្នាក់ខេត្តឡើងវិញសម្រាប់ងាយស្រួលប្រមូលពន្ធ។ ផ្នែករដ្ឋបាលថ្នាក់មូលដ្ឋានគឺឃុំ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩០៨ និងកែប្រែនៅឆ្នាំ១៩១៩ ដើម្បីពង្រឹងសន្តិសុខ និងសម្រួលដល់ការងារប្រមូលពន្ធដារ។ ក្រុងភ្នំពេញ ត្រូវបានកំណត់ព្រំដែន និងស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់បារាំងតាំងពីឆ្នាំ១៩០១ ហើយបារាំងបានចេញបទបញ្ញត្តិជាច្រើនសម្រាប់ការរស់នៅប្រចាំថ្ងៃ និងការសម្អាតមុខផ្ទះជាដើម។ ផ្នែកតុលាការក៏ត្រូវបានវិវត្ត និងកំណត់ឋានានុក្រមចៅក្រមផងដែរ។

នយោបាយសារពើពន្ធ បារាំងបានលុបបំបាត់បទបញ្ញត្តិពន្ធដារបែបប្រពៃណី និងបានបង្កើតកម្មសិទ្ធិឯកជនលើដីធ្លី។ ពួកគេបានដាក់ចេញនូវប្រភេទពន្ធជាច្រើន ដែលមានលក្ខណៈធ្ងន់ធ្ងរចំពោះប្រជាជនខ្មែរ ដូចជាពន្ធថ្លៃរាជការខ្លួន (impôt personnel) (ចាប់ពីឆ្នាំ១៨៧០) និងពន្ធកំណែន ដែលតម្រូវឱ្យពលរដ្ឋខ្មែរត្រូវបម្រើការងាររដ្ឋ១០ថ្ងៃក្នុងមួយឆ្នាំ ឬបង់ប្រាក់លោះ។ ក្រៅពីនេះ ក៏មានពន្ធលើដីដាំដុះ ពន្ធលើដំណាំ(ស្រូវម្រេច) និងពន្ធលើយានជំនិះ ផងដែរ។ គណៈកម្មការត្រួតពិនិត្យបានរកឃើញថាប្រជាជនខ្មែរបង់ពន្ធខ្លួនច្រើនហួសហេតុ។

ហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍ ការកសាងផ្លូវគមនាគមន៍ (ដូចជាផ្លូវអាណានិគមលេខ១ និងលេខ១ស្ទួន) ត្រូវបានធ្វើឡើងដោយប្រើប្រាស់ ពន្ធកំណែន (កម្លាំងពលកម្ម) របស់ប្រជារាស្ត្រខ្មែរ។ ផ្លូវទាំងនេះត្រូវបានរៀបចំឡើងដើម្បីត្រៀមបង្ក្រាបពួកបះបោរ សម្រួលការគ្រប់គ្រង និងដឹកជញ្ជូនទំនិញសម្រាប់សេដ្ឋកិច្ច។ វិស័យអប់រំ និងវប្បធម៌ បារាំងបានកែទម្រង់ការអប់រំបែបបុរាណនៅតាមវត្ត និងបានបង្កើតសាលារៀនផ្លូវការបារាំង-ខ្មែរ (បឋមសិក្សាដល់មធ្យមសិក្សា ដូចជា អនុវិទ្យាល័យស៊ីសុវត្ថិ)។ ការបង្កើត សាលាបាលី និង ពុទ្ធសាសនបណ្ឌិត្យ ក៏ដូចជាសាលាបារាំងចុងបូព៌ា (ÉFEO) បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិរក្ស និងពង្រឹងភាសាខ្មែរ និងវប្បធម៌ ដែលនាំឱ្យបញ្ញវន្តខ្មែររកឃើញឡើងវិញនូវអត្តសញ្ញាណជាតិ និងស្មារតីជាតិ

និយម។ នយោបាយ និងសេដ្ឋកិច្ច ក្រោយសង្គ្រាមលោកលើកទី២ បារាំងបានដាក់លំហាត់ប្រជាធិបតេយ្យឱ្យខ្មែរសាកល្បងអនុវត្ត ដោយផ្តល់សេរីភាពបង្កើតសមាគម និងគណបក្សនយោបាយ (១៩៤៦) ដែលនាំទៅដល់ការបង្កើតរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ និងរបបសភានិយម។ ទោះជាយ៉ាងណាក៏ដោយ វិស័យសេដ្ឋកិច្ចត្រូវបានជំរុញទៅរកវិស័យកសិកម្ម(ដូចជាចម្ការកៅស៊ូ) ដើម្បីផ្គត់ផ្គង់ទីផ្សារនាំចេញ។ វិស័យពាណិជ្ជកម្មត្រូវបានបារាំងប្រគល់ឱ្យពួកចិនក្តោបក្តាប់ ដែលធ្វើឱ្យពួកចិនក្លាយជាវណ្ណៈសេដ្ឋពាណិជដ៏មានឥទ្ធិពល និងសេរីភាពនៅកម្ពុជា។

សរុបមក អភិក្រមទំនើបកម្មរបស់បារាំង គឺជាការបញ្ចូលប្រព័ន្ធរដ្ឋបាល និងច្បាប់ទំនើបតាមបែបបស្ចិមលោក ប៉ុន្តែវាក៏ជាយន្តការសម្រាប់បារាំងទាញយកធនធាន (តាមរយៈពន្ធធ្ងន់ធ្ងរ និងការកែនពលកម្ម) និងជះឥទ្ធិពលវប្បធម៌ផងដែរ។

## ៤-ចលនាតស៊ូដើម្បីទាមទារឯករាជ្យ[270]

ការទាមទារឯករាជ្យជាតិរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវបានសម្រេចដោយជោគជ័យ និងពេញបរិបូរណ៍នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ ឯករាជ្យដែលទទួលបាននេះ គឺជាសមិទ្ធផលចុងក្រោយនៃដំណើរការតស៊ូដ៏យូរអង្វែង ក្រោយពីកម្ពុជាធ្លាប់ទទួលបានឯករាជ្យទ្រឹស្តីពីជប៉ុននៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៤៥ និងឯករាជ្យក្លែងក្លាយតាមសន្ធិសញ្ញាបារាំង-ខ្មែរនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩។ ចាប់ពីឆ្នាំ១៩៤៥ តទៅ ការចុះទន់ខ្សោយនៃមហាអំណាចអាណានិគមនៅអឺរ៉ុប ក្រោយសង្គ្រាមលោកលើកទី២ បានបង្កើតជាឱកាសដ៏ល្អសម្រាប់បណ្តាប្រទេសក្រោមអាណានិគមដើម្បីក្រោកឈរទាមទារឯករាជ្យជាតិ។ ចលនានេះបានប្រព្រឹត្តទៅក្នុងទម្រង់ទ្វេភាគីគឺការតស៊ូដោយសន្តិវិធីនៅក្នុងរដ្ឋាភិបាល (ព្រះរាជបូជនីយកិច្ច) និងចលនាប្រដាប់អាវុធនៅក្រៅរដ្ឋាភិបាល(ខ្មែរឥស្សរៈ)។ នៅក្នុងរដ្ឋាភិបាល សម្តេចព្រះនរោត្តម សីហនុ បានដឹកនាំយុទ្ធនាការទាមទារឯករាជ្យ ដោយចាប់ផ្តើមប្រកាស«ផែនការទាមទារឱ្យបានឯករាជ្យជាតិទាំងស្រុង» នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២។ នៅឆ្នាំ១៩៥៣ ព្រះអង្គបានចាប់ផ្តើមយុទ្ធនាការការទូតនៅក្រៅប្រទេស ដោយយាងទៅប្រទេសបារាំង (ថ្ងៃទី៩ ខែកុម្ភៈ) កាណាដា និងសហរដ្ឋអាម៉េរិក (ថ្ងៃទី១១ ខែមេសា) ដើម្បីស្វែងរកការគាំទ្រអន្តរជាតិ។ ការថ្លែងការណ៍របស់ព្រះអង្គនៅសហរដ្ឋអាម៉េរិកទទួលបានជោគជ័យយ៉ាងខ្លាំងជាមួយកាសែត New York Times ដែលបណ្តាលឱ្យមានការស្នើពិភាក្សារវាងបារាំង-ខ្មែរនៅថ្ងៃទី២៣ ខែមេសា។ ក្រោយត្រឡប់មកវិញពីប្រទេសថៃ ព្រះមហាក្សត្របានគង់នៅតំបន់ស្វយ័ត (សៀមរាប បាត់ដំបង កំពង់ធំ) ដោយបានប្រកាសថាមិនយាងមកភ្នំពេញវិញឡើយ បើមិនបានឯករាជ្យបរិបូរណ៍ជូនជាតិ។ នៅទីនោះ ព្រះអង្គបានរៀបចំ«ផែនការសីហនុ» នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៥៣ ដែលមានគោលដៅកេណ្ឌ ជីវពល (កម្លាំងរស់) របស់ជាតិដែលមាន៥កង រួមទាំង កងនារីក្លាហាន ដើម្បីជំរុញឱ្យប្រជាពលរដ្ឋក្រោកឈរតស៊ូដោយអាវុធទាមទារឯករាជ្យ។ ទន្ទឹមនឹងនេះ នៅក្រៅរដ្ឋាភិបាល ចលនាខ្មែរឥស្សរៈ ដែលជាចលនាមហាជនជាតិនិយមបានក្រោកឡើងប្រឆាំងនឹងបារាំងតាំងពីក្រោយសង្គ្រាមលោកលើកទី២។ ចលនាខ្មែរឥស្សរៈមានពីរនិន្នាការគឺ និន្នាការសេរី (ដូចជាក្រុមបង្កើតកាសែតនគរវត្ត) និង និន្នាការកុម្មុយនីស្ត ដែលស្ថិតក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន(ICP)។ ក្រុមខ្មែរឥស្សរៈ បានកសាងមូលដ្ឋានរបស់ខ្លួននៅក្នុងប្រទេសកម្ពុជានៅអំឡុងឆ្នាំ១៩៤៧-១៩៤៨ ដោយទទួលបានការគាំទ្រពីកម្លាំងកងទ័ពវៀតណាមខាងជើង ហើយហូតដល់ឆ្នាំ

[270] សូមមើល : ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៤១១-៤២៤។

១៩៤៩ កងទ័ពខ្មែរឥស្សរៈបានកាន់កាប់ទឹកដីកម្ពុជាចំនួន១ភាគ៣។ ភាពខ្លាំងក្លានៃចលនាតស៊ូនេះ បានក្លាយជាកត្តាមួយជំរុញឱ្យបារាំងសម្រេចចុះហត្ថលេខាលើកិច្ចព្រមព្រៀងឆ្នាំ១៩៤៩។ យ៉ាងណាមិញ ពួកឧទ្ទាមឥស្សរៈជាងពាក់កណ្តាលក៏បានចូលរួមជាមួយរាជរដ្ឋាភិបាលតាមសេចក្តីទាមទាររបស់ព្រះមហាក្សត្រ ដើម្បីសម្រេចបំណងជាតិ។

ជាលទ្ធផល ដោយសារសម្ពាធទាំងពីរគឺក្នុង និងក្រៅប្រទេស រួមទាំងការចុះខ្សោយនៃមហាអំណាចអឺរ៉ុប និងតម្រូវការដកទ័ពរបស់បារាំងទៅសមរភូមិឡៀន បៀនហ្វូ បារាំងបានចាប់ផ្តើមផ្ទេរស្ថាប័នសំខាន់ៗមកឱ្យកម្ពុជាវិញនៅឆ្នាំ១៩៥៣។ ការផ្ទេរអធិបតេយ្យភាពការទូតត្រូវបានធ្វើឡើងនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៥៣។ អំណាចតុលាការ និងប៉ូលិស ផ្ទេរនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ ហើយអំណាចយោធាផ្ទេរនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៥៣។ ព្រឹត្តិការណ៍នេះបានឈានដល់ការប្រារព្ធពិធីផ្ទេរអំណាចទាំងស្រុងរបស់បារាំងមកឱ្យកម្ពុជានៅព្រះបរមរាជវាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ ឯករាជ្យពេញបរិបូរណ៍នេះបានផ្តល់ឱ្យកម្ពុជានូវឯករាជ្យផ្នែកនយោបាយ កិច្ចការបរទេស និងសេដ្ឋកិច្ច ព្រមទាំងរួចផុតពីការបង់ពន្ធដារកម្រិតខ្ពស់ និងមានសិទ្ធិកំណត់ជោគវាសនាដោយខ្លួនឯង។ អ្វីដែលសំខាន់គឺកម្ពុជាទទួលបានឯករាជ្យនេះ មុនសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ ដែលមានសមត្ថកិច្ចត្រឹមតែការបញ្ឈប់សង្គ្រាម និងការស្តារសន្តិភាពនៅក្នុងឧបទ្វីបឥណ្ឌូចិនទាំងបីប៉ុណ្ណោះ។ ឯករាជ្យនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គឺជាចំណុចរបត់ប្រវត្តិសាស្ត្រថ្មីមួយ ដែលបានផ្តល់មកវិញនូវកិត្តិយស និងសេចក្តីថ្លៃថ្នូរជាប្រជាជាតិឯករាជ្យមួយស្របតាមច្បាប់អន្តរជាតិ។

## ៥-ផលវិជ្ជមាន និងផលអវិជ្ជមាននៃរបបអាណាព្យាបាលបារាំងនៅកម្ពុជា

| ផលវិជ្ជមាន | ផលអវិជ្ជមាន |
|---|---|
| – កំណែទម្រង់ថ្នាក់ក្រោមជាតិ ដែលពីមុនជាទម្រង់នៅការគ្រប់គ្រង បែបមណ្ឌលអំណាចក្នុងប្រទេស មកជាការគ្រប់គ្រងបែបពីរ៉ាមីត<br>– អភិវឌ្ឍវិស័យគមនាគមន៍<br>– ជួយរក្សាទឹកដីឱ្យខ្មែរគង់វង្សដល់សព្វថ្ងៃ<br>– សៀមដកខ្លួនចេញពីទឹកដីខ្មែរនៅភាគខាងជើង និងភាគពាយ័ព្យ នៃប្រទេសកម្ពុជាមានៈ<br>• នៅឆ្នាំ១៨៩០ សៀមដកពីធ្លូងលើ<br>• នៅឆ្នាំ១៨៩៣ សៀមដកពីខេត្តស្ទឹងត្រែង<br>• នៅឆ្នាំ១៩០៤សៀមដកពីម្លូព្រៃ និងទន្លេរពៅ<br>• នៅឆ្នាំ១៩០៧ សៀមដកពីខេត្តបាត់ដំបង សៀមរាប និងស៊ីសុផុន។<br>– ក្នុងរាជ្យព្រះបាទមុនីវង្សមានការកសាងផ្លូវគមនាគមន៍ ផ្លូវដែក ស្ពាន...<br>– ដំណាំកសិឧស្សាហកម្មមានការរីកចម្រើន<br>– ក្នុងរាជ្យព្រះបាទស៊ីសុវត្ថិការសិក្សាបានចាប់ផ្តើម<br>– ឆ្នាំ១៩១៥ រៀបចំវចនានុក្រមខ្មែរ | – ការយកពន្ធដារយ៉ាងធ្ងន់ធ្ងរ<br>– កេណ្ឌប្រជាជនខ្មែរឱ្យទៅបម្រើយោធាស្លាប់នៅសមរភូមិសង្គ្រាមលោកលើកទី១ និងទី២<br>– តំបន់ដាឡាត់កាត់ទៅឱ្យវៀតណាម<br>– ខេត្តត្រាចត្រូវធ្លាក់ក្នុងដៃប្រទេសសៀម<br>– ដឹកជញ្ជូនវត្ថុកេតនភ័ណ្ឌទៅស្រុកបារាំង<br>– ឆ្នាំ១៩០៧ កាត់ខេត្តត្រាចទៅឱ្យសៀម<br>– ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣៩ បារាំងដាក់បញ្ចូលកោះត្រល់ ចូលក្នុងដែនរដ្ឋបាលកូសាំងស៊ីន<br>– ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩ បារាំងបានកាត់ទឹកដីកម្ពុជាក្រោមឱ្យទៅវៀតណាម។<br>– មានចម្លើយត្រឹមត្រូវផ្សេងទៀត |

| | |
|---|---|
| – លុបបំបាត់របបទាសភាព<br>– រៀបចំសង្គមខ្មែរឱ្យក្លាយជាសង្គមទំនើប<br>– បណ្តុះបណ្តាលផ្នែកអប់រំ និងបញ្ញវន្តខ្មែរ<br>– គូសផែនទីដងវែកនៅឆ្នាំ១៩០៨<br>– មានការចងក្រងប្រវត្តិខេត្ត<br>– សិក្សាស្រាវជ្រាវ ចងក្រងពីអរិយធម៌ប្រវត្តិសាស្ត្រខ្មែរ និងធ្វើការផ្សព្វផ្សាយទៅលើឆាកអន្តរជាតិ និងជួយជួសជុល ការពារប្រាសាទខ្មែរ<br>– ការបង្កើតសាលាបាលី, សាលាបារាំងចុងបូព៌ា, បណ្ណាល័យជាតិនិងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនាដើមសតវត្សរ៍ទី២០ បានជួយខ្មែររកឃើញវិញនូវអត្តសញ្ញាណជាតិ។<br>– ចម្លើយត្រឹមត្រូវផ្សេងទៀត | |

សរុបសេចក្តីមកសម័យអាណាព្យាបាលបារាំងបានបន្សល់ទុកនូវកេរដំណែលពីរយ៉ាងផ្ទុយគ្នាសម្រាប់កម្ពុជា។ ក្នុងន័យវិជ្ជមាន បារាំងបានអនុវត្តកំណែទម្រង់រដ្ឋបាលបែបពីរ៉ាមីត និងអភិវឌ្ឍវិស័យគមនាគមន៍។ សំខាន់ជាងនេះបារាំងបានជួយថែរក្សាទឹកដីខ្មែរឱ្យគង់វង្ស និងបានទាមទារខេត្តបាត់ដំបង និងសៀមរាបពីសៀមមកវិញនៅឆ្នាំ១៩០៧។ តាមរយៈការបង្កើតស្ថាប័នស្រាវជ្រាវ ក៏ដូចជាការចងក្រងវចនានុក្រមខ្មែរ ការអប់រំ និងបញ្ញវន្តខ្មែរត្រូវបានលើកស្ទួយ ហើយខ្មែរបានរកឃើញវិញនូវអត្តសញ្ញាណជាតិ។ ទោះជាយ៉ាងណា ក៏មានផលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដែរ ដូចជាការជំរិតទារពន្ធដារខ្លាំងពេក ដែលបង្កឱ្យមានគម្លាតសង្គម។ លើសពីនេះ កម្ពុជាបានបាត់បង់ទឹកដីសំខាន់ៗមួយចំនួន ជាក់ស្តែងការដាក់បញ្ចូលកោះត្រល់ក្នុងរដ្ឋបាលកូសាំងស៊ីននៅឆ្នាំ១៩៣៩ និងការកាត់ទឹកដីកម្ពុជាក្រោមទៅឱ្យវៀតណាមនៅឆ្នាំ១៩៤៩។ កេរដំណែលនេះគឺជាការរួមបញ្ចូលគ្នារវាងការបង្កើតមូលដ្ឋានគ្រឹះនៃសង្គមទំនើបកម្ម និងការធ្វើអាណានិគមនិយមផ្នែកសេដ្ឋកិច្ច។ ប៉ុន្តែទោះជាយ៉ាងនេះក្តី តាមទម្រង់រដ្ឋបាលបារាំងបានដាក់អាណាព្យាបាលនៅកម្ពុជា មិនមែនអាណានិគមឡើយ។ សម្រាប់មតិលើកឡើងថាចាប់ពីឆ្នាំ១៨៦៣ ដល់១៨៨៤ អាណាព្យាបាលបារាំងនៅកម្ពុជា ហើយចាប់១៨៨៤ ដល់១៩៥៣ ជាអាណានិគមបារាំងនៅកម្ពុជាគឺមិនត្រឹមត្រូវឡើយ។

## ៦-សំណួរត្រិះរិះ

១-តើអ្នកយល់យ៉ាងណាចំពោះការនាំយកអារ្យធម៌មកឱ្យកម្ពុជាដោយអាណាព្យាបាលបារាំង? ចូរពន្យល់។

២-តើការដាក់អាណានិគម និងអាណាព្យាបាលរបស់បារាំងនៅឥណ្ឌូចិនអាចប៉ះពាល់ដល់ប្រពៃណីរបស់អ្នកស្រុកអាយបែបណាខ្លះ? ចូរពន្យល់ និងលើកឧទាហរណ៍មកបញ្ជាក់។

៣-តើមហាអំណាចអឺរ៉ុបណាខ្លះដែលបានចូលមកទាញផលប្រយោជន៍ ឬដាក់អាណានិគមក្នុងតំបន់អាស៊ីអាគ្នេយ៍? ហេតុអ្វីបានជាប្រទេសអឺរ៉ុបទាំងនោះមិនផ្តោតការដាក់អាណានិគមលើកម្ពុជា?

៤-មានមតិមួយពោលថា៖ ការបង្កើតសាលាបាលី ការបង្កើតសាលាបារាំងចុងបូព៌ា (EFEO) ការបង្កើតបណ្ណាល័យជាតិ និងការបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនាដើមសតវត្សរ៍ទី២០ បានជួយខ្មែររកឃើញវិញនូវអត្តសញ្ញាណជាតិ។ ចូរពន្យល់មតិខាងលើនេះ។

## មេរៀនទី១០ ប្រទេសកម្ពុជាសម័យសង្គមរាស្ត្រនិយម (ពីឆ្នាំ១៩៥៥ ដល់១៩៧០)

### ១-ស្ថានភាពសង្គមខ្មែរឆ្នាំ១៩៤៦-១៩៥៥

នៅពេលដែលបារាំងឈានជើងចូលទឹកដីកម្ពុជាជាលើកទី២ក្រោយឆ្នាំ១៩៤៥ បារាំងបានធ្វើការផ្លាស់ប្តូរយ៉ាងច្រើននូវតំរិយាបថទាំងឡាយដែលធ្លាប់មានកាលពីមុនមក។ ក្នុងការត្រឡប់មកវិញនេះប្រទេសកម្ពុជាស្ថិតក្នុងទម្រង់អាណាព្យាបាលដដែល តែបារាំងមានឋានៈជាទីប្រឹក្សារបស់ខ្មែរ។ នៅក្នុងរយៈកាលលើកទី១ ដែលបារាំងត្រួតត្រាកម្ពុជា បាននាំឱ្យមានភាពមិនសប្បាយចិត្តយ៉ាងច្រើនពីសំណាក់ប្រជារាស្ត្រខ្មែរ ចំពោះអ្នកអាណាព្យាបាល ទើបបង្កបង្កើតឱ្យមាននូវចលនាជាច្រើនដែលប្រឆាំងនឹងបារាំង។ ដើម្បីជាការលួងចិត្តខ្មែរឱ្យងាកចេញពីការតស៊ូប្រឆាំងនឹងខ្លួនបារាំងបានដាក់លំហាត់ប្រជាធិបតេយ្យបែបបារាំងមកឱ្យខ្មែរអនុវត្ត។ ការអនុវត្តជាបឋម គឺព្រះរាជក្រមលេខ១៦៦ន.ស និងព្រះរាជក្រមលេខ១៦៧ន.ស ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៤៦ ដែលចែងអំពីសេរីភាពនៃការចូលប្រជុំ និងសេរីភាពនៃការបង្កើតសមាគម។ ព្រះរាជក្រមទាំងពីរនេះបានផ្តល់ឱ្យប្រជារាស្ត្រខ្មែរនូវសេរីភាពនៃការរួមប្រជុំ និងការបង្កើតសមាគមដោយរួមទាំងគណបក្សនយោបាយផង។ ទោះបីជាព្រះរាជក្រមទាំងពីរនេះ ដាក់ឱ្យប្រើជាបណ្តោះអាសន្នក៏ដោយ។ ក្រោយពី ការប្រកាសឱ្យប្រើព្រះរាជក្រមនេះ សមាគមនយោបាយនៅប្រទេសកម្ពុជាក៏ចាប់បដិសន្ធិឡើងដែរ ដែល សុទ្ធសឹងតែស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមព្រះញាតិវង្ស[271]។ នៅឆ្នាំ១៩៤៦ គណបក្សនយោបាយចំនួនបីត្រូវបានបង្កើតឡើងដោយក្រុមញាតិវង្សដូចជាគណបក្សប្រជាធិបតេយ្យ[272], គណបក្សសេរីភាព[273], គណបក្សចម្រើនជាតិ[274] ដែលគណបក្សនេះពុំសូវសំខាន់ឡើយហើយបានបាត់ខ្លួនពីឆាកនយោបាយយ៉ាងឆាប់រហ័ស[275]។

នេះជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលមានការកើតឡើងនូវរបបនយោបាយពហុបក្ស។ ក្នុងចំណោមគណបក្សនយោបាយទាំងបីខាងលើ មានតែគណបក្សប្រជាធិបតេយ្យទេដែលទាញការគាំទ្រពីសំណាក់ប្រជារាស្ត្របានច្រើន។ ក្នុងខែកញ្ញា ឆ្នាំ១៩៤៦ ក្រោយពីគណបក្សនានាបានកើតឡើងភ្លាមនោះ គេបានរៀបចំការបោះឆ្នោតជ្រើសរើសសភាធម្មនុញ្ញ ដើម្បីបង្កើតក្រុមមួយ ដែលមាននាទីផ្តល់ការប្រឹក្សាដល់ ព្រះមហាក្សត្រ ក្នុងការបង្កើតរដ្ឋធម្ម នុញ្ញសម្រាប់ប្រទេសជាតិ។ អ្នកបោះឆ្នោតដែលទទួលសិទ្ធិថ្មីៗនោះចំនួន ៦០%បាននាំគ្នាទៅបោះឆ្នោត។ គណបក្សប្រជាធិបតេយ្យបានអាសនៈចំនួន៥០ ក្នុងចំណោមអាសនៈ៦៧។ គណបក្សសេរីភាពបានអាសនៈចំនួន១៤និងបេក្ខជនឯកច្ឆន្ទទទួលបាន៣អាសនៈ។ លទ្ធផលបានបង្ហាញពីប្រជាប្រិយភាពរបស់គណបក្សប្រជាធិបតេយ្យ ក្នុងចំណោមឥស្សរជនខ្មែរដែលមានឥទ្ធិពល និងវោហារស័ព្ទ ហើយដែលអាចប្រមូលផ្តុំសំឡេងឆ្នោតឱ្យគណបក្សបានច្រើន។ តាមការពិនិត្យលើលទ្ធផលឆ្នោតនៅក្នុងការបោះឆ្នោតជំនាន់នោះ មិនខុសពីការបោះឆ្នោតក្រោយៗមកទៀតប៉ុន្មានទេ ប្រជាកសិករភាគច្រើន បានទៅបោះឆ្នោតតាមតែការណែនាំរបស់មនុស្សដែលខ្លួនគោរពរាប់អាន។ ពួកប្រជាធិបតេយ្យមានមេខ្យល់ដែលភាគច្រើនជាមន្ត្រីតាមស្រុក ឃុំ គ្រូបង្រៀន និងព្រះសង្ឃជាដើម។

---

[271] វ៉ង់ សុធារ៉ា និងណុប សុខា, *ប្រវត្តិសាស្ត្រកម្ពុជា*, ជ.ឯ.ម., ទំព័រ២០៧។

[272] ដឹកនាំដោយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស។

[273] ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត ដែលនិយមបារាំង បានទទួលជំនួយថវិកាពីបារាំងដើម្បីប្រជែង និងទ្រង់ស៊ីសុវត្ថិ យុត្តិវង្ស។

[274] ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា មានគំនិតអភិរក្សនិយម។

[275] ដេវិឌ ឆាឌល័រ, *ប្រវត្តិសាស្ត្រខ្មែរ,* ជ.ឯ.ម., ទំព័រ១៩១។

សម្តេចព្រះ នរោត្តម សីហនុ ហាក់បីដូចជាមានព្រះទ័យព្រួយបារម្ភក្រៃលែងចំពោះជ័យជម្នះដ៏លើសលប់របស់ក្រុមប្រជាធិបតេយ្យ ដែលព្រះអង្គឈ្វេងយល់ថា គឺការប្រានព្រះអង្គចេញពីឆាកនយោបាយយ៉ាងពិតប្រាកដ ទោះបីព្រះអង្គពុំទាន់មានគណបក្សផ្ទាល់នៅឡើយក៏ដោយ។ ពួកអ្នកប្រជាធិបតេយ្យគិតថាពួកគេមានអាណត្តិសម្រាប់តាក់តែងរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា គឺពុំមានតួនាទីសម្រាប់តែផ្តល់យោបល់ថ្វាយព្រះមហាក្សត្រអំពី រដ្ឋធម្មនុញ្ញ តែប៉ុណ្ណោះនោះទេ។ រដ្ឋធម្មនុញ្ញដែលពួកប្រជាធិបតេយ្យបានព្រៀងឡើងនៅឆ្នាំ១៩៤៦ ដល់១៩៤៧ នោះបានកាត់បន្ថយអំណាចព្រះរាជា ដែលនេះហើយជាមូលហេតុធ្វើឱ្យសម្តេចព្រះនរោត្តម សីហនុ មិនសូវសព្វព្រះរាជហឫទ័យចំពោះអត្ថបទរដ្ឋធម្មនុញ្ញនេះទាំងស្រុងនោះទេ។

ទោះបីជាយ៉ាងណាក៏ដោយ គេបានបង្កើតអត្ថបទរដ្ឋធម្មនុញ្ញមួយ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧ ដោយព្រះមហាក្សត្រ។ នេះជារដ្ឋធម្មនុញ្ញខ្មែរដំបូងបង្អស់ដែលយកតាមគំរូស្ទើរតែទាំងស្រុង ពីរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋទី៤បារាំង ឆ្នាំ១៩៤៦។ ដោយហេតុដូចនោះហើយ ទើបរដ្ឋធម្មនុញ្ញនៅឆ្នាំនោះបង្កើតឱ្យមានសភាពីរដូចបារាំងដែរ គឺរដ្ឋសភាជាតិ ជ្រើសរើសឡើងដោយវិធីបោះឆ្នោតជាសកលចំពោះ សម្ងាត់ សេរី និងស្មើភាព ហើយមួយទៀតគឺក្រុមប្រឹក្សារាជាណាចក្រ (Council of Kingdom) ដែលមានសមាជិកជ្រើសតាំងឡើង, វិធីចាត់តាំងខ្លះ, វិធីបោះឆ្នោតអសកលខ្លះ, មានសមាជិកចាត់តាំងដោយព្រះមហាក្សត្រ និងមានចាត់តាំងដោយរដ្ឋសភាក្នុងចំណោមមនុស្សក្រៅរដ្ឋសភា[276]។ តាមរដ្ឋធម្មនុញ្ញថ្ងៃទី៦ខែឧសភា ឆ្នាំ១៩៤៧ របបនយោបាយខ្មែរជារបបសភានិយមគឺ រដ្ឋាភិបាលត្រូវតែមានសេចក្តីទុកចិត្តរបស់សភាដូច្នេះរដ្ឋាភិបាលត្រូវទទួលខុសត្រូវខាងនយោបាយចំពោះមុខសភា។ របបនយោបាយនេះអនុញ្ញាតឱ្យមានការសហការគ្នា និងទម្លាក់ ឬ រំលាយគ្នាទៅវិញទៅមកបានរវាងរដ្ឋសភា និងរដ្ឋាភិបាលតាមរយៈញត្តិបន្ទោស។

នៅឆ្នាំ១៩៥៤ កិច្ចព្រមព្រៀងក្រុងហ្សឺណែវ[277] បានធ្វើឡើងនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ ដែលសន្និសីទហ្សឺណែវឆ្នាំ១៩៥៤ បានទាក់ទងចំពោះកម្ពុជាដូចជា៖

- ក្រុមខ្មែរតស៊ូចូលមករួមក្នុងសហគមន៍ជាតិ ហើយមានសិទ្ធិជាអាទិ៍ឱ្យបានការធ្វើក្នុងក្រុមរាជការស៊ីវិល ឬ ទាហាន បោះឆ្នោត ឬ ធ្វើជាបេក្ខជនឱ្យគេបោះឱ្យ
- មិនឱ្យមានការសងសឹកទៅវិញទៅមក
- មានការបោះឆ្នោតបង្កើតរដ្ឋសភាឡើងវិញតាមរដ្ឋធម្មនុញ្ញ
- ប្រជាជាតិខ្មែរទាំងមូលបានទទួលសិទ្ធិ សេរីភាពដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ
- កងទ័ពបរទេសដកថយចេញ មិនមានមូលដ្ឋានទ័ពបរទេសនៅដែនដីខ្មែរតទៅ
- ប្រទេសខ្មែរស្ថិតនៅក្នុងឋានៈជាអព្យាក្រឹតភាព
- គោរពដល់ឯករាជ្យ, អធិបតេយ្យ, ឯកភាព និងបូរណភាពដែនដីកម្ពុជា ជាដើម។

សូមបញ្ជាក់ថាសន្និសីទក្រុងហ្សឺណែវ ដើម្បីស្តារបនាសន្តិភាពនៅឥណ្ឌូចិនឡើងវិញ ប្រព្រឹត្តទៅនៅប្រទេសស្វីស ចាប់ពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤។ ប៉ុន្តែ ដំណាក់កាលតំបូងគេបាន

[276] សេង ប៊ុនធឿន, *រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជា(ពីទសវត្សឆ្នាំ៤០រហូតដល់ឆ្នាំ២០១៥)*, ឆ្នាំ២០១៥, ទំព័រ៣៧។

[277] សន្និសីទនេះបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ ។

ពិភាក្សាពីបញ្ហារបស់ឧបទ្វីបកូរ៉េ។ រហូតមកដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៥៤ ទើបមានកិច្ចពិភាក្សាពីបញ្ហាឥណ្ឌូចិន។ ចំណែកថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ ជាថ្ងៃចុះហត្ថលេខានៃកិច្ចព្រមព្រៀង[278]។

## ២-ការបង្កើតចលនាសង្គមរាស្ត្រនិយម និងការបោះឆ្នោត

នៅឯសន្និសីទហ្សឺណែវ រដ្ឋាភិបាលនៃប្រទេសឡាវ និងកម្ពុជាបានប្ដេជ្ញាចិត្តថានឹងចាត់វិធានការទាំងឡាយដើម្បីធានាដល់ប្រជាពលរដ្ឋរបស់ខ្លួន អាចចូលរួមនៅក្នុងការបោះឆ្នោតដោយសេរី សម្ងាត់ និងយុត្តិធម៌នៅឆ្នាំ១៩៥៥ ដោយអនុលោមទៅតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសរៀងៗខ្លួន។ នៅប្រទេសកម្ពុជា ក្រោយពីឯករាជ្យឆ្នាំ១៩៥៣ សម្តេចព្រះ នរោត្តម សីហនុ បានធ្វើប្រជាមតិស្តីអំពីព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យរបស់ព្រះអង្គ។ ការធ្វើប្រជាមតិនេះដើម្បីផ្សព្វផ្សាយពង្រឹង និងពង្រីកឋានៈរបស់ព្រះអង្គជាបិតាឯករាជ្យ។ នីតិវិធីនៃការធ្វើប្រជាមតិនៅពេលនោះអ្នកណាពេញចិត្តត្រូវបោះក្រដាស-ស ដែលមានរូបព្រះឆាយលក្ខណ៍នៅលើក្រដាសនោះ ហើយអ្នកណាមិនពេញចិត្តត្រូវបោះក្រដាសខ្មៅ ដែលមានសរសេរអក្សរថាទេ[279]។ លទ្ធផលនៃការធ្វើប្រជាមតិនោះគឺមានសំឡេងគាំទ្រយ៉ាងច្រើន។ បន្ទាប់មក សម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គបានសម្រេចព្រះទ័យចូលប្រឡូកផ្ទាល់ក្នុងការបោះឆ្នោត។ ប្រសិនបើព្រះអង្គគង់នៅជាព្រះមហាក្សត្រសោយរាជ្យ ព្រះអង្គមិនអាចចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតបានឡើយ ព្រោះវាផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៤៧។ ហេតុនេះដើម្បីគេចផុតពីឧបសគ្គខាងផ្លូវច្បាប់ព្រះអង្គបានសម្រេចព្រះទ័យដាក់រាជ្យថ្វាយព្រះបិតាគឺព្រះបាទនរោត្តម សុរាម្រឹត នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៥[280] ហើយព្រះអង្គបាននៅក្រោមរាជបល្ល័ង្កវិញនេះដើម្បីបម្រើជាតិ និងរាស្ត្រហើយទ្រង់មិនប្រកាន់ខ្លួនទេក្នុងការបម្រើជាតិ រកប្រយោជន៍ជូនជាតិ[281]។ ដើម្បីចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ សម្តេចព្រះ នរោត្តម សីហនុ បានបង្កើតចលនាសង្គមរាស្ត្រនិយមនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ ១៩៥៥[282]ហើយសង្គមរាស្ត្រនិយមដែលទ្រង់បង្កើតឡើងនេះគឺតាមពាក្យសុំរបស់ប្រជានុរាស្ត្រច្រើនសែនដែលបានសុំឱ្យទ្រង់រកច្បាប់ថ្មី យុត្តិធម៌ជូន ដែលរងនូវការអយុត្តិធម៌បោកបញ្ឆោតរបស់ពួកគណបក្ស និងដើម្បីដឹកនាំរាស្ត្រទៅរកសេចក្ដីសុខចម្រើន អធិបតេយ្យដ៏ពិតប្រាកដតាមបំណងរបស់ប្រជាជាតិ[283]។ នៅក្នុងសេចក្តីថ្លែងការណ៍ជាច្រើនរបស់ សម្តេចព្រះនរោត្តម សីហនុ បានគូសបញ្ជាក់អំពីទិសដៅរបស់ចលនាសង្គមរាស្ត្រនិយមគឺ

- បដិសេធប្រព័ន្ធពហុបក្សដែលនាំឱ្យមានអស្ថិរភាពនយោបាយនៅក្នុងសង្គម
- ដើម្បីបង្រួបបង្រួមជាតិ
- ធ្វើឱ្យមានអារម្មណ៍ស្នេហាជាតិ និងមានភក្តីភាពចំពោះប្រពៃណីទំនៀមទម្លាប់
- តស៊ូប្រឆាំងនឹងអំពើអយុត្តិធម៌ និងអំពើពុករលួយ បក្សពួកនិយម
- ដើម្បីវឌ្ឍនភាពលទ្ធិប្រជាធិបតេយ្យសម្រាប់ប្រជាជន
- មាគ៌ាចម្បងដើម្បីទទួលបានទិសដៅនេះគឺភក្តីភាពចំពោះសាសនា និងព្រះមហាក្សត្រ។

---

[278] ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម.,ទំព័រ៤៣១។

[279] ដេវីឌ ឆាណ្ឌល័រ, *ប្រវត្តិសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំព័រ២០៦។

[280] ឯកសារខ្លះថា ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៥៥។ ប៉ុន្តែ យោងតាមស្នាព្រះហស្តសម្តេចព្រះ នរោត្តម សីហនុ ដាក់ថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៥។

[281] ព្រះរាជសាសន៍ សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៥៨។

[282] វ៉ាន់ ឌីកាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា*, ភាគ១, ដ.ឯ.ម., ទំព័រ១៤៦។

[283] ព្រះរាជសាររបស់សម្តេចព្រះនរោត្តម សីហនុឧបយុវរាជ ជូនជនរួមជាតិ, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៥ នៅរាជធានីភ្នំពេញ។

គណៈកម្មាធិការប្រតិបត្តិនៃសង្គមរាស្ត្រនិយម បានបញ្ជាក់ថាសង្គមរាស្ត្រនិយមមានលក្ខណៈខុសប្លែកគ្នាពីពួកម៉ាស៊ីស ឬ កុម្មុយនីស្ត។ សង្គមនិយមខ្មែរកើតចេញពីគោលការណ៍ព្រះពុទ្ធសាសនា ប្រៀនប្រដៅមនុស្សឱ្យចេះជួយសង្គ្រោះគ្នាទៅវិញទៅមក ជួយបំពេញកិច្ចការដល់សង្គម គោរពមនុស្សលោក ហើយមានគោលបំណងចង់ឱ្យកើតមានសុខុមាលភាព និងវឌ្ឍនភាពដល់បុគ្គលទាំងឡាយទូទៅ[284]។ ប៉ុន្តែ ទោះជាមានគោលការណ៍ និងការបញ្ជាក់ពីគណៈកម្មាធិការប្រតិបត្តិនៃចលនាសង្គមរាស្ត្រនិយមបែបនេះក៏ដោយ អ្នកដែលចូលជាសមាជិកសង្គមរាស្ត្រនិយមត្រូវចាកចេញពីគណបក្សនយោបាយផ្សេងទៀតនៅពេលនោះ លោក លន់ នល់, លោក ដាប ឈួន ជាដើមបានមកចូលរួមជាមួយចលនាសង្គមរាស្ត្រនិយមផងដែរ។ សង្គមរាស្ត្រនិយមចលនាគឺជាអង្គការដែលបានជះឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើសង្គម និងជីវភាពនយោបាយកម្ពុជា។ នៅក្នុងលក្ខន្តិកៈរបស់សង្គមដែលបានចុះផ្សាយនៅខែមីនា ឆ្នាំ១៩៥៥ បានគូសបញ្ជាក់ថាសង្គមរាស្ត្រនិយមមិនមែនជាគណបក្សនយោបាយទេ ប៉ុន្តែជាអង្គការបង្រួបបង្រួមជាតិ ដែលមានគោលបំណង និងកសាងរាជសង្គមនិយមព្រះពុទ្ធសាសនានៅកម្ពុជា[285]។ ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៥៩ រៀងរាល់ខែសង្គមរាស្ត្រនិយមបានទទួលពាក្យសុំចូលថ្មីៗជាច្រើន អំពីសមាជិកចាស់នៃគណៈបក្សប្រជាធិបតេយ្យ ដែលយល់ថាគេនឹងអាចបម្រើឧត្តមភាព ប្រយោជន៍ជាតិ បានយ៉ាងប្រសើរដោយរក្សាទុកនូវឧត្តមគតិរបស់គេក្នុងផ្ទៃនៃសង្គម ហើយគណបក្សប្រជាធិបតេយ្យបានបរាជ័យនេះគឺបណ្តាលមកពីការបែកបាក់សាមគ្គីផ្ទៃក្នុងបក្ស[286]។

ដើម្បីធ្វើឱ្យចលនាសង្គមរាស្ត្រនិយម កាន់តែមានលក្ខណៈរឹងមាំ និងមានឈ្មោះបោះសំឡេងកាន់តែខ្លាំងថែមទៀតនោះ នៅក្នុងសមាជជាតិលើកទី២៣ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១០ ដល់ទី១៣ ខែកញ្ញា ឆ្នាំ១៩៦៧ អង្គសមាជបានសំណូមពរឱ្យមានច្បាប់ស្តីពីការរំឭកថ្ងៃកំណើតនៃចលនាសង្គមរាស្ត្រនិយម។ ដើម្បីបំពេញតាមសំណូមពររបស់អង្គសមាជជាតិ រដ្ឋសភាបានអនុម័តនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៦៨ នូវច្បាប់ស្តីពីការប្រកាសបុណ្យជាតិ សម្រាប់រំឭកថ្ងៃកំណើតនៃចលនាសង្គមរាស្ត្រនិយម។ ក្រោយពីរដ្ឋសភាបាន អនុម័តរួចហើយ គេបានចេញព្រះរាជក្រមចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៦៨ ប្រកាសឱ្យប្រើច្បាប់ស្តីពី បុណ្យជាតិសម្រាប់រំឭកថ្ងៃកំណើតនៃចលនាសង្គមរាស្ត្រនិយម។ ព្រះរាជក្រមនេះមានមាត្រាតែមួយ ហើយបានចែងថាបុណ្យជាតិសម្រាប់រំឭកថ្ងៃខួបកំណើតនៃចលនាសង្គមរាស្ត្រនិយម ត្រូវបានប្រកាសជាបុណ្យពេញលក្ខណៈច្បាប់។ បុណ្យនេះត្រូវបានធ្វើឡើងរៀងរាល់ឆ្នាំ នៅថ្ងៃទី២៤ ខែមីនា ដែលជាថ្ងៃប្រកាសឱ្យប្រើលក្ខន្តិកៈនៃចលនាសង្គមរាស្ត្រនិយម[287]។ សង្គមរាស្ត្រនិយមបានជួយបង្រួមគណបក្សនយោបាយពី១១គណបក្ស មកនៅត្រឹម៣ គណបក្សហើយក្នុងចំណោមនោះមានគណបក្សមួយដែលទើបនឹងបង្កើតឡើងក្រោយសន្និសីទក្រុងហ្សឺណែវគឺគណបក្សកុម្មុយនីស្ត ឬ គណបក្សប្រជាជន។ ចំណែកសមាជិកគណបក្ស ប្រជាធិបតេយ្យជាច្រើនរូបបានមកចូលរួមជាមួយនឹងចលនាសង្គមរាស្ត្រនិយម កែរដ្ឋធម្មនុញ្ញដើម្បីឱ្យប្រជារាស្ត្រមានសេចក្តីទុកចិត្តលើការគ្រប់គ្រងដោយមានរដ្ឋសភា[288]។ ទាក់ទងទៅនឹងការកែសម្រួលរដ្ឋធម្មនុញ្ញនេះ សម្តេចព្រះនរោត្តម សីហនុបានប្រកាសឱ្យដឹងថា៖

---

[284] នយោបាយសេដ្ឋកិច្ចនៃសង្គមរាស្ត្រនិយ, ឆ្នាំ? ទំព័រ២។

[285] មីហោយេវ, *ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា,* ជ.ឯ.ម., ទំព័រ៣៤៤។

[286] ព្រះរាជសន្និសីទនយោបាយនៃសម្តេចព្រះឧបយុវរាជព្រះបិតា ឯករាជ្យជាតិនៅបាត់ដំបងកាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៥៩។

[287] រាជកិច្ចលេខ៦៣ ចេញផ្សាយថ្ងៃទី១៧ សីហា ឆ្នាំ១៩៦៨ ។

[288] ទស្សនាវដ្តី នៃយុជន លេខ១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥៧ ទំព័រ៣០។

- ការដែលមានគណបក្សច្រើនធ្វើឱ្យប្រជាជនមានការភ័ន្តច្រឡំផ្នែកគំនិត
- ការបោះឆ្នោតតាមរបៀបសព្វថ្ងៃ(មុនឆ្នាំ១៩៥៥)នាំឱ្យគណបក្សបង់ខាតសោហ៊ុយ ជាច្រើន ដែលជាហេតុនាំឱ្យគណបក្សទាំងនោះ ទៅពឹងពាក់អ្នកមានធនជានទុច្ចរិត ហើយបន្ទាប់ពីការបោះឆ្នោត គេតែតែសងបំណុលព្រមទាំងឱ្យការប្រាក់យ៉ាងធ្ងន់ទៀតផង។ នេះហើយជាមូលហេតុជំរុញឱ្យរដ្ឋមន្ត្រី តំណាងរាស្ត្រ អ្នកជំនួញ និងអ្នករាជការដែលនិយមគណបក្សនយោបាយនោះ ឱ្យរិះរកមធ្យោបាយមិនស្របច្បាប់ និងផ្ទុយអំពីប្រយោជន៍របស់ប្រជាជាតិ។
- តំណាងរាស្ត្រ ដែលកើតឡើងពីរបៀបគ្រប់គ្រងប្រជាធិបតេយ្យនៅពេលមុននេះ បានបំភ័ន្តសេចក្តីទុកចិត្តរបស់ប្រជារាស្ត្រ ភ្លេចពាក្យសន្យានៅពេលមុននឹងក្លាយជាតំណាងរាស្ត្រ ឬ មិនបានបញ្ចេញមតិរបស់ប្រជារាស្ត្រឱ្យទៀងទាត់ ដោយគិតតែពីប្រយោជន៍នៃគណបក្សរបស់ខ្លួន និងតាមសេចក្តីបង្គាប់របស់គណៈកម្មាធិការនាយករបស់គណបក្ស ដែលពុំមានសមាជិកចេញពីសង្គមរាស្ត្រនិយម។
- មានតំណាងរាស្ត្រជាច្រើន ឥតធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងរាស្ត្រឡើយគេតាំងខ្លួនគេធំជាងប្រជារាស្ត្រ។ ការខ្វះការប្រាស្រ័យទាក់ទងទាំងនេះនាំឱ្យតំណាងរាស្ត្រពុំស្គាល់មណ្ឌលបោះឆ្នោតរបស់ខ្លួន ដែលជាហេតុនាំឱ្យមិនស្គាល់ច្បាស់ចំពោះមនោសញ្ចេតនា ឧត្តមគតិ និងសេចក្តីត្រូវការពិតរបស់ប្រជារាស្ត្រ។
- ប្រជារាស្ត្រ បានត្អូញត្អែរអំពីការស៊ីសំណូកដែលមានកាន់តែច្រើនឡើងៗ និងអ្នករាជការមិនបានបំពេញការងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ។
- ប្រជារាស្ត្រ បានត្អូញត្អែរអំពីការផ្លាស់ប្តូររដ្ឋាភិបាលញឹកញយបន្ទាប់ពីមានការបង្កើតគណបក្សនយោបាយច្រើនមក។
- ប្រជារាស្ត្រសុំកុំឱ្យព្រះមហាក្សត្រ ប្រគល់ការគ្រប់គ្រងប្រទេសទៅឱ្យក្រុមគណបក្សតទៅទៀត ព្រោះប្រជារាស្ត្រមានទំនុកចិត្តតែចំពោះអង្គព្រះមហាក្សត្រមួយប៉ុណ្ណោះ ដែលជាតំណាងខ្លួនយ៉ាងពេញចិត្តឥតខ្ចោះ[289]។

ស្ថានភាពនៅក្នុងប្រទេសកម្ពុជានាពេលនោះ ក្រុមគណបក្សប្រជាធិបតេយ្យ[290] បានចុះទន់ខ្សោយដោយសារជម្លោះផ្ទៃក្នុងរបស់បក្ស និងដោយសារការបាត់បង់អំណាចរបស់ខ្លួនអស់រយៈពេលជិត៣ឆ្នាំកន្លងមក។ អ្នកប្រជាធិបតេយ្យវ័យក្មេងៗជាច្រើន បានប្រឆាំងនឹងគោលនយោបាយគាំទ្រសហរដ្ឋអាម៉េរិក ដែលសម្តេចព្រះ នរោត្តម សីហនុ បានអនុវត្តតាំងពីការបញ្ចប់សន្និសីទហ្សឺណែវមកនោះបានអះអាងថា ប្រទេសកម្ពុជាគួរតែប្រកាន់យកនយោបាយអព្យាក្រឹត។

[289] រាជវិចារណ៍ដើម្បីសម្រួលរដ្ឋធម្មនុញ្ញដែលព្រះមហាក្សត្រិយ៍ បានប្រោសព្រះទានដល់ប្រជារាស្ត្រព្រះអង្គក្នុងឆ្នាំ១៩៤៧ ទំព័រ៣។

[290] គណបក្សប្រជាធិបតេយ្យ ត្រូវបានបង្កើតឡើងដោយលោកស៊ីម វ៉ា និងលោក សឺន សាន (សូមអាន: ហ្វ្រង់ស្វ័រ ប៉ុងសូដ៏, *ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា*, ភ្នំពេញ, ឆ្នាំ២០០៧, ទំព័រ៥៤)។ បន្ទាប់ពីបានវិលត្រឡប់មកពីប្រទេសបារាំងវិញនាខែមិថុនា ឆ្នាំ១៩៤៦ ព្រះអង្គស៊ីសុវត្ថិ យុត្តិវង្ស (ព្រះអង្គប្រសូត្រនៅឆ្នាំ១៩១៣ នៅរាជធានីឧដុង្គ។ ព្រះបិតានាមអង្គអេង ចម្រើនវង្ស និងមាតានាមស៊ីសុវត្ថិ យុត្តិផាន ដែលឯកសារខ្លះថា ស៊ីសុវត្ថិ យូភិផាន់។ ព្រះអង្គទទួលសញ្ញាបត្របណ្ឌិតគណិតវិទ្យាមកពីប្រទេសបារាំង។ ព្រះអង្គចុលទិវង្គតនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៤៧ ដោយជំងឺស្ងួត) ត្រូវបានជ្រើសរើសឱ្យធ្វើជាប្រធានគណបក្សប្រជាធិបតេយ្យ។

ក្រុមប្រជាធិបតេយ្យនេះ ហាក់មានគំនិតស្របនឹងគំនិតរបស់ក្រុមកុម្មុយនីស្តកម្ពុជាដែលមានឈ្មោះថាក្រុមប្រជាជន។ ក្នុងលក្ខន្តិកៈ របស់ក្រុមប្រជាជនបានគូសបញ្ជាក់ថា គោលដៅដ៏ចម្បងរបស់គេស្ថិតនៅលើការបង្រួមប្រជាជនខ្មែរទូទៅ មកក្នុងសង្គមជាតិដោយគ្មានការប្រកាន់ពូជសាសន៍ និងជំនឿសាសនា[291]។

នៅឆ្នាំ១៩៥៤ ពួកអ្នកប្រជាធិបតេយ្យក្មេងៗបានបង្វែរទិសដៅគណបក្សរបស់ខ្លួនទៅរកនិន្នាការឆ្វេងនិយម ដោយគេបានដកចេញនូវមនុស្សដែលមានភាពស្មោះត្រង់ចំពោះគណបក្សប្រជាធិបតេយ្យកាលពីមុនមានដូចជាលោក ស៊ឹម វ៉ា និងលោក សឺន សាន ជាដើម ហើយដាក់បញ្ចូលមនុស្សអព្យាក្រឹត ដែលប្រឆាំងនឹងរាជានិយមមកវិញដូចជាលោកកេង វ៉ាន់សាក់ លោក ស្វាយ សូ ព្រមទាំងឥស្សរជនខ្លះដូចជាលោក ជួន មុម្ម ដែលលោកជាសមាជិកបក្សកុម្មុយនីស្តបារាំងនាពេលនោះ។ នៅក្នុងការបោះឆ្នោតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥[292] មានគណបក្សដែលបានចូលរួមគឺ សង្គមរាស្ត្រនិយមដែលមានរូបសញ្ញាព្រះឆាយាលក្ខណ៍ សម្តេច សីហនុ[293] គណបក្សប្រជាធិបតេយ្យ មានរូបសញ្ញាក្បាលដំរី គណបក្សសេរី[294]មានរូបសញ្ញាអង្គរវត្ត គណបក្សប្រជាជនមានរូបសញ្ញានង្គ័ល គណបក្សតម្កើងជាតិមានរូបសញ្ញាហនុមានគណបក្សខ្មែរឯករាជ្យ គណបក្សពលករខ្មែរ និងគណបក្សឯករាជ្យ។ ព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត ប្រធានគណបក្សសេរី បន្ទាប់ពីបានទទួលតំណែងជាអ្នកការទូតកម្ពុជាប្រចាំក្រុងប៉ារីស ភ្លាមព្រះអង្គបានទុកគណបក្សនេះឱ្យស្ថិតនៅក្នុងភាពច្របូកច្របល់។

លទ្ធផលនៃការបោះឆ្នោតនេះ គឺចលនាសង្គមរាស្ត្រនិយមទទួលបានសន្លឹកឆ្នោតចំនួន ៦៣០ ៦២៥ សន្លឹកស្មើនឹង៨៣% នៃសន្លឹកឆ្នោតសរុប ហើយទទួលបានអាសនៈនៅក្នុងរដ្ឋសភាចំនួន៩១។ គណបក្សប្រជាធិបតេយ្យទទួលបានសន្លឹកឆ្នោតចំនួន៩៣ ៩១៩ សន្លឹក ស្មើនឹង១២% គណបក្សប្រជាជនទទួលបានសន្លឹកឆ្នោតចំនួន២៩ ៥០៨សន្លឹក ស្មើនឹង៤%។ ចំពោះគណបក្សផ្សេងទៀតបានទទួលសន្លឹកឆ្នោតមានដូចជាគណបក្សសេរីភាពទទួលបាន ៥ ៤៨៨ សំឡេង, គណបក្សចម្រើនជាតិ[295]ទទួលបាន ១ ១៥៤ សំឡេង, គណបក្សខ្មែរឯករាជ្យទទួលបាន ៧៩៤ សំឡេង, គណបក្សពលករខ្មែរទទួលបាន ២៨៩ សំឡេង និងគណបក្សឯករាជ្យទទួលបាន ១៨៦ សំឡេង។ គណបក្សទាំងអស់នេះ មិនមានអត្ថិភាពទៀតឡើយ[296]។ ការឃោសនាបោះឆ្នោតនៅ ពេលនោះ គណបក្សប្រជាធិបតេយ្យបានជួបការលំបាកក្នុងការឃោសនា ព្រោះនៅពេលឡើងនិយាយម្តងៗ គេតែងតែជួបប្រទះនឹងមនុស្សមកឡូឡាជាពាក្យជៀមជាម ព្រមទាំងមានគេវាយប៉ោតក្ទុងក្តាំងរំខានដល់ការឃោសនា[297]។ តែទោះជាយ៉ាងនេះក្តី ការបោះឆ្នោតនោះយើងទទួលបានបទពិសោធន៍ដ៏

---

[291] មីហេយេរ, *ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា*, ដ.ឯ.ម., ទំព័រ៣៤៤។

[292] យុទ្ធនាការឃោសនាបោះឆ្នោតក៏មានលក្ខណៈខុសពីធម្មតាទៀត ដោយហេតុថាគណបក្សនានាពុំសូវនិយាយឱ្យបានច្បាស់អំពីកម្មវិធីនយោបាយរបស់ខ្លួនទេ។

[293] គណបក្សនេះ ផ្អែកការឃោសនារបស់គេ ជាពិសេសទៅលើការទាមទារឯករាជ្យរបស់អតីតព្រះមហាក្សត្រខ្មែរ។

[294] គណបក្សនេះដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត មានទស្សន និងជំហរជាអ្នកអភិរក្សនិយម ហើយមានគោលការណ៍ផ្ទុយពីគណបក្សប្រជាធិបតេយ្យ។ ប្រធានបក្សនេះបានមានទស្សនថា ក្នុងនយោបាយខ្មែរគួរតែមានការអប់រំប្រជារាស្ត្រ ហើយកម្ពុជាគួរពឹងផ្អែកលើប្រទេសបារាំងតទៅទៀត។ គណបក្សនេះមានការឧបត្ថម្ភថវិកាដោយលួចលាក់ពីបារាំង ដែលគេមានការភ័យខ្លាចចំពោះប្រជាប្រិយភាពរបស់គណបក្សប្រជាធិបតេយ្យ។

[295] ឈ្មោះគណបក្សនេះបើតាមឯកសារខ្លះសរសេរថា គណបក្សចម្រើនជឿនលឿន។ គណបក្សនេះដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា។ បើតាមសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោក ដេវិឌឆាណ្ឌលែរ ទំព័រ១៩១ បានបញ្ជាក់ថាគណបក្សចម្រើនជាតិប្រហែលជាមានការគាំទ្រខ្លះៗពីព្រះមហាក្សត្រ។

[296] Charles Meyer, *ក្រោយស្នាមញញឹមរបស់ខ្មែរ(Meyer, C. (1971). Derrière le sourire khmer)*, ប្រែសម្រួលដោយ ទី ឃាយុ, ឆ្នាំ( ? ), ទំព័រ១១០។

[297] ប៊ុន ថាន, *រំលឹកប្រវត្តិអ្នកតស៊ូខ្មែរ*, ប៉ារីស, ខែធ្នូ ឆ្នាំ១៩៩៥, ទំព័រ១៦។

សំខាន់ គឺនៅចុងបញ្ចប់ប្រទេសកម្ពុជាបានប្រកាន់យកនយោបាយឯករាជ្យអព្យាក្រឹត ព្រោះនៅពេលនោះគណបក្សប្រជាធិបតេយ្យបានរួបរួមជាមួយនឹងក្រុមប្រជាជនក្នុងការទាមទារឱ្យកម្ពុជា ដើរតាមនយោបាយអព្យាក្រឹត ហើយអ្នកទាំងពីរក្រុមនេះបានលើកយកបញ្ហានេះមកឃោសនាឱកាសបោះឆ្នោតឆ្នាំ១៩៥៥។ នៅឆ្នាំ១៩៥៣ សម្ដេច ព្រះនរោត្តម សីហនុ ទ្រង់ឈ្វេងយល់ថាដើម្បីជាផលប្រយោជន៍វែងឆ្ងាយនៃរាជបល្ល័ង្កមានតែព្រះអង្គដកព្រះកាយចេញឱ្យឆ្ងាយពីអាណាព្យាបាលបារាំង។ លុះមកដល់ឆ្នាំ១៩៥៥ព្រះអង្គក៏ឈ្វេងយល់ទៀតថាផ្លូវដែលជានាព្រះអង្គឈ្នះឆ្នោត ហើយជានាអនាគតនយោបាយវែងឆ្ងាយមានតែព្រះអង្គជ្រើសរើសយកនយោបាយអព្យាក្រឹត និងមិនចូលបក្សសម្ពន្ធ។ ដូច្នេះ ទើបកម្ពុជាបានរកឃើញនូវមាគ៌ាសន្តិភាព និងអធិបតេយ្យភាពរបស់ខ្លួនព្រមទាំងបានពុះពារថែរក្សានយោបាយអព្យាក្រឹតនេះ។ ក៏ប៉ុន្តែ មានមតិមួយចំនួនធំមិនសូវទុកចិត្តព្រះអង្គឡើយ ដោយគេយល់ឃើញថាជាលំដាប់លំដោយពីមុនមកព្រះអង្គធ្លាប់តែពឹងផ្អែកលើកម្លាំងបារាំង។ នៅគ្រាដែលប្រទេសបារាំងដកចេញទៅព្រះអង្គក៏បានពឹងផ្អែកលើសហរដ្ឋអាម៉េរិក។ នៅខែសីហា ឆ្នាំ១៩៥៤ ពេលគឺក្រោយសន្និសីទក្រុងហ្សឺណែវមួយខែ ព្រះអង្គបានទទួលអ្នកជំនាញការយោធា សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងវប្បធម៌ជាច្រើនដែលសហរដ្ឋអាម៉េរិក បានបញ្ជូនមក។ បញ្ហានេះសម្រាប់មតិជាតិ គេមើលឃើញថាព្រះអង្គធ្វើដូច្នេះមានហេតុផលពីរសំខាន់គឺ ដើម្បីទទួលបានជំនួយយោធាពីសហរដ្ឋអាម៉េរិក និងដើម្បីជាកាយវិការបញ្ជាក់ប្រាប់សហរដ្ឋអាម៉េរិក ថាពិតមែនតែប្រទេសកម្ពុជាមិនអាចចូលជាសមាជិករបស់សេអាតូជាចំហតែព្រះអង្គនៅតែជាកម្លាំងមួយ ទប់ទល់នឹងកុម្មុយនីស្តជាដដែល។ ប៉ុន្តែនៅពេលនោះ លោក ហ្វូស្ទ័រ ឌុលឡេស ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់សហរដ្ឋអាម៉េរិក បាននិយាយថា នយោបាយអព្យាក្រឹតគឺ*អសីលធម៌* មានន័យថាបើអ្នកមិននៅជាមួយយើងមានតែអ្នកប្រឆាំងនឹងយើង។

ក្រោយការបោះឆ្នោតឆ្នាំ១៩៥៥-១៩៥៨ គណបក្សប្រឆាំងនឹងសង្គមរាស្ត្រនិយមបានប្រកាសថា ការបោះឆ្នោតសកលនេះ បានប្រព្រឹត្តទៅដោយប្រើឧបាយកលបោកបញ្ឆោតថា សង្គមដែលមានជ័យជម្នះក្នុងការបោះឆ្នោតនោះ ដោយសារតែការសង្កត់សង្កិន និងការគំរាម ដែលចៅហ្វាយខេត្តទាំងឡាយ កងទ័ព និងប៉ូលិសបានប្រព្រឹត្តលើប្រជារាស្ត្រ។ ម្យ៉ាងទៀតមានការប្រព្រឹត្តមិនត្រឹមត្រូវយ៉ាងសន្ធឹកសន្ធាប់ក្នុងការិយាល័យបោះឆ្នោត។ ក្រុមនេះក៏បានពោលថាគណៈកម្មការអន្តរជាតិខាងត្រួតត្រាដែលបានពិនិត្យយ៉ាងដាក់លាក់ នូវភាពត្រឹមត្រូវយ៉ាងពេញលេញក្នុងការបោះឆ្នោតនោះ បានបណ្ដោយឱ្យគេបំពានលើខ្លួន។ ប៉ុន្តែចំពោះការចោទប្រកាន់នេះដែរសម្ដេចព្រះ នរោត្តម សីហនុ បានមានព្រះរាជបន្ទូលថា៖ «*សេចក្ដីឆ្លើយចំពោះការចោទប្រកាន់នេះ គឺស្រេចនៅលើប្រជារាស្ត្រយើងនេះឯង ដែលតែងតែមាន សេចក្ដីទុកចិត្តអស់ពីពោះ ដោយមានសេចក្ដីពិចារណាផងចំពោះមកលើរូបខ្ញុំ។ អ្នកសង្កេតការអាម៉េរិកកាំងនេះឯង ព្រមទាំងសារព័ត៌មានរបស់គេដែលធ្លាប់តែមិនជឿដល់ការទាក់ទងលើរូបខ្ញុំនោះ ក៏បានទទួលសារភាពថាគេពុំអាចយល់ទាស់នឹងប្រជាមានិតរបស់ខ្ញុំ នៅជិតប្រជារាស្ត្រយើងនេះសោះឡើយ*»[298]។

ការបោះឆ្នោតរដ្ឋសភាចាប់ពីឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៦៦ បង្ហាញពីការផ្លាស់ប្ដូរយ៉ាងច្បាស់លាស់នៃអំណាចនយោបាយ ដោយមានការបែងចែកជាពីរដំណាក់កាលនៃការគ្រប់គ្រងដោយគណបក្សផ្សេងគ្នា។

[298] ព្រះរាជសន្និសីទនយោបាយនៃសម្ដេចព្រះឧបយុវរាជព្រះរាជបិតា ឯករាជ្យជាតិ នៅបាត់ដំបងកាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៥៩។

**ដំណាក់កាលទី១** : ការគ្រប់គ្រងដោយគណបក្សប្រជាធិបតេយ្យ (១៩៤៦-១៩៥១) នៅក្នុងអំឡុងពេលនេះ គណបក្សប្រជាធិបតេយ្យ គឺជាកម្លាំងនយោបាយដ៏លេចធ្លោ។ ក្នុងចំណោមការបោះឆ្នោតទាំងបីលើក ដែលគណបក្សនេះបានរក្សាបាននូវអាសនៈភាគច្រើនដាច់ខាតៈ

- ឆ្នាំ១៩៤៦ : គណបក្សប្រជាធិបតេយ្យឈ្នះ ៥០អាសនៈ ក្នុងចំណោម ៦៧អាសនៈ។
- ឆ្នាំ១៩៤៧ : គណបក្សប្រជាធិបតេយ្យឈ្នះ ៥៤អាសនៈ ក្នុងចំណោម ៧៥អាសនៈ។
- ឆ្នាំ១៩៥១ : គណបក្សនេះនៅតែឈ្នះ ៥៤អាសនៈ ក្នុងចំណោម ៧៨អាសនៈសរុប។

**ដំណាក់កាលទី២** : ការគ្របដណ្តប់របស់ចលនាសង្គមរាស្ត្រនិយម(១៩៥៥-១៩៦៦) អំណាចនយោបាយបានផ្លាស់ប្តូរទាំងស្រុងទៅលើចលនាសង្គមរាស្ត្រនិយម។ នៅក្នុងការបោះឆ្នោតនារយៈពេលនេះ ចលនានេះបានឈ្នះទាំងស្រុងៈ

- ឆ្នាំ១៩៥៥ : ចលនាសង្គមរាស្ត្រនិយមបានឈ្នះ៩១អាសនៈ ក្នុងចំណោម៩១អាសនៈ ដោយបក្សប្រឆាំងទាំងអស់រួមទាំងគណបក្សប្រជាធិបតេយ្យផងមិនទទួលបានអាសនៈឡើយ។
- ឆ្នាំ១៩៥៨ និង ១៩៦៦: ចលនាសង្គមរាស្ត្រនិយមនៅតែបន្តឈ្នះអាសនៈទាំងអស់(៦១/៦១អាសនៈក្នុងឆ្នាំ១៩៥៨ និង៨២/៨២ អាសនៈក្នុងឆ្នាំ១៩៦៦)។

សរុបមក ការបោះឆ្នោតបានបង្ហាញពីការផ្លាស់ប្តូរពីការប្រកួតប្រជែងគ្នារវាងគណបក្សទៅជាប្រព័ន្ធនយោបាយឯកបក្សក្រោមការគ្រប់គ្រងរបស់ចលនាសង្គមរាស្ត្រនិយមចាប់ពីឆ្នាំ១៩៥៥។

## ៣-សភាប្រជារាស្ត្រប្រចាំខេត្ត និងរាជធានី

ស្ថាប័នសភាប្រជារាស្ត្រប្រចាំខេត្ត និងរាជធានី តំណាងឱ្យមហិច្ឆតានៃការអនុវត្តវិមជ្ឈការ និងការពង្រីកលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជាដោយមានឫសគល់តាំងពីឆ្នាំ១៩៤៧ តាមរយៈរាជវិចារណ៍របស់ព្រះមហាក្សត្រ ដែលបានប្រគល់អំណាចថ្មីមួយបន្ថែមទៀតដល់ប្រជារាស្ត្រ និងអ្នកតំណាងរាស្ត្រ ក្នុងការត្រួតត្រាគ្រប់គ្រងកិច្ចការរដ្ឋបាលតាមខេត្តគ្រប់ជាន់គ្រប់ថ្នាក់។ យោងតាមគំនិតដំបូង ការតំណាងប្រជារាស្ត្រត្រូវបានរៀបចំជាពីរជាន់ ដោយសភាខេត្តជាជាន់ទី១ ដែលមានតំណាងគ្រប់ឃុំជាសមាជិក ប៉ុន្តែស្ថានភាពពិតមុនឆ្នាំ១៩៥៥ គឺមានត្រឹមរដ្ឋសភានៅរាជធានីភ្នំពេញតែមួយគត់ រហូតដល់ឆ្នាំ១៩៥៦ទើបគោលការណ៍នៃការបង្កើតសភាខេត្ត ត្រូវបានបញ្ចូលជាផ្លូវការនៅក្នុងរដ្ឋធម្មនុញ្ញនាជំពូកទី៧ បន្ទាប់ពីមានការពិភាក្សានៅសមាជជាតិលើកទី២នៅឆ្នាំ១៩៥៥ ដោយចែងថាត្រូវបង្កើតសភាប្រជារាស្ត្រមួយនៅគ្រប់ទីប្រជុំខេត្ត ឬតំណាងសង្កាត់ក្នុងរាជធានី។ សមាជិកនៃសភានេះ ដែលមានអាណត្តិ២ឆ្នាំ ត្រូវបានជ្រើសរើសតាមការបោះឆ្នោតដោយសកលពីពលរដ្ឋអាយុ២០ឆ្នាំឡើង និងបេក្ខជនត្រូវមានអាយុ២៥ឆ្នាំឡើង។ ពួកគេតម្រូវឱ្យបំពេញលក្ខណៈសម្បត្តិ និងមានអភ័យឯកសិទ្ធិដូចតំណាងរាស្ត្ររដ្ឋសភាដែរ តែទទួលបានប្រាក់បំណាច់តិចជាង ព្រមទាំងតម្រូវឱ្យបង់ប្រាក់ធានាចំនួន៣០០រៀលនៅក្រសួងមហាផ្ទៃ ដែលត្រូវរក្សាទុកជាសម្បត្តិរដ្ឋ ប្រសិនបើបេក្ខជននោះពុំទទួលបានសន្លឹកឆ្នោតគ្រប់មួយភាគបួននៃចំនួនសន្លឹកឆ្នោតដែលបានបោះ។ ក្នុងន័យភារកិច្ច សភាខេត្តមានអំណាចអនុម័តលើថវិកាខេត្ត រាជធានី និងថវិកាឃុំ៤០៤ ព្រមទាំងបញ្ជីស្រង់ប្រាក់ចំណូលចំណាយផ្តាច់ឆ្នាំនៃសមូហភាពទាំងនេះ សម្រេចលើការបង្កើត ឬការលុបពន្ធអាករសម្រាប់ដែនចំណុះរបស់ខ្លួន បញ្ហាបែបបទ អាករពន្ធដារ និងគុណប្រយោជន៍ផ្សេងៗដល់បណ្តាជនក្នុងខេត្ត ព្រមទាំងមានសិទ្ធិដេញដោលអ្នករាជការនានា និងតាមពិនិត្យមើលលើកិច្ចការកាន់កាប់របស់ចៅហ្វាយខេត្ត ចៅហ្វាយស្រុក និងអ្នករាជការទាំងអស់។ លើសពីនេះ សភាមានភារៈជូនយោបល់ទៅរដ្ឋសភាលើថវិកាជាតិ

បញ្ជីចំណូលចំណាយផ្តាច់ឆ្នាំ និងសេចក្តីព្រាងកិច្ចចងការប្រាក់របស់រដ្ឋាភិបាលក្នុងរយៈពេលកំណត់មួយខែយ៉ាងយូរ។ ទោះជាយ៉ាងណាក៏ដោយ យន្តការវិមជ្ឈការនេះមិនអាចរក្សានិរន្តរភាពបានឡើយ ហើយត្រូវបានផ្អាកបណ្តោះអាសន្នដោយពុំមានពេលកំណត់ តាមរយៈប្រជាមតិចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩ និងតាមច្បាប់ដែលអនុម័តដោយរដ្ឋសភាទី៥ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៦៤ បើទោះជាគណៈកម្មការរដ្ឋធម្មនុញ្ញ តុលាការ និងនីតិកម្ម ធ្លាប់បានបដិសេធមិនឱ្យផ្អាកដោយសំអាងថាការសម្រេចនេះផ្ទុយនឹងមាត្រា១១៥ នៃរដ្ឋធម្មនុញ្ញក៏ដោយ។ ការបញ្ចប់សភានេះត្រូវបានគេសន្និដ្ឋានថាបណ្តាលមកពីកត្តាជាច្រើនរួមមាន ដំណើរការមិនទៀងទាត់ ខ្វះសមត្ថភាព និងមានប្រាក់បៀវត្សរ៍ទាប ការខ្វះភាពចាស់ទុំផ្នែកនយោបាយ និងការអប់រំរបស់ប្រជាកសិករដែលត្រូវបានតែងតាំងឱ្យចូលសភា ព្រមទាំងការប៉ះទង្គិចជាមួយការចាត់ចែងផ្ទៃក្នុងរបស់អភិបាលខេត្ត និងការប្រកែករបស់មន្ត្រីជាន់ខ្ពស់ និងបុគ្គលិករាជការដែលមិនព្រមឱ្យសភាត្រួតពិនិត្យ[299]។

### ៤-សមាជជាតិ

សមាជជាតិ[300] ត្រូវបានបង្កើតឡើងក្រោយការបង្កើតសង្គមរាស្ត្រនិយម ហើយសមាជជាតិត្រូវបានធ្វើឡើងជាលើកដំបូងនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៥។ នៅក្នុងរដ្ឋធម្មនុញ្ញដំបូងរបស់ប្រទេសកម្ពុជា ឆ្នាំ១៩៤៧ មិនមានចែងអំពីសមាជជាតិនេះទេ។ សមាជជាតិបានដំណើរការដំបូងគឺមិនមានចែងនៅក្នុង រដ្ឋធម្មនុញ្ញទេ រហូតមកដល់ឆ្នាំ១៩៥៨ ដើម្បីធ្វើឱ្យវេទិកានេះមានលក្ខណៈពេញច្បាប់នៃប្រទេសកម្ពុជា គេបានដាក់បញ្ចូលសមាជជាតិទៅក្នុងរដ្ឋធម្មនុញ្ញតាមព្រះរាជក្រមលេខ ២៤២ន.ស ចុះថ្ងៃទី៨ ខែមករា ឆ្នាំ១៩៥៨[301]។ សមាជជាតិនេះត្រូវបានធ្វើឡើង ២ដងក្នុងមួយឆ្នាំ ដើម្បីពិភាក្សាទៅលើបញ្ហាសំខាន់ៗ ដែលទាក់ទងទៅនឹងនយោបាយក្នុង និងក្រៅប្រទេស ហើយសមាជជាតិនេះមានតួនាទីសំខាន់នៅក្នុងវិស័យនយោបាយរបស់ប្រទេសកម្ពុជា។ គណៈកម្មាធិការកណ្តាលសង្គមរាស្ត្រនិយមនឹងរៀបចំសមាជជាតិ ហើយត្រូវដឹកនាំដោយសម្តេចព្រះនរោត្តម សីហនុផ្ទាល់ព្រះអង្គ។ នៅក្នុងសមាជជាតិលើកទី២ ដែលប្រព្រឹត្តទៅ នៅថ្ងៃទី២៥-២៦ ខែកញ្ញា ឆ្នាំ១៩៥៥ គេបានពិភាក្សាគ្នាស្តីពីការផ្តល់នូវសិទ្ធិបោះឆ្នោតដល់ស្ត្រីខ្មែរ[302] និងគោលការណ៍នៃការជ្រើសរើសសភាខេត្ត[303]។

---

[299] សូមមើល : ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៤៨២-៤៨៦។

[300] យោងទៅតាមមតិមួយចំនួនថានេះជាលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ព្រោះតាមរយៈអ្នកតំណាងរបស់គេ ប្រជាជនអាចធ្វើការព្រមានរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាលបានដោយផ្ទាល់តែម្តង។ តែការអនុវត្តគោលបារណ៍នេះបានបង្កើតនូវវិបត្តិរដ្ឋាភិបាលជាច្រើន។ រដ្ឋាភិបាលសង្គមរាស្ត្រនិយមត្រូវផ្លាស់ប្តូរជាញឹកញាប់ ជាហេតុធ្វើឱ្យកម្មវិធី និងនយោបាយរបស់រដ្ឋាភិបាលនីមួយៗ រកពេលយកទៅអនុវត្តន៍សឹងតែមិនបាន។ ប៉ុន្តែមន្ត្រីរាជការពុករលួយ ឬ ទុច្ចរិត ក៏រកពេលពុករលួយ ឬ ធ្វើបាបប្រជារាស្ត្រស្ទើរតែមិនបានដែរ ព្រោះសម្តេចព្រះនរោត្តម សីហនុ ដែលដឹកនាំអង្គសមាជជាទៀងទាត់ មានមុខនាទីជាអ្នករកយុត្តិធម៌ជូនប្រជាពលរដ្ឋតែម្តង។

[301] រាជកិច្ចលេខ១ ចេញផ្សាយថ្ងៃទី១ ខែមករា ឆ្នាំ ១៩៥៨ ទំព័រ១៣-១៦ និង សុង ស៊ីណា, *នយោបាយអព្យាក្រឹតនៃព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៥៧-ដល់ឆ្នាំ១៩៧០*, ដ.ឯ.ម., ទំព័រ៤៨។ ចំពោះកាលបរិច្ឆេទនេះផ្សេងគ្នាពីសៀវភៅ Charles Meyer, *ក្រោមស្នាមញញឹមរបស់ខ្មែរ*, ដ.ឯ.ម., ទំព័រ១១២ បានរៀបរាប់ថា ការបង្កើតសមាជខ្មែរម្តង ដែលត្រូវបញ្ចូលទៅក្នុងរដ្ឋធម្មនុញដោយច្បាប់មួយចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៥៧។ សូមបញ្ជាក់ផងដែរថា រាល់ការប្រើប្រាស់កាលបរិច្ឆេទណាមួយ ដែលមានក្នុងរាជកិច្ច ឬ រដ្ឋកិច្ច សូមយកតាមឯកសារបណ្ណសារទាំងនោះ។

[302] សូមបញ្ជាក់ថា នៅក្នុងរដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៤៧, ១៩៥១ ស្ត្រីមិនមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតឡើយ។ នៅក្រោយការបោះឆ្នោតឆ្នាំ១៩៥៥ គេបានធ្វើវិសោធនកម្មទៅលើមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ហើយរដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៥៦ បានផ្តល់សិទ្ធិឱ្យស្ត្រីមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត។

[303] នីតិក្រម ដែលប្រកាសឱ្យប្រើ ដោយក្រមលេខ ៦៥ ន.ស. ចុះថ្ងៃទី១៤ មករា ១៩៥៦ តម្រូវឱ្យបង្កើតសភាប្រជាជន តាមខេត្ត និងសភាប្រជាជននៅក្នុងរាជធានី។

សមាជ អាចសម្រេចឱ្យមានការបោះឆ្នោតដកតំណាងរាស្ត្រពីមុខតំណែង ទោះបីតំណាងរាស្ត្រនោះកំពុងស្ថិតនៅក្នុងនីតិកាលនៃរដ្ឋសភាក៏ដោយ។ សមាជជាតិលើទី២ បានយល់ព្រមទទួលយកជំនួយរបស់សហរដ្ឋអាម៉េរិក ទាំងស្រុង។ សមាជជាតិលើកទី៣ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២១ ដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ ១៩៥៦ បានផ្តល់ការយល់ព្រមស្តីពីការប្រកាន់យកនយោបាយអព្យាក្រឹត្យ របស់កម្ពុជានៅក្នុងឆាកអន្តរជាតិ និងការជជែកពិភាក្សាគ្នាអំពីបញ្ហាធ្វើឧស្សាហូបនីយកម្ម។ សមាជជាតិសម័យសង្គមរាស្ត្រនិយមបានធ្វើឡើងចំនួន២៨ដង ហើយសមាជជាតិលើកទី២៨ គឺជាសមាជចុងក្រោយបំផុតរបស់សង្គមរាស្ត្រនិយមបានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៦៩។

សមាជជាតិជាអង្គការថ្មីមួយដែលសង្គមរាស្ត្រនិយម បានបង្កើតឡើងដើម្បីបើកសេរីភាពឱ្យ ប្រជាពលរដ្ឋកម្ពុជាគ្រប់មជ្ឈដ្ឋានមិនប្រកាន់ថាអ្នកមាន អ្នកក្រ ឬ មន្ត្រីជាន់ខ្ពស់ឡើយ មកបញ្ចេញមតិយោបល់ទាក់ទងទៅនឹងជីវភាពនយោបាយទាំងក្នុង និងក្រៅប្រទេស។ សមាជជាតិ ជាវេទិកាដែលមាន លក្ខណៈ ប្រជាធិបតេយ្យផ្ទាល់ ហើយអាចសាកសួរចំពោះ ស្ថាប័នថ្នាក់កំពូលរបស់ជាតិ មានរដ្ឋសភា រដ្ឋាភិបាលជាដើម។ សមាជជាតិមានតួនាទីអនុម័តលើសេចក្តីសម្រេចផ្សេងៗដើម្បីដាក់ជូនរដ្ឋាភិបាល និង រដ្ឋសភាជាតិពិនិត្យ ហើយរដ្ឋសភាអាចចាត់ចែងធ្វើប្រជាមតិ ចំពោះបញ្ហាណាដែលជាសេចក្តីសម្រេចរបស់ សមាជ។ វេទិកាសមាជនេះជាការបើកសិទ្ធិឱ្យប្រជាពលរដ្ឋខ្មែរធ្វើការរិះគន់ទៅលើមន្ត្រីរដ្ឋាភិបាល ឬ សមាជិករដ្ឋសភាណាដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់។ ហេតុនេះសមាជប្រៀបបានដូចជាស្ពានសម្រាប់តភ្ជាប់ព័ត៌មានពីថ្នាក់មូលដ្ឋានមកថ្នាក់ជាតិសម្រាប់ជាមធ្យោបាយទ្រទ្រង់ និងការពារអធិបតេយ្យប្រជារាស្ត្រខ្មែរទូទៅ។ ហេតុដែលបើកអំណាចឱ្យប្រជារាស្ត្រទូទៅ ដើម្បីចូលមកសម្រេចកិច្ចការប្រទេសជាតិជាមួយនឹងថ្នាក់ដឹកនាំប្រទេសជាការពិសោធ ដែលប្រទេសឯទៀតពុំហ៊ានធ្វើ។ តែការបើកឱ្យមានសមាជនេះគឺមានផលវិជ្ជមាន និងអវិជ្ជមាន។ លទ្ធផលជាវិជ្ជមានគឺ បានធ្វើឱ្យមន្ត្រីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ សមាជិករដ្ឋសភាមានការយកចិត្តទុកដាក់ និងប្រយ័ត្នប្រយែងក្នុងការបំពេញការងាររបស់ខ្លួន។ សមាជ គឺហាក់ដូចជាបន្ទាត់ច្បាប់មួយទៀតដែលសម្រាប់ឱ្យមន្ត្រីរាជការអនុវត្តតាម។ ប្រសិនបើសមាជជាតិជាមធ្យោបាយស័ក្តិសិទ្ធិការពារសិទ្ធិប្រជារាស្ត្រទូទៅ មន្ត្រីអ្នករាជការតូចតាច និងជាបន្ទាត់តម្រង់ផ្លូវនយោបាយអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិជាដើមនោះ ប្រជារាស្ត្រខ្មែរពិតជាចាត់ទុកថា សមាជជាតិជាទ្រព្យសម្បត្តិដ៏ធំធេងរបស់គេ។

តាមលោក សាល មីយ៉ែ (Charles Meyer) បានសរសេរសម្គាល់ថា សមាជបានធ្វើឱ្យថមថយតម្លៃរបស់ខ្លួននៅខែធ្នូ ឆ្នាំ១៩៦៨ នៅពេលដែលអង្គសមាជយល់ព្រមតាមសំណើដែលឱ្យយោបល់ដោយសម្តេចព្រះនរោត្តម សីហនុ ក្នុងការបង្កើតកាស៊ីណូមួយដែលមិនស្របនឹងមតិសាធារណៈ។ ពាក់ព័ន្ធនឹងសមាជជាតិនេះដែរ លោក វ៉ាស៊ី យន ជាសមាជិកគណៈកម្មការតុលាការ និងរដ្ឋធម្មនុញ្ញបានមានមតិនៅក្នុងកិច្ចពិភាក្សាលើ សេចក្តីព្រាងច្បាប់ស្តីពីការអនុញ្ញាតឱ្យបើកគ្រឹះស្ថានល្បែងនៅក្នុងប្រទេសកម្ពុជានាខែមករា ឆ្នាំ១៩៦២ ថាសមាជគ្មានអ្វីជាភស្តុតាងពិតប្រាកដយកមកធ្វើច្បាប់ទេ មានតែការចាំពាក្យសំដីយកមកធ្វើជាគោល[304]។ សមាជចុងក្រោយបង្អស់នាសម័យសង្គមរាស្ត្រនិយមត្រូវបានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៦៩ នៅក្នុងឱកាសនោះមានវាគ្មិនម្នាក់ឈ្មោះ ហែម វណ្ណឬទ្ធិ បានឡើងមានមតិទាក់ទងទៅនឹងបញ្ហាធ្លាក់ចុះផ្នែកសេដ្ឋកិច្ចកម្ពុជានៅសម័យសង្គមរាស្ត្រនិយម។ លោក ហែម វណ្ណឬទ្ធិ បាននិយាយចោទប្រកាន់ថាភាព

[304] រាជកិច្ចលេខ៥០ ចេញផ្សាយថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៦២, ទំព័រ៤១៣៤។

អនាធិបតេយ្យ និងការបរាជ័យសេដ្ឋកិច្ចគឺបណ្តាលមកពីការដឹកនាំមិនល្អនៃសង្គមរាស្ត្រនិយម[305]។ គេសង្កេតឃើញថា នៅក្នុងសមាជចុងក្រោយនេះមានការប៉ះទង្គិចមតិគ្នាយ៉ាងធ្ងន់ធ្ងរ រវាងវាគ្មិនដែលបានចូលរួមក្នុងអង្គសមាជ និងថ្នាក់ដឹកនាំសមាជជាតិ។

## កាលបរិច្ឆេទនៃការធ្វើសមាជជាតិ នាសម័យសង្គមរាស្ត្រនិយម[306]

| ល.រ | សមាជាតិ | កាលបរិច្ឆេទ |
|---|---|---|
| ១ | សមាជជាតិលើកទី ១ | ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៥ |
| ២ | សមាជជាតិលើកទី ២ | ថ្ងៃទី២៥-២៦ ខែកញ្ញា ឆ្នាំ១៩៥៥ |
| ៣ | សមាជជាតិលើកទី ៣ | ថ្ងៃទី២០-២២ ខែមេសា ឆ្នាំ១៩៥៦ |
| ៤ | សមាជជាតិលើកទី ៤ | ថ្ងៃទី១២-១៥ ខែមករា ឆ្នាំ១៩៥៧ |
| ៥ | សមាជជាតិលើកទី ៥ | ថ្ងៃទី១៥-១៦ ខែកក្កដា ឆ្នាំ១៩៥៧ |
| ៦ | សមាជជាតិលើកទី ៦ | ថ្ងៃទី៤-៦ ខែមករា ឆ្នាំ១៩៥៨ |
| ៧ | សមាជជាតិលើកទី ៧ | ថ្ងៃទី១៣-១៥ ខែធ្នូ ឆ្នាំ១៩៥៨ |
| ៨ | សមាជជាតិលើកទី ៨ | ថ្ងៃទី៤-៦ ខែកក្កដា ឆ្នាំ១៩៥៩ |
| ៩ | សមាជជាតិលើកទី ៩ | ថ្ងៃទី ខែ ឆ្នាំ១៩៥៩ |
| ១០ | សមាជជាតិលើកទី ១០ | ថ្ងៃទី២៧-២៩ ខែធ្នូ ឆ្នាំ១៩៦០ |
| ១១ | សមាជជាតិលើកទី ១១ | ថ្ងៃទី ខែ ឆ្នាំ១៩៦១ |
| ១២ | សមាជជាតិលើកទី ១២ | ថ្ងៃទី ខែ ឆ្នាំ១៩៦១ |
| ១៣ | សមាជជាតិលើកទី ១៣ | ថ្ងៃទី ខែ ឆ្នាំ១៩៦២ |
| ១៤ | សមាជជាតិលើកទី ១៤ | ថ្ងៃទី ខែ ឆ្នាំ១៩៦២ |
| ១៥ | សមាជជាតិលើកទី ១៥ | ថ្ងៃទី១-៣ ខែកក្កដា ឆ្នាំ១៩៦៣ |
| ១៦ | សមាជជាតិលើកទី ១៦ | ថ្ងៃទី២៩-៣១ ខែធ្នូ ឆ្នាំ១៩៦៣ |
| ១៧ | សមាជជាតិលើកទី ១៧ | ថ្ងៃទី ខែ ឆ្នាំ១៩៦៤ |
| ១៨ | សមាជជាតិលើកទី ១៨ | ថ្ងៃទី ខែ ឆ្នាំ១៩៦៤ |
| ១៩ | សមាជជាតិលើកទី ១៩ | ថ្ងៃទី ខែ ឆ្នាំ១៩៦៥ |
| ២០ | សមាជជាតិលើកទី ២០ | ថ្ងៃទី ខែ ឆ្នាំ១៩៦៥ |
| ២១ | សមាជជាតិលើកទី ២១ | ថ្ងៃទី១៨-២០ ខែកក្កដា ឆ្នាំ១៩៦៦ |
| ២២ | សមាជជាតិលើកទី ២២ | ថ្ងៃទី២២-២៧ ខែធ្នូ ឆ្នាំ១៩៦៦ |

305 សុទ្ធ ប៉ូលីន, *សមាជចុងក្រោយនៃសង្គមរាស្ត្រនិយម*, អង្គរបូរី (សំឡេងខ្មែរនៅបរទេស), ឆ្នាំ?
306 ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៤៦៧-៤៦៨។

| | | |
|---|---|---|
| ២៣ | សមាជជាតិលើកទី ២៣ | ថ្ងៃទី១០-១៣ ខែកញ្ញា ឆ្នាំ១៩៦៧ |
| ២៤ | សមាជជាតិលើកទី ២៤ | ថ្ងៃទី ខែ ឆ្នាំ១៩៦៧ |
| ២៥ | សមាជជាតិលើកទី ២៥ | ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៦៨ |
| ២៦ | សមាជជាតិលើកទី ២៦ | ថ្ងៃទី ខែ ឆ្នាំ១៩៦៨ |
| ២៧ | សមាជជាតិលើកទី ២៧ | ថ្ងៃទី ខែ ឆ្នាំ១៩៦៩ |
| ២៨ | សមាជជាតិលើកទី ២៨ | ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៦៩ |

## ៥- នយោបាយអព្យាក្រឹត និងចលនាមិនចូលបក្សសម្ព័ន្ធ

នយោបាយការបរទេសរបស់ព្រះរាជាណាចក្រកម្ពុជា ក្រោយការបោះឆ្នោតឆ្នាំ១៩៥៥ ត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមរយៈការប្រកាន់យក នយោបាយអព្យាក្រឹត និងចលនាមិនចូលបក្សសម្ព័ន្ធ(M.N.A) ដែលជាមាគ៌ានយោបាយដែលដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ។ ជំហរនេះត្រូវបានប្រកាសជាលើកដំបូងនៅក្នុងសន្និសីទក្រុងបានឌុង (Bandung) នៃប្រទេសអាស៊ី-អាហ្វ្រិក ចន្លោះថ្ងៃទី១៨ ដល់ទី២៤ ខែមេសា ឆ្នាំ១៩៥៥ ដើម្បីបង្កើតមាគ៌ានយោបាយ«មិនចូលបក្សសម្ព័ន្ធ» ដែលស្ថិតនៅចន្លោះមហាអំណាចធំៗទាំងពីរ។ សម្តេចព្រះ នរោត្តម សីហនុ បានបញ្ជាក់ថា នយោបាយអព្យាក្រឹតនេះជាគោលការណ៍ដែលប្រជាជាតិទាំងមូលបានតម្រូវតាមរយៈសមាជជាតិលើកទី២។ ខ្លឹមសារនៃអព្យាក្រឹតនេះតម្រូវឱ្យកម្ពុជាកាន់អាកប្បកិរិយាដ៏ជាច់ខាតដោយរក្សាមិត្តភាពជាមួយបក្សខាងលិច និងបក្សកុម្មុយនីស្តស្មើគ្នា ដោយទទួលជំនួយដែលពុំធ្វើឱ្យសាបរលាបដល់ អធិបតេយ្យភាព និងអព្យាក្រឹតរបស់ជាតិ។ គោលនយោបាយនេះត្រូវបានកំណត់ផងដែរនៅក្នុងសេចក្តីសម្រេចនៃសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ ដែលជាការទាមទាររបស់ចិន និងសូវៀតដើម្បីបញ្ចៀសមិនឱ្យសហរដ្ឋអាម៉េរិកកសាងមូលដ្ឋានទ័ពនៅកម្ពុជា។ លើសពីនេះ គោលការណ៍នេះត្រូវបានពង្រឹងតាមរយៈការចុះហត្ថលេខាជាមួយលោក នេរុ ដែលជានាយករដ្ឋមន្ត្រីឥណ្ឌាលើសេចក្តីប្រកាសរួមស្តីពីការរួមរស់ជាមួយគ្នាដោយសុខសន្តិភាព ព្រមទាំងការដាក់បញ្ចូល គោលការណ៍បញ្ចសីលា ទៅក្នុងនយោបាយជាតិ ដែលរួមមានការគោរពអធិបតេយ្យភាព និងបូរណភាពទឹកដីគ្នាទៅវិញទៅមក ការមិនឈ្លានពាន និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង។ ជាការអនុវត្តជាក់ស្តែង កម្ពុជាបានប្រកាសពីការដើរលើមាគ៌ាអព្យាក្រឹតនេះពេលចូលជាសមាជិកអង្គការសហប្រជាជាតិនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ ហើយបានបដិសេធជាដាច់ខាតមិនចូលរួមក្នុងអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍(SEATO) ដោយអះអាងថាវាផ្ទុយទៅនឹងស្មារតីកិច្ចព្រមព្រៀងក្រុងហ្សឺណែវ។ ថ្វីត្បិតតែនយោបាយនេះត្រូវបានលោក បារុងបិចហ្វ្រិស និងលោក ហាម៉ាហ្សូល នៃអង្គការសហប្រជាជាតិទទួលស្គាល់ និងសរសើរក៏ដោយ ក៏សម្តេចព្រះ នរោត្តម សីហនុ បានព្រះរាជសន្និដ្ឋានថា អព្យាក្រឹតភាពដ៏បរិសុទ្ធនេះបានធ្វើឱ្យកម្ពុជានៅដាច់ពីគេឯកឯង ហើយបាត់បង់មិត្តភក្តិដែលអាចពឹងពាក់បាន ធ្វើឱ្យប្រទេសដែលមានបំណងចង់ធ្វើបាបរំលោភមកលើកម្ពុជាកាន់តែខ្លាំង។ ដើម្បីការពារខ្លួន ព្រះរាជក្រមឆ្នាំ១៩៥៧ បានបញ្ជាក់ថា«កម្ពុជាពុំត្រូវការចងសម្ព័ន្ធមិត្តយោធា ឬផ្លូវមនោគមន៍ជាមួយបរទេសទេ តែមានសិទ្ធិការពារខ្លួន

ដោយអាវុធ និងអំពាវនាវដល់អង្គការសហប្រជាជាតិ ឬប្រទេសមហាអំណាចដែលជាមិត្តក្នុងករណីមានការបង្កសង្គ្រាម»[307]។

## ៦-សម្ដេចព្រះនរោត្ដម សីហនុ និងជាប្រមុខរដ្ឋឆ្នាំ ១៩៦០

ដំណើរការនៃការឡើងកាន់តំណែងជាប្រមុខរដ្ឋរបស់សម្ដេចព្រះនរោត្ដម សីហនុ នៅឆ្នាំ១៩៦០ គឺជាករណីពិសេសមួយក្នុងប្រវត្តិសាស្ត្ររដ្ឋធម្មនុញ្ញកម្ពុជា ដែលបានកើតឡើងដោយសារភាពស្មុគស្មាញនៃការបន្តរាជ្យសម្បត្តិ បន្ទាប់ពីព្រះបាទសុរាម្រិតសោយទិវង្គតនៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៦០។ ដោយសម្ដេចព្រះនរោត្ដម សីហនុ បានបដិសេធមិនសោយរាជ្យវិញទេដោយគោរពតាមការសន្យារបស់ទ្រង់តាំងពីឆ្នាំ១៩៥៥។ ក្នុងរយៈពេលបី ថ្ងៃដែលរដ្ឋធម្មនុញ្ញកំណត់សម្រាប់ការចាត់តាំងព្រះមហាក្សត្រថ្មីបានកន្លងផុតទៅ រដ្ឋសភាបានសម្រេចបង្កើត«ក្រុមប្រឹក្សារាជានុសិទ្ធិ» ជាបណ្ដោះអាសន្ន ហើយព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ត្រូវបានតែងតាំងជាប្រធាននៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៦០។ យ៉ាងណាមិញ ដើម្បីពង្រឹងភាពស្របច្បាប់ផ្នែកនយោបាយ សម្ដេចព្រះ នរោត្ដម សីហនុ បានស្នើសុំឱ្យរដ្ឋសភារៀបចំការបោះឆ្នោតប្រជាមតិមួយ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៦០ ហើយលទ្ធផលផ្លូវការបានបង្ហាញនូវជ័យជម្នះដ៏លើសលប់ ដោយមានប្រជាពលរដ្ឋរហូតដល់៩៩.៩៨% នៃអ្នកមកបោះឆ្នោត បានយល់ស្របតាមនយោបាយរបស់សង្គមរាស្ត្រនិយម ដែលបង្ហាញយ៉ាងច្បាស់នូវឆន្ទៈរបស់ប្រជារាស្ត្រ។ ឆ្លើយតបទៅនឹងការដង្ហែជាក្បួនរបស់ប្រជាពលរដ្ឋប្រមាណ៧០.០០០នាក់ នៅមុខរដ្ឋសភានៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៦០ ដើម្បីទទូចសុំឱ្យទ្រង់កាន់កាប់មុខងារជាប្រមុខរដ្ឋ រដ្ឋសភាបានអនុម័តច្បាប់ស្ដីពីការបន្ថែមបទបញ្ញត្តិពិសេសជាឯកច្ឆន្ទ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៦០។ បទបញ្ញត្តិពិសេសនេះត្រូវបានបញ្ចូលក្នុង ជំពូក១២ មាត្រា១២២ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ដោយបានចែងថា សភាទាំងពីរអាចលើកអំណាច និងបុព្វសិទ្ធិទាំងឡាយរបស់ប្រមុខរដ្ឋ ទៅប្រគល់ជូនឥស្សរជនមួយរូបណា ដែលប្រជាពលរដ្ឋស្រលាញ់ទុកចិត្ត និងបានបញ្ចេញមតិដ៏ជាក់ច្បាស់។ ផ្អែកលើច្បាប់ថ្មីនេះ ក្រុមប្រឹក្សារាជ្យសម្បត្តិក៏ប្រកាសរំសាយ ហើយរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជាបានប្រជុំនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៦០ ដើម្បីជ្រើសតាំងសម្ដេចព្រះ នរោត្ដម សីហនុ ជាប្រមុខរដ្ឋ មុននឹងទ្រង់យាងទៅធ្វើសច្ចាប្រណិធានចំពោះមុខរដ្ឋសភា នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៦០ ដើម្បីចូលកាន់តំណែងជាផ្លូវការ[308]។ បទបញ្ញត្តិពិសេសនៃមាត្រា១២២ បានក្លាយជាភស្តុតាងសម្រាប់បកស្រាយផ្សេងៗគ្នាក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០[309]។

## ៧-កម្ពុជា និងទំនាក់ទំនងជាមួយប្រទេសសេរី និងកុម្មុយនីស្ត

នយោបាយអព្យាក្រឹតបានក្លាយជាមូលដ្ឋានគ្រឹះនៃនយោបាយការបរទេសរបស់កម្ពុជា នាសម័យសង្គមរាស្ត្រនិយម។ ទាក់ទងនឹងការប្រកាន់យកនយោបាយអព្យាក្រឹតនេះដែរ សម្ដេចព្រះនរោត្ដម សីហនុ បានមានព្រះរាជបន្ទូលថា គេពុំអាចរកឃើញមានប្រទេសឯណាមួយដែលមានឯករាជ្យបរិបូរណ៍ ដាច់ដោយឡែកពីប្លុកប្រឆាំងគ្នាដោយលទ្ធិ និងប្រយោជន៍ផ្ទុយគ្នា ព្រមទាំងដាច់ចេញពីការជិះជាន់របស់មហាអំណាចចក្រពត្តិនិយម

[307] សូមមើល : ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៤៩០-៥១១។

[308] ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៥១១-៥១៥។

[309] សូមមើលការពន្យល់លម្អិត : -ដ- ទំព័រ៥១១-៥១៤។

ទាំងខាងលិច ទាំងខាងកើតឱ្យស្មើនឹងកម្ពុជាបានឡើយ[310]។ ដោយមិនអាចគាបសង្កត់ប្រទេសកម្ពុជាឱ្យលះបង់អព្យាក្រឹត និងបង្ខំឱ្យចូលរួមក្នុងអង្គការសេអាតូបាននោះ នៅដើមខែមិថុនា ឆ្នាំ១៩៥៨ កងទ័ពវៀតណាមខាងត្បូងបានវាយចូលក្នុងតំបន់ភាគឦសាននៃខេត្តស្ទឹងត្រែង[311] ហើយដើម្បីឆ្លើយតបនឹងការរំលោភបំពាននេះសម្តេចព្រះ នរោត្តម សីហនុ បានផ្ញើលិខិត[312]មួយច្បាប់ដើម្បីឱ្យអាមេរិកជួយចាត់វិធានការណ៍ដើម្បីបញ្ចប់ការទន្ទ្រាននេះ។ បើតាមរបាយការណ៍ដាក់បង្ហាញជូនសមាជជាតិលើកទី១៥ (ថ្ងៃទី១-៣ ខែកក្កដា ឆ្នាំ១៩៦៣) ប្រទេសវៀតណាមខាងត្បូងបានរំលោភដែនដី និងដែនអាកាសខ្មែរជាច្រើនលើកច្រើនសារមាន[313]៖

- យប់ថ្ងៃទី២៥ ដល់២៦ ខែវិច្ឆិកា ឆ្នាំ១៩៦២ វៀតណាមវាយប្រហារស្រែតានង់ នៅមេមត់ ក្នុងខេត្តកំពង់ចាម។
- ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៦៣ យន្តហោះវៀតណាមទម្លាក់គ្រាប់មកលើឃុំទ្រាក ក្នុងស្រុកមេមត់។
- ថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៦៣ នៅកោះរកា (ខេត្តព្រៃវែង) កងនាវាភូមិន្ទចាប់បាននាវាពីរគ្រឿងធុន L.C.V.P ដែលបានរំលោភដែនទឹករបស់កម្ពុជាលើទន្លេមេគង្គ
- ថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៦៣ ពលទាហាននៃកងយោធាវៀតណាម វាយប្រហារតំបន់តាណយក្នុងខេត្តស្វាយរៀង។
- ពីខែវិច្ឆិកា ឆ្នាំ១៩៦២ ដល់ខែមីនា ឆ្នាំ១៩៦៣ មានការរំលោភដែនអាកាសរបស់ខ្មែរ១៦ដង។

នៅក្នុងឆ្នាំ១៩៥៨ នេះដែរ ទំនាក់ទំនងកម្ពុជាថៃបានចាប់ផ្តើមមានភាពល្អក់កករ។ នៅពេលនោះប៉ូលិសថៃបានចូលមកកាន់កាប់ប្រាសាទព្រះវិហារ។ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៥៨ សម្តេចព្រះនរោត្តម សីហនុ បានយាងទៅធ្វើទស្សនកិច្ចនៅក្រុងបាងកកដើម្បីបើកកិច្ចចរចាទ្វេភាគីជាមួយសៀម[314]។ ការរំលោភតាមព្រំដែនកម្ពុជាពីសំណាក់កងទ័ពថៃពីខែ មីនា ដល់ខែឧសភា ឆ្នាំ១៩៥៨ មានចំនួន៦ដង[315]។ ចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦២ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៦៣ ប្រទេសថៃបានរំលោភព្រំដែន និងប្រព្រឹត្តអំពើចោរកម្មមកលើកម្ពុជាចំនួន១០លើកគឺថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦២, ថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៦៣, ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៦៣, ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៦៣, ថ្ងៃទី២១ ខែមករា ឆ្នាំ១៩៦៣, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៦៣, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៦៣, ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៦៣, ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៦៣ និងនៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦៣[316]។

---

[310] ព្រះរាជសុន្ទរកថានៃសម្តេចព្រះនរោត្តម សីហនុ នាយករដ្ឋមន្ត្រីថ្លែងក្នុងឱកាសបើកការសិក្សាពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងសម្ពោធគ្រឹះស្ថានព្រះសីហនុ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥៩ ទំព័រ៦-៧។

[311] Norodom Sihanouk and Wilfred G. Burchett, *La C.I.A. contre le Cambodge*, François Maspero, Paris, 1973, p.86.

[312] ព្រះសារលិខិតនេះព្រះអង្គបានផ្ញើទៅនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥៨។ នៅពេលនោះរដ្ឋាភិបាលសហរដ្ឋអាម៉េរិកបានឆ្លើយតបមកវិញថាខ្លួនមិនអាចអន្តរាគមន៍ក្នុងរឿងនេះបានទេ ប៉ុន្តែក៏មិនអាចឱ្យកម្ពុជាយកគ្រឿងសព្វាវុធដែលជាជំនួយរបស់សហរដ្ឋអាម៉េរិកទៅប្រើប្រាស់ប្រឆាំងនឹងកងទ័ពវៀតណាមខាងត្បូង ដែលជាសម្ពន្ធមិត្តរបស់សហរដ្ឋអាម៉េរិកនោះបានឡើយ( សូមមើលៈ Charles Meyer, *ក្រោមស្នាមញញឹមរបស់ខ្មែរ*, ដ.ឯ.ម., ទំព័រ២១០)។

[313] ស្នាដៃសង្គមរាស្ត្រនិយម *ពីខែធ្នូ ឆ្នាំ១៩៦២ ដល់ខែមិថុនា ឆ្នាំ១៩៦៣* ការដាក់បង្ហាញសមាជជាតិលើកទី១៥ ទំព័រ២១០-២១១។

[314] កិច្ចចរចានោះមិនបានឈានទៅរកការព្រមព្រៀងគ្នាណាមួយឡើយ។

[315] មីហេយេរ, *ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា,* .ដ.ឯ.ម.,ទំព័រ៤០១-៤០២។

[316] ស្នាដៃសង្គមរាស្ត្រនិយម *ពីខែធ្នូ ឆ្នាំ១៩៦២ ដល់ខែមិថុនា ឆ្នាំ១៩៦៣* ការដាក់បង្ហាញសមាជជាតិលើកទី១៥ ទំព័រ២១៨-២១៩។

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ១៩៦៤ សម្តេចព្រះនរោត្តម សីហនុ បានស្នើសុំបើកសន្និសីទចតុភាគីមួយដើម្បីការពារអព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា។ សម្តេចនរោត្តម សីហនុបានស្នើសុំឱ្យប្រទេសលាវ ថៃ និងប្រទេសវៀតណាមគោរពបូរណភាពដែនដីខ្មែរ។ ប៉ុន្តែ១៧ ថ្ងៃក្រោយមកគឺថ្ងៃទី៦ ខែមីនា ក្រសួងការបរទេសសហរដ្ឋអាម៉េរិក បែរជាគាំទ្រការទាមទារ[317]របស់ថៃ និងវៀតណាមខាងត្បូងដែលជាសម្ពន្ធមិត្តរបស់ សហរដ្ឋអាម៉េរិកទៅវិញ។ នៅពេលនោះដែរ ប្រទេសចិនបានផ្តល់ការគាំទ្រផ្នែកយោធារបស់គេឱ្យកម្ពុជាក្នុងករណីណាមានជម្លោះឈ្លានពាន។ រីឯរណសិរ្សរំដោះជាតិរបស់វៀតកុង[318] សន្យាថានឹងគោរពបូរណភាពដែនដីខ្មែរដែរ។ មួយឆ្នាំក្រោយមកគឺនៅខែមិថុនា ឆ្នាំ១៩៦៥ ប្រទេសវៀតណាមខាងជើង បានសាកល្បង ប្រើ ចលនាកុម្មុយនីស្តខ្មែរឱ្យប្រយុទ្ធនឹងសហរដ្ឋអាម៉េរិក ជាមួយខ្លួនថែមទៀត។ នៅខែមិថុនា ឆ្នាំ១៩៦៥ នោះហើយដែលសាឡុត ស, កែ មាស និងអ្នកដឹកនាំចលនាកុម្មុយនីស្តខ្មែរមួយចំនួនបានធ្វើដំណើរតាមផ្លូវលំហូរជីមិញទីកាន់ក្រុងហាណូយ[319]។ នៅចុងឆ្នាំ១៩៦៥ វៀតណាមខាងជើងបានមកទំនាក់ទំនងជាសម្ងាត់ជាមួយសម្តេចព្រះនរោត្តម សីហនុ ដើម្បីជួយដោះស្រាយការលំបាកទាំងនោះ ហើយព្រះអង្គក៏បានសម្រេចចិត្តតាមសំណូមពររបស់ពួកអ្នកតស៊ូវៀតណាម។ ការសម្រេចចិត្តបែបនេះ គឺជាការឃ្លាតចាកពីនយោបាយអព្យាក្រឹត និងជាការប្រថុយប្រថានមួយ[320]។ សកម្មភាពបែបនេះហើយដែលសហរដ្ឋអាម៉េរិក និងប្រទេសសេរីមួយចំនួនទៀតបានមើលឃើញថានយោបាយអព្យាក្រឹតរបស់សម្តេច ព្រះនរោត្តមសីហនុបានដើរលើវិថីក្រហម[321]។

ក្នុងទំនាក់ទំនងជាមួយប្រទេសលោកសេរី និងកុម្មុយនីស្ត នាំឱ្យនយោបាយអព្យាក្រឹតវិវត្ត៦ដំណាក់កាលដូចខាងក្រោម[322]៖

## ដំណាក់កាលទី១
## ចំណងការទូតជាមួយសហរដ្ឋអាម៉េរិក

ការភ្ជាប់ទំនាក់ទំនងជាមួយសហរដ្ឋអាម៉េរិកក្នុងឆ្នាំ១៩៥៥ ដើម្បីទទួលជំនួយអភិវឌ្ឍប្រទេសជាតិឱ្យស្របតាមគោលនយោបាយអភិវឌ្ឍកម្ពុជា។ បេសកកម្មជំនួយបច្ចេកទេស និងសេដ្ឋកិច្ចអាម៉េរិកគឺមានការិយាល័យរបស់ខ្លួននៅក្រុងភ្នំពេញតាំងពីឆ្នាំ១៩៥៤។ បេសកកម្មនេះបានធ្វើសកម្មភាពពេញដៃនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៥។

## ដំណាក់កាលទី២
## ចំណងការទូតជាមួយចិន ហើយបានបដិសេធមិនចូលជាសមាជិក សេអាតូ(SEATO)

អង្គការសេអាតូស្ថិតក្រោមការគ្រប់គ្រង និងដឹកនាំរបស់សហរដ្ឋអាម៉េរិក ហើយអង្គការនេះត្រូវបានបង្កើតឡើងនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៥៤បន្ទាប់ពីសង្គ្រាមឥណ្ឌូចិនលើកទី១បានបញ្ចប់ភ្លាមៗ ហើយបានចូលជាធរមាននៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៥៥ បន្ទាប់ពីសមាជិកទាំងអស់ចុះហត្ថលេខាលើសន្ធិសញ្ញានេះ

[317] នៅថ្ងៃទី៩ មីនា និងថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៦០ រដ្ឋាភិបាលវៀតណាមខាងត្បូងបានទាមទារយកជាផ្លូវការនូវកោះនានារបស់កម្ពុជាមានដូចជាកោះសេះ, កោះអន្លាយ, កោះតាគៀវ, កោះពោរ និងកោះអង្រ្កង។

[318] ពួកវៀតកុង បង្កើតឡើងដោយវៀតណាមខាងជើងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៦០(សូ សាយ, ការសាកល្បងសិក្សាស្រាវជ្រាវអំពីកុម្មុយនីស្តឥណ្ឌូចិន, ដ.ឯ.ម., ទំព័រ២៥៨)។

[319] វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា*, ភាគ១, .ដ.ឯ.ម., ទំព័រ២១០។

[320] ខៀវ សំផន, *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ*, ពុម្ពផ្សាយរាហ៊ុ, ឆ្នាំ២០០៧, ទំព័រ១០២។

[321] ការដើរតាមផ្លូវកុម្មុយនីស្ត។

[322] ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម.,ទំព័រ៥០០-៥០៦។

រួច។ សមាជិករបស់អង្គការសេអាតូមាន សហរដ្ឋអាម៉េរិក, អង់គ្លេស, បារាំង, អូស្ត្រាលី, ថៃ, ហ្វីលីពីន, ប៉ាគីស្ថាន និងនូវែលហ្សេឡង់ ហើយនឹងគ្រោងបញ្ចូលប្រទេសមួយចំនួនទៀតនៅក្នុងតំបន់ដូចជា ប្រទេសកូរ៉េខាងត្បូង, កោះតៃវ៉ាន់, វៀតណាមខាងត្បូង, កម្ពុជា, ឡាវ, ជប៉ុន និងប្រទេសឥណ្ឌា។ ប៉ុន្តែ ប្រទេសកម្ពុជា បានបាត់បង់ឱកាសក្នុងការចូលជាសមាជិកអង្គការសេអាតូ ដោយសារសម្តេចព្រះ នរោត្តម សីហនុ មានការជឿជាក់ទៅលើបរទេសកុម្មុយនីស្ត។

សម្តេចព្រះនរោត្តម សីហនុ បានជួបជាមួយលោក ជូ អេនឡាយ នៅក្នុងឱកាស ដែលព្រះអង្គដឹកនាំប្រតិភូនៃប្រទេសកម្ពុជា ទៅចូលរួមក្នុងសន្និសីទនាក្រុងបានឌុង ប្រទេសឥណ្ឌូណេស៊ី នៅឆ្នាំ១៩៥៥ ស្តីពីប្រទេសអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ។ នៅខែកុម្ភៈ ឆ្នាំ១៩៥៦ សាធារណរដ្ឋប្រជាមានិតចិននឹងផ្តល់ជំនួយសេដ្ឋកិច្ច ដោយឥតលក្ខខណ្ឌមកឱ្យប្រទេសកម្ពុជា។ ដើម្បីធ្វើឱ្យប្រទេសទាំងពីរនេះមានទំនាក់ទំនងកាន់តែប្រសើរឡើង ប្រទេសកម្ពុជាបានបង្កើតស្ថានឯកអគ្គរាជទូតរបស់ខ្លួនប្រចាំសាធារណរដ្ឋប្រជាមានិតចិននៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៥៩។ ប្រទេសកម្ពុជាបានទទួលស្គាល់ប្រទេសប្រជាមានិតជាប្រទេសពេញលក្ខណៈច្បាប់ ហើយគាំទ្រយ៉ាងម៉ឺងម៉ាត់ចំពោះកិច្ចប្រជុំទាំងឡាយនៅក្នុងឆាកអន្តរជាតិ។ ដោយសារតែសម្តេចព្រះនរោត្តម សីហនុ បានប្រកាន់យកនយោបាយអព្យាក្រឹត ទើបនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៥៥ រដ្ឋមន្ត្រីការបរទេសអាម៉េរិក លោក ហ្វូស្ទ័រ ឌុល្លេស ( Foster Dulles ) បានមកទស្សនកិច្ចនៅក្រុងភ្នំពេញ ដើម្បីទទួលនូវការដាក់បញ្ចូលប្រទេសកម្ពុជាក្នុងអង្គការសេអាតូ ប៉ុន្តែសម្តេចព្រះនរោត្តម សីហនុបានបដិសេធ។

## ដំណាក់កាលទី៣
## ការគាបសង្កត់ពីសំណាក់សហរដ្ឋអាម៉េរិក
## ផ្នែកនយោបាយ និងសេដ្ឋកិច្ច

ស្ថានការណ៍នយោបាយរវាងសង្គមរាស្ត្រនិយម និងសហរដ្ឋអាម៉េរិកគឺមានលក្ខណៈមិនសូវរលូនឡើយ។ ដោយសារតែនៅក្នុងសមាជាតិលើកទី១៦ បានឯកភាពគ្នាបដិសេធមិនទទួលយកជំនួយយោធា និងស៊ីវិលពីសហរដ្ឋអាម៉េរិក។ ចាប់ពីពេលនោះមកធ្វើឱ្យសហរដ្ឋអាម៉េរិកចាប់ផ្តើមគាបសង្កត់លើសង្គមរាស្ត្រនិយម ដោយផ្តល់អាវុធដល់កម្លាំងខ្មែរសេរីរបស់លោក សឺង ង៉ុកថាញ់ ហើយការរំលោភដែនអាកាសកម្ពុជា និងការចូលលុកលុយតាមព្រំដែនប្រទេសកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ពីសំណាក់ថៃ និងវៀតណាមខាងត្បូងក៏បានកើតឡើងដោយមានការគាំទ្រពីសហរដ្ឋអាម៉េរិក។ នៅឆ្នាំ១៩៥៦ កងទ័ពវៀតណាមខាងត្បូងបានចាត់ឱ្យកងទ័ពរបស់ខ្លួនចូលលុកលុយតាមផ្លូវគោកជាច្រើនលើក និងប៉ុនប៉ងកាន់កាប់កោះនានានៅតាមសមុទ្រកម្ពុជារហូតមកដើមខែមិថុនា ឆ្នាំ១៩៥៨ កងទ័ពវៀតណាមខាងត្បូងបានចូលមកក្នុងតំបន់ភាគឦសាននៃខេត្តស្ទឹងត្រែង។ ចំណែកការរំលោភបំពានរបស់ថៃ មកលើប្រទេសកម្ពុជាតែងតែកើតឡើងជាបន្តបន្ទាប់។ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៦១ តម្រួតថៃបានចាប់ឃុំឃាំងជនជាតិខ្មែរចំនួន៤នាក់នៅឃុំស្វាយចេក។

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦៤ បាតុកម្មប្រឆាំងនឹងស្ថានទូតអាម៉េរិក និងអង់គ្លេសបានកើតឡើងនៅក្រុងភ្នំពេញ។ បញ្ហានេះហើយដែលនាំឱ្យចំណងការទូតរវាងកម្ពុជា និងសហរដ្ឋអាម៉េរិកត្រូវបានកាត់ផ្តាច់នាថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៦៥។

## ដំណាក់កាលទី៤
## ចំណងមិត្តភាពបើកមុខជាមួយប្រទេសកុម្មុយនីស្ត

ការមិនទុកចិត្តរបស់សហរដ្ឋអាម៉េរិកចំពោះសង្គមរាស្ត្រនិយម និងភាពមិនអើពើរបស់សហរដ្ឋអាម៉េរិក ចំពោះការឈ្លានពានរបស់វៀតណាមខាងត្បូង ចូលមកលើទឹកដីកម្ពុជា។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥៨ ព្រះមហាក្សត្រខ្មែរបានបញ្ជូនព្រះសារលិខិតមួយច្បាប់អំពាវនាវឱ្យសហរដ្ឋអាម៉េរិក ចាត់វិធានការគ្រប់បែបយ៉ាង ក្នុងការទន្ទ្រានចូលទឹកដីខេត្តស្ទឹងត្រែងដោយខុសច្បាប់ពីសំណាក់កងទ័ពវៀតណាមខាងត្បូង។ នៅពេលនោះ សហរដ្ឋអាម៉េរិកបានឆ្លើយតបមកវិញថា ខ្លួនមិនអាចធ្វើអន្តរាគមន៍ក្នុងរឿងនេះបានទេ ប៉ុន្តែក៏មិនបណ្តោយឱ្យកម្ពុជាយកគ្រឿងសព្វាវុធរបស់អាម៉េរិកទៅប្រើប្រាស់ប្រឆាំងនឹងវៀតណាមខាងត្បូង ដែលជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាម៉េរិកនោះឡើយ។

បញ្ហាទាំង អស់នេះហើយដែលនាំឱ្យសម្តេចព្រះនរោត្តម សីហនុ គ្មានជម្រើសអ្វីក្រៅពីចងសម្ព័ន្ធមិត្តជាមួយប្រទេសជាសមាជិកវ៉ាសូវី(Varsovie)[323], ប្រទេសមិនចូលបក្សសម្ព័ន្ធ[324]និងប្រទេសកុម្មុយនីស្តឡើយ។ ពេលនោះហើយ ដែលសម្តេចព្រះនរោត្តម សីហនុ បានអនុញ្ញាតឱ្យកងទ័ពវៀតណាមខាងជើង និងវៀតកុងប្រើប្រាស់ទឹកដីខ្មែរនៅតំបន់ភូមិភាគខាងកើតប្រទេស និងផ្តល់ស្បៀង គ្រឿងសព្វាវុធ យុទ្ធភ័ណ្ឌដល់វៀតកុង និងវៀតណាមខាងជើងផង ហើយក្រុមហ៊ុនហាក់លី ជាអ្នកដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវដែលចេញពីភ្នំពេញ និងកំពង់ផែកំពង់សោម យកទៅឱ្យកងទ័ពយៀកកុងនៅពេលយប់ៗ។ ត្រង់ចំណុចនេះហើយ ដែលជាសញ្ញាណនាំឱ្យមានការមិនទុកចិត្តគ្នាកាន់តែខ្លាំងរវាងសម្តេចព្រះនរោត្តម សីហនុ និងសហរដ្ឋអាម៉េរិក។

សម្រាប់កំពង់ផែកំពង់សោមគឺជាចំណុចគោលដៅ សម្រាប់ដឹកអាវុធយុទ្ធភណ្ឌ មកផ្លូវលំហូជីមិញ។ ប៉ុន្តែ ក្រោយរដ្ឋប្រហារ ទីតាំងកំពង់សោម ត្រូវបានកាត់ផ្តាច់នោះ នាំឱ្យផ្លូវលំហូជីមិញ ត្រូវបានប្រើប្រាស់ខ្លាំងឡើង។ អាវុធយុទ្ធភណ្ឌត្រូវបានដឹកជញ្ជូន តាមផ្លូវនេះដោយឡាន និងកង់។ ផ្លូវនេះជាបណ្តាញផ្លូវគោក និងផ្លូវទឹកដ៏ស្មុគស្មាញ កាត់តាមប្រទេសឡាវប៉ែកខាងកើតតាមបណ្តោយព្រំដែនវៀតណាម-ឡាវ ដែលមកបែករសេមរសាមចូលតំបន់ខាងជើងនៃប្រទេសវៀតណាមខាងត្បូង និងតំបន់ពាយព្យនៃប្រទេសកម្ពុជាចម្ងាយជាង៧០០គីឡូម៉ែត្រ។

## ដំណាក់កាលទី៥
## នយោបាយប្តូរទិស និងការភ្ជាប់ទំនាក់ទំនងជាថ្មីជាមួយអាម៉េរិក

សម្តេចព្រះនរោត្តម សីហនុ បានប្រើប្តូរទិសពីគោលនយោបាយពីមុនទ្រង់បានផ្តើមផ្សារភ្ជាប់សម្ព័ន្ធមិត្តភាពការទូតជាថ្មីជាមួយសហរដ្ឋអាម៉េរិក ដោយអនុញ្ញាតឱ្យអាម៉េរិកទម្លាក់គ្រាប់បែកលើផ្លូវលំហូជីមិញ ហើយបានតែងតាំងលោកសេនាប្រមុខលន់ នល់ ដែលតែងតែប្រឆាំងនឹងលទ្ធិកុម្មុយនីស្តជានាយករដ្ឋមន្ត្រីថ្មីនាថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៦៦ ហើយលាលែងពីតំណែងវិញនៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៦៧។ នៅថ្ងៃទី២ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៦៧ មានដំណើរទស្សនកិច្ចមួយរបស់លោកជំទាវ Jacqueline Kennedy បានមកដល់ក្រុងភ្នំពេញ ដែលចាប់ពីពេលនោះបរិយាកាសរវាងអាម៉េរិក និងកម្ពុជាកាន់តែប្រសើរឡើងវិញ។

---

[323] អង្គការកតិ្តកាសញ្ញាវ៉ាសូវីបង្កើតឡើងនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៥ ហើយដួលរលំវិញនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩១។ ប្រទេសជាសមាជិកនៅអង្គការនេះមានដូចជា សហភាពសូវៀត, អាល់បានី, ប៊ុលហ្គារី, ឆេកូស្លូវ៉ាគី, អាល្លឺម៉ង់ខាងកើត, ហុងគ្រី, ប៉ូឡូញ និងរ៉ូម៉ានី។

[324] សន្និសីទក្រុងបានឌុងប្រទេសឥណ្ឌូណេស៊ីដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៨ ដល់២៤ ខែមេសា ឆ្នាំ១៩៥៥ នេះជាមូលហេតុដែលនាំទៅរកការបង្កើតចលនាមិនចូលបក្សសម្ព័ន្ធ។

វត្តមានរបស់លោកជំទាវគឺដើម្បីមកសម្ពោធមហាវិថី Jonh F.Kennedy នៅខេត្តកំពង់សោម ដែលក្រោយមកនាំឱ្យមានការបើកស្ថានទូតជាថ្មីឡើងវិញនាថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៦៩។

## ដំណាក់កាលទី៦

## ការផ្តាច់និរន្តរភាពនៃអព្យាក្រឹត

សម្តេចព្រះនរោត្តម សីហនុ បានថ្លែងថា«បើសិនជាខ្ញុំត្រូវចាប់ផ្តើមរឿងនេះឡើងវិញ ខ្ញុំមិនផ្តាច់ទំនាក់ទំនងជាមួយអាម៉េរិកកាំងទេ។ ការកាត់ផ្តាច់ជាមួយអាម៉េរិកកាំងនាំលក្ខណៈវិនាសសម្រាប់ខ្ញុំ...» និងសម្រាប់សេដ្ឋកិច្ចប្រទេសជាតិ។ ការផ្លាស់ប្តូរគោលនយោបាយរបស់សម្តេចព្រះនរោត្តម សីហនុ ទាំងអស់ពេលនោះគឺយឺតពេលទៅហើយក្នុងបញ្ចៀសគ្រោះមហន្តរាយដែរ។

ប្រជាជនខ្មែរ ដែលស្ថិតក្នុងរបបអព្យាក្រឹតមួយនេះ គឺមិនចង់រស់នៅក្រោម ឬ ក្លាយជាសមាជិករបស់មហាអំណាចមនោគមវិជ្ជាមួយណាឡើយ។ កម្ពុជាចង់ត្រឹមតែរស់ដោយសន្តិភាពមួយតាមមាគ៌ាសង្គមនិយមព្រះពុទ្ធសាសនា។ ការយកសាសនាជាមាគ៌ាគឺចង់ឱ្យមន្ត្រីធំៗយកធម៌ព្រះពុទ្ធជាធម៌អប់រំចិត្ត ដើម្បីកុំឱ្យជិះជាន់ប្រជាជនក្រីក្រ និងដើម្បីបន្សាបសង្គមនិយមមែនទែនផងដែរ។ ប៉ុន្តែ ប្រទេសជាតិបែរជាមានវត្តមានកងទ័ពវៀតកុងបានកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយវិស័យសេដ្ឋកិច្ចក៏ទទួលរងនូវវិបត្តិក្នុងអំឡុងឆ្នាំ១៩៦៧។ គោលនយោបាយជាតូបនីយកម្មសេដ្ឋកិច្ចធ្វើឱ្យហិរញ្ញវត្ថុសាធារណៈ ជាពិសេសថវិកាជាតិជួបនឹងឱនភាពរូបិយវត្ថុជាតិ«ប្រាក់រៀល» បាត់បង់តម្លៃបន្តិចម្តងៗ និងការគ្រប់គ្រងក្រុមហ៊ុនរដ្ឋគ្មានប្រសិទ្ធភាពផងដែរ។ ចំពោះក្រុមអ្នកនយោបាយស្រុកខ្មែរមួយចំនួន បានអស់ទំនុកចិត្តលើសម្តេចព្រះនរោត្តម សីហនុ និងក្រុមខ្លះទៀតក៏ចង់បានអំណាចពីសហរដ្ឋអាម៉េរិកផងបាន។ ដោយសារបញ្ហាទាំងនេះ គឺជាបុព្វហេតុនៃរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

សរុបមកនយោបាយអព្យាក្រឹតនេះហាក់មិននឹងនរឡើយ។ ចំពោះនយោបាយការបរទេសរបស់អាម៉េរិកអាចបានធ្វើឱ្យសម្តេចព្រះនរោត្តម សីហនុ ព្រួយបារម្ភផងដែរប្រសិនបើនៅជិតអាម៉េរិកនោះគឺ អាចមានវាសនាដូចលោកប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញឌៀម ដែលមិនស្តាប់អាម៉េរិកក្នុងឆ្នាំ១៩៦៣។ នៅឆ្នាំ១៩៦៣ សម្តេចព្រះនរោត្តម សីហនុ បានបដិសេធជំនួយរបស់អាម៉េរិក ព្រោះជំនួយនេះមានគោលដៅសម្រាប់តែបង្កើតចលនាគាំទ្រអាម៉េរិក។ ក្រោយពីការផ្តាច់ចំណងការទូតជាមួយនឹងសហរដ្ឋអាម៉េរិកឆ្នាំ១៩៦៥ ប្រទេសកម្ពុជាបានចាប់កុម្មុយនីស្តចិនដែលនៅឆ្នាំ១៩៦៦ ចិនក៏បានប្រើប្រាស់កំពង់ផែកំពង់សោម។ ក្រោយមក ប្រហែលជាសហរដ្ឋអាម៉េរិក មានការភ្ញាក់ខ្លួនដែលបានដើរក្រោយចិននោះ ទើបនៅឆ្នាំ១៩៦៧ អាម៉េរិកបានបញ្ជូនលោកជំទាវ Jacqueline Kennedy មកកម្ពុជាដើម្បីផ្សះផ្សា ប៉ុន្តែនោះហួសពេលបាត់ទៅហើយដែលសហរដ្ឋអាម៉េរិកកំពុងតែដើរពីក្រោយចិនផ្នែកនយោបាយការបរទេសនៅប្រទេសកម្ពុជា។

សរុបសេចក្តីមកនៅឆ្នាំ១៩៥០ សហរដ្ឋអាម៉េរិកទទួលស្គាល់កម្ពុជា ក្រោយខ្មែរបានឯករាជ្យឆ្នាំ១៩៤៩។ សម្រាប់ជំនួយសហរដ្ឋអាម៉េរិក កើនឡើងខ្លាំងក្រោយឆ្នាំ១៩៥៤។ ប៉ុន្តែឆ្នាំ១៩៥៥ មានចំណុចបត់មួយនៃសន្និសីទក្រុងបាឌុង ដែលធ្វើឱ្យសម្តេចព្រះ នរោត្តម សីហនុ ប៉ះទង្គិចជាមួយនឹងការទូតក្រអើតក្រទោមរបស់សហរដ្ឋអាម៉េរិក ហើយម្យ៉ាងទៀតគឺប្រទេសចិនប្រជាមានិត ដែលជាមហាអំណាចថ្មីចាប់ផ្តើមបង្កើតទំនាក់ទំនងល្អជាមួយកម្ពុជា។ នៅឆ្នាំ១៩៥៧ សហរដ្ឋអាម៉េរិក អូសទាញកម្ពុជាឱ្យចូលសេអាតូ ដែលពេលនោះកម្ពុជាបានចេញព្រះរាជក្រមប្រកាសពីអព្យាក្រិតភាពរបស់ខ្លួន។ នៅឆ្នាំ១៩៥៨ សហរដ្ឋអាម៉េរិក បាននៅពីក្រោយវត្តមានវៀតណាមចូលលុកលុយភាគឦសាននៃខេត្តស្ទឹងត្រែង (បច្ចុប្បន្ន ជាស្រុកបរកែវ រតនគិរី)។ ចំណុច

នេះគឺសហរដ្ឋអាម៉េរិក បានបង្កហេតុឆ្នាំ១៩៥៨ដោយមិនបានប៉ះផ្ទាល់ជាមួយខ្មែរទេ ព្រោះវៀតណាមបានចូលរួមជាសង្គ្រាមតំណាង។ ចាប់ពីពេលនោះមកឃើញថា នយោបាយការទូតរបស់សហរដ្ឋអាម៉េរិកបានដើរពីក្រោយចិនសម្រាប់ទំនាក់ទំនងការទូតជាមួយប្រទេសកម្ពុជារហូតដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

## ៨-ស្ថានភាពសង្គមខ្មែរ និងការអភិវឌ្ឍជនបទ

នៅក្នុងសមិទ្ធផលផ្នែកវិស័យរដ្ឋបាល រដ្ឋាភិបាលសង្គមរាស្ត្រនិយមបានផ្តោតការយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍជនបទដាច់ស្រយាល។ ដើម្បីឆ្លើយតបនឹងផែនការអភិវឌ្ឍនេះ រដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើត ឃុំ ស្រុក ខេត្តថ្មី នៅតាមជាយដែននៃប្រទេសកម្ពុជា។ នៅតាមព្រំដែនភាគខាងលិចជាប់សមុទ្រ គេបានបង្កើតខេត្តថ្មីមួយគឺខេត្តកោះកុង ហើយក្រុងកំពង់សោម ត្រូវបានដូរឈ្មោះទៅជាក្រុងព្រះសីហនុវិញ។ ចំណែកនៅប៉ែកឦសាន្តប្រទេសកម្ពុជាឯណោះវិញគេក៏ឃើញមានការបង្កើតខេត្តថ្មីផងដែរដូចជាខេត្តរតនគិរីមានទីតាំងស្ថិតនៅអណ្តូងពេជ្រ និងមានខេត្ត និងស្រុកជាច្រើនទៀតបានបង្កើតថ្មីដើម្បីងាយស្រួលក្នុងការគ្រប់គ្រងផ្នែករដ្ឋបាល និងធ្វើការអភិវឌ្ឍ។ នៅឆ្នាំ១៩៥៥ ដើម្បីរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខ ក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលបានចាត់វិធានការមិនអនុញ្ញាតឱ្យប្រជាពលរដ្ឋលេងល្បែងស៊ីសងជាដាច់ខាត។

សម្តេចព្រះ នរោត្តម សីហនុ ជាពុទ្ធសាសនិកដ៏ឆ្នើម ដែលទ្រង់បានយកចិត្តទុកដាក់ក្នុងការកសាងវត្តអារាម ជាឱកាសដល់ព្រះសង្ឃបានរៀនសូត្រផងដែរ។ ការរស់នៅតាមសីលធម៌ខាងព្រះពុទ្ធសាសនាដែលអប់រំឱ្យស្រឡាញ់គ្នា។ យុវជនប្រុសៗធំដឹងក្តីនៅក្នុងភូមិត្រូវតែបួស។ បួសគឺជាការអប់រំចិត្តយើងឱ្យនៅក្នុងគន្លងព្រះពុទ្ធសាសនា ដូចនេះគេទទួលបានសីលធម៌ស្រឡាញ់គ្នានៅក្នុងសង្គម។ ទីវត្តអារាមជាថ្នាលសម្រាប់អប់រំកូនខ្មែរឱ្យក្លាយជាពលរដ្ឋល្អទាំងអស់។

## ៩-សមិទ្ធផល[325] និងស្ថានភាពសង្គមខ្មែរចុងសម័យសង្គមរាស្ត្រនិយម

សមិទ្ធផល និងស្ថានភាពសង្គមខ្មែរនៅចុងសម័យសង្គមរាស្ត្រនិយមគឺជាសម័យកាលដែលបានផ្តោតលើកិច្ចកសាងជាតិដ៏សំខាន់ដោយផ្អែកលើការពង្រីកសង្គមកិច្ច, វប្បធម៌, ហេដ្ឋារចនាសម្ពន្ធ និងសេដ្ឋកិច្ច។ ក្នុងវិស័យអប់រំ និងវប្បធម៌ មានការពង្រីកគ្រឹះស្ថានសិក្សាពីបឋមរហូតដល់សាកលវិទ្យាល័យ។ ជាមួយនឹងការកើនឡើងចំនួននិស្សិតសរុបដល់៧ ១៣១នាក់(ប្រុស) និង៨០៥ នាក់(ស្រី) នៅក្នុងឆ្នាំ១៩៦៦ ហើយយុទ្ធនាការអក្ខរកម្មបានផ្តល់វិញ្ញាបនបត្រដល់២៦៩ ៤៨៤នាក់ត្រឹមដំណាច់ឆ្នាំ១៩៦៦។ ផ្នែកសុខាភិបាលមានផ្ទះពេទ្យសាធារណៈ និងឯកជនសរុប ៤៩៨ខ្នង។ ចំណែកឯកីឡាវិញ ព្រះរាជាណាចក្រកម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាវុឌ្ឍិកនវពល(GANEFO) នៃទ្វីបអាស៊ី នាចុងឆ្នាំ១៩៦៦ ដែលកីឡាករខ្មែរទទួលបានមេដាយមាសចំនួន១៣គ្រឿង។ ទាក់ទងនឹងហេដ្ឋារចនាសម្ពន្ធសំខាន់ៗ មានការស្ថាបនាផ្លូវថ្នល់ក្រាលកៅស៊ូសរុប២ ៥១២គីឡូម៉ែត្រ(ត្រឹមខែវិច្ឆិកា ឆ្នាំ១៩៦៦), ការពង្រីកកំពង់ផែព្រះសីហនុជិតរួចរាល់ ៩០ ភាគរយ និងការបន្តស្ថាបនាផ្លូវរថភ្លើងភ្នំពេញ-ក្រុងព្រះសីហនុប្រវែង២៦៣គីឡូម៉ែត្រ។ នៅក្នុងវិស័យសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើកសិកម្ម ដោយផលស្រូវបានកើនឡើងពី១ ៤៨៤ ០០០តោន (ឆ្នាំ១៩៥៥) ដល់៣ ២៥០ ០០០ តោន(ឆ្នាំ១៩៦៨)។ រីឯឧស្សាហកម្មជាតិវិញ មានការសាងសង់រោងចក្រ

[325] សូមមើល : ស្នាដៃនៃសង្គមរាស្ត្រនិយម សម្រាប់ដាក់ជូនសមាជជាតិនាថ្ងៃទី ២២ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៦៦ និងក្រសួងអប់រំ យុវជន និងកីឡា, *សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រខ្មែរសម្រាប់ជំនួយដល់សិស្សថ្នាក់ទី១២*, ឆ្នាំ២០១៧។

សំខាន់ៗជាច្រើនដូចជារោងចក្រវាយនភណ្ឌ, ក្តារបន្ទះ, កែវ, ស៊ីម៉ងត៍ និងរោងចក្រដំឡើងត្រាក់ទ័រ ព្រមទាំងមានគ្រឹះស្ថានឧស្សាហកម្មឯកជនធុនមធ្យម និងតូចៗប្រហែល៣ ៥០០កន្លែង។

ទោះបីយ៉ាងនេះក្តី ស្ថានភាពសង្គមខ្មែរនៅចុងសម័យសង្គមរាស្ត្រនិយមបានប្រឈមនឹងវិបត្តិសេដ្ឋកិច្ចផ្ទៃក្នុងគឺក្រុមហ៊ុនរដ្ឋទាំងឡាយត្រូវបានគ្រប់គ្រងដោយគ្មានប្រសិទ្ធភាព ដែលបណ្តាលឱ្យហិរញ្ញវត្ថុសាធារណៈជួបឱនភាព និងរូបិយវត្ថុជាតិ(ប្រាក់រៀល) បាត់បង់តម្លៃបន្តិចម្តងៗ ព្រមទាំងមានបញ្ហាបោះបង់ចោលជំនួយយោធាអាម៉េរិកក្នុងឆ្នាំ១៩៦៣ ដែលមានតម្លៃស្មើនឹង១៥ភាគរយនៃថវិកាជាតិ។ ចាប់ពីឆ្នាំ១៩៦៧ ដល់១៩៦៨ សេដ្ឋកិច្ចជាតិមានដំណើរការរាំងស្ទះយ៉ាងខ្លាំង រហូតដល់រដ្ឋប្រហាឆ្នាំ១៩៧០។

**១០-សំណួររត្រិះរិះ**

១-ហេតុដូចម្តេចបានជាសម្តេចព្រះ នរោត្តម សីហនុ បង្កើតអង្គការនយោបាយសង្គមរាស្ត្រនិយម ?

២-ដូចម្តេចដែលហៅថាសមាជជាតិ ? តើសមាជជាតិបានផ្តល់នូវផលអ្វីខ្លះដល់កម្ពុជានាសម័យនោះ ?

៣-ចូរពន្យល់ពីមូលហេតុដែលនាំឱ្យមានការតែងតាំងសម្តេចនរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋនៅឆ្នាំ១៩៦០?

៤-ចូររៀបរាប់អំពីសមិទ្ធផលសង្គមរាស្ត្រនិយម។

៥-ចូររៀបរាប់អំពីនយោបាយអព្យាក្រឹត និងផលវិបាកនៃការប្រកាន់នយោបាយអព្យាក្រឹត។

# មេរៀនទី១១ សម័យសាធារណរដ្ឋខ្មែរ(ពីឆ្នាំ១៩៧០ ដល់១៩៧៥)

## ១-ការលេចឡើងនៃរបបសាធារណរដ្ឋខ្មែរ

សន្និសីទហ្សឺណែវឆ្នាំ១៩៥៤ ស្ដីពីឥណ្ឌូចិនបានរំលត់ភ្លើងសង្គ្រាមអស់មួយរយៈដែរចំពោះប្រទេសកម្ពុជា។ ប៉ុន្តែ នៅប្រទេសលាវ និងប្រទេសយួនឯណោះវិញ សង្គ្រាមបានបន្តទៅទៀតដោយមានទំនាស់នៅក្នុងការរៀបចំនយោបាយសម្រាប់ប្រទេសលាវ ពីព្រោះបំណងធំរបស់យួនគឺ បង្រួបបង្រួមវៀតណាមខាងត្បូងទៅជាវៀតណាមខាងជើង ពុំអាចធ្វើកើតចំពោះយួន[326]។ ប្រតិបត្តិការសឹកនៃសង្គ្រាមឥណ្ឌូចិនបានឆាបឆេះនៅឆ្នាំ១៩៦៧។ ការបះបោររបស់កសិករនៅសំឡូត និងការជ្រៀតជ្រែកពីវៀតកុង គឺជាការបង្ហាញឱ្យឃើញនូវការបែកបាក់គ្នា ខាងនយោបាយយ៉ាងជ្រាលជ្រៅរបស់មេដឹកនាំ អ្នកនយោបាយ ជាន់ខ្ពស់នៅក្នុងសង្គមកម្ពុជា។ នៅពេលនោះក៏មានការបែកបាក់គ្នាជា៣ក្រុមនៅក្នុង«គំនិត»របស់មហាជនខ្មែរគឺខាងរាជាធិបតេយ្យ, លោកសេរី និងកុម្មុយនីស្ត ដែលនាំឱ្យជោគវាសនានៃការដឹកនាំប្រទេសបានរបូតពីដៃខ្មែរ។ សង្គ្រាមបានឆាបឆេះនៅលើទឹកដីខ្មែរ ដោយការប្រណាំងប្រជែងគ្នារបស់លោកសេរី និងកុម្មុយនីស្ត។ ជាពិសេសរវាងសហរដ្ឋអាម៉េរិកជាមួយវៀតណាមខាងជើង និងវៀតកុង តែសង្គ្រាមនេះបានទម្លាក់មកលើទឹកដីកម្ពុជា រួចរុញច្រានសង្គ្រាមនោះឱ្យក្លាយជាសង្គ្រាមស៊ីវិលនៅកម្ពុជា(១៩៧០-១៩៧៥)។

នៅទស្សវត្សរ៍ ឆ្នាំ១៩៦០ និងដើមទស្សវត្សរ៍ ឆ្នាំ១៩៧០ស្ថានភាពនយោបាយរបស់កម្ពុជាកើតរូបភាពរឹកវរគ្រប់កន្លែងដោយការដែលមិនពេញចិត្តនឹង របបគ្រប់គ្រងរបស់សម្ដេចព្រះនរោត្តម សីហនុ។ ការធ្វើរដ្ឋប្រហារផ្ដួលរំលំអំណាចរបស់សម្ដេចព្រះនរោត្តម សីហនុដោយសារ ឧត្តមសេនីយ៍ លន់ នល់ និងព្រះអង្គម្ចាស់សិរិមតៈមានទំនាស់ជាមួយសម្ដេច។ ដោយសារសម្ដេចនិយមប្រើអំណាចផ្ទាល់ខ្លួន លើកស្ទួយនយោបាយអព្យាក្រឹត ក្នុងសម្ពន្ធភាពបរទេសដែលតែងលំអៀងទៅខាងកុម្មុយនីស្តលើកស្ទួយសេដ្ឋកិច្ច បែបសង្គមនិយម។ ចំណែកឯ ទ្រង់សិរិមតៈ និងលោក លន់ នល់ មាននយោបាយផ្នែកសេដ្ឋកិច្ច និងសម្ពន្ធភាពបរទេសលំអៀងចូលខាងសហរដ្ឋអាម៉េរិកច្រើនជាង ចំណុចសំខាន់ដែលធ្វើឱ្យភាគីក្រោយបានជ្រាបលើ ភាគីដំបូងគឺ សម្ដេចសីហនុ យល់ព្រមឱ្យកងកម្លាំងវៀតណាមកុម្មុយនីស្តប្រើដែនដីកម្ពុជាតំបន់ព្រំដែនជាប់នឹងប្រទេសវៀតណាមជាច្រើនកន្លែងជាមូលដ្ឋានប្រតិបត្តិការ ឬ ជាកន្លែងលាក់ខ្លួនដើម្បីធ្វើសង្គ្រាមទ័ពព្រៃនៅប្រទេសវៀតណាមខាងត្បូងដែលគាំទ្រ ដោយសហរដ្ឋអាម៉េរិក។ មុនពេលដណ្ដើមអំណាចលោក លន់ នល់ និងទ្រង់ សិរិមតៈ បានប្រមូលអ្នកស្រុកជាច្រើនកន្លែង ក្នុងខេត្តស្វាយរៀងប្រជុំគ្នាដើរក្បួនប្រាប់ឱ្យរដ្ឋាភិបាលសីហនុ បញ្ជូនទាហានចូលទៅបណ្ដេញកុម្មុយនីស្តវៀតណាមឱ្យចេញពីទឹកដីកម្ពុជា។ មានការទាមទារដូចគ្នាឆ្លងតាមការផ្សាយព័ត៌មានផ្សេងៗ នៅក្នុងក្រុងភ្នំពេញផងដែរ។ តំណាងរបស់ CIA ចូលទៅណែនាំនៅក្នុងស្ថានការណ៍បង្កើតនូវភាពតានតឹង ដែលនាំទៅដល់ការដណ្ដើមអំណាចនៅ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ដោយនៅពេលបានស្ថានភាពតានតឹងភាគីលោក លន់ នល់ និងទ្រង់សិរិមតៈ ក៏អាចប្រើរដ្ឋសភាដកអ្នកដឹកនាំប្រទេស ដោយការបញ្ចូលមតិអាចកំបាំងក្នុងពេលដែលកងកម្លាំងរថក្រោះរបស់លោក លន់ ណុន បានឡោមព័ទ្ធអគាររដ្ឋសភារួចរាល់អស់ហើយ។ ពេលដែលប្រតិបត្តិការដណ្ដើមអំណាចពេលចុងក្រោយនោះសម្ដេចព្រះ នរោត្តម សីហនុស្ថិតនៅចន្លោះការធ្វើដំណើរទស្សនកិច្ចនៅបរទេស ដែលកំពុងធ្វើដំណើរចេញពីក្រុងមូស្គូទៅក្រុងប៉េកាំង[327]។

---

[326] សាំង ម៉ាក់សាង, *កូសាំងស៊ីន ជាដែនដីរបស់ខ្មែរត្រូវប្រគល់ឱ្យខ្មែរវិញ* , ឆ្នាំ១៩៧៣, ទំព័រ៨៥ ។

[327] Norodom Sihanouk, *My War with the CIA* ( Penguin Book, 1973 ) , pp-36-59។

ក្រោយពីរដ្ឋាភិបាលបានបោះឆ្នោតគាំទ្រ៨៦សំឡេង និងប្រឆាំង៣សំឡេងក្នុងការដកសេចក្តីទុកចិត្តលើសម្តេចព្រះ នរោត្តម សីហនុ និងដកពីតំណែងជាប្រមុខរដ្ឋដោយដាក់លោក ចេង ហេង ដែលជាប្រធានសភាជំនួសវិញ រហូតដល់មានការបោះឆ្នោតជ្រើសរើសប្រមុខរដ្ឋថ្មី។ ដោយធ្វើទៅតាមច្បាប់រដ្ឋធម្មនុញ្ញ ជាពិសេសរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋលើកនេះដោយត្រូវតែងប្រធានាធិបតីនិងបន្ទាប់ពីការរៀបចំការ បោះឆ្នោតនីតិបញ្ញត្តិរួចនោះលោក លន់ នល់ បានទទួលអំណាចទាំងអស់ និងបង្កើត «ការរួបរួម» មួយជាមួយទ្រង់សិរិមតៈជាថ្មី[328]។ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាព្រឹត្តិការណ៍ផ្លាស់ប្តូរមេដឹកនាំដែលដូរពី សន្តិភាពឆ្ពោះទៅរកសង្គ្រាមផ្ទៃក្នុង និងជា «បុព្វហេតុផ្ទាល់»នៃសង្គ្រាម។ ចំពោះព្រឹត្តិការណ៍នេះម្ខាងៗអះអាងថាធ្វើតាមរដ្ឋធម្មនុញ្ញ[329]។ ការដែលទម្លាក់សម្តេចសីហនុគឺយោងទៅតាមមាត្រា១២២នៃរដ្ឋធម្មនុញ្ញ។ នៅក្នុងមាត្រានេះបានចែងថា ក្នុងកាលៈទេសៈ មិនអនុញ្ញាតឱ្យចាត់តាំងព្រះមហាក្សត្រថ្មី ឬ ចាត់តាំង ព្រះរាជានុសិទ្ធសភាទាំងពីរ គឺរដ្ឋសភានិងក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជាអាចកោះប្រជុំ ហើយអាចប្រគល់មុខតំណែងប្រមុខរដ្ឋដល់ឥស្សរជនដែលពុំមានគេជំទាស់ និងដែលសមតាមបំណង[330] ។ បើយោងតាមសៀវភៅរបស់សម្តេចព្រះនរោត្តមសីហនុចំណងជើងថា « La C.I.A. contre le Cambodge, 1973» មានខ្លឹមសារថា ថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៦០ប្រជាមតិថ្នាក់ជាតិមួយមានការយល់ព្រមពីប្រជាជនជាង២លាននាក់...។ តាមមាត្រា១២វិសោធនកម្ម គឺ«ប្រមុខរដ្ឋមានអំណាច និងបុព្វសិទ្ធិជាព្រះមហាក្សត្រ»។ រដ្ឋសភាបានយល់ព្រម នៅថ្ងៃទី៩ ខែមិថុនា ហើយនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៦០ ព្រះអង្គត្រូវបានជ្រើសតាំងក្នុងតំណែងថ្មីជាប្រមុខរដ្ឋជាឯកច្ឆន្ទ។ ដូច្នេះ បើតាមសម្តេចព្រះនរោត្តម សីហនុនៅក្នុងសៀវភៅខាងលើនេះ រដ្ឋសភា មិនអាចទម្លាក់ព្រះអង្គបានទេ។

មាត្រា**១២២** ជាមូលដ្ឋានមួយដែលលើកសម្តេចព្រះ នរោត្តម សីហនុឱ្យសោយរាជ្យ និងក៏ជាមូលដ្ឋានដែលគេទម្លាក់ សម្តេចព្រះនរោត្តម សីហនុ ដែរ។ នៅថ្ងៃទី២០ ខែមីនា ក្នុងសេចក្តីថ្លែងការណ៍ដ៏វែង និងដ៏ស្រពេចស្រពិលមួយដែលចែកផ្សាយដល់បណ្តាសារព័ត៌មានសម្តេចបានអះអាងថា ការទម្លាក់ព្រះអង្គពីមុខតំណែងគឺ «ផ្ទុយនឹងរដ្ឋធម្មនុញ្ញ និងមិនស្របច្បាប់» ព្រោះថា ក្នុងរដ្ឋធម្មនុញ្ញរបស់យើងពុំមានបញ្ញត្តិណាមួយដែលអនុញ្ញាតឱ្យសភាទាំងពីរ និងរដ្ឋាភិបាលទម្លាក់ប្រមុខរដ្ឋដែលតែងតាំងដោយដាក់លាក់អស់មួយជីវិតវិញឡើយ ហើយ ព្រះមហាក្សត្រ និងព្រះប្រមុខរដ្ឋត្រូវបានប្រកាសយ៉ាងច្បាស់ដោយច្បាប់រដ្ឋធម្មនុញ្ញថាជា «អង្គព្រះមហាក្សត្រជាទីគោរពសក្ការៈនរណានឹងល្មើសពុំបាន» ដែលតាមរដ្ឋធម្មនុញ្ញដដែល នេះថារាល់បញ្ហាវិវាទ ទាំងអស់ដែលមានលក្ខណៈជាតិ អាចត្រូវដោះស្រាយតាមរយៈធ្វើ ការបោះប្រជាមតិ(Rfrendum) ប៉ុណ្ណោះ[331]។ ប្រាកដណាស់ថានៅពេលដែលព្រះមហាក្សត្រិយ៍ឡើងសោយរាជ្យគឺអត់មានក្នុងរដ្ឋធម្មនុញ្ញ ដូច្នេះមានតែធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នាឆ្នាំ១៩៦០ ដើម្បីបង្កើតតំណែងប្រមុខរដ្ឋដែលមានអំណាចស្មើព្រះមហាក្សត្រដោយមិនអាចមាននរណាម្នាក់អាចប៉ះបាន។ នៅក្នុងចំណុចនេះហើយដែលត្រូវបានអ្នកគាំទ្រសម្តេចព្រះនរោត្តមសីហនុ ចោទក្រុមលន់ នល់ ថាបានធ្វើរដ្ឋប្រហារ ចំណែកអ្នកគាំទ្រខាង នល់ នល់ ថានេះជារឿងស្រប

---

[328] Ros Chantrabot, *សាធារណរដ្ឋខ្មែរ (Ros, C. (1993). La République khmère:(1970-1975). L'Harmattan)*, ប្រែសម្រួលដោយ ទី យាយុ, ឆ្នាំ( ? ), ទំព័រ ៥៧។

[329] ចំពោះព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ម្ខាងៗអះអាង និងយល់ថាខ្លួនត្រូវនោះហើយទើបនាំឱ្យសង្គ្រាមកើតឡើងអស់រយៈពេលប្រាំឆ្នាំដោយមិនមានការចរចា។

[330] សៅ ឆាត, *វិបត្តិកម្ពុជា*, ឆ្នាំ១៩៩៤, ទំព័រ៤៨។

[331] Charles Meyer, *ក្រោមស្នាមញញឹមរបស់ខ្មែរ*, ដ.ឯ.ម., ទំព័រ៣៥១-៣៥២។

ច្បាប់ដោយយោងតាមមាត្រាទី១២២ ដែលរដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបន្ថែមនូវបទបញ្ញត្តិពិសេសជាឧបសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៦០ [332]។

ក្រោយការទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីប្រមុខរដ្ឋនាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ប្រទេសកម្ពុជាត្រូវបានប្រកាសជាសាធារណរដ្ឋនៅ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧០ វេលាម៉ោង៧ព្រឹក តាមរយៈ ក្រមលេខ ៤៤២/៧០-ប.រ. ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧០ ហើយពិធីដ៏អធិកអធមមួយនេះត្រូវបានរៀបចំប្រព្រឹត្តទៅនៅមុខព្រះបរមរាជវាំង។ លោកសេនាប្រមុខ លន់ នល់ ក៏ត្រូវបានតែងតាំងជាប្រធានាធិបតីសាធារណរដ្ឋខ្មែរដំបូងបង្អស់។ នៅពេលនោះគេបានបង្កើតរដ្ឋធម្មនុញថ្មីមួយដែលត្រូវបានសម្រេចយកមកប្រើនៅក្រោយប្រជាមតិថ្ងៃទី៣០ ខែ មេសា ឆ្នាំ១៩៧២។

ក្នុងខណៈពេល ដែលរដ្ឋធម្មនុញ្ញថ្មីពុំទាន់បានរៀបចំនៅឡើយគេនៅបន្តប្រើប្រាស់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ លើកលែងតែបទបញ្ញត្តិដែលផ្ទុយនឹងគោលការណ៍នៃរបបសាធារណរដ្ឋ។ បន្ទាប់មកសាធារណរដ្ឋខ្មែរ ក៏បានចាត់ចែងទៅតាមនីតិវិធីរៀបចំឱ្យមានការបោះឆ្នោតអ្នកតំណាងរាស្ត្រនាថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧២ និងព្រឹទ្ធសភាទី១នាថ្ងៃទី១៧ ខែកញ្ញាឆ្នាំ១៩៧២[333] ដែលអាសនៈទាំងអស់នៃសភាជាតិត្រូវបានទៅលើគណបក្សសង្គមសាធារណរដ្ឋ[334]ដោយសារតែគណបក្សអ្នកសាធារណរដ្ឋ[335] និងគណបក្ស ប្រជាធិបតេយ្យ[336]មិនចូលរួមប្រកួត។ ក្រោយបានឡើងកាន់អំណាចសាធារណខ្មែរ បានក៏រៀបចំ គោលនយោបាយរបស់ខ្លួនជាមួយប្រទេសជិតខាង នយោបាយប្រទេសជាតិ និងនយោបាយសេដ្ឋកិច្ចរបស់ខ្លួន និងរបៀបគ្រប់គ្រងនៃប្រទេសដែលនយោបាយទាំងនោះមានអត្ថន័យសង្ខេបថា «គោលនយោបាយសំខាន់ៗរួមមាននយោបាយជាមួយប្រទេសជិតខាងដែលត្រូវប្រកាន់ខ្ជាប់នូវភាពជាមិត្តភាពខណៈដែលនយោបាយប្រទេសជាតិ គឺផ្តោតលើអព្យាក្រឹត ឯករាជ្យ និងការរៀបចំការពារជាតិឱ្យបានមាំមួន ដើម្បីបង្ការការឈ្លានពានពីពួកវៀតណាមខាងជើង ពួកវៀតកុង និងប៉ាថេតឡាវ ក៏ដូចជាធានាថាមិនមានជាតិណាមួយឈ្លានពានកម្ពុជាតាមអំពើចិត្តទៀតឡើយ។ ចំណែកឯនយោបាយសេដ្ឋកិច្ចរបស់ប្រទេសវិញ គឺជារបៀបបើកចំហជាមួយនឹងបរទេសជាមិត្ត និងសហការគ្នាក្នុងចំណោមភូមិភាគជាមួយគ្នា ក្នុងគោលបំណងក្រេបជញ្ជក់យកបច្ចេកទេសសម័យ ដើម្បីឱ្យប្រទេសជាតិរីកចម្រើនបានឆាប់។ របៀបគ្រប់គ្រងនៃប្រទេសគឺផ្អែកលើគោលការណ៍ សេរីភាព មនុស្សមានសិទ្ធិភាពស្មើគ្នា និងភាតរភាព ដោយមានគោលដៅចម្បងដើម្បីធានាឱ្យកូនចៅខ្មែរចំនួន៤៥លាននាក់ នៅឆ្នាំ ២០២០ បានក្លាយជាមនុស្សមានសេរីភាព ចេះដឹងពីរបៀបរៀបរយត្រឹមត្រូវ និងមានបានគ្រប់ៗគ្នាផង»[337]។

សាធារណរដ្ឋនិយម ជារបៀបរស់នៅយ៉ាងសម័យនិយមរបស់សង្គមជាតិនៅក្នុងទ្វីប។ មនុស្សក្នុងប្រទេសក្នុងឋានៈស្មើគ្នា គ្មានរាស្ត្រ គ្មានស្តេច ក្នុងសេរីភាព ក្នុងមិត្តភាព ខ្នះខ្នែងជាមួយគ្នារៀបរៀងតាមរបៀបច្បាប់

---

[332] ការបកស្រាយរដ្ឋធម្មនុញ្ញគឺតាមការយល់ឃើញរៀងៗខ្លួន។

[333] ការបោះឆ្នោតជ្រើសរើសព្រឹទ្ធសភា លែងមានក្រុមប្រឹក្សាព្រះរាជាណាចក្រហើយ ព្រោះដូរមកសាធារណរដ្ឋ។ រដ្ឋប្រហារឆ្នាំ១៩៧០គឺជាការប្រើកម្លាំងមនុស្សមួយក្តាប់តូចផ្តួលរំលំរដ្ឋអំណាចចាស់ ហើយមកជំនួសរដ្ឋអំណាចចាស់វិញ។ ប៉ុន្តែដើម្បីឱ្យព្រឹត្តិការណ៍នេះក្លាយទៅជាស្របច្បាប់នោះ នៅឆ្នាំ១៩៧២ គេមានការបោះឆ្នោតជ្រើសរើសសភា២គឺព្រឹទ្ធសភា និងរដ្ឋសភា។ ទោះបីជាបែបនេះក៏ដោយ ក៏នៅតែមានការអះអាងថា រដ្ឋអំណាចថ្មីរបស់ លន់ នល់ មិនស្របច្បាប់ឡើយ ទោះបីជាយកសភាទាំងពីមកប្រើក៏ដោយ ប៉ុន្តែនេះជាការរំលោភច្បាប់ធម្មនុញ្ញ។

[334] គណបក្សនេះជារបស់លោក លន់ ណុន ប្អូនប្រុសលោក លន់ លន់។

[335] គណបក្សនេះជារបស់ទ្រង់ សិរិមតៈ។

[336] គណបក្សនេះជារបស់លោក អ៊ិន តាំ។

[337] សូមមើល : ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៥២២-៥២៣។

ប្រជាធិបតេយ្យ របៀបគ្រប់គ្រងរដ្ឋរបស់ខ្លួន។ ប្រធានាធិបតី ត្រូវជ្រើសរើសតាមរបៀបណាមួយសម្រាប់កំណត់១ឆ្នាំ (ស្រេចនឹងសម្រេចគ្នា) ហើយជ្រើសរើសទៀតនូវតំណាងរាស្ត្រ ក្រុមប្រឹក្សា និងផ្នែកតំណាងការងារផ្សេងៗ។

ជាមួយគ្នានេះដែរនឹងមានរដ្ឋាភិបាលដែលត្រូវតែងតាំង ហើយទទួលខុសត្រូវនៅចំពោះមុខសភាជាតិ ព្រមទាំងមានអគ្គស្នងការទាំងឡាយជាអំណាចផង សម្រាប់អនុវត្តការងារពិសេសខ្លះ មានចំនួនសម្រាប់ឱ្យបានរៀបដំណើរការសេដ្ឋកិច្ច និងជីវភាពរបស់ប្រទេសឱ្យបានមានល្បឿនជាក់ស្តែងបាន។ អគ្គស្នងការទាំងនោះមានដូចជា អគ្គស្នងការដ្ឋាននៃផែនការ, អគ្គស្នងការដ្ឋាននៃយុវជន, អគ្គស្នងការដ្ឋាននៃអតីតយុវជន, អគ្គស្នងការដ្ឋាននៃការស្រាវជ្រាវផ្នែកកសិកម្ម, អគ្គស្នងការដ្ឋាននៃដំណាំស្រូវ, អគ្គស្នងការដ្ឋាននៃដំណាំកៅស៊ូ, អគ្គស្នងការដ្ឋាននៃការចិញ្ចឹមសត្វ, អគ្គស្នងការដ្ឋាននៃប្រមាញ់ និងនេសាទ, អគ្គស្នងការដ្ឋាននៃការបង្កើនផលិតផលឱសថ និងអគ្គស្នងការដ្ឋាននៃទេសចរណ៍។ នៅឆ្នាំ១៩៧២សាធារណរដ្ឋខ្មែរបានចេញក្រឹត្យស្តីពីការកំណត់ព្រំប្រទល់ខ្ពង់រាបដែនសមុទ្ទខ្មែរ[338]។

**ទង់ជាតិក្នុងរបបនេះមានអត្ថន័យ**[339]

| ទង់ជាតិ | អត្ថន័យ |
|---|---|
|  | – ពណ៌ខៀវ តំណាងឱ្យសីលធម៌។<br>– ពណ៌ក្រហម តំណាងឱ្យទឹកចិត្តអង់អាចក្លាហាន មោះមុត។<br>– ពណ៌ស ជានិមិត្តរូបនៃភាពបរិសុទ្ធទៀងត្រង់ តំណាងឱ្យព្រះពុទ្ធសាសនា។<br>– ប្រាសាទ ជានិមិត្តរូបនៃអារ្យធម៌។<br>– រូបផ្កាយទាំងបី មានន័យថា ជាតិ សាសនា សាធារណរដ្ឋ (ត្រីបាវចនា), ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ(រតនត្រ័យ)និងអំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ តុលាការ(អំណាចទាំងបី)។ |

## ២-សង្គម សេដ្ឋកិច្ច នយោបាយ និងវប្បធម៌សម័យសាធារណរដ្ឋខ្មែរ

សង្គមខ្មែរក្នុងរបបសាធារណរដ្ឋ បានក្លាយទៅជាសង្គមពុករលួយដែលមានលក្ខណៈ ធំជាងសម័យរាស្ត្រនិយមទៅទៀតដោយសារតែក្រុមអ្នកពុករលួយ បក្សពួក អ្នកបង្កើតភាពអយុត្តិធម៌សង្គមទាំងអស់នោះបានបន្តឆ្លៀតឱកាសរកផលសម្រាប់ខ្លួនគ្រួសារ និងបក្សពួកខ្លួនបន្តទៀត។ យើងដឹងហើយថាព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាការប្តូរមេដឹកនាំ ដូច្នេះមន្ត្រីរាជការទាំងអស់នោះបន្តនៅកាន់អំណាចសម័យសាធារណរដ្ឋខ្មែរ ហើយមន្ត្រីរាជការមួយចំនួននោះ ធ្លាប់មានឈ្មោះស្អុយរលួយរួចទៅហើយក្នុងសម័យសង្គមរាស្ត្រនិយមដែលម្នាក់ខំស្រវាំតាមតែខ្លួនចង់បាន ព្រោះសម័យនោះជាកាលមួយដែលអាម៉េរិកកំពុងផ្តល់ជំនួយយ៉ាងសន្ធឹកសន្ធាប់ក្នុងការធ្វើសង្គ្រាមទប់ទល់នឹងកុម្មុយនីស្ត ហើយអំពើពុករលួយដែលលេចធ្លោជាងគេនោះ

[338] ក្រឹត្យ, *ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ លេខ៤៣៩-៧២-បសខ,* ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៧២។

[339] យោងតាមការប្រកាសឱ្យប្រើច្បាប់រដ្ឋសភាដែលបានអនុម័តជាលើកទី២នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧១(សូមមើលរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ នាថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២)។

គឺការឃុបឃិតគេងប្រវ័ញ្ចយកប្រាក់បៀវត្សរ៍ទាហាន[340]។ ក្រោយរដ្ឋប្រហារមិនបានប៉ុន្មានថ្ងៃផង នៅរដ្ឋធានីភ្នំពេញលេចឡើងនូវចោរលួចឆក់ ជាច្រើនកន្លែងដែលបង្ហាញពីភាពឆ្លៀតឱកាសដែលបង្កឱ្យមានអសន្តិសុខសង្គម។

ចំពោះវិស័យសេដ្ឋកិច្ចគឺមិនមានមូលដ្ឋានច្បាស់លាស់ទេរស់ ដោយសារតែជំនួយរបស់សហរដ្ឋអាម៉េរិកដែលវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះកើតឡើងជាបន្តបន្ទាប់ ដោយសារតែសាធារណរដ្ឋខ្មែរកើតឡើងក្នុងសភាពចៃដន្យមួយគ្មានព្រៀងទុក គ្មានគម្រោងរៀបចំច្បាស់លាស់ត្រឹមត្រូវ និងគ្មានការពិចារណា។ ចំពោះសេដ្ឋកិច្ចនេះលោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ ក៏បានរៀបរាប់ថា[341] នៅសម័យនោះមិនមានសកម្មភាពអ្វីទាំងអស់ដូច្នេះជនភៀសខ្លួនពិបាករកស្បៀងអាហារបរិភោគខ្លាំង។ រដ្ឋការពុករលួយ ស៊ីសំណូក និងធ្វើអ្វីបានតាមចិត្តដូចសុភាសិតថា៖ «អ្នកធំស៊ីធំ អ្នកតូចស៊ីតូច»។ ប្រាក់រៀលចេះតែចុះថ្លៃ រីឯតម្លៃទំនិញចេះតែឡើងថ្លៃហួសកម្រិត។ ប្រជាជនរស់រានមានជីវិតទៅមុខទៀតបាន ដោយសារតែស្បៀងដែលរដ្ឋាភិបាលសហរដ្ឋអាម៉េរិកផ្តល់មកឱ្យតែប៉ុណ្ណោះ។ ជំនួយស្បៀងទាំងនោះដឹកតាមផ្លូវកងនាវា ដែលឡើងតាមទន្លេ មេគង្គ។ ជាញឹកញាប់ខ្មែរក្រហមវាយបិទផ្លូវទន្លេនេះ រួចកងទ័ពសាធារណរដ្ឋខ្មែរត្រូវវាយបើកវិញ។ ចាប់តាំងពីខែមករា ឆ្នាំ១៩៧៥ មកការដឹកនាំតាមទន្លេនេះត្រូវខ្មែរក្រហមកាត់ផ្តាច់ទាំងស្រុង។ នៅសល់តែផ្លូវអាកាសពីក្រុងបាងកកប៉ុណ្ណោះសម្រាប់នាំអង្ករមកចិញ្ចឹមមនុស្សជាច្រើនលាននាក់នៅភ្នំពេញ។

កសិកម្ម ពាណិជ្ជកម្ម ត្រូវបានហ៊ុមព័ទ្ធក្រុមរណសិរ្សរួបរួមជាតិកម្ពុជា[342] ហើយសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយនានាត្រូវបានគេរឹតបន្តឹងដែលនាំឱ្យស្ថាប័នទាំងនេះអស់ទំនុកចិត្តលើរបបសាធារណរដ្ឋខ្មែរ។ សកម្មភាពនយោបាយលិចស្រឹមទៅក្នុងជម្លោះបក្សពួក ឬ ជម្លោះបុគ្គល ហើយប្រជាជនរស់នៅក្រុងរកអនាគតភ្លឺស្វាងពុំឃើញឡើយ[343] ដែលជាហេតុនាំឱ្យប្រជាជនអស់សង្ឃឹមចំពោះសាធារណរដ្ឋខ្មែរ។ បទចម្រៀងសម័យសង្គមរាស្ត្រនិយម ត្រូវបានគេហាមឃាត់មិនឱ្យចាក់ផ្សាយ ហើយគេតម្រូវឱ្យអ្នកនិពន្ធនិពន្ធបទចម្រៀងស្នេហាជាតិជាច្រើន ដើម្បីជំរុញទឹកចិត្តយុទ្ធជនឱ្យមានកម្លាំងចិត្តក្នុងការច្បាំងជាមួយសត្រូវ។ ចំពោះចម្រៀងស្នេហាជាតិមានជាច្រើនដូចជា វត្តជំពុះក្អែក, ពលទោអភ័ព្វ, លាម៉ែទៅច្បាំង, ថ្ងៃទី១២ កក្កដា, កំបិតស្នៀតឱ, ឱ!អូរអក្ខរា, វាចារយុទ្ធជនភូមិគគីធំ, ឧត្តមភរិយាទាហាន, ក្រឡាហោមគង់, ស្ម័គ្រចូលធ្វើទាហាន, ខ្ញុំពិការ, ស្នេកលាម៉ែធ្វើទាហាន,សម្រែកឈាមខ្មែរ,លាពៅទៅច្បាំងជាដើម។

### ៣-សង្គ្រាមឆ្នាំ១៩៧០ ដល់១៩៧៥ (ភ្នំពេញជាដង្ហើមចុងក្រោយ) [344]

លោក William Shawcross មានរៀបរាប់ថា នៅក្នុងសម័យសង្គមរាស្ត្រនិយមក្រុងភ្នំពេញនេះមិនមានសម្ពាធពាណិជ្ជកម្ម និងសង្គ្រាមខ្លាំងនោះទេ។ ប្រជាជនរស់នោះនៅក្នុងរដ្ឋធានីមានត្រឹមតែ៦០០.០០០នាក់ប៉ុណ្ណោះ ហើយមានសញ្ញាតិចតួចនៃតំបន់អនាធិបតេយ្យ ខណៈដែលប្រជាជនថៃ និង ប្រជាជនវៀតណាម បាន និងកំពុងរស់នៅយ៉ាងលំបាកវេទនា។ នៅក្រោមដំបូលផ្សារធំៗ ផលិតផលក្នុងស្រុកជាច្រើន ត្រូវបានដាក់គរ

---

[340] ទាហានខ្មោច។

[341] ហ្វ្រង់ស្វ័រ ប៉ុងសូដ៏, *ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា,* ឆ្នាំ២០០៧, ទំព័រ៨៥-៨៦។

[342] នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេចព្រះនរោត្តម សីហនុ បានបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ដែលបានអំពាវនាវឱ្យប្រជាជនខ្មែរនៃគ្រប់និន្នាការនយោបាយ ប្រយុទ្ធប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ។

[343] ហ្វ្រង់ស្វ័រ ប៉ុងសូដ៏, *ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា,* ដ.ឯ.ម., ទំព័រ៨៦។

[344] ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៥៥៧-៥៦១។

លើគ្នាយ៉ាងខ្ពស់ដូចជា បន្លែ អង្ករ និងប្រភេទត្រីជាច្រើន ដែលចាប់បាននៅក្នុងទន្លេ ឬបឹង។ នៅដើមឆ្នាំ ១៩៧០ អតីតរាជធានីដ៏ស្រស់បំព្រងនេះ ក៏បានផ្លាស់ប្តូរអ្នកគ្រប់គ្រងជាន់ខ្ពស់របស់ខ្លួនហើយ ប្រជាជនចាប់ផ្តើមមានការកើនឡើងជាលំដាប់។

នៅឆ្នាំ១៩៧០ កងទ័ពវៀតណាមខាងជើង និងវៀតកុង បានធ្វើការវាយប្រហារមកទីប្រជុំជនស្គន់ ក្នុងខេត្តកំពង់ចាម ដែលធ្វើឱ្យក្រុមនេះស្លាប់អស់ចំនួន៧០០នាក់ និងមានអ្នករបួស ចំនួន១០០០នាក់ទៀត ដែលត្រូវរំដោះ ទៅក្នុងតំបន់ចម្ការលើ។ ចំណែកឯនៅព្រែកតាម៉ាក់(ខេត្តកណ្តាល) ប្រយុទ្ធតទល់គ្នារវាងកងទ័ពសាធារណរដ្ឋ និងកងទ័ពកុម្មុនីស្តវៀតកុង និងវៀតណាមខាងជើងផងដែរ។ នៅខែកញ្ញា ឆ្នាំ១៩៧២ ទ័ពវៀតកុង និងយួនខាងជើងបានផ្តក់ ដោយកាំភ្លើងត្បាល់មកលើទ័ពសាធារណរដ្ឋខ្មែរនៅ សំរោងយ៉ោង ,ចំបក់, ត្រពាំងលាន ដែលស្ថិតនៅផ្លូវជាតិលេខ២។ នៅឆ្នាំនេះស្ថានភាពសឹកនៅតាមផ្លូវជាតិលេខ២ មានសភាពកាន់តែធ្ងន់ធ្ងរ ដោយសារតែក្រុមខ្មែរក្រហមធ្វើការឡោមព័ទ្ធ និងវាយប្រហារកងទ័ពសាធារណរដ្ឋខ្មែរនៅ តាគោក, ភូមិល្វា ភូមិត្នោតជ្រុស។ ចាប់ពីឆ្នាំ១៩៧២ រហូតដល់ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញហាក់ក្លាយជាកោះមួយដែលហ៊ុំព័ទ្ធទៅដោយគ្រាប់សំណ និងសម្លេងបាញ់ផ្លោងឥតឈប់ឈរ ដែលនៅខែមីនាឆ្នាំ១៩៧៣ ក៏មានការទម្លាក់គ្រាប់បែកលើវិមានសាធារណរដ្ឋផងដែរ។ ក្រោយពេលកើតហេតុប៉ុន្មានម៉ោងលោកសេនាប្រមុខ លន់ នល់ ក៏បានចេញសារមួយនាថ្ងៃទី១៣ មីនា ឆ្នាំ១៩៧៣ ជម្រាបជូនជនរួមជាតិខ្មែរដោយបញ្ជាក់ថាការទម្លាក់គ្រាប់បែកនោះថា *«សត្រូវនៃសាធារណរដ្ឋខ្មែរ ដែលប៉ុនប៉ងសម្លាប់របបសាធារណរដ្ឋខ្មែរ បានទិញអតីតអ្នកបើកយន្តហោះយើងម្នាក់ ឱ្យបន្លំខ្លួនធ្វើល្បិចមកទម្លាក់គ្រាប់បែកលើវិមានសាធារណរដ្ឋ ដើម្បីសម្លាប់ខ្លួនខ្ញុំផ្ទាល់»*

លោក ហ្គាន់ចឹដៀន ឯកអគ្គរដ្ឋទូតអាម៉េរិកកាំងប្រចាំទីក្រុងភ្នំពេញ និងលោក ស្លេស៊ីងហ្គ័ររដ្ឋលេខាធិការ ការពារប្រទេសអាម៉េរិកកាំង មានទស្សនៈដូចគ្នាថា «*ស្រុកខ្មែរនឹងស្លាប់នៅពេលឆាប់ៗខាងមុខនេះ ប្រសិនបើអាម៉េរិកកាំង មិនបន្ថែមជំនួយមកឱ្យទាន់ពេលទេ ហើយបើទន្លេមេគង្គនៅតែស្ទះ*»។ ការដែលអ្នកទាំងពីរមើលឃើញបែបនេះពិតជាត្រឹមត្រូវណាស់ ព្រោះបើអាម៉េរិកមិនបានផ្តល់ជំនួយឱ្យបានគ្រប់គ្រាន់សម្រាប់ពង្រឹងកងទ័ពឱ្យបានរឹងប៉ឹងជាមួយពួកកុម្មុយនីស្តទេនោះ ក្រុងភ្នំពេញដែលជាបេះដូងនៃសាធារណរដ្ឋខ្មែរ *នឹងត្រូវខ្ទេច ទោះបីជាមិនខ្ទេចដោយសារពួកកុម្មុយនីស្តវាយប្រហារចូលមកទេ ក៏ខ្ទេចដោយសារគ្រាប់ផ្លោងដែលក្រុមកុម្មុយនីស្ត បាញ់ស្រោចមករាល់ថ្ងៃនោះដែរ។* ហើយបើអាម៉េរិកមិនផ្តល់ជំនួយទាន់ពេល ដើម្បីទាន់ពេលយកមកប្រើប្រាស់ក្នុងការបង្កើនកម្លាំង វាយរំដោះដងទន្លេមេគង្គដែលជាដង្ហើមយ៉ាងធំរបស់ក្រុងភ្នំពេញទេនោះ ក្រុងភ្នំពេញក៏ត្រូវចប់ដែរ គឺ*ចប់ដោយសារអត់ស្បៀងតែម្តង។* លោក ហ្គាន់ចឹដៀន បានទស្សន៍ទាយថា *ខ្មែរនឹងត្រូវស្លាប់នៅក្នុងរយៈពេល១ខែ ឬ២ខែទៀតយ៉ាងយូរ* គឺលោកមើលឃើញថាពេលវេលាខ្មែរត្រូវស្លាប់គឺមានពេលខ្លីណាស់ប្រសិនបើជំនួយអាម៉េរិក ផ្តល់មកឱ្យខ្មែរមិនទាន់ពេលទេនោះ។ ចំណែកលោក ហាប៊ីត បានសំដែងឱ្យដឹងទៀតថាជំនួយជាចំបាច់នេះ អាចឱ្យខ្មែររស់តទៅទៀត ដោយបានការពារខ្លួនទប់ទល់នឹងការវាយលុករបស់ពួកកុម្មុយនីស្តផង។ លោកបង្ហាញឱ្យឃើញថា បើកងទ័ពរដ្ឋាភិបាលខ្មែរ(សាធារណរដ្ឋខ្មែរ) អាចទប់ទល់បាននោះ ការចរចារកសន្តិភាពនឹងអាចប្រព្រឹត្តឡើងជាដាច់ខាតពីព្រោះបរាជ័យរបស់ខ្មែរក្រហមអាចជំរុញខ្លួនគេឱ្យ រកកិច្ចការដោះស្រាយជាមិនខាន។ នៅឆ្នាំ១៩៧៥ រ៉ូក្កែត១០ គ្រាប់ធ្លាក់ចូលផ្សារចាស់ និងម្តុំផ្សារថ្មី បណ្តាលឱ្យស្លាប់២នាក់ និង៦នាក់ទៀតត្រូវរបួសជាទម្ងន់ ហើយនៅពោធិ៍ចិនតុងធ្លាក់ចូល៨គ្រាប់ទៀត គឺជាការបាញ់ផ្តក់យ៉ាងសាហាវ។ ចំណែក នៅក្រុងឧដុង្គកងទ័ពខ្មែរក្រហម ដែលស្ថានការណ៍សឹកមានលក្ខណៈតឹងតែង ដែលគេត្រូវជម្លៀសប្រជាជនចេញពីខេត្តដើម្បីចៀសវាងគ្រោះថ្នាក់ជាយថាហេតុ។

លោកសេនាប្រមុខ លន់ នល់ បានដាក់គម្រោងការចរចា ជាផ្លូវការជាមួយខ្មែរក្រហមដែរ ហើយនៅពេលសង្គ្រាមវាមានការចរចាស្ងាត់ៗ ច្រើនរវាងខ្មែរក្រហម និងនាយទាហាន និងអ្នកនយោបាយជាន់ខ្ពស់ខ្មែរ។ ប៉ុន្តែការជួបគ្នាស្ងាត់ៗ វាជាការស្វែងស្ទាបគ្នាទៅវិញទៅមកជារបៀបលួចលាក់ ហៅថា «*ជាការក្បត់គ្នា*» ក៏បានមិនមែនសភាពជាផ្លូវការណាមួយឡើយ។ នាយទាហានសាធារណៈរដ្ឋខ្មែរខ្លះបានទទួល តួនាទី ឋានន្តរស័ក្តិខ្មែរក្រហមទៅហើយ។ បន្តិចម្តងៗខ្មែរក្រហមបានប្រើមធ្យោបាយនេះនាំឱ្យទាហានសាធារណរដ្ឋខ្មែរ ដាក់កាំភ្លើងចុះឈប់ច្បាំង។ នៅឆ្នាំ១៩៧៥ មាន៣ក្រុមនៅក្នុងរដ្ឋការសាធារណរដ្ឋខ្មែរដែលគិតផ្សេងគ្នាចំពោះព្រឹត្តិកាណ៍ដែលកំពុងតែតានតឹងនាពេលនោះគឺៈ

ក្រុមទី១: យើងចរចាទៅពីព្រោះអំណាចនេះបានទៅសម្តេចព្រះនរោត្តម សីហនុ ។

ក្រុមទី២: យើងត្រូវតែតស៊ូដល់ទីបញ្ចប់ ព្រោះអំណាចដែលខ្មែរក្រហមដណ្តើមបានមិនបានដល់ សម្តេចឪទេ ព្រោះខ្មែរក្រហមមានផែនការច្បាស់ណាស់ ហើយគេក៏ស្អប់របបរាជានិយមដែរ។

ក្រុមទី៣: ក្រុមមួយផ្សេងទៀតនេះជឿថា ស្លាប់រស់ ត្រូវតែចងសម្ពន្ធភាពជាមួយខ្មែរក្រហម បន្តរបបសាធារណៈរដ្ឋតទៅទៀត ពីព្រោះសម្តេចសីហនុលេងសើចច្រើនណាស់ មិនអាចគ្រប់គ្រងខ្មែរក្រហមបានទេ។ វាមានការជួបគ្នាស្ងាត់ៗខ្លះ ដូចជាបងលន់ ណុន ហង់ធុន ហាក់ និងកុយ ធួនជាដើម ប៉ុន្តែលោកសេនាប្រមុខឥតបានអនុញ្ញាតទេ។ ការចរចាពិតប្រាកដពុំមានទេ គ្រាន់ជាគំនិតស្នង់ ផ្លូងចោល ហៅថា «Proposal» តែប៉ុណ្ណោះ។ លោក សុង ឆាងបន្ថែមទៀតថា ដូចជានៅខែមិថុនាឆ្នាំ១៩៧៤ មានលោក ឡុងបូរ៉េត លោកសាក់ ស៊ុតសាខន និងខ្ញុំជាអ្នកចាត់ការរឿងនេះ។

នៅឆ្នាំ១៩៧៥ កាំភ្លើងធំ គ្រាប់រ៉ុកកែតរបស់ក្រុមកុម្មុយនីស្ត ត្រូវបានផ្លោងចូលមកក្រុងភ្នំពេញ ហើយភាគខាងជើងនៃក្រុងក៏ត្រូវបានបំផ្លាញខ្ទេចខ្ទី។ ជាលទ្ធផលចុងនយោបាយខ្មែរក្រហមជានយោបាយតឹងរឹងបំផុត ប្រើប្រាស់ចុងអាវុធវាយយកឈ្នះហើយជានយោបាយ «ផ្លាស់ប្តូរសង្គម» មួយនេះបានចូលកាន់កាប់ទីក្រុងភ្នំពេញនាព្រឹក ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពួកគេលើកដៃគ្រវី ស្របពេលដែលប្រជាជនក្នុងក្រុងកំពុងតែអបអរសាទរ ឱ្យពួកគេទាំងទឹកភ្នែកលាយឡំជាមួយ។

## ៤-ដំណាក់កាលចុងក្រោយនៃរបបសាធារណរដ្ឋខ្មែរ[345]

នៅចុងឆ្នាំ១៩៧០ និងឆ្នាំ១៩៧១ លន់ នល់ បានធ្វើយុទ្ធនាការចំនួនពីរលើកប្រឆាំងនឹង វៀតណាម ដែលមានឈ្មោះថា «ចេនឡា»។ ប្រតិបត្តិការចេនឡាទី១ ចាប់ផ្តើមនៅដើមខែកញ្ញា ឆ្នាំ១៩៧០ ដែលទទួលបានជោគជ័យគួឱ្យកត់សម្គាល់។ មួយឆ្នាំបន្ទាប់មក នាខែកញ្ញាដដែលប្រតិបត្តិការសឹកថ្មីមួយទៀតដែលមានទ្រង់ទ្រាយដូចគ្នា មានឈ្មោះចេនឡាទី២។ ប្រតិបត្តិការសឹកលើកនេះ ត្រូវបានដឹកនាំផ្ទាល់ដោយ លន់ នល់ និង សាក់ ស៊ុតសាខន។ ចេនឡាទី២ នេះបានទទួលនូវបរាជ័យទាំងស្រុង បណ្តាលឱ្យ លេចឮពេញផ្ទៃប្រទេស និងឆាកអន្តរជាតិនៅខែវិច្ឆិកា ឆ្នាំ១៩៧១។ ចេនឡាទី១ និងទី២ មានគោលបំណងរំដោះភូមិភាគពាយ័ព្យរាជធានី ហើយបើកផ្លូវពីស្គន់ ប្រមាណ៧០គីឡូម៉ែត្រទៅកំពង់ធំ ដែលជាតំបន់កសិកម្មមួយដ៏ល្បី និងជាកន្លែងតំណាក់មួយយ៉ាងសំខាន់ដែលតភ្ជាប់ពីកំពង់ធំ ទៅសៀមរាប។ សត្រូវរបស់សាធារណរដ្ឋត្រូវបានកាត់ផ្តាច់ និងត្រួតត្រាគោលដៅនេះ ដោះបានបោះទីតាំងដ៏រឹងមាំមួយនៅលើភ្នំចន្លោះពីស្គន់ ទៅកំពង់ធំ ហើយថែមទាំងមានមូលដ្ឋានយោធាស្ថិតនៅចម្ការអណ្តូង ផងដែរ។ សាធារណរដ្ឋខ្មែរមានផែនការមិនមែនគ្រាន់តែរំដោះតំបន់

[345] ទី សុផល, ប្រវត្តិវិទ្យា, ដ.ឯ.ម., ទំព័រ៥៦១-៥៦៥។

នោះទេ ប៉ុន្តែឈានទៅកាន់កាប់ និងត្រួតត្រាឱ្យបានដើម្បីជានាផ្គត់ផ្គង់ស្បៀង និងផលិតផលកសិកម្មកុំឱ្យជួប នឹងការកាត់ផ្តាច់ផ្លូវក្នុងរយៈពេលយូរ។ លោក លន់ នល់ បានបញ្ជូនទៅកាន់តំបន់នោះ នូវកងឯកភាព សំខាន់ៗ មានដូចជាកងធំទី១ និងកងធំទី២ បំពាក់ដោយកងរថក្រោះ និងកងកាំភ្លើងជាច្រើន កងឯកភាព។ ចំនួនទាហាន៥ ០០០ អ្នកនេះ បានធ្វើដំណើរបន្តកន្ទុយគ្នាជាជួរតាមដងផ្លូវជាតិ អមដោយភ្នំធំ និងភ្នំតូចៗជាច្រើន ដែលជាសាច់រឿងមិនងាយប៉ុន្មានសោះ បើនិយាយពីក្បួន យុទ្ធសាស្ត្រ។ កំហុសដ៏ធ្ងន់របស់ចេនឡាទី២ នេះ ដូចជាបានខ្សឹបប្រាប់សត្រូវឱ្យបើកការវាយបកមកវិញ នៅកណ្តាលវាលតែម្តង។ ក្រុមសត្រូវរបស់ សាធារណរដ្ឋខ្មែរ បានបណ្តោយឱ្យទាហានសាធារណរដ្ឋខ្មែរឆ្លងកាត់តំបន់សមរភូមិដោយងាយ បន្ទាប់មកគេ ក៏កាត់ផ្តាច់កន្ទុយទ័ព រួចបានបាញ់សន្ទាប់ ដោយមិនទុកធ្វើសម្រាប់សាធារណរដ្ឋខ្មែរចេញបញ្ជាឱ្យទាហាន រៀបចំខ្លួនឡើយ[346]។ សកម្មភាពនេះគឺមានការគាំទ្រដោយសហរដ្ឋអាម៉េរិក តែមិនបានទទួលជោគជ័យជាដុំ កំភួននោះទេ ដោយសារតែទាហានរបស់ លន់ នល់ មានចំនួន តិចតួច និងហ្វឹកហាត់ពុំបានត្រឹមត្រូវល្អ។ ការឡើង កាន់អំណាចរបស់រដ្ឋាភិបាលនៅសម័យនេះមានភាពលំបាកលំបិន និងមានការផ្លាស់ប្តូរឥតឈប់ឈរ ហើយ ភាគច្រើនរស់ដោយសារជំនួយសហរដ្ឋអាម៉េរិក។ នៅសម័យនេះ អំពើពុករលួយកើតពេញផ្ទៃប្រទេស។ នៅ តាមជនបទមន្ត្រីយោធាតែងតែក្លែងបន្លំ ចំនួនទាហានដែលនៅក្រោមបញ្ជារបស់ខ្លួន ដើម្បីកេងយកប្រាក់ បៀវត្សរ៍ពីជំនួយយោធារបស់សហរដ្ឋអាម៉េរិក។ ក៏ប៉ុន្តែរាល់សកម្មភាពទាំងអស់ហាក់ដូចជាអល់អែក ក្នុងការ ដាក់ទណ្ឌកម្មទៅលើមន្ត្រីទាំងអស់នោះ។ ដើម្បីទប់ទល់ការបាក់ស្រុតនៃសេដ្ឋកិច្ចជាតិ លោកប្រធានាធិបតី លន់ នល់ បានសរសេរសំបុត្រផ្ញើទៅប្រធានាធិបតីសហរដ្ឋអាអាម៉េរិកគឺលោក និច សុន ដើម្បីសុំជំនួយបន្ថែម។

នៅដើមឆ្នាំ១៩៧១ លោកសេនាប្រមុខ លន់ នល់ មានជំងឺស្លាប់មួយជំហៀងខ្លួនការគ្រប់គ្រងរបស់ លោកមិនបានពេញលេញឡើយ ជាហេតុធ្វើឱ្យអំណាចកណ្តាលមានការធ្លាក់ចុះជាលំដាប់។ នៅឆ្នាំ១៩៧២ ប្រទេសចំនួន៦២ បានបោះឆ្នោតសម្រេចផ្តល់អាសនៈឱ្យប្រទេសកម្ពុជាវិញគឺប្រទេស១៧ បោះឆ្នោតប្រឆាំង និង ១៧ប្រទេសទៀតបោះអនុប្បវាទ (ការបោះឆ្នោតនៅថ្ងៃទី២៨ ខែតុលា នោះគឺជាការបោះឆ្នោតរបស់គណៈ កម្មាធិការពិនិត្យបញ្ជាក់សេចក្តីសម្រេចផ្សេងៗ (ឱ្យដឹងខុសត្រូវ) នៃមហាសន្និបាតអង្គការសហប្រជាជាតិ។ នៅពេលនោះសហភាពសូវៀតបានបោះឆ្នោតអនុគ្រោះឱ្យសារធារណរដ្ឋខ្មែរ។ ចំណែកឯមហាសន្និបាតវិញ ប្រទេសចំនួន១១ ក្នុងចំណោមសមាជិករបស់ខ្លួន១៣២ប្រទេស បានបោះឆ្នោតនៅ ថ្ងៃទី១២ ខែតុលា មុន ប្រឆាំងនឹងភាពជាតំណាងរបស់សាធារណរដ្ឋខ្មែរមានប្រទេស អាល់បានី, អាល់ហ្សេរី, ចិនប្រជាមានិត, កុងហ្គោ, គុយបា, អ៊ីរ៉ាក់, ម៉ូរី តានី, រ៉ូម៉ានី, សេណេហ្គាល់, ស៊ីរី, យូហ្គោស្លាវី)។ នៅឆ្នាំ១៩៧៣ ជាឆ្នាំដែលមាន ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីសទាក់ទងនឹងប្រទេសវៀតណាម។ មហាសន្និបាតនៃអង្គការសហ ប្រជាជាតិ បានលើកយកបញ្ហាស្តីពីការ កំណត់អាសនៈឱ្យប្រទេសកម្ពុជា លើកទៅធ្វើនៅឆ្នាំក្រោយវិញ ក្រោម ការជំរុញរបស់អ្នកតំណាងសហរដ្ឋអាម៉េរិក។ ប៉ុន្តែ ក្នុងឱកាសនៃការជជែកពិភាក្សាគ្នាអំពីរឿងនេះមានតែ៥៣ ប្រទេសប៉ុណ្ណោះ ដែលបង្ហាញនូវការយោគយល់ចំពោះការលើកពេលមួយបែបនោះទប់នឹងប្រទេស៥០ ប្រឆាំង និងអនុប្បវាទ២១ ប្រទេស។ នៅឆ្នាំ១៩៧៣ ដដែលនោះ៣២ប្រទេស បានទទួលស្គាល់រដ្ឋាភិបាលរួបរួមជាតិ កម្ពុជាដែលដឹកនាំដោយសីហនុជាផ្លូវការ។

---

[346] សូមអាន: Sosthène FERNANDEZ, *MÉMOIRES D'UNE GUERRE OUBLIÉE: Le testament jamais publié de l'ancien chef d'Etat-Major de Lon Nol ( French Edition )*, Paris, AsieInfo, 2015.

នៅពាក់កណ្ដាលទីមួយនៃឆ្នាំ១៩៧៣ សហរដ្ឋអាម៉េរិកបានទម្លាក់គ្រាប់បែកជាងមួយសែនតោន មកលើជនបទកម្ពុជាមុនពេលដែលសភាសហរដ្ឋអាម៉េរិកបានហាមឃាត់។ ការទម្លាក់នេះធ្វើឱ្យប្រជាជនមិនអាចរស់នៅបានតាមភូមិស្រុកជនបទក៏នាំគ្នាមករស់នៅទីរួមខេត្តនានា និងនៅក្រុងភ្នំពេញ។ ក្នុងឆ្នាំ១៩៧៣ នេះដែរ ប្រជាជននៅតំបន់រំដោះក្នុងខេត្តកំពង់ចាមមួយចំនួនបានរត់ចេញ ដើម្បីចូលមកជាមួយរបបសាធារណរដ្ឋខ្មែរ ដោយពួកគាត់ដឹងថា ក្រុមខ្មែរក្រហមបានប្រឆាំងនឹងសម្ដេចព្រះ នរោត្តម សីហនុ ដោយគ្រាន់តែយកទ្រង់បិទបាំងនយោបាយរបស់ខ្លួនប៉ុណ្ណោះ។ ពេលនោះលេចចេញនូវពាក្យស្លោកដែលប្រជាជនក្នុងតំបន់នោះពោលថា៖

| | |
|---|---|
| បំបាត់នាយទុន | បញ្ចេញអង្គការ |
| បំបាត់ពន្ធដារ | បញ្ចេញវិភាគទាន |
| បំបាត់អ្នកមាន | បញ្ចេញអ្នកក្រ |
| បំបាត់ពណ៌ស | បញ្ចេញពណ៌ខ្មៅ |
| បញ្ចេញអ្នកខ្លៅ | បំបាត់អ្នកចេះដឹង |
| បើបំបាត់មឹ្លងៗ | មានន័យយ៉ាងម៉ិច? |

ការដួលរលំនៃរបបសាធារណរដ្ឋខ្មែរបានកើតឡើងនៅខែមេសា ឆ្នាំ១៩៧៥ ដោយក្រុមខ្មែរក្រហមដែលមាននៅគ្រប់ច្រកល្ហក និងមានការដាក់មីនផ្ដាច់ផ្លូវមកកាន់ក្រុងភ្នំពេញដែលជាបុព្វហេតុនៃការរារាំងការដឹកជញ្ជូនស្រូវអង្ករ និងគ្រាប់រំសេវ។ ចាប់ពីខែមករា ឆ្នាំ១៩៧៥ មកផ្លូវទាំងឡាយត្រូវបានកាត់ផ្ដាច់ ជាហេតុធ្វើឱ្យកងទ័ពសាធារណរដ្ឋខ្វះស្បៀងដូច្នេះហើយបានជាសហរដ្ឋអាម៉េរិកបានដឹកជញ្ជូនអង្ករ និងគ្រាប់រំសេវតាមអាកាសពីប្រទេស វៀតណាមខាងត្បូង និងប្រទេសថៃមកកាន់ក្រុងភ្នំពេញ ប៉ុន្តែ វាក៏មិនអាចគ្រប់គ្រាន់នោះដែរ។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ ស្ថានភាពនយោបាយកម្ពុជាកាន់តែដុនដាបហើយ លោកសេនាប្រមុខ លន់ នល់ បានចាកចេញពីប្រទេសកម្ពុជាជាមួយទាហាន និងឧត្ដមសេនីយ៍ ជាង៣០នាក់ ដែលបានភៀសខ្លួនទៅមូលដ្ឋានសឹកសហរដ្ឋអាម៉េរិកនៅអូតាប៉ាវប្រទេសថៃ។ បន្ទាប់មកតាមរយៈប្រទេសឥណ្ឌូណេស៊ី ពួកគេបានធ្វើដំណើរទៅកោះហាវ៉ៃសហរដ្ឋអាម៉េរិក។ នៅថ្ងៃជាមួយគ្នានោះនៅពេលល្ងាចកងកម្លាំងអ្នកស្នេហាមាតុភូមិបានវាយដណ្ដើមយកបានចំណុចយុទ្ធសាស្ត្រដ៏សំខាន់មួយ គឺក្រុងអ្នកលឿង ដែលស្ថិតនៅចម្ងាយ៥០គីឡូម៉ែត្រពីភ្នំរាជធានីភ្នំពេញ។ ក្រុងនេះជាចំណុចការពារចុងក្រោយបំផុត របស់របបគ្រប់គ្រងក្រុងភ្នំពេញតាមទន្លេមេគង្គ និងជាសេចក្ដីសង្ឃឹមចុងក្រោយតាមផ្លូវទឹក។ នៅ ថ្ងៃទី១១ ដល់១២ ខែមេសា ឆ្នាំ១៩៧៥ តាមបញ្ជារបស់ឯកអគ្គរដ្ឋទូតអាម៉េរិកឈ្មោះ ឌីន ពលរដ្ឋអាម៉េរិកដែលនៅសេសសល់ចំនួន៨២នាក់បានត្រូវចាកចេញ ពីក្រុងភ្នំពេញតាមឧទ្ធម្ភាចក្រ ៣៦គ្រឿងក្រោមកិច្ចការពាររបស់ទាហានជើងទឹកចំនួន៣៥០នាក់[347]។ ក្រោយពីសហរដ្ឋអាម៉េរិកបានចាកចេញពីប្រទេសកម្ពុជា ភាពអនាធិបតេយ្យបានកើតឡើង ដោយសារតែជំនួយសហរដ្ឋអាម៉េរិកផ្ដល់បានកាត់ផ្ដាច់ ។

នៅថ្ងៃទី១៤ ខែមេសា កងកម្លាំងអ្នកស្នេហាមាតុភូមិបានវាយដណ្ដើមយកបានអាកាសយានដ្ឋានរដ្ឋធានី ហើយនៅថ្ងៃទី១៧ ខែមេសា អង្គភាពនៃកងទ័ពរំដោះបានចូលដល់ក្រុងភ្នំពេញ។ បន្ទាប់ពីការរំដោះរដ្ឋធានី ក្រុងដទៃទៀតនៃប្រទេសកម្ពុជាក៏បានត្រូវរំដោះជាបន្តបន្ទាប់។ សំណល់នៃរបបគ្រប់គ្រងមុនបានរលំរលីង ហើយបានប្រកាសសារភាពចុះចាញ់។ ការប្រយុទ្ធរបស់កងកម្លាំងអ្នកស្នេហាមាតុភូមិ ដែលបាន

[347] មីហេយេវ, *ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា*, ដ.ឯ.ម., ទំព័រ៤៧៥ ។

ប្រព្រឹត្តទៅអស់រយៈពេលចំនួន៥ឆ្នាំ និង១ខែ បានបញ្ចប់ទៅដោយជ័យជម្នះពេញលេញរបស់កងកម្លាំងស្នេហាជាតិមាតុភូមិ និងដោយបរាជ័យនៃរបបសាធារណរដ្ឋខ្មែរគាំទ្រដោយកងកម្លាំងចក្រពិត្តនិយម អាម៉េរិក[348]។

ប្រជាជនចំនួនពីរលាននាក់រស់នៅក្នុងក្រុងមានភាពក្រីក្រច្រើន ហើយរស់ដោយក្ដីព្រួយបារម្ភ។ ដោយសកម្មភាពរំដោះ បានរបស់ខ្មែរក្រហមនេះប្រជាពលរដ្ឋខ្មែរពេលនោះនឹកស្មានតែជាការសង្គ្រោះ ប្រទេសជាតិឱ្យរួចផុតពីអន្តរាយ។ បើយោងតាមការស្រាវជ្រាវបញ្ចប់ថ្នាក់បណ្ឌិតប្រវត្តិសាស្ត្រមួយបានបង្ហាញថា របបសាធារណរដ្ឋខ្មែរដួលរលំដោយសារមូលហេតុជាច្រើនដូចជា៖[349]

- វិបត្តិនៅក្នុងការរៀបចំគណៈរដ្ឋមន្ត្រីដោយការប្រកាសរបបសាធារណរដ្ឋខ្មែរ
- ឥទ្ធិពលនៃការទម្លាប់គ្រាប់បែករបស់អាម៉េរិក ជាហេតុធ្វើឱ្យប្រជាពលរដ្ឋមានកំហឹងឈឺចាប់ចំពោះរដ្ឋាភិបាលដែលរួមដៃជាមួយសហរដ្ឋអាម៉េរិក
- ប្រជាពលរដ្ឋអស់សង្ឃឹមលើរដ្ឋាភិបាលក្នុងដំណោះស្រាយបញ្ហាដែលកំពុងប្រឈម
- ប្រជាប្រិយរបស់សម្ដេចព្រះ នរោត្តម សីហនុ ដែលទទួលបាននូវការគាំទ្រពីប្រជាពលរដ្ឋភាគច្រើននៅក្នុងប្រទេស
- សង្គ្រាមស៊ីវិលដែលបង្កឡើងដោយប្រទេសមហាអំណាច បានធ្វើឱ្យសេដ្ឋកិច្ចរបស់កម្ពុជាត្រូវរស់នៅដោយពឹងផ្អែកលើជំនួយបរទេសទាំងស្រុង
- ភាពគ្មានសុទិដ្ឋិនិយមពីសំណាក់មេដឹកនាំ ក្នុងគោលនយោបាយដឹកនាំប្រទេស
- នយោបាយការបរទេសសហរដ្ឋអាម៉េរិកត្រូវបញ្ចប់សង្គ្រាមនៅឥណ្ឌូចិនឱ្យបានឆាប់ ដោយអនុវត្តនយោបាយត្រីកោណជាមួយសហភាពសូវៀត និងចិន
- នយោបាយការបរទេសរបស់ប្រទេសមហាអំណាចកុម្មុយនីស្ត(ចិន និងសូវៀត) ក្នុងការដណ្ដើមឥទ្ធិពលគ្នានៅតំបន់ឥណ្ឌូចិន។

## ៥-ការខូចខាត និងផលវិបាក

ប្រទេសកម្ពុជាក្នុងរយៈពេល៥ឆ្នាំ(ពីឆ្នាំ១៩៧០-១៩៧៥) បានបង្កឡើងនូវមហាវិនាសកម្ម និងការខូចខាតយ៉ាងធ្ងន់ធ្ងរលើគ្រប់វិស័យដោយសារសង្គ្រាម។ ផលវិបាកធំបំផុតគឺសង្គ្រាមបានសម្លាប់ប្រជាជនខ្មែរជាងមួយលាននាក់ ហើយបានបន្សល់ទុកនូវជនពិការ អ្នករបួស ក្មេងកំព្រា និងស្ត្រីមេម៉ាយជាច្រើនសែននាក់។ ការទម្លាក់គ្រាប់បែក, ការបាញ់ប្រហារ និងការបាញ់តតាំងគ្នារវាងភាគីជម្លោះបានបណ្ដាលឱ្យប្រជាជនប្រមាណមួយភាគបី(១/៣) នៃចំនួនប្រជាជនសរុប ភៀសខ្លួនពីជនបទចូលមកកាន់ទីក្រុងភ្នំពេញដែលបណ្ដាលឱ្យពួកគេរស់នៅដោយខ្វះខាតស្បៀងអាហារ ជួបភាពអនាធិបតេយ្យ អំពើហិង្សា និងចោរកម្ម។ ក្នុងអំឡុងពេលនោះអំពើសូកប៉ាន់ក៏បានរីកដុះដាលដល់វិស័យសិក្សាធិការផងដែរ។ ផ្នែកហេដ្ឋារចនាសម្ពន្ធ និងសេដ្ឋកិច្ចវិញ សង្គ្រាមបានបំផ្លាញធនធានមនុស្ស គ្រឹះស្ថានសិក្សា វត្តអារាម និងលំនៅឋាន។ រោងចក្រឧស្សាហកម្មប្រមាណ៧៥ភាគរយត្រូវបានបំផ្លិចបំផ្លាញ ខណៈដែលចម្ការកៅស៊ូក៏ត្រូវបាត់បង់។ ផ្លូវថ្នល់ និងស្ពានពី៧០ភាគរយទៅ៨០ភាគរយ ត្រូវបានអន្តរាយ។ ដីស្រែចម្ការត្រូវបានបោះបង់ចោល ហើយបានក្លាយទៅជាចម្ការមីន និងរណ្ដៅគ្រាប់B៥២។ សរុបមក អស្ថិរភាពនយោបាយដែលបង្កឡើងដោយសង្គ្រាមស៊ីវិល បាននាំមកនូវ

[348] មីហេយេវ, *ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា,* ដ.ឯ.ម., ទំព័រ៤៧៧-៤៧៨ ។

[349] ហេង ហុកវេន, *ការដួលរលំនៃរបបសាធារណរដ្ឋខ្មែរ*, និក្ខេបបទបណ្ឌិត, ភ្នំពេញ, ឆ្នាំ២០១៥, ទំព័រ២១៤។

វិនាសកម្មលើគ្រប់វិស័យ ដែលជាឱកាសដ៏ធំឱ្យកងកម្លាំងខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ហើយនាំប្រទេសកម្ពុជាឆ្ពោះទៅរករបបប្រល័យពូជសាសន៍។

**៦-សំណួរត្រិះរិះ**

១-ចូរវិភាគពីលេចឡើងនូវរបបសាធារណរដ្ឋខ្មែរ។

២-ហេតុអ្វីបានជាមានរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០? ផ្តល់ផលវិបាកអ្វីខ្លះ?

៣-តើពួកខ្មែរក្រហមមានសកម្មភាពយ៉ាងណា ដើម្បីអូសទាញប្រជាជនខ្មែរឱ្យគាំទ្រពួកគេ?

៤-តើមូលហេតុអ្វីខ្លះដែលធ្វើឱ្យរបបសាធារណរដ្ឋខ្មែរដួលរលំ?

៥-តើសង្គ្រាមស៊ីវិលឆ្នាំ១៩៧០-១៩៧៥ នាំមកនូវផលវិបាកអ្វីខ្លះ?

# មេរៀនទី១២ របបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)

## ១-តើខ្មែរក្រហមកើតឡើងដោយរបៀបណា?

យោងតាមការសិក្សាស្រាវស្រាវជ្រាវពាក្យ «ខ្មែរក្រហម» គឺជាពាក្យដែលកើតចេញពីភាសាបារាំងថា (Les *Khmers rouges*)។ ដែលពាក្យ Rouges នេះសំដៅលើពណ៌ក្រហម ហើយនៅទសវត្សរ៍ឆ្នាំ១៩៥០ សម្តេចព្រះនរោត្តម សីហនុ បានប្រើពាក្យ «ខ្មែរក្រហម» នេះសំដៅលើក្រុមឆ្វេងនិយម ដែលតែងតែប្រឆាំងនឹងការដឹកនាំរបស់ទ្រង់។ សម្តេចព្រះ នរោត្តម សីហនុ **បានប្រើពាក្យ «ខ្មែរក្រហម» នៅឆ្នាំ១៩៥៦** នៅក្នុង «ព្រះរាជសុន្ទរកថា ថ្លែងបញ្ជាក់អំពីព្រះរាជកម្មវិធីរបស់រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមទី៥ នៅចំពោះមុខរដ្ឋសភា ថ្ងៃទី១៥ កញ្ញា ១៩៥៦»។ ពាក្យ «ក្រហម» ត្រូវបានទ្រង់ប្រើជាមួយពាក្យ «និស្សិត» គឺនិស្សិតក្រហមដែលទ្រង់សំដៅលើនិស្សិតមួយចំនួនដែលទៅរៀននៅស្រុកបារាំង ហើយត្រឡប់មកវិញបានប្រឆាំងនឹងនយោបាយរបស់ទ្រង់[350]។ នៅក្នុងព្រះសារលិខិតមួយដែលបានចុះកាលបរិច្ឆេទនាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៦០ ដែលមានចំណងជើងថា ព្រះសារលិខិតនៃសម្តេចព្រះអគ្គមគ្គទេសក៍ខ្មែរទៅកាន់ពួកនិស្សិតក្រហមនោះបានរៀបរាប់ថា[351]*ក្នុងឱកាសដែលខ្ញុំបានធ្វើសន្និសីទនៅវិសនដ្ឋានកម្ពុជរដ្ឋយើងនេះ ខ្ញុំបានដំណឹងថាមាននិស្សិត«ក្រហម» ខ្លះបានរិះគន់ពេបជ្រាយចំពោះនិស្សិតដែលស្រលាញ់ទុកចិត្តខ្ញុំថាមិនគួរចេះតែជឿនូវពាក្យសំដីរបស់«សីហនុ» សោះ។ និស្សិតក្រហមនោះបើនិយាយពីខ្លួនខ្ញុំកាលណា រមែងតែហៅខ្ញុំដោយឈ្មោះ «សីហនុ» «សីហនុ» ដាច់សាច់។ និស្សិតក្រហមព្រហើនចំពោះខ្ញុំបែបនេះមិនជាអ្វីទេ ព្រោះខ្ញុំមិនរវល់នឹងការផតប្រយោជន៍ទាំងនេះទេ។ ខ្ញុំគ្រាន់តែសូមបញ្ជាក់ ជូនកូនចៅទាំងឡាយដែលនៅទីនេះជ្រាបចាប់តាំងពីអតីតកាល មកទល់បច្ចុប្បន្នកាលនេះ ខ្ញុំពុំដែលបោកបញ្ឆោទ ឬ ក្បត់ប្រជាជាតិដូចពួកខ្មែរក្រហម ទេ។* នៅមុនពេលដែលទ្រង់បានចេញព្រះសារលិខិតទៅកាន់ពួកនិស្សិតក្រហមនេះក៏មានញាត្តិរបស់សិស្ស និស្សិត បុគ្គលិក និងសាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិគរុកោសល្យក្រុងភ្នំពេញ[352] ថ្វាយចំពោះទ្រង់ពីក្តីព្រួយបារម្ភខ្លាចបែកបាក់សាមគ្គីជាតិ ក្នុងបណ្តាយុវជន សិស្ស និស្សិត និងសាស្ត្រាចារ្យក្នុងការជង្ហៃទ្រង់ ប្រែក្លាយទៅជាផ្តល់ផលប្រយោជន៍ទៅបរទេសដែលចង់បំផ្លាញអធិបតេយ្យ និងអព្យាក្រឹតរបស់ខ្មែរ[353]។

ចាប់ពីឆ្នាំ១៩៤៥ មហាអំណាចអង់គ្លេស, អាល្លឺម៉ង់ និងបារាំង មានបំណងពង្រីកឥទ្ធិពលមកលើរដ្ឋនានានៅអាស៊ីអាគ្នេយ៍ ដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្លួនពីមុនសង្គ្រាមលោកលើកទី២។ នៅខែកក្កដា ជប៉ុន, សហរដ្ឋអាម៉េរិក, អង់គ្លេស និងចិនបានបែងចែកតំបន់ត្រួតត្រាខាងផ្នែកយោធា។ និន្នាការនេះ បានជំរុញវៀតណាមដែលប្រឈមនឹងការកាន់កាប់របស់ប្រទេសចិនឱ្យរៀបចំបង្កើតរណសិរ្សជាតិ ដឹកនាំដោយ គណៈបក្សកុម្មុយនីស្តឥណ្ឌូចិន ក្នុងការកាន់កាប់រដ្ឋអំណាចទូទៅនៅប្រទេសវៀតណាម។ ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ ជាការប្រកាសសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម នៅក្រុងហាណូយ។ នៅពេលនោះកងទ័ពចិនស្ថិតក្រោមបញ្ជាការឧត្តមសេនីយ៍ Siao Wai មានចំនួន១៨០ ០០០នាក់ បានតាំងទីនៅក្រុងហាណូយនៅថ្ងៃទី៩ ខែកញ្ញា។ ចំណែកកងទ័ពអង់គ្លេសស្ថិតក្រោមបញ្ជាការ Douglas Gracey ចូលកាន់ក្រុងព្រៃនគរនៅ

---

[350] ទី សុផល, *សហគមន៍អន្តរជាតិ និង ដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៩១*, ជ.ឯ.ម.,។

[351] កាសែតអ្នកជាតិនិយម, ចុះផ្សាយថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៦០, ទំព័រ៣០។

[352] វិទ្យាស្ថានជាតិគរុកោសល្យក្រុងភ្នំពេញនាពេលបច្ចុប្បន្ននេះគឺមានឈ្មោះថា វិទ្យាស្ថានជាតិអប់រំ។

[353] ក្នុងចំណោម បុគ្គលិក និស្សិតនោះ ក៏មានឈ្មោះលោក កេង វ៉ាន់ សាក់, លោក សុន សេន ដែលពេលនោះជា Directeur d'Etudes ជាអ្នកមើលសណ្តាប់ធ្នាប់សិស្សដែលនៅវិទ្យាល័យ ឬ អនុវិទ្យាល័យនៅពេលនោះគេហៅថា Surveillant général។

ថ្ងៃទី១៣ ខែកញ្ញា។ ចំណែកបារាំងប្រគល់ភារកិច្ចឧត្តមនាវី George Thierry d'Argenlieu ទទួលបន្ទុកឥណ្ឌូចិន ហើយបន្ទាប់មកឧត្តមសេនីយ៍ Phillippe Leclerc ដែលបញ្ជាទ័ពនៅចុងបូព៌ាបានមកដល់ក្រុងព្រៃនគរនៅថ្ងៃទី៥ ខែតុលា។ ឥរិយាបថនៃរដ្ឋាភិបាលបារាំងរបស់ឧត្តមសេនីយ៍ De Gaulles ដែលមិនព្រមទទួលស្គាល់ការប្រកាសឯករាជ្យ និងការបង្រួបបង្រួមប្រទេសវៀតណាម និងការប្រើកម្លាំងបង្ក្រាបចលនាទាមទារទាំងនេះធ្វើឱ្យមានកើតសង្គ្រាមឥណ្ឌូចិន។

ការគ្រប់គ្រងរបស់បារាំងនៅឥណ្ឌូចិន បានធ្វើឱ្យប្រជាជនខ្មែររងទុក្ខលំបាក ដោយឃើញពីការ ធ្វើបាបពលរដ្ឋខ្លួននេះហើយ ដែលជាហេតុនាំឱ្យក្រុមពលរដ្ឋមួយចំនួនដែលមានគំនិតស្នេហាជាតិបានបោះបង់ការសិក្សាចូលតស៊ូ ។ ដូចជាលោកនួន ជា ពេលលោករៀន នៅប្រទេសថៃ និងធ្វើការនៅទីនោះផងនោះ លោកបានទទួលឃើញ សេចក្តីរាយការណ៍ផ្សេងៗ ពីទូតថៃនៅភ្នំពេញពីរឿងបារាំងបាញ់ប្រជាជនខ្មែរនោះ លោកក៏សុំឈប់ធ្វើការ ចេញមកតស៊ូ រំដោះជាតិនាឆ្នាំ១៩៥០ និង១៩៥១[354]។ តែពេលនោះវាគ្រាន់តែជាចលនាតស៊ូប្រឆាំងជាមួយបារាំងតែប៉ុណ្ណោះ ព្រោះក្រុមកុម្មុយនីស្តពេលនោះមិនទាន់ក្លាយជាកម្លាំងនយោបាយសំខាន់ប៉ុន្មានទេ ព្រោះដូចជាលោកខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ជាដើមធ្វើនយោបាយនៅក្នុងចលនាសង្គមរាស្ត្រនិយម ហើយខ្លះធ្លាប់បានកាន់តំណែងក្នុងរដ្ឋាភិបាលសង្គមរាស្ត្រនិយមទៀតផង។

ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៦៦ មានបដិវត្តន៍វប្បធម៌មួយបានផ្ទុះឡើងនៅប្រទេសចិន។ បដិវត្តន៍ដែលរៀបចំឡើងដើម្បីការពារ និងរក្សាអំណាចបក្សកុម្មុយនីស្តចិនរបស់ ម៉ៅ សេទុង បាននាំប្រទេសចិនឱ្យធ្លាក់ក្នុងព្យុះព្យោមា សង្គ្រាមស៊ីវិល ជំរំលត់ដំ កម្ទាត់ និងបោសសម្អាតអ្នកប្រឆាំង។ ចាប់ពីឆ្នាំ១៩៦៦មក ក្រោមការដឹកនាំរបស់ម៉ៅ បដិវត្តន៍វប្បធម៌មហាអស្ចារ្យពលករ បានអូសបន្លាយចិនរយៈពេលជិត១០ឆ្នាំ។ ចំពោះបដិវត្តន៍វប្បធម៌របស់ចិននេះត្រូវបានលោកឯកអគ្គរាជទូត បណ្ឌិតហូលីយ៉ូ ដែលជ្រេស នៃសាកលវិទ្យាល័យ ម៉ូណាហ្សេ និងជាអតីតព្រះរាជលេខាផ្ទាល់របស់សម្តេចព្រះនរោត្តម សីហនុ បានរៀបរាប់និងពន្យល់ថា[355] «នៅពេលដែលលោក ម៉ៅសេទុង(Mao Zedong)ចាប់ផ្តើមធ្វើបដិវត្តន៍វប្បធម៌ក្នុងប្រទេសចិននាខែតុលា ឆ្នាំ១៩៦៦ ស្ថាប័នដំបូងដែលធ្លាក់ក្នុងការគ្រប់គ្រងពួកមូលធនកំណែទម្រង់ស៊ីជម្រៅ (Some of the most radical new supporters of Sihanouk) និងពួកឆ្វេងក្រហមគឺ ក្រសួងការបរទេស ដែលក្រសួងនេះបានបន្តទៅកោះហៅឯកអគ្គរដ្ឋទូតរបស់សាធារណរដ្ឋប្រជាមានិតចិនទាំងអស់ឱ្យមកប្រទេសវិញ ហើយបញ្ជាឱ្យ ស្ថានទូតចិននៅក្រៅប្រទេសទាំងអស់ ឃោសនាអំពីបដិវត្តន៍វប្បធម៌ នៅតាមប្រទេសដែលទទួលស្គាល់ រដ្ឋាភិបាលរបស់ចិន។ លោកបណ្ឌិត លូ ស៊ាវហុង (Liu Xiao hong) អតីតអ្នកការទូតរបស់ចិន បានសង្កេតឃើញថា *គោលនយោបាយការបរទេសបែបមនោគមន៍វិជ្ជា នៃសម័យកាលបដិវត្តន៍វប្បធម៌ចិន បានកាត់បន្ថយភាពពាក់ព័ន្ធរបស់ចិននៅក្នុងទំនាក់ទំនងការទូត និងទំនាក់ទំនងជាមួយនឹងប្រទេសដទៃយ៉ាងខ្លាំងក្លា ហើយក្នុងពេលព្រមជាមួយគ្នានោះ បង្កើនសារៈសំខាន់នៃការទំនាក់ទំនងរបស់ចិនជាមួយបក្សកុម្មុយនីស្តឆ្វេងនិយមនៅបរទេស ជាពិសេសប្រទេសជិតខាងរបស់ចិនដូចជា កូរ៉េខាងជើង កម្ពុជា ភូមា*»។ នៅដើមឆ្នាំ១៩៦៦ ប៉ុល ពត បានធ្វើដំណើរពីហាណូយ ទៅប្រទេសចិនមួយថ្ងៃមុនពេលមានបដិវត្តន៍វប្បធម៌។ មន្ត្រីប្រទេសចិនបានប្រាប់ ប៉ុល ពត

[354] https://www.youtube.com/watch?v=UN1eZwXruTU.

[355] Ambassador Julio A. Jeldres, *Democratic Kampuchea's foreign policy: a leftover from the Chinese cultural revolution*, A Research Paper, May 2017, pp.2.

ថាប្រទេសចិន បានគាំទ្រការធ្វើបដិវត្តន៍នៅជុំវិញពិភពលោកដែលមិនផ្ដោតលើទិដ្ឋភាព និងកាតព្វកិច្ចរបស់សង្គមនិយមអន្តរជាតិ។ តាមការពិត ប្រទេសចិនគាំទ្របដិវត្តន៍ដែលបានឆ្លើយតបនឹងស្ថានភាពក្នុងស្រុករបស់ប្រទេសដែលធ្វើបដិវត្តន៍នោះច្រើនជាង។ នេះមានន័យថា ប្រទេសចិនទំនងជាគាំទ្របដិវត្តន៍របស់ប៉ុល ពត។ ដោយសារតែចិនគាំទ្រសម្ដេចព្រះនរោត្តម សីហនុ នោះការធ្វើ ទស្សនកិច្ចរបស់ប៉ុល ពត ត្រូវបានរក្សាការសម្ងាត់ ហើយមន្ត្រីដែលបានមកជាមួយនឹងប៉ុល ពត ត្រូវតែលាក់ការសម្ងាត់[356]។ នៅឆ្នាំ១៩៦៥ ដល់ឆ្នាំ ១៩៦៦ នេះចិនមានមុខពីរ ដោយម្ខាងឱបសម្ដេចព្រះនរោត្តម សីហនុ និងម្ខាងឱបប៉ុល ពត ដែលពេលនេះហើយជម្លោះរបស់ខ្មែរបានរបូតពីដៃរបស់ខ្មែរជាអ្នកដោះស្រាយដោយខ្លួនឯង។

បើយើងក្រឡេកទៅមើលប្រវត្តិរបស់ប៉ុល ពតវិញឃើញថាលោក ជាលេខាបក្សកុម្មុយនីស្តកម្ពុជាដែលជាតំណែងខ្ពស់បំផុតនៅក្នុងបក្ស និងជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ជាកូនចៅរបស់កសិករម្នាក់ ដែលពីតូចគាត់ធ្លាប់រួមរស់ធ្វើការងារស្រែចម្ការជាមួយឪពុកម្ដាយ។ ក្រោយមក មកនៅវត្ត ជាទំនៀមទម្លាប់ដើម្បីរៀនសូត្រអក្សរ។ យោងតាមលោក David Chandler គ្រួសាររបស់សាឡុត ស មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះបរមរាជវាំង។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩២០ បងស្រីជីដូនមួយម្នាក់របស់សាឡុត ស ឈ្មោះ មាយ គឺជាអ្នករាំបម្រើព្រះរាជទ្រព្យ។ សាឡុត ស ដែលរស់នៅជាមួយបង ប្រហែលជាបានអានកាសែតនេះជាប្រចាំ ពីព្រោះថា បើយោងតាមលោក David Chandler នាងមាយ និងសួង ដែលត្រូវជាបងរបស់សាឡុត ស បានជាវកាសែតនគរវត្តមកអានជាប្រចាំ។ នៅឆ្នាំ១៩៤៩ លោកបានទទួលអាហារូបករណ៍ ដើម្បីទៅបន្តការសិក្សានៅប្រទេសបារាំងផ្នែកអេឡិចត្រូនិច។ នៅពេលដែលទៅរៀននៅស្រុកបារាំងនេះហើយនាំឱ្យលោកបានចូលជាសមាជិកនៃបក្សកុម្មុយនីស្តបារាំង។ លោក បានត្រឡប់មកប្រទេសកម្ពុជាវិញនៅខែធ្នូ ឆ្នាំ ១៩៥២ ហើយបានចូលជាមួយចលនាតស៊ូកុម្មុយនីស្ត ក្រោមបញ្ជារបស់វៀតណាម ដើម្បីប្រឆាំងនឹងបារាំង។ លោកបានទាក់ទងជាមួយលោក ផាំ វ៉ាន់បា(Pham Van Ba) ដែលជាអ្នកតំណាងកុម្មុយនីស្តឥណ្ឌូចិននៅតាមតំបន់ដើម្បីសុំចូលជាសមាជិក[357]។ ពេលចប់ការសិក្សា និស្សិតទាំងឡាយចេញពីប្រទេសបារាំងមកកាន់មាតុភូមិវិញ(សាឡុត ស មកវិញនៅឆ្នាំ១៩៥២) ព្រមទាំងចាប់ផ្ដើមផ្សព្វផ្សាយគំនិតរបស់ពួកគេក្នុងចំណោមយុវវ័យ។ ពួកគេភាគច្រើនបង្រៀននៅសាលាឯកជនកម្ពុជបុត្រដែលក្លាយជាកន្លែងដ៏សំខាន់មួយអប់រំអំពីបដិវត្តន៍[358]។

## តើឥទ្ធិពលបដិវត្តន៍វប្បធម៌បារាំងចំពោះនិស្សិតខ្មែរនៅស្រុកបារាំងជាបញ្ហានាំឱ្យការកើតខ្មែរក្រហមមែនទេ?

គណបក្សប្រជាធិបតេយ្យដែលជាគណបក្សប្រឆាំងនឹងបារាំង បានបញ្ជូននិស្សិតដែលគាំទ្របក្សខ្លួនទៅរៀននៅស្រុកបារាំង។ និស្សិតដែលគាំទ្រលទ្ធិប្រជាធិបតេយ្យមានឈ្មោះនៅឆ្នាំ១៩៤៩-១៩៥២ រួមមាន ប៉ុល ពត, សុន សេន, អៀង សារី និងខៀវ សំផន ដែលអ្នកទាំងអស់នោះបានក្លាយជាសមាជិកបក្សកុម្មុយនីស្តបារាំង រួមទាំងនិស្សិតផ្សេងៗទៀតដែលមិនបានក្លាយជាសមាជិកបក្សទេ។ ក្រុមអ្នកទាំងអស់នេះហើយដែលបានក្លាយសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន។ ក្រោយមកអ្ន កទាំងអស់នេះ ក៏បានក្លាយជាលេខាបក្ស អនុលេខាបក្ស និងជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា និងជាអ្នកដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ។

---

356 ដេវីឌ ឆាណ្ឌល័រ, *ខ្មែរក្រហមក្នុងបរិបទសង្គ្រាមត្រជាក់,* មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងវគ្គបណ្ដុះបណ្ដាលសាស្ត្រាចារ្យសាកលវិទ្យាល័យ (២៥-២៧ ខែកក្កដា ឆ្នាំ២០១៧), ទំព័រ១៩។

357 សារព័ត៌មានស្មារតីជាតិខ្មែរ, *ចុះថ្ងៃទី១៦-៤-១៩៩២* អត្ថបទ នរណាជាឃាតករ, ហ៊ិន ស៊ីថាន់។

358 ហ្វ្រង់ស្វ័រ ប៉ុងសូដ៏, *ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា,* ដ.ឯ.ម., ទំព័រទី៧១។

ចលនាខ្មែរកុម្មុយនីស្ត ដែលបានកកើតឡើងនៅក្នុងប្រទេសកម្ពុជា ក្រោយកិច្ចព្រមព្រៀងក្រុងហ្សឺណែវឆ្នាំ ១៩៥៤ មានទំនាក់ទំនងជិតស្និទ្ធវាំងបញ្ញវន្តខ្មែរមួយក្រុម មានដូចជា សាឡុត ស, នួន ជា និងអ្នកតស៊ូប្រឆាំងបារាំងមួយចំនួនទៀតដូចជា ទូ សាមុត, ស៊ីវ ហេង ជាដើមដែលមានខ្សែរយៈជាមួយអង្គការវៀតមិញ។ ប៉ុន្តែ សាឡុត ស ដែលជាអតីតសមាជិកម្នាក់នៃសមាគមនិស្សិតខ្មែរនៅស្រុកបារាំងនាឆ្នាំ១៩៥០ នឹងដើរតួនាទីយ៉ាងសំខាន់នៅចន្លោះឆ្នាំ១៩៦២-១៩៧៩[359]។ ទសវត្សរ៍ឆ្នាំ១៩៥០នេះ ពួកយុវជនស្រករៗសាឡុត ស បានពិភាក្សាគ្នាមិនចេះចប់អំពីនយោបាយ, សិល្បៈ និងទស្សនវិជ្ជា។ ពួកគេដឹងថាបន្ទាប់ពីសង្គ្រាមលោកលើកទី២ ពិភពលោកថ្មីមួយនឹងចាប់កំណើតឡើង។ ដើម្បីយល់ដឹងពីការផ្លាស់ប្តូរគំនិតរបស់សាឡុត ស ទៅរកលទ្ធិកុម្មុយនីស្ត គេត្រូវដាក់គាត់នៅកន្លែងដដែលវិញក្នុងហេតុការណ៍ ដែលកើតមានជុំវិញហាងកាហ្វេទាំងឡាយនៅសង្កាត់ឡាតាំង ជាកន្លែងដែលយុវជនប្រុស ស្រីរាប់ពាន់នាក់បានប្រកាសយក ស្ថានភាពខាងផ្លូវនយោបាយមួយរបៀបដូចគ្នា។ នៅឆ្នាំ១៩៥១ គាត់បានត្រូវនាំយកទៅដោយរលកសុទិដ្ឋិនិយមទាក់ទងនឹងអនាគត នៃចលនាកុម្មុយនីស្តពិភពលោកថែមទៀត។ ដោយផ្ទុយនឹងអ្នកស្រករៗគាត់ជាច្រើន សាឡុត ស មិនដែលបោះបង់លទ្ធិកុម្មុយនីស្តសោះឡើយ ហើយក៏មិនដែលសោកស្តាយចំពោះការសម្រេចចិត្តរបស់គាត់ដែរ។ ក្នុងមួយជីវិតរបស់គាត់គាត់នៅតែស្មោះត្រង់ចំពោះបុព្វហេតុបដិវត្តន៍ជានិច្ច[360]។

## ២-កម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយជ្រុលនិយម

នៅវេលាមួយនៃការរំដោះក្រុងភ្នំពេញជាលើកដំបូងគឺ ជាពន្លឺមួយដែលប្រជាពលរដ្ឋខ្មែរចាប់ផ្តើមមើលឃើញសន្សឹមៗដោយនឹកស្រមើស្រមៃគិតថា ខ្លួនរួចផុតពីរបបដែលមានតែការជិះជាន់ កេងប្រវ័ញ្ច អំពើពុករលួយប្រកាន់បក្សពួកនោះហើយ ប៉ុន្តែគួរឱ្យស្តាយក្នុងរយៈពេលជាងបីឆ្នាំកន្លះក្រោយពីការដណ្តើមបានក្រុងភ្នំពេញនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាសម័យការដែលពោរពេញទៅដោយក្តីរន្ធត់ភាព ស្រមើស្រមៃការភ័យខ្លាច ការសង្ស័យគ្រប់ពេលវេលារបស់ពលរដ្ឋខ្មែរទៅវិញ។ នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាពេលវេលាមួយដែលខ្មែរក្រហមចូលកាន់កាប់ក្រុងភ្នំពេញ បានបណ្តេញប្រជាជនឱ្យចេញតាមតំបន់ភូមិភាគដែលគេបានព្រៀងទុក។ ខ្មែរក្រហមបានប្រជុំគណៈអចិន្ត្រៃយ៍រួមជាមួយសមាជិកមជ្ឈិមមិនពេញអង្គខ្លះនៅពាក់កណ្តាលឆ្នាំ១៩៧៤ ស្តីពីការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និងទីរួមខេត្ត។ ដោយឃើញហេតុការណ៍បែបនេះ គ្រប់ៗគ្នាបានធ្វើដំណើរទៅដែលមានកងទ័ពដាក់តម្រៀបគ្នាជាជួរ រហូតដល់ ទិសដៅទាំងប្រាំមួយភូមិភាគដូចខាងក្រោម[361] ៖

- ប្រជាជនដែលរស់នៅខាងកើតភាគខាងត្បូងភ្នំពេញត្រូវបញ្ជូនទៅខេត្តព្រៃវែង និងស្វាយរៀង។
- ប្រជាជន ដែលរស់នៅខាងកើតភាគខាងជើងភ្នំពេញត្រូវបញ្ជូនទៅខេត្តកំពង់ចាម,ខេត្តកំពង់ធំ និងខេត្តសៀមរាប។
- ប្រជាជនដែលរស់នៅខាងលិចភាគខាងជើងភ្នំពេញត្រូវបញ្ជូនទៅខេត្តពោធិ៍សាត់និងបាត់ដំបង។
- ប្រជាជនដែលរស់នៅខាងលិចភាគខាងត្បូងភ្នំពេញត្រូវបញ្ជូនទៅខេត្តកំពង់ឆ្នាំងនិងកំពង់ស្ពឺ ។
- ប្រជាជនដែលរស់នៅខាងត្បូងភាគខាងលិចត្រូវបញ្ជូនទៅខេត្តកំពត និងតាកែវ។

---

[359] វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រសង្ខេបនៅប្រទេសកម្ពុជា*, ភាគ១, ដ.ឯ.ម., ទំព័រ៨៣-៨៤។

[360] ដេវិឌ ឆាណ្ឌល័រ, *ប៉ុលពត បងធំទី១*, ដ.ឯ.ម., ទំព័រ៥១។

[361] ទស្សនាវដ្តីស្វែងរកការពិត, *លេខ២៤ខែ មេសា ឆ្នាំ ២០០០*, ទំព័រ៣។

– ប្រជាជនដែលរស់នៅភាគខាងត្បូងភាគខាងកើតត្រូវបញ្ជូនទៅខេត្តតាកែវ និងផ្លូវជាតិលេខ២។

ការធ្វើដំណើរចាកចេញ របស់ប្រជាជនមើលទៅហាក់ដូចជាគ្មានគោលដៅ និងគ្មានថ្ងៃត្រលប់ក្រោយវិញឡើយគឺ ពួកគេធ្វើដំណើរទៅតាមការចង្អុលបង្ហាញរបស់ពួកខ្មែរក្រហមដែលគេមានគម្រោងរៀបចំទុកជាស្រេច។ ពួកខ្មែរក្រហមចាប់ផ្ដើមការបដិវត្តន៍ទី២របស់ខ្លួននៅថ្ងៃដែលពួកគេដណ្ដើមបានជ័យជម្នះ។ ជំហានដំបូងនៃយុទ្ធសាស្ត្ររបស់គេគឺ ដំណាក់កាលប្រើ «នយោបាយកុម្មុយនីស្តនៃសង្គ្រាម» បានបន្តស្ថិតមានរហូតដល់ពេលដែលគេរៀបចំកម្មវិធីមួយជាផ្លូវការសម្រាប់មហាសន្និបាតទី៤ របស់បក្ស ដែលប្រារព្ធធ្វើនៅ ខែមករា ឆ្នាំ១៩៧៦។ ជាមួយការជម្លៀស និងការផ្លាស់ប្ដូរទីលំនៅដោយបង្ខំឱ្យប្រជាជនទៅរស់នៅតាមជនបទ ពួកខ្មែរក្រហមបែរជាបដិវត្តន៍ផ្លាស់ប្ដូរវប្បធម៌មួយគួរឱ្យភ័យខ្លាច ដែលអ្នកនៅក្រុងនាពេលនោះមួយចំនួនបានគិតទុកក្នុងចិត្តរបស់ពួកគេ។ បើយោងតាមការសង្ខេបដោយគណៈកម្មាធិការនយោបាយនៃកងវរសេនាធំខ្មែរក្រហម ដែលបានដកស្រង់ដោយប្រវត្តិវិទូ Ben Kiernanថា នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដាក់ចេញឱ្យអនុវត្តគោលការណ៍៨ចំណុចៈ[362]

១- ជម្លៀសប្រជាជនចេញពីក្រុងទាំងអស់

២- លុបបំបាត់ទីផ្សារ

៣- លុបបំបាត់ការប្រើប្រាស់រូបិយវត្ថុរបស់របបលន់ នល់ និងដកឈប់ឱ្យប្រើប្រាស់នូវរូបិយវត្ថុបដិវត្តន៍ដែលបានបោះពុម្ពរួច

៤- ផ្សឹកព្រះសង្ឃក្នុងសំណាក់ព្រះពុទ្ធសាសនាទាំងអស់ ហើយឱ្យទៅធ្វើស្រែចម្ការ

៥- ប្រហារជីវិតមេដឹកនាំក្នុងរបបសាធារណរដ្ឋខ្មែរទាំងអស់ ដោយផ្ដើមចេញពីមេដឹកនាំកំពូល

៦- បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស ជាមួយនឹងការបរិភោគរួមគ្នា

៧- បណ្ដេញជនជាតិភាគតិចវៀតណាមឱ្យចេញទាំងអស់

៨- បញ្ជូនទ័ពទៅតាមព្រំដែន ជាពិសេសព្រំប្រទល់កម្ពុជា-វៀតណាម។

**នៅក្នុងរបបនេះសមាជិកមួយចំនួន មានតួនាទីធំទាំងក្នុងបក្ស និងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ**

| ល.រ | ឈ្មោះ | តួនាទីក្នុងបក្សកុម្មុយនីស្តកម្ពុជា | តួនាទីក្នុងការគ្រប់គ្រងរដ្ឋ |
|---|---|---|---|
| ១ | ប៉ុល ពត | លេខាបក្ស | នាយករដ្ឋមន្ត្រី |
| ២ | នួន ជា | អនុលេខាបក្ស | ប្រធានសភាតំណាងប្រជាជនបដិវត្តន៍កម្ពុជា |
| ៣ | សោ ភឹម | សមាជិក | កាន់កាប់ភូមិភាគបូព៌ា(២០៣) |
| ៤. | អៀង សារី | សមាជិក | ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេស |
| ៥ | សុន សេន | សមាជិក | ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិ |
| ៦ | ឈិន ជឿន ហៅ តាម៉ុក | សមាជិក | អនុប្រធានសភាតំណាងប្រជាជនបដិវត្តន៍កម្ពុជា និងកាន់កាប់ភូមិភាគនិរតី(៤០៥) |

[362] ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៥៨៨។

| | | | |
|---|---|---|---|
| ៧ | វន វេត | សមាជិក | ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច |
| ៨ | កែ ពក | សមាជិក | លេខា ភូមិភាគឧត្តរ(៣០៣) |
| ៩ | ខៀវ សំផន | សមាជិក(ឆ្នាំ១៩៧៦) | ប្រមុខរដ្ឋ |
| ១០ | រស់ ញឹម | សមាជិក | កាន់កាប់ភូមិភាគពាយ័ព្យ(៥៦០) |

នៅឆ្នាំ១៩៧៦បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកតំបន់រដ្ឋបាលជា៦ភូមិភាគ ដែលរួមមាន៣២តំបន់ ភូមិភាគនីមួយៗចែកជាតំបន់ ហើយតំបន់នីមួយៗចែកជាស្រុក និងឃុំតាមលំដាប់ថ្នាក់។ នៅឆ្នាំ១៩៧៦ មានការបង្កើតតំបន់ស្វយ័តពីរទៀត ដែលមិនចំណុះឱ្យភូមិភាគដែលតំបន់ទាំងពីរនេះមានតំបន់សៀមរាប-ឧត្តរមានជ័យ(តំបន់១០៦) និងតំបន់ព្រះវិហារ(តំបន់១០៣)។ ចំណែកក្រុងព្រះសីហនុ ក៏ត្រូវចាត់តាំងដោយឡែកពីភូមិភាគដែរ។ នៅឆ្នាំ១៩៧៧ បានបែងចែកជា៧ភូមិភាគវិញដោយមានបង្កើតនូវ ភូមិភាគកណ្តាល មួយទៀត។ ភូមិភាគថ្មីនេះស្ថិតនៅត្រង់អតីតភូមិភាគឧត្តរ។ ចំណែកភូមិភាគឧត្តរថ្មី ត្រូវបានប្តូរទីតាំងតំបន់សៀមរាប-ឧត្តរមានជ័យ និងព្រះវិហារ។ តំបន់ក្រចេះ(៥០៥) និងតំបន់មណ្ឌលគិរី(១០៥) ត្រូវបំបែកចេញពីភូមិភាគឦសាន្ត និងចាត់តាំងជាតំបន់ស្វយ័ត នៅថ្នាក់ឃុំមានការបែងចែកជា សហករណ៍។ ភូមិភាគ តំបន់ និងស្រុកទាំងអស់ សុទ្ធតែមានលេខសម្គាល់ ដើម្បីរក្សាការសម្ងាត់តាំងពីអំឡុងពេលធ្វើសង្គ្រាម រហូតដល់ពេលគ្រប់គ្រងប្រទេស។ ខាងក្រោមនេះជាព័ត៌មានដែលទាក់ទងនឹងភូមិភាគនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[363]។

| ល.រ | ឈ្មោះភូមិភាគ | ព័ត៌មានសំខាន់ៗ |
|---|---|---|
| ១ | បូព៌ា (ភូមិភាគ ២០៣) | ភូមិភាគបូព៌ាមានមូលដ្ឋាននៅស្វាយ ដឹកនាំដោយ សោ ភឹម ដែលធ្វើអត្តឃាតនៅឧសភា ឆ្នាំ១៩៧៨។ ភូមិភាគនេះរួមមានខេត្តព្រៃវែង និងខេត្តស្វាយរៀងទាំងមូល ផ្នែកខ្លះនៃខេត្ត កំពង់ចាម ដែលស្ថិតនៅត្រើយខាងកើតទន្លេមេគង្គទាំងអស់ កាត់ចេញពីស្រុកមួយក្នុងខេត្តក្រចេះគឺ ស្រុកឆ្លូង និងកាត់យកស្រុកខ្លះពីខេត្តកណ្តាល មានស្រុកខ្សាច់កណ្តាល ល្វាឯម និងមុខកំពូល។ ភូមិភាគនេះចែកចេញជាប្រាំតំបន់គឺតំបន់ ២០, ២១, ២២, ២៣ និង២៤។ |
| ២ | និរតី (ភូមិភាគ ៤០៥) | ភូមិភាគនិរតីមានមូលដ្ឋាននៅខេត្តតាកែវដឹកនាំដោយឈិត ជឿន ហៅតាម៉ុក។ ភូមិភាគនេះរួមមានខេត្តកំពត និងខេត្តតាកែវទាំងមូល ស្រុកពីរក្នុងខេត្តកំពង់ស្ពឺ គឺស្រុកសំរោងទង និងស្រុកគងពិសី រួមទាំងស្រុកប្រាំក្នុងខេត្តកណ្តាល គឺស្រុកកណ្តាលស្ទឹង, ស្អាង, កោះធំ, កៀនស្វាយ និងស្រុកលើកដែក។ ភូមិភាគ |

[363] មជ្ឈមណ្ឌលឯកសារកម្ពុជា, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*, ឆ្នាំ២០២០, ទំព័រ៣៣។

| | | |
|---|---|---|
| | | នេះចែកចេញជាបួនតំបន់គឺតំបន់១៣, តំបន់៣៣, តំបន់៣៥ និងតំបន់២៥ ។ |
| ៣ | ឧត្តរ (ភូមិភាគ ៣០៣) | ភូមិភាគឧត្តរដឹកនាំដោយ កុយ ធួន ហៅ ធុច ពីឆ្នាំ១៩៧០ ដល់ដើមឆ្នាំ១៩៧៦។ បន្ទាប់ពី កុយ ធួន ត្រូវបានចាប់ខ្លួន និងសម្លាប់នៅគុកទួលស្លែង។ នៅឆ្នាំ ១៩៧៦ កែ ពក ត្រូវបានចាត់តាំងជាលេខាភូមិភាគ។ នៅឆ្នាំ១៩៧៧ កែ ពក ត្រូវបានចាត់តាំងឱ្យធ្វើជាលេខាភូមិភាគកណ្ដាល ដែលទើបបង្កើតថ្មី ហើយលេខាថ្មីរបស់ភូមិភាគឧត្តរគឺ កង ចាប។ ភូមិភាគនេះរួមមានខេត្តកំពង់ធំ ផ្នែកខាងលិច(ខាងស្តាំ)ទន្លេមេគង្គទាំងអស់នៃខេត្តកំពង់ចាម និងស្រុកមួយក្នុងខេត្តក្រចេះ គឺស្រុកព្រែកប្រសប់ ហើយចែកចេញជាបីតំបន់គឺ៤១, ៤២ និង៤៣។ |
| ៤ | ពាយ័ព្យ(ភូមិភាគ៥៦០) | ភូមិភាគពាយ័ព្យដឹកនាំដោយ រស់ ញឹម[364] ដែលមានឈ្មោះដើម មូល សម្បត្តិ។ ភូមិភាគនេះរួមមានខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលចែកចេញជាប្រាំពីរតំបន់ រួមមានតំបន់១, ២, ៣, ៤, ៥ , ៦ និង៧។ |
| ៥ | បស្ចិម(ភូមិភាគ ៤០១) | ភូមិភាគបស្ចិមដឹកនាំដោយ ជូ ជេត។ ភូមិភាគនេះរួមមាន ខេត្តកោះកុង និងខេត្តកំពង់ឆ្នាំង និងផ្នែកខាងជើងផ្លូវជាតិលេខ៤នៃខេត្តកំពង់ស្ពឺ ហើយចែកចេញជាប្រាំតំបន់គឺ៣១, ៣២, ៣៧, ១៥ និង១១។ |
| ៦ | ឦសាន(ភូមិភាគ ១០៨) | ភូមិភាគឦសានដឹកនាំដោយ ណៃ សារ៉ាន់ ហៅ យ៉ា ត្រូវបានសម្លាប់នៅឆ្នាំ១៩៧៦។ ភូមិភាគនេះរួមមានខេត្តរតនគិរី ខេត្តមណ្ឌលគិរី ផ្នែកខ្លះនៃខេត្តក្រចេះនិងផ្នែកខ្លះនៃខេត្តស្ទឹងត្រែងដែលស្ថិតនៅត្រើយខាងលិច និងខាងកើតទន្លេមេគង្គ។ ភូមិភាគនេះចែកចេញជាប្រាំមួយតំបន់ គឺ១០១, ១០២, ១០៤, ១០៥, ១០៧ និង៥០៥ ។ |
| ៧ | តំបន់ស្វយ័ត និងភូមិភាគកណ្ដាល | ក្នុងឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យបានបង្កើតតំបន់ស្វយ័តចំនួនពីរផ្សេងទៀត ដែលទាក់ទង ការងារផ្ទាល់ជាមួយគណៈកម្មាធិការមជ្ឈិមបក្ស។ តំបន់ទាំងនេះមានតំបន់សៀមរាប ឧត្តរមានជ័យ(តំបន់១០៦) |

[364] រស់ ញឹម មិនមែន ញឹម រស់ ទេ។

| | | |
|---|---|---|
| | | និងតំបន់ព្រះវិហារ(តំបន់១០៣)។ ក្រុងកំពង់សោម (បច្ចុប្បន្នខេត្តព្រះសីហនុ) ក៏ត្រូវបានចាត់តាំងដោយឡែកពីភូមិភាគដែរ។ នៅឆ្នាំ៩៧៧ ភូមិភាគថ្មីមួយទៀតគឺភូមិភាគកណ្តាលត្រូវបានបង្កើតឡើង។ ភូមិភាគនេះមានទីតាំងស្ថិតនៅត្រង់អតីតភូមិភាគឧត្តរ។ ចំណែកភូមិភាគឧត្តរថ្មីត្រូវបានប្តូរទីតាំងទៅតំបន់សៀមរាបឧត្តរ មានជ័យ និងតំបន់ព្រះវិហារ ដែលជាអតីតតំបន់ពិសេស។ តំបន់ក្រចេះ(តំបន់៥០៥) និងតំបន់មណ្ឌលគីរី (តំបន់ ១០៥) ត្រូវបានបំបែកចេញពីភូមិភាគឦសាន និងបង្កើតជាតំបន់ស្វយ័ត។ |

ក្នុងគោលនយោបាយជ្រុលនិយមនេះ ខ្មែរក្រហមបានកំណត់ផែនការសេដ្ឋកិច្ចបែបកាត់ក្បាលតម្រូវម្ចុក។ ខ្មែរក្រហមបានធ្វើការបោសសម្អាតប្រជាជនចេញពីក្រុង និងទីប្រជុំជននានា ដើម្បីកសាងកម្ពុជាមួយថ្មី និងមានភាពដាច់ខាត។ នៅឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានប្រញាប់ប្រញាល់រៀបចំផែនការបួនឆ្នាំលើកទីមួយពីឆ្នាំ១៩៧៧-១៩៨០ ដែលតម្រូវឱ្យប្រមូលផ្តុំសម្បត្តិឯកជនទាំងអស់ និងផែនការដាំដុះស្រូវជាអាទិភាពរបស់ជាតិ។ បញ្ហាសន្តិសុខជាតិ សមូហភាវូបនីយកម្ម គឺជាគោលនយោបាយដ៏សំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៧៦ អង្គការតម្រូវឱ្យប្រមូលទ្រព្យសម្បត្តិឯកជនទាំងអស់រួមទាំងសម្ភារផ្ទះបាយផង ទុកជាសម្បត្តិសមូហភាព និងប្រើប្រាស់រួម ព្រមទាំងបែងចែកកម្លាំងពលកម្មទៅតាមក្រុមរៀងៗខ្លួនដូចជា បុរស ស្ត្រី កុមារ ជាដើម។ ផែនការបួនឆ្នាំមានគោលដៅពង្រីកផលិតផលស្រូវ ធ្វើយ៉ាងណាឱ្យទិន្នផលជាមធ្យមទទួលបានបីតោនក្នុងមួយហិកតា។

ម្យ៉ាងទៀត ផែនការបួនឆ្នាំមានរួមបញ្ចូលទាំងគម្រោងដាំបន្លែបង្ការ អនុផលព្រៃឈើ ការនេសាទ ការចិញ្ចឹមសត្វ និងការដាំដើមឈើ។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យសង្ឃឹមថា នឹងធ្វើឱ្យកម្ពុជាមានឯករាជ្យពេញបរិបូរណ៍ទាំងវិស័យសេដ្ឋកិច្ច និងវិស័យនយោបាយ ដោយប្រែក្លាយកម្ពុជាពីប្រទេសកសិកម្មអន់ថយ ឱ្យទៅជាកសិកម្មទំនើបមួយ។ ទិន្នផលស្រូវក្នុងផែនការបួនឆ្នាំនេះ ត្រូវបានគេបែងចែកជាបួនចំណែក។ មួយចំណែក សម្រាប់ ជាស្បៀងរបស់ប្រជាជន ដែលម្នាក់ទទួលបាន៣១២គីឡូក្រាមស្រូវក្នុងមួយឆ្នាំ ឬ ០.៨៥ គីឡូក្រាមស្រូវសម្រាប់ពលរដ្ឋម្នាក់ក្នុងមួយថ្ងៃ។ ក្រៅពីនេះ មានស្រូវសម្រាប់ធ្វើពូជ និងស្រូវសម្រាប់ទុកបម្រុង។ ស្រូវសល់ពីការបែងចែកខាងលើត្រូវនាំចេញទៅបរទេស ហើយនាំចូលមកវិញនូវម៉ាស៊ីនសម្រាប់ធ្វើស្រែចម្ការ គ្រឿងសព្វាវុធ និងសម្ភារប្រើប្រាស់ផ្សេងៗទៀត។ ទោះយ៉ាងណា ផែនការនេះផ្តោតលើលទ្ធផលដោយពុំបានគិតពីលទ្ធភាពរបស់ប្រជាជនខ្មែរដែលឆ្លងកាត់សង្គ្រាមអស់រយៈពេលជាច្រើន ខ្វះខាតកម្លាំងពលកម្មនិងសត្វពាហនៈ ដីធ្លីត្រូវបោះបង់ចោលជាច្រើនកន្លែង ហើយផលិតកម្មស្បៀងនៅតែប្រព្រឹត្តដោយប្រើកម្លាំងមនុស្សសុទ្ធសាធ។ ដូច្នេះតាមរយៈផែនការនេះ ប្រជាជននៅទូទាំងប្រទេស ត្រូវបង្ខំឱ្យធ្វើការធ្ងន់ធ្ងរជាច្រើនម៉ោងក្នុងមួយថ្ងៃ ដើម្បីបំពេញឱ្យទាន់ផែនការផលិតស្រូវ។ លើសពីនេះទៀត ស្បៀងអាហារសម្រាប់

ប្រជាជនហូបដែលមានក្នុងផែនការពុំត្រូវបានអនុវត្តនោះទេ នៅតំបន់ជាច្រើនប្រជាជនអត់ឃ្លាន និងជួបគ្រោះទុរភិក្ស។ មនុស្សជាច្រើនស្លាប់ដោយសារការធ្វើការហួសកម្លាំង និងអត់ឃ្លាន។

**ផែនទីកម្ពុជាប្រជាធិបតេយ្យ (១៩៧៦)**




**ប្រភព:** មជ្ឈមណ្ឌលឯកសារកម្ពុជា

## ៣-ប្រព័ន្ធសន្តិសុខ និងអំពើប្រល័យពូជសាសន៍

ជ័យជម្នះ និងអំណរសោទររបស់ប្រជាជននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាជ័យជម្នះមួយបង្កប់នៅអាថ៌កំបាំងដែលពលរដ្ឋនឹកស្មានមិនដល់។ ជាមួយនឹងជ័យជម្នះ ការប្រុងប្រយ័ត្នរបស់គេរឹតតែត្រូវបង្កើតកាន់ខ្លាំងជាជាងត្រូវបន្ធូរបន្ថយ[365] ជាជ័យជម្នះដែលឈ្នះដោយចុងកាណុង។ ភាពសង្ស័យរបស់មេខ្មែរក្រហមនៅតែមានមិនចេះចប់ មិនចេះហើយទោះបីពួកគេបានលើកសរសើរដល់ប្រជាជនជាញឹកញាប់ក្នុង សេចក្តីថ្លែងការនានា និងតាម រយៈបទចម្រៀងដែលគេនិពន្ធក៏ដោយ។ អ្វីដែលពួកខ្មែរក្រហមមានការសង្ស័យបំផុតនោះគឺរបបសង្គមចាស់ដែលពួកគេគិតថាសំបុករបស់សត្រូវ ហើយមុខព្រួញក្នុងការបោសសម្អាតដ៏សំខាន់របស់ពួកគេ។ ពួកគេមានការសង្ស័យគ្រប់បែបយ៉ាង សូម្បីតែនិយាយប្រាស្រ័យទាក់ទងគ្នាក៏ពួកគេហាមឃាត់ដែរ។ ពួកគេគិតថាពួកអ្នកដែលស្មោះនឹងអង្គការមានតែវណ្ណៈកម្មករ កសិករ និងទាហានតែប៉ុណ្ណោះ។ ដោយបញ្ហាសង្ស័យនេះហើយធ្វើឱ្យ ប្រជាជនបាត់បង់នូវសេរីភាពរបស់ពួកគេដោយសិទ្ធិទាំងអស់ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ «អង្គការ»។ អង្គការនេះជាពាក្យមួយម៉ាត់ដែលគេសំដៅលើអំណាច៣ គឺអំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ

[365] អេលីហ្សាបែក បេិកខិរ, *នៅពេលដែលសង្គ្រាមលេត់ទៅ*, ប្រែសម្រួលជាភាសាខ្មែរដោយ ទេព ម៉េងឃាន និងសុគ្គា អ៊ីវ៉ែន, មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០០៥, ទំព័រ១៨២។

និងអំណាចតុលាការ ហើយពាក្យនេះប្រភពនៃអំណាច និងឥទ្ធិពលដែលមិនសំដៅទៅបុគ្គល។ គ្រាន់តែឮពាក្យថា «អង្គការ» នេះប្រជាជនខ្មែរនៅពេលនោះត្រូវតែធ្វើតាមគឺ ហាក់ដូចជាពលរដ្ឋដែលកំពុងតែមានជំនឿយ៉ាងមុតមាំទៅលើសាសនាដូច្នេះដែរ។

ការចាប់ផ្ដើមពីបដិវត្តន៍ដែលម៉ៅហៅថា «យុវជនសម័យថ្មី» ត្រូវបាន ប៉ុល ពត យកមកអនុវត្តនៅកម្ពុជាដែលបណ្ដាលឱ្យប្រជាជនខ្មែរស្លាប់អស់ប្រហែល២លាននាក់[366]។ ប៉ុល ពត ជាជនកុម្មុយនីស្តផ្ដាច់ការជ្រុលនិយម ដែលយកគោលគំរូតាមម៉ៅស្ទើរតែទាំងស្រុង គឺគេជម្លៀសប្រជាជនចេញពីក្រុង ដើម្បីយកទៅកសាងវណ្ណៈថ្មីមួយ ដែលស្អាតស្អំពឹងទៅលើរបរកសិកម្មសមូហភាព គឺកសាងប្រទេសពីកសិករបាតដៃទទេ ហើយប្រជាជនណាដែលជាប់ពាក់ព័ន្ធមូលធននិយមដូចជា មន្ត្រីរាជការរបបមុន និស្សិត បញ្ញវន្ត ពាណិជ្ជករ សាស្ត្រាចារ្យ...ត្រូវបានពួកគេសម្លាប់គ្មានសល់។ មានមូលហេតុជាច្រើនដែលនាំឱ្យ ប៉ុល ពត ជម្លៀស ប្រជាជនចេញពីក្រុងហើយឈានទៅដល់ការសម្លាប់ស្ទើរតែពេញផ្ទៃប្រទេសនោះគឺៈ

១-ប្រកាន់យកបដិវត្តន៍កុម្មុយនីស្តធ្វើជាមាគ៌ាតស៊ូនោះតម្រូវឱ្យមានការ«កម្ទេច» ដើម្បី«កសាងជាថ្មី»

២-គោលការណ៍«មហាលោតផ្លោះមហាអស្ចារ្យ»ដើម្បីសម្រេចគោលដៅឱ្យឆាបរហ័ស

៣-គំនិតស្នេហាជាតិនិយមងងឹតងងុលតម្រូវឱ្យជឿជាក់តែលើអង្គការមួយបើពុំនោះទេសម្លាប់ចោល

៤-ការអប់រំបំពាក់កំហឹងវណ្ណៈដល់កម្មាភិបាលខ្មែរក្រហម តាំងពីមុនឆ្នាំ១៩៧៥ឱ្យប្រឆាំង និងសងសឹកចំពោះវណ្ណៈក្រៅពីកម្មករ កសិករក្រីក្រ ដោយមេដឹកនាំជាន់ខ្ពស់របស់អង្គការ

៥-នយោបាយវិមជ្ឈការសិទ្ធិអំណាចកាប់សម្លាប់មនុស្ស ដល់កម្មាភិបាលថ្នាក់ទាបដែលភាគច្រើនជាមនុស្សមានការសិក្សាតិចតួច ឬល្ងង់ខ្លៅ និងបានក្លាយជាអ្នកដឹកនាំតាមមូលដ្ឋាន

៦-ប៉ុល ពត មានជំងឺសង្ស័យថា មានសត្រូវលាក់មុខនៅជុំវិញខ្លួនកំពុងរៀបផែនការក្បត់សម្លាប់គាត់ទើបគាត់ចាត់ការសម្លាប់សមមិត្តរបស់ខ្លួនយ៉ាងរង្គាលតាមខ្សែនីមួយៗ

៧-គោលនយោបាយបោសសម្អាត សម្រិតសម្រាំង ខ្មាំង (purge) ចាប់តាំងពីមន្ត្រីរដ្ឋការ និងយោធាក្នុងរបបចាស់, ប្រជាជន១៧មេសា រហូតដល់កម្មាភិបាលក្នុងជួរបក្សរបស់ខ្លួនដែលអង្គការចោទថា ជាភ្នាក់ងារខ្មាំងស៊ីរូងផ្ទៃក្នុង មាន CIA, KGB និងភ្នាក់ងារយួន គឺសំដៅលើៈ អ្នកធ្លាប់រៀនសូត្រនៅស្រុកយួន យួនវៀតកុងលើកឱ្យធ្វើជាប្រធាន ឬ មេបញ្ជាការយោធាយួន បណ្ដុះបណ្ដាលក្នុងតំបន់រំដោះអំឡុង ឆ្នាំ១៩៧០-១៩៧៣។ អ្នកទាំងនោះត្រូវមេខ្មែរក្រហមចោទលាបពណ៌ថា «ក្បាលយួនខ្លួនខ្មែរ»[367]។ ខ្មែរក្រហមបារម្ភជាងគេគឺខ្មាំងផ្ទៃក្នុង។ នេះជាអ្វីដែលធ្វើឱ្យបក្សមានការព្រួយបារម្ភជាងគេនោះគឺ ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង។ ទោះបីជាប្រជាជនទាំងនេះបានចូលរួមបម្រើបដិវត្តន៍ក៏ដោយ ប៉ុន្តែឥឡូវកំពុងតែក្បត់នឹងបដិវត្តន៍វិញ[368]។

ចំពោះបញ្ហាដែលបណ្ដាលឱ្យខ្មែរស្លាប់អស់មួយចំនួននោះ គឺពួកខ្មែរក្រហមតាមធ្វើការបោសសម្អាតជនបង្កប់វៀតមិញ វៀតកុង នៅក្នុងជួរកងទ័ព និងរដ្ឋអំណាចខ្មែរក្រហម។ សកម្មភាពទាំងឡាយក្រោយពីការជម្លៀសមកយើងឃើញថា កម្មាភិបាលរបស់កម្ពុជាប្រជា ធិបតេយ្យសុទ្ធតែជាកុមារ នេះអាចថាពួកខ្មែរក្រហមយោងតាមទ្រឹស្តីមួយថា «អ្នកចេះប្រៀបបានកំប្លោកឯអ្នកល្ងង់ប្រៀបបានទៅនឹងដុំថ្ម»។ ន័យនេះបានបង្ហាញថា

---

[366] ការប៉ាន់ប្រមាណមានភាពខុសគ្នា ពីព្រោះស្ថិតិជាច្រើនដែលផ្ដល់ដោយរដ្ឋាភិបាល ដូចជាចំនួនប្រជាជនសរុបពីមុន និងក្រោយសម័យខ្មែរក្រហមក៏មិនស៊ីសង្វាក់គ្នាដែរ។

[367] Face book: Vong Sotheara ថ្ងៃទី២ ខែមិថុនា ឆ្នាំ ២០១៦។

[368] ដេវី ឆេនល័រ, *សំឡេងពីមន្ទីរ ស-២១*, ប្រែសម្រួលដោយ សួ ប៊ុនស៊ូ, ឆ្នាំ( ? ), ទំព័រ៥០។

ប៉ុល ពត យកក្មេងទៅប្រើការព្រោះពួកនេះមានខួរក្បាល សស្អាត និងងាយស្រួលប្រើ គឺដាក់កន្លែងណាទៅកន្លែងណានោះ។

ការវាយប្រហារ នឹងសង្គមជាតិឯងនេះត្រូវបាននាំមុខធ្វើឡើង ក្នុងនាមនៃការធ្វើឱ្យបដិវត្តន៍ស្អាតស្អំបរិសុទ្ធ ដើម្បីការពារកម្មាភិបាលកុម្មុយនីស្តពីធាតុមិនល្អផ្សេងៗ ដែលជាមេរោគចម្លងនៃសង្គមចាស់ សត្រូវវណ្ណៈ[369]។ នៅខែកក្កដា ឆ្នាំ១៩៧៥ បក្សបានរៀបចំទីស្នាក់ការរបស់ខ្លួននៅភ្នំពេញហើយអគ្គលេខាធិការរង នួន ជា ត្រូវចាត់ឱ្យទទួលបន្ទុកមើលខុសត្រូវលើបណ្តាអង្គការបក្សរួមទាំងសាលាអប់រំផ្នែកនយោបាយថ្មីរបស់គាត់ និងសហព័ន្ធយុវជន។ ក្នុងពេលដែលការបដិវត្តន៍ក្រោយសម័យសង្គ្រាមចេះតែរំកិលទៅមុខ នួន ជា ប្រហែលជាមេដឹកនាំតែម្នាក់គត់ដែលរងគ្រោះដោយរលកនៃការបោសសម្អាតផ្សេងៗ។ ពួកមេដឹកនាំដែលធ្លាប់រៀនសូត្រនៅក្រុងប៉ារីស បានស្ថិតនៅក្នុងចំណោមមនុស្សដំបូងដែលត្រូវដកហូតពីមុខតំណែង ឬ ត្រូវបាត់ខ្លួននៅក្នុងការរើរុះរៀបចំគណៈរដ្ឋមន្ត្រីជាច្រើនលើក[370]។ ទិសដៅចម្បងមួយនោះគឺក្រុមដែលពួកនេះចាត់ទុកថា «ក្បាលយួនខ្លួនខ្មែរ» គឺពាក់ព័ន្ធទៅនឹងកងទ័ពវៀតមិញ និងវៀតកុងនៅក្នុងតំបន់បូព៌ាដោយសារតែតំបន់នេះពួកវៀតមិញ និងវៀតកុងបង្កប់ខ្លួនច្រើនជាងគេ ជាពិសេសនោះកងទ័ពមួយចំនួនដែលបានទៅរៀននៅប្រទេសវៀតណាមក៏គេចាត់ទុកថាជា «ពួកក្បាលយួនខ្លួនខ្មែរ» ដែរ ហើយការសង្ស័យ ចំពោះគ្នាឯងមានជាបន្តបន្ទាប់។ បើតាមស្ថិតិបានឱ្យដឹងថាគេធ្វើទារុណកម្មាភិបាល ១៧ ០០០នាក់ ព្រមទាំងអ្នកដែលគេចោទថាឃុបឃិតនោះផង[371]។ ចំពោះក្រុមរបស់ខ្លួន ប៉ុល ពតចាប់ផ្តើមសម្លាប់ម្តងមួយៗដូចជា[372]សោ ភឹម,ហ៊ូ នឹម និងហ៊ុយ យន់[373]។

យើងឃើញថាសន្តិសុខផ្ទាល់ខ្លួន ក៏ដូចជាសន្តិសុខ និងសុវត្ថិភាពសង្គមត្រូវគេរិតបន្តឹង។ សិទ្ធិសេរីភាព និងជំនឿគ្រប់យ៉ាងត្រូវហាមឃាត់។ ប្រព័ន្ធសន្តិសុខ របស់ខ្មែរក្រហម គឺគុកសម្រាប់ដាក់មនុស្ស។ នៅទូទាំងប្រទេសមានគុកជិត២០០ កន្លែង។ គេហៅគុកទាំងនេះថា «មន្ទីរសន្តិសុខ» ជំនួសពាក្យ «គុក ឬ ពន្ធនាគារ»។ មន្ទីរសន្តិសុខ ឬមន្ទីរនគរបាលស្រុក និងតំបន់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានរៀបចំឡើងជាប្រាំថ្នាក់។ មន្ទីរសន្តិសុខទាំងនេះ ជាកន្លែងឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់។ អ្នកទោសដែលជាប់ឃុំក្នុងគុកបីថ្នាក់ដំបូង គឺថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ ភាគច្រើនជាអតីតទាហាននិងមន្ត្រីរដ្ឋការស៊ីវិលរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ហើយអ្នកទោសផ្សេងទៀត គឺជាប្រជាជនសាមញ្ញដែលជាប់ចោទពីបទលួចចំណីអាហារ រត់ចោលកន្លែង ឬនិយាយអាក្រក់ពីអង្គការ។ មន្ទីរសន្តិសុខថ្នាក់ភូមិភាគ សម្រាប់ឃុំឃាំងយុទ្ធជនខ្មែរក្រហម និងក្រុមគ្រួសារ ឬជនជាប់ចោទពីបទឧក្រិដ្ឋដែលប្រព្រឹត្តកំហុសក្នុងភូមិភាគ។ មន្ទីរសន្តិសុខថ្នាក់ខ្ពស់បំផុត គឺមន្ទីរសន្តិសុខមជ្ឈិមនៅភ្នំពេញដែលមានឈ្មោះ សម្ងាត់ថា «មន្ទីរស២១»។ មន្ទីរឃុំឃាំងនេះដំណើរការពីឆ្នាំ១៩៧៥ រហូតដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អក្សរ «ស» តំណាងឱ្យពាក្យ «សន្តិបាល» ហើយលេខ «២១» តំណាងឱ្យលេខតេអូរបស់ប្រធានគុក។ គុកនេះបានផ្លាស់ប្តូរចំនួនបីលើក ហើយមានទី

---

[369] អេលីហ្សាបែក ប៊េកខ័រ, *ពេលសង្គ្រាមផុតរលត់ទៅ,* ដ.ឯ.ម., ទំព័រ២៨៣។

[370] -ដ- ទំព័រ២៧០។

[371] François Ponchaud, *កម្ពុជាឆ្នាំសូន្យ*, ដ.ឯ., ទំព័រ២៨៤ ។

[372] ផន សុផល, *កម្ពុជាក្នុងសង្គ្រាមវៀតណាម (១៩៥៤-១៩៧៥) : ប្រវត្តិសាស្ត្រ និងនយោបាយកម្ពុជា១៩៥៣ ដល់១៩៧៩*, ភ្នំពេញ, ឆ្នាំ ២០១១, ទំព័រ២៥៩។

[373] មានឯកសារសរសេរផ្សេងៗគ្នាគឺ ហ៊ុយ យន់ /ហ៊ូ យន់។

តាំងចុងក្រោយនៅខណ្ឌបឹងកេងកេង លើទីតាំងអតីតវិទ្យាល័យព្រះបាទពញាយ៉ាត ឬទួលស្វាយព្រៃ។ ក្រៅពីទីតាំងនេះ ស-២១ ក៏មានសាខាពីរផ្សេងទៀត មួយនៅស-២១ ឃ ឬ ស-២៤ ស្ថិតនៅព្រៃសដែលប្រើសម្រាប់ឃុំឃាំងអ្នកជាប់ឃុំកម្រិតស្រាលនិងបង្ខំឱ្យធ្វើកសិកម្មផ្គត់ផ្គង់ស្បៀង ហើយមួយទៀតជើងឯកជាកន្លែងសម្លាប់មនុស្សដែលបញ្ជូនពីស-២១។

## ៤-ខ្មែរក្រហម និងការធ្វើបដិវត្តន៍

នៅក្នុងចម្រៀងជាតិរបស់កម្ពុជាប្រជាធិបតេយ្យ បានបង្ហាញពីភាពអស្ចារ្យ របស់គេដែលល្អជាង មហានគរ។ ប្រហែលជាក្រុមនេះចង់បង្អួតថាពួកគេអាចធ្វើបានលើសជាច់ពីរបបចាស់ និងមានចំណុចពិសេសរបស់ខ្លួនគឺវាលស្រែយកទៅប្រៀបជាមួយយុគមាសមួយនេះបាន។ ប្រាកដណាស់ថាបដិវត្តន៍មិនមែនជាការកើតឡើងដោយចៃដន្យនោះទេ។ នេះគឺជាការរៀបចំទុកជាមុនស្រេចព្រោះក្រោយជ័យជម្នះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនពីទៅក្រុងភ្នំពេញទៅជនបទ ដែលបង្ហាញពី*បដិវត្តន៍វប្បធម៌ដែលឈរទៅលើវប្បធម៌ថ្មី* (ផ្លាស់ប្តូរសង្គម)គឺៈ

- បញ្ជូនពួកបញ្ញវន្ត អ្នកជំនួញ ឱ្យទៅរៀនសូត្រពីកសិករដើម្បីឱ្យពួកគេបម្រើបដិវត្តន៍
- ផ្តល់អំណាចឱ្យក្រុមបដិវត្តន៍វ័យក្មេង ដើម្បីត្រៀមខ្លួនអនុវត្តបទបញ្ជាពីអង្គការលើ
- បោសសម្អាតក្រុង កសាងសង្គមថ្មីជាមួយជនបទ និងវាលស្រែ
- ចម្រៀងប្រពៃណី ចម្រៀងសម័យ ចម្រៀងពីសង្គមចាស់ត្រូវបំបាត់ចោល ដោយដាក់ជំនួសនូវចម្រៀងបដិវត្តន៍
- ការបញ្ជូនឱ្យទៅរៀនសូត្រនៅសាលា ត្រូវប្តូរទៅជាការរៀនសូត្រជាមួយត្បូងចប ភ្លៅរទេះ កាំភ្លើងជាដើមដែលតា ម៉ុក តែងនិយាយថាធ្វើស្រែស៊ីបាយ រៀនសូត្រស៊ីក្រដាស។
- លុបបំបាត់ទីផ្សារសេដ្ឋកិច្ចដែលជាមាគ៌ាសម្រាប់អភិវឌ្ឍរបស់ប្រទេសជាតិ
- ពីមួយថ្ងៃទីមួយថ្ងៃ គេតែងតែនិយាយពាក្យច្រំដែលៗថាៈបញ្ញាជនមិនចេះធ្វើការ និងមិនចេះលះបង់ដូចកសិករទេ ត្រូវកសាងជម្រុះឥទ្ធិពលបរទេស និងសម្អាធចាស់ដើម្បីដើរឱ្យទាន់*បដិវត្តន៍*[374]
- អង្គការបានប្រាប់ ជួន មុម្ម ត្រូវធ្វើយ៉ាងណាកសាងសិស្សឱ្យបានទៅជាវិស្វករក្នុងរយៈពេល៦ខែ[375] ដែលនេះជាការអប់រំបញ្ច្រាសទិស
- ចង់គ្រប់គ្រងដោយគ្មានលក្ខណៈរដ្ឋបាល និងការិយាធិបតេយ្យ
- បណ្តុះមនោគមន៍វិជ្ជាជ្រុលនិយម(ដោយគេតែងតែនិយាយថាពួកអាណុល ពាលាអាវ៉ាសែ ជាកញ្ជះអាម៉េរិក...)។

ការធ្វើបដិវត្តន៍នេះជាការរៀបចំទុកជាស្រេច របស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដោយខ្មែរក្រហមមិនធ្វើការចរចានោះទេ ព្រោះនយោបាយខ្មែរក្រហម ជានយោបាយតឹងរឹងបំផុតប្រើប្រាស់ចុងអាវុធវាយយកឈ្នះ មិនមែនសម្រាប់ចរចាទេគឺជានយោបាយ «ផ្លាស់ប្តូរសង្គម» ទាំងមូលមិនមែនគ្រាន់តែផ្លាស់ប្តូររបៀបគ្រប់គ្រង និងអ្នកគ្រប់គ្រងប៉ុណ្ណោះទេ។បដិវត្តន៍កម្ពុជា មានលក្ខណៈដាច់ខាត ជាងបដិវត្តន៍ចិន និងបដិវត្តន៍សហភាពទៅទៀត បដិវត្តន៍នោះក៏ដឹកនាំឱ្យសង្គមប្រែប្រួលខ្លាំងជាងបដិវត្តន៍ឯទៀតៗដែរ។ ការខុសប្លែកខ្លាំង

---

[374] ពុទ្ធី ទត់, *លោកព្រឹទ្ធាចារ្យបណ្ឌិត ជួន មុម្ម*, ឆ្នាំ២០១៩, ទំព័រ១០៩។

[375] -ដ- ទំព័រ១១២។

ពីបដិវត្តន៍ចិននោះដោយសារបដិវត្តន៍កើតចេញពីមេដឹកនាំដោយខ្លួនឯងផ្ទាល់។ បដិវត្តន៍នេះបានធ្វើឱ្យពិភពលោកទាំងមូលភ្ញាក់ផ្អើលស្រឡាំងកាំង ដែលអន្តរជាតិតែងចាត់ទុកខ្មែរ ជាជនដែលស្លូតបូត។ បើទោះបីជាមនោគមវិជ្ជាជាមូលដ្ឋាននៃបដិវត្តន៍នេះមកពីក្រៅក្ដី ក៏របៀបចាត់ការសុទ្ធតែមានលក្ខណៈជាខ្មែរដែរ[376]។

## ៥-ប្រជាជន និងជីវភាពប្រចាំថ្ងៃ

បដិវត្តន៍ដែលដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា មិនមែនជាការកើតឡើងដោយចៃដន្យនោះទេ ប៉ុន្តែជាយន្តការដែលត្រូវបានរៀបចំទុកជាមុនសម្រាប់ការអនុវត្តនូវ ការផ្លាស់ប្តូរសង្គមទាំងស្រុង (Total Societal Transformation)។ របបកម្ពុជាប្រជាធិបតេយ្យ(ក.ប.ដ.) បានប្រកាសពីមហិច្ឆតាដ៏ធំធេងរបស់ខ្លួន ក្នុងការកសាងភាពអស្ចារ្យដែលប្រសើរជាងសម័យមហានគរដោយផ្តោតលើភាពពិសេសរបស់ខ្លួនគឺវាលស្រែ។

នយោបាយរបស់ខ្មែរក្រហមមានលក្ខណៈតឹងរ៉ឹងបំផុត ដោយប្រើប្រាស់ចុងអាវុធវាយយកជ័យជម្នះ មិនមែនសម្រាប់ចរចាឡើយហើយបដិវត្តន៍នេះត្រូវបានគេចាត់ទុកថាមានលក្ខណៈដាច់ខាតខ្លាំងជាងបដិវត្តន៍ចិន និងបដិវត្តន៍សហភាពសូវៀតទៅទៀត។ ក្រោយជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានអនុវត្តភ្លាមនូវបដិវត្តន៍វប្បធម៌ថ្មីដោយការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញទៅកាន់ជនបទ ដែលបង្ហាញពីចេតនាក្នុងការបោសសម្អាតទីក្រុង និងកសាងសង្គមថ្មីមួយជាមួយជនបទ និងវាលស្រែ។ នៅក្នុងទស្សនៈជ្រុលនិយមនេះ បញ្ញវន្ត និងអ្នកជំនួញត្រូវបានបញ្ជូនទៅរៀនសូត្រពីកសិករដើម្បីបម្រើបដិវត្តន៍។ ចម្រៀងប្រពៃណីសម័យ និងពីសង្គមចាស់ត្រូវបានបំបាត់ចោល ហើយជំនួសមកវិញដោយចម្រៀងបដិវត្តន៍។ ក្រុមមេដឹកនាំបក្សតែងនិយាយច្រំដែលៗថាបញ្ញាជនមិនចេះធ្វើការ និងមិនចេះលះបង់ដូចកសិករនោះទេ ដូច្នេះត្រូវតែលុបបំបាត់ឥទ្ធិពលបរទេស និងសម្ភារចាស់ ដើម្បីដើរឱ្យទាន់បដិវត្តន៍។ ទន្ទឹមនឹងការផ្លាស់ប្តូរវប្បធម៌របប ក.ប.ដ. បានបង្កើតនូវវណ្ណៈសង្គមថ្មីពីរគឺ «ប្រជាជនចាស់» ដែលរស់នៅជនបទមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងអាចកាន់តំណែងក្នុងសហករណ៍។ «ប្រជាជនថ្មី» ឬ «ប្រជាជន ១៧ មេសា» ដែលត្រូវបានជម្លៀសចេញពីទីក្រុង។ អង្គការគ្មានទំនុកចិត្តលើប្រជាជនថ្មីទេ ដោយចាត់ទុកពួកគេជាជនបញ្ឆោតក្អែក ជាអ្នកចាញ់សង្គ្រាម និងជាឈ្លើយសឹក ដែលជាប់នឹងពាក្យស្លោកថា«ទុកក៏មិនចំណេញ ដកចេញក៏មិនខាត»។ គួរកត់សម្គាល់ថាទោះបីជាគោលការណ៍ចង់ឱ្យប្រជាជនមានភាពស្មើគ្នា រហូតដល់សម្លៀកបំពាក់ក៏ដោយ ក៏មេដឹកនាំខ្មែរក្រហម និងមេកងមួយចំនួនរស់នៅស្រួល និងហូបចុកគ្រប់គ្រាន់ ខណៈប្រជាជនទូទៅហូបបបរទឹកតែប៉ុណ្ណោះនៅក្នុងសហករណ៍ជាមួយគ្នា។

ប្រព័ន្ធអប់រំនៅក្នុងរបបនេះត្រូវបានបំផ្លាញចោលទាំងស្រុង ដោយសាលារៀនត្រូវបានបិទ និងគ្រូបង្រៀនត្រូវបានរំលាយក្របខ័ណ្ឌ ដែលជាការបដិសេធចោលនូវសមត្ថភាពរបស់អ្នកចេះដឹង។ ការរៀនសូត្រត្រូវប្តូរទៅជាការអនុវត្តជាក់ស្តែងជាមួយនឹងត្បូងចប ភ្លៅរទេះ និងកាំភ្លើង ដែលឆ្លុះបញ្ចាំងពីទស្សនៈរបស់តា ម៉ុក ថា «ធ្វើស្រែស៊ីបាយ រៀនសូត្រស៊ីក្រដាស»។ អង្គការបានបណ្តុះមនោគមន៍វិជ្ជាជ្រុលនិយមដល់កុមារា កុមារី ឱ្យចាត់ទុកខ្លួនឯងជាកូនអង្គការ ដោយត្រូវមានឆន្ទៈដាច់ខាត ស្រឡាញ់ និងដឹងគុណអង្គការតែមួយគត់។ ពួកគេត្រូវបានអប់រំឱ្យហ៊ានធ្វើពលិកម្មគ្រប់យ៉ាងចំពោះអង្គការ ហើយពេលខ្លះកុមារថែមទាំងហ៊ានសម្លាប់ឪពុកម្តាយ

---

[376] សូមមើល: François Ponchaud, *កម្ពុជាឆ្នាំសូន្យ,* ប៉ារីស, ឆ្នាំ១៩៧៦, បកប្រែដោយដោយមជ្ឈមណ្ឌលវប្បធម៌កាតូលិកកម្ពុជា, ភ្នំពេញ, ២០១០, ទំព័រ១៩៩-២០៥ ។

ខ្លួនឯង ដោយចោទថាជាខ្មាំង។ នៅតាមសហករណ៍ កុមាររៀនច្រៀងបទបដិវត្តន៍ និងរាំរបាំបដិវត្តន៍ច្រើនជាង ការអាន ឬសរសេរ ដោយមានជំនឿថា «ចេះអក្សរពុំចាំបាច់សម្រាប់ដាំដុះឡើយ»។

ចំពោះជីវភាពប្រចាំថ្ងៃ ពិធីរៀបអាពាហ៍ពិពាហ៍ក៏មានលក្ខណៈខុសពីប្រពៃណីទាំងស្រុង និងមាន លក្ខណៈបង្ខំដោយអង្គការបានរៀបចំទុកដាក់គូអនាគតដោយមិនឱ្យសាមីខ្លួនដឹងមុនសូម្បីតែឈ្មោះ ឬមុខមាត់ ក៏ដោយ។ ពិធីរៀបការច្រើនតែធ្វើឡើងដោយមានកូនកំលោះ និងកូនក្រមុំច្រើនគូក្នុងពេលតែមួយ (ចាប់ពី ៣០ ដល់ជាង ១០០ គូ) ដោយគ្មានប្រារព្ធពិធីតាមប្រពៃណីខ្មែរ។ មូលហេតុមួយនៃការរៀបការដោយបង្ខំ គឺ ខ្មែរក្រហមស្អប់នារីស្អាតៗ និងប្រឆាំងនឹងទំនៀមទម្លាប់នៃអរិយធម៌ជាទូទៅ ជាពិសេសអរិយធម៌នៃប្រជាជាតិ ខ្មែរ។ ដូច្នេះហើយ យុវនារីដែលមានរូបសម្ផស្សស្អាតៗជារឿយៗត្រូវបានបង្ខំឱ្យរៀបការជាមួយយោធាពិការ ឬ មានរូបរាងអាក្រក់ក្រៃលែង។ អ្វីដែលកាន់តែអាក្រក់នោះ គឺនៅពេលរាត្រីផ្សំដំណេក អង្គការបានបញ្ជូនឈ្លប នៅក្រោមផ្ទះ ឬ ជុំវិញកន្លែងសម្រាក ដើម្បីឃ្លាំមើលថាតើពួកគេស្រុះស្រួលគ្នាឬអត់ ហើយបើពួកគេមិន ស្រុះស្រួលគ្នា នឹងត្រូវគេយកទៅអប់រំ ឬសម្លាប់ចោល។

ចំពោះសុខុមាលភាព មន្ទីរពេទ្យនានា ត្រូវបានសាងសង់ជារោងប្រក់ស្បូវតូចចង្អៀត ដែលគេសង្កេត ឃើញថាបែងចែកសម្រាប់យោធា និងសម្រាប់ពលករ។ ចំនួនគ្រូពេទ្យមិនគ្រប់គ្រាន់ទេ ដោយគ្រូពេទ្យបដិវត្តន៍ ភាគច្រើនមានជំនាញតិចតួច។ ការព្យាបាលពឹងផ្អែកលើថ្នាំបុរាណផលិតពីដើមឈើ ឫសឈើ ហើយថ្នាំដែល ហៅថា«អាចម៍ទន្សាយ» ត្រូវបានប្រើសម្រាប់ព្យាបាលជំងឺស្ទើរគ្រប់ប្រភេទ។ ដោយសាររបបអាហាររួមនៅក្នុង សហករណ៍ជាលក្ខណៈសមូហភាព បានធ្វើឱ្យប្រជាជនហូបចុកមិនគ្រប់គ្រាន់ និងខ្វះជីវជាតិយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះហើយ ជំងឺរុំរ៉ៃដូចជាជំងឺគ្រុនចាញ់ និងជំងឺក្រពះបានកើតមានជាញឹកញាប់ និងបានយាយីសុខភាព របស់ប្រជាជននៅតាមទីជនបទ ដែលជាហេតុធ្វើឱ្យចំនួនអ្នកស្លាប់កើនឡើងរហូត។

## ៦-ចលនាប្រឆាំង និងការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការដួលរលំនៃរបបនេះដោយសារ មានមូលហេតុ៣ គឺបញ្ហាសេដ្ឋកិច្ច បញ្ហាសង្គម និង នយោបាយ។

### ៦.១-បញ្ហានយោបាយ និងការប៉ះទង្គិចជាមួយវៀតណាម

មិត្តភាពកម្ពុជាវៀតណាម ចាប់ផ្ដើមរសាយបន្តិចម្តងៗបន្ទាប់ពីក្រុងភ្នំពេញ ត្រូវបានរំដោះ ពួកខ្មែរក្រហម បានលើកទ័ពបណ្តេញវៀតណាមឱ្យចេញពីកម្ពុជា។ ក្រោយពេលរដ្ឋការក្រុងព្រៃនគរដួល រលំនា ថ្ងៃទី៣០ ខែ មេសា ឆ្នាំ១៩៧៥ បានចាប់ផ្ដើមការប៉ះទង្គិចគ្នាដោយអាវុធរវាងកម្ពុជា និងវៀតណាមដោយបញ្ហារឿងកោះ ទាំងឡាយនៅក្នុងឈូងសមុទ្រសៀម[377]។ ការប្រយុទ្ធគ្នាជាមួយវៀតណាមកាន់តែខ្លាំងឡើងៗ នៅពាក់កណ្ដា លខែមិថុនា។ ដើម្បីដោះស្រាយវិបត្តិនេះប៉ុល ពត និងខៀវ សំផន បានធ្វើដំណើរទៅហាណូយដើម្បីបញ្ចប់ សង្គ្រាមនេះ។ ប៉ុន្តែទោះបីវិបត្តិនេះអាចដោះស្រាយបានក៏ដោយតែរឿងព្រំដែនវិញមិនទាន់ ដោះស្រាយបាន ទេ។ នៅដើមខែសីហា ឆ្នាំ១៩៧៥ ឡេ យន់ បានមកទស្សនកិច្ចនៅកម្ពុជាក្នុងគោលបំណងធ្វើការចរចា។ ពួក ខ្មែរក្រហមក៏មានទស្សនផ្សព្វផ្សាយលទ្ធិកុម្មុយនីស្តទៅប្រទេសដទៃទៀត ប៉ុន្តែគេមិនចង់ស្ថិត នៅក្រោមការបង្គាប់បញ្ជាពីវៀតណាមឡើយ។ នៅក្នុងទំនាក់ទំនងការបរទេស កម្ពុជាប្រជាធិតេយ្យបានចាប់ដៃជាមួយក្រុង ប៉េកាំងដោយបញ្ជូន ខៀវ សំផន ទៅធ្វើទស្សនកិច្ចផ្លូវការនៅប៉េកាំងនា ខែសីហា ឆ្នាំ ១៩៧៥ ដើម្បីប្រកាស

---

[377] ដៀប សុផល, *សង្គ្រាម និង សន្តិភាពកម្ពុជា: កត្តាតំបន់ និងកត្តា សកលលោក ១៩៤៥-១៩៩១*, ភ្នំពេញ,ឆ្នាំ២០០៥, ទំព័រ៨៩ ។

ទិសដៅនយោបាយក្រៅប្រទេសរបស់កម្ពុជា។ នៅក្នុងដំណើរនេះត្រូវបានគាំទ្រ ពីក្រុងប៉េកាំង កម្ពុជាប្រជាធិតេយ្យបានបង្ហាញពីគោលនយោបាយឯករាជ្យការមិនចូលបក្សសម្ព័ន្ធ និងអព្យាក្រឹតរបស់គេ។ នៅខែកញ្ញា ឆ្នាំ ១៩៧៥ ខៀវ សំផន និងសម្តេចព្រះនរោត្តម សីហនុបានទៅចូលរួមធ្វើខួប៣០ឆ្នាំនៃថ្ងៃកំណើតសាធារណរដ្ឋប្រជាមាធិតេយ្យវៀតណាម។ ប៉ុន្តែលើកនេះ ខៀវ សំផន មិនបានទទួលលទ្ធផលតាមសំណើរបស់ ប៉ុល ពត ដែលចង់ចុះហត្ថលេខាមិត្តភាពជាមួយវៀតណាម ដែលនិយាយពីបញ្ហាព្រំដែនទាំងពីរទេ[378]។ ការលួចវាយប្រហារឆ្លងព្រំដែនទៅវិញទៅមកជារឿយៗចាប់ពីចុងឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦។

ប្រទេសវៀតណាម មិនដែលលាក់គម្រោងការរបស់ខ្លួនទេគឺថាប្រមូលប្រទេសទាំង៣ នៃជ្រោយឥណ្ឌូចិន (ស្ថិតនៅក្រោមការណែនាំរបស់ហាណូយតែមួយ)។ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៧ វៀតណាម និងឡាវចុះ «សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការគ្នា» សម្រាប់២៥ឆ្នាំ ដែលអាចបន្ត១០ឆ្នាំម្តងៗ ប្រសិនបើគ្មានការណ៍អ្វីដែលកើតឡើងនោះទេ។ ប្រទេសឡាវចុះចូលក្រោមអាណានិគមវៀតណាមទាំងស្រុង។ រីឯកម្ពុជាប្រជាធិបតេយ្យវិញ មិនព្រមចុះហត្ថលេខា ទទួលយកសន្ធិសញ្ញាបែបនេះទេ។ ណាមួយអង្គការកម្ពុជាប្រជាធិបតេយ្យ សម្លាប់កម្មាភិបាលដែលគាំទ្រវៀតណាម ណាមួយទៀតកងយោធាតែងតែវាយសម្រុកតាមព្រំដែនយ៉ាងសាហាវនោះ នាំឱ្យវៀតណាមខ្លាចក្រែងថាកម្ពុជានឹងក្លាយទៅជាទីតាំងរបស់ចិន ដែលអាចវាយវៀតណាមពីខាងលិច និងពីខាងជើងប្រទេសគេ[379]។ នៅតាម ព្រំដែនប្រទេសទាំងពីរមកគឺ ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ សង្គ្រាមក៏កើតឡើងទៀតគឺកងទ័ពខ្មែរក្រហមបានវាយលុកភូមិជាច្រើន និងក្រុងតូចក្នុងខេត្តអានយ៉ាង (An Giang) និងចូវដុក (Chau Doc) របស់វៀតណាមខាងត្បូងធ្វើការដុតផ្ទះសម្លាប់ជនស៊ីវិលរាប់រយនាក់[380]។ នៅខែកក្កដា ឆ្នាំ១៩៧៧ មេដឹកនាំបក្សកុម្មុយនីស្តវៀតណាមសម្រេចថាត្រូវកម្ទេច ប៉ុល ពត និងរបបនេះចោល។ ចាប់ពីខែកក្កដា មកមាន «ផ្ទុះសង្គ្រាម ដែលគេមិនបានប្រកាស» រវាងប្រទេសទាំងពីរ។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧[381] ខៀវ សំផន បានជូនដំណឹងដល់សហគមន៍អន្តរជាតិថា កងទ័ពវៀតណាមលុកលុយតែគ្នាអ្នកជឿ។ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ កងទ័ព វៀតណាម ដកក្រោយវិញ ដោយនាំទាំងជនជាតិកម្ពុជាប្រមាណ ៣០០ ០០០នាក់ទៅជាមួយដែរ។ វៀតណាមប្រកាសថាជនទាំងនោះរត់មកតាមគេ រីឯអង្គការខ្មែរក្រហមថាវៀតណាមកៀរអ្នកទាំង នោះវិញ[382]។ នៅចុងខែកក្កដា ឆ្នាំ១៩៧៨ សុន សេន បានធ្វើដំណើរទៅក្រុងប៉េងកាំង ដើម្បីសុំជំនួយយោធាប្រឆាំងនឹងវៀតណាម។ របាយការណ៍នៃការប៉ះទង្គិចគ្នាធំៗរវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមបានផ្សព្វផ្សាយនៅលោកខាងលិចជាច្រើនខែ។

វៀតណាមបានដាក់កងទ័ពប្រយុទ្ធលើសចំនួនទ័ពខ្មែរ២ដង (៦០ ០០០នាក់ ទល់នឹង២៨ ០០០នាក់) និងប្រើឧទ្ធម្ភាគចក្រប្រដាប់ដោយកាំភ្លើងយន្ត ព្រមទាំងរថក្រោះជាច្រើនគ្រឿង។ ដោយគ្មានគ្រឿងសាស្ត្រាវុធបែបនោះ ពួកកម្ពុជាបានប្រើយុទ្ធវិធីជាសង្គ្រាមទ័ពព្រៃវិញ។ វៀតណាមបានសម្រុកចូលមកក្នុងទឹកដីរបស់កម្ពុជា

---

[378] ជៀប សុផល, *សង្គ្រាម និង សន្តិភាពកម្ពុជា: កត្តាតំបន់ និងកត្តា សកលលោក ១៩៤៥-១៩៩១,* ជ.ឯ.ម.,ទំព័រ១០០។

[379] François Ponchaud, *កម្ពុជាឆ្នាំសូន្យ*, ឆ្នាំ១៩៧៦, ជ.ឯ.ម, ទំព័រ២៨៥។

[380] ស្តេហ្វិនច ម៉ូរីស, *ហេតុម្តេចវៀតណាមលុកចូលកម្ពុជា: បុព្វហេតុនយោបាយ និងបុព្វហេតុនៃសង្គ្រាម*, បកប្រែ និងប្រែសម្រួលដោយ អួន វីរៈ, ភ្នំពេញ, ឆ្នាំ ២០០៨, ទំព័រ១៩៧ ។

[381] នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នេះហើយដែលកម្ពុជាប្រជាធិបតេយ្យ បានផ្តាច់ចំណងទាក់ទងផ្សេងៗរបស់ខ្លួនជាមួយក្រុងហាណូយ ។

[382] François Ponchaud, *កម្ពុជាឆ្នាំសូន្យ*, ឆ្នាំ១៩៧៦, ជ.ឯ.ម., ទំព័រ២៨៥។

ដោយឆ្លងកាត់ខេត្តស្វាយរៀង សំដៅមកអ្នកលឿងដែលជាចំណុចឆ្លងកាត់ទន្លេមេគង្គដ៏សំខាន់[383] ហើយនៅម៉ោង១២កន្លះថ្ងៃត្រង់នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រាជធានីភ្នំពេញទាំងមូលត្រូវបានរំដោះ។

### ៦.២-បញ្ហាសេដ្ឋកិច្ច

នៅក្នុងគោលការណ៍របស់ខ្មែរក្រហមគឺមានការលុបបំបាត់ទីផ្សារ និងលុបបំបាត់ចរាចរណ៍រូបិយវត្ថុដែលបង្ហាញពីការលុបបំបាត់ចោលទាំងស្រុង នៅសេដ្ឋកិច្ច ទីផ្សារ ហើយអនុវត្តគោលនយោបាយឯករាជ្យម្ចាស់ការ និង គោលនយោបាយមហាលោតផ្លោះមហាអស្ចារ្យ ដែលនៅក្នុងវិស័យកសិកម្មប្រើកម្លាំងមនុស្សសុទ្ធសាធ។ កម្លាំងបញ្ញា ត្រូវដូរមកកម្លាំងបាយ ហើយបច្ចេកវិទ្យា និងបច្ចេកទេសត្រូវប្ដូរមកប្រើកម្លាំងមនុស្សធ្វើតាមការចាត់តាំងវិញ។

ក្រុមខ្មែរក្រហមបានប្រាប់ប្រជាជនថា «ទៅរៀនយកបាក់ឌុប បាក់អង នៅទំនប់ ប្រឡាយទៅ មិនចាំបាច់ទៅរៀនឯណាឆ្ងាយទេ»។ មានន័យថាគេត្រូវឱ្យមនុស្សមកសិក្សាស្វែងយល់នៅក្នុងវិស័យកសិកម្ម តែការសិក្សានេះជាការប្រើកម្លាំងសុទ្ធសាធតែម្ដង។ ការជួញដូរក្រៅប្រទេសត្រូវបានបញ្ឈប់ស្ទើរតែទាំងស្រុង ទោះបីយ៉ាងណា ក៏មានការរស់ឡើងវិញជាកម្រិតនៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧[384]។ ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឯករាជ្យម្ចាស់ការ, ខ្លួនទីពឹងខ្លួន, មហាលោតផ្លោះមហាអស្ចារ្យ, ការសម្លាប់អ្នកចេះ, ការប្រើកម្លាំងពលកម្មមនុស្សសុទ្ធសាធក្នុងវិស័យកសិកម្ម, ការធ្វើឧស្សាហូបនីយកម្មដោយមិនប្រើបច្ចេកទេសនិងបច្ចេកវិទ្យា(មិនបើអ្នកចេះដឹង), ការលុបបំបាត់នូវសេវាកម្ម(គ្មានពាណិជ្ជកម្ម និងគ្មានប្រាក់កាស) និងការសម្រាប់ប្រជាជនខ្លួនឯងជិត៣០%នៃប្រជាជនសរុប បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះយ៉ាងគំហុក[385]។ សេដ្ឋកិច្ចប្រទេសមួយដែលរីកចម្រើនគឺអាស្រ័យលើប្រជាជនសកម្ម តែខ្មែរក្រហមបានសម្លាប់មនុស្សទៅវិញ។

### ៦.៣-ប្រជាជនហូបមិនគ្រប់គ្រាន់

នៅព្រឹកថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមនិយាយថា ក្រុងខូចអាក្រក់ណាស់ព្រោះនៅក្រុងប្រជាជនចាយប្រាក់បណ្ដាលឱ្យមនុស្សមានវណ្ណៈមិនស្មើភាពគ្នា នៅក្រុងមិត្តមិនដែលបង្កើតភោគផលបរិភោគឡើយ ជនជាតិខ្មែរត្រូវដឹងថាខ្លួនកើតពីគ្រាប់ស្រូវ"។ ហេតុនេះហើយបានជាប្រជាជនខ្មែរត្រូវមានជីវិតថ្មីដោយធ្វើស្រែចម្ការវិញ[386]។ គោលការណ៍រួមបង្កើតសហករណ៍ ហូបរួម ទុកដាក់រួមគ្នា ដោយពឹងលើរបរកសិកម្មនោះ គឺគេយោងទៅលើពាក្យបុរាណមួយឃ្លាពោលថា «ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ» ដូច្នេះហើយគេបានបញ្ជូនប្រជាជនឱ្យជីកប្រឡាយខ្វាត់ខ្វែងវាលស្រែមានរាងក្រឡាចត្រង្គ។ យើងក៏ដឹងយ៉ាងច្បាស់ថាសញ្ញានៃលទ្ធិមូលធននិយមទាំងអស់ត្រូវបានបំផ្លាញ ហើយកិច្ចការសេដ្ឋកិច្ចក្នុងក្រុងត្រូវបានបញ្ចប់។ ប្រជាជនរស់នៅអាស្រ័យទៅលើរបរកសិកម្មដែលស្ថិតក្នុងកម្មសិទ្ធិសហករណ៍។ ប្រជាជនធ្វើការជាច្រើនម៉ោងក្នុងមួយថ្ងៃដោយយោងទៅតាមរដូវ និងតំបន់។ ការធ្វើការរបស់ប្រជាជនគឺញាប់ដៃដូចស្រមោច ហើយនៅពេលធ្វើការនោះមានអ្នកណាធ្វើខុសធ្ងន់ធ្ងរត្រូវបានគេយកទៅសម្លាប់ចោល។ ការប្រព្រឹត្តបែបនេះ គឺវាផ្ទុយទាំងស្រុងទៅនឹងមាត្រា១២នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យដែលមានសេចក្ដីជាអាថ៌ថា កម្មករគ្រប់រូបជាម្ចាស់រោងចក្រ, កសិករគ្រប់

---

[383] អេលីហ្សាបែក បេកខ័រ, *ទឹកភ្នែកកម្ពុជា(Becker, E. (1988). Les larmes du Cambodge:[l'histoire d'un autogénocide]*, ប្រែសម្រួលដោយ ទី យាយុ, ឆ្នាំ(?), ទំព័រ៤៦៧។

[384] https://km.wikipedia.org/wiki/.

[385] ហង់ជួន ណារ៉ុន, *ប្រវត្តិសាស្ត្រកម្ពុជាក្នុងបរិបទសកលលោក*, ឆ្នាំ២០១៩, ទំព័រ២០៦។

[386] ហ្វ្រង់ស័រ ប៉ុង សូជ៏, *ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា,* ដ.ឯ.ម., ទំព័រ៩០។

រូបជាម្ចាស់ស្រែចម្ការ, ពលករផ្សេងទៀតមានសិទ្ធិមានការងារធ្វើទាំងអស់គ្នា និងភាពគ្មានការងារធ្វើមិនមានដាច់ខាតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[387]។

ក្នុងការធ្វើស្រែចម្ការ គេធ្វើតាមផែនការបួនឆ្នាំ មានគោលដៅសម្រេចឱ្យបានផលិតផលស្រូវបីតោនក្នុងមួយហិចតាជាមធ្យម។ ចាប់ពីចុងឆ្នាំ១៩៧៧ ដំណាំបានផលល្អដោយកម្លាំងធ្វើការដ៏ខ្លាំងក្លានេះ ស្រូវក៏បរិបូរណ៍ដែរតែអង្គការចាប់ផ្តើមប្រមូលផលិតផល រីឯជីវភាពរបស់ប្រជាជនកាន់តែតឹងរឹងឡើងៗមានតែបបររាវៗប៉ុណ្ណោះ។ ប្រហែលអង្គការនាំស្រូវចេញទៅប្រទេសចិនដើម្បីសងបំណុល ឬ ទុកក្នុងជង្រុកធំៗ ដោយរៀបចំធ្វើសង្គ្រាមជាមួយវៀតណាម[388]។ ចំពោះបញ្ហាហូបចុកនេះ បើតាមប្រសាសន៍របស់ប្រជាជននៅតំបន់ផ្សេងៗគ្នាបានបញ្ជាក់ថានៅតំបន់ខ្លះប្រជាជនមានបាយហូបហើយតំបន់ខ្លះហូបបបរ។

ចំណែកឯលោក ខៀវ សំផន ក៏បានបញ្ជាក់ក្នុងសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហានរបស់ខ្ញុំបន្តបន្ទាប់» ថា៖ *កងទ័ព និងប្រជាជនយើងត្រូវខ្វះស្បៀងយ៉ាងខ្លាំងត្រូវយកចេក និងដំឡូងទៅដាំជំនួសអង្ករលាយជាមួយអង្ករតែបន្តិចបន្តួចតែប៉ុណ្ណោះ។ នៅកន្លែងខ្លះទៀតដូចជាកំពង់ស្ពឺជាដើមប្រជាជនហូបតែគល់ប្រង់[389] គល់ល្ហុងទេ*[390]។ ដោយភាពអត់ឃ្លានការល្វិតល្វៃដៃជើងនេះ ធ្វើឱ្យប្រជាជនចាប់ផ្តើមប្រឆាំងជាមួយអង្គការលែងស្តាប់បង្គាប់ស៊ូស្លាប់។ ចំណែកឯកងទ័ពក៏បាត់បង់កម្លាំងដើម្បីទប់ទល់ជាមួយ សត្រូវ។

### ៦.៤-ការកាប់សម្លាប់ប្រជាជនខ្លួនឯង និងបញ្ហាសម្រិតសម្រាំង

ការកាប់សម្លាប់ប្រជាជនខ្លួនឯង ជាមូលហេតុដែលនាំឱ្យរបបត្រូវបានប្រជាជនលែងគាំទ្រប្រជាជនដែលស្មោះត្រង់បាត់បង់ជំនឿនាំឱ្យរបបបាត់បង់នូវកម្លាំងស្នូល។ បញ្ហាចម្បងនៃការកាប់សម្លាប់ គឺការសម្រិតសម្រាំង។ «ការធ្វើសម្រិតសម្រាំង» ដំបូងៗបានកើតឡើងនៅឆ្នាំ១៩៧៦[391]។ ចំពោះបញ្ហាសម្រិតសម្រាំងក្នុងភូមិភាគទាំងអស់ គឺមានការប៉ះធ្ងន់ធ្ងរទៅលើភូមិភាគនិរតីដែលកាន់កាប់ដោយ ឈិត ជឿន ហៅតាម៉ុក។ នៅពេលដែលពួកកម្មាភិបាលមានជំនឿថាអ្នកណាខ្មាំង អ្នកនោះប្រាកដជាមិនអាចគេចផុតពីសេចក្តីស្លាប់បានឡើយ។ បើយោងទៅតាមសំដីរបស់លោក Adolf Hitler (១៨៨៩-១៩៤៥) ថា «ជំនឿពិបាកលុបបំបាត់ជាងចំណេះដឹង»។ ការកាប់សម្លាប់កាន់តែខ្លាំងទៅៗនៅក្នុងផ្ទៃប្រទេស ដោយសារតែភាពគ្មានចំណេះដឹងរបស់ កម្មាភិបាលក្នុងរបបនេះ។ វាស្ទើរតែពិតប្រាកដណាស់ការបង្ហាញខ្លួនតាមការហៅឱ្យទៅប្រជុំរបស់អង្គការនេះមានន័យថាគឺទៅស្លាប់[392]។ រាល់ការកោះហៅទាំងឡាយគឺជាបញ្ហាដែលធ្វើឱ្យប្រជាជនមានការតក់ស្លុតគ្រប់ពេលវេលា។ ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ប្រជាជនខ្មែរប្រហែល១/៤ស្លាប់ យ៉ាងអាណោចអាធម[393]។ ប្រជាជនដែលស្លាប់ទាំងនេះគឺ ដោយសារតែអត់អាហារ និងការចោទប្រកាន់ថាជាខ្មាំងសត្រូវ ហើយការចោទប្រកាន់មួយចំនួនកើតពីគំនុំការចង់ចាញ់ឈ្នះកម្មាភិបាលដែលខ្វះចំណេះដឹង។

---

[387] ឌី ខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥ -១៩៧៩)*, មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០០៧, ទំព័រ៤៧។

[388] ហ្វ្រង់ស្វ័រ ប៉ុងសូដ៏, *ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា*, ដ.ឯ.ម., ទំព័រ៩៤ ។

[389] ប្រង់ ឈ្មោះប្រទាលមួយពួក មានជាងរឹង ស្លឹករឹងល្អិត មើមពុល។

[390] ពាក្យ «យើង»ជាសំដីរបស់លោក ខៀវ សំផន។

[391] Philippe Richer, *កម្ពុជា: សោកនាដកម្មមួយនៃសម័យយើង (LE CAMBODG: ne tragédie de notre temps, 2001)*, ប្រែសម្រួលដោយ ទីឃាយុ, ឆ្នាំ( ? ), ទំព័រ៥១។

[392] -ដ- ទំព័រ៤៦ ។

[393] ហ្វ្រង់ស្វ័រ ប៉ុងសូដ៏, *ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា*, ដ.ឯ.ម., ទំព័រ៩៥ ។

ការកាប់សម្លាប់មានសភាពខ្លាំងក្លាណាស់ក្នុងអំឡុងឆ្នាំ១៩៧៧ នៅភូមិភាគឧត្តរ និងបូព៌ាទិស ជាពិសេស ក្រោយដែល សោ ភឹម បានក្បត់ចូលដៃគាំទ្រយួនហើយលើកទ័ពសំដៅមកភ្នំពេញ។ ការកាប់សម្លាប់ប្រជាជន តំបន់ភូមិភាគឧត្តរ និងបូព៌ានោះគឺធ្វើដោយរបៀបឃោរឃៅបំផុតដូចជាពុំមែនជាជាតិខ្មែរដូចគ្នាបន្តិចសោះ ប៉ុល ពត បញ្ជាឱ្យសម្លាប់ចោលទាំងគ្រួសារ[394]។ ការកាប់សម្លាប់រាលដាលទៅលើសត្រូវពិត និងមិនពិតគឺប ណ្តាលមកពីភាពភ័យខ្លាចផ្នែកនយោបាយដែលនាំទៅដល់ទីបញ្ចប់នៃការដួលរលំ។ នេះវាជាសោកនាដកម្ម និងការខាតបង់ដ៏មហិមាមួយ និងជារឿងដ៏អភ័ព្វសម្រាប់ប្រជាជាតិខ្មែរ ដែលថ្នាក់ដឹកនាំយកជីវិតមនុស្សទៅ ដកពិសោធន៍ក្នុងការគ្រប់គ្រង។

### ៦.៥-ប្រជាជនខ្មែរមិនគាំទ្រ និងងើបឡើងប្រឆាំង

ភូមិភាគបូព៌ាជាភូមិភាគដែលពួកមជ្ឈិមបានចាប់ផ្តើមចាប់ខ្លួនកម្មាភិបាលជាច្រើននាក់។ កម្មាភិបាលក្នុង ភូមិភាគនេះប្រហែលបួនរយនាក់ត្រូវបានចាប់ដាក់គុកនៅទួលស្លែង(ស២១)។

នៅថ្ងៃទី២៥ ខែឧសភា មជ្ឈិមបានបញ្ជាឱ្យធ្វើការវាយលុកទៅលើភូមិភាគបូព៌ាដោយកងពលតូចពីរដែល កងពលមួយមានទាំងរថក្រោះថលជលិកផង (ថលជលិកជាឈ្មោះគ្រឿងរថយន្តចម្បាំងដែលអាចចុះទឹកក៏ បានឡើងគោកក៏បាន) ឆ្លងកាត់ទន្លេមេគង្គដើរចុះតាមផ្លូវជាតិលេខ៧ដើម្បីសម្រុកទៅរក សោ ភឹម[395] ហើយ សហការីជាច្រើនរបស់ សោ ភឹម បានរត់ចូលព្រៃអស់ ។

នៅប៉ុន្មានខែក្រោយមកគឺនៅខែតុលា សមមិត្ត ជា ស៊ីម បានដឹកនាំប្រជាជនរបស់ភូមិភាគបូព៌ាចំនួន ៣០០នាក់ ឆ្លងកាត់ព្រំដែនចូលទៅប្រទេសវៀតណាម។ ក្រោយបន្តិចកងទ័ពវៀតណាមបានលុកចូលមក កម្ពុជា ហេង សំរិន និងកងទ័ពរបស់គាត់បាននាំយកអ្នកទាំងនេះទៅទុកនៅកន្លែងមួយដែលមានសុវត្ថិភាពគ្រប់គ្រាន់ ក្នុងប្រទេសវៀតណាម។ សមមិត្ត ហេង សំរិន និងកងទ័ពរបស់គាត់ពី២ ទៅ៣ពាន់នាក់បានឆ្លងកាត់ព្រំដែន ដោយទទួលស្គាល់ចំពោះពួកអ្នកដែលពួកគេបានវាយប្រយុទ្ធកាលពីប៉ុន្មានខែមុនប៉ុណ្ណោះ។

ការបោសសម្អាតភូមិភាគបូព៌ា ជាព្រឹត្តិការណ៍សប្បាយរីករាយមួយ ដែលកើតឡើងត្រូវពេលវេលា សម្រាប់ ប្រទេសវៀតណាមដែលកំពុងត្រូវការរឿងបែបនេះយ៉ាងខ្លាំង គឺពួកក្រុមកុម្មុយនីសកម្ពុជាមួយក្រុមដែលមាន សារៈសំខាន់ និងបទពិសោធគ្រប់គ្រាន់ដើម្បីដឹកនាំ «រណសិរ្ស» មួយប្រឆាំងនឹងប៉ុលពត។ ពួកអ្នកដែលរត់ ភៀសខ្លួនទៅប្រទេសវៀតណាមបានការគាំទ្រពីវៀតណាម ក៏បានបង្កើតជា«រណសិរ្សសង្គ្រោះជាតិកម្ពុជា» ឡើងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ដើម្បីផ្តួលរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកដឹកនាំរណសិរ្សនេះមាន សមមិត្ត ហេង សំរិន ជាប្រធាន។ ក្នុងចំណោមសមាជិកនៃរណសិរ្សនេះគឺមានសមមិត្ត ហ៊ុន សែន ដែលបានភៀសខ្លួន ទៅប្រទេសវៀតណាម តាំងពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ជាមួយយុទ្ធមិត្ត៤រូបទៀតមានញឹក ហួន, នុច ថន, វ៉ា ប៉ោអៀន និងសាន សាញ់។

### ៦.៦-ការគ្រប់គ្រងបែបព្រៃផ្សៃ

ប្រជាជនជនជិត២លាននាក់ បានបាត់បង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រជាជនថ្មី និងប្រជា ជនចាស់រស់នៅក្នុងរបបនេះដូចជាការរស់នៅក្នុងគុកឥតជញ្ជាំង ព្រោះពួកគាត់បានបាត់បង់សិទ្ធិសេរីភាពគ្រប់

[394] ហ៊ិន ស៊ីថាន, *នរណា ...ជាឃាតករ?,* ឆ្នាំ(?), ទំព័រ១៥១ ។

[395] អេលីហ្សាបែក បេកខ័រ, *នៅពេលដែលសង្គ្រាមរលត់ទៅ*, ដ.ឯ.ម., ទំព័រទី៤១៣ ។

បែបយ៉ាង។ ប្រជាជនបានស្លាប់បណ្ដើរៗដោយការសម្លាប់, អត់អាហារ, ជំងឺ និងធ្វើការហួសកម្លាំងដែលជាហេតុនាំឱ្យប្រជាជនទ្រាំទ្រលែងបានត្រូវតែងើបឡើងបះបោរ។

សរុបសេចក្ដីមកការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺបណ្ដាលមកពីកត្តាចម្បងចំនួនបីគឺបញ្ហាសេដ្ឋកិច្ច បញ្ហាសង្គម និងបញ្ហានយោបាយ។ នៅក្នុងវិស័យសេដ្ឋកិច្ចរបបនេះបានលុបបំបាត់ទាំងស្រុងនូវទីផ្សារ និងចរាចរណ៍រូបិយវត្ថុ ដោយអនុវត្តគោលនយោបាយ«មហាលោតផ្លោះមហាអស្ចារ្យ» និង«ឯករាជ្យម្ចាស់ការ»។ គោលនយោបាយនេះបានប្រើកម្លាំងមនុស្សសុទ្ធសាធក្នុងវិស័យកសិកម្ម ដោយជំនួសកម្លាំងបញ្ញា និងបច្ចេកវិទ្យាមកប្រើកម្លាំងបាយវិញ។ ការសម្លាប់អ្នកចេះដឹង ការប្រើកម្លាំងពលកម្មខ្លាំងក្លា និងការលុបបំបាត់សេវាកម្ម ព្រមទាំងការសម្លាប់ប្រជាជនខ្លួនឯងជិត៣០% នៃចំនួនប្រជាជនសរុបបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះយ៉ាងគំហុក។ ទន្ទឹមនឹងនេះ គោលការណ៍ហូបរួមនៅក្នុងសហករណ៍បានធ្វើឱ្យប្រជាជនភាគច្រើនទទួលទានតែបបររាវៗ រហូតដល់ត្រូវយកចេក ដំឡូង ឬគល់ប្រេង គល់ល្ហុងទៅដាំជំនួសអង្ករ ដែលបង្កឱ្យមានភាពអត់ឃ្លាន និងល្វិតល្វៃដៃជើង។ បញ្ហាសង្គមដ៏ធ្ងន់ធ្ងរមួយទៀត គឺការកាប់សម្លាប់ប្រជាជនខ្លួនឯងជិត១/៤ នៃប្រជាជនសរុប ដោយសារអត់អាហារ ជំងឺ ការធ្វើការហួសកម្លាំង និងការចោទប្រកាន់ថាជាខ្មាំងសត្រូវ ដែលបណ្ដាលមកពីភាពគ្មានចំណេះដឹងរបស់កម្មាភិបាលក្នុងរបបនេះ។ ការកាប់សម្លាប់រាលដាលខ្លាំង ជាពិសេសនៅភូមិភាគឧត្ដរ និងបូព៌ាទិស ដែលធ្វើឱ្យប្រជាជនដែលស្មោះត្រង់បាត់បង់ជំនឿ នាំឱ្យរបបបាត់បង់នូវកម្លាំងស្នូល ហើយទ្រាំទ្រលែងបាន ក៏ងើបឡើងប្រឆាំង។ ចំពោះបញ្ហានយោបាយទំនាក់ទំនងមិត្តភាពកម្ពុជា-វៀតណាមបានរសាយបន្តិចម្ដងៗ ក្រោយឆ្នាំ១៩៧៥ ដោយសារបញ្ហាដីកោះ និងព្រំដែន។ ប្រទេសវៀតណាម មានគម្រោងប្រមូលប្រទេសទាំងបីនៃជ្រោយឥណ្ឌូចិនឱ្យស្ថិតក្រោមការដឹកនាំរបស់ហាណូយតែមួយ។ ប៉ុន្តែ កម្ពុជាប្រជាធិបតេយ្យមិនព្រមចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាព ហើយបែរជាចាប់ដៃជាមួយក្រុងប៉េកាំងវិញ។ ការប៉ះទង្គិចគ្នាដោយអាវុធបានកើតឡើងជារឿយៗ ហើយនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ កងទ័ពខ្មែរក្រហមបានវាយលុកភូមិ និងក្រុងតូចៗរបស់វៀតណាមខាងត្បូង។ នៅខែកក្កដា ឆ្នាំ១៩៧៧ មេដឹកនាំបក្សកុម្មុយនីស្តវៀតណាមសម្រេចចិត្តកម្ទេច ប៉ុល ពត និងរបបនេះចោល។ ភាពតានតឹងផ្ទៃក្នុង ពិសេសការបោសសម្អាតភូមិភាគបូព៌ា បានផ្ដល់ឱកាសឱ្យវៀតណាមគាំទ្រក្រុមមេដឹកនាំខ្មែរក្រហមដែលបានរត់គៀសខ្លួនឱ្យបង្កើត«រណសិរ្សសង្គ្រោះជាតិកម្ពុជា» នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ដើម្បីផ្ដួលរលំរបបនេះ។ ទីបំផុត កងទ័ពវៀតណាមបានដាក់កងទ័ពប្រយុទ្ធលើសទ័ពខ្មែរក្រហមពីរដង(៦០.០០០នាក់ ទល់នឹង២៨.០០០នាក់) ដោយប្រើឧទ្ធម្ភាគចក្រ និងរថក្រោះជាច្រើនគ្រឿង ហើយបានសម្រុកចូលភ្នំពេញនៅម៉ោង ១២កន្លះថ្ងៃត្រង់ នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រំដោះរដ្ឋធានីទាំងមូល។

# មេរៀនទី១៣ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា( ១៩៧៩ ដល់១៩៩៣ )[396]

## ១-ស្ថានភាពសង្គមខ្មែរក្រោយឆ្នាំ១៩៧៩

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រដ្ឋធានីភ្នំពេញត្រូវបានរំដោះចេញពីរបបកម្ពុជាប្រជាធិបតេយ្យ។ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ខេត្តក្នុងប្រទេសកម្ពុជាបានរំដោះបន្តបន្ទាប់៖

| ល.រ | ខេត្ត | កាលបរិច្ឆេទ |
|---|---|---|
| ១ | ខេត្តក្រចេះ | ៣០ ធ្នូ ១៩៧៨ |
| ២ | ខេត្តរតនគិរី | ៣១ ធ្នូ ១៩៧៨ |
| ៣ | ខេត្តមណ្ឌលគិរី | ៣ មករា ១៩៧៩ |
| ៤ | ខេត្តស្ទឹងត្រែង | ៤ មករា ១៩៧៩ |
| ៥ | ខេត្តស្វាយរៀង | ៤ មករា ១៩៧៩ |
| ៦ | ខេត្តកំពង់ចាម | ៦ មករា ១៩៧៩ |
| ៧ | ភ្នំពេញ | ៧ មករា ១៩៧៩ |
| ៨ | កណ្ដាល | ៧ មករា ១៩៧៩ |
| ៩ | តាកែវ | ៨ មករា ១៩៧៩ |
| ១០ | ព្រៃវែង | ៨ មករា ១៩៧៩ |
| ១១ | កំពង់ស្ពឺ | ៩ មករា ១៩៧៩ |
| ១២ | កំពង់ធំ | ៩ មករា ១៩៧៩ |
| ១៣ | កំពត | ៩ មករា ១៩៧៩ |
| ១៤ | ខេត្តសៀមរាប | ១០ មករា ១៩៧៩ |
| ១៥ | ឧត្តរមានជ័យ | ១០ មករា ១៩៧៩ |
| ១៦ | កំពង់ឆ្នាំង | ១២ មករា ១៩៧៩ |
| ១៧ | បាត់ដំបង | ១៣ មករា ១៩៧៩ |
| ១៨ | ពោធិ៍សាត់ | ១៤ មករា ១៩៧៩ |
| ១៩ | ព្រះវិហារ | ១៦ មករា ១៩៧៩ |
| ២០ | កោះកុង | ១៧ មករា ១៩៧៩ |
| ២១ | កំពង់សោម | ១៧ មករា ១៩៧៩ |

[396] សូមមើល : ទី សុផល, *ប្រវត្តិវិទ្យា*, ដ.ឯ.ម., ទំព័រ៦២៤-៦៥៣។

កាលបរិច្ឆេទនៃការរំដោះប្រទេសកម្ពុជា ពីរបបកម្ពុជាប្រជាធិបតេយ្យ




ការលុកលុយរបស់កងទ័ពវៀតណាម រួមជាមួយការតស៊ូប្រឆាំងពួកខ្មែរក្រហម ដែលមានរាយប៉ាយក្នុងប្រទេស និងការផ្លាស់ទីរបស់ប្រជាជនក្នុងទ្រង់ទ្រាយធំនៅដើមឆ្នាំ១៩៧៩ បានបន្ថចបង្អាក់យ៉ាងខ្លាំងដល់ការប្រមូលផលស្រូវប្រចាំឆ្នាំដ៏សំខាន់របស់ប្រទេសនេះនាដើមឆ្នាំនោះ។ កងទ័ពទាំងសងខាងបានបំផ្លាញស្រូវក្នុងស្តុក ឬស្រូវដែលមិនទាន់បានប្រមូលផល ដើម្បីកុំឱ្យទិន្នផលនោះធ្លាក់ចូលទៅក្នុងដៃសត្រូវខ្លួន។ រាល់ម្ហូបអាហារដែលមិនត្រូវបានកាន់កាប់ ឬដែលមិនត្រូវបានដុតចោលត្រូវបានបរិភោគដោយជនភៀសខ្លួនដែលបានធ្វើដំណើរទូទាំងប្រទេស។ ក្រោយថ្ងៃរំដោះ ផលវិបាកផ្ទាល់ពីគ្រោះទុរ្ភិក្សកើតមានឡើងស្ទើរគ្រប់ទីកន្លែងបានគំរាមកំហែងប្រជាជនប្រមាណជាង៥លាននាក់។ អ្វីជាឧបសគ្គសម្រាប់ប្រជាជននៅពេលនោះគឺមានបញ្ហាសុខភាពដែលស្គមរីងរៃ និងបាក់កម្លាំង ហើយនឹងការជួបគ្រោះអត់ឃ្លាន, ខ្វះសម្លៀកបំពាក់, ខ្វះទីជម្រក, ខ្វះឧបករណ៍ប្រើប្រាស់ជាពិសេសផ្នែកកសិកម្ម។

នៅក្រុងភ្នំពេញគឺគ្មានសកម្មភាពឡើយ។ មណ្ឌលកុមារកំព្រាមួយ មានកុមារស្ទើរស្លាប់ដោយការអត់ឃ្លានជាច្រើននាក់។ វិទ្យាល័យមួយដែលខ្មែរក្រហមបានយកធ្វើជាពន្ធនាគារ ហើយដែលក្នុងនោះមានមនុស្សច្រើនជាង១៦ ០០០នាក់ ត្រូវបានធ្វើទារុណកម្មរហូតដល់ស្លាប់។ ទោះបីជាមានការជួបបញ្ហាទុរ្ភិក្សក៏ដោយ ក៏ប្រជាជនខ្មែរអាចដោះស្រាយបញ្ហាបានចំពោះអាហារហូបចុកដែរ ព្រោះកម្ពុជាគឺជាប្រទេសមួយដែលសម្បូរទៅដោយធនធានធម្មជាតិដូចជាសត្វព្រៃ, មច្ឆា, បន្លែ និងផ្លែឈើ ជាដើម។ ទោះបីប្រទេសកម្ពុជាបានរំដោះពីរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏កម្ពុជាមិនទាន់ទទួលបានសន្តិភាពពេញលេញ និងរួមគ្នាជាផ្លូងមួយនោះ

ឡើយគឺប្រទេសកម្ពុជាពេលនោះចែកជាបួនក្រុមដែលមាននិន្នាការ, ទិសដៅ និងការគាំទ្រផ្សេងគ្នាពីមជ្ឈដ្ឋានអន្តរជាតិផ្សេងៗគ្នា។

## ភាគីនៅក្នុងជម្លោះក្រោយឆ្នាំ១៩៧៩

| ល.រ | ភាគីនៃជម្លោះ | ព័ត៌មានសំខាន់ៗ |
|---|---|---|
| ១ | **រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា** | – ថ្នាក់ដឹកនាំ: សមមិត្ត ហេង សំរិន។<br>– ទិសដៅ : កសាងជាតិឡើងវិញព្រមទាំងទប់ស្កាត់ការវិលត្រឡប់របស់ខ្មែរក្រហម<br>– តំបន់គ្រប់គ្រង: កាន់កាប់ទឹកដីស្ទើរទាំងអស់នៃទឹកដីប្រទេសកម្ពុជា។<br>– ការគាំទ្រ : ទទួលការឧបត្ថម្ភគាំទ្រពីប្រទេសវៀតណាម, សហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយមជាមិត្ត។ |
| ២ | **កម្ពុជាប្រជាធិបតេយ្យ ឬ ខ្មែរក្រហម** | – ខ្មែរក្រហម លែងគ្រប់គ្រងកម្ពុជាក៏ពិតមែន ប៉ុន្តែ ពួកគេនៅតែរក្សាបានអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិ ដោយមានការគាំទ្រពីសហរដ្ឋអាម៉េរិក, ចិន និងប្លុកសេរី។ កងទ័ពខ្មែរក្រហមនៅតែបន្តគ្រប់គ្រងទឹកដីកម្ពុជាមួយភាគ និងជំរំជនភៀសខ្លួនមួយចំនួនដែលស្ថិតនៅតាមព្រំដែនខ្មែរ-ថៃ។<br>– ទទួលជំនួយជាច្រើនពីបរទេស ជាពិសេសប្រទេសចិន។ ចំពោះថវិកាដែលបានមកពីជំនួយបរទេស ការលក់ព្រៃឈើ និងរ៉ែត្បូងនៅប៉ៃលិនបានធ្វើឱ្យកម្លាំងខ្មែរក្រហមនៅតែរឹងមាំ និងគំរាមកំហែងសន្តិសុខជាតិគ្រប់ពេលវេលា។ ពួកខ្មែរក្រហមនៅតែព្យាយាមវិលត្រឡប់មកកាន់អំណាចវិញ។ |
| ៣ | **ក្រុមរាជានិយម** ( FUNCINPEC- ហ៊្វុនស៊ិនប៉ិច ) | – កំណើត : បង្កើតឡើងនៅខែមីនា ឆ្នាំ១៩៨១ ដោយមានការចូលរួមពីក្រុមម៉ូលីណាកា និងអ្នកតស៊ូជាច្រើនក្រុមទៀត ដែលបង្កើតតាំងពីឆ្នាំ១៩៧៩។<br>– ទិសដៅសំខាន់ : ប្រឆាំងនឹងវត្តមានរបស់កងទ័ពវៀតណាមនៅលើទឹកដីកម្ពុជា។<br>– ការគ្រប់គ្រង : ភាគីនេះកាន់កាប់ទឹកដី និងជំរំជនភៀសខ្លួនមួយចំនួន តាមព្រំដែនខ្មែរ-ថៃ។ ជំរំ ដែលសំខាន់ជាងគេរបស់ក្រុមនេះគឺស្ថិតនៅអូរស្មាច់ខេត្តឧត្តរមានជ័យ។ |
| ៤ | **រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ.)** | – ថ្នាក់ដឹកនាំ : ឯកឧត្តម សឺន សាន។<br>– កំណើត : នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៩។<br>– អ្នកចូលរួម : មានប្រភពខុសៗគ្នា។<br>– ទិសដៅ : មានទិសដៅសំខាន់៣គឺ រំដោះប្រទេសកម្ពុជាពីអំណាចរបស់វៀតណាម,ប្រឆាំងការវិលត្រឡប់មកកាន់អំណាចរបស់ខ្មែរក្រហម និងកសាងជាតិឡើងវិញ។ |

| | | |
|---|---|---|
| | | – តំបន់គ្រប់គ្រង : កាន់កាប់ទឹកដី និងជំរំជនភៀសខ្លួនមួយចំនួននៅតាមព្រំដែនខ្មែរ-ថៃ។ |

ចំពោះប្រជាជនក្រោយថ្ងៃរំដោះ គឺត្រូវត្រឡប់មករកស្រុកកំណើតបងប្អូនវិញ ហើយប្រជាជនមួយចំនួនបានស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ ក្រៅពីនេះក៏មានប្រជាជនជាច្រើនពាន់នាក់ គេចចេញពីតំបន់ដែលខ្មែរក្រហមគ្រប់គ្រងចូលទៅរស់នៅក្នុងប្រទេសថៃ។ ប៉ុន្តែ ក៏មានប្រជាជនមួយចំនួន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើចំណាកស្រុកទៅប្រទេសទី២ និងទី៣ដែរ ដោយសារតែពួកគាត់មិនទុកចិត្ត និងមិនពេញចិត្តដែលឃើញវៀតណាមជាអ្នកជួយជ្រោមជ្រែងនោះ និងមានជំនាញការវៀតណាមចូលមកគ្រប់ទីកន្លែង។ ការរងទុក្ខរបស់ប្រជាពលរដ្ឋកម្ពុជា បានអុជភ្លើងនៃសតិសម្បជញ្ញៈរបស់សហគមន៍អន្តរជាតិ។ ពេលនោះ អាស៊ាន និងអង្គការសហប្រជាជាតិ បានសម្រេចដកកងទ័ពវៀតណាមចេញពីកម្ពុជា។ ប៉ុន្តែ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចោទថាជាការជ្រៀតជ្រែកផ្ទៃក្នុងរបស់កម្ពុជា និងនៅលើឆាកអន្តរជាតិមានប្រទេសជាង៣០គាំទ្ររបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយប្រទេសជាង៣០ទៀត បានបិតនៅក្នុងជំហរអនុបវាទ។ ចំណែកឯ ប្រទេសដែលប្រកាន់នូវរបបកុម្មុយនីស្តក្នុងតំបន់អាស៊ីអាគ្នេយ៍ និងប្រទេសមួយចំនួនទៀត នៅក្នុងពិភពលោកមិនគាំទ្រចំពោះការឈ្លានពានរបស់វៀតណាមមកលើទឹកដីកម្ពុជាទេ ហើយពួកគេនៅតែទទួលស្គាល់របបខ្មែរក្រហមថាជារដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា។ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាមានភារៈចាំបាច់របស់ខ្លួន ដែលត្រូវតែរៀបចំការស្តារប្រទេសឡើងវិញជាមួយបញ្ហាប្រឈមជាច្រើន នៅចំពោះមុខក្នុងស្ថានភាពជម្លោះ និងការស្តារប្រទេសជាតិ។

ការរៀបចំស្ថាប័នរដ្ឋឱ្យមានដំណើរការសន្សឹមៗសិន ក៏ជួបនឹងបញ្ហាឧបសគ្គច្រើនណាស់ដែរពីព្រោះកិច្ចការនេះ ទាមទារនូវទុនផ្នែកបញ្ញាយ៉ាងខ្លាំងក្លា ជាពិសេសសមត្ថកិច្ច, បច្ចេកទេស និងឯកទេសគ្រប់ប្រភេទ។ ដើម្បីកសាងមូលដ្ឋានសេដ្ឋកិច្ចរដ្ឋត្រូវបង្កើតរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុជាចាំបាច់។ អ្នកដឹកនាំខ្មែរ និងអ្នកជំនាញការវៀតណាមបានប្រមែប្រមូលអ្នកច្បាប់ខ្មែរដែលនៅសល់ពីការស្លាប់ ឱ្យមករៀបចំបង្កើតនូវមូលដ្ឋានច្បាប់មួយសម្រាប់គ្រប់គ្រងប្រទេស។ ក្រោយការបោះឆ្នោតជ្រើសតាំងសភាជម្មនុញ្ញនៅឆ្នាំ១៩៨០ រដ្ឋធម្មនុញ្ញមួយ ក៏បានត្រូវអនុម័តដោយអង្គប្រជុំសភាដំបូងបង្អស់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១។

ចំណែកភាគីតស៊ូតាមជាយដែន បានសម្រេចបង្កើតនូវរដ្ឋាភិបាលរួមគ្នាមួយ។ នៅខែកញ្ញា ឆ្នាំ១៩៨១ សម្តេចព្រះនរោត្តម សីហនុ និងឯកឧត្តម សឺន សាន បានធ្វើដំណើរទៅប្រទេសសិង្ហបុរីក្នុងគោលបំណងដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងគ្នាលើ៤ចំណុចៈ

១-ការបង្កើតឱ្យមានរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ

២-ការបង្កើតឱ្យមានក្រុមប្រឹក្សារៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋាភិបាលចម្រុះ

៣-ដំណើរការស្វែងរកការគាំទ្រក្នុងការដោះស្រាយជម្លោះរបស់កម្ពុជាក្នុងកិច្ចពិភាក្សាជាលក្ខណៈអន្តរជាតិអំពីកម្ពុជាក៏ដូចជាការស្វែងរកការជួយដោះស្រាយពីសំណាក់អង្គការសហប្រជាជាតិ

៤-ការអំពាវនាវសម្រាប់ការគាំទ្រពីអន្តរជាតិមកលើរដ្ឋាភិបាលចម្រុះ។

ចំពោះការបង្កើតរដ្ឋាភិបាលចម្រុះ ហាក់ដូចជាអនុគ្រោះដល់ក្រុមខ្មែរក្រហមច្រើនជាងគេ។ ចំពោះការបោះឆ្នោតនោះត្រូវស្របទៅ លើមតិភាគច្រើននៃការប្រើច្បាប់របស់កម្ពុជាប្រជាធិបតេយ្យជាមូលដ្ឋានច្បាប់របស់រដ្ឋាភិបាលចម្រុះ ដែលសម្តេចព្រះនរោត្តម សីហនុ និងឯកឧត្តម សឺន សាន មានការបារម្ភខ្លាចក្រុមខ្មែរ

ក្រហមអាចទាញយកបានផលប្រយោជន៍ច្រើនរឿងនេះ។ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៨២ សម្តេចព្រះនរោត្តម សីហនុ និងលោក ខៀវ សំផន ក៏បានជួបគ្នានៅក្រុងប៉េកាំងប្រកាសគម្រោងបង្កើតចលនាចម្រុះតែឯកឧត្តម សឺន សាន មិនបានចូលរួមទេ។ សម្តេចព្រះនរោត្តម សីហនុ បានស្នើសុំឱ្យឯកឧត្តម សឺន សាន ជួយដោះស្រាយការខ្វែងគំនិតគ្នារវាងទ្រង់និងលោក ខៀវ សំផន ហើយក៏បានសុំឱ្យឯកឧត្តម សឺន សាន ចូលរួមក្នុងរដ្ឋាភិបាលចម្រុះ។ ចំពោះសហគមន៍អន្តរជាតិ និងសហរដ្ឋអាម៉េរិកបានធ្វើឱ្យសម្តេចព្រះ នរោត្តម សីហនុ និងឯកឧត្តម សឺន សាន បានដឹងយ៉ាងច្បាស់ថាពួកគេយល់ព្រមផ្តល់ជំនួយរបស់ខ្លួនទៅឱ្យរដ្ឋាភិបាលស្របច្បាប់មួយគឺពុំមែនជាចលនាកងទ័ពព្រៃឡើយ។

ចុងបញ្ចប់ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៨២ ដោយការជំរុញ និងជ្រោមជ្រែងពីប្រទេសចិន, អាស៊ាន និងប្រទេសលោកខាងលិចផងនោះធ្វើឱ្យចលនាតស៊ូទាំងបីជួបជុំគ្នាជាថ្មីនៅកូឡាឡាំពួរបង្កើតនូវ«រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ»ជាផ្លូវការ។ ដៃគូរបស់រដ្ឋាភិបាលនេះ បានយល់ស្របនឹងលក្ខខណ្ឌបួនរបស់ពួកគេគឺរចនាសម្ព័ន្ធត្រីភាគី ការមិនមានភាពលើសលប់ជាងគេរបស់ភាគីណាមួយក្នុងចំណោមភាគីបី(បានន័យថាគ្មានអ្នកណាលើសអ្នកណាទេ) បែបប្រកាន់យកការសម្រេចចិត្តឯកច្ឆន្ទ និងការអនុម័តយកទង់ជាតិ និងបទភ្លេងជាតិប្រជាធិបតេយ្យ។ រដ្ឋាភិបាលនេះគ្រប់គ្រងទឹកដីតិចជាង១០ភាគរយ និងប្រជាជនតិចជាង៥ភាគរយនៅតាមព្រំដែនខ្មែរ-ថៃ និងតំបន់មួយចំនួនតូចទៀតនៅក្នុងប្រទេស។

របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រកាន់យកលទ្ធិសង្គមនិយមតាមគំរូសហភាពសូវៀត ដែលគ្រប់គ្រងដោយបក្សតែមួយគឺបក្សប្រជាជនបដិវត្តន៍កម្ពុជា និងមានអង្គការគ្រប់គ្រងកំពូលសំខាន់ៗចំនួន៤។

## ស្ថាប័នគ្រប់គ្រងកំពូល

| ល.រ | ស្ថាប័ន | ព័ត៌មានសំខាន់ៗ |
|---|---|---|
| ១ | បក្សប្រជាជនបដិវត្តន៍កម្ពុជា | –ដឹកនាំដោយសមមិត្ត ប៉ែន សុវណ្ណ ដែលជាអគ្គលេខាធិការ<br>–នៅខែធ្នូ ឆ្នាំ១៩៨១ សមមិត្ត ហេង សំរិន បានកាន់តំណែងនេះជំនួសវិញ និងនៅតែបន្តកាន់តំណែងជាប្រធានរដ្ឋ។<br>–តួនាទី : ជាកម្លាំងដឹកនាំផ្ទាល់នូវការងារបដិវត្តទាំងមូលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា[397]។ |
| ២ | ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ | –ស្ថាប័ននេះ ក្រោយមកបានក្លាយជារដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដឹកនាំដោយប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី។<br>–ជាអង្គការនីតិប្រតិបត្តិ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យសម្រេចទិសដៅសំខាន់ៗរបស់បក្ស។<br>–ដំបូងក្រុមប្រឹក្សានេះ មានសមមិត្ត ប៉ែន សុវណ្ណ ជាប្រធាន។<br>–ចុងឆ្នាំ១៩៨១ សមមិត្ត ចាន់ ស៊ី បានឡើងកាន់តំណែងជំនួសសមមិត្ត ប៉ែន សុវណ្ណ។<br>–នៅឆ្នាំ១៩៨៥ សមមិត្ត ហ៊ុន សែន បានឡើងកាន់តំណែងជំនួសសមមិត្ត ចាន់ ស៊ី ដែលបានទទួលមរណភាពនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៨៤។<br>–ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវកំណត់ការប្រជុំយ៉ាងទៀងទាត់ ដើម្បីចាត់វិធានការរដ្ឋបាលយ៉ាងច្បាស់លាស់សម្រាប់រដ្ឋមន្ត្រីយកទៅផ្សព្វផ្សាយតាមក្រសួង មន្ទីរនានា ចៀសវាងនូវការអនុវត្តខុសទិសដៅ ហើយតំណាងក្រសួងនីមួយៗឡើងរាយការណ៍បង្ហាញពីសមិទ្ធផល និងបញ្ហាផ្សេងៗដែលកើតមាន។ |
| ៣ | រដ្ឋសភាជាតិ | –នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ សភាជាតិបានអនុម័តរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ព្រមទាំងបានតែងតាំងសមមិត្ត ហេង សំរិន ជាប្រធានក្រុមប្រឹក្សារដ្ឋ និងសមមិត្ត ប៉ែន សុវណ្ណ ជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី។<br>–រដ្ឋសភាគឺជាអង្គការកំពូលនៃរដ្ឋអំណាច និងជាតំណាងរបស់ប្រជាជន។<br>–រដ្ឋសភា ជាអង្គការតែមួយគត់ដែលមានសិទ្ធិធ្វើច្បាប់ ហើយនិតិកាលរបស់រដ្ឋសភាមានកំណត់៥ឆ្នាំ។ |
| ៤ | សាលាជំនុំជម្រះក្តី ឬ អយ្យការ | –តុលាការប្រជាជនបដិវត្ត ត្រូវបានប្រើសម្រាប់ជំនុំជម្រះក្តីលើប៉ុល ពត, អៀង សារី នាខែសីហា ឆ្នាំ១៩៧៩។<br>–តុលាការប្រជាជន និងតុលាការយោធា ជាអង្គជំនុំជម្រះនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។<br>–ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។<br>–ក្រុមប្រឹក្សារដ្ឋអាចបង្កើតតុលាការពិសេសដើម្បីជំនុំជម្រះរឿងដែលមានលក្ខណៈពិសេស។ |

[397] មាត្រាទី៤ ក្នុងរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

រដ្ឋាភិបាលដំបូងដឹកនាំដោយ សមមិត្ត ប៉ែន សុវណ្ណ ត្រូវបានបង្កើតឡើងនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ ១៩៨១ ហើយបានរុះរើទៅវិញនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៨១ បន្ទាប់ពីលោកបានកាន់តំណែងអស់រយៈពេល៦ ខែ។ ក្រោយការបញ្ចប់តំណែងរបស់សមមិត្ត ប៉ែន សុវណ្ណ គឺសមមិត្ត ចាន់ ស៊ី បានឡើងកាន់អំណាចចាប់ពី ខែធ្នូ ឆ្នាំ១៩៨១ ហើយបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៨៤ នៅខណៈពេលដែលលោកទទួលមរណភាព ទើបក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាតែងតាំង សមមិត្ត ហ៊ុន សែន[398] ជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ស្ថានភាពនោះគឺជាភារកិច្ចមួយដ៏ពិបាកសម្រាប់នាយករដ្ឋមន្ត្រីទើបនឹងតែងតាំងថ្មី ដែលក្នុងឆ្នាំ១៩៨៥ រូបគាត់ និងគណបក្សប្រជាជនបដិវត្តកម្ពុជា មិនត្រូវបានបណ្តាប្រទេសមិនមែនកុម្មុយនីស្តនៅអាស៊ី និងលោកខាងលិចរាប់រក។

## ២-ការទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហម

រដ្ឋអំណាចមូលដ្ឋាន បានបង្កើតកងសេនាជនភូមិ ឬស្វ័យត្រាណ ក្រុមស្វ័យការពារ ក្រុមយាមកាម ដែលតម្រូវឱ្យប្រជាជន, សិស្ស, និស្សិត និងមន្ត្រីរដ្ឋការចូលរួម ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់តាមភូមិ ឃុំ និងអង្គភាពរបស់ខ្លួន។ សិស្ស និស្សិតតែងទទួលការហ្វឹកហាត់ក្បួនយោធានៅមុនពេលបវេសនកាលរៀងរាល់ឆ្នាំ។ នៅតាមភូមិនានារដ្ឋអំណាចតម្រូវឱ្យប្រជាជនប្រើគ្រដោកសម្រាប់គោះប្រកាសអាសន្ន។ នៅតាមតំបន់ជនបទ មានការកសាងរបងយុទ្ធសាស្ត្រព័ទ្ធជុំវិញភូមិ និងទុកច្រកចេញ-ចូល ២ ឬ៣ច្រក ដែលគេដាក់គ្រាប់មីនបង្ការរៀងរាល់យប់។ រៀងរាល់រដូវប្រាំង រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាតែងវាយសម្រុកទៅលើពួកខ្មែរក្រហម និងគ្រប់គ្រងតំបន់មួយចំនួននៅតាមព្រំដែន។ ក៏ប៉ុន្តែ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវដកទ័ពមកវិញ នៅរដូវវស្សាជាហេតុធ្វើឱ្យពួកខ្មែរក្រហមដណ្តើមយកបានវិញនូវទីតាំង ដែលវាយបាន។ មូលហេតុដែលរដ្ឋាភិបាល ត្រូវដកទ័ពត្រលប់មកវិញនៅរដូវវស្សា គឺដោយសារប្រព័ន្ធផ្លូវថ្នល់មានការលំបាកខ្លាំង ពិបាកក្នុងការដឹកជញ្ជូនផ្គត់ផ្គង់ស្បៀងនិងសព្វាវុធ កម្លាំងនៅសមរភូមិក្រោយនៅមិនទាន់រឹងមាំ ដែលទាមទារការដកកម្លាំងពីព្រំដែន ឬសមរភូមិមុខមកពង្រឹងសមរភូមិក្រោយ។ នៅឆ្នាំ១៩៨៤ កងកម្លាំងនៅសមរភូមិក្រោយរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា មានការរីកចម្រើនច្រើនដែលអាចបន្តវាយលុកនៅរដូវវស្សា និងការពារទីតាំងដែលដណ្តើមបានកាលពីរដូវប្រាំង។ នៅឆ្នាំ១៩៨៥ រដ្ឋាភិបាលបានវាយកាន់កាប់ជំរំជនភៀសខ្លួនខ្មែរ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយភាគីទាំងបី តាំងនៅតាមព្រំដែនខ្មែរ-ថៃ។ ប៉ុន្តែយុទ្ធនាការយោធានេះ បានធ្វើឱ្យពួកគេដកថយទៅបោះជំរំថ្មីនៅតាមជាយដែន នៃទឹកដីថៃវិញ។

នៅខែកក្កដា ឆ្នាំ១៩៨៤ ការិយាល័យនយោបាយមជ្ឈិមបក្សបានចេញសេចក្តីសម្រេចចិត្តមួយស្តីពីការបង្កើនការការពារនៅតាមព្រំដែនកម្ពុជា-ថៃដោយឱ្យឈ្មោះថា ផែនការ ក៥ «កែនកម្លាំងកាប់ឆ្ការព្រៃការពារព្រំដែនកម្ពុជា»។ ផែនការនេះតម្រូវឱ្យមានការចូលរួមពីប្រជាជនខ្មែរ ដើម្បីសាងសង់ផ្លូវនៅតាមព្រំដែន សម្រួលក្នុងការដឹកជញ្ជូនកងទ័ព អាវុធ ស្បៀង, កាប់ឆ្ការព្រៃនៅក្បែរភូមិ ជុំវិញផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក តាមជនបទ និងតាមតំបន់ព្រំដែន ដើម្បីបំផ្លាញជម្រកលាក់ខ្លួនរបស់ពួកកងទ័ពនៃរដ្ឋាភិបាលត្រីភាគី ព្រមទាំងរៀបចំកសាងប្រព័ន្ធការពារនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ដោយក្នុងនោះមានការដាក់ចម្រូងឫស្សី ដាក់មីន លើកទំនប់

[398] យោងតាមក្រឹត្យលេខ០៣ ក្រ ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៨៥ ក្នុងមាត្រាទី១បានសម្រេចថា« បានតែងតាំងជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បន្ថែមលើមុខតំណែងជារដ្ឋមន្ត្រីក្រសួងការបរទេស»។ សមមិត្ត ហ៊ុន សែន គឺជាសមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តកម្ពុជា។ ថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨៥ គឺជាថ្ងៃបញ្ចប់(១០-១៤/១/១៩៨៥)នៃសម័យប្រជុំរដ្ឋសភាលើកទី៨ និតិកាលទី១ ហើយសភាបានជ្រើសតាំងសមមិត្ត ហ៊ុន សែន ជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីថ្មី។

និងជីកលេណដ្ឋាន ជាដើម។ នៅរដូវប្រាំងចុងឆ្នាំ១៩៨៤ ដើមឆ្នាំ១៩៨៥ កងទ័ពរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានទទួលជោគជ័យច្រើនជាងមុននៅតាមព្រំដែន។ ក៏ប៉ុន្តែពួកកងទ័ពត្រីភាគីបានឆ្លៀតឱកាសនោះប្រើប្រាស់ក្រុមតូចៗក្នុងការបំផ្លាញ និងបង្កអស្ថិរភាពនៅសមរភូមិក្រោយ។ ក្នុងស្ថានភាពបែបនេះរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានកំណត់នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៨៥ នូវកាតព្វកិច្ចយោធារយៈពេល៥ឆ្នាំ សម្រាប់ពលរដ្ឋខ្មែរដែលមានអាយុចាប់ពី១៨ឆ្នាំឡើង។ សង្គ្រាមស៊ីវិលនៅតែអូសបន្លាយដោយគ្មានអ្នកឈ្នះ គ្មានអ្នកចាញ់ គឺមានតែជនរងគ្រោះ និងអ្នកស្លាប់ដោយសារសង្គ្រាម ដោយជនទាំងនោះសុទ្ធសឹងតែជាជនជាតិខ្មែរ។

## ៣-ដំណើរស្វែងរកកិច្ចចរចាសន្តិភាពនៅកម្ពុជា(១៩៨១-១៩៩១)

ដំណើរការស្វែងរកសន្តិភាពនៅប្រទេសកម្ពុជា គឺមានការចូលរួមពីសហគមន៍អន្តរជាតិយ៉ាងសកម្មក្នុងរយៈពេល៥ឆ្នាំដំបូងពីឆ្នាំ១៩៨១ ដល់១៩៨៦ និងបន្តដោយភាគីកម្ពុជាដែលពាក់ព័ន្ធក្នុងជម្លោះ៥ឆ្នាំបន្ទាប់ពីឆ្នាំ១៩៨៧ ដល់១៩៩១។ ដោយមានការចូលរួមពីភាគីកម្ពុជា, ប្រទេសក្នុងតំបន់, សហគមន៍អន្តរជាតិ និងលេខាធិការនៃអង្គការសហប្រជាជាតិនោះ ទើបនាំឱ្យកើតមានឡើងនូវសន្និសីទអន្តរជាតិថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានឈានមកដល់ «កិច្ចព្រមព្រៀងក្រុងប៉ារីសស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា»ដែលមានប្រទេសបារាំង និងប្រទេសឥណ្ឌូណេស៊ី ជាសហប្រធាន និងមានការចូលរួមពីបណ្តាប្រទេសដែលពាក់ព័ន្ធ និងគ្រប់ភាគីកម្ពុជាក្នុងជម្លោះនេះ។

### ៣.១-ការចូលរួមពីសហគមន៍អន្តរជាតិពីឆ្នាំ១៩៨១ ដល់១៩៨៦

របបថ្មីមួយបានចាប់បដិសន្ធិក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មានឈ្មោះថា«សាធារណរដ្ឋប្រជាមានិតកម្ពុជា» ដឹកនាំដោយសមមិត្ត ហេង សំរិន។ ទោះបីជារួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែកម្ពុជាមិនទាន់ទទួលបានសុខសន្តិភាពឡើយព្រោះរដ្ឋាភិបាលថ្មីនេះមិនមានការទទួលស្គាល់ពីអង្គការសហប្រជាជាតិ, សហគមន៍អឺរ៉ុប, សហរដ្ឋអាម៉េរិក, ចិន និងអាស៊ាន រួមទាំងប្រទេសលោកសេរីជាច្រើនទៀត។ ដូច្នេះសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវប្រឈមមុខក្នុងស្ថានភាព«ស៣»គឺ ស្តារប្រទេស, សង្គ្រាម និងស្វែងរកសន្តិភាព។ នៅក្នុងដំណាក់កាលការស្តារប្រទេស រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវកសាងនូវមូលដ្ឋានសេដ្ឋកិច្ចជាតិដោយបានបង្កើតហិរញ្ញវត្ថុ, ប្រព័ន្ធហិរញ្ញវត្ថុ និងការបោះឆ្នោតជ្រើសរើសសភាធម្មនុញ្ញនៅឆ្នាំ១៩៨០។ រដ្ឋធម្មនុញ្ញមួយបានត្រូវអនុម័តដោយអង្គប្រជុំសភាដំបូងបង្អស់នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១។ បន្ថែមពីនេះ សាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានចាប់ផ្តើមផ្សព្វផ្សាយគោលនយោបាយសន្តិភាពរបស់ខ្លួនទៅកាន់ពិភពលោក និងពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋាន ដែលគោលនយោបាយនេះត្រូវបានអន្តរជាតិទទួលស្គាល់ និងចាប់ផ្តើមមានការគាំទ្រ។ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវចំណាយពេលវេលាច្រើនក្នុងការស្វែងរកកិច្ចសហប្រតិបត្តិការគ្រប់មជ្ឈដ្ឋាន។

ក្នុងដំណាក់កាលនោះ ប្រទេសលោកខាងលិច បានគាំទ្រក្រុមតស៊ូតាមជាយដែនខ្មែរ-ថៃ ប្រឆាំងនឹងកងទ័ពវៀតណាមនៅកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ក្រុមបស្ចិមប្រទេស និងសមាជិកអាស៊ានមួយចំនួន បានជួយជំរុញឱ្យក្រុមតស៊ូតាមជាយដែនខ្មែរ-ថៃទាំងបីបង្កើតក្រុមរណសិរ្សរួមគ្នាឡើងនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៨២ មានឈ្មោះថា«រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ(GCDK) ឬរដ្ឋាភិបាលត្រីភាគី» ដែលមានសម្តេចព្រះនរោត្តម សីហនុ ជាប្រធាន និងឯកឧត្តម សឺន សាន ជានាយករដ្ឋមន្ត្រី។

ចំពោះអង្គការសហប្រជាជាតិចាប់តាំងពីឆ្នាំ១៩៧៩ មកជារៀងរាល់ឆ្នាំអង្គការនេះ តែងតែបោះឆ្នោតទទួលញត្តិបញ្ហាឱ្យវៀតណាមដកទ័ពចេញពីកម្ពុជា។ ដូចគ្នាដែរ ចំពោះប្រទេសក្នុងឥណ្ឌូចិនចាប់តាំងពីឆ្នាំ១៩៨០ រហូតដល់ឆ្នាំ១៩៨៦ ការរៀបចំសន្និសីទរបស់រដ្ឋមន្ត្រីការបរទេសទាំងបីនៅឥណ្ឌូចិនគឺជាការសហការក្នុងតំបន់ និងជាការរួមចំណែកក្នុងដំណើរឆ្ពោះទៅរកសន្តិភាពនៅឥណ្ឌូចិន ក៏ដូចជាកម្ពុជាផងដែរ។

ចាប់ពីឆ្នាំ១៩៨៤ មកសហគមន៍អន្តរជាតិ កាន់តែយល់ច្បាស់អំពីសភាពការណ៍ពិតប្រាកដនៃការរស់ឡើងវិញរបស់ប្រជាជនខ្មែរ ហើយពិភពលោកក៏កាន់តែយល់ដឹងអំពីអំពើប្រល័យពូជសាសន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ម៉្យាងទៀត រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានប្រើយុទ្ធនាការការទូត, ការអូសទាញជនវង្វេងផ្លូវ, យោធា និងផែនការ«ក៥» ក្នុងការរក្សាស្ថិរភាព, ការអភិវឌ្ឍ និងទប់ទល់ការរស់ឡើងវិញនូវរបបកម្ពុជាប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៨៤ ស្ថានការណ៍បានធ្វើឱ្យសាធារណរដ្ឋប្រជាមានិតកម្ពុជាមានកិត្យានុភាពលើឆាកអន្តរជាតិ និងអាចមានការរៀបចំផ្នែករដ្ឋបាល និងការអភិវឌ្ឍជនបទ នៅក្រោយឆ្នាំ១៩៨៤ ដើម្បីអភិវឌ្ឍប្រទេស និងទប់ទល់ជាមួយរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យផង។ នៅចុងឆ្នាំ១៩៨៤ កម្ពុជាបានបង្ហាញពីសញ្ញាណនៃតួអង្គសំខាន់របស់ខ្លួនគឺឯកឧត្តម ហ៊ុន សែន ជារដ្ឋមន្ត្រីក្រសួងការបរទេសបានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកកិច្ចចរចា។ សម្រាប់រដ្ឋាភិបាលត្រីភាគីមានការបន្ទន់ឥរិយាបថផងដែរ ជាពិសេសនោះសម្តេចព្រះ នរោត្តម សីហនុ ទ្រង់មានបំណងក្នុងការចរចាតាំងពីឆ្នាំ១៩៨៤ ក្នុងស្វែងរកការចរចាដើម្បីបញ្ចប់ជម្លោះនៅលើទឹកដីកម្ពុជា។ ប៉ុន្តែបំណងនោះត្រូវបានទ្រង់លុបចោលវិញ ដែលប្រភពខ្លះបានអះអាងថាមានការជំទាស់ពីចិន និងដៃគូក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ។ សម្រាប់ការចូលរួមរបស់សមាជិកក្នុងតំបន់ តែងតែបានលើកពីបញ្ហាជម្លោះនៅកម្ពុជាជាប្រធានបទមួយក្នុងចំណោមប្រធានបទផ្សេងៗទៀត ហើយរាល់ការពិភាក្សារវាងឥណ្ឌូចិន-អាស៊ានសំដៅប្រែក្លាយអាស៊ីអាគ្នេយ៍ឱ្យទៅជាតំបន់សន្តិភាព, ស្ថិរភាព និងការដកទ័ពវៀតណាមចេញពីទឹកដីកម្ពុជា និងការមិនជ្រៀតជ្រែករបស់ចិនចំពោះបញ្ហាជម្លោះកម្ពុជា។

សរុបសេចក្តីមក រហូតមកដល់ឆ្នាំ១៩៨៤ សហគមន៍អន្តរជាតិកាន់តែយល់ច្បាស់អំពីសភាពការពិតនៃការរស់ឡើងវិញរបស់ប្រជាជនខ្មែរ និងចលនាសន្តិភាពកាន់តែមានការគាំទ្រយ៉ាងទូលំទូលាយ។ ប៉ុន្តែប្រទេសកម្ពុជាបានស្ថិតនៅក្នុងសន្តិភាពផង និងសង្គ្រាមផង ហើយប្លុកខាងលិចនៅតែប្រមូលកម្លាំងប្រឆាំងនឹងរដ្ឋាភិបាលក្រុងភ្នំពេញដោយមានការគាំទ្រពីអង្គការសហប្រជាជាតិផងដែរ។

### ៣.២-កម្ពុជា និងការពាក់ព័ន្ធក្នុងជម្លោះពីឆ្នាំ១៩៨៧ ដល់១៩៩១

នៅឆ្នាំ១៩៨៥ បានបង្ហាញពីតួអង្គឯកឧត្តម ហ៊ុន សែន ដែលជាតួអង្គសំខាន់ក្រោយពេលលោកបានក្លាយជានាយករដ្ឋមន្ត្រី។ ដំណើរឈានទៅរកជំនួបចាប់ពីឆ្នាំ១៩៨៥ គឺជាការខិតជិតគ្នានៃភាគីខ្មែរ សំដៅដោះស្រាយបញ្ហាជាតិដោយខ្លួនឯងដោយមិនរង់ចាំតែឱកាសពីអន្តរជាតិ។ ឯកឧត្តម ហ៊ុន សែន បានធ្វើសម្បទានដើម្បីការបង្រួបបង្រួមជាតិ ដោយលោកបានផ្ញើសារទូរលេខទៅកាន់អង្គការសហប្រជាជាតិនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៨៥។ អត្ថន័យសំខាន់ក្នុងទូរសារនោះគឺរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាស្វាគមន៍រាល់ការប្រឹងប្រែង និងការផ្តួចផ្តើមគំនិតទាំងឡាយសំដៅដំណោះស្រាយបញ្ហាសន្តិភាព និងស្ថិរភាពនៅអាស៊ី និងកម្ពុជា។

នៅឆ្នាំ១៩៨៥ សហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិ រួមទាំងប្រទេសជាច្រើនទៀត ដែលមានដំណើរពីក្រោយ ឬ ស្របគ្នាជាមួយការចេញមុខរបស់ថ្នាក់ដឹកនាំកម្ពុជាបានចាប់ផ្តើមធ្វើអន្តរាគមន៍។ ប្រទេស

ទាំងនោះបានដាក់សំណើផែនការសន្តិភាព និងចូលរួមដោះស្រាយបញ្ហាជម្លោះរបស់កម្ពុជា។ ប្រទេសទាំងនោះមានដូចជាប្រទេសជប៉ុន, ប្រទេសឥណ្ឌូណេស៊ី ស្នើធ្វើជាម្ចាស់ផ្ទះ និងជាដៃគូចរចាតំណាងអាស៊ានជាមួយវៀតណាមតំណាងឥណ្ឌូចិន និងសហភាពសូវៀតផងដែរ។

នៅខែសីហា ឆ្នាំ១៩៨៥ លោក ហ្គោ បាចូវ បានបញ្ជូនបេសកកម្មពាណិជ្ជកម្មមួយទៅកាន់ក្រុងប៉េកាំងជាលើកដំបូងក្នុងរយៈពេលជួបបញ្ហាការទូត និងនយោបាយជាមួយគ្នា២០ឆ្នាំកន្លងមក។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៨៦ «ការត្រិះរិះថ្មី» ក្នុងនយោបាយអាស៊ីរបស់សូវៀត ដែលប្រកាសលោក ហ្គោ បាចូវ នៅ Vladivostok នោះបាននាំឱ្យទំនាក់ទំនងចិន-សូវៀត មានការប្រសើរឡើងវិញយ៉ាងលឿន។ ទំនាក់ទំនងនោះបានដោះស្រាយឧបសគ្គទាំងបីជាមួយនឹងចិនមាន ការដកទ័ពសូវៀតចេញពីតំបន់ព្រំដែនចិន, ដំណោះស្រាយបញ្ហាសង្គ្រាមនៅកម្ពុជាដោយសន្តិវិធី និងការដកកងទ័ពសូវៀតចេញពីអាហ្វកានីស្ថាន។

ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៨៦ ក្នុងសារទូរលេខ១ច្បាប់ផ្ញើជូនចំពោះឯកឧត្តម ប៉េរ៉េដឺគូអេយ៉ា ចំណុចសំខាន់ៗដែលឯកឧត្តម ហ៊ុន សែន បានគូសបញ្ជាក់នោះមាន ការគាំទ្រសេចក្តីថ្លែងការណ៍នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៨៦ របស់សហភាពសូវៀត និងការដកកងទ័ពវៀតណាមបាន៥លើករួចមកហើយ ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជាមានភាពរឹងមាំ និងការទាមទារឱ្យមានការកម្ចាត់ក្រុមប៉ុល ពត។ រហូតមកដល់ខែឧសភា ឆ្នាំ១៩៨៧ ការបត់បែនមួយយ៉ាងធំនៃកិច្ចការទូតរបស់សូវៀតចំពោះកម្ពុជាកើតមាននៅក្នុងខែឧសភា ឆ្នាំ១៩៨៧ នៅពេលមានលោក ហ្គោបាចូវ(Gorbachev) ដែលលោកយកគំរូតាមអាហ្វកានីស្ថានបានជំរុញឱ្យក្រុងហាណូយ និងក្រុងភ្នំពេញទទួលយករូបមន្ត«បង្រួបបង្រួមជាតិ»សម្រាប់សន្តិភាពនៅកម្ពុជា។

| **តារាងសង្ខេបពីការដកទ័ពវៀតណាមចេញពីកម្ពុជា ពីឆ្នាំ១៩៨២ ដល់១៩៨៩**[399] | | |
|---|---|---|
| **កាលបរិច្ឆេទ** (៥លើក)[400] | **មូលហេតុ** (សំខាន់ៗ) | **ចំនួនកងទ័ព** (នាក់) |
| កក្កដា/១៩៨២ | – ការទាមទាររបស់សហគមន៍អន្តរជាតិ | មិនមានតួលេខឡើយព្រោះការដកទ័ពនេះគឺគ្រាន់តែផ្លាស់ប្តូរទ័ពធម្មតាដោយមិនមានការស្រុតចំនួនបន្តិចឡើយ |
| ១/ឧសភា/១៩៨៣ | – បង្ហាញឱ្យឃើញពីការរីកចម្រើនរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា<br>– បង្ហាញឱ្យឃើញពីកិច្ចសហប្រតិបត្តិការដ៏ស្មោះត្រង់របស់វៀតណាមជាមួយកម្ពុជា និងការឆ្លើយតបនឹងការមួលបង្កាច់របស់ប៉េកាំង និងវ៉ាស៊ីនតោន<br>– បង្ហាញឱ្យឃើញនូវសុឆន្ទៈរបស់កម្ពុជា និងវៀតណាមចំពោះអាជ្ញាធរ ថៃ ក៏ដូចជាប្រទេសជិតខាងខ្លួន។ | |

---

[399] ទី សុផល, *សហគមន៍អន្តរជាតិ និងដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៩១*, ដ.ឯ.ម.។

[400] តាមព័ត៌មានក្នុងសៀវភៅ: កែវ បាគ្នំ, *សម្តេចតេជោ ហ៊ុន សែន អ្នកគូសវាសជោគវាសនាកម្ពុជា*, ឆ្នាំ២០២២ បង្ហាញឱ្យឃើញថាការដកទ័ពវៀតណាមចេញពីប្រទេសកម្ពុជាមាន«លើសពី៥លើក»។ ក្នុងទំព័រទី៣២១ក្នុងសៀវភៅនេះរៀបរាប់ថា«នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៨៨ ក្រសួងការពារប្រទេសនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចេញសេចក្តីប្រកាសស្តីពីការដកកងទ័ពស្ម័គ្រចិត្តវៀតណាមលើកទី៧ចំនួន៥០ ០០០នាក់ចេញពីកម្ពុជាក្នុងឆ្នាំ១៩៨៨។

| | | |
|---|---|---|
| មិថុនា/១៩៨៤ | – ការទាមទាររបស់សហគមន៍អន្តរជាតិ | |
| មិថុនា-ធ្នូ/១៩៨៨ | – ការទាមទាររបស់សហគមន៍អន្តរជាតិ និងបង្ហាញពីភាពរឹងមាំរបស់កម្ពុជា | ៥០ ០០០នាក់ |
| ២១-២៦/កញ្ញា/១៩៨៩ | – ការទាមទារនៅ JIM1 និងJIM2<br>– បង្ហាញអំពីការរីកចម្រើនរបស់កងកម្លាំងប្រដាប់អាវុធបដិវត្តន៍កម្ពុជា ដែលអាចធានាប់រងបាននូវរាល់ភារកិច្ចការពារប្រទេសដោយខ្លួនឯង។<br>– គំរូពីសហភាពសូវៀត និងការបង្កើតឱ្យមានភាពធូរស្រាលផ្នែកនយោបាយរបស់វៀតណាម | ២៦ ០០០នាក់ |

ឃើញថាចាប់ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩១ ដៃគូចរចាសន្តិភាពរបស់កម្ពុជាគឺសម្តេចព្រះ នរោត្តម សីហនុ និងឯកឧត្តម ហ៊ុន សែន ចាប់ផ្តើមសកម្មភាពដើម្បីសន្តិភាពនៅកម្ពុជា។ នៅខែមិថុនា ឆ្នាំ១៩៨៧ លោក Javier Pérez de Cuéllarអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ បានដាក់ចេញនូវផែនការសម្របសម្រួលមួយដែលអំពាវនាវឱ្យមានការដកកងទ័ពវៀតណាមជាជំហានៗ, ការបង្រួបបង្រួមជាតិខ្មែរឈានទៅរកការបង្កើតរដ្ឋាភិបាលចម្រុះថ្មីដែលមានសម្តេចព្រះនរោត្តម សីហនុ ជាប្រមុខ, ការដកទ័ពវៀតណាមទាំងអស់, ការបោះឆ្នោតដោយសេរី និង«ខពិសេស» សម្រាប់ដោះស្រាយបញ្ហាភាគីខ្មែរប្រដាប់អាវុធ។ ក្នុងដំណាក់កាលវាយផង ចរចាផង មានន័យថាភាគីទាំងពីរនេះបន្តតទល់គ្នានៅលើដែនសមរភូមិសឹក ក៏ប៉ុន្តែមេដឹកនាំនៃក្រុមទាំងពីរនេះនៅតែរកផ្លូវជួបគ្នា ដើម្បីចរចាបញ្ចប់ជម្លោះកម្ពុជា។ ការស្នើជួបគ្នារវាងសម្តេចព្រះនរោត្តម សីហនុ និងឯកឧត្តម ហ៊ុន សែន ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីនៃរដ្ឋកម្ពុជាដែលបានកើតឡើងជាលើកទី១ នាថ្ងៃទី២ ដល់ថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៨៧ នៅហ្វែរអង់តាជឺន័រ ប្រទេសបារាំងមានសេចក្តីរាយការណ៍រួមមាន៤ចំណុច[401]៖

១-ការវិវាទនៅក្នុងប្រទេសកម្ពុជា គឺចាំបាច់ត្រូវតែឈានទៅរកដំណោះស្រាយនយោបាយមួយ។

២-បញ្ហាកម្ពុជាចាំបាច់ ត្រូវតែដោះស្រាយដោយប្រជាជនខ្មែរខ្លួនឯង តាមរយៈការចរចារវាងភាគីដែលកំពុងវិវាទគ្នា សំដៅបញ្ចប់សង្គ្រាមបង្ហូរឈាមគ្នា ដើម្បីកសាងកម្ពុជាជាមួយសន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យ អព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ។

៣-ចាប់ពីពេលមានកិច្ចព្រមព្រៀងមួយ ដែលនឹងត្រូវសម្រេចរវាងភាគីកម្ពុជានានានោះ សន្និសីទអន្តរជាតិមួយនឹងត្រូវកោះប្រជុំឡើងដើម្បីធានាកិច្ចព្រមព្រៀងនោះ ធានាឯករាជ្យភាពរបស់ប្រជាជនខ្មែរ សន្តិភាព និងស្ថិរភាពនៅអាស៊ីអាគ្នេយ៍។

៤-ភាគីទាំងពីរទទួលយកការជួបគ្នាថ្មីម្តងទៀតនៅអំឡុងខែមករា ឆ្នាំ១៩៨៩ នៅហ្វែរអង់តាជឺន័រ ប្រទេសបារាំង។

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៨៧ ឯកឧត្តម ហ៊ុន សែន បានវិលត្រឡប់មកពីប្រទេសបារាំងវិញ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស បានចេញសារលិខិតជូនជនរួមជាតិមានខ្លឹមសារជាអាទិ៍ថា៖

– នេះជាការជួបលើកដំបូង មានចរិតជាប្រវត្តិសាស្ត្រ

[401] ទស្សនាវដ្តីកម្ពុជា *លេខ២២៤ ចុះខែសីហា ឆ្នាំ១៩៨៩* ទំព័រ២។

- សេចក្តីប្រកាសរួមមួយ(មានជាភាសាបារាំងហើយ នៅតែភាសាខ្មែរ)
- បញ្ហាកម្ពុជាត្រូវដោះស្រាយតាមផ្លូវនយោបាយដោយខ្លួនឯង
- ត្រូវមានសន្និសីទអន្តរជាតិមួយ
- ត្រូវដោះស្រាយបញ្ហាជនភៀសខ្លួននៅថៃ
- សេចក្តីប្រកាសរួមហ៊ុន សែន-សីហនុ ជាការអំពាវនាវឱ្យភាគីខ្មែរបដិបក្ខពីរទៀតចូលកាន់តុចរចាផងដែរ

បន្ទាប់ពីជំនួបជាមួយសម្តេចព្រះនរោត្តម សីហនុ ឯកឧត្តម ហ៊ុន សែន បានផ្ញើសារលិខិតមួយជូនទៅប្រជាជាតិនៅថ្ងៃ១៨ ខែធ្នូ ឆ្នាំ១៩៨៧ បានបញ្ជាក់ច្បាស់អំពីគោលនយោបាយរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា«បដិវត្តន៍យើងបានចាប់ផ្តើមផ្ទេរមកដំណាក់កាលវាយផង និងចរចាផង»។ ឧបសគ្គក្នុងការដោះស្រាយបញ្ហាកម្ពុជាគឺចិន និងខ្មែរក្រហម ពិតមែនតែគេមិនមែនជាកូនសោរតែមួយគត់ក្នុងការដោះស្រាយបញ្ហាកម្ពុជាប៉ុន្តែ គេនៅតែមានលទ្ធភាពជាឧបសគ្គសម្រាប់កិច្ចដំណើរការរកសន្តិភាពឱ្យកម្ពុជា។ ក្រៅពីខ្មែរក្រហមមិនចូលរួមចរចាអស់ចំនួន២លើក ចិនក៏មានលទ្ធភាពដាក់គំនាបសង្កត់ទៅលើឯកឧត្តម ហ៊ុន សែន និងឯកឧត្តម សឺន សាន តាមរយៈការគំរាមកំហែងកាត់ជំនួយ ដើម្បីកម្រិតសកម្មភាពក្រុមទាំងពីរក្នុងរង្វង់ត្រួតត្រារបស់ចិន។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយឃើញថាចាប់ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩១ ដៃគូចរចាសន្តិភាពរបស់កម្ពុជាគឺសម្តេចព្រះនរោត្តម សីហនុ និងឯកឧត្តម ហ៊ុន សែន នៅតែបានបន្តចាប់ផ្តើមសកម្មភាពដើម្បីសន្តិភាពនៅកម្ពុជា។ លើសពីនេះទៅទៀត ចាប់ពីឆ្នាំ១៩៨៥មក ក៏មានការចូលរួមពីសហគមន៍អន្តរជាតិ, អង្គការសហប្រជាជាតិ និងប្រទេសជាច្រើនទៀត ដែលមានដំណើរពីក្រោយ ឬ ស្របគ្នាជាមួយការចេញមុខរបស់ថ្នាក់ដឹកនាំកម្ពុជា ដែលជាហេតុនាំប្រទេសកម្ពុជាឆ្ពោះទៅរកកិច្ចព្រមព្រៀងនាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩១ សម្តេចព្រះនរោត្តម សីហនុ និងឯកឧត្តមហ៊ុន សែនបានចេញប្រកាសរួមមួយក្នុងទិសដៅជំរុញនូវដំណោះស្រាយនៃបញ្ហាកម្ពុជានិងការបង្រួបបង្រួមជាតិ។ ខ្លឹមសារសំខាន់ៗមួយចំនួនបង្ហាញថាឯកឧត្តម ហ៊ុន សែន បានព្រមព្រៀងប្រគល់ថ្វាយសម្តេចព្រះ នរោត្តម សីហនុ ធ្វើជាប្រធាននៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់(អេស អ៊ិន ស៊ី : SNC)។ ដោយមិនចាំបាច់មានអនុប្រធាន និងដោយរក្សាចំនួនសមាសភាពក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ត្រឹម១២រូបដដែល។ ដើម្បីអនុវត្តបានពេញលេញនូវតួនាទីនេះសម្តេចព្រះនរោត្តម សីហនុ ត្រូវឈប់ពីមុខតំណែងជាប្រធានចលនាតស៊ូកម្ពុជា និងប្រធាននៃរដ្ឋាភិបាលជាតិកម្ពុជា ហើយទ្រង់ត្រូវនៅអព្យាក្រឹត។ សម្តេចព្រះនរោត្តម សីហនុ និងឯកឧត្តមហ៊ុន សែនចាត់ទុកថា នេះជាដំណោះស្រាយដ៏ល្អបំផុតដើម្បីបញ្ចប់នូវអរិភាពរវាងភាគីកម្ពុជាទាំងឡាយ ដែលមានជម្លោះជាមួយគ្នាតាមរយៈតួនាទីអព្យាក្រឹត និងសម្របសម្រួលរបស់សម្តេចព្រះនរោត្តម សីហនុ។ ក្នុងន័យនេះសម្តេច និងឯកឧត្តម ហ៊ុន សែន អំពាវនាវចំពោះសមាជិកដទៃទៀតនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ឱ្យគាំទ្រនូវការព្រមព្រៀងនេះ។

## សរុបសេចក្តី

ដោយឆ្លងតាមរយៈការស្រាវជ្រាវបានបង្ហាញថា ដំណោះស្រាយអាចសម្រេចទៅបានលុះថាតែប្រជាជនខ្មែរគឺជាអ្នកដោះស្រាយដោយខ្លួនឯង។ ដូច្នេះ ជំនួបថ្ងៃទី២ ដល់ទី៤ ខែធ្នូ ឆ្នាំ១៩៨៧ គឺជាជំនួបលើកដំបូងមានចារិតជាប្រវត្តិសាស្ត្រមុនពេលឈានដល់កិច្ចព្រមព្រៀងថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ សម្រាប់សន្ធិសញ្ញាសន្តិភាពនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ កើតឡើងបានដោយសារកត្តាសំខាន់ចំនួន៦៖

- សហភាពសូវៀតលែងគាំទ្រវៀតណាមនិងវៀតណាមដកទ័ពចេញជាលើកចុងក្រោយនាឆ្នាំ១៩៨៩។
- សាធារណរដ្ឋប្រជានិតកម្ពុជារឹងមាំ អាចកែតម្រូវនយោបាយថ្មី និងតម្រង់ទៅរកកំណែទម្រង់ដែលអាចឆ្លើយតបទៅនឹងជំនួយពីគ្រប់មជ្ឈដ្ឋានដោយប្រសិទ្ធិភាព, តម្លាភាព, សមធម៌, ប្រជាធិបតេយ្យ, យុត្តិធម៌, សិទ្ធិមនុស្សក្រោមឆត្រសន្តិភាព។ នៅឆ្នាំ១៩៨៩ ប្រធានក្រុមប្រឹក្សារដ្ឋបានចុះហត្ថលេខាលើក្រឹត្យលេខ២៩ក្រ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញកែប្រែ«រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា»។
- ការប្តេជ្ញាតម្កល់ផលប្រយោជន៍សន្តិភាពជាតិជាចម្បង និងការចេះបត់បែន របស់សម្តេចព្រះនរោត្តម សីហនុ និងឯកឧត្តម ហ៊ុន សែន តាមសភាពការណ៍ និងបរិការណ៍អន្តរជាតិ។
- ការចូលរួមធ្វើអន្តរាគមន៍ និងបណ្តាអង្គការ និងស្ថាប័នជាតិ-អន្តរជាតិ រួមទាំងសម្ព័ន្ធមិត្តអន្តរជាតិ។
- ការសម្រេចចិត្តរបស់សម្តេចព្រះ នរោត្តម សីហនុ, ឯកឧត្តម ហ៊ុន សែន និងប្រទេសវៀតណាម ឈរលើប្រយោជន៍ជាតិ, តំបន់, ពិភពលោក និងផ្ទាល់ខ្លួន។
- ការបន្ធូរឥរិយាបថរបស់សហរដ្ឋអាមេរិក, សហភាពសូវៀត និងចិន។

តួនាទីសហគមន៍អន្តរជាតិ និងបណ្តាភាគីខ្មែរក្នុងដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាបាននាំឱ្យកម្ពុជាទទួលបាននូវកិច្ចព្រមព្រៀងបញ្ចប់ជម្លោះ នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលមានតម្លៃជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ នាសហសម័យមួយដែលកូនខ្មែរ, អ្នកសិក្សាស្រាវជ្រាវ និងអ្នកនយោបាយ ត្រូវតែចងចាំដោយសារនេះជាថ្ងៃ«បើកផ្លូវសន្តិភាពប្រជាធិបតេយ្យ និងការបង្រួបបង្រួម» មានការទទួលស្គាល់ជាអន្តរជាតិ។ ថ្ងៃជាប្រវត្តិសាស្ត្រនេះបាននាំមកឱ្យកម្ពុជានូវបូរណភាពទឹកដីអធិបតេយ្យភាព, សន្តិភាព និងមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជាបន្ទាប់ពីបានបាត់បង់អស់រយៈពេលជិត៣០ឆ្នាំ។ ចំពោះកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១ ជាដំណោះស្រាយដ៏ប្រសើរចំពោះជម្លោះប្រដាប់អាវុធនៅកម្ពុជាដោយមានអន្តរាគមន៍ពីអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩១ ដល់១៩៩៣។ ទោះជាយ៉ាងនេះក្តី ក៏សន្តិភាពទាំងស្រុងនៅកម្ពុជាបានមកពីនយោបាយឈ្នះ ឈ្នះ ចាប់ពីឆ្នាំ១៩៩៦-១៩៩៨ របស់សម្តេចតេជោ ហ៊ុន សែន។

### ៤-សំណួរត្រិះរិះ

១- កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ត្រូវបានភាគីខ្មែរទាំងបួន និងប្រទេសមួយចំនួនចុះហត្ថលេខានាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ចូររៀបរាប់ អធិប្បាយ និងវិភាគអំពី៖

- អំពីការវិវត្តនយោបាយក្នុង និងក្រៅប្រទេសដែលនាំឱ្យឈានឆ្ពោះទៅរកកិច្ចព្រមព្រៀងនេះ
- ទិដ្ឋិភាព និងខ្លឹមសារនៃកិច្ចព្រមព្រៀង
- ការអនុវត្តកិច្ចព្រមព្រៀង និងលទ្ធផលផ្តល់ចំពោះកម្ពុជា។

២-ចូរអធិប្បាយពីដំណើរប្រព្រឹត្តទៅនៃសង្គ្រាមនីមួយៗ គូប្រយុទ្ធ សំខាន់ៗនៅក្នុងសង្គ្រាមនីមួយៗ និងផលប៉ះពាល់នៃសង្គ្រាមនីមួយៗនោះមកលើកម្ពុជា នៃសង្គ្រាមឥណ្ឌូចិនទាំងបីលើក។

# មេរៀនទី១៤ ព្រះរាជាណាចក្រកម្ពុជាទី២[402]

## ១-វត្តមានរបស់អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា(អ៊ុនតាក់)

សន្ធិសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ បានទុករយៈពេល២ឆ្នាំឱ្យប្រទេសកម្ពុជារៀបចំការបោះឆ្នោត ដើម្បីដឹកនាំមាតុភូមិកម្ពុជាដោយខ្លួនឯង ក្រោមការត្រួតពិនិត្យពីអន្តរជាតិ។ សម្រាប់កិច្ចព្រៀមព្រៀងសន្តិភាព ក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ តម្រូវឱ្យអង្គការសហប្រជាជាតិទទួលខុសត្រូវលើការរៀបចំ និង គ្រប់គ្រងការបោះឆ្នោតមួយដែលមានលក្ខណៈសេរី និងយុត្តិធម៌ ដើម្បីបង្កើតរដ្ឋាភិបាលថ្មី។

តាមរយៈកិច្ចព្រមព្រៀងក្រុងប៉ារីស កម្ពុជាត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធបណ្តោះអាសន្ន របស់អង្គការសហប្រជាជាតិ។ អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា គឺជាប្រតិបត្តិការថែរក្សាសន្តិភាព របស់សហប្រជាជាតិ នៅកម្ពុជាក្នុងឆ្នាំ១៩៩២ ដល់១៩៩៣ ដែលបានបង្កើតឡើងនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ១៩៩២។ រហូតមកដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩២ តំណាងពិសេសរបស់អគ្គលេខាធិការដ្ឋាន និង មេបញ្ជាការកងកម្លាំងអ៊ុនតាក់បានមកដល់ប្រទេសកម្ពុជា។ នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ក្រុមប្រឹក្សា សន្តិសុខអង្គការសហប្រជាតិ បានយល់ព្រមឱ្យអ៊ុនតាក់ត្រួតត្រាទៅលើក្រសួងមួយចំនួនទៀតដូចជាក្រសួង អប់រំ, កសិកម្ម, នេសាទ, ដឹកជញ្ជូន ថាមពល, ទេសចរណ៍, ធនធានរ៉ែ និងរដ្ឋបាលកិច្ចការទូទៅ។ លើសពីនេះ ទៅទៀត ក៏មានប្រទេសចំនួន៤៥ នៅក្នុងពិភពលោកដែលបានជាប់ទាក់ទងក្នុងរឿងដំណោះស្រាយរកសន្តិភាព ជូនកម្ពុជាបានបញ្ជូនកងទ័ព និងរដ្ឋការបច្ចេកទេសស៊ីវិលមកកម្ពុជាដើម្បីរៀបចំការបោះឆ្នោតដែលប្រព្រឹត្តទៅ នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣។ អាជ្ញាធរនេះមានថវិកាជិត៣០០០លានដុល្លារ ដើម្បីបំពេញបេសកម្ម៤ យ៉ាង៖

១-ដកអាវុធពីកងទ័ពដែលនៅប្រឈមមុខគ្នាគឺពីទ័ពរបស់រដ្ឋកម្ពុជា និងភាគីខ្មែរក្រហម, រណសិរ្សរំដោះ ប្រជាពលរដ្ឋខ្មែរ(FNLPK) និងកងទ័ពរាជានិយមរបស់សម្តេចព្រះ នរោត្តម សីហនុ(ANS)។

២-បញ្ចូលរដ្ឋអំណាចទាំងសងខាងឱ្យរួមគ្នារដ្ឋកម្ពុជា និងរដ្ឋាភិបាលត្រីភាគី។

៣-រៀបចំការបោះឆ្នោតដោយសេរី ។

៤-នាំជនភៀសខ្លួនប្រហែល៣៥០ ០០០នាក់ ធ្វើមាតុភូមិនិវត្តន៍វិញ ។

នៅក្នុងកិច្ចព្រមព្រៀង គឺអ៊ុនតាក់មានសិទ្ធិអំណាចយ៉ាងធំក្នុងការដោះស្រាយវិបត្តិឱ្យជ្រះស្រឡះ និងរក សន្តិភាពជូនកម្ពុជា ជាពិសេសគឺការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ ប្រសិនបើកម្ពុជាបានបោះឆ្នោតជា សកលហើយ នោះបញ្ហាជំនុំជម្រះជាអន្តរជាតិត្រូវបានបញ្ចប់។ ប៉ុន្តែ ជិតដល់ពេលបោះឆ្នោត កងកម្លាំងយោធា របស់អ៊ុនតាក់បានផ្លាស់ប្តូរទិសដៅភារកិច្ចរបស់ខ្លួនមកអនុវត្តកិច្ចការពារសុន្តិសុខ និងជួយសម្រួលការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ទៅវិញ។ ដើម្បីអនុវត្តនូវសិទ្ធិអំណាចទាំងអស់នេះ អ៊ុនតាក់ ក៏បានបណ្តុះបណ្តាលមន្ត្រី ការិយាល័យបោះឆ្នោតអន្តរជាតិចំនួន៩០០នាក់ មកពីប្រទេសចំនួន៤៤ រួមជាមួយសហអន្តរសេភាមកពី លេខាធិការដ្ឋានអ៊ុនតាក់ចំនួន១៣០នាក់មកពីអ៊ុនតាក់ចំនួន៣៧០នាក់ព្រមទាំងជ្រើសរើស និងបណ្តុះបណ្តាល បុគ្គលិកបោះឆ្នោតជនជាតិខ្មែរចំនួន៥០ ០០០នាក់ផងដែរ។

[402] ទី សុផល, ប្រវត្តិវិទ្យា, ដ.ឯ.ម., ទំព័រ៦៥៤-៦៦៨។

## ២-មាតុភូមិនិវត្តន៍

តាមស្ថិតិដែលរ.ជ.រ.ប.ខ. ផ្តល់ឱ្យជនភៀសខ្លួនស៊ីវិលដែលត្រូវធ្វើមាតុភូមិនិវត្តន៍មានចំនួនសរុប១៩០ ២៧៧នាក់ ដែលរួមមាន៥១ ៥៤០នាក់ នៅជំរំអំពិល, ២៩ ៥៣៨នាក់ នៅជំរំណងខាន់, ២៥ ១០២នាក់ នៅជំរំដងរែក, ១៦ ១៩៦នាក់ នៅជំរំសម្លូ, ៧៩ ៦៦៥នាក់ នៅជំរំវីទ្វីសែន, ៨ ២៦៨នាក់ នៅជំរំសុខសាន្ត។ នៅខែឧសភា ឆ្នាំ១៩៩២ រដ្ឋបានចេញប្រកាសផ្តល់ជូនចំពោះមាតុភូមិនិវត្តន៍ជននូវជម្រើសកសិកម្ម, ផ្ទះសម្បែង, ប្រាក់កាស, ដីធ្លី និងកន្លែងស្នាក់នៅ។ នៅកន្លែងមួយចំនួនត្រូវបានរដ្ឋអំណាចកាប់ឆ្ការព្រៃ និងដោះមីន ជូនប្រជាពលរដ្ឋផងដែរ។ ឃើញថាចាប់ពីខែតុលា ឆ្នាំ១៩៩២ ដល់ខែមេសា ឆ្នាំ១៩៩៣ អ៊ុនតាក់ត្រូវធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួនចំនួនជាង៣៥ម៉ឺននាក់ ពីជំរំភៀសខ្លួនចូលមកកម្ពុជាវិញ។

## ៣-ការបោះឆ្នោតឆ្នាំ១៩៩៣

យោងតាមកិច្ចព្រៀមព្រៀងក្រុងប៉ារីស ដែលតម្រូវឱ្យអង្គការសហប្រជាជាតិទទួលខុសត្រូវលើការរៀបចំ និងដឹកនាំការបោះឆ្នោតមួយ ដែលមានលក្ខណៈសេរី និងយុត្តិធម៌គឺក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ បានសម្រេចយកថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ ជាកាលបរិច្ឆេទនៃការបោះឆ្នោត ដែលប្រព្រឹត្តទៅតាមប្រព័ន្ធសមាមាត្រ។ គណបក្សនយោបាយចំនួន២០ បានចូលរួមប្រកួតប្រជែងយកសំឡេងពីប្រជារាស្ត្រចំនួន៤លាននាក់ ដែលបានចុះឈ្មោះបោះឆ្នោតនៅកម្ពុជា។ បេក្ខជនទាំងអស់មានចំនួនសរុប ៣២៦៨នាក់ ក្នុងនោះ២៤០នាក់ មកពីគណបក្សប្រជាជន២៤០នាក់ មកពីគណបក្សហ៊្វុនស៊ិនប៉ិច និង ២៣៨នាក់ មកពីគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា។

| គណបក្សដែលចូលរួមប្រកួតប្រជែង | | |
|---|---|---|
| **ល.រ** | **គណបក្ស** | **តំណាងគណបក្ស** |
| ១ | ប្រជាជនកម្ពុជា | លោក សុខអាន |
| ២ | សម្ព័ន្ធសាធារណរដ្ឋ | លោក ចេង ហេង |
| ៣ | ខ្មែរអព្យាក្រឹត | លោក ងិន ទុន |
| ៤ | សាមគ្គីធម៌ប្រជាជាតិ | លោក ទេព លឹមផន |
| ៥ | កម្ពុជាអព្យាក្រឹតប្រជាធិបតេយ្យ | លោក គិត ពង្ស |
| ៦ | ប្រជាធិបតេយ្យ | លោក អ៊ិន តាំ |
| ៧ | កម្ពុជាសេរី ឯករាជ្យ ប្រជាធិបតេយ្យ | លោក ឡុង ប៉ូរ៉ា |
| ៨ | ប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា | លោក សឺន ស៊ូប៊ែរ |
| ៩ | ហ៊្វុនស៊ិនប៉ិច | ទ្រង់នរោត្តម រណឫទ្ធិ |
| ១០ | សភាជាតិខ្មែរ | លោក កុលផេង |
| ១១ | សាធារណរដ្ឋសេរីនិយម | លោក ប៊ិត ស៊ាងលឹម |
| ១២ | កម្ពុជារស់ឡើងវិញ | លោក អ៊ី ផានដារា |
| ១៣ | សេរីបង្រួបបង្រួមជាតិ | លោក សំរិត រ៉េត |
| ១៤ | សាធារណរដ្ឋអភិវឌ្ឍន៍សេរី | លោក តឹក ង៉ុយ |
| ១៥ | សាធារណរដ្ឋប្រជាធិបតេយ្យខ្មែរ | លោក គឹម កិត្តាវី |

| | | |
|---|---|---|
| ១៦ | ប្រជាធិបតេយ្យសេរី | លោក សាក់ ស៊ុតសាខន |
| ១៧ | ម៉ូលីណាកា និងអ្នកតស៊ូខ្មែរដើម្បីសេរីភាព | លោក ព្រហ្ម នាគរាជ |
| ១៨ | កសិករប្រជាធិបតេយ្យសេរី | លោក គឹម និដ្ឋា |
| ១៩ | ខ្មែរអ្នកជាតិនិយម | លោក ឃឹម ភួងវិហាន |
| ២០ | ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ | លោក ចក់ សារឿន |

គណបក្សសាមគ្គីខ្មែរក្រហមដែលជាគណបក្សរបស់លោក ខៀវ សំផន មិនត្រូវបានឈរឈ្មោះឱ្យគេបោះឆ្នោតឡើយ។ ភាគីខ្មែរក្រហមពេលនោះ បានចោទកងរក្សាអ៊ុនតាក់ថាមានភាពលម្អៀងដោយមិនឱ្យភាគីខ្មែរក្រហម មានឋានៈស្មើនឹងភាគីខ្មែរចរចាឯទៀតៗនោះឡើយ។ ខ្មែរក្រហមដកខ្លួនពីការបោះឆ្នោតពេលនោះ ដោយពួកគេគិតថាមានកម្លាំងឃុនបង្កប់៥លាននាក់ ដើម្បីជួយស្តារស្ថានការណ៍បោះឆ្នោត។ ប៉ុន្តែនេះគ្រាន់តែជាលេសប៉ុណ្ណោះ ព្រោះក្រុមខ្មែរក្រហមខ្លួនឯងដឹងច្បាស់ណាស់ថាខ្លួនប្រាកដជាមិនអាចទទួលជ័យជម្នះ។ ខ្មែរក្រហមបានប្រឆាំងចំពោះការរៀបចំរបស់អ៊ុនតាក់ តែក្នុងករណីនេះអ៊ុនតាក់បានឆ្លើយតបតាមរយៈការទូតជំនួសឱ្យតាមកងទ័ព ហើយអ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ(UNVs) បានចុះឈ្មោះអ្នកដែលមានសិទ្ធិបោះឆ្នោតចំនួន៤ ៧៦៤ ៤៣០នាក់។ តាមសេចក្តីរាយការណ៍របស់អ្នកនាំពាក្យអ៊ុនតាក់ បានឱ្យដឹងថាគណបក្សនយោបាយទាំងអស់បានរៀបចំការឃោសនាក្នុងអង្គមីទ្ទីញ និងការជួបជុំមហាជនចំនួន១ ៥២៩ លើក ដែលមានប្រជារាស្ត្រចូលរួមចំនួន៨០០ ០០០នាក់។ លទ្ធផលប្រកាសផ្សាយនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ ១៩៩៣ បានឱ្យដឹងពីលទ្ធផលសរុបមានដូចតទៅ៖

| **ល.រ** | **សន្លឹកឆ្នោត** | **ចំនួនសន្លឹកឆ្នោត** |
|---|---|---|
| ១ | ចំនួនសន្លឹកឆ្នោតបានការធម្មតា | ៣ ៧៦៧ ៤១២ |
| ២ | ចំនួនសន្លឹកឆ្នោតបានការបន្ទាប់ពីតវ៉ារួច | ២៤៤ ២១៩ |
| ៣ | ចំនួនសន្លឹកឆ្នោតបានការសរុប | ៤ ០១១ ៦៣១ |
| ៤ | ចំនួនសន្លឹកឆ្នោតមិនបានការធម្មតា | ១១២ ៧៦១ |
| ៥ | ចំនួនសន្លឹកឆ្នោតត្រូវបដិសេធបន្ទាប់ពីតវ៉ារួច | ១៣៦ ៨១៦ |
| ៦ | ចំនួនសន្លឹកឆ្នោតមិនបានការបន្ទាប់ពីតវ៉ារួច | ៥ ៩៨៤ |
| ៧ | ចំនួនសន្លឹកឆ្នោតសរុបដែលបានបោះ | ៤ ២៦៧ ១៩២ |
| ៨ | ភាគរយនៃអ្នកចុះឈ្មោះបោះឆ្នោតទាំងអស់ | ៨៩.៥៦% |

| លទ្ធផលបោះឆ្នោតរបស់គណបក្សទាំង២០ | | | | |
|---|---|---|---|---|
| **ល.រ** | **គណបក្សនយោបាយ** | **សន្លឹកឆ្នោត** | **ភាគរយ** | **អាសនៈ** |
| ១ | ប្រជាជន | ១ ៥៣៣ ៤៧១ | ៣៨.២៨ | ៥១ |
| ២ | ប្រជាធិបតេយ្យសេរីនិយម ព្រះពុទ្ធសាសនា | ១៥២ ៧៦៤ | ៣.៨១ | ១០ |
| ៣ | ហ៊្វុនស៊ិនប៉ិច | ១ ៨២៤ ១៨៨ | ៤៥.៤៧ | ៥៨ |
| ៤ | ម៉ូលីណាកា និងអ្នកតស៊ូខ្មែរ ដើម្បីសេរីភាព | ៥៥ ១០៧ | ១.៣៧ | ០១ |
| ៤ | គណបក្ស ១៦ផ្សេងទៀត | ៤៤៦ ១០១ | ១១.១២ | ០ |
| **សរុប** | **២០គណបក្ស** | **៤ ០១១ ៦៣១** | **១០០%** | **១២០** |

តាមតួលេខខាងលើនេះ គណបក្សប្រជាធិបតេយ្យនិយមព្រះពុទ្ធសាសនា បានចំណេញអត្រាអាសនៈច្រើនជាងគេ។ ចំពោះការបែងចែកអាសនៈនៅតាមខេត្ត ក្រុងធ្វើតាមចំនួនមធ្យមភាគធំដោយផ្អែកលើចំនួនអាសនៈក្នុងខេត្ត ក្រុង និងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្តក្រុង។ ចំនួនអាសនៈដែលគណបក្សចំនួន៤ឈ្នះមានសិទ្ធចូលអង្គុយក្នុងរដ្ឋសភាដែលមានកៅអីសរុប១២០កៅអី[403]៖

| **ល.រ** | **ខេត្ត/ក្រុង** | **អាសនៈ សរុប** | **ហ៊្វុនស៊ិនប៉ិច** | **បបដ** | **គបសព** | **ម៉ូលីណាកា** |
|---|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៦ | ៣ | ២ | ១ | ០ |
| ២ | បាត់ដំបង | ៨ | ៤ | ៣ | ១ | ០ |
| ៣ | ពោធិ៍សាត់ | ៤ | ២ | ២ | ០ | ០ |
| ៤ | កោះកុង | ១ | ០ | ០ | ១ | ០ |
| ៥ | កំពង់ស្ពឺ | ៦ | ២ | ៣ | ១ | ០ |
| ៦ | កំពង់ឆ្នាំង | ៤ | ២ | ២ | ០ | ០ |
| ៧ | ភ្នំពេញ | ១២ | ៧ | ៤ | ១ | ០ |
| ៨ | កណ្តាល | ១១ | ៧ | ៣ | ១ | ០ |
| ៩ | កំពត | ៦ | ៣ | ៣ | ០ | ០ |
| ១០ | ក្រុងព្រះសីហនុ | ១ | ១ | ០ | ០ | ០ |
| ១១ | តាកែវ | ៨ | ៤ | ៣ | ១ | ០ |
| ១២ | ព្រៃវែង | ១១ | ៤ | ៦ | ១ | ០ |
| ១៣ | ស្វាយរៀង | ៥ | ២ | ៣ | ០ | ០ |

403 សៅ ឆាត, *វិបត្តិកម្ពុជា*, ដ.ឯ.ម., ទំព័រទី២១៧ ។

| | | | | | | |
|---|---|---|---|---|---|---|
| ១៤ | កំពង់ចាម | ១៨ | ១០ | ៦ | ១ | ១ |
| ១៥ | ក្រចេះ | ៣ | ២ | ១ | ០ | ០ |
| ១៦ | មណ្ឌលគិរី | ១ | ០ | ១ | ០ | ០ |
| ១៧ | រតនគិរី | ១ | ០ | ១ | ០ | ០ |
| ១៨ | ស្ទឹងត្រែង | ១ | ០ | ១ | ០ | ០ |
| ១៩ | ព្រះវិហារ | ១ | ០ | ១ | ០ | ០ |
| ២០ | កំពង់ធំ | ៦ | ២ | ៣ | ១ | ០ |
| ២១ | សៀមរាប | ៦ | ៣ | ២ | ១ | ០ |
| **សរុប** | | **១២០** | **៥៨** | **៥១** | **១០** | **១** |

សរុបមក ការបោះឆ្នោតនាថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ មានគណបក្សចំនួន២០ចូលរួម។ ជាលទ្ធផល គណបក្សហ្វ៊ុនស៊ិនប៉ិច ទទួលបាន៥៨អាសនៈ, គណបក្សប្រជាជនកម្ពុជាទទួលបាន៥១អាសនៈ, គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាទទួលបាន១០អាសនៈ និងគណបក្សម៉ូលីណាកា និងអ្នកតស៊ូខ្មែរដើម្បីសេរីភាព ទទួលបានចំនួន១អាសនៈ ផងដែរ។

ក្រោយការប្រកាសលទ្ធផលការបោះឆ្នោត សភាធម្មនុញ្ញបានកើតឡើង ដើម្បីរៀបចំតាក់តែងរដ្ឋធម្មនុញ្ញថ្មី ដែលត្រូវបានអនុម័តនាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ខ្លឹមសាររដ្ឋធម្មនុញ្ញថ្មីនេះប្រទេសកម្ពុជាបានក្លាយជា«ព្រះរាជាណាចក្រកម្ពុជា ប្រកាន់លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និងអាស្រ័យរដ្ឋធម្មនុញ្ញ»។ ចំណែក សម្តេចព្រះនរោត្តម សីហនុ បានឡើងសោយរាជ្យជាលើកទី២។ ក្រោយការបោះឆ្នោត ការប្រកាសលទ្ធផលបានបញ្ចប់មែន ប៉ុន្តែ បញ្ហាវិបត្តិនយោបាយក្រោយការបោះឆ្នោតបាននាំឱ្យស្ថានភាពសង្គមជួបនូវការជាប់គាំងនយោបាយមួយរយៈពេលខ្លី។

ព្រះរាជកិច្ចដំបូងរបស់សម្តេចព្រះនរោត្តម សីហនុ គឺទ្រង់ឡាយព្រះរាជក្រឹត្យតែងតាំងសម្តេចក្រុមហ្លួងនរោត្តម រណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី១ និងឯកឧត្តមហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២នៃរាជរដ្ឋាភិបាលអាណត្តិទី១។ តាមព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ចែងថានាយករដ្ឋមន្ត្រីទាំងពីរមានសិទ្ធិអំណាច និងបុព្វសិទ្ធិស្មើៗ[404]។ រាជរដ្ឋាភិបាលចម្រុះនេះ យោងតាមលទ្ធផលនៃការបោះឆ្នោត និងស្មារតីផ្សះផ្សាជាតិ មានឧបនាយករដ្ឋមន្ត្រីចំនួន២រូបគឺព្រះអង្គម្ចាស់នរោត្តម សិរីវុឌ្ឍ មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច និងឯកឧត្តម ស ខេង មកពីគណបក្សប្រជាជនកម្ពុជា។ ក្នុងរាជរដ្ឋាភិបាលនេះមានក្រសួងចំនួនពីរ ដែលមានសហរដ្ឋមន្ត្រីនោះគឺក្រសួងការពារជាតិ(ឯកឧត្តម ទៀ បាញ់ និងឯកឧត្តម ទា ចំរ៉ាត់) និងក្រសួងមហាផ្ទៃ(ឯកឧត្តម ស ខេង និងឯកឧត្តម យូ ហុកគ្រី)[405]។ គណបក្សធំទាំងពីរបានបែងចែកអំណាចស្មើគ្នានៅក្នុងក្រសួង និងរដ្ឋលេខាធិការលើចំនួនក្រសួងទាំងអស់ចំនួន១៨[406]។ ពុំឃើញមានគណបក្សណាមួយ ដែលមានសម្លេង

---

[404] រាជកិច្ចឆ្នាំទី១ លេខ៣ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៩៣ ទំព័រ៥៥។

[405] រាជកិច្ចឆ្នាំទី១ លេខ៧ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ទំព័រ១៥៣។

[406] ក្រសួងទាំង១៨មានដូចជា ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ការពារជាតិ, មហាផ្ទៃ, សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ព័ត៌មាន, សាធារណការនិងដឹកជញ្ជូន, កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, យុត្តិធម៌, អប់រំយុវជន និងកីឡា, ពាណិជ្ជកម្ម, ឧស្សាហកម្ម រ៉ែ និងថាមពល, ផែនការ, សុខាភិបាល, ទេសចរណ៍, ធម្មការ និងសាសនា, ប្រៃសណីយ៍ និងទូរគមនាគមន៍, វប្បធម៌ និងវិចិត្រសិល្បៈ, សង្គមកិច្ច ការងារ និងអតីតយុទ្ធជន។

នៅក្នុងរដ្ឋសភាស្ថិតនៅក្នុងរាជរដ្ឋាភិបាល ហើយក្លាយជាបក្សប្រឆាំងនោះទេ។ ចំពោះផ្នែកអាជ្ញាធរដែនដីគឺគណបក្សធំទាំងពីរបានបែងចែកអំណាចគ្នាថ្នាក់អភិបាល និងអភិបាលរងខេត្តក្រុង។ ប៉ុន្តែ គណបក្សប្រជាជនកម្ពុជានៅរក្សាសឹងតែទាំងស្រុង មិនទាន់បែងចែកនូវតំណែងនៃអភិបាលស្រុក-ខណ្ឌចំនួន១៧២ និងមេឃុំចៅសង្កាត់ជាង១ ៥០០ឃុំ-សង្កាត់នៅក្នុងទូទាំងប្រទេសដែលជាកម្លាំងគ្រប់គ្រងផ្នែករដ្ឋបាល និងនយោបាយដ៏សំខាន់សម្រាប់ការបោះឆ្នោត។ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៩៣ លោក Akashi ជាប្រមុខអ៊ុនតាក់បានធ្វើពិធីជម្រាបលា និងចាកចេញដំណើរពីកម្ពុជា ដែលជានិមិត្តរូបនៃការបញ្ចប់ទាំងស្រុងនបេសកកម្មអង្គការសហប្រជាជាតិនៅកម្ពុជា ទុកឱ្យប្រជាជនខ្មែរជាអ្នកដោះស្រាយបញ្ហាខ្លួនដោយខ្លួនឯង។

រូបមន្តនៃការបង្កើតរដ្ឋាភិបាលមួយ ដែលមាននាយករដ្ឋមន្ត្រីពីរនិងគណបក្សធំៗទាំងពីរព្រមព្រៀងចែកអំណាចស្មើគ្នារវាងគណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា ពេលដំបូងនៃរាជរដ្ឋាភិបាលអាណត្តិទី១បានធ្វើឱ្យមន្ត្រី និងសមាជិកនៃគណបក្សធំៗទាំងពីរមានក្តីសប្បាយរីករាយនិងអបអរសាទរយ៉ាងក្លៀវក្លាបំផុត។ ដោយការយកចិត្តទុកដាក់ចំពោះប្រជារាស្ត្រ សម្តេចព្រះនរោត្តម សីហនុ ទ្រង់បានចេញព្រះរាជក្រឹត្យចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៩៣ បង្កើតនូវក្រុមអន្តរាគមន៍សង្គ្រោះប្រជាជនក្រីក្រ«ក្រុមសម្តេចឪ» ដែលមានឯកឧត្តម គង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីព្រះបរមរាជវាំងជាប្រធាន។ ក្រុមមួយនេះមានភារកិច្ចជួយឧបត្ថម្ភ និងសង្គ្រោះប្រជាជនជាបន្ទាន់ក្នុងករណីជួបការលំបាក និងគ្រោះធម្មជាតិ។ រាជរដ្ឋាភិបាលក៏មានភារកិច្ចសហការជាមួយក្រុមនេះផងដែរ។

ការបញ្ចប់ការបោះឆ្នោត អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិបានបញ្ចប់បេសកកម្មដោយជោគជ័យ។ ប៉ុន្តែ ជោគជ័យលើផ្នែកការបោះឆ្នោត សម្រាប់អសន្តិសុខសង្គមនៅតែបន្ត ហើយខ្មែរក្រហមនៅតែបន្តឥទ្ធិពលរបស់ខ្លួននៅព្រំដែនខ្មែរ-ថៃនៅឡើយ។ មិនត្រឹមតែពួកខ្មែរក្រហមបង្កភាពចលាចលជាមួយទង្វើរបស់ពួកគេនោះទេពាក្យសំដីរបស់ពួកគេមានឥទ្ធិពលបំផ្លាញផងដែរ។ លោក ខៀវ សំផន បានចេញសេចក្តីថ្លែងការណ៍នៅរដ្ឋធានី ដោយបន្ទោសការធ្លាក់ចុះនៃតម្លៃរូបិយវត្ថុទៅកេការចាកចេញចៀសមិនផុតរបស់អ៊ុនតាក់នៅចុងឆ្នាំ១៩៩៣ ដូចគ្នានឹងការហោះចេញរបស់ពួកអ្នកជំនួញបរទេសដែរ។

## ៤-ស្ថានភាពនយោបាយក្រោយឆ្នាំ១៩៩៣ និងនយោបាយឈ្នះ ឈ្នះ

ក្រោយឆ្នាំ១៩៩៣ កម្ពុជាបានរៀបចំរដ្ឋធម្មនុញ្ញថ្មីឈរលើមាគ៌ាប្រជាធិបតេយ្យ សេរីពហុបក្ស ប៉ុន្តែកម្ពុជានៅមិនទាន់មានសន្តិភាពពេញលេញនៅឡើយទេ។ ពួកខ្មែរក្រហម ដែលកាន់កាប់តំបន់មួយភាគធំតាមព្រំដែនកម្ពុជា-ថៃ ប៉ែកខាងជើង និងប៉ែកពាយព្យនៃប្រទេសកម្ពុជា មិនព្រមចូលរួមក្នុងការបោះឆ្នោត និងនៅតែបន្តគំរាមកំហែងសន្តិសុខជាតិ។ រាជរដ្ឋាភិបាលបានខិតខំចរចាជាមួយពួកខ្មែរក្រហម ដើម្បីឱ្យពួកគេចុះចូល តែនោះជាការឥតប្រយោជន៍។ ដូច្នេះ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៤ សភាជាតិ ក៏បានសម្រេចដាក់ពួកខ្មែរក្រហមឱ្យនៅក្រៅច្បាប់។ ចំណែកគណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា ក៏ចាប់ផ្តើមមានភាពរង្គោះរង្គើ ជាបណ្តើរៗផងដែរ។

ដើម្បីសន្តិសុខជាតិ និងការរួបរួមមួយដ៏ពិតប្រាកដនោះរាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តចរចាជាមួយពួកខ្មែរក្រហមតាមទម្រង់យុទ្ធសាស្ត្រឪហ្វីដ។នៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៩៦ អៀង សារី បានប្រកាសផ្តាច់ទំនាក់ទំនងជាមួយប៉ុល ពត និងចុះចូលជាមួយរាជរដ្ឋាភិបាល និងស្នើសុំលើកលែងទោសពីសំណាក់សម្តេចព្រះនរោត្តម សីហនុ។ នៅពាក់កណ្តាលឆ្នាំ១៩៩៧ គណបក្សហ្វ៊ុនស៊ិនប៉ិច បានបន្តចរចាជាមួយក្រុមខ្មែរក្រហមដែលដឹកនាំដោយ តា ម៉ុក និងខៀវ សំផន នៅអន្លង់វែង ។ ស្របពេលជាមួយគ្នានោះ ពួកខ្មែរក្រហមកំពុងតែ

បែកបាក់គ្នា។ ដោយលែងទុកចិត្តសហការីរបស់ខ្លួន ប៉ុល ពតបានឃាត់ខ្លួន ខៀវ សំផន និង សម្លាប់សុន សេន ព្រមទាំងក្រុមគ្រួសារ។ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៩៧ តា ម៉ុក ក៏បានចុះចូលជាមួយគណបក្សហ៊្វុនស៊ិនប៉ិច។ នៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ មានព្រឹត្តិការណ៍ផ្ទុះអាវុធប្រយុទ្ធគ្នារវាងកងកម្លាំងស្មោះត្រង់នឹង គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជននៅក្រុងភ្នំពេញ។ ជាលទ្ធផលនៅក្រុងភ្នំពេញ ត្រូវបានរៀបចំឱ្យមានសណ្តាប់ធ្នាប់ និងសន្តិសុខឡើងវិញ។ ចំណែកសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិបានចាកចេញទៅប្រទេសបារាំង ហើយមន្ត្រី និងនាយទាហានមួយចំនួនដែលស្មោះត្រង់នឹងទ្រង់បានភៀសខ្លួនទៅកាន់អូរស្មាច់ ដើម្បីបន្តការប្រយុទ្ធពីជាយដែនប្រឆាំងនឹងកងទ័ពរាជរដ្ឋាភិបាល។ ឯកឧត្តម អ៊ឹង ហួត ដែលមកពីគណបក្សហ៊្វុនស៊ិនប៉ិច ជាអ្នកឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីទី១ ជំនួសសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ដើម្បីបន្តការងារក្នុងរាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២ ដដែល។ ដើម្បីបង្រួបបង្រួមជាតិ ស្វែងរកសន្តិភាពពិតប្រាកដនៅកម្ពុជា សម្តេចនាយករដ្ឋមន្ត្រីទី២ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រមួយចំនួនដូចជាការចរចាធ្វើសមាហរណកម្ម យុទ្ធសាស្ត្រឌីហ្វីដ និងនយោបាយឈ្នះ ឈ្នះ។ គោលនយោបាយឈ្នះ ឈ្នះ ជាគោលនយោបាយ ឬ ជាយុទ្ធសាស្ត្រក្នុងការដោះស្រាយជម្លោះដោយការសម្របសម្រួលគ្នារវាងភាគីជម្លោះពីរ ឬ ច្រើនដើម្បីឈានទៅរកកិច្ចព្រមព្រៀង ដែលភាគីទាំងអស់ទទួលបានផលប្រយោជន៍ទាំងអស់គ្នា ឬ ឈ្នះទាំងអស់គ្នា។ យោងតាមការអនុម័តរបស់ក្រុមប្រឹក្សាភាសាជាតិនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ គោលនយោបាយឈ្នះ ឈ្នះ ជាទស្សនវិជ្ជាសន្តិភាព និងការប្តេជ្ញាចិត្តខាងនយោបាយរបស់សម្តេច ហ៊ុន សែន ដែលចាប់ផ្តើមនាខែកុម្ភៈ ឆ្នាំ១៩៩៦ និងទទួលជោគជ័យនាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ហើយជាថ្ងៃដែលលោក ខៀវ សំផន, លោក នួន ជា និងលោក អៀង សារី បានចូលជួបសម្តេច ហ៊ុន សែន នៅភូមិគ្រឹះសម្តេច ក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល។

## ៥-ផលលាភនៃសន្តិភាព និងការអភិវឌ្ឍ

នៅក្នុងការអភិវឌ្ឍប្រទេស រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យ, គោលដៅ, បេសកកម្ម និងផែនការច្បាស់លាស់។ យុទ្ធសាស្ត្រចំនួនពីរ ដែលរាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តគឺយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ។ ក្រោយការបោះឆ្នោតឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយុទ្ធសាស្ត្រត្រីកោណ ដែលមានទិសដៅជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។ នៅក្នុងឆ្នាំ២០០៤ សម្តេចតេជោហ៊ុន សែន បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។ ចំណុចស្នូលនៃយុទ្ធសាស្ត្រនេះគឺអភិបាលកិច្ចល្អ[407]។ បើគិតដល់ត្រឹមឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តលើយុទ្ធសាស្ត្រចតុកោណចំនួន៤ដំណាក់កាលគឺដំណាក់កាលទី១ពីឆ្នាំ២០០៤ ដល់២០០៨, ដំណាក់កាលទី២ពីឆ្នាំ២០០៨ ដល់២០១៣, ដំណាក់កាលទី៣ ពីឆ្នាំ២០១៣ ដល់២០១៨ និងដំណាក់កាលទី៤ ពីឆ្នាំ២០១៨ ដល់២០២៣[408]។ ការដឹកនាំប្រទេសដែលមានយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាលនេះរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដោយសម្តេចតេជោ ហ៊ុន សែន សម្រេចបានសមិទ្ធផលទាំងផ្នែកទន់, ផ្នែករឹង, ផ្នែកទឹកចិត្តចូលរួមអភិវឌ្ឍប្រទេសជាមួយរាជរដ្ឋាភិបាល និងភាពស្មើមុខលើឆាតអន្តរជាតិក្នុងនាមជាដៃគូអភិវឌ្ឍ,

[407] សូមមើលយុទ្ធសាស្ត្រចតុកោណ។

[408] ចំពោះរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែលមានសម្តេចបវរធិបតី ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាបានដាក់ចេញនូវ«យុទ្ធសាស្ត្របញ្ចកោណ» ក្នុងកម្មវិធីនយោបាយរបស់ខ្លួនសម្រាប់ការកសាង និងការពារមាតុភូមិឆ្នាំ២០២៣ ដល់២០២៨។ យុទ្ធសាស្ត្រនេះមានបាវចនាចំនួន៥គឺកំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព, និងចីរភាព។

ការថែរក្សាសន្តិភាពពិភពលោក និងជាម្ចាស់ផ្ទះក្នុងដឹកនាំ រៀបចំព្រឹត្តិការណ៍ និងកម្មវិធីថ្នាក់អន្តរជាតិធំៗជាច្រើនផងដែរ។

### ៦-ការកាត់ទោសខ្មែរក្រហមៈ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)

ដើម្បីឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍របស់របបកម្ពុជាប្រជាធិបតេយ្យ និងជាផ្នែកមួយនៃការចូលរួមយុទ្ធនាការជាសកល ក្នុងទប់ស្កាត់ការកើតឡើងវិញនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះកម្ពុជា, ផ្សព្វផ្សាយបួសផ្លូវចិត្ត និងការបញ្ចប់និទណ្ឌភាព រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានផ្តួចផ្តើមឱ្យមានតុលាការថ្មីមួយមានឈ្មោះថា «អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ឬ«សាលាក្តីខ្មែរក្រហម»។ តុលាការនេះបង្កើតឡើងដោយនៅឆ្នាំ២០០១ និងចាប់ផ្តើមសកម្មភាពការងារនៅឆ្នាំ២០០៧។

នៅក្នុងបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភដ៏ធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា, ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ តុលាការនេះ មានបេសកកម្មស្វែងរកយុត្តិធម៌ជូនប្រជាជនខ្មែរតាមរយៈការកាត់ទោសមេខ្មែរក្រហមថ្នាក់កំពូល និងអ្នកទទួលខុសត្រូវខ្ពស់បំផុតដែលនៅរស់រានមានជីវិត។ មេដឹកនាំទាំងនោះ ត្រូវទទួលទោសដោយសារតែពួកគាត់បានប្រព្រឹត្តនូវឧក្រិដ្ឋកម្មសង្គ្រាម, បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការប្រព្រឹត្ត ឬបញ្ជាឱ្យប្រព្រឹត្តអំពើបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ អំពីអំពើប្រឆាំងមនុស្ស ឬ ទ្រព្យសម្បត្តិ។ អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យ ទោសជនសង្ស័យទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការបំផ្លាញសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះ និងបទឧក្រិដ្ឋប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ។ ក្នុងនោះមានមេដឹកនាំខ្មែរក្រហមចំនួន៥រូបដែលត្រូវបាននាំខ្លួនមកកាត់ទោស។ អ្នកទាំង៥រូបនោះមានដូចជា នួន ជា, អៀង សារី, អៀង ធិរិទ្ធ, កាំង ហ្កេកអ៊ាវ និងខៀវ សំផន។

នៅទី២២ ខែកញ្ញា ឆ្នាំ២០២២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលកាត់ទោសឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យបានចេញសេចក្តីសម្រេចក្នុងសវនាការជំនុំជម្រះ ហើយក៏អង្គជំនុំជម្រះចុងក្រោយលើ ខៀវ សំផន។ សេចក្តីសម្រេចរបស់តុលាការបានបិទសំណុំរឿងលេខ០០២ទាំងស្រុង។ ក្រោយពីដំណើរការកាត់ក្តីអស់រយៈពេល១៦ឆ្នាំ ចាប់ពីពេលបើកការស៊ើបអង្កេតដំបូងរហូតដល់សកម្មភាពកាត់ក្តី និងការប្រកាសសាលដីកា ដែលបិទបញ្ចប់សំណុំរឿងស្តីពី«ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលកាន់អំណាចចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩»។ សរុបសេចក្តីមកការប្រកាសសាលដីកានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ គឺជាការបញ្ចប់នូវនីតិវិធីច្បាប់ និងសំណុំរឿងទាំងអស់ដែលពាក់ព័ន្ធនឹងមេដឹកនាំខ្មែរក្រហម ត្រូវបានបិទបញ្ចប់។ ប៉ុន្តែពុំមានន័យថាតុលាការខ្មែរក្រហម ត្រូវបិទទ្វារទាំងស្រុងនោះទេ។ តុលាការនេះ ជាកន្លែងគ្រប់គ្រងបណ្ណសារនៃសំណុំរឿង ដែលត្រូវរក្សាទុកដើម្បីឱ្យសាធារណជនចូលមើល និងសិក្សាស្រាវជ្រាវ ហើយក្លាយជាកន្លែងអប់រំផ្សព្វផ្សាយអំពីសមិទ្ធផលរបស់ខ្លួនដល់សាធារណជន និងអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ។

## ៧-យុទ្ធសាស្ត្របញ្ចកោណ

ប្រទេសកម្ពុជាក្រោយការសម្រេចបានសន្តិភាពពេញលេញ បូរណភាពទឹកដី និងឯកភាពជាតិទាំងស្រុងតាមរយៈនយោបាយឈ្នះ ឈ្នះ របស់សម្តេច ហ៊ុន សែន នោះរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល។ ការអនុវត្តនេះសម្រេចបានសមិទ្ធិផលធំៗលើគ្រប់វិស័យទាំងនយោបាយ សេដ្ឋកិច្ច និងសង្គម ដែលនាំកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មីក្នុងតំបន់ និងអន្តរជាតិ។ សម្រាប់អាណត្តិទី៧នៃរដ្ឋាភិបាលកម្ពុជា ដែលជាវដ្តថ្មីមួយសម្រាប់ប្រទេសជាតិ។ វដ្តថ្មីនេះគឺកម្ពុជាមានមហិច្ឆិតាចង់លើកស្ទួយមោទនភាពជាតិឱ្យកាន់តែខ្ពស់ឡើងដូចសម័យអង្គរដ៏រុងរឿងតាមរយៈការកសាងជាតិមួយដ៏រឹងមាំ រុងរឿង និងមានវិបុលភាពក្លាយជាប្រទេសដែលមានចំណូលខ្ពស់។ ដោយឈរលើមូលដ្ឋានសមិទ្ធិផលដែលសម្រេចបានក្នុងអាណត្តិមុនៗ និងពិនិត្យវាយតម្លៃនិន្នាការតំបន់ និងសកលលោកជាមួយការប្រមើលទៅមុខ២៥ឆ្នាំ សំដៅឆ្លើយតបនឹងបំណងប្រាថ្នារបស់ប្រជាជនខ្មែរនោះ រាជរដ្ឋាភិបាលបានដាក់ចេញ«យុទ្ធសាស្ត្របញ្ចកោណ» ដើម្បីជំរុញកំណើនសេដ្ឋកិច្ច, បង្កើតការងារ, ធានាសមធម៌, បង្កើនប្រសិទ្ធភាព និងរក្សាចីរភាព។ ជារួមយុទ្ធសាស្ត្របញ្ចកោណគឺជាយុទ្ធសាស្ត្រសម្លឹងទៅមុខសម្រាប់រយៈពេល២៥ឆ្នាំ ដែលត្រូវគិតគូរដាក់ចេញ និងអនុវត្តជា៥ដំណាក់កាលបន្តបន្ទាប់ និងបានតម្រង់ និងសម្រួលទៅតាម«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នៃនីតិកាលនីមួយៗនៃរដ្ឋសភា។

យុទ្ធសាស្ត្របញ្ចកោណមានមុំ៥ ដែលរួមមាន ការអភិវឌ្ឍធនធានមនុស្ស, ការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការអភិវឌ្ឍវិស័យឯកជននិងការងារ, ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព។

### ១-បាវចនានៃយុទ្ធសាស្ត្របញ្ចកោណ

បាវចនាមានន័យថាពាក្យគោលចារឹក ឬ សម្តីជាសំអាងទុកជាគោលប្រតិបត្តិ។ បាវចនានៃយុទ្ធសាស្ត្របញ្ចកោណមានកំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព។

### ២-បេសកកម្មចម្បង និងអាទិភាព

បេសកកម្មគឺមុខការងារមានកំណត់ជាក់ប្រាកដថា ដែលរដ្ឋាភិបាលបានប្រគល់ឱ្យដល់ភ្នាក់ងាររាជការដើម្បីធ្វើឱ្យបានសម្រេចបាន។ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ មានបេសកកម្មជាប្រវត្តិសាស្ត្រចម្បងពីរដែលទី១គឺរក្សា និងថែបំប៉នសុខភាពសន្តិភាព។ ក្នុងន័យនេះ មានន័យថាត្រូវរក្សាឱ្យបាននូវសន្តិភាពដែលសម្រេចបានដោយលំបាកជាមួយនឹងការលះបង់មិនអាចកាត់ថ្លៃបាន និងពូនជ្រំនិន្នាការកើនឡើងនៃសេដ្ឋកិច្ច និងការអភិវឌ្ឍជារួម។ សម្រាប់បេសកកម្មទី២គឺកសាង និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសម្ទុះនៃការអភិវឌ្ឍប្រទេសជាតិ។ បញ្ហាដ៏សំខាន់នេះគឺត្រូវប្រែក្លាយប្រទេសកម្ពុជា ឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឆ្ពោះសម្រេចនូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ តាមរយៈការកសាងភាពធន់រឹងមាំនៃវិស័យ៥គឺវិស័យសាធារណៈ, សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, មូលធនមនុស្សនិងសង្គម និងវិស័យបរិស្ថាននិងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

**៣-រចនាសម្ព័ន្ធ និងខ្លឹមសារសង្ខេប**

នៅក្នុងយុទ្ធសាស្ត្របញ្ចកោណមានមុំចំនួន៥ និងកិច្ចការអាទិភាពចំនួន៥។

**១-មុំទី១ : ការអភិវឌ្ឍមូលធនមនុស្ស**

- ការពង្រឹងគុណភាព វិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស
- ការលើកកម្ពស់ សុខភាព និងសុខុមាលភាពប្រជាជន
- ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង
- ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌, សមធម៌ និងបរិយាប័ន្ន

**២-មុំទី២: ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង**

- ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច
- ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទីក, វិស័យថាមពល, វិស័យទឹកស្អាត និង វិស័យឌីជីថល
- ការកែលម្អបរិយាកាស ធុរកិច្ច និងការវិនិយោគ
- ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរី
- ការធ្វើនវានុវត្តន៍ យន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគ

**៣-មុំទី៣: ការអភិវឌ្ឍវិស័យឯកជន និងការងារ**

- ការអភិវឌ្ឍទីផ្សារការងារ
- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម, ធុរកិច្ចថ្មី, សហគ្រិនភាព និង ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ការពង្រឹងភាពជាដៃគូ វិស័យសាធារណៈ និងវិស័យឯកជន
- ការពង្រឹងការប្រកួតប្រជែង
- ការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

**៤-មុំទី៤: ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន**

- ការធ្វើបរមភាវូបនីយកម្ម (Optimization) ផលលាភប្រជាសាស្ត្រ, ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ
- ការគ្រប់គ្រងធនធានធម្មជាតិ, បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ ប្រកបដោយចីរភាព
- ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ
- ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម
- ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង

**៥-មុំទី៥ : ការអភិវឌ្ឍ សេដ្ឋកិច្ច និងសង្គមឌីជីថល**

– ការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល
– ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ធុរកិច្ចឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តន៍ឌីជីថល
– ការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល
– ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល
– ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ

សរុបមក នយោបាយបញ្ចកោណ មានគោលដៅដើម្បីបង្កើនការអភិវឌ្ឍជាតិតាមរយៈការពង្រឹងសេដ្ឋកិច្ច បង្ការ និងបន្ទាបភាពក្រីក្រ ពង្រឹងការចងសម្ព័ន្ធសង្គម និងធានាសុវត្ថិភាព និងសុភមង្គលរបស់ប្រជាជន។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបានប្រើវិជ្ជាមានសំខាន់ៗដូចជាបង្កើនកំណើនសេដ្ឋកិច្ចតាមរយៈវិស័យកសិកម្ម និងឧស្សាហកម្ម, ការអភិរក្ស និងការអភិវឌ្ឍធនធានមនុស្ស, ការរួមបញ្ចូលសង្គម និងការពង្រឹងលទ្ធិប្រជាធិបតេយ្យ, ការពង្រឹងការគ្រប់គ្រងរដ្ឋបាល និងគោលនយោបាយការពារជាតិ និងការបរទេស។ នយោបាយបញ្ចកោណ គឺជាយុទ្ធសាស្ត្រប្រកបដោយចក្ខុវិស័យ ដែលផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីធានាអនាគតរុងរឿងរបស់ប្រទេសកម្ពុជា។

## ៨-សំណួរត្រិះរិះ

១-ចូរពណ៌នាពីនយោបាយឈ្នះ ឈ្នះ។
២-តើការចូលជាសមាជិកអាស៊ានបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់កម្ពុជា ?
៣-តើយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណបានធ្វើឱ្យកម្ពុជាមានការអភិវឌ្ឍដូចម្តេចខ្លះ ?
៤-ចូរពណ៌នាពីដំណើរកសាងជាតិឡើងវិញពីឆ្នាំ១៩៩៣ ដល់១៩៩៨។
៥-មតិមួយពោលថា«សន្តិភាពបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ»។ ចូរពន្យល់។

# ផ្នែកទី២

# ប្រវត្តិសាស្ត្រតំបន់

# មេរៀនទី១ ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍សម័យបុរាណ

## ១-អាស៊ីអាគ្នេយ៍ជាអ្វី?

នៅទសវត្សឆ្នាំ១៩៣០ ពាក្យអាស៊ីអាគ្នេយ៍អាចធ្វើឱ្យគេភ្ញាក់ផ្អើល ព្រោះថា មានមនុស្សពីរឬបីនាក់ប៉ុណ្ណោះ ដែលគិតនិងនិយាយអំពី **«អាស៊ីអាគ្នេយ៍»**។ អ្នកនិពន្ធមួយចំនួនប្រើពាក្យ «ឥណ្ឌាខាងក្រៅ» ដើម្បីពណ៌នាអំពីភូមិភាគមួយចំនួនក្នុងអាស៊ីអាគ្នេយ៍ ដែលហាក់ដូចជាសំដៅលើតំបន់ហួសពីឈូងសមុទ្រ បេងហ្គាល់ គឺជាឧបទ្វីបឥណ្ឌាតូចមួយ។ មុនសង្គ្រាមលោកលើកទី២ មានការប្រើប្រាស់ពាក្យ «អាស៊ីមូសុង» (អាស៊ីខ្យល់រដូវ) សម្រាប់សម្គាល់តំបន់អាស៊ីអាគ្នេយ៍។ ពាក្យនេះបានមកពីរបបអាកាសធាតុខ្យល់រដូវ ដែលមានសារៈសំខាន់នៅស្ទើរគ្រប់ប្រទេសទាំងអស់ក្នុងតំបន់អាស៊ីអាគ្នេយ៍។ អ្នកភូមិវិទ្យានិយមប្រើពាក្យនេះ មិនមែនគ្រាន់តែសំដៅទៅលើតំបន់ដែលអ្នកប្រាជ្ញសម័យទំនើបហៅថា អាស៊ីអាគ្នេយ៍ រួមទាំងភូមិភាគខាងត្បូងរបស់ចិនដែរ ព្រោះថា តំបន់ទាំងនេះ ក៏បានទទួលរបបខ្យល់រដូវ (មូសុង) ដូចគ្នា។

ភាគច្រើន ទាំងអ្នកប្រាជ្ញបរទេសដែលធ្វើការនៅអាស៊ីអាគ្នយ៍មុនសង្គ្រាមលោកលើកទី២ និងទាំងអ្នកស្រុកអាស៊ីអាគ្នេយ៍ សុទ្ធតែមិនធ្លាប់គិតអំពីអាស៊ីអាគ្នេយ៍ក្នុងន័យទូទៅមួយឡើយ។ ទំនោរបែបនេះទើបកើតមានឡើងក្នុងសម័យសង្គ្រាមលោកលើកទី២ ប៉ុណ្ណោះ។ នៅពេលនោះ ពាក្យថា «អាស៊ីអាគ្នេយ៍» បានកើតឡើងដោយសារព្រឹត្តិការណ៍យោធា។ តាមទស្សនៈបែបយុទ្ធសាស្ត្រយោធា អាស៊ីអាគ្នេយ៍ទំនងជាតំបន់ដែលមិនមែនជាឥណ្ឌា មិនមែនចិន ហើយក៏មិនមែនជាផ្នែកមួយនៃប៉ាស៊ីហ្វិកដែរ។ ផ្ទុយទៅវិញ គេចាប់ផ្តើមយល់ថា ប្រទេសប្រ៊ុយណេ ភូមា ថៃ ឡាវ កម្ពុជា វៀតណាម ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន និងឥណ្ឌូណេស៊ី រួមគ្នាបង្កើតជាតំបន់ភូមិសាស្ត្រមួយ។ នៅក្នុងការសិក្សាអំពីប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ គេកម្រនិយាយដល់ទីម័រខាងកើតណាស់ រហូតដល់ពេលដែលទឹកដីនេះត្រូវឥណ្ឌូណេស៊ីឈ្លានពាននាឆ្នាំ១៩៧៥។

ពេលសព្វថ្ងៃនេះ និយមន័យអាស៊ីអាគ្នេយ៍ ដោយរាប់ចាប់ពីប្រទេសខាងលិចទៅខាងកើតរួមមាន ភូមា ថៃឡង់ ឡាវ កម្ពុជា និងវៀតណាម ដែលជាប្រទេសដីគោក រួមគ្នាជាមួយប្រទេសដីកោះ ហ្វីលីពីននិងកោះឥណ្ឌូណេស៊ី ដែលមានឥណ្ឌូណេស៊ី ម៉ាឡេស៊ី សិង្ហបុរី និងប្រ៊ុយណេ។ នេះគ្រាន់តែជាការកំណត់ខាង ភូមិសាស្ត្រប៉ុណ្ណោះ ដោយមិនចាត់ទុកនូវភាពខុសគ្នា និងលក្ខណៈប្រហាក់ប្រហែលគ្នាខាងភាសា វប្បធម៌ សាសនាទេ។ គេគ្រាន់តែរួមបញ្ចូលប្រទេសថ្មីៗទាំងអស់ ដែលមានទីតាំងស្ថិតនៅខាងកើតប្រទេសឥណ្ឌា និងខាងត្បូងប្រទេសចិន។

ទោះជាយ៉ាងណា ឈ្មោះរួមនៃអាស៊ីអាគ្នេយ៍ពីអតីតកាល មានចំនួនច្រើនដោយប្រែប្រួលតាម ពេលវេលា ការសន្មត និងលទ្ធផលនៃការសង្កេតរបស់អ្នកដំណើរបរទេសដែលបានឆ្លងកាត់តំបន់នេះដោយផ្ទាល់តែម្តង។ តាមរយៈសិលាចារឹកព្រះបាទអសោកនៅចុងសតវត្សទី៣មុនគ.ស. និងបណ្តាឯកសារ ពុទ្ធសាសនាថេរវាទ នៅពេលក្រោយមកបានឱ្យដឹងថា ឥណ្ឌាហៅថា «សុវណ្ណភូមិ» ឬភាសាបាលីថា «សុវណ្ណភូមិ» សំដៅប្រទេសហ្វុណនរបស់ខ្មែរ ព្រោះបើតាមចិនកត់ត្រានៅសតវត្សទី៣ថា ប្រទេសនេះមានអំណាចគ្រប់គ្រងលើកំពង់ផែជាច្រើន ចាប់តាំងពីឆ្នេរភាគកណ្តាលនៃប្រទេសវៀតណាម សព្វថ្ងៃរហូតដល់ជ្រោយម៉ាឡេស្យាតំបន់ស៊ុងខ្លាសព្វថ្ងៃ និងឆ្នេរសមុទ្របេងហ្គាល់នៃប្រទេសភូមា។ ហេតុនេះហើយ បានជាប្រទេសភាគច្រើននៅក្នុងតំបន់នេះតែងតែអះអាងដូចៗគ្នាថា ប្រទេសខ្លួនត្រូវនឹងដែនដីសុវណ្ណភូមិដែរ។

ទន្ទឹមនោះអ្នកដំណើរចិនបុរាណ បានកត់ត្រាសម្គាល់មនុស្ស និងសំពៅដែលចេញពីតំបន់អាស៊ីអាគ្នេយ៍ ឬតំបន់សមុទ្រចិនខាងត្បូងនេះថា សំពៅពួកឃុនលុន មនុស្សឃុនលុន។ បើតាមកស្តុតាងនេះ មានន័យថា

ក្នុងគំនិតពួកចិនបានហៅតំបន់អាស៊ីអាគ្នេយ៍បុរាណ " យុន-លុន " នេះឯង។ ទោះជាយ៉ាងណាក៏ដោយ ក៏ឈ្មោះនេះមិនសូវមានប្រជាប្រិយភាព និងមានគេចងចាំបានយូរដែរនៅក្នុងសង្គមពាណិជ្ជកម្មឯនាយសមុទ្ររបស់ចិន។

ចាប់តាំងពីឆ្នាំ១៨៥២ ឬពាក់កណ្តាលសតវត្សទី១៩មក លោក Malte Brun ដែលជាភូមិសាស្ត្រវិទូជនជាតិដាណឺម៉ាក បានដាក់ឈ្មោះអាស៊ីអាគ្នេយ៍នេះថា «**ឥណ្ឌូចិន**» ដែលមានន័យថា ជាតំបន់ដែលស្ថិតនៅខាងកើតឥណ្ឌា និងខាងត្បូងចិន ហើយដែលទទួលបានឥទ្ធិពលវប្បធម៌នៃមហាប្រទេសទាំងពីរនេះ[409]។ គាត់បានកត់សម្គាល់ឃើញថា ឥទ្ធិពលនៃវប្បធម៌ធំទាំងពីរនេះត្រូវខណ្ឌចែកដាច់ពីគ្នាដោយសារជួរភ្នំអាណ្ណាម ឬជឿងសឺន(Trung Son) ដែលជាជញ្ជាំងធម្មជាតិសណ្តូកពីជើងទៅត្បូងខណ្ឌចែកប្រទេសវៀតណាម ពីឡាវ និងកម្ពុជា។ ប្រជាជនដែលរស់នៅភាគខាងលិចជួរភ្នំនេះ បានទទួលវប្បធម៌អរិយធម៌ពីឥណ្ឌាយ៉ាងជោគជាំ។ ចំណែកអ្នករស់នៅខាងកើតជួរភ្នំវិញ គឺជនជាតិវៀតណាមដែលជាប្រជាជាតិបានទទួលឥទ្ធិពលវប្បធម៌ចិន។ មិនយូរប៉ុន្មាន ក្រោយពេលបារាំងដណ្តើមយកបានប្រទេសកម្ពុជា ឡាវ និងវៀតណាមដាក់ជាប្រទេសអាណានិគមអស់នៅឆ្នាំ១៨៨៧ គេបានបង្កើតដែនដីរដ្ឋបាលសហភាពរបស់ខ្លួនមួយ ដោយយកឈ្មោះ «ឥណ្ឌូចិន» មកដាក់ភ្ជាប់ជាមួយ គឺសហភាពឥណ្ឌូចិនបារាំង។ ហេតុនេះហើយទើបបច្ចេកពាក្យនេះ ត្រូវបំព្រួញន័យមកសម្គាល់ត្រឹមបីប្រទេសវិញ។

បើគេពិចារណាអំពីទំនាក់ទំនងខាងសាសនា យើងគួរតែត្រូវរាប់បញ្ចូលនូវផ្នែកនៃប្រទេសឥណ្ឌា ភាគឦសាន មានតំបន់ខាស៊ី(Khasi) ហើយប្រហែលនៅមានកន្លែងដទៃទៀតនៅភូមិភាគខាងជើង និងផ្នែកកណ្តាលនៃប្រទេសឥណ្ឌា ដែលមានគេនិយាយភាសាមុណ្ឌ (Munda)។ ចំណែកនៅប្រទេសចិនភាគនិរតីដែលមានក្រុមមនុស្សនិយាយភាសាតៃ និងនៅកោះតៃវ៉ាន់ ដែលជាកន្លែងមានអ្នកនិយាយភាសាអូស្ត្រូណេស៊ី ឬឥណ្ឌូណេស៊ីរស់នៅមុនគេ។ មានអ្នកប្រវត្តិសាស្ត្រខ្លះ បានស្នើយោបល់ថា គេគួរតែរាប់បញ្ចូលប្រទេស*ស្រីលង្កា*(សៃលេន) ទៅក្នុងតំបន់អាស៊ីអាគ្នេយ៍ផងដែរ។ ពីព្រោះនៅប្រទេសនេះមានសាសនាសំខាន់ៗ ជាពិសេសសាសនាថេរវាទ ដូចគ្នានឹងនៅ ភូមា ថៃ ឡាវ និងកម្ពុជាដែរ។ ផ្ទុយទៅវិញ ទោះបីមានភូមិសាស្ត្រជាប់ជាមួយអាស៊ីអាគ្នេយ៍ក៏ដោយ ក៏គេមិនបានរាប់បញ្ចូលតំបន់ដីកោះដ៏ធំឈ្មោះប៉ាពួញូហ្គីណេ (ឥណ្ឌូណេស៊ី អ៊ីរីយ៉ានជយ៉ា) មកក្នុងតំបន់ជាមួយគ្នានេះដែរ ព្រោះគេយល់ថា ភាសា សេដ្ឋកិច្ច វប្បធម៌ និងប្រវត្តិជាតិពន្ធនៃអនុតំបន់នេះ ខុសគ្នាពីរបស់មនុស្សនៅអាស៊ីអាគ្នេយ៍។ នៅក្នុងសម័យបុរេប្រវត្តិសាស្ត្រ មុនដើមសតវត្សទី១ តំបន់មួយផ្នែកធំ ដែលសព្វថ្ងៃជាប្រទេសចិនភាគខាងត្បូង លាតសន្ធឹងចាប់ពីខាងត្បូងទន្លេយ៉ង់សេ ក៏មានប្រភេទវប្បធម៌ និងភាសារបស់អាស៊ីអាគ្នេយ៍។ តាមពិតទឹកដីដើមកំណើតរបស់ចិន ក៏ដូចជាមជ្ឈមណ្ឌល វប្បធម៌ចិនបុរាណ ស្ថិតនៅខាងជើងទន្លេយ៉ង់សេ មកដល់ប្រហែល ២០០ទៅ១០០ឆ្នាំមុនគ.ស. ហើយភាសាកំណើតរបស់មនុស្សនៅភាគខាងត្បូងទន្លេយ៉ង់សេ គឺជារបស់អាស៊ីអាគ្នេយ៍ ដែលមានថៃ អូស្ត្រូណេស៊ី មន-ខ្មែរ និងទីបេតូ-ភូមា។ មកដល់សព្វថ្ងៃនេះក៏នៅតែមានមនុស្សជាច្រើនក្រុមបន្តនិយាយអម្បូរភាសាថៃ និងទីបេតូ-ភូមានៅក្នុងតំបន់នេះដែរ។ ថ្វីបើគ្មានមនុស្សនិយាយភាសាមន-ខ្មែរ ឬអូស្ត្រូណេស៊ីនៅក្នុងប្រទេសចិនពេលនេះក៏ដោយ ក៏នៅតែមានវត្តមានពាក្យកម្ចីភាសានេះនៅក្នុងភាសាចិនតាំងពីសម័យបុរេប្រវត្តិប្រមាណ ២០០០-៣០០០ឆ្នាំមុនមកម្ល៉េះ បើផ្អែកតាមភស្តុតាង ហើយក៏មានមនុស្សនិយាយភាសាមន-ខ្មែរនៅក្នុងភាគខាងត្បូងទន្លេយ៉ង់សេនៃប្រទេសចិនសព្វថ្ងៃនេះ។

[409] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ភ្នំពេញ, ឆ្នាំ២០១២-២០១៣, ទំព័រ២២។

នៅចន្លោះប្រទេសចិនខាងត្បូង និងអាស៊ីអាគ្នេយ៍ ក៏មានទំនាក់ទំនងគ្នាខាងភូមិសាស្ត្រយ៉ាងសំខាន់ដែរ។ នៅមុនសម័យទំនើប នៅពេលដែលមនុស្សបានផ្លាស់ប្ដូរទីតាំង ឬធ្វើជំនួញជាមួយកន្លែងដទៃទៀត មធ្យោបាយដ៏ប្រសើរបំផុតដើម្បីធ្វើដំណើរ គឺតាមផ្លូវទឹក ទាំងតាមដងទន្លេវែងៗ និងទាំងតាមផ្លូវសមុទ្រ។ ចំពោះផ្លូវគោកត្រូវប្រឈមមុខនឹងការលំបាកច្រើនបំផុត ហើយមិនអាចដើរតួនាទីជំនួសទន្លេ ដែលជាផ្លូវគមនាគមន៍ដ៏សំខាន់បំផុតរហូតដល់សតវត្សទី២០។ មានទន្លេធំៗជាច្រើន ដែលភ្ជាប់ទំនាក់ទំនងពីប្រទេសចិនមកអាស៊ីអាគ្នេយ៍៖ (១)ទន្លេក្រហម ចាប់ពីចិនខាងត្បូងហូរចុះទៅវៀតណាមខាងជើង (២)ទន្លេមេគង្គហូរពីចិនកណ្ដាលឆ្លងកាត់ប្រទេសថៃ ឡាវ កម្ពុជា និងវៀតណាមខាងត្បូង (៣)ទន្លេសាលវីន(Salween) និង(៤)ទន្លេឥរ៉ាវតី(Irrawaddy) ហូរចេញពីចិនខាងត្បូងទៅប្រទេសភូមា។ បន្ថែមលើទន្លេទាំងនោះ ការរីកសាយភាយនៃភាសាអូស្ត្រូណេស៊ី បង្ហាញឱ្យឃើញនូវសារៈសំខាន់នៃទំនាក់ទំនងតាមសមុទ្រពីចិនខាងត្បូង និងតៃវ៉ាន់ កាត់តាមបណ្ដាកោះនៃអាស៊ីអាគ្នេយ៍។ ប៉ុន្តែសង្គមអាស៊ីអាគ្នេយ៍ ការទទួលមរតកជាទ្រព្យសម្បត្តិ និងឋានៈតាមរយៈមាតា មិនមែនតាមរយៈបិតា ដូចនៅក្នុងសង្គមចិនទេ។

ដូច្នោះ «អាស៊ីអាគ្នេយ៍» ប្រហែលជាត្រូវគេកំណត់ថា ជាតំបន់ដ៏ធំមួយ ដែលក្នុងនោះធ្វើស្រែវស្សា និងនាវាចរណ៍តាមសមុទ្រ បានរីកលូតលាស់យ៉ាងឆើតឆាយតាំងពីសម័យបុរេប្រវត្តិ ដ៏យូរអង្វែង ហើយប្រហែលក្នុងសម័យប្រមាណ ៥០០០ឆ្នាំនោះ ភាសាជាច្រើន មានភាសាមន-ខ្មែរ អូស្ត្រូណេស៊ី ទីបេតូ-ភូមា និងថៃបានបង្កើត និងអភិវឌ្ឍន៍ឡើង។

អាស៊ីអាគ្នេយ៍ជាអនុតំបន់របស់ទ្វីបអាស៊ី ដែលរួមបញ្ចូលរវាងបណ្ដាប្រទេស ដែលមានភូមិសាស្ត្រនៅខាងត្បូងប្រទេសចិន ខាងកើតប្រទេសឥណ្ឌា និងខាងជើងប្រទេសអូស្ត្រាលី។ អាស៊ីអាគ្នេយ៍មានតំបន់ភូមិសាស្ត្រសំខាន់ពីរគឺ៖ អាស៊ីអាគ្នេយ៍ដីគោករួមមាន មីយ៉ាន់ម៉ា កម្ពុជា ឡាវ ថៃ វៀតណាម និងឧបទ្វីបម៉ាឡេស៊ី (ផ្នែកមួយនៃប្រទេសម៉ាឡេស៊ី) និងប្រទេសដីកោះរួមមានឥណ្ឌូណេស៊ី ហ្វីលីពីន ប្រ៊ុយណេដារ៉ូសាឡឹម ទីម័រខាងកើត សិង្ហបុរី និងម៉ាឡេស៊ី(ខាងកើត) ហើយគេរាប់បញ្ចូលទាំងប្រទេសប៉ាពួញូគីណេ ផងដែរ។ ទំហំផ្ទៃដីនៃតំបន់អាស៊ីអាគ្នេយ៍លាតសន្ធឹងលើខ្សែរយៈទទឹងជាង ៣៥អង្សា និងខ្សែរយៈបណ្ដោយជិត៥០ អង្សា។

## ២-ភាសា នៃប្រជាជនអាស៊ីអាគ្នេយ៍

ក្នុងការទំនាក់ទំនងគ្នា ភាសាជាមធ្យោបាយសំខាន់បំផុតដែលមិនអាចខ្វះបាន គ្រាន់តែភាសានោះប្រើដើម្បីទាក់ទងរវាងក្រុមជនជាតិមួយ និងក្រុមជនជាតិមួយ ហើយរវាងក្រុមជនជាតិមួយ និងក្រុមជនជាតិមួយទៀត។ ភាសាខ្លះប្រើបានតែសម្រាប់ជនជាតិខ្លួនប៉ុណ្ណោះ រីឯភាសាខ្លះទៀតប្រើបានក្នុងប្រទេស តំបន់ និងជាសកលផងដែរ។

### ២.១-ភាសាមន-ខ្មែរ និងអូស្ត្រូអាស៊ីយ៉ាទិក

ប្រហែលអម្បូរភាសាដំបូងគេ ដែលគេទទួលស្គាល់នៅអាស៊ីអាគ្នេយ៍ គឺភាសាមន-ខ្មែរ មានឈ្មោះកើតមកពីភាសាពីរ ដែលមានកំណត់ហេតុជាលាយលក្ខណ៍អក្សរបុរាណខ្លះៗ គឺមន(មានសិលាចារឹកពីសតវត្សទី៦ គ.ស. នៅក្នុងប្រទេសភូមា និងថៃ) និងភាសាខ្មែរ (មានសិលាចារឹកពីសតវត្សទី៧នៃគ.ស.)។

នៅពេលពួកភាសាវិទូចាប់ផ្ដើមស្រាវជ្រាវដោយប្រៀបធៀបពាក្យស័ព្ទ និងវេយ្យាករណ៍ ពីភាសាមន ភាសាខ្មែរ និងភាសាដទៃទៀតជាច្រើនដែលជាភាសាគ្មានសំណេរ ធ្វើឱ្យពួកគេសម្រេចចិត្តថា អម្បូរភាសានេះគប្បីគេរួបរួមបញ្ចូលគ្នា ដោយបន្ថែមភាសាមននិងខ្មែរ ភាសាវៀតណាម ភាសាជនជាតិភាគតិចជាច្រើនក្រុមជាតិពន្ធុទៀតនៅក្នុងប្រទេសកម្ពុជា(ព័រ, សំរែ , គួយ, ទំពួន ,ព្រៅ) នៅក្នុងប្រទេសឡាវ(កាតុ, ប្រូ, ខ្មុ) នៅ

ក្នុងប្រទេសវៀតណាម(បាហ្នា, ស្ទៀង, ម្នង) នៅភូមិភាគខាងជើងប្រទេសថៃ ភាគខាងជើងភូមា (ប៉ាលុង) ប្រទេសម៉ាឡេស៊ី(អាស្លៀន) និងខាស៊ី នៅភាគឦសានប្រទេសឥណ្ឌា។

ដោយសារការសាយភាយនាពេលសព្វថ្ងៃ ហើយសិលាចារឹកដំបូង ជាភាសាមន និងខ្មែរ បានមករស់នៅពាសពេញតំបន់អាស៊ីអាគ្នេយ៍ដីគោក។ ពួកនោះហើយ ជាមនុស្សសំខាន់នៅភាគខាងត្បូងប្រទេសភូមាភាគកណ្តាល និងភាគខាងត្បូងប្រទេសថៃ រហូតមកដល់កម្ពុជា។ ភាសាមន-ខ្មែរបុរាណមាន ខ្មែរ, មន, វៀត, បាហ្នា, គួយ, ខ្មុ ,អាស្លៀន និងខាស៊ី។ ភាសាមន-ខ្មែរ និងភាសាមុណ្ឌ របស់ឥណ្ឌា រួមបញ្ចូលគ្នាបង្កើតបានជាអម្បូរភាសាអូស្ត្រូអាស៊ីយ៉ាទិក។

ដោយសារនៃអម្បូរមន-ខ្មែរ មានលក្ខណៈខុសគ្នាឆ្ងាយច្រើន នាំឱ្យអ្នកឯកទេសគិតថា ភាសានេះប្រហែលបានជាចាប់ផ្តើមបែកចេញពីភាសាបុរាណ តាំងពីយូរយារណាស់ហើយ ប្រហែល៤០០០-៥០០០ឆ្នាំមុន។ សព្វថ្ងៃនេះ គេមិនអាចកត់សម្គាល់មនុស្សម្នាក់ដែលចេញពីក្រុមណាមួយក្នុងចំណោមក្រុមទាំងអស់នេះថា ជាមនុស្សមកពីក្រុមណាមួយទៀតបានឡើយ។

## ២.២-ភាសាអូស្ត្រូណេស៊ី ឬម៉ាឡាយូ-ប៉ូលីនេស្យាន

អម្បូរភាសានេះមាន៧ក្រុមគឺៈ (១)ភាសាទាំងអស់របស់ឥណ្ឌូណេស៊ី, (២)ភាសាទាំងអស់របស់ ហ្វីលីពីន, (៣)ភាសាជាច្រើននៃភាសាប៉ូលីនេស៊ីនៅតំបន់មហាសមុទ្រប៉ាស៊ីហ្វិក, (៤)ភាសាអ្នកកោះម៉ាដាហ្គាស្កា នៅជិតឆ្នេរសមុទ្រខាងជើងនៃទ្វីបអាហ្វ្រិក, (៥)ភាសាជនជាតិភាគតិចខ្លះនៅលើកោះតៃវ៉ាន់, (៦)ម៉ាឡេ, (៧) ចាម្ប។

ដោយយោងទៅលើការប្រៀបធៀបភាសាទាំងអស់នេះ ភាសាវិទូបាននិយាយថា ៤៥០០ឆ្នាំកន្លងមកហើយ មនុស្សនិយាយភាសាអូស្ត្រូនេស៊ីបុរាណ បានធ្វើដំណើរពីឆ្នេរសមុទ្រចិនខាងត្បូងទៅតៃវ៉ាន់។ បន្ទាប់មកនៅប្រហែល៣៥០០ឆ្នាំមុន មានពួកគេខ្លះបានធ្វើដំណើរទៅដល់កោះទាំងឡាយរបស់ហ្វីលីពីន ហើយមកដល់ប្រហែល២០០០ឆ្នាំមុន មនុស្សនិយាយភាសារបស់ក្រុមនេះ បានធ្វើដំណើរទៅកាន់កោះនៃមហាសមុទ្រប៉ាស៊ីហ្វិក ឥណ្ឌូណេស៊ី ហើយនឹងយូរមកទៀតទៅដល់ម៉ាដាហ្គាស្កា ចាម្ប(នៅឆ្នេរសមុទ្រវៀតណាម) និងឧបទ្វីបម៉ាឡេ។ ចាម្បប្រហែលបានមកដល់វៀតណាមនៅប្រមាណ១០០០ឆ្នាំមុនគ.ស.។ មានភាសាជនជាតិភាគតិចពីរទៀត ដែលបានកើតចេញពីភាសាចាម្ប គឺចារ៉ាយ និងរ៉ាដេ នៅក្នុងខេត្តរតនគិរី មណ្ឌលគិរី និងវៀតណាមភាគខាងត្បូង។

នៅលើតំបន់ដីកោះ គ្មានភាសាក្នុងអម្បូរមន-ខ្មែរទេ ផ្ទុយមកវិញ ក៏គ្មានភាសាក្នុងអម្បូរអូស្ត្រូណេស៊ីនៅលើតំបន់ដីគោកដែរ លើកលែងតែភាសាចាម្ប និងម៉ាឡេដែលជិតឆ្នេរសមុទ្រ ហើយភាសាពីរក្រុមនេះទំនងជាមកដល់តំបន់នេះនៅពេលក្រោយប៉ុណ្ណោះ។

## ២.៣-ភាសាថៃ

ភាសាថៃ ជាអម្បូរភាសាដ៏សំខាន់ទី៣នៃតំបន់អាស៊ីអាគ្នេយ៍។ អម្បូរនេះគេរួមបញ្ចូលនូវភាសារបស់ជាតិពន្ធ និងគ្រាមភាសា ដែលសរុបមានប្រមាណ៣០០។ អម្បូរនេះខុសពីអម្បូរមន-ខ្មែរត្រង់ក្រុមផ្សេងៗ គ្នានៃអ្នកប្រើភាសាក្នុងអម្បូរថៃនេះ អាចយល់ដឹងភាសាគ្នាទៅវិញទៅមកក្នុងកម្រិតយ៉ាងខ្ពស់ បានន័យថាភាសាអម្បូរនេះទើបចាប់ផ្តើមបែកចេញពីគ្នាយ៉ាងយូរក្រោយអម្បូរភាសា មន-ខ្មែរ។ ភាសាថៃ ជាភាសាផ្លូវការសម័យថ្មីរបស់ប្រទេសថៃ និងឡាវ ព្រមទាំងគ្រាមភាសាដទៃទៀត នៅក្នុងប្រទេសថៃ ជាពិសេសនៅភាគខាង

ជើង។ មានភាសាខ្លះនៅភាគពាយ័ព្យប្រទេសវៀតណាម ភាគខាងត្បូងប្រទេសចិន រដ្ឋសាន នៅភាគឦសាន ប្រទេសភូមា។

សព្វថ្ងៃនេះ ភាសាវិទូជឿថា ដើមកំណើតភាសាថៃ ធ្លាប់មានគេនិយាយនៅក្នុងតំបន់មួយដែលឥឡូវនេះនៅភាគខាងជើងវៀតណាម និងភាគអាគ្នេយ៍ប្រទេសចិន។ ប្រហែលជិត២០០០ឆ្នាំមុន ក្រុមមនុស្សនៅតំបន់នេះបានចាប់ផ្តើមធ្វើដំណើរទៅកាន់ទិសដៅផ្សេងៗគ្នា ទៅប្រទេសឡាវ ទៅភាគខាងជើងថៃ ភូមា ឥណ្ឌា និងរហូតដល់ភាគខាងត្បូងចិន។ នៅពេលភាសានេះបានសាយភាយ វាក៏ប្រែប្រួលក្លាយទៅជាភាសាថៃសម័យថ្មី។ ប្រហែលអ្នកនិយាយភាសាថៃ បានមកដល់ដែនដីដែលឥឡូវនេះ គឺជាភាសាភាគកណ្តាលនៃប្រទេសថៃនាពេលប្រហែល១០០០ឆ្នាំនៃគ.ស. និងបន្ទាប់មកបានសាយភាយយ៉ាងសន្សឹមៗ រហូតទៅដល់ភាគខាងត្បូង ចូលទៅដល់កន្លែងដែលមានពួក មន-ខ្មែរតាំងទីលំនៅ។

### ២.៤-ភាសាទីបេតូ-ភូមា

អម្បូរភាសានេះមិនសូវមានសារៈសំខាន់ណាស់ណាទេ សម្រាប់ការសិក្សាប្រវត្តិសាស្ត្រនៃប្រទេស កម្ពុជា។ អម្បូរនេះរួមមានភាសាភូមា ទីបេត៍ និងភាសាជនជាតិភាគតិចជាច្រើននៅភាគខាងជើងនៃប្រទេសភូមា និងថៃបច្ចុប្បន្ន និងភាគខាងត្បូងប្រទេសចិន។

### ២.៥-ភាសាប៉ាពួន-អូស្ត្រាលៀន-មេឡានេស្យាន

អម្បូរភាសាបាពួន-អូស្ត្រាលៀន-មេឡានេស្យា ជាភាសារបស់ប៉ាពួញូវហ្គីណេ ភាសារបស់អ្នកស្រុកកោះដទៃខ្លះទៀត នៅជិតកោះ ញូវហ្គីណេ និងប្រជាជនអូស្ត្រាលី ដែលបានរស់នៅទីនោះប្រមាណ៤០០០០ ឆ្នាំមុនពេលជនជាតិអឺរ៉ុបមកដល់។ ភាសាទាំងអស់នេះ មិនមែនជាអម្បូរភាសាតែមួយនោះទេ ប៉ុន្តែវាជាអម្បូរភាសាដែលខុសគ្នាឆ្ងាយពីក្រុមភាសាអាស៊ីអាគ្នេយ៍ ហើយជាហេតុផលមួយ ដែលតាមធម្មតា គេមិនបានរួមបញ្ចូលកោះញូវហ្គីណេ នៅក្នុងការសិក្សាអំពីអាស៊ីអាគ្នេយ៍ទេ។

ប្រហែលប្រជាជនដែលនិយាយភាសានេះ បានបន្តរស់នៅលើកោះខ្លះ ក្នុងចំណោមកោះឥណ្ឌូណេស៊ី មុនពេលដែលពួកនិយាយភាសាអូស្ត្រូនេស៊ីបានមកដល់។ ក្រោយពីពួកអូស្ត្រូណេស៊ី មកដល់ ប្រជាជនប៉ាពួន_មេឡានេស្យាន បានចាប់ផ្តើមរលាយបាត់ដោយសារការរៀបការឆ្លងជាតិពន្ធុ, ការរស់នៅលាយឡំគ្នា ឬក៏ការធ្វើដំណើរចាកចេញទៅកាន់ទីឆ្ងាយ ជាឧទាហរណ៍ ទៅដល់ កោះញូវហ្គីណេ មានភាសាប៉ាពួនតិចតួចប៉ុណ្ណោះ ដែលនៅមានសេសសល់នៅឡើយនៅលើកោះ ភាគខាងកើតនៃប្រទេសឥណ្ឌូណេស៊ី ជាពិសេស កោះទីម័រ។

យើងត្រូវតែយល់ថា ឈ្មោះទាំងអស់នេះ និងទ្រឹស្តីនៃអម្បូរភាសានេះ គ្រាន់តែនិយាយសំដៅ ទៅលើតែភាសាប៉ុណ្ណោះ។ គេមិនបាននិយាយសំដៅខាងពូជសាសន៍ ព្រមទាំងក្រុមជាតិពន្ធុ ដែលបានកំណត់ដោយរាងរៅមុខមាត់ ឬក៏វប្បធម៌ដែរ។

នៅក្នុងសៀវភៅប្រវត្តិសាស្ត្រស្តីពីអាស៊ីអាគ្នេយ៍ពីកាលមុន គេបាននិយាយថា មានប្រភេទមនុស្សខុសៗគ្នាជាច្រើន ដែលគេបានឱ្យនិយមន័យ ដោយផ្អែកលើការមើលឃើញរាងរៅមុខមាត់ ដែលបន្តិចម្តងៗ មនុស្សប្រភេទនេះ បានធ្វើដំណើរចាកចេញពីប្រទេសចិនភាគខាងត្បូងឆ្លងកាត់តាមរយៈអាស៊ីអាគ្នេយ៍ដីគោក ទៅកាន់កោះឥណ្ឌូណេស៊ី ហើយបន្ទាប់មកបានបន្តទៅកាន់ប្រទេសអូស្ត្រាលី។ ដូច្នោះ ក្រុមដំបូងគេ គឺ ជាមនុស្ស «អូស្ត្រាឡូអ៊ីត» ដែលឥឡូវនេះ ឃើញ សេសសល់រស់នៅអូស្ត្រាលី។ ប៉ុន្តែ បានបាត់បង់ពីអាស៊ីអាគ្នេយ៍ទៅហើយ។ បន្ទាប់មក មានពួកឥណ្ឌូណេស៊ី ដែលបានធ្វើដំណើរឆ្លងកាត់ដីគោកទៅដីកោះ និងបានរុញច្រានពួកអូស្ត្រា-

ឡូអ៊ីត ចេញទៅ។ ភាសារបស់ឥណ្ឌូណេស៊ីខ្លះ នៅសល់ជីវិតនៅលើតំបន់ដីគោក ដូចជាភាសាចាម្ប និងម៉ា-ឡេ។ បន្ទាប់ពីនោះមក ពួកមន-ខ្មែរ ក៏បានមកដល់។ គេបានកាន់កាប់តំបន់ដីគោក និងបានរុញច្រានពួកឥណ្ឌូណេស៊ីភាគច្រើនឱ្យចេញទៅកាន់ដីកោះ។ នៅទីបញ្ចប់ ពួកអម្បូរជនជាតិថៃ បានមកដល់ក្រោយ ពួកមន-ខ្មែរ។

ទ្រឹស្ដីចាស់នោះ មិនបានពឹងផ្អែកទៅលើការប្រៀបធៀបភាសាទេ តែគេបានផ្អែកទៅលើ ជំនឿមួយថា ក្រុមប្រជាជននីមួយៗ ក្នុងចំណោមប្រជាជនទាំងអស់មានជាតិពន្ធុខុសគ្នា។

មានភាពខុសគ្នា ដ៏សំខាន់រវាងទ្រឹស្ដីជាតិពន្ធុ និងទ្រឹស្ដីអំពីអម្បូរភាសា ដែលពាក់ព័ន្ធនឹងភាសាអូស្ត្រូណេស៊ី ឬឥណ្ឌូណេស៊ី។ ដោយយោងទៅលើការប្រៀបធៀបភាសា មនុស្សនិយាយភាសា អូស្ត្រូណេស៊ី រួមមានភាសាឥណ្ឌូណេស៊ី បានធ្វើដំណើរតាមសមុទ្ទ ហើយទំនងជាបានមកដល់បណ្ដាកោះនៃពិភពឥណ្ឌូណេស៊ី នៅពេលដែលភាសាមន-ខ្មែរ បានកាន់កាប់ដីគោករួចជាស្រេចហើយ។ បន្ទាប់មក ភាសាចាម្បបានមកតាមសមុទ្ទ ពីកោះមួយប្រហែលជាកោះប័រណេអូ ទៅកាន់ឆ្នេរសមុទ្ទវៀតណាមសព្វថ្ងៃ ជាកន្លែងដែលមានប្រជាជនមន-ខ្មែរ កំពុងរស់នៅ។ ប៉ុន្តែយោងទៅលើទ្រឹស្ដីជាតិពន្ធុ មនុស្សនិយាយភាសា អូស្ត្រូណេស៊ី បានធ្វើដំណើរមកតាមផ្លូវគោក ពីប្រទេសចិនភាគខាងត្បូង ដែលឥឡូវនេះ គឺជាប្រទេសថៃ វៀតណាម និងកម្ពុជាហើយ បន្ទាប់មកបានបន្តដំណើរទៅកាន់ដីកោះ។ ចំណែកទ្រឹស្ដីភាសារបស់ពួកអ្នកប្រាជ្ញសព្វថ្ងៃនេះ មានគេទទួលស្គាល់ច្រើនជាងទ្រឹស្ដីនៃក្រុមជាតិពន្ធុ[410]។

## ៣-ប្រភពសំណេរប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍

ក្នុងការសិក្សាប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ ពឹងផ្អែកលើឯកសារបីប្រភេទសំខាន់ៗ គឺទីមួយ សិលាចារឹកដែលគេចារឹកនៅលើថ្ម ឬលោហធាតុ។ ទីពីរគឺឯកសារប្រូតូប្រវត្តិសាស្ត្រ( Proto-Historical Document) ដែលមានសារៈសំខាន់ណាស់ចំពោះកន្លែងជាច្រើននៅអាស៊ីអាគ្នេយ៍។

ឯកសារខ្លះត្រូវបានសរសេរដោយចិន តែមានប្រភពព័ត៌មានល្អៗតិចតួចប៉ុណ្ណោះ។ ក្រោយមកនៅក្នុងសតវត្សទី១៦-១៩ ប្រវត្តិសាស្ត្រ ត្រូវបានសរសេរឡើងដោយពួកជនជាតិអឺរ៉ុបដំបូង ដែលបានមកទស្សនកិច្ចនៅអាស៊ីអាគ្នេយ៍ ហើយបានធ្វើឡើងក្នុងគោលបំណងដូចគ្នា។

ឯកសារប្រភេទទីបី ជាឯកសារសរសេរលើសម្ភារៈដែលឆាប់ខូច( ស្លឹកត្នោត,ស្លឹកទ្រាំង,ក្រដាស ) ដែលមិនអាចគង់វង្សលើសពី២០០ឆ្នាំ ហើយប្រហែលត្រូវបានគេចម្លងជាច្រើនលើកច្រើនគ្រា ពីព្រោះដោយសារកត្តាអាកាសធាតុ និងបច្ចេកទេសនៃការថែរក្សាមិនបានល្អ។

ប្រភពឯកសារសំណេររបស់កម្ពុជាពឹងផ្អែកលើ សិលាចារឹកជាភាសាខ្មែរបុរាណ, ភាសាសំស្ក្រឹត, ភាសាបាលី, របាយការណ៍អ្នកធ្វើដំណើរចិន និងអឺរ៉ុប ពង្សាវតារក្រោយសម័យអង្គរ និងមុនពេលបារាំងចូលមកបន្តិច ព្រមទាំងឯកសារផ្សេងៗទៀត។

## ៤-បុរេប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍

### ៤.១-មនុស្សដំបូងគេនៅអាស៊ីអាគ្នេយ៍

មនុស្សដំបូងគេបានចាប់កំណើតនៅទ្វីបអាហ្វ្រិកនៅរវាង១ និង២លានឆ្នាំមកហើយ ហើយបាន សាយភាយចេញពី ទ្វីបអាហ្វ្រិកទៅកាន់ផ្នែកដទៃទៀតនៃពិភពលោក។ មនុស្សដំបូងបានមកដល់ អាស៊ីអាគ្នេយ៍នៅ

[410] សូមមើល : ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ៣២។

ប្រហែល១លានឆ្នាំមុន។ មានមនុស្សពីរប្រភេទផ្សេងគ្នា ដែលសាយភាយមកកាន់ អាស៊ីអាគ្នេយ៍ ទី១ Homo Erectus(មនុស្សHomo+ជំហរត្រង់Erectus) និងទី២ គឺHomo Sapiens (មនុស្សចេះដឹង) ដែលត្រូវជាបុព្វបុរសរបស់មនុស្សទាំងអស់នៅក្នុងពិភពលោកសព្វថ្ងៃនេះ[411]។

ការងារស្រាវជ្រាវរបស់បុរាណវិទូនៅក្នុងប្រទេសឥណ្ឌូណេស៊ី និងប្រទេសចិន បានធ្វើឡើងជាច្រើនឆ្នាំកន្លងមកហើយ គេបានរកឃើញនូវសំណល់គ្រោងឆ្អឹង ដែលមើលទៅដូច មនុស្ស។ ប៉ុន្តែជាមនុស្សដែលមានអាយុច្រើនរាប់រយពាន់ឆ្នាំមកហើយ បើតាមគេគណនារកអាយុ។ មានឆ្អឹងខ្លះក្នុងចំណោមឆ្អឹងទាំងអស់នេះ ជារបស់មនុស្សមួយប្រភេទដែលខុសពីមនុស្សសម័យថ្មី។ វានោះជាពូជមនុស្សHomo Erectus ហើយវាបានសាយភាយចូលមកកាន់តំបន់ភាគច្រើននៃទ្វីបអាស៊ី មុនពេលវាក្លាយជាមនុស្សពិតប្រាកដ។

នៅមានទ្រឹស្តី២ និយាយអ្វីៗដែលបានកើតឡើងនៅពេលបន្ទាប់ពីនោះគឺ (១)ក្រុមនីមួយៗក្នុងចំណោមក្រុមទាំងនោះជាបុរេមនុស្ស Homo Erectus ដែលបានវិវត្តទៅជាមនុស្ស អូម៉ូសាភៀន(អូម៉ូសាព្យាង) Homo Sapien។ (២) មនុស្សពិតប្រាកដបានកើតឡើងនៅទ្វីបអាហ្វ្រិក បន្ទាប់មកបានសាយភាយទៅកាន់ទីកន្លែងដទៃនៃពិភពលោក ហើយបុរេមនុស្ស ក៏បានអន្តរជានទៅ។ ការតាំងទីលំនៅពិតប្រាកដរបស់មនុស្សដំបូង ត្រូវបុរាណវិទូរកឃើញនៅតំបន់អាស៊ីអាគ្នេយ៍ ដែលមានអាយុប្រហែល ៤០០០០ឆ្នាំមកហើយ។ គ្រោងឆ្អឹង និងលលាដ៍ក្បាល ដែលត្រូវគេប្រទះឃើញនៅទីនោះ បង្ហាញថា ជាមនុស្ស អូម៉ូសាភៀន។

មនុស្សដំបូងគេទាំងនោះ មើលទៅមិនដូចមនុស្សនៅអាស៊ីអាគ្នេយ៍សម័យថ្មីទេ។ ពួកគេជាក្រុមជាតិពន្ធុឬពូជសាសន៍ដែលមានរាងរៅមុខមាត់ខុសៗគ្នា។ អ្នកបុរេប្រវត្តិសាស្ត្របានហៅពួកគេថា អូស្ត្រាឡូ-មេឡាណេស៊ី ហើយគេជឿថា ពួកនេះមើលទៅមានរាងរៅដូចមនុស្ស ដែលសព្វថ្ងៃនេះរស់នៅលើកោះប៉ាពូញូវ ហ្គីណេ និងពូជអ្នកស្រុកដើមនៅអូស្ត្រាលី។ មនុស្សទាំងអស់នេះ មានសម្បុរស្បែកខ្មៅក្រិប សក់រួញ ហើយមានទម្រង់មុខខុសគ្នាខ្លាំងពីមនុស្សអាស៊ីអាគ្នេយ៍សម័យថ្មីនេះ។

នៅប្រហែលរវាង ២០០០-៤០០០ឆ្នាំមុន គេបានរស់នៅពាសពេញទឹកដីទាំងអស់ ដែលឥឡូវនេះជាប្រទេសភូមា ថៃ កម្ពុជា វៀតណាម និងឥណ្ឌូណេស៊ី មុនពេលដែលបុព្វការីជនរបស់មនុស្សសព្វថ្ងៃមកដល់។ មានមនុស្សអាស៊ីអាគ្នេយ៍ខ្លះក្នុងចំណោមនោះ បានធ្វើដំណើរទៅកាន់អូស្ត្រាលីនៅពេលនោះ។ ភាសារបស់ពួកគេប្រហែលជាបុព្វភាសាប៉ាពូន អ៊ីរីយ៉ាន ជយា ឬក៏ជាភាសាកំណើតរបស់ពួកអូស្ត្រាលីដើម។ គេជឿថា ជនជាតិអូស្ត្រាឡូ-មេឡានេស៊ី មិនចេះធ្វើកសិកម្មទេ ប៉ុន្តែគេអាចរស់នៅបានដោយសារការបរបាញ់ បេះផ្លែឈើព្រៃស្រាប់ និងការដាំដុះនៅក្នុងព្រៃ។ ដូច្នោះ ប្រជាជននៅទីនោះមានតិចតួច ហើយផ្ទៃដីដ៏ធំទូលាយជាទីកន្លែងដែលពួកគេបានរស់នៅនោះ ទំនងជាមិនធ្លាប់មានមនុស្សរស់នៅពីមុនពួកគេនោះទេ។

នៅរវាង ២០០០០ និង ៤០០០០ឆ្នាំមុន កម្ពស់ទឹកសមុទ្រទាក់ជាងសព្វថ្ងៃយ៉ាងច្រើន ហើយវាមាន ដីគោកតភ្ជាប់គ្នាចាប់តាំងពីប្រទេសថៃ កម្ពុជា និងម៉ាឡេស៊ីជាមួយកោះមួយចំនួនរបស់ឥណ្ឌូណេស៊ី ហើយវាក៏មានដីគោកតភ្ជាប់ពីញូគីណេទៅនឹងកោអូស្ត្រាលីផងដែរ ព្រមជាមួយរង្វះសមុទ្រចម្ងាយខ្លីៗ ពីកោះផ្លាទៅកាន់កោះទាំងឡាយនៅភាគខាងកើត។ អញ្ចឹងហើយ ទើបយើងជឿថា ភាគច្រើនបំផុតមនុស្សដើមរបស់ អូស្ត្រាលីអាចធ្វើដំណើរយ៉ាងងាយ ចេញពីតំបន់អាស៊ីអាគ្នេយ៍ទៅកាន់អូស្ត្រាលីតាមដីគោកនោះ នៅរវាង ២០០០០ និង៤០០០០ឆ្នាំមុន។

---

[411] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ជ.ឯ.ម., ទំព័រ១៤។

បន្ទាប់ពី១៨០០០ឆ្នាំមុន កម្ពស់ទឹកសមុទ្ទចាប់ផ្តើមជោរឡើង ហើយមកដល់៧០០០ឆ្នាំចុងក្រោយនេះ នីវ៉ូទឹកសមុទ្ទបានរក្សាកម្ពស់ថេរដូចសព្វថ្ងៃនេះ។

មនុស្សភាគច្រើននៅអាស៊ីអាគ្នេយ៍សព្វថ្ងៃ ជាពូជកាត់ចេញពីពូជសាសន៍ទី២ នៃក្រុមទ្រឹស្តីដែលផ្អែកលើរាងរៅមុខមាត់ ដែលបុរេប្រវត្តិវិទូឱ្យឈ្មោះថា «ម៉ុងហ្គោឡូអ៊ីដភាគខាងត្បូង»។ អញ្ចឹងហើយទើបភាគច្រើននៃប្រជាជនភូមា ថៃ ខ្មែរ ចាម្ប ឥណ្ឌូណេស៊ី និងវៀតណាម មើលទៅមានរាងរៅមុខមាត់ស្រដៀងគ្នាខ្លាំង ហើយតាមរយៈរាងរៅមុខមាត់ គេមិនអាចបែងចែកជាតិពន្ធុភាពរបស់គេឡើយ។ បុរេប្រវត្តិវិទូជឿថា ជាតិសាសន៍ម៉ុងហ្គោឡូអ៊ីដខាងត្បូង បានអភិវឌ្ឍន៍ខ្លួនឯងនៅភាគខាងត្បូងប្រទេសចិន ពីខាងត្បូងទន្លេ យ៉ង់សេ និងជាផ្នែកមួយនៃប្រទេសចិនដែលធ្លាប់ជាកន្លែងរបស់ពួកបុព្វបុរសនិយាយភាសាអូស្ត្រូណេស៊ី, មន-ខ្មែរ, ថៃ និងទីបេ-ភូមា រស់នៅកាលពីរាប់ពាន់ឆ្នាំមុន។

បន្ទាប់ពីមនុស្សម៉ុងហ្គោឡូអ៊ីដភាគខាងត្បូង អភិវឌ្ឍន៍ការដាំដំណាំស្រូវ ពួកគេចាប់ពង្រីកដែនដីមកទិសខាងត្បូង។ ការដាំដុះតែងផលិតបានស្បៀងអាហារច្រើនជាងការបរបាញ់ និងបេះផលានុផលក្នុងព្រៃស្រាប់ ហើយបន្ទាប់ពីមនុស្សបុរាណរៀនចេះធ្វើកសិកម្ម នាំឱ្យប្រជាជនពួកគេកើនឡើងដែរ។ កំណើនប្រជាជនមានន័យថា ពួកគេអាចពង្រីកនិងកាន់កាប់ដែនដីថ្មីៗទៀត។ នៅពេលដែលពួកគេមកដល់ទឹកដីដែលកាន់កាប់ដោយពួកអូស្ត្រាឡូ-មេឡាណេស៊ី ពួកគេអាចរួមបញ្ចូលជាមួយគ្នាដោយរៀបការឆ្លងជាតិពន្ធុ។ នេះជាមធ្យោបាយងាយស្រួលមួយ ដោយសារតែប្រជាជនអូស្ត្រាឡូ-មេឡាណេស៊ីមានចំនួនតិចតួច។ ជាចុងក្រោយ មនុស្សម៉ុងហ្គោឡូអ៊ីដខាងត្បូងបានកាន់កាប់ទាំងអស់នូវអ្វីដែលជាអាស៊ីអាគ្នេយ៍បច្ចុប្បន្ន ហើយគេអាចរកឃើញពួកអូស្ត្រាឡូ-មេឡាណេស៊ី តែនៅក្នុងកោះប៉ាពូញូវហ្គីណេប៉ុណ្ណោះ។

## ៤.២-ចុងសម័យបុរេប្រវត្តិសាស្ត្រ និងអន្តរកាលនៃសម័យប្រវត្តិសាស្ត្រ

ក្នុងការស្រាវជ្រាវបុរាណវិទ្យាដែលល្បីល្បាញបំផុតនៅអាស៊ីអាគ្នេយ៍ ត្រូវបានគេធ្វើនៅក្នុងប្រទេសថៃ, ឧបទ្វីបម៉ាឡេ, វៀតណាម និងប្រទេសឥណ្ឌូណេស៊ី។

### ៤.២.១-ស្ថានីយបានឈៀង

នៅភាគឦសានប្រទេសថៃ បុរាណវិទូបានជួបប្រទះសំណល់លំនៅស្ថានបុរាណ ដែលបង្ហាញពីការធ្វើកសិកម្ម ការផលិតកុលាលភាជន៍ល្អៗ និងការប្រើលោហៈធាតុ ជាពិសេសស្ពាន់។ ទីកន្លែងដែលល្បីល្បាញជាងគេ ឈ្មោះថា បានឈៀង(Ban Chiang) ជាកន្លែងដែលគេបានធ្វើកំណាយ។ វាបង្ហាញពីការមកតាំងទីលំនៅនៅទីនោះ តាំងពីប្រមាណ៣០០០ឆ្នាំមុនគ.ស. រហូតដល់ក្រោយគ.ស.។ មនុស្សដែលបានមករស់នៅទីនោះ ប្រហែលជានិយាយភាសាមន-ខ្មែរ ឬភាសាអូស្ត្រូអាស៊ីយ៉ាទិក។ ពីព្រោះជនជាតិថៃ មិនទាន់មកតាំងទីលំនៅនៅទីនោះនៅឡើយទេ រហូតមកដល់១០០០ឆ្នាំក្រោយគ.ស.។

### ៤.២.២-ស្ថានីយដុងសឺន

នៅក្នុងប្រទេសវៀតណាម មានភស្តុតាងវប្បធម៌សម័យបុរេប្រវត្តិសាស្ត្រពីរ ដែលអ្នកគួរតែដឹង។ ទី១គឺ ដុងសឺន(Dong Son) ស្ថិតនៅភាគខាងជើង និងទី២គឺ សាហុយ្ហ(Sa Huynh) នៅតាមបណ្តោយ សមុទ្ទភាគកណ្តាលវៀតណាម។ ដុងសឺន គឺជាស្ថានីយដែលល្បីល្បាញស្គរសំរឹទ្ធ ដែលគេបានចាប់ផ្តើមធ្វើនៅប្រហែលឆ្នាំ៦០០មុនគ.ស.។ ឥឡូវនេះ វាពិតណាស់ដែលថាវប្បធម៌ដុនសឺន បានវិវត្តន៍ពីសង្គមជំនាន់ដើមនៅកន្លែងដដែល ហើយគេមិនបាននាំវាមកកាន់ប្រទេសវៀតណាមដោយជនជាតិបរទេស ដូចដែលប្រវត្តិវិទូអឺរ៉ុបដំបូងគេបានគិតនោះឡើយ។ ក្រៅពីស្គរ មនុស្សដុនសឺន ចេះផលិតអាវុធជាច្រើន និងឧបករណ៍ធ្វើពីសំរឹទ្ធ

និងស្គរដែលត្រូវគេនាំចេញទៅដល់ប្រទេសឥណ្ឌូណេស៊ី រហូតដល់យ៉ាងតិចក៏នៅសតវត្សទី៣ នៃគ.ស.ដែរ។ នៅក្នុងយុគសម័យនោះ ពីឆ្នាំ៦០០មុនគ.ស. ដល់ឆ្នាំ៣០០នៃគ.ស. គេជឿថា មនុស្សនៅក្នុងតំបន់ដុងសឺន ភាគខាងជើងវៀតណាម ធ្លាប់បាននិយាយភាសាមន-ខ្មែរ ឬភាសាថៃ។

**២-៣-ស្ថានីយសាហុយ្ហ**

នៅរវាងឆ្នាំប្រហែល៦០០មុនគ.ស. និង៥០០នៃគ.ស. វប្បធម៌សាហុយ្ហ នៅវៀតណាម កណ្តាល ល្បីល្បាញខាងការផលិតកុលាលភាជន៍ធំៗ ដែលគេយកមកប្រើសម្រាប់ដាក់សាកសព។ ក្រឡភាជន៍ សាហុយ្ហ បង្ហាញលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនឹងក្រឡភាជន៍នៅប្រទេសហ្វីលីពីន ហើយគេស្ទើរតែប្រាកដថា មនុស្សសាហុយ្ហ ជាជនជាតិចាម្ប ដែលមានភាសាក្នុងអម្បូរអូស្ត្រូណេស៊ី ដែលមានដើមកំណើតមកពីកន្លែង មួយក្នុងប្រទេសឥណ្ឌូណេស៊ី។

នៅកន្លែងជាច្រើនទៀតសម័យបុរេប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ គេបានដឹងពីរបៀបកសាងសំណង់ពីថ្ម យ៉ាងយូរមុនពេលទទួលឥទ្ធិពលពីឥណ្ឌា។ ត្រង់នេះមានន័យថា នៅពេលគេសាងសង់ប្រាសាទពុទ្ធសាសនា និងហិណ្ឌូសាសនាដំបូងនោះទំនងជាពួកអាស៊ីអាគ្នេយ៍នេះឯង ជាអ្នកកសាងឡើងដោយគ្រាន់តែរៀនសូត្រ តាមគំនិតឥណ្ឌា។ មានសំណង់ជាច្រើននៅលើកោះស៊ូម៉ាត្រា,ជ្វា និងកោះបាលី។ ភាគច្រើនក្នុងចំណោមនោះ ជាបន្ទប់ថ្ម ឬអគារដែលធ្វើសម្រាប់ដាក់សាកសពមនុស្ស និងជាប្រភេទស្ថាបត្យកម្មខាងសាសនា។ សំណង់ ទាំងនោះដូចប្រាសាទ ដែលបានកសាងនៅពេលក្រោយមកក្រោមឥទ្ធិពលឥណ្ឌា។

## ៥-សាចតារ និចកំណាកំណើតរដ្ឋអាស៊ីអាគ្នេយ៍ពីស.ច.ទី១ដល់ស.ច.ទី៩

### ៥.១-អាណាចក្រហ្វូណាន

ចំពោះទីតាំងភូមិសាស្ត្រនៃហ្វូណានមានទស្សនៈខុសៗគ្នាជាច្រើន ៖

- លោក ម៉ា ទាន់លីន បានបញ្ជាក់ថា ហ្វូណានជាកោះមួយដែលមានចំងាយប្រហែល ៣ ០០០លី (១លី= ៥៧៦ម៉ែត្រ) នៅភាគអាគ្នេយ៍នៃនគរលីនយី (Linyi) (នគរចាម្ប) និងភាគខាងត្បូង ប្រទេសចិន។
- លោក អេម៉ូនីយេ (Etienne Aymonier) បានឱ្យដឹងថា ហ្វូណានមានទីតាំងចាប់ពីភាគខាងត្បូង តុងកឹង រហូតដល់សមុទ្ទនិងខាងលិចដល់ប្រទេសថៃសព្វថ្ងៃ។
- លោក ប៉ូល ប៉េល្យូត៍ (Paul Pelliot) បានសន្និដ្ឋានថា នគរហ្វូណានមានទីតាំងស្ថិតនៅភាគខាង លើទន្លេមេគង្គ រហូតដល់ទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) និងទៅដល់ឈូងសមុទ្ទម៉ាតាបាន់នៃ ឧបទ្វីប ម៉ាឡាយូ។
- ជនជាតិអឺរ៉ុបផ្សេងទៀតបានអះអាងថា ហ្វូណានស្ថិតនៅតាមបណ្តោយឆ្នេរតុងកឹងដល់សមុទ្ទខ្មែរ និងខាងលិចសន្ទឹងដល់ប្រទេសភូមាសព្វថ្ងៃ។

ដូច្នេះក្រោយបង្រួបបង្រួម អាណាចក្រភ្នំ ឬហ្វូណានមានព្រំប្រទល់ខាងជើងជាប់ប្រទេសចិន (រដ្ឋណានឆាវ តុងកឹង) ខាងកើតជាប់រដ្ឋចាម្ប ឈូងសមុទ្ទចិន ខាងត្បូងឈូងសមុទ្ទខ្មែរ និងខាងលិចជាប់រដ្ឋ មន ឬភូមា។

នៅដើមសតវត្សទី៣នៃគ.ស. លោក កាំង តៃ និងជូ យីង ដែលបេសកទូតចិនបានមកចងទំនាក់ទំនង ការទូត និងពាណិជ្ជកម្មជាមួយនឹងហ្វូណាន។ បើតាមការអះអាងរបស់លោក ឃើញថាហ្វូណានជារដ្ឋចំណាស់ មួយនៅអាស៊ីអាគ្នេយ៍មុនពេលដែលគាត់មកដល់ទៅទៀត។

លោក ប៉ូល ប៉េល្យូត៍ថា ហ្វូណានបានកកើតជារដ្ឋនៅដើមសតវត្សទី១ ក្នុងអំឡុងឆ្នាំ៥០ នៃគ.ស.។

ចំណែកលោក ហ្សិក សឺដែស បានបញ្ជាក់ថា នគរភ្នំបានកកើតជារដ្ឋរួចស្រេចហើយ ទើបអរិយធម៌ឥណ្ឌាចូលផ្សព្វផ្សាយនៅអាស៊ីអាគ្នេយ៍ ពិសេសលើរដ្ឋហ្វូណាន។ ការទទួលថ្មីពីឥណ្ឌាដូចជារដ្ឋបាល សាសនា អក្សរ។ រីឯពាក្យ ហ្វូណានមកពីពាក្យខ្មែររឺដែលសព្វថ្ងៃក្លាយជាពាក្យភ្នំ ព្រោះស្តេចសម័យនោះមានឋានន្តរនាមថាស្តេចភ្នំ ត្រូវនឹងពាក្យខ្មែរបុរាណថា កុរុងវ្នំ ត្រូវនឹងភាសាសំស្ក្រឹតថា បវ៌តភូបាល ឬសៃលរាជ។ ដូចនេះ ឈ្មោះហ្វូណាននេះមកពីជនជាតិចិនហៅត្រាប់តាមឈ្មោះភ្នំជាភាសាខ្មែរមិនច្បាស់ទៅជា ប៊ូយូណាម ឬហ្វូណាន។

ខ្មែរ ជារដ្ឋចំណាស់មួយនៅអាស៊ីអាគ្នេយ៍ដែលចិនហៅថាហ្វូណាន ។ ប្រវត្តិវិទូបារាំងបានបកស្រាយថា«ហ្វូណាន» ត្រូវនឹងពាក្យ «ភ្នំ» ទើបអ្នកសិក្សាខ្មែរបានហៅរដ្ឋនេះថា «អាណាចក្រភ្នំ» បើតាមលោកបណ្ឌិត វង់ សុធារ៉ា បានអះអាងថា ឈ្មោះ "ហ្វូណាន" ត្រូវអានថា ហ្វូណាន។ ពាក្យ ហ្វូ ដែលចិនសរសេរនេះអាចមិនមែនជាពាក្យដើមដែលកត់ត្រាដោយលោក កាំង និង ជូយីង កាលពីសតវត្សទី៣ នោះទេ។ ពាក្យនេះគួរសរសេរពាក្យ «ហ្វូ» ដែលមានន័យថា «អ្នកមាន» ឬ «ទ្រព្យសម្បត្តិមហាសាល»។ រីឯពាក្យ «ណាន» មានន័យថា «ខាងត្បូង» ដូច្នេះ ពាក្យ«ហ្វូណាន» ជាពាក្យដែលចិនហៅសំដៅដល់ប្រទេសដែលមានភោគទ្រព្យស្ថិតនៅខាងត្បូង។ វៀតណាមបុរាណហៅខ្មែរថា «កាវមៀន / Kiao Mien» មានន័យថា «អ្នកមានខ្ពង់ខ្ពស់» ឥណ្ឌាហៅ ខ្មែរថា «សុវណ៌្ណភូមិ» ឬ «សុវណ្ណភូមិ» ដែលមានន័យថា «ដែនដីមាស»។ ម្យ៉ាងទៀត ចិនហៅឈ្មោះទីតាំងភូមិសាស្ត្រតាមទិសជាក់ស្តែងរបស់ទឹកដីខ្លួន ដូចជាស្ថាននាមជាច្រើនដែលស្ថិតនៅប៉ែកខាងត្បូងចិន តែប្រើពាក្យ «ណាន» ឬ«ណាម» ដែលមានន័យថា ខាងត្បូង ដូចជា ណានជីង យូណាន ហឺណាន ជាំងណាន ហៃណាន វៀតណាមជាដើម ដែលសុទ្ធសឹងមានទីតាំងនៅខាងត្បូង និងភាគខាងត្បូងនៃប្រទេសចិន។

**៥.២-ចាម្ប**

ទឹកដីនៃរដ្ឋចាម្បលាតសន្ធឹងចាប់ពីតំបន់ង៉ែអាន នៃប្រទេសវៀតណាមភាគខាងជើង សណ្តូកតាមបណ្តោយឆ្នេរសមុទ្រចិន រហូតមកដល់ ប៊ីញថ្វាន់ វៀតណាមភាគខាងត្បូងសព្វថ្ងៃ។ រដ្ឋចម្ប៉ាមានក្រុងធំៗបួន គឺ ក្រុងឥន្ទ្របុរៈ ក្រុងវិជ័យ ក្រុងកៅឋារៈ និងក្រុងបាណ្ឌុរង្គ។

សណ្ឋានដីរដ្ឋចាម្ប សម្បូរភ្នំសណ្តូកតាមមាត់សមុទ្រ ដីសម្បូរជីជាតិច្រើនសម្រាប់ដំណាំកសិកម្មដូចជា ស្រូវ ពោត តែ កាហ្វេ។ល។

មុនគ.ស. រដ្ឋចាម្ប ពុំទាន់កើតជារដ្ឋទេ ពួកគេរស់នៅជាកុលសម្ពន្ធតូចៗ នៅតាមជើងភ្នំ និងមាត់ទឹក ដូចខ្មែរដែរដូចជា ស្រុកអមរាវតី (យួនហៅខេត្តក្វាងណាម) ស្រុកវិជ័យ (យួនហៅប៊ិញឌិញ) ស្រុកកៅឋារៈ (យួនហៅហ្វាងរ៉ាង)...។ រដ្ឋនេះស្ថិតក្រោមការគ្រប់គ្រងរបស់ចិនរហូតមក។

លុះមកដល់ឆ្នាំ១៩២ ទើបមានមេកុលសម្ពន្ធចាម្បមួយរូប ដែលចិនហៅថា គ្រុយលានជាក្សត្រចាម្ប បានចេញតតាំងនឹងចៅហ្វាយខេត្តចិន ដែលត្រួតត្រានៅបណ្តាស្រុកទាំងនោះ ហើយរៀបចំបង្រួបបង្រួម ចាម្បឱ្យមានឯកភាពឡើង។ ក្រោយពីការផ្តាច់ខ្លួនពីចិននៅចុងសតវត្សទី២ នៃគ.ស. នគរចម្ប៉ាស្ថិតនៅខាងកើតប្រទេសកម្ពុជា គឺនៅចំភាគកណ្តាលប្រទេសវៀតណាមសព្វថ្ងៃនេះ។ ពួកចាម្បបានច្បាំងនឹងចិន ហើយក្រោយមកសង្គ្រាមនឹងយួនក្នុងអំឡុងជាច្រើនសតវត្សដើម្បីពង្រីកទឹកដីឱ្យទូលំទូលាយសម្រាប់ប្រជាជនគេ ដែលចេះតែកើនឡើងៗជាលំដាប់។ នៅឆ្នាំ៣៣៦ រាជវង្សចាម្បនាម ផាន វ៉េន បានផ្តួលរំលំរាជវង្ស គ្រុយលាន រួចឡើងសោយរាជ្យរហូតដល់ឆ្នាំ៤២០។ ក្នុងរដូវកាលនោះចាម្បបានបន្តសង្គ្រាមជាមួយចិន ដើម្បីត្រួតត្រាខេត្ត

គារឈើរ។ រាជវង្សានុវង្សពង្រឹងអំណាច និងកសាងរាជធានីឈ្មោះ ឥន្ទ្របុរៈ ព្រមទាំងកសាងប្រាសាទតាមបែប ឥណ្ឌានៅ មីសឺន ជិតក្រុង វេ៉ សព្វថ្ងៃ ដើម្បីរំលឹកដល់ព្រះសិរលិង្គនាម ព្រះភទ្រេស្វរៈ សិលាចារឹកពីរនៅត្រាខឺ ជាភាសាសំស្ក្រឹតមួយ ជាភាសាចាម្បមួយ បានបង្ហាញឧត្តមភាពក្នុងការគោរពព្រះឥសូរ។ អ្នកប្រវត្តិសាស្ត្រចិន បានកត់សម្គាល់ថាប្រទេសចម្ប៉ាជាប្រទេសដែលសម្បូរទៅដោយដើមគីប៉ឹយ មាស ស្នូកអណ្តើក សំបកខ្យង សម្រាប់ជំនួសរូបិយបណ្ណក្នុងផ្លូវពាណិជ្ជកម្ម[412]។

**៥.៣-រដ្ឋមន**

តាមប្រវត្តិសាស្ត្រ នៅលើអាស៊ីអាគ្នេយ៍ដែនដីគោកបច្ចុប្បន្ន មានរដ្ឋជាច្រើនដែលមានជនជាតិផ្សេងៗ រស់នៅ ក្នុងនោះមានជនជាតិមន ដែលជាជាតិសាសន៍មួយមានសែស្រឡាយជិតបំផុតជាមួយជនជាតិខ្មែរ។ នៅវាងដើមសតវត្សទី១ ជនជាតិមនទំនងជាបានបង្កើតរដ្ឋរបស់ខ្លួន ប៉ុន្តែ គេពុំទាន់រកឃើញឯកសារណា បញ្ជាក់ហេតុការណ៍នេះទេ។ នៅសម័យនោះ អាណាចក្រហ្វូណន មានវិសាលភាពធំធេង ហើយត្រួតត្រាលើ រដ្ឋតូចៗរួមទាំងជនជាតិមនផងដែរ។

នៅសតវត្សទី៦ ដោយសារការតស៊ូរបស់ខ្លួន ប្រជាជនតំបន់កណ្តាល និងតំបន់ខាងត្បូង ទន្លេចៅព្រះ យ៉ាត្រង់ប្រទេសថៃសព្វថ្ងៃ បានរើបម្រាស់រួចពីការត្រួតត្រារបស់អាណាចក្រហ្វូណាន ហើយបង្កើតជារដ្ឋ អធិបតេយ្យមួយ។ នៅសតវត្សទី៧ រដ្ឋទ្វារវតី (Dvaravatti) របស់ពួកមនបានបង្រួបបង្រួមរដ្ឋតូចៗ មួយចំនួន ហើយបង្កើតជារដ្ឋឯករាជ្យមួយ។

នៅពាក់កណ្តាលទី២ នៃស.វ.ទី៧ ជនជាតិមននៅតំបន់ខាងជើងបង្កើតរដ្ឋមួយផ្សេងទៀតគឺ ហរិបុញ្ជ័យ (Haripunjaya)។ តាមរយៈកំណាយនៅតំបន់មួយចំនួន អ្នកបុរាណវិទ្យាទាំងឡាយបាន រកឃើញកេរដំណែល អរិយធម៌របស់រដ្ឋទាំងពីរនេះ រដ្ឋមនទាំងឡាយទទួលឥទ្ធិពលពុទ្ធសាសនា ហើយធ្វើ ទំនាក់ទំនងការទូតជាមួយ ប្រទេសចិន។

នៅស.វ.ទី១ មនបានបង្កើតរាជាណាចក្រពើគូ (Pegu) តាមដងទន្លេឥរ៉ាវតីខាងក្រោម និងរាជាណា ចក្រថាទង(Thaton) តាមដងទន្លេស៊ីតង់ភាគខាងក្រោម។ ក្នុងអំឡុងពេលនោះ រដ្ឋថ្មីមួយ ត្រូវបានលេចឡើង គឺ រាជាណាចក្រហង្សាវតី (Hangsavati) គ្រប់គ្រងដោយបងប្អូនពីរនាក់ឈ្មោះ សមល និងវិមល។ រដ្ឋនេះស្ថិត នៅខាងត្បូងប្រទេសភូមា ចន្លោះទន្លេឥរ៉ាវតី និងទន្លេសាលីន[413]។

មានរបាយការណ៍ចិនមួយអំពីហ្វូណានដែលនិយាយថា មានប្រទេសមួយឈ្មោះ **ទុន ស៊ុន** ដែលមានទី ក្រុង៥ និងព្រះរាជា៥ព្រះអង្គ ហើយភាសាមានភាពខុសគ្នាបន្តិចបន្តួចពីភាសារបស់ហ្វូណន។ ឈ្មោះ ទុន ស៊ុន នោះមានន័យថា "**ទីក្រុងប្រាំ**" ជាភាសាមន ហើយនោះគឺជាភស្តុតាងលើកដំបូងអំពីប្រទេសមន។ ទុន ស៊ុន ប្រហែលស្ថិតនៅផ្នែកខាងជើងនៃឧបទ្វីបម៉ាឡេ ដែលឥឡូវនេះមួយផ្នែកនៅប្រទេសថៃ និងមួយផ្នែក ទៀតនៅប្រទេសភូមា។

[412] ក្រសួងអប់រំ យុវជន និងកីឡា, *សិក្សាសង្គមថ្នាក់ទី៨*, គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, ឆ្នាំ២០១៥, ទំព័រ១៣១។

[413] ក្រសួងអប់រំ យុវជន និងកីឡា, *សិក្សាសង្គមថ្នាក់ទី៧*, គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, ឆ្នាំ២០១៥, ទំព័រ១៤៧។

មានរបាយការណ៍របស់ចិនមួយទៀត ដែលបានសរសេរដោយព្រះសង្ឃចិនមួយអង្គដែលបានសិក្សានៅក្នុងប្រទេសឥណ្ឌា នៅសតវត្សទី៧និយាយថានៅខាងកើតប្រទេសឥណ្ឌា គឺ**ទីក្រុងស្រីក្សេត្រ**(ភូមាកណ្ដាល) បន្ទាប់មក **ទ្វារវតី**(ថៃកណ្ដាល) បន្ទាប់មក **ឥសានបុរៈ** (សំបូរព្រៃគុកនៅកម្ពុជា) និងបន្ទាប់មកចាម្ប[414]។

## ៥.៤-វៀតណាម

វប្បធម៌សម័យដុងសឺន មានមកពីប៉ុន្មានសតវត្សមុនគ.ស. ដល់ក្រោយគ្រិស្តសករាជ។ ស្ថានីយដុង សឺន ល្បីល្បាញខាងសំរឹទ្ធ ឧបករណ៍ប្រើប្រាស់ និងស្គរធំៗ។ ឆាកមានរូបទូកដែលគេគូរនៅលើស្គរ។ ឯកសារមុនប្រវត្តិសាស្ត្ររបស់ចិននិយាយអំពីសម័យដុន សឺន ហៅវាថា **ឡាច**(ឡូ)**វៀត**។

យោងទៅលើប្រវត្តិប្រពៃណីរបស់វៀតណាមមានអាណាចក្រមួយឈ្មោះថា **វ៉ាន់-ឡាច** មានកំណើតពីសតវត្សទី៧មុនគ.ស. ដល់សតវត្សទី១នៃគ.ស. ហើយរាជវង្សស្ដេចដែលគ្រប់គ្រងអំណាចឈ្មោះ **ហុង**។ រឿងនេះត្រូវបានគេយល់ស្របជាទូទៅថា ជាព័ត៌មានលើកដំបូងអំពីវៀតណាមសម័យបុរាណ។ ទោះបីភាសាវិទូខ្លះនិយាយថា នៅពេលនោះ ថៃសំខាន់ជាងនៅតំបន់នោះក៏ដោយ។

នៅសតវត្សទី៣ ការឈ្លានពានរបស់ចិន ដែលមានរដ្ឋាភិបាលធូរលុងនៅចាវ-ជី។ បន្ទាប់មក ក្រោយពីសន្តតិវង្សហានដួលរលំនៅសតវត្សទី១ នៃគ.ស. មានការធ្វើអន្តោប្រវេសន៍ចិនដ៏ធំទៅចាវ-ជី។

មានឥទ្ធិពលឥណ្ឌានៅចាវ-ជី តាមរយៈលីន-យី និងចាម្ប។ ចាវ-ជី គឺជាមជ្ឈមណ្ឌលមួយនៃឥទ្ធិពលព្រះពុទ្ធសាសនានៅក្នុងប្រទេសចិន រួមជាមួយនឹងចរន្តផ្សេងទៀតនៃឥទ្ធិពលពុទ្ធសាសនាឥណ្ឌាមកតាមដីគោកពីប្រទេសឥណ្ឌា។

គិតពីទស្សនៈនេះចាវ-ជី ត្រូវបានទទួលឥណ្ឌានីយកម្មខ្លះនៅសតវត្សទី១-៣ នៃគ.ស.។ ពុទ្ធបដិមាសម័យនោះ នៅវៀតណាមខាងជើង និងនៅប្រទេសចិនខាងត្បូងមើលទៅដូចរូបបដិមារបស់កោះជ្វា។

ក្នុងអំឡុងសតវត្សដំបូងនេះ មានវណ្ណៈកាន់អំណាចថ្មីមួយបានរីកចម្រើនចេញពីជនអន្តោប្រវេសន៍របស់ចិន ដែលលាយចម្រុះគ្នា និងមេកន្ទ្រាញក្នុងស្រុក។

មានម្នាក់ក្នុងចំណោមអ្នកកាន់អំណាចប្រភេទថ្មីឈ្មោះ លី បុន បានសាកល្បងស្ថាបនាអាណាចក្រផ្ទាល់របស់គេក្នុងឆ្នាំ៥៤០ ដែលគេឱ្យឈ្មោះខ្លួនគេថា «**មហារាជ ណាម-វៀត**» ហើយគាត់ និងកូនប្រុសរបស់គាត់បានកាន់អំណាចរហូតដល់ឆ្នាំ៦០២។ គេត្រូវទទួលយកចិននីយកម្ម ប៉ុន្តែមានឯករាជ្យខាងនយោបាយ។

-បន្ទាប់មក មានការឈ្លានពានរបស់ចិនមួយទៀត ដោយសន្តតិវង្សតាង ជាសន្តតិវង្សដ៏ធំរបស់ចិនក្រោយឆ្នាំ៦១៨។ ចិនបានបង្កើតឈ្មោះថ្មីមួយ «អាណាព្យាបាលអាន-ណាន(ម)» ក្នុងសតវត្សទី៧។

-អាណ្ណាមជាកំពង់ផែមួយសំខាន់ណាស់ និងជាកន្លែងផែកប៉ាល់សំខាន់សម្រាប់លោកសង្ឃចិននិមន្តទៅកាន់អាស៊ីអាគ្នេយ៍ និងឥណ្ឌា។

-ក្នុងសតវត្សទី៩ នៅពេលដែលរដ្ឋតាងបានចុះទន់ខ្សោយ មានអ្នកដឹកនាំថ្មីកាន់តែមានអំណាច។ អាណ្ណាមបានបញ្ចប់ក្នុងឆ្នាំ៨៦៦ ហើយអ្នកដឹកនាំក្នុងស្រុកថ្មីបានប្រកាសឯករាជ្យនាឆ្នាំ៩០៥។ ក្នុងឆ្នាំ៩៦៦ ស្ដេចត្រាញ់បានយកគោរម្រងារជាមហារាជ ដាយកូវៀត។ ប៉ុន្តែ ចិននៅតែហៅស្ដេចត្រាញ់នោះថា «**ស្ដេចត្រាញ់ខេត្តចាវ-ជី**» ។

[414] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ជ.ឯ.ម., ទំព័រ៥១។

**កំណត់សម្គាល់** ៖ ប្រភពលាយលក្ខណ៍អក្សរស្តីពីវៀតណាម សុទ្ធតែបានសរសេរឡើងជាភាសាចិន ទុកជាវាបានសរសេរដោយជនជាតិវៀតណាមក៏ដោយ រហូតដល់សតវត្សទី១២ ឯកសារដែលបានសរសេរជាភាសាវៀតណាម ហើយនៅគង់វង្សលើកដំបូងត្រូវបានគេសរសេរជាតួអក្សរចិនតាំងពីពេលនោះមកម្ល៉េះ។ អ្នកស្រុក ប្រហែលជាបានរស់នៅលាយចម្រុះគ្នាជាមួយជនជាតិមន-ខ្មែរ (រួមមានវៀតណាម)ជនជាតិ មន-ខ្មែរដទៃទៀត និងថៃ[415]។

## ៥.៥-ឥណ្ឌូណេស៊ី

នៅក្នុងសម័យបុរេប្រវត្តិដែលបាននិយាយរួចមកហើយនោះ បណ្ដាកោះឥណ្ឌូណេស៊ី(លើកលែង ញូវហ្គីណេ) ត្រូវបានអ្នកនិយាយភាសាអូស្ត្រូនេស៊ីតាំងទីលំនៅ ដែលចាប់ផ្ដើមពី២០០០-៣០០០ឆ្នាំមុន បានសាយភាយពីឆ្នេរសមុទ្រចិនភាគអាគ្នេយ៍ទៅតៃវ៉ាន់ ហ្វីលីពីន កោះប៉ូលីនេស៊ីនៃមហាសមុទ្រប៉ាស៊ីហ្វិក ម៉ាដាហ្គាស្កា និងឥណ្ឌូណេស៊ី។ ពួកខ្លះជាជនជាតិចាម្ប បានទៅពីបរំណេអូ ដល់ឆ្នេរសមុទ្រវៀតណាម ប្រហែលនៅសតវត្សទី១នៃគ.ស. ហើយក្រោយមកទៀត ម៉ាឡេបានផ្លាស់ប្ដូរប្រហែលពីស៊ូម៉ាត្រាទៅឧបទ្វីបម៉ាឡេ។

ការសាយភាយនៃភាសាអូស្ត្រូណេស៊ីនេះ ជាភស្តុតាងនៃកម្រិតបច្ចេកវិទ្យាខ្ពស់តាមសមុទ្ទ ទាំងសំណង់នាវា និងនាវាចរណ៍ក្នុងចំណោមប្រជាជនទាំងអស់នេះមុនពេល ដែលមានទំនាក់ទំនងជាមួយនឹងឥណ្ឌា។ ប្រសិនបើគេអាចធ្វើដំណើរតាមសំពៅទៅមហាសមុទ្ទប៉ាស៊ីហ្វិក និងទៅម៉ាដាហ្គាស្កាគេពិតជាអាចធ្វើដំណើរទៅឥណ្ឌាបាន ហើយគេប្រហែលជាអ្នកនាំមុខក្នុងការទាក់ទងនឹងឥណ្ឌាដែលបានផ្ដល់ឱ្យសមាសធាតុនៃវប្បធម៌ឥណ្ឌាទៅដល់អាស៊ីអាគ្នេយ៍។ នៅក្នុងការពន្យល់របស់គាត់អំពីការរីកចម្រើននៃពាណិជ្ជកម្មឥណ្ឌូណេស៊ីដំបូង លោក Wolters បានទទួលស្គាល់ថា ឥណ្ឌូណេស៊ីមានទំនាក់ទំនងតាមសមុទ្ទជាមួយឥណ្ឌានៅមុនពេលដែលគេចាប់ផ្ដើមមានពាណិជ្ជកម្ម ជាមួយចិន។

រដ្ឋពិតប្រាកដដំបូងគេនៅហ្សាវ៉ា ត្រូវបានគេស្គាល់ពីរបាយការណ៍ចិនប៉ុណ្ណោះ មិនមែនមកពីកំណត់ហេតុក្នុងស្រុកទេ។ នៅក្នុងរបាយការណ៍ចិនលើកដំបូងអំពីឥណ្ឌូណេស៊ី នៅសតវត្សទី៥-៦ មានឈ្មោះច្រើនដែលយើងមិនអាចបញ្ជាក់បានទាំងស្រុងទេនៅពេលសព្វថ្ងៃនេះ។ មានកាន-តូ-លី (ប្រហែលជាមាននៅស៊ូម៉ាត្រា) កូ-យីង(កោះជ្វា ឬស៊ូម៉ាត្រា) ហូ-លូ-តាន (ប្រហែលជាកោះជ្វា)ហូ-លីង (កោះជ្វា) ឡាង-យ៉ាស៊ី (ឧបទ្វីបម៉ាឡេ នៅលង្កាសូកា ម៉ាឡាយូ) ជី-ទូ(ឧបទ្វីបម៉ាឡេ) ម៉ូ-ឡូ-យូ(ម៉ាឡាយូ ប៉ុន្តែសម័យនោះនៅស៊ូម៉ាត្រា)។

នៅប្រហែលឆ្នាំ៤៦០ ចិនបានស្គាល់ទីកន្លែងមួយនៅកោះជ្វាឈ្មោះ ហូ-លីង ហើយបេសកជនមកពីហូ-លីង បានធ្វើដំណើរទៅកាន់ប្រទេសចិន រហូតដល់ឆ្នាំ ៨៤០។ បន្ទាប់មកឈ្មោះចិនសម្រាប់ហៅកោះជ្វាបានប្ដូរទៅជា "ហ្សាវ៉ា" (ស៊ី-ប៉ូ)។ ទីកន្លែងរបស់វាមិនត្រូវគេបានស្គាល់ទេ។ ចិនបានរៀបរាប់ពី ហូ-លីង កោះជ្វា ថាជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយ ដែលជាកន្លែងឈប់សំចតតាមផ្លូវទៅកាន់ប្រទេសឥណ្ឌា ហើយមជ្ឈមណ្ឌលមួយសម្រាប់ការសិក្សាលទ្ធិព្រះពុទ្ធសាសនា។ ស្ថាបត្យកម្មអស្ចារ្យដំបូងគេនៅកោះជ្វា គឺកសាងនៅចុងសតវត្សទី៩ មានប្រាសាទបូរបួឌួរ(សំណង់ខាងពុទ្ធសាសនា) ប្រាមបាណាន់ (សំណង់ខាងព្រហ្មញ្ញសាសនា) និងសំណង់អគារដទៃទៀតសម្រាប់បម្រើដល់សាសនាទាំងពីរ។

[415] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ដ.ឯ.ម., ទំព័រ៤៧។

នៅប្រហែលចុងសតវត្សទី៧ ចិនបានសរសេរអំពីទីកន្លែងតែពីរគត់ មួយឈ្មោះ ហូ-លីង នៅកោះជ្វា តាមសមុទ្ទ និងទាំងមជ្ឈមណ្ឌលនៃការសិក្សាព្រះនិងមួយទៀតឈ្មោះ ស៊ី-លី-ហ្វូ-ជី (ស្រីវិជ័យ) នៅកោះស៊ូម៉ាត្រា។ ស្រីវិជ័យ គឺល្បីល្បាញទាំងខាងពាណិជ្ជកម្ម ពុទ្ធសាសនា និងភាសាសំស្ក្រឹត។ តាមការប្រមើលមើលទៅ ស៊ូម៉ាត្រាបានមានទំនាក់ទំនងជាមួយប្រទេសឥណ្ឌាអស់រយៈពេលដ៏យូរមកហើយ នៅមុនពេលដែលមានការទាក់ទងជាមួយប្រទេសចិន[416]។

នៅក្នុងសតវត្សទី៥-៦ ផ្លូវពាណិជ្ជកម្មតាមសមុទ្ទថ្មីមួយបានរីកចម្រើនពីឥណ្ឌូណេស៊ីទៅចិនដោយមិនឆ្លងកាត់តាមហ្វូណន។ រឿងនេះគឺដោយសារឥណ្ឌូណេស៊ីមានទំនាក់ទំនងល្អជាមួយឥណ្ឌា ហើយដោយសារផលិតផលខ្លះដែលចិនចង់បានពីប្រទេសឥណ្ឌា ក៏អាចត្រូវបានគេរកបាននៅក្នុងប្រទេសឥណ្ឌូណេស៊ីដែរ ហើយប្រជាជនឥណ្ឌូណេស៊ីបានទាញយកអត្ថប្រយោជន៍ពីរឿងនេះ ដើម្បីបើកផ្លូវថ្មីមួយជំនួសប្រទេសហ្វូណនក្នុងទំនាក់ទំនងជាមួយចិន។

**សំណួរត្រិះរិះ**

១-តើអាស៊ីអាគ្នេយ៍មានន័យដូចម្ដេច?

២-តើនៅតំបន់អាស៊ីអាគ្នេយ៍មានអម្បូរភាសាអ្វីខ្លះ?

៣-ចូររៀបរាប់ពីការតាំងទីរបស់ប្រជាជនដំបូងៗនៃតំបន់អាស៊ីអាគ្នេយ៍?

៤-ចូររៀបរាប់ពីកំណើតរដ្ឋនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

៥-តើបណ្ដារដ្ឋនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទទួលឥទ្ធិពលអ្វីខ្លះពីឥណ្ឌា និងចិន?

---

[416] ម៉ាយឃើល វិកឃើរី, *ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់*, ជ.ឯ.ម., ទំព័រ៥៣។

# មេរៀនទី២ ការពង្រីកអំណាចរបស់ពួកអឺរ៉ុប មកលើបណ្តារដ្ឋអាស៊ីអាគ្នេយ៍

## ១-ការដាក់អាណានិគមរបស់ពួកអឺរ៉ុបនៅអាស៊ីអាគ្នេយ៍

ពួកអឺរ៉ុប បានឈានជើងចូលមកក្នុងតំបន់អាស៊ីអាគ្នេយ៍ តាំងពីដើមសតវត្សទី១៦មកម្ល៉េះ។ វត្តមានរបស់ជនជាតិអឺរ៉ុបនានា នៅក្នុងតំបន់នេះកាលពីគ្រាដំបូងគឺក្នុងគោលបំណងធ្វើពាណិជ្ជកម្ម និងការផ្សព្វផ្សាយសាសនាគ្រិស្តជាសំខាន់ តែការផ្សព្វផ្សាយសាសនាក៏ពិបាកផងដែរក្នុងការផ្តាច់ចេញពីសកម្មភាពពាណិជ្ជកម្មគ្រឿងទេស។ ប៉ុន្តែក្រោយមកពួកអឺរ៉ុបបានប្រែក្លាយតំបន់ទាំងឡាយនៅ អាស៊ីអាគ្នេយ៍ទៅជាដែនដីអាណានិគមរបស់ខ្លួន។ គោលបំណងសំខាន់ៗនៃនយោបាយអាណានិគមរួមមាន ការស្វែងរកធនធានកម្រៗ ឬវត្ថុធាតុដើម ការរកទីផ្សារសម្រាប់ផលិតផលឧស្សាហកម្ម ការតាំងមូលដ្ឋានទ័ព (ពង្រឹងសន្តិសុខជាតិបន្ថែម) និងការពង្រីកកិត្យានុភាពជាតិរបស់ខ្លួន(សាសនា ភាសា វប្បធម៌...)។

ក្នុងចំណោមមហាអំណាចអាណានិគមអឺរ៉ុបទាំងនោះ យើងឃើញមាន ចក្រភពអង់គ្លេស បារាំង ហូឡង់ អេស្ប៉ាញ ព័រទុយហ្គាល់ និង ក្រោយមកអាម៉េរិកបានចូលមកជំនួសកន្លែងរបស់អេស្ប៉ាញ នៅប្រទេសហ្វីលីពីន។

នៅក្នុងសម័យនោះយើងឃើញថា ចក្រភពអង់គ្លេសបានតាំងអាណានិគមរបស់ខ្លួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍លើប្រទេសភូមា ម៉ាឡេស៊ី និងពង្រីកឥទ្ធិពលយ៉ាងខ្លាំងទៅលើប្រទេសសៀម។ ចំណែកប្រទេសបារាំងបានតាំងអំណាចរបស់ខ្លួនលើទឹកដីកូសាំងស៊ីន អាណ្ណាម តុងកឹង កម្ពុជា និងឡាវ។ ចំពោះប្រទេស ហូឡង់បានគ្រប់គ្រងកម្រងកោះដ៏ច្រើន ដែលក្រោយមកបានរួបរួមជាប្រទេសឥណ្ឌូណេស៊ី។ ប្រទេសហ្វីលីពីន ដើមឡើយស្ថិតនៅក្រោមអាណានិគមរបស់ប្រទេសអេស្ប៉ាញ តែក្រោយមកត្រូវបានប្រគល់ទៅឱ្យសហរដ្ឋអាម៉េរិកក្នុងឆ្នាំ១៨៩៨។

## ២-អាណានិគមរបស់អង់គ្លេស

### ២.១-ប្រទេសភូមា

រហូតដល់ចុងសតវត្សទី១៨ ភូមាមិនទាន់ក្លាយជាគោលដៅសំខាន់នៃការពង្រីកអំណាចរបស់អឺរ៉ុបនៅឡើយទេ។ ដោយរងនូវផលប៉ះពាល់ពីបញ្ហាពុំរ៉ៃនៃកង្វះ ឯកភាពផ្ទៃកជាតិសាសន៍រាប់សតវត្សមកហើយ នៅពាក់កណ្តាលទី២នៃសតវត្សទី១៨ ភូមាហាក់ដូចជាមានជីវិតថ្មីក្រោមការដឹកនាំដ៏អង់អាចនៃរាជវង្សថ្មីមួយឈ្មោះថា **រាជវង្សកុនបោង**។ ក្រោមការដឹកនាំរបស់អ្នកស្ថាបនារាជវង្សនេះ គឺព្រះចៅ **អាឡុងប៉ាយ៉ា** (សោយរាជ្យ គ.ស.១៧៥២-១៧៦០) និងព្រះរាជាក្រោយៗ រៀងមក ពិសេសគឺ ព្រះចៅ **បូ-ដប៉ាយ៉ា** (សោយរាជ្យ គ.ស.១៧៨២-១៨១៩) ភូមាបានសម្រេចនូវឯកភាពផ្ទៃក្នុងមួយកម្រិត និងមានសមត្ថភាពកាត់បន្ថយនូវការគំរាមកំហែងពីសំណាក់ប្រទេសជិតខាងខ្លះ។ ទោះបីជាយ៉ាងណា ជោគជ័យខ្លះៗ នៃផ្នែកនេះ គ្រាន់តែបានជួយដោះស្រាយនូវបញ្ហាមួយចំនួន ដែលរដ្ឋភូមាមានប៉ុណ្ណោះ។ បញ្ហាដទៃទៀតកើតឡើង ដោយការពង្រីកអំណាចបន្តិចម្តងៗ របស់មហាអំណាចអង់គ្លេស ទៅកាន់បណ្តាភូមិភាគនៅឥណ្ឌាភាគឦសាន ដែលពីមុនមក ភូមាចាត់ទុកថា ជាភូមិភាគដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្លួន។

ព្រះរាជាភូមាកាលពីសតវត្សទី១៨ ចាត់ទុកដែនអាសាំង(អាស្សាម) មណីបុរៈ និងអារ៉ាកាំង ដែលស្ថិតនៅភាគខាងលិចនៃប្រទេសភូមាបច្ចុប្បន្នថា ជាតំបន់ព្រំដែនដែលស្ថិតក្រោមការត្រួតត្រារបស់ខ្លួន។ ប៉ុន្តែភូមាជាទូទៅ ពុំបានព្យាយាមរក្សានូវការគ្រប់គ្រងឱ្យបានតឹងរ៉ឹងលើដែនដីទាំងនេះទេ។ អ្វីដែលគេរំពឹងទុកនោះគឺថា ភូមាគួរមានអំណាចខ្លាំងជាងគេនៅទីនេះ ហើយភូមានឹងមិនអនុគ្រោះដល់ជនណា ដែលមានបំណងចង់តតាំងនឹងអំណាចនេះឡើយ។ ទស្សនៈនេះផ្ទុយស្រឡះពីទស្សនៈរបស់ក្រុមហ៊ុនឥណ្ឌាខាងកើតរបស់អង់គ្លេស

ដែលបានពង្រីកអំណាចលើដែនដីដ៏ធំទូលាយនៅឥណ្ឌារួចទៅហើយ។ ទស្សនៈដែលគិតពីតំបន់ ព្រំដែន តែគ្មានបន្ទាត់ព្រំដែនកំណត់ច្បាស់លាស់ ជាការចម្លែកមួយចំពោះអង់គ្លេស។ អ្វីដែលចម្លែកចំពោះពួកបស្ចឹមប្រទេសដូចគ្នាដែរ នោះគឺរចនាសម្ពន្ធនយោបាយ ដែលអនុញ្ញាតឱ្យព្រះរាជាភូមារក្សាបាននូវអំណាចខ្លាំងជាងគេ លើភូមិភាគដែលនៅចន្លោះឥណ្ឌានិងភូមា ប៉ុន្តែទន្ទឹមនឹងនោះ ភូមាបែរជាពុំទទួលខុសត្រូវចំពោះការប្រព្រឹត្តទៅនៃជីវភាពប្រចាំថ្ងៃរបស់ប្រជាជននៅភូមិភាគទាំងនេះទៅវិញ ប្រសិនបើមិនមានប្រយោជន៍ដល់ពួកគេទេ។ ការអះអាងរបស់ពួកអង់គ្លេសបន្តទៀតថា ប្រសិនបើមានការវាយឆ្មក់ពីអាសាំង មណីបុរៈ ឬអារ៉ាកាំង វាយចូលទៅក្នុងដែនដីត្រួតត្រាដោយក្រុមហ៊ុនឥណ្ឌាខាងកើត រដ្ឋាភិបាលភូមាត្រូវទទួលខុសត្រូវ និងចាត់វិធានការទប់ស្កាត់មិនឱ្យ «អាណាប្រជារាស្ត្រ» របស់ខ្លួនមានអាកប្បកិរិយាដូច្នេះឡើយ។

ភាគីទាំងពីរពុំមានគំនិតស្របគ្នាទេ។ លើសពីនេះទៀត បញ្ហាតំបន់ព្រំដែនមិនមែនជាបញ្ហាតែមួយក្នុងជម្លោះរវាងភូមានិងអង់គ្លេសនោះទេ។ ចំណុចរំខានដទៃទៀត ពាក់ព័ន្ធនឹងទស្សនៈខុសគ្នាលើសិទ្ធិរបស់អ្នកជំនួញអង់គ្លេស (ដែលសម្រាប់ភូមា ពុំអាចផ្តល់ឱ្យបាននោះ) និងលើកម្រិតត្រឹមត្រូវនៃការដោះដូរផ្នែកការទូតបានធ្វើឱ្យទំនាក់ទំនងប្រេះស្រាំបន្តិចម្តងៗ និងការនាំទៅរកការសម្រេចព្រះទ័យដែលប្រកបដោយមហន្តរាយរបស់ព្រះរាជាភូមា។ ព្រះចៅបាកយីដ (គ.ស.១៨១៩-១៨៣៧) បានតតាំងនឹងពួកអង់គ្លេស ដោយឈ្លានពានដែនបេងហ្គាល់។

លទ្ធផលដែលប្រកបដោយសោកនាដកម្មសម្រាប់ភូមាគឺថា អង់គ្លេសបានពង្រឹងអំណាចរបស់គេមកក្នុងប្រទេសភូមាផ្នែកខាងក្រោម គ្រប់គ្រងក្រុងយ៉ាងគុង (រ៉ង់ហ្គូន) ហើយក្រោយមក ក្នុងឆ្នាំ១៨២៦ បង្ខំឱ្យភូមាទទួលយកនូវសន្ធិសញ្ញាយ៉ាន់ដាបូ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនឥណ្ឌាខាងកើតត្រួតត្រាដែនអារ៉ាកាំង និងតេណាសារិង ។

ក្នុងរយៈពេលជាង២០ឆ្នាំ ការពង្រីកអំណាចរបស់អង់គ្លេសនៅមានកម្រិត។ ចំណែកនៅរាជធានី អាវ៉ារបស់ភូមាវិញ ការយកចិត្តទុកដាក់លើនយោបាយផ្ទៃក្នុង មានសារៈសំខាន់ច្រើនជាងការយកចិត្តទុកដាក់លើវត្តមានរបស់អង់គ្លេសនៅអារ៉ាកាំង និងតេណាសារិង ដែលមានភាពរំខានក៏ពិតមែន ក៏ភូមានៅអាចទ្រាំទ្រ បាន។ ជាថ្មីម្តងទៀត គំនិតផ្ទុយគ្នាទាំងស្រុង អំពីរបៀបរបបដឹកនាំរដ្ឋាភិបាលនិងការធ្វើពាណិជ្ជកម្ម បាននាំទៅរកការប្រឈមមុខដាក់គ្នារវាងភូមានិងអង់គ្លេស ។

ការវិវត្តនៅយ៉ាងគុង កាលពីដើមទសវត្សរ៍ឆ្នាំ១៨៥០ និងនៅក្វាងទុង (ចិន) ក្នុងឆ្នាំ១៨៣៩-១៨៤២ មានភាពដូចគ្នាយ៉ាងខ្លាំង គឺចំពេលដែលចក្រកពអង់គ្លេសប្រយុទ្ធក្នុងសង្គ្រាមអាភៀនលើកទី១។ មន្ត្រីភូមានៅយ៉ាងគុង អនុញ្ញាតឱ្យពាណិជ្ជករអង់គ្លេសធ្វើជំនួញ ប៉ុន្តែពួកគេក៏ស្វែងរកភាពមានបានផ្ទាល់ខ្លួនតាមរយៈការធ្វើទុកបុកម្នេញលើពាណិជ្ជករបរទេសដែរ។ មន្ត្រីភូមាជឿថា ការប្រព្រឹត្តបែបនេះ ជាការលើកតម្កើងនូវកិត្យានុភាពរបស់ភូមាព្រោះថា ការប្រព្រឹត្តនេះជាតឹកតាងនៃអំណាចអធិបតេយ្យរបស់ខ្លួន ដែលគេមិនអាចឱ្យប៉ះពាល់បាន។ ការវិនិច្ឆ័យរបស់ពួកគេខុសស្រឡះ និងមានគ្រោះថ្នាក់យ៉ាងខ្លាំង ដោយហេតុថាពួកអង់គ្លេសនៅឥណ្ឌាចាត់ទុកព្រឹត្តិការណ៍នៅភូមាថា ជាការសាកល្បងនូវកម្លាំង ដែលកម្លាំងនេះមានសារៈសំខាន់សម្រាប់តួនាទីរបស់គេនៅប៉ែកបូព៌ាទាំងមូល។ កម្លាំងយោធាអង់គ្លេស បានបើកការវាយប្រហារក្នុងសង្គ្រាមលោកលើកទី២ ទោះជានៅពេលដំបូង គ្មានការអនុញ្ញាតពីរដ្ឋាភិបាលអង់គ្លេស។ តែក្រោយមក ក៏មានការយល់ព្រមពីទីក្រុងឡុងដ៍។ ការវាយប្រហារនេះ បានធ្វើឱ្យអង់គ្លេសទទួលបានការត្រួតត្រាលើភូមាភាគ ខាងក្រោម ដែលជាភូមិភាគមួយមានសក្តានុពលខ្ពស់ផ្នែកកសិកម្មនិងឈើ។

ជាថ្មីម្តងទៀត ការពង្រីកអំណាចរបស់អង់គ្លេស ក៏មានការឈប់សម្រាកមួយរយៈដែរ។ ដល់ឆ្នាំ១៨៥៣ ពេលដែលបានស្ថាបនា នូវអំណាចរបស់ខ្លួននៅភូមាភាគខាងក្រោមរួចរាល់ហើយ ពួកអង់គ្លេសរីករាយរង់ចាំបន្តទៀត។ ចំណែករដ្ឋាភិបាលភូមាយល់ឃើញថា ខ្លួនពុំអាចកៀងគរកម្លាំងយោធាបាន គ្រប់គ្រាន់ ដើម្បីបណ្តេញពួកអង់គ្លេសបានឡើយ ឬសូម្បីតែបង្ហាញនូវសាមគ្គីភាពខាងការទូត ក៏គ្មានដែរ។ នេះក៏ដោយសារការប្រកួតប្រជែងផ្ទៃក្នុងដ៏រ៉ាំរ៉ៃ នៅតែបន្តកើតមាន ទោះក្នុងខណៈដែលមានគ្រោះថ្នាក់ខាងការទូតដូច្នេះក៏ដោយ។ មកដល់ទសវត្សរ៍ឆ្នាំ១៨៨០ ភូមាមានសារៈសំខាន់ណាស់ចំពោះចក្រភពអង់គ្លេស មិនត្រឹមតែជាប្រភពភោគទ្រព្យដែលមានសក្តានុពលប៉ុណ្ណោះទេ តែក៏ជាធាតុមួយក្នុងការរកដែនអាណានិគមបន្ថែមរបស់អង់គ្លេសនៅអាស៊ីដើម្បីប្រកួតប្រជែងជាមួយបារាំង។ គេចង់ដឹងថា តើរាជវាំងភូមា ព្រះរាជ វង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីភូមា បានជ្រាបពីបញ្ហានេះច្រើនប៉ុនណានោះទេ។ មន្ត្រីមួយចំនួននៅតែមើលឃើញថា វត្តមានរបស់អ្នកជំនួញអង់គ្លេស ជាការផ្តល់នូវ ឱកាសសម្រាប់ភាពមានបានរបស់គេ និងសម្រាប់ឱ្យគេមើលងាយមើលថោកលើជនបរទេស។ សម្រាប់មន្ត្រីដទៃទៀតនៅរាជវាំងម៉ាន់ដាលេបញ្ហាពិធីការជារឿយៗ សំខាន់ជាងបញ្ហាអំណាច (ទោះជាទាំងពួកអង់គ្លេស ទាំងពួកភូមាបានផ្តល់ការយកចិត្តទុកដាក់ច្រើនលើសំណួរថា តើជនបរទេសគួរតែពាក់ស្បែកជើង ឬអត់ពេលចូលគាល់ព្រះរាជា)។ បញ្ហាច្រើនបានកើតឡើងយ៉ាងតក់ក្រហល់ក្នុងឆ្នាំ១៨៨៥ ពេលដែលរដ្ឋាភិបាលភូមានៅម៉ាន់ដាលេ វិនិច្ឆ័យខុសអំពីកម្លាំងនៃការតាំងចិត្តរបស់អង់គ្លេស ដើម្បីគ្រប់គ្រងអំណាចនៅភូមា និងដើម្បីធានាថា ផលប្រយោជន៍ខាងពាណិជ្ជកម្មរបស់ពួកគេ ឱ្យមានប្រៀបលើជំនួញរបស់បារាំង។ ព្រះរាជាភូមាព្រះនាម ធី-ប បានបញ្ចប់នូវជោគវាសនារបស់ប្រទេសនេះ ដោយបដិសេធនូវឱសានវាទរបស់អង់គ្លេស ដែលជាហេតុធ្វើឱ្យទ័ពអង់គ្លេសចាប់ផ្តើមធ្វើសង្គ្រាមលើភូមា ជាលើកទី៣ ក្នុងខែវិច្ឆិកា ឆ្នាំ១៨៨៥។

មកដល់ដើមឆ្នាំ១៨៨៦ ចក្រភពអង់គ្លេសបានកាន់កាប់ម៉ាន់ដាលេ និងប្រកាសដាក់ការគ្រប់គ្រងលើភូមិភាគដទៃទៀតក្នុងប្រទេសភូមា ដែលពួកគេពុំបានគ្រប់គ្រងពីមុនមក។ ទោះបីជាក្នុងរយៈពេលប្រមានបីបួនឆ្នាំបន្ទាប់មក មានការប្រយុទ្ធដ៏តានតឹងហើយជារឿយៗ មានការដាក់ទណ្ឌកម្មយ៉ាងសាហាវឃោរឃៅចំពោះអ្នកដែលអង់គ្លេសចាប់ខ្លួនបានក៏ដោយ ក៏«ដែនអាណានិគមភូមារបស់អង់គ្លេស» បានលេចជារូបរាងឡើងហើយព្រំដែនខាងលិចរវាងភូមានិងឥណ្ឌា ក៏ត្រូវបានកំណត់ដែរ។ តើមានអ្វីនឹងកើតមានឡើង ប្រសិនបើថ្នាក់ដឹកនាំភូមា បានយល់ច្រើនជាងនេះអំពីចរិតនៃអ្វីដែលគេបានប្រឈម? សំណួរនេះគេពុំអាចឆ្លើយបានទេ។ ការវិនិច្ឆ័យដោយប្រើពាក្យចំៗ តែមិនពិរោះពិសាមួយ អាចនិយាយបានថាអ្នកដឹកនាំភូមា ដែលជាអ្នកទោសនៃទស្សនៈផ្ទាល់របស់គេចំពោះពិភពលោក ពុំមានលទ្ធភាពយល់ឱ្យបានច្បាស់ថា តម្លៃដែលខ្លួនលើកតម្កើងខ្ពស់ពេកពុំមានន័យអ្វីទាល់តែសោះចំពោះពួកអង់គ្លេស។

### ២.២-ប្រទេសម៉ាឡេស៊ី សិង្ហបុរី និងព្រុយណេ

ភូមិសាស្ត្ររបស់រដ្ឋម៉ាឡេស៊ីសព្វថ្ងៃមានកំណើតនៅសម័យអាណានិគម។ នៅសម័យបុរាណរដ្ឋម៉ាឡេស៊ីសព្វថ្ងៃ គឺជាផ្នែកមួយនៃពិភពដ៏ធំទូលាយមួយដែលឈ្មោះថា ពិភពឥណ្ឌូណេស៊ី-មឡាយូ។ ស្តេចស៊ុលតង់មឡាយូគ្រប់គ្រងតាមបណ្តារដ្ឋតូចធំ នៅតាមបណ្តោយមាត់សមុទ្រនៃឧបទ្វីបម៉ាឡាយូ តាមបណ្តាភូមិភាគភាគខាងជើងនៃកោះប៊រណេអូដ៏ធំទូលាយ និងនៅស៊ូម៉ាត្រាភាគខាងកើតដែលជាកោះមួយបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ហូឡង់។ ក្រុមមនុស្សដែលមិនមែនជាអម្បូរមឡាយូ រស់នៅតាមតំបន់ខ្ពង់រាបក្នុងជ្រោយនេះ និងនៅលើកោះប៊រណេអូ។ តាំងពីបុរាណរៀងមក ភូមិភាគមួយដែលសព្វថ្ងៃគ្រប់គ្រងដោយម៉ាឡេស៊ី ជាភូមិ

ភាគដែលមានការផ្លាស់ប្តូរអំណាច និងសម្ពន្ធភាពជាច្រើន។ បណ្តារដ្ឋភាគខាងជើងរបស់ជ្រោយមឡាយូ មានទំនាក់ទំនងជារដ្ឋចំណុះឱ្យសៀម ចំណែកឯរដ្ឋភាគខាងត្បូងនៃជ្រោយនេះ មានទំនាក់ទំនងជាមួយរដ្ឋស៊ុលតង់ តាមភូមិភាគដែលសព្វថ្ងៃជាផ្នែកមួយនៃឥណ្ឌូណេស៊ី។

ការពង្រឹងអំណាចរបស់ពួកអឺរ៉ុបមកក្នុងភូមិភាគនេះ ប្រព្រឹត្តទៅតាមលំនាំយឺតៗ ហើយពុំមានលំដាប់លំដោយទេ។ ក្រោយបានកាន់កាប់មលក្កា(ម៉ាឡាកា) នាដើមសតវត្សទី១៦មក ពួកព័រទុយហ្គាល់ ពុំបានបន្តពង្រីកអំណាចក្នុងទ្រង់ទ្រាយធំណាមួយ ទៅក្នុងភូមិភាគដទៃទៀតក្នុងប្រទេសម៉ាឡេស៊ីសព្វថ្ងៃរហូតដល់ចុងសតវត្សទី១៨ ឡើយ។ មកដល់ពេលនេះ ការគ្រប់គ្រងលើមលក្ការបស់ពួក ព័រទុយហ្គាល់ ត្រូវជំនួសដោយពួកហូឡង់ ហើយការតាំងទីលំនៅដំបូងរបស់ពួកអង់គ្លេសលើដែនដី ប្រទេសម៉ាឡេស៊ីសព្វថ្ងៃ ត្រូវធ្វើឡើងនៅកោះប៉េណាំង ក្នុងឆ្នាំ១៧៨៦ ក្រោយមកពួកអង់គ្លេស បានពង្រីកអំណាចរបស់ខ្លួន ទៅកាន់កាប់កន្លែងដែលពួកគេបានតាំងទីលំនៅចំនួនបី នៅជាយជ្រោយមឡាយូ រួមមាន សិង្ហបុរី ប៉េណាំង និងមលក្កា (ជំនួសពួកហូឡង់វិញ)។

ទីតាំងទាំងនេះមិនត្រឹមតែមានភូមិសាស្ត្រចុងបំផុតនៅតាមជាយជ្រោយប៉ុណ្ណោះទេ ទំនាក់ទំនងរវាងទីតាំងទាំងនេះ ជាមួយបណ្តារដ្ឋនៅជ្រោយមឡាយូ មានលក្ខណៈតិចតួចស្តួចស្តើងថែមទៀតផង។

ក្នុងឆ្នាំ១៨០០ ចក្រភពអង់គ្លេសគ្រប់គ្រងកោះប៉េណាំង ខេត្តវែល្លស្លី និងមលក្កា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហូឡង់មុនឆ្នាំ១៧៩៥។ ក្នុងឆ្នាំ១៨១៩ ចក្រភពអង់គ្លេសបានគ្រប់គ្រងសិង្ហបុរីបន្ថែម រីឯមលក្កាត្រូវផ្ទេរទៅឱ្យហូឡង់កាន់កាប់វិញនៅឆ្នាំ១៨១៨។ ក្នុងឆ្នាំ១៨៩៥ ចក្រភពអង់គ្លេសបានគ្រប់គ្រង រដ្ឋជហ៊រ ដែលនៅចុងជ្រោយខាងត្បូងបំផុត។ បណ្តារដ្ឋខាងជើងមានប៊ីរលិស កិដះ កិឡាន់តាន់ និងត្រិងហ្គានូ ត្រូវបានសៀមកាត់ឱ្យចក្រភពអង់គ្លេស នៅឆ្នាំ១៩០៩ ហើយជហ៊រស្ថិតក្រោមការគ្រប់គ្រងរបស់អង់គ្លេសជាផ្លូវការក្នុងឆ្នាំ១៩១៤ និងឧបទ្វីបមឡាយ៉ាទាំងមូល។ ពេលគេបង្កើតសហព័ន្ធម៉ាឡេស៊ីក្នុងឆ្នាំ១៩៦៣ សិង្ហបុរីក៏ក្លាយជាសមាជិកក្នុងរយៈពេលមួយរយៈពេលខ្លីដែរ ប៉ុន្តែត្រូវដកចេញវិញក្នុងឆ្នាំ១៩៦៥។

សារៈសំខាន់ក្នុងការស្តាបនាឱ្យមានបន្ទាត់ព្រំដែនរបស់មហាអំណាចអឺរ៉ុប មានច្រើនក្នុងករណីឧបទ្វីបមឡាយូ ប៉ុន្តែគ្មានភូមិភាគណាអាចបញ្ជាក់ឱ្យបានច្បាស់លាស់ជាងកាការវិវត្ត ដែលកើតមាននៅលើកោះ ប៊រណេអូ ដែលបង្កើតបានជាម៉ាឡេស៊ីខាងកើត (មានរដ្ឋសារ៉ាវ៉ាក់ និងរដ្ឋសាបា សព្វថ្ងៃ) និងព្រុយណេឡើយ។ ជាផ្នែកមួយនៃការពង្រីកអំណាចអាណានិគមនិយមនៅសតវត្សទី១៩ ពួកអឺរ៉ុបបានពិចារណារកលទ្ធភាពដណ្តើមឱ្យបាននូវផលចំណេញខាងផ្នែកសេដ្ឋកិច្ច និងខាងផ្នែកយុទ្ធសាស្ត្រនៅប៊រណេអូខាងជើង។ គោលបំណងនេះអាចធ្វើទៅបានក៏ដោយសារការបន្តបំផ្លិចបំផ្លាញដល់អំណាច ដែលកំពុងធ្លាក់ចុះរួចទៅហើយរបស់អាណាចក្រព្រុយណេ។ អាណាចក្រនេះធ្លាប់មានអំណាចខ្លាំងនៅតាមបណ្តោយឆ្នេរប៊រណេអូ និងលើផ្នែកខ្លះនៅប្រជុំកោះស៊ូលូ។ នៅពេលដែលភូមិភាគទាំងឡាយ ដែលសព្វថ្ងៃនៅក្នុងប្រទេសម៉ាឡេស៊ី ត្រូវបានមហាអំណាចអាណានិគមនិយមអឺរ៉ុបពីរ ដាក់ឱ្យនៅក្រោមការគ្រប់គ្រងខាងផ្នែកនយោបាយរបស់ខ្លួន ព្រុយណេត្រូវបានគេចាត់ទុកនៅជាភូមិភាគចន្លោះ (ស្រុកទ្រនាប់) តូចមួយ ដែលបានក្លាយជាដែនដីស្ថិតនៅក្រោមអាណាព្យាបាលអង់គ្លេស ក្នុងឆ្នាំ១៨៨៨។

នៅសារ៉ាវ៉ាក់ ភ្នាក់ងារនៃការពង្រីកអំណាចអាណានិគមនិយម មិនមែនជាមន្ត្រីរដ្ឋាភិបាល ប៉ុន្តែជាបុគ្គលមួយរូបដែលមានឈ្មោះថា ចេមស៍ ប្រ៊ូក (james Brooke)។ លោកជាជនដំបូងចេញពីក្រុម "រាជាស្បែកស" ហើយមានគេសិក្សាច្រើនអំពីលោក។ ផ្ទុយទៅវិញ នៅសាបា មហាអំណាចអាណានិគមនិយម គឺជាក្រុមហ៊ុន

ដែលបានទទួលកតិកាសញ្ញារបស់បិរណេអូខាងជើង។ ក្នុងករណីទាំងនេះ លក្ខណៈពិសេសជាច្រើននៃ "មហាអំណាច" អាណានិគមនិយម បាននាំទៅរកការវិវត្តដោយឡែកៗ នៅក្នុងដែនដីទាំងពីរនេះ។ ទោះជាយ៉ាងនេះក៏ដោយ ចំណុចគ្រឹះនៃការអះអាងអំពីទំនាក់ទំនងរបស់មហាអំណាចអាណានិគមនិយម និងការវិវត្តនៅពិភពដែនទឹក ពិតជាមានប្រាកដមែន។ នៅសារ៉ាវ៉ាក់និងសាបា ក៏ដូចជាភូមិភាគដទៃទៀតដែរ ការកកើតឡើងនូវបណ្តារដ្ឋក្រោយសម័យអាណានិគម គឺជាលទ្ធផលមួយផ្នែកនៃការពង្រឹងអំណាចរបស់មហាអំណាចអឺរ៉ុប។ ទោះជាភូមិភាគមិនធ្លាប់មានរដ្ឋ និងបន្ទាត់ព្រំដែនពីមុនមក ដូចករណីចម្លែកទាំងពីរនេះជាដើម ក៏មានការស្ថាបនាអង្គភាពដឹកនាំនយោបាយថ្មីៗនៅសតវត្សទី១៩ ដែរ។

## ៣-អាណានិគមបារាំង

ដែនដីបារាំងនៅអាស៊ីអាគ្នេយ៍មាន៥តំបន់ គឺ កូសាំងស៊ីន កម្ពុជា លាវ អាណ្ណាម និងតុងកឹង។ ក្នុងចំណោមដែនដីក្រោមការគ្រប់គ្រង់ របស់បារាំងនេះចែកជាពីរផ្នែកគឺ កូសាំងស៊ីនជាដែនដីអាណានិគម ចំណែកដែនដី៤ទៀត ស្ថិតក្រោមបែបអាណាព្យាបាល។

### ៣.១-ប្រទេសវៀតណាម

ប្រទេសវៀតណាមត្រូវបានបារាំងឈ្លានពានលើកទី១ នៅចុងទសវត្សរ៍ឆ្នាំ១៨៥០ក្រោមលេស ជួយសង្គ្រោះអ្នកផ្សព្វផ្សាយសាសនាគ្រិស្តកាតូលិក។ បារាំងបានវាយវៀតណាមបន្តិចម្តងៗ រហូតបានទាំងមូលចាប់ពីឆ្នាំ១៨៥៨ ដល់ឆ្នាំ១៨៨៦។ បារាំងសង្ឃឹមថា នឹងទទួលបានផលប្រយោជន៍ខាងជំនួញ និងដើម្បីការពារអ្នកផ្សព្វផ្សាយសាសនាគ្រិស្ត ព្រមទាំងច្រណែននឹងការពង្រីក អំណាចរបស់ពួកម្ចាស់អាណានិគមអង់គ្លេសនៅតំបន់ផ្សេងទៀត រាជវាំងវៀតណាមសឹងតែពុំជឿនូវអ្វីដែលបានកើតឡើងនៅពេលនោះឡើយ។

កងនាវាបារាំង-អេស្ប៉ាញ ជាច្រើនបានមកដល់ត្វ៉ាន នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៨៥៨។ បន្ទាប់មកនាវា**ឡាឌូរ៉ង់ស្ស** La Durance ដែលមានកងពល៥៥៥នាក់ ក៏បានមកដល់ត្វ៉ានដែរ។ នៅព្រឹកថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៥៨ លោកឧត្តមនាវី **រីហ្គោ ដឺ ហ្សឺនូយី**(Rigault de Genouilly) បានបញ្ជូននាយទាហានម្នាក់ឱ្យយកលិខិតព្រមានមួយទៅជូន *ទេសាភិបាលត្វ៉ាន* ឱ្យយល់ព្រមចុះចូលក្នុងរយៈពេល២ម៉ោង បើពុំនោះសោតទេ លោកនឹងបាញ់កម្ទេចបន្ទាយការពារទីក្រុងទាំងពីរ។ ដោយគ្មានចម្លើយ នាវាបារាំង-អេស្ប៉ាញបានបាញ់ចូលបន្ទាយទាំងពីរ ទាហានយួន១០,០០០នាក់រត់កៀសខ្លួនយកតែអាយុ។ បារាំង-អេស្ប៉ាញ យកបាន និងកាន់កាប់ *ត្វ៉ាន* អស់មួយរយៈពេល។

ក្រោយពេលវាយយកបានត្វ៉ានហើយ លោកឧត្តមនាវី **រីហ្គោ ដឺ ហ្សឺនូយី** ស្ទាក់ស្ទើរថាតើត្រូវឡើងទៅលើវិញ ទៅវាយប្រដៅយួនតុងកឹង ដែលបានសម្លាប់ជាពិសេស សម្តេចឪយ៉ាស៍ និងសម្តេច **មេគ្យ័រ** ឬចុះមកក្រោមរហូតដល់ព្រៃនគរ ដែលយួនកំពុងកាន់កាប់។ ទីបំផុតលោកឧត្តមនាវី សម្រេចចុះមកយកព្រៃនគរដោយមានការគាំទ្រទាំងស្រុង ពីលោកឧត្តមនាវីរដ្ឋមន្ត្រីនាវាចរ **អាមើឡាំង** ដោយទុកកងទ័ពខ្លះឱ្យនៅការពារត្វ៉ាន។

នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៨៥៩ កងនាវាចម្បាំងបារាំង-អេស្ប៉ាញ បានចាកចេញពីត្វ៉ាន ឆ្ពោះមកត្បូងមកដល់ច្រកទន្លេចូលព្រៃនគរ ឬអូរកាប់ នៅល្ងាចថ្ងៃទី៩ ខែកុម្ភៈ។ ស្អែកឡើងបន្ទាយពីរ ដែលការពារ **អូរកាប់** ត្រូវបានវាយកម្ទេច។ ក្នុងដំណើរ៨០គ.ម ពីច្រកចូលអូរកាប់ ទៅព្រៃនគរ កងនាវាចម្បាំងបារាំង-អេស្ប៉ាញ បានវាយកម្ទេចបន្ទាយការពារយួននៅតាមផ្លូវអស់៦។ មកដល់ព្រៃនគរ ដែលនៅពេលនោះមានមនុស្សប្រហែល ២,០០០នាក់ និងការពារដោយបន្ទាយទាហានយួនពីរ មួយតូច មួយធំ នៅល្ងាចថ្ងៃទី១៥ ខែកុម្ភៈ បារាំង

អេស្ប៉ាញ វាយកម្ទេចបន្ទាយតូចភ្លាមៗ។ ក្រោយពីស៊េបយកការណ៍បានប្លង់ច្បាស់លាស់អស់ហើយ នៅថ្ងៃទី១៧ ខែកុម្ភៈ បារាំង-អេស្ប៉ាញ បានហ៊ុមព័ទ្ធពីមុខពីក្រោយបន្ទាយធំនៅខាងជើង បាញ់កាំភ្លើងធំចូល យួនក៏បាញ់តបមកវិញដែរ។ មិនយូរប៉ុន្មានកងកម្លាំងការពារយួនចុះអន់ថយទៅៗ ទាហានបារាំង-អេស្ប៉ាញ ចេញពីកប៉ាល់ឡើងគោក បាញ់សំរុកចូលទៅក្នុងបន្ទាយយ៉ាងខ្លាំង។ ទាហានយួនបាក់ស្បាត រត់ខ្ចាត់ខ្ចាយ នៅម៉ោង១០ព្រឹក កងនាវាចម្បាំងបារាំង-អេស្ប៉ាញ កាន់កាប់ទាំងស្រុងបន្ទាយប្រាការ និងទីរួមខេត្តព្រៃនគរ។

ក្រោយពេលមានជ័យជម្នះលើយួនហើយ លោកឧត្តមនាវី **រីហ្គោ ដឺ ហ្សឺនូយី** មានបញ្ហាពីរ ដែលត្រូវដោះស្រាយជាបន្ទាន់ ចិនមិនគោរពសន្ធិសញ្ញាសន្តិភាពឆ្នាំ១៨៥៨ និងយួនវាយយកតួរ៉ាន វិញកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៨៥៩។ ដោយគ្មានជំនួយទ័ពបន្ថែម លោកហាក់ដូចជាត្រូវទីក្រុងប៉ារីសបំភ្លេចចោល។ នៅចុងខែមេសា កងនាវាចម្បាំងបារាំង-អេស្ប៉ាញមួយក្រុម បានត្រឡប់ទៅបង្ក្រាបចិន នៅកង់តុង និងយួននៅតួរ៉ាន ដោយទុកមួយក្រុមឱ្យនៅការពារព្រៃនគរ ក្រោមបញ្ជាការលោកវរសេនីយ៍ទោ **ហ្សូរេហ្គីយេរី** (Jauréguilerry) និងក្រោយមកលោកនាវីឯក **ដារីយ៉េស៍** និងលោកវរសេនីយ៍ត្រី **ម៉ាតាំង ដេ ប៉ាលីយ៉េរ៍**។ ថ្ងៃទី៨ ខែឧសភា ឆ្នាំ១៨៥៩ លោកឧត្តមនាវី **ប៉ាស្ហ (Page)** បានមកដល់ព្រៃនគរ ជំនួសបណ្តោះអាសន្នលោកឧត្តមនាវី **ដឺ ហ្សឺនូយី**។ លោកបានអញ្ជើញមន្ត្រីយួនមកចរចា សន្តិភាពតែបរាជ័យ។ លោកបានប្រកាសឱ្យប្រើកំពង់ផែព្រៃនគរ ក្រោមការការពាររបស់បារាំង។

នៅឆ្នាំ១៨៦២ អធិរាជ **ទឺ ឌឹក** មានបញ្ហាធំពីរត្រូវដោះស្រាយ។ នៅតុងកឹង ក្រុម **ឡេ ភុង** (Lé Phung) កំពុងរៀបចំបះបោរឡើងប្រឆាំងនឹងទីក្រុងវេ។ តាំងពីជំនាន់អធិរាជ **យ៉ា ឡុង** មកម្ល៉េះក្រុមនេះទុកយួនវេ ជាអ្នកឈ្លានពានយកប្រទេសគេ។ តាំងពីឆ្នាំ១៨៥៨ មកម្ល៉េះ ក្រុម **ឡេ ភុង** បានសុំឱ្យបារាំងជួយ ដោយយល់ព្រមដាក់ **តុងកឹង** ក្រោមអាណានិគមបារាំង។

នៅខាងត្បូង **ទឺ ឌឹក**[417] គ្មានមធ្យោបាយអីប្រឆាំងនឹងបារាំងទេ។ **ទឺ ឌឹក** បានស្នើសុំសន្តិភាព និងបំពេញបំណងបារាំងទាំងស្រុង។ កប៉ាល់បារាំង ហ្វកបាំង បានទាញសណ្តោង កប៉ាល់យួនមួយ ដែលមានគណប្រតិភូមួយក្រុម ក្រោមការដឹកនាំរបស់លោក **ផាន ថិនយ៉ាង** (Phan Thanh Giang ) រដ្ឋមន្ត្រី ពាណិជ្ជកម្ម និងយុត្តិធម៌ និងមានសមាជិក១៣៥នាក់ ពីទីក្រុងវេ មកដល់ព្រៃនគរ។ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៨៦២ សន្ធិសញ្ញាសន្តិភាពមួយ ត្រូវបានចុះហត្ថលេខា រវាងលោកឧត្តមនាវី **បូណាដ៍** តំណាងអធិរាជបារាំង ណាប៉ូឡេអុងទី៣ និងលោក **ផាន ថិនយ៉ាង** តំណាងអធិរាជ **ទឺ ឌឹក**។ តាមសន្ធិសញ្ញានេះ **ទឺ ឌឹក** យល់ព្រមៈ

- ប្រគល់ខេត្ត ចំនួនបីគឺ ខេត្តចង្វាត្រពាំង (Bién Hoa) តាឌិន (Gia Dinh) និង មេស (My Tho) ព្រមទាំងកោះត្រឡាច (Poulo Condor) ទៅឱ្យបារាំងធ្វើជាកម្មសិទ្ធិ។
- ផ្តល់សេរីភាពដល់អ្នកកាន់សាសនាកាតូលិក
- សងសោហ៊ុយសង្គ្រាមចំនួន២០លានហ្វ្រង់ដល់បារាំង

សន្ធិសញ្ញានេះ ក៏បានបើកសេរីភាពឱ្យបារាំងធ្វើជំនួញ ដោយប្រើប្រាស់កំពង់ផែយួនជាច្រើនមានជាអាទិ៍ តួរ៉ាន ព្រមទាំងហាមមិនឱ្យយួនប្រគល់ទឹកដីខ្លួនទៅឱ្យប្រទេសណាមួយ បើគ្មានការយល់ព្រមពីបារាំង

[417] ទឺ ឌឹក ឯកសារមួយចំនួនអានថា ធូ ឌឹក

ទេ។ ពិធីប្តូរសច្ចាប័នត្រូវបានធ្វើឡើងយ៉ាងឱឡារិក នៅរាជវាំងអធិរាជ **ទី ឌឹក** នៅវេ នាថ្ងៃទី១០ ខែមេសា ឆ្នាំ ១៨៦៣[418]។

បន្ទាប់ពីគ្រប់គ្រងនៅកូសាំងស៊ីនរួចហើយ បារាំងបានរិះរកមធ្យោបាយដើម្បីវាយដណ្តើមកាន់កាប់ទឹកដីវៀតណាម ដែលនៅសេសសល់ជាបន្តទៀត។ នៅចុងឆ្នាំ១៨៧៣ កងទ័ពបារាំងបានចូលទៅដល់តុងកឹង។ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៨៧៣ កងទ័ពបារាំង បានបើកការវាយប្រហារបន្ទាយនៅហាណូយ និងនៅតំបន់នេះ ហើយក្នុងមួយរយៈពេលដ៏ខ្លីកងទ័ពបារាំងបានកាន់កាប់ស្ទើរទាំងស្រុងនូវតំបន់ និងខេត្តដែលខ្លួនបានវាយលុយ។ តែដោយមានការប្រែប្រួលខ្លះៗ កងទ័ពបារាំងត្រូវបានបញ្ជាឱ្យដកចេញអស់ពីហាណូយ។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ ១៨៧៤ សន្ធិសញ្ញាមួយត្រូវបានចុះហត្ថលេខានៅព្រៃនគរ រវាងលោកទេសាភិបាល ជាមួយលោក **ឡេទ្វឹង** តំណាងអធិរាជ **ទី ឌឹក**។

សន្ធិសញ្ញានេះបានចែងថា៖

❖ **ចំពោះយួនអាណ្ណាម**
  - ឱ្យបរទេសប្រើប្រាស់ទន្លេក្រហមដោយសេរី និងសន្យាកំចាត់ក្រុមចោរទង់ខ្មៅ ធ្វើឱ្យមានសន្តិសុខ នៅតាមឆ្នេរសមុទ្ទ និងតាមទន្លេក្រហម
  - ទទួលស្គាល់អធិបតេយ្យភាពបារាំងនៅកូសាំងស៊ីន សម្រួលនយោបាយការបរទេសឱ្យស្របតាមនយោបាយបារាំង (ឃ្លានេះចង់និយាយថា អាណ្ណាមត្រូវនៅក្រោមអាណាព្យាបាលបារាំង)
  - ឱ្យបារាំងដាក់កុងស៊ុលនៅហាណូយ និងហាយផុង ដោយមានទាហាន១០០នាក់ការពារ និងស្ថានទូតនៅក្រុងវេ។

❖ **ចំពោះភាគីបារាំង**
  - ប្រគល់បន្ទាយប្រាការនៅហាណូយ ទៅឱ្យយួនវិញ និងដកទ័ពចេញពីន្លេក្រហម
  - លប់ចោលសំណងសេសសល់តាមសន្ធិសញ្ញាឆ្នាំ១៨៦២
  - ទទួលស្គាល់អធិបតេយ្យភាពរបស់អាណ្ណាមលើតុងកឹង
  - ទទួលការពារអាណ្ណាម ពីការវាយប្រហារពីសត្រូវនានា តាមការស្នើសុំពីរដ្ឋាភិបាលអាណ្ណាម

សន្ធិសញ្ញាខាងលើនេះគេឃើញថា ពុំត្រូវបានភាគីយួនគោរពនោះទេ គេឃើញភាគីយួនចូលទាក់ទងជាមួយនឹងក្រុមចិនទង់ខ្មៅ បញ្ឆេះកំហឹងអ្នកស្រុកតុងកឹង ឱ្យប្រឆាំងនឹងបារាំងទៅវិញ។ ក្រុមចិនទង់ខ្មៅបានដៃកាន់កាប់ទន្លេក្រហម បិទផ្លូវមិនឱ្យបរទេសចេញចូលធ្វើជំនួញ។ ដោយយកលេសថា ភាគីយួន មិនគោរពសន្ធិសញ្ញាឆ្នាំ១៨៧៤ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៨៨២ លោកទេសាភិបាល កូសាំងស៊ីន **ឡឺ មៀរ៍ ដឺ វីឡែរ៍** បានបញ្ជូនកងនាវាមួយក្រុម ៥០០នាក់ទៅតុងកឹង ដឹកនាំដោយលោក វរសេនីយ៍ឯក **អង់រី រីវីយ៉ែរ៍**។ ដោយចរចាឱ្យយួនគោរពតាមសន្ធិសញ្ញាឆ្នាំ១៨៧៤ ពុំបានលទ្ធផលអ្វីនោះ លោក រីវីយ៉ែរ៍ នៅថ្ងៃទី២៥ ខែមេសា បានសម្រេចបើកការវាយលុយ និងកាន់កាប់តុងកឹង។

---

[418] ត្រាំងធាត ប៊ុត, *វៀតណាម ឬស្រុកយួន*, គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ, ឆ្នាំ២០១៧, ទំព័រ៨៣។

ការវាយលុកកាន់កាប់តុងកឹង ពីសំណាក់បារាំងធ្វើឱ្យចិនពុំសប្បាយចិនឡើយ ដោយនៅថ្ងៃទី៦ ខែឧសភា រដ្ឋទូតចិននៅប៉ារីសបានទាមទារឱ្យបារាំងដកទ័ពចេញពីតុងកឹងវិញ។ នៅថ្ងៃទី៣០ ខែមិថុនា កងទ័ពចិន បានបញ្ជូនមកតុងកឹង តែដោយញញើតនឹងបារាំង ចិនថាដើម្បីកម្ចាត់ក្រុមចោរទង់ខ្មៅ។ កងទ័ពចិនបានជ្រៀតចូលរហូតដល់ជាយក្រុងហាណូយទៀតផង។ ពេលនោះបារាំងព្រមានវិញថា គេមិនអនុញ្ញាតឱ្យចិនជ្រៀតជ្រែកក្នុងនយោបាយគេនៅតុងកឹងឡើយ។ នៅចុងឆ្នាំ១៨៨២ លោកទេសាភិបាល **ជីវីឡែរ៍** បានប្រកាសថា មិនអនុញ្ញាតឱ្យមានទាហានចិនម្នាក់នៅតុងកឹង ព្រមទាំងចាប់បញ្ជូនទៅកោះត្រឡាច នូវជនណាម្នាក់ចេញមុខប្រឆាំងនឹងបារាំង។

សង្គ្រាមរវាងបារាំង និងយួនអាណ្ណាម បានបន្តមួយរយៈពេល ហើយទីបំផុតដោយបារាំងមានកម្លាំងខ្លាំងក្លាជាង បានបង្ខំឱ្យអាណ្ណាមទទួលយកអាណាព្យាបាលបារាំង។ ដោយមិនអាចប្រកែកបាន អធិរាជ **ហៀប ហ៊ា** (Hiép Hoa) បានយល់ព្រមទទួលយកសន្ធិសញ្ញាទីក្រុងវេ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៨៨៣។ សន្ធិសញ្ញានេះមានចែងដូចតទៅ៖

- អាណ្ណាមទទួលស្គាល់ និងយល់ព្រមទទួលអាណាព្យាបាលបារាំង (មាត្រា១)
- រដ្ឋាភិបាលអាណ្ណាម ដកទ័ពអស់ភ្លាមចេញពីតុងកឹង(មាត្រា៤)
- រដ្ឋាភិបាលអាណ្ណាម ប្រកាសបើកឱ្យគ្រប់ប្រទេសធ្វើជំនួញ (មាត្រា៧)
- បារាំងកាន់កាប់ផ្នែកគយទាំងស្រុង (មាត្រា១៩)
- បារាំងដាក់ប៉ុស្តិ៍តាមទន្លេក្រហម សម្រាប់ការពារសន្តិសុខ (មាត្រា២២)
- បារាំងសន្យាការពារអធិបតេយ្យភាពអាណ្ណាម តទល់ជាមួយសត្រូវពីខាងក្រៅ និងការបះបោរនៅក្នុងប្រទេស។ បារាំងជាអ្នកដេញកម្ចាត់ក្រុមចោរទង់ខ្មៅឱ្យចេញអស់ពីតុងកឹង (មាត្រា២៣) ។ល។

ទោះបីជាមានសន្ធិសញ្ញាខាងលើនេះយ៉ាងណាក៏ដោយ តែភាគីយួននៅតែមិនមានឆន្ទៈក្នុងការគោរពដូចសន្ធិសញ្ញាមុនៗដែរ។ ដោយយកងទ័ពយួនមិនព្រមដកចេញពីតុងកឹង ហើយកងទ័ពចិន ដែលចូលមកតុងកឹងពីមុន ថាមកកម្ចាត់ពួកក្រុមចោរទង់ខ្មៅ បែរជាចូលរួមជាមួយក្រុមនោះ ព្រមទាំងយួនហើយធ្វើការប្រឆាំងនឹងបារាំង។ បារាំងពិតជាមានការពិបាកក្នុងការធ្វើសង្គ្រាម ព្រោះនៅទីតាំងនោះសុទ្ធតែព្រៃ ហើយសត្រូវរបស់ខ្លួនស្គាល់ទឹកដីច្បាស់លាស់ណាស់ តែទោះបីជាយ៉ាងនេះក៏ដោយ បារាំងមានបំណងយកតុងកឹងទាំងមូលឱ្យខាងតែបាន។

ដោយមានប្រៀបខាងកងទ័ព បារាំងបានធ្វើការកៀបសង្កត់ចិន ឱ្យដកទ័ពចេញពីតុងកឹង និងបញ្ចប់ជាស្ថាពរនូវភាពជាចំណុះរបស់យួនចំពោះខ្លួន ដោយបានចុះហត្ថលេខាលើ សន្ធិសញ្ញាបណ្តោះអាសន្ន **ទៀងស៊ីន** ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៨៨៤។

ក្រោយពីមានសន្ធិសញ្ញាទៀងស៊ីនហើយ បារាំងចង់បញ្ជាក់ឱ្យច្បាស់ជាងមុន ពីអំណាចបារាំង នៅអាណ្ណាម ដែលរួមមានតុងកឹងផងដែរ។ បារាំងយកអំណាចទាំងអស់មកកាន់ផ្ទាល់ខ្លួន ទុកតែផ្នែក រដ្ឋបាលឱ្យយួនកាន់ តែនៅក្រោមការទទួលខុសត្រូវរបស់បារាំងទៀត មន្ត្រីណាហ៊ានជំទាស់បារាំងដកចេញភ្លាម។

សន្ធិសញ្ញា**ទៀងស៊ីន** ជាស្ថាពរ រវាងបារាំង និងចិន ត្រូវបានចុះហត្ថលេខា នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៨៨៥។ សន្ធិសញ្ញា សន្តិភាព មិត្តភាព និងពាណិជ្ជកម្មនេះមានសារៈសំខាន់ណាស់ចំពោះអនាគត **អាណ្ណាម** គឺចិនអស់មានសិទ្ធិជាអធិរាជលើយួនទៀតហើយ។ ចិនបានទទួលស្គាល់អាណាព្យាបាល បារាំងលើអាណ្ណាមដែរ។

ទោះជាមានសន្ធិសញ្ញា ដែលពួកយួនអាណ្ណាមទទួលយកអំណាចបារាំងហើយក៏ដោយ ក៏គេមើលឃើញថាចលនាប្រឆាំងនៅតែកើតមានជាបន្តបន្ទាប់រវាងបារាំង ជាមួយយួន។ ដែលការបះបោរនេះធ្វើឱ្យទាំងទាហ៊ាន និងជនស៊ីវិលជាច្រើននាក់ស្លាប់បាត់បង់ជីវិត។ ចលនានេះកើតឡើងនៅចន្លោះ ឆ្នាំ១៨៨៥-១៨៨៩ ដែលមានឈ្មោះថាចលនា កឹង យឿង(Cán Vuong)។

## ៣.២-ប្រទេសកម្ពុជា

ប្រទេសកម្ពុជា មានទំនាក់ទំនងជាមួយពួកអឺរ៉ុប គឺពួកព័រទុយហ្គេ ហូឡង់ និងអេស្ប៉ាញតាំងពីសតវត្សទី១៥-១៦មកម្ល៉េះ នៅសម័យចតុមុខ សម័យលង្វែក ប៉ុន្តែទំនាក់ទំនងនេះមានតែលើផ្នែកជំនួញ និងសាសនាគ្រិស្តប៉ុណ្ណោះ។

ប្រវត្តិសាស្ត្រខ្មែរ សម័យឧដុង្គជាសម័យកាលដ៏ខ្មៅងងឹតដែលពោរពេញដោយជម្លោះផ្ទៃក្នុងការដណ្តើមរាជសម្បត្តិ ការពឹងពាក់យួន និងសៀមឱ្យជួយ ដើម្បីបានអំណាច ទោះបីបាត់បង់ទឹកដី ហើយស្ថិតនៅក្រោមឥទ្ធិពលរបស់យួន-សៀមក៏ដោយ។ ដើម្បីរំដោះខ្លួនចេញពីឥទ្ធិពលយួន-សៀម ព្រះអង្គដួងបានសុំជំនួយពីបារាំង ដោយផ្ញើព្រះរាជសារទៅព្រះចៅណាប៉ូឡេអុងទី៣ នៅឆ្នាំ១៨៥៣។ នៅឆ្នាំ១៨៥៥ ព្រះចៅអធិរាជបារាំងឆ្លើយតបទទួលស្គាល់ជាដៃគូពាណិជ្ជកម្មប៉ុណ្ណោះ។ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៥៨ បារាំង និងអេស្ប៉ាញបានលើកទ័ពចូលមកដល់ទីក្រុងដាណាង ដើម្បីជួយសង្គ្រោះពួកអ្នកផ្សព្វផ្សាយសាសនាកាតូលិក ហើយនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៨៥៩ បារាំងកាន់កាប់ទីក្រុងព្រៃនគរ និងតំបន់ជិតខាង។ ឃើញឱកាសនេះ ព្រះអង្គដួងបានបញ្ជូនទ័ពខ្មែរមួយកងទៅកាន់ខេត្តមាត់ជ្រូក ក្នុងបំណងបង្ហាញថាទឹកដីកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរ តែត្រូវអាក់ខានព្រោះព្រះអង្គចូលទីវង្គតនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៨៦០។

ព្រះបាទនរោត្តម (១៨៦០-១៩០៤) បានឡើងសោយរាជ្យបន្តពីព្រះបិតា។ នៅក្នុងរាជ្យរបស់ព្រះអង្គបារាំងបានចូលមកដល់កម្ពុជា ហើយចុះសន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ដោយផ្សព្វផ្សាយជាសាធារណៈ។ ហើយព្រះអង្គបានអភិសេកឡើងសោយរាជ្យនៅទីក្រុងឧដុង្គនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៨៦៤។ នៅឆ្នាំ១៨៨៤ បារាំងបានព្យាយាមធ្វើកំណែទម្រង់ និងសាកល្បងដណ្តើមយកអំណាចពីព្រះមហាក្សត្រខ្មែរ ។

អាណាព្យាបាលបារាំង មកលើកម្ពុជាមានរយៈពេល៩០ឆ្នាំ (ពីថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ដល់ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣) មានព្រះរាជា៤ព្រះអង្គសោយរាជ្យគឺ ព្រះបាទនរោត្តម(១៨៦០-១៩០៤) ព្រះបាទស៊ីសុវត្ថិ(១៩០៤-១៩២៧) ព្រះបាទស៊ីសុវត្ថិ មុនីវង្ស(១៩២៧-១៩៤១) ព្រះបាទនរោត្តម សីហនុ (១៩៤១-១៩៥៥)។

## ៣.៣-ប្រទេសលាវ

ប្រទេសលាវជាផ្នែកមួយរបស់ឥណ្ឌូចិនផងដែរ ដែលមានកម្ពុជា និងវៀតណាម ស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំង។ នៅសតវត្សទី១៩ លាវពុំមានឯកភាពជាតិទេ ព្រោះទឹកដីរបស់លាវមួយចំនួនស្ថិតក្រោមការគ្រប់គ្រងរបស់សៀម ហើយមួយចំនួនទៀតក្រោមការគ្រប់គ្រងរបស់វៀណាម។

បារាំងបានចូលកាន់កាប់លាវនៅចន្លោះឆ្នាំ១៨៨៥ និងឆ្នាំ១៨៩៩ ហើយបានតាំងអាណាព្យាបាល នៅប្រទេសលាវ តាមរយៈការរួមផ្សំរវាងសេចក្តីក្លាហាន បុគ្គល ការប្រើឧបាយកលបែបពួកមហាអំណាច និងអាស្រ័យលើហេតុផលពុំច្បាស់លាស់ ទាក់ទងនឹងការគ្រប់គ្រងរបស់វៀតណាម ពីអតីតកាលនៅលើតំបន់ខ្លះរបស់លាវ។ ជារូបភាពមួយច្បាស់ជាងដែនដីដទៃទៀត នៅអាស៊ីអាគ្នេយ៍ដីគោកការពង្រីកអំណាចរបស់អឺរ៉ុប

បានបង្កើតជារដ្ឋថ្មីមួយ ហើយទោះបីមានការផ្លាស់ប្តូរផ្នែកនយោបាយ សំខាន់ៗ ជាច្រើនក៏ដោយ រដ្ឋថ្មីនេះអាចរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃ។

## ៤-អាណានិគមហូឡង់នៅឥណ្ឌូណេស៊ី

ពួកហូឡង់បានមកដល់ប្រជុំកោះឥណ្ឌូណេស៊ីក្នុងនាមជាអ្នកជំនួញៗ។ ដើម្បីសម្រេចនូវគោលបំណងចម្បងរបស់ពួកគេ ជនជាតិហូឡង់គ្រាន់តែដណ្តើមគ្រប់គ្រងកំពង់ផែធំៗ នៅកោះជ្វាខាងជើង និងមជ្ឈមណ្ឌលពាណិជ្ជកម្មចម្បងៗ នៅតាមបណ្តាកោះដទៃទៀត ដែលធ្វើជំនួញគ្រឿងទេសនោះ គឺជាការ គ្រប់គ្រាន់ទៅហើយ។ ប៉ុន្តែបន្តិចម្តងៗ ដូចគ្នាទៅនឹងការពង្រីកអំណាចរបស់ពួកអង់គ្លេសនៅឥណ្ឌាដែរ ក្រុមហ៊ុនឥណ្ឌាខាងកើតរបស់ហូឡង់ក៏បានក្លាយជាមហាអំណាចគ្រប់គ្រងដែនដីផង និងជាក្រុមហ៊ុនជំនួញផង។ ពេលដែលការប្រកួតប្រជែងនៅជ្វា បាននាំទៅរកការដួលរលំរបស់រាជាណាចក្រម៉ាតារ៉ាំ កាលពីសតវត្សទី១៨ ពួកហូឡង់មានឥទ្ធិពលយ៉ាងច្រើនរួចទៅហើយ។ ឥទ្ធិពលទាំងនេះមានជាពិសេស ក្នុងការប្រើប្រាស់កិច្ចការផ្ទៃក្នុងរបស់ជ្វា សំខាន់សំដៅឱ្យខ្លួនមានតួនាទីក្នុងការចាត់ចែងស្ថាបនាបណ្តារដ្ឋក្រោយៗទៀត ជំនួសឱ្យម៉ាតារ៉ាំ ដែលមានរាជធានីនៅជោគចាការតា និងស៊ូរ៉ាការតា នៅជ្វាកណ្តាល ។

មកដល់ពាក់កណ្តាលសតវត្សទី១៨ ក្រុមហ៊ុនឥណ្ឌាខាងកើតរបស់ហូឡង់អាចធានាបាននូវការគ្រប់គ្រងនយោបាយលើកោះជ្វាមួយភាគធំ។ ប៉ុន្តែ ការគ្រប់គ្រងនេះនៅមានលក្ខណៈទន់ខ្សោយនៅឡើយ និងពុំបានធ្វើឱ្យជ្វាទទួលឥទ្ធិពលពីវប្បធម៌ ឬបច្ចេកវិទ្យារបស់ពួកហូឡង់ឡើយ។ ទោះជាយ៉ាងនេះក្តី ការគ្រប់គ្រងនេះពុំបានធ្វើឱ្យមានការប៉ះពាល់លើផ្នែកសេដ្ឋកិច្ច ដោយសារតែពួកហូឡង់ធ្វើការតាមរយៈ វរជនជ្វា និងតាមរយៈភ្នាក់ងារប្រមូលពន្ធជនជាតិចិន បានបង្កើតនូវមធ្យោបាយជាច្រើន ដែលពុំធ្លាប់មានពីមុនមក ដើម្បីប្រមូលថវិកានិងផលិតផលកសិកម្មឱ្យបានជាអតិបរមា សម្រាប់ជាប្រយោជន៍ដល់ក្រុមហ៊ុនរបស់ខ្លួន ។ អំរែកនៃផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចទាំងនេះ បានធ្លាក់ទៅលើប្រជាកសិករ។ ប៉ុន្តែ សម្រាប់ប្រជាកសិករនិងពួកវរជន ការប្រែប្រួលផ្នែកសេដ្ឋកិច្ចនេះ មិនបានធ្វើឱ្យពិភពប្រពៃណី និងឋានានុក្រមរបស់ពួកគេ មានការប្រែប្រួលនោះទេ។

ភូមិភាគមួយចំនួនតូចនៅឆ្ងាយពីកោះជ្វា ដែលជាភូមិភាគរងនូវផលប៉ះពាល់ពីហូឡង់មុនសតវត្ស ទី១៩ នោះ ពុំទាន់មានការផ្លាស់ប្តូរអ្វីទេ។ ការប្រឈមមុខចំពោះទំនាក់ទំនងដែលបានបង្កើតឡើង និងប្រព័ន្ធតម្លៃនៃប្រពៃណី គឺជាផ្នែកមួយនៃប្រវត្តិសាស្ត្រនៅសតវត្សទី១៩ និងទី២០ ដែលនៅពេលនោះ ពួកហូឡង់បានបន្តពង្រីកការគ្រប់គ្រងលើប្រជុំកោះឥណ្ឌូណេស៊ីបន្តិចម្តងៗ ទោះបីមានការអាក់ខានខ្លះក៏ដោយ។ ការពង្រីកនេះមួយផ្នែក ធ្វើឡើងជាការឆ្លើយតបទៅនឹងការកើនឡើងនូវតម្រូវការផលិតផលពីតំបន់ត្រូពិក ក្នុងទីផ្សារអឺរ៉ុប ហើយមួយផ្នែកទៀត ជាការឆ្លើយតបនឹងសកម្មភាព ដែលចេះតែកើនឡើងៗ ពីសំណាក់មហាអំណាចអឺរ៉ុបដទៃទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

តាមគំនិតរបស់ពួកហូឡង់ សម្ពាធនៃតម្រូវការសេដ្ឋកិច្ច និងការប្រកួតប្រជែងរបស់ពួកបរទេស មានន័យថា ការបន្តរក្សានូវការគ្រប់គ្រងបែបធូររលុងនៅលើបណ្តាកោះដែលនៅរាយប៉ាយ ជាមួយនឹងរបៀបដឹកនាំតាមមូលដ្ឋាន ដែលដឹកនាំនៅភូមិភាគទាំងឡាយ ធ្លាប់បានអនុវត្តកន្លងមកនោះ លែងមានប្រសិទ្ធភាពទៀតហើយ។ ដូច្នេះ រដ្ឋាភិបាលហូឡង់នៅលើប្រជុំកោះឥណ្ឌូណេស៊ី (ព្រោះថាក្រុមហ៊ុនឥណ្ឌាខាងកើតរបស់ហូឡង់ ត្រូវគេរំលាយចោលកាលពីចុងសតវត្សទី១៨) ពេលនោះព្យាយាមស្ថាបនា នូវការគ្រប់គ្រងឱ្យជិតដល់ជាងមុន និងបង្កើតនូវរដ្ឋបាលមួយ ដែលមានឯកភាពជាងមុនដែរ។ គោលបំណងទាំងនេះ ជួនកាលបាននាំទៅរកជម្លោះបង្ហូរឈាមយ៉ាងស្រួចស្រាវជាមួយកម្លាំងតាមមូលដ្ឋាន ពិសេសនៅបណ្តាភូមិភាគនៅកោះ ស៊ូម៉ាត្រា។

ពិសេសជាងនេះទៅទៀត ពួកហូឡង់ត្រូវប្រយុទ្ធរាប់សតវត្ស ទើបអាចសម្រេចបាននូវការគ្រប់គ្រងលើដែនដីនៅស៊ូម៉ាត្រាខាងជើង កាលពីចុងសតវត្សទី១៩។ នៅកោះបាលីក៏ដូចគ្នាដែរ ពួកហូឡង់អាចកាន់កាប់បានតាមរយៈជ័យជម្នះដ៏ជូរចត់លើចលនាប្រឆាំងនៅទីនោះ។

មកដល់ដើមសតវត្សទី២០ រចនាសម្ពន្ធគ្រឹះរបស់ដែនដីអាណានិគមឥណ្ឌាខាងកើត(សំដៅលើ ឥណ្ឌូណេស៊ី) របស់ហូឡង់ត្រូវបានស្ថាបនាឡើង។ ជាលទ្ធផលនៃការវាយដណ្ដើម និងសន្ធិសញ្ញា ពួកហូឡង់បានសម្រេចនូវការគ្រប់គ្រងលើបណ្ដាប្រជុំកោះទាំងអស់ ដែលលាតសន្ធឹងពីកោះស៊ូម៉ាត្រាខាងលិច ទៅដែនដីផ្នែកខាងលិចនៃញូវហ្គីនេភាគខាងកើត។ មានតែកូនកោះទីម័រខាងកើត ដែលស្ថិតនៅក្រោមការតាំង អាណានិគមរបស់ព័រទុយហ្គាល់មួយប៉ុណ្ណោះ ដែលអាចគេចផុតពីអំណាចរបស់ហូឡង់។ ពេលនោះ ទង់ជាតិ ហូឡង់បក់រវិចៗនៅលើបណ្ដាកោះជាច្រើនដែលមានការរីកចម្រើនខុសៗ គ្នាខាងវប្បធម៌ចាប់តាំងពីជ្វា ដែលមានវប្បធម៌ដ៏ប្រណីតដោយឡែក រហូតដល់ញូវហ្គីនេដែលនៅមានវប្បធម៌យុគសម័យថ្មនៅឡើយនោះ។ នៅក្នុងភូមិភាគដែលពោរពេញដោយលក្ខណៈខុសៗគ្នាបែបនេះ ការទទួលរងនូវឥទ្ធិពលរបស់អឺរ៉ុបក៏ខុសពីគ្នាដែរ។ ផលប៉ះពាល់ទាំងនេះ មានដូចជា ការបន្តធ្វើឱ្យប្រជាកសិករនៅជ្វាកណ្ដាលនិងខាងកើត កាន់តែក្រទៅៗ និងការសាបព្រោះគ្រិស្តសាសនានៅតាមបណ្ដាកោះ ដែលមានលក្ខណៈខុសគ្នាដូចជា នៅតំបន់ភ្នំតូបានៅស៊ូម៉ាត្រា និងកោះអាំបុននៅជាយដែនឥណ្ឌូណេស៊ី ។

អ្វីដែលសំខាន់ជាងការផ្លាស់ប្ដូរនិងការរីកចម្រើនទាំងឡាយ ដែលបង្កឡើងដោយការគ្រប់គ្រងរបស់ហូឡង់នោះ គឺការស្ថាបនានូវការត្រួតត្រារបស់ហូឡង់ នៅពេលក្រោយលើបណ្ដាកោះទាំងអស់ នៅ ឥណ្ឌូណេស៊ីបច្ចុប្បន្ន បាននាំមកនូវអ្វីម្យ៉ាងផ្សេងទៀត។ នោះគឺជាលទ្ធផលដែលអនុញ្ញាតឱ្យក្រុមជាតិពន្ធុ ខុសៗ គ្នានៅដែនដីអាណានិគមប្រជុំកោះឥណ្ឌាខាងកើត ដែលកាន់កាប់ដោយហូឡង់ គិតអំពីផលប្រយោជន៍រួមរបស់ពួកគេ និងអត្តសញ្ញាណជាតិរួមមួយសម្រាប់ថ្ងៃអនាគត។ នៅសម័យកាលមុននេះ អ្នកដឹកនាំខ្លះធ្លាប់គិតអំពីការកសាងនូវចក្រភពប្រជុំកោះមួយ (មានឈ្មោះថា នុសន្តរៈ)។ ជាលទ្ធផលនៃការគ្រប់គ្រងរបស់អាណានិគមនិយម ការផ្ដួចផ្ដើមឱ្យមានចក្រភពដូច្នេះ ត្រូវបានបង្កើតឡើងក្នុងរូបភាពមួយច្បាស់លាស់និងរឹងមាំជាងមុន។ ការស្ថាបនាសាធារណរដ្ឋឥណ្ឌូណេស៊ីនៅចុងក្រោយនេះ ជាស្នាដៃរបស់ ប្រជាជនឥណ្ឌូណេស៊ី។ ប៉ុន្តែ ស្នាដៃនេះអាចសម្រេចបាននៅក្នុងក្របខ័ណ្ឌមួយ ដែលមួយភាគធំ គេបានដាក់ចេញនៅក្នុងសម័យកាលនៃការគ្រប់គ្រងអាណានិគមរបស់ហូឡង់។

## ៥-អាណានិគមព័រទុយហ្គាល់

ក្នុងរយៈពេលប្រាំឆ្នាំនៃការគ្រប់គ្រងកំពង់ផែដ៏ធំនៅមលក្កា ពួកព័រទុយហ្គាល់បានធ្វើទំនាក់ទំនងជាមួយទីម័រខាងកើត ដែលជាដែនដីមួយគេស្គាល់ទូទៅនៅប្រជុំកោះឥណ្ឌូណេស៊ីថា ជាប្រភពឈើចន្ទន៍ក្រស្នា។ ទោះជាយ៉ាងណា ពួកព័រទុយហ្គាល់ពុំបានស្ថាបនាជាទីកន្លែងតាំងទីលំនៅអចិន្ត្រៃយ៍ដំបូងរបស់ខ្លួនឡើយ រហូតដល់ទសវត្សរ៍ឆ្នាំ១៥៦០ហើយមកដល់ពាក់កណ្ដាលសតវត្សទី១៧ ទើបមានពួកព័រទុយហ្គាល់ក្នុងចំនួនជាច្រើនរយនាក់ បានមករស់នៅលើកោះទីម័រនេះ។ ភាគច្រើននៃអ្នកតាំងទីលំនៅ គឺជាសមាជិកមកពី គណៈនិកាយផ្សេងៗ។ ក្រោយពីបំពេញប្រតិបត្តិការពីមូលដ្ឋាននៅលីហ្វៅ ស្ថិតនៅភូមិភាគអូគូស្សេក្នុងកោះនេះ អស់មួយរយៈមកពួកព័រទុយហ្គាល់បានរើទីបញ្ជាការរដ្ឋបាលរបស់គេទៅក្រុឌីលីក្នុងឆ្នាំ១៧៦៩ ។

ដោយស្ថិតនៅឆ្ងាយពីប្រទេសព័រទុយហ្គាល់ និងធនធានមានកំណត់មូលដ្ឋានអាណានិគមនៅកោះទីម័រខាងកើតបានក្លាយជាភូមិភាគមួយ ដែលចក្រភពឯនាយសមុទ្ររបស់ព័រទុយហ្គាល់ព្រងើយ កន្តើយ។ លើស

ពីនេះទៀត ដោយសារកោះនេះមានទីតាំងនៅជិតដែនអាណានិគមរបស់ហូឡង់នៅប្រជុំកោះឥណ្ឌាខាងកើត ដែលមានអំណាចខ្លាំងផង ទីម័រជារឿយៗ ទំនងអាចជារងគ្រោះពីការទាញស្រូបចូលទៅក្នុងដែនអាណានិគមរបស់ហូឡង់។ ទោះជាយ៉ាងណាក៏ដោយ បណ្តាសន្ធិសញ្ញាដែលបានចុះហត្ថលេខាជាមួយ ហូឡង់ក្នុងឆ្នាំ ១៨៥៩ និង១៨៩៣ អាចជួយឱ្យកោះនេះស្ថិតស្ថេរនៅគង់វង្សបាន។ ការធានាពីសន្ធិសញ្ញាទាំងនេះពុំបានជួយអ្វីច្រើនដល់ការអភិវឌ្ឍខាងសេដ្ឋកិច្ច ឬនយោបាយរបស់ទីម័រខាងកើតឡើយ ហើយកោះនេះរហូតមកដល់សង្គ្រាមលោកទី២ ត្រូវរដ្ឋាភិបាលព័រទុយហ្គាល់នៅទីក្រុងលីស្បោនយកធ្វើជាមូលដ្ឋានមួយ សម្រាប់ធ្វើនិរទេសអ្នកប្រឆាំងខាងនយោបាយរបស់រដ្ឋដែលពេលនោះ គ្រប់គ្រងដោយព័រទុយហ្គាល់។

## ៦-អាណានិគមអេស្ប៉ាញនៅប្រទេសហ្វីលីពីន

ការគ្រប់គ្រងរបស់អេស្ប៉ាញអស់រយៈពេលយ៉ាងយូរ លើបណ្តាកោះទាំងនោះមានសារៈសំខាន់ពុំអាចកាត់ថ្លៃបានឡើយ ក្នុងការកំណត់ព្រំដែនរដ្ឋ ដែលពីមុនមកពុំមានព្រំសីមា ឬរចនាសម្ពន្ធដូចហ្វីលីពីនសព្វថ្ងៃនេះឡើយ។ ទោះជាយ៉ាងនេះក៏ដោយ ជោគជ័យរបស់អេស្ប៉ាញក្នុងការគ្រប់គ្រងនៅប្រទេស ហ្វីលីពីនជាដំណើរការដែលប្រព្រឹត្តទៅសន្សឹមៗ ដូចពួកហូឡង់ធ្វើនៅឥណ្ឌូណេស៊ីផងដែរ។ មិនតែប៉ុណ្ណោះ ដំណើរការបង្កើតការគ្រប់គ្រងនៅឥណ្ឌូណេស៊ីទាំងមូលរបស់ហូឡង់ ធ្វើឡើងក្នុងល្បឿនយឺតជាងអ្វីដែលគេធ្លាប់ដឹង។ ជ័យជម្នះរបស់អេស្ប៉ាញ មិនត្រឹមតែយឺតប៉ុណ្ណោះទេ តែថែមទាំងមិនពេញលេញទៀតផង។ មកដល់ពាក់កណ្តាលសតវត្សទី១៨ ទោះបីជាមហាអំណាចអេស្ប៉ាញ មានលទ្ធភាពគ្រប់គ្រងលើតំបន់ទំនាបភាគច្រើននៅ ហ្វីលីពីនភាគខាងជើងក៏ពិតមែន ក៏តំបន់ខ្ពង់រាបនៅតែជាតំបន់ដាច់ដោយឡែកនៅឡើយ។ លើសពីនេះទៀត ភូមិភាគដែលកាន់សាសនាអ៊ីស្លាមនៅហ្វីលីពីនភាគខាងត្បូង ពុំធ្លាប់ស្ថិតក្រោមការគ្រប់គ្រងរបស់អេស្ប៉ាញពិតប្រាកដនោះទេ។ ការប៉ុនប៉ងរបស់ពួក អេស្ប៉ាញម្តងហើយម្តងទៀត ដើម្បីធ្វើការត្រួតត្រាលើបណ្តារដ្ឋស៊ុលតង់ដែលមានឯករាជ្យរឹងមាំនៅភាគខាងត្បូង ត្រូវទទួលបរាជ័យ។ ពួកអេស្ប៉ាញសម្រេចបាននូវការកាន់កាប់កំពង់ផែធំៗ ភាគខាងត្បូងមួយចំនួន ដូចជាផែហ្សាំបូ-អាងហ្គា ប៉ុន្តែស្តេចស៊ុលតង់នៅកោះស៊ូលូ និងស្តេចស៊ុលតង់មួយចំនួនទៀត ដែលមានអំណាចខ្លះៗនោះ ពុំធ្លាប់ជាស្រុកចំណុះអេស្ប៉ាញទេ។ គ្រាប់ពូជនៃចលនាបំបែកខ្លួនរបស់ពួកមូស្លីមសព្វថ្ងៃនៅហ្វីលីពីនភាគខាងត្បូង ត្រូវបានគេបណ្តុះជាយូរមកហើយ។

ប៉ុន្តែ ទោះជាបទពិសោធនៃការទទួលឥទ្ធិពលអឺរ៉ុបនៅហ្វីលីពីន មានចំណុចដូចគ្នាច្រើនទៅនឹងប្រទេសឥណ្ឌូណេស៊ីនិងមឡាយ៉ា ដែលទើបធ្វើការកត់សម្គាល់រួចមក ការតាំងអាណានិគមរបស់អេស្ប៉ាញបានផ្តល់ជាតុមួយដែលមិនមាននៅដែនអាណានិគមដទៃបន្ថែមទៅលើអ្វី ដែលធ្លាប់មានក្នុងប្រវត្តិសាស្ត្រនៃបណ្តាកោះទាំងនេះ។ ជាតុដែលសំខាន់បំផុតនេះ គឺសាសនាកាតូលិក។ ការប្តូរទៅចូលសាសនារបស់មហាអំណាចអាណានិគមនិយមឈ្លានពានជាតិអឺរ៉ុប ក៏នៅមានកន្លែងផ្សេងទៀតដែរ ពិសេសនៅប្រទេសវៀតណាម។ ប៉ុន្តែនៅអាស៊ីអាគ្នេយ៍ (រាប់ទាំងទីម័រខាងកើតរបស់ព័រទុយហ្គាល់មុនឆ្នាំ១៩៧៥ដែរ) ពុំមានកន្លែងណាដែលសាសនារបស់ម្ចាស់អាណានិគម បានក្លាយជាសាសនារបស់អ្នករស់នៅក្រោមអាណានិគម ដូចហ្វីលីពីន ភាគខាងជើងទេ។

បើមើលឱ្យទូលាយជាងនេះទៅទៀត គេអាចយល់បានថាការសាបព្រោះសាសនាកាតូលិក គឺជាការស្តែងឱ្យឃើញអំពីតថភាពទូទៅមួយថា ការគ្រប់គ្រងរបស់អេស្ប៉ាញនៅប្រទេសហ្វីលីពីន បានផ្តល់ដល់ បណ្តាកោះភាគខាងជើងទាំងនោះ នូវក្របខ័ណ្ឌសង្គមថ្មីមួយ។ សំអាងលើរចនាសម្ពន្ធភូមិដែលមានមុនសម័យអាណានិគម ពួកអេស្ប៉ាញបានបង្កើតនូវប្រព័ន្ធថ្មីមួយ ដែលខុសពីប្រព័ន្ធអ្នកស្រុកអាយ។ នេះមិនមានន័យថា រចនា

សម្ពន្ធថ្មីនេះបានទាត់ចោលនូវជាតុសំខាន់របស់អ្នកស្រុកអាយទាំងអស់ ចេញពីសង្គមហ្វីលីពីននោះទេ។ ប៉ុន្តែគេក៏ត្រូវទទួលស្គាល់ដែរថា រចនាសម្ពន្ធខាងរដ្ឋបាលនិងសេដ្ឋកិច្ច ក៏ដូចជាខាងសាសនា បានទទួលឥទ្ធិពលច្រើនបំផុតពីពួកអេស្ប៉ាញ។

រឿងដែលគួរឱ្យអស់សំណើចនៅក្នុងប្រវត្តិសាស្ត្រ ដែលកំណត់អំពីប្រតិកម្មពីសំណាក់ប្រជាជនហ្វីលីពីនប្រឆាំងនឹងការគ្រប់គ្រងរបស់អេស្ប៉ាញ។ ប្រជាជនហ្វីលីពីន មិនសប្បាយចិត្តនឹងការគ្រប់គ្រងរបស់អេស្ប៉ាញពេលដែលគេឃើញច្បាស់ថា មហាអំណាចអាណានិគមនិយមមិនអនុញ្ញាតឱ្យពួកឥណ្ឌីយ៉ូ (មនុស្សដែលមិនមែនជាជាតិអេស្ប៉ាញរស់នៅតាមបណ្តាកោះហ្វីលីពីន) មានសិទ្ធិជាពលរដ្ឋនិងសិទ្ធិខាងសាសនា ដូចជនជាតិអេស្ប៉ាញ។ ទោះជាយ៉ាងនេះក្តី ពួកឥណ្ឌីយ៉ូអាចធ្វើការទាមទារនូវសិទ្ធិទាំងនេះ ក៏ដោយសារគេបានសិក្សានៅសាលា នៅតាមសិក្ខាសាលា និងនៅសាកលវិទ្យាល័យ ដែលពួកអេស្ប៉ាញផ្តល់ឱ្យដែរ។ ពួកអេស្ប៉ាញ ដែលគ្រប់គ្រងនៅប្រទេសហ្វីលីពីនបានបង្កើតនូវស្ថានភាពមួយ ដែលមិនដូចនៅកន្លែងដទៃទៀតនៅ អាស៊ី អាគ្នេយ៍។ មនុស្សដែលស្ថិតក្រោមការតាំងអាណានិគម បានចាប់ផ្តើមរៀបចំការបះបោរប្រឆាំងនឹងការគ្រប់គ្រងរបស់អេស្ប៉ាញនៅសតវត្សទី១៩ តាមពិតក៏ដោយសារជនជាតិហ្វីលីពីនមិនត្រូវបានគេអនុញ្ញាតឱ្យមានតួនាទីដូចអេស្ប៉ាញ។ ក្នុងការប្រយុទ្ធប្រឆាំងនឹងឧបសគ្គទាំងឡាយ ដែលរាំងស្ទះមិនឱ្យពួកគេមានសិទ្ធិដូចពួកអេស្ប៉ាញនោះ ជនជាតិហ្វីលីពីនបានបង្កើតនូវអត្តសញ្ញាណជាតិផ្ទាល់របស់គេ។ តែទោះជាយ៉ាងណា អត្តសញ្ញាណជាតិនេះ នៅតែមានទំនាក់ទំនងយ៉ាងស្អិតល្មួតជាមួយបទពិសោធនៃការគ្រប់គ្រងរបស់អេស្ប៉ាញ ហើយនិងតួនាទីសំខាន់នៃសាសនាកាតូលិកដែរ។

គេអាចយល់ឃើញយ៉ាងត្រឹមត្រូវថា មហាអំណាចអាណានិគមនិយមបានបង្កើត ព្រំដែនដែលមិនធ្លាប់មានពីមុនមក ហើយសកម្មភាពរបស់ពួកគេមិនចំពោះថា អាក្រក់ ឬល្អ មិនថាសម្រាប់ជាផលប្រយោជន៍ខ្លួនគេផ្ទាល់ ឬសម្រាប់ផលប្រយោជន៍អ្នកដទៃ ដែលបានរួមចំណែកក្នុងការបង្កើតថ្មីៗ នៅអាស៊ីអាគ្នេយ៍នោះឡើយ។ គេក៏គួរចងចាំដែរថា ការវិវឌ្ឍក្នុងសភាពដូច្នេះ មិនកើតមានឡើងតែក្នុងតំបន់មួយក្នុងពិភពលោកទេ។ ការកំណត់ព្រំដែនថ្មី និងការស្ថាបនារដ្ឋថ្មីៗ នៅសម័យអាណានិគមមាននៅទ្វីបអាម៉េរិក និងអាស៊ីអាគ្នេយ៍ដូចគ្នា។

ទោះជាយ៉ាងណា ក្រៅពីបញ្ហារដ្ឋបាលទាំងនេះ ក៏នៅមានបញ្ហាដទៃទៀតកើតឡើងជាមួយគ្នាដែរគ្រាន់តែថា ចំណុចទាំងនេះរហូតមកមានរៀបរាប់ត្រួសៗប៉ុណ្ណោះ។ មហាអំណាចអាណានិគមបានកំណត់នូវបន្ទាត់ព្រំដែនរដ្ឋ និងបានរួមចំណែកក្នុងការកំណត់ស្ថានភាពប្រជាជនរបស់រដ្ឋទាំងនេះ។ ទោះជាយ៉ាងនេះក៏ដោយក៏ប្រជាជនស្រុកអាយដែលជាជនជាតិអាស៊ីអាគ្នយ៍ខ្លួនឯងផ្ទាល់ គឺជាអ្នកសម្រេចថា តើខ្លួនគួររស់នៅតាមរបៀបណា និងតាមក្រិត្យក្រមណាមួយ។ ពេលសិក្សាអំពីការប្រឈមនិងការពង្រីកអំណាចរបស់ពួកអឺរ៉ុបក្នុងតំបន់អាស៊ីអាគ្នយ៍ គេចាំបាច់ត្រូវចងចាំនូវចំណុចនេះ ។

## ៧-ការប្រែប្រួលផ្នែកសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍

វត្តមានរបស់ពួកអឺរ៉ុបនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បានធ្វើឱ្យតំបន់នេះមានការប្រែប្រួលយ៉ាងខ្លាំង ស្ទើរតែគ្រប់ផ្នែកទាំងអស់ ជាពិសេសវិស័យសេដ្ឋកិច្ចក៏មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ផងដែរ។

ថ្វីបើការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ចាប់តាំងពីសតវត្សទី១៧ រហូតមក មានការចូលរួមដ៏សំខាន់របស់ប្រជាជនម្ចាស់ស្រុកនៅក្នុងតំបន់នេះក៏ដោយ ក៏ពុំមានមធ្យោបាយណាមួយអាចចៀសឱ្យផុតពីសេចក្តីសន្និដ្ឋានថា ការផ្លាស់ប្តូរដ៏ធំនោះបានកើតឡើងដោយសារ តែគំនិតរបស់ពួករដ្ឋបាល អាណានិគម ដែលគ្រប់គ្រងប្រទេសទាំងអស់នោះឡើយ។ បើនិយាយពីផលប្រយោជន៍របស់ពួកម្ចាស់ស្រុកវិញ ការ

ផ្លាស់ប្តូរជាច្រើននេះ មានលក្ខណៈអវិជ្ជមាន ហើយម្យ៉ាងទៀត យើងនឹងឃើញថា ពួកម្ចាស់ អាណានិគមកម្រគិតគូរពីផលប្រយោជន៍របស់ប្រជាជនក្នុងស្រុកជាជាងប្រយោជន៍របស់ពួកគេណាស់។

ដូចបានបញ្ជាក់ខាងលើហើយថា វត្តមានរបស់ពួកអឺរ៉ុបដំបូងនៅអាស៊ីអាគ្នេយ៍ គឺពាណិជ្ជកម្ម គ្រឿងទេស និងការផ្សព្វផ្សាយសាសនាគ្រិស្ត។ នៅអំឡុងពេលចន្លោះសតវត្សទី១៦ និងទី១៧ ពួកព័រទុយហ្គាល់ និងពួកហូឡង់ បានសម្រេចនូវគោលបំណងរបស់ពួកគេ។ ពួកគេបានគ្រប់គ្រងផ្តាច់មុខនូវគ្រឿងទេស នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសនោះគឺនៅប្រជុំកោះទាំងឡាយនៅក្នុងប្រទេសឥណ្ឌូណេស៊ីសព្វថ្ងៃនេះ ហើយនេះគឺមានន័យថា គេបានគ្រប់គ្រងការផ្គត់ផ្គង់ផលិតផលទាំងនោះសម្រាប់ទីផ្សារអឺរ៉ុប។ ប៉ុន្តែដើម្បីធ្វើដូច្នេះទៅបាន ពួកគេចាប់ផ្តើមបង្កើតនូវយន្តការមួយ ដែលធ្វើឱ្យមានភាពក្រីក្រនៅក្នុងចំណោម កសិករនៅក្នុងភូមិភាគទាំងឡាយនៅប្រទេសឥណ្ឌូណេស៊ី ដែលបញ្ហានេះនៅតែមានស្លាកស្នាមបន្តរហូតមកដល់បច្ចុប្បន្ន។ ពួកហូឡង់មានគោលបំណងក្នុងការគ្រប់គ្រងទាំងស្រុងទៅលើជំនួញគ្រឿងទេស និងខំប្រឹងធ្វើឱ្យសម្រេចបាននូវគោលបំណងនេះតាមរយៈការបំផ្លិចបំផ្លាញដើមគ្រឿងទេសទាំងឡាយណា ដែលនៅក្រៅភូមិភាគដែលគេកាន់កាប់។ ក្នុងនាមជាអ្នកមកពីខាងក្រៅ ដែលបានធ្វើការនៅក្នុងប្រព័ន្ធមានស្រាប់នោះ ពួកហូឡង់ ដោយមានឧត្តមភាពខាងផ្នែកបច្ចេកទេស និងការគ្រប់គ្រង បានចាប់ផ្តើមផ្លាស់ប្តូរនូវប្រព័ន្ធដែលមានស្រាប់នោះ។ ប្រជុំកោះទាំងឡាយ ដែលពេលមួយនោះ គឺជាចំណែកនៅក្នុងជំនួញមួយដែលមានលំនាំតាមរបៀបបុរាណនោះបានត្រូវគេដកចេញ។ ម្យ៉ាងទៀត ទោះជានៅពេលដែលគេអនុញ្ញាតឱ្យមានការដាំដំណាំទាំងនោះក៏ដោយ ក៏ពួកហូឡង់បានបំផ្លាញចោលដែរ ដើម្បីថែរក្សាតម្លៃឱ្យនៅកាន់តែខ្ពស់ដោយចំណាយពេលវេលាដ៏ខ្លី។ ដូច្នេះសកម្មភាពសេដ្ឋកិច្ចតំបន់អាស៊ីអាគ្នេយ៍ បានផ្សារភ្ជាប់យ៉ាងឆាប់រហ័សជាមួយនឹងសេដ្ឋកិច្ចទីផ្សាររបស់ពួកអឺរ៉ុបដែលមិនដែលមានពីមុនមក។

នៅពេលពួកហូឡង់ ទទួលជោគជ័យក្នុងការគ្រប់គ្រងជំនួញផ្កាក្លាំពូ និងគ្រាប់ប៉ូចកាក់ នៅផ្នែកខាងកើតប្រទេសឥណ្ឌូណេស៊ី និងជំនួញម្រេចនៅភាគជាច្រើននៃភូមិភាគខាងលិចហើយនោះ នៅអំឡុងសតវត្សទី១៨ ពួកគេបានបន្តបង្កើនការគ្រប់គ្រងកាន់តែខ្លាំងឡើងថែមទៀត ទៅលើការដាំដុះ និងការស្វែងរកទីផ្សារសម្រាប់ផលិតផលនៅក្នុងកោះជ្វា។ ជាពិសេសបំផុតនោះ កាហ្វេ បានក្លាយទៅជាកម្មវត្ថុនៃការបញ្ញត្តិច្បាប់របស់ពួកហូឡង់។ ពួកហូឡង់បានធ្វើជំនួញទាំងនោះតាមរយៈពួកមេដឹកនាំ នៅតាមតំបន់និងពួកភ្នាក់ងារចិនក្នុងពេលនោះ ពួកគេបានដក់ខ្លួនចេញពីដំណើរការសកម្មភាព។ ប៉ុន្តែពួកហូឡង់ គឺជាអ្នកកំណត់ លើប្រព័ន្ធនៃ "ការប្រគល់ឱ្យដោយបង្ខំ" ដែលទាមទារយកផលិតផលទៅតាមចំនួនដែលគេបានកំណត់ ដើម្បីផ្តល់ទៅឱ្យក្រុមហ៊ុនឥណ្ឌាខាងកើត ដោយគំរាមថា នឹងដាក់ទណ្ឌកម្មយ៉ាងធ្ងន់ទៅលើភូមិទាំងឡាយណា ដែលមិនបានផ្តល់ផលិតផលតាមការគ្រោងទុក។ នៅពេលដដែលនេះដែរ ការរំពឹងទុករបស់ពួកហូឡង់ គឺថា ប្រជាជនឥណ្ឌូណេស៊ីដែលបានផ្តល់ផលិតផល ទៅតាមសេចក្តីត្រូវការទីផ្សារអឺរ៉ុបនោះ នឹងមានទីផ្សារសម្រាប់ផលិតផលសម្រេច ជាពិសេសក្រណាត់ ដែលពួកនេះបាននាំតាមកប៉ាល់ចូលមកតំបន់ អាស៊ីអាគ្នេយ៍ វិញផងដែរ។

សតវត្សទី១៩ គឺជាយុគនៃការធ្វើឧស្សាហូបនីយកម្មនៅបណ្តាប្រទេសអឺរ៉ុប។ បដិវត្តន៍បច្ចេកទេសនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឱ្យមានការុករកដែនដីអាណានិគមក្រៅប្រទេស។ ក្នុងន័យសាមញ្ញ ដែនដីអាណានិគម គឺជាធាតុសំខាន់ក្នុងបែបបទសកម្មភាពសេដ្ឋកិច្ច ដែលតម្រូវឱ្យមានការផ្គត់ផ្គង់វត្ថុធាតុដើមទៅដល់ប្រទេសឧស្សាហកម្មទាំងឡាយនៅអឺរ៉ុប។ នៅពេលគេកែច្នៃវត្ថុធាតុដើមឱ្យទៅជាផលិតផលសម្រេចហើយគេក៏អាចលក់ទៅកាន់ទីផ្សារនានានៅលើពិភពលោក បើអាចទៅរួច រួមទាំងដែនដីអាណានិគម ដែលជាទី

កន្លែងផ្តល់វត្ថុធាតុដើមនោះផងដែរ។ បើពិនិត្យមើលត្រឡប់ទៅក្រោយវិញនោះ ប្រព័ន្ធទាំងមូល ហាក់ដូចជាមិនមានតុល្យភាពទេ។ ចំពោះពួកអឺរ៉ុប ពួកម្ចាស់ស្រុកនៅតំបន់អាស៊ីអាគ្នេយ៍ ឧទាហរណ៍ដូចជា នៅភូមា នៅវៀតណាម ឬនៅហ្វីលីពីន ត្រូវបំពេញតួនាទីរបស់ខ្លួន ដោយគ្មានការត្អូញត្អែរ ដើម្បីជួយឱ្យពួកម្ចាស់អាណានិគម ដែលជាចៅហ្វាយនាយរបស់ពួកគេ កាន់តែមានហូរហៀរថែមទៀត ទោះជាពួកម្ចាស់ស្រុកផ្ទាល់បានទទួលមកវិញនូវកម្រៃដ៏តិចតួចបំផុតនោះក៏ដោយ។ រឿងដែលថាមាននូវអតុល្យភាព ហើយថាបញ្ហានេះមិនបានបង្កនូវភាពស្មុគស្មាញ ដល់ពួកអាណានិគមនិយមអឺរ៉ុបមួយចំនួនធំនោះ ជារឿងដែលពិបាកនឹងជឿក៏ពិតមែន ប៉ុន្តែនោះគឺជារឿងពិតជាក់ស្តែង។ លក្ខណៈសំខាន់មួយនៃសម័យពង្រីកដែនដីអាណានិគម និងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច ដែលបានដើរទន្ទឹមគ្នាមកនោះគឺជាជំនឿមួយថា អ្វីដែលពួកអាណានិគមកំពុងធ្វើនោះគឺត្រឹមត្រូវនិងសមស្រប។

សេចក្តីត្រូវការជាច្រើននៅក្នុងវិស័យឧស្សាហកម្ម បានជំរុញឱ្យពួកម្ចាស់អាណានិគមទាំងឡាយ ពង្រីកដីដាំកៅស៊ូ ការជីករុករកសំណប៉ាហាំង និងការដាំដើមដូង។ តំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជាតំបន់ អាហ្វ្រិកដែរ គឺជាតំបន់ដែលអាចផ្គត់ផ្គង់វត្ថុសំខាន់ៗ ជាច្រើនសម្រាប់បំពេញសេចក្តីត្រូវការរបស់ប្រទេសទំនើបនៅអឺរ៉ុប និងអាម៉េរិកនៅក្នុងសតវត្សទី១៩។ សំណប៉ាហាំងពីមឡាយូ និងឥណ្ឌូណេស៊ីរបស់ហូឡង់ ដែលអាចជួយបំពេញសេចក្តីត្រូវការដល់ប្រទេសឧស្សាហកម្មដទៃទៀត ដើម្បីផលិតដែក ថោកៗនិងកងគ្លី ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតឱ្យមានឱ្យមានម៉ាស៊ីនរោងចក្រមានល្បឿនលឿន។ កៅស៊ូមកពីតំបន់អាស៊ីអាគ្នេយ៍ទាំងមូល ជាពិសេសមកពីមឡាយូ ឥណ្ឌូណេស៊ី និងឥណ្ឌូចិន បារាំង អាចបំពេញសេចក្តីត្រូវការជាច្រើនដល់សង្គមទាំងឡាយដែលនឹងអភិវឌ្ឍបន្ថែមទៀតទៅលើ សម្ភារមួយចំនួន ចាប់តាំងពីកង់ រថយន្ត។ ដូងចូលរួមយ៉ាងសំខាន់ក្នុងការពង្រីកនូវឧស្សាហកម្មសាប៊ូ ដោយសារជីវភាពរស់នៅ នៅអឺរ៉ុប និងអាមេអាម៉េរិករិក មានការធ្វើ អនាម័យខ្លួនប្រាណជារឿងធម្មតា។

នៅសតវត្សទី១៩ ចាប់តាំងពីតំបន់អាស៊ីអាគ្នេយ៍ បានបំពេញសេចក្តីត្រូវការថ្មីៗ របស់អឺរ៉ុបមក យើងអាចយល់ឃើញថា ទំនាក់ទំនងសេដ្ឋកិច្ចបែបថ្មីរវាងតំបន់អាស៊ីអាគ្នេយ៍ និងប្រទេសឧស្សាហកម្ម បានចាប់ផ្តើមនៅក្នុងសតវត្សនោះ។ ប្រព័ន្ធចាស់ដែលជាជំនួញគ្រឿងទេសផ្តាច់មុខរបស់ពួកហូឡង់ នោះ បានក្លាយជារឿងមិនសំខាន់នៅពេលដែលលំនាំថ្មីបានកើតឡើង[419]។

## សំណួរត្រិះរិះ

១-ចូរពន្យល់ពីគោលបំណង នៃនយោបាយអាណានិគមនិយមរបស់ពួកអឺរ៉ុប។

២-តើមហាអំណាចអឺរ៉ុបណាខ្លះ ដែលបានមកដាក់អាណានិគមនៅអាស៊ីអាគ្នេយ៍? ដាក់ការត្រួតត្រាលើប្រទេសណាខ្លះនៅក្នុងតំនប់នោះ?

៣-ក្រោមវត្តមានរបស់បារាំង តើតំបន់ឥណ្ឌូចិនមានការប្រែប្រួលដូចម្តេចខ្លះ?

៤-តើវត្តមានបារាំងបានផ្តល់ផលវិបាកដូចម្តេចខ្លះដល់ឥណ្ឌូចិន?

[419] មិល្តុន អូស្បិន, *ផ្តើមល្បែងយល់ពីប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍*, មជ្ឈមណ្ឌលខេមរសិក្សា, ឆ្នាំ២០០៩, ទំព័រ១០៦។

# មេរៀនទី៣ អាស៊ីអាគ្នេយ៍ និងឯករាជ្យ

តើមូលហេតុអ្វីខ្លះដែលនាំឱ្យបណ្តាប្រទេសអាស៊ីអាគ្នេយ៍ទទួលបានឯករាជ្យ ជាបន្តបន្ទាប់ក្រោយសង្គ្រាមលោកលើកទី២?

១-ការលេចឡើងនូវបញ្ញវន្តនៅអាស៊ីអាគ្នេយ៍ដែលទទួលបានការអប់រំ ពីប្រទេសលោកខាងលិច ៖

- បញ្ញវន្តតាមបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ទទួលបានចំណេះដឹងពីគំនិតជាតិនិយម ហើយពួកគេចាប់ផ្តើមមានគំនិតចង់រំដោះជាតិខ្លួន។
- បញ្ញវន្តទាំងនោះចាប់ផ្តើមបង្កើតក្រុម សមាគមបោះពុម្ព កាសែត ទស្សនា វដ្តី ដើម្បីផ្សព្វផ្សាយអំពីគំនិតសេរីភាព និងចលនាតស៊ូ ទាមទារឯករាជ្យរបស់ពួកគេ។

២-ឥទ្ធិពលសង្គ្រាមលោកលើកទី២ និងការឈ្លានពានរបស់ជប៉ុន ៖

- សង្គ្រាមលោកលើកទី២ បានធ្វើឱ្យប្រទេសម្ចាស់អាណានិគម ខ្ទេចខ្ទាំ និងទន់ខ្សោយទាំងផ្នែកសេដ្ឋកិច្ច និងយោធា។ ឧទាហរណ៍ ប្រទេសបារាំង និងហូឡង់ ត្រូវបានអាល្លឺម៉ង់ឈ្លានពានតាំងតែពីឆ្នាំ១៩៤០មកម្ល៉េះ។
- ការឈ្លានពានរបស់ជប៉ុនមកលើប្រទេសអាស៊ីអាគ្នយ៍ ដែលនៅក្រោមអាណានិគមអឺរ៉ុប បានធ្វើឱ្យប្រជាជន អាស៊ីអាគ្នេយ៍ភ្ញាក់ខ្លួនថា អាណានិគមអឺរ៉ុបមិនមែនមិនអាចផ្តួលរំលំបាននោះទេ។
- នៅក្រោមការត្រួតត្រារបស់ជប៉ុន ម្ចាស់ស្រុកបានគ្រប់គ្រងការងាររដ្ឋបាលដោយខ្លួនឯង ហើយជប៉ុនបានហ្វឹកហាត់កងទ័ពនៃប្រទេសទាំងនោះដើម្បីប្រឆាំងនឹងពួកអឺរ៉ុប។ នៅពេលដែលជប៉ុនចាកចេញ មានលទ្ធភាពច្រើនក្នុងការប្រឆាំងនឹងពួកអឺរ៉ុបដោយខ្លួនឯង។

៣-ឥទ្ធិពលសង្គ្រាមត្រជាក់៖

សង្គ្រាមត្រជាក់បានជំរុញចលនាទាមទារឯករាជ្យឱ្យកាន់តែខ្លាំងបន្ថែមទៀត តាមរយៈការគាំទ្រពីភាគីលោកសេរីផង និងក្រុមដែលទទួលបានការគាំទ្រពីភាគីកុម្មុយនីស្តផង។ **ឧទាហរណ៍** : ចលនាតស៊ូរបស់វៀតមិញបានធ្វើសង្គ្រាមប្រឆាំងបារាំងនៅវៀតណាមខាងជើង ដោយទទួលបានការគាំទ្រពីមហាអំណាចកុម្មុយនីស្ត ចិន និងសូវៀត។ ចំណែកកម្ពុជាវិញ ព្រះបាទនរោត្តម សីហនុ បានទាមទារឯករាជ្យដោយអហិង្សាតាមរយៈការជំរុញឱ្យបារាំងផ្តល់ឯករាជ្យ ដើម្បីទប់ស្កាត់ការរីករាលដាលនៃចលនាកុម្មុយនីស្តនៅកម្ពុជា[420]។

## ១-ប្រទេសវៀតណាមក្រោយសង្គ្រាមលោកលើកទី២

### ១.១-ដំណាក់កាលតស៊ូដណ្តើមឯករាជ្យ

ប្រវត្តិសាស្ត្រនៃការតស៊ូរបស់វៀតណាមប្រឆាំងនឹងរបបអាណានិគម នៅក្នុងប្រទេសវៀតណាម គឺមានភាពខុសគ្នាយ៉ាងខ្លាំង ដូច្នេះហើយលទ្ធផលនៃការតស៊ូនោះ ក៏មានភាពខុសគ្នាដែរ ភាពខុសគ្នាទាំងអស់នេះមិនត្រឹមតែស្ថិតនៅលើរឿងដែលថា ជនកុម្មុយនីស្តនៅក្នុងប្រទេសវៀតណាម បានដឹកនាំការប្រយុទ្ធប្រឆាំងទៅនឹងពួកបារាំងប៉ុណ្ណោះទេ។ មានភាពខុសគ្នាយ៉ាងច្រើនផងដែរ បើយើងនិយាយពីរយៈពេល ដែលចំណាយក្នុងការតស៊ូ ហើយនឹងសង្គ្រាមយោធាក៏ខ្លាំង ដែលបានធ្វើនោះ។ បន្ថែមលើសនេះទៅទៀតនៅពេលដែលពួកបារាំង បានចាកចេញពីប្រទេសវៀតណាម និងលះបង់ការព្យាយាមរបស់ខ្លួនក្នុងការថែរក្សានូវគំនិតអាណា

[420] ក្រសួងអប់រំ យុវជន និងកីឡា, *សេចក្តីសង្ខេបប្រវត្តិសាស្ត្រតំបន់អាស៊ីអាគ្នេយ៍ និងពិភពលោក*, ឆ្នាំ២០២០, ទំព័រ១០។

និគមនិយមនៅក្នុងឆ្នាំ១៩៥៤ នោះ ទឹកដីប្រទេសវៀតណាមតែពាក់ កណ្ដាលប៉ុណ្ណោះ ស្ថិតក្រោមការកាន់កាប់របស់កងកម្លាំងវៀតណាម ដែលបានធ្វើឱ្យពួកបារាំងបរាជ័យគួរឱ្យភ្ញាក់ផ្អើលបំផុត នៅសមរភូមិឌៀន-បៀនភូ។

ជាការបើកឆាកដល់សង្គ្រាមឥណ្ឌូចិនលើកទី២ ពីចុងទសវត្សរ៍ឆ្នាំ១៩៥០ រហូតដល់ឆ្នាំ១៩៧៥ សង្គ្រាមវៀតណាម ប្រឆាំងនឹងបារាំងក្នុងចន្លោះឆ្នាំ១៩៤៦ មកដល់ឆ្នាំ១៩៥៤នោះ មានគេដឹងតិចតួចណាស់។ ព្រឹត្តិការណ៍ដែលកើតឡើងនៅពេល ដែលពួកអាម៉េរិកលូកដៃចូលរវាងទសវត្សរ៍ឆ្នាំ១៩៦០ និងទសវត្សរ៍ឆ្នាំ១៩៧០ បានធ្វើឱ្យគេមិនសូវចាប់អារម្មណ៍ចំពោះការវិវត្តនៃព្រឹត្តិការណ៍មុនៗទេ។ ប៉ុន្តែ ទោះបីជាព្រឹត្តិការណ៍ចន្លោះឆ្នាំ១៩៤៦ និង១៩៥៤ នៅក្នុងប្រទេសវៀតណាម មានគេយល់ក្តី ក៏ពិបាកនឹងយល់ឱ្យច្បាស់ថា ហេតុអ្វីជនកុម្មុយនីស្តវៀតណាមក្រោយមកត្រូវតែធ្វើសង្គ្រាមអស់រយៈពេលយ៉ាងយូរ ទើបបានសម្រេចនូវគោលបំណងរបស់ពួកគេខណៈដែលពួកបារាំងលែងជាសត្រូវទៅហើយនោះ។

បដិវត្តន៍វៀតណាមដ៏សម្បើមឆ្នាំ១៩៤៥ និងការប្រកាសឯករាជ្យបន្ទាប់មកនោះ មិនអាចរារាំងមិនឱ្យបារាំងត្រឡប់មកវិញបានឡើយ។ នៅវៀតណាមខាងត្បូងកងទ័ពអង់គ្លេសបានរៀបចំផ្លូវមួយ សម្រាប់រៀបចំបង្កើតរដ្ឋបាលអាណានិគមឡើងវិញ។ នៅក្នុងទឹកដីពាក់កណ្តាលទៀត នៅភាគខាងជើង កងកម្លាំងអ្នកជាតិនិយមចិន បានដើរតួនាទីជាអ្នកតំណាងឱ្យសម្ពន្ធមិត្តរបស់ខ្លួនរហូតទាល់តែពួកបារាំងអាចត្រៀមខ្លួនរួចរាល់មកប្រកាសការតាំងអាណានិគមរបស់ខ្លួនឡើងវិញ។ កងកម្លាំងឈ្លានពានទាំងនេះ ទាំងនៅក្នុងវៀតណាមភាគខាងជើង និងភាគខាងត្បូងបានរារាំងមិនឱ្យពួកវៀតមិញដែលដឹកនាំ ដោយពួកកុម្មុយនីស្តសម្រេចគោលបំណងរបស់ពួកគេ ក្នុងការបង្កើតនូវរដ្ឋបាលអចិន្ត្រៃយ៍មួយបានឡើយ។ ប៉ុន្តែនៅទូទាំងប្រទេស ហើយជាពិសេសនៅភាគខាងជើង ដែលជាតំបន់ដែលពួកកុម្មុយនីស្តមានកងកម្លាំងច្រើនបំផុតនោះ ពួកវៀតមិញខំប្រឹងប្រែងពង្រឹងគោលជំហរ ផ្នែកនយោបាយរបស់ខ្លួននៅខណៈដែលពួកគេចាប់ផ្តើមធ្វើការចរចាជាលើកដំបូងនៃការចរចាជាបន្តបន្ទាប់ជាមួយពួកបារាំង។

ដោយសារតែមានការប្រយុទ្ធគ្នាយ៉ាងជូរចត់ និងយូរអង្វែងកើតឡើងបន្ទាប់មកនោះគេច្រើនភ្លេចថា មួយភាគធំនៃឆ្នាំ១៩៤៦ បានចំណាយទៅលើការចរចាទ្វេភាគី រវាងបារាំង និងវៀតណាម។ យ៉ាងហោចណាស់នៅត្រង់ចំណុចនេះមានភាពស្រដៀងគ្នារវាងការវិវត្តនៅប្រទេសវៀតណាម និងនៅឥណ្ឌូណេស៊ី។ ក្នុងករណីទាំងពីរ កងកម្លាំងប្រឆាំងអាណានិគមបានត្រៀមខ្លួនជាស្រេច ដើម្បីធ្វើការចរចាជាមួយនឹងអតីត របបអាណានិគម។ ប៉ុន្តែ នៅក្នុងករណីទាំងពីរសេចក្តីសង្ឃឹមរបស់ជនជាតិឥណ្ឌូណេស៊ី និងវៀតណាម គឺមានភាពខុសគ្នាយ៉ាងខ្លាំងពីសេចក្តីសង្ឃឹមរបស់ពួកហូឡង់ និងបារាំង ដែលមានលទ្ធភាពពិតប្រាកដណាមួយក្នុងការស្វែងរកដំណោះស្រាយតាមរយៈការចរចានោះ។ ប្រហែលអាចលើស ពីសេចក្តីសង្ឃឹមរបស់ពួកហូឡង់ ក្នុងទំនាក់ទំនាក់ទំនងជាមួយនឹងឥណ្ឌូណេស៊ីក្រោយសង្គ្រាមលោកលើកទី២ បញ្ចប់ទៅភ្លាមៗ រដ្ឋាភិបាលបារាំងមួយហើយមួយទៀតបានប្តេជ្ញាចិត្តរឹតបន្តឹងការគ្រប់គ្រង ទៅលើអតីតទឹកដីអាណានិគមរបស់ខ្លួននៅប្រទេសវៀតណាម នៅកម្ពុជា និងឡាវ។ ដោយសារតែពួក វៀតមិញបានប្តេជ្ញាចង់ឱ្យគេគោរពឯករាជភាព ដែលបានប្រកាសឡើងនៅឆ្នាំ១៩៤៥ ប៉ុន្តែដោយទន្ទឹម គ្នានឹងនោះដែរពួកបារាំងនៅតែជឿជាក់យ៉ាងមុតមាំថា ប្រទេសវៀតណាមជាផ្នែកមួយនៃឥណ្ឌូចិនរបស់បារាំងនោះ ដូច្នេះច្រកចេញនោះគ្មានអ្វីក្រៅពីសង្គ្រាមនោះឡើយ។

សង្គ្រាមឥណ្ឌូចិនលើកទី១ បានចាប់ផ្តើមឡើងក្នុងលក្ខណៈជាសង្គ្រាមទ័ពព្រៃ ប៉ុន្តែ នៅដំណាក់កាលជិតចប់សង្គ្រាមនេះ បានប្រើប្រាស់កម្លាំងយោធាគ្រប់កម្រិតគឺតាំងពីការប្រយុទ្ធធំៗដោយប្រើកងកម្លាំងធំៗ រហូត

ទៅដល់ ការប្រទូសប្រទាស់តូចតាចនៅតាមតំបន់។ ជាពិសេសបើតាមទស្សនៈរបស់វៀតណាម សង្គ្រាមនេះមានលក្ខណៈជាសង្គ្រាមនយោបាយធំណាស់។ ការវាយឱ្យពួកបារាំងបរាជ័យ មិនមែនជាគោលដៅដែលត្រូវប្រើកម្លាំងទ័ពតែមួយមុខប៉ុណ្ណោះនោះទេ ប៉ុន្តែដោយសារមានប្រមូលផ្តុំ រាល់ធនធានទាំងអស់ ដែលអាចយកមកប្រើដើម្បីរាំងដល់គោលបំណងរបស់សត្រូវ។ ពួកវៀកមិញ ខំប្រឹងប្រែងធ្វើឱ្យពួកបារាំងនៅក្នុងប្រទេសវៀតណាមចុះខ្សោយគ្រប់កម្រិតទាំងអស់ ដោយរៀបចំរដ្ឋបាលស្រដៀងគ្នា នឹងរដ្ឋបាលរបស់បារាំងដែរ។ ការធ្វើដូច្នេះពួកអ្នកប្រមូលពន្ធ របស់ពួកវៀតមិញ មិនត្រឹមតែប្រមូលពន្ធនៅក្នុងតំបន់ដែលពួក វៀតមិញកាន់កាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏ប្រមូលដោយលួចលាក់នៅក្នុងតំបន់ដែលគេគិតថា ជាតំបន់របស់ពួកបារាំងផងដែរ។ លើសពីនេះទៅទៀតទស្សនរបស់វៀតមិញទៅលើសង្គ្រាមថា គ្រាន់តែជាទិដ្ឋភាពមួយនៃការ តស៊ូខាងផ្នែកនយោបាយដែលមានទិដ្ឋភាពធំជាងមុននោះ បាននាំឱ្យមេដឹកនាំពួកគេ បន្តនូវគោលដៅដែលពីដំបូងមើលទៅហាក់ដូចជាមិនទាន់អាចមានតម្លៃផ្នែកយោធាច្រើនប៉ុន្មានទេ តែដល់យូរៗ ទៅបានដើរតួនាទីយ៉ាងសំខាន់សម្រាប់យុទ្ធសាស្ត្រទាំងមូលនោះ។ ដូចជានៅក្នុងករណីដែលពួកវៀតមិញខំប្រឹងប្រែងលើកស្ទួយវិស័យអក្ខរកម្ម។ សារប្រយោជន៍ដែលអាចនាំមកពីការមានប្រជាជនចេះអក្សរ អាចអានសេចក្តីពន្យល់ណែនាំរបស់អ្នកដឹកនាំបាន ដើម្បីបន្តនយោបាយណាមួយនោះ គឺមានន័យថាទោះបីមានសង្គ្រាមក៏ដោយក៏កម្មវិធីនេះអាចបន្តទៅទៀតបានដែរ។

កម្លាំងរបស់កងទ័ពវៀតណាម វាយប្រឆាំងជាមួយនឹងពួកបារាំងនោះ មានសន្ទុះខ្លាំងបំផុតនៅក្នុងតំបន់ភាគខាងជើង ហើយគឺនៅក្នុងតំបន់ខាងជើងនោះហើយ ដែលសមរភូមិធំៗបានផ្ទុះឡើង។ រឿងនេះមិនមែនសំដៅលើន័យថា សង្គ្រាមឥណ្ឌូចិនលើកទី១ គឺគ្រាន់តែជារឿងដែលពាក់ព័ន្ធនឹងប្រជាជនវៀតណាមខាងជើងនឹងពួកបារាំងនោះទេ។ ពួកវៀតណាមបានវាយប្រយុទ្ធនឹងពួកបារាំងពាសពេញប្រទេសវៀតណាមទាំងអស់ ហើយនៅប៉ុន្មានឆ្នាំចុងក្រោយនៃសង្គ្រាមផែនទីកងទ័ពរបស់បារាំងផ្ទាល់បានបង្ហាញថា ទឹកដី ភាគច្រើននៅវៀតខាងត្បូងបានស្ថិតនៅក្នុងកណ្តាប់ដៃរបស់ពួកវៀតមិញទៅហើយ។ ប៉ុន្តែយុទ្ធនាការដំបូងនៃសង្គ្រាមទ័ពព្រៃរបស់ពួកវៀតមិញនៅភាគខាងជើង បានវិវត្តទៅជាយុទ្ធនាការ ដែលជាប់ពាក់ព័ន្ធនឹងកងទ័ពរាប់ពាន់ និងសមរភូមិសង្គ្រាមធំៗ ជាច្រើននេះមានសភាពខុសគ្នាពីអ្វីដែលកើតឡើងនៅវៀតណាមខាងត្បូង។ នៅវៀតណាមខាងត្បូង កងកម្លាំងវាយប៉ាយរបស់ភាគីទាំងពីរ បានប៉ះទង្គិចគ្នាជាលក្ខណៈសង្គ្រាម វាយឆ្មក់ជាញឹកញាប់ ហើយសកម្មភាពជាច្រើនរបស់កងកម្លាំងតូចៗ ដែលធ្វើការគ្រប់គ្រងលើទាំងទឹកដី និងទាំងប្រជាជនដែលច្រើនតែមាន ជម្លោះរវាងគ្នានឹងគ្នា។

បញ្ហាចម្បងរបស់ពួកបារាំងក្នុងការធ្វើសង្គ្រាម ដើម្បីបង្កើតការតាំងអាណានិគមសាជាថ្មីទៅលើ ប្រទេសវៀតណាមនោះគឺជាបញ្ហាពេលវេលា។ ពួកវៀតមិញបានត្រៀមខ្លួនជាស្រេចក្នុងការទទួលយក ការខាតបង់បណ្តាលមកពីការធ្វើសង្គ្រាមយ៉ាងយូរ ដោយព្រមទទួលស្គាល់ថាការខាតបង់ ដែលបណ្តាលមកពីការធ្វើសង្គ្រាមរយៈពេលយូរ បានផ្តល់នូវលទ្ធភាពក្នុងការបន្តទិសដៅរបស់ពួកគេយ៉ាងមានប្រសិទ្ធភាព។ ប៉ុន្តែសម្រាប់ពួកបារាំងគេមិនមានទស្សនៈដូចគ្នានេះទេ។ មេដឹកនាំទាំងឡាយរបស់បារាំង នៅឥណ្ឌូចិន ទាំងផ្នែកយោធា និងស៊ីវិលយល់ថា ការធ្វើសង្គ្រាមដ៏រាំរ៉ៃគ្មានថ្ងៃបញ្ចប់អាចនឹងនាំឱ្យមានការ អស់ជំនឿក្នុងចំណោមប្រជាជននៅក្នុងប្រទេសបារាំង។ ដូច្នេះពួកគេត្រូវតែប្រឹងប្រែងធ្វើយ៉ាងណាឱ្យសង្គ្រាមឆាប់ចប់។ ប៉ុន្តែនេះគឺអ្វីដែលយុទ្ធសាស្ត្ររបស់ពួកវៀតមិញមិនបានផ្តល់ឱកាសឱ្យពួកបារាំងទេ។ ពួកបារាំងមានលទ្ធភាពបង្កើតការតាំងអាណានិគមរបស់ពួកគេនៅក្នុងក្រុងហាណូយ និងនៅក្នុង ដីសណ្តទន្លេក្រហមនៅវៀតណាមខាងជើង។

ពួកគេនៅតែអាចរក្សាផ្លូវថ្នល់ និងផ្លូវដែកជាច្រើនឱ្យមានដំណើរ ការទោះបីជាមិនអាចធ្វើបានទាំងអស់ក៏ដោយ។ ម្យ៉ាងទៀតពួកគេអាចធានាថា ក្រុងមួយចំនួននៅក្នុងប្រទេសវៀតណាម មិនថាតូចឬធំនឹងមិនធ្លាក់ទៅក្នុងការវាយប្រហារភ្លាមៗ នោះទេ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ពួកបារាំងមិនអាចធ្វើឱ្យពួកសត្រូវ វៀតណាម ដឹកនាំដោយលោក វ៉ូ ង្វៀងយ៉ាប ស្គាល់បរាជ័យធ្ងន់នោះដែរ។ លោក យ៉ាប ក៏ដូចមេដឹកនាំ កុម្មុយនីស្តជាច្រើនទៀតដែរ គឺធ្លាប់បានពួករដ្ឋបាលអាណានិគម ចាប់ឃុំឃាំងក្នុងគុកអំឡុងទសវត្សរ៍ ឆ្នាំ១៩៣០។ នៅរវាងដើមឆ្នាំ ១៩៤៧ និងឆ្នាំ១៩៥០ កងកម្លាំងរបស់យ៉ាប បានធ្វើសង្គ្រាមជារបៀបជាយុទ្ធនាការវាយឆ្មក់ដោយមានជំនួយពីមេដឹកនាំយោធាវៀតមិញ ដែលណែនាំពីការយល់ដឹងនូវសារៈសំខាន់ នៃការងាររបស់លោក។ ការវាយប្រហារជាច្រើនលើកទៅលើពួកបារាំង គឺធ្វើឡើងនៅពេលពួកវៀតមិញមានឧត្តមភាពខាងចំនួន និងផ្នែកយុទ្ធសាស្ត្រច្រើនជាងប៉ុណ្ណោះ។ ពួកវៀតមិញបានជ្រើសរើសឱកាស និងទីកន្លែងដើម្បីធ្វើការវាយប្រហារ មកលើពួកបារាំងដោយមានការប្រុងប្រយ័ត្នបំផុត ដើម្បីបញ្ចៀសពួកបារាំងមិនឱ្យប្រមូលកម្លាំង មកតបតវិញ ភ្លាមៗបាន ឬប្រើកម្លាំងទ័ពអាកាស ដែលជាអាវុធមួយបែបដែលពួកវៀតមិញមិនមាននៅអំឡុងពេលធ្វើសង្គ្រាមនោះ។

តាមរយៈការបន្តគោលនយោបាយនេះ ពួកវៀតមិញមិនត្រឹមតែធ្វើឱ្យពួកបារាំងចំណាយពេល យ៉ាងច្រើនប៉ុណ្ណោះទេ តែពួកគេក៏អាចពង្រីក សមត្ថភាពរបស់ខ្លួន ទាំងផ្នែកយោធា និងនយោបាយផងដែរ។ នេះគឺជាផ្នែកនៃការពន្យល់ដាក់ច្បាស់ពីមូលហេតុអ្វី បានជាកងកម្លាំងរបស់ឧត្តមសេនីយ៍ យ៉ាប បានឡើងជាកងកម្លាំងយោធាដ៏សំខាន់។ បុគ្គលម្នាក់ដែលធ្លាប់បានទទួលការបណ្ដុះបណ្ដាលជាមេធាវី និងធ្លាប់បង្រៀនប្រវត្តិសាស្ត្រ ក្នុងនាមជាគ្រូបង្រៀន មិនអាចក្លាយទៅជាឧត្តមសេនីយ៍មួយរូប ដែលវិទ្យាល័យ យោធាទូទាំងពិភពលោក បានសិក្សាពីយុទ្ធនាការរបស់លោកដោយសារតែការចៃដន្យណាមួយនោះ។ ប៉ុន្តែបទពិសោធយោធារបស់យ៉ាប បានរីកចម្រើននៅក្នុងគន្លងមួយដែលលោកមានលទ្ធភាព អាចផ្គូផ្គង នឹងការរីកចម្រើននៃទេពកោសល្យកម្រិតខ្ពស់ក្នុងវិស័យយោធា ជាមួយនឹងតម្រូវការដែលកំពុងផ្លាស់ប្ដូរ និងកំពុងកើនឡើងក្នុងស្ថានភាពយុទ្ធសាស្ត្រ។ ប៉ុន្តែទោះបីជាលោកមានទេពកោសល្យក៏ដោយ ក៏លោកយ៉ាប នៅតែទទួលនូវការរុញច្រានឱ្យថយក្រោយដែរ នៅក្នុងអំឡុងឆ្នាំ១៩៥០ និង១៩៥១ នៅពេលពួកវៀតមិញព្យាយាមខ្លាំងឡើងៗ ក្នុងការវាយប្រយុទ្ធជាទ្រង់ទ្រាយធំជាមួយ នឹងពួកបារាំង។ ព្រឹត្តិការណ៍នៃការដកថយនេះមានសារប្រយោជន៍យ៉ាងខ្លាំង ដោយសារវាទាញអារម្មណ៍យើងឱ្យពិនិត្យមើលការប្រទាក់ក្រឡាគ្នា និងការខាតបង់ក្នុងបដិវត្តវៀតណាម។ ទោះបីជានៅក្នុងការវិភាគចុងក្រោយបដិវត្តកុម្មុយនីស្តនេះ បានទទួលភាពជោគជ័យក៏ដោយ ក៏ការរៀបរាប់អំពីប្រវត្តិប្រទេសវៀតណាម នៅក្រោយសង្គ្រាមលោកលើកទី២ នឹងនាំឱ្យមានការយល់ច្រឡំដែរ ប្រសិនបើយើងមិនបានគិតពីការលំបាកទាំងឡាយដែលបានកើតឡើងនៅពេលនោះ និងការខាតបង់យ៉ាងខ្លាំងមុននឹងឃើញលទ្ធផលនោះ។

ចំណុចនេះសមនឹងគេចងចាំនៅពេលគេនឹកឃើញដល់សង្គ្រាមដែលបានកំណត់នូវលទ្ធផល នៃសង្គ្រាមឥណ្ឌូចិនលើកទី១ ដែលជាសង្គ្រាមនៅឌៀនបៀនភូ ដែលបានបញ្ចប់ទៅនៅខែឧសភា ឆ្នាំ១៩៥៤ ការទទួលបានជោគជ័យរបស់ពួកវៀតមិញ នៅក្នុងសង្គ្រាមនេះបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការនាំឱ្យមានការដោះស្រាយមួយឈានទៅរកការចរចាគ្នា នៅសន្និសីទក្រុងហ្សឺណែវ នៅខែកក្កដា ឆ្នាំ១៩៥៤ ដែលទុកភាគខាងជើងនៃប្រទេសវៀតណាម នៅក្នុងការគ្រប់គ្រងរបស់ពួកកុម្មុយនីស្ត និងបានបន្សល់ទុកឱ្យភាគខាងត្បូងស្ថិតក្នុងបញ្ហា ដែលអាចដោះស្រាយបានទាល់តែនៅពេលដែលទឹកដី វៀតណាមទាំងអស់បានស្ថិតនៅ ក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលក្រុងហាណូយក្នុងឆ្នាំ១៩៧៥។ សេចក្ដីពិស្តារនៃសង្គ្រាមនេះបានធ្វើឱ្យអ្នកសិក្សា អំពី

ប្រវត្តិយោធាមានការចាប់អារម្មណ៍យ៉ាងខ្លាំង ជាពិសេស ដោយសារកំហុសដ៏ធំរបស់ពួកបារាំងក្នុងការជ្រើសរើសធ្វើការប្រយុទ្ធគ្នាជាមួយពួកវៀតមិញ នៅក្នុងតំបន់ឆ្ងាយៗ "ឆ្ងាយយ៉ាងខ្លាំងពីទីបញ្ជាការទ័ពរបស់ខ្លួននៅក្នុងក្រុងហាណូយ" ហើយបើគិតតាមស្ថាន ភាពជាក់ស្តែងគឺតំបន់ ដែលមិនសមនឹងយកមកធ្វើជាសមរភូមិទប់ទល់នឹងការឡោមព័ទកាន់តែច្រើនឡើងៗ របស់សត្រូវនោះទេ។ ភាគីទាំងពីរបានទទួលស្គាល់អំពីសារសំខាន់នៃលទ្ធផលសង្គ្រាម ហើយពួកគេបានបង្ហាញនូវសេចក្តីក្លាហាន និងការអត់ធ្មត់ ដ៏គួរឱ្យ កោតខ្លាចនៅក្រោមលក្ខខណ្ឌដែលស្ទើរតែអត់ទ្រាំមិនបាន។ នៅពេលដែលពួកវៀតមិញ ជាចុងបញ្ចប់បានចូលមកជំនួសតួនាទីរបស់ម្ចាស់អាណានិគមបារាំងនោះ ការទទួលស្គាល់ជោគជ័យរបស់ពួកគេ បានធ្វើឱ្យ ពួកគេខាតបង់យ៉ាងច្រើនដែរ។ ពួកវៀតមិញមានចំនួនអ្នករបួស និងស្លាប់ច្រើនជាងខាងពួកបារាំងឆ្ងាយណាស់។ ការបាត់បង់នេះស្របទៅនឹងការគូសបញ្ជាក់របស់លោកម៉ៅសេទុង ដែលថា បដិវត្តគឺមិនមែនស្រួលដូចការជួបជុំគ្នាញុំាទឹកតែទេ។

ការបរាជ័យរបស់បារាំង នៅឌៀនបៀនភូ ជាសញ្ញាបញ្ចប់ការប្រឹងប្រែងរបស់ពួកបារាំង ក្នុងការតាំងអាណានិគមរបស់ខ្លួនឡើងវិញនៅប្រទេសវៀតណាម។ ចាប់តាំងពីឆ្នាំ១៩៤៦ មក ការខំប្រឹងប្រែង នេះបានបន្តធ្វើក្នុងវិស័យពីរគឺ យោធា និងនយោបាយ។ យុទ្ធសាស្ត្រយោធា បានបរាជ័យ ប៉ុន្តែលទ្ធផល គោលនយោបាយទាំងឡាយរបស់បារាំងពោលគឺមានភាពមិនច្បាស់លាស់សោះ។ ទោះបីជាពួកបារាំងមិនបានទទួលជោគជ័យក្នុងការធ្វើសង្គ្រាម តែពួកគេបានបន្សល់ទុកនូវរចនាសម្ពន្ធរដ្ឋបាលដែលអាចធ្វើជាគ្រឹះដើម្បី កសាងរដ្ឋបាលថ្មីបាន នៅពេលសង្គ្រាម ឥណ្ឌូចិនលើកទី១បានបញ្ចប់ទៅ ហើយនៅពេលសហរដ្ឋអាម៉េរិក បានសម្រេចចិត្តគាំទ្ររដ្ឋមួយ នៅវៀតណាមខាងត្បូងថា ជាផ្នែកមួយនៃយុទ្ធសាស្ត្រទូទាំងពិភពលោក ដើម្បីទប់ស្កាត់លទ្ធិកុម្មុយនីស្ត។

## ១.២-សង្គ្រាមឥណ្ឌូចិនលើកទី២

### ១.២.១-សន្និសីទក្រុងហ្សឺណែវ ១៩៥៤

សន្និសីទក្រុងហ្សឺណែវស្តីពីបញ្ហាឥណ្ឌូចិន ចាប់ផ្តើមឡើងនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៥៤ ក្រោមអធិបតីភាពសហប្រធាន **ម៉ូឡូតូហ្វ និង អ៊ីដែន** (សូវៀត និងអង់គ្លេស) ដោយមានប្រទេសចូលរួមជាពិសេស សហរដ្ឋអាម៉េរិក សហភាពសូវៀត បារាំង អង់គ្លេស កម្ពុជា លាវ រដ្ឋវៀតណាម(**បាវ ដាយ**) សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម(**ហូ ជីមិញ**) ។ល។ ចាប់ពីអង្គប្រជុំ លើកទី១មក **ផាម យ៉ាំងដុង** ប្រធានគណប្រតិភូ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ខិតខំភ្ជាប់ បញ្ហា វៀតណាមទៅនឹងកម្ពុជា និងលាវ ដោយតវ៉ាសុំឱ្យគណប្រតិភូរដ្ឋាភិបាលបដិវត្តន៍ខ្មែរ(ខ្មែរឥស្សរៈ) និងគណប្រតិភូរដ្ឋាភិបាលលាវ ចូលរួមប្រជុំផងដែរ។ តែលោក **ប៊ីដូ** ប្រធានគណប្រតិភូបារាំងជំទាស់ដាច់ខាត។ លោក **ទេព ផន** ប្រធានគណប្រតិភូកម្ពុជា បានធ្វើការកត់សម្គាល់ថា រដ្ឋាភិបាលខ្មែរឥស្សរៈ ជារដ្ឋាភិបាលដែលបានកើតឡើងដោយវៀតមិញ និងចិន ហើយវាគ្រាន់តែឧបករណ៍របស់ប្រទេសទាំងពីរ តែប៉ុណ្ណោះ។ នៅពេលដែលលោក **ប៊ីដូ** សុំឱ្យវៀតមិញដកចេញឱ្យអស់ពីកម្ពុជា និងលាវ និងបញ្ចប់សង្គ្រាមស៊ីវិលនៅវៀតណាម ទុកឱ្យវៀតណាមដោះស្រាយបញ្ហាផ្ទៃក្នុង ក្នុងនាមជាប្រទេសឯករាជ្យ និងឯកភាព **ផាំម យ៉ាំងដុង** តបវិញដោយសុំឱ្យបារាំងដកទ័ពចេញឱ្យអស់ពីឥណ្ឌូចិន ទុកឱ្យវៀតណាម កម្ពុជា និងលាវ ដោះស្រាយបញ្ហានយោបាយដោយបោះឆ្នោត។

មកដល់ជិតដាច់ខែឧសភាទៅហើយ សន្និសីទហាក់ដូចជាជាប់គាំងដំណើរ មកពីគូបដិបក្សសំខាន់ទាំងពីរ គឺបារាំង និងវៀតមិញ ម្ខាងៗការពារតែគោលជំហររបស់ខ្លួន។ ចិនប្រជាមានិតទើបតែបានបង្កើតឡើង ហើយជាលើកទី១ និងជាកិត្តិយស ដែលចិនចូលរួមសន្និសីទអន្តរជាតិបែបនេះ លោក **ជូ អេនឡាយ** និងគណប្រតិភូទាំង២០០នាក់ ខ្លាចបរាជ័យសន្និសីទណាស់ ចំណែកអង់គ្លេស និងសូវៀត ក្នុងនាមជាសហប្រធាន

ក៏ខ្លាចបរាជ័យដូចគ្នា។ បារាំងក៏រកច្រកចេញកុំឱ្យអាម៉ាសមុខដែរ។ **អ៊ីដែន** មានគំនិតបែងចែកវៀតណាមជាពីរ ដូចកូរ៉េ ដែលផាំមយាំងដុងដូចជាមិនជំទាស់ទេ។

លោក **ជូ អេនឡាយ** បារម្ភខ្លាំង ខ្លាចសន្និសីទបរាជ័យ បានជួប **អ៊ី ដែន** ហើយយល់ព្រមឱ្យបញ្ហាកម្ពុជា និងលាវ បែកចេញពីវៀតណាម ដែលក្រោយមកនៅចុងខែមិថុនា នៅពេលលោកធ្វើទស្សនកិច្ចនៅឥណ្ឌា លោកថែមទាំងទទួលស្គាល់ជាផ្លូវការប្រទេសទាំងពីរនេះទៀតផង។

ទោះបីមានចំណុចជាច្រើនត្រូវពិភាក្សាគ្នាដោះស្រាយក៏ដោយ ក៏សន្និសីទនេះត្រូវបានបញ្ចប់ សព្វគ្រប់ និងចុះហត្ថលេខានៅយប់ថ្ងៃទី២០ឆ្លងចូល២១ ខែកក្កដា ឆ្នាំ១៩៥៤។ រដ្ឋវៀតណាម(បាវដាយ) មិនបានចុះហត្ថលេខជាមួយទេ ចំណែកអាម៉េរិក ដោយយកលេសថាមិនទទួលស្គាល់ចិន ក៏មិនបានចុះហត្ថលេខាជាមួយដែរ។ ជាសង្ខេបកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ បានសម្រេចៈ

- បែងចែកវៀតណាមជាពីរបណ្តោះអាសន្ន នៅខ្សែស្របទី១៧ វៀតណាមខាងជើង ឬសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងវៀតណាមខាងត្បូង ឬរដ្ឋវៀតណាម។
- ឱ្យមានការបោះឆ្នោតទូទៅនៅខែកក្កដា ឆ្នាំ១៩៥៦ ក្រោមការត្រួតពិនិត្យអន្តរជាតិ ដើម្បីឱ្យប្រជាជាតិវៀតណាម អាចសម្រេចជោគវាសនាខ្លួនដោយខ្លួនឯង
- ក្នុងរយៈពេល៣០០ថ្ងៃ បារាំង និងវៀតមិញត្រូវដកទ័ពចេញឱ្យអស់ពីវៀតណាមខាងជើង និងវៀតណាមខាងត្បូង។ នៅក្នុងរយៈពេលជាមួយគ្នាពលរដ្ឋវៀតណាម អាចជ្រើសរើសដោយសេរីនូវវៀតណាមមួយសម្រាប់រស់នៅរៀងខ្លួន[421]។

## ១.២.២-ស្ថានភាពនយោបាយវៀតណាម ក្រោយសន្និសីទក្រុងហ្សឺណែវ

ក្រោយសន្និសីទក្រុងហ្សឺណែវ ប្រទេសវៀតណាមត្រូវបានបែងចែកជាពីរបណ្តោះអាសន្ន គឺ វៀតណាមខាងជើង (សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម) និងវៀតណាមខាងត្បូង (រដ្ឋវៀតណាម)។ បើយោងតាមសន្ធិសញ្ញាក្រុងហ្សឺណែវ វៀតណាមទាំងពីរត្រូវបង្រួបបង្រួមគ្នាឡើងវិញតាមរយៈ ការបោះឆ្នោត ដោយមានការត្រួតពិនិត្យពីអន្តរជាតិ។

នៅវៀតណាមខាងជើង រដ្ឋាភិបាលរបស់ ហូ ជីមិញ បានត្រឡប់ចូលទីក្រុងហាណូយវិញ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៥៥ បន្ទាប់ពីចាក់ចេញពីទីក្រុងនេះអស់រយៈពេល៨ឆ្នាំ។

នៅវៀតណាមខាងត្បូងវិញ បន្ទាប់ពីបារាំងបរាជ័យនៅឌៀនបៀនភូ ឆ្នាំ១៩៥៤ បាវដាយ បានអញ្ជើញ ង៉ោ ឌិនយីម ដែលកំពុងរស់នៅសហរដ្ឋអាម៉េរិក ព្រមទាំងមានប្រជាប្រិយភាព និងស្គាល់អ្នកនយោបាយអាម៉េរិកជាច្រើនផង ឱ្យចូលស្រុកវិញ ដោយបានតែងតាំងលោកជានាយករដ្ឋមន្ត្រីវៀតណាម នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៥៤។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៥៥ ក្រុមង៉ោ ឌិនញូ ប្រមាណ២០០នាក់បាននាំគ្នាប្រកាសទម្លាក់បាវដាយ ហើយង៉ោ ឌិនយីម ចោទថាស្តេចនេះមិនគិតផលប្រយោជន៍ជាតិ គិតតែពីសប្បាយនឹងអបាយមុខ និងដើរលេងសប្បាយនៅបារាំង។

ប្រជាមតិក្លែងបន្លំមួយ រៀបចំដោយគ្រួសារង៉ោ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៥៥ ដោយ៩៨% សម្រេចទម្លាក់ បាវដាយ ចេញពីតំណែង ហើយថ្ងៃបន្ទាប់មក ង៉ោ ឌិនយីម ប្រកាសបង្កើតសាធារណរដ្ឋវៀតណាម និងប្រកាសខ្លួនឯងជាប្រមុខរដ្ឋ។ ង៉ោ ឌិនយីម ដែលមិនចូលចិត្តបារាំង ស្អប់របបកុម្មុយនីស្ត មិន

[421] ត្រាំងធាតប៊ុង, *វៀតណាម ឬ ស្រុកយួន* , គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ,(ឆ្នាំ ? ), ទំព័រ១៧៧។

មានបំណងគោរពកិច្ចព្រមព្រៀងក្រុងហ្សឺណែវទេ ដោយលោកបានប្រកាសថា ធ្វើចម្បាំងជាជាង ទៅនៅក្នុងជំរំអប់រំឡើងវិញ។ ក្នុងការវាយកម្ទាត់ក្រុមកុម្មុយនីស្ត អាម៉េរិក បានជួយគាំទ្ររបបយីម ទាំងស្រុង ចំណែកបារាំងវិញ ដែលមានបំណងតែមួយ គឺដកខ្លួនចេញឱ្យអស់ពីវៀតណាម ក៏បានដើរតាមអាម៉េរិកទាំងស្រុងដែរ[422]។ ដោយការកាន់អំណាចផ្តាច់ការ គ្រួសារនិយម ពុករលួយ របស់គ្រួសារង៉ោ បានធ្វើឱ្យស្ថានភាពនៅវៀតណាមខាងត្បូង មានសភាពពុំសូវល្អ ប្រជាពលរដ្ឋ និងពួកវៀតកុងបានបះបោរប្រឆាំងកាន់តែខ្លាំងឡើងៗ។ នៅពេលនោះក្រុងវ៉ាស៊ីនតោន មើលឃើញថា របបពុករលួយរបស់ង៉ោ ឌិនយីម មិនអាចយកជ័យជម្នះលើ ពួកកុម្មុយនីស្តបានឡើយ។ ទីបំផុត យីម ត្រូវទម្លាក់ពីអំណាចនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៦៣ ដោយរដ្ឋប្រហារដឹកនាំដោយលោកឧត្តមសេនីយ៍ យឿង យ៉ាំងមិញ ឧត្តមសេនីយ៍ ឡេ យ៉ាំងគីម ឧត្តមសេនីយ៍ ត្រឹង យ៉ាំងដូង។

### ១.២.៣-ការលូកដៃរបស់អាម៉េរិកនៅឥណ្ឌូចិន

កងទ័ពរបស់សហរដ្ឋអាម៉េរិក បានឈានជើងចូលមកក្នុងប្រទេសវៀតណាមខាងត្បូង តាមរយៈសន្ធិសីទហ្សឺណែវដោយស្របច្បាប់ បន្ទាប់ពីកងទ័ពបារាំងដកចេញពីឥណ្ឌូចិន។ ការចូលទៅជំនួសកងទ័ពបារាំងនេះជាយុទ្ធសាស្ត្ររបស់លោក ទ្រូម៉ាន់ ប្រធានាធិបតីសហរដ្ឋអាម៉េរិក បានរៀបចំទុកជាមុនស្រេចហើយ គឺកងទ័ពអាម៉េរិក ត្រូវចូលទៅជំនួស គ្រប់តំបន់របស់អង់គ្លេស និងបារាំងជុំវិញពិភពលោក ដូចជាតំបន់ឥណ្ឌូចិនជាដើម។ ក្រោយសន្ធិសីទ ក្រុងហ្សឺណែវ អាម៉េរិកបានចុះអនុវត្តតួនាទីរបស់ខ្លួននៅវៀតណាម ក្នុងនាមជាគណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិ។ ប៉ុន្តែពេលនោះសហរដ្ឋអាម៉េរិក មិនទាន់បញ្ជូនកងទ័ពរបស់ខ្លួន ទៅវៀតណាមភ្លាមៗទេ គ្រាន់តែបញ្ជូនទីប្រឹក្សាយោធា ព្រមទាំងផ្តល់ជំនួយសេដ្ឋកិច្ច និងជំនួយយោធាទៅឱ្យវៀតណាមខាងត្បូង ក្នុងគោលបំណងទាក់ទាញទឹកចិត្តរដ្ឋាភិបាល និងប្រជាជនវៀតណាម ឱ្យគាំទ្រនូវវត្តមានរបស់កងទ័ពខ្លួន។ ស្ថិតនៅក្នុងស្ថានភាពដែលទទួលជំនួយ ជាច្រើនពីសហរដ្ឋអាម៉េរិកបែបនេះ ប្រទេសវៀតណាមខាងត្បូងមិនអាចម្ចាស់ការលើខ្លួនឯងបានឡើយ ដូច្នេះដើម្បីកុំឱ្យធ្លាក់ទៅក្នុងដៃកុម្មុយនីស្តគឺមានតែសហការជាមួយសហរដ្ឋអាម៉េរិក។

នៅក្នុងអំឡុងឆ្នាំ១៩៥០-១៩៥៣ ឥទ្ធិពលកុម្មុយនីស្ត បានវាយលុកយ៉ាងខ្លាំងចូលមកតំបន់អាស៊ី ជាក់ស្តែងសង្គ្រាមនៅឧបទ្វីបកូរ៉េ រវាងកុម្មុយនីស្តចិន ជាមួយសហរដ្ឋអាម៉េរិក ស្របពេលនោះដែលឥទ្ធិពលកុម្មុយនីស្តក៏បានវាយលុកយ៉ាងខ្លាំងនៅក្នុងតំបន់ឥណ្ឌូចិន ជាពិសេសទៅលើប្រទេសវៀតណាម។ បញ្ហានេះជាកត្តាមួយដែលជំរុញឱ្យសហរដ្ឋអាម៉េរិក ចូលមកធ្វើអន្តរាគមន៍ជាបន្ទាន់មួយនៅឥណ្ឌូចិន។

ដោយយោងតាមយុទ្ធសាស្ត្ររបស់លោកប្រធានាធិបតីអាម៉េរិក ទ្រូម៉ាន់ ដែលតម្រូវឱ្យកងទ័ពអាម៉េរិកចូលមកគ្រប់គ្រងវៀតណាមខាងត្បូង ជំនួសកងទ័ពបារាំងដែលបានដកចេញ ពីឥណ្ឌូចិន ដូច្នេះ នៅខែមេសា ឆ្នាំ១៩៦១ លោកប្រធានាធិបតី ចន កេណ្ណឺឌី បានបង្កើតក្រុមការងារដើម្បីរៀបចំកម្មវិធីជំនួយផ្នែកសេដ្ឋកិច្ច និងសង្គមទៅវៀតណាមខាងត្បូង ក្នុងគោល បំណងការពារកុំឱ្យកុម្មុយនីស្តរាលដាលមកឥណ្ឌូចិន ដូចនេះ ទោះបីជាអាម៉េរិកត្រូវចំណាយថវិកាប៉ុន្មានក៏ដោយ ក៏ត្រូវទប់ទល់កុម្មុយនីស្តឱ្យនៅត្រឹមខ្សែស្របទី១៧ ដែរ ព្រោះនៅក្នុងកាលៈទេសៈនោះ អាម៉េរិកគឺមិនអាចអនុញ្ញាតឱ្យកុម្មុយនីស្តវាតទីចូលវៀតណាមខាងត្បូងបានទេ ព្រោះបើអាចគ្រប់គ្រងលើវៀតណាមខាងត្បូងបាន ឥទ្ធិពលកុម្មុយនីស្តនឹងមានសន្ទុះកាន់តែខ្លាំងឡើងៗ។

[422] ត្រាំងធាតប៊ុង, *វៀតណាម ឬ ស្រុកយួន*, ដ.ឯ.ម., ទំព័រ១៨១។

ដោយសារការប្រឈមមុខដាក់គ្នាកាន់តែតានតឹងទៅៗរវាងក្រុមប្រទេសកុម្មុយនីស្ត ដែលមានសហភាពសូវៀត ចិន និងវៀតកុង ជាមួយប្រទេសសេរី មានសហរដ្ឋអាម៉េរិក និងប្រទេសសម្ពន្ធរបស់ខ្លួន ធ្វើឱ្យអាម៉េរិកចេញមុខជាចំហ ដោយផ្លាស់ប្តូរពីដើរតួនាទីជាអ្នកសង្កេតការណ៍អន្តរជាតិ ចាប់ផ្តើមបញ្ជូនកងទ័ពប្រយុទ្ធ ចូលមកអន្តរាគមន៍នៅវៀតណាមខាងត្បូងដោយផ្ទាល់ ហើយក៏គ្មានអន្តរជាតិណាស្រែកថ្កោលទោសដែរ ព្រោះវៀតណាមទាំងពីរភាគី សុទ្ធតែមានការលូកដៃយ៉ាងពេញទំហឹងពីក្រុមប្រទេសមហាអំណាចរៀងៗខ្លួន ដូច្នេះភ្លើងសង្គ្រាមបានចាប់ផ្តើមយ៉ាងខ្លាំងក្លាបំផុត។

ក្នុងការធ្វើអន្តរាគមន៍នៅក្នុងសង្គ្រាមវៀតណាម សហរដ្ឋអាម៉េរិកមានគោលបំណងសំខាន់ៗ ៦ករណីដើម្បីទប់ទល់ជាមួយពួកកុម្មុយនីស្ត ដូចជា ៖

១-ទប់ស្កាត់ឥទ្ធិពលកុម្មុយនីស្តឱ្យនៅត្រឹមខ្សែស្របទី១៧ ជាខ្សែបន្ទាត់យោធា ដែលបែងចែកប្លុកកុម្មុយនីស្ត និងប្លុកសេរីជាពីរដាច់ពីគ្នា ដូច្នេះអាម៉េរិក រិះរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីទប់ស្កាត់កុំឱ្យកុម្មុយនីស្តចូលមកតំបន់អាស៊ី ដោយខ្លាចមាន ការប៉ះពាល់ដល់ផល ប្រយោជន៍របស់សហរដ្ឋអាមរិក និងអង់គ្លេសជាច្រើន ដូចនេះសហរដ្ឋអាម៉េរិក មិនអនុញ្ញាតឱ្យកុម្មុយនីស្ត ចូលមកបំផ្លិចបំផ្លាញ បានឡើយ។

២-បំពេញជំនួសកងទ័ពបារាំង ដែលត្រូវបានដកចេញពីវៀតណាម។

៣-ការពារផលប្រយោជន៍ និងឥទ្ធិពលនៃអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ ជាងនេះទៅទៀត ការពារប្រទេសថៃ កម្ពុជា និងឡាវ ឱ្យនៅជារដ្ឋឯករាជ្យ មិនស្ថិតនៅក្រោមឥទ្ធិពលរបស់ ប្រទេសកុម្មុយនីស្ត បើយោងទៅតាមតំបន់ភូមិសាស្ត្រ របស់ប្រទេសទាំង៣ គឺមានព្រំប្រទល់ ជាប់គ្នា ដូច្នេះបើយោងទៅតាមទ្រឹស្តី "Domino Theory " យើងឃើញថា តំបន់នេះមានគ្រោះថ្នាក់យ៉ាងខ្លាំង ដូច្នេះគឺមិនអាចបណ្តែតបណ្តោយបានឡើយ។

៤-ការពារនិងអនុវត្ត គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងរបស់សន្និសីទហ្សឺណែវ ដែលហូជីមិញ មិនគោរពតាមកិច្ចព្រមព្រៀង ព្រមទាំងចង់បង្កើតរដ្ឋាភិបាលរួមគ្នាតែមួយក្រោមការដឹកនាំរបស់ខ្លួន។ ទោះបីសន្និសីទសម្រេចបែងចែកវៀតណាមជាពីរក៏ដោយ ក៏វៀតណាមនៅ តែព្យាយាមបង្រួបបង្រួមចូលគ្នាតែមួយដែរ ព្រោះហូជីមិញ មើលឃើញយុទ្ធសាស្ត្ររបស់ អាម៉េរិកយ៉ាងច្បាស់ គឺមិនចង់ឱ្យវៀតណាមរួបរួមគ្នាទេ ចំណែកអាម៉េរិកមិនបានគិតដល់ សេចក្តីសុខសន្តិភាពរបស់ប្រជាជនវៀតណាមទេ មានតែលើកទឹកចិត្តឱ្យវៀតណាមខាងត្បូង កាប់សម្លាប់បង្ហូរឈាមគ្នាឯង ដើម្បីផលប្រយោជន៍របស់ខ្លួន។

៥-កសាងប្រទេសវៀតណាម កម្ពុជា និងឡាវ ឱ្យក្លាយទៅជារដ្ឋសេរីមួយតាមរបៀប លោកខាងលិច ប៉ុន្តែអាម៉េរិកមិនអាចសម្រេចបានដូចបំណងទេ ព្រោះបញ្ហានយោបាយ និងមេដឹកនាំ ខ្លះនៃប្រទេសទាំងបីមិនឯកភាព និងមិនគាំទ្រនយោបាយរបស់អាម៉េរិកឡើយ ព្រមទាំងងាកទៅគាំទ្រ និងចូលរួមជាមួយប្រទេសកុម្មុយនីស្ត ប្រឆាំងនឹងសហរដ្ឋអាម៉េរិក បញ្ហាទាំងនេះជាកត្តាប្រឈមមុខយ៉ាងខ្លាំង ចំពោះអាម៉េរិកដែលឈានទៅរកភាពទាល់ច្រក និងត្រូវ ទទួលបរាជ័យ។

៦-ការពារស្ថេរភាពនយោបាយ ឱ្យរឹងមាំដល់ប្រទេសទាំងបី និងប្រែក្លាយឱ្យទៅជាប្រទេសជឿនលឿនប្រជាធិបតេយ្យ ដូចប្រទេសលោកសេរី នៅក្នុងពិភពលោក ប៉ុន្តែដោយ សារទំនាក់ទំនងនយោបាយការទូត មិនបានស្ថិតរម្ងួត ធ្វើឱ្យប្រទេសខ្លះ មានភាពរង្គោះរង្គើ ផ្នែកនយោបាយ ហើយងាយទៅគាំទ្រប្រទេសកុម្មុយនីស្ត[423]។

---

[423] ឥន សុផល, *កម្ពុជាក្នុងសង្គ្រាមវៀតណាម១៩៥៤-១៩៧៥*, ឆ្នាំ២០១១, ទំព័រ៨៩។

យុទ្ធសាស្ត្ររបស់សហរដ្ឋអាម៉េរិកនៅឆ្នាំ ១៩៦១ ជាដំណាក់កាលដំបូងដែលរដ្ឋាភិបាលសហរដ្ឋអាម៉េរិក បានសម្រេចបញ្ជូនទីប្រឹក្សាយោធាចំនួន១៥០០នាក់ ឱ្យទៅជួយសាធារណរដ្ឋវៀតណាម ដើម្បីទប់ទល់នឹងការវាតទីរបស់កងទ័ពកុម្មុយនីស្តវៀតកុង។ សហរដ្ឋអាម៉េរិកបានប្រើតួនាទីរបស់ខ្លួនដែលជា គណៈកម្មាធិការអន្តរជាតិ ដើម្បីទៅត្រួតពិនិត្យការបោះឆ្នោតនៅវៀតណាម ផ្ទុយទៅវិញសហរដ្ឋអាម៉េរិក បានបញ្ជូនទីប្រឹក្សាយោធា ទៅជួយបង្ហាត់បង្រៀនកងទ័ពវៀតណាមខាងត្បូង ការលូកដៃរបស់អាម៉េរិកកាន់តែជ្រៅទៅៗ ទៅតាមយុទ្ធសាស្ត្រដែលបានរៀបចំទុកជាមុន។ ជាក់ស្តែងនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ១៩៦២ សហរដ្ឋអាម៉េរិកបានបញ្ជូនមេបញ្ជាការយោធាជាន់ខ្ពស់មានឋានៈជាឧត្តមសេនីយ៍ផ្កាយ៤ ទៅបោះមូលដ្ឋានយោធានៅវៀតណាមខាងត្បូង ជំនួសក្រុមទីប្រឹក្សាយោធាដែលបានបញ្ជូនទៅពេលមុន។ ការផ្លាស់ប្តូរទីប្រឹក្សាយោធា មកជាជំនួយការយោធានេះ គឺជាសញ្ញាមួយ ដែលបញ្ជាក់បានថា សហរដ្ឋ អាម៉េរិក កំពុងត្រៀមលក្ខណៈធ្វើសង្គ្រាមប្រឆាំងកុម្មុយនីស្ត ដូច្នេះសាធារណរដ្ឋវៀតណាម ចាប់ផ្តើមជ្រើសរើស និងបង្ហាត់បង្រៀនកងទ័ពឱ្យកាន់តែខ្លាំងឡើងៗ ចំណែកជំនួយយោធារបស់អាម៉េរិកមានចំនួនកាន់តែច្រើនឡើងៗដែរ។ ការពង្រីកកម្លាំងយោធារបស់ភាគីទាំងពីរបានធ្វើឱ្យស្ថានភាពយោធាកាន់តែមានភាពតានតឹងទៅៗ ។ ចំណែក ហូ ជីមិញក៏បានបង្កើត និងហ្វឹកហាត់កងទ័ពរបស់ខ្លួនឥតឈប់ឈរដែរ។ ជាងនេះទៀតប្រទេសចិន និងសហភាពសូវៀត បានចាប់ដៃគ្នា ចូលមកជួយអន្តរាគមន៍ កងទ័ពវៀតកុង ធ្វើឱ្យស្ថានភាព នេះមានការប្រឈមមុខដាក់គ្នាយ៉ាងខ្លាំង រវាងក្រុមប្រទេសកុម្មុយនីស្ត និងក្រុមប្រទេសសេរី កាន់តែគ្រោះថ្នាក់ខ្លាំងឡើងៗ។

ជាក់ស្តែងគ្រាន់តែគិតមកត្រឹមឆ្នាំ១៩៦៣ សហរដ្ឋអាម៉េរិក បានបញ្ជូនជំនួយការយោធារបស់ខ្លួនទៅវៀតណាមខាងត្បូងប្រមាណជាង ១៥,០០០នាក់។ ដោយមើលឃើញ យុទ្ធសាស្ត្ររបស់សហរដ្ឋអាម៉េរិក កំពុងត្រៀមខ្លួនធ្វើសង្គ្រាមបែបនេះ ហូ ជីមិញ បានធ្វើការសម្រេចចិត្ត បើកការវាយប្រហារផ្តួលរំលំរបបសាធារណរដ្ឋវៀតណាមឱ្យបានឆាប់ តែត្រូវបរាជ័យដោយកងទ័ពអាកាសរបស់សហរដ្ឋអាម៉េរិក។

នៅក្នុងអំឡុងពេលនៃសង្គ្រាមវៀតណាម សហរដ្ឋអាម៉េរិក មានគម្រោងជ្រើសរើស ប្រជាពលរដ្ឋប្រមាណ ២៦.៨ លាននាក់ ឱ្យចូលបំរើកាតព្វកិច្ចយោធា ក្នុងនោះមានយុវជនស្ម័គ្រចិត្ត ប្រមាណជាង ៨.៧លាននាក់។ ក្រោយមកដោយមើលឃើញពីស្ថានភាពដ៏ធ្ងន់ធ្ងរ របស់អាម៉េរិកនៅវៀតណាម មានយុវជនជាង ២.២លាននាក់ទៀត បានស្ម័គ្រចិត្តចូលបម្រើកងទ័ព។ នេះជាលើកទី១ ហើយដែលសហរដ្ឋអាម៉េរិក បានជ្រើសរើសកងទ័ពយ៉ាងច្រើនបែបនេះ នៅក្នុងដំណាក់កាលនោះស្ទើរតែគ្មានយុវជន អាម៉េរិកណាម្នាក់ អាចជៀសផុតពីកាតព្វកិច្ចយោធាដ៏ចម្បងនេះឡើយ ក្នុងនោះមាននារីស្ម័គ្រចិត្ត ចូលបម្រើក្នុងជួរកងទ័ពជាង ២៦០ ពាន់នាក់ ប៉ុន្តែក្នុងចំណោមកងទ័ពទាំងនោះ មានកុមារជាច្រើនចូលបម្រើកងទ័ព ហើយកុមារមួយចំនួនត្រូវបានបញ្ជូនមកក្នុងប្រទេសវៀតណាម។ បន្ទាប់ពីមានការហ្វឹកហាត់រួចមក កងទ័ពជិតបីលាននាក់ ត្រូវបានបញ្ជូនមកដាក់ពង្រាយនៅក្នុងតំបន់អាស៊ី សម្រាប់ត្រៀមធ្វើអន្តរាគមន៍នៅវៀតណាម។ ចំណែកកងទ័ពចំនួន៥២៨ ០០០នាក់ ត្រូវបានបញ្ជូនឱ្យទៅធ្វើ សង្គ្រាមនៅវៀតណាម ហើយនៅក្នុងចំណោមនោះ មានទ័ពព្រៃជាង ៣០០ ០០០ នាក់ ព្រោះភូមិសាស្ត្រ នៅវៀតណាមមានភាពស្មុគស្មាញណាស់ សូម្បីតែបារាំង ក៏ត្រូវបរាជ័យដោយសារតែភូមិសាស្ត្រនេះដែរ [424]។

---

[424] ឥន សុផល, *កម្ពុជាក្នុងសង្គ្រាមវៀតណាម ១៩៥៤-១៩៧៥,* ដ.ឯ.ម., ទំព័រ៩២។

នៅក្នុងដំណាក់កាលសង្គ្រាមនៅវៀតណាមពីឆ្នាំ១៩៦២-១៩៧៥ កងទ័ពអាម៉េរិក ជាច្រើនត្រូវបាន បញ្ជូនមកធ្វើសង្គ្រាមនៅវៀតណាម ដែលក្នុងនោះមានចំនួនដល់ទៅ៥២៨០០០នាក់ ហើយខាងភាគី អាម៉េរិកនេះដែរមានកងទ័ព វៀតណាមខាងត្បូង និងកងទ័ព ប្រទេសសម្ពន្ធមិត្តរបស់អាម៉េរិក រាប់សែននាក់ ទៀតផង ដែលគិតត្រឹមឆ្នាំ ១៩៦៨ កងទ័ពសរុបរបស់ភាគីអាម៉េរិក មានចំនួន១ ៤៤៨ ៨៧១នាក់[425]។

### ១.២.៤-ការដកទ័ពអាម៉េរិកចេញពីសង្គ្រាមនៅវៀតណាម

សង្គ្រាមនៅវៀតណាមបានធ្វើឱ្យសហរដ្ឋអាម៉េរិកទទួលរងនូវការខាតបង់ ជាច្រើនទាំងផ្នែក នយោបាយ សេដ្ឋកិច្ច ព្រោះសហរដ្ឋអាម៉េរិកបានចំណាយថវិការាប់ពាន់លានដុល្លារ ក្នុងមួយឆ្នាំៗ រួមទាំងជីវិតកងទ័ព ស្លាប់អស់រាប់ម៉ឺននាក់។ ទីបំផុតស្ថានភាពនានា បានជំរុញឱ្យសហរដ្ឋអាម៉េរិកដកខ្លួនចេញពីសង្គ្រាម ដោយ បានប្រកាសផ្តាច់ជំនួយពីវៀតណាម ទាំងជំនួយយោធា និងទាំងជំនួយផ្នែកសេដ្ឋកិច្ច។

ការសម្រេចចិត្តធ្វើសង្គ្រាមនៅវៀតណាមរបស់ប្រធានាធិបតីអាម៉េរិក **ចនសុន** បានធ្វើឱ្យពលរដ្ឋអាម៉េរិក ជាច្រើនមានប្រតិកម្មប្រឆាំងនឹងការសម្រេចចិត្តរបស់រដ្ឋាភិបាលអាម៉េរិក ដោយសារពួកគេយល់ថា គ្មានហេតុ ផលណាមួយដែលហសរដ្ឋអាម៉េរិកទៅធ្វើសង្គ្រាមនៅវៀតណាមនោះទេ។ ចំណែកសភាសហរដ្ឋ អាម៉េរិក ក៏ បានជំទាស់ទៅនឹងការសម្រេចចិត្ត របស់លោកប្រធានាធិបតីសហរដ្ឋអាម៉េរិក មិនឱ្យធ្វើសង្គ្រាមនៅវៀតណាម នោះទេ ប៉ុន្តែការជំទាស់របស់សភា ត្រូវប្រធានាធិបតីធ្វើការប្រានចោល ដូច្នេះពេលនោះសភាក៏បានបើកកិច្ច ប្រជុំបន្ទាន់មួយដើម្បីរាំងការធ្វើសង្គ្រាមនៅវៀតណាម ហេតុនេះសភាមានតែអនុម័តទៅលើការកាត់បន្ថយ ថវិកា សម្រាប់វិស័យការពារជាតិ ដែលអាចធ្វើឱ្យប្រធានាធិបតីមានការផ្លាស់ប្តូរចិត្ត។ តែផ្ទុយទៅវិញ ទោះបី មានការសម្រេចពីសភាបែបនេះក្តី ក៏សភាមិនអាចទប់ស្កាត់ការសម្រេចចិត្តរបស់ប្រធានាធិបតី **ចនសុន** បានដែរ ហើយលោក ចនសុន នៅតែបន្តសង្គ្រាមនេះដដែល ដោយរដ្ឋាភិបាលបានធ្វើការកាត់បន្ថយទៅលើសេវាសង្គម ផ្សេងៗ ដូចជាសេវា សាធារណៈ សេវាសុខាភិបាល ប្រាក់សង្គមកិច្ចសម្រាប់អ្នកឥតការងារធ្វើ រួមទាំងប្រាក់ សោធននិវត្តន៍ផងដែរ ដើម្បីយកថវិកាទាំងនោះ មកបង្គ្រប់ទៅលើកង្វះខាតថវិកាសម្រាប់ ចំណាយលើវិស័យ ការពារជាតិទៅវិញ។ បញ្ហានេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសេវា សង្គម និងប្រជាពលរដ្ឋអាម៉េរិកទាំងមូល ហើយក៏ជាកត្តាមួយដែលនាំឱ្យប្រជាពលរដ្ឋអាម៉េរិក មិនពេញចិត្តទៅនឹង រដ្ឋាភិបាល ព្រមទាំងឈានទៅធ្វើ បាតុកម្មប្រឆាំងនឹងវត្តមានកងទ័ពរបស់អាម៉េរិកនៅវៀតណាម រហូតទាល់តែសម្រេចគោលដៅរបស់ពួកគេ គឺ ដកកងទ័ពរបស់សហរដ្ឋអាម៉េរិកទាំងអស់ចេញពីប្រទេសវៀតណាម និងចេញពីឥណ្ឌូចិនទាំងមូល។

ដោយមើលឃើញការបញ្ជាំងពីការប្រយុទ្ធគ្នា ដ៏គួរឱ្យខ្លាចរន្ធត់នៅតាមកញ្ចក់ទូរទស្សន៍នោះ ប្រជាជន អាម៉េរិកបានផ្តើមតវ៉ាប្រឆាំងនឹងការជាប់ពាក់ព័ន្ធប្រទេសរបស់គេនៅក្នុងសង្គ្រាមនោះ។ ប្រជាជនអាម៉េរិកបាន តាមដានសភាពការណ៍ នៅពេលដែលយុទ្ធនាការយោធាដ៏សន្ធឹកសន្ធាប់ ហាក់ដូចជាគ្មានឥទ្ធិពលអ្វីទៅលើ សង្គ្រាមសោះ។ ការមិនពេញចិត្តរបស់សាធារណជនចំពោះនយោបាយ សហរដ្ឋអាម៉េរិក ជាពិសេសក្នុងចំណោម យុវជននោះបានកៀបសង្កត់ឱ្យលោក ចនសុន ផ្តើមចរចាសន្តិភាព។

មនោសញ្ចេតនាប្រឆាំងនឹងសង្គ្រាមនៅក្នុងឆ្នាំ១៩៦៨ នាំឱ្យលោក ចនសុន បោះបង់ចោលនូវបំណង ចង់ស្វះស្វែងកាន់អំណាចមួយអាណត្តិទៀត។ នៅឯសន្និបាតជាតិប្រជាធិបតេយ្យនៅទីក្រុងស៊ីកាហ្គោរដ្ឋអ៊ីលីណយ ពួកអ្នកប្រឆាំងតវ៉ា បានប្រយុទ្ធគ្នាតាមផ្លូវជាមួយប៉ូលិស។ ភាពវឹកវរ នៅក្នុងគណបក្សប្រជាធិបតេយ្យ ពិសេស

---

[425] គន សុផល, *កម្ពុជាក្នុងសង្គ្រាមវៀតណាម ១៩៥៤-១៩៧៥*, ផ.ឯ.ម., ទំព័រ៩៩។

គឺក្រោយពីមានឃាតកម្មលើរូប លោក រ៉ូប៊ែរ កេណ្ណឺឌី នៅក្នុងខែ មិថុនា ជាមួយនឹងការប្រឆាំងចំពោះវិធានការសិទ្ធិជនស៊ីវិល នាទសវត្សរ៍ឆ្នាំ១៩៦០ ព្រមទាំងបេក្ខភាពប្រធានាធិបតីរបស់គណបក្សទីបី គឺអភិបាលរដ្ឋអាឡាបាម៉ា លោកហ្សក វ៉ាឡេម ផងនោះបានជួយឱ្យមានការបោះឆ្នោតជ្រើសតាំង លោក រីឆាដ និចសុន របស់គណបក្សសាធារណរដ្ឋដែលគាត់ឈរឈ្មោះបោះឆ្នោតមានផែនការរំដោះប្រទេស ចេញពីសង្គ្រាម និងបង្កើតច្បាប់និងរបៀបរបបនៅក្នុងសង្គម។

ស្របពេលដែលដកកងទ័ពយ៉ាងយឺតៗចេញនោះ និចសុន បានបញ្ជាឱ្យធ្វើការទំលាក់គ្រាប់បែកយ៉ាងសាហាវបំផុតនៅក្នុងសង្គ្រាមនោះ។ គាត់ក៏បានចូលលុកលុយប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៧០ ដើម្បីកាត់ផ្ដាច់ខ្សែរយៈផ្គត់ផ្គង់របស់វៀតណាមខាងជើង។ ប្រការនេះបាននាំឱ្យមានការតវ៉ា និងបាតុកម្មប្រឆាំងមួយព្រឹបទៀត នៅពេលដែលនិស្សិតនៅសាកលវិទ្យាល័យជាច្រើនបានដង្ហែក្បួនប្រឆាំង។ នៅក្នុងបាតុកម្មមួយនៅ កេន ស្តេតរដ្ឋអូហៃយ៉ូ កងទ័ពឆ្មាំជាតិដែលនៅរក្សារបៀបរៀបរយមានការភ័យស្លន់ស្លោ ហើយបានសម្លាប់និស្សិតអស់បួនរូប[426]។

ការចរចាពីបទឈប់បាញ់គ្នា រវាងអាម៉េរិក និងវៀតណាម នៅទីបំផុតត្រូវបានចុះហត្ថលេខានៅឆ្នាំ១៩៧៣។ តែទោះបីជាមានកិច្ចដកកងទ័ពនេះក្ដី ក៏សង្គ្រាមនៅតែបន្តរហូត ដល់ខែមេសាឆ្នាំ១៩៧៥ ដែលនៅពេលនោះវៀតណាមខាងជើង បានពង្រីកការគ្រប់គ្រងរបស់លើផ្ទៃប្រទេសទាំងមូល។

នៅចន្លោះពេលនៃការបោះឆ្នោតប្រធានាធិបតីទាំងពីរលើកគឺឆ្នាំ១៩៦៤ និងឆ្នាំ១៩៦៨ សង្គ្រាមវៀតណាមបានក្លាយជាបញ្ហាដ៏ចំបងក្នុងជីវិតនយោបាយរបស់សហរដ្ឋអាមេរិក។ នៅក្នុងការឃោសនានាឆ្នាំ១៩៦៨ លោក រីឆាត និចសុន មានកម្មវិធីច្បាស់លាស់ បង្ហាញជូនមហាជនអាម៉េរិក។ លោកបានសន្យាថាបើលោកជាប់ឆ្នោតជាប្រធានាធិបតីសហរដ្ឋអាម៉េរិក លោកនឹងបញ្ចប់សង្គ្រាម ដោយដកកងទ័ពអាម៉េរិកចេញពីឥណ្ឌូចិន[427]។

នៅពេលដែលលោក និចសុន បានក្លាយជាប្រធានាធិបតី នាឆ្នាំ ១៩៦៩ លោកបានអនុវត្តនូវអ្វី ដែលគាត់បានសន្យាក្នុងការឃោសនាបោះឆ្នោតទាក់ទងនឹងនយោបាយវៀតណាមូបនីយកម្ម ហើយដែលក្រោយមកគាត់បានប្រកាសដោយខ្លួនគាត់ថាជា "ទ្រឹស្តីនិចសុន" ដែលតម្រូវឱ្យមានការកាត់បន្ថយវត្តមានកងកម្លាំងអាម៉េរិកនៅអាស៊ីជាទូទៅ។ នយោបាយអាម៉េរិកនៅពេលនោះគឺបញ្ឈប់វត្តមានអាម៉េរិកទាំងអស់ចេញពីឥណ្ឌូចិន។ តែក្រោយមកលោក ប្រធានាធិបតី និចសុន បានធ្វើខុសនូវអ្វីដែលគាត់បានសន្យា ដោយគាត់នៅតែបន្តឱ្យមានការផ្តល់ជំនួយដល់ប្រទេសវៀតណាម ហើយលើសពីនោះទៅទៀតគាត់បានផ្តល់ជំនួយយោធា ដល់របបសាធារណរដ្ឋខ្មែរ។

នៅក្នុងព្រឹទ្ធសភា មេដឹកនាំនៃគណបក្សប្រជាធិបតេយ្យ លោក Mike Mansfield កុំឱ្យផ្តល់ជំនួយយោធាដល់ប្រទេសកម្ពុជា។ លើសពីនេះទៅទៀតអ្នកតំណាងក្រសួងការពារជាតិអាម៉េរិកបាននិយាយប្រឆាំងនឹងការប្រើប្រាស់ទ័ពអាម៉េរិកក្នុងប្រត្តិបត្តិការនៅប្រទេសកម្ពុជា។ ចំណែកសមាជិកព្រឹទ្ធសភាជាច្រើនទៀត ក៏មានការជំទាស់យ៉ាងខ្លាំងចំពោះ ការបញ្ជូនជំនួយមកឱ្យរបបសាធារណរដ្ឋខ្មែរ។ ទោះបីជាមានការប្រឆាំង យ៉ាងណាក៏ដោយក៏លោកនិចសុន មិនបានបង្អាក់សកម្មភាពរបស់ខ្លួនក្នុងការផ្តល់ជំនួយយោធាដល់ប្រទេសកម្ពុជា

[426] ទីភ្នាក់ងារសោរព័ត៌មានស.រ.អ., *កម្រងប្រវត្តិសាស្ត្រអាម៉េរិក*, ឆ្នាំ( ? ), ទំព័រ៣៧៤។

[427] នួន សុធិមន្ត, *សង្គ្រាមអាម៉េរិកនៅកម្ពុជា*, ភ្នំពេញ, ឆ្នាំ២០០៥, ទំព័រ១៤៧។

ដោយ លោកបានធ្វើការសម្រេចចិត្ត ជាចុងក្រោយដោយមិនមានការពិភាក្សាជាមួយគណកម្មាធិការសភាណាមួយឡើយ។ សភាមានអារម្មណ៍ថាពួកគេត្រូវបានបោះបង់ចោល ហើយគេជឿថាលោកប្រធានាធិបតីមានបំណងបំពានលើអំណាចនីតិបញ្ញត្តិ។ ដោយប្រើអំណាចរបស់គាត់តាមរដ្ឋធម្មនុញ្ញ ជាអគ្គមេបញ្ជាការក្នុងការបញ្ជូនទ័ពអាម៉េរិក លោកនិចសុន បាននិយាយការពារ ទង្វើរបស់គាត់ថា គាត់មានភារកិច្ចការពារជីវិតជនជាតិអាម៉េរិកនៅវៀតណាម ហើយអះអាងថាការទទួលខុសត្រូវរបស់គាត់ចំពោះទាហានទាំងនោះ វាធំធេងជាងកាតព្វកិច្ចរបស់គាត់ ចំពោះសភាទៅទៀត។ ការសម្រេចចិត្តរបស់លោកប្រធានាធិបតីនេះ បានធ្វើឱ្យមានការប្រឆាំងយ៉ាងខ្លាំងក្លា។

ចលនាប្រឆាំងសង្គ្រាមរបស់សាធារណជន និងមេដឹកនាំអាម៉េរិកនេះមានគោលបំណងដើម្បីបញ្ចៀសការបាត់បង់ជីវិតជនជាតិអាម៉េរិកនៅបរទេស តែផ្ទុយទៅវិញជីវិតជនជាតិអាម៉េរិកនៅតែបាត់បង់ជាបន្តបន្ទាប់ ទោះបីជាអាម៉េរិកបានចំណាយធនធានសេដ្ឋកិច្ចរបស់ខ្លួនអស់យ៉ាងច្រើនជារៀងរាល់ឆ្នាំក៏ដោយ។ ហេតុនេះហើយទើបប្រជាពលរដ្ឋ និងមេដឹកនាំអាម៉េរិកមួយភាគធំប្រឆាំងនឹងការធ្វើសង្គ្រាមនៅវៀតណាម និងឥណ្ឌូចិនទាំងមូល។

ដើម្បីបញ្ចប់ការបែកបាក់ផ្ទៃក្នុងជាតិ មេដឹកនាំបានផ្លាស់ប្តូរនយោបាយក្រៅប្រទេសរបស់ខ្លួន ដោយបានជំរុញឱ្យមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ដើម្បីបញ្ចប់សង្គ្រាមនៅវៀតណាម នាថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៣ ដែលនាំឱ្យមានការបញ្ឈប់ធ្វើសង្គ្រាមទាំងស្រុងនៅវៀតណាម ហើយនៅក្នុងមាត្រា២០ នៃកិច្ចព្រមព្រៀងនោះ ក៏បានចែងពីការដកកងទ័ពបរទេសទាំងអស់ចេញពីកម្ពុជាផងដែរ។ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ សភាអាម៉េរិកក៏ត្រូវឱ្យមានការបញ្ឈប់ទម្លាក់គ្រាប់បែក និងអន្តរាគម យោធាដោយផ្ទាល់របស់អាម៉េរិកទាំងអស់នៅឥណ្ឌូចិន[428]។

ពាក់ព័ន្ធទៅនឹងនយោបាយក្រៅប្រទេសនៅទសវត្សរ៍ឆ្នាំ១៩៦០ សហរដ្ឋអាម៉េរិក បានអនុវត្តនយោបាយដែលធ្វើឱ្យមហាអំណាចកុម្មុយនីស្តទាំងពីរបែកបាក់គ្នា គឺសហរដ្ឋអាម៉េរិក គាំទ្រសហភាពសូវៀត ធ្វើការប្រឆាំងចំពោះការអភិវឌ្ឍអាវុធនុយក្លេអ៊ែរនៅក្នុងឆ្នាំ១៩៦៣-១៩៦៤ ដែលជាការគំរាមកំហែងមួយដល់សន្តិសុខរបស់សហភាពសូវៀត។ ជាងនេះទៅទៀត សហរដ្ឋអាមេរិកជំរុញឱ្យសូវៀត ធ្វើការវាយប្រហារទៅលើប្រទេសចិននៅឆ្នាំ១៩៦៩ ដោយអាម៉េរិកសុខចិត្តធ្វើជាថ្នូរទៅឱ្យសូវៀត នូវការបញ្ចប់សង្គ្រាមនៅវៀតណាម។ ក្រោយមកហរដ្ឋអាម៉េរិកបានចាប់ផ្តើមធ្វើការចរចា ជាមួយប្រទេសចិន ក្នុងឆ្នាំ១៩៦៩ ក្នុងគោលបំណងចែករំលែកផលប្រយោជន៍ទៅឱ្យប្រទេសចិន និងផ្តល់ផលប្រយោជន៍សម្រាប់សហភាពសូវៀត ក្នុងការដកកងទ័ពអាម៉េរិកចេញពីប្រទេសវៀតណាម[429]។

ក្រៅពីតវ៉ាប្រឆាំងអន្តរាគមន៍អាម៉េរិកនៅវៀតណាម និងឥណ្ឌូចិនទាំងមូល ពីសំណាក់ សាធារណជនអាម៉េរិក និងសមាជិកសភាមួយភាគធំ ព្រមទាំងបក្សនយោបាយអាម៉េរិក ចំណែកបញ្ហាសេដ្ឋកិច្ចក៏ជាបញ្ហាចំបងផងដែរ ដែលធ្វើឱ្យអាម៉េរិកប្រញាប់ប្រញាល់ស្វែងរក ដំណោះស្រាយសង្គ្រាមនៅវៀតណាម។ ក្នុងការ

[428] នួន សុធិមន្ត, *សង្គ្រាមអាម៉េរនៅកម្ពុជា*, ដ.ឯ.ម., ទំព័រ១៤៩។
[429] គន សុផល, *កម្ពុជា ក្នុងសង្គ្រាមវៀតណាម ១៩៥៤-១៩៧៥*, ដ.ឯ.ម., ទំព័រ១០៣។

ផ្តល់ជំនួយដល់ឥណ្ឌូចិននេះសហរដ្ឋអាម៉េរិក ត្រូវចំណាយថវិកាយ៉ាងច្រើនជារៀងរាល់ឆ្នាំ ហើយជីវិតជនជាតិអាម៉េរិកនៅវៀតណាមក៏នៅតែបាត់បង់ជាបន្តបន្ទាប់។

សរុបសេចក្តីមក សង្គ្រាមឥណ្ឌូចិនលើកទី២ត្រូវបានបញ្ចប់ជាស្ថាពរនៅឆ្នាំ១៩៧៥បន្ទាប់ពីវៀតណាមខាងជើង(ពួកកុម្មុយនីស្ត) វាយកាន់កាប់ទីក្រុងព្រៃនគរ និងគ្រប់គ្រងលើវៀតណាមទាំងមូល។ ចាប់ពីពេលនោះមកវៀតណាមត្រូវបានបង្រួបបង្រួមដោយជាស្ថាពរដោយប្រើកម្លាំង ខុសពីអ្វីដែលបានចែងនៅក្នុងសន្និសីទទីក្រុងហ្សឺណែវឆ្នាំ១៩៥៤។ វៀតណាមទាំងមូលត្រូវគ្រប់គ្រងដោយពួកកុម្មុយនីស្ត ដោយដឹកនាំ វៀតណាមចាប់ពីពេលនោះរហូតដល់សព្វថ្ងៃ។

## ២-ប្រទេសឥណ្ឌូណេស៊ីក្រោយសង្គ្រាមលោកលើកទី២

### ២.១-ឥណ្ឌូណេស៊ីក្រោមការគ្រប់គ្រងរបស់ជប៉ុន

នៅក្នុងប្រទេសឥណ្ឌូណេស៊ី ការដួលរលំនៃរបបអាណានិគមហូឡង់ បាននាំឱ្យមានការដោះលែងអ្នកជាតិនិយមឥណ្ឌូណេស៊ីជាច្រើន ដែលរងទុក្ខនៅក្នុងគុកអាណានិគម (អ្នកខ្លះជាប់ជាងមួយទសវត្សរ៍ ឬក៏យូរជាងនេះក៏មាន)។ ដោយសារព្រឹត្តិការណ៍នេះ និងដោយសារការបរាជ័យរបស់ពួកម្ចាស់អាណានិគមចាស់ផងនោះ បានធ្វើឱ្យប្រជាជនឥណ្ឌូណេស៊ីជាច្រើន នាំគ្នាបាក់ទៅគាំទ្រពួកជប៉ុន។ អ្នកខ្លះទៀតដូចជាលោក ស៊ូកាណូ និង លោក ហត្តា តាមរយៈការធ្វើការជាមួយនឹងពួកជប៉ុន។ ការសម្រេចចិត្តដែលជាប់ទាក់ទងនឹង ការវិនិច្ឆ័យតាមលក្ខណៈនយោបាយនេះ មានន័យថា សកម្មភាពនេះគឺជាមធ្យោបាយយ៉ាងមានប្រសិទ្ធភាពបំផុត ដើម្បីរៀបចំការទាមទារឯករាជ្យផង និងការត្រៀមខ្លួនរួចជាស្រេចក្នុងការសហការជាមួយអ្នក ដែលបានផ្តួលរំលំពួកហូឡង់នោះផង។ ការសម្រេចចិត្តនោះ គឺដើម្បីធ្វើឱ្យល្អក់កករដល់អ្នកជាតិនិយម ឥណ្ឌូណេស៊ី និងរដ្ឋាភិបាលហូឡង់ នៅពេលសង្គ្រាមបញ្ចប់ទៅ។ ដោយពុំបានទទួលការអាណិតអាសូរពីជនជាតិឥណ្ឌូណេស៊ីនៅពេលដែលខ្លួនទទួលបរាជ័យនោះ ពួកហូឡង់បែរជាចោទប្រកាន់យ៉ាងខ្លាំងនៅពេលចប់សង្គ្រាមលោកលើកទី២ ថាមនុស្សដូចជាលោក ហត្តា និងស៊ូកាណូ គឺត្រូវតែចាត់ទុកថាជា «ជនចូលដៃចូលជើង» ជាមួយពួកកងទ័ពជប៉ុន។

មិនមានការសម្រុះសម្រួលគ្នាអាចធ្វើទៅបានទេ នៅពេលដែលការប៉ះទង្គិចគ្នាសម័យសង្គ្រាម បានកើតឡើង។ មូលហេតុខ្លះនៃរឿងនេះកើតឡើងដោយសារពួកហូឡង់ ដែលបរាជ័យជាធម្មតា មិនឱ្យតម្លៃទៅលើទំនាក់ទំនងដ៏ស្មុគស្មាញ និងលួចលាក់រវាងជនជាតិឥណ្ឌូណេស៊ី និងជប៉ុន នៅពេលសង្គ្រាមលោកលើកទី២ បានចាប់ផ្តើមកើតឡើង។ ដោយមានការស្វាគមន៍ពីប្រជាជនឥណ្ឌូណេស៊ី ជាច្រើនថា ជាអ្នករំដោះនោះពួកជប៉ុនបានក្លាយទៅជា ពួកមហាអំណាចខាងក្រៅថ្មីមួយទៀត។ មានតែនៅពេលនេះទេ ដែលជនជាតិអាស៊ីបានក្លាយទៅជាមហាអំណាចនោះ។ បើទោះបីជាពួកជប៉ុន បានបង្ហាញឱ្យឃើញភ្លាមៗថា ពួកគេគិតពីផលប្រយោជន៍របស់ខ្លួនគេខ្ពស់ជាងអ្វីទាំងអស់ក្តី ក៏ប្រជាជនឥណ្ឌូណេស៊ីនៅក្នុងអំឡុងនៃការគ្រប់គ្រងរបស់ជប៉ុន អាចចូលប្រឡូកក្នុងការរៀបចំនយោបាយបាន ច្រើនជាង ពេលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកហូឡង់។ នេះគឺជាទិដ្ឋភាពមួយដ៏សំខាន់ជាង ក្នុងចំណោមទិដ្ឋភាពសំខាន់ៗទាំងឡាយនៃការគ្រប់គ្រងរបស់ជប៉ុន នៅក្នុងប្រទេសឥណ្ឌូណេស៊ី។ មេដឹកនាំជាតិនិយមជាច្រើនរូប អាចរៀបចំបង្កើតកងប្រដាប់អាវុធជាច្រើន ដោយមានការយល់ស្របពីកងកម្លាំងមួយចំនួន នឹងអាចពង្រីកគោលបំណងជាតិនិយម ដើម្បីឯករាជ្យរបស់គេតាមរយៈការផ្សព្វផ្សាយ។

ពួកកងទ័ពជប៉ុនបានខិតខំយ៉ាងខ្លាំង ដើម្បីបង្កើតឱ្យមានការគាំទ្រការធ្វើសង្គ្រាម ដើម្បីប្រទេសពួកគេ ប៉ុន្តែប្រជាជនឥណ្ឌូណេស៊ីដែលចូលរួមក្នុងការហ្វឹកហាត់យោធា ទោះជានៅក្នុងក្រុមអង្គការ អ៊ីស្លាមក្តី ឬនៅ

ក្នុងក្រុមយុវជនក្ដី យល់ថា បញ្ហាស្ថិតនៅក្រោមការគ្រប់គ្រងរបស់បរទេស មិនសូវមានសារសំខាន់ជាងឱកាសក្នុងការបង្ហាញនូវអត្តសញ្ញាណជាតិឥណ្ឌូណេស៊ីរបស់ពួកគេនោះទេ។ ទង់ជាតិឥណ្ឌូណេស៊ី ដែលហាមឃាត់មិនឱ្យប្រើកាលពីពេលហូឡង់គ្រប់គ្រងនោះ បានបង្ហូតឡើង ហើយចម្រៀងឯករាជ្យក៏បានបើកឱ្យច្រៀងឡើងវិញផងដែរ។ ទាំងអស់នេះគឺជាការផ្លាស់ប្ដូរនិមិត្តរូប ហើយតួនាទីជានិមិត្តរូបក៏មានសារសំខាន់មិនតិចដែរ។ ការពង្រឹងនូវអត្តសញ្ញាណជាតិឥណ្ឌូណេស៊ី ដែលមិនគិតពីផលប្រយោជន៍មូលដ្ឋាន សាសនា និងវណ្ណៈសង្គម ជំរុញឱ្យមានការអនុវត្តជាក់ស្ដែងមួយចំនួនដូចជាការអភិវឌ្ឍនៃស្ថាប័នរដ្ឋបាល និងការបង្កើតឱ្យមានអង្គការយោធាទាំងបើកចំហ និងសម្ងាត់។

ការគ្រប់គ្រងរបស់ពួកជប៉ុន ផ្ដល់នូវនិមិត្តរូបដ៏សំខាន់មួយទៀត សម្រាប់ប្រជាជនឥណ្ឌូណេស៊ី ជាពិសេសសម្រាប់ពួកយុវជន។ ស្ទើរតែពាសពេញប្រទេសឥណ្ឌូណេស៊ី និងជាពិសេសនៅកោះជ្វា តម្លៃវប្បធម៌ប្រពៃណី ឥណ្ឌូណេស៊ី បានសង្កត់យ៉ាងធ្ងន់ទៅលើការគោរព និងយល់ថា អាកប្បកិរិយាដ៏ឥតខ្ចោះ គឺអាកប្បកិរិយាដែលរក្សាទុក តែនៅក្នុងចិត្ត និងមិនមានភាពឆេវឆាវ។ ឥលូវពួកជប៉ុន ដែលមាន ជ័យជម្នះ បានផ្ដល់នូវគំរូផ្សេងមួយទៀតសម្រាប់ពួកគេធ្វើតាម។ នោះគឺជាគំរូដែលទទួលស្គាល់ថា ការប្រើប្រាស់កម្លាំង និងអំពើហិង្សា មិនគ្រាន់តែមានការចាំបាច់ប៉ុណ្ណោះទេ ប៉ុន្តែ គឺជាការគួរឱ្យចង់ប្រព្រឹត្ត។ គ្មានអ្វីដែលស្ថិតនៅដាច់ពីគ្នាស្រឡះជាងភាពខុសគ្នា រវាងឧត្ដមគតិដែលស្ថិតនៅក្នុងប្រពៃណីយោធាជប៉ុន និងឧត្ដមគតិដែលជាប់ទាក់ទងជាមួយនឹងភាពស្ងប់សុខ នៃជីវិតជាប្រពៃណីរបស់ជនជាតិជ្វាទេ។ ប៉ុន្តែដោយសារភាពផ្ទុយគ្នានេះ ពួកយុវជនឥណ្ឌូណេស៊ីបានចាប់ផ្ដើមជជីកសួរពីគុណតម្លៃនៃអ្នកជំនាន់មុនរបស់ពួកគេថា កាលពីមុននោះ ហេតុអ្វីបានជាពួកអ្នកជំនាន់មុននោះមិនប្រឆាំងតបចំពោះការតាំង អាណានិគមរបស់ហូឡង់ ម្ដេចក៏បែរជាទទួលយកដោយគ្មានការតវ៉ាអ្វីទៅវិញ? ពួកយុវជនឥណ្ឌូណេស៊ី ដែលបានចោទសួរអំពីតម្លៃរបស់ពួកជំនាន់មុនៗ របស់ពួកគេ មិនបានទទួលយកនូវគុណតម្លៃរបស់ ជប៉ុនទាំងស្រុងនោះទេ។ ប៉ុន្តែពួកគេពិតជាបានមើលឃើញនូវទិដ្ឋភាពមួយចំនួននូវអាកប្បកិរិយារបស់ជប៉ុនថា មានទំនាក់ទំនងជាមួយនឹងគោលជំហររបស់ ពួកគេមែន។ ដោយសារមើលឃើញយ៉ាងនេះហើយទើបពួកគេគិតថា ពួកគេគឺពួកជំនាន់ថ្មីដែលផ្ដាច់ចេញពីអ្នកជំនាន់មុនរបស់ពួកគេ។ មនុស្សជំនាន់មុនយល់ព្រមទទួលយកការគ្រប់គ្រងរបស់ពួកហូឡង់ នៅក្នុងទសវត្សរ៍ឆ្នាំ១៩២០ និង១៩៣០ ហើយពេលដែលជប៉ុនចូលមកគ្រប់គ្រងម្ដង ពួកគេបានត្រៀមខ្លួនជាស្រេចក្នុងការធ្វើការឱ្យមេដឹកនាំថ្មីនេះ ដោយមិនចាំបាច់បានសួរនាំអ្វីទាំងអស់។ គំនិតថ្មីរបស់ក្មេងឥណ្ឌូណេស៊ីជំនាន់ក្រោយនេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រៀមខ្លួនជាស្រេច ដើម្បីវាយប្រឆាំងទៅនឹងការតាំងអាណានិគមឡើងវិញ បន្ទាប់ពីសង្គ្រាមបានបញ្ចប់។

## ២.២-សង្គ្រាមដណ្ដើមឯករាជ្យ

កងកម្លាំង និងពួករដ្ឋបាលហូឡង់ បានចាប់ផ្ដើមត្រឡប់មកកាន់ប្រទេសឥណ្ឌូណេស៊ីវិញ នៅចុងឆ្នាំ១៩៤៥។ នៅខែមករា ឆ្នាំ១៩៤៦ ពួកគេបានគ្រប់គ្រងក្រុងប៉ាតាវីយ៉ា (ជាក្រុងហ្សាកាតាបច្ចុប្បន្ន)។ ពួកគេយល់ឃើញថា ពួកអ្នកជាតិនិយមឥណ្ឌូណេស៊ី បានប្ដេជ្ញាចិត្តយ៉ាងមុតមាំក្នុងការទាមទារឯករាជ្យឱ្យបានសម្រេច បើទោះជាក្រុមគាំទ្រការទាមទារឯករាជ្យនានាមានការខ្វែងគំនិតគ្នាជាច្រើន ដោយសារមិនដឹងថា គួរដើរផ្លូវណាមួយ ដើម្បីទទួលបានឯករាជ្យក៏ដោយ។ អ្វីដែលសំខាន់បំផុតនោះ គឺការខ្វែងគំនិតគ្នារវាងអ្នកដែលចង់វាយបណ្ដេញពួកម្ចាស់អាណានិគមភ្លាមៗ យកឯករាជ្យ(ពួកគេភាគច្រើនជាក្រុមអ្នកជំនាន់ក្រោយ ដែលបានចូលរួមប្រយុទ្ធប្រឆាំងនឹងការតាំងអាណានិគមឡើងវិញ របស់កងទ័ពហូឡង់ នៅក្នុងក្រុងសំខាន់ៗ កន្លងមក)

និងក្រុមដែលចង់ទាមទារឯករាជ្យតាមរយៈការចរចា។ ជម្រើសយកការចរចា ដែលពួកមេដឹកនាំស្ថាបនិកចលនាជាតិនិយមមានចំណាប់អារម្មណ៍ តាំងតែពីពេលដំបូងមកនោះ បានជួយបញ្ចៀសការបង្ហូរឈាមគ្នា។ លើសពីនេះទៅទៀតការភ្ញាក់ផ្អើលមួយនៅពេលពួក ហូឡង់ ត្រឡប់មកវិញនោះ គឺពួកគេព្រមទទួលស្គាល់នូវសំណើទាមទារឯករាជ្យរបស់ពួកឥណ្ឌូណេស៊ី លុះត្រាតែពួកគេនៅទទួលបានផលប្រយោជន៍ ដែលនៅសេសសល់ខ្លះៗ របស់ខ្លួន។ ប៉ុន្តែក្រោយមកមិនយូរប៉ុន្មាន មុនដំណាច់ឆ្នាំ១៩៤៦ ការខ្វែងគំនិតគ្នារវាងភាគីទាំងពីរបានលេចចេញមកយ៉ាងច្បាស់។

សម្រាប់ទស្សនៈរបស់ឥណ្ឌូណេស៊ី ការចរចាគឺត្រូវតែជាប់ទាក់ទងជាមួយនឹងការផ្តល់ឯករាជ្យ។ ប្រការនេះបានប្រឆាំងទាំងស្រុងទៅនឹងគោលជំហររបស់ពួកហូឡង់ ដែលគិតថា គួរតែមានការចរចា ដើម្បីរៀបចំសម្រួលឱ្យប្រទេសឥណ្ឌូណេស៊ីទទួលបានឯករាជ្យពេញលេញមួយ នៅពេលក្រោយ ប៉ុន្តែមិនដឹងពេលណាប្រាកដនោះទេ។ ដោយសារតែគេបានប្រកាសឯករាជ្យភាពក្នុងខែសីហា ឆ្នាំ១៩៤៥ រួចហើយ ប្រជាជនឥណ្ឌូណេស៊ីអន្ទះសាចង់ឃើញភាពពិតនៃក្តីស្រមៃ ដែលពួកគេលើកមកពិភាក្សាជាញឹកញាប់ ហើយដែល ជនរួមជាតិរបស់ពួកគេជាច្រើននាក់ បានរងការចាប់ឃុំឃាំង ឬនិរទេសខ្លួនចេញពីស្រុក។ ផ្ទុយទៅវិញពួក ហូឡង់មិនអាចបោះបង់ចោលនូវគំនិត និងឫកពាដែលខ្លួនធ្លាប់មានក្នុងរយៈពេលអាណានិគមទេ។ ទោះបីជារដ្ឋាភិបាលរបស់ពួកគេបានធ្វើការសន្យាមិនច្បាស់លាស់ជាច្រើន នៅក្នុងអំឡុងពេលចាប់ដៃធ្វើសង្គ្រាមជាមួយនឹងពួកជប៉ុន ពួកអ្នកចរចាហូឡង់មិនជឿថា ប្រជាជនដែលនៅក្រោមអាណានិគមរបស់ពួកគេនោះ បានត្រៀមខ្លួនជាស្រេចសម្រាប់ការទាមទារឯករាជ្យទាំងស្រុង ឬពិតជាចង់បានឯករាជ្យទាំងស្រុងនោះឡើយ។ ការប៉ាន់ស្មានរបៀបនេះមិនមែនគ្រាន់តែកើតឡើងដោយសារតែការពុំចង់ប្រឈមមុខជាមួយនឹងការពិត ដែលថា គេលែងទទួលស្វាគមន៍រដ្ឋបាលហូឡង់នៅក្នុងប្រទេសឥណ្ឌូណេស៊ីទៀតហើយនោះ ប៉ុណ្ណោះទេ។ លើសពីនេះទៅទៀតការមិនពេញចិត្តរបស់លោក ស៊ូកាណូ ដែលបានត្រៀមខ្លួនជាស្រេចនៅក្នុងអំឡុងពេលសង្គ្រាមធ្វើការជាមួយនឹងពួកជប៉ុន ដើម្បីសម្រេចឱ្យបាននូវគោលបំណងជាតិនិយមរបស់លោកនោះ បានរារាំងពួកហូឡង់មិនឱ្យគិតលើស្ថានភាពក្រោយសង្គ្រាមទៅតាមសច្ចភាព ប៉ុន្តែជាការស្រមើស្រមៃហួសពេលវេលារបស់ខ្លួនដែលថា ពួកជនជាតិស្បែកសមានភារកិច្ចលើជនជាតិផ្សេងទៀត និងការគិតថា បំណងប្រាថ្នាចង់បានឯករាជ្យរបស់ប្រជាជនឥណ្ឌូណេស៊ីគឺគ្រាន់តែជាការស្មានប៉ុណ្ណោះ។

ការខ្វែងគំនិតគ្នារវាងពួកហូឡង់ និងឥណ្ឌូណេស៊ី មានន័យថា ការចរចាទាំងឡាយនឹងចៀសមិនផុតពីបរាជ័យទេ។ ជាធម្មតារឿងនេះដោយសារក្រុមទាំងពីរ ដែលត្រៀមខ្លួនចរចានោះ មិនទាំងយល់ស្របដូចគ្នាទៅលើអ្វី ដែលជាសារៈសំខាន់នៃការពិភាក្សារបស់ពួកគេផង។ កិច្ចព្រមព្រៀងសំខាន់ពីរ រវាងឥណ្ឌូណេស៊ី និងហូឡង់ នៅក្នុងដំណាក់កាលតស៊ូដណ្តើមឯករាជ្យ គឺកិច្ចព្រមព្រៀង Linggadjati នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៤៦ និងកិច្ចព្រមព្រៀងរ៉េនវីល្ល(Renville) (ដាក់ឈ្មោះតាមកប៉ាល់យោធា ដែលគេរៀបចំការចរចានៅក្នុងនោះ) នៅខែមករា ឆ្នាំ១៩៤៨ បានបរាជ័យដោយសារតែការខ្វះឆន្ទៈរបស់ពួកហូឡង់ ក្នុងការគិតពិចារណាពីប្រទេសឥណ្ឌូណេស៊ីឯករាជ្យដ៏ពេញលេញនាពេលអនាគត។ ដូច្នេះហើយប្រជាជនឥណ្ឌូណេស៊ីមិនដែលប្រាកដក្នុងចិត្តទេថា ពួកហូឡង់នឹងត្រៀមខ្លួនជាស្រេចក្នុងការទទួលយកថា អ្នកជាតិនិយមឥណ្ឌូណេស៊ីជាដៃគូស្មើភាពគ្នាជាមួយនឹងពួកម្ចាស់អាណានិគមក្នុងការក្លាយទៅជាអ្នកគាំទ្របង្កើត "សហរដ្ឋឥណ្ឌូណេស៊ី" ដែលគេបានគ្រោងរួចមកហើយនោះ។ លើសពីនេះទៅទៀត ពួកអ្នកជាតិនិយមឥណ្ឌូណេស៊ី កាន់តែជឿខ្លាំងៗថា ការគាំទ្ររបស់ពួកហូឡង់ចំពោះរដ្ឋសហព័ន្ធឥណ្ឌូណេស៊ី ដែលកើតចេញពីតំបន់ពាក់កណ្តាល

ស្វយ័តជាច្រើនទាំងឡាយនៅលើទឹកដីអាណានិគមឥណ្ឌូណេស៊ីរបស់ខ្លួននោះ គឺជាការខិតខំប្រឹងប្រែងផ្សេងមួយទៀតដើម្បីថែរក្សាតួនាទីរបស់ពួកគេ។ នៅពេលបន្តគោលនយោបាយនេះ ពួកហូឡង់បានទាញយកផលប្រយោជន៍ពីព្រឹត្តិការណ៍ពិតជាក់ស្តែង ដែលមានឬនៅតែមានការសង្ស័យ ឬនៅក្នុងករណីខ្លះទៀតជាការចងកំហឹងយ៉ាងខ្លាំង ចំពោះភាព គ្របដណ្តប់របស់ជនជាតិជ្វា ពីសំណាក់ប្រជាជនដទៃទៀតនៅក្នុងតំបន់ដទៃទៀត ដូចជានៅកោះ ស៊ូម៉ាត្រា កោះបាលី កោះស៊ូឡាវ៉ឺស៊ី និងកោះឆ្ងាយៗទៀតនៅផ្នែកខាងកើត។ ប៉ុន្តែទោះបីជាពួកហូឡង់ ចាប់អារម្មណ៍នឹងវត្តមាននៃភាពមន្ទិលនេះប៉ុនណា និងប្រឹងរកចម្លើយខ្លះពីពួកអភិរក្សនិយម ដូចដែលពួកគេបានធ្វើនោះក៏ដោយ ក៏គេដឹងកាន់តែច្បាស់ថា ការព្យាយមរបស់ពួកគេក្នុងការប្រើប្រាស់ដំណោះ ស្រាយសហព័ន្ធ តាមពិតទៅ គឺជាការព្យាយាមចង់រក្សាការគ្រប់គ្រងរបស់ពួកហូឡង់ ឬយ៉ាងហោចណាស់ រក្សាវត្តមានរបស់ពួកហូឡង់តាមរយៈមធ្យោបាយជាប្រយោល[430]។

គម្រោងការរបស់ពួកហូឡង់គឺមិនគ្រាន់តែប្រឈមមុខនឹងការប្រឆាំងយ៉ាងជូរចត់ ពីសំណាក់ពួកអ្នកជាតិនិយមដ៏សកម្ម មកពីបណ្តារដ្ឋនានាពាសពេញប្រទេសឥណ្ឌូណេស៊ីប៉ុណ្ណោះទេ ប៉ុន្តែ ជាចុងបញ្ចប់ គោលនយោបាយរបស់ ពួកហូឡង់ក៏លែងបង្កើតឱ្យមានការជឿទុកចិត្តពីសំណាក់ប្រជាជនក្នុងតំបន់ដែល រដ្ឋសហព័ន្ធត្រូវបានបង្កើតឡើងដែរ។ កត្តាជាច្រើនបានជួយឱ្យមានការផ្លាស់ប្តូរចិត្តគំនិត។ សង្គ្រាមលោកលើក ទី២ បានបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងរួចទៅហើយ ក្នុងការផ្សព្វផ្សាយ និងបានបណ្តុះគំនិតយ៉ាងរឹងមាំមួយដល់ប្រជាជនឥណ្ឌូណេស៊ីភាគច្រើនថា ពួកគេគួរតែតាំងខ្លួនជាជនជាតិឥណ្ឌូណេស៊ីផង និងជាប្រជាជននៃតំបន់មានវប្បធម៌ជាក់លាក់រៀងខ្លួនផង។ អ្វីដែលពួកហូឡង់បានប្រព្រឹត្តក្រោមឈ្មោះថា "វិធានការប៉ូលិសរឹតបន្តឹង" នៅពាក់កណ្តាលឆ្នាំ១៩៤៧ និងចុងឆ្នាំ១៩៤៨ ក៏មានសារៈសំខាន់ដូចគ្នាក្នុងការផ្លាស់ប្តូរ និងបង្កើតគំនិតជាច្រើនដែរ។

នៅពេលដែលការចរចាជាប់ផុងហើយ ក្រុមទាំងពីរបានគិតថា ភាគីបដិបក្សធ្វើនូវអ្វីដែលមិនអាចទទួលយកបាននោះ ពួកហូឡង់បានធ្វើប្រតិបត្តិការនូវអ្វីដែលគេហៅថា វិធានការប៉ូលិសរឹតបន្តឹងនៅខែកក្កដា ឆ្នាំ១៩៤៧។ ក្នុងន័យយោធា ពីព្រោះថា នោះជាយុទ្ធនាការរបស់កងកម្លាំងយោធា មិនមែនជារបស់កងកម្លាំងប៉ូលិសទេ ដែលធ្វើប្រតិបត្តិការនោះ ពួកហូឡង់បានទទួលបានជោគជ័យខ្លះៗ ដែរ។ ពួកគេបានគ្រប់គ្រងលើតំបន់សំខាន់ៗ នៅកោះជ្វា និងកោះស៊ូម៉ាត្រា ហើយដោយសារតែគេបាន គ្រប់គ្រងតំបន់ទាំងនោះហើយ ទើបពួកគេអាចរាំងស្ទះមិនឱ្យមានផ្គត់ផ្គង់ស្បៀងដល់កងយោធារបស់ពួកអ្នកជាតិនិយមឥណ្ឌូណេស៊ី។ ប៉ុន្តែទោះបីជាទទួលបានជោគជ័យយ៉ាងនេះក្តី ក៏ការខាតបង់កម្លាំងកងទ័ពរបស់ហូឡង់ មានសភាពធ្ងន់ធ្ងរណាស់ដែរ តាមពិតទៅគឺធ្ងន់ជាងអ្វីដែលពួកហូឡង់បានគិតទៅទៀត។ នេះគ្រាន់តែជាព្រឹត្តិការណ៍មួយក្នុងចំណោមព្រឹត្តិការណ៍ទាំងឡាយនៅក្នុងប្រវត្តិនៃតំបន់អាស៊ីអាគ្នេយ៍នាសម័យក្រោយសង្គ្រាមលោកលើកទី២ ស្តីពីពួកមហាអំណាចអាណានិគមនិយមបរទេស ដែលខ្វះការពិចារណាឱ្យបានវែងឆ្ងាយ ដោយផ្តល់សារៈសំខាន់ទៅលើបញ្ហាយោធាជាជាងកិច្ចការផ្នែកនយោបាយដ៏ទូលំទូលាយ។ ទោះបីជាវិធានការប៉ូលិសរឹតបន្តឹង ដំបូងរបស់ពួកហូឡង់ វាយបានទឹកដីនិងស្បៀងអាហារ ព្រមទាំងគ្រប់គ្រងលើប្រជាជនខ្លះៗក៏ដោយ ក៏វិធាន ការរឹតបន្តឹងនេះ ប្រែក្លាយទៅជាកត្តាសំខាន់ក្នុងការបង្រួបបង្រួមឱ្យមានការគាំទ្របន្ថែមទៀតទៅលើ ចលនាជាតិនិយមទៅវិញ។ អ្នកខ្លះនៅតែមានការសង្ស័យចំពោះការយល់ឃើញរបស់មេដឹកនាំជាតិនិយមនានា ដែលអះអាងថា

[430] មិលុន អូស្ប៊ន, *ផ្តើមឈ្វេងយល់ពីប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍*, មជ្ឈមណ្ឌលខេមរសិក្សា, ឆ្នាំ២០០៩, ទំព័រ១៨៩។

តាមការពិត ពួកហូឡង់មិនទាន់ត្រៀមខ្លួនប្រគល់ឯករាជ្យឱ្យប្រទេសឥណ្ឌូណេស៊ីឡើយ ប៉ុន្តែ នៅពេលដែលពួក គេឃើញការប្រើអាវុធរបស់កងកម្លាំងហូឡង់ ក៏ព្រមជឿថា អ្វីដែលមេដឹកនាំជាតិនិយមនិយាយនោះគឺ ជាការពិត។ និយាយឱ្យខ្លីទៅ នៅពេលដែលពួកហូឡង់កាន់តែមានប្រៀបក្នុងអំឡុងខែកក្កដា និងខែសីហា ឆ្នាំ ១៩៤៧ ក្នុងពេលតែមួយនោះ ពួកគេក៏បានគាំទ្រដល់អ្នកជាតិនិយមកាន់តែខ្លាំងឡើងដែរ។ ពួកមហាអំណាចអាណានិគមនិយមចាស់ បានធ្វើច្រើនជាងនេះទៅទៀត ពីព្រោះការសម្រេចចិត្តប្រើកម្លាំងយោធារបស់ពួកគេ បណ្តាលឱ្យមានការប្រឆាំងពីសំណាក់ក្រុមសំខាន់ៗ របស់សហគមន៍អន្តរ ជាតិ។ ចាប់ពីចុងឆ្នាំ ១៩៤៧ មក កង្វល់របស់សហគមន៍អន្តរជាតិទៅលើជម្លោះ ដែលចេះតែកើនឡើង នៅក្នុងប្រទេសឥណ្ឌូណេស៊ីកាន់តែមានសារៈសំខាន់ខ្លាំងឡើងជាងពេលមុនៗទាំងអស់។ នៅចុងបញ្ចប់ គេអាចនិយាយបានថា ការដាក់សម្ពាធពីសហគមន៍អន្តរជាតិនេះហើយ ដែលបង្ខំឱ្យពួកហូឡង់លះបង់ការខំប្រឹងប្រែងរបស់ខ្លួនក្នុងការពន្យារការប្រគល់ឯករាជ្យឱ្យឥណ្ឌូណេស៊ី។

យោបល់របស់សហគមន៍អន្តរជាតិ ដែលបានបង្ហាញតាមរយៈអង្គការសហប្រជាជតិ ដែលទើបនឹងបង្កើតថ្មីៗនោះ អាចមានលទ្ធភាពក្នុងការនាំឱ្យមានការបញ្ឈប់វិធានការប៉ូលិសរឹតបន្តឹងលើកដំបូងរបស់ហូឡង់ និងឱ្យត្រឡង់ទៅរកការចរចាឡើងវិញ។ ជាថ្មីម្តងទៀត ការចរចានេះហាក់ដូចជាមានល្បឿនយឺត ដោយមិនមានការសម្រេចចិត្តអ្វីសោះតាំងពីចុងឆ្នាំ១៩៤៧ រហូតដល់ចុងឆ្នាំ១៩៤៨ នៅពេលពួកហូឡង់ចង់ដោះស្រាយតាមការប្រើប្រាស់កម្លាំងយោធា នៅក្នុងវិធានការប៉ូលិស រឹតបន្តឹងលើកទី២ ដែលចំណាយពេលតាំងពីពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៤៨ រហូតដល់ដើមខែមករា ឆ្នាំ១៩៤៩។ ព្រឹត្តិការណ៍ ដែលកើតឡើងក្នុងយុទ្ធនាការយោធាលើកទី២នេះ គឺមានភាពស្រដៀងគ្នាទៅនឹងអ្វីដែលកើតឡើងក្នុងឆ្នាំ១៩៤៧ ដែរ។ ពួកហូឡង់បានរុលកងកម្លាំងយោធារបស់ខ្លួនទៅមុខ ប៉ុន្តែ ដើម្បីធ្វើដូច្នេះបាន ពួកគេបានពង្រឹងគោលជំហរនយោបាយនៃអ្នកជាតិនិយមឥណ្ឌូណេស៊ី និងបន្ថយនូវការគាំទ្រ ដែលពួកគេបានទទួលពីសម្ពន្ធមិត្តលោកខាងលិចរបស់ពួកគេ។ នៅពេលវិធានការប៉ូលិសរឹតបន្តឹងលើកទី២ នេះជិតបញ្ចប់ទៅ មានការគាំទ្របន្តិចបន្តួចប៉ុណ្ណោះពីសំណាក់មេដឹកនាំនៃកោះឆ្ងាយៗ ក្នុងការចូលរួមបន្តជាមួយនឹងពួកហូឡង់។ ប៉ុន្តែ លទ្ធផលគឺជាការខំប្រឹងប្រែងបន្ថែមទៀត ទៅដល់ការចរចាគ្នាមួយ ដែលនាំទៅរកការយល់ព្រមផ្ទេរអធិប-តេយ្យភាពឱ្យប្រទេសឥណ្ឌូណេស៊ី នៅចុងឆ្នាំ១៩៤៩។ ប៉ុន្តែ មុនពេលធ្វើអង្កេតអំពីការវិវត្តទៅដល់ការផ្ទេរអធិបតេយ្យភាពនោះ យើងក៏គួរតែពិនិត្យមើលខ្លះៗផងដែរ នូវដំណើរវិវត្តនយោបាយផ្ទៃក្នុង នៅអំឡុងពេលធ្វើបដិវត្តន៍ ឥណ្ឌូណេស៊ី។

ជាទូទៅពេលគេនិយាយពីចលនាបដិវត្ត គេតែងតែចងចាំលទ្ធផលរបស់វា ជាជាងប្រវត្តិដ៏ស្មុគស្មាញនៃការវិវត្តរបស់ចលនាតាំងពីដើមដំបូងរហូតដល់ចុងបញ្ចប់។ នៅក្នុងបញ្ហានេះយើងឃើញមាន ការវិវត្តពីរដែលគួរចាប់អារម្មណ៍ គឺតួនាទីរបស់គណបក្សកុម្មុយនីស្តឥណ្ឌូណេស៊ី និងការខំប្រឹងប្រែង របស់ក្រុមអ៊ីស្លាមនិយម ដើម្បីបង្កើតរដ្ឋអ៊ីស្លាមឥណ្ឌូណេស៊ី ដែលមានឈ្មោះថា "ដារុលអ៊ីស្លាម" ជាភាសាអារាប់ដែលមានន័យថា "ដែនអ៊ីស្លាម"។ នៅក្នុងប្រទេសឥណ្ឌូណេស៊ី ពួកកុម្មុយនីស្តមិនមែនជាមេដឹកនាំតស៊ូប្រឆាំងនឹងការតាំងអាណានិគមជាថ្មីឡើងវិញនោះទេ។ ពួកកុម្មុយនីស្តឥណ្ឌូណេស៊ីគ្រាន់តែ ជាគណបក្សមួយក្នុងចំណោមគណបក្សនយោបាយ និងក្រុមទាំងឡាយ ដែលរួបរួមគ្នាប្រឆាំងនឹងពួកហូឡង់ ប៉ុន្តែនៅពេលដំណាលគ្នានោះដែរ ពួកគេព្យាយាមលើកតម្កើងកម្មវិធីនយោបាយរបស់គណបក្សរៀងខ្លួន។ការជាប់ពាក់ព័ន្ធជាមួយផលប្រយោជន៍ផ្ទាល់ខ្លួន ដែលមានលក្ខណៈផ្ទុយពីចលនាជាតិនិយម ប្រឆាំងនឹងពួកហូឡង់ បាននាំឱ្យសមាជិកខ្លះនៅក្នុង

គណបក្សកុម្មុយនីស្តឥណ្ឌូណេស៊ីព្យាយាមដឹកនាំចលនាបដិវត្ត[431]។ មិនដល់មួយខែផង នៅខែកញ្ញា ឆ្នាំ ១៩៤៨ ជនកុម្មុយនីស្តដែលបានធ្វើប្រតិបត្តិការ ចេញពីមូលដ្ឋានរបស់ខ្លួននៅកោះជ្វា កណ្តាល ឯម៉ាឌីយុន បានទទួលជោគជ័យបន្តិចបន្តួច ហើយក្រោយមកទទួលជោគជ័យស្ទើរតែទាំងស្រុង។ កងកម្លាំងជំនាញៗ បំផុតនៅក្នុងកងកម្លាំងបដិវត្តឥណ្ឌូណេស៊ី ដែលដឹកនាំ ដោយលោកវរសេនីយ៍ឯក អាប់ឌុល ហារិស ណាស៊ុទីយ៉ុន (A.H. Hasution) បានបញ្ជូនឱ្យទៅម៉ាឌីយុន ដើម្បីវាយយកលទ្ធផលនេះ។ បន្ទាប់ពីការបរាជ័យរបស់កងកម្លាំងកុម្មុយនីស្ត នៅក្រុងនោះ កងកម្លាំងបដិវត្តឥណ្ឌូណេស៊ីក៏បានវាយដណ្តើមបានជ័យជម្នះជាបន្តបន្ទាប់ ដោយវាយកម្ទេចយ៉ាងឃោរឃៅទៅលើក្រុមសេសសល់ ដែលបានចូលរួមធ្វើការប្រយុទ្ធក្នុងពេលដ៏ខ្លីមួយជាមួយនឹងពួកកុម្មុយនីស្ត។

ព្រឹត្តិការណ៍នៅម៉ាឌីយុន ដែលធ្វើឱ្យគេចងចាំតាំងពីពេលនោះមក បានបន្សល់ទុកនូវប្រតិកម្មដ៏ ខ្លាំងក្លា ដែលនៅតែធ្វើឱ្យរង្គោះរង្គើដល់ផ្នែកនយោបាយឥណ្ឌូណេស៊ីជាង៥០ឆ្នាំ ក្រោយមក។ សូម្បីតែមុនពេលមានការព្យាយាមដណ្តើមអំណាច មានមនុស្សជាច្រើនដែលបានជជែកវែកញែកថា ជនកុម្មុយនីស្តមិនមែនធ្វើសកម្មភាពឡើង ដើម្បីបុព្វហេតុជាតិនិយមឥណ្ឌូណេស៊ីស្មើនឹងជោគជ័យ នៃលទ្ធិនយោបាយរបស់ពួកគេ នោះទេ។ នេះគឺជាទស្សនៈសំខាន់ៗ នៅក្នុងកងកម្លាំងទ័ពឥណ្ឌូណេស៊ី ហើយព្រឹត្តិការណ៍ ទាំងនេះបានបញ្ជាក់ថា គំនិតពួកគេពិតជាត្រឹមត្រូវមែន។ លោកមេបញ្ជាការ ណាស៊ុទីយ៉ុន នៃកងទ័ព ដែលបានវាយបំបាក់ជនកុម្មុយនីស្តនៅម៉ាឌីយុន ត្រូវតែបន្តដើរតួនាទីសំខាន់នៅក្នុងនយោបាយ ឥណ្ឌូណេស៊ី ក្រោយពីបាន ឯករាជ្យហើយ ព្រមទាំងត្រូវតែប្រកាន់ភ្ជាប់ដូចមន្ត្រីដទៃទៀតដែរ នូវជំនឿថា កំហុសរបស់ជនកុម្មុយនីស្ត ឥណ្ឌូណេស៊ី ត្រូវចាត់ទុកចលនាជាតិនិយមឱ្យខ្ពស់ជាងផលប្រយោជន៍ និងជំនឿនយោបាយរបស់ពួកគេ ផ្ទាល់។ នៅពេលដូចគ្នានេះដែរ ដូចជាមនុស្សជាច្រើនបានសង្កេតឃើញថា នៅក្នុងការវិភាគដំបូងៗ នៃព្រឹត្តិការណ៍នេះ រឿងដែលថារដ្ឋាភិបាលបដិវត្តឥណ្ឌូណេស៊ី និងកងកម្លាំងយោធារបស់រដ្ឋាភិបាលនេះបានត្រៀមខ្លួនជាស្រេច ក្នុងការបង្ក្រាបពួកកុម្មុយនីស្តនៅម៉ាឌីយុននោះ ធ្វើឱ្យពួកហូឡង់បាត់បង់លទ្ធភាពក្នុងការប្រើលេសថា ការក្រាញនៀលរក្សាតួនាទីរបស់ពួកគេនៅក្នុងប្រទេសឥណ្ឌូណេស៊ី សមតែទទួលបាននូវ ការគាំទ្រថា ជាផ្នែកមួយនៃសង្គ្រាមប្រឆាំងនឹងលទ្ធិកុម្មុយនីស្ត នៅទូទាំងពិភពលោក។

ក្រុមដារុលអ៊ីស្លាម បានទទួលការគាំទ្រពីតំបន់ ដែលមានអ្នកជឿលើសាសនាអ៊ីស្លាម យ៉ាងខ្លាំងក្លា ដូចជានៅកោះជ្វាខាងលិច កោះស៊ូម៉ាត្រាខាងជើង និងផ្នែកជាច្រើននៅលើកោះបរណេអូ (កាលី ម៉ាន់តាន់) របស់ឥណ្ឌូណេស៊ី។ នៅពេលអនុវត្តវិធានការប៉ូលិសរឹតបន្តឹងលើកទី២ របស់ពួកហូឡង់ ក្រុមអ្នកដែលធ្វើសកម្មភាពគាំទ្រដល់ដារុលអ៊ីស្លាម បានព្យាយាមធ្វើការគ្រប់គ្រងលើទឹកដីតាមរយៈកងកម្លាំងប្រដាប់អាវុធ។ បើទោះបីជាការព្យាយាមនេះបានទទួលជោគជ័យក្តី ក៏ដារុលអ៊ីស្លាម បានបន្តប្រឆាំងរដ្ឋាភិបាលកណ្តាលរហូតដល់ឆ្នាំ ១៩៦២។ ដូចគ្នាទៅនឹងព្រឹត្តិការណ៍នៅម៉ាឌីយុនដែរ ការចងចាំពីសកម្មភាពរបស់ដារុលអ៊ីស្លាម បានស្ថិតនៅក្នុងគំនិតអ្នកនយោបាយឥណ្ឌូណេស៊ីទាំងឡាយ ទាំងស៊ីវិល និងយោធា ជាពិសេសនៅពេលការគាំទ្រក្នុងការធ្វើឱ្យប្រទេសឥណ្ឌូណេស៊ីក្លាយទៅជារដ្ឋអ៊ីស្លាម បានលេចឡើងជាថ្មីម្តងទៀត។ ប៉ុន្តែ បើទោះបីជាមើលទៅហាក់បីដូចជាអះអាងថា នៅតែមានការទទួលយកជារួមថា ជាតិមិនទាក់ទងនឹងសាសនា គឺជាអ្វីដែលគេចង់បាន

---

[431] មិលុន អូស្បិន, *ផ្តើមល្បែងយល់ពីប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍*, មជ្ឈមណ្ឌលខេមរសិក្សា, ឆ្នាំ២០០៩, ទំព័រ១៩១។

នៅក្នុងប្រទេសឥណ្ឌូណេស៊ី ជាការត្រឹមត្រូវនៅក្នុងសមាជិកឥស្សរជនដែលប្រចាំនៅហូឡាការតានោះក៏ដោយ ក៏គ្មានអ្វីគួរឱ្យសង្ស័យទេថា សាសនាអ៊ីស្លាមដើរតួនាទីក្នុងផ្នែកនយោបាយសំខាន់ជាងក្រោយបដិវត្តន៍ភ្លាមៗ។

ការចរចាជាច្រើន ដែលធ្វើឡើងបន្ទាប់ពីវិបានការប៉ូលិសរឹតបន្តឹងលើកទី២ បានបញ្ចប់ទៅនៅក្រោមលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌ ដែលបានដាក់ស្នើពីពេលមុនៗ។ ជាពិសេសបំផុតនោះពួកហូឡង់ បានស្ថិតនៅក្រោមការគាបសង្កត់ខ្លាំងឡើងៗ ពីសហរដ្ឋអាម៉េរិក ឱ្យធ្វើសម្បទានដល់ប្រជាជនឥណ្ឌូណេស៊ី។ នៅក្នុងកាលៈទេសៈនេះ ភាគីឥណ្ឌូណេស៊ី បានទទួលយកថា ពួកគេក៏ត្រូវធ្វើសម្បទានផងដែរ គឺការទទួលយកនូវបំណុលយ៉ាងច្រើនសន្ធឹកសន្ធាប់ រួមទាំងការចំណាយក្នុងការធ្វើប្រតិបត្តិការយោធាហូឡង់នៅក្នុងប្រទេសឥណ្ឌូណេស៊ីផង និងការពន្យារពេលក្នុងការសម្រេចអំពីស្ថានភាពរបស់ ញូហ្គីណេ ខាងលិច (ប៉ាពូ)។ បន្ទាប់ពីការពិភាក្សាគ្នាអស់រយៈពេលយ៉ាងយូរមក ជាចុងបញ្ចប់រដ្ឋាភិបាលហូឡង់ ក៏បានប្រគល់អធិបតេយ្យភាពនៃតំបន់ទាំងឡាយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេឱ្យ រដ្ឋាភិបាល បដិវត្តនៅក្នុងខែធ្នូ ឆ្នាំ១៩៤៩។ ក្នុងរយៈពេលតែមួយឆ្នាំ រដ្ឋពាក់កណ្តាលស្វយ័តទាំងឡាយនៅឆ្ងាយ ពីកោះជ្វា ដែលបានបង្កើតឡើងដោយពួកហូឡង់ នៅអំឡុងពេលជម្លោះ និងការចរចា រយៈពេល៣ឆ្នាំ បានបញ្ចូលទៅជារដ្ឋអព្យាក្រឹតក្នុងវិស័យសាសនា រួបរួមឥណ្ឌូណេស៊ី ដែលជាគោលបំណងរបស់អ្នក ជាតិនិយមភាគច្រើន តាំងតែពីយូរយាណាស់មកហើយ។

ដោយទទួលបានឯករាជ្យពីហូឡង់មក ពួកអ្នកជាតិនិយមត្រូវប្រឈមមុខនឹងបញ្ហា នៃប្រទេស ឥណ្ឌូណេស៊ីជាច្រើន។ នៅពេលដែលពួកគេបានប្រឈមមុខចំពោះបញ្ហានយោបាយទាំងនោះ ភាពសប្បាយរីករាយយ៉ាងខ្លាំងក្នុងការទទួលបានជោគជ័យទាំងនោះ បានរលាយបាត់បន្តិចម្តងៗ ហើយព្រឹត្តិការណ៍ និងបញ្ហាផ្សេងៗគ្នាជាច្រើនបានលេចឡើងយ៉ាងច្បាស់ក្រឡែត។ បាវចនាជាតិនៃប្រទេសឥណ្ឌូណេស៊ី«ភាពរួមក្នុងភាពដោយឡែក» គឺជាការថ្លែងដ៏គួរឱ្យកោតសរសើរនៃព្រឹត្តិការណ៍ និងការសង្ឃឹម។ បាវចនានេះក៏បានឆ្លុះបញ្ចាំងនូវភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងរដ្ឋឥណ្ឌូណេស៊ី ដែលជានិច្ចកាលតែងចោទជាបញ្ហាជាច្រើន ខ្លះតូច ខ្លះធំ ដល់ការគ្រប់គ្រងរបស់អំណាចកណ្តាល និងពួកអាជ្ញាធរ។ វត្តមាននៃផលប្រយោជន៍ជា លក្ខណៈតំបន់ និងផលប្រយោជន៍សំខាន់ដទៃទៀត មិនអាចលុប បំបាត់បានទេ ដោយសារតែការតស៊ូបដិវត្ត។

## ២.៣-ឥណ្ឌូណេស៊ីក្រោយឯករាជ្យ

បន្ទាប់ពីមានការតស៊ូប្រដាប់អាវុធប្រឆាំងនឹងពួកហូឡង់ រួចមក ពួកអ្នកជាតិនិយមឥណ្ឌូណេស៊ី បានសម្រេចគោលបំណងឯករាជភាពរបស់ខ្លួននៅខែធ្នូ ឆ្នាំ១៩៤៩។ រដ្ឋថ្មីមួយបានលេចឡើងជារូបរាង យ៉ាងពិតប្រាកដតាមរយៈការតស៊ូដណ្តើមឯករាជ្យ។ ជនជាតិឥណ្ឌូណេស៊ី បានទទួលជ័យជម្នះ ប៉ុន្តែជ័យជម្នះនេះនៅពើបប្រទះបញ្ហាជាច្រើន ដែលមិនទាន់អាចដោះស្រាយបាននៅឡើយ។ ពួកហូឡង់ បានប្រគល់អធិបតេយ្យភាពឱ្យឥណ្ឌូណេស៊ីវិញ ក៏ប៉ុន្តែ អនាគតរបស់រដ្ឋឥណ្ឌូណេស៊ីនៅពុំទាន់ច្បាស់នៅឡើយ នៅត្រង់ថា តើឥណ្ឌូណេស៊ីគួរតែជារដ្ឋរួបរួម ឬក៏ជារដ្ឋដែលគិតគូរដល់អារម្មណ៍ចង់បំបែកខ្លួន នៅតំបន់ទាំងឡាយ ដូចជានៅភាគខាងជើងកោះស៊ូម៉ាត្រា និងនៅកោះភាគខាងកើតជាច្រើនទៀត ដោយរួមមានផ្នែកខ្លះនៃកាលីម៉ាន់តាន់ (បិរណេអូ) និងស៊ូឡាវ៉ីស៊ី ដែលនៅទីនោះមានការអាក់អន់ចិត្តចំពោះតួនាទីធ្វើមជ្ឈការ និងឥទ្ធិពលក្តោបក្តាប់របស់អ្នកនយោបាយជ្វា។ នៅមានភាពមិនច្បាស់លាស់របស់តួនាទីសាសនាអ៊ីស្លាម ដោយសារនៅមានក្រុមនយោបាយខ្លះនៅមានបំណងចង់បដិសេធចោលមាត្រាមួយក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៥ ដែលបានប្រកាសថា ឥណ្ឌូណេស៊ីគឺជារដ្ឋអាណាចក្រ (ឬរដ្ឋលោកវិស័យ គឺអព្យាក្រឹតក្នុងវិស័យសាសនា)នោះ។ បន្ទាប់

ពីមានការប្រើប្រាស់ទាំងសកម្មភាពយោធា និងនយោបាយដ៏ស្វិតស្វាញ ដើម្បីដាក់ការគ្រប់គ្រងតែមួយ ទៅលើប្រជុំកោះទាំងឡាយ ដោយរដ្ឋាភិបាល ឯករាជ្យថ្មីនៅទីក្រុងហ្សាកាតា សាធារណរដ្ឋឥណ្ឌូណេស៊ីបានប្រកាសបង្កើតឡើងនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៥០[432]។ អំណាចរដ្ឋឥឡូវគ្រប់ដណ្តប់ទាំងទឹកដី អាណានិគមហូឡង់កាលពីមុន ដោយលើកលែងតែតំបន់មួយចេញ។

បន្ទាប់ពីទទួលបានឯករាជ្យ ការដឹកនាំរដ្ឋឥណ្ឌូណេស៊ី គឺស្ថិតក្នុងកណ្តាប់ដៃគណរដ្ឋមន្ត្រី ដែលដឹកនាំដោយលោក ស៊ូកាណូ ជាប្រធានាធិបតី។ គេមានបំណងរៀបចំបោះឆ្នោតសភា ដែលនឹងពិចារណាការផ្លាស់ប្តូររដ្ឋធម្មនុញ្ញបណ្តោះអាសន្ន ដែលបានដាក់ឱ្យប្រើប្រាស់នៅពេលនោះ។ ប៉ុន្តែការបោះឆ្នោតពុំបានកើតឡើងទេ។ ផ្ទុយទៅវិញ អ្នកមានអំណាចខ្លាំងជាងគេនៅទីក្រុងហ្សាកាតា បានជ្រើសរើសជាមុននូវសមាជិកភាពរបស់គណៈអ្នកតំណាងរាស្ត្រ ដែលមានសមាជិក ២៣២រូប ដើម្បីដំណើរការជារដ្ឋសភាឥណ្ឌូណេស៊ីនៅពេលនោះ។

ប្រវត្តិសាស្ត្រក្នុងរយៈពេលដ៏ខ្លីក្រោយឯករាជ្យ បានបង្ហាញយ៉ាងច្បាស់ថា ការទទួលឯករាជ្យនៅមិនទាន់បានដោះស្រាយការបែកបាក់ជាច្រើននៅក្នុងសង្គមឥណ្ឌូណេស៊ីនៅឡើយទេ។ យ៉ាងហោចណាស់ក៏មាននាយករដ្ឋមន្ត្រី៥រូបដែរ ដែលបានឡើងកាន់អំណាចចុះឡើងក្នុងរយៈពេលយ៉ាងខ្លីនៅចន្លោះឆ្នាំ១៩៥០ ដល់ ១៩៥៥ ដោយសារតែហេតុការណ៍ផ្លាស់ប្តូររដ្ឋាភិបាលចម្រុះជាបន្តបន្ទាប់ ដើម្បីគិតគូរពីជម្លោះផលប្រយោជន៍រវាងអ្នកផ្លូវលោកនិយម និងអ្នកដែលតវ៉ាឱ្យមានការផ្តល់តួនាទីសំខាន់ជាងមុនដល់សាសនាអ៊ីស្លាម ដែលជាសាសនារបស់ប្រជាជនឥណ្ឌូណេស៊ីដ៏ច្រើនលើសលប់។ ស្របពេលជាមួយគ្នានោះដែរ ពួកកងទ័ពដែលចាត់ទុកខ្លួនឯងថា ជាអ្នកថែរក្សាជ័យជម្នះបដិវត្ត បានប្រឹងប្រែងដើម្បីធានាឱ្យបានថា គេទទួលស្គាល់ប្រយោជន៍របស់ខ្លួន។ ពួកកុម្មុយនីស្តក្នុងគណបក្សកុម្មុយនីស្តឥណ្ឌូណេស៊ី បានតស៊ូប្រកបដោយជោគជ័យខ្លះ ដើម្បីស្តារកេរ្តិ៍ឈ្មោះមិនល្អរបស់គណបក្ស ដែលបណ្តាលមកពីព្រឹត្តិការណ៍នៅម៉ាឌីយុន។ ការខំប្រឹងប្រែងទាំងអស់នេះបានកើតឡើង ចំពេលដែលមានវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ ការបន្តចង់មាននិន្នាការចង់បំបែកខ្លួននៅតាមតំបន់ដែលនៅឆ្ងាយៗ ពីកោះជ្វា ហើយនិងការប្តេជ្ញាចិត្តរកវិធីយកកោះញូហ្គីណេ (អ៊ីរៀនជយា) ដែល ហូឡង់កំពុងកាន់កាប់មកវិញ។

នៅពេលចុងក្រោយបង្អស់គេបានរៀបចំការបោះឆ្នោតឡើងនៅឆ្នាំ១៩៥៥ ដែលមានគណបក្សមិនតិចជាង២៨ទេ ដែលបានឈរឈ្មោះជាបេក្ខជន។ នៅពេលគេបង្ហាញលទ្ធផល គ្មានគណបក្សណាមួយអាចទទួលបានសំឡេងភាគច្រើនទេ។ បរិមាណច្រើនជាងគេបង្អស់នៃសំឡេងឆ្នោតចំនួន២២% បានទៅគណបក្សអ្នកជាតិនិយមឥណ្ឌូណេស៊ី។ លទ្ធផលនេះតាមប្រកិតដោយគណបក្សអ៊ីស្លាមសំខាន់ៗ ចំនួនពីរទៀត គឺ គណបក្សម៉ាស៊ូមី (Masyumi) បានសំឡេង២១% ហើយនិងគណបក្ស ណះដាទុលអ៊ូឡាម៉ា (Nahdatul Ulama) បានសំឡេង១៨%។ ជាសញ្ញាបង្ហាញថា នៅមានការបន្តចាប់អារម្មណ៍ ចំពោះ គណបក្សកុម្មុយនីស្តឥណ្ឌូណេស៊ី ក្នុងចំណោមអ្នកក្រីក្រនៅទីក្រុង និងជនបទ គណបក្សនោះបានទទួលសំឡេង១៦% នៃសំឡេងឆ្នោតទាំងអស់។ លទ្ធផលនេះជាកត្តានាំឱ្យមានអស្ថិរភាព ហើយរឿងនោះជាអ្វី ដែលគេគិតថា នឹងកើតឡើង។ លទ្ធផលនៃការបោះឆ្នោតនោះមិនត្រឹមតែបង្ហាញភាពទន់ខ្សោយរបស់ប្រព័ន្ធគណបក្សប៉ុណ្ណោះទេ តែថែមទាំង

[432] មិល្តុន អូស្បិន, *ផ្តើមឈ្វេងយល់ពីប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍*, ដ.ឯ.ម., ទំព័រ២២២។

គួសបញ្ជាក់ម្តងទៀតនូវការប្រេះឆា ដែលមានរវាងអ្នកនយោបាយ ដែលមានទំនាក់ទំនងទៅនឹងកោះជ្វាជាមួយនឹងអ្នកដែលមានមូលដ្ឋានអំណាចនៅកោះដទៃទៀត [433]។

លោកស៊ូកាណូ បានបង្ហាញយ៉ាងច្បាស់ពីការមិនទុកចិត្តរបស់លោក ចំពោះរដ្ឋាភិបាលអាស្រ័យ សភា។ នៅឆ្នាំ១៩៥៦ ខណៈដែលការប្រកួតប្រជែងគណបក្សនៅបន្តមាននៅថ្នាក់រដ្ឋសភា លោកស៊ូកាណូ បានថ្លែងបង្ហាញជំនឿរបស់លោកថា អ្វីដែលប្រទេសឥណ្ឌូណេស៊ី ត្រូវការគឺមិនមែនជា "លទ្ធិប្រជាធិបតេយ្យ សេរី" តាមបែបប្រទេសលោកខាងលិចទេ តែផ្ទុយទៅវិញគឺ "លទ្ធិប្រជាធិបតេយ្យដែលមានមគ្គុទេសក៍ និងថ្នាក់ដឹកនាំ" ។ ការមិនចុះសំរុងគ្នាខាងនយោបាយដែលចេះតែបន្តមាននៅហ្សាកាតា និងការផ្ទុះឡើង នូវការបះបោរផ្តាច់ខ្លួននៅកោះស៊ូម៉ាត្រា គឺជាការបង្ខំឱ្យអនុវត្តតាមគំនិតរបស់លោកស៊ូកាណូ។ ដោយប្រឈមមុខបញ្ហាលំបាក ទាំងនេះ និងដោយមានការគាំទ្រពីកងទ័ព ដែលដឹកនាំដោយឧត្តមសេនីយ៍ ណាស៊ូទីយ៉ុន លោកស៊ូកាណូ បានប្រកាសច្បាប់អាជ្ញាសឹកនៅខែមីនា ឆ្នាំ១៩៥៧។

ជោគជ័យរបស់កងទ័ពនៅឥណ្ឌូណេស៊ីក្នុង ការបង្ក្រាប់ការបះបោរបំបែកខ្លួន បានផ្តល់ឱកាសឱ្យ លោកស៊ូកាណូ រុលទៅមុខនូវគម្រោងលទ្ធិប្រជាធិបតេយ្យ ដែលមានការដឹកនាំរបស់លោក។ លោកស៊ូកាណូ បានអំពាវនាវដល់សភាធម្មនុញ្ញ ដែលនៅមាននៅឡើយ ឱ្យបោះឆ្នោតគាំទ្ររដ្ឋធម្មនុញ្ញថ្មី ជារដ្ឋធម្មនុញ្ញឆ្នាំ១៩៤៥ ដែលបានប្រគល់អំណាចឱ្យប្រធានាធិបតី ច្រើនជាងរដ្ឋធម្មនុញ្ញបណ្តោះអាសន្ន ដែលបានដាក់ឱ្យប្រើនៅឆ្នាំ១៩៥០។ នៅពេលដែលរដ្ឋសភាមិនបានបោះឆ្នោតគាំទ្ររដ្ឋធម្មនុញ្ញថ្មីឱ្យបានសំឡេងភាគច្រើនពីរភាគបី ទៅតាមសេចក្តីត្រូវការទេនោះលោក ស៊ូកាណូ នៅតែមានជំហររឹងមាំគ្រប់គ្រាន់នៅឡើយ ក្នុងការប្រកាសដាក់រដ្ឋធម្មនុញ្ញថ្មីដែលជារដ្ឋធម្មនុញ្ញឆ្នាំ១៩៤៥ឱ្យចូលជាធរមាន។ រយៈពេលនៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ ដែលមានថ្នាក់ដឹកនាំបានចាប់ផ្តើមឡើង ហើយរបត់សំខាន់ដំបូងពីដំណោះស្រាយក្រោយសម័យអាណានិគមក៏បានកើតឡើង។

ដំបូងលោកស៊ូកាណូ ហាក់ដូចជាជម្នះបានរាល់ការលំបាក់។ ក្នុងនាមជាឥស្សរជន ដែលមានឫទ្ធិអំណាច និងជាវាគ្មិនដ៏ប៉ិនប្រសប់ក្នុងការនិយាយដ៏គួរឱ្យចាប់អារម្មណ៍ក្រៃលែង កិត្យានុភាពបុគ្គលរបស់លោកបានជួយជ្រោមជ្រែងឡើង ដោយសន្និសីទអាស៊ី-អាហ្វ្រិក ធ្វើឡើងនៅក្រុងបាណ្តុង នៅឆ្នាំ១៩៥៥ ធ្វើឱ្យរូបលោកក្លាយជាឥស្សរជន ដែលគេស្គាល់ច្រើននៅលើឆាកអន្តរជាតិ។ បន្ទាប់មកនៅឆ្នាំ ១៩៦២ លោក ស៊ូកាណូ ទទួលបានកិត្តិយស ដោយសារការសម្រេចចិត្តរបស់លោក ដែលគាំទ្រដោយ អង្គការសហប្រជាជាតិក្នុងការប្រគល់ការគ្រប់គ្រងតំបន់ញូហ្គីណេ មកឥណ្ឌូណេស៊ី។ សម្រាប់ពេលនោះ ហាក់ដូចជាគេសម្រេចបានដំណោះស្រាយថ្មីមួយ ដែលជាដំណោះស្រាយធ្វើឱ្យលោកស៊ូកាណូ ទទួលបានជោគជ័យទាំងកិច្ចការក្នុងស្រុក និងកិច្ចការអន្តរជាតិ។

ការគាំទ្ររបស់កងទ័ព គឺសំខាន់ចំពោះអាយុជីវិត ជាមេដឹកនាំរបស់ប្រទេសឥណ្ឌូណេស៊ី របស់លោកស៊ូកាណូ។ ប៉ុន្តែសូម្បីតែនៅមុនយុទ្ធនាការប្រកបដោយជោគជ័យក្នុងការទទួលបានការគ្រប់គ្រង ញូហ្គីណេ ដែលជាព្រឹត្តិការណ៍មួយពាក់ព័ន្ធកងកម្លាំងប្រដាប់អាវុធយ៉ាងខ្លាំង លោកស៊ូកាណូ បានចាប់ប្រតិបត្តិការគោលការណ៍នយោបាយក្នុងស្រុក ដែលដាក់ឱ្យលោកស្ថិតនៅក្នុងស្ថានភាពមិនចុះសំរុងនឹងពួកយោធារួច ជាស្រេចទៅហើយ។ ស្ថិតនៅលើឆាកអន្តរជាតិ ហើយប្រឆាំងនឹងនិន្នាការរបស់ឥស្សរជនមានអំណាចបំផុតជាច្រើនរូបនៅក្នុងជួរកងទ័ព លោកស៊ូកាណូ បានប្តេជ្ញាចិត្តថា ប្រឆាំងនឹងការបង្កើត រដ្ឋសហព័ន្ធម៉ាឡេស៊ីថ្មី ដែលជាការ

---

[433] មិល្តុន អូស្បិន, *ផ្តើមឈ្វេងយល់ពីប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍*, ដ.ឯ.ម., ទំព័រ២២៣។

បញ្ចូលគ្នានូវមេឡាយ៉ាជាមួយនឹងសិង្ហបុរី និងដែនដី ដែលគ្រប់គ្រងដោយចក្រភពអង់គ្លេសនៅ បិរណេអូ។ នយោបាយ "ប្រឈមមុខ" នេះ មិនមានន័យអ្វីចំពោះមនុស្សជា ច្រើននៅក្នុងស្រទាប់វរជនស៊ីវិលនោះទេហើយ ក៏មិនមានន័យអ្វីចំពោះការបង្កជាការប្រឆាំងយោធាដែរ។ តែស្របពេលជាមួយគ្នានោះដែរ លោកស៊ូកាណូ បាន បង្ហាញឱ្យឃើញថា ខ្លួនលោកកាន់តែត្រៀមស្វែងរកការគាំទ្រពីពួកនយោបាយឆ្វេងនិយមឥណ្ឌូណេស៊ី ដោយ រួមទាំងគណបក្សកុម្មុយនីស្តឥណ្ឌូណេស៊ីក្នុងស្រុក។ រឿងនេះជាកំហុសឆ្គងដ៏ធ្ងន់ធ្ងរ ដែលអាចមើលឃើញច្បាស់ នៅឆ្នាំ១៩៦៥។ បន្ទាប់ពីការប៉ុនប៉ងធ្វើរដ្ឋប្រហារមួយ នៅខែកញ្ញា ឆ្នាំ១៩៦៥ ដែល គូបដិបក្សរបស់លោក ស៊ូកាណូ មានជាប់ទាក់ទងនឹងពួកកុម្មុយនីស្ត ពួកកងទ័ពដែលមានលោកឧត្តមសេនីយ៍ ស៊ូហាតូ ជាប្រមុខនៅ ពេលនោះ បានធ្វើសកម្មភាពយ៉ាងឆាប់រហ័សឆ្ពោះទៅរកការគ្រប់គ្រងរដ្ឋឥណ្ឌូណេស៊ី ដោយបានធ្វើឱ្យលោក ស៊ូកាណូ គ្រាន់តែ ជាប្រធានាធិបតីកិត្តិយសប៉ុណ្ណោះ។ នៅខែមិថុនា ឆ្នាំ១៩៦៦ លោកស៊ូហាតូ បានទាមទារ បានអំណាច គ្រប់គ្រងរដ្ឋពេញបរិបូណ៌។ បន្ទាប់ពីឡើងកាន់អំណាចជាប្រធានាធិបតី បណ្តោះអាសន្នពី១ឆ្នាំ មុន នៅឆ្នាំ១៩៦៨ លោកស៊ូហាតូ បានក្លាយជាប្រធានាធិបតីប្រទេសឥណ្ឌូណេស៊ី។ អ្វីដែលគេហៅថា **របៀប របបថ្មី** ក៏បានចាប់ផ្តើមអនុវត្ត ហើយលោកស៊ូហាតូ បានរក្សាការគ្រប់គ្រងប្រទេស ឥណ្ឌូណេស៊ី របស់លោក អស់រយៈពេលពីទេសវត្សរ៍ ។

នៅក្រោយពេលភ្លាមៗ ក្រោយបរាជ័យរដ្ឋប្រហារខែកញ្ញា ឆ្នាំ១៩៦៥ និងមុនពេលលោក ស៊ូហាតូ ឡើង កាន់តំណែងជាផ្លូវការ ប្រទេសឥណ្ឌូណេស៊ីត្រូវញាំញីដោយអំពើហិង្សាដ៏ឃោរឃៅ។ នៅខណៈដែលពួក កង ទ័ពបានរឹតបន្តឹងការកាន់កាប់អំណាចរបស់ខ្លួន ពួកអ្នកប្រឆាំងពួកកុម្មុយនីស្តរាប់ម៉ឺននាក់នៅក្នុងស្រទាប់ប្រជា ជន បានក្តាប់ឱកាសដើម្បីធ្វើការប្រឆាំងនឹងពួកសត្រូវនយោបាយរបស់ខ្លួន។ ដោយមានកងទ័ពជាអ្នកឈរ មើល ឬនៅករណីខ្លះជាអ្នកលើកទឹកចិត្ត ឬចូលរួមផង អំពើហិង្សាបានចាប់ផ្តើមឡើងនៅចុងឆ្នាំ១៩៦៥ ហើយ បន្តចូលដល់ឆ្នាំក្រោយទៀត។ ក្រុមអ្នកប្រឆាំងពួកកុម្មុយនីស្ត បានចាប់ផ្តើមសម្លាប់មនុស្សយ៉ាងវង្វាលជារឿយៗ ដោយប្រើមធ្យោបាយដ៏ឃោរឃៅបំផុត ដើម្បីសម្រេចបំណងរបស់ខ្លួន។ មិនមានតួលេខច្បាស់លាស់ណាមួយ អំពីចំនួនពួកកុម្មុយនីស្ត និងពួកអ្នកគាំទ្រកុម្មុយនីស្ត ដែលគេសម្លាប់នៅគ្រានោះទេ។ រឿងនេះហាក់ដូចជា ច្បាស់ប្រាកដថា យ៉ាងហោចណាស់ក៏ករណីមួយចំនួននៃការសម្លាប់ ដែលបានកើតឡើងពាក់ព័ន្ធនឹងហេតុ ផលបុគ្គលច្រើនដូចគ្នា និងហេតុផលនយោបាយដែរ។ ប៉ុន្តែអ្នកអង្កេតការណ៍បរទេសភាគច្រើន ចាត់ទុកតួ លេខ ២៥០,០០០នាក់ ដែលគេបានសម្លាប់ក្នុងអំឡុងពេលភាពវឹកវរនយោបាយចន្លោះឆ្នាំ១៩៦៥ ដល់១៩៦៦ ជាការប៉ាន់ស្មានដ៏ទាបបំផុត។ ការប៉ាន់ស្មានខ្លះមានចំនួនលើសនេះយ៉ាងច្រើន។ ហេតុការណ៍នេះ គឺជាកេរ ដំណែលនយោបាយ ដែលគេមិនអាចបំភ្លេចបាននៅក្នុងរយៈពេលយ៉ាងយូរនៃការអនុវត្ត **របៀបរបបថ្មី។**

ខណៈពេលប្រទេសឥណ្ឌូណេស៊ី កំពុងព្យាបាលរបួស បន្ទាប់ពីការដួលរលំរបបស៊ូកាណូ និងរយៈពេល បង្ហូរឈាមក្រោយមកទៀត មានមនុស្សតិចតួចណាស់ ដែលអាចទស្សន៍ទាយថា មិនយូរទេឥណ្ឌូណេស៊ី នឹង ចាប់ផ្តើមដំណើរផ្សងព្រេងអាណានិគមរបស់ខ្លួន។ ផ្ទុយពីការអះអាង ដែលរដ្ឋាភិបាលឯករាជ្យឥណ្ឌូណេស៊ីថា នឹងត្រួតត្រាទាំងអស់នូវទឹកដីទាំងឡាយដែលធ្លាប់គ្រប់គ្រងដោយម្ចាស់អាណានិគមហូឡង់ កាលមុនរដ្ឋាភិបាល នេះមិនបានធ្វើការអះអាងបែបនេះ ចំពោះទឹកដីព័រទុយហ្គាល់ នៅកោះទីម័រខាងកើត ដែលជាផ្នែកមួយ ដែល គេមិនសូវចាប់អារម្មណ៍របស់ចក្រភពក្រៅប្រទេសដ៏ទ្រុឌទ្រោមរបស់ព័រទុយហ្គាល់នោះទេ។ ប៉ុន្តែ នៅពេលដែល រដ្ឋបាលព័រទុយហ្គាល់បោះបង់ទឹកដីនេះចោល នៅក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ ឥណ្ឌូណេស៊ីបានចាត់ ទុកទីម័រខាងកើត ថាជាការគំរាមកំហែងដ៏មានសក្តានុពលដល់សន្តិសុខ របស់ឥណ្ឌូណេស៊ីដោយសារតែមាន

ដំហរនយោបាយឆ្វេងនិយមរបស់ក្រុមខ្លះ ដែលកំពុងប្រជែងដណ្ដើមអំណាចនៅលើទឹកដីនេះ។ ប្រការនេះ បាននាំឱ្យមានការឈ្លានពាន របស់ឥណ្ឌូណេស៊ីចូលកោះទីម័រខាងកើត នៅឆ្នាំ១៩៧៥ និងការបញ្ចូលទឹកដីនេះទៅក្នុងប្រទេសឥណ្ឌូណេស៊ី នៅឆ្នាំ១៩៧៦។

### ២.៣.២-ស្ថានភាពសេដ្ឋកិច្ច

#### ក-កសិកម្ម

នៅក្រោយព្រឹត្តិការណ៍ឆ្នាំ១៩៦៥ រដ្ឋាភិបាលលោកស៊ូហាតូ បានលើកផែនការ៥ឆ្នាំ(១៩៦៩-១៩៧៤) ដើម្បីធ្វើបដិវត្តន៍បៃតង។ ផែនការនេះត្រូវគាំទ្រដោយធនាគារពិភពលោក រួមជាមួយនឹងជំនួយរបស់ប្រទេសមហាអំណាចឧស្សាហកម្មធំៗដូចជា សហរដ្ឋអាម៉េរិក និងជប៉ុនជាដើម។ ផែនការនេះ រដ្ឋាភិបាលបានជំរុញកំណើនទិន្នផលស្រូវ និងពោតដោយពង្រីកផ្ទៃដីដាំដុះបន្ថែមកើនដល់៨លានហិចតាទូទាំងប្រទេស។ ជំហានដំបូងរដ្ឋាភិបាលជួយប្រជាកសិករ តាមរយៈមន្ត្រីជំនាញផ្នែកកសិកម្ម ពីរបៀប ជ្រើសរើសពូជ ការថែទាំ ការប្រើប្រាស់ជីការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងដោយប្រើប្រព័ន្ធធារាសាស្ត្រ។ ជាលទ្ធផលដោយមានអន្តរាគមន៍របស់រដ្ឋ ទិន្នផលស្រូវបានកើនឡើងពី៣តោន ទៅ៥តោនក្នុងមួយហិចតា។ ឥណ្ឌូណេស៊ី ឈរចំណាត់ថ្នាក់ទី២ ក្នុងចំណោមប្រទេសសម្បូរព្រៃឈើច្រើន បន្ទាប់ពី ប្រទេសប្រេស៊ីល ប៉ុន្តែការបំផ្លាញព្រៃឈើមានល្បឿនលឿនធ្វើឱ្យព្រៃឈើទទួលរងវិនាសយ៉ាងខ្លាំងនៅ ទសវត្សរ៍ឆ្នាំ១៩៦០ និង១៩៨០ គឺបាត់បង់ពី២០ ទៅ៣០ លានហិចតា។ នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ប្រទេសឥណ្ឌូណេស៊ី ឈរលំដាប់ទី១ក្នុងការនាំឈើមូលចេញ។ នៅឆ្នាំ១៩៧៤ រោងចក្រក្ដារបន្ទះមួយ ត្រូវបានបង្កើតជាមួយនឹងការនាំចេញនូវក្ដារបន្ទះ ១៣ពាន់ម៉ែត្រគូប ក្នុងមួយឆ្នាំ ស្មើនឹង២% នៃចំនួន ក្ដារបន្ទះនាំចេញក្នុងពិភពលោក។ នៅឆ្នាំ១៩៩០ ប្រទេសឥណ្ឌូណេស៊ី បានបង្កើតរោងចក្រក្ដារបន្ទះបានជាង១០០កន្លែងដែលនាំចេញក្ដារបន្ទះចំនួន៨៤៣ពាន់ម៉ែត្រគូប ស្មើនឹង៥២%នៃចំនួនក្ដារបន្ទះនាំចេញនៅលើ ពិភពលោក។ ក្រៅពីនាំចេញឈើ គឺមាននាំចេញ តែ កាហ្វេ កាកាវ...។ កៅស៊ូជាដំណាំឧស្សាហកម្ម ដែលឈរលំដាប់ថ្នាក់ទី១ក្នុងការនាំចេញ ដោយសារកំណើនប្រជាជនខ្ពស់ មានដង់ស៊ីតេ៨០០នាក់/គ.ម² ប្រជាជនឥណ្ឌូណេស៊ី នៅតែមានភាពក្រីក្រ ពិសេសនៅលើកោះជ្វា។

#### ខ-ឧស្សាហកម្ម

ប្រទេសឥណ្ឌូណេស៊ី ជាប្រទេសទី១ នៅអាស៊ីអាគ្នេយ៍ ដែលសម្បូរធនធានក្រោមដី ដូចជា នីកែល សំណប៉ាហាំង ស្ពាន់ ត្បូងថ្ម និងអ៊ុយរ៉ាញ៉ូម។ នៅបាតសមុទ្រសម្បូរទៅដោយប្រេងកាត និងឧស្ម័នធម្មជាតិ។ ការនាំចេញប្រេង និងឧស្ម័នធម្មជាតិ បានជំរុញកំណើនសេដ្ឋកិច្ច របស់ប្រទេសអស់រយៈពេល ២ទសវត្សរ៍ ក្នុងអត្រា៦% ក្នុងមួយឆ្នាំ គិតមកដល់វិបត្តិសេដ្ឋកិច្ចទ្វីបអាស៊ីឆ្នាំ១៩៩៧[434]។

**សំណួរត្រិះរិះ**

១-តើក្រោយសង្គ្រាមលោកលើកទី២ បណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ធ្លាក់ក្នុងភាពវឹកវរដូចម្ដេចខ្លះ?
២-ហេតុអ្វីបានជាបារាំងព្រមប្រគល់ឯករាជ្យពេញលេញដល់ប្រទេសវៀតណាម?
៣-ចូរពន្យល់ពីមូលហេតុ និងផលវិបាកនៃសង្គ្រាមឥណ្ឌូចិនលើកទី២?
៤-ហេតុអ្វីខ្លះបានជាហូឡង់ព្រមប្រគល់ឯករាជ្យដល់ប្រទេសឥណ្ឌូណេស៊ី?
៥-តើសេដ្ឋកិច្ចឥណ្ឌូណេស៊ីពឹងផ្អែកលើវិស័យអ្វីខ្លះ? ចូររៀបរាប់។

[434] ក្រសួងអប់រំ យុវជន និងកីឡា, *ប្រវត្តិវិទ្យាថ្នាក់ទី១១*, គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, ឆ្នាំ២០១០, ទំព័រ១៦៧។

# មេរៀនទី៤ មជ្ឈិមបូព៌ាសម័យសង្គ្រាមត្រជាក់

## ១-បញ្ហាចម្រូះជាតិសាសន៍ និងសាសនា

### ១.១-ស្ថានភាពទូទៅ

តំបន់មជ្ឈិមបូព៌ា លាតសន្ធឹងចាប់ពីសមុទ្រមេឌីទែរ៉ានេ (Mediterranear Sea) ខាងកើតរហូតដល់ឈូងសមុទ្រពែក្ស (Persian Gulf)។ វាលខ្សាច់ធំៗ បានគ្របដណ្ដប់លើមជ្ឈិមបូព៌ាទាំងមូល លើកលែង តែតំបន់ដែលស្ថិតតាមជ្រលងទន្លេ ប្រកបដោយដីមានជីជាតិ និងទឹកសម្រាប់ប្រជាពលរដ្ឋប្រកបអាជីវកម្ម ផ្សេងៗតែប៉ុណ្ណោះ។

តំបន់មជ្ឈិមបូព៌ាមានអាកាសធាតុក្ដៅពេញផ្ទៃដីទាំងអស់ លើកលែងតែតំបន់ក្បែរមាត់សមុទ្រខ្មៅ (Black Sea) សមុទ្រកាសព្យែន(Caspian Sea) ប៉ែកខាងជើង តាមជម្រាលភ្នំយេម៉ែនប៉ែកខាងត្បូង និងតាមទំនាបដែលលាតសន្ធឹងតាមដងទន្លេទីគ្រ(Tigre) ទន្លេអឺប្រាត(Euphrate) និងទន្លេនីល(Nile)។

ទឹកជាធនធានដ៏សំខាន់ និងជាអាយុជីវិតនៃប្រជាជនមជ្ឈិមបូព៌ា។ ពួកគេត្រូវមានវិន័យខាងសង្គមមួយយ៉ាងតឹងរ៉ឹងក្នុងការចែកចាយ និងប្រើប្រាស់ទឹក ដើម្បីជាប្រយោជន៍ដល់កសិកម្ម។

### ១.២-ប្រទេស និងប្រជាជន

មជ្ឈិមបូព៌ាជាតំបន់មួយដែលមានកំណើនប្រជាជនខ្ពស់។ ចំនួនប្រជាជនកើនយ៉ាងឆាប់រហ័សពី ៦៣ ២០០ ០០០ នាក់ ក្នុងឆ្នាំ១៩៣៧ ដល់ ៧៥ ៥០០ ០០០នាក់ ក្នុងឆ្នាំ១៩៦០។ គិតត្រឹមឆ្នាំ២០២២ ចំនួនប្រជាជនកើនឡើងដល់ជាង៤៧៦លាននាក់។ តំបន់មជ្ឈិមបូព៌ាមានដីទាំងអស់៧ ២០៧ ៥៧៥ គីឡូម៉ែត្រការេចែកជា១៦ប្រទេសរួមមាន អេហ្ស៊ីប អារ៉ាប៊ីសាអូឌីត អារ៉ាប់រួម អ៊ីរ៉ាក់ អ៊ីរ៉ង់ តួកគី អស្រាអែល ហ្សកដានី ស៊ីរី លីបង់ អូម៉ង់ យេមែន គុយវ៉ែត កាតា បារ៉ែន និងកោះស៊ីប រួមទាំងដែនដីប៉ាឡេស្ទីន។

មជ្ឈិមបូព៌ាជាតំបន់មួយដែលអរិយធម៌ចំណាស់ជាងគេលើពិភពលោក។ អរិយធម៌នៅតំបន់នេះ បានចាប់កំណើតតាំងពី៣ ៥០០ ឆ្នាំមុនគ.ស. និងបានបន្សល់ដល់សម័យបច្ចុប្បន្ន។ សក្ខីកម្មនៃអរិយធម៌ដ៏ត្រចះត្រចង់ទាំងនោះមានដូចជា ពីរ៉ាមីត និងទីក្រុងជាច្រើនដែលលេចត្រដែតកណ្ដាលវាលខ្សាច់។

នៅពាក់កណ្ដាលសតវត្សរ៍ទី៧ ពួកអារ៉ាប់បានធ្វើសញ្ជ័យលើប្រទេសនានា ជាហេតុធ្វើឱ្យភូមិភាគនេះទទួលរងនូវឥទ្ធិពលសាសនាអ៊ិស្លាមទាំងខាងសម្ភារៈ សិល្បៈ និងផ្នត់គំនិត។ តំបន់នេះទទួលបានឯកភាពមួយរយៈពេលខ្លីក្រោមការត្រួតត្រារបស់ពួកអារ៉ាប់។ ក្រោយមកទៀត ពួកតួកគីក៏បានចូលមកដល់ តំបន់ នេះដែរ។

ចាប់ពីសតវត្សរ៍ទី១៥ ចក្រភពអូតូម៉ង់ (ចក្រភពតួក) របស់ពួកតួកគី បានត្រួតត្រាលើភូមិភាគនេះអស់រយៈពេល៥សតវត្សរ៍ រហូតដល់ការបញ្ចប់នៃសង្គ្រាមលោកលើកទី១ នៅឆ្នាំ១៩១៨។ ការត្រួតត្រារបស់ចក្រភពនេះបានបន្សល់ទុកនូវភាពដូចគ្នានៅទូទាំងតំបន់មជ្ឈិមបូព៌ា ដូចជាលក្ខន្តិកៈដីធ្លី ឋានានុក្រមខាងសង្គម នយោបាយ និងមុខងារសាសនា។

## ២-មជ្ឈិមបូព៌ាក្រោយសង្គ្រាមលោកលើកទី១

ក្រោយសង្គ្រាមលោកលើកទី១ ព្រឹត្តិការណ៍ជាច្រើនបានកើតឡើង ជួនកាលឈានដល់ការបង្ហូរឈាមផងបានធ្វើឱ្យផែនទីនយោបាយ នៃភូមិភាគនេះប្រែប្រួលជាច្រើន ហើយរចនាសម្ពន្ធនយោបាយថ្មីមួយបានបែងចែកមជ្ឈិមបូព៌ាជាមណ្ឌលនៃដែនឥទ្ធិពលមហាអំណាចដូចតទៅៈ

- ប៉ែកខាងពាយ័ព្យ ជាតំបន់ស្ថិតក្រោមការត្រួតត្រារបស់បារាំង តាមអាណត្តិសង្គមប្រជាជាតិ មានរដ្ឋលីបង់ រដ្ឋស៊ីរី រដ្ឋាភិបាលអាឡាអូអ៊ីត (Alabouites) និងសឺបែលឌុស (Djebel Duze)។

– ប៉ែកខាងត្បូងនិងខាងលិចស្ថិតក្រោមអាណត្តិអង់គ្លេស : រដ្ឋប៉ាឡេស្ទីន រដ្ឋហ្សកដានី និងរដ្ឋអ៊ីរ៉ាក់។
– ក្នុងឧបទ្វីបអារ៉ាប់ រដ្ឋពីរចាប់កំណើតគឺ រដ្ឋអារ៉ាប៊ីសាអូឌីត និងរាជាណាចក្រយេម៉ែន។ ក្រៅពីនេះ មានប្រទេសដទៃទៀតបានទទួលលក្ខន្តិកៈជាផ្លូវការថាជារដ្ឋឯករាជ្យ ដូចជាប្រទេសតួកគី អ៊ីរ៉ង់ អាហ្វហ្គានីស្ថាន ជាដើម។ នៅក្នុងរយៈពេលចន្លោះសង្គ្រាមលោកទាំងពីរ ប្រទេសជាច្រើនបានរើបម្រះចេញពីឥទ្ធិពលអឺរ៉ុប។ តាមពិតប្រទេសទាំងនេះ ទោះបីមានឈ្មោះថាជារដ្ឋឯករាជ្យក៏ដោយ ក៏សុទ្ធសឹងស្ថិតនៅក្រោមអាណាព្យាបាលដោយប្រយោល របស់មហាអំណាចអឺរ៉ុបមួយណាដែរ។

## ៣-ការប្រជែងឥទ្ធិពលនៃមហាអំណាច

### ៣.១-មជ្ឈិមបូព៌ាក្រោយសង្គ្រាមលោកលើកទី២

ក្រោយសង្គ្រាមលោកលើកទី២ ប្រទេសជាច្រើននៅមជ្ឈិមបូព៌ារួចផុតពីនឹមអាណានិគមមហាអំណាចអឺរ៉ុប។ ក្រោយឯករាជ្យប្រទេសទាំងនោះត្រូវប្រឈមមុខនឹងគ្រោះថ្មីទៀត គឺឥទ្ធិពលនៃសង្គ្រាមត្រជាក់ ដែលបណ្តាលមកពីការប្រកួតប្រជែងរវាងមហាអំណាចពិភពលោកពីរ គឺសហរដ្ឋអាម៉េរិក និងសហភាពសូវៀត ដែលបញ្ចូលអាណានិគមនិយមសម័យថ្មីជំនួសអាណានិគមនិយមអឺរ៉ុបវិញ។

កត្តាសំខាន់បំផុតដែលធ្វើឱ្យមជ្ឈិមបូព៌ាទទួលការប្រែប្រួលយ៉ាងខ្លាំង គឺធនធានធម្មជាតិក្រោមដី ដែលប្រទេសទាំងនោះមានយ៉ាងច្រើន ជាពិសេសធនធានប្រេងកាត។ ដោយសារសម្បូរប្រេងកាត តំបន់មជ្ឈិមបូព៌ាបានក្លាយទៅជាមណ្ឌលមួយដ៏សំខាន់នៃអន្តរាគមន៍របស់ពួកមហាអំណាចជំនាន់ថ្មី។ ការចម្រាញ់យកធនធានធម្មជាតិដោយមូលធនបរទេស បណ្តាលឱ្យមានការក្តៅក្រហាយយ៉ាងខ្លាំងពីសំណាក់អ្នកជាតិនិយម ព្រមទាំងពង្រឹងចិត្តគំនិតពួកទាំងនោះក្នុងការរើបម្រះចេញពីឥទ្ធិពលបរទេស ដោយពួកគេយល់យ៉ាងច្បាស់ថា ធនធានធម្មជាតិទាំងអស់នេះ គឺជាមូលដ្ឋានសំខាន់សម្រាប់ឧស្សាហូបនីយកម្ម របស់ប្រទេស ដែលជាមធ្យោបាយតែមួយគត់ក្នុងដំណោះស្រាយបញ្ហាទុក្ខវេទនារបស់ប្រជាពលរដ្ឋ។

### ៣.២-កំណើតរដ្ឋអ៊ីស្រាអែល

ក្រោយសង្គ្រាមលោកលើកទី២ មណ្ឌលជាតិជ្វីហ្វបង្កើតដោយចក្រភពអង់គ្លេសមានប្រជាជាតិជ្វីហ្វ ២៥% នៃប្រជាជនទាំងអស់ដែលមានចំនួន១ ៣៦០ ០០០នាក់។ ការពង្រីកទីក្រុង និងវិស័យឧស្សាហកម្ម ព្រមទាំងការពង្រីកដីកសិកម្មទំនេរល្អៗដែលចលនាស្យូនីសនិយម (Sionisme) បានប្រមូលទិញ បង្កើតឱ្យមានការក្តៅក្រហាយយ៉ាងខ្លាំងពីសំណាក់ជនជាតិអារ៉ាប់ ដែលមានស្ថានភាពសេដ្ឋកិច្ចដុនដាបជាងជនជាតិជ្វីហ្វ។ ចក្រភពអង់គ្លេសមិនព្រមទទួលស្គាល់ជាផ្លូវការនូវជនជាតិប៉ាឡេស្ទីនទេ តែផ្ទុយទៅវិញនៅឆ្នាំ១៩៤៤ អង់គ្លេសសុខចិត្តបណ្តោយឱ្យបង្កើតក្រុមជ្វីហ្វដែលមានពាក់ស្លាកសញ្ញា និងទង់ជាតិជ្វីហ្វ ទៀតផង។ នៅពេលនោះ ដើម្បីសន្តោសជនជាតិអារ៉ាប់នៅប៉ាឡេស្ទីន និងនៅប្រទេសជិតខាង អង់គ្លេសបានបន្ថយចំនួនចំណូលស្រុកនៃជនជាតិជ្វីហ្វ ដែលរដ្ឋាភិបាលអង់គ្លេសបានអនុម័តចាប់តាំងពីឆ្នាំ១៩៣៩ មក។

វិធានការនេះបណ្តាលឱ្យ មានការក្តៅក្រហាយយ៉ាងខ្លាំងពីសំណាក់ជនជាតិជ្វីហ្វដែលឃើញជនរួមជាតិរបស់ពួកគេរាប់លាននាក់ ត្រូវទទួលរងការកាប់សម្លាប់យ៉ាងឃោរឃៅពីសំណាក់ពួកណាស៊ីអ៊ីត្លែរ ក្នុងសង្គ្រាមលោកលើកទី២(១៩៣៩-១៩៤៥)។

នៅមុនឆ្នាំ១៩៤៨ នៅក្នុងតំបន់ដើមបូព៌ា មិនមានទេរដ្ឋអ៊ីស្រាអែល គឺមានតែទឹកដីប៉ាឡេស្ទីន។ ហេតុដូច្នេះហើយបានជាមនុស្សជាច្រើន ជាពិសេស អ្នកកាន់សាសនាអ៊ិស្លាមយល់ថា វត្តមានរបស់អ៊ីស្រាអែល នៅក្នុងតំបន់ដើមបូព៌ានេះ គឺជារឿងខុសច្បាប់ ដោយសារតែរដ្ឋអ៊ីស្រាអែលនេះត្រូវបានបង្កើតឡើងនៅលើទឹកដី

របស់ ប៉ាឡេស្ទីន។ ក៏ប៉ុន្តែដំណើររឿងវាមានលក្ខណៈស្មុគស្មាញជាងនេះ។ តាមពិត នៅក្នុងតំបន់ដើមបូព៌ា មុនឆ្នាំ១៩៤៨ ក៏គ្មានរដ្ឋប៉ាឡេស្ទីនដែរ គឺមានតែទឹកដីមួយ ដែលគេឱ្យឈ្មោះថា «ប៉ាឡេស្ទីន» ហើយដែលត្រូវបាន ប្រទេសមហាអំណាចដូរដៃគ្នាកាន់កាប់ពីមួយទៅមួយ អស់រយៈពេលរាប់ពាន់ឆ្នាំ។ ទឹកដី ដែលគេឱ្យឈ្មោះថា «ប៉ាឡេស្ទីន» នេះ ក៏មានបន្ទាត់ព្រំដែនមិនស្ថិតស្ថេរច្បាស់លាស់ដែរ ដោយពេលខ្លះត្រូវគេរាប់បញ្ចូលទាំងប្រទេសមួយចំនួន ដែលនៅជុំវិញនោះ ដូចជា លីបង់ ស៊ីរី និងហ្សកដានី ជាដើម អាស្រ័យទៅតាមសម័យកាល និងអាស្រ័យទៅតាមការចាត់ចែងរបស់ប្រទេសមហាអំណាច ដែលកាន់កាប់តំបន់នេះ។ កាលពីជាង៣ពាន់ឆ្នាំមុន តំបន់ដែលគេឱ្យឈ្មោះថា «ប៉ាឡេស្ទីន» នេះ មានប្រជាជនជាច្រើនអម្បូររស់នៅ ក្នុងនោះក៏មានដែរ ជនជាតិជ្វីហ្វ ដែលបានបង្កើតជារដ្ឋ និងបានសាងសង់បុរីជាទីសក្ការៈមួយ គឺទីក្រុងយេរូសាឡឹម។ ក៏ប៉ុន្តែ នៅក្នុងសម័យកាលចក្រភពរ៉ូម ទីក្រុងយេរូសាឡឹមត្រូវបានទាហានរ៉ូមវាយកម្ទេចចោល ហើយជនជាតិជ្វីហ្វ ដែលហ៊ានងើបឡើងបះបោរប្រឆាំងនឹងអាជ្ញាធររ៉ូម ត្រូវបានគេបណ្តេញចេញពីទឹកដីកំណើតឱ្យបែកខ្ញាត់ខ្ញាយ ទៅរស់នៅជាសហគមន៍ជនជាតិជ្វីហ្វនៅបរទេស។ ចាប់ពីពេលនោះមក ទឹកដីអ៊ីស្រាអែលក៏លែងស្គាល់ឯករាជ្យ ដោយត្រូវប្រទេសមហាអំណាចប្តូរដៃគ្នាគ្រប់គ្រងពីមួយទៅមួយ ដោយភាគច្រើន ស្ថិតក្រោមការ កាន់កាប់របស់មហាអំណាចកាន់សាសនាអ៊ិស្លាម រួមមានដូចជា ចក្រភពអារ៉ាប់ អេហ្ស៊ីប និងតួកគីក្នុងសម័យកាលចក្រភពអូតូម៉ង់។ នៅក្រោយសង្គ្រាមលោកលើកទី១ ចក្រភពអូតូម៉ង់ដែលចាញ់សង្គ្រាមត្រូវដួលរលំ។ តំបន់ដែលស្ថិតនៅចន្លោះសមុទ្រមេឌីទែរ៉ាណេ និងទន្លេយ័រដាន់ (Jordan) ពោលគឺ ទឹកដីប៉ាឡេស្ទីន និងរដ្ឋអ៊ីស្រាអែលបច្ចុប្បន្ន ក៏ត្រូវធ្លាក់ក្រោមការកាន់កាប់របស់ចក្រភពអង់គ្លេស។

នៅក្នុងអំឡុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០ ចលនាមួយបានរីកដុះដាលឡើង នៅក្នុងចំណោមសហគមន៍ជ្វីហ្វនៅអឺរ៉ុប ដែលមានគំនិតចង់ឱ្យជនជាតិជ្វីហ្វវិលត្រឡប់ទៅបង្កើតរដ្ឋនៅទឹកដីកំណត់របស់ខ្លួនវិញ។ ចលនានេះត្រូវបានគេឱ្យឈ្មោះថា «ស៊ីយ៉ូនិស្ត» (Sioniste)។ ស៊ីយ៉ូន គឺជាឈ្មោះដែលគេឃើញមានប្រើនៅក្នុងគម្ពីរប៊ីប ដោយសម្តៅទៅលើទីក្រុងយេរូសាឡឹម។ ចលនាអន្តោប្រវេសន៍របស់ជនជាតិជ្វីហ្វ ដែលចូលទៅតាំងទីលំនៅ នៅក្នុងទឹកដីប៉ាឡេស្ទីនក៏ចាប់ផ្តើមកើតមានឡើង ហើយនៅពេលដែលចំនួនជនជាតិជ្វីហ្វមានការកើនឡើង ភាពតានតឹងជាមួយជនជាតិអារ៉ាប់ប៉ាឡេស្ទីនក៏ចាប់ផ្តើមកើតមានឡើងដែរ ដែលបង្កជាបញ្ហាស្មុគស្មាញដល់ចក្រភពអង់គ្លេស ដែលជាអាណាព្យាបាល។ អង់គ្លេសធ្លាប់បានសន្យាជាមួយនឹងពួកអារ៉ាប់ប៉ាឡេស្ទីនថានឹងឱ្យ ពួកគេបង្កើតរដ្ឋឯករាជ្យ ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា អង់គ្លេសក៏បានសន្យាដល់ចលនាស៊ីយ៉ូនិស្តផងដែរថានឹងឱ្យពួកគេមាន ទឹកដីជាមាតុភូមិមួយនៅប៉ាឡេស្ទីន។

នៅក្រោយសង្គ្រាមលោកលើកទី២ ហេតុការណ៍នៃការសម្លាប់រង្គាលជនជាតិជ្វីហ្វដោយអាល្លឺម៉ង់ បានធ្វើឱ្យចលនាអន្តោប្រវេសន៍ជនជាតិជ្វីហ្វចូលទៅក្នុងទឹកដីប៉ាឡេស្ទីនបានកើតមានកាន់តែខ្លាំង ការបង្កើតរដ្ឋឱ្យពួកជ្វីហ្វនៅប៉ាឡេស្ទីនក៏ចាប់ផ្តើមទាក់ទាញនូវ ការគាំទ្រកាន់តែច្រើនពីសំណាក់បណ្តាប្រទេសនៅទូទាំងពិភពលោក ជាពិសេស បណ្តាប្រទេសនៅអឺរ៉ុបដែលគិតថាខ្លួនមានចំណែកទទួលខុសត្រូវ នៅក្នុងសោកនាដកម្មរបស់ពួកជ្វីហ្វ។

នៅឆ្នាំ១៩៤៧ ដោយមើលឃើញអំពីស្ថានភាពស្មុគស្មាញនៅប៉ាឡេស្ទីន អង់គ្លេសក៏បានប្រកាសបញ្ចប់អាណត្តិជាអ្នកគ្រប់គ្រងទឹកដី ប៉ាឡេស្ទីន ប៉ុន្តែ មិនព្រមកំណត់ឱ្យបានច្បាស់លាស់ថា តើទឹកដីប៉ាឡេស្ទីននឹងត្រូវចាត់ចែងបង្កើតជារដ្ឋយ៉ាងដូចម្តេចនោះទេ ដោយបានរុញសំណុំរឿងនេះទៅឱ្យអង្គការសហប្រជាជាតិជាអ្នកដោះស្រាយ។ អ.ស.បក៏បានសម្រេចបង្កើតគណៈកម្មាធិការពិសេសមួយ ដែលមានសមាជិកមកពី

ប្រទេសចំនួន១១ ឱ្យធ្វើការសិក្សាអំពីដំណោះស្រាយនៅប៉ាឡេស្ទីន។ នៅក្នុងគណៈកម្មាធិការនេះ មានប្រទេសខ្លះ រួមមាន អ៊ីរ៉ង់ ឥណ្ឌា និងយូហ្គោស្លាវី បានស្នើនូវគំនិតបង្កើតជារដ្ឋសហព័ន្ធប៉ាឡេស្ទីនមួយ ដោយមានរដ្ឋពីរជាសមាជិក គឺរដ្ឋមួយសម្រាប់ពួកអារ៉ាប់ និងរដ្ឋមួយទៀត សម្រាប់ពួកជ្វីហ្វ។ ក៏ប៉ុន្តែ ប្រទេសចំនួន៧ ផ្សេងទៀត (កាណាដា ឆេកូស្លូវ៉ាគី ហូឡង់ ស៊ុយអែត ក្វាតេម៉ាឡា ប៉េរូ អ៊ុយរូហ្គាយ) ស្នើឱ្យអារ៉ាប់ និងជ្វីហ្វ បង្កើតរដ្ឋពីរឯករាជ្យដាច់ពីគ្នាទាំងស្រុង។

នៅទីបំផុត គឺដំណោះស្រាយបង្កើតរដ្ឋឯករាជ្យពីរដាច់ពីគ្នា ដែលត្រូវបានមហាសន្និបាតអ.ស.បអនុម័ត នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៤៧ (សេចក្តីសម្រេចលេខ ១៨១)។ នៅក្នុងសេចក្តីសម្រេចនេះ មហាសន្និបាត អ.ស.បក៏បានកំណត់ផងដែរថា ទីក្រុងយេរូសាឡឹម ដែលជាចំណុចប្រទាញប្រទង់ខ្លាំងរវាងអារ៉ាប់ និងជ្វីហ្វ នឹងមិនត្រូវបញ្ចូលទៅក្នុងរដ្ឋណាមួយនោះទេ តែត្រូវដាក់ជាតំបន់ស្ថិតក្រោមការគ្រប់គ្រងអន្តរជាតិ។ សេចក្តីសម្រេចលេខ ១៨១ ត្រូវបានប្រទេសជាសមាជិកអ.ស.ប. អនុម័តដោយសំឡេងគាំទ្រលើសពី ២ភាគ៣ ក៏ប៉ុន្តែគ្រប់បណ្តាប្រទេសអារ៉ាប់ និងប្រទេសកាន់សាសនាអ៊ិស្លាមទាំងអស់បាននាំគ្នាបោះឆ្នោត ប្រឆាំង។ បណ្តាប្រទេសអារ៉ាប់បានប្រឆាំងដាច់ខាតនឹងការបង្កើតរដ្ឋអ៊ីស្រាអែល ដោយទាមទារឱ្យយកទឹកដីប៉ាឡេស្ទីនទាំងអស់បង្កើតជារដ្ឋតែមួយ សម្រាប់ពួកអារ៉ាប់។ អ៊ីស្រាអែលវិញបានទទួលស្វាគមន៍ចំពោះដំណោះស្រាយរបស់ អ.ស.ប. ហើយមេដឹកនាំពួកជ្វីហ្វនៅប៉ាឡេស្ទីនគឺលោក David Ben-Gourion ក៏បានប្រកាសបង្កើតរដ្ឋអ៊ីស្រាអែលជាផ្លូវការ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៤៨។ មួយថ្ងៃក្រោយការប្រកាសបង្កើតរដ្ឋអ៊ីស្រាអែល បណ្តាប្រទេសអារ៉ាប់ ដែលនៅជុំវិញនោះ គឺរួមមាន អេហ្ស៊ីប ស៊ីរី ហ្សកដានី លីបង់ និងអ៊ីរ៉ាក់ ក៏បាននាំគ្នាលើកទ័ពបើកការវាយប្រហារលើអ៊ីស្រាអែល។ សង្គ្រាមនេះត្រូវបានគេឱ្យឈ្មោះថា សង្គ្រាមអារ៉ាប់-អ៊ីស្រាអែលលើកទី១ ហើយមានរយៈពេលជាង ៩ខែ។ ជាលទ្ធផល គឺអ៊ីស្រាអែលជាអ្នកទទួលជោគជ័យ។ រដ្ឋអ៊ីស្រាអែលត្រូវបានបណ្តាប្រទេសជាច្រើនទទួលស្គាល់ជាផ្លូវការ។ ចំណែកឯរដ្ឋប៉ាឡេស្ទីនវិញនៅតែមិនអាចបង្កើតបាន រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ[435]។

## ៣.៣.សង្គ្រាមអ៊ីស្រាអែល ជាមួយប្រទេសអារ៉ាប់

សង្គ្រាមលើកទី១ ដែលអ៊ីស្រាអែលហៅថា «សង្គ្រាមឯករាជ្យ» បានកើតមានឡើងនៅឆ្នាំ១៩៤៨ មួយថ្ងៃក្រោយពីអ៊ីស្រាអែលប្រកាសបង្កើតរដ្ឋឯករាជ្យ ដោយនៅពេលនោះ កងទ័ពអារ៉ាប់មកពីប្រទេសអេហ្ស៊ីប ហ្សកដានី លីបង់ ស៊ីរី និងអ៊ីរ៉ាក់ ព្រមទាំងកងកម្លាំងប្រដាប់អាវុធរបស់ប៉ាឡេស្ទីន បានរួមដៃគ្នាបើកការវាយប្រហារទៅលើអ៊ីស្រាអែល។ នៅក្នុងសង្គ្រាមនេះ អ៊ីស្រាអែលថ្មីជ្បិតតែមានតែម្នាក់ឯង ក៏ប៉ុន្តែ មានកម្លាំងទ័ពខ្លាំងជាងប្រទេសអារ៉ាប់ ហើយក្រោយពីបានវាយប្រយុទ្ធគ្នាអស់រយៈពេលជាង ៩ខែ បណ្តាប្រទេសអារ៉ាប់ក៏សុខចិត្តចុះចាញ់ ហើយចុះកិច្ចព្រមព្រៀងបញ្ចប់សង្គ្រាម នៅឆ្នាំ១៩៤៩។ កិច្ចព្រមព្រៀងនេះបានកំណត់នូវព្រំដែនបណ្តោះអាសន្នមួយ ដែលក្រោយមកត្រូវបានអ.ស.បទទួលស្គាល់ជាព្រំដែនស្របច្បាប់របស់រដ្ឋ អ៊ីស្រាអែល។ ខ្សែបន្ទាត់ព្រំដែននេះ ដែលគេតែងតែហៅថា «បន្ទាត់បៃតង» (Green Line/Ligne verte) បានកាត់យកទឹកដីជាច្រើន ដែលកាលពីមុនត្រូវបានអ.ស.បបែងចែកទុកធ្វើជាទឹកដីរដ្ឋប៉ាឡេស្ទីន។

ជាលទ្ធផល បណ្តាប្រទេសអារ៉ាប់មិនត្រឹមតែមិនអាចកម្ចាត់អ៊ីស្រាអែលចេញពី តំបន់ដើមបូព៌ាដូចក្តីបំណងនោះទេ តែថែមទាំងត្រូវអ៊ីស្រាអែលវាយបំបាក់ឱ្យបរាជ័យ ហើយពង្រីកទឹកដីបានកាន់តែធំលើសពីអ្វី

[435] សេង ឌីណា, *ប្រវត្តិសាស្រ្តពិភពលោក*: វិទ្យុបារាំងអន្តរជាតិ ថ្ងៃ១ កុម្ភៈ ២០១៥។

ដែលបានកំណត់នៅក្នុង សេចក្តីសម្រេចរបស់អ.ស.ប កាលពីឆ្នាំ១៩៤៧ទៅទៀត។ សម្រាប់ប៉ាឡេស្ទីនវិញ រដ្ឋឯករាជ្យក៏មិនអាចបង្កើតឡើងបាន ដោយទឹកដីមួយផ្នែកត្រូវអ៊ីស្រាអែលកាត់យក ចំណែកឯទឹកដីដែលនៅសេសសល់ត្រូវស្ថិតក្រោមការកាន់កាប់របស់ប្រទេស អារ៉ាប់គ្នាឯង គឺតំបន់ហ្កាហ្សាស្ថិតក្រោមការកាន់កាប់របស់អេហ្ស៊ីប ចំណែកតំបន់ West Bank ឬ Cisjordanie ត្រូវស្ថិតក្រោមការកាន់កាប់របស់ហ្សកដានី។ ប្រជាជនប៉ាឡេស្ទីនជាង ៧០ម៉ឺននាក់ ដែលរត់ភៀសខ្លួនក្នុងអំឡុងសង្គ្រាម ក៏មិនអាចវិលត្រឡប់ទៅផ្ទះសម្បែងវិញបាន ដោយស្រុកភូមិរបស់ពួកគេត្រូវក្លាយជាទឹកដីអ៊ីស្រាអែល។ សិទ្ធិវិលត្រឡប់របស់ជនភៀសខ្លួនប៉ាឡេស្ទីននេះហើយដែលជាបញ្ហាចម្រូងចម្រាសដ៏ចម្បងមួយ នៅក្នុងការចរចាសន្តិភាព រវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។

នៅឆ្នាំ១៩៥៦ (៧ឆ្នាំក្រោយពីសង្គ្រាមទី១ត្រូវបញ្ចប់) សង្គ្រាម រវាងអ៊ីស្រាអែល និងប្រទេសអារ៉ាប់បានផ្ទុះឡើងសាជាថ្មីម្តងទៀត គឺសង្គ្រាមទល់នឹងអេហ្ស៊ីប ក៏ប៉ុន្តែ លើកនេះ គឺអ៊ីស្រាអែល ដែលបានចូលដៃជាមួយបារាំង និងអង់គ្លេស ចូលឈ្លានពានទឹកដីអេហ្ស៊ីប នៅក្នុងវិបត្តិព្រែកជីកស៊ុយអេ (Suez)។ នៅក្នុងសង្គ្រាមនេះ បើនិយាយខាងផ្នែកយោធា អ៊ីស្រាអែល អង់គ្លេស និងបារាំង គឺជាអ្នកទទួលជោគជ័យ ដោយអាចវាយដណ្តើមកាន់កាប់ទីតាំងសំខាន់ៗ របស់អេហ្ស៊ីប ជាពិសេស អ៊ីស្រាអែលបានវាយដណ្តើមកាន់កាប់តំបន់ស៊ីណៃ។ ក៏ប៉ុន្តែ ខាងផ្នែកនយោបាយ និងការទូតវិញ ប្រទេសទាំង ៣នេះត្រូវទទួលរងនូវការរិះគន់ពីគ្រប់ទិសទី។ សូម្បីតែសហរដ្ឋអាម៉េរិក ដែលជាសម្ពន្ធមិត្តក៏រិះគន់សកម្មភាពឈ្លានពានទៅលើអេហ្ស៊ីបនេះដែរ។ ចំណែកបណ្តាប្រទេសអារ៉ាប់ ដែលកំពុងតែមិនចូលចិត្តអ៊ីស្រាអែលស្រាប់ ក៏កាន់តែស្អប់អ៊ីស្រាអែលខ្លាំងឡើងថែមទៀត។

នៅខែឧសភា ឆ្នាំ១៩៦៧ នៅក្នុងពេលដែលទំនាក់ទំនង រវាងអ៊ីស្រាអែល និងប្រទេសអារ៉ាប់ជិតខាងកំពុងតែស្ថិតក្នុងសភាពតានតឹងយ៉ាងខ្លាំងស្រាប់ អេហ្ស៊ីបបានទទួលព័ត៌មានខុសពីទីភ្នាក់ងារចារកិច្ចសូវៀតថា អ៊ីស្រាអែលកំពុងប្រមូលកម្លាំងទ័ពយ៉ាងច្រើនសន្ធឹកសន្ធាប់ នៅក្បែរព្រំដែនស៊ីរី។ អេហ្ស៊ីប ដែលបានចុះសន្ធិសញ្ញាការពារជាតិជាមួយស៊ីរី ក៏បានប្រមូលកម្លាំងទ័ពឱ្យចូលមកក្បែរព្រំដែនអ៊ីស្រាអែល ព្រមទាំងបានបណ្តេញកងកម្លាំងមួកខៀវរបស់អ.ស.បឱ្យចេញពីតំបន់ស៊ីណៃ និងហ្កាហ្សា។

នៅថ្ងៃទី៥ ខែមិថុនា សង្គ្រាមក៏បានផ្ទុះឡើងរវាងម្ខាងអ៊ីស្រាអែល និងម្ខាងទៀត អេហ្ស៊ីប ស៊ីរី និងហ្សកដានី។ សង្គ្រាមអ៊ីស្រាអែល-អារ៉ាប់ លើកទី៣នេះមានរយៈពេលតែ ៦ថ្ងៃប៉ុណ្ណោះ។ ហេតុដូច្នេះហើយបានជាគេច្រើនហៅថា «សង្គ្រាម៦ថ្ងៃ»។ ជាថ្មីម្តងទៀត គឺអ៊ីស្រាអែលជាអ្នកទទួលជោគជ័យ ដោយបានវាយដណ្តើមកាន់កាប់ទឹកដីហ្កាហ្សា និង West Bank/Cisjordanie របស់ប៉ាឡេស្ទីន តំបន់ស៊ីណៃរបស់អេហ្ស៊ីប និងតំបន់ខ្ពង់រាប Golan របស់ស៊ីរី។ និយាយជារួម អ៊ីស្រាអែលបានពង្រីកទឹកដីរបស់ខ្លួនមួយជាបី។ ក៏ប៉ុន្តែទឹកដីដែលអ៊ីស្រាអែលទើបនឹងដណ្តើមកាន់កាប់ថ្មីនេះ មិនត្រូវបានទទួលស្គាល់ដោយ សហគមន៍អន្តរជាតិនោះទេ។

នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៧ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ បានចេញសេចក្តីសម្រេចមួយ (សេចក្តីសម្រេចលេខ២៤២) ទាមទារឱ្យអ៊ីស្រាអែលដកថយចេញពីដែនដី ដែលខ្លួនទើបនឹងដណ្តើមកាន់កាប់ ក្នុងសង្គ្រាម ៦ថ្ងៃ ដោយវិលត្រឡប់ទៅរកបន្ទាត់ព្រំដែនចាស់ (បន្ទាត់បៃតង) ដែលកំណត់ដោយកិច្ចព្រមព្រៀងកាលពីឆ្នាំ១៩៤៩។ ជាថ្នូរមកវិញ ប្រទេសអារ៉ាប់ដែលជាប់ជម្លោះត្រូវចុះសន្ធិសញ្ញាសន្តិភាពជាមួយនឹង អ៊ីស្រាអែល។ លើកលែងតែប្រទេសស៊ីរីមួយចេញ ប្រទេសជាប់ជម្លោះទាំងអស់ ដោយរួមទាំង

អ៊ីស្រាអែលផង សុទ្ធតែសុខចិត្តទទួលយកសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប.។ ក៏ប៉ុន្តែ ការបកស្រាយផ្សេងគ្នាបានធ្វើឱ្យការអនុវត្តសេចក្ដីសម្រេចនេះត្រូវ ជាប់គាំង ដោយប្រទេសអារ៉ាប់ទាមទារឱ្យអ៊ីស្រាអែលដកទ័ពចេញពីទឹកដីរបស់គេ ជាមុន ទើបសុខចិត្តបើកការចរចាលើសន្ធិសញ្ញាសន្តិភាព ចំណែកអ៊ីស្រាអែលវិញទាមទារឱ្យប្រទេសអារ៉ាប់ទទួលស្គាល់រដ្ឋ អ៊ីស្រាអែល និងចុះសន្ធិសញ្ញាសន្តិភាពជាមួយគ្នាជាមុន ទើបសុខចិត្តដកទ័ព។

នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៣ នៅក្នុងពេលដែលការចរចាត្រូវជាប់គាំង អេហ្ស៊ីប និងស៊ីរី ក៏បានបើកការវាយប្រហារទៅលើអ៊ីស្រាអែល ក្នុងគោលដៅដណ្ដើមតំបន់ស៊ីណៃ និងខ្ពង់រាប Golan ពីអ៊ីស្រាអែលមកវិញ។ សង្គ្រាមនេះត្រូវបានគេឱ្យឈ្មោះថា «សង្គ្រាមយ៉ុមគីពួរ» ( Yom Kippour ) ដោយសារតែវាកើតឡើង នៅចំថ្ងៃយ៉ុមគីពួរ ដែលជាថ្ងៃបុណ្យសាសនាដ៏ធំរបស់ពួកជ្វីហ្វ។ សង្គ្រាមយ៉ុមគីពួរនេះ ក៏បានបង្កឱ្យមានការប្រឈមមុខដាក់គ្នាយ៉ាងខ្លាំងដែរ រវាងសហរដ្ឋអាម៉េរិក ដែលគាំទ្រអ៊ីស្រាអែល និងសហភាពសូវៀត ដែលគាំទ្រអេហ្ស៊ីប។ ក្រោយពីមានការចរចាសម្រុះសម្រួលគ្នា សហរដ្ឋអាម៉េរិក និងសហភាពសូវៀត ក៏បានព្រមព្រៀងឱ្យក្រុមប្រឹក្សាសន្តិសុខអ.ស.ប. ចេញសេចក្ដីសម្រេចមួយបង្គាប់ឱ្យអ៊ីស្រាអែល អេហ្ស៊ីប និងស៊ីរី ចុះកិច្ចព្រមព្រៀងឈប់បាញ់ ដើម្បីបញ្ចប់សង្គ្រាម។ បទឈប់បាញ់ ដែលត្រូវភាគីជម្លោះទទួលយក នៅថ្ងៃទី២៥ ខែតុលា។

សង្គ្រាមយ៉ុមគីពួរ ត្រូវបានគេចាត់ទុកថាជាសង្គ្រាមទ្រង់ទ្រាយធំលើកចុងក្រោយ រវាងអ៊ីស្រាអែល និងប្រទេសអារ៉ាប់។ ក៏ប៉ុន្តែ ក្រោយៗ មកទៀត សង្គ្រាមក្នុងទ្រង់ទ្រាយតូចៗ ផ្សេងទៀតបានកើតមានឡើងជាញឹកញាប់ រវាងអ៊ីស្រាអែល និងលីបង់ ឬអ៊ីស្រាអែល និងក្រុមប្រដាប់អាវុធប៉ាឡេស្ទីន។ ការងើបឡើងបះបោររបស់ប្រជាជនប៉ាឡេស្ទីន ដែលគេហៅតាមភាសាអារ៉ាប់ថា "អ៊ីនទីហ្វាដា" ដើម្បីប្រឆាំងនឹងអ៊ីស្រាអែលក៏បានកើតឡើងចំនួនពីរលើកផងដែរ គឺលើកទី១ ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩៣ និងលើកទី២ នៅឆ្នាំ២០០០ ដោយអ៊ីនទីហ្វាដាមួយលើកៗ បានបណ្ដាលឱ្យមនុស្សរាប់ពាន់នាក់ត្រូវបាត់បង់ជីវិតភាគច្រើន គឺជនស៊ីវិលប៉ាឡេស្ទីន។

ជម្លោះ រវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន មិនមែនដូចកុនល្ខោន ដែលមានម្ខាងជាតួចិត្តល្អ ហើយម្ខាងទៀតជាតួចិត្តអាក្រក់នោះទេ ក៏ប៉ុន្តែ វាជាសោកនាដកម្មមួយ ដែលភាគីម្ខាងៗ សុទ្ធតែមានហេតុផលសមរម្យរៀងៗខ្លួន។ ម្ខាងៗ សុទ្ធតែជាជនរងគ្រោះផង និងជាអ្នកបង្ករឿងផង។ កាលពីដំបូង អ៊ីស្រាអែលទទួលយកនូវដំណោះស្រាយរបស់អ.ស.ប. ដែលបែងចែកទឹកដីប៉ាឡេស្ទីនជារដ្ឋឯករាជ្យពីរ គឺរដ្ឋអ៊ីស្រាអែល និងរដ្ឋប៉ាឡេស្ទីន ក៏ប៉ុន្តែ គឺភាគីប៉ាឡេស្ទីន និងប្រទេសអារ៉ាប់ដែលមិនព្រម ដោយចង់បានទឹកដីប៉ាឡេស្ទីនទាំងមូលសម្រាប់តែខ្លួនឯង ហើយនាំគ្នាលើកទ័ពមកវាយប្រហារលើអ៊ីស្រាអែល។ បច្ចុប្បន្ននេះ ប៉ាឡេស្ទីនចង់បានត្រឹមតែសុខសន្តិភាព និងអាចបង្កើតរដ្ឋឯករាជ្យមួយផ្ទាល់ខ្លួននឹងគេ ក៏ប៉ុន្តែ គឺអ៊ីស្រាអែលវិញម្ដងដែលចេះតែយកជើងរាទឹកមិនឱ្យរដ្ឋប៉ាឡេស្ទីននេះ បង្កើតឡើងបាន។ អ៊ីស្រាអែលចេះតែបន្ត និងពង្រីកអាណានិគមទៅលើទឹកដីរបស់ប៉ាឡេស្ទីន ដោយរំលោភទៅលើច្បាប់អន្តរជាតិ និងធ្មើននឹងការទាមទាររបស់សហគមន៍អន្តរជាតិ ធ្វើឱ្យជម្លោះដ៏រ៉ាំរ៉ៃមួយនេះមិនអាចរកដំណោះស្រាយចេញរួច។ នៅទីចុងបំផុត អ្នកដែលរងទុក្ខវេទនាខ្លាំងជាងគេ គឺប្រជាជនស៊ីវិលប៉ាឡេស្ទីន ដែលរងគ្រោះដោយអំពើជិះជាន់របស់អ៊ីស្រាអែល រងគ្រោះដោយកត្តាភូមិសាស្ត្រនយោបាយនិងការប្រជែងគ្នា រវាងមហាអំណាចអ៊ិស្លាមស៊ុននីត និងស៊ីអ៊ីតនៅក្នុងតំបន់ រងគ្រោះដោយសារនយោបាយរបស់មេដឹកនាំប៉ាឡេស្ទីនខ្លួនឯងផ្ទាល់[436]។

---

[436] សេង ឌីណា, *ប្រវត្តិសាស្ត្រពិភពលោក*, ដ.ឯ.ម., ថ្ងៃ៨ កុម្ភៈ ២០១៥។

## ៣.៤-សង្គ្រាមឈូងសមុទ្ទពែក្ស ឆ្នាំ១៩៩១

### ៣.៤.១-បុព្វហេតុនៃសង្គ្រាម

សង្គ្រាមឈូងសមុទ្ទពែក្សនៅឆ្នាំ១៩៩១បានចាប់ឆាបឆេះឡើង ជាមួយនឹងការឈ្លានពានរបស់អ៊ីរ៉ាក់ទៅលើកូវ៉ែត ក៏ប៉ុន្តែ ដើមឫសនៃសង្គ្រាមបានកើតមានតាំងពីរាប់ឆ្នាំមុនមកម្ល៉េះ គឺចាប់តាំងពីសង្គ្រាមអ៊ីរ៉ាក់-អ៊ីរ៉ង់ (ឆ្នាំ១៩៨០-១៩៨៨)។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០ ពិភពលោកកំពុងតែស្ថិតនៅក្នុងសង្គ្រាមត្រជាក់ ហើយទាំងអ៊ីរ៉ាក់ និងទាំងអ៊ីរ៉ង់ សុទ្ធតែជាប្រទេសដែលកំពុងមានទំនាស់ជាមួយនឹងសហរដ្ឋអាម៉េរិក ។ អ៊ីរ៉ាក់នៅពេលនោះ គឺជាប្រទេសសម្ពន្ធមិត្តរបស់សហភាពសូវៀត ចំណែកឯអ៊ីរ៉ង់វិញ បានក្លាយទៅជាសត្រូវដ៏ធំមួយរបស់អាម៉េរិក ក្រោយពីមានវិបត្តិចំណាប់ខ្មាំងអាម៉េរិក នៅអ៊ីរ៉ង់ នៅក្រោយបដិវត្តន៍ឆ្នាំ១៩៧៩។

ហេតុដូច្នេះហើយបានជានៅពេលដែលសង្គ្រាមអ៊ីរ៉ាក់-អ៊ីរ៉ង់ចាប់ផ្តើម ផ្ទុះឡើង នៅឆ្នាំ១៩៨០ សហរដ្ឋអាម៉េរិក បានប្រកាន់យកជំហរកណ្តាលមួយ ដោយមិនលូកដៃចូលជួយភាគីណាមួយនោះទេ។ ក៏ប៉ុន្តែជំហររបស់អាម៉េរិក បានចាប់ផ្តើមប្រែប្រួល នៅពេលដែលអ៊ីរ៉ង់មានប្រៀបខ្លាំងទៅលើអ៊ីរ៉ាក់ នៅក្នុងសង្គ្រាម។ ក្តីបារម្ភដ៏ធំរបស់អាម៉េរិក នៅពេលនោះ គឺខ្លាចអ៊ីរ៉ង់ទទួលជ័យជម្នះលើអ៊ីរ៉ាក់ រួចហើយវាតទីចូលឈ្លានពានប្រទេសផ្សេងៗទៀត នៅក្នុងតំបន់ឈូងសមុទ្ទពែក្ស ដែលជាសម្ពន្ធមិត្តរបស់អាម៉េរិក ។

អ៊ីរ៉ង់ ដែលជាប្រទេសមហាអំណាចអ៊ិស្លាមនិកាយស្ហ៊ីអ៊ីត គឺជាគូប្រជែងដ៏ធំរបស់អារ៉ាប៊ីសាអ៊ូឌីត ព្រមទាំងប្រទេសផ្សេងទៀតនៅតំបន់ឈូងសមុទ្ទពែក្ស ដែលសុទ្ធសឹងជាប្រទេសអ៊ិស្លាមស៊ុននីត។ អ៊ីរ៉ាក់វិញ ថ្វីដ្បិតតែជាប្រទេសមានប្រជាជនភាគច្រើនកាន់និកាយស្ហ៊ីអ៊ីត ក៏ប៉ុន្តែ ស្ថិតក្រោមការគ្រប់គ្រងរបស់ពួកស៊ុននីត គឺគណបក្សរបស់សាដាមហ៊ូសេន។ ហេតុដូច្នេះហើយបានជាអារ៉ាប៊ីសាអ៊ូឌីត និងសម្ពន្ធមិត្តនៅឈូងសមុទ្ទពែក្ស បាននាំគ្នាសហការជាមួយអាម៉េរិក ក្នុងការផ្តល់ជំនួយយោធាទៅឱ្យសាដាមហ៊ូសេន ដើម្បីទប់ទល់ជាមួយនឹងអ៊ីរ៉ង់។ ដោយសារតែបានជំនួយអស់ទាំងនេះហើយ ទើបអ៊ីរ៉ាក់អាចមានតុល្យភាពកម្លាំងទ័ពជាមួយនឹងអ៊ីរ៉ង់ ហើយនៅឆ្នាំ១៩៨៨ ភាគីជម្លោះទាំងពីរក៏បានចុះកិច្ចព្រមព្រៀងឈប់បាញ់ ដើម្បីឈានទៅបញ្ចប់សង្គ្រាម។ នៅក្រោយពេលដែលសង្គ្រាមអ៊ីរ៉ាក់-អ៊ីរ៉ង់ត្រូវបញ្ចប់ នៅឆ្នាំ១៩៨៨ គេរំពឹងថា សាដាមហ៊ូសេន និងប្រទេសនៅឈូងសមុទ្ទពែក្សអាចនឹងបន្តរក្សាទំនាក់ទំនងជិតស្និទ្ធ នឹងគ្នា ដូចកាលពីអំឡុងសង្គ្រាម ដោយគេឃើញថា នៅក្នុងអំឡុងឆ្នាំ១៩៨៩ អ៊ីរ៉ាក់បានចុះសន្ធិសញ្ញាមិនឈ្លានពានគ្នា និងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នាទៅវិញទៅមកជាមួយនឹង អារ៉ាប៊ីសាអ៊ូឌីត និងបន្ទាប់មកទៀត ចុះកិច្ចព្រមព្រៀងផ្គត់ផ្គង់ទឹកសាបទៅឱ្យកូវ៉ែត។ ក៏ប៉ុន្តែ ភាពល្អកល្អឺននេះមានរយៈពេលប្រមាណតែមួយឆ្នាំប៉ុណ្ណោះ។

នៅអ៊ីរ៉ាក់ សាដាមហ៊ូសេនត្រូវប្រឈមមុខនឹងបញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងរ ដោយសារតែការខូចខាតក្នុងសង្គ្រាមជាមួយអ៊ីរ៉ង់។ បន្ថែមពីលើនេះទៅទៀត បំណុលដែលអ៊ីរ៉ាក់ខ្ចីពីអារ៉ាប៊ីសាអ៊ូឌីត ដើម្បីយកទៅចំណាយធ្វើសង្គ្រាមក៏មានទំហំធំធេងដែលជាបន្ទុកកាន់តែធ្ងន់សម្រាប់សេដ្ឋកិច្ចជាតិ ហើយក្នុងពេលជាមួយគ្នា តម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិក៏មានកម្រិតទាប ដែលហេតុធ្វើឱ្យអ៊ីរ៉ាក់ ដែលជាប្រទេសនាំចេញប្រេងឆៅពិបាកនឹងបង្កើនប្រាក់ចំណូលយកមកស្តារសេដ្ឋកិច្ចរបស់ខ្លួន។ ប្រឈមមុខនឹងបញ្ហានេះ សាដាមហ៊ូសេនបានស្នើសុំឱ្យអារ៉ាប៊ីសាអ៊ូឌីត និងប្រទេសផ្សេងទៀត នៅក្នុងតំបន់ឈូងសមុទ្ទពែក្ស លុបចោលបំណុលប្រមាណជា ៣០ពាន់លានដុល្លារដែលអ៊ីរ៉ាក់ខ្ចី កាលពីសម័យសង្គ្រាមជាមួយអ៊ីរ៉ង់ ព្រមទាំងទាមទារឱ្យអង្គការ OPEC ចាត់វិធានការ ដើម្បីបង្កើនតម្លៃប្រេងឆៅ។ ក៏ប៉ុន្តែ ការទាមទារទាំងនេះត្រូវបានប្រានចោលដោយអារ៉ាប៊ីសាអ៊ូឌីត។

នៅក្នុងអំឡុងឆ្នាំ១៩៩០ សាដាមហ៊ូសេនក៏បានចាប់ផ្ដើមធ្វើការបរិហារិះគន់យ៉ាងធ្ងន់ៗ ទៅលើ អារ៉ាប៊ីសាអ៊ូឌីត និងសម្ពន្ធមិត្តនៅឈូងសមុទ្រពែក្ស ដោយបានចោទប្រទេសអស់ទាំងនេះថាកំពុងតែធ្វើនយោបាយបម្រើផលប្រយោជន៍ អាម៉េរិក ហើយបំផ្លិចបំផ្លាញប្រទេសអារ៉ាប់គ្នាឯង។ សម្រាប់សាដាមហ៊ូសេន ការណ៍ដែលអារ៉ាប៊ីសាអ៊ូឌីតដាក់សម្ពាធលើប្រទេសផ្សេងទៀតក្នុងអង្គការ OPEC កុំឱ្យចាត់វិធានការដំឡើងតម្លៃប្រេងឆៅ គឺដើម្បីតម្រូវចិត្តសហរដ្ឋអាម៉េរិក ដែលចង់ទិញប្រេងពីមជ្ឈិមបូព៌ាក្នុងតម្លៃថោក។

នៅខែកក្កដាឆ្នាំ១៩៩០ សាដាមហ៊ូសេនបានចោទកូវ៉ែតថាបានលួចបូមប្រេងចូលមកក្នុងទឹកដី អ៊ីរ៉ាក់ ហើយបានប្រកាសគំរាមជាសាធារណៈចង់ប្រើកម្លាំងទ័ពបើកការវាយប្រហារ ទៅលើកូវ៉ែត។ ព្រមជាមួយនឹងពាក្យគំរាម សាដាមហ៊ូសេនបានចល័តទ័ពប្រមាណជា ៣ម៉ឺននាក់ឱ្យទៅកាន់ព្រំដែនជាមួយកូវ៉ែត។ ដោយមើលឃើញពីស្ថានភាពក្ដៅគគុកបែបនេះ លោកហូស្នី មូបារ៉ាក់ ប្រធានាធិបតីអេហ្ស៊ីប ក្នុងនាមបក្សសម្ពន្ធអារ៉ាប់ បានព្យាយាមសម្រុះសម្រួលភាគីជម្លោះ ឱ្យដោះស្រាយវិវាទតាមរយៈការចរចា ដើម្បីបញ្ចៀសកុំឱ្យមានសង្គ្រាម រវាងប្រទេសអារ៉ាប់គ្នាឯង។

នៅថ្ងៃទី៣១កក្កដា កិច្ចចរចា រវាងអ៊ីរ៉ាក់ និងកូវ៉ែតក៏បានចាប់បើកធ្វើឡើង នៅក្នុងប្រទេសអារ៉ាប៊ីសាអ៊ូឌីត ដោយមានលោកហូស្នី មូបារ៉ាក់ ធ្វើជាអន្តរការី។ នៅក្នុងការចរចានេះ អ៊ីរ៉ាក់បានទាមទារឱ្យកូវ៉ែតបង់លុយជាសំណងចំនួន ១០ពាន់លានដុល្លារអាម៉េរិក ដើម្បីជាការប៉ះប៉ូវការខាតបង់ប្រេងរបស់អ៊ីរ៉ាក់។ កូវ៉ែតបានយល់ព្រមបង់សំណងទៅតាមការទាមទារ ក៏ប៉ុន្តែ សុំតថ្លៃបញ្ចុះសំណងមកនៅត្រឹម ៩ពាន់លានដុល្លារ។ ឆ្លើយតបមកវិញ សាដាមហ៊ូសេនស្រាប់តែបានប្រកាសចេញបញ្ជាឱ្យកងទ័ពអ៊ីរ៉ាក់បើកការវាយលុកភ្លាមៗ ដោយឥតបង្អង់ទៅលើទឹកដីកូវ៉ែត។ នៅថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩០ កងទ័ពអ៊ីរ៉ាក់បានចាប់ផ្ដើមបើកការវាយលុកចូលឈ្លានពានប្រទេសកូវ៉ែត។ អាម៉េរិកចូលមកជួយកូវ៉ែត ហើយសង្គ្រាមឈូងសមុទ្រពែក្សក៏ចាប់ផ្ដើម ផ្ទុះឡើងនៅខែមករា ឆ្នាំ១៩៩១[437]។

### ៣.៤.២ ដំណើរប្រព្រឹត្តទៅនៃសង្គ្រាម

នៅថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩០ សាដាមហ៊ូសេនបានបញ្ជូនកងទ័ពអ៊ីរ៉ាក់ឱ្យចូលឈ្លានពានប្រទេស កូវ៉ែតដែលជាប្រទេសជិតខាងដ៏តូចមួយ ស្ថិតនៅជាប់នឹងឈូងសមុទ្រពែក្ស។ សង្គ្រាម រវាងអ៊ីរ៉ាក់ និងកូវ៉ែតនៅពេលនោះ គឺប្រៀបដូចជាពងមាន់ជល់នឹងថ្ម ពីព្រោះថា អ៊ីរ៉ាក់ដែលទទួលបានជំនួយយ៉ាងច្រើនសន្ធឹកសន្ធាប់ពីសហរដ្ឋអាម៉េរិក និងអារ៉ាប៊ីសាអ៊ូឌីត នៅក្នុងពេលធ្វើសង្គ្រាមទល់នឹងអ៊ីរ៉ង់ គឺជាប្រទេសដែលមានកម្លាំងទ័ពខ្លាំងជាងគេលំដាប់ទី៤ នៅលើពិភពលោក។ ចំណែកឯកូវ៉ែតវិញ គ្រាន់តែជាកូនប្រទេសតូចមួយ ដែលមានប្រជាជនប្រមាណតែ ២លាននាក់ និងកងទ័ពតិចតួចតែប៉ុណ្ណោះ។

ហេតុដូច្នេះ ហើយបានជាគ្រាន់តែក្នុងរយៈពេលត្រឹមតែ ១២ម៉ោង កងទ័ពអ៊ីរ៉ាក់ក៏អាចវាយលុកចូលកាន់កាប់រដ្ឋធានីរបស់កូវ៉ែតបាន ហើយក្រុមគ្រួសាររាជវង្ស ព្រមទាំងសមាជិករដ្ឋាភិបាលកូវ៉ែត ក៏បាននាំគ្នារត់ភៀសខ្លួនទៅកាន់ប្រទេសអារ៉ាប៊ីសាអ៊ូឌីត។ ក៏ប៉ុន្តែ ថ្វីដ្បិតតែអាចយកឈ្នះលើកូវ៉ែតយ៉ាងងាយនៅលើ សមរភូមិទ័ពតែនៅលើសមរភូមិការទូតវិញ សាដាមហ៊ូសេនត្រូវប្រឈមមុខនឹងការបរិហារិះគន់ស្ទើរតែគ្រប់ទិសទី។ ត្រឹមតែប៉ុន្មានម៉ោងប៉ុណ្ណោះ ក្រោយពីអ៊ីរ៉ាក់ចាប់ផ្ដើមចូលឈ្លានពានកូវ៉ែត ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប បានជួបប្រជុំគ្នាហើយចេញសេចក្ដីសម្រេចមួយ (សេចក្ដីសម្រេចលេខ ៦៦០) ទាមទារឱ្យអ៊ីរ៉ាក់ដកកងទ័ពចេញពីកូវ៉ែតជាបន្ទាន់

[437] សេង ឌីណា, *ប្រវត្តិសាស្ត្រពិភពលោក*, ដ.ឯ.ម.,ថ្ងៃ៣ មេសា ២០១៦។

និងដោយគ្មានលក្ខខណ្ឌ។ មួយថ្ងៃក្រោយមក នៅថ្ងៃទី៣ សីហា សម្ពន្ធអារ៉ាប់ ដែលទាំងអ៊ីរ៉ាក់ និងទាំងកូវ៉ែត សុទ្ធតែជាសមាជិកដូចគ្នានោះ ក៏បានចេញសេចក្តីសម្រេចមួយទាមទារឱ្យអ៊ីរ៉ាក់ដកទ័ពផងដែរ។ ក៏ប៉ុន្តែ សាដាម ហ៊ូសេន មិនធ្វើតាម ហើយថែមទាំងប្រកាសកាត់យកប្រទេសកូវ៉ែតទាំងមូលទៅដាក់ជាខេត្តមួយ របស់អ៊ីរ៉ាក់។ នៅថ្ងៃទី៨ ខែសីហា ថ្ងៃដែលអ៊ីរ៉ាក់ប្រកាសកាត់យកប្រទេសកូវ៉ែត សហរដ្ឋអាម៉េរិក បានបញ្ជូនកងទ័ពរបស់ខ្លួន ទៅដល់ប្រទេស អារ៉ាប៊ីសាអ៊ូឌីត នៅក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការរួមជាមួយកងកម្លាំងអូតង់ និងកងទ័ពមកពី ប្រទេសអារ៉ាប់ផ្សេងទៀត ដើម្បីត្រៀមការពារប្រទេសអារ៉ាប៊ីសាអ៊ូឌីត ពីការវាយប្រហាររបស់អ៊ីរ៉ាក់ ដោយសារតែ គេឃើញថា ក្រោយពី វាយចូលកាន់កាប់កូវ៉ែតបានហើយ សាដាមហ៊ូសេនបានបង្កើន ការវាយប្រហារដោយពាក្យ សម្តីកាន់តែខ្លាំងទៅលើ អារ៉ាប៊ីសាអ៊ូឌីត។ តាមការពិត ការណ៍ដែលអាម៉េរិក ចូលមកបោះទីតាំងទ័ពនៅក្នុងទឹកដី អារ៉ាប៊ីសាអ៊ូឌីត នៅពេលនោះ គឺជាដើមឫសដ៏សំខាន់មួយ ដែលនាំទៅរកការវាយប្រហារភេរវកម្មជាប្រវត្តិសាស្ត្រ មួយនៅក្នុង ទឹកដីអាម៉េរិក ១០ឆ្នាំក្រោយមកទៀត គឺព្រឹត្តិការណ៍ ១១កញ្ញា ឆ្នាំ២០០១។

នៅពេលដែលសាដាមហ៊ូសេនបង្កើនការគំរាមកំហែងដល់អារ៉ាប៊ីសាអ៊ូឌីត មេដឹកនាំវ័យក្មេង នៃក្រុម មូចាហ៊ីឌីន ដែលធ្លាប់មានបទពិសោធន៍ធ្វើសង្គ្រាមនៅអាហ្វហ្គានីស្ថាន គឺអូសាម៉ា ប៊ិនឡាដិន ដែលជាពលរដ្ឋ អារ៉ាប៊ីសាអ៊ូឌីតផងនោះ បានស្នើទៅរដ្ឋាភិបាលអារ៉ាប៊ីសាអ៊ូឌីត ឱ្យយកក្រុមមូចាហ៊ីឌីនរបស់ខ្លួនយកមកធ្វើជា កម្លាំងការពារ អារ៉ាប៊ីសាអ៊ូឌីត ពីការឈ្លានពានរបស់អ៊ីរ៉ាក់។ ក៏ប៉ុន្តែ មេដឹកនាំអារ៉ាប៊ីសាអ៊ូឌីតបដិសេធ ដោយ ជ្រើសរើសយកអាម៉េរិក មកធ្វើជាខែលការពារវិញ ដែលជាហេតុធ្វើឱ្យអូសាម៉ាប៊ិនឡាដិនមានកំហឹងយ៉ាងខ្លាំង ហើយចងគំនុំទុកក្នុងចិត្ត ដោយចាត់ទុកវត្តមានកងទ័ពអាម៉េរិក នៅលើទឹកដីអារ៉ាប៊ីសាអ៊ូឌីតថាជាការ ប្រមាថ ដល់សាសនាអ៊ិស្លាម។

នៅថ្ងៃទី១២ ខែសីហា ដោយប្រឈមមុខនឹងការថ្កោលទោសជាអន្តរជាតិ ក្នុងនោះរួមមានទាំងប្រទេសអារ៉ាប់គ្នាឯងផង សាដាមហ៊ូសេនក៏បានព្យាយាមភ្ជាប់បញ្ហាកូវ៉ែតទៅនឹងសំណុំរឿងប៉ាឡេស្ទីន ក្នុងគោលដៅទាក់ ទាញការគាំទ្រពីសំណាក់អ្នកកាន់សាសនាអ៊ិស្លាម។ សាដាមហ៊ូសេនបានប្រកាសថា អ៊ីរ៉ាក់នឹងសុខចិត្តដកកង ទ័ពចេញពីកូវ៉ែត លុះត្រាតែអ៊ីស្រាអែលសុខចិត្តដកកងទ័ពចេញពីទឹកដីប៉ាឡេស្ទីន ហើយកងទ័ពបរទេសទាំង អស់ត្រូវដកចេញពីតំបន់មជ្ឈិមបូព៌ា។ ក៏ប៉ុន្តែ នេះគឺជាការថ្លែងជាសាធារណៈ។ រីឯនៅពីខាងក្រោយឆាកវិញ សាដាមហ៊ូសេន បានបញ្ជូនមន្ត្រីរបស់ខ្លួនឱ្យទៅចរចាដោយសម្ងាត់ជាមួយមន្ត្រីអាម៉េរិក ដោយបានលើកឡើងនូវ លក្ខខណ្ឌចំនួន៣ ជាថ្នូរនឹងការដកទ័ពចេញពីកូវ៉ែត គឺទី១ ការដកចេញវិញទាំងអស់នូវទណ្ឌកម្មរបស់អ.ស.ប ទី២ ការធានាឱ្យមានការបើកច្រកផ្លូវពីទឹកដីអ៊ីរ៉ាក់ទៅកាន់ឈូងសមុទ្ទ ពែក្សដោយឆ្លងកាត់តាមទឹកដីកូវ៉ែត និងទី៣ កាត់ផ្តាច់ប្លុកប្រេងកាតមួយផ្នែករបស់កូវ៉ែតយកទៅឱ្យអ៊ីរ៉ាក់ គ្រប់គ្រង។ ក៏ប៉ុន្តែ លក្ខខណ្ឌអស់ទាំងនេះត្រូវបាន អាម៉េរិក ច្រានចោល ដោយនៅពេលនោះ លោកប្រធានាធិបតីប៊ូសបានប្រកាន់នូវជំហរដ៏តឹងរ៉ឹងមួយថា ប្រសិនបើ គេសុខចិត្តធ្វើតាមការទាមទាររបស់អ៊ីរ៉ាក់ គឺមានន័យស្មើនឹងការ ផ្តល់រង្វាន់ដល់សកម្មភាពឈ្លានពាន ដែលសាដាមហ៊ូសេនធ្វើទៅលើកូវ៉ែត។ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩០ ក្រុមប្រឹក្សាសន្តិសុខអ.ស.ប ក៏បានអនុម័តសេចក្តីសម្រេចថ្មីមួយទៀត ដោយបានដាក់ឱសានវាទឱ្យអ៊ីរ៉ាក់ដកកងទ័ពទាំងអស់ចេញពីប្រទេសកូវ៉ែត យ៉ាងយូរ បំផុតត្រឹមថ្ងៃទី១៥ មករា ១៩៩១ ព្រមទាំងបានផ្តល់សិទ្ធិដល់ប្រទេសសមាជិកទាំងអស់ក្នុងការប្រើ កម្លាំងទ័ពទៅ លើអ៊ីរ៉ាក់ ប្រសិនបើអ៊ីរ៉ាក់នៅតែមិនព្រមដកទ័ពទៅតាមឱសានវាទនេះ។

នៅក្នុងពេលជាមួយគ្នានោះ បក្សសម្ពន្ធយោធាអន្តរជាតិមួយត្រូវបានបង្កើតឡើង ដឹកនាំដោយ សហរដ្ឋ អាម៉េរិក និងមានការចូលរួមពីសំណាក់ប្រទេសចំនួន៣៤ ដោយក្នុងនោះក៏មានផងដែរ បណ្តាប្រទេសកាន់

សាសនាអ៊ិស្លាម ដូចជា អារ៉ាប៊ីសាអូឌីត អេហ្ស៊ីប និងប៉ាគីស្ថាន ជាដើម។ បក្សសម្ពន្ធ អន្តរជាតិនេះមានកងទ័ពសរុបប្រមាណជា ៧៥ម៉ឺននាក់ ក្នុងនោះ ប្រមាណជា ៥៤ម៉ឺននាក់ ជាកងទ័ព អាម៉េរិក ។ ចំណែកពីខាងអ៊ីរ៉ាក់វិញ សាដាមហ៊ូសេនទទួលបាននូវការគាំទ្រពីសំណាក់ប្រទេសហ្សកដានី អាល់ហ្សេរីស៊ូដង់យេម៉ែនទុយនីស៊ីនិងប៉ាឡេស្ទីន។

នៅថ្ងៃ ទី១៧ ខែមករា ឆ្នាំ១៩៩១ ពីរថ្ងៃក្រោយផុតឱសានវាទរបស់ក្រុមប្រឹក្សាសន្តិសុខ អាម៉េរិកក៏បានចាប់ផ្តើមបើកការវាយប្រហារទៅលើអ៊ីរ៉ាក់ ដោយចាប់ផ្តើមដំបូង ពីការវាយប្រហារតាមផ្លូវអាកាស។ ប្រតិបត្តិការយោធារបស់អាម៉េរិក នៅពេលនោះ ត្រូវបានធ្វើឡើង ដោយយកទឹកដីអារ៉ាប៊ីសាអូឌីតធ្វើជា មូលដ្ឋាន បូករួមជាមួយនឹងនាវាផ្ទុកយន្តហោះជាច្រើនគ្រឿង ដែលបោះទីតាំងនៅក្នុងឈូងសមុទ្រពែក្ស និងក្នុងសមុទ្រក្រហមក្បែរប្រទេសអេហ្ស៊ីប។

កងទ័ពអ៊ីរ៉ាក់ ថ្វីដ្បិតតែនៅពេលនោះជាប់ឈ្មោះជាកងទ័ពខ្លាំងជាងគេលំដាប់ទី៤ នៅលើពិភពលោក ក៏ប៉ុន្តែ ចាញ់ប្រៀបយ៉ាងដាច់ឆ្ងាយកងទ័ពអាម៉េរិក ដែលបំពាក់ទៅដោយបច្ចេកវិទ្យាទំនើបៗ បំផុតរួមមានដូចជាយន្តហោះបំបាំងកាយ (យន្តហោះធុន F-117) មីស៊ីលបណ្តែត (Tomahawk Cruise missiles) និងគ្រាប់បែកកំណត់ចំណុចស៊ីបដោយប្រើកាំរស្មីឡាស៊ែរ (Laser-guided Smart Bombs)។ គ្រាន់តែក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ កងទ័ពអាម៉េរិក អាចគ្រប់គ្រងដែនអាកាសអ៊ីរ៉ាក់បានស្ទើរតែទាំងស្រុង រួចហើយក៏ចាប់ផ្តើមធ្វើការទម្លាក់គ្រាប់បែកទៅលើទីបញ្ជាការដ្ឋាន សំខាន់ៗរបស់អ៊ីរ៉ាក់ ហើយនៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៩១ អាម៉េរិក និងសម្ពន្ធមិត្តក៏បានចាប់ផ្តើមបើកប្រតិបត្តិការទ័ពជើងគោក វាយលុកចូលរំដោះប្រទេសកូវ៉ែត។ គិតត្រឹមចុងខែកុម្ភៈ ឆ្នាំ១៩៩១ កងទ័ពអាម៉េរិក រំដោះបានទាំងស្រុងនូវទឹកដីកូវ៉ែត មុននឹងបើកការវាយលុកឆ្លងដែនចូលទៅក្នុងប៉ែកខាងត្បូងប្រទេស អ៊ីរ៉ាក់[438]។

### ៣.៤.៣-ផលវិបាកនៃសង្គ្រាម

នៅដើមឆ្នាំ ១៩៩១ នៅពេលដែលកងទ័ពអាម៉េរិក បើកការវាយប្រហារទៅលើអ៊ីរ៉ាក់ គោលដៅ និងអាណត្តិដែលផ្តល់ដោយក្រុមប្រឹក្សាសន្តិសុខអ.ស.ប គឺដើម្បីរំដោះកូវ៉ែតឱ្យផុតពីការឈ្លានពានរបស់អ៊ីរ៉ាក់។

នៅ ចុងខែកុម្ភៈ ឆ្នាំ១៩៩១ កូវ៉ែតត្រូវបានរំដោះ ហើយកងទ័ពអ៊ីរ៉ាក់ ទាំងអស់ដែលស្ថិតនៅក្នុងទឹកដីកូវ៉ែតត្រូវបង្ខំចិត្តដកថយចូលទៅក្នុងទឹកដីខ្លួនវិញ។ មកដល់ត្រឹមនេះ អាម៉េរិកអាចមានផ្លូវ២៖ ឬមួយបញ្ចប់ប្រតិបត្តិការតែត្រឹមនេះ ឬមួយ បន្តវាយលុកចូលឈ្លានពានអ៊ីរ៉ាក់ ដើម្បីផ្តួលរំលំរបបដឹកនាំរបស់សាដាមហ៊ូសេន។ ក៏ប៉ុន្តែ ប្រធានាធិបតីអាម៉េរិក គឺលោកចច ប៊ូស រួមជាមួយនឹងប្រទេសជាសម្ពន្ធមិត្ត បានកំណត់ជាស្រេចតាំងពីមុនរួចទៅហើយថា អន្តរាគមន៍យោធារបស់ពួកគេមានគោលដៅត្រឹមតែរំដោះប្រទេសកូវ៉ែត ប៉ុណ្ណោះ មិនមែនដើម្បីផ្តួលរំលំរបបសាដាមហ៊ូសេននោះទេ។

ក្រោយពីរំដោះប្រទេសកូវ៉ែតបានហើយ កងទ័ពអាម៉េរិក និងសម្ពន្ធមិត្ត បានបន្តវាយលុកចូលទៅក្នុងទឹកដីអ៊ីរ៉ាក់ប៉ែកខាងត្បូង ក៏ប៉ុន្តែ ចូលក្នុងជម្រៅត្រឹមតែប្រមាណជា ២០០គីឡូម៉ែត្រ ក៏បញ្ឈប់ដំណើរ ត្រឹមនោះ ហើយលោកប្រធានាធិបតីប៊ូស បានប្រកាសឈប់បាញ់ បិទបញ្ចប់សង្គ្រាមឈូងសមុទ្រពែក្ស នៅ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩១។

[438] សេង ឌីណា, *ប្រវត្តិសាស្រ្តពិភពលោក*, ថ្ងៃ១០ មេសា ២០១៦។

នៅក្នុងកិច្ចព្រមព្រៀងដែលបានចុះជាមួយអាម៉េរិក នៅក្រោយសង្គ្រាម សាដាមហ៊ូសេនបានសុខចិត្តទទួលស្គាល់អធិបតេយ្យយ៉ាងពេញលេញរបស់ប្រទេស កូវ៉ែត ព្រមទាំងត្រូវជាប់កាតព្វកិច្ចកម្ទេចចោលទាំងអស់នូវអាវុធប្រល័យលោក គ្រប់ប្រភេទដែលអ៊ីរ៉ាក់មាន ទាំងអាវុធនុយក្លេអ៊ែរ អាវុធគីមី និងជីវសាស្ត្រ។ នៅក្នុងសៀវភៅចេញផ្សាយកាលពីឆ្នាំ១៩៩៨ លោកប្រធានាធិបតីប៊ូស (Georges H Bush) និងទីប្រឹក្សាសន្តិសុខជាតិរបស់លោក គឺលោកប្រេន ស្កូវក្រហ្វត៍ (Brent Scowcroft) បានធ្វើការពន្យល់ថា ការសម្រេចបន្តទុកឱ្យសាដាមហ៊ូសេននៅកាន់អំណាច ហើយមិនវាយលុកចូលក្រុងបាកដាដ គឺដោយសារតែអាម៉េរិក មិនចង់ឱ្យបាត់បង់អាយុជីវិតទាហានច្រើនដែល មិនចាំបាច់ និងកាន់តែសំខាន់ជាងនេះទៅទៀត គឺដោយសារតែមិនចង់ឱ្យមានការបាក់បែកជាមួយប្រទេសសម្ពន្ធមិត្ត។ បណ្តាប្រទេសជាច្រើន ដែលស្ថិតនៅក្នុងបក្សសម្ពន្ធជាមួយអាម៉េរិក ជាពិសេស ប្រទេសអ៊ិស្លាមស៊ុននីត ចង់រក្សាទុកសាដាមហ៊ូសេនឱ្យនៅកាន់អំណាចនៅអ៊ីរ៉ាក់ដើម្បីទុកទប់ទល់នឹងអ៊ីរ៉ង់។ ក៏ប៉ុន្តែ ប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញថា ការរក្សាសាដាមហ៊ូសេនឱ្យនៅកាន់អំណាចនៅអ៊ីរ៉ាក់បានបង្កឱ្យមាន ផលវិបាកយ៉ាងច្រើនទាំងនៅក្នុងប្រទេសអ៊ីរ៉ាក់ នៅក្នុងតំបន់មជ្ឈិមបូព៌ា និងនៅតំបន់ផ្សេងទៀតនៅជុំវិញពិភពលោក។

នៅដើមខែមីនា ឆ្នាំ១៩៩១ នៅក្រោយពីមានបទឈប់បាញ់បញ្ចប់សង្គ្រាម រវាងអាម៉េរិក និងអ៊ីរ៉ាក់ ហើយសាដាមហ៊ូសេននៅបន្តកាន់អំណាចនៅអ៊ីរ៉ាក់ ចលនាបះបោរក្នុងស្រុកមួយបានផ្ទុះឡើង ក្នុងគោលដៅទម្លាក់សាដាមហ៊ូសេនពីអំណាច។ ចលនាបះបោរនេះមានទាំងពួកជនជាតិគួឌីស្ថាននៅប៉ែកខាងជើងអ៊ីរ៉ាក់ ទាំងពួកអ្នកកាន់និកាយស្ស៊ីអ៊ីត និងទាហានដែលផ្តាច់ខ្លួនពីជួរកងទ័ពជាតិអ៊ីរ៉ាក់។ ចលនាបះបោរនេះបានចាប់ផ្ទុះឡើងដោយសារតែមូលហេតុសំខាន់ចំនួនពីរ។ ទីមួយ គឺដោយសារតែគេមិនសប្បាយចិត្តនឹងការដឹកនាំរបស់សាដាមហ៊ូសេន ដែលមិនគិតគូរពីសេដ្ឋកិច្ចជាតិ និងសុខមាលភាពរបស់ប្រជាជនខ្លួនឯង ហើយបានទាញប្រទេសអ៊ីរ៉ាក់ឱ្យធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាម ម្តងហើយម្តងទៀត គឺសង្គ្រាមជាមួយអ៊ីរ៉ង់ និងសង្គ្រាមជាមួយអាម៉េរិក ។ លើសពីនេះទៅទៀត ប្រជាជនអ៊ីរ៉ាក់ភាគច្រើនគឺជាអ្នកកាន់សាសនាអ៊ិស្លាមនិកាយស្ស៊ីអ៊ីត ចំណែកសាដាមហ៊ូសេន និងបក្សពួក គឺជាអ្នកកាន់និកាយស៊ុននីត។ ទីពីរ គឺដោយសារតែមានការជំរុញទឹកចិត្តពីសំណាក់សហរដ្ឋអាម៉េរិក ។ លោកប្រធានាធិបតីប៊ូស ថ្វីដ្បិតតែមិនបានលើកទ័ពចូលវាយលុកក្រុងបាកដាដ ដើម្បីផ្តួលរំលំរដ្ឋាភិបាលសាដាមហ៊ូសេន ក៏ប៉ុន្តែ មានបំណងចង់ឃើញសាដាមហ៊ូសេនត្រូវធ្លាក់កម្ទាត់ចេញពីអំណាចដោយ ប្រជាជនអ៊ីរ៉ាក់ខ្លួនឯង។ ហេតុដូច្នេះហើយបានជា លោកប៊ូស បានថ្លែងសារម្តងហើយម្តងទៀត តាមវិទ្យុសំឡេងសហរដ្ឋអាម៉េរិក ជំរុញឱ្យប្រជាជន និងកងទ័ពអ៊ីរ៉ាក់ទម្លាក់សាដាមហ៊ូសេនពីអំណាច។

ដោយសារតែមានការជំរុញទឹកចិត្តពីសំណាក់សហរដ្ឋអាម៉េរិក និងដោយសារតែមើលឃើញពីការធ្លាក់ចុះទន់ខ្សោយរបស់សាដាមហ៊ូសេន ដែលទើបនឹងទទួលបរាជ័យក្នុងសង្គ្រាម ទើបចលនាបះបោរបានចាប់ផ្ទុះឡើង ដោយក្រុមបះបោរមួយចំនួនដាក់ក្តីរំពឹងថានឹងអាចទទួលបានការជួយ ជ្រោមជ្រែងពីសំណាក់កងទ័ពអាម៉េរិក ។ ក៏ប៉ុន្តែ ខុសពីក្តីរំពឹង កងទ័ពអាម៉េរិក មិនបានលូកដៃចូលជួយក្រុមបះបោរនោះទេ ដែលជាហេតុធ្វើឱ្យចលនាបះបោរត្រូវកងកម្លាំងរបស់សាដាមហ៊ូសេនធ្វើ ការបង្ក្រាបយ៉ាងព្រៃផ្សៃ បណ្តាលឱ្យមនុស្សរាប់ម៉ឺននាក់ត្រូវបាត់បង់ជីវិត ហើយជនស៊ីវិលប្រមាណជាជិត ២លាននាក់ផ្សេងទៀតត្រូវបង្ខំចិត្តរត់គៀសខ្លួនចោលផ្ទះសម្បែង។

នៅដើមខែមេសា ឆ្នាំ១៩៩១ ចលនាបះបោរអ៊ីរ៉ាក់បានបញ្ចប់ ក៏ប៉ុន្តែ សង្គ្រាមរវាងកងកម្លាំងសាដាមហ៊ូសេន និងកងកម្លាំងគួឌីស្ថាននៅតំបន់ស្វ័យ័តប៉ែកខាងជើងអ៊ីរ៉ាក់នៅតែបន្ត កើតមាន ហើយអូសបន្លាយ

ពេលជាច្រើនឆ្នាំបន្តបន្ទាប់មកទៀត។ ដើម្បីការពារជនស៊ីវិលគួឌីស្ថាន កុំឱ្យទទួលរងការសម្លាប់រង្គាលពីសំណាក់សាដាមហ៊ូសេន ដូចកាលពីឆ្នាំ១៩៨៨ អាម៉េរិក និងសម្ពន្ធមិត្ត ក៏បានសម្រេចបង្កើតតំបន់ហាមឃាត់ការហោះហើរ (No-Fly Zone) នៅតំបន់ប៉ែកខាងជើងអ៊ីរ៉ាក់។

ប្រតិបត្តិការយោធានេះហើយ ដែលបានធ្វើឱ្យកងទ័ពអាម៉េរិក និងកងទ័ពអ៊ីរ៉ាក់ត្រូវប៉ះទង្គិចគ្នាជាច្រើនលើកច្រើនសារ ហើយបូករួមជាមួយនឹងភាពចម្រូងចម្រាសជុំវិញបេសកកម្មនៃក្រុម អធិការកិច្ចសព្វាវុធរបស់ អ.ស.ប. សហរដ្ឋអាម៉េរិក និងអ៊ីរ៉ាក់ នៅតែបន្តជាប់ជម្លោះនឹងគ្នាអូសបន្លាយពេលជាច្រើនឆ្នាំ រហូតដល់ផ្ទុះសង្គ្រាមសាជាថ្មី នៅឆ្នាំ២០០៣ គឺនៅក្រោយពីមានការវាយប្រហារភេរវកម្មថ្ងៃ១១ កញ្ញា ឆ្នាំ២០០១[439]។

**សំណួររំលឹក**

១-តើប្រទេសណាខ្លះស្ថិតនៅក្នុងតំបន់មជ្ឈិមបូព៌ា?

២-ហេតុដូចម្តេចបានជាមជ្ឈិមបូព៌ាក្លាយជាតំបន់ប្រកាន់សាសនាអ៊ិស្លាម?

៣-ចូររៀបរាប់ពីដំណើរការបង្កើតរដ្ឋអ៊ីស្រាអែល ក្រោយសង្គ្រាមលោកលើកទី២។

៤-តើអ្វីជាប្រភពទំនាស់រវាងអ៊ីស្រាអែល ជាមួយពិភពអារ៉ាប់?

៥-តើសង្គ្រាមនៅឈូងសមុទ្រពែរ្ស ឆ្នាំ១៩៩១ កើតចេញពីបុព្វហេតុអ្វីខ្លះ? តើសង្គ្រាមនេះផ្តល់ផលវិបាកដូចម្តេច?

៦-ហេតុអ្វីបានជាមហាអំណាចប្រជែងគ្នានៅតំបន់មជ្ឈិមបូព៌ា?

[439] សេង ឌីណា, *ប្រវត្តិសាស្រ្តពិភពលោក*, ថ្ងៃទី១៧ មេសា ២០១៦។

# មេរៀនទី៥ សមាគមអាស៊ាន

**សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍** ( ជាភាសាអង់គ្លេស Association of Southeast Asian Nations ) ដែលហៅកាត់ថា **អាស៊ាន** (ASEAN) គឺជាអង្គការនយោបាយ និងសេដ្ឋកិច្ចមួយនៃបណ្តាប្រទេសដែលស្ថិតនៅក្នុងតំបន់ អាស៊ីអាគ្នេយ៍។ អាស៊ានត្រូវបានបង្កើតឡើងនៅថ្ងៃទី៨ សីហាឆ្នាំ១៩៦៧ ដោយរួមមានប្រទេសហ្វីលីពីន ម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី និងសិង្ហបុរី ដើម្បីជានិមិត្តរូបនៃសាមគ្គីភាពប្រឆាំងនឹងការរីកសាយនៃលិទ្ធិកុម្មុយនិស្ត នៅប្រទេសវៀតណាមនិងកុបកម្មនានានៅតាមបណ្តោយព្រំដែនរបស់ប្រទេសខ្លួន។ បន្ទាប់ពីជំនុំកំពូលបាលីឆ្នាំ១៩៧៦ អង្គការនេះបានបង្កើតនូវកម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចមួយ ដែលជួបប្រទះការជាប់គាំងក្នុងអំឡុងពាក់កណ្តាលទសវត្សរ៍ទី៨០ ហើយបានដំណើរការឡើងវិញក្នុងរូបភាពជាគម្រោងសំណើតំបន់ពាណិជ្ជកម្មសេរី ថ្នាក់តំបន់មួយ។ ប្រទេសជាសមាជិកទាំងអស់នេះ ជួបគ្នាជារៀងរាល់ឆ្នាំ។

## ១-អង្គការក្នុងតំបន់មុនការបង្កើតអាស៊ាន

នៅក្រោយសង្គ្រាមលោកលើកទី២ ពិភពលោកបានធ្លាក់ចូលទៅក្នុងសង្គ្រាមថ្មីមួយទៀតគឺសង្គ្រាមត្រជាក់។ នៅក្នុងពេលនោះពិភពលោកទាំងមូលត្រូវបានបែងចែកពីរប្លុក គឺប្លុកមនោគមន៍វិជ្ជាសេរី (ដឹកនាំដោយអាម៉េរិក) និងប្លុកសង្គមនិយម(ដឹកនាំដោយសហភាពសូវៀត)។ ចំណែកនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក៏ទទួលរងសម្ពាធនៃសង្គ្រាមត្រជាក់នេះយ៉ាងខ្លាំងផងដែរ។ ដោយហេតុនេះហើយទើបគេឃើញ បណ្តាប្រទេសមួយចំនួននៅក្នុងតំបន់នេះ ខិតខំបង្កើតអង្គការតំបន់របស់ខ្លួនដើម្បីពង្រឹងសន្តិសុខ រក្សាសន្តិភាព និងដើម្បីទប់ទល់ការរីក រាលដាលនៃលទ្ធិកុម្មុយនីស្តផងដែរ។

សមាគមអាស៊ាន ត្រូវប្រើពេលជាយូរទំរាំបង្កើតបានជារូបរាងឡើង។ មុននឹងលេចរូបរាងសមាគម អាស៊ាននៅក្នុងតំបន់នេះ ប្រទេសមួយចំនួនខិតខំបង្កើតបានអង្គការនានា ដែលជាបុព្វអាស៊ាន ប៉ុន្តែអង្គការទាំង នេះមិនអាចរស់រានបានយូរឡើយ។

### ១.១-សមាគមអាស៊ីអាគ្នេយ៍ ( Association of Southeast Asia/ASA )

#### ១.១.១-ការបង្កើត

ASA ជាគំនិតផ្តួចផ្តើមរបស់លោក Tunku Abdul Rahman នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី។ លោក Rahman បានពិភាក្សាអំពីគំនិតនេះជាមួយប្រធានាធិបតីប្រទេសហ្វីលីពីនគឺលោក Carlos Garcia នៅក្នុងឱកាសនៃការធ្វើទស្សនកិច្ចក្រៅផ្លូវការរបស់លោកនៅប្រទេសហ្វីលីពីន កាលពីខែមករា ឆ្នាំ១៩៥៩។ ឆ្លង តាមកិច្ចពិភាក្សាកាលនោះ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានឯកភាពគ្នាថានឹងខិតខំបញ្ចុះបញ្ចូលប្រទេសជិតខាងខ្លួនឱ្យចុះហត្ថលេខាលើសន្ធិសញ្ញាសេដ្ឋកិច្ច និងមិត្តភាពនៅអាស៊ីអាគ្នេយ៍ ដើម្បីដាក់ចេញនូវគម្រោងសហប្រតិបត្តិការថ្នាក់តំបន់មួយ។ គម្រោងនេះត្រូវបានរដ្ឋមន្ត្រីការបរទេសថៃលោក Thanat Khoman មានការពេញចិត្ត ហើយសំដែង ការគាំទ្រទាំងស្រុង។ ផ្ទុយទៅវិញប្រទេសឥណ្ឌូណេស៊ី មិនត្រឹមតែមិនពេញចិត្តចំពោះគំរោងនេះទេ ហើយថែម ទាំងបដិសេធថា មិនចូលរួមក្នុងសមាគមនេះទៀតផង។

ការដែលប្រទេសឥណ្ឌូណេស៊ីបដិសេធមិនចូលរួមក្នុង ASA ពិតជាមានហេតុផលផ្ទាល់ខ្លួនរបស់គេ។ តាមការវិភាគរបស់អ្នកការទូត និងអ្នកច្បាប់មួយចំនួនបានឱ្យដឹងថា មានហេតុផលបីយ៉ាងដែលនាំឱ្យឥណ្ឌូណេស៊ីឃ្លាតឆ្ងាយពី ASA ៖

**-ភាពដើរបញ្ច្រាស់គ្នាខាងនយោបាយ៖** ព្រោះថាកាលនោះលោក អាម៉េត ស៊ូកាណូ ប្រធានាធិបតីឥណ្ឌូណេស៊ី បានអនុវត្តគោលនយោបាយការបរទេសរបស់ខ្លួនទៅរកពួកកុម្មុយនីស្តចិន និងសហភាពសូវៀត ដែលផ្ទុយពីគោលការណ៍ចំបងរបស់ASA ព្រោះលោកស៊ូកាណូ យល់ឃើញថាគម្រោងASA ដែលបានរៀបចំឡើង មិនមែនដោយសារឆន្ទៈរបស់ប្រទេសក្នុងតំបន់ទេ តែវាជាគំនិតផ្តួចផ្តើមរបស់លោកខាងលិច ក្នុងគោលបំណង ទប់ស្កាត់នូវការរីករាលដាលនៃមនោគមវិជ្ជាកុម្មុយនីស្តក្នុងតំបន់។

**-ឥណ្ឌូណេស៊ីយល់ឃើញថា៖** ខ្លួនមិនបានជួយរួមចំណែកអ្វីជាគំនិតយោបល់ជាមួយ ASA ទាល់តែសោះ ខ្លាច់ក្រែងថ្ងៃក្រោយគេមិនឱ្យខ្លួនមានតួនាទីអ្វីធំដុំនៅក្នុងអង្គការនេះ។

**-ឥណ្ឌូណេស៊ីបានអនុវត្តកលល្បិចហួសពីការទទួលយកបាន៖** ដោយចង់ឱ្យប្រទេសកម្ពុជា និងភូមាចូលរួមក្នុង ASA ដែរ ទោះបីឥណ្ឌូណេស៊ីដឹងរួចជាស្រេចហើយថា កម្ពុជា និងភូមាមិនអាចចូលរួមបានក៏ដោយ ព្រោះកាលនោះ ក្រោយពីទទួលបានឯករាជ្យពីអាណានិគមនិយមបារាំងឆ្នាំ ១៩៥៣ កម្ពុជាបានប្រកាស ខ្លួនឯងថា ជារដ្ឋឯករាជ្យ អព្យាក្រឹត មិនចូលបក្សសម្ពន្ធ រីឯប្រទេសភូមាក៏ដូចគ្នាដែរ ក្រោយពីទទួលបាន ឯករាជ្យឆ្នាំ១៩៤៨ ក៏បានប្រកាន់នូវនយោបាយអព្យាក្រឹតដែរ។

ទោះបីជាយុទ្ធនាការបញ្ចុះបញ្ចូលឥណ្ឌូណេស៊ីត្រូវទទួលបរាជ័យក៏ដោយ ក៏ប្រទេសស្ថាបនិកមិនបោះបង់ចោលនូវគម្រោងការរបស់ពួកគេឡើយ។

ជាក់ស្តែង ASA ត្រូវបានងនុវម័តបង្កើតតាមរយៈសេចក្តីសម្រេចមួយនាកិច្ចប្រជុំរបស់រដ្ឋមន្ត្រីការបរទេសនៃប្រទេសម៉ាឡេស៊ី ថៃ និងហ្វីលីពីន កាលពីថ្ងៃទី ៣១ កក្កដា ឆ្នាំ ១៩៦១ នៅទីក្រុងបាងកក។ ASA ត្រូវបានបង្កើតឡើងដោយមិនចំណុះទៅនឹងប្លុកណាមួយ ហើយក៏មិនប្រឆាំងជាមួយនឹងប្រទេសណាមួយដែរ។

តាំងពីដំបូងមក ASA ទទួលបានការគាំទ្រតិចតួចណាស់ពីសំណាក់បណ្តាប្រទេសក្នុងតំបន់ ព្រោះដោយ គេចាត់ទុកថាជាសមាគមមួយដែលត្រូវបង្កើតឡើងដោយសហរដ្ឋអាម៉េរិក។ តែខុសពីអង្គការដទៃទៀត ដែលល្បីឈ្មោះនៅក្នុងតំបន់នៃទ្វីបអាស៊ី ដូចជា COLOMBO PLAN ឬ SEATO តែ ASA បានបង្កើតឡើង ក្រោមគំនិតផ្តួចផ្តើម និងការប្រឹងប្រែងរបស់ប្រទេសអាស៊ី ដោយផ្ទាល់។

**១.១.២-ទិសដៅ ASA**

ទិសដៅ ASA មានដូចតទៅ៖

១.សហប្រតិបត្តិការ និងជួយគ្នាទៅវិញទៅមករវាងប្រទេសជាសមាជិក នៅក្នុងវិស័យសេដ្ឋកិច្ច សង្គម និងរដ្ឋបាល។

២.បង្កឱ្យមានទំនាក់ទំនងល្អជាមួយនឹងប្រទេស ដែលមានទិសដៅរួម ជាពិសេសបង្កើនការស្វែងយល់ គ្នាទៅវិញទៅមកជាមួយបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ឱ្យបានកាន់តែប្រសើរឡើង។

៣.ជួយគ្នាក្នុងការបង្កើតអ្នកឯកទេស អ្នកបច្ចេកទេសក្នុងជួរពលរដ្ឋប្រទេសជាសមាជិកសមាគម។

៤.បន្លាស់ប្តូរសារព័ត៌មានគ្នាចំពោះបញ្ហាដែលទាក់ទងនឹងផលប្រយោជន៍រួម ទាក់ទងនឹងវិស័យសេដ្ឋកិច្ច និងអភិវឌ្ឍវិស័យវិទ្យាសាស្ត្រនៃប្រទេសជាសមាជិក។

៥.ប្រសិទ្ធភាពក្នុងកិច្ចសហប្រតិបត្តិការ ដើម្បីប្រើប្រាស់សម្បត្តិធម្មជាតិឱ្យបានត្រឹមត្រូវ អភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម ពង្រីកវិស័យពាណិជ្ជកម្ម គមនាគមន៍ និងប្រៃសណីយ៍។

៦.សិក្សាវិះរកមធ្យោបាយដើម្បីស្ថិរភាពតម្លៃផលិតផលកសិកម្មនាំចេញ វត្ថុធាតុដើមនៅលើទីផ្សារអន្តរជាតិ។

៧.បន្លាស់ប្តូរយោបល់គ្នា និងសហប្រតិបត្តិការ ដើម្បីឱ្យមានប្រសិទ្ធភាព ការបំពេញការងាររបស់សមាគម នៅលើវិស័យការបរទេស។

**ដើម្បីបំពេញនូវកម្មវិធីរបស់សមាគមគូភាគីបានស្រុះស្រួលគ្នា**

១.ប្រារព្ធសន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេស ជារៀងរាល់ឆ្នាំដោយប្រកាន់យកកន្លែងតាមលេខរៀងបន្តបន្ទាប់គ្នា។

២.បង្កើតគណៈកម្មការអចិន្ត្រៃយ៍ ដោយអគ្គរដ្ឋទូតនៃប្រទេសជាសមាជិកដើម្បីដឹកនាការងារសមាគម នៅក្នុងចន្លោះពេលរវាងសន្និសីទថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេស។

៣.បង្កើតគណៈកម្មការពិសេស និងអចិន្ត្រៃយ៍នៅក្នុងប្រទេសជាសមាជិកសមាគម និងលេខាជាតិរបស់ ASA។

**១.១.៣-រចនាសម្ព័ន្ធនៃASA**

-ការប្រព្រឹត្តទៅរបស់ ASA គឺតាមរយៈកិច្ចប្រជុំប្រចាំឆ្នាំរបស់រដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងបី មាន ហ្វីលីពីន ថៃ និងម៉ាឡេស៊ី។

-មានគណៈកម្មាធិការអចិន្ត្រៃយ៍សម្រាប់ពិគ្រោះ ពិភាក្សាអំពីនយោបាយរបស់ ASA ក្នុងចន្លោះពេលនៃ កិច្ចប្រជុំរបស់រដ្ឋមន្ត្រីការបរទេសនៃប្រទេសសមាជិកទាំងបី។

-នៅក្នុងប្រទេសជាសមាជិកនីមួយៗ មានលេខាធិការដ្ឋានជាតិមួយដែលមានគណៈកម្មការជំនាញអចិន្ត្រៃយ៍បី សម្រាប់ធ្វើសហប្រតិបត្តិការលើវិស័យស្រាវជ្រាវសេដ្ឋកិច្ច សង្គម វប្បធម៌ និងបច្ចេកទេស។

សរុបសេចក្តីទៅ ASA មានគោលបំណងចូលរួមផ្តល់នូវសុខមាលភាព និងវឌ្ឍនភាពលើវិស័យសេដ្ឋកិច្ច សង្គម និងវប្បធម៌ នៅក្នុងតំបន់តាមរយៈការខិតខំប្រឹងប្រែងរួមរបស់បណ្តាប្រទេសជាសមាជិក។ ក៏ប៉ុន្តែ ASA ពុំមានដំណើរការល្អឡើយ ពោលគឺពុំមានប្រសិទ្ធភាពអ្វីទេ ពីព្រោះបានទទួលការគាំទ្រពី បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍តិចតួចណាស់។ នៅទីបំផុត ASA ត្រូវបញ្ចប់សកម្មភាពរបស់ខ្លួនក្រោយពីការបង្កើតសម្ព័ន្ធរដ្ឋ MAPHILINDO នៅឆ្នាំ ១៩៦៣។

ដូច្នេះអង្គការ ASA បង្កើតឡើង ពុំបានធ្វើឱ្យមានឥទ្ធិពលទៅលើបណ្តាប្រទេសក្នុងប្លុកសេរី ប្លុកសង្គមនិយម និងប្លុកមិនចូលបក្សសម្ព័ន្ធទាំងនោះឡើយ ពោលគឺនយោបាយASA ពុំមានប្រសិទ្ធភាព។

**១.២-សម្ព័ន្ធរដ្ឋ** MAPHILINDO

គាប់ជួនពេលដែល ASA នៅសំងំស្ងៀមគ្មានសកម្មភាពអ្វីទាំងអស់លោក Macapagal ប្រធានាធិបតីហ្វីលីពីន ក៏បានផ្តួចផ្តើមនូវផែនការមួយដែលហៅថា Macapagal Plan គឺក្នុងគោលបំណងបង្រួបបង្រួម សម្ព័ន្ធរដ្ឋមួយឈ្មោះថា MAPHILINDO។ ជាកុសលល្អ គំនិតផ្តួចផ្តើមនេះត្រូវបានគាំទ្រ និងចូលរួមពីសំណាក់ ម៉ាឡេស៊ី និងឥណ្ឌូណេស៊ី។

មិនបង្អង់យូរ ប្រទេសទាំងបីក៏បានកំណត់កិច្ចប្រជុំនៅទីក្រុងម៉ានីល នាខែកក្កដា និងសីហា ឆ្នាំ ១៩៦៣ ដែលកិច្ចប្រជុំនេះ ត្រូវបានចូលរួមពីសំណាក់ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងបី។

ឆ្លងតាមកិច្ចប្រជុំកំពូលនេះ គេឃើញមានសេចក្តីសម្រេចមួយចំនួនត្រូវបានចុះហត្ថលេខា។

-កិច្ចព្រមព្រៀងទីក្រុងម៉ានីលថ្ងៃទី ៣១ កក្កដា ១៩៦៣ (ជាកិច្ចព្រមព្រៀងដែលបង្កើត MAPHILINDO)

-សេចក្តីប្រកាសទីក្រុងម៉ានីល និងសេចក្តីថ្លែងការរួមដែលបានអនុម័តនៅថ្ងៃទី ០៥ សីហា ឆ្នាំ ១៩៦៣។

នៅក្នុងសេចក្តីថ្លែងការណ៍រួមគឺមានចែងថា "មូលដ្ឋានយោធាបរទេសនឹងមិនអាចត្រូវបានប្រើប្រាស់ប្រឆាំងទៅនឹងរដ្ឋណាមួយឡើយ ហើយបើមានគឺត្រូវស្ថិតនៅក្នុងសភាពជាបណ្តោះអាសន្នប៉ុណ្ណោះ។

ដូចនេះហើយ ទើបនៅសម័យនោះលោក Sukarno ប្រធានាធិបតីឥណ្ឌូណេស៊ីបានប្រើប្រាស់គ្រប់មធ្យោបាយបញ្ចុះបញ្ចូលដៃគូរបស់ខ្លួន ដើម្បីធ្វើការបញ្ចេញ នូវបណ្តាមូលដ្ឋានទ័ពអាម៉េរិកចេញពីហ្វីលីពីន។

តែជាការគួរឱ្យសោកស្តាយ MAPHILINDO ដែលត្រូវបានបង្កើតឡើងត្រឹមតែជាងមួយខែប៉ុណ្ណោះ ក៏ត្រូវរលាយទៅវិញជាមួយនឹងជម្លោះធំៗពីរគឺ ប្រទេសហ្វីលីពីនជាមួយម៉ាឡេស៊ី និងម៉ាឡេស៊ី ជាមួយឥណ្ឌូណេស៊ី។

-នៅដំណាច់ឆ្នាំ១៩៦៣ ហ្វីលីពីននិងម៉ាឡេស៊ី បានធ្លាក់ចូលទៅក្នុងជម្លោះមួយគឺការដណ្តើមកោះ Sabahគ្នា។ សូមបញ្ជាក់ថាកោះ Sabah ជាដែនដីផ្នែកឥសាននៃកោះ Borneo ដែលស្ថិតនៅក្រោមអាណានិគមរបស់អង់គ្លេសតាំងពីឆ្នាំ១៨៧៧ ដល់ឆ្នាំ១៩៦៣។

នៅពេលនោះទំនាក់ទំនងរវាងប្រទេសទាំងពីរកាន់តែអាក្រក់ឡើង រហូតដល់ការដកស្ថានទូតចេញពីគ្នារៀងខ្លួន ក្នុងបំណងផ្តាច់ទំនាក់ទំនងការទូតទាំងស្រុង។

-បន្ទាប់ពីការប្រកាសរបស់ប្រទេសម៉ាឡេស៊ីទៅជាសហព័ន្ធមក ម៉ាឡេស៊ីនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ១៩៦៣ ត្រូវប្រឈមមុខម្តងទៀតជាមួយឥណ្ឌូណេស៊ី ដោយឥណ្ឌូណេស៊ីទាមទារតំបន់ Sarawak ពីម៉ាឡេស៊ី។ នៅទីបំផុត ទំនាក់ទំនងរវាងប្រទេសទាំងពីរក៏ត្រូវបានកាត់ផ្តាច់ទាំងស្រុងផងដែរ។

## ១.៣-បណ្តាអង្គការដែលមិនមែនជាបុព្វដើមរបស់អាស៊ាន

អ្នកខ្លះតែងពោលដោយយល់ច្រឡំថា SEATO និង ASPAC ជាប្រភពដើមរបស់អាស៊ានផងដែរ។ ដូច្នេះយើងគួរតែពិនិត្យមើលឱ្យបានច្បាស់ជាមុនសិន៖

### ១.៣.១- SEATO ( South East Asian Treaty Organization )

អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ ត្រូវបានបង្កើតឡើងនៅថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ១៩៥៤ ក្រោមឥទ្ធិពលរបស់សហរដ្ឋអាម៉េរិក តាមរយៈការចុះហត្ថលេខាលើសន្ធិសញ្ញានៃការការពាររួមនៅទីក្រុង ម៉ានីល ប្រទេសហ្វីលីពីន។

នៅពេលនោះគេឃើញមានប្រទេសហត្ថលេខីចំនួន៨ គឺថៃ ហ្វីលីពីនប៉ាគីស្ថាន បារាំង អង់គ្លេស សហរដ្ឋអាម៉េរិក អូស្ត្រាលី និងណូវែលហ្សេឡង់។

តាមអ្នកវិភាគរបស់អ្នកជំនាញការច្បាប់បានឱ្យដឹងថា SEATO គឺជាអង្គការមួយដែលមានសមត្ថកិច្ចដែនដីនៅអាស៊ីមែន ប៉ុន្តែការពិតអង្គការនេះត្រូវបានបង្កើតឡើងដោយមហាអំណាចក្រៅទ្វីប ដូចនេះ ភូមិសាស្ត្រនេះ ដើរតួតែសំបកក្រៅប៉ុណ្ណោះ។ ការពិតវាជាអង្គការមួយដែលតំណាងឱ្យសាមគ្គីភាពខាង នយោបាយ ដែលទប់ទល់ប្រឆាំងនឹងការរីសាយរបស់ប្លុកកុម្មុយនីស្តតែប៉ុណ្ណោះ។

ម្យ៉ាងទៀតគោលបំណងរបស់អង្គការនេះគឺអនុញ្ញាតឱ្យសហរដ្ឋអាម៉េរិក និងសម្ពន្ធមិត្តរបស់គេតាមរយៈយន្តការ នៃការធ្វើអន្តរាគមន៍ខាងផ្នែកយោធាដរាបណាមានការចូលលុកលុយរបស់ពួកកុម្មុយនីស្ត។

មាត្រា៤នៃសន្ធិសញ្ញា SEATO បានចែងថា ក្នុងករណីដែលមានការឈ្លានពានខាងយោធាទៅលើតំបន់ ដែលគ្របដណ្តប់ដោយ SEATO មហាអំណាចហត្ថលេខីនឹងធ្វើសកម្មភាពតបវិញ ទៅតាមវិធានការទាំងឡាយ ដែលមានចែងក្នុងសន្ធិសញ្ញានេះ។ មិនតែប៉ុណ្ណោះនៅមានសេចក្តីប្រកាសពិសេសមួយទៀតដែលសហរដ្ឋអាម៉េរិកសន្យាធ្វើអន្តរាគមន៍ដោយផ្ទាល់ក្នុងជម្លោះ បើសិនជាមានការឈ្លានពានពីពួកកុម្មុយនីស្ត។

លើសពីនេះទៀតអង្គការ SEATO នៅមានគោលបំណងបន្ទាប់បន្សំទៀតគឺការចូលរួមអភិវឌ្ឍន៍ និងផ្តល់ជំនួយខាងផ្នែកបច្ចេកទេសផងដែរ ព្រោះកាលនោះគេឃើញមានសាលាបណ្តុះបណ្តាលវិស្វករ របស់ SEATO ឈ្មោះវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី។

តែអង្គការនេះពុំបានសម្រេចគោលបំណងរបស់ខ្លួនទេ គឺត្រូវរលាយទៅវិញនៅឆ្នាំ១៩៧៧ ព្រោះ ចក្រភពអង់គ្លេស និងអាម៉េរិក មិនបានគោរពខ្ជាប់ខ្ជួនតាមគោលការណ៍ទាំងឡាយដែលមានចែងក្នុងសន្ធិសញ្ញានេះ។

**១.៣.២-ក្រុមប្រឹក្សាអាស៊ី និងប៉ាស៊ីហ្វិក** (Asia Pacific council/ ASPAC)

ក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើងនៅខែមិថុនា ឆ្នាំ១៩៦៦ ដែលមានសមាជិកចំនួន៩គឺ

- ប្រទេសបី នៅអាស៊ី ៖ ជប៉ុន កូរ៉េខាងត្បូង និងចិន
- ប្រទេសបួន នៅអាស៊ីអាគ្នេយ៍៖ ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាមខាងត្បូង
- ប្រទេសពីរ នៅប៉ាស៊ីហ្វិក៖ ណូវែលហ្សេឡង់ និងអូស្ត្រាលី

គោលបំណងរបស់ក្រុមប្រឹក្សានេះគឺចូលរួមសហប្រតិបត្តិការ ដើម្បីសន្តិភាព និងជំរុញឱ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងបច្ចេកទេស។

ប៉ុន្តែបន្ទាប់ពីគ្មានសកម្មភាព ដោយសារមិនសូវមានការចូលរួមពីសំណាក់ប្រទេសចិន និង បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ ក្រុមប្រឹក្សានេះត្រូវបានរំលាយតាមរយៈកិច្ចប្រជុំ ឆ្នាំ១៩៧២។

ហេតុផលដែលបញ្ជាក់ថា SEATO និង ASPAC មិនមែនជាបុព្វរបស់អាស៊ានគឺ៖

-សមាជិកនៃអង្គការទាំងពីរនេះ ច្រើនមកពីក្រៅតំបន់

-អង្គការទាំងពីរនេះ នៅបន្តដំណើរការរបស់ខ្លួននៅឡើយ ក្នុងពេលដែលសមាគមអាស៊ានត្រូវបានបង្កើតឡើង។

## ២-បុព្វហេតុនៃការបង្កើតអាស៊ាន

បុព្វហេតុនៃការបង្កើតសមាគមអាស៊ានមានពីរសំខាន់គឺ បុព្វហេតុសេដ្ឋកិច្ច និងបុព្វហេតុនយោបាយ។ ប៉ុន្តែអាស៊ានបានបង្ហាញបុព្វហេតុជាផ្លូវការរបស់ខ្លួន គឺផ្នែកសេដ្ឋកិច្ច។ ទន្ទឹមនឹងនេះដែរបុព្វហេតុដ៏សំខាន់មួយ ទៀតនៅពេលនោះដែរគឺបុព្វហេតុនយោបាយ។

### ២.១.១-បុព្វហេតុសេដ្ឋកិច្ច

-ដំណើរអភិវឌ្ឍសេដ្ឋកិច្ច កំពុងតែធ្វើដំណើរយ៉ាងលឿនឆ្ពោះទៅមជ្ឈិមបូព៌ា។

-ប្រទេសអឺរ៉ុប គេមានសមាគមសេដ្ឋកិច្ចអឺរ៉ុប ដែលជាទីផ្សាររួមដ៏សំខាន់ តាំងពីឆ្នាំ១៩៥១មកម្ល៉េះ។

-ប្រមូលផ្តុំទីផ្សារអាស៊ីអាគ្នេយ៍ ដើម្បីការអភិវឌ្ឍរួម និងការប្រកួតប្រជែងលើទីផ្សារអន្តរជាតិផងដែរ។

### ២.១.២-បុព្វហេតុនយោបាយ

-មានការប្រឈមមុខដាក់គ្នារវាងប្លុកសេរី និងប្លុកសង្គមនិយម

-មនោគមវិជ្ជាកុម្មុយនីស្តរាលដាលយ៉ាងខ្លាំង ជាពិសេសនៅអាស៊ី

-រួបរួមគ្នាជាសមាគមដើម្បីការពារខ្លួនផង និងដើម្បីទប់ស្កាត់ការរាលដាលនៃលទ្ធិកុម្មុយនីស្តនៅក្នុងតំបន់ផង។

## ៣-កំណើតអាស៊ាន

អាស៊ានត្រូវបានចុះហត្ថលេខា បង្កើតឡើងដោយប្រទេស៥ នៅទីក្រុងបាងកកដែលរួមមានប្រទេស ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧។ ប្រទេសដែលបានចូលជាសមាជិកថ្មីនៃអាស៊ានជាបន្តបន្ទាប់មាន៖

- រាជាណាចក្រព្រុយណេដារូសាឡឹមសមាជិកទី៦ ចូលថ្ងៃទី៨ ខែមករា ឆ្នាំ ១៩៨៤។
- សាធារណរដ្ឋសង្គមនិយមវៀតណាមជាសមាជិកទី៧ ចូលថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៥។
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវជាសមាជិកទី៨ ចូលថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ១៩៩៧។
- សហភាពមីយ៉ាន់ម៉ាជាសមាជិកទី៩ ចូលនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៧។
- ព្រះរាជាណាចក្រកម្ពុជាជាសមាជិកទី១០ ចូលនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។
- សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត ចូលនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។

### ៣.១-គោលបំណងអាស៊ាន

គោលដៅបង្កើតអាស៊ានគឺ៖

- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងការអភិវឌ្ឍវប្បធម៌ក្នុងតំបន់ ដោយឈរលើស្មារតីស្មើភាព និងសមភាគី
- ជំរុញឱ្យមានស្ថិរភាព និងសន្តិសុខក្នុងតំបន់តាមរយៈការគោរពដ៏ខ្ជាប់ខ្ជួននូវយុត្តិធម៌ និងគោលការណ៍ច្បាប់ទាំងឡាយក្នុងទំនាក់ទំនងរវាងប្រទេសក្នុងតំបន់ និងប្រកាន់ខ្ជាប់នូវធម្មនុញ្ញសហប្រជាជាតិ
- ជំរុញកិច្ចសហការ និងជួយគ្នាទៅវិញទៅមកលើការងារជាផលប្រយោជន៍រួមក្នុងវិស័យសេដ្ឋកិច្ច វប្បធម៌ បច្ចេកទេស វិទ្យាសាស្ត្រ និងរដ្ឋបាល
- ជួយគ្នាទៅវិញទៅមកតាមរូបភាពផ្តល់សម្ភារបរិក្ខាសម្រាប់បណ្តុះបណ្តាល និងស្រាវជ្រាវក្នុងវិស័យអប់រំ វិជ្ជាជីវៈ បច្ចេកទេស និងរដ្ឋបាល
- សហការគ្នាឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីប្រើប្រាស់លើវិស័យកសិកម្ម និងឧស្សាហកម្មឱ្យបានច្រើន ដើម្បីពង្រីកពាណិជ្ជកម្ម រួមមានការសិក្សាអំពីពាណិជ្ជកម្មអន្តរជាតិលើមុខទំនិញប្រើប្រាស់ ការកែលម្អមធ្យោបាយដឹកជញ្ជូន និងគមនាគមន៍ និងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ
- ជំរុញឱ្យមានការសិក្សាពីតំបន់អាស៊ីអាគ្នេយ៍
- រក្សាកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងមានផលប្រយោជន៍ជាមួយអង្គការអន្តរជាតិនានា និងអង្គការក្នុងតំបន់ដែលមានស្រាប់។

**បើយោងតាមធម្មនុញ្ញរបស់អាស៊ាន បានកំណត់នូវគោលបំណងជាច្រើនដូចខាងក្រោម៖**

១.រក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាព និងពង្រឹងថែមទៀតនូវតម្លៃឆ្ពោះទៅរក សន្តិភាពក្នុងតំបន់។

២.លើកកម្ពស់ភាពរឹងមាំនៃតំបន់ តាមរយៈការជំរុញកាន់តែខ្លាំងថែមទៀតនូវសហប្រតិបត្តិការផ្នែកនយោបាយ-សន្តិសុខ សេដ្ឋកិច្ច និងសង្គម-វប្បធម៌។

៣.រក្សាតំបន់អាស៊ីអាគ្នេយ៍ ជាតំបន់គ្មានអាវុធនុយក្លេអែរ និងគ្មានអាវុធប្រល័យលោកផ្សេងទៀត។

៤.ធានាថា ប្រជាជន និងរដ្ឋសមាជិកអាស៊ានរស់នៅប្រកបដោយសន្តិភាពជាមួយពិភពលោកទាំងមូលក្នុងបរិយាកាសយុត្តិធម៌ ប្រជាធិបតេយ្យ និងភាពសុខដុមរមនា។

៥.បង្កើតទីផ្សាររួមមួយ និងមូលដ្ឋានផលិតកម្មរួម ដែលមានស្ថិរភាព វិបុលភាព មានការប្រកួតប្រជែងខ្ពស់ និងសមាហរណកម្មសេដ្ឋកិច្ច ជាមួយនឹងការសម្របសម្រួលដ៏មានប្រសិទ្ធភាពសម្រាប់ ពាណិជ្ជកម្ម និងការវិនិយោគ ដែលក្នុងនោះមានលំហូរដោយសេរីនូវទំនិញ សេវាកម្ម និងវិនិយោគ សម្រួលចលនាពាណិជ្ជកម្ម ង្នកមានវិជ្ជាជីវៈ អ្នកមានទេពកោសល្យ និងពលករ។

៦.កាត់បន្ថយភាពក្រីក្រ និងបង្រួមគម្លាតនៃការអភិវឌ្ឍនៅក្នុងតំបន់អាស៊ាន តាមរយៈការជួយគ្នា ទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ។

៧.ពង្រឹងលទ្ធិប្រជាធិបតេយ្យ លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ ការពារ និងលើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដោយយកចិត្តទុកដាក់ចំពោះសិទ្ធិ និងការទទួលខុសត្រូវរបស់ រដ្ឋសមាជិក អាស៊ាន។

៨.ឆ្លើយតបយ៉ាងមានប្រសិទ្ធភាព ទៅតាមគោលការណ៍នៃសន្តិសុខពេញលេញ ចំពោះការគំរាមកំហែង គ្រប់រូបភាព ឧក្រិដ្ឋកម្មឆ្លងដែន និងបញ្ហាប្រឈមឆ្លងដែននានា។

៩.លើកស្ទួយការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដើម្បីធានាការការពារបរិស្ថានតំបន់ និរន្តរភាព នៃធនធានធម្មជាតិ និងការអភិរក្សមរតកវប្បធម៌ និងគុណភាពនៃជីវភាពរស់នៅខ្ពស់របស់ប្រជាជន។

១០.អភិវឌ្ឍធនធានមនុស្ស តាមរយៈកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ក្នុងការអប់រំ និងការសិក្សា ក្នុងមួយជីវិត និងលើផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីផ្តល់ជូនប្រជាជនអាស៊ាន និងការពង្រឹងសមាគម អាស៊ាន។

១១.លើកកម្ពស់ភាពសុខដុមរមនា និងជីវភាពរស់នៅរបស់ប្រជាជនអាស៊ាន ដោយការផ្តល់ឱ្យនូវលទ្ធភាពទទួលបានសមភាព ក្នុងការអភិវឌ្ឍមនុស្ស សុខុមាលភាពសង្គម និងយុត្តិធម៌។

១២.ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការកសាងបរិស្ថានប្រកបដោយសុវត្ថិភាព សន្តិសុខ និងភាពគ្មានគ្រឿងញៀនសម្រាប់ប្រជាជនអាស៊ាន។

១៣.ជំរុញការយកចិត្តទុកដាក់ដល់ប្រជាជនអាស៊ាន ក្នុងនោះគ្រប់ផ្នែកទាំងអស់នៃសង្គមត្រូវបាន លើកទឹកចិត្តឱ្យចូលរួម និងទទួលយកផលប្រយោជន៍ពីដំណើរការសមាហរណកម្ម និងការកសាងសហគមន៍អាស៊ាន។

១៤.ជំរុញអត្តសញ្ញាណអាស៊ាន តាមរយៈការជំរុញឱ្យរីកចម្រើនឡើងនូវការយល់ដឹងអំពីវប្បធម៌ និងមរតកចម្រុះក្នុងតំបន់ និង...

១៥.ថែរក្សាតួនាទីស្នូលដ៏សកម្មរបស់អាស៊ាន ជាកម្លាំងចលករដ៏សំខាន់ ក្នុងទំនាក់ទំនង និង សហប្រតិបត្តិការរបស់ខ្លួនជាមួយដៃគូក្រៅតំបន់ ក្នុងស្ថាបត្យកម្មតំបន់ប្រកបដោយភាពបើកចំហ តម្លាភាព និងការរួមបញ្ចូលគ្នា។

## ៣.២-គោលការណ៍នានា

អាស៊ានបានចេញគោលការណ៍ជាច្រើនទៀត បន្ទាប់ពី ឆ្នាំ១៩៦៧មក៖

### ៣.២.១-ការបង្កើតតំបន់សន្តិភាព សេរីភាព និង អព្យាក្រឹតភាព

ZOPFAN: Zone of Peace, Freedom and Neutrality

នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧១ ZOPFAN ត្រូវបានបង្កើតឡើងនៅទីក្រុងកូឡាឡាំពួ។

- សមាជិកអាស៊ានប្ដេជ្ញា ខិតខំរក្សាតំបន់អាស៊ីអាគ្នេយ៍ ឱ្យទៅជាតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹតភាព មិនស្ថិតនៅក្រោមអន្តរាគមន៍នៃមហាអំណាចបរទេសឡើយ។
- សមាជិកអាស៊ានខិតខំបង្កើនសហប្រតិបត្តិការឱ្យកាន់តែទូលាយ ដោយពង្រឹងសាមគ្គីភាព និងមិត្តភាពរវាងគ្នា នឹងគ្នា។
- បំណងបន្ធូរភាពតានតឹងអន្តរជាតិ និងធ្វើឱ្យសម្រេចបានសន្តិភាពដ៏យូរអង្វែងមួយនៅអាស៊ីអាគ្នេយ៍។
- គោរពបូរណភាពដែនដីរបស់រដ្ឋដទៃទៀត ដោះស្រាយដោយសន្តិវិធីរាល់ទំនាស់ជាអន្តរជាតិនានាដោយឈរលើភាពស្មើគ្នា ប្រើសិទ្ធិស្វ័យសម្រេច ដោយមិនជ្រៀតជ្រែកលើកិច្ចការផ្ទៃក្នុងរបស់រដ្ឋណា មួយ។

### ៣.២.២-ការបង្កើត សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការ

TAC: Treaty of Amity and Cooperation

ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការ បានត្រូវចុះហត្ថលេខា ក្រោយពេលដែលឥណ្ឌូចិនទាំងមូល ធ្លាក់ក្រោមការដឹងនាំរបស់ពួកកុំមុយនីស។ គោលដៅនៃសន្ធិសញ្ញានេះ គឺដើម្បីរក្សាសន្តិភាព មិត្តភាពយឺនយូរ និងសហប្រតិបត្តិការដ៏ល្អប្រពៃ រវាងប្រជាជននៅក្នុងរង្វង់អាស៊ានដែលនាំទៅដល់សុពលភាព សាមគ្គីភាពរវាងគ្នា និងគ្នា។ ក្នុងទំនាក់ទំនងរវាងគ្នា និងគ្នា សមាជិកអាស៊ាន មានគោលការណ៍ដូចតទៅៈ

- គោរពគ្នាទៅវិញទៅមកលើឯករាជ្យ អធិបតីភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិនៃបណ្ដាប្រទេសទាំងអស់។
- គោរពសិទ្ធិរបស់រដ្ឋនីមួយៗ ក្នុងដំនឹកនាំប្រទេសខ្លួនឱ្យចៀសផុតពីការជ្រៀតជ្រែកពីក្រៅ។
- មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក។
- ដោះស្រាយរាល់ទំនាក់ទំនងនានាតាមមធ្យោបាយសន្តិវិធី។
- ប្រឆាំងចំពោះការគំរាម ប្រើកម្លាំងទ័ព។
- រួមសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងគ្នា និងគ្នា។
- ធ្វើឱ្យតំបន់អាស៊ីអាគ្នេយ៍ គ្មានអាវុធនុយក្លេអ៊ែ។

**ជារួមមកប្រទេសជាសមាជិកអាស៊ាន ត្រូវគោរពនូវគោលការណ៍នានារបស់ខ្លួនដែលមានចែងជាបន្តបន្ទាប់នៅក្នុងកិច្ចព្រមព្រៀង និងសន្ធិសញ្ញានានា ហើយធម្មនុញ្ញអាស៊ានបានកំណត់នូវគោលការណ៍ជាច្រើនដូចខាងក្រោមៈ**

ក.គោរពឯករាជ្យភាព អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិ នៃរដ្ឋសមាជិកអាស៊ានទាំងអស់។

ខ.ចូលរួមការប្ដេជ្ញាចិត្ត និងការទទួលខុសត្រូវរួមគ្នា ក្នុងការលើកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់។

គ.បដិសេធនូវអំពើឈ្លានពាន និងការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង ឬសកម្មភាពទាំងឡាយណាក្នុងលក្ខណៈដែលមិនសមស្របតាមច្បាប់អន្តរជាតិ។

ឃ.ប្រកាន់យកដំណោះស្រាយជម្លោះដោយសន្តិវិធី។

ង.មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃរដ្ឋជាសមាជិកអាស៊ាន។

ច.គោរពសិទ្ធិរបស់រដ្ឋសមាជិកនីមួយៗ ក្នុងការដឹកនាំអត្តិភាពជាតិរបស់ខ្លួន ដោយពុំមានការជ្រៀតជ្រែកពីខាងក្រៅ ការធ្វើវិទ្ធង្សនា និងការបង្ខិតបង្ខំ។

ឆ.លើកកម្ពស់ការពិគ្រោះយោបល់លើបញ្ហាធ្ងន់ធ្ងរទាំងឡាយ ដែលមានឥទ្ធិពលប៉ះពាល់ដល់ ផលប្រយោជន៍រួមរបស់អាស៊ាន។

ជ.ប្រកាន់ភ្ជាប់នូវនីតិរដ្ឋអភិបាលកិច្ចល្អ គោលការណ៍ប្រជាធិបតេយ្យ និងរដ្ឋាភិបាល អាស្រ័យដោយរដ្ឋធម្មនុញ្ញ។

ឈ.គោរពសេរីភាពជាមូលដ្ឋាន លើកស្ទួយ និងការពារសិទ្ធិមនុស្ស និងលើកកម្ពស់យុត្តិធម៌សង្គម

ញ.លើកកម្ពស់ធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌ អន្តរជាតិនានាដែលរដ្ឋសមាជិកអាស៊ានទាំងអស់បានយល់ព្រម។

ដ.មិនចូលរួមក្នុងគោលនយោបាយ ឬសកម្មភាពណាមួយ ដែលរួមមានការដាក់ឱ្យប្រើប្រាស់នូវទឹកដីរបស់ខ្លួនឱ្យរដ្ឋសមាជិកអាស៊ាន ឬរដ្ឋមិនមែនជាសមាជិកអាស៊ាន ឬឱ្យតួអង្គដទៃទៀតដែលពុំមែនជារដ្ឋ គំរាមកំហែងដល់អធិបតេយ្យភាព បូរណភាពទឹកដី ឬ ស្ថិរភាពសេដ្ឋកិច្ច និងនយោបាយរបស់រដ្ឋ សមាជិកអាស៊ាន។

ឋ.គោរពវប្បធម៌ផ្សេងៗគ្នា ភាសា និងសាសនារបស់ប្រជាជនអាស៊ាន ដោយសង្កត់ធ្ងន់ទៅលើ តម្លៃរួមក្នុងស្មារតី ភាពឯកភាពក្នុងពហុភាព។

ឌ.ភាពជាស្នូលរបស់អាស៊ាន ក្នុងទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ក្រៅតំបន់ដោយរក្សាការចូលរួមដ៏សកម្ម ការសម្លឹងមើលឆ្ពោះទៅខាងក្រៅភាពរួម បញ្ចូលគ្នា និងភាពមិនរើសអើង និង

ធ.ប្រកាន់ភ្ជាប់នូវវិធានពាណិជ្ជកម្មពហុភាគី និងរបបផ្អែកលើមូលដ្ឋានច្បាប់របស់អាស៊ាន ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកិច្ចខិតខំប្រឹងប្រែងផ្នែកសេដ្ឋកិច្ច និងកាត់បន្ថយជាវិជ្ជមានឆ្ពោះទៅលុបបំបាត់របាំងទាំងស្រុង សម្រាប់សមាហរណកម្មសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចទីផ្សារ។

## ៤-ដំណើរការវិវត្តនៃអាស៊ាន

គេអាចបែងចែកការវិវត្តនៃអាស៊ានជា២ដំណាក់កាលគឺ៖

### ៤.១-ដំណាក់កាលទី១

ជាដំណាក់កាលមួយនៃការរីកចម្រើនរបស់ប្រទេសអាស៊ាន ដែលមានទិសដៅបែបផែនផលិតកម្មមូលធននិយម មានទំនោរទៅរកប្រទេសលោកខាងលិចនៅក្នុងវិស័យទំនាក់ទំនងអន្តរជាតិ។ ដំណាក់កាលនេះយើងអាចកំណត់ការចាប់ផ្តើមនៅពេលដែលសមាគមនេះទើបតែចាប់បដិសន្ធិឡើងនៅឆ្នាំ១៩៦៧ រហូតដល់ដំណាក់កាលចុងក្រោយនៃសង្គ្រាមត្រជាក់ និងដំណោះស្រាយបញ្ហាជម្លោះកម្ពុជា។ ក្នុងរយៈពេល២៥ឆ្នាំនៃដំណាកកាលនេះ គឺមានតែប្រទេសព្រុយណេមួយគត់ដែលចូលជាសមាជិកថ្មីរបស់សមាគមនេះ។

### ៤.២-ដំណាក់កាលទី២

ក្រោយសង្គ្រាមត្រជាក់ អាស៊ានបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចសហប្រតិបត្តិការពង្រឹង វិស័យសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច និងសន្តិសុខនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិច។ នៅក្នុងដំណាក់កាលនេះផងដែរអាស៊ានបានសម្រេចក្តីសុបិនរបស់ខ្លួន គឺប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំង ១០ បានចូលជាសមាជិកជាបន្តបន្ទាប់។

## ៥-លក្ខខណ្ឌសម្រាប់សមាជិកភាពក្នុងអាស៊ាន

ដើម្បីបានក្លាយជាសមាជិកអាស៊ានប្រទេសនានាត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន ដូចខាងក្រោម៖

១-នីតិវិធីនៃការដាក់ពាក្យ និងការទទួលជាសមាជិកអាស៊ានត្រូវបញ្ញត្តិដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន។

២-ការទទួលយកសមាជិកថ្មីត្រូវផ្អែកទៅលើលក្ខណៈវិនិច្ឆ័យសំខាងក្រោមៈ

ក.ទីតាំងភូមិសាស្ត្រដែលត្រូវបានទទួលស្គាល់ថា ស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍

ខ.មានការទទួលស្គាល់ពីបណ្ដារដ្ឋជាសមាជិកអាស៊ានទាំងអស់

គ.ឯកភាពគោរព និងប្រតិបត្តិតាមធម្មនុញ្ញអាស៊ាន និង

ឃ.មានលទ្ធភាព និងឆន្ទៈអនុវត្តនូវកាតព្វកិច្ចទាំងអស់នៃសមាជិកភាព។

៣-ការទទួលយកជាសមាជិកដីត្រូវសម្រេចដោយកុងសង់ស៊ីសនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន បន្ទាប់ពីបានទទួលអនុសាសន៍ពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន។

៤-រដ្ឋស្នើសុំនឹងទទួលបានសមាជិកភាព បន្ទាប់ពីការចុះហត្ថលេខាលើលិខិតូបករណ៍នៃការយល់ព្រមចំពោះធម្មនុញ្ញអាស៊ាននេះ។

## ៦-អត្ថន័យទង់អាស៊ាន

សមាគមនេះ មាននិមិត្តសញ្ញាទៅតាមលក្ខណៈនៃប្រទេសក្នុងតំបន់ដែលមានអត្ថន័យ និងខ្លឹមសារដូចខាងក្រោមៈ

- និមិត្តសញ្ញាសមាគមអាស៊ានមាន៤ពណ៌គឺ
  - ពណ៌ខៀវតំណាងឱ្យសន្តិភាព និងស្ថិរភាព
  - ពណ៌ក្រហមតំណាងឱ្យសេចក្ដីក្លាហាន និងភាពស្វាហាប់
  - ពណ៌សតំណាងឱ្យភាពបរិសុទ្ធ
  - ពណ៌លឿងតំណាងឱ្យវិបុលភាព និងភាពសំបូររុងរឿង។
- ដើមស្រូវទាំង១០តំណាងឱ្យបិតាបង្កើតអាស៊ានដែលមានបំណងប្រមូលផ្ដុំប្រទេសទាំងដប់នៅអាស៊ីអាគ្នេយ៍ ឱ្យក្លាយជាសមាគមដែលប្រកបដោយមិត្តភាព និងសាមគ្គីភាព។
- រង្វង់ព័ទ្ធជុំវិញ តំណាងឱ្យឯកភាពគ្នារបស់អាស៊ាន។
- ទង់អាស៊ាន តំណាងឱ្យសមាគមអាស៊ានមួយដែលមានស្ថិរភាព សន្តិភាព រួបរួមគ្នា និងប្រកបដោយថាមពល។
- ពណ៌ទាំងអស់របស់ទង់អាស៊ាន តំណាងឱ្យពណ៌សំខាន់ៗនៃទង់ជាតិរបស់ប្រទេសជាសមាជិកនីមួយៗ

## សំណួរត្រិះរិះ

១-តើមុនការបង្កើតអាស៊ានឡើង នៅក្នុងតំបន់អាស៊ីអាគ្នេយ៍បានកើតឡើងនូវអង្គការអ្វីខ្លះ ?

២-តើអាស៊ានត្រូវបានបង្កើតឡើងក្នុងគោលបំណងអ្វីខ្លះ ?

៣-តើអាស៊ានត្រូវបានបង្កើតឡើងនៅថ្ងៃខែឆ្នាំណា ? ប្រទេសណាខ្លះជាបិតាស្ថាបនិក ?

៤-តើអាស៊ានមានគោលការណ៍ដូចម្ដេចខ្លះ ?

៥-ចូររៀបអំពីលក្ខខណ្ឌសម្រាប់ចូលជាសមាជិកអាស៊ាន។

៦-តើការចូលជាសមាជិកអាស៊ានផ្ដល់លទ្ធផលដូចម្ដេចខ្លះចំពោះកម្ពុជា ?

# មេរៀនទី៦ អាស៊ាន និងសកលភាវូបនីយកម្ម

## ១-អាស៊ានក្នុងបរិបទសង្គ្រាមត្រជាក់

-ដំណាក់កាលទី១ ៖ ជាដំណាក់កាលមួយនៃការរីកចម្រើនរបស់អាស៊ាន ដែលមានទិសដៅបែបផែនផលិតកម្មមូលធននិយម មានទំនោរទៅរកប្រទេសលោកខាងលិច នៅក្នុងវិស័យទំនាក់ទំនងអន្តរជាតិ។ ដំណាក់កាលនេះយើងអាចកំណត់ការចាប់ផ្តើម នៅពេលដែលសមាគមទើបតែចាប់បដិសន្ធិឡើងនៅឆ្នាំ១៩៦៧ រហូតដល់ដំណាក់កាលចុងបញ្ចប់នៃសង្គ្រាមត្រជាក់ និងដំណោះស្រាយបញ្ហាកម្ពុជា។ ជាការពិតណាស់ក្នុងរយៈជាងពីរទសវត្សរ៍នេះ មានតែប្រទេសប្រ៊ុយណេ មួយគត់ ដែលចូលជាសមាជិកថ្មីរបស់សមាគម។

-ដំណាក់កាលទី២ ៖ ក្រោយសង្គ្រាមត្រជាក់អាស៊ានបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងកិច្ចសហប្រតិបត្តិការ ពង្រឹងសេដ្ឋកិច្ច ក្នុងតំបន់ និងតំបន់អាស៊ីប៉ាស៊ីហ្វិច។ សមាគមបានបង្រួបបង្រួមប្រទេសទាំង១០ នៅភូមិភាគអាស៊ី អាគ្នេយ៍ ប្រកបដោយជោគជ័យ។

ដំណើរសមាសហរណកម្មនៅក្នុងដំណាក់កាលទី១ មានទិសដៅដឹកនាំមាគ៌ានយោបាយ ដែលមានទំនាក់ទំនងនឹងប្រទេសខាងក្រៅដើម្បីជួយធ្វើអន្តរាគមន៍ទំនាស់ក្នុងតំបន់ ជាពិសេសទប់ទល់នឹងមនោគមន៍វិជ្ជាកុម្មុយនីស្ត។ ថ្វីត្បិតតែអាស៊ានមានមនោគមន៍វិជ្ជាប្រឆាំងកុម្មុយនីស្ត ប៉ុន្តែអាស៊ានក៏ជាសមាគមទី១នៅទ្វីបអាស៊ី ដែលមានសេរីភាពក្នុងការសម្រេចចិត្ត ចូលរួមទៅក្នុងរចនាសម្ពន្ធប្រទេសមហាអំណាចចក្រពត្តិនិយម។

ឯកសារទី១ គឺសេចក្តីថ្លែងការណ៍រួមរបស់អាស៊ាន បានត្រូវលេចរូបរាងឡើងនៅលើឆាកអន្តរជាតិ ក្នុងនាមជាសមាគមនៅក្នុងតំបន់ ត្រូវបានអនុម័តនៅថ្ងៃទី៨ សីហា ១៩៦៧ ក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេសនៃប្រទេស ៥ក្នុងភូមិភាគអាស៊ីអាគ្នេយ៍ (ថៃ ឥណ្ឌូណេស៊ី ហ្វីលីពីន ម៉ាឡេស៊ី និងសិង្ហបុរី)។

នៅក្នុងសេចក្តីប្រកាសរួមលើកទី១នេះ គេបានបង្កើតស្ថាប័នដឹកនាំសមាគម។ ស្ថាប័នសំខាន់បំផុត គឺសន្និសីទថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសជាសមាជិកអាស៊ាន ដែលប្រារព្ធឡើងមិនឱ្យតិចជាងមួយដងឡើយក្នុងមួយឆ្នាំ។ នៅក្នុងសន្និសីទគេត្រូវពិភាក្សាអំពីបញ្ហាដំណើរការនៃសមាគម និងបញ្ហាទទួលយកសមាជិកថ្មី។

ការបង្កើតអាស៊ានមានទិសដៅដើម្បីបង្វែរពាល់ដំណោះស្រាយទំនាស់នៅក្នុងតំបន់ ឱ្យឆ្លងកាត់ការពិភាក្សាជុំវិញតុមូល។ ក្នុងស្ថានភាពមួយដែលបានកើតឡើង ទាក់ទងទៅនឹងបញ្ហាទំនាស់ទិសដៅនយោបាយរបស់សមាជិក អាស៊ាន បានកើតឡើងនូវទស្សនៈជាតិនិយម ដែលមិនងាយនឹងស្វែងរកការយោគយល់គ្នាបាន ហើយមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការសម្រេចចិត្តលើបញ្ហាផ្សេងៗ នៅក្នុងសមាគម។ គេបានលើកបងា **ឯកភាពមួយក្នុងរូបភាពច្រើន** ដែលជាគោលដៅសម្របសម្រួលនៅក្នុងជួរសមាជិកអាស៊ាន។ គេបានធ្វើពិធីសារដែលមានដូចតទៅ៖ **ពិគ្រោះយោបល់ សហប្រតិបត្តិការ អប់រំឱ្យមានជំនឿទុកចិត្ត គ្រប់គ្រងស្ថានភាពទំនាស់តឹងតែង មិនលូកដៃចូលបញ្ហាផ្ទៃក្នុងគ្នា...**។

ដោយការប្រឹងប្រែង និងតស៊ូទ្រាំអស់រយៈពេលយូរអង្វែង ទីបំផុតក៏បានលេចចេញនូវទស្សនៈរួមនៅក្នុងជួរ ប្រទេសសមាជិកនៃសមាគម។ ក្នុងខណៈនេះ ថ្វីត្បិតតែកើតឡើងនូវទំនាស់លើរចនាសម្ពន្ធ គោលការណ៍នៃសេចក្តី សម្រេចចិត្ត របស់សមាគម ទីបំផុតសមាជិកអាស៊ានបានផ្លាស់ប្តូរលំនឹងកម្លាំង ទៅរកលំនឹងផលប្រយោជន៍ ហើយបានលើកមុខមាត់សមាគមនៅលើឆាកអន្តរជាតិ។

ស្ថានការណ៍នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ក្នុងដំណាក់កាលឆ្នាំដំបូង ដែលសមាគមទើបនឹងចាប់បដិសន្ធិឡើងមានភាពមិនប្រក្រតី។ ប្រទេសវៀតណាម ត្រូវបានបែងចែកជាពីរ គឺវៀតណាមខាងជើង និង វៀតណា

មខាងត្បូង ប្រទេសប្រ៊ុយណេ ស្ថិតនៅជាប្រទេសក្រោមការគ្រប់គ្រងរបស់អង់គ្លេស ប្រទេសភូមាបានបិទខ្លួនឯងពីពិភពខាងក្រៅ ចំណែកប្រទេសកម្ពុជា និងប្រទេសឡាវ ជាប្រទេសដែលប្រកាសថា អព្យាក្រិត្យ។ ឥទ្ធិពលរបស់សហរដ្ឋអាម៉េរិក មានយ៉ាងខ្លាំងនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ដែលជាកម្លាំងមួយធានាដល់ការរាំងស្ទះនូវសកម្មភាពប្រឆាំងនឹងរដ្ឋាភិបាល និងរាំងស្ទះសកម្មភាពឃោសនា របស់ពួកកុម្មុយនីស្ត។

ទោះជាយ៉ាងណាក៏ដោយ ស្ថាបនិកអាស៊ាន តែងតែមានក្តីសង្ឃឹមថា ទៅថ្ងៃខាងមុខប្រទេសក្នុងភូមិភាគ អាស៊ីអាគ្នេយ៍នឹងបង្រួបបង្រួមគ្នាក្នុងសមាគមតែមួយ។ សេចក្តីប្រកាសរួមស្តីពីការបង្កើតសមាគមអាស៊ានបាននិយាយដោយចំហរថា **«អាស៊ានបើកចំហរសម្រាប់ប្រទេសទាំងអស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលទទួលយកគោលការណ៍ និងលក្ខខន្តិកៈរបស់សមាគម»**។

ព្រឹត្តិការណ៍នៅក្នុងឥណ្ឌូចិន ជានិច្ចកាលតែងតែស្ថិតនៅក្នុងស្ថានភាពដែលគេចាប់អារម្មណ៍ ម្យ៉ាងវិញទៀត ប្រទេសហ្វីលីពីន និងប្រទេសថៃ ដែលជាសមាជិកអាស៊ាន បានបញ្ជូនកងទ័ពរបស់ខ្លួន ដើម្បីចូលរួមធ្វើសង្គ្រាមជាមួយ សហរដ្ឋអាម៉េរិក នៅក្នុងសមរភូមិវៀតណាម និងឡាវ។

ប្រទេសភូមា នៅក្នុងដំណាក់កាល ដែល **ណេវីន** កាន់អំណាច និងប្រទេសកម្ពុជាក្នុងដំណាក់កាលនៃសម្តេច នរោត្តម សីហនុ បានបដិសេធពុំព្រមចូលរួមជាសមាជិកអាស៊ាន ដូចបានបញ្ជាក់ខាងលើ ហើយប្រទេសភូមាបិទខ្លួន ឯង រីឯប្រទេសកម្ពុជាបានប្រកាន់យកនយោបាយអព្យាក្រិត្យយ៉ាងរឹងមាំ។ ប្រទេសទាំងពីរបានវាយតម្លៃថា អាស៊ាន ជាសមាគម ដែលស្ថិតនៅក្រោមឥទ្ធិពលសហរដ្ឋអាម៉េរិក។

ដំណាក់កាលទី១ ដែលប្រទេសអាស៊ានបានពាក់ព័ន្ធនឹងប្រទេសកម្ពុជា គឺបន្ទាប់ពីមានសភាពការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ នៅពេលដែលមានរដ្ឋប្រហារផ្តួលរំលំរបបសង្គមរាស្ត្រនិយមរបស់សម្តេចនរោត្តម សីហនុ ហើយអំណាចត្រូវកាន់កាប់ដោយរដ្ឋាភិបាលយោធារបស់សេនាប្រមុខលន់ នល់ និងព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ សហរដ្ឋអាម៉េរិកបានបញ្ជូនកងទ័ពចូលមកក្នុងប្រទេសកម្ពុជា។ របបយោធានិយមបានប្រឈមមុខ ប្រយុទ្ធប្រឆាំងនឹងពួកវៀតកុង និងការតស៊ូរបស់រណសិរ្សបង្រួបបង្រួមជាតិខ្មែរ ដែលដឹកនាំដោយសម្តេចនរោត្តម សីហនុ។ បន្ទាប់ពីបាន ពិភាក្សារួចមក លោក **អាដាម ម៉ាលីក** រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី បានធ្វើសេចក្តីប្រកាសឱ្យបើកសន្និសីទអន្តរជាតិ ស្តីអំពីបញ្ហាកម្ពុជា ហើយដែលបានប្រព្រឹត្តទៅនាខែឧសភា ឆ្នាំ១៩៧០ នៅទីក្រុងចាការតា។ សមាជិកទាំង៥ របស់អាស៊ាន និងមានតំណាងនៃប្រទេសជប៉ុន កូរ៉េខាងត្បូង អូស្ត្រាលី ណូវែលហ្សេឡង់ វៀតណាមខាងត្បូង និងប្រទេស កម្ពុជា បានចូលរួមក្នុងសន្និសីទនេះ។ ទិសដៅនៃសន្និសីទគឺ **«ការពារឯករាជ្យ បូរណភាពទឹកដី និងឯករាជ្យភាព កម្ពុជាទាំងស្រុង»**។ យ៉ាងណាមិញអង្គប្រជុំមិនត្រឹមតែ ទទួលស្គាល់នូវស្ថានភាពស្មុគស្មាញប្រកបដោយគ្រោះថ្នាក់ទាក់ទង នឹងបញ្ហា ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជានោះទេ គេថែមទាំងបានដាក់វិធានការ ការពារទៀតផង។

តំណាងសាធារណរដ្ឋវៀតណាមខាងត្បូង ដែលបានចូលរួមក្នុងសន្និសីទអាស៊ាន ថ្នាក់រដ្ឋមន្ត្រីការបរទេស ក្នុងឋានៈជាអ្នកសង្កេតការណ៍ បានធ្វើសំណូមពរជាញឹកញាប់ ដើម្បីចូលជាសមាជិកអាស៊ាន។ ប៉ុន្តែស្ថានភាពនយោបាយ នៅក្នុងប្រទេសវៀតណាមខាងត្បូង បានធ្វើឱ្យប្រទេសអាស៊ានរួញរាក្នុងការសម្រេចចិត្តទទួលយក។ រីឯព្រះរាជាណាចក្រឡាវ និងសាធារណរដ្ឋខ្មែរ ក៏បានចូលរួមក្នុងសន្និសីទអាស៊ានក្នុងឋានៈជាអ្នកសង្កេតការណ៍ដែរ ចាប់តាំងពីដើម ទសវត្សឆ្នាំ១៩៧០ ហើយក៏បានសំណូមពរចូលជាសមាជិកអាស៊ានផងដែរ។ ស្ថិតនៅក្នុងស្ថានភាពដែលសហរដ្ឋអាម៉េរិក កំពុងលូកដៃចូលក្នុងសង្គ្រាមឥណ្ឌូចិន មេដឹកនាំអាស៊ា

នមិនហ៊ានប្រថុយ ឱ្យសភាពការណ៍ភ្លើងសង្គ្រាម នៅឥណ្ឌូចិន ចូលមករុះរើនៅក្នុងប្រទេសអាស៊ានទេ។ នយោបាយប្រទេសអាស៊ាន ចំពោះបញ្ហាឥណ្ឌូចិន បានន័យថា **«គេចង់ចុចប៊ូតុងបាញ់ចូលភ្លើងសង្គ្រាមឥណ្ឌូចិនពីចម្ងាយ ជាជាងបណ្តាលឱ្យឆេះរាលដាលដល់ប្រទេសគេ ដែលអាចកើតមានឡើងប្រសិនបើប្រទេសឥណ្ឌូចិនក្លាយជាសមាជិកអាស៊ាន»។**

គ្រប់កត្តាទាំងអស់ ទាំងខាងក្នុង និងខាងក្រៅប្រទេស ដើម្បីនាំមកនូវសន្តិសុខដល់ប្រទេសអាស៊ាន គេបានដាក់ទិសដៅត្រូវតែរកដំណោះស្រាយដោយផ្លូវនយោបាយ ដែលគេបានមូលមតិគ្នាសម្រេចធ្វើសេចក្តីប្រកាសរួម ស្តីពីតំបន់សន្តិភាព សេរីភាព និងអព្យាក្រិត្យ(ZOPFAN) នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍។ សេចក្តីប្រកាសអំពីតំបន់ សន្តិភាព សេរីភាព និងអព្យាក្រិត្យ ត្រូវបានគេធ្វើឡើង នៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេស ដែលប្រារព្ធឡើង នៅប្រទេសម៉ាឡេស៊ី ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧១។

ទស្សនៈទាន ZOPFAN បានឆ្លុះបញ្ចាំងការតស៊ូ របស់សមាជិកអាស៊ានក្នុងដំណោះស្រាយវិបត្តិក្នុងការពង្រីក កិច្ចសហប្រតិបត្តិការរវាងប្រទេសនៅក្នុងតំបន់ ក៏ដូចជានៅក្រៅតំបន់។ ទ្រឹស្តី ZOPFAN គឺឈរលើទស្សនៈរៀបចំតំបន់ឱ្យមានរបៀបរៀបរយ នោះនឹងអាចនាំមកនូវសន្តិភាពគ្រប់ប្រទេសទាំងអស់ក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងការទទួលយកប្រទេសឥណ្ឌូចិនចូលជាសមាជិកអាស៊ាន ក្រោយពេលដែលសង្គ្រាមជាមួយសហរដ្ឋអាម៉េរិកបានចប់ហើយ។ នៅឆ្នាំ១៩៧៣ ក្រោយពេលដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីស ស្តីពីការឈប់បាញ់គ្នា និងដើម្បីសន្តិភាពនៅក្នុងប្រទេសវៀតណាម រដ្ឋមន្ត្រីក្រសួងការបរទេសអាស៊ាន បានធ្វើសេចក្តីថ្លែងការណ៍ ស្តីអំពីគោលបំណងរបស់គេ ចង់ពង្រីកសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដោយទទួលយកប្រទេសទាំងអស់នៅក្នុងឧបទ្វីបឥណ្ឌូចិន។

នៅខែមីនា ឆ្នាំ១៩៧៣ ប្រទេសម៉ាឡេស៊ី ដាក់ចំណងការទូតជាមួយប្រទេសវៀតណាមខាងជើង ក្នុងកម្រិតឯកអគ្គរដ្ឋទូត។ នៅក្នុងខែឧសភា ឆ្នាំនោះដដែល ប្រទេសសិង្ហបុរី ក៏បានចាប់ផ្តើមមានទំនាក់ទំនងការទូតជាមួយនឹង សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមដែរ។ ឯប្រទេសឥណ្ឌូណេស៊ី មានទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋ ប្រជាធិបតេយ្យវៀតណាមតាំងពីសម័យស៊ូការណូ កាន់អំណាចម្លេះ។ នៅពេលនោះប្រទេសអាស៊ានបាន ប្រឹងប្រែងកាត់ផ្តាច់វៀតណាមខាងជើង និងវៀតណាមខាងត្បូងឱ្យចេញពីប្រព័ន្ធប្រឈមមុខស៊ីសាច់ហុតឈាមគ្នារវាងលទ្ធិសង្គមនិយម និងលទ្ធិមូលធននិយម។

បន្ទាប់ពីពួកឆ្វេងនិយមបានទទួលជោគជ័យនៅក្នុងប្រទេសកម្ពុជា និងឡាវ និងការដកខ្លួនរបស់អាម៉េរិកចេញ ពីវៀតណាមខាងត្បូង ឆ្នាំ១៩៧៥ ពេលនោះចំពោះបញ្ហាបញ្ចូលប្រទេសទាំងនោះទៅក្នុងសមាជិកអាស៊ានបានបាត់ បង់លក្ខណៈភាពរបស់ខ្លួន ក៏ប៉ុន្តែអ្នកនយោបាយនៅតែបន្តការឃោសនារបស់ខ្លួនតទៅទៀត អំពីអត្ថិភាពគ្មានមូល ហេតុ។ នៅខែឧសភា ឆ្នាំ១៩៧៥ បានប្រារព្ធឡើងនូវសន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន។ សន្និសីទនេះទាក់ទងទៅនឹងបញ្ហាថ្មី ដែលកើតឡើងក្នុងតំបន់ និងរៀបចំគោលនយោបាយដែលទាក់ទងទៅនឹងតំបន់ឥណ្ឌូចិន។ នៅក្នុងសេចក្តីថ្លែងការណ៍រួម រដ្ឋមន្ត្រីការបរទេសបានធ្វើសេចក្តីប្រកាសស្តីអំពីផលប្រយោជន៍ប្រទេសរបស់ខ្លួន ទំនាក់ទំនង ទៅនឹងប្រទេសទាំងបីនៅឥណ្ឌូចិន និងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់។ បម្រែបម្រួលស្ថានភាពនៅក្នុងប្រទេសឥណ្ឌូចិន បានពន្លឿនកាលបរិច្ឆេទ ជំនួបថ្នាក់ដឹកនាំកំពូលអាស៊ាន ដែលបានប្រព្រឹត្តទៅនៅកោះបាលី នាខែកុម្ភៈ ឆ្នាំ១៩៧៦។ នៅក្នុងជំនួបគេបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅក្នុងភូមិភាគ អាស៊ីអាគ្នេយ៍ និងការបើកចំហរដល់ប្រទេសទាំងអស់នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ដើម្បីភ្ជាប់ខ្លួនមកចូលក្នុងសមាគម ប្រជាជាតិអាស៊ីអាគ្នេយ៍។

កិច្ចព្រមព្រៀងក៏បានបញ្ជាក់ផងដែរដល់ប្រទេសទាំងអស់នៅក្នុងតំបន់ ដោយឯករាជ្យពីទិសដៅនយោបាយ និងគោរពគោលការណ៍បូរណភាពទឹកដី មិនលូកដៃចូលបញ្ហាផ្ទៃក្នុង។ កិច្ចព្រមព្រៀងក្លាយជាឧបករណ៍មួយ ដើម្បីហៅប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់ចូលរួមពិភាក្សាគ្នា និងជាទិសដៅយុទ្ធសាស្ត្រ គឺផ្សារភ្ជាប់ ប្រទេសទាំងអស់ក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ឱ្យនៅក្នុងសមាគមតែមួយ និងប្រែក្លាយសមាគមឱ្យទៅជាមជ្ឈមណ្ឌលនយោបាយតែមួយ ដែលមានឥទ្ធិពលនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

អាស៊ាន ជាសមាគមមួយដែលមានទិសដៅពឹងលើជោគវាសនានិយម មិនប្រឈមមុខចំពោះព្រឹត្តិការណ៍នៅក្នុងប្រទេសវៀតណាម ឡាវ និងកម្ពុជា ដែលបានប្រកាសខ្លួនអំពីការជ្រើសរើសការកសាងប្រទេសតាមផ្លូវសង្គមនិយម។

នៅក្នុងដំណាក់កាលពីរឆ្នាំដំបូង ដែលប្រទេសវៀតណាមទាំងពីរបានបង្រួបបង្រួមគ្នា ទំនាក់ទំនងប្រទេសអាស៊ាន និងក្រុងហាណូយបានប្រសើរឡើងវិញ។ ប៉ុន្តែជាតថភាពទៅថ្ងៃអនាគត មេដឹកនាំនៃប្រទេសអាស៊ានមិនអាចនៅស្ងៀមបានទេ នៅពេលដែលក្នុងតំបន់ជាមួយគ្នាមានប្រទេសដែលមានកម្លាំងយោធាខ្លាំង និងចំនួនប្រជាជនច្រើន ដូចប្រទេសវៀតណាម ហើយមានទិសដៅនយោបាយផ្ទុយពីគ្នាដូច្នេះ។ នារដូវក្តៅ ឆ្នាំ ១៩៧៦ ប្រទេសហ្វីលីពីន និងប្រទេសថៃ បានដាក់កាទូតជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម។

ថ្វីត្បិតតែមានជំហានទៅរកគ្នារវាងប្រទេសអាស៊ាន និងប្រទេសឥណ្ឌូចិនយ៉ាងណាក្តី ក៏គេសង្កេតឃើញ មាននៅសល់ទំនាស់ជាច្រើនទៀត ដែលបានចេញរូបរាងនៅក្នុងសន្និសីទប្រទេសមិនចូលបក្សសម្ព័ន្ធ ដែលប្រារព្ធឡើងនៅទីក្រុងកឡូមបូ នាខែសីហា ឆ្នាំ១៩៧៦។ ទស្សនៈរបស់ប្រទេសអាស៊ាន និងប្រទេសឥណ្ឌូចិន មិនចុះសម្រុងគ្នាលើ បញ្ហាសំខាន់ៗជាច្រើន។ តំណាងប្រទេសសមាជិកអាស៊ាន បានចោទប្រកាន់វៀតណាម និងប្រទេសឡាវថា ជាអ្នក ឃោសនាផ្សព្វផ្សាយមនោគមន៍វិជ្ជាកុម្មុយនីស្ត និងបានទាក់ទាញប្រទេសដែលមិនចូលបក្សសម្ព័ន្ធឱ្យចូលរួម ក្នុងចលនាប្លុកសង្គមនិយម។ កាយវិការនេះគឺរំលោភលើគោលការណ៍សំខាន់ៗ គឺលក្ខន្តិកៈ **«សមភាព និងមិនលូកដៃ ចូលបញ្ហាផ្ទៃក្នុង...»**។ គេក៏បានឆ្លើយតបវិញថា គម្រោង ZOPFAN មិនអាចឱ្យប្រទេសដែលចូលរួមក្នុងតំបន់ មានឯករាជភាពពីពួកចក្រពត្តិនិយមបានឡើយ។ លោកអាន់ពារ ដ.ហ្ស អ្នកប្រាជ្ញជនជាតិឥណ្ឌូណេស៊ី បាននិយាយថា វៀតណាម បានធ្វើគម្រោងស្តីអំពីបម្លាស់ប្តូរ ZOPFAN ទៅជា ZOPIFAN "I" មានន័យថាឯករាជភាព(Independent)។

ទោះបីគេសង្កេតឃើញមានទំនាស់គ្នាច្រើនយ៉ាងណាក្តី គូភាគីបានឈរលើគោលការណ៍ យោគយល់គ្នា។ នៅខែឧសភា ឆ្នាំ១៩៧៧ រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី បានទៅធ្វើទស្សនៈកិច្ចនៅទីក្រុងហាណូយ ដោយបានធ្វើសេចក្តី ថ្លែងការណ៍ទៅកាន់មេដឹកនាំវៀតណាម ស្តីអំពី **«ឥរិយាបថមិនសមហេតុផលរបស់ប្រទេសអាស៊ាននៅក្នុងសន្និសីទ នាទីក្រុងកូឡូមបូ»**។

នៅក្នុងឯកសារនៃលទ្ធផលជំនួប មេដឹកនាំកំពូលប្រទេសអាស៊ានជាលើកទី២ ឆ្នាំ១៩៧៧ បានគូសបញ្ជាក់ពី ការខិតខំប្រឹងប្រែងរបស់អាស៊ាន ក្នុងការធ្វើទំនាក់ទំនងដោយសន្តិភាពជាមួយប្រទេសទាំងអស់នៅក្នុងភូមិភាគអាស៊ី អាគ្នេយ៍ ដោយរួមទាំងប្រទេសកម្ពុជា វៀតណាម និងឡាវ និងមានកម្មវិធីពង្រឹងតំបន់ យោគយល់ និងកិច្ចសហប្រតិបត្តិ ការជាមួយប្រទេសឥណ្ឌូចិន ដោយឈរលើគោលគារណ៍គោរពផលប្រយោជន៍រួម។ មេដឹកនាំប្រទេសអាស៊ាន បានគាំទ្រដល់សំណើរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាតិ ស្តីពីការទទួលស្គាល់យកសាធារណរដ្ឋសង្គមនិយមវៀតណាមជាសមាជិករបស់អង្គការសហប្រជាជាតិ។

ក្នុងឱកាសដែលលោកនាយករដ្ឋមន្ត្រី**ផាម យ៉ាងដុង** បានធ្វើទស្សនៈកិច្ចនៅក្នុងប្រទេសអាស៊ាននានាដូចវស្លឹកឈើជ្រុះ ឆ្នាំ១៩៧៨ គេបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីគោលការណ៍ដំណោះស្រាយទំនាស់ដោយឈរលើ សន្តិភាវូបនីយកម្ម។ ទំនាក់ទំនងរបស់វៀតណាមជាមួយ ប្រទេសអាស៊ានមានដំណើរប្រក្រតីរយៈពេលខ្លីណាស់ ដោយទាក់ទងទៅនឹងទំនាស់ប្រឈមមុខគ្នារវាងសហភាពសូវៀត ជាមួយនិងសាធារណរដ្ឋប្រជាមានិតចិន ជុំវិញបញ្ហាដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ចំពោះការវាយលុករបស់កងទ័ព វៀតណាម។ ក្នុងស្ថានភាពបែបនេះ ថ្វីត្បិតតែលោក ផាម វ៉ាន់ដុង បានចុះហត្ថលេខាលើវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្របច្ចេកទេស ពាណិជ្ជកម្ម និងទេសចរណ៍ ក្នុងកម្រិតជា ទ្វេភាគីហើយក៏ដោយ ប៉ុន្តែប្រទេសសមាជិកអាស៊ានបានបដិសេធចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយវៀតណាម ស្តីពីមិត្តភាព សន្តិភាព និងកិច្ចសហប្រតិបត្តិការ ព្រោះប្រទេសអាស៊ានពិតជាមានហេតុផលរបស់គេ។

ពួកខ្មែរក្រហម ដែលមានទិសដៅនយោបាយទៅរកចិនប៉េកាំង និងមាននយោបាយអមនុស្សធម៌ទាល់តែសោះ ចំពោះប្រជាជនខ្លួនឯង ហើយក៏គ្មាននយោបាយសន្តិភាពជាមួយប្រទេសជិតខាងដែរ និងធ្វើឱ្យមេដឹកនាំអាស៊ានមិន ពេញចិត្តជាខ្លាំង។ ប៉ុន្តែយើងគួរតែកត់សម្គាល់ដែរថា ការកំណត់នយោបាយក្រៅប្រទេសដ៏សំខាន់នាពេលនោះ គឺប្រទេសវៀតណាម។

នៅឆ្នាំ១៩៧៨ សាធារណរដ្ឋសង្គមនិយមវៀតណាម ត្រូវបានចូលជាសមាជិកអង្គការកូមិញហ្វមរបស់ពួកសង្គមនិយម។ វៀតណាមបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងសហភាពសូវៀត-វៀតណាម ស្តីពីមិត្តភាព និងកិច្ចសហប្រតិបត្តិការ។ បន្ទាប់ពីចុះហត្ថលេខាបានមួយសប្តាហ៍ កងទ័ពសាធារណរដ្ឋសង្គមនិយមវៀត និងកងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជា ដឹកនាំដោយលោកហេងសំរិន បានបើកការវាយប្រហារតម្រង់មកក្រុងភ្នំពេញ ទីបំផុតរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ ហើយសាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានចាប់កំណើតឡើង។

ទំនាក់ទំនងរវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងសហភាពសូវៀត ត្រូវបានពង្រឹងកាន់តែខ្លាំងឡើង ក្នុងខណៈនោះដែរ ទំនាក់ទំនងសហភាពសូវៀត និងចិនប្រជាមានិតកាន់តែថយចុះ។ ប្រទេសអាស៊ាន បានវាយតម្លៃសភាពការណ៍នេះថាៈ ជាការបាត់បង់នូវកម្លាំងយោធានៅក្នុងតំបន់។ ស្របពេលនេះអាស៊ានបានប្តូរទិសដៅទំនាក់ ទំនងជាមួយប្រទេសវៀតណាម។ ការដកទ័ពសហរដ្ឋអាម៉េរិកចេញពីឥណ្ឌូចិនកម្លាំងថ្មីបានកើតឡើងនៅក្នុងតំបន់នេះ ស្របពេលវៀតណាមចុះកិច្ចព្រមព្រៀងជាមួយសហភាពសូវៀត និងការវាយលុកចូលកាន់កាប់ប្រទេសកម្ពុជា។ សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋប្រជាមានិតកម្ពុជា បានទទួលការគាំទ្រគ្រប់វិស័យពីសំណាក់ សហភាពសូវៀត និងពីបណ្តាប្រទេសសង្គមនិយមដទៃទៀត។ សម្ពន្ធភាព រវាងសូវៀត និងវៀតណាម បានប្រឈមមុខនឹងភាពជាគូកនរវាងសហរដ្ឋអាម៉េរិក និងចិនប្រជាមានិតអស់រយៈពេល ១០ឆ្នាំ នៃជម្លោះកម្ពុជា។

សភាពការណ៍នៅក្នុងប្រទេសកម្ពុជា ក្រោយការដួលរលំរបបខ្មែរក្រហម ប្រទេសអាស៊ានបានចាត់ទុកជាវិបត្តិមួយក្នុងតំបន់អាស៊ីអាគ្នេយ៍។ ទំនាក់ទំនងដ៏ស្អិតរមួតរបស់អាស៊ាន ជាមួយលោកខាងលិច ជាពិសេសជាមួយសហរដ្ឋអាម៉េរិក ដែលគាំទ្រប្រទេសចិន នាំឱ្យអាស៊ានបិទភ្នែកចំពោះការវាយលុក របស់កងទ័ពចិនមកលើប្រទេសវៀតណាម នៅខែកុម្ភៈ ឆ្នាំ១៩៧៩។ សេចក្តីថ្លែងការណ៍របស់អាស៊ានស្តីពីគោលជំហរ «**អព្យាក្រឹត**» របស់ខ្លួនបានន័យថា អាស៊ានបានវាយតម្លៃអ្នកដែលឈ្លានពាន និងអ្នកដែលត្រូវរងគ្រោះ គឺដូចតែគ្នា ម្យ៉ាងទៀតឥរិយាបថនេះបានបង្ហាញនូវការគាំទ្រនយោបាយ ក្រុងប៉េកាំងយ៉ាងច្បាស់។

នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ គេបានឃើញយ៉ាងច្បាស់នូវការបែងចែកភូមិភាគនេះ ជាអនុតំបន់ពីរ ដែលមានគោលនយោបាយប្រឆាំងគ្នា ដោយម្ខាងមានសម្ពន្ធភាពជាមួយប្រទេសសង្គមនិយមនៅក្នុងឧបទ្វីបឥណ្ឌូចិន(កម្ពុជា វៀតណាម ឡាវ)។ ម្ខាងទៀតគឺជាសម្ពន្ធភាពប្រទេសដែលជាសមាជិកអាស៊ាន។

ប្រទេសនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ទាំងអស់ មិនអាចដឹកនាំនយោបាយឯករាជ្យបានទេនៅក្នុងស្ថានភាព **«សង្គ្រាមត្រជាក់»** ដោយសារការគាំទ្រពីកំពូលមហាអំណាចសហភាពសូវៀត និងអាម៉េរិក។ ដូច្នេះ នៅក្នុងដំណាក់កាលនេះ នយោបាយប្រទេសអាស៊ីអាគ្នេយ៍នៅក្នុងកម្រិត (ជាតិ តំបន់ ឬក្រៅតំបន់) មានទំនាក់ទំនងយ៉ាងស្អិតរម្មួតជាមួយ ប្រទេសមហាអំណាច។ នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ក្នុងភូមិភាគអាស៊ីអាគ្នេយ៍ បានបង្កើតប្រព័ន្ធពហុប៉ូល ម្តងទៀត នៅក្នុងទំនាក់ទំនងអន្តរជាតិ ដោយសារការបង្កើតឡើងនូវប្រព័ន្ធពីរប្រឆាំងគ្នារវាងអាស៊ាន នឹងឥណ្ឌូចិន។

សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជា មានិតឡាវ បានបង្កើតសម្ពន្ធភាពរបស់ខ្លួនហៅថា «តំបន់ទំនាក់ទំនងពិសេស» ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀង ប្រទេសទាំងបី។ ប្រទេសទាំងបីមានទិសដៅទៅរកសហភាពសូវៀត និងមានការគាំទ្រពីអង្គការសេដ្ឋកិច្ច នៃប្រទេស សង្គមនិយម ដើម្បីស្តារ និងលើកកម្ពស់សេដ្ឋកិច្ចរបស់ខ្លួន។ ទំនាក់ទំនងជាមូលដ្ឋាននៅក្នុងសម្ពន្ធភាពប្រទេសឥណ្ឌូចិន ទទួលឥទ្ធិពលយ៉ាងខ្លាំងពីប្រទេសវៀតណាម ទាំងយោធា នយោបាយ និងសេដ្ឋកិច្ច។

ចាប់ពីពេលនោះមក យើងអាចនិយាយបានអំពីសមាហរណកម្មពីរ ដែលដើរស្របគ្នានៃអនុតំបន់ទាំងពីរ នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ៖

-ប្រទេសអាស៊ានបានពង្រឹងវិស័យនយោបាយ និងសេដ្ឋកិច្ចរបស់ខ្លួនយ៉ាងខ្លាំង។

-ប្រទេសឥណ្ឌូចិន បានពង្រឹងវិស័យនយោបាយយោធា ដើម្បីពង្រឹងគោលការណ៍សង្គមនិយមនៅក្នុងតំបន់។

នៅពេលនោះ ប្រទេសអាស៊ានបានក្លាយជាប្រទេសដែលមានកម្លាំងថាមពលសេដ្ឋកិច្ចដ៏ខ្លាំងក្លានៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍។

ទំនាស់រវាងអនុតំបន់ទាំងពីរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជុំវិញបញ្ហាកម្ពុជា ជាទំនាស់យូរអង្វែង ដែលមានឥទ្ធិពលយ៉ាងខ្លាំងដល់ការពង្រឹងឯកភាពនៅក្នុងជួរប្រទេសអាស៊ាន។ ទាក់ទងនឹងដំណោះស្រាយវិបត្តិកម្ពុជា នយោបាយ អាស៊ានបានធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព ដោយឈរលើគម្រោងទស្សនៈទាន «នយោបាយបង្រួបបង្រួមជាតិកម្ពុជា» នៅក្រោមការត្រួតពិនិត្យពីសំណាក់អង្គការសហប្រជាជាតិ។

នៅខែមករា ឆ្នាំ១៩៨១ ប្រទេសកម្ពុជា វៀតណាម និងឡាវ បានជួបប្រជុំគ្នានៅទីក្រុងហាណូយ ដោយបានធ្វើ សេចក្តីប្រកាសរួមមួយស្តីពី «សន្តិភាព ស្ថិរភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងភូមិភាគអាស៊ីអាគ្នេយ៍»។ គេបាន ធ្វើសំណើឱ្យបើកសន្និសីទប្រទេសអាស៊ាន និងប្រទេសឥណ្ឌូចិន និងត្រៀមខ្លួនជានិច្ចក្នុងការធ្វើដំណោះស្រាយបញ្ហានៅក្នុងតំបន់។

ទោះជាយ៉ាងណាក៏ដោយ សំណើរបស់ប្រទេសឥណ្ឌូចិន ពុំបានទទួលការគាំទ្រពីសំណាក់ប្រទេសអាស៊ាន នោះទេ។ នៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេសអាស៊ាន នៅម៉ានីល ខែមិថុនា ឆ្នាំ១៩៨១ សមាជិកអាស៊ាន បានប្រកាសថា ដោយឈរលើគោលការណ៍យោគយល់ថា ដើម្បីធ្វើដំណោះស្រាយជុំវិញបញ្ហាកម្ពុជា នៅក្នុងឋានៈសន្និសីទអន្តរជាតិ ក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ។ ថ្វីត្បិត

សន្និសីទអន្តរជាតិស្តីពីបញ្ហាកម្ពុជា ដែលប្រព្រឹត្តទៅនៅទីក្រុងញូយ៉ក ពីថ្ងៃទី១៣-១៧ ខែកក្កដា ឆ្នាំ១៩៨១ ដោយគ្មានវត្តមានប្រទេសឥណ្ឌូចិន និងប្រទេស សង្គមនិយមដទៃទៀតចូលរួម ហេតុនេះ «វិបត្តិកម្ពុជា» នៅតែគ្មានច្រកចេញដដែល។

នៅពេលនោះទស្សនៈទាន ដែលប្រទេសឥណ្ឌូចិនបានផ្សព្វផ្សាយ គឺការកសាងប្រទេសកម្ពុជា ជាប្រទេសកុម្មុយនីស្ត យកគំរូតាមប្រទេសវៀតណាម។ ឯប្រទេសអាស៊ានបានផ្តល់ទស្សនៈទាន ស្តីអំពីរចនាសម្ពន្ធប្រទេសកម្ពុជា គឺជាប្រទេសដែលមានអធិបតេយ្យភាព បូរណភាពទឹកដី អព្យាក្រឹត មិនចូលបក្សសម្ពន្ធណាមួយ" និងបានទាមទារ ជំហានទីមួយ ត្រូវដកកងទ័ពវៀតណាមឱ្យអស់ពីប្រទេសកម្ពុជា ប៉ុន្តែទន្ទឹមនឹងនេះអាស៊ានបែរជាគាំទ្រខ្មែរក្រហម។ ប្រទេសអាស៊ានបានគិតថា ត្រូវតែថៃរក្សាលំនឹងកម្លាំងរវាងកងទ័ពខ្មែរក្រហម ដែលមានមូលដ្ឋានទ័ពនៅតាមព្រំប្រទល់ប្រទេសថៃ ជាមួយនឹងកងទ័ពវៀតណាម ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា និងកំពុងគាំទ្ររដ្ឋាភិបាលក្រុងភ្នំពេញ។ ទន្ទឹមនឹងនេះកម្លាំងទី៣ ក៏ចាប់ផ្តើមរួបរួមគ្នាក្រោមការដឹកនាំរបស់សម្តេចសីហនុ។

នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ទស្សនៈទាន ZOPFAN បានផ្លាស់ប្តូរយ៉ាងច្រើនបើប្រៀបធៀបទៅនឹងទសវត្សរ៍ឆ្នាំ១៩៧០ គឺកម្មវិធីមានទិសដៅប្រឆាំងនឹងប្រទេសវៀតណាម និងឡាវ។ ប្រសិនបើប្រទេសទាំងនោះមិនចូលរួមក្នុងកម្មវិធី ZOPFAN ទេនោះ តំបន់សន្តិភាពក៏មិនអាចកើតមានដែរ។ ហេតុដូចនេះគោលការណ៍ ZOPFAN តាមលក្ខណៈ ជាក់ស្តែង ត្រូវបានគេទុកជាជំហានទី២ បញ្ហាចំពោះមុខគឺទស្សនៈទាន «ការតស៊ូរបស់ប្រជាជាតិ និងក្នុងតំបន់» ជាត្រីវិស័យនាំទៅរកការការពារសន្តិសុខនៅក្នុងតំបន់។

នៅក្នុងលក្ខន្តិកៈស្មុគស្មាញ និងតឹងតែងនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ មេដឹកនាំប្រទេស អាស៊ាន នៅថែរក្សាគោលការណ៍តំបន់ស្វយ័ត ដឹកនាំប្រទេសតាមរចនាសម្ពន្ធមូលធននិយម ក្នុងទិសដៅពង្រីក និងពង្រឹងសមាគមទៅថ្ងៃ អនាគត។ អាស៊ានបានទទួលយកសមាជិកទី៦ របស់ខ្លួនគឺ ប្រទេសព្រុយណេ ដែលបានទទួលឯករាជភាព ពីចក្រភពអង់គ្លេស នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៨៤។ ដើម្បីរំដោះខ្លួនចេញពីគ្រោះថ្នាក់ដែលអាចកើតឡើងដោយសារទំនាស់រវាងមហាអំណាចទាំងពីរ គឺអាម៉េរិក និងសូវៀត និងគ្រោះថ្នាក់ដែលបណ្តាលមកពីមហាអំណាចកុម្មុយនីស្តពីរ គឺសូវៀត និងចិនប្រជាមានិត អាស៊ាន និងប្រទេសឥណ្ឌូចិន បានប្រឹងប្រែងធ្វើយ៉ាងណា កុំឱ្យបញ្ហានៅក្នុងតំបន់រីករាលដាលទៅខាងក្រៅ។ គេសង្កេតឃើញ ព្រឹត្តិការណ៍ ពាក់ព័ន្ធបីដំណាក់កាលៈ

-ដំណាក់កាលទី១៖ ទំនាស់របស់មហាអំណាច និងប្រព័ន្ធពីរដែលមានលក្ខណៈជាសាកល។

-ដំណាក់កាលទី២៖ ទំនាស់រវាងប្រទេសឥណ្ឌូចិន និងប្រទេសអាស៊ានក្នុងតំបន់។

-ដំណាក់កាលទី៣៖ ទំនាស់រដ្ឋាភិបាលកម្ពុជា និងខ្មែរដែលប្រឆាំងក្នុងកម្រិតជាតិ។

ដំណោះស្រាយអាចធ្វើទៅរួចដោយឈរលើគោលការណ៍យោគយល់គ្នា នៅក្នុងកម្រិតអន្តរជាតិ ចូលរួមដោយតំណាងអ្នកពាក់ព័ន្ធទាំងអស់។ យើងគួរធ្វើការកត់សម្គាល់ផងដែរថា ចាប់តាំងពីកើតមានបញ្ហា កម្ពុជា (ចុងទសវត្សរ៍ឆ្នាំ១៩៧០ និងពាក់កណ្តាលទសវត្សរ៍១៩៨០) ប្រទេសអាស៊ានបានបដិសេធនូវដំណោះស្រាយដោយកម្លាំងយោធា ជានិច្ចកាលតែងដង្ហើយហៅឱ្យមានការដោះស្រាយដោយសន្តិវិធី។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ អាស៊ានក្លាយជាអ្នកផ្តួចផ្តើម និងមានសកម្មភាពយ៉ាងសកម្ម នៅក្នុងការស្វែងរកដំណោះស្រាយជំវិញវិបត្តិកម្ពុជា។

នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣ នៅទីក្រុងម៉ានីល ឆ្នាំ១៩៨៧ អាស៊ានបានចុះហត្ថលេខាលើពិធីសារ នៃកិច្ចព្រមព្រៀងស្តីពីមិត្តភាព និងកិច្ចសហប្រតិបត្តិការប្រទេសអាស៊ីអាគ្នេយ៍ ឆ្នាំ១៩៧៦ ដែលអាចផ្តល់លទ្ធភាពឱ្យប្រទេសដទៃទៀតភ្ជាប់ខ្លួនទៅនឹងកិច្ចព្រមព្រៀងនេះដែរ។

យើងគួរកត់សម្គាល់ដែរ ថាទំនាស់រវាងប្រទេសអាស៊ាន និងប្រទេសទាំងបីនៅឥណ្ឌូចិន បើសិនមិនគិតពីប្រព័ន្ធទំនាស់ជាសាកលនោះ យើងនឹងឃើញថាគ្មានអ្វីដែលធ្វើឱ្យទំនាស់នេះកាន់តែស្មុគស្មាញ នោះទេ។ នៅទសវត្សរ៍ឆ្នាំ១៩៨០ ទស្សនៈទាននៃរចនាសម្ពន្ធទាំងពីរនេះ គេសង្កេតឃើញគ្មានអ្វីខុសគ្នាជា ធំដុំនោះទេចំពោះប្រទេសនៅអាស៊ីអាគ្នេយ៍។ ឯទស្សនៈបង្កើតតំបន់សន្តិភាព គឺជាទិសដៅរួមរបស់ប្រជាជាតិអាស៊ីអាគ្នេយ៍ទាំងមូល។ ប្រទេសឥណ្ឌូចិន ខុសពីប្រទេសអាស៊ាន ត្រង់ពួកគេតែងតែធ្វើសេចក្តីប្រកាសទាមទារឱ្យបង្កើតតំបន់សន្តិភាព និងសេរីភាព នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែ «ឯករាជភាព» ពីគោលការណ៍ ZOPFAN ។

ចំណែកឯសហរដ្ឋអាម៉េរិក និងចិនប្រជាមានិត ក៏បានប្រកាសគាំទ្រគំនិតអាស៊ាន នៅក្នុងដំណោះស្រាយ វិបត្តិនៅកម្ពុជា។ គំនិតផ្តួចផ្តើមរបស់អាស៊ានក៏ទទួលបានការគាំទ្រពីមេដឹកនាំសហភាពសូវៀតថ្មី គឺលោក ហ្គោបាឆូវ ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០ ជំនួបនៅទីក្រុងចាការតា ប្រទេសឥណ្ឌូណេស៊ី បានសម្រេចចេញ លទ្ធផលជាវិជ្ជមាន ដែលអាចដកវិបត្តិកម្ពុជា ពីរបៀបវារៈចេញពីបញ្ហាអន្តរជាតិ នេះក៏ជាលទ្ធផលដែលបានមកពីសន្និសីទទីក្រុងប៉ារីស ក្នុងពីរដំណាក់ ស្តីពីបញ្ហាកម្ពុជា ដែលបានប្រារព្ធឡើងនៅឆ្នាំ១៩៨៩ និងឆ្នាំ១៩៩១។

ដំណោះស្រាយបញ្ហាកម្ពុជា បានបើកទ្វារចំហរសម្រាប់អាស៊ាន ឱ្យមានលទ្ធភាពក្លាយទៅជាសមាគមមួយនៃ ប្រទេសភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូល ដោយបញ្ចូលប្រទេសឥណ្ឌូចិន និងប្រទេសភូមាទៅជាសមាជិករបស់សមាគមផងដែរ។ ជាការពិតហើយ ដែលសេចក្តីប្រកាសនៅទីក្រុងបាងកក ឆ្នាំ១៩៦៧ ដែលអះអាងថា «**ការបង្កើតសមាគម ជាទិសដៅបង្កើតតំបន់ដែលមានសកម្មភាពពេញលេញលើទឹកដីភូមិភាគអាស៊ីអាគ្នេយ៍**»។ នៅក្នុងដំណាក់កាលទី១ សមាជិកអាស៊ានមានតែ៥ប្រទេស ប៉ុន្តែនៅក្នុងសេចក្តីប្រកាសចែងថា ការពង្រីកអត្តិភាពរបស់សមាគម និងធ្វើទៅបានដោយការពង្រីកសមាជិករបស់ខ្លួន។

ចំពោះសេចក្តីថ្លែងការរបស់មេដឹកនាំវៀតណាម ស្តីអំពីការរៀបចំខ្លួនរួចជាស្រេច ដើម្បីចូលជាសមាជិកអាស៊ាន ជាដំណឹងមួយ ដែលអាស៊ានមិននឹកស្មានដល់។ សេចក្តីថ្លែងការណ៍នេះបានធ្វើឡើងដោយអគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ង្វៀន វ៉ាន់លីញ នៅខែធ្នូ ឆ្នាំ១៩៨៨ ក្នុងឱកាសជំនួបរដ្ឋមន្ត្រីក្រសួងការបរទេស ហ្វីលីពីន លោក ម៉ាន់ក្លាពូស។ បន្ទាប់មកលោក **ង្វៀង កូថាច់** រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាមបានថ្លែងស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចនៅក្នុងតំបន់ នៅក្នុងសិក្ខាសាលានាទីក្រុងបាងកក នាខែមេសា ឆ្នាំ១៩៨៩ ដែលមានសេចក្តីថា "ដើម្បីបម្រើផលប្រយោជន៍ដល់កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចនៅក្នុងតំបន់ ប្រទេសវៀតណាម ត្រៀមខ្លួនរួចជាស្រេចដើម្បីចូលជាសមាជិកអាស៊ាន"។ ដោយយកចិត្តទុកដាក់ចំពោះទិសដៅថ្មីនៅក្នុងប្រព័ន្ធបែងចែកពលកម្មពិភពលោក យើងអាចរំពឹងទាំងស្រុងទៅលើលទ្ធភាពកិច្ចសហប្រតិបត្តិការ លើគ្រប់វិស័យដោយយកប្រព័ន្ធដូចតទៅ «អ្នកឯកទេសកម្រិតខ្ពស់ តែតម្លៃ ពលកម្មថោករបស់វៀតណាម រួមនិងហិរញ្ញវត្ថុ ឧបករណ៍បច្ចេកទេស របស់ប្រទេស អាស៊ាន និងរួមបញ្ចូលផងដែរនូវផ្សារអន្តរជាតិ និងទីផ្សារប្រទេសសង្គមនិយម»។

ចំពោះប្រទេសឡាវ ពុំមានឥរិយាបថរឹងត្អឹងដូចវៀតណាមទេ ប៉ុន្តែផ្ទុយទៅវិញប្រទេសអាស៊ាន មើលឃើញលក្ខណៈទន់ខ្សោយរបស់ប្រទេសឡាវ ក្នុងការប្រឈមមុខនឹងប្រទេសអាស៊ាន។ ដូចនេះពួកគេបាន

វាយតម្លៃថា ប្រទេសឡាវ ជាប្រទេសតែមួយគត់ក្នុងចំណោមប្រទេសឥណ្ឌូចិន ដែលអាចធ្វើកិច្ចសហប្រតិបត្តិការជាមួយបាន។ មិនមែនជារឿងចៃដន្យនោះទេ ដែលប្រទេសឡាវក្លាយជាអាជ្ញាកណ្តាល ក្នុងកិច្ចពិភាក្សារវាងប្រទេសអាស៊ាន និងប្រទេសវៀតណាម ប្រទេសកម្ពុជា។

នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និងឆ្នាំ១៩៩០ ដោយសារតែប្រព័ន្ធទ្វេប៉ូល ត្រូវបានបាក់បែកនៅក្នុងប្រព័ន្ធទំនាក់ទំនងអន្តរជាតិ ម្យ៉ាងទៀតសហព័ន្ធរូស៊ី មានទិសដៅទៅរកលោកខាងលិច ដែលនាំឱ្យទំនាក់ទំនងនយោបាយសេដ្ឋកិច្ច និងបច្ចេកទេសយោធារបស់រុស្ស៊ី ជាមួយនិងប្រទេសកម្ពុជា វៀតណាម និងឡាវ ក៏ត្រូវបានបញ្ចប់ដែរ។ ការឈានទៅចាប់ដៃគ្នា រវាងប្រទេសដែលធ្លាប់ជាសត្រូវនឹងគ្នា នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ បានមកពីកត្តាជាច្រើនដូចជា៖ បម្រែបម្រួលជាមូលដ្ឋាននៃប្រទេសឥណ្ឌូចិនទាំងបី ដែលជាមូលដ្ឋានមួយដើម្បីពិនិត្យឡើងវិញ ចំពោះកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសអាស៊ាន និងទីបំផុតសេចក្តីសម្រេចចិត្តរបស់ប្រទេសឥណ្ឌូចិន ចូលជាសមាជិកអាស៊ានដោយឈរលើគោលការណ៍មិត្តភាព និងកិច្ចសហប្រតិបត្តិការ។

ការបញ្ចប់នៃសង្គ្រាមត្រជាក់ និងដំណោះស្រាយបញ្ហាកម្ពុជាក្នុងកម្រិតអន្តរជាតិ និងក្នុងកម្រិតថ្នាក់តំបន់ មានឥទ្ធិពលយ៉ាងខ្លាំងចំពោះដំណើរសកម្មភាពអាស៊ានទៅថ្ងៃអនាគត។ ចំពោះគោលការណ៍ប្រឆាំងនឹងលទ្ធិកុម្មុយនីស្តនិយម របស់អាស៊ានបានបាត់បង់លក្ខណៈជាក់ស្តែង ម្យ៉ាងវិញទៀត បន្ទាប់ពីសូវៀតដួលរលំ(១៩៩១) បានផ្តល់លទ្ធភាពយ៉ាងល្អដល់នយោបាយទំនាក់ទំនង «បូព៌ា-បស្ចិម»។ មានអ្នកទស្សន៍ទាយនយោបាយជាច្រើនបានទស្សទាយថា អាស៊ាននឹងត្រូវបាត់បង់។ ពួកគេគិតថានៅក្នុងស្ថានភាពនៃសង្គ្រាមត្រជាក់ នឹងធ្វើឱ្យសមាគមបាត់បង់អត្តិភាពរបស់ខ្លួន។ គេមិនបានគិតទៅដល់ថាអាស៊ានបានកើតឡើង និងធ្វើសកម្មភាពរបស់ខ្លួននៅក្នុងស្ថានភាពប្រកបទៅដោយការតស៊ូ និងស្មុគស្មាញជាទីបំផុត។ ជាការពិតណាស់ហើយនៅក្នុងដំណាក់កាលសង្គ្រាមត្រជាក់អាស៊ានបានជួបបញ្ហាលំបាកយ៉ាងច្រើន តែគេមិនបានវាយតម្លៃពីលទ្ធផល ដែលអាស៊ានបានឆ្លងកាត់បន្តិចម្តងៗដោយកម្លាំងរបស់ខ្លួនផ្ទាល់។

មេដឹកនាំអាស៊ានបានប្រឹងប្រែងធ្វើដំណោះស្រាយបញ្ហាថ្មីនៅក្នុងតំបន់ ទុកដូចជាបញ្ហារួម ដើម្បីការពារដល់ស្ថិរភាព សន្តិភាព និងសន្តិសុខនៅក្នុងតំបន់ ប្រឹងប្រែងពង្រឹង ពង្រីកស្ថានភាពសមាគម ថ្នាក់តំបន់តាមរយៈការបង្កើន សមាជិកភាព។ ជំហានទី១ ដែលគេធ្វើ ដើម្បីបំពេញនូវកម្មវិធីនេះ គឺការភ្ជាប់ប្រទេសឥណ្ឌូចិន និងភូមា ទៅនឹងកិច្ចព្រមព្រៀងស្តីពីមិត្តភាព និងកិច្ចសហប្រតិបត្តិការ (១៩៧៦) គេគិតថា នេះជាជំហានដ៏ប្រសើរដើម្បីបញ្ចូលសមាជិកថ្មីទៅក្នុងសមាគមអាស៊ាន។

សេចក្តីប្រកាសរួមរបស់អាស៊ាននៅទីក្រុងសិង្ហបុរី បានគូសបញ្ជាក់ស្តីពីការដោះស្រាយបញ្ហាកម្ពុជាឱ្យបានទាំងស្រុង អនុវត្តផែនការទំនាក់ទំនងស្អិតរមួតជាមួយប្រទេសកម្ពុជា វៀតណាម ឡាវ និងបំពេញបានយ៉ាងសកម្មនៃ កម្មវិធីអន្តរជាតិ ហេតុដូចម្តេចបានជាមិនមែនចិន?។ នៅក្នុងសន្និសីទលោក ស៊ូហាតូប្រធានាធិបតេយ្យប្រទេស ឥណ្ឌូណេស៊ី បានគូសបញ្ជាក់នូវកត្តាចាំបាច់ពង្រឹងទំនាក់ទំនងរវាងប្រទេសអាស៊ាន និង ប្រទេសដៃគូដទៃទៀតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍។ «ប្រទេសឥណ្ឌូណេស៊ីបានស្វាគមចំពោះប្រទេសវៀតណាម និងឡាវ ដែលមានបំណងចង់បានកិច្ចសហប្រតិបត្តិការជាមួយនឹងអាស៊ាន» លោក ស៊ូ ហាតូ បានគូសបញ្ជាក់បន្ថែមទៀតថា «បេក្ខជនបន្ទាប់ទៀតនោះ គឺ កម្ពុជា និងភូមា»។

សាធារណរដ្ឋសង្គមនិយមវៀតណាម បានយល់ច្បាស់ថា ប្រទេសអាស៊ាន បានផ្តល់អាទិភាពរបស់ខ្លួនក្នុងដំណោះស្រាយបញ្ហាកម្ពុជា ហើយទន្ទឹមនឹងនេះក៏ជាការថយចុះនៃនយោបាយវៀតណាម នៅក្នុងឥណ្ឌូចិន គឺការបាត់បង់ «ទំនាក់ទំនងពិសេស» រវាងប្រទេសទាំងបី។ នៅក្នុងស្ថានភាពនេះប្រទេសវៀតណាមបានដាក់

ទិសដៅថ្មីនៃនយោបាយរបស់ខ្លួន ដែលមានលក្ខណៈម្ចាស់ការឯករាជ្យ និងទំនាក់ទំនងវិស័យផ្សេងៗ ជាមួយនឹងប្រទេសលើសាកលលោក ជាពិសេសពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាស៊ានដោយធ្វើសមាហរណកម្មមួយជំហានម្តងៗ ជាមួយគ្នា។ គេអាចអះអាងថា បើមិនផ្លាស់ប្តូរភូមិសាស្ត្រទេនោះ យើងក៏មិនអាចផ្លាស់ប្តូរនយោបាយតំបន់បានដែរ។

ប្រទេសឥណ្ឌូចិន បានដកខ្លួនថយពីស្ថានភាពមនោគមន៍វិជ្ជា នៅក្នុងនយោបាយក្រៅប្រទេសទៅកិច្ចសហប្រតិបត្តិការជាមួយប្រទេសអាស៊ានទាំង៦ និងនៅក្នុងរង្វង់នយោបាយសេដ្ឋកិច្ចរបស់គេ។ ចំណែកប្រទេសអាស៊ាន ក្រោយសង្គ្រាមត្រជាក់ បានប្រឹងប្រែងពង្រឹងកម្លាំងរបស់ខ្លួន យកចិត្តទុកដាក់ជាខ្លាំងចំពោះការអភិវឌ្ឍសេដ្ឋកិច្ច ដែលជាកូន សោរស្ថិរភាពជាតិ និងស្ថិរភាពតំបន់។

ដើម្បីការពារផលប្រយោជន៍រួមរបស់សមាគម និងសកម្មភាពរបស់ប្រទេស ដែលមានកម្លាំងសេដ្ឋកិច្ចខ្លាំង អាស៊ាន បានអនុម័តបង្កើតតំបន់ពាណិជ្ជកម្មសេរី (AFTA) និងបង្កើតទំនាក់ទំនងជាមួយសហភាពអឺរ៉ុប ដើម្បីបង្កើតទំនាក់ ទំនងទ្វេភាគី ASEAN-EU ម្យ៉ាងទៀតដើម្បីបង្កើតទំនាក់ទំនងត្រីកោណ ASEAN-American-Europe។

មកដល់ឆ្នាំ១៩៩២ ទំនាក់ទំនងរវាងអាស៊ាន-ឥណ្ឌូចិន ឈានកាន់តែប្រសើរមួយកម្រិតទៀត ដែលប្រទេសនៅក្នុងតំបន់ព្យាយាមពិភាក្សាគ្នាស្វែងរកយន្តការថ្មី ក្នុងការធ្វើសហប្រតិបត្តិការ។ ប្រទេសវៀតណាម និងឡាវ បានបង្ហាញវត្តមានក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេសអាស៊ាន ដែលធ្វើឡើងនៅទីក្រុងម៉ានីល ចាប់ពីថ្ងៃទី២១-២២ ខែកក្កដា ឆ្នាំ១៩៩២ ដែលក្នុងឱកាសនោះរដ្ឋមន្ត្រីការបរទេសវៀតណាម និងឡាវ បានប្រគល់ឯកសារស្តីពីការភ្ជាប់ប្រទេស ទាំងពីរទៅនឹងកិច្ចព្រមព្រៀងស្តីអំពីមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ មានន័យថា ប្រទេសទាំងពីរបានទទួលនាទីជាអ្នកសង្កេតការណ៍ និងមានសិទ្ធិមួយជំហានថ្មីទៀត គឺការចូលជាសមាជិកពេញសិទ្ធិ របស់អាស៊ាន។ អាស៊ានបានសន្យានឹងបញ្ចូលប្រទេសទាំងពីរ នៅពេលដែលបានបញ្ចប់ដំណោះស្រាយបញ្ហា នៅប្រទេសកម្ពុជា។

នៅក្នុងឱកាសខួបទី២៥ របស់អាស៊ាន ប្រទេសកម្ពុជា និងភូមាក៏បានចូលរួមជាមួយដែរ ទន្ទឹមនឹងនេះគឺក៏បាន បង្ហាញពីបំណងចូលរួមជាមួយអាស៊ានផងដែរ។ សម្តេចក្រុមព្រះបានប្រកាសថា «កម្ពុជានឹងប្រឹងប្រែងដើម្បីក្លាយទៅជាសមាជិកពេញសិទ្ធិរបស់អាស៊ាន»។

នៅឆ្នាំ១៩៩៣ ជាដំណាក់កាលដែលតំណាងអង្គការសហប្រជាជាតិ UNTAC រៀបចំការបោះឆ្នោតជាសាកលនៅកម្ពុជា។ ក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ គេបានបង្កើត រដ្ឋាភិបាលចំរុះពីគ្រប់គណបក្ស លើកលែងតែពួកខ្មែរក្រហម ទោះបីគេបានចុះហត្ថលេខាលើសន្ធិសញ្ញា ក្រុងប៉ារីស និងបានចូលរួមនៅក្នុងដំណាក់កាលចរចាសន្តិភាពក៏ដោយ ប៉ុន្តែពួកគេបានប្រឆាំងនឹងការបោះឆ្នោតសេរីនេះ។ នៅថ្ងៃទី២៤ ខែកញ្ញា ១៩៩៣ មានការអនុម័តរដ្ឋធម្មនុញ្ញថ្មីរបស់ប្រទេសកម្ពុជា ដើម្បីបង្កើត «ព្រះរាជាណាចក្រកម្ពុជា» ជាផ្លូវការ ដែលមានសម្តេច នរោត្តម សីហនុ ជាព្រះមហាក្សត្រ។ ប្រទេសអាស៊ានបានទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត និងទទួលស្គាល់រដ្ឋាភិបាលចម្រុះ ថែមទាំងបាន អញ្ជើញប្រទេសកម្ពុជា (ដោយសិង្ហបុរី) ក្នុងឋានៈជាភ្ញៀវពិសេសចូលរួមក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេស អាស៊ានជារៀងរាល់ឆ្នាំទៀតផង។

តួនាទីអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជាត្រូវបានបញ្ចប់ ប៉ុន្តែមិនមែនបានន័យថា បញ្ហាកម្ពុជាត្រូវបាន ដោះស្រាយទាំងស្រុងនោះទេ។ ប៉ុន្តែការបញ្ចូលវៀតណាមជាសមាជិកអាស៊ាន ត្រូវបានពន្លឿន។ ប្រទេសវៀតណាម ត្រូវបានគេចាប់អារម្មណ៍ប្រៀបដូចជាប្រភពវត្ថុធាតុដើម និងកម្លាំងពលករថោក ដែល

ប្រកបដោយបច្ចេកទេសខ្ពស់ និងម្យ៉ាងទៀតក៏ជាទីផ្សារដ៏ធំសម្រាប់ប្រទេសអាស៊ានផងដែរ។ នាពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសវៀតណាម ទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់ ដែលមានសន្ទុះស្មើនឹងប្រទេសចិន។ កំណើនឧស្សាហកម្មក្នុងមួយឆ្នាំបានកើនដល់១៣៥ រីឯអតិផរណាបានធ្លាក់ចុះមកដល់កម្រិតទាបបំផុត។ មានអ្នកនយោបាយមួយចំនួនបានវាយតម្លៃថា ហាណូយ មិនសុខចិត្តដើរតួជាអ្នកទី២ នៅក្នុងចំណោមប្រទេសអាស៊ានទេ ។ មិនមែនជារឿងចៃដន្យទេ ដែលមេដឹកនាំវៀតណាម បានគូសបញ្ជាក់ជាច្រើនលើកច្រើនសារថា វៀតណាមបានចូលជាសមាជិកអាស៊ានចំពេលល្អណាស់។

ទន្ទឹមនឹងនេះមេដឹកនាំប្រទេសអាស៊ានក៏បានវាយតម្លៃជាវិជ្ជមាន និងអវិជ្ជមានចំពោះការបញ្ចូលប្រទេសឥណ្ឌូចិនជាសមាជិកអាស៊ាន។ ឈរលើទស្សនៈនយោបាយ យោធា និងសេដ្ឋកិច្ច ក្នុងនាមអាស៊ានជាសមាគមនៅក្នុងតំបន់ ត្រូវតែប្រឹងប្រែងដើម្បីបង្កើតបរិយាកាសតែមួយនៅក្នុងតំបន់ដែលមានទិសដៅការពារស្ថិរភាព និងសន្តិភាព នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល និងដើម្បីអភិវឌ្ឍសេដ្ឋកិច្ច។ ម្យ៉ាងវិញទៀតការទទួលយកប្រទេសវៀតណាម និងឡាវ ជាសមាជិកអាស៊ាន នឹងមានការលំបាកដល់សមាគមច្រើន ដែលអាចឱ្យមានបញ្ហាស្មុគស្មាញដល់ទំនាក់ទំនងរបស់សមាគមជាមួយប្រទេសលោកខាងលិច(ជាពិសេស សហរដ្ឋអាម៉េរិក)។ អ្នកដែលប្រឆាំងទស្សនៈតំបន់ភាវូបនីយកម្ម បានអះអាងថា គ្រោះថ្នាក់នឹងមានមកដល់អាស៊ានព្រោះប្រទេសឡាវ និងវៀតណាមគ្មានទីផ្សារ ដែលមានតម្លៃសេរី ម្យ៉ាងវិញទៀតភាពក្រីក្ររបស់ប្រទេសឥណ្ឌូចិននឹងគៀបសង្កត់ប្រទេសដទៃទៀត ដោយអះអាងអំពីសាមគ្គីភាព និងភាពជាផ្សារួមនៅក្នុងអាស៊ាន។

ចំពោះវៀតណាមបានប្រឹងប្រែង ប្រើអត្ថិភាពអាស៊ាន ដើម្បីពង្រឹងគោលជំហររបស់ខ្លួននៅក្នុង ទំនាក់ទំនងជា មួយនឹងប្រទេសចិន និងមហាអំណាចដទៃទៀត។ នៅក្នុងសម័យប្រជុំពេញអង្គសន្និសីទ ប្រជាជននៃសាធារណរដ្ឋ សង្គមនិយមវៀតណាម ដែលប្រព្រឹត្តទៅនៅខែសីហា ឆ្នាំ១៩៩៣ លោក **វ៉ូ វ៉ាន់គៀត** បានគូសបញ្ជាក់ថា ផលប្រយោជន៍របស់វៀតណាម ផ្សារភ្ជាប់នឹងផលប្រយោជន៍របស់វៀតណាមក្នុងតំបន់។ វៀតណាមប្រឹងប្រែងគាំទ្រដល់ការបង្កើតសន្តិភាព ស្ថិរភាព និងមិត្តភាពនៅក្នុងភូមិភាគ អាស៊ីអាគ្នេយ៍។

តែពួកនយោបាយវិទូលោកខាងលិចបានទស្សទាយថា **នៅក្នុងជួរប្រទេសអាស៊ានគ្មានឯកភាពទេ** ។ គេចង់វាយតម្លៃថា វត្តមានរបស់វៀតណាមដែលជាប្រទេសកុម្មុយនីស្ត នៅក្នុងសមាគមអាស៊ាន នឹងទាមទារឱ្យមានបម្រែបម្រួលទំនាក់ទំនងនយោបាយខាងក្រៅរបស់អាស៊ានដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អាស៊ានបានបង្ហាញថា បើសិនជាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ប្រាកដជាចង់រួបរួមឯកភាពគ្នាមែននោះ គ្មានមនោគមន៍វិជ្ជានយោបាយណា អាចមករាំងស្ទះពួកគេបានឡើយ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៩៥ សន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន ដែលប្រព្រឹត្តទៅក្នុងប្រទេសប្រ៊ុយណេ គេបានប្រកាសបញ្ចូលសាធារណរដ្ឋសង្គមនិយមវៀតណាម ឱ្យចូលជាសមាជិកពេញសិទ្ធិរបស់ អាស៊ាន។ ព្រឹត្តិការណ៍នេះចាត់ទុកថា បានបើកទំព័រប្រវត្តិសាស្ត្រអាស៊ាន និងលើកកម្ពស់តួនាទីអាស៊ានកាន់តែខ្ពស់នៅក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិក។

ការបញ្ចូលប្រទេសវៀតណាមជាសមាជិកអាស៊ាន ដែលជាប្រទេសមានកម្លាំងយោធា និងសេដ្ឋកិច្ចអាចបម្រែបម្រួលលំនឹងកម្លាំងនៅក្នុងតំបន់។ ទោះជាយ៉ាងណានៅក្នុងសមុទ្ទចិនខាងត្បូង ទំនាស់នៅតែបន្តជុំវិញបញ្ហាប្រជុំ កោះស្ព្រាតលី។ បន្ទាប់ពីប្រទេសវៀតណាមបានក្លាយជាសមាជិកពេញសិទ្ធិរបស់អាស៊ាន ប្រទេសឡាវ ភូមា និងកម្ពុជា នៅក្រៅអាស៊ានគ្រាន់តែជាលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ។

បើសិនជាយើងពិនិត្យមើលប្រទេសឡាវ ដែលជាអ្នកសង្កេតការណ៍បានយល់ថា មិនមែនជាការងាយស្រួលទេ ក្នុងការបំពេញកាតព្វកិច្ចជាសមាជិកអាស៊ាន ព្រោះត្រូវយកលុយទៅដាក់ក្នុងមូលនិធិអាស៊ានចំនួន ១លានដុល្លារ នៅឆ្នាំដំបូង ហើយត្រូវបង់ជាបន្តបន្ទាប់ទៀត។ ក្នុងខណៈនេះប្រទេសឡាវ មិនបានប្រឹងប្រែងបង្ខំចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ានភ្លាមទេ។ ប៉ុន្តែទោះជាយ៉ាងណានៅពេលដែលវៀតណាមបានក្លាយជាសមាជិកពេញសិទ្ធិ របស់អាស៊ាន គឺមានឥទ្ធិពលយ៉ាងខ្លាំងចំពោះប្រទេសដទៃទៀតក្នុងការចូលជាសមាជិកសមាគម។ នយោបាយវៀតណាមមានទិសដៅចង់ឱ្យដៃគូរបស់ខ្លួន មានប្រទេសឡាវ និងប្រទេសកម្ពុជា ចូលជាសមាជិកពេញសិទ្ធិដែរ ព្រោះអាចជួយគាំទ្រ ដល់គំនិតផ្តួចផ្តើមរបស់វៀតណាមលើគ្រប់វិស័យក្នុងរង្វង់អាស៊ាន។

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៥ ប្រទេសកម្ពុជាបានភ្ជាប់ខ្លួនទៅនឹងកិច្ចព្រមព្រៀងស្តីអំពីមិត្តភាព និងសហប្រតិបត្តិការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ នៅខែកក្កដា ១៩៩៥ នៅក្នុងសន្និសីទលើកទី២៨ ថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន ប្រទេសកម្ពុជាទទួលលក្ខណៈ ជាអ្នកសង្កេតការណ៍។

នៅក្នុងសន្និសីទនេះដែរ ប្រទេសភូមាក៏បានធ្វើសំណើសុំធ្វើជាអ្នកសង្កេតការណ៍អាស៊ាន។ សំណើរបស់ភូមា ឆ្លើយតបទៅនឹងទិសដៅរបស់អាស៊ាន ដែលចង់ធ្វើឱ្យក្រុងរ៉ុងហ្គោន នៅដាច់ឆ្ងាយពីក្រុងប៉េកាំង។ អាស៊ានចង់ឃើញ ប្រទេសភូមានៅក្នុងក្លឹបរបស់ខ្លួន ជាជាងនៅក្នុងក្រុមដទៃ។ ម្យ៉ាងទៀតអាស៊ានក៏មើលឃើញដែរថា ភូមាសម្រាប់អាស៊ាន គឺជាគូកនមួយខ្សោយ មិនត្រឹមតែលើវិស័យសេដ្ឋកិច្ចនោះទេ ព្រមទាំងភាពប្រក្រតីនៅក្នុងសង្គមថែមទៀត។ ក្រោយដែលអំណាចយោធាភូមា មិនព្រមទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ឆ្នាំ១៩៩០ មក សហរដ្ឋអាម៉េរិក និងប្រទេសលោកខាងលិច បានទិទៀនអាស៊ានក្នុងការធ្វើ ទំនាក់ទំនងជាមួយនឹងភូមា។

ក្នុងកិច្ចប្រជុំកមពូលអាស៊ាន នៅក្រុងបាងកក នាខែធ្នូ ឆ្នាំ១៩៩៥ នៅក្នុងសេចក្តីប្រកាសគេបានអះអាងថា ដល់ចុងសតវត្សទី២០ អាស៊ាននឹងបង្រួបបង្រួមប្រទេសទាំង១០ នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍។ ឯកសារដ៏សំខាន់ដែលគេបានចុះហត្ថលេខានៅក្នុងសន្និសីទនេះ គឺជាកិច្ចព្រមព្រៀងស្តីពីការបង្កើតភូមិភាគអាស៊ីអាគ្នេយ៍គ្មានអាវុធ នុយក្លេអ៊ែរ។

អាស៊ានបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងអង្គការ APEC ដែលបានបង្កើតឡើងនៅឆ្នាំ១៩៨៨ ហើយបានប្រឹងប្រែងពង្រឹងតួនាទី របស់ខ្លួនយ៉ាងខ្លាំងនៅលើឆាកអន្តរជាតិ ពិសេសមានទិសដៅបង្កើតទំនាក់ទំនងជាមួយនឹងប្រទេសអឺរ៉ុប។ នៅខែមីនា ឆ្នាំ១៩៩៦ នៅទីក្រុងបាងកក បានប្រព្រឹត្តឡើងនូវជំនួបរវាងមេដឹកនាំ EU ចំនួន១៥ ប្រទេស ជាមួយមេដឹកនាំប្រទេសភូមិភាគអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ចំនួន១០ប្រទេស (៧ប្រទេសជាសមាជិកអាស៊ាន រួមជាមួយប្រទេសចិន កូរ៉េខាងត្បូង និងជប៉ុន)។ ជំនួបបានផ្តើមការងារវេទិកា "អាស៊ី-អឺរ៉ុប" ហើយទៅថ្ងៃអនាគត ប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសភូមា ក៏អាចចូលរួមក្នុងវេទិកា នេះដែរ។

រដ្ឋមន្ត្រីការបរទេសអាស៊ាន បានមូលមតិគ្នាអំពីការបញ្ចូល ប្រទេសកម្ពុជា ឡាវ និងភូមា នៅខែកក្កដា ឆ្នាំ១៩៩៧ ជំណាលគ្នាតែម្តង។ នៅពាក់កណ្តាលខែសីហា ឆ្នាំ១៩៩៦ ប្រទេសភូមា បានធ្វើសំណើចូលជាសមាជិកពេញសិទ្ធិអាស៊ាន ទោះបីជាមានការរិះគន់ពីសហរដ្ឋអាម៉េរិកក៏ដោយ ក៏ប្រទេសអាស៊ានចាត់ទុក «នេះជាបញ្ហាផ្ទៃក្នុងរបស់អាស៊ាន និងជាវិធីមួយយ៉ាងល្អប្រសើរ ដើម្បីស្វែងរកស្ថិរភាពនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូល ដោយទី១ ត្រូវឯករាជ្យពីប្រទេសកំពូលមហាអំណាច និងទី២ មិនអាស្រ័យលើគោលនយោបាយ បើសិនជាប្រទេសអាស៊ីអាគ្នេយ៍ ពិតជាចង់បង្រួបបង្រួមគ្នាតែមួយពិតមែនគេត្រូវតែធ្វើបាន»។

ចាប់តាំងពីថ្ងៃដែលអាស៊ាន ចាប់បដិសន្ធិឡើង គោលនយោបាយរបស់គេ គឺមិនលូកដៃចូលកិច្ចការផ្ទៃក្នុងគ្នា ទៅវិញទៅមក។ ក៏ប៉ុន្តែគោលការណ៍នេះ វាអាចប្រែប្រួលទៅតាមលក្ខណៈជាក់ស្តែងរបស់អាស៊ានតែប៉ុណ្ណោះ នៅពេលនោះដោយយោងលើមូលហេតុបីយ៉ាង៖

១.មិនផ្តល់លទ្ធភាពឱ្យមានការគាំទ្រពីមហាអំណាច ដល់ចលនាកុម្មុយនីស្ត ឬចលនាផ្សេងៗទៀត នៅក្នុងប្រទេសរបស់ខ្លួន។

២.ដោយសារលក្ខខណ្ឌសេដ្ឋកិច្ចនៅមានកម្រិតទាប ដោយបញ្ហាសញ្ជាតិ ជំនឿសាសនា និងនយោបាយផ្សេងគ្នា អាចនាំឱ្យមានការផ្ទុះឡើងនូវទំនាស់គ្មានព្រៀងទុក។

៣.រដ្ឋាភិបាលនៃសមាជិកអាស៊ាន មិនចង់ឱ្យបញ្ហាផ្ទៃក្នុងតំបន់ខ្លួន ត្រូវបានពិភាក្សាដោយប្រទេសដទៃទៀត ក្រៅតំបន់។

ប្រទេសអាស៊ានបានដឹកនាំនយោបាយតាមវិធី **«ដេញចាប់ទន្សាយពីរក្នុងពេលតែមួយ»** គឺស្ថិរភាព និងប្រជាធិបតេយ្យ។ វិធីសាស្ត្រដែលអាស៊ានចង់ប្រើប្រាស់គឺតម្រូវពីរស្ថានភាព៖

-ពីខាងក្រៅ គឺមហាអំណាចដែលទាមទារឱ្យមានលទ្ធិប្រជាធិបតេយ្យ ។

-ក្នុងតំបន់ដែលប្រឆាំងនឹងការលូកដៃចូលមកពីខាងក្រៅ រំខាន់ដល់ភូមិភាគអាស៊ីអាគ្នេយ៍។

លោក **ស៊ូហាតូ** ប្រធានាធិបតីប្រទេសឥណ្ឌូណេស៊ី នៅក្នុងឱកាសជួបពិភាក្សាជាមួយនាយករដ្ឋមន្ត្រីថៃ នៅចុងឆ្នាំ១៩៩៦ បានគូសបញ្ជាក់ថា បើពន្យារពេលបញ្ចូលប្រទេសឡាវ កម្ពុជា និងភូមា ជាសមាជិកអាស៊ាន គឺជាកាយវិការ នាំមកនូវផលអវិជ្ជមានដល់គម្រោងបង្កើត **«អាស៊ាន-១០»** នៅភូមិភាគអាស៊ីអាគ្នេយ៍ និងម្យ៉ាងទៀតក៏ពន្យឺតទិសដៅ នយោបាយឯករាជ្យរបស់អាស៊ានក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ស្ថានភាពនេះនឹងឆ្លើយតបទៅនឹងបំណងរបស់សហរដ្ឋអាម៉េរិក និងចិន ដែលមិនចង់ឱ្យអាស៊ានពង្រឹងកម្លាំងរបស់ខ្លួននោះទេ។ ដោយយោលទៅលើស្ថានភាពបែបនេះ នៅខែធ្នូ ឆ្នាំ១៩៩៦ នៅក្នុងជំនួបមេដឹកនាំអាស៊ាន គេបានស្រុះស្រួលគ្នាបញ្ចូលប្រទេសកម្ពុជា ឡាវ និងភូមា ជាសមាជិកអាស៊ាន នៅឆ្នាំ១៩៩៧។

ក្នុងឱកាសប្រារព្ធខួបលើកទី៣០ របស់អាស៊ាន ប្រទេសឡាវ និងភូមា ត្រូវបានគេបញ្ចូលជាសមាជិកពេញសិទ្ធិ ដោយឡែកប្រទេសកម្ពុជា ត្រូវបានគេពន្យាពេលមួយរយៈសិន ដោយសារជួបវិបត្តិនយោបាយ (ព្រឹត្តិការណ៍ថ្ងៃ៥-៦ ខែកក្កដា ឆ្នាំ១៩៩៧)។ សមាជិកសន្និសីទបានថ្លែងនូវសេចក្តីសោកស្តាយ ដែលប្រទេសកម្ពុជាមិនអាចរៀបចំស្ថានភាព ដើម្បីចូលជាសមាជិកអាស៊ានបាន ហើយគេបានអះអាងថា ចំពោះឋានៈជាអ្នកសង្កេតការណ៍ ត្រូវការថែរក្សាទុក។

ពេលនោះអាស៊ាន មិនចង់ទទួលយកប្រទេសកម្ពុជា ជាសមាជិកអាស៊ានក្នុងសភាពបែបនេះទេ បានន័យថា អាស៊ានទទួលស្គាល់រដ្ឋាភិបាល ដែលដឹកនាំដោយសម្តេចហ៊ុនសែន។ ដោយឈរលើគោលការណ៍អព្យាក្រឹត្យ ជុំវិញបញ្ហាកម្ពុជា អាស៊ាននៅតែទទួលស្គាល់រដ្ឋាភិបាលសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងសម្តេចហ៊ុន សែន ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ អាស៊ាន បានបង្ហាញឥរិយាបថរបស់ខ្លួនដោយប្រយោលថា អាស៊ានមិនពេញចិត្តនូវការប្រើកម្លាំងយោធាដោយគូភាគីទាំងសងខាងនៅក្នុងដំណោះស្រាយទំនាស់ ឬបម្រែបម្រួលស្ថានភាពនយោបាយ នៅក្នុងប្រទេស ម្យ៉ាងទៀតក៏អាស៊ានមិនចង់ឱ្យបញ្ហាកម្ពុជាចូលមកក្នុងផ្ទះរបស់គេទេ។ ជាទូទៅការពង្រីកសមាជិកថ្មីរបស់អាស៊ាន ចាំបាច់ប្រទេសនោះត្រូវគោរព **គោលការណ៍អាស៊ាន។**

មេដឹកនាំអាស៊ានបានយកចិត្តទុកដាក់ចំពោះទស្សនៈរបស់កម្ពុជា ដែលបានថ្លែងដោយរដ្ឋមន្ត្រីការបរទេស លោក អ៊ឹង ហួត និងសម្តេចហ៊ុន សែន ស្តីអំពីការទទួលយកវត្តមានរបស់ប្រទេសអាស៊ាន ក្នុងការស្វែងរកស្ថិរភាព នយោបាយនៅក្នុងប្រទេសកម្ពុជា។

ដោយយកចិត្តទុកដាក់ចំពោះបញ្ហាដែលកើតឡើងនៅកម្ពុជា គេបានបង្កើតរចនាសម្ពន្ធអន្តរជាតិពីរដើម្បីដោះស្រាយ បញ្ហាកម្ពុជាចេញពីវិបត្តិ។ ក្រោមការត្រួតពិនិត្យពីUN គេបានបង្កើតក្រុមមិនផ្លូវការមួយជាមិត្តភក្តិកម្ពុជា ដែលចូលរួមដោយសមាជិកសន្និសីទទីក្រុងប៉ារីសស្តីពីបញ្ហាកម្ពុជា និងនៅកម្រិតថ្នាក់តំបន់បានបង្កើតប្រទេស **ត្រីភាគី** អាស៊ាន ដែលមានប្រទេសថៃ ហ្វីលីពីន និងឥណ្ឌូណេស៊ី។ ប្រទេសអាស៊ានទាំងបីបានចូលរួមយ៉ាងសកម្ម ជាមួយនឹងប្រទេសជាមិត្តរបស់កម្ពុជា គេបានយកចិត្តទុកដាក់ចំពោះបញ្ហា ធ្វើយ៉ាងណាដើម្បីបញ្ឈប់ការបាញ់គ្នា រវាងបក្សជំទាស់ ទាំងសងខាង ឱ្យធ្វើការបោះឆ្នោតសភាជាតិនៅឆ្នាំ១៩៩៨ ដោយស្របតាមគម្រោងដែលបានគ្រោងទុកតាំងពីមុន រួចមកហើយ និងចំពោះបញ្ហាអនាគតរបស់ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ និងការចូលរួមក្នុងការបោះឆ្នោតរបស់ព្រះអង្គ។

នយោបាយអាស៊ានមានទិសដៅប្រឹងប្រែង ដើម្បីកុំឱ្យមហាអំណាចនៅក្រៅតំបន់ ចូលមកលូកដៃក្នុងរឿងកម្ពុជា រហូតដល់ប្រទេសកម្ពុជាក្លាយជាសមាជិករបស់អាស៊ាន។ កម្មវិធីដើម្បីបំពេញនូវទិសដៅនេះ គេបានអនុម័តស្តង់ដារ( Standard )មួយ ដែលសម្រាប់សមាជិកចាស់ដ៏ដូចជាសមាជិកថ្មីរបស់អាស៊ាន។

នៅក្នុងខណៈដែលមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៥២ បានសម្រេចចិត្តថា ទុកអាសនៈកម្ពុជា ឱ្យនៅទំនេរ រីឯសហរដ្ឋអាម៉េរិកបានបញ្ឈប់រាល់រូបភាពជំនួយមកដល់ប្រទេសកម្ពុជា។ ប្រទេសអាស៊ានបានអនុម័តយក តាមគម្រោងរបស់ប្រទេសជប៉ុន។ គម្រោងរបស់ជប៉ុន គឺមានកម្មវិធីបង្កើតឱ្យមានការកាត់ទោសសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ការលើកលែងទោសដោយព្រះមហាក្សត្រ និងការចូលរួមក្នុងការបោះឆ្នោតឆ្នាំ១៩៩៨។

លទ្ធផលនៃការបោះឆ្នោត គឺគណបក្សប្រជាជនកម្ពុជា ទទួលបានជ័យជម្នះ។ ការបោះឆ្នោតបានប្រព្រឹត្តទៅក្រោមការសើបអង្កេតដោយតំណាងនៃប្រទេសបារាំង និងប្រទេសអាស៊ាន។ លទ្ធផលនៃការបោះឆ្នោតក៏ត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិផងដែរ។ ដូចនេះសមាជិកភាពកម្ពុជាក្នុងអាស៊ានកាន់តែប្រសើរឡើង។

នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន នាទីក្រុងហាណូយ ក្នុងខែធ្នូ ឆ្នាំ១៩៩៨ បានសម្រេចបញ្ចូលប្រទេសកម្ពុជា ជាសមាជិកទី១០ របស់អាស៊ាន ប៉ុន្តែរដ្ឋមន្ត្រីក្រសួងការបរទេសអាស៊ាន បានទទួលបទបញ្ជាឱ្យរៀបចំពិធីបញ្ចូលកម្ពុជា ជាសមាជិកផ្លូវការនៅឆ្នាំ១៩៩៩។ ដូច្នេះពិធីនេះត្រូវបានប្រារព្ធឡើងដោយការពន្យាពេល។

ស្ថានភាពនេះបានបញ្ជាក់ថា មេដឹកនាំរបស់អាស៊ាន បានសម្រេចចិត្តចំពោះបញ្ហានេះ ដោយផ្សេងៗពីគ្នា។ ប្រទេសហ្វីលីពីន ថៃ និងសិង្ហបុរី បានជំទាស់ចំពោះការប្រញាប់ប្រញាល់ខ្លាំងពេក នៅពេលដែលប្រទេសកម្ពុជាមិនទាន់ដោះស្រាយបញ្ហាផ្ទៃក្នុងបានទាំងស្រុងនោះ កម្ពុជាមិនទាន់បានរៀបចំខ្លួនឱ្យបាន ពេញលេញ ដើម្បីចូលជាសមាជិករបស់អាស៊ាននោះទេ។ ដោយឡែកប្រទេសទាំងនេះចង់ឱ្យកម្ពុជា ជាដំបូងត្រូវបង្កើតព្រឹទ្ធសភា ដែលជាស្ថាប័នថ្មី ដោយមានការចូលរួមពីគណបក្សប្រជាជនកម្ពុជា បក្សហ្វុនស៊ិនប៉ិច និងបក្សសមរង្ស៊ី។ ក្រៅពីនេះនៅសល់បញ្ហា ពួកខ្មែរក្រហម ដែលត្រូវដោះស្រាយដោយសន្តិវិធី និងជាស្ថាពរ។ ចំពោះបញ្ហាជនឥន្តោប្រវេសន៍ ពីប្រទេសកម្ពុជាទៅប្រទេសថៃ ក៏ជារបាំងក្នុងការចូលជាសមាជិកអាស៊ាន

របស់កម្ពុជាដែរ។ ដើម្បីឱ្យប្រទេសកម្ពុជាក្លាយជាសមាជិក ពេញសិទ្ធិរបស់អាស៊ាន ត្រូវតែធ្វើសច្ចាប័នលើកិច្ចព្រមព្រៀង ២៦ចំណុច របស់អាស៊ាន នៅក្នុងសភាព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ នាទីក្រុងហាណូយ បានប្រារព្ធឡើងនូវពិធីបញ្ចូលព្រះរាជាណាចក្រកម្ពុជា ជាសមាជិកអាស៊ានផ្លូវការ។ មេដឹកនាំអាស៊ានបានគិតថាការបង្រួបបង្រួមប្រទេសភូមិភាគ អាស៊ីអាគ្នេយ៍នៅក្នុងសមាគម តែមួយ គឺជាក្តីស្រមៃជាង៣០ឆ្នាំ របស់បិតាស្ថាបនិកអាស៊ាន និងអាចគាំពារដល់ការប្រឆាំង និងការគំរាមកំហែងដោយនយោបាយ និងសេដ្ឋកិច្ចពីប្រទេសមហាអំណាច ដែលចង់ ប្រែក្លាយភូមិភាគអាស៊ីអាគ្នេយ៍ជាតំបន់ប្រគួតប្រជែង អំណាចគ្នា។

នៅពេលដែលបានបង្រួបបង្រួម **អាស៊ាន**-១០ រួចជាស្ថាពរមក សមាគមអាស៊ានបានទទួល សមិទ្ធផលដែលឆ្លើយតបទៅនឹងឈ្មោះរបស់ខ្លួន **សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍**-ASEAN ជាសមាគមសម្រាប់ប្រទេសទាំងអស់ នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ អាស៊ានទទួលសិទ្ធិក្នុងនាមតំណាងឱ្យប្រទេសទាំងអស់នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងត្រៀមខ្លួនទទួលបានកន្លែងដ៏រឹងមាំនៅ ក្នុងប្រព័ន្ធទំនាក់ទំនងនយោបាយអន្តរជាតិ។

ទន្ទឹមនឹងនេះដែរ មេដឹកនាំសមាគមបានសម្រេចចិត្តថា ការពង្រីកសមាជិកសមាគមត្រូវបញ្ចប់។ **អាស៊ានសម្រាប់ប្រទេស១០** នេះជាការគូសបញ្ជាក់របស់រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី លោក **បាដាវី**។ បានន័យថា បើសមាគមទទួលយកប្រទេសដទៃ ចូលជាសមាជិករបស់ខ្លួននោះអាស៊ាននឹងបាត់ភាពដើម របស់ខ្លួនជាក់ជាមិនខាន។

ជាមួយគ្នានេះដែរ សមាជិកអាស៊ានបានប្រកាសជាអចិន្ត្រៃយ៍ ស្តីអំពីការប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីផ្តល់លទ្ធភាពឱ្យប្រទេសដែលនៅក្រៅតំបន់ផ្សារភ្ជាប់ខ្លួននឹងកិច្ចព្រមព្រៀងឆ្នាំ១៩៧៦ បានន័យថាអាស៊ានមិនបានបិទទ្វាររបស់ខ្លួនទេទៅថ្ងៃអនាគត។ រដ្ឋមន្ត្រីក្រសួងការបរទេសសិង្ហបុរី បានគូសបញ្ជាក់ថា **បញ្ចូលប្រទេសកម្ពុជា ជាសមាជិកអាស៊ាន មិនមែនបានន័យថាបញ្ចប់ផ្លូវនោះទេ។ តំបន់អាស៊ី អាគ្នេយ៍បានបើកទ្វារជូនពិភពលោក យើងចង់ធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រទេសទាំងអស់។**

លទ្ធភាពថ្មីដើម្បីពង្រីកអាស៊ាន មានទំនាក់ទំនងទៅនឹងការទទួលឯករាជភាពរបស់ប្រទេសទីម័រខាងកើត ដែលស្ថិតនៅក្នុងសហព័ន្ធឥណ្ឌូណេស៊ីចាប់តាំងពីឆ្នាំ១៩៧៥។ បើសិនជាការពង្រីក អាស៊ានដោយយោលតាមអត្ថន័យ ជាភូមិសាស្ត្រនោះ ប្រទេសប៉ាពូញូហ្គីណេ ដែលសព្វថ្ងៃមានឋានៈជាអ្នកសង្កេតការណ៍អាស៊ាននោះ ក៏អាចរាប់បញ្ចូលផងដែរ។ ហេតុដូច្នេះការពង្រីកសមាគមអាស៊ាននៅបន្តធ្វើទៅទៀត។

នៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៣៣ ដែលបានប្រព្រឹត្តទៅនាវដូវក្តៅ ឆ្នាំ២០០០ ក្រៅពីរដ្ឋមន្ត្រីការបរទេសអាស៊ានទាំង១០ គឺមានរដ្ឋមន្ត្រីការបរទេសប្រទេស ប៉ាពូញូហ្គីណេ និងមានការចូលរួមផងដែរ ដោយតំណាងប្រទេសតតីយលោកនៃទ្វីបអាហ្វ្រិក និងតំណាងបណ្តោះអាសន្ន របស់អង្គការសហប្រជាជាតិសម្រាប់ ទីម័រខាងកើត ក្នុងឋានៈជាភ្ញៀវ ហើយក៏ជាចំណុចមួយ កំណត់លទ្ធភាពក្នុងការពង្រីកសមាគម។

ចាប់តាំងពីការបង្កើតអាស៊ានឡើងនៅខែសីហា ឆ្នាំ១៩៦៧ អាស៊ានមានសមាជិកតែ៥ប៉ុណ្ណោះ នៅពេលនោះ គ្មានអ្នកណានឹកស្មានបានទេថា ទីបំផុតអាស៊ានបានបំពេញទិសដៅរបស់ខ្លួន។ ប៉ុន្តែតាំងពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៨៣ គ្មានសមាជិកចូលថ្មីទេ ទាំងនេះក៏ដោយសារបញ្ហាការបែងចែកពិភពលោករបស់កំពូលមហាអំណាច។ នៅឆ្នាំ១៩៨៤ ទើបប្រទេសប្រ៊ុយណេ បានចូលជាសមាជិកទី៦របស់អាស៊ាន។ នៅឆ្នាំ១៩៩១ សង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ទើប គេឃើញថា ការចូលជាសមាជិកថ្មីរបស់អាស៊ានមានសន្ទុះយ៉ាង

ខ្លាំង។ នៅឆ្នាំ១៩៩៩ កម្ពុជាបានចូលជាសមាជិកទី១០របស់ អាស៊ាន។ សមាគមអាស៊ាន ត្រូវប្រើរយៈពេលអស់៣២ឆ្នាំ ដើម្បីបង្រួបបង្រួមប្រទេសទាំង១០ នៅភូមិភាគអាស៊ីអាគ្នេយ៍ ។

## ២-ការបង្កើត តំបន់ពាណិជ្ជកម្មសេរី អាស៊ាន

AFTA: Asean Free Trade Area

ថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៣ AFTA បានត្រូវប្រកាសបង្កើតជាផ្លូវការ។ ដំណាក់ដំបូង AFTA មានគោលដៅទាក់ទងនឹងការបញ្ចុះតម្លៃផលិតផលមួយចំនួន បន្ទាប់មកនឹងបើកឱ្យមានពាណិជ្ជកម្មសេរី។ ការបង្កើត AFTA ក៏មានគោលបំណងទាក់ទាញវិនិយោគទុន និងការរកផ្សារនៅតំបន់ឥណ្ឌូចិនផងដែរ។ សន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន លើកទី២៧ នៅទីក្រុងបាងកកពីថ្ងៃទី២២ ដល់ ២៣ ខែកក្កដា ឆ្នាំ១៩៩៤ បានចេញសេចក្តីថ្លែងការណ៍មួយ បញ្ជាក់សាជាថ្មីពីទិសដៅនាំ AFTA៖

- សម្រេចអនុវត្តលើកការបន្ថយតម្លៃទំនិញតាមកម្មវិធីឆ្នាំ១៩៩៤។
- លើកទឹកចិត្តចំពោះលំនាំចូលនៃវិនិយោគទុនបរទេស។
- ឯកភាពចំពោះការភ្ជាប់ពាណិជ្ជកម្ម ជាមួយតំបន់ដទៃទៀត ក្នុងពិភពលោកជាពហុភាគី។

នៅក្នុងកិច្ចប្រជុំលើកទី៥ ក្រុមប្រឹក្សា AFTA ដែលមានការចូលរួមពីរដ្ឋមន្ត្រីពាណិជ្ជកម្មអាស៊ាន បានចេញសេចក្តីថ្លែងការណ៍រួមក្នុងសន្និសីទកាសែត ដែលមានជាអាទិ៖

- ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៤ ប្រកាសកាត់បន្ថយរយៈពេលអនុវត្តផែនការ ពី១៥ឆ្នាំ មកត្រឹម១០ឆ្នាំ។
- ជំរុញចលនាសេរីនីយកម្មក្នុងបណ្តាប្រទេសអាស៊ាន។
- យោងតាមការសម្រួលថ្មី ផែនការ AFTA នឹងត្រូវសម្រេចបានជោគជ័យនៅថ្ងៃទី១ ខែមករា ឆ្នាំ ២០០៣ មុនគម្រោងចាស់ដែលកំណត់កាលបរិច្ឆេទដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០០៨។
- បញ្ចូល AFTA ទៅក្នុងអគ្គលេខាធិការដ្ឋានអាស៊ានដើម្បីជាជំនួយដល់ដំណោះស្រាយទំនាស់ផ្នែកពាណិជ្ជកម្មផ្សេងៗ ក្នុងចំណោមប្រទេសសមាជិកអាស៊ាន។

អាហ្វតា(AFTA) បានជួយតាមរយៈយន្តការសេរីភាវូបនីយកម្មពាណិជ្ជកម្មក្នុងតំបន់ដោយលុបបំបាត់ពន្ធក្នុងតំបន់មិនឱ្យលើសពី៥ភាគរយ និងជួយលុបបំបាត់ឧបសគ្គនានាដទៃផ្សេងទៀតដែលរាំងស្ទះដល់ការធ្វើពាណិជ្ជកម្ម។

តាមរបាយការណ៍របស់សហគមន៍សេដ្ឋកិច្ចអាស៊ាន បង្ហាញថា ទំហំពាណិជ្ជកម្មរវាងប្រទេសក្នុងតំបន់អាស៊ាន ចន្លោះពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៥ មានរហូតដល់៧០០ពាន់លានដុល្លា។ ក្រៅជួយដល់ការធ្វើពាណិជ្ជកម្មរវាងគ្នាជាមួយប្រទេសក្នុងតំបន់ អាហ្វតា (AFTA)ក៏បានជួយសម្រួលដល់ប្រទេសជាសមាជិកអាស៊ាន ដែលក្នុងនោះមានកម្ពុជាផងដែរនោះ មានភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មជាមួយបណ្តាប្រទេសដែលជាដៃគូរសន្ទនារបស់អាស៊ានមានដូចជាសហរដ្ឋអាម៉េរិក ចិន អឺរ៉ុប អូស្ត្រាលីនិងបណ្តាប្រទេសផ្សេងៗមួយចំនួនទៀតផង។ អាស៊ាន ក៏ជួយដល់ការវិនិយោគក្នុងតំបន់ផងដែរតាមរយៈក្រុមប្រឹក្សាវិនិយោគតំបន់អាស៊ាន។

ក្រុមប្រឹក្សាវិនិយោគក្នុងតំបន់អាស៊ាន បានតួនាទីជួយសម្រួលធ្វើយ៉ាងណាឱ្យមានលំហូរដោយសេរីនៃការវិនិយោគនៅក្នុងតំបន់។ យោងតាមរបាយការណ៍របស់សហគមន៍ សេដ្ឋកិច្ចអាស៊ានដែលចេញកាលពីឆ្នាំ២០១៧ ការវិនិយោគដោយផ្ទាល់រវាងប្រទេសក្នុងតំបន់អាស៊ានដូចគ្នាមានប្រមាណជា១២១ពាន់លានដុល្លារ។

ក្រៅពីការសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងការវិនិយោគទុនក្នុងតំបន់ គេក៏មិនត្រូវភ្លេចទេថា ការចូលជាសមាជិក អាស៊ានក៏ជួយជំរុញឱ្យមានកំណើនទេសចរ ដែលជាជនជាតិរបស់ប្រទេសជាសមាជិកអាស៊ានមក

លេងប្រទេសជាសមាជិកអាស៊ានដទៃផ្សេងទៀតផងដែរ។ ក្នុងលិខិតអបអរសាទរខួបលើកទី៥០ នៃការបង្កើតអាស៊ាន លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា បានបង្ហាញថាតួលេខទេសចរមកពីតំបន់អាស៊ានដែលចូលមកលេងកម្សាន្តនៅកម្ពុជា មានការកើនឡើង ពោលពី៥០ម៉ឺននាក់នៅឆ្នាំ២០០៨ កើនដល់ជាង ២លាននាក់នៅឆ្នាំ២០១៦[440]។

## ៣-កិច្ចសហប្រតិបត្តិការអាស៊ាន

### ៣.១-ASEAN+1

ប្រទេសអាស៊ានទាំង១០ រួមជាមួយប្រទេសឥណ្ឌា សហការគ្នាលើវិស័យជាច្រើន ជាពិសេសផ្នែកសេដ្ឋកិច្ច។ ការបង្កើតរូបមន្ត ASEAN+1 ឥណ្ឌានេះគឺដើម្បីធ្វើសហប្រតិបត្តិការឱ្យបាន ល្អិតល្អន់ជាមួយប្រទេសមហាអំណាចមួយ មានចំនួនប្រជាជនលំដាប់លេខ២ក្នុងពិភពលោក ដែលមានទីផ្សារដ៏ធំធេងរបស់អាស៊ាន និងសម្រាប់ផលប្រយោជន៍ទៅវិញទៅមក។

### ៣.២-ASEAN+2 រូបមន្តនេះមានន័យថា

ប្រទេសអាស៊ានទាំង១០ រួមជាមួយប្រទេសញូហ្សេឡង់ដ៍ និងប្រទេសអូស្ត្រាលី( ASEAN+New Zealand+Australia )។ ការរួមបញ្ចូលគ្នារវាងអាស៊ាន និងប្រទេសទាំងពីរនេះ គឺមាន សារៈប្រយោជន៍ ព្រោះវាបានផ្តល់ដល់អាស៊ាននូវបទពិសោធន៍ ការរីកចម្រើនខាងផ្នែកបច្ចេកទេស ធនធានមនុស្ស ដែលសមាគមអាស៊ានកំពុងតែស្វែងរក និងត្រូវការចាំបាច់។ រូបមន្តនេះបានធ្វើឱ្យ អាស៊ានមានដៃគូចូលរួមដ៏សំខាន់សម្រាប់ធ្វើការអភិវឌ្ឍតំបន់អាស៊ីអាគ្នេយ៍ទាំងមូល ឱ្យឈានឡើង ស្របតាមស្តង់ដាកម្រិតអន្តរជាតិ។

### ៣.៣-ASEAN+3 រូបមន្តនេះមានន័យថា

ប្រទេសទាំង១០របស់អាស៊ាន និងប្រទេសចិនប្រជាមានិត ប្រទេសកូរ៉េខាងត្បូង និងប្រទេសជប៉ុន។ ការរួបរួមបញ្ចូលគ្នារវាងអាស៊ានជាមួយប្រទេសទាំងបីនេះ គឺបានផ្តល់ឱ្យអាស៊ាននូវ អ្វីៗទាំងអស់ ដែលអាស៊ានចង់បាន កិច្ចសហប្រតិបត្តិការទៅវិញទៅមកឱ្យបានជិតស្និទ្ធ។ ការបង្កើតរូបមន្ត ASEAN+3 ធ្វើឱ្យអាស៊ានមួយបាននូវជំនួយដ៏ច្រើនសន្ធឹកសន្ធាប់ដល់ការហ្វឹកហ្វឺន ការបំប៉នដល់សមាជិកនានា នូវបទពិសោធបច្ចេកវិទ្យា វិទ្យាសាស្ត្រ ចំនេះដឹងគ្រប់បែបយ៉ាងសម្រាប់ ការអភិវឌ្ឍឱ្យដូចប្រទេសជឿនលឿននានា។ម្យ៉ាងវិញទៀតអាស៊ានទទួលបានផលប្រយោជន៍ ដ៏ធំមហិមាពីរូបមន្តនេះ ដូចជាទីផ្សារធំមហិមាសម្រាប់ផលិតផល អាស៊ាន ទាំងកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងបច្ចេកវិទ្យានានា ដែលអាចធ្វើឱ្យសមាគមអាចអភិវឌ្ឍគ្រប់វិស័យដោយពុំមានគិតបារម្ភ អ្វីអំពីការស្វែងរកទីផ្សារឡើយ។

### ៣.៤-កម្ពុជា និង ASEAN+3

កម្ពុជាបានចូលរួមជាសមាជិកអាស៊ានក្នុងឆ្នាំ១៩៩៩ ស្របពេលដែលសមាគមអាស៊ាន កំពុងប្រឈមមុខទៅនឹងតម្រូវការដៃគូបន្ថែម ពោលគឺតំបន់អាស៊ីអាគ្នេយ៍ទទួលផលប៉ះពាល់ដល់វិបត្តិសេដ្ឋកិច្ច។ ASEAN ត្រូវការផងដែរនូវការពង្រីកដៃគូបន្ថែមទៀត។

លោក Thanat Khoman អតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសថៃ ហើយជាបុគ្គលមួយរូបដែលបានចូលរួមចំណែកផ្តួចផ្តើម បង្កើតនូវសមាគមអាស៊ាននេះឡើង។ បញ្ហាប្រទេសមួយចំនួន បានចង្អុលបង្ហាញឱ្យឃើញថា ក្នុងរយៈពេលដ៏ខ្លីមួយការចូលជាសមាជិកនៃប្រទេសកម្ពុជាក្នុងអាស៊ាន គឺស្របពេល

[440] ការផ្សាយរបស់វិទ្យុ VOD ៣០ មេសា ២០១៨

ដែលសមាគមអាស៊ានមានភាពទន់ខ្សោយ ហើយការបែកខ្ញែកគ្នាពុំប្រមូលផ្តុំ ដើម្បីឱ្យមានកម្លាំងខ្លាំង។ ចំណុចទាំងនេះហើយ ដែលជាប្រការមួយគួរឱ្យសោកស្តាយយ៉ាងខ្លាំង។

ការពង្រីកអាស៊ាន និងផលប៉ះពាល់ដល់វិបត្តិសេដ្ឋកិច្ចអាស៊ីនេះស្ថិតនៅក្នុងផ្នែកមួយនៅក្នុងអង្គការគ្រប់គ្រងតំបន់ ដើម្បីលើកឡើងវិញនូវចំនងទាក់ទងគ្នា និងភាពចាំបាច់ក្នុងការភ្ជាប់ទំនាក់ទំនងទៅនឹងបណ្តាប្រទេសអាស៊ីភាគខាងកើត ដូចជាប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង ជាដើម។

ការប្រជុំកំពូលនៃ ASEAN+3 ត្រូវបានរៀបចំឡើងក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលក្នុងនោះរួមមានមេដឹកនាំនៃបណ្តាប្រទេសជាសមាជិកអាស៊ាន និងមេដឹកនាំនៃបណ្តាប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង ដើម្បីចូលរួមក្នុងសេចក្តីថ្លែងការណ៍ស្តីពីកិច្ចសហប្រតិបត្តិការជាមួយអាស៊ីខាងកើត ហើយពួកគេបានធ្វើការសម្រេចចិត្តម្តងទៀត នាកិច្ចប្រជុំកំពូលអាស៊ានក្នុងទីក្រុងហាណូយស្តីពីសេចក្តីត្រូវការបន្ថែមលើដំណើរការពិភាក្សា និងការពង្រឹងកិច្ចសហប្រតិបត្តិការ សិទ្ធិជាអាទិភាពក្នុងតំបន់ និងចូលរួមចំណែកចាប់អារម្មណ៍ទៅនឹងកង្វល់ផ្សេងៗក្នុងតំបន់ថែមទៀត។ ការនិយាយអំពី ផលប៉ះពាល់ក្នុងតំបន់ ដែលទើបនឹងកើតមានឡើងក្នុងវិបត្តិនៅអាស៊ី កត្តាសំខាន់ពីក្នុងតំបន់ដែល ASEAN+3 បានដំណើរការយកចិត្តទុកដាក់យ៉ាងខ្លាំង គឺបញ្ហាដំណើរការកិច្ច សហប្រតិបត្តិការសេដ្ឋកិច្ច និងស្វ័យភាពហិរញ្ញវត្ថុ។

នៅលើកទី១ ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃ ASEAN+3 ធ្វើការប្រជុំ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០០០ នាទីក្រុង Yangon ក្នុងនោះបញ្ហារដ្ឋមន្ត្រីនីមួយៗបានព្រមព្រៀងគ្នា ធ្វើការពិភាក្សាស្តីពីការបង្កើតផ្នែកសេដ្ឋកិច្ចដូចខាងក្រោម៖

-ពង្រឹងការប្រឹងប្រែងក្នុងការបង្កើតពាណិជ្ជកម្ម ការវិនិយោគ និងផ្លាស់ប្តូរបច្ចេកវិទ្យា ទៅវិញទៅមក។

-ផ្តល់ការលើកទឹកចិត្ត ចំពោះផ្នែកកិច្ចសហប្រតិបត្តិការខាងបច្ចេកទេស ដូចជាព័ត៌មានវិទ្យា និងពាណិជ្ជកម្មជាដើម...។

-លើកទឹកចិត្តចំពោះការចូលរួមចំណែកក្នុងការអភិវឌ្ឍ ចំពោះតំបន់ត្រូវការភាពចាំបាច់ដែលអាចធ្វើឱ្យមានការរីកចម្រើនបានចូលរួមមាន ដូចជា អាងសម្រាប់ស្តុកទឹកទន្លេមេគង្គជាដើម។

-លើកកំពស់ការខិតខំប្រឹងប្រែងនៃកិច្ចសហប្រតិបត្តិការ ស្តីពីការអភិវឌ្ឍធនធាន មនុស្ស។

-ផ្សព្វផ្សាយស្តីពីការចូលរួមផ្នែកឯកជនឱ្យកាន់តែទូលំទូលាយ ដោយឆ្លងតាមរយៈការផ្តួចផ្តើមនូវការតគ្នានូវចំណុចបណ្តាញ ដូចជាក្រុមប្រឹក្សាសេដ្ឋកិច្ច ប្រចាំតំបន់អាស៊ីខាងកើត និងសេដ្ឋកិច្ចឧស្សាហកម្មឱ្យមានភាពច្បាស់លាស់ឡើង។

-ផ្សព្វផ្សាយអំពីកិច្ចសហប្រតិបត្តិការ ផ្នែកកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍។

-ធ្វើការពង្រឹងសហគ្រាសខ្នាតតូច និងខ្នាតមធ្យមព្រមទាំងមានការឧបត្ថមភ ឬការជួយជ្រោមជ្រែងខាងផ្នែកឧស្សាហកម្មផងដែរ។

-សហការលើផ្នែកវិទ្យាសាស្ត្រ និងអភិវឌ្ឍបច្ចេកវិទ្យាផ្សេងៗ...។

-ធ្វើការសម្របសម្រួល និងសហការផ្នែកអន្តរជាតិផ្សេងៗ និងសហការនៅក្នុងតំបន់

យោលទៅតាមសំណើសំខាន់ៗក្នុងតំបន់នៃកិច្ចសហប្រតិបត្តិការ គឺវាមានភាពធំទូលាយ និងសារសំខាន់យ៉ាងខ្លាំងរវាងភាគីទាំងពីរ គឺអាស៊ាន ១០ និងប្រទេសអាស៊ីខាង កើតទាំងបី។ ដើម្បីដោះស្រាយនូវដំណើរការ និងបញ្ហាផ្សេងៗ គឺគេត្រូវបើកកិច្ចប្រជុំ SEOM+3(កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចជាន់ខ្ពស់) ដែលចូលរួមដោយមន្ត្រីជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច នៃបណ្តាប្រទេសអាស៊ាន ហើយនិងមន្ត្រីជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចនៃ

ប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង។ មិនតែប៉ុណ្ណោះរដ្ឋមន្ត្រីហិរញ្ញវត្ថុនៃបណ្តាប្រទេសអាស៊ាន និងរដ្ឋមន្ត្រីហិរញ្ញវត្ថុនៃប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង បានធ្វើការប្រជុំនៅខេត្តឈៀងម៉ៃ ប្រទេសថៃ នាខែឧសភា ឆ្នាំ ២០០០ ផងដែរ ដើម្បីធ្វើការគោរពទៅលើកិច្ចសហប្រតិបត្តិការខាងផ្នែកហិរញ្ញវត្ថុ។ បណ្តារដ្ឋមន្ត្រីហិរញ្ញវត្ថុនៃប្រទេសទាំងអស់ ដែលបានចូលរួមប្រជុំពេលនោះ បានលើកឡើងនូវភាពចាំបាច់មួយចំនួន ដើម្បីធ្វើការព្រមព្រៀងគ្នា ដែលបញ្ហាទាំងនោះមានដូចជា៖

- ASEAN+3 ប្រើប្រាស់គម្រោងដើម្បីសម្រួលដល់ការផ្លាស់ប្តូរនូវអ្វី ដែលមិនអាចកែ ប្រែកើត និងទិន្នន័យព្រមទាំងព័ត៌មានស្តីពីរដ្ឋធានី ឫរាជធានីនីមួយៗផងដែរ។

-បង្កើតឱ្យមានបណ្តាញនៃការទាក់ទងមនុស្ស ដើម្បីសម្រួលដល់ការតាមដានមើល ក្នុងតំបន់

-ធ្វើការពង្រឹងគម្រោងការនៃកិច្ចសហប្រតិបត្តិការក្នុងការរស់នៅក្នុងចំណោមអាជ្ញាធររូបិយវត្ថុនៃ ASEAN+3។

-សំណូមពរទៅដល់អគ្គលេខាធិការ ASEAN ក្នុងការដឹកនាំ និងសម្របសម្រួល ទៅលើដំណើរការផ្សេងឱ្យបានសមរម្យ ហើយវាអាចរួមមានការបន្ថែមសមត្ថភាព ដែលអាចធ្វើការបែងចែកការគ្រប់គ្រង ហើយនិងការចំណាយនៅពេលលំបាក ដើម្បីធានាឱ្យមានភាពប្រាកដប្រជានៃហិរិញ្ញវត្ថុនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

-បង្កើតឱ្យមានបណ្តាញការស្រាវជ្រាវមួយ ហើយនិងស្ថាប័នហ្វឹកហ្វឺនមួយ ដើម្បីដឹកនាំការស្រាវជ្រាវ និងហ្វឹកហ្វឺនទៅលើបញ្ហានៃភាពសំខាន់ទាំងសងខាង។

ដំណើរការនៃ ASEAN+3 ពុំមែនមានសារសំខាន់សំរាប់តែអាស៊ានប៉ុណ្ណោះទេ ក៏ប៉ុន្តែវាក៏មានសារសំខាន់ខ្លាំងណាស់ដែរចំពោះប្រទេសកម្ពុជា។

តើកម្ពុជា និងដំណើរការសកម្មភាពយ៉ាងដូចម្តេចនៅក្នុង ASEAN+3 នេះ?

វាគឺមានភាពប្រហាក់ប្រហែលទៅនឹងបណ្តាប្រទេសដទៃទៀតក្នុង ASEAN+3 ដែរ ចំពោះការអនុវត្តនូវដំណើរការក្នុង ASEAN+3នេះ។ កម្ពុជាបានលាតសន្ធឹងយ៉ាងមានចំណាប់អារម្មណ៍របស់ ASEAN+3 ដែរ ជាយុទ្ធសាស្ត្រខាងផ្នែកសេដ្ឋកិច្ច ការទូត និងកិច្ចការការពារធម្មានរូប។ ចំណុចទាំងអស់នេះសុទ្ធសឹងជាចំណុច ដែលគួរឱ្យចាប់អារម្មណ៍។ ដំណើរការកម្ពុជាក្នុង ASEAN+3មាន ៖

ការគិតឃើញនូវចំណាប់អារម្មណ៍ជាយុទ្ធសាស្ត្រ មានន័យថា ការចូលរួមរបស់ កម្ពុជា ទៅក្នុងដំណើរការនៃ ASEAN+3 គឺសម្រាប់ទ្រទ្រង់នូវភាពចាំបាច់របស់ប្រទេសជាតិឱ្យបានល្អដូចជាធ្វើការស្រាវជ្រាវនៅក្រៅប្រទេសជាតិឱ្យបានច្រើន ដើម្បីកុំឱ្យមានដល់ការ ប៉ះពាល់ដល់បរិស្ថានកម្ពុជាទាំងពេលបច្ចុប្បន្ន និងនាពេលអនាគត។ មិនតែប៉ុណ្ណោះប្រសិនបើយើងនិយាយពីទំនាក់ទំនងទ្វេភាគីវិញនោះ គឺបច្ចុប្បន្ននេះ កម្ពុជាអាចចងសម្ពន្ធមេត្រីភាពជាមួយប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង បានដោយឆ្លងតាមរយៈគម្រោងការណ៍ ASEAN+3 ដោយមិនចាំបាច់ និងផ្អែកទៅលើការចរចាជាទ្វេភាគីឡើយ។

បើយើងគិតពីគំនិតនៃចំណងទ្វេភាគីវិញនោះ គឺកម្ពុជាមានទំនាក់ទំនងការទូត ជាមួយប្រទេសកូរ៉េខាងជើងតែប៉ុណ្ណោះ នេះជាលទ្ធផលមួយ ដែលទទួលបានពីទំនាក់ទំនងផ្ទាល់ខ្លួនរវាងព្រះមហាក្សត្រនរោត្តម សីហនុ ហើយនឹងលោកប្រធានាធិបតី គីមអ៊ីស៊ុង។

នៅពេលបច្ចុប្បន្ននេះ កម្ពុជានៅតែបន្តឱ្យមានទំនាក់ទំនងការទូតជាមួយនឹងទីក្រុងព្យុងយ៉ាង។ មិនតែប៉ុណ្ណោះទីក្រុងភ្នំពេញ ក៏បានព្យាយាមបង្កើតនូវសម្ពន្ធមេត្រីភាព ជាមួយក្រុងសេអូលផងដែរ។ យុទ្ធសាស្ត្ររបស់កម្ពុជា គឺធ្វើយ៉ាងណារក្សាទុកនូវទំនាក់ទំនងទ្វេភាគីរវាងភាគីទាំងពីរ គឺព្យុងយ៉ាង និងសេអូល ឱ្យស្ថិត

ក្នុងពេលតែមួយ។ កម្ពុជាតែងផ្តល់នូវអាទិភាពស្មើគ្នាចំពោះទំនាក់ទំនងជាមួយបណ្តាប្រទេសទាំង៤នេះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏កម្ពុជាត្រូវការនូវអាទិភាពចម្បងចំពោះចំណាប់អារម្មណ៍នានានៃ ASEAN+3 ក្នុងប្រទេសទាំងបួន ឱ្យស្ថិតក្នុងដៃតែមួយរបស់កម្ពុជា។

ដំណើរការកម្ពុជាចូលក្នុង ASEAN+3 គឺបានទទួលផលចំណេញខាងផ្នែកសេដ្ឋកិច្ច។ ដូចជាពេលថ្មីៗកន្លងទៅនេះ មានកិច្ចពិភាក្សាស្តីអំពីការសុំយោបល់ពីគម្រោងការណ៍ ASEAN+3 ឱ្យមានការយកចិត្តទុកដាក់ការចូលរួមធ្វើកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូចគ្នានេះដែរ កម្ពុជាក៏ត្រូវគិតឡើងវិញអំពីការចូលរួមនៅក្នុងគម្រោងសេដ្ឋកិច្ចបើកទូលាយ ដូចជាបញ្ហាដែលថា សមាជិកនៅក្នុង ASEAN+3 នេះដែរ ហើយវាក៏ស្ថិតនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងកម្រិតផ្សេងគ្នាផងដែរ។

ជាការពិតណាស់កម្ពុជាបានចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះការវិនិយោគបរទេស ដោយផ្ទាល់មកលើប្រទេសកម្ពុជា ហើយការវិនិយោគទាំងនោះ មានដូចជា ពាណិជ្ជកម្ម បច្ចេកទេស ព័ត៌មានវិទ្យា ទេសចរណ៍ គមនាគមន៍ ការអភិវឌ្ឍធនធានមនុស្ស និងផ្នែកកសិកម្មផងដែរ។ ប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង បានដើរតួយ៉ាងសំខាន់ក្នុងការឱ្យជា ជំនួយសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា។ នៅខណៈពេលបច្ចុប្បន្ននេះ ពុំទាន់មានភាពច្បាស់លាស់ថាតើកម្ពុជាមានដំណើរការបែបណាក្នុងការផ្សារភ្ជាប់ជាមួយ ASEAN+3 នៅពេលនឹងមានការផ្តល់ជំនួយបន្ថែមសម្រាប់ទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

ក្នុងបរិបទនៃចំណាប់អារម្មណ៍ខាងផ្នែកការទូតរបស់ ASEAN+3 កម្ពុជានឹងធ្វើការពង្រឹងនូវទំនាក់ទំនងជាមួយបណ្តាប្រទេសទាំងអស់ ជាពិសេសប្រទេសជប៉ុន និងកូរ៉េខាងត្បូង។ សម្ពន្ធទ្វេភាគីជាមួយនឹងបណ្តាប្រទេសទាំងអស់ ដែលជាសមាជិកនៃតំណាង ASEAN+3 វាគឺជាការទ្រទ្រង់ ឬជំនួយសម្រាប់កម្ពុជា។ ហេតុដូចនេះហើយគឺយើងត្រូវការជាចាំបាច់នូវភាពប៉ិនប្រសប់ខាងការទូត ដើម្បីជាស្ពានក្នុងការចង់សម្ពន្ធមេត្រីភាពជាមួយ នឹងបណ្តាប្រទេសនានាលើសាកលលោក។

### ៣.៥-ASEAN **និងឥណ្ឌាក្នុងសតវត្សទី២១**

តាមសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំកំពូលអាស៊ាន ឥណ្ឌាលើកទី១ នៅទីក្រុងភ្នំពេញ នាថ្ងៃទី៥ វិច្ឆិកា ឆ្នាំ២០០២ ដែលក្នុងនាមជាប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលនៃសមាជិកអាស៊ាន និងនាយករដ្ឋមន្ត្រីសាធារណរដ្ឋឥណ្ឌា បានសម្តែងនូវសេចក្តីពេញចិត្តថា ទំនាក់ទំនងអាស៊ាន ឥណ្ឌា ត្រូវបានលើកកំពស់ និងរីកចម្រើនយ៉ាងរហ័ស តាំងពីការបង្កើតភាពជាដៃគូ ចរចាតាមវិស័យក្នុងឆ្នាំ១៩៩២ និងជាពិសេសចាប់ឥណ្ឌាក្លាយជាដៃគូ ចរចាពេញសិទ្ធិនៅខែធ្នូ ឆ្នាំ១៩៩៥ ហើយបន្ទាប់មកជាសមាជិកនៃវេទិកាតំបន់អាស៊ាន នៅខែកក្កដា ឆ្នាំ១៩៩៦។ ថ្នាក់ដឹកនាំអាស៊ាន-ឥណ្ឌា ជឿជាក់ថាការពង្រឹងទំនាក់ទនង អាស៊ាន-ឥណ្ឌា ដែលបានចាក់ឫសគល់ក្នុងទំនាក់ទំនងជាប្រវត្តិសាស្ត្រ និងផ្នែកវប្បធម៌ដ៏ជិតស្និទ្ធ បានបំរើផលប្រយោជន៍ជាមូលដ្ឋានរបស់ប្រជាជនរៀងៗខ្លួន ព្រមទាំងសន្តិភាព ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

-ប្រមុខរដ្ឋ/រដ្ឋាភិបាល អាស៊ាន-ឥណ្ឌា បានទទួលស្គាល់នូវលក្ខណៈសម្បូរបែបនៃសង្គមរបស់គេ ដែលមានសាសនាធំៗ របស់ពិភពលោក និងសម្បត្តិវប្បធម៌ផ្សេងៗទៀត។ ប្រមុខរដ្ឋ/រដ្ឋាភិបាល អាស៊ាន-ឥណ្ឌា បានឯកភាពថា ទាំនាក់ទំនងនេះជាទុនពិសេសមួយ សម្រាប់ពង្រីកទំនាក់ទំនងដ៏ជិតស្និទ្ធរបស់ខ្លួនថែមទៀត។

-អាស្រ័យដោយព្រឹត្តិការណ៍ថ្មី និងភាពប្រឈមនានា ដែលកើតឡើងក្នុងសតវត្សទី២១ ថ្នាក់ដឹកនាំកំពូលអាស៊ាន និងឥណ្ឌា បានសម្រេចជំរុញបន្ថែមទៀតនៃកិច្ចសហប្រតិបត្តិការរបស់ខ្លួនឱ្យដល់កម្រិតខ្ពស់ថ្មីមួយ ដើម្បីដោះស្រាយនូវបញ្ហារួម ដែលកំពុងប្រឈមមុខក្នុងតំបន់ និងពិភពលោក។ ផ្អែកលើមូលដ្ឋាននៃ

ទំនាក់ទំនង កិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធ និងដោយទទួលស្គាល់នូវសារសំខាន់នៃកិច្ចប្រឹងប្រែងរួមគ្នា ថ្នាក់ដឹកនាំកំពូល អាស៊ានឥណ្ឌា បានឯកភាពរៀបចំឱ្យមានកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាលើកទី១ នៅកម្ពុជា ដោយអនុលោមទៅតាមការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំអាស៊ានទាំងអស់នា កិច្ចប្រជុំកំពូលអាស៊ានលើកទី៧ នៅប្រទេសប្រ៊ុយណេ ក្នុងខែវិច្ឆិកា ឆ្នាំ២០០១។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការលើកកំពស់ភាពជាដៃគូ ថ្នាក់ដឹកនាំអាស៊ាន និងឥណ្ឌា បានកត់សម្គាល់ជាពិសេសចំពោះសារសំខាន់នៃកិច្ចសន្ទនាកម្រិតខ្ពស់ និងបានសម្រេចរៀបចំកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌា ជារៀងរាល់ឆ្នាំ។

ក្នុងកិច្ចសហប្រតិបត្តិការនេះ យើងឃើញថ្នាក់ដឹកនាំ អាស៊ាន-ឥណ្ឌា ឯកភាពគ្នាជំរុញបន្ថែមនូវការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ការផ្លាស់ប្តូរកម្មវិធីរបស់យុវជន បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ អ្នកស្រាវជ្រាវ អ្នកជំនាញ មន្ត្រីរាជការ និងសិល្បៈករទៀតផង។

### ៣.៦-កិច្ចសហប្រតិបត្តិការ អាស៊ាន-ជប៉ុន

ក្នុងឱកាសទស្សនកិច្ចនៅក្នុងប្រទេសអាស៊ានចំនួន៥ នាខែមេសា ឆ្នាំ២០០២ លោក នាយករដ្ឋមន្ត្រីជប៉ុន ជូនីជីរ៉ូកូអ៊ីហ្សូមី បានលើកឡើងនូវគំនិតផ្តួចផ្តើម៥ សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន-ជប៉ុន ទៅថ្ងៃអនាគត ដោយផ្តោតទៅលើះ

-សហប្រតិបត្តិការលើវិស័យអប់រំ និងការអភិវឌ្ឍធនធានមនុស្ស

-ស្នើចាត់ទុកឆ្នាំ២០០៣ ជាឆ្នាំផ្លាស់ប្តូររវាង អាស៊ាន -ជប៉ុន

-សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន-ជប៉ុន

-គំនិតផ្តួចផ្តើមសម្រាប់អភិវឌ្ឍតំបន់អាស៊ីបូព៌ា

-កិច្ចសហប្រតិបត្តិការវិស័យសន្តិសុខ។

គោលបំណងនៃការផ្លាស់ប្តូររបស់លោកនៅឆ្នាំ ២០០៣ រួមមាន នយោបាយ សេដ្ឋកិច្ចនិងឧស្សាហកម្ម សន្តិសុខ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងវប្បធម៌។

### ៣.៧-កិច្ចសហប្រតិបត្តិការអាស៊ាន-ចិន

ថ្នាក់ដឹកនាំអាស៊ាន ក៏ដូចជាថ្នាក់ដឹកនាំចិនសុទ្ធតែបានយល់អំពីសារប្រយោជន៍ទំនាក់ទំនង នៃកិច្ចសហប្រតិបត្តិការជាមួយគ្នា។ ក្នុងន័យនេះហើយទើបអាស៊ានបានធ្វើទំនាក់ទំនងនឹងធ្វើការសហការណ៍គ្នាស្ទើរតែគ្រប់វិស័យជាមួយប្រទេសចិន ដោយរួមទាំង សេដ្ឋកិច្ច នយោបាយ បច្ចេកទេស វប្បធម៌ ការសិក្សាស្រាវជ្រាវជាដើម...។

បើនិយាយពីទំនាក់ទំនងទ្វេភាគីវិញប្រទេសនីមួយៗនៅក្នុងតំបន់សុទ្ធតែមានទំនាក់ទំនង និងការផ្តល់ផលប្រយោជន៍គ្នាទៅវិញទៅមក ជាមួយប្រទេសចិនយ៉ាងច្រើន។ ក៏ប៉ុន្តែនាប៉ុន្មានឆ្នាំចុងក្រោយនេះ ទំនាក់ទំនងចិន ជាមួយប្រទេសមួយចំនួននៃបណ្តាសមាជិកអាស៊ាន កំពុងតែមានភាពទំនាស់នឹងគ្នា ជាពិសេសជាមួយប្រទេសវៀតណាម ហ្វីលីពីន ប្រ៊ុយណេ ម៉ាឡេស៊ី ជាដើម។ ទំនាស់នេះទាក់ទងនឹងការ ដណ្តើមកាន់កាប់ដែនដោះក្នុង សមុទ្រចិនភាគខាងត្បូង ដែលប្រទេសក្នុងតំបន់ចោទប្រកាន់ថាចិនជាអ្នកបំពានមកលើ ដែនសមុទ្ររបស់ពួកគេ។ ចំណែកប្រទេសចិននៅតែយល់ថាដែនកោះទាំងនោះជារបស់ខ្លួន។ បញ្ហានេះហើយដែលជំរុញឱ្យមានភាពតានតឹងរវាងចិន និងវៀតណាម នាខែឧសភា ឆ្នាំ២០១៤ កន្លងទៅនេះ។

បើយើងក្រឡេកមើល កាលពីសន្និសីទកំពូលអាស៊ាន នៅទីក្រុងភ្នំពេញ ឆ្នាំ ២០១២ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជានៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ បានប្រកាសថា រដ្ឋមន្ត្រីការបរទេស អាស៊ាន បានឯកភាពលើគោលការណ៍ចំនួន៦ចំណុច ស្តីពីការដោះស្រាយដោយសន្តិវិធីពីជម្លោះនៅសមុទ្រចិនខាងត្បូង។ សេចក្តីប្រកាស គឺនៅគ្រាដែលមានការយល់ព្រមថ្មីៗនេះ ក្រោយពីរដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌូណេស៊ី បានជួបពិភាក្សា និងស្វែងរកការឯកភាពពីរដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម ហ្វីលីពីន និងរដ្ឋមន្ត្រីការបរទេសអាស៊ានមួយចំនួនទៀត។

គោលការណ៍ចំនួន៦ចំណុច ដែលរដ្ឋមន្ត្រីការបរទេសអាស៊ានទើបបានយល់ព្រមគ្នានេះ គឺជាការបើកផ្លូវសំខាន់មួយ ដើម្បីបន្តចរចា និងដោះស្រាយជម្លោះទ្វេភាគីជាមួយប្រទេសចិន ស្តីអំពីវិបត្តិនៅសមុទ្រចិនខាងត្បូង។ គោលការណ៍៦ចំណុចមាន៖ ទី១ អនុវត្តទាំងស្រុងនូវសេចក្តីប្រកាសពាក់ព័ន្ធនឹងការប្រតិបត្តិ នៃភាគីនៅសមុទ្រចិនខាងត្បូង ឆ្នាំ២០០២។ ទី២ គោលការណ៍ណែនាំសម្រាប់ការអនុវត្តសេចក្តីប្រកាស ពាក់ព័ន្ធនៃភាគីនៅសមុទ្រចិនខាងត្បូង ឆ្នាំ២០១១។ ទី៣ សម្រេចឱ្យបានឆាប់នូវក្រមប្រតិបត្តិតំបន់នៅ សមុទ្រចិនខាងត្បូង។ ទី៤ គោរពទាំងស្រុងគោលការណ៍នៃច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសមុទ្រឆ្នាំ១៩៨២។ ទី៥ បន្តរក្សាភាពអត់ធ្មត់ និងការមិនប្រើកម្លាំងនៃភាគីទាំងអស់ និងទី៦ ដោះស្រាយវិវាទនេះដោយសន្តិវិធីស្របតាមគោលការណ៍នៃច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ១៩៨២។

សេចក្តីប្រកាសនេះ គឺជាជម្រើសល្អមួយ ដើម្បីបន្តចរចា ដោះស្រាយជម្លោះនៅសមុទ្រចិនខាងត្បូងនោះ។ ក្នុងឋានៈកម្ពុជាជាប្រធានអាស៊ាន ក្នុងឋានៈជាប្រធានរបស់អង្គការតំបន់ដ៏សំខាន់នេះ នៅពេលដែលជម្លោះគ្នា មានលក្ខណៈតឹងតែងបំផុតរវាងភាគីពាក់ព័ន្ធ ប្រធានអាស៊ាន មិនត្រូវយកសាំងចាក់លើភ្លើងថែមទេ។ ប្រធានអាស៊ាន ត្រូវតែធ្វើយ៉ាងណាឱ្យមានការធូរស្រាល នេះជាជំហរគោលការណ៍របស់កម្ពុជា។ ជំហរគោលការណ៍ទី៣ របស់កម្ពុជា គឺកម្ពុជាចង់ចេញសេចក្តីថ្លែងការណ៍រួមនេះ ទុកបើកចំហទ្វារមួយឱ្យលទ្ធភាពធ្វើការចរចាទៅថ្ងៃមុខ រវាងភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដោយសន្តិវិធីផង ដោយមិត្តភាពរបស់ប្រទេសពាក់ព័ន្ធនេះក្នុងជម្លោះនេះផង។

ប្រទេសសមាជិកអាស៊ាន ចំនួន១០ កន្លងមក បានចុះហត្ថលេខា និងយល់ព្រមលើសេចក្តីថ្លែងការណ៍រួម ឌីអូស៊ី (DOC = Declaration of Conducts) កាលពីឆ្នាំ២០០២ កន្លងទៅ ដោយបានសន្យាថានឹងដោះស្រាយជម្លោះនៅសមុទ្រចិនខាងត្បូងនោះដោយសន្តិវិធី។ រហូតដល់ឆ្នាំ២០១២ នៅគ្រាដែលកម្ពុជាធ្វើជាប្រធានអាស៊ាន ក្រសួងការបរទេសកម្ពុជា និងឧត្តមមន្ត្រីអាស៊ាន ចំនួន១០ប្រទេស បានធ្វើសេចក្តីព្រាងនៃក្រមប្រតិបត្តិ ស្តីពីការដោះស្រាយដោយសន្តិវិធី ពីជម្លោះនៅសមុទ្រចិនខាងត្បូងនោះ ស៊ីអូស៊ី (COC = Code of Conducts on South China Sea)។

រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម និងហ្វីលីពីន នៅក្នុងប្រទេសចំនួន២ទៀត មានប្រទេសម៉ាឡេស៊ី និងប្រទេសប្រ៊ុយណេ បានទាមទារឱ្យកម្ពុជា ជាប្រធានអាស៊ាន យកបញ្ហាជម្លោះទ្វេភាគីជាមួយប្រទេសចិន នោះ ដាក់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍រួមរបស់អាស៊ាន ប៉ុន្តែកម្ពុជាមិនបានយល់ព្រមទេ។ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា នៅថ្ងៃសុក្រ ទី២០ ខែកក្កដា ឆ្នាំ២០១២ បានបញ្ជាក់ជាថ្មីទៀតថា អាស៊ានមិនមែនជាតុលាការទេ។ ការទាមទារនោះ គឺជាការយកបញ្ហារបស់ខ្លួនធ្វើជាចំណាប់ខ្មាំង មិនឱ្យចេញសេចក្តីថ្លែងការណ៍រួមកន្លងមកនេះបាន។

## ៤-ការបង្កើតសហគមន៍អាស៊ាន

ធម្មនុញ្ញអាស៊ាន ជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយក្នុងការជួយឱ្យសម្រេច បាននូវសហគមន៍អាស៊ាន តាមរយៈការផ្តល់នូវក្របខ័ណ្ឌស្ថាប័ន និងលក្ខន្តិកៈគតិយុត្ត សម្រាប់អាស៊ាន។ ធម្មនុញ្ញនេះក៏បានរៀបចំផងដែរនូវបទដ្ឋានច្បាប់ និងគោលការណ៍របស់អាស៊ាន កំណត់នូវទិសដៅច្បាស់លាស់ សម្រាប់អាស៊ាន និងបង្ហាញនូវគណនេយ្យភាព និងអនុលោមភាព។

ធម្មនុញ្ញអាស៊ាន បានចូលជាធរមាននៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨។ ការជួបប្រជុំគ្នារវាងរដ្ឋ មន្ត្រីការបរទេស អាស៊ានបានធ្វើឡើង នៅឯលេខាធិការដ្ឋានអាស៊ាន នៅទីក្រុងហ្សាការតា ដើម្បី ប្រារព្ធនូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដ៏ធំនេះសម្រាប់អាស៊ាន។ ជាមួយនឹងការចូលជាធរមាននៃធម្មនុញ្ញអាស៊ាននេះ អាស៊ាននឹងអនុវត្តចាប់ពីពេលនេះទៅ ក្រោមក្របខ័ណ្ឌគតិយុត្តិថ្មីមួយ និងបង្កើតនូវអង្គភាពថ្មីៗមួយចំនួនដើម្បីជំរុញដំណើរការការកសាងសហគមន៍របស់ខ្លួន។ ជាលទ្ធផលធម្មនុញ្ញអាស៊ានបានក្លាយជាកិច្ចព្រមព្រៀង មានលក្ខណៈជាកាតព្វកិច្ចតាមផ្លូវច្បាប់រវាងសមាជិកអាស៊ានទាំង ១០ប្រទេស។

សហគមន៍អាស៊ានៈ ទស្សនវិស័យអាស៊ាន សម្រាប់ឆ្នាំ២០២០ ដែលត្រូវបានអនុម័តដោយប្រមុខដឹកនាំអាស៊ាន នៅក្នុងឱកាសនៃខួបអនុស្សាវរីយ៍ ៣០ឆ្នាំ របស់អាស៊ាន បានឯកភាពលើទស្សនវិស័យរួមរបស់អាស៊ានថាជាការព្រមព្រៀងរបស់ប្រជាជាតិ អាស៊ីអាគ្នេយ៍ ដោយសំលឹងមើលទៅខាងក្រៅ រស់នៅក្នុងសុខសន្តិភាព ស្ថិរភាព និងវឌ្ឍនភាព ស្អិតរមួតជាមួយគ្នានៅក្នុងភាពជាដៃគូនៅក្នុងការអភិវឌ្ឍប្រកបដោយថាមវន្ត និងនៅក្នុងសហគមន៍មួយរបស់សង្គម ដែលប្រកបដោយការយកចិត្តទុកដាក់ចំពោះគ្នា។

នៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទី៩ នៅក្នុងឆ្នាំ២០០៣ ប្រមុខដឹកនាំអាស៊ាន បានសម្រេចថាសហគមន៍អាស៊ាននឹងត្រូវបង្កើតឡើង។ នៅឯកិច្ចប្រជុំ កំពូលអាស៊ានលើកទី១២ នៅខែមករា ឆ្នាំ២០០៧ ប្រមុខដឹកនាំបានអះអាង នូវការប្តេជ្ញាចិត្តដ៏មុតមាំរបស់ខ្លួនក្នុងការជំរុញឱ្យបានឆាប់រហ័ស នូវការបង្កើតសហគមន៍អាស៊ានមួយនៅឆ្នាំ២០១៥ និងបានចុះហត្ថលេខាលើសេចក្តី ថ្លែងការណ៍សេប៊ូ ស្តីពីការជំរុញនូវការបង្កើតសហគមន៍អាស៊ានមួយនៅឆ្នាំ២០១៥។

សហគមន៍អាស៊ាន មានសសរស្តម្ភ ៣ គឺ សហគមន៍នយោបាយ-សន្តិសុខអាស៊ាន សហគមន៍សេដ្ឋកិច្ចអាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ាន។ សសរស្តម្ភនីមួយៗមានផែនការលម្អិត របស់គេផ្ទាល់ ហើយរួមគ្នានឹងគំនិតផ្តួចផ្តើម សម្រាប់ក្របខ័ណ្ឌយុទ្ធសាស្ត្រសមាហរណកម្មអាស៊ាន និងផែនការការងារទី២ នៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (២០០៩-២០១៥) បង្កើតបានជាផែនទីបង្ហាញផ្លូវសម្រាប់សហគមន៍អាស៊ាន ២០០៩-២០១៥[441]។

### សំណួរត្រិះរិះ

១-ហេតុអ្វីបានជានៅក្នុងដំណាក់កាលដំបូង បិតាស្ថានិកអាស៊ានមិនអាចសម្រេចបាននូវក្តីស្រមៃរបស់ខ្លួនគឺអាស៊ាន១ មានសមាជិក១០?

២-តើសង្គ្រាមត្រជាក់ជះឥទ្ធិពលយ៉ាងដូចម្តេចចំពោះការវិវត្តនៃអាស៊ាន?

៣-វិភាគពីមូលហេតុដែលនាំឱ្យមានអាស៊ាន បូក១ អាស៊ានបូក២ និងអាស៊ានបូក៣។

៤-វិភាគពីសក្តានុពល និងបញ្ហាប្រឈមរបស់ប្រទេសទាំងអស់នៅក្នុងសហគមន៍អាស៊ាន។

---

441 ជា ចន្ថា **ភូមិវិទ្យាអាស៊ាន** ឯកសារបង្រៀននៅCUS 2012

# ផ្នែកទី៣

# ប្រវត្តិសាស្ត្រសកលលោក

# មេរៀនទី១ អរិយធម៌ពិភពលោកបុរាណ

## ១.អរិយធម៌អេហ្ស៊ីប មេសូប៉ូតាមី ឥណ្ឌា និងចិន

នៅប្រមាណជា៨ពាន់ឆ្នាំមុនគ្រិស្តសករាជ (ប្រមាណជា ១ម៉ឺនឆ្នាំមុន) មនុស្សចាប់ផ្តើមចេះធ្វើកសិកម្មដើម្បីចិញ្ចឹមជីវិតជំនួសឱ្យការបរបាញ់។ បដិវត្តន៍កសិកម្មនេះបានធ្វើឱ្យមនុស្សចាប់ផ្តើមមានតម្រូវការសំខាន់មួយ គឺត្រូវការឱ្យមានអ្នកដឹកនាំ និងរចនាសម្ពន្ធសហគមន៍ត្រឹមត្រូវ ដែលជាទម្រង់ដំបូង នៃរដ្ឋ ដើម្បីចាត់ចែងបែងចែកធនធានទឹកឱ្យបានស្មើភាពគ្នា ដើម្បីប្រើប្រាស់ក្នុងការប្រកបរបរកសិកម្ម ព្រមទាំងរក្សាសណ្តាប់ធ្នាប់ និងការពារសុវត្ថិភាពរបស់ប្រជាកសិករ។

រដ្ឋ និងអរិយធម៌បានចាប់កំណើតឡើងមុនគេ នៅតាមតំបន់ដែលមនុស្សចាប់ផ្តើមបង្កើតរបរកសិកម្ម គឺតំបន់ទាំង៤ ដែលជាប់នឹងទន្លេសំខាន់ៗ រួមមាន អេហ្ស៊ីប ជាប់នឹងទន្លេនីល មេសូប៉ូតាមី ជាប់នឹងដងទន្លេអឺប្រាត និងទន្លេទីគ្រីស ឥណ្ឌា ជាប់នឹងដងទន្លេឥណ្ឌុស និងចិន ជាប់នឹងដងទន្លេលឿង។ ដោយសារតែសកម្មភាពដាំដុះ និងចិញ្ចឹមសត្វ ជាសកម្មភាពដែលអាចផ្តល់ផលបានយ៉ាងច្រើនលើសពីតម្រូវការប្រចាំថ្ងៃ រដ្ឋត្រូវមានភារៈដ៏សំខាន់មួយទៀត គឺចាត់ចែងស្តុកផលិតផលកសិកម្ម ដើម្បីបម្រុងទុកសម្រាប់ឆ្នាំណាដែលការដាំដុះមិនសូវផ្តល់ផលច្រើន។ ដើម្បីចាត់ចែងស្តុកផលិតផលដ៏ច្រើន និងក្នុងរយៈពេលយូរអង្វែងបែបនេះ គេចាំបាច់ត្រូវការឱ្យមានបញ្ជីកត់ត្រាចំណាំឱ្យបានច្បាស់លាស់ ហើយដើម្បីអាចកត់ត្រាបានគេចាំបាច់ត្រូវបង្កើតអក្សរ។

ការបង្កើតអក្សរត្រូវបានគេចាត់ទុកថាជាដែនកំណត់ ពីសម័យកាលបុរេប្រវត្តិ ឈានចូលក្នុងសម័យកាលប្រវត្តិសាស្ត្រ។ ក៏ប៉ុន្តែ ដែនកំណត់នៃបុរេប្រវត្តិ មិនដូចគ្នាទាំងអស់ នៅគ្រប់ទីកន្លែងទូទាំងពិភពលោកនោះទេ ពីព្រោះថា ក្រុមមនុស្សដែលនៅកន្លែងផ្សេងៗគ្នា មិនបានចាប់ផ្តើមបង្កើតអក្សរក្នុងពេលព្រមគ្នានោះទេ។ នៅកន្លែងណា ដែលមិនទាន់មានការបង្កើតអក្សរ មនុស្សបន្តរស់នៅ ក្នុងសម័យកាលបុរេប្រវត្តិ។ ក្នុងពេលជាមួយគ្នានោះ នៅកន្លែងផ្សេងទៀត ដែលមានការបង្កើតអក្សរ មនុស្សចាប់ផ្តើមបោះជំហានចូលក្នុងសម័យកាលនៃប្រវត្តិសាស្ត្រ។

នៅអេហ្ស៊ីប មនុស្សចាប់ផ្តើមបង្កើតអក្សរ នៅប្រមាណជា៣ពាន់ ទៅ៤ពាន់ឆ្នាំមុនគ្រិស្តសករាជ (៥ពាន់ ទៅ៦ពាន់ឆ្នាំមុនសម័យកាលបច្ចុប្បន្ន) ហើយទម្រង់រដ្ឋដំបូងបង្អស់ក្នុងប្រវត្តិមនុស្សជាតិ គឺបានចាប់កំណើតឡើង នៅអេហ្ស៊ីបនេះឯង។

រដ្ឋចាប់កំណើតដំបូងនៅអេហ្ស៊ីប តាមដងទន្លេនីល គឺមកពីតម្រូវការចាំបាច់ នៃអាកាសធាតុ។ អេហ្ស៊ីបដែលស្ថិតនៅក្បែរវាលខ្សាច់សាហារ៉ា ជាតំបន់ដែលកម្រនឹងមានភ្លៀងធ្លាក់ ហើយប្រជាកសិករដែលរស់នៅទីនោះ ត្រូវការឱ្យមេដឹកនាំ និងរចនាសម្ពន្ធរដ្ឋ ដើម្បីជួយចាត់ចែងបែងចែកធនធានទឹកប្រើប្រាស់ឱ្យបានស្មើភាពគ្នា ចៀសវាងវិវាទ។ អេហ្ស៊ីបនៅក្នុងសម័យកាលនោះ គឺជាអាណាចក្រដែលមានប្រជាជនយ៉ាងច្រើន គឺប្រមាណពី៧ ទៅ ៨លាននាក់ ហើយអាណាចក្រអេហ្ស៊ីបបានស្គាល់នូវភាពរុងរឿង និងឯករាជ្យ អស់រយៈពេលប្រមាណជា២៥សតវត្ស។ គឺនៅក្នុងអាណាចក្រអេហ្ស៊ីបសម័យបុរាណ និងសម័យកាលរុងរឿងនេះហើយ ដែលមានការសាងសង់ពីរ៉ាមីតជាច្រើន បន្សល់ទុកជាអច្ឆរិយវត្ថុរបស់មនុស្សជាតិរហូតមកទល់នឹងពេលបច្ចុប្បន្ន។

អាណាចក្រអេហ្ស៊ីបឯករាជ្យ ត្រូវបានបញ្ចប់ នៅឆ្នាំ៥២៥មុនគ.ស. នៅពេលដែលអេហ្ស៊ីបត្រូវបានអាណាចក្រពែរ្សវាយដណ្តើមកាន់កាប់។ ចាប់ពីពេលនោះមក អេហ្ស៊ីបក៏ត្រូវធ្លាក់ដុនដាប លែងស្គាល់ឯករាជ្យ

រហូតទាល់តែដល់អំឡុងឆ្នាំ១៩៥០ថ្មីៗ នេះប៉ុណ្ណោះទើបអេហ្ស៊ីបសម័យទំនើប និងឯករាជ្យបានចាប់កំណើតឡើងវិញ។

បន្ទាប់ពីអេហ្ស៊ីប រចនាសម្ពន្ធរដ្ឋក៏បានចាប់ផ្តើមចេញជារូបរាងឡើងដែរ នៅមេសូប៉ូតាមី (អ៊ីរ៉ាក់បច្ចុប្បន្ន)។ នៅតាមដងទន្លេអឺហ្វ្រាត និងទីហ្គ្រីស គេឃើញមានអាណាចក្រជាច្រើនបានចាប់កំណើតឡើងជាបន្តបន្ទាប់ ដែលក្នុងនោះ អាណាចក្រមួយ ដែលត្រូវបានគេស្គាល់ទូទៅច្រើនជាងគេ គឺបាប៊ីឡូន។ អាណាចក្របាប៊ីឡូន មានរាជធានី នៅក្បែររដ្ឋធានីបាកដាដរបស់អ៊ីរ៉ាក់នាពេលបច្ចុប្បន្ន ហើយអាណាចក្របាប៊ីឡូនសម័យបុរាណ មានមហាក្សត្រមួយអង្គ គឺព្រះចៅហាមូរ៉ាប៊ី (Hammourabi) ដែលមានឈ្មោះល្បីក្នុងការយកមាត្រាច្បាប់មកចងក្រងធ្វើជាក្រម ច្បាប់ដ៏ពេញលេញមួយ ដែលគេស្គាល់ជាទូទៅថាជា "ក្រមហាមូរ៉ាប៊ី" បង្កើតឡើង តាំងពីប្រមាណជា១៧៥០ឆ្នាំមុនគ.ស. ហើយជាក្រមច្បាប់ដ៏ពេញលេញដំបូងគេបង្អស់នៅក្នុងប្រវត្តិសាស្ត្រ មនុស្សជាតិ។

អាណាចក្រនៅក្នុងតំបន់មេសូប៉ូតាមីក៏ជាអាណាចក្រដែលមានស្ថាបត្យកម្ម ដ៏រុងរឿងមិនចាញ់អេហ្ស៊ីបប៉ុន្មានដែរ ក៏ប៉ុន្តែ នៅមេសូប៉ូតាមី សំណង់ភាគច្រើន សង់ពីដីឥដ្ឋ ដែលមិនអាចនៅគង់វង់បានយូរដល់ពេលបច្ចុប្បន្ន ដូចជាសំណង់នៅអេហ្ស៊ីប ដែលសង់ពីថ្ម។

កាលពីសម័យដើម អេហ្ស៊ីប និងមេសូប៉ូតាមី ដែលមានព្រំប្រទល់ដែនជាប់គ្នា នៅប៉ាឡេស្ទីន គឺជាគូប្រជែងនឹងគ្នាយ៉ាងស្រួចស្រាវ។ ចេញពីមេសូប៉ូតាមី បើគេធ្វើដំណើរឆ្ពោះទៅទិសខាងកើត ហើយធ្វើដំណើរឆ្លងកាត់ពេលវេលា ប្រមាណជា១ពាន់ ៥រយឆ្នាំក្រោយមកទៀត គេនឹងឃើញមានអរិយធម៌ពីរទៀត គឺឥណ្ឌានៅតាមដងទន្លេឥណ្ឌុស (Indus) និងចិន នៅតាមដងទន្លេលឿង។

ហេតុអ្វីបានជា១ពាន់ ៥រយឆ្នាំ ក្រោយមក ទើបរដ្ឋចាប់កំណើតនៅ ឥណ្ឌា និងចិន ? នៅក្នុងតំបន់នេះថ្វីដ្បិតតែ ការប្រែប្រួលអាកាសធាតុបណ្តាលឱ្យបាត់បង់ព្រៃឈើ បង្កជាវាលខ្សាច់ច្រើន ក៏ប៉ុន្តែ ខុសពី អេហ្ស៊ីប និងមេសូប៉ូតាមី តំបន់ជុំវិញដងទន្លេឥណ្ឌុស និងទន្លេលឿង គឺជាតំបន់ដែលសម្បូរភ្លៀង។ ហេតុដូច្នេះហើយបានជាដំណើរវិវឌ្ឍ ឆ្ពោះទៅការបង្កើតរដ្ឋ នៅឥណ្ឌា និងចិន បានធ្វើឡើងដោយសន្សឹមៗ ដោយសារតែ មនុស្សនៅក្នុងតំបន់នេះ មិនសូវជាមានតម្រូវការចាំបាច់ និងបន្ទាន់ខ្លាំង ក្នុងការបង្កើតជារចនាសម្ពន្ធរដ្ឋ ដើម្បីគ្រប់គ្រងបែងចែកធនធានទឹក ដូចជា នៅអេហ្ស៊ីប និងមេសូប៉ូតាមីនោះទេ។

១ពាន់ឆ្នាំមុនគ.ស. (ជាង ៣ពាន់ឆ្នាំមុនសម័យកាលយើងបច្ចុប្បន្ន) អរិយធម៌ចំនួន៤ បានចាប់កំណើតនៅលើភពផែនដី៖ អេហ្ស៊ីប មេសូប៉ូតាមី ឥណ្ឌា និងចិន ដោយមួយៗ មានប្រជាជនសរុបប្រមាណជា១០លាននាក់ ហើយមានទំនាក់ទំនងជាមួយគ្នាច្រើន ទាំងការធ្វើសង្គ្រាម និងការជួញដូរ។

សូត្រ ដែលពេលនោះមានផលិតតែនៅចិន ត្រូវបានគេនាំយកទៅលក់រហូតទៅដល់អេហ្ស៊ីប ដោយឆ្លងកាត់តាមផ្លូវគោកដ៏វែងឆ្ងាយ ដែលគេឱ្យឈ្មោះថា "ផ្លូវសូត្រ" ចេញពីឆាងអាន កាត់តាមឥណ្ឌា និងមេសូប៉ូតាមី រហូតទៅដល់អេហ្ស៊ីប។

និយាយពីសង្គ្រាមវិញ ចិន និងឥណ្ឌា ក្នុងសម័យបុរាណ មិនសូវជាធ្វើសង្គ្រាមនឹងគ្នាដោយផ្ទាល់ច្រើនដូចជា អេហ្ស៊ីប និងមេសូប៉ូតាមីនោះទេ ក៏ប៉ុន្តែ រដ្ឋ និងបុរី នៅខាងផ្ទៃក្នុងអាណាចក្រចិនវិញ មានការធ្វើសង្គ្រាមស៊ីសាច់ហុតឈាមរវាងគ្នានិងគ្នា ដោយឥតត្រាប្រណី រហូតដល់ជាប់ឈ្មោះថាជា "អាណាចក្រសង្គ្រាម"។ រហូតដល់ឆ្នាំ២២០មុនគ.ស. ទើបអាណាចក្រចិនបានស្គាល់ការរួបរួមគ្នា ក្រោមការដឹកនាំរបស់អធិរាជ "ឈីន" (Qin)។

នៅក្នុងប្រវត្តិសាស្ត្រចិនសម័យបុរាណ គេឃើញមានយុគសម័យកាលរួបរួម និងរុងរឿង គឺសម័យរាជវង្សហាន (ពីឆ្នាំ២០០មុនគ.ស. ដល់ឆ្នាំ២០០គ.ស.) រាជវង្សថាង (នៅអំឡុងសតវត្សទី៧ ដល់ទី១០) រាជវង្សសុង (ចុងសតវត្សទី១០ ដល់សតវត្សទី១៣) រាជវង្សមីង (ចន្លោះសតវត្សទី១៤ ដល់ទី១៧) ដែលត្រូវបានគេចាត់ទុកថាជាសម័យកាលរុងរឿងបំផុតមួយ ក្នុងប្រវត្តិសាស្ត្រចិន ក៏ដូចជាប្រវត្តិមនុស្សជាតិ។ នៅចន្លោះសម័យកាលដ៏រុងរឿងអស់ទាំងនេះ ចិនធ្លាក់ក្នុងសម័យកាលខ្មៅងងឹត ដែលប្រជាជនស្គាល់នូវភាពបាក់បែក ប្រកាប់ប្រចាក់គ្នា និងភាពអនាធិបតេយ្យ ដូចជា សម័យកាលនគរទាំងបី ជាដើម ដែលជាសម័យកាលមួយមានការបង្ហូរឈាមខ្លាំងបំផុតក្នុងប្រវត្តិសាស្ត្រចិន និងដែលគេច្រើនយកមកសរសេរជារឿង ជាល្ខោន ឬផលិតជាកុន ដូចជា រឿង «សាមកុក» ជាដើម។

ក្រៅពីហេតុការណ៍បះបោរ រដ្ឋប្រហារ ការធ្វើសង្គ្រាមផ្ទៃក្នុងគ្នាឯង អាណាចក្រចិនសម័យបុរាណ ក៏ប្រឈមមុខនឹងការគំរាមកំហែងដ៏ធំមួយទៀតដែរ គឺការឈ្លានពានពីសំណាក់ពួកក្រុមកុលសម្ព័ន្ធ ដែលបន្តរស់នៅតាមរបៀបសម័យបុរេប្រវត្តិ។ ដើម្បីការពារខ្លួនពីការឈ្លានពាន ពីសំណាក់ពួកទាំងនេះហើយ ដែលចិនបានសង់ជាមហាកំផែង ដែលបន្តទុករហូតមកទល់នឹងសព្វថ្ងៃនេះ។

អេហ្ស៊ីប មេសូប៉ូតាមី ឥណ្ឌា ចិន... នេះហើយគឺជាអរិយធម៌ដំបូងបង្អស់នៃមនុស្សជាតិ។ គឺជាទីកន្លែងចាប់កំណើតនៃកសិកម្ម តាំងពីរាប់ពាន់ឆ្នាំមុន។ របៀបរស់នៅ ដែលយើងនៅតែបន្តឃើញមានមកទល់នឹងពេលបច្ចុប្បន្ន។ គំនិតច្នៃប្រឌិត និងរបកគំហើញមួយចំនួន ដូចជា ត្រីវិស័យ រំសេវផ្ទុះ ក្រមច្បាប់ ជាដើម គឺសុទ្ធសឹងជាមរតក ដែលបន្សល់ទុកដោយអរិយធម៌ដ៏ចំណាស់ទាំង៤នេះ ឱ្យមនុស្សជាតិយើងបន្តប្រើប្រាស់ រហូតមកទល់នឹងពេលបច្ចុប្បន្ន។ នៅពេលដែលយើងអាន ស្តាប់ និងមើលព័ត៌មានជារៀងរាល់ថ្ងៃ យើងនៅតែឃើញ ចិន ឥណ្ឌា អេហ្ស៊ីប និងតំបន់ដើមបូព៌ា បន្តជាប្រធានរឿងធំៗ ជាចំណុចចាប់អារម្មណ៍នៃមនុស្សជាតិសម័យបច្ចុប្បន្ន[442]។

## ២.អរិយធម៌ផេនីស៊ី

ផេនីស៊ី(Phénicie) ជារដ្ឋមួយដែលមានអរិយធម៌ដ៏ចំណាស់ក្នុងបណ្តាប្រទេសនៅមជ្ឈិមបូព៌ា ឥឡូវរលាយបាត់ឈ្មោះទៅហើយ។

### ២.១-ទីតាំងភូមិសាស្ត្រ

រដ្ឋផេនីស៊ីមានទីតាំងនៅចន្លោះប្រទេសលីបង់សព្វថ្ងៃ និងសមុទ្រមេឌីទែរ៉ានេ។ រដ្ឋនេះមានទទឹងតូចចង្អៀតហើយសម្បូរទៅដោយជួរភ្នំ តំបន់វាលទំនាបមានតិចតួច ហើយតាមឆ្នេរសមុទ្រ មានកំពង់ផែសំខាន់ៗដូចជា កំពង់ផែតៀ(Tyr) ប៊ីប្លូស(Byblos) និងស៊ីដុង(Sidon)។ កំពង់ផែទាំងនោះជាទីក្រុង និងជាមជ្ឈមណ្ឌលដែលមានជីវភាពនយោបាយដាច់ពីគ្នា ពុំសូវមានឯកភាពគ្នាជាធ្លុងមួយឡើយពីព្រោះពួកគេចង់រក្សាការពារឯករាជ្យរបស់គេផ្ទាល់ខ្លួន។ ការបាត់បង់ឯកភាពជាតិនេះជាបុព្វហេតុនាំឱ្យទីក្រុងទាំងនោះធ្លាក់ក្នុងកណ្តាប់ដៃរបស់ប្រទេសអេហ្ស៊ីប អាណាចក្រពែរ្ស និងប្រទេសអាស៊ីរីម្តងមួយៗ។

### ២.២-ជីវភាពប្រជាជន

---

[442] សេង ឌីណា, *ប្រវត្តិសាស្ត្រពិភពលោក*, ឆ្នាំ២០១៣។

ជនជាតិផេនីស៊ីមានដើមកំណើតពីជាតិសាសន៍សេមីទិក(Sémitique) ដែលបានមកតាំងទីលំនៅតាំងពី ឆ្នាំ៣០០០ មុនគ. ស.។ ជនជាតិនេះប៉ិនប្រសប់ក្នុងការធ្វើសំពៅធំៗពីឈើ និងយកសំបកខ្យង ទៅបុកធ្វើជាពណ៌សម្រាប់ជ្រលក់កំណាត់សំពត់បានល្អប្រណីត។

ជនជាតិក្រិកដែលល្បីថាពូកែធ្វើពាណិជ្ជកម្ម ប៉ុន្តែចាញ់ពួកផេនីស៊ី ពួកគេបានក្លាយទៅជាមហាអំណាចមួយដ៏សំខាន់ខាងពាណិជ្ជកម្មនៅតាមឆ្នេរសមុទ្រមេឌីទែរ៉ានេ។

ជនជាតិដើមផេនីស៊ីជាអ្នកនេសាទយ៉ាងពូកែ គេបានទន្ទ្រានលើសមុទ្រឌីទែឌីទែរ៉ានេប៉ែកខាងលិចហួតដល់មហាសមុទ្រអាត្លង់ទិចនិងសមុទ្រខាងជើងនៃទ្វីបអឺរ៉ុប ។ ការរុករកនេះ មានគោលដៅជាចម្បងគឺពាណិជ្ជកម្ម។ ជនជាតិផេនីស៊ីបានបង្កើតគណនីដ្ឋាន និងឃ្លាំងផ្ទុកទំនិញនៅគ្រប់តំបន់ដែលគេបានទៅដល់។ ការបង្កើតឃ្លាំងទាំងនេះ ក្នុងគោលបំណងបម្រើផលប្រយោជន៍នៃអាជីវកម្មតែម្យ៉ាងរបស់ពួកគេ។

តាមផ្លូវគោក ពួកផេនីស៊ីបានធ្វើជំនួញជាក្បួនរទេះជាមួយនឹងក្រុងជំនួញធំៗមាន អាស៊ីខាងលិច អេហ្ស៊ីប អាហ្វ្រិក និងប្រទេសអេស្ប៉ាញ។ ពួកនេះជាឈ្មួញកណ្តាលដែលទិញទំនិញពីកន្លែងមួយទៅកន្លែងមួយទៀត និងជាអ្នកដឹកនាំផលិតផលរបស់ប្រទេសខ្លួនទៅលក់នៅប្រទេសក្រៅផង។ សម្ភារៈប្រើប្រាស់ និងវត្ថុប្រណីតដូចជា កែវចរណៃ អាវុធ គ្រឿងអលង្ការ ជាពិសេសសំពត់ឡែនដែលពេញនិយមក្នុងសម័យនោះ។

## ៣.៣-អរិយធម៌

ជនជាតិផេនីស៊ី បានបន្សល់ទុកនូវអរិយធម៌ដល់មនុស្សជាតិជំនាន់ក្រោយ ដូចជាពាណិជ្ជកម្មផ្លូវសមុទ្រ និងការបង្កើតអក្សរក្រម។

### ៣.៣.១-សកម្មភាពពាណិជ្ជកម្ម

ជនជាតិផេនីស៊ី ប៉ិនប្រសប់ និងល្បីល្បាញខាងធ្វើជំនួញជុំវិញសមុទ្រមេឌីទែរ៉ានេ។ ពួកគេបាននាំចូលទំនិញសព្វសារពើ ពីប្រទេសក្រិក និងប្រទេសអេហ្ស៊ីប ពិសេសវត្ថុធាតុដើម ដើម្បីបំពេញតម្រូវការ សិប្បកម្មក្នុងស្រុក។

ពួកផេនីស៊ីចេះមើលផ្កាយសម្គាល់ទិសដោយមិនព្រួយពីការវង្វេងផ្លូវឡើយ។ ពួកគេធ្វើដំណើរឆ្លងកាត់សមុទ្រមេឌីទែរ៉ានេ ចូលមហាសមុទ្រអាត្លង់ទិក ឆ្ពោះទៅកាន់កោះទាំងឡាយនៃចក្រភពអង់គ្លេសរួចឆ្លងចូលសមុទ្របាល់ទិក(Mer Baltique)ទៀតផង។ ក្រៅពីនេះពួកផេនីស៊ីបានឆ្លងទៅដល់អាហ្វ្រិកប៉ែកខាងលិច និងឈូងសមុទ្រគីនេ (Golfe de Guinee) ។

នៅសតវត្សទី៦ មុនគ.ស. ព្រះចៅផារ៉ាអុង ណេចាវនៃប្រទេសអេហ្ស៊ីប បានបញ្ជូនកងសំពៅផេនីស៊ីឱ្យធ្វើដំណើរជុំវិញទ្វីបអាហ្វ្រិកទាំងមូល។ ពាណិជ្ជកម្មផេនីស៊ីល្បីល្បាញខាងជំនួញ គ្រប់ច្រកល្ហកនៅតំបន់មេឌីទែរ៉ានេ ទ្វីបអាហ្វ្រិក និងអឺរ៉ុបប៉ែកខាងលិចផងដែរ។

ក្រុងពាណិជ្ជកម្មធំៗទាំងឡាយត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ពាណិជ្ជករផេនីស៊ី ព្រោះពួកគេបានដណ្តើមអំណាចពីព្រះមហាក្សត្រ ដោយសារការសម្បូរទ្រព្យសម្បត្តិ និងប្រាក់កាសរបស់ពួកគេ។

រដ្ឋផេនីស៊ីតូចពិតមែន តែប្រជាជននៅស្រុកនេះចូលចិត្តធ្វើពាណិជ្ជកម្ម ពុំសូវចូលចិត្តមុខរបរផ្សេងទៀតឡើយ។ ពួកផេនីស៊ីបង្កើតឧបនិវេសន៍ និងគ្រឹះស្ថានជំនួញក្នុងប្រទេសអេស្ប៉ាញ ប្រទេសហ្គោល (បារាំងសព្វថ្ងៃ)។ ឧបនិវេសន៍ដែលសំខាន់ និងល្បីល្បាញជាងគេ គឺក្រុងកាតាស (បច្ចុប្បន្ននៅប្រទេសទុយនីស៊ី) ដែលបានស្ថាបនាឡើងនៅសតវត្សទី៩ មុនគ.ស.។

នៅសតវត្សទី២ មុនគ.ស. ក្រុងកាតាសបានប្រកួតប្រជែងខាងពាណិជ្ជកម្មជាមួយចក្រភពរ៉ូម ហើយចក្រភពរ៉ូមបានបំផ្លាញក្រុងនេះខ្ទេចខ្ទី បាត់ឈ្មោះពីផែនទីពិភពលោក។

### ៣.៣.២-វិស័យវប្បធម៌

វិស័យសិល្បៈ និងវប្បធម៌ពុំសូវរីកចម្រើនដូចប្រទេសអេហ្ស៊ីប ក្រិក និងរ៉ូមទេ ពីព្រោះវត្ថុសិល្បៈរបស់ផេនីស៊ីច្រើនចម្លងចេញពីប្រទេសអេហ្ស៊ីប អាស៊ីរីជាដើម។

របកគំហើញដែលសំខាន់ជាងគេរបស់ផេនីស៊ី គឺការបង្កើតអក្សរក្រមនៅសហវត្សរ៍ទី២ មុនគ.ស. (អម្បូរភាសាសេមីទិច)។ គេចាត់ទុកថា ពួកអឺរ៉ុបប្រើភាសាសព្វថ្ងៃ ជាភាសារបស់ពួកផេនីស៊ី គឺអម្បូរភាសាសេមីទិច។ ភាសានេះមានព្យញ្ជនៈតែ២២តួ ខុសពីភាសាអេហ្ស៊ីបដែលមានព្យញ្ជនៈរាប់ពាន់តួ។ តួអក្សរផេនីស៊ីនីមួយៗមានសូរសព្ទដោយឡែកពីគ្នា ធ្វើឱ្យងាយយល់ និងងាយចងចាំទៀតផង។ អក្សរក្រមទាំងនេះជាប្រភពនៃតួអក្សរក្រិក ឡាតាំង អេស្បាញ អ៊ីតាលី និងបារាំងជាដើម។

### ៣.៣.៣-ជំនឿ និងសាសនា

ពួកផេនីស៊ីមានជំនឿ និងសាសនាដូចពួកអេហ្ស៊ីប និងអាស៊ីរីដែរ គឺគោរពពហុទេពនិយម។ នៅតាមក្រុងនីមួយៗមានទេវៈមួយអង្គនៅចាំថែរក្សាដូចជាក្រុងតៀ គេគោរពទេវៈ មេលកា(Melkar) ក្រុងប៊ីប្លូស គេគោរពទេវៈ អាដូនីស(Adonis) និងក្រុងកាតាស គេគោរពទេវៈបាអាល់(Baal) និងទេវៈ តានីត (Tanit)។

## ៣-អរិយធម៌ហេប្រឺ

ជនជាតិហេប្រឺ(Hébreu)ជាបុព្វបុរសរបស់ជនជាតិជ្វីហ្វ ឬអ៊ីស្រាអែលសព្វថ្ងៃ ហើយគេអាចដឹងពីប្រវត្តិរបស់ជនជាតិនេះ តាមរយៈគម្ពីរប៊ីបរបស់សាសនាគ្រិស្ត។ គម្ពីរនេះបានបង្ហាញពីសាសនាប្រវត្តិសាស្ត្ររបៀបគ្រប់គ្រងរដ្ឋ និងទំនៀមទម្លាប់នៃជនជាតិហេប្រឺ ទៀតផង។

### ៣.១-ប្រវត្តិទឹកដី និងជនជាតិហេប្រឺ

រាប់ពាន់ឆ្នាំមកហើយ ជនជាតិហេប្រឺ ជាកុលសម្ព័ន្ធរស់នៅជាចរកជន ចិញ្ចឹមជីវិតដោយរបរចិញ្ចឹមចៀមនិងអូដ្ឋតាមតំបន់វាលខ្សាច់ស៊ីរីនៅត្រើយខាងស្តាំនៃទន្លេ អឺប្រាត។ ជនជាតិនេះរស់នៅក្រោមឱវាទចៅហ្វាយម្នាក់ដែលមានអំណាចទូលំទូលាយហៅថាព្រឹទ្ធាចារ្យ។ តាមរយៈគម្ពីរប៊ីប បានឱ្យដឹងថាក្នុងអំឡុងឆ្នាំ២០០០ មុនគ.ស. ព្រឹទ្ធាចារ្យនៃជនជាតិហេប្រឺម្នាក់ឈ្មោះអាប្រាហាម បានដឹកនាំកុលសម្ព័ន្ធរបស់ខ្លួននៅលើទឹកដីប៉ាលេស្ទីន ដែលជាទឹកដីមានជីជាតិល្អបង្គួរ ហើយពួកគេចាត់ទុកជាដីដែលព្រះប្រទានឱ្យពួកគេ។

នៅសតវត្សទី៥ មុនគ. ស. ជនជាតិហេប្រឺរស់នៅតំបន់មួយហៅថាប៉ាលេស្ទីន (Palestine)។ តំបន់នេះមានសណ្ឋានដីវែង តូចចង្អៀត ហើយស្ថិតនៅចន្លោះវាលខ្សាច់ស៊ីរីនិងសមុទ្រមេឌីទែរ៉ាណេ។ ទន្លេ ស្ទួកដាំង(Jourdain) ហូរតាមតំបន់នេះពីជើងទៅត្បូងរួចចាក់ក្នុងសមុទ្រក្ស័យ(Mer Morte)។ សមុទ្រក្ស័យជាសមុទ្រទឹកប្រៃខ្លាំងមិនអាចឱ្យត្រី ឬសត្វរស់នៅបាន។

ប៉ាលេស្ទីន ជាតំបន់ដែលមានអាកាសធាតុក្តៅខ្លាំង ហើយស្ងួតពុំសូវមានភ្លៀងធ្លាក់ឡើយ។ ទន្លេស្ទួកដាំង ជាទេវៈដែលប្រោះព្រំអាយុជីវិតមនុស្សសត្វ និងរុក្ខជាតិនៅតំបន់ប៉ាលេស្ទីននេះ។

នៅឆ្នាំ១៧០០ មុនគ.ស. ដោយឃើញប្រទេសអេហ្ស៊ីប ប្រកបដោយដោយធនធានស្តុកស្តម្ភ កុលសម្ព័ន្ធហេប្រឺបានចាកចោលដែនដីប៉ាលេស្ទីនទៅរស់នៅប្រទេសអេហ្ស៊ីប ដោយសម្របខ្លួនរស់នៅ ជានិសិទ្ធជន។

ដំបូងឡើយព្រះចៅផារ៉ាអុងនៃប្រទេសអេហ្ស៊ីបបានអបអរ រាក់ទាក់ជាមួយជនជាតិចំណូលថ្មី តែក្រោយមកព្រះអង្គបានរឹតបណ្តឹងច្បាប់ខ្លាំងឡើងៗ ទៅដល់ជនចំណូលថ្មី។ ដោយទ្រាំនឹងច្បាប់ព្រះចៅ

ផារាំអុងមិនបាន ពួកហេប្រឺបានវិលត្រឡប់មករស់នៅលើទឹកដីប៉ាលេស្ទីនវិញដោយវាយកំចាត់ជនជាតិផ្សេងៗនៅទីនោះចាកចេញ មានជនជាតិភីលីស្តាំង (Philistins)ជាដើម។ រួចតាំងប្រទេសនៅទីនេះជារៀងរហូតមក។

## ៣.២-សម័យកាលសំខាន់ៗ

### ក-សម័យកាលរុងរឿង

ក្រោយពីកុលសម្ពន្ធហេប្រឺទាំងអស់បានស្រុះស្រួលមូលមតិគ្នា ជ្រើសរើសនាយទាហានមួយរូបធ្វើជាព្រះមហាក្សត្រគ្រប់គ្រងលើកុលសម្ពន្ធទាំងអស់ព្រមទាំងបានរៀបចំឱ្យមានកងទ័ពអចិន្ត្រៃយ៍។

នៅសតវត្សទី១០ មុនគ.ស. ព្រះបាទដាវីត(David) បានវាយបង្ក្រាបសត្រូវឱ្យអស់ពីទឹកដី ហើយបានស្ថាបនារាជធានីដ៏ល្អវិចិត្រមួយ ដែលមានទាហានការពារនិងមានសកម្មភាពពាណិជ្ជកម្មដ៏ល្អប្រសើរ គឺទីក្រុងហ្សេរុយសាឡិម(Jérusalem)។

នៅឆ្នាំ៩៣២ មុនគ.ស. ព្រះបាទដាវីតសោយទិវង្គត ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមសាឡូម៉ុង (Salomon) បានសោយរាជសម្បត្តិបន្ត។ នៅក្នុងរជ្ជកាលព្រះបាទសាឡូម៉ុងជនជាតិហេប្រឺបានស្គាល់នូវភាពរុងរឿងដ៏ត្រចះត្រចង់ ដោយសារការលូតលាស់ខាងវិស័យពាណិជ្ជកម្មក្រៅប្រទេស។

ព្រះបាទសាឡូម៉ុង ជាក្សត្រប្រកបដោយគតិយុត្តិធម៌ ប៉ិនប្រសប់ក្នុងការដឹកនាំ និងឈ្លាសវៃក្នុងការគ្រប់គ្រងរដ្ឋ។ ព្រះអង្គមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងគ្រប់គ្រងវិសាលភាពទឹកដីធំទូលាយ គឺលាតសន្ធឹងចាប់ពីទន្លេអឺប្រាតរហូតដល់សមុទ្រក្រហម។ ព្រះអង្គបានបញ្ជាឱ្យគេកសាងព្រះរាជវាំងមួយ និងព្រះវិហារមួយប្រកបដោយក្បូរក្បាច់រចនាដ៏វិចិត្រនៅទីក្រុងហ្សេរុយសាឡិម ដែលព្រះអង្គចាត់ទុកជានិមិត្តរូបនៃឯកភាពជាតិរបស់ជនជាតិហេប្រឺតរៀងមក។

### ខ-សម័យចុះខ្សោយ

ក្រោយពីមានភាពរុងរឿងមួយរយៈ វិបត្តិផ្ទៃក្នុងបានកើតឡើង បណ្តាលមកពីការបាក់បែកសាមគ្គីដែលជាហេតុធ្វើឱ្យជនជាតិហេប្រឺបែងចែកជាច្រើនក្រុម។ សង្គ្រាមផ្ទៃក្នុងបានធ្វើឱ្យប្រទេសចែកជាពីរ គឺអាណាចក្រខាងជើង និងអាណាចក្រខាងត្បូង។

- អាណាចក្រខាងជើង ហៅថាអ៊ីស្រាអែល មានរាជធានីឈ្មោះសាម៉ារី (Samarie)។ នៅឆ្នាំ៧២១ មុនគ.ស. ទីក្រុងសាម៉ារីត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទីអស់ដោយពួកអាស៊ីរីក្នុងរជ្ជកាលព្រះបាទសាកុង (Sargon)។
- អាណាចក្រខាងត្បូង ហៅថាជូដា (Juda) មានរាជធានីឈ្មោះហ្សេរុយសាឡិម។ នៅឆ្នាំ៥៨៧ មុន គ. ស. ពួកអាស៊ីរីបានវាយយករាជធានី និងចាប់ពួកហេប្រឺជាឈ្លើយនាំយកទៅក្រុងបាប៊ីឡូន។

ក្រោយមកអាណាចក្រពែរ្សក្នុងរជ្ជកាលព្រះបាទស៊ីរុស បានវាយដណ្តើមយកក្រុងបាប៊ីឡូន រួចដោះលែងឈ្លើយសឹកហេប្រឺឱ្យមករស់នៅមាតុភូមិខ្លួននៅប៉ាលេស្ទីន និងកសាងហ្សេរុយសាឡិមឡើងវិញ។

ជាអវសាន ក្រុងហ្សេរុយសាឡិមត្រូវបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ចក្រភពរ៉ូម ក្នុងសតវត្សទី១ មុនគ.ស. ហើយជនជាតិហេប្រឺក៏រលាយបាត់ឈ្មោះប្រទេសតាំងពីពេលនោះ។

## ៣.៣-អរិយធម៌ហេប្រឺ

ជនជាតិហេប្រឺ បានរួមចំណែកយ៉ាងសំខាន់ដល់អរិយធម៌ពិភពលោក ជាពិសេសខាងវិស័យសាសនា មានសាសនាជូដា សាសនាគ្រិស្ត និងសាសនាអ៊ីស្លាម មានប្រភពពីជនជាតិហេប្រឺ។

ទស្សនៈសាសនានៃជនជាតិហេប្រឺ មានលក្ខណៈ ខុសប្លែកពីសាសនាដទៃក្នុងសម័យកាលជាមួយគ្នា។ សាសនាជូដាបានអះអាងថាទេវៈ តែមួយអង្គនៅក្នុងលោកសន្និវាសយើងនេះ គឺសាសនាឯកទេពនិយមផ្ទុយពីប្រទេសដទៃមាន អេហ្ស៊ីប ក្រិក និងឥណ្ឌា ដែលជាសាសនាពហុទេពនិយម។

ជនជាតិជ្វីហ្វ គោរពសាសនាជូដាដែលមានអាទិទេពអ៊ីយ៉ាវ៉េ ដែលជាអាទិទេពធំតែមួយគត់ក្នុងពិភពលោក។ បើជនជាតិហេប្រឺណាគោរពទេវៈដទៃទៀតត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរពីអាទិទេពអ៊ីយ៉ាវ៉េ។ តែបើគោរពអ៊ីយ៉ាវ៉េតែមួយអង្គ ធ្វើឱ្យពួកគេក្លាយជាជនជាតិសំណព្វរបស់អាទិទេពដែលមានមហិទ្ធិឫទ្ធិអាចឈ្នះសត្រូវគ្រប់ទិសទី។ ការគោរពសាសនាតម្រូវឱ្យសាសនិកជនប្រារព្ធពិធីបូជាយញ្ញ ឬសូត្រធម៌ស្វាធ្យាយនៅចំពោះទូរទេសបញ្ញត្តិ(ច្បាប់ទូន្មានប្រៀនប្រដៅទាំង១០ របស់អាទិទេព)នៅក្នុងព្រះវិហារ។ ព្រះបាទ សាឡូម៉ុងបានស្ថាបនាវិហារមួយតម្កល់ផ្ទាំងទូរទេសបញ្ញត្តិសម្រាប់ជាទីសក្ការៈបូជារហូតមក។ ក្រោយមកសាសនាជូដាបានទទួលបម្រែបម្រួលជាច្រើន ព្រមទាំងមានលក្ខណៈជាសកលទៀតផង ដោយសារឥទ្ធិពលនៃពួកប្រូផែតមានលោកសេរេមី(Jeremie) អ៊ីសាអ៊ី(Isaie) និងដាញ៉ែល (Daniel)។

ចំណែកគ្រិស្តសាសនា ដែលចាប់កំណើតឡើងនៅតំបន់កាលីឡេ ក្នុងប្រទេសប៉ាលេស្ទីនមានមូលដ្ឋានធម៌ស្រង់ចេញពីសាសនាជូដាសុទ្ធសាធ ដោយមានជនជាតិជ្វីហ្វម្នាក់ឈ្មោះ យេស៊ូ ជាប្រូផែតមួយរបស់ខ្លួនដែរ។ រីឯសាសនាអ៊ីស្លាមបង្កើតឡើងដោយពួកហេប្រឺដែរគឺមហាម៉ាត់។

## ៤-ក្រិកបុរាណ

នៅលើជ្រោយ ដែលលយចូលក្នុងសមុទ្រមេឌីទែរ៉ានេភាគខាងជើង បានលេចឡើងនូវអរិយធម៌បុរាណមួយ ដ៏រុងរឿង ហើយបានជះឥទ្ធិពលដល់មនុស្សជំនាន់ក្រោយមិនសាបសូន្យនោះ គឺអរិយធម៌ក្រិក។

### ៤.១-ស្ថានភាពភូមិសាស្ត្រ និងប្រជាជន

ក្រិក គឺជាប្រទេសមួយនៅជាប់សមុទ្រមេឌីទែរ៉ានេភាគខាងត្បូងនៃទ្វីបអឺរ៉ុប មានទំហំប្រមាណ ៦៤ ០០០ គីឡូម៉ែត្រក្រឡា។ ប្រទេសនេះសម្បូរភ្នំ និង ព្រៃឈើ មានសមុទ្រព័ទ្ធជុំវិញ និងមានអាកាសធាតុក្តៅហើយស្ងួត។ នៅប៉ែកខាងត្បូងប្រកបដោយឈូងសមុទ្រ និងឆកជាច្រើន។ ជនជាតិក្រិក ជាអ្នកល្បីល្បាញ ប៉ិនប្រសប់ធ្វើដំណើរតាមឈូងសមុទ្រណាស់។

គេចែកភូមិសាស្ត្រប្រទេសក្រិកជាពីរផ្នែកគឺ ខាងជើងជាតំបន់ដីគោក និងខាងត្បូងជាតំបន់សមុទ្រដែលសម្បូរទៅដោយក្រុមកោះជាច្រើន មានកោះអេសេ(Egées) កោះអ៊ីយ៉ូនី(Ioniennies) និងឆ្នេរសមុទ្រដែលស្ថិតនៅខាងលិចអាស៊ីមីន័រ(Asie Mineure)។

ក្រិកពុំសូវសម្បូរដីកសិកម្មប៉ុន្មានទេ តែសម្បូរភោគទ្រព្យក្នុងដី មានដូចជា រ៉ែទង់ដែង រ៉ែប្រាក់។ ប្រទេសក្រិកមានមនុស្សរស់នៅជាយូរលង់មកហើយ។ មនុស្សដើមទាំងនោះ ហៅថាប៉េឡាស(Pèlasges) និងការី(Cariens) ដែលជាបក្សសម្ពន្ធប្រកបអាជីវកម្មខាងនេសាទ និងប្រមាញ់។ ឯកសិកម្មពុំសូវមាន ការលូតលាស់ឡើយ។

នៅអំឡុងសតវត្សទី១៥មុនគ.ស. ក្រិកត្រូវបានលុកលុយរាតត្បាត ពីក្រុមបក្សសម្ពន្ធចុះពីទិស ខាងជើងមានពួកអាកេ (Achéens) ពួកដូរី (Doriens)និងពួកអ៊ីយ៉ូនី ជាដើម។ ពួកគេបានតាំងទីលំនៅពាសពេញប្រទេសក្រិក និងបង្កាត់កូនចៅតៗមកបង្កើតបានជាជនជាតិក្រិក។

## ៤.២-រដ្ឋបុរីនានា

ប្រទេសក្រិកមានរដ្ឋបុរីតូចៗជាច្រើន ដែលមានស្វ័យភាពក្នុងការគ្រប់គ្រងរៀងៗខ្លួន។ គេឃើញមានបុរីអាថែន(Athènes) ស្ប៉ាត(Sparte) កូរាំង(Corinthe) តែប(Thèbes) អាកូស(Argos) ...។ បណ្ដាបុរីទាំងអស់នោះមានរដ្ឋាភិបាលកងទ័ព កងនាវា និងរូបិយវត្ថុផ្ទាល់ខ្លួននីមួយៗ។ ក្នុងចំណោមបុរីទាំងនោះ អាថែន និងស្ប៉ាកជាបុរីដែលល្បីល្បាញជាងគេ។

### ៤.២-១- បុរីស្ប៉ាត

បុរីស្ប៉ាតស្ថិតនៅតំបន់ប៉េឡូប៉ូណែស(Péloponnèse) ភាគខាងត្បូង។ បុរីស្ប៉ាតមានទិដ្ឋភាពប្រៀបបាននឹងភូមិមួយដែលមានផ្ទះរង្វើលៗ។ គេស្គាល់បុរីនេះមិនសូវច្បាស់ទេ ព្រោះប្រមុខដឹកនាំនៅបុរីនេះមិនឱ្យពលរដ្ឋចាកចោលទឹកដីកំណើត និងពុំទទួលយកអ្នកផ្សេងក្រៅពីអ្នកបុរីនេះឡើយ។

ក្នុងសង្គមស្ប៉ាត គេចែកពលរដ្ឋជាបីប្រភេទខុសគ្នា ហើយរស់នៅដោយឡែក ពុំលាយឡំគ្នាឡើយ។ ពលរដ្ឋស្ប៉ាតមានឋានៈក្នុងសង្គមខ្ពស់ជាងគេ ជាអ្នកដឹកនាំរដ្ឋ ហើយធ្វើអាជីវកម្មលើវណ្ណៈដទៃទៀត។

វណ្ណៈទាសករ ហៅថា អ៊ីឡូត ជាទាសាទាសីរស់នៅគ្មានតម្លៃក្នុងសង្គម ហើយធ្វើការងារធ្ងន់ធ្ងរ និងលំបាកបំផុត។ ពួកគេធ្វើកិច្ចការផ្សេងៗមានកសិកម្មជាដើម។ ទាសករទាំងនោះជាកម្មសិទ្ធិ ជាទ្រព្យសម្បត្តិផ្ទាល់របស់រដ្ឋ ហើយរដ្ឋចែកទាសករទាំងនោះទៅឱ្យវណ្ណៈដឹកនាំ ដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ពិសេសបម្រើពលរដ្ឋស្ប៉ាត ដែលជាក្រុមទី១។ មានជនមួយប្រភេទទៀតដែលមានស្រែចម្ការផ្ទាល់ខ្លួន ប្រកបអាជីវកម្មដោយសេរី តែពុំមានសិទ្ធិជាពលរដ្ឋឡើយ ព្រមទាំងពុំអាចចងស្ពានមេត្រី និងជនជាតិស្ប៉ាតបានទៀតផង។

រដ្ឋបានប្រមូលកូនប្រុសៗ ចាប់ពីអាយុ ៦ឆ្នាំឡើង យកទៅអប់រំបង្ហាត់បង្រៀនវិជ្ជាប្រយុទ្ធយ៉ាងតឹងរ៉ឹង មានរត់ ចោលថាស បង្ខំឱ្យដើរជើងទទេ និងគ្មានសម្លៀកបំពាក់គ្រប់ពេលវេលាទៀតផង។ ការបង្វឹកដ៏ហ្មត់ចត់នេះធ្វើឱ្យពួកគេចេះតស៊ូ ចេះអត់ធ្មត់គ្រប់បែបយ៉ាង និងធ្វើឱ្យកងទ័ពស្ប៉ាតមានអានុភាពខ្លាំងពូកែបំផុត។

យុវជនកាលណាដល់អាយុពេញវ័យត្រូវចូលបម្រើការទ័ពដោយស្វ័យប្រវត្តិ។ អាយុពី២០ ដល់៦០ឆ្នាំ ជនស្ប៉ាតគ្រប់រូបមានកាតព្វកិច្ចប្រជុំរៀងរាល់ថ្ងៃ ហើយហាត់រៀនគ្រប់មុខវិជ្ជាទាហាន។ សមាគមនីមួយៗមានអគាររបស់គេសម្រាប់ទទួលទានចំណីអាហាររួមគ្នា ដេក និងហាត់រៀនជាមួយគ្នា។ មិនតែប៉ុណ្ណោះរដ្ឋបានជ្រៀតជ្រែកក្នុងជីវភាពរបស់ពួកគេ ដូចជាការជ្រើសរើសគូស្រករក្ដី ក្នុងការអប់រំកូនប្រុសកូនស្រីក្ដី។ ឪពុកម្ដាយត្រូវមានភារកិច្ចចិញ្ចឹមកូន បង្ហាត់បង្រៀនកូនឱ្យមានសុខភាពរឹងមាំ មានចំណេះដឹង និងឈ្លាសវៃទៀតផង។

### ៤.២-២- បុរីអាថែន

ក្រោយពីមានចម្បាំងជាមួយពែរ្សក្នុងសតវត្សទី៥ មុនគ.ស. អាថែន ក្លាយជាបុរីមួយខ្លាំងពូកែជាងគេក្នុងចំណោមបុរីទាំងឡាយរបស់ក្រិក។ អានុភាព និងកិត្តិសព្ទនៃបុរីអាថែន បានឡើងដល់កំពូលក្រោម ការដឹកនាំដោយរដ្ឋបុរស ប៉េរីក្លេស(Périclès)។

ក្នុងវិស័យនយោបាយគេបានអនុវត្តរបបប្រជាធិបតេយ្យ ដោយបែងចែកអំណាចរដ្ឋដាច់ពីគ្នាគឺៈ

អំណាចនីតិបញ្ញត្តិ ស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាអចិន្ត្រៃយ៍មួយដែលគេហៅថា ប៊ូលេ(Boulé) ដែលមានសមាជិក ៥០០នាក់ជ្រើសរើសចេញពីពលរដ្ឋអាថែនដែលមានអាយុចាប់ពី៣០ឆ្នាំ ជាបុរស។

អំណាចនីតិប្រតិបត្តិ ត្រូវបានប្រគល់ឱ្យមន្ត្រីជាន់ខ្ពស់ ១០រូបដែលទទួលអនុវត្តច្បាប់ទាំងឡាយ ដែលចេញដោយនីតិបញ្ញត្តិ។

អំណាចតុលាការ ទទួលភារៈឱ្យគេគោរពច្បាប់ព្រមទាំងជំនុំជម្រះអធិករណ៍ដែលកើតមានឡើងក្នុងសង្គមអាថែន។

មន្ត្រីជាន់ខ្ពស់នៃអង្គការទាំងបីខាងលើនេះ ត្រូវបានជ្រើសរើសក្នុងចំណោមឥស្សរជននៃវណ្ណៈអភិជន។ ក្នុងករណីនេះ គេបាននិយាយថា ការបែកអំណាចឱ្យដាក់ពីគ្នានៅក្នុងការគ្រប់គ្រងរដ្ឋ ជាប្រការមួយជឿនលឿននាសម័យនោះ។ នៅក្នុងរបបប្រជាធិបតេយ្យផ្ទាល់ ពលរដ្ឋសេរីគ្រប់រូបអាចចូលរួមសម្រេចកិច្ចការដោយផ្ទាល់ មិនតាមរយៈតំណាងឡើយ។

នៅក្នុងសង្គមអាថែន គេចែកមនុស្សជា ៤ថ្នាក់ ទៅតាមកំណើត ទៅតាមជីវភាព និងទៅតាមឋានៈក្នុងសមូហភាព។ ជាបឋម សង្គមត្រូវចែកជាពលរដ្ឋដែលសុទ្ធតែជាជនជាតិក្រិក និងទាសីទាសាដែលមិនមែនជាជនជាតិក្រិក ដែលខ្លះទៀតមានប្រភពពីឈ្លើយសឹក។ ពលរដ្ឋចែកជាបីវណ្ណៈ គឺវណ្ណៈអភិជន កសិករ និងសិប្បករ។ ចំណែកពួកទាសករមិនត្រូវបានរាប់បញ្ចូលជាពលរដ្ឋអាថែនទេ។ ក្នុងសម័យនោះ បុរីអាថែនមានឈ្មោះល្បីល្បាញខាងពាណិជ្ជកម្ម សិប្បកម្ម និងធនាគារ។

### ៤.៤-ការធ្លាក់ចុះដុនដាប់នៃក្រិកបុរាណ

កាលពីប្រមាណជា ២៣ន់ ៥រយឆ្នាំមុន ក្រិក ដែលមានការរួបរួមគ្នា អាចច្បាំងឈ្នះមហាអំណាចពិភពលោក គឺអាណាចក្រពែរស៍ រួចហើយក្រិកខ្លួនឯងក៏ស្គាល់នូវភាពរុងរឿង ជាប្រទេសមហាអំណាចដ៏សំខាន់មួយ នៅលើពិភពលោក។ ក៏ប៉ុន្តែ ភាពរុងរឿងរបស់ក្រិកបានឈានមកដល់ទីបញ្ចប់ នៅពេលដែលក្រិកបែកបាក់គ្នា ហើយគិតតែពីធ្វើសង្គ្រាមហែកហួរគ្នាឯង គឺនៅក្នុងសង្គ្រាម ដែលអ្នកប្រវត្តិសាស្ត្រដាក់ឈ្មោះថា « សង្គ្រាមប៉េឡូប៉ូនែស» (Peloponnèse)។

ក្រិកសម័យបុរាណ គឺជាបណ្តុំនៃបុរីតូចៗជាច្រើន ដែលមានរចនាសម្ពន្ធដឹកនាំឯករាជ្យដាច់ចេញពីគ្នាប្រៀបបាននឹងកូនរដ្ឋ ដែលគេឱ្យឈ្មោះថា «បុរីរដ្ឋ» (City-State/Cité-Etat)។ សង្គ្រាមប៉េឡូប៉ូនែស ដែលចាប់ផ្ទុះឡើង ពីឆ្នាំ៤៣១មុនគ.ស. ហើយអូសបន្លាយពេលរហូតដល់ឆ្នាំ៤០៤មុនគ.ស. គឺជាសង្គ្រាមរវាងបក្ស សម្ពន្ធពីរនៃបុរីរដ្ឋក្រិកៈ បក្សសម្ពន្ធម្ខាងដឹកនាំដោយអាថែន (Athènes) និងបក្សសម្ពន្ធម្ខាងទៀតដឹកនាំដោយស្ប៉ាត (Sparte)។

នៅទីបញ្ចប់ គឺខាងបក្សសម្ពន្ធរបស់ស្ប៉ាត ដែលជាអ្នកទទួលជ័យជម្នះ ក៏ប៉ុន្តែ សង្គ្រាម៣០ឆ្នាំនេះបានធ្វើឱ្យក្រិកទាំងមូលត្រូវធ្លាក់ចុះទន់ខ្សោយ។ អាថែន ដែលចាញ់សង្គ្រាម ត្រូវវិនាសហិនហោច ហើយរបបប្រជាធិបតេយ្យត្រូវដួលរលំ។ ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា បក្សសម្ពន្ធរបស់ស្ប៉ាត ដែលជាអ្នកឈ្នះសង្គ្រាមក៏បានជួបប្រទះនឹងភាពក្រីក្រនៅស្ទើរតែគ្រប់ទីកន្លែងដែរ។ សង្គ្រាមប៉េឡូប៉ូនែសបានធ្វើឱ្យភាពរុងរឿងនៃមហាអំណាចក្រិកត្រូវ បញ្ចប់ជាស្ថាពរ ហើយមិនយូរប៉ុន្មាន អតីតមហាអំណាចមួយនេះក៏ត្រូវធ្លាក់ក្រោមការត្រួតត្រារបស់មហាអំណាច ថ្មីមួយទៀត គឺអាណាចក្រម៉ាសេដ្វាន (Macédoine) ដឹកនាំដោយអធិរាជដ៏ល្បីល្បាញមួយរូប គឺ Alexandre le Grand (តាមភាសាអង់គ្លេស Alexander the Great)។

ម៉ាសេដ្វាន តាមពិតទៅ ក៏ជានគរមួយ ដែលទទួលឥទ្ធិពលពីវប្បធម៌ក្រិកដែរ ហើយបច្ចុប្បន្ននេះម៉ាសេដ្វាន គឺជាតំបន់ស្វ័យ័តមួយរបស់ក្រិក។ Alexandre ដែលជាអធិរាជដ៏ល្បីល្បាញរបស់ម៉ា-សេដ្វាន គឺជាកូនសិស្សរបស់អារីស្តូត ដែលជាទស្សនវិទូក្រិក។ Alexandre le Grand ដែលមានវ័យត្រឹមតែ២០ឆ្នាំ បាន

ឡើងគ្រងរាជជាស្តេចរបស់ម៉ាសេដ្វាន ក្រោយពីស្តេចហ្វីលីព ដែលជាបិតា ត្រូវគេលបធ្វើឃាត នៅឆ្នាំ៣៣៦ មុនគ.ស.។ Alexandre គឺជាបញ្ញវន្តមួយរូបដែលពូកែខាងកំណាព្យ និងទស្សនវិជ្ជា ហើយក៏ជាអ្នកជំនាញខាងទ័ពសេះផងដែរ។ នៅពេលឡើងគ្រងរាជភ្លាម បញ្ហាដែល Alexandre le Grand ត្រូវប្រឈមមុខមុនគេ គឺការរកវិធីបញ្ចប់វិវាទផ្ទៃក្នុង ដើម្បីបង្រួបបង្រួមបុរីរដ្ឋក្រិកឡើងវិញ ហើយវិធីដ៏ល្អបំផុតក្នុងការបង្រួបបង្រួម គូប្រជែងអស់ទាំងនេះ គឺស្វែងរកសត្រូវរួមមួយ។ Alexandre le Grand ក៏គិតឃើញគំនិតមួយ គឺ ប្រមែប្រមូលទ័ពម៉ាសេដ្វាន រួមជាមួយនឹងទ័ពក្រិកទាំងអស់ ប្រកាសសង្គ្រាមទល់នឹងអាណាចក្រពែរ្ស ដើម្បីជាការសងសឹកចំពោះអំពើឈ្លានពានរបស់ពែរ្ស ទៅលើក្រិក កាលពីមុន។

ដោយសារតែអាណាចក្រពែរស៍គឺជាសត្រូវចាស់របស់ក្រិក ហើយម៉ាសេដ្វាន គឺជាផ្នែកមួយនៃវប្បធម៌ក្រិក កងទ័ពក្រិកបានប្រមូលគ្នា ចេញទៅតាម Alexandre le Grand ក្នុងការធ្វើសង្គ្រាមទល់នឹងអាណាចក្រពែរស៍ ដោយគេចាត់ទុកថានេះគឺជាសង្គ្រាម រវាងក្រិក និងពែក្ស។ ចេញពីក្រិក កងទ័ពរបស់ Alexandre le Grand បានវាយបំបាក់កងទ័ពរបស់អាណាចក្រពែរស៍ នៅតួកគី ហើយបន្ទាប់មក វាយចុះទៅទិសខាងត្បូង ចូលកាន់កាប់លីបង់ ស៊ីរី អ៊ីស្រាអែល អេហ្ស៊ីប បាប៊ីឡូន (អ៊ីរ៉ាក់) និងចុងក្រោយ ទឹកដីពែរស៍ផ្ទាល់ (អ៊ីរ៉ង់)។ នៅឆ្នាំ៣៣១មុនគ.ស. កងទ័ពពែរស៍ ដែលនៅសេសសល់ចុងក្រោយ ត្រូវបានកងទ័ព Alexandre le Grand វាយកម្ទេច អាណាចក្រពែរស៍ត្រូវដួលរលំ ហើយ Alexandre le Grand ក៏ប្រកាសខ្លួនថាជាអធិរាជរបស់ពិភពលោក។

អាណាចក្រម៉ាសេដ្វាន ដែលដឹកនាំដោយ Alexandre le Grand ដែលត្រូវបានគេចាត់ទុកថាអធិរាជរបស់ក្រិកដែរនោះ បានជំនួសអាណាចក្រពែរស៍ ក្នុងឋានៈជាមហាអំណាចពិភពលោក គ្រប់គ្រងដែនដី ដែលលាតសន្ធឹងចាប់តាំងពីតំបន់មេឌីទែរ៉ាណេ កាត់តាមដើមបូព៌ា រហូតដល់អាស៊ី។ ក៏ប៉ុន្តែ Alexandre le Grand មិនស្កប់ចិត្តតែត្រឹមនោះទេ ដោយបានបែកគំនិតមានមហិច្ឆតាថ្មីមួយទៀត គឺចង់វាតទីគ្រប់គ្រងពិភពលោកទាំងមូល។

Alexandre le Grand បានលើកទ័ពចេញពីពែរស៍វាយលុកឆ្ពោះទៅទិសខាងកើត រហូតដល់ឥណ្ឌា។ ក៏ប៉ុន្តែ ទៅដល់កន្លែងមួយ ក្បែរក្រុងញូវដេលីបច្ចុប្បន្ន Alexandre le Grand ត្រូវគាំងដំណើរ ទៅមុខទៀតលែងបាន ដោយសារតែកងទ័ពនាំគ្នាធ្វើកូដកម្មលែងប្រយុទ្ធ។ ទាហានក្រិកចាប់ផ្តើមធុញទ្រាន់នឹងសង្គ្រាមម្យ៉ាង គឺដោយសារតែពួកគេបានចាកចេញឆ្ងាយពីស្រុកកំណើតអស់រយៈពេល ៩ឆ្នាំមកហើយ។ ម្យ៉ាងទៀត អាណាចក្រពែរស៍ ដែលជាគូសត្រូវរបស់ក្រិក និងដែលជាគោលដៅចម្បងនៃការធ្វើសង្គ្រាមនេះ ក៏ត្រូវបានពួកគេវាយកម្ទេចរួចហើយដែរ។ ដូច្នេះ សម្រាប់ពួកក្រិក វាគ្មានន័យអ្វី ដែលត្រូវធ្វើសង្គ្រាមវាតទីតទៅមុខទៀតនោះទេ។ នៅពេលដែលកងទ័ពឈប់ស្តាប់បញ្ជា លែងចង់ធ្វើដំណើរតទៅមុខទៀត Alexandre le Grand បានត្រឹមតែខឹងសម្បារ តែធ្វើអ្វីមិនកើត ក៏សុខចិត្តស្តាប់តាមការទាមទាររបស់កងទ័ពខ្លួន។ ពីសាច់រឿងនេះ គេអាចទាញបានមេរៀនដ៏សំខាន់មួយថា គ្រប់អំណាចទាំងអស់ មានមូលដ្ឋានគ្រឹះ នៅលើការព្រមព្រៀងស្តាប់បង្គាប់របស់រាស្ត្រ មិនថា ក្នុងរបបផ្តាច់ការ ឬរបបប្រជាធិបតេយ្យនោះទេ។ នៅពេលដែលរាស្ត្រលែងស្តាប់បង្គាប់ទោះបីជាអំណាចផ្តាច់ការ ឬអំណាចយោធា ក៏ត្រូវតែដួលរលំដែរ។

ដោយគ្មានជម្រើស Alexandre le Grand ក៏បានដកកងទ័ពចេញពីឥណ្ឌា ហើយធ្វើដំណើរត្រឡប់ក្រោយវិញ ទៅដល់បាប៊ីឡូន ទីដែលព្រះអង្គចង់តាំងរាជធានី សម្រាប់អាណាចក្ររបស់ព្រះអង្គ គឺរាជធានីរបស់ពិភពលោក។ ក៏ប៉ុន្តែ នៅឆ្នាំ៣២៣មុនគ.ស. ក្រោយពីគ្រងរាជ្យបានតែ ១៣ឆ្នាំ Alexandre le Grand

បានចូលទិវង្គត ក្នុងវ័យ ៣២ឆ្នាំ។ មូលហេតុនៃការស្លាប់នេះ ត្រូវបានគេយល់ឃើញផ្សេងៗពីគ្នា ខ្លះថាមកពីការផឹកស្រាច្រើនហួសហេតុ ឬក៏ដោយសារតែមានគេដាក់ថ្នាំបំពុលក្នុងស្រា ហើយខ្លះទៀតថា មកពីជំងឺគ្រុនចាញ់ ឬជំងឺគ្រុនពោះវៀន។ សាកសពរបស់ Alexandre le Grand ត្រូវបានគេដង្ហែយកទៅបញ្ចុះ នៅអេហ្ស៊ីប ក្នុងទីក្រុងមួយដែលយកឈ្មោះតាម Alexandre le Grand គឺទីក្រុងអាឡិចសង់ឌ្រី (Alexandrie)។ ជាង ១០ឆ្នាំ ក្រោមការដឹកនាំរបស់ Alexandre le Grand ម៉ាសេដ្វាន និងក្រិក បានស្គាល់នូវភាពរុងរឿង ក្នុងឋានៈជាមហាអំណាចពិភពលោក ដែលគ្រប់គ្រងផ្ទៃដីលាតសន្ធឹងជាង ៥លានគីឡូម៉ែត្រក្រឡា ហើយវប្បធម៌ និងអរិយធម៌ក្រិកបានជះឥទ្ធិពលទៅគ្រប់ទីកន្លែង ចាប់តាំងពីអឺរ៉ុប និងមេឌីទែរ៉ាណេ រហូតដល់ឥណ្ឌា។ មានតែចិនមួយប៉ុណ្ណោះ ដែលមិនទទួលឥទ្ធិពលពីក្រិក។ ក៏ប៉ុន្តែ នៅក្រោយពេលដែល Alexandre le Grand ចូលទិវង្គត ដោយសារតែការឈ្លោះដណ្តើមរាជបល្ល័ង្ក រវាងមេទ័ពកំពូលៗ អាណាចក្រម៉ាសេដ្វាន ក៏ត្រូវបាក់បែកគ្នា ហើយនៅឆ្នាំ២៨១មុនគ.ស. ក្រោយពីមានសង្គ្រាមដណ្តើមរាជបល្ល័ង្កអស់រយៈពេល៤០ឆ្នាំ អាណាចក្ររបស់ Alexandre le Grand ក៏ត្រូវពុះជាបួនចំណែក បង្កើតទៅជាអាណាចក្របួនផ្សេងគ្នា នៅអេហ្ស៊ីប នៅបាប៊ីឡូន នៅក្រិក និងនៅម៉ាសេដ្វាន[443]។

### ៤.៤-អរិយធម៌ក្រិក

ជនជាតិក្រិកមានអរិយធម៌លូតលាស់ ខ្ពង់ខ្ពស់ ហើយបានផ្សាយអរិយធម៌របស់ខ្លួនលើពិភពលោក។

ដោយហេតុអាកាសធាតុក្តៅ ជនជាតិក្រិកមិនសូវបារម្ភ និងបញ្ហាស្លៀកពាក់ឡើយ។ គេចែកការងារទៅតាមអាយុ ទៅតាមភេទ បានត្រូវអនុវត្តតាំងពីដើមរៀងមក។ ស្ត្រីមេផ្ទះមានភារកិច្ចរៀបចំម្ហូបអាហារ កិច្ចការតម្បាញ ចិញ្ចឹមអប់រំកូន។ បុរសជាអ្នកទទួលកិច្ចការធ្ងន់ៗដូចជាបរបាញ់ ចិញ្ចឹមសត្វ និងរបរកសិកម្ម ព្រមទាំងធ្វើពាណិជ្ជកម្មតាមសមុទ្ទ ពិសេសជុំវិញសមុទ្ទមេឌីទែរ៉ានេ។

ជនជាតិក្រិកជាអ្នកជឿសាសនាដ៏មោះមុត ហើយគោរពពហុទេពនិយម ហើយទេវៈនីមួយៗមានឋានៈ និងមុខងារខុសៗគ្នា។ ទេវៈសំខាន់មានបីអង្គគឺ៖

- ស៊ីស(Zeus) ជាទេវៈសោយរាជ្យលើមហាមេឃ ហើយត្រួតត្រាលើទេវៈទាំងអស់ ។
- ប៉ូសេអ៊ីដុង(Poséidon) ជាទេវៈសោយរាជ្យលើមហាសាគរទាំងមូល។
- ហាដែស(Hadès) ជាទេវខាងតុលាការ សោយរាជ្យនៅឋាននរក។

ទេវៈខ្លះមានរូបរាងជាសត្វ ខ្លះមានក្បាលជាមនុស្សខ្លួនជាសត្វ ហើយមានភាពអមតៈ រស់នៅក្នុងទេវដ្ឋាន ពិសេសលើកំពូលភ្នំអូឡាំ និងនៅក្រុងដែលហ្វ៍(Delphe)។

ប្រទេសក្រិកមានកវី និងអ្នកប្រាជ្ញជំនាញល្បីៗជាច្រើន៖

- ផ្នែកសោកនាកម្ម៖ កវីជំនាញមានលោកអេស៊ីល(Eschyle) លោកសូផូក(Sophocle) និង អឺរីពីត (Euripide)
- រឿងកំប្លែង៖ មានលោក អារីស្តូផាន (Aristophane)។
- ផ្នែកទស្សនវិជ្ជា៖ មាន សូក្រាត(Socrate) ប្លាតុង(Platon) អារីស្តូត(Aristote)
- ប្រវត្តិវិទ្យា៖ មានលោក អេរេដូត(Hérédote) និង ធុយស៊ីឌីត(Thucydide)

[443] សេង ឌីណា (២០១៣) *ប្រវត្តិសាស្ត្រពិភពលោក* : ការចេញផ្សាយរបស់វិទ្យុបារាំងអន្តរជាតិ RFI ថ្ងៃ21 កក្កដា ២០១៣

- គណិតវិទ្យា និងតារាវិទ្យា៖ មានលោក អឺគ្លីត(Euclide) លោកពីតាករ(Pythagore) លោក តាឡេស (Thalés) និងលោក អ៊ីប៉ូក្រាត(Hepocrate)។

ស្ថាបត្យករល្បីជាងគេគឺ ភីដ្យាស(Phidias) ដែលបានស្ថាបនាវិហារ អាក្រូប៉ូល(Acropole) ក្នុងទីក្រុងអាថែន និងវិហារប៉ាតេណុង(Parthénon)។ វិហារទាំងពីរនេះគេចាត់ទុកជាស្នាដៃស្ថាបត្យកម្មមួយដែលឈានដល់ភាពកំពូលក្នុងវិស័យសិល្បៈនាសតវត្សទី៥ មុនគ.ស.។

ជនជាតិក្រិកនិយមកីឡាគ្រប់ៗគ្នា ពោលគឺគេស្រឡាញ់ ហើយថែរក្សារូបរាងកាយរបស់ពួកគេណាស់។ ក្រៅពីល្បែងកីឡា ជនជាតិនេះបានរៀបចំឱ្យមានមហាព្យុហយាត្រាកីឡា ដើម្បីជាកិត្តិយសដល់ទេវផ្សេងៗ មានមហាព្យុហយាត្រាល្បែងកីឡាអ៊ីស្មិក ជាកិត្តិយសដល់ទេវប៉ូសេអ៊ីដុង កីឡាអូឡាំពិកជាកិត្តិយសដល់ទេវៈ សឺស។ កីឡាអូឡាំពិករៀបចំឡើង ៤ឆ្នាំម្តង ហើយក្នុងឱកាសមហាព្យុហយាត្រានេះ គេផ្អាកសង្គ្រាមមួយរយៈពេល។ គេអនុញ្ញាតឱ្យតែជនជាតិក្រិកប៉ុណ្ណោះដែលចូលរួមការប្រកួតកីឡានេះ។ អ្នកប្រកួតឈ្នះបានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់ក្រៃលែង ពីព្រោះជ័យជម្នះផ្តល់កិត្តិយសទៅឱ្យបុរីរបស់គេទាំងមូល។

## ៥.អរិយធម៌រ៉ូម

### ៥.១-ស្ថានភាពប្រវត្តិសាស្ត្រ

តាមរឿងនិទានបានឱ្យដឹងថា ទីក្រុងរ៉ូមបានបង្កើតឡើងតាំងពីឆ្នាំ៧៥៣ មុនគ.ស. ដោយស្នាព្រះហស្តព្រះបាទរ៉េមុស(Rémus) និងរ៉ូមុយលុស(Romulus) ដែលជាប់សាច់ឈាមជាមួយក្សត្រនៃទីក្រុងត្រ័រ(Troie) ព្រះនាមអេនេ(Enée)។ តែប្រវត្តិវិទូបានបញ្ជាក់ថារ៉ូមគ្រាន់តែជាភូមិតូចមួយ ដែលពួកអេទ្រុស(Étrusque) នៅភាគខាងជើងប្រទេសអ៊ីតាលី បានមកវាយលុកត្រួតត្រានៅឆ្នាំ៦០០មុនគ.ស.។ ក្រោយមករ៉ូមបានរំដោះរួចខ្លួនពីការត្រួតត្រារបស់ពួកអេទ្រុស រួចប្រកាសជាសាធារណរដ្ឋនៅឆ្នាំ៥០៩ មុនគ. ស.។

### ៥.២-ព្រឹត្តិការណ៍នយោបាយ

#### ៥.២-១-សម័យសាធារណរដ្ឋ (៥០៩-៣១ មុនគ. ស.)

ក-ការវាយត្រួតត្រាដែនដីអ៊ីតាលី (៥០៩-២៧០ មុនគ. ស.)

ចាប់ពីឆ្នាំ៣៩០ មុនគ.ស. ពួករ៉ូមវាយបានជាបន្តបន្ទាប់នូវតំបន់ឡាស្យូម កំប៉ានី និងអេទ្រុយរី ព្រមទាំងដែនដីនិគមកម្មរបស់ក្រិកនៅខាងត្បូងអ៊ីតាលី។ លុះដល់ឆ្នាំ២៧០ មុនគ.ស. ទើបពួករ៉ូមបានត្រួតត្រាលើអ៊ីតាលីទាំងមូល។ ក្នុងពេលជាមួយគ្នានោះ រាស្ត្រតូចតាចកំពុងប្រយុទ្ធដណ្តើមសិទ្ធិអំណាចពីពួកវណ្ណៈ អភិជនដែរ។

ខ-ការវាយយកដែនដីនៅជុំវិញសមុទ្រមេឌីទែរ៉ានេ (ស.វ.ទី៣ ដល់ស.វ.ទី១ មុនគ.ស.)

ក្នុងរវាងជាង ២០០ឆ្នាំប៉ុណ្ណោះ រ៉ូមវាយយកបានហើយត្រួតត្រាសមុទ្រមេឌីទែរ៉ានេទាំងមូល។ ដែនដីទាំងនេះ នៅជុំវិញ មានក្រុងកាតាស ប្រទេសក្រិក ប្រទេសហ្គោល និងប្រទេសអេស្ប៉ាញជាដើម។ នយោបាយចក្រពត្តិនិយមបែបនេះបានបំបាត់វណ្ណៈកណ្តាល ដោយប្រមូលទ្រព្យសម្បត្តិឱ្យតែពួកព្រឹទ្ធសភា ឈ្មួញធំៗ និងពួកមេទ័ព។ ចំណែកប្រជាកសិករកាន់តែក្រីក្រទៅ ហើយចំនួនទាសីទាសាកាន់តែច្រើនឡើង។

គ-សង្គ្រាមផ្ទៃក្នុងនិងការវិនាសរបបសាធារណរដ្ឋ

ក្រោយពេលចក្រភពរ៉ូមត្រួតត្រាដែនដីទាំងឡាយជុំវិញសមុទ្រមេឌីទែរ៉ានេទាំងមូលហើយ គ្មានសត្រូវណាពីខាងក្រៅ ដែលហ៊ានងើបឡើងប្រឈមមុខជាមួយនឹងរ៉ូមនោះទេ ក៏ប៉ុន្តែ រ៉ូមត្រូវប្រឈមមុខនឹងវិបត្តិមួយផ្សេងទៀត គឺជម្លោះផ្ទៃក្នុង។

កសិករតូចតាចទាមទារកម្មសិទ្ធិលើដីស្រែចម្ការ តែមិនបានសម្រេច។ ការធ្វើអន្តរាគមរបស់ឧត្តមសេនីយ ពីឆ្នាំ១៣២ដល់ឆ្នាំ១២២មុនគ.ស. ដើម្បីប៉ុនប៉ងដណ្តើមកម្មសិទ្ធិដីធ្លី យកទៅឱ្យកសិករតូចតាចត្រូវទទួលបរាជ័យ។ បន្ទាប់មក ពួកមេទ័ពបានច្បាំងគ្នាឯង ដើម្បីយកអំណាចត្រួតត្រា។ នៅទីបំផុត មេទ័ពអុកតាវ (Octave) បានទទួលជ័យជម្នះនៅឆ្នាំ៣១ មុនគ.ស. ហើយបានប្រកាសខ្លួនជាអធិរាជដោយយកព្រះនាមថា អូហ្គុស (Augustus)។

### ៥.២.២-សម័យចក្រភពរុងរឿង (៣១មុនគ.ស.ដល់១៩២ នៃ គ. ស.)

អធិរាជអូហ្គុស បានស្តារប្រទេសជាតិឡើងវិញ ឱ្យចេញពីភាពប្រេះឆា នៃវិវាទផ្ទៃក្នុង ដែលបានអូសបន្លាយពេលអស់រយៈពេលប្រមាណជា ១សតវត្សកន្លងទៅ ហើយដឹកនាំចក្រភពរ៉ូម ឆ្ពោះទៅរកសុខសន្តិភាព និងវិបុលភាព និងកំណែទម្រង់សង្គមជាច្រើន។

វិស័យយោធា រ៉ូមបានបង្កើតនូវរចនាសម្ពន្ធកងទ័ពថ្មីមួយ គឺកងទ័ពអាជីព។ នៅក្នុងអំឡុងសតវត្សទី១ ដល់ ទី២ នៃគ.ស.ចក្រភពរ៉ូមមានវិសាលភាពលាតសន្ធឹងដល់កម្រិតអតិបរមា។ នៅពេលនោះ ចក្រភពរ៉ូមមានផ្ទៃដីសរុបរហូតដល់ទៅ ៥លានគីឡូម៉ែត្រក្រឡា ដែលគ្របដណ្តប់លើទ្វីបអឺរ៉ុប អាហ្វ្រិកខាងជើង និងតំបន់មជ្ឈិមបូព៌ា។

នាសតវត្សទី២នៃគ.ស. ក្រោមការគ្រប់គ្រងនៃរាជវង្សអង់តូណាំង(Antonin) រ៉ូមបានស្គាល់ភាពរុងរឿងត្រចះត្រចង់ជាងគេ។ រាជវង្សនេះបានជួយសង្គ្រោះជនទុរគត ក្មេងក្រីក្រជាដើម ឯតុលាការវិញបានរៀបចំឱ្យមានយុត្តិធម៌ប្រសើរជាងមុន។

### ៥.២-៣-សម័យចក្រភពចុះខ្សោយ (ពីឆ្នាំ១៩២ ទៅឆ្នាំ៤៧៦គ.ស.)

ចាប់ពីឆ្នាំ១៩២ មេទ័ពទាំងឡាយចេះតែច្បាំងដណ្តើមអំណាចគ្នាឥតឈប់ឈរ ធ្វើឱ្យចក្រភពរ៉ូមធ្លាក់ចុះដុនដាបជាលំដាប់។ ចំពោះមុខសភាពការណ៍បែបនេះ ព្រះបាទដ្យូក្លេជាង(Dioclétien) បានបង្កើតរបបគ្រប់គ្រងមួយហៅថា តេត្រាស៊ី(Tétrarchie)។

ក្នុងសម័យដុនដាបនេះ គ្រិស្តសាសនាត្រូវបានព្រះបាទកុងស្តង់តាំង(Constantin) បើកសេរីភាពធំទូលាយដល់អ្នកកាន់គ្រិស្តសាសនា។ នៅឆ្នាំ៣៩៤ ព្រះបាទតេអូដូស(Théodose) ធ្វើឱ្យសាសនាគ្រិស្តទទួលជោគជ័យបានពេញលេញ។ បន្ទាប់មកក្នុងឆ្នាំ៣៩៥ ព្រះបាទតេអូដូស បានបែងចែកចក្រភពរ៉ូមជាពីរគឺ ចក្រភពរ៉ូមខាងលិច និងចក្រភពរ៉ូមខាងកើត។

ចាប់ពីឆ្នាំ៣៩៥ ដោយសារការបាក់បែកសាមគ្គីផ្ទៃក្នុង បានធ្វើឱ្យចក្រភពរ៉ូមធ្លាក់ចុះទន់ខ្សោយ ផ្តល់ឱកាសឱ្យពួកអនារ្យជន វាយលុករាតត្បាត ជាហេតុធ្វើឱ្យចក្រភពរ៉ូមខាងលិចដួលរលំនៅឆ្នាំ៤៧៦។ ចក្រភពរ៉ូមខាងកើតមានជំហររឹងមាំរហូតឆ្នាំ១៤៥៣។

## ៥.៣-អរិយធម៌រ៉ូម

### ៥.៣.១-សង្គម

ស្ថានភាពសង្គមមនុស្សនៅក្រុងរ៉ូមនៅពុំមានផ្លាស់ប្តូរអ្វីឡើយ។ ផ្ទុយទៅវិញ នៅតាមអាណាខេត្តសង្គមតែងវិវត្តនិងកែប្រែជានិច្ច។

- **ក្រុងរ៉ូម** ដែលបានលូតលាស់ពីសតវត្សទី៨ មុនគ.ស. មកដល់សវត្សទី៣ មុនគ.ស. ជាក្រុងធំមហិមាក្នុងសម័យបុរាណកាល។ ភាពខុសគ្នានារវាងអ្នកមាន និងអ្នកក្រដែលមានតាំងពីសម័យនៃរបបសាធារណរដ្ឋមកនោះកាន់តែមានគម្លាតខ្លាំងឡើងៗ។ យ៉ាងណាមិញ ពួកអ្នកក្ររស់នៅប្រជ្រៀតគ្នាយ៉ាងត្រដាបត្រដួស

តាមផ្ទះច្រើនជាន់ តាមសង្កាត់តូចតាចយ៉ាងស្មោកគ្រោក។ ពួកអ្នកមានរស់នៅលើភ្នំទាបៗជិតផ្សារក្នុង គេហដ្ឋានស្អាតបានលម្អដោយគ្រឿងសង្ហារិមយ៉ាងប្រណីត និងតាមសួនច្បារធំៗព័ទ្ធជុំវិញ។ គេមានទាសា ទាសីបម្រើរាប់រយនាក់។ ចំណែកព្រះចៅអធិរាជគង់នៅរាជវាំងស្ថិតនៅលើភ្នំ។ ព្រះអង្គបានស្ថាបនាហ្វូរ៉ំ (Forum) ជាមជ្ឈមណ្ឌលនយោបាយ និងពាណិជ្ជកម្ម ដែលមានប្រាសាទ និងបដិមាលម្អព្រោងព្រាត។

មន្ត្រីធំៗ និងពួកអ្នកមាន មានផ្ទះសម្រាប់លំហែកំសាន្តនៅជនបទថែមទៀតផង។ ពួកគេជាសមាជិក ព្រឹទ្ធសភា និងសីវ៉ាល្បេ(Chevalier) ទទួលឋានៈខ្ពង់ខ្ពស់ទៅតាមគុណបំណាច់ដែលគេបានផ្តល់ចំពោះរដ្ឋ និងព្រះចៅអធិរាជ។ ពួកគេខ្លះចំណាយពេលជាច្រើនក្នុងការតែងខ្លួន ឬទៅលេងកន្លែងមុជទឹកសាធារណៈ។ អ្នកមានខ្លះទទួលទានអាហារពេលល្ងាច ចាប់ពីពេលរសៀលរហូតដល់យប់ ហើយបញ្ចប់ដោយការស៊ីផឹក ហួសប្រមាណ។

ចំណែកអ្នកក្រមានជីវិតរស់នៅដោយសារតែការប្រទានពីព្រះចៅអធិរាជនិងឥស្សរជនធំៗ។ ចំនួន អ្នកក្រកើនដល់២០ម៉ឺននាក់នៅសតវត្សទី២។ ដោយក្តីបារម្ភខ្លាចពួកអ្នកក្រទាំងនោះអផ្សុកហើយនាំគ្នាបះបោរ ព្រះចៅអធិរាជប្រទានការកំសាន្តសប្បាយជាញឹកញាប់ មានល្ខោន ការប្រណាំងទេះសេះ ការប្រយុទ្ធជាមួយ សត្វសាហាវ ការប្រយុទ្ធជាមួយពួកក្លាដ្យាទ័រ (Gladiateurs) ជាដើម។ វណ្ណៈទាសករ ជាវណ្ណៈទាបបំផុតនៅ ក្នុងសង្គមរ៉ូម ដែលមានកាតព្វកិច្ចដូចមុនដដែល។ ពួកនេះមានជីវភាពធូរស្រាលបន្តិចម្តងៗ ដោយសេចក្តី មេត្តាករុណារបស់ព្រះចៅអធិរាជ។ នៅរ៉ូមគេមិនអាចចេញពីវណ្ណៈទាសករទៅវណ្ណៈថ្នាក់លើបានទេ។

• **នៅតាមអាណាខេត្ត** គេអាចផ្លាស់ប្តូរពីវណ្ណៈមួយទៅវណ្ណៈមួយទៀត បានព្រោះមន្ត្រីធំៗដែលកាន់ អំណាចនៅក្រុងរ៉ូម ភាគច្រើនចេញពីវណ្ណៈខ្ពស់ជាងគេនៅតាមខេត្ត ដូចជាសមាជិកព្រឹទ្ធសភាខ្លះ និងព្រះចៅ អធិរាជជាច្រើននៅសតវត្សទី២ ជាដើម។ អ្នកគ្រប់គ្រងខេត្ត សុទ្ធតែជាអ្នកចេះដឹងច្រើនមកពីវណ្ណៈគហបតី ក្រុង។

### ៥.៣.២-សេដ្ឋកិច្ច

នៅសតវត្សទី១ និងទី២ នៃគ.ស. ក្រុងរ៉ូមមានសន្តិភាព ជាហេតុធ្វើឱ្យសេដ្ឋកិច្ចចក្រភពរ៉ូមមានការរីក ចម្រើនគ្រប់វិស័យ។ ផលិតផលកសិកម្ម និងសិប្បកម្មលូតលាស់ខ្លាំង។ ជំនួញក្នុងស្រុករវាងភូមិភាគផ្សេងៗ បានបង្កើតសកម្មភាពរបស់ខ្លួនកាន់តែខ្លាំង។ ឯពាណិជ្ជកម្មក្រៅស្រុក ចក្រភពរ៉ូមបានធ្វើទាក់ទំនងជាមួយ បណ្តាប្រទេសនៅទ្វីបអាស៊ីមានប្រទេសចិនជាដើម។

នៅសម័យរុងរឿង ចក្រភពរ៉ូម បានកកើតទីក្រុងជាច្រើន។ ទីក្រុងទាំងនោះមានទម្រង់ដូចគ្នានឹង ទីក្រុងរ៉ូម គឺមានមជ្ឈមណ្ឌលមួយ ដែលមានមុខងារដូចជា ផ្សារសម្រាប់ធ្វើទំនាក់ទំនងពាណិជ្ជកម្ម ជា មជ្ឈមណ្ឌលនយោបាយ និងជាកន្លែងកម្សាន្ត។ ក្រុងនីមួយៗបានប្រណាំងប្រជែងគ្នាក្នុងការកសាងប្រាសាទ។

ក្រុងរ៉ូមជាក្រុងធំជាងគេបង្អស់ និងជាមជ្ឈមណ្ឌលពាណិជ្ជកម្មមានទំនិញគ្រប់មុខ នាំមកពីគ្រប់ទិសទី តាមកំពង់ផែ អូស្ទី។ ក្រុងរ៉ូមពុំសូវមានទំនិញនាំចេញទេ តែនាំចូលពីបរទេសមានច្រើនដូចជាស្បៀងអាហារ វត្ថុធាតុដើម និងឧបករណ៍ប្រើប្រាស់សព្វសារពើ។

### ៥.៣.៣-អក្សរសាស្ត្រនិងសិល្បៈ

រជ្ជកាលព្រះបាទអូហ្គុស ជាសម័យត្រចះត្រចង់បំផុតនៃអក្សរសាស្ត្រឡាតាំង។ សម័យនេះ សម្បូរ អ្នក ប្រាជ្ញល្បីៗ ខាងប្រវត្តិសាស្ត្រ និងអក្សរសាស្ត្រ ដូចជាប្រវត្តិវិទូទីតលីវ (Tite Live ) កវីវៀស៊ីល(Virgile)ជា ដើម។ ក្រោយរជ្ជកាលព្រះបាទអូហ្គុស ស្នាដៃកំណាព្យ និងសិល្បៈនិទានមានការថយចុះ ប៉ុន្តែប្រវត្តិវិទ្យា និងទស្សន

វិជ្ជាមានការលូតលាស់ខ្លាំង ដូចជា ប្រវត្តិវិទូតាស៊ីត(Tacite) ជាអ្នកបាននិទានប្រវត្តិរឿងនៃអធិរាជ ជាច្រើន និងសេណែក(Sénèque) ជាទស្សនវិទូសំខាន់មួយរូបដែលទទួលភារៈអប់រំអនាគតអធិរាជនេរ៉ុង(Néron)។ ស្ថាបត្យកម្មរបស់រ៉ូមច្រើនសង់ទៅតាមលំនាំពួកក្រិក ប៉ុន្តែគេចេះប្រើស៊ីម៉ងត៍និងបច្ចេកទេសក្បាច់រូតទៀតផង។

**សំណួរត្រិះរិះ**

១-តើអរិយធម៌ចំណាស់ៗលើពិភពលោកមានកំណើតនៅតំបន់ណាខ្លះ? ហេតុអ្វី?

២-តើអេហ្ស៊ីបានសន្សល់ទុកអ្វីខ្លះសម្រាប់មនុស្សជាតិបច្ចុប្បន្ន?

៣-តើរដ្ឋបុរាណនៅតំបន់មេសូប៉ូតាមីមានអ្វីខ្លះ? តើមេសូប៉ូតាមីបានបន្សល់ទុកអ្វីខ្លះសម្រាប់ពិភពលោកបច្ចុប្បន្ន?

៤-តើក្រិកបុរាណចុះទន់ខ្សោយដោយសារមូលហេតុអ្វីខ្លះ?

៥-តើប្រទេសក្រិកបានបន្សល់ទុកអ្វីខ្លះសម្រាប់ពិភពលោកបច្ចុប្បន្ន?

៦-តើមូលហេតុអ្វីខ្លះដែលនាំឱ្យចក្រភពរ៉ូមមានការរីកចម្រើនខ្លាំង?

៧-ចូរពន្យល់ពីមូលហេតុនៃការចុះទន់ខ្សោយនៃចក្រភពរ៉ូម។

៨-តើអ្នកដកស្រង់អ្វីខ្លះពីអរិយធម៌ពិភពលោកបុរាណ ដើម្បីអភិវឌ្ឍប្រទេសអ្នកឱ្យរីកចម្រើន?

# មេរៀនទី២ ទ្វីបអឺរ៉ុបក្នុងមជ្ឈិមសម័យ និងនវសម័យ

## ១-មជ្ឈិមសម័យនៅអឺរ៉ុប

មជ្ឈិមសម័យនៅអឺរ៉ុប ជាសម័យកាលមួយមានរយៈពេលប្រហែល១០០០ឆ្នាំ ដែលផ្ដើមឡើងនៅ សតវត្សទី៥ គឺចាប់ពីការដួលរលំនៃចក្រភពរ៉ូមខាងលិច រហូតដល់ការដួលរលំចក្រភពរ៉ូមខាងកើតឆ្នាំ១៤៥៣ ឬការរកឃើញដែនដីថ្មីគឺទ្វីបអាម៉េរិកនៅឆ្នាំ១៤៩២។

### ១.១-កំណើតនៃរបបសក្តិភូមិ

#### ក-អស្ថិរភាព និងការកកើតនៃរបបសក្តិភូមិ

ការដួលរលំចក្រភពរ៉ូមខាងលិចបណ្ដាលឱ្យមានអស្ថិរភាពដូចជា អំពើឃោរឃៅ ភាពអនាធិបតេយ្យ និងការប្រើអំណាចផ្ដាច់ការជាដើម។ ចំពោះមុខស្ថានភាពនេះ ពួកអ្នកខ្សត់ខ្សោយគ្មានអ្វីក្រៅពីរត់ទៅរកការការពារពីពួកអ្នកមានអំណាចឡើយ។ ពលរដ្ឋសេរីទាំងនោះបានទៅពឹងពាក់អ្នកមានអំណាចឱ្យជួយ ដោយដោះដូរជាមួយការចូលបម្រើអ្នកដែលជួយការពារពួកគេ ជួនកាលបានទាំងជំនួយសង្គ្រោះផ្នែកសម្ភាររហូតដល់ថ្ងៃដែលពួកគេស្លាប់។ ពួកអ្នកខ្លាំង និងមានអំណាចទាំងនោះក្លាយជា **«ស្ដេចត្រាញ់»**។ នៅជុំវិញពួកស្ដេចត្រាញ់មានក្រុមមនុស្សដែលសុំជំនួយពីពួកស្ដេចត្រាញ់ដទៃទៀតដែលមានស្វាមីភក្តិចេះប្រយុទ្ធ គេឱ្យឈ្មោះថា «**ពួកមនុស្សចំណុះស្ដេចត្រាញ់ ឬស្ដេចសួយ**»។

#### ខ-សេដ្ឋកិច្ចបិទ

ការរួមរួមរវាងអ្នកខ្សត់ខ្សោយ និងពួកអ្នកមានអំណាចកើតឡើងស្របពេលជាមួយការប្រែប្រួលនៃសេដ្ឋកិច្ច។ ចាប់តាំងពីការដួលរលំចក្រភពរ៉ូមខាងលិចមក សេដ្ឋកិច្ចតំបន់នេះបានធ្លាក់ចុះដុនដាបជាលំដាប់។ ដោយសារមានការវាយលុកចូលរាតត្បាតពីពួកអនារ្យជន រោងសិប្បកម្មទាំងឡាយគ្មានសកម្មភាព ជាហេតុធ្វើឱ្យពួកគេពឹងផ្អែកលើការនាំចូលគ្រឿងឧបភោគបរិភោគល្អៗ ពីរ៉ូមខាងកើត ប៉ុន្តែមិនមែនជាទំនិញអ្វីធំដុំទេ។ ដូចនេះ មាស និងប្រាក់ដែលរក្សាទុកថយចំនួនចុះបន្តិចម្ដងៗ រូបិយវត្ថុប្រែប្រួលតាមតំបន់ បណ្ដូរទំនិញផ្ទៃក្នុងចុះខ្សោយ ដីក្លាយជាវត្ថុមានតម្លៃ ហើយពួកម្ចាស់ដីធំៗគឺ ជាអ្នកមានអនុភាព។ ពួកគេប៉ុនប៉ងក្ដោបក្ដាប់ស្ថានភាពនេះដើម្បីកេងចំណេញតែរៀងៗខ្លួន។ បែបនេះគេហៅថា«សេដ្ឋកិច្ចបិទ»។

#### គ-ការវិវត្តនៃទម្រង់សក្តិភូមិ (Feodalité)

ស្ដេច ឬមហារាជបានផ្ដល់អំណោយជាដីធ្លី និងងារជាស្ដេចសាមន្តរាជដល់ពួកស្ដេចត្រាញ់ ដើម្បីតបស្នងចំពោះភក្ដីភាពរបស់ពួកគេ។ **ពួកសាមន្តរាជមានសិទ្ធិអំណាចចាត់ចែង និងស្វ័យគ្រប់គ្រងដីធ្លីដែលព្រះមហារាជប្រគល់ឱ្យ។ ទង្វើដូចនេះបានរាលដាលទៅលើមនុស្សសំខាន់ៗនៅក្នុងរាជាណាចក្រទាំងមូល** ពួកអ្នកមានប្រាក់ និងម្ចាស់ដីទាំងឡាយ ឬពួកអភិជនតំណាងអាជ្ញាធរខេត្ត ក៏បានសុំសិទ្ធិក្លាយជាស្ដេចត្រាញ់ (សាមន្តរាជផ្ទាល់) ពីមហារាជដែរ។

ពួកម្ចាស់ដីថ្នាក់កណ្តាលបានទៅសុំជំនួយពីស្តេចសាមន្តរាជដើម្បីឱ្យមហារាជតែងតាំងជាស្តេចសួយ។ ហេតុនេះទើបមានរចនាសម្ពន្ធដូចខាងក្រោម៖

## ១.២-ឥរិយាបថបែបសាសនា និងទំនៀមទំម្លាប់ក្នុងរបបសក្តិភូមិ

### ក-ឥរិយាបថ ឬកាយវិការបែបសាសនា

នៅពេលដែលម្ចាស់ដីធំៗណាម្នាក់ត្រូវបានជ្រើសរើសជាស្តេចត្រាញ់គឺត្រូវឆ្លងកាត់ពិធី "គារវភក្តី"។ នៅក្នុងពិធីនេះ បុគ្គលដែលត្រូវបានជ្រើសរើសនោះ លុតជង្គង់ចំពោះសាក្សីជាច្រើននាក់ ក្បាលទទេ គ្មានអាវុធ យកដៃទៅភ្ជាប់នឹងដៃមហារាជ រួចពោលថា "ព្រះករុណា! ខ្ញុំព្រះអង្គក្លាយជាមនុស្សរបស់ព្រះអង្គហើយ" មហារាជចាប់លើកឡើងហើយឱបរឹតគេ។ ក្នុងពិធីនេះមនុស្សធ្វើការស្បថស្បែ បញ្ជាក់ភាពស្មោះត្រង់របស់ខ្លួន ដោយដាក់ដៃត្រង់ទៅរកគម្ពីរនៃលទ្ធិព្រះយេស៊ូ។

ពិធីប្រគល់តំណែងស្តេចត្រាញ់បានបញ្ចប់ មហារាជប្រគល់ជាឱឡារិកនូវដីដល់ស្តេចត្រាញ់ជាមួយវត្ថុតំណាង គឺមែកឈើមួយ លំពែងមួយ សោរវិមានឬបន្ទាយមួយ និងទង់ជ័យចម្បាំងមួយ។

### ខ-កិច្ចការជាទម្លាប់របស់សាមន្តរាជ

ស្តេចត្រាញ់ដ៏ល្អម្នាក់ មិនត្រូវធ្វើឱ្យខូចប្រយោជន៍ដល់មហារាជ រីឯមហារាជត្រូវផ្តល់ដីធ្លីដល់ ស្តេចត្រាញ់ជាការតបស្នង។ ស្តេចត្រាញ់ត្រូវមាន«ជំនួយ» និង «ឱវាទ»ជាថ្នូរសម្រាប់មហារាជ។ ប្រសិនបើ ស្តេចត្រាញ់ធ្វើផ្ទុយ ឬក្បត់នឹងពាក្យសម្បថចំពោះមហារាជ នោះនឹងត្រូវចាត់ទុកជា "មនុស្សវៀចវេរ ឬមនុស្សក្បត់" ហើយមហារាជនឹងដកហូតដីធ្លីទាំងអស់វិញ។

**ជំនួយ** សំដៅលើការផ្តល់កងទ័ពរយៈពេល ៤០ថ្ងៃក្នុងមួយឆ្នាំ ដើម្បីរៀបចំធ្វើសង្គ្រាម ក្រោមការចាត់ចែងគ្រប់យ៉ាងរបស់មហារាជ។ ក្រៅពីជំនួយខាងកងទ័ព ស្តេចត្រាញ់មានជំនួយជាប្រាក់កាសសម្រាប់កិច្ចការ៤យ៉ាងទៀតដូចជា៖

- ពេលណាមហារាជបំពាក់អាវុធ បុត្រច្បងជាសីវ៉ាល្បេ (Chevalier)
- ពេលដែលមានអាពាហ៍ពិពាហ៍ បុត្រីច្បងរបស់មហារាជ
- ពេលត្រូវបង់តម្លៃលស់ ក្នុងករណីមហារាជត្រូវបានគេចាប់ជាឈ្លើយ
- ពេលដែលមហារាជបំពេញបូជនីយកិច្ច។

**ឱវាទ** មានន័យថា ស្តេចត្រាញ់ត្រូវចូលគាល់មហារាជដើម្បីសុំយោបល់ពីព្រះអង្គ ក្នុងចន្លោះពេលដ៏ទៀងទាត់បំផុត។ ស្តេចត្រាញ់ត្រូវមានមុខក្នុងសនោការ ផ្តល់យោបល់ផ្សេងៗដើម្បីរកដំណោះស្រាយស្តីពីបញ្ហារឹតចំណងទាក់ទងរវាងមនុស្សក្នុងសង្គម។

## ២.១.៣-សង្គមសក្តិភូមិ

វណ្ណៈសង្គមសក្តិភូមិក៏ដូចសង្គមក្នុងប្រវត្តិសាស្ត្រសម័យបុរាណ មានបំណែងចែកដូចជា៖

### ក-ស្តេចត្រាញ់ (សាមន្តរាជ ឬស្តេចចំណុះ)

ស្តេចត្រាញ់ និងស្តេចចំណុះណាដែលមានអានុភាពជាងគេសុទ្ធតែជាអ្នកចម្បាំងទាំងអស់។ ក្នុងពិធីប្រយុទ្ធដូចជា ការជិះសេះប្រយុទ្ធតទល់ដោយលំពែង ការបរបាញ់ សុទ្ធតែជាឱកាសសម្រាប់ស្តេចត្រាញ់ហ្វឹកហាត់ ពិសេសសម្រាប់ពួកសីវ៉ាល្បេដែលនឹងក្លាយជាអ្នកចម្បាំងអាជីព។

អនាគតស្តេចត្រាញ់ត្រូវពាក់អាវក្រោះ រៀនកាន់អាវុធ កាន់លំពែង រៀនជិះសេះ ឬហាត់ហ្វឹកហ្វឺនកីឡាគ្រប់បែបយ៉ាង ដែលមានលក្ខណៈឃោរឃៅក្រៃលែង។ លុះបានអាយុ១៥ឆ្នាំ គេចូលទៅបម្រើមហារាជផ្ទាល់

ក្នុងឋានៈជាបាវបម្រើ។ ៥ឆ្នាំក្រោយមក អនាគតស្ដេចត្រាញ់មានវ័យពេញលេញ ស្ទាត់ជំនាញក្នុងការប្រើអាវុធ អាចទទួលបាននូវកិត្តិយសជាសីវ៉ាល្យេ ក្នុងពិធីពិសេសតាមទំនៀមទម្លាប់។

**ខ-វណ្ណៈបព្វជិត**

បព្វជិត គឺជាបុគ្គលដែលគេគោរពតាមបែបសាសនា បន់ស្រន់ សូត្រធម៌ ហើយមានបុព្វសិទ្ធិ ពិសេសផ្នែកយុត្តិធម៌ ដីធ្លី និងពន្ធអាករផ្សេងៗ ព្រមទាំងមានឥទ្ធិពលខាងអប់រំស្មារតីដ៏ធំធេងក្នុងសកម្មភាពនានា។ បព្វជិត ធ្វើទៅតាមឆន្ទៈរបស់អាទិទេព ក្នុងការជួយគ្នាទៅវិញទៅមករវាងវណ្ណៈសង្គមទាំងអស់នៃប្រព័ន្ធ សក្តិភូមិ ដើម្បីជានាចំណងទាក់ទងជាមួយការកសាងគ្រិស្តសាសនា។ ពួកស្ដេចត្រាញ់បានធ្វើអំណោយជា ដីធ្លីដល់ព្រះវិហារជាច្រើនទសវត្សរ៍មកហើយ ដើម្បីលប់លាងទោស កំហុសនានាសម្រាប់ពេលខ្លួនស្លាប់ទៅ។

**គ-វណ្ណៈមេទ័ព**

ពួកសីវ៉ាល្យេ ជាអ្នកការពារផលប្រយោជន៍ស្ដេចត្រាញ និងមហារាជ។ ពួកនេះអាចរស់រានបានដោយសារតែមហារាជ ឬស្ដេចត្រាញ់ ប្រទានដីឱ្យយ៉ាងច្រើន ហើយធ្វើអាជីវកម្មលើដីនោះ។ ពួកគេបានយកដីដែលខ្លួនទទួលបានមួយចំនួនទៅជួលឱ្យកសិករធ្វើស្រែចម្ការ និងប្រមូលពន្ធដារ ព្រមទាំងកាតព្វកិច្ចផ្សេងៗ។

**ឃ-វណ្ណៈកសិករ**

ប្រជាកសិករចាត់ជាវណ្ណៈមួយដោយឡែក មានសមាជិកច្រើនលើសលប់ជាងវណ្ណៈដទៃទៀតទាំងអស់ ដែលមានចំនួនពី៨០ទៅ៩០ភាគរយនៃប្រជាជនសរុប។ វណ្ណៈកសិករចែកជាពីរប្រភេទទៀតទៅតាមស្ថានភាពសង្គម។

- **ប្រជាកសិករសេរី**

ពួកនេះគ្មានដីផ្ទាល់ខ្លួនទេ គេធ្វើកសិកម្មនៅលើដីមហារាជ ស្ដេចត្រាញ់ និងសីវ៉ាល្យេ ដោយបង់ថ្លៃឈ្នួលដី ជាប្រាក់ឬជាផលដំណាំ។ គេត្រូវបង់ពន្ធយ៉ាងធ្ងន់ធ្ងរលើកិច្ចសន្យានៃការធានាសុវត្ថិភាពចំពោះខ្លួន ហើយក៏ត្រូវជាប់កំណែនការងារផ្សេងៗ ដោយគ្មានកម្រៃជាច្រើនថ្ងៃក្នុងមួយសប្ដាហ៍។ កសិករប្រភេទនេះអាចមានសេរីភាពចាកចេញពីដែនដីស្ដេចត្រាញ់បាន។

**បន្ទុកប្រជាកសិករ**

បន្ទុកទាំងឡាយដែលប្រជាកសិករទទួលមានដូចជា

- អាករជាធម្មជាតិ ប្រជាកសិករត្រូវយកភាគនៃភោគផលដែលខ្លួនធ្វើបានទៅបង់ឱ្យម្ចាស់ដី និង បព្វជិត។ មិនត្រឹមតែប៉ុណ្ណោះ ពួកគេត្រូវជាប់កំណែនធ្វើការជូនស្ដេចត្រាញ់ដោយឥតយកថ្លៃ មានដូចជា ជួសជុលវិមាន ផ្លូវថ្នល់ ឬធ្វើស្រែចម្ការជាដើម ដើម្បីដោះដូរនឹងការផ្ដល់សុវត្ថិភាពពីស្ដេចត្រាញ់។

- អាករជាប្រាក់ គឺសារពើពន្ធផ្សេងៗមានពន្ធខ្លួន និងពន្ធដីជាដើម។

- អាករបន្ទាប់បន្សំ គឺជាអាករមិនចំពោះដូចជាត្រូវជួលត្បាល់កិន ឡ ឃ្នាប របស់ស្ដេចត្រាញ់ដើម្បីកិនស្រូវ ឬកិនម្សៅ។

- **ពួកអ្នកងារ (Serf)**

ពួកនេះមានជីវភាពយ៉ាប់យ៉ឺនណាស់ មិនខុសពីជីវភាពទាសករក្នុងសម័យបុរាណឡើយ។ ពួកអ្នកងារគ្មានសិទ្ធិចាកចោលដីធ្លីរបស់ស្ដេចត្រាញ់បានឡើយ។ កាលណាស្ដេចត្រាញ់ត្រូវការលក់កម្មសិទ្ធិរបស់គេ គេត្រូវលក់អ្វីៗទាំងអស់ដែលមាននៅទីនោះដូចជា ផ្ទះសំបែង សត្វពាហនៈ ផលដំណាំព្រមទាំងគ្រួសារអ្នកងារទាំងអស់ ដែលរស់នៅលើទឹកដីនោះ។ ក្នុងការលក់អ្នកងារ គេលក់ទាំងគ្រួសារដោយឥតបំបែកឪពុកពីកូន ឬ

កូនពីឪពុកឡើយ។ អ្នកងារអាចរកគូស្រករក្រៅដែនដីរបស់ខ្លួនបានដែរ ប្រសិនបើមានការអនុញ្ញាតពីស្តេចត្រាញ់ ហើយសាមីជនត្រូវបង់ពន្ធអាករថែមទៀតផង។

ម្យ៉ាងទៀត អ្នកងារទាំងឡាយអាចទៅជាប្រជាកសិករសេរីបាន លុះត្រាតែមានប្រាក់បង់អាករដើម្បីទិញសេរីភាពរបស់ខ្លួន។

## ២-ការរស់ឡើងវិញនៃអរិយធម៌អឺរ៉ុប

នៅក្នុងសតវត្សទី១៥ និងទី១៦ នៅពេលដែលអេស្ប៉ាញកំពុងតែវាតទីពង្រីកអាណានិគមនៅលើទ្វីបអាម៉េរិក ដែលគេហៅថា «ដែនដីថ្មី» នៅអឺរ៉ុបដែលជាដែនដីចាស់ឯណោះវិញ គេបានស្គាល់នូវការវិវឌ្ឍដ៏សំខាន់មួយ គឺការវិវឌ្ឍខាងវប្បធម៌ ដែលគេឱ្យឈ្មោះតាមភាសាបារាំងថា "La Renaissance" មានន័យថាបុនសម័យ។ គេកំណត់បុនសម័យ ពីព្រោះថានៅពេលនោះ អឺរ៉ុបបានចាប់ផ្តើមស្គាល់ឡើងវិញនូវវប្បធម៌រុងរឿងដែលគេធ្លាប់មានកាលពីក្នុងសម័យបុរាណ ដែលត្រូវវលាយបាត់បង់ស្ទើរតែបាត់សូន្យនៅក្រោយការដួលរលំនៃចក្រភពរ៉ូម។

នៅក្រោយការដួលរលំនៃចក្រភពរ៉ូម នៅសតវត្សទី៥ តំបន់អឺរ៉ុបដែលធ្លាប់តែស្ថិតនៅក្នុងមហារដ្ឋតែមួយ គឺចក្រភពរ៉ូម ត្រូវបានបំបែកទៅជានគរផ្សេងៗគ្នា ហើយនគរអស់ទាំងនោះបានចំណាយពេលច្រើនទៅលើការធ្វើសង្គ្រាមរវាងគ្នា និងគ្នា ឬធ្វើសង្គ្រាមដណ្តើមអំណាចផ្ទៃក្នុងនគររបស់ខ្លួន។ អឺរ៉ុបត្រូវធ្លាក់ក្នុងភាពអនាធិបតេយ្យ សេដ្ឋកិច្ចត្រូវខ្ទេចខ្ទាំ ប្រជាជនគ្មានសុខសន្តិភាព និងគ្មានការអប់រំ ដែលជាហេតុធ្វើឱ្យវប្បធម៌ដ៏រុងរឿងកាលពីមុន ត្រូវវលាយបាត់បង់បន្តិចម្តងៗ រហូតធ្លាក់ក្នុងដំណាក់កាលមួយ ដែលអ្នកប្រវត្តិសាស្ត្រឱ្យឈ្មោះថា «យុគខ្មៅងងឹត»។

នៅឆ្នាំ១៤៥៣ មានហេតុការណ៍ដ៏សំខាន់មួយ ដែលធ្វើឱ្យយុគខ្មៅងងឹតនៅអឺរ៉ុបចាប់ផ្តើមទទួលពន្លឺឡើងវិញ។ ចក្រភពអូតូម៉ង់របស់ពួកតួកគីបានវាយផ្តួលរំលំទីក្រុងកុងស្តង់ទីណូប ដែលជារាជធានីនៃចក្រភពប៊ីហ្សង់តាំង (អតីតចក្រភពរ៉ូមខាងកើត)។ អ្នកប្រាជ្ញជាច្រើនរបស់ប៊ីហ្សង់តាំងក៏បាននាំគ្នារត់គៀសខ្លួនទៅកាន់អឺរ៉ុប ដោយនាំយកទៅជាមួយនូវឯកសារល្អៗ ដែលបន្សល់ទុកពីអ្នកប្រាជ្ញក្រិកសម័យបុរាណ។ អ្នកប្រាជ្ញ និងឯកសារក្រិកទាំងនេះហើយ ដែលជាគ្រឹះដ៏សំខាន់មួយ ដែលនាំទៅរកការស្តារឡើងវិញនៃវប្បធម៌រុងរឿងនៅអឺរ៉ុប ហើយឆ្នាំ១៤៥៣ ត្រូវបានអ្នកប្រវត្តិសាស្ត្រអឺរ៉ុប ជាពិសេស អ្នកប្រវត្តិសាស្ត្របារាំង ចាត់ទុកថាជាឆ្នាំចុងក្រោយនៃយុគសម័យកណ្តាល និងជាឆ្នាំចាប់ផ្តើមនៃសម័យកាល Renaissance។

ប្រទេសដែលបានដើរតួនាទីសំខាន់បំផុត នៅក្នុងការធ្វើឱ្យរស់ឡើងវិញ នៃវប្បធម៌រុងរឿងនេះ គឺអ៊ីតាលី។ គេសង្កេតឃើញថា អ្នកប្រាជ្ញល្បីៗ ទាំងខាងសិល្បៈ ស្ថាបត្យកម្ម ទស្សនវិជ្ជា នយោបាយ ហិរញ្ញវត្ថុ និងតារាសាស្ត្រ ភាគច្រើនចេញមកពីអ៊ីតាលី។

Michel-Ange, Raphael និង Léonard de Vinci ដែលត្រូវបានគេចាត់ទុកថាជាវិចិត្រករ ដែលមានស្នាដៃឆ្នើមបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ គឺពូកែខាងចម្លាក់ គំនូរ ស្ថាបត្យកម្ម និងវិស្វកម្ម សុទ្ធសឹងជាអ្នកប្រាជ្ញអ៊ីតាលី។ រហូតមកទល់នឹងពេលសព្វថ្ងៃនេះ ក្នុងមួយថ្ងៃៗ គេឃើញមានហ្វូងមនុស្សណែនណាន់តាន់តាប់ នាំគ្នាឈរតម្រង់ជួរចាំមើលរូបគំនូរ Monalisa ដែលគូរដោយ Léonard de Vinci ហើយដែលគេដាក់តាំងនៅក្នុងសារមន្ទីរ Louvre នៅប៉ារីស។ ចំណែក Michel-Ange វិញ ក្រៅពីគំនូរ និងចម្លាក់ បានបន្សល់ទុកនូវស្នាដៃស្ថាបត្យកម្មដ៏ល្បីល្បាញជាច្រើន ជាពិសេស គឺវិហារ Saint Pierre នៅបុរីវ៉ាទីកង់ ហើយដែលត្រូវបានគេចម្លងតាម នៅក្នុងការសាងសង់អគារជាច្រើនផ្សេងទៀត រួមមាន វិហារ Saint Paul នៅអង់គ្លេស និងវិមានកាពីតូលរបស់សហរដ្ឋអាម៉េរិកជាដើម។

អ្នកប្រាជ្ញមួយរូបទៀតរបស់អ៊ីតាលី នាសម័យកាល Renaissance គឺទស្សនវិទូនយោបាយ ឈ្មោះ Machiavelli បាននិពន្ធសៀវភៅមួយក្បាល ដែលល្បីសុះសាយរហូតមកដល់សព្វថ្ងៃ គឺសៀវភៅ ដែលមានចំណងជើងជាភាសាបារាំងថា "Le Prince"។ នៅក្នុងសៀវភៅនេះ Machiavelli បានសរសេរអំពីរបៀបដឹកនាំរដ្ឋ ដោយប្រើប្រាជ្ញាផង ប្រើកម្លាំងផង និងប្រើកលល្បិចផង។ បើតាម Machiavelli មេដឹកនាំរដ្ឋត្រូវតែចេះប្រើកម្លាំងដូចជាសត្វតោ និងចេះក្រឡិចក្រឡុចដូចជាសត្វកញ្ជ្រោង ក៏ប៉ុន្តែ កម្លាំង និងភាពក្រឡិចក្រឡុចនេះ មិនមែនដើម្បីគ្រាន់តែរក្សាអំណាចយកមកបំពេញប្រយោជន៍ផ្ទាល់ខ្លួន នោះទេ ប៉ុន្តែ គឺដើម្បីរក្សាអំណាចយកទៅបម្រើផលប្រយោជន៍របស់ប្រជាជនទូទៅ។ រដ្ឋអាចរំលោភច្បាប់ ឬធ្វើនូវទង្វើដែលគ្មានសីលធម៌ បើសិនជាវាចាំបាច់ ដើម្បីផលប្រយោជន៍ជាតិ ដែលគេហៅតាមភាសាបារាំងថា "Raison d'Etat"។ គោលគំនិតរបស់ Machiavelli ត្រូវបានអ្នកខ្លះរិះគន់ថាជាគំនិតអ្នកនយោបាយដែលគ្មានសីលធម៌ ក៏ប៉ុន្តែ ខ្លះទៀត យល់ថាវាជាគំនិតនយោបាយដែលមានលក្ខណៈប្រាកដនិយម។ មកទល់នឹងពេលបច្ចុប្បន្ននេះ សៀវភៅ "Le Prince" របស់ Machiavelli នៅតែជាសៀវភៅគោល ដែលគេយកមកបង្រៀននៅស្ទើរតែគ្រប់សាលាវិទ្យាសាស្ត្រនយោបាយ។

នៅសតវត្សទី១៦ ចលនា Renaissance ដែលចាប់កំណើតនៅអ៊ីតាលី បានជះពន្លឺបន្តិចម្តងៗ ទៅដល់បណ្តាប្រទេសផ្សេងទៀត នៅទូទាំងតំបន់អឺរ៉ុប រាប់ចាប់តាំងពីអេស្ប៉ាញ បារាំង អាល្លឺម៉ង់ និងអង់គ្លេស រហូតទៅដល់ប៉ូឡូញ។

នៅឆ្នាំ១៥៤៣ តារាវិទូប៉ូឡូញម្នាក់ឈ្មោះ Nicolas Corpernic ដែលធ្លាប់បានទៅសិក្សានៅអ៊ីតាលី បានចេញផ្សាយសៀវភៅមួយ អំពីទ្រឹស្តីថ្មីនៃតារាសាស្ត្រ ដែលត្រូវបានគេចាត់ទុកថាជាបដិវត្តន៍នៃការយល់ដឹងរបស់មនុស្ស ទៅលើចក្រវាល។

តាំងពីដើមរៀងមក មនុស្សក្នុងសម័យបុរាណយល់ថា ផែនដីគឺជាចំណុចកណ្តាលនៃចក្រវាល។ គ្រប់អ្វីៗ ទាំងអស់ដែលនៅលើមេឃ ទាំងព្រះចន្ទ ព្រះអាទិត្យ និងគ្រប់ផ្កាយទាំងអស់ សុទ្ធតែធ្វើដំណើរជុំវិញផែនដី។ Nicolas Copernic ដែលបានចំណាយពេលរាប់ឆ្នាំ សិក្សាអំពីតារាសាស្ត្រ បានបង្កើតនូវទ្រឹស្តីដ៏ថ្មីស្រឡាងមួយ គឺថា មិនមែនព្រះអាទិត្យទេ ដែលវិលជុំវិញផែនដី គឺផែនដីវិញទេ ដែលជុំវិញព្រះអាទិត្យ។ ហេតុដែលគេមើលទៅឃើញហាក់ដូចជាព្រះអាទិត្យ និងអ្វីៗទាំងអស់នៅលើមេឃវិលជុំវិញផែនដី តាមការពិត គឺដោយសារតែផែនដីវិលជុំវិញខ្លួនឯង ដែលក្នុងមួយជុំៗ មានរយៈពេល ២៤ម៉ោង។ យោងតាមទ្រឹស្តីរបស់ Copernic ផែនដីគ្រាន់តែជាភពមួយ ក្នុងចំណោមភពជាច្រើនផ្សេងទៀតប៉ុណ្ណោះ ហើយមិនមែនជាចំណុចកណ្តាលនៃចក្រវាល ដូចដែលគេធ្លាប់ជឿពីមុននោះទេ។ ទ្រឹស្តីរបស់ Nicolas Copernic គឺជាចំណុចចាប់ផ្តើមនៃតារាសាស្ត្រសម័យបុរាណ ក៏ប៉ុន្តែ វាផ្ទុយទៅនឹងជំនឿរបស់វិហារកាតូលិកនាសម័យកាលនោះ។ ហេតុដូច្នេះហើយបានជា Copernic រង់ចាំរហូតដល់ដង្ហើមចុងក្រោយនៃជីវិតរបស់លោក ទើបចេញផ្សាយសៀវភៅស្តីពីបដិវត្តន៍នៃតារាស្ត្រ។



រូបគំនូរ បង្ហាញពី Nicolas Copernic តារាវិទូប៉ូឡូញ ដែលគេចាត់ទុកថាជាបិតានៃតារាស្រ្តសម័យបុរាណ

និយាយ អំពីវិហារកាតូលិក យុគសម័យ Renaissance ក៏ជាយុគសម័យដែលមានការបែកបាក់នៃគ្រិស្តសាសនានិកាយកាតូលិក ផងដែរ។ យើងដឹងហើយថា នៅពេលដែលចក្រភពរ៉ូមត្រូវពុះចែកជាពីរ គ្រិស្តសាសនាត្រូវបាក់បែកជាពីរនិកាយរួចមកហើយ គឺនិកាយអ័រតូដុក្ស (Orthodox) នៅចក្រភពរ៉ូមខាងកើត (ចក្រភពប៊ីហ្សង់តាំង) និងនិកាយកាតូលិក នៅចក្រភពរ៉ូមខាងលិច (អឺរ៉ុបខាងលិច)។ ក្រោយពេលចក្រភពរ៉ូមខាងលិចដួលរលំបែកខ្ញែកទៅជានគរផ្សេងៗគ្នា គ្រប់នគរទាំងអស់នៅអឺរ៉ុបខាងលិចនៅតែបន្តស្ថិតក្រោមអំណាចនៃវិហារកាតូលិកដដែល ដោយមានសម្តេចប៉ាប នៅទីក្រុងរ៉ូម ជាអ្នកមានអំណាចកំពូលខាង សាសនា។ ប៉ុន្តែ នៅឆ្នាំ១៥១៧ បព្វជិតកាតូលិកអាល្លឺម៉ង់ម្នាក់ ឈ្មោះ Martin Luther (សូមកុំច្រឡំជាមួយ Martin Luther King ដែលជាសកម្មជនការពារសិទ្ធិជនជាតិស្បែកខ្មៅនៅអាម៉េរិក!) បានចេញមុខជា សាធារណៈរិះគន់សេចក្តីបង្រៀន រចនាសម្ពន្ធ និងរបៀបដឹកនាំរបស់សម្តេចប៉ាប ព្រមទាំងបានទាមទារឱ្យធ្វើកំណែទម្រង់ស៊ីជម្រៅនៃវិហារកាតូលិក។ នៅឆ្នាំ១៥២១ Marthin Luther ត្រូវបានសម្តេចប៉ាបបណ្តេញចេញពីវិហារកាតូលិក ព្រមទាំងត្រូវបានអធិរាជ Charles Quint ចាត់ទុកថាជាឧទ្ទាមក្រៅច្បាប់។ ប៉ុន្តែ គំនិតរបស់ Martin Luther បានទទួលនូវការគាំទ្រកាន់តែច្រើន ហើយចលនាប្រឆាំងនឹងថ្នាក់ដឹកនាំវិហារកាតូលិកចេះតែបន្តរីករាលដាលកាន់តែធំឡើង រហូតបង្កើតទៅជានិកាយមួយថ្មីទៀត ដែលគេឱ្យឈ្មោះថា «ប្រូតេស្តង់» (Protestant)។ ប្រូតេស្តង់ ដោយសារតែពួកគេជាអ្នកតវ៉ាប្រឆាំងនឹងអំណាចរបស់សម្តេចប៉ាប និងសេចក្តីបង្រៀនជាទូទៅរបស់វិហារកាតូលិក។

នៅឆ្នាំ១៥៣៤ នៅអង់គ្លេស ដែលស្ថិតនៅក្រោមអំណាចរបស់សម្តេចប៉ាបដែរនោះ ព្រះបាទ Henri VIII ចង់លែងព្រះមហេសីរបស់ព្រះអង្គ ប៉ុន្តែ សម្តេចប៉ាបមិនអនុញ្ញាត។ ព្រះបាទ Henri VIII ក៏បានផ្តាច់ខ្លួនចេញពីអំណាចរបស់សម្តេចប៉ាប ដោយបានបង្កើតជានិកាយថ្មីមួយទៀត សម្រាប់អង់គ្លេស គឺនិកាយ

Anglican។ រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ វិហារគ្រិស្តសាសនានិកាយ Anglican នៅតែត្រូវកាត់ផ្ដាច់ពីអំណាចរបស់សម្ដេចប៉ាប។ ប្រមុខដឹកនាំវិហារ Anglican គឺ ព្រះមហាក្សត្រអង់គ្លេស[444]។

## ៣-ការរុករកដីថ្មី និងការបែងចែកទឹកដីរវាងអេស្ប៉ាញ និងព័រទុយហ្គាល់

នៅចុងសតវត្សទី១៥ និងដើមសតវត្សទី១៦ មានការរុករកតាមផ្លូវសមុទ្រដឹកនាំដោយស្ដេចព័រទុយហ្គាល់ និងអេស្ប៉ាញ។ ពួកអ្នកស្រាវជ្រាវសំខាន់ៗមានលោក វ៉ាស្កូដឺហ្គាម៉ា(Vasco de Gama) គ្រីស្តុហ្វកូឡុំ (Christophe Colomb) និងលោក ម៉ាសេឡង់(Magellan) ដែលធ្វើឱ្យមានការផ្លាស់ប្ដូរចក្ខុវិស័យផ្នែកភូមិសាស្ត្រពិភពលោក និងសេដ្ឋកិច្ចនៅអឺរ៉ុប។

### ៣.១-ការរុករកធំៗ

#### ក-វ៉ាស្កូដឺហ្គាម៉ា រកឃើញផ្លូវទៅឥណ្ឌា

ស្ដេចហង់រី (Henri) បានជំរុញទឹកចិត្តជនជាតិព័រទុយហ្គាល់ ដោយព្រះអង្គបានតែងតាំងពួកនាវិកឱ្យរុករកតាមឆ្នេរអាត្លង់ទិកនៃដែនដីអាហ្វ្រិក ដើម្បីរុករកផ្លូវថ្មីទៅកាន់ឥណ្ឌា។ នៅឆ្នាំ១៤៨៨ លោកបាតេឡេមី ឌីយ៉ាស(Barthelemy Dias) បានទៅដល់ជ្រោយចុងខាងត្បូងនៃទ្វីបអាហ្វ្រិក ដែលគេដាក់ឈ្មោះថា «ជ្រោយសង្ឃឹម»។ ពីឆ្នាំ១៤៩៧-១៤៩៨ លោក វ៉ាស្កូដឺហ្គាម៉ា ជាជនជាតិព័រទុយ-ហ្គាល់ បានធ្វើដំណើរព័ទ្ធដែនដីទ្វីបអាហ្វ្រិកតាមភាគខាងត្បូងដែលនាំផ្លូវដោយនាវិកជាតិអារ៉ាប់ម្នាក់ ហើយបានទៅដល់កាលីគូត (Calicut) នៃប្រទេសឥណ្ឌា នៅឆ្នាំ១៤៩៨។ ដោយពួកអារ៉ាប់នៅទីនោះទទួលគាត់ពុំបានល្អ លោក វ៉ាស្កូដឺហ្គាម៉ា បានធ្វើដំណើរបកក្រោយត្រឡប់មកព័រទុយហ្គាល់វិញ។

#### ខ-ដំណើររុករកទៅទិសខាងលិច

ប្រទេសអេស្ប៉ាញ បានមើលឃើញនូវភាពជោគជ័យរបស់ប្រទេស ព័រទុយហ្គាល់ ដែលជាប្រទេសជិតខាងខ្លួន ដោយក្ដីច្រណែន។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៤០០ អ្នកនឹងនឹកឃើញដល់ស្ដេចដែលជាគ្រិស្តសាសនិកនៅក្នុងប្រទេស អេស្ប៉ាញ ដែលបានបូជាកម្លាំងកាយចិត្តរបស់ទ្រង់ដើម្បីច្បាំងដណ្ដើមយកនូវបាំងការពារ ដ៏រឹងមាំចុងក្រោយរបស់ពួក មូស្លីម នៅតំបន់ **ហ្គ្រាណាដា** (Granada)។ នៅពេលដែល **ហ្វឺឌីណង់ (Ferdinand) និង អ៊ីសាបេឡា** (Isabella)បានបំពេញនូវបេសកកម្មនេះរួចរាល់ហើយនោះ ពួកគេក៏បានគិតទុកជាស្រេចនូវគោលដៅផ្សេងៗទៀត។

ដូចនឹងប្រទេសព័រទុយហ្គាល់ដែរ ប្រទេសអេស្ប៉ាញ ចង់ចូលរួមក្នុងការធ្វើពាណិជ្ជកម្មលើគ្រឿងទេសដ៏សំបូរបែបនៅទ្វីបអាស៊ី។ ចំណុចដែលសំខាន់ស្មើគ្នានឹងចំណុចខាងលើសម្រាប់ម្ចាស់ក្សត្រីយានីយ៍អ៊ីសាបេឡា ដែលជឿស៊ប់ទៅលើ សាសនានោះ គឺឱកាសនៃការផ្សព្វផ្សាយនូវគ្រិស្តសាសនា។ ទ្រង់ជឿថា លោក គ្រីស្តូប កូឡុំ (Christopher Culumbus) ដែលជាកាពីទែនដែនសមុទ្រម្នាក់មកពីតំបន់ **ហ្សេណូវ** (Genoa) ប្រហែលជាអាចជួយឱ្យប្រទេសអេស្ប៉ាញ សម្រេចបាននូវគោលបំណងទាំងនេះ។

អស់រយៈពេលជាច្រើនឆ្នាំ ដែលលោកកូឡុំ ព្យាយាមសុំជំរុញប្រទេស ព័រទុយហ្គាល់ បន្ទាប់មកប្រទេសអេស្ប៉ាញ ឱ្យជួយឧបត្ថម្ភដល់ដំណើរតាមទិសខាងលិចមួយទៅកាន់ទ្វីបអាស៊ី ដោយឆ្លងកាត់ មហាសមុទ្រ អាត្លង់ទិក។ លោក កូឡុំ មានជំនឿជាក់ថា តាមរយៈការធ្វើដំណើរតាមទិសខាងលិច កប៉ាល់អាចទៅដល់ទ្វីបអាស៊ី ដោយប្រើរយៈពេលតែពីរខែប៉ុណ្ណោះ។

---

[444] សូមមើល: សេង ឌីណា *ប្រវត្តិសាស្ត្រពិភពលោក*: ការចេញផ្សាយរបស់វិទ្យុបារាំងអន្តរជាតិ ថ្ងៃ៣ វិច្ឆិកា ២០១៣

នៅក្នុងសតវត្សទី១៥ មានមនុស្សជាច្រើនមានការយល់ឃើញខុសៗគ្នាចំពោះទំហំរបស់ផែនដី។ មនុស្សមួយចំនួនរួមទាំងលោក កូឡុំ ផង បានយកស្នាដៃរបស់អ្នកភូមិវិទូបុរាណគឺលោក ប្តូឡេមី (Ptolemy) មកធ្វើជាគោល។ ក៏ប៉ុន្តែលោក ប្តូឡេមី បានប៉ាន់ប្រមាណស្ទើរនូវទំហំផែនដី។ មានអ្នកប្រាជ្ញជាច្រើននៅសាកលវិទ្យាល័យ សាលាម៉ាន់ចា (Salamanca) ក្នុងប្រទេសអេស្ប៉ាញ បានគណនាយ៉ាងត្រឹមត្រូវថាផែនដីមានទំហំធំជាងការប៉ាន់ប្រមាណរបស់លោក ប្តូឡេមី ។ ពួកគេបានជំទាស់ថា ការធ្វើដំណើរនោះនឹងត្រូវប្រើពេលអស់បួនខែដើម្បីទៅដល់ទ្វីបអាស៊ី ហើយកប៉ាល់មិនអាចស្តុកអាហារ និងទឹកស្អាតគ្រប់គ្រាន់ក្នុងដំណើរ នេះឡើយ។ អ្វីដែលទាំង លោក កូឡុំ និង អ្នកប្រាជ្ញទាំងនោះ មិនបានដឹងនោះគឺថា មានទ្វីបមួយដែលស្ថិតនៅចម្ងាយល្មមនឹងអាហារផ្គត់ផ្គង់សម្រាប់រយៈពេលពីរខែត្រូវអស់។

ម្ចាស់ក្សត្រីយានី អ៊ីសាបេឡា បានទទួលយកនូវគំនិតរបស់លោក កូឡុំ ហើយបានសម្រេចព្រះទ័យជួយឧបត្ថម្ភដល់ដំណើររុករករបស់គាត់។ នៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៤៩២ កប៉ាល់តូចៗចំនួន ៣ គ្រឿង ដែលមាននាវិកសរុបទាំងអស់ ៩០នាក់ បានចាកចេញពីទីក្រុង**ប៉ាឡូស** (Palos) នៃប្រទេសអេស្ប៉ាញ។ ទោះបីជាការធ្វើដំណើរតាមទិសខាងលិចគឺជា ការល្អក៏ដោយ ក៏ពួកកម្មករនាវាទាំងអស់មានការរសាប់រសល់ ខ្វល់ខ្វាយឡើងពីបញ្ហាស្បៀងបំរុងកាន់តែតិចទៅៗ ហើយពួកគេមិនទាន់បានឃើញនូវសញ្ញាណនៃដីទៀត។ ទីបំផុតនៅថ្ងៃទី២ ខែតុលា ពួកគេទទួលជារង្វាន់នូវសញ្ញាណដំបូងនៃដី។ ដោយជឿជាក់ថា គាត់បានទៅដល់ប្រទេសឥណ្ឌាភាគខាងកើតនោះ លោក កូឡុំ បានហៅអ្នកស្រុកនោះថាជា «ជនជាតិឥណ្ឌា» ហើយមានចិត្តសប្បាយរីករាយខ្លាំងណាស់ក្នុងការទទួលយកនូវវត្ថុធ្វើពីមាសដែលពួកគេឱ្យទៅគាត់។ តាមពិតទៅ លោក កូឡុំ បានធ្វើដំណើរទៅដល់ប្រជុំកោះមួយ ដែលពេលក្រោយមកទៀតគេឱ្យឈ្មោះថា **ឥណ្ឌាខាងលិច**។

នៅក្នុងការធ្វើដំណើរបីដងបន្ថែមទៀត លោក កូឡុំ បានរកឃើញ ប្រជុំកោះ ការីប៊ីន (Caribbean) នៃប្រទេស គុយបា និង ហ៊ីសប៉ានីយ៉ូឡា (Hispaniola) ដែលសព្វថ្ងៃនេះគឺប្រទេស ហៃទី និង សាធារណរដ្ឋដូមីនីគែន (Dominican Republic)។ គាត់បានទាមទារសិទ្ធិលើកោះថ្មីនោះឱ្យទៅប្រទេសអេស្ប៉ាញ និងបានតាំងទីលំនៅនៅទីនោះ។ លោក កូឡុំ មិនដែលយល់ថាគាត់មិនបានទៅដល់ភាគខាងកើតនៃប្រទេសឥណ្ឌានោះទេ ប៉ុន្តែដំណើររុករករបស់លោក គឺជាមាគ៌ាមួយដែលអាចឱ្យប្រទេសអេស្ប៉ាញដាក់អាណានិគមទៅលើទ្វីបធំៗទាំងពីរនេះបាន។

## សន្ធិសញ្ញា ថរដេស៊ីឡាស (Tordesillas)

ដំណើររុករករបស់លោក កូឡុំ បានធ្វើឱ្យមានការផ្ទុះឡើងនូវការប្រជែងគ្នា រវាងពួក អេស្ប៉ាញ និង ព័រទុយហ្គាល់។ ស្តេច ចន ទី២ នៃប្រទេស ព័រទុយហ្គាល់ ជំទាស់ទៅនឹងការទាមទារយកប្រជុំកោះការីប៊ីនរបស់អេស្ប៉ាញ។ ប្រទេសទាំងពីរបានធ្វើការប្រឆាំងទៅនឹងសិទ្ធិក្នុងការរុករកដែនដីថ្មី របស់ប្រទេសម្ខាងទៀត។ ដើម្បីរក្សាឱ្យបាននូវសន្តិភាព សម្តេចប៉ាប រៀបចំឱ្យមានការតាំងទីលំនៅមួយ។

បន្ទាប់ពីមានការចរចាអស់រយៈពេលយ៉ាងយូរមក ទើបប្រទេសទាំងពីរធ្វើការចុះហត្ថលេខាលើ សន្ធិសញ្ញា ថរដេស៊ីឡាស (Tordesillas) នៅឆ្នាំ១៤៩៤។ សន្ធិសញ្ញាបានកម្រិតនូវបន្ទាត់ព្រំដែនពីជើង ទៅត្បូងមានចម្ងាយប្រមាណជា ១.១០០ ម៉ាយ (១.៧៧០ គ.ម) នៅភាគខាងលិចនៃប្រជុំកោះ អាហ្សរ (Azores) ក្នុងមហាសាគរអាត្លង់ទិក។ សន្ធិសញ្ញាបានផ្តល់នូវដីដែលទើបនឹងរកឃើញថ្មីៗ ដែលនៅខាងលិចនៃខ្សែបន្ទាត់ទាំងអស់ ឱ្យទៅអេស្ប៉ាញ។ ប្រទេស ព័រទុយហ្គាល់ មានសិទ្ធិធ្វើអាណានិគម និង ជំនួញជាមួយនឹងដីទាំងឡាយណា ដែលស្ថិតនៅ ភាគខាងកើតនៃខ្សែបន្ទាត់។

សន្ធិសញ្ញាបានផ្តល់សិទ្ធិឱ្យ អេស្ប៉ាញ ប្រកាសយកដែនដីភាគខាងជើង និង ខាងត្បូង នៃទ្វីបអាម៉េរិក មកធ្វើជាកម្មសិទ្ធិ ទោះបីជានៅពេលនោះគ្មានអ្នកណាដឹងថាទីកន្លែងនោះមាននូវវិសាលភាព នៃទឹកដីទាំងនេះក៏ដោយ។ នៅក្នុងឆ្នាំ ១៥០០ អ្នករុករកជាតិ ព័រទុយហ្គាល់ ប៉េឌ្រូ កាប្រាល (Pedro Cabral) ត្រូវបានព្យុះកំណាចបោកបក់ខុស ទិសដៅ។ គាត់បានសំចតនៅ ប្រេស៊ីល។ ដោយសារតែ ប្រេស៊ីល ស្ថិតនៅភាគខាងកើតនៃខ្សែបន្ទាត់កម្រិតព្រំដែន កាប្រាល បានប្រកាសទាមទារសិទ្ធិកាន់កាប់ផ្នែកនៃភាគខាងត្បូងអាម៉េរិក នេះឱ្យទៅប្រទេស ព័រទុយហ្គាល់។

## ទ្វីបមួយនៅតាមផ្លូវមួយទៅកាន់ប្រទេសឥណ្ឌា

ការធ្វើដំណើររុករកក្រោយៗមកទៀត បានបង្ហាញឱ្យឃើញថា លោក កូឡុំ មិនបានទៅដល់ឥណ្ឌាភាគខាងកើតនោះទេ ប៉ុន្តែគាត់បានរកឃើញទ្វីបដ៏ធំល្វឹងល្វើយមួយ។ ជនជាតិ អ៊ីតាលី ម្នាក់គឺលោក អាមីរីហ្គោ វេស្ពូស៊ី (Amerigo Vespucci) ជាតំណាងធនាគា មេឌីស៊ី ក្នុងប្រទេសអេស្ប៉ាញ បានធ្វើដំណើររុករកមួយចំនួនឱ្យប្រទេសអេស្ប៉ាញ។ គាត់បានធ្វើដំណើរតាមបណ្តោយមាត់សមុទ្រអាម៉េរិក កណ្តាល និង បានហៅទ្វីបមួយនេះថា មុនឌូស ណូវូស (Mundos Novus)ជាពាក្យឡាតាំងដែលមាន ន័យថា ពិភពថ្មី។ នៅឆ្នាំ ១៥០៧ អ្នកគូរផែនទីជនជាតិ អាល្លឺម៉ង់ ម្នាក់បាន គូរទ្វីប អាម៉េរិក ចូលទៅក្នុងផែនទីដោយផ្អែកទៅលើកំណត់ត្រារបស់ លោក អាមីរីហ្គោ វេស្ពូស៊ី (Amerigo Vespucci)។

បន្តិចក្រោយមកអ្នករុករកជនជាតិ អេស្ប៉ាញ បានធ្វើដំណើរឆ្លងកាត់សមុទ្រ ការីប៊ីន (Caribean)។ ដំណើររុករក របស់ពួកគេបានផ្តល់ជាមូលដ្ឋានសម្រាប់អាណាចក្រ អេស្ប៉ាញ នៅលើទឹកដីអាម៉េរិក ។ នៅឆ្នាំ ១៥១៣ លោក ជួន ប៉ុន ដឺ ឡេអុង (Juan Ponce de León) ប្តេជ្ញាថានឹងរកឱ្យឃើញនូវប្រភពទឹក ផុសយុវវ័យដែលមាននៅក្នុងរឿងព្រេង ដែលមនុស្សគ្រប់គ្នាជឿថាទឹកផុសនោះអាចធ្វើឱ្យមនុស្សក្លាយ ទៅជាក្មេងវិញបាន។ លោក ប៉ុន ដឺ ឡេអុង មិនដែលជួបប្រទះនឹងប្រភពទឹកផុសនោះឡើយ ប៉ុន្តែគាត់បានឈានជើងលើទឹកដីមួយដែលលោកបានឱ្យឈ្មោះថា **ផ្លរីដា** (Florida) ក្បែរទីក្រុង St. Augustine បច្ចុប្បន្ន។

នៅឆ្នាំដដែលនេះ លោក វ៉ាស្កូ ដឺ បាលបៅ (Vasco de Balboa) បានរុលទៅមុខតាមខ្សែទឹក ក្នុងព្រៃអាម៉េរិក កណ្តាល ហើយទីបំផុតគាត់ក៏បានទៅដល់វិសាលភាពដ៏ធំធេងនៃផ្ទៃទឹកទាំងមូល។ លោក បាលបៅ បានដាក់ឈ្មោះថា សមុទ្រខាងត្បូង ដោយគិតថាសមុទ្រនេះស្ថិតនៅភាគខាងត្បូងនៃទ្វីបអាស៊ី។ តាមពិតទៅផ្ទៃទឹកដ៏ធំល្វឹងល្វើយ ដែលគាត់បានឃើញនោះគឺជាមហាសមុទ្រប៉ាស៊ីភិច។

ប្រាំមួយឆ្នាំក្រោយមក ដំណើរបេសកកម្មរុករករបស់ជនជាតិអេស្ប៉ាញមួយ ដែលដឹកនាំឡើងដោយលោក ហ្វែឌីណង់ ម៉ាហ្សេឡង់ (Ferdinand Magellan) បានឆ្លងកាត់មហាសមុទ្រ ប៉ាស៊ីភិច ដ៏ធំល្វឹងល្វើយនេះ។ លោក ម៉ាហ្សេឡង់ បានធ្វើដំណើររុករកផ្លូវសមុទ្រភាគខាងលិច ដើម្បីទៅកាន់ទ្វីបអាស៊ី នៅឆ្នាំ១៥១៩។ គាត់បានធ្វើដំណើរទៅភាគខាងត្បូង តាមបណ្តោយឆ្នេរអាម៉េរិក ខាងត្បូង និងបានចូលទៅក្នុងមហាសមុទ្រ ប៉ាស៊ីហ្វិក កាត់តាមផ្លូវទឹកដ៏តូចចង្អៀត ដែលនៅមានបន្សល់នូវឈ្មោះរបស់គាត់ រហូត មកដល់សព្វថ្ងៃនេះ។

នៅក្នុងឆ្នាំ១៥៧៨ កាពីទែនសមុទ្រជនជាតិអង់គ្លេសម្នាក់ គឺលោកហ្វ្រេនស៊ីស ដ្រេក (Froncis Drake) បានធ្វើដំណើរជុំវិញជ្រោយអាម៉េរិក ខាងត្បូង។ គាត់បានវាយឆ្មក់កន្លែងឈរជើងរបស់ អេស្ប៉ាញ ដែលស្ថិតនៅភាគខាងលិចឆ្នេរ។ បន្ទាប់មកគាត់បានធ្វើដំណើរបន្តជុំវិញពិភពលោក ហើយបានត្រឡប់ទៅ កាន់ប្រទេសអង់គ្លេសវិញក្នុងឆ្នាំ១៥៨០។

## ដំណើរស្វែងរកផ្លូវឆ្លងទៅភាគខាងជើង

ប្រទេសអេស្ប៉ាញ និងព័រទុយហ្គាល់ គឺជាជាតិសាសន៍ដំបូងគេដែលបានធ្វើដំណើរឆ្លងកាត់មហា សមុទ្រអាត្លង់ទិក ប៉ុន្តែបន្តិចក្រោយមក មានជាតិសាសន៍ជាច្រើនបានយកតម្រាប់តាម។ សន្ធិសញ្ញា ថរដេស៊ីឡាស (Tordesillas) បានបដិសេធមិនទទួលស្គាល់ប្រទេសក្រោយៗទាំងនេះ ចំពោះការទាមទារសិទ្ធិនៅលើទឹកដីថ្មីៗទាំងនោះ ប៉ុន្តែប្រទេស អង់គ្លេស ប្រទេសហូឡង់ និង ប្រទេសបារាំង បានប្រឆាំងទៅនឹងសន្ធិសញ្ញានេះ។ នៅអំឡុងទសវត្សរ៍ឆ្នាំ១៥០០និងដើមទសវត្សរ៍ឆ្នាំ១៦០០ ប្រទេសទាំងនេះបានបញ្ជូន អ្នករុករករបស់ខ្លួនឱ្យធ្វើដំណើរ កាត់តាមឆ្នេរអាម៉េរិក ខាងជើង។ ព្រោះថានៅផ្លូវភាគខាងត្បូង ជុំវិញជ្រោយ **ហ៊ន** (Cape Horn) ដែលពោរពេញដោយគ្រោះថ្នាក់ ដូច្នេះពួកគេសង្ឃឹមថានឹងអាចរកផ្លូវនៅភាគខាងជើងដើម្បីធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌា។

នៅឆ្នាំ១៤៩៧ លោក ចន កាបូត (John Cabot)ជា កាពីទែនដែនសមុទ្រជាតិ អ៊ីតាលី ម្នាក់បានយល់ព្រមធ្វើដំណើររុករកឱ្យប្រទេសអង់គ្លេស។ នៅក្នុងដំណើរផ្សងព្រេងពីរលើករបស់គាត់ៗ បានរកឃើញឆ្នេរភាគខាងជើងនៃទ្វីបអាម៉េរិក ដែលសព្វថ្ងៃនេះនៅចន្លោះពី តំបន់**ឌីឡូវែរ** (Delaware) ទៅដល់ដំបន់ **ញូហ្វោនឡែន** (Newfoundland)។ យើងឃើញថាដំណើររុករករបស់ប្រទេសអង់គ្លេស មានសភាពយឺតយ៉ាវជាងប្រទេសក្នុងតំបន់ដទៃទៀត រហូតដល់ពេល ដែលលោក ម៉ាទីន ហ្វ្រូប៊ីសឺ ធ្វើដំណើរទៅដល់ចន្លេផ្លូវទឹកតូចៗ **ហុដសុន** (Hudson Strait) និងត្រឡប់មកវិញជាមួយនឹងអ្វីដែលគាត់ប្រកាសថាជាប្រភពរ៉ែមាស។ ក៏ប៉ុន្តែ រ៉ែមាសចាប់ផ្តើមអស់តម្លៃទៅៗ ហើយប្រទេសអង់គ្លេសក៏បានផ្អាកការរុករកផ្លូវសមុទ្រភាគខាងជើង ដើម្បីធ្វើដំណើរទៅកាន់ទ្វីបអាស៊ីជាបណ្តោះអាសន្នសិន។

នៅឆ្នាំ១៥២៤ ប្រទេសបាំរាំង បានឧបត្ថម្ភជាថវិការដល់ដំណើររុករកមួយរបស់ជនជាតិ អ៊ីតាលី គឺលោក ជីអូវ៉ានី វេរ៉ាហ្សាណូ (Giovanni da Verrazano)។ គាត់បានរកឃើញឆ្នេរសមុទ្រភាគខាងជើង នៃទ្វីបអាម៉េរិក ដែលសព្វថ្ងៃនេះស្ថិតនៅចន្លោះតំបន់ **ការ៉ូលីណាស** (Caroninas)និងតំបន់ **ណូវ៉ាស្កូតៃ** (Nova Scotia)។ ពីរបីឆ្នាំក្រោយមក លោក ដេយ្វី កាទីយ៉ា (Jacques Cartier) បានធ្វើដំណើរឡើងតាម ទន្លេ **ឡូរ៉ង់** (St. Lawrence River) ដោយសង្ឃឹមថាទន្លេនេះនឹងអាចនាំគាត់ទៅដល់មហាសមុទ្រ ប៉ាស៊ីហ្វិក។ ទោះបីជា គាត់ធ្លាប់បានឮតម្រុយជាច្រើនពីរឿងមាសយ៉ាងណាក្តី ក៏លោកមិនដែលបានជួបប្រទះឃើញមាសទាំងនោះឡើយ ហើយលោកក៏បានរកឃើញផ្លូវសមុទ្រទៅកាន់ប្រទេសឥណ្ឌាដែរ។

ដូចទៅនឹងជនជាតិព័រទុយហ្គាល់ដែរ ពួកហូឡង់ បានធ្វើដំណើរជុំវិញទ្វីបអាហ្វ្រិក ដើម្បីទៅកាន់ទ្វីបអាស៊ី។ ប៉ុន្តែពួកគេក៏បានជួលនាវិកជាតិអង់គ្លេស គឺលោក ហង់រី ហុដសុន (Henry Hudson) ដើម្បីស្វែងរកផ្លូវទៅកាន់ទ្វីបអាម៉េរិក ។ ក្នុងឆ្នាំ១៦០៩ លោក ហុដសុន បានរកឃើញទន្លេមួយ ដែលបានដាក់ឈ្មោះតាមឈ្មោះរបស់គាត់។ គាត់បានធ្វើដំណើរកាន់តែឆ្ងាយទៅៗ រហូតដល់ **អាល់បានី** (Albany) **ញូវយ៉ក** (New Yourk) ប៉ុន្តែគាត់បានដឹង ថាទន្លេនេះ មិនមែនជាផ្លូវទៅកាន់ប្រទេសឥណ្ឌានោះទេ។

ទោះបីជាអ្នករុករកទាំងនេះ មិនបានរកឃើញផ្លូវភាគខាងជើងសម្រាប់ធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌាក៏ដោយ ក៏ពួកគេបានបន្ថែមនូវចំណេះដឹងជាច្រើនដល់ពួកអឺរ៉ុប អំពីពិភពថ្មី (ទ្វីបអាម៉េរិក )ដែរ។ លើសពីនេះទៅទៀតនោះគឺថា ដំណើររុករករបស់គេបានជំរុញឱ្យមានអ្នកតាំងទីលំនៅថ្មីនៅលើដីថ្មីទាំងនោះ។

ដោយច្បាំងឈ្នះម៉ិកស៊ីកូក្នុងឆ្នាំ១៥២២ នោះពួកអេស្ប៉ាញ បានពង្រីកទៅទៀតនូវទីតាំងរបស់ខ្លួនក្នុងអឌ្ឍគោលខាងលិច។ ការរកឃើញជាបន្តបន្ទាប់ បានបន្ថែមទៅនឹងការយល់ដឹងរបស់អឺរ៉ុបនូវអ្វី ដែលឥឡូវ

នេះឱ្យឈ្មោះថា សហរដ្ឋអាមេរិក នោះ បន្ទាប់ពីជនជាតិអ៊ីតាលីឈ្មោះ Amerigo Vespucci ដែលបានសរសេរដំណើររឿងដ៏គួរឱ្យជក់ចិត្តស្តីពីដំណើររបស់គាត់ទៅកាន់ «ពិភពថ្មី» មួយនោះ។ នៅត្រឹមឆ្នាំ១៥២៩ ផែនទីដែលគួរឱ្យជឿបានស្តីពីទ្រង់ទ្រាយឆ្នេរសមុទ្រអាត្លង់ទិក ចេញពី Labrador ទៅ Tierra Del Fuego បានត្រូវគេគូរឡើងថ្មីបើវាត្រូវស៊ីពេលជាងមួយសតវត្សទៀតមុននឹងគេបោះបង់ចោលសេចក្តីសង្ឃឹមថា នឹងរកឃើញ «ច្រកពាយ័ព្យ» ទៅកាន់អាស៊ីនោះក៏ដោយ។

ក្នុងចំណោមការរុករកដំបូងដែដ៏សំខាន់បំផុតរបស់ពួកអេស្ប៉ាញនោះគឺ ការរុករករបស់ Hernando De Soto ជាអ្នកប្រយុទ្ធមានជោគជ័យជើងចាស់មួយរូបរបស់អេស្ប៉ាញ ដែលបានអមដំណើរ Franciso Pizzaro ក្នុងអំឡុងពេលច្បាំងដណ្តើមយកប្រទេសប៉េរូ។ ចាក់ចេញពីក្រុងឡាហាវ៉ាន់ នៅក្នុងឆ្នាំ១៥៣៩ នោះបេសកកម្មរបស់ De Soto បានឡើងគោកនៅហ្លរីដា ហើយធ្វើដំណើរកាត់តាម សហរដ្ឋអាម៉េរិក ភាគអាគ្នេយ៍ ទៅដល់ទន្លេ Mississippi ក្នុងការស្វែងរកភោគទ្រព្យ។

ជនជាតិអេស្ប៉ាញម្នាក់ទៀតគឺ Francisco Coronado បានចេញដំណើរពីម៉ិកស៊ិកូ ក្នុងឆ្នាំ ១៥៤០ ក្នុងការស្រាវជ្រាវរកទីក្រុងទេពនិទានទាំង៧ របស់ Cibola។ ការធ្វើដំណើររបស់ Coronado បាននាំគាត់ទៅដល់ Grand Canyon និងកានសាស ប៉ុន្តែមិនបានរកឃើញមាស ឬគេនសម្បត្តិ ដែលមនុស្សរបស់គាត់បានស្វែងរកនោះទេ។ តែយ៉ាងណាក៏ដោយក្រុមរបស់ Coronado បានបន្សល់ទុកឱ្យប្រជាជនតំបន់ នោះនូវជំនូនដ៏ប្រសើរមួយទោះបីជាគាត់មិនបានតាំងចិត្តថានឹងផ្តល់ជូនក៏ដោយ គឺសេះមួយចំនួនបានគេចចេញពីក្រុមរបស់គាត់ទៅរស់នៅទីវាលដ៏ធំនេះ។ ក្នុងរង្វង់ពីរបីជំនាន់មកពួកឥណ្ឌានៅលើវាលយ៉ាង ធំនេះ បានក្លាយទៅជាអ្នកពូកែខាងជិះសេះ ហើយកាន់តែពង្រីកបាននូវវិសាលភាពនៃកន្លែងធ្វើសកម្មភាពរបស់ពួកគេ។ នៅពេលដែលពួកអេស្ប៉ាញរុលចេញពីត្បូងទៅនោះ ផ្នែកខាងជើងនៃសហរដ្ឋអាម៉េរិក សព្វថ្ងៃនេះ ត្រូវបានគេដឹងតៗគ្នាតាមរយៈការធ្វើដំណើរនៃមនុស្ស។

មួយទសវត្សក្រោយមកជនជាតិបារាំងឈ្មោះ Jacques Cartier បានចេញដំណើរតាមកប៉ាលដោយក្តីសង្ឃឹម ថានឹងរកឃើញច្រកសមុទ្រមួយនៅអាស៊ី។ ការធ្វើដំណើររបស់ Cartier តាមបណ្តោយទន្លេ St. Lawrence នោះបានធ្វើជាគ្រឹះ សម្រាប់ការទាមទារយកអាម៉េរិក ខាងជើងរបស់បារាំងដែលមាន រយៈពេលរហូតដល់ឆ្នាំ១៧៦៣។

ក្រោយពីការដួលរលំអាណានិគម Quebec ជាលើកដំបូងរបស់ពួកគេនៅក្នុងទសវត្សឆ្នាំ១៥៤០ នោះពួក Huguenots បារាំង បានប៉ុនប៉ង តាំងទីលំនៅតាមឆ្នេរសមុទ្រហ្លរីដាភាគខាងជើងក្នុងអំឡុងពេល ២ ទសវត្សក្រោយមក។ ពួកអេស្ប៉ាញ ដែលមើលឃើញពួកបារាំងថាជាការគំរាមកំហែងដល់ផ្លូវពាណិជ្ជកម្មរបស់ពួកគេនៅតាមបណ្តោយឈូងសមុទ្រ ស្ទ្រីម (Gulf Stream) នោះបានកម្ទេចអាណានិគមនោះនៅក្នុងឆ្នាំ ១៥៦៥។ តែស្មានមិនដល់ថាមេទ័ពអេស្ប៉ាញឈ្មោះ Pedro Menendez ក៏បែរជាបានបង្កើតភ្លាមៗ នូវទីក្រុងមួយនៅក្បែរនោះគឺ ក្រុង St. Augustine។ នោះគឺជាការតាំងទីលំនៅជាអចិន្ត្រៃយ៍របស់ពួក អឺរ៉ុបលើកដំបូងនៅក្នុងអ្វីដែលឥឡូវនេះក្លាយទៅជា សហរដ្ឋអាម៉េរិក នោះ។

មហាសម្បត្តិដែលហូរចូលទៅក្នុងប្រទេសអេស្ប៉ាញពីទឹកដីអាណានិគមនៅម៉ិកស៊ិកូ កាអ៊ីប និងប៉េរូ នោះបានបង្កឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងដល់មហាអំណាចអឺរ៉ុបដទៃទៀត។ នៅពេលនោះ បណ្តាប្រទេស ដែលលេចមុខមាត់ខ្លាំងតាមសមុទ្រ ដូចជាប្រទេសអង់គ្លេសជាដើម ហើយដែលបានទាក់ចិត្តដោយសារ

តែជោគជ័យ នៃការវាយឆ្មក់របស់ Francis Drake ទៅលើនាវាដឹកទំនិញនិងសម្បត្តិរបស់អេស្ប៉ាញ នោះបានចាប់ផ្តើមយកចិត្តទុកដាក់នឹងពិភពថ្មីនោះហើយ។

**គ-ដំណើរជុំវិញផែនដីលើកទី១**

នៅឆ្នាំ១៥១៩ លោក ម៉ាសេឡង់ ជនជាតិព័រទុយហ្គាល់ បានធ្វើដំណើរជុំវិញពិភពលោក។ គាត់ចេញដំណើរជាមួយនាវា ៥គ្រឿង និងនាវិករាប់រយនាក់ ដោយឆ្លងកាត់មហាសមុទ្រអាត្លង់ទិករហូតដល់ឆ្នេរតំបន់ រីយោ(Rio) រួចបន្តដំណើរទៅទិសខាងត្បូង។ លោក ម៉ាសេឡង់ បានរកឃើញភាគខាងត្បូងនៃទ្វីបអាម៉េរិក តាមច្រកមួយ (បច្ចុប្បន្ន ឈ្មោះច្រក ម៉ាសេឡង់) ហើយបន្តដំណើរទៅមហាសមុទ្រប៉ាស៊ីហ្វិក។

ដំណើរឆ្លងកាត់មហាសមុទ្រនេះមានរយៈពេលប្រហែល៤ខែដោយមិនបានជួបប្រទះដីសោះ។ ពួកគាត់បានទៅដល់កម្រងកោះ ម៉ារីយ៉ាន (Archipel des Mariannes) រួចទៅដល់ហ្វីលីពីន ដែលនៅទីនោះលោក ម៉ាសេឡង់ បានស្លាប់ក្នុងឆ្នាំ១៥២១ ដោយចម្បាំងនឹងជនម្ចាស់ស្រុក។ សហការីរបស់ លោកគឺ អនុនាវីឯក សាបាជាង ដែលកាណូ (Sabastien del cano) ទទួលបន្ទុកនាវាគ្រឿងទេសចុងក្រោយបានត្រឡប់ចូលដល់ប្រទេសអេស្ប៉ាញវិញ នៅឆ្នាំ១៥២២ ជាមួយអ្នកដែលរួចពីគ្រោះថ្នាក់តែ១៨នាក់ប៉ុណ្ណោះ។ ដំណើររុករកនេះជាភស្តុតាងបង្ហាញថា ផែនដីមានរាងមូល។

**ឃ-អង់គ្លេស និងបារាំងរកឃើញពិភពថ្មី**

ប្រទេសនៅអឺរ៉ុបខាងជើងបានរកឃើញដីថ្មីដែរ តាមរយៈការរុករកផ្នែកខាងជើងតាមផ្លូវមួយសំដៅទៅប្រទេសចិន។ នៅឆ្នាំ១៤៩៧ ដោយបំពេញការងារថ្វាយស្តេចអង់គ្លេស លោក ហ្សង់កាបូ (Jean Cabot) ជនជាតិអ៊ីតាលី បានរកឃើញតំបន់ឡាប្រាដ័រ (Labrador)។ នៅឆ្នាំ១៥៣៤ ជនជាតិបារាំង លោក ហ្សាក់កាដេ (Jacques Cartier) រកឃើញពាមសាំងឡូរ៉ង់ (Saint Lorent) ហើយសំចតនៅកាណាដា។

## ៣.២-ការច្បាំងដណ្តើមយកដី

**ក-ពួកព័រទុយហ្គាល់ និងអេស្ប៉ាញ បែងចែកពិភពលោក**

បំណងនៃការរុករកដ៏ធំ គឺការរកផ្លូវថ្មីមួយទៅកាន់ឥណ្ឌា។ ប៉ុន្តែក្រោយការបង្ហាញដោយពួកនាវិកស្តីពីការរកឃើញដីថ្មីមក ស្តេចនៃប្រទេសអេស្ប៉ាញ និងព័រទុយហ្គាល់ប្រាថ្នាចង់ធ្វើជាម្ចាស់នៃដែនដីទាំងនោះ។

នៅឆ្នាំ១៤៩៤ ស្តេចប៉ាប បានធ្វើអន្តរាគមន៍ដើម្បីកំណត់តំបន់ឥទ្ធិពលព័រទុយហ្គាល់ និងអេស្ប៉ាញ។ ព្រះអង្គដឹកនាំធ្វើការបែងចែកពិភពលោកមួយរវាងប្រទេសទាំងពីរនេះ។ តាមសន្ធិសញ្ញាទ័រដឺស៊ីឡាស (Tordesillas) បានកំណត់ឱ្យអេស្ប៉ាញនូវទឹកដីផ្នែកខាងលិចនៃខ្សែស្របពីជើងមកត្បូង គូសនៅក្នុង មហាសមុទ្រអាត្លង់ទិកក្នុងកម្រិតខ្សែបណ្តោយទី៤៧ដឺក្រេ និងប្រទេសព័រទុយហ្គាល់នូវទឹកដីប៉ែកខាងកើត។

**ខ-ពួកព័រទុយហ្គាល់កាន់កាប់តំបន់កំពង់ផែ**

ពួកព័រទុយហ្គាល់គ្រាន់តែប្រាថ្នាក្លាយទៅជាម្ចាស់សេដ្ឋកិច្ចជាមួយឥណ្ឌាតែប៉ុណ្ណោះ។ ពួកគេចូលចតនៅតាមកំពង់ផែនៃឆ្នេរតំបន់អាហ្វ្រិក ឥណ្ឌា រហូតដល់ចិន និងជប៉ុន។ នៅក្នុងមហាសមុទ្រឥណ្ឌាពួក ព័រទុយហ្គាល់ ប្រើកម្លាំងទ័ពដណ្តើមយកទីតាំងជំនួញពីអារ៉ាប់។ នៅឆ្នាំ១៥១០ ពួកព័រទុយហ្គាល់ បានកាន់កាប់កំពង់ផែ ហ្គ័រ(Goa) នៅផ្នែកខាងលិចនៃប្រទេសឥណ្ឌា។ នៅឆ្នាំ១៥១១ ពួកព័រទុយហ្គាល់ បានទៅដល់ម៉ាឡាកា បន្ទាប់មកប្រជុំកោះម៉ូលូក(Moluques) ព្រមទាំងម៉ាកាវ។ ពួកព័រទុយហ្គាល់បានបន្តទាក់ទងផ្ទាល់ជាមួយចិន និងជប៉ុន ដើម្បីទិញគ្រឿងទេស សូត្រ ប៉សឺឡែន។

ពួកព័រទុយហ្គាល់ បានជំនួសពួកអារ៉ាប់ ជាអ្នកផ្គត់ផ្គង់ទៅឱ្យតំបន់អឺរ៉ុបនូវផលិតផលដ៏ប្រណីតៗ ពីតំបន់ខាងកើត។

ពាណិជ្ជកម្មជាជំនួញផ្តាច់មុខរបស់រដ្ឋ តាមរយៈការត្រួតពិនិត្យផ្ទាល់ពីស្តេចព័រទុយហ្គាល់។ ជារៀងរាល់ឆ្នាំនៅរដូវផ្ការីក កប៉ាល់ធំៗបួន ឬប្រាំគ្រឿងចាកចេញពីលីស្បោន (Lisbonne)។ នៅរដូវស្លឹកឈើជ្រុះ កប៉ាល់ទាំងនោះចាកចេញទៅវិញ ផ្ទុកទៅដោយម្រេច សំពត់ អំបោះ គ្រឿងទេស ថ្មមានតម្លៃ សូត្រ ទឹកអប់ និងប៉សឺឡែន។ ការធ្វើពាណិជ្ជកម្មផ្តាច់មុខនៅអឺរ៉ុបនាំឱ្យព័រទុយហ្គាល់ចំណេញប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់។

ចំពោះបេសកជនទាំងឡាយ ដែលមានភារកិច្ចផ្សព្វផ្សាយសាសនាគ្រិស្ត ត្រូវធ្វើដំណើរតាមពួកជំនួញ។ ជារឿយៗ អ្នកដែលរស់នៅក្នុងតំបន់ត្រួតត្រាដោយពួកព័រទុយហ្គាល់ ចាំបាច់ក្លាយទៅជាគ្រិស្តសាសនិក ហើយវិហារអ៊ីស្លាមមួយចំនួនក្លាយទៅជាវិហារកាតូលិក។ នៅអាម៉េរិកខាងត្បូងក្នុងសតវត្សទី១៦ ពួកព័រទុយហ្គាល់ធ្វើអាណានិគមលើប្រទេសប្រេស៊ីល ហើយនាំពួកទាសករពីអាហ្វ្រិកទៅកាន់ទីនោះដើម្បីបម្រើការងារកសិកម្ម មានដាំអំពៅ និងកម្មករអណ្តូងរ៉ែមាស។

### គ-ពួកអេស្ប៉ាញដណ្តើមបានចក្រភពមួយ

ផ្ទុយពីពួកព័រទុយហ្គាល់ ពួកអេស្ប៉ាញប្រាថ្នាចង់បានទឹកដីដ៏ធំធេង។ នៅឆ្នាំ១៥១៩ លោក ក័រតែស (Cortes) ជាមួយសហការី ៦០០នាក់ ប្រដាប់ដោយអាវុធកាំភ្លើងធំចំនួន៦ និងសត្វសេះចំនួន១៦ បានទៅបំផ្លាញចក្រភពអាស្តែកនៅម៉ិកស៊ិក ធ្វើឱ្យទីនោះក្លាយទៅជាដែនដីអេស្ប៉ាថ្មី។ ពួកអាស្តែកមានជំនឿស៊ប់លើរឿងព្រេង ពួកគេជឿថា ពួកអេស្ប៉ាញជាអាទិទេពដែលជួយពួកគេដូចរឿងព្រេង។

នៅឆ្នាំ១៥៣១ អ្នកផ្សងព្រេងជាតិអេស្ប៉ាញពីររូប គឺលោក ពីហ្សា (Pizazze) និងអាល់ម៉ាក្រូ (Almagro) ចុះចតនៅតាមឆ្នេរខាងលិចអាម៉េរិកខាងត្បូង ហើយចូលលុកុយចក្រភពអាំងកា ដោយការធក់ប្លន់បាញ់សម្លាប់ និងដុតបំផ្លាញរាជធានីយ៉ាងសាហាវឃោរឃៅ។ ប្រការនេះទើបកើតមានតំបន់កាស្ទីថ្មី ឬញូវ កាសល(Novelle Castille) ដែលមានទីក្រុងឈ្មោះលីម៉ា។

## ៣.៣-ចក្រភពអាណានិគមនិយម

### ក-ចក្រភពអេស្ប៉ាញ

ជាចក្រភពដ៏រឹងមាំ កើតឡើងនៅពាក់កណ្តាលសតវត្សទី១៦។ ដើម្បីគ្រប់គ្រងដែនដីអាណានិគមនៅអាម៉េរិក ពួកអេស្ប៉ាញ បានក្រុមប្រឹក្សាមួយមានឈ្មោះថាក្រុមប្រឹក្សាឥណ្ឌា តាំងទីនៅក្រុងសេវីល(Seville) រួចមកតាំងនៅម៉ាឌ្រីត ដែលដឹកនាំរដ្ឋបាលអាណានិគម ហើយស្តេចអេស្ប៉ាញចាត់តាំងអ្នកជំនួសព្រះអង្គពីររូបឱ្យទៅគ្រប់គ្រងនៅម៉ិកស៊ិកកូ និងនៅលីម៉ា។

ពួកស្បែកស ដែលមកពីអេស្ប៉ាញ ឬកើតនៅអាម៉េរិកសុទ្ធតែជាអ្នកដឹកនាំ។ ស្តេចបានផ្តល់ឋានៈ ឱ្យពួកនេះ ជាមនុស្សខ្លាំង(ស្តេចត្រាញ់) ដើម្បីត្រួតត្រាលើប្រជាជនឥណ្ឌាទាំងឡាយណា ដែលរស់នៅក្រោមឱវាទរបស់ពួកគេ។ ដើម្បីដឹងគុណចំពោះស្តេច ពួកគេត្រូវទារពន្ធដារ ធ្វើឱ្យពួកឥណ្ឌាគោរពស្តេចអេស្ប៉ាញ ហើយធ្វើឱ្យពួកនេះក្លាយទៅជាគ្រិស្តសាសនិកទាំងអស់។

អាណានិគមជនមកពីប្រទេសអេស្ប៉ាញធ្វើអាជីវកម្មដ៏ធ្ងន់ធ្ងរចំពោះកម្មករឥណ្ឌាភេទស្រី។ ពួកឥណ្ឌា ឬពួកទាសករចេញទៅដាំអំពៅ កាកាវ ថ្នាំជក់ ចិញ្ចឹមសត្វចៀម ទៅរោងជាតម្បាញ ពិសេសធ្វើការក្នុងអណ្តូងរ៉ែមាសនៅម៉ិកស៊ិកក និងអណ្តូងរ៉ែប្រាក់នៅប៉ូតូស៊ី(Potosi) នៃប្រទេសប៉េរូ។ ពេលនោះមានការឆ្លងមេរោគរាតត្បាត គឺ ជំងឺមិនស្គាល់ឈ្មោះ នៅអាម៉េរិកមានជំងឺអុតធំដែលធ្វើឱ្យឆ្លងរីករាលដាល ហើយប្រជាជនឥណ្ឌា

ថយចំនួនយ៉ាងឆាប់រហ័ស។ ក្នុងចំនួនប្រជាជនប្រហែល៨០លាននាក់ ដែលបានរាប់ចំនួនតាំងពីមានការមកដល់អាម៉េរិករបស់ពួកអឺរ៉ុប គឺមាននៅសល់ទាំងអស់ប្រហែល ១០លាននាក់ប៉ុណ្ណោះក្នុងមួយសតវត្សក្រោយមក។

ដើម្បីជំនួសនូវកង្វះមនុស្សធ្វើការងារ ពួកអេស្ប៉ាញបានចាប់ផ្តើមធ្វើដូចពួកព័រទុយហ្គាល់ដែរក្នុងការនាំចូលទាសករស្បែកខ្មៅមកពីទ្វីបអាហ្វ្រិក។

**ខ-ទាសៈពាណិជ្ជកម្ម (ការដឹកនាំជនស្បែកខ្មៅទៅលក់)**

ដើម្បីបំពេញកាងារដាំដុះដោយកម្លាំងពលកម្ម ពួកព័រទុយហ្គាល់ និងពួកអេស្ប៉ាញអនុវត្តនូវអ្វីមួយដែលគេហៅថា "ទាសៈពាណិជ្ជកម្ម"។ កប៉ាល់ទាំងឡាយចេញដំណើរពីទ្វីបអឺរ៉ុបទៅទ្វីបអាហ្វ្រិកដោយផ្ទុកកំណាត់គ្រឿងអលង្ការ វត្ថុធ្វើពីកែវ និងទាសករស្បែកខ្មៅដែលត្រូវដឹកជញ្ជូនយកទៅលក់នៅអាម៉េរិក។

ទាសករជាច្រើនត្រូវស្លាប់ក្នុងរយៈពេលឆ្លងកាត់មហាសមុទ្ទ គឺ ជាដើមហេតុនៃប្រជាជនស្បែកខ្មៅនៅលើទឹកដីអាម៉េរិក។

បន្តិចម្តងៗ ការលាយឡំពូជសាសន៍រវាងពួកអឺរ៉ុប ពួកអាំងឌីយាង និងពួកអាំងឌីយាង និងពួកស្បែកខ្មៅ ជាកំណើតនៃប្រជាជនអាម៉េរិកឡាទីនបច្ចុប្បន្ន។

**គ-ពួកបារាំងនិងអង់គ្លេសតាំងទីនៅអាម៉េរិកខាងជើង**

មហាអំណាចឯទៀតមិនយល់ព្រមចំពោះសន្ធិសញ្ញាទ័កដឺស៊ីឡាស(Tordesillas) ដែលផ្តល់ដល់ប្រទេសអេស្ប៉ាញ និងព័រទុយហ្គាល់នូវដែនដីថ្មី។ ស្តេចហ្វ្រង់ស្វ័ទី១ មានអារម្មណ៍ថាបានទទួលផលបន្តិចបន្តួចដែរនូវចំណែកដែនដីរកឃើញថ្មីនេះ។ ពេលចុះចតនៅសាំងឡូរ៉ង់ (Saint Lornt) លោក ហ្សាក់កាជេ (Jacques Cartier) បានដៅបង្ហាញផ្លូវសម្រាប់រុករកក្នុងពេលអនាគត។ នេះគឺ ជាដើមហេតុនៃការចូលចតរបស់ពួកបារាំងនៅកេបិច(Quebec)។ ចំណែកពួកអង់គ្លេសគេចេញដំណើរជាច្រើនដង ដើម្បីចូលចតនៅតាមឆ្នេរនៃដែនដីអាម៉េរិកខាងជើង។

## ៤.បដិវត្តន៍គហបតីនៅអឺរ៉ុប និងអាម៉េរិក

### ៤.១-បដិវត្តន៍គហបតីនៅអង់គ្លេស

#### ៤.១.១-របបរាជានិយមផ្តាច់ការនៅអង់គ្លេស

ម្ចាស់ក្សត្រីអេលីហ្សាប៊ែតមិនមានរាជបុត្រាឡើយ ហើយសាច់ញាតិជិតស្និតបំផុតរបស់ទ្រង់គឺបងប្អូនជីដូនមួយរបស់ទ្រង់ព្រះនាមជេមស៍ ស្កាត។ ដោយក្លាយជាស្តេចស្កុតឡែនរួចហើយ ព្រះអង្គម្ចាស់ជេមស៍ស្កាតបាន ក្លាយជាស្តេចជេមទី១ របស់អង់គ្លេសនៅក្នុងឆ្នាំ១៦០៣។ បើទោះបីជាអង់គ្លេស និងស្កុតឡែនមិនបានបង្រួបបង្រួមគ្នារហូតដល់ឆ្នាំ១៧០៧ ក៏ដោយ ប៉ុន្តែពេលនោះប្រទេសទាំងពីរនេះមានមេដឹកនាំរួម។

បញ្ហារបស់ព្រះអង្គម្ចាស់ស្តេចជេមស៍៖ ព្រះអង្គម្ចាស់ជេមស៍ទទួលមរតកបញ្ហាដែលមិនទាន់ ដោះស្រាយនៅក្នុងរាជ្យរបស់ម្ចាស់ក្សត្រីអេលីហ្សាប៊ែត។ ការតស៊ូដ៏លំបាកបំផុតរបស់ទ្រង់ជាមួយសភាតំណាងរាស្ត្រគឺបញ្ហាហិរញ្ញវត្ថុ។ ក្នុងការបន្ថែម ជេមស៍ប្រឆាំងជាមួយពួកពូរីតាន ដែលជាសមាជិកសភាតំណាងរាស្ត្រ។ ពួកពូរីតានសង្ឃឹមថាទ្រង់ នឹងធ្វើកំណែទម្រង់ដើម្បីបន្សុទ្ធព្រះវិហារអង់គ្លេសឱ្យប្រតិបត្តិ កាតូលិក។ ប៉ុន្តែលើកលែងតែការយល់ព្រមនៅក្នុងបកប្រែគម្ពីរប៊ីបថ្មីមួយ ទ្រង់បានបដិសេធនៅក្នុងការធ្វើកំណែទម្រង់តាមពួកពូរីតាន។ ព្រះអង្គម្ចាស់សាលទី១ វាយប្រយុទ្ធជាមួយសភាតំណាងរាស្ត្រ៖ នៅក្នុងឆ្នាំ១៦២៥ ព្រះអង្គម្ចាស់ជេមស៍ទី១ចូលទិវង្គត។ រាជបុត្ររបស់ទ្រង់ព្រះអង្គម្ចាស់ឆាលទី១បានឡើងគ្រងរាជ្យបន្ត។ ព្រះអង្គម្ចាស់ឆាលតែងតែត្រូវការលុយ ដោយសារទ្រង់ធ្វើសង្គ្រាមជាមួយអេស្ប៉ាញ និងបារាំង។ ជាច្រើនលើកនៅពេល

ដែលសភាតំណាងរាស្ត្របដិសេធក្នុងការផ្ដល់ថវិកាដល់ទ្រង់ ទ្រង់បានរំលាយសភាតំណាងរាស្ត្រចោល។ ត្រឹមឆ្នាំ១៦២៨ ព្រះអង្គម្ចាស់ឆាលត្រូវបានបង្ខំឱ្យកោះហៅសភាតំណាងរាស្ត្រសាជាថ្មី។ នៅពេលនោះពួកគេបដិសេធនៅក្នុងការផ្ដល់ថវិកាដល់ទ្រង់ ដ៏រាបណាទ្រង់ឡាយព្រះហស្តលេខាលើឯកសារមួយ ដែលត្រូវបានគេស្គាល់ថាញត្តិនៃសិទ្ធិ។ នៅក្នុងញត្តិនេះ ស្ដេចយល់ព្រម៤ចំណុច៖ (១) ទ្រង់នឹងមិនចាប់ប្រជានុរាស្ត្រដាក់គុកដោយគ្មានមូលហេតុឡើយ។(២)ទ្រង់នឹងមិនយកពន្ធដោយគ្មានការយល់ព្រមពីសភាតំណាងរាស្ត្រឡើយ។ (៣) ទ្រង់នឹងមិនដាក់ទាហានឱ្យស្ថិតនៅជាលក្ខណៈ ឯកជនឡើយ។ (៤)ទ្រង់នឹងមិនដាក់ច្បាប់អាជ្ញាសឹកក្នុងពេលគ្មានសង្គ្រាមឡើយ។ បន្ទាប់ពីយល់ព្រមជាមួយញត្តិ ស្ដេចឆាលមិនបានយកចិត្តទុក ចំពោះវា។ បើទោះបីជាយ៉ាងដូច្នេះក៏ដោយញត្តិនេះមាន សារៈសំខាន់ណាស់។ ចំណុចទាំង៤ នៅក្នុងញត្តិនេះបង្ហាញថាច្បាប់ខ្ពស់ជាងស្ដេចទៅទៀត។ គំនិតនេះផ្ទុយគ្នាជាមួយទ្រឹស្ដីរាជាធិបតេយ្យផ្ដាច់ការ។ នៅក្នុងឆ្នាំ១៦២៩ ព្រះអង្គម្ចាស់ឆាលបានរំលាយសភាតំណាងរាស្ត្រ និងបដិសេធការប្រជុំសភាជាថ្មី។ ដើម្បីទទួលបានថវិកា ទ្រង់បានដាក់ចេញនូវថ្លៃសេវា និងការផាកពិន័យគ្រប់ប្រភេទលើប្រជាជនអង់គ្លេស។ ចាប់ពីពេលនោះមកប្រជាប្រិយភាពរបស់ទ្រង់បានធ្លាក់ចុះជាបន្តបន្ទាប់[445]។

### ៤.១.២-បដិវត្តន៍គហបតី និងសង្គ្រាមស៊ីវិល

ព្រះអង្គម្ចាស់ឆាលបានប្រឆាំងជាមួយពួកពូរីតា តាមរយៈឧបត្ថម្ភដល់ ការប្រារព្ធក្បួនពិធីនៅក្នុង ព្រះវិហារអង់គ្លីកាន។ នៅក្នុងឆ្នាំ១៦៣៧ ព្រះអង្គម្ចាស់ឆាលព្យាយាមនៅក្នុងបង្ខំឱ្យពួកប្រេសប៊ីធើរៀនស្កុត ទទួលយកសៀវភៅបន់ស្រន់មួយរបស់អង់គ្លីកាន។ ទ្រង់ចង់ឱ្យព្រះរាជាណាចក្រទាំងពីររបស់ទ្រង់ដើរតាមសាសនាតែមួយ។ ពួកស្កុតបានបះបោរប្រឆាំង ប្រមូលផ្ដុំទាហាដ៏ធំមួយ និងគំរាមកំហែងនៅក្នុងការឈ្លានពានអង់គ្លេស។ ដើម្បីប្រឈមជាមួយគ្រោះថ្នាក់នេះ ព្រះអង្គម្ចាស់ឆាលត្រូវការថវិកា ដែលទ្រង់អាចទទួលបានតាមរយៈការ កោះហៅសភាតំណាងរាស្ត្រប្រជុំ។ ហេតុនេះបានផ្ដល់ឱកាលមួយឱ្យសភាតំណាងរាស្ត្រប្រឆាំងទ្រង់។

សង្គ្រាមផ្ដួលរំលំព្រះមហាក្សត្រ៖ អំឡុងសរទរដូវឆ្នាំ១៦៤១ សភាតំណាងរាស្ត្រអនុម័តច្បាប់មួយចំនួនដើម្បីកម្រិតអំណាចរបស់រាជវង្ស។ ដោយកំហឹង ព្រះអង្គម្ចាស់ឆាលព្យាយាមនៅក្នុងការចាប់ខ្លួន មេដឹកនាំសភាតំណាងរាស្ត្រនៅក្នុងខែមករា ឆ្នាំ១៦៤២ ប៉ុន្តែ លោកបានរត់គេចខ្លួន។ ដោយកំហឹងដូចគ្នា ហ្វូងមហាជននៅក្រុងឡុងដ៍បានប្រមូលផ្ដុំខាងក្រៅរាជវាំង។ ព្រះអង្គម្ចាស់ឆាលរត់គេចពីទីក្រុងឡុងដ៍ និងប្រមូលទ័ពមួយក្រុមនៅអង់គ្លេសភាគខាងជើង ជាទីកន្លែងដែលប្រជាជនមានភក្តីភាពចំពោះទ្រង់។ ចាប់ពីឆ្នាំ១៦៤២ ដល់ឆ្នាំ១៦៤៩ អ្នកគាំទ្រ និងអ្នកប្រឆាំងព្រះអង្គម្ចាស់ឆាលបានវាយប្រយុទ្ធគ្នានៅក្នុងសង្គ្រាមស៊ីវិលនៅអង់គ្លេស។ អ្នកទាំងឡាយណាដែលនៅបន្តមានភក្តីភាពចំពោះស្ដេចឆាល ត្រូវបានគេហៅថាអ្នករាជានិយម ឬ**កាវ៉ាល្យេ**។ នៅមួយផ្នែកទៀតពួកពូរីតាន គាំទ្រសភាតំណាងរាស្ត្រ។ ដោយសារតែពួកពូរីតានទាំងនេះកាត់សក់ពួកគេខ្លីលើត្រចៀក ពួកកាកាវ៉ាល្យេហៅពួកគេថា**ពួកក្បាលមូល។** នៅពេលប្រយុទ្ធគ្នាដំបូងភាគីទាំងសងខាងមិនមានភាគីណាមានប្រៀបលើភាគីណាឡើយ។ ប៉ុន្តែ ត្រឹមឆ្នាំ១៦៦៤ ពួកពូរីតានបានផ្ដល់ជំនួយដល់ឧត្តមសេនីយ៍មួយរូបឈ្មោះអូលីវើ ក្រំវែល(Olivier Cromwell) ដែលអាចយកឈ្នះលើសង្គ្រាម។ នៅក្នុងឆ្នាំ១៦៤៥ កងទ័ពគំរូថ្មីរបស់ក្រុមវិលបានចាប់ផ្ដើមយកជ័យជំនះលើពួក កាវ៉ាលីយី ហើយជ័យជម្នះបានត្រឡប់ឆ្ពោះទៅរកពួកពូរីតាន។ នៅក្នុងឆ្នាំ ១៦៤៧ ពួកគេបានចាប់ព្រះមហាក្សត្រ ឃុំខ្លួន។ នៅក្នុងឆ្នាំ១៦៤៩ ក្រំវែល

[445] គួង គីនី, *ប្រវត្តិសាស្ត្រពិភពលោក*, ឆ្នាំ២០២២, ទំព័រ៣៣២។

និងពួកពូរីតានបាននាំយកព្រះអង្គម្ចាស់ឆាលទៅកាត់ទោសសម្រាប់អំពើក្បត់ ជាតិប្រឆាំងសភាតំណាងរាស្ត្រ។ ពួកគេបានរកឃើញថាទ្រង់មានទោស និងកាត់ទោសប្រហារជីវិតទ្រង់។ ការប្រហារជីវិតព្រះអង្គម្ចាស់ឆាលគឺជាការធ្វើបដិវត្តមួយ។ ព្រះមហាក្សត្រជាញឹកញាយត្រូវបានទម្លាក់ពីតំណែង, សម្លាប់នៅក្នុងសមរភូមិ, ឬសម្លាប់ដោយអាថ៌កំបាំង។ ប៉ុន្តែ មិនធ្លាប់មានពីមុនមកទេដែលព្រះមហាក្សត្រត្រូវបានគេកាត់ទោស និងប្រហារជីវិតចំពោះសាធារណជនបែបនេះ។

ការដឹកនាំរបស់ក្រំវែល៖ ឥឡូវនេះក្រំវែលគឺជាអ្នកស្នងតំណែង។ នៅក្នុងឆ្នាំ១៦៤៩ លោកបានបោះបង់រាជាធិបតេយ្យ និងសភាពជាន់ខ្ពស់។ លោកបានបង្កើតទម្រង់រដ្ឋាភិបាលបែបសាធារណរដ្ឋមួយដែលមានឈ្មោះ ថា**ខំមិនវែល។** នៅក្នុងឆ្នាំ១៦៥៣ ក្រំវែលបានបញ្ជូនសមាជិកសភាតំណាងរាស្ត្រដែលនៅសេសសល់ទៅផ្ទះវិញ។

ជំនួយការរបស់ក្រំវែល ឈ្មោះ ចន ឡាំបឺត បានពង្រាងរដ្ឋធម្មនុញ្ញមួយដែលជារដ្ឋធម្មនុញ្ញសម័យទំនើបដំបូងរបស់ប្រទេសទាំងឡាយនៅប្រទេសអឺរ៉ុប។ ប៉ុន្តែ ក្រំវែល ដាយថាហេតុបានហែកឯកសារនោះចោល និងបានក្លាយជាមេដឹកនាំ យោធាផ្តាច់ការ។ ក្រំវែលស្ទើរតែភ្លាមៗបង្ក្រាបការបះបោរមួយនៅអៀរឡង់។ ប្រទេសអង់គ្លេសបានដាក់អាណានិគម លើអៀរឡង់នៅក្នុងទសវត្សរ៍ឆ្នាំ១១០០ ស្ថិតនៅក្រោមព្រះអង្គម្ចាស់ហេនរីទី២។ ព្រះអង្គម្ចាស់ហេនរីទី៣ និងរាជបុត្ររបស់ទ្រង់បានាំយកប្រទេសនេះឱ្យស្ថិតនៅក្រោមការត្រួតត្រារបស់អង់គ្លេសនៅអំឡុងទសវត្សឆ្នាំ១៥០០។ នៅក្នុងឆ្នាំ១៦៤៩ ក្រំវែល បានធ្វើដំណើរទៅដល់ ឆ្នេរសមុទ្រអៀកឡង់ជាមួយនឹងកងទ័ពមួយក្រុម និងបង្ក្រាបការបះបោរ។ ទ្រង់បានដណ្តើមកាន់កាប់ដី និងផ្ទះរបស់ពួកអៀឡង់ និងបានផ្តល់វាឱ្យទៅទាហានអង់គ្លេស។ ការវាយប្រយុទ្ធប្រឆាំង ជំងឺប៉េស្ត និងគ្រោះអត់ឃ្លានបានសម្លាប់មនុស្សរាប់ម៉ឺននាក់។

នៅក្នុងប្រទេសអង់គ្លេសក្រំវែល និងពួកពូរីតានសម្លឹងទៅរកការធ្វើកំណែទម្រង់សង្គម។ ពួកគេបានបង្កើតច្បាប់នានាដើម្បីលើកកម្ពស់សីលធម៌ពូរីតាន និងលុបបំបាត់ចោលសកម្មភាពទាំងឡាយណា ដែលពួកគេរកឃើញថាជាអំពើបាប ក្នុងនោះមានដូចជារោងកុន ព្រឹត្តិការណ៍កីឡា និងការរាំជាដើម។ បើទោះបីជាលោកគឺជាពូរីតានដ៏តឹងរឹងមួយរូបក៏ដោយ ក្រំវែលចូលចិត្តការអត់ឱនខាងសាសនាសម្រាប់គ្រិស្តបរិស័ទទាំងអស់លើកលែងតែកាតូលិក។ លោកថែមទាំងបានអនុញ្ញាតឱ្យពួកជ្វីហ្វត្រឡប់មកកាន់ប្រទេសអង់គ្លេសវិញថែមទៀតផង បន្ទាប់ពីពួកគេត្រូវបាននិរទេសចេញពីអង់គ្លេសនៅក្នុងឆ្នាំ១២៩០។

### ៤.១.៣-របបរាជធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ

នៅឆ្នាំ១៦៨៥ បុត្រាស្តេចសាលទី២ នាម ហ្សាក់ទី២ បានឡើងគ្រងរាជ្យបន្ត។ ព្រះអង្គជាស្តេចកាតូលិក បានធ្វើឱ្យពួកអ្នកប្រកាន់តឹងប្រូតេស្តង់ក្តៅក្រហាយ។ ឯបុត្រីហ្សាក់ទី២ ព្រះនាងម៉ារី និងព្រះរាជសុណិសាព្រះនាម ហ្គីយ៉ូមដូរ៉ង់ (Guillaume d'orange) ជាអ្នកគោរពប្រូតេស្តង់ ទទួលបានការគាំទ្រជាខ្លាំងពីប្រជាជន និងលើកឱ្យសោយរាជ្យនៅអង់គ្លេស។ ស្តេចហ្សាក់ទី២ ភៀសខ្លួនចេញ ចំណែកហ្គីយ៉ូមដូរ៉ង់ដែលមកពីហូឡង់ បានទទួលអបអរសាទរយ៉ាងរាក់ទាក់។ នេះគឺ ជាបដិវត្តន៍មួយដ៏ជោគជ័យបំផុត ដែលធ្វើឱ្យពួកអ្នកប្រកាន់ច្បាប់តឹងរ៉ឹងក្តៅក្រហាយ។

នៅខែមករា ឆ្នាំ១៦៨៩ ស្តេចហ្គីយ៉ូមដូរ៉ង់ និងម្ចាស់ក្សត្រីម៉ារី ត្រូវបានប្រកាសជាមហាក្សត្រ និងមហាក្សត្រី នៅប្រទេសអង់គ្លេស ក្រោយពីព្រះអង្គទាំងពីរ បានប្រកាសទទួលស្គាល់រាល់សេចក្តីសម្រេចរបស់សភា

ក្នុងការកម្រិតអំណាចរបស់ស្តេច។ ចាប់ពីពេលនោះមកអង់គ្លេសលែងជារាជានិយមផ្តាច់ការដូចមុន ហើយបានក្លាយជារាជាធិបតេយ្យអាស្រ័យសភា។

## ៤.២-បដិវត្តន៍ និងដំណើរឆ្ពោះទៅរកឯករាជ្យអាមេរិក

ចាប់តាំងពីក្រោយពេលដែលគ្រីស្តូហ្វ កូឡុំ រកឃើញទ្វីបអាម៉េរិក នៅចុងសតវត្សទី១៥ មហាអំណាចនៅអឺរ៉ុប រួមមាន អេស្ប៉ាញ ព័រទុយហ្គាល់ បារាំង និងអង់គ្លេស បាននាំគ្នាពង្រីកអាណានិគមរបស់ខ្លួន នៅលើដែនដីថ្មីនេះ ដោយអេស្ប៉ាញ និងព័រទុយហ្គាល់ កាន់កាប់តំបន់ អាម៉េរិក ខាងត្បូង ចំណែកឯបារាំង និងអង់គ្លេសវិញ កាន់កាប់អាម៉េរិក ខាងជើង (នៅត្រង់មុំសហរដ្ឋអាម៉េរិក និងកាណាដាសព្វថ្ងៃ)។

ក៏ប៉ុន្តែ គិតត្រឹមសតវត្សទី១៨ ដែនដីអាម៉េរិកខាងជើងភាគច្រើនស្ថិតក្រោមការកាន់កាប់របស់បារាំង។ ហួតមកទល់នឹងពេលបច្ចុប្បន្ននេះ គេឃើញមានទីក្រុងធំៗជាច្រើន នៅអាម៉េរិក ខាងជើង នៅតែរក្សាឈ្មោះជាបារាំង ដូចជា Montréal នៅកាណាដា និង Nouvelle-Orléan (ដែលបច្ចុប្បន្នហៅជាភាសាអង់គ្លេសថា New Orlean), Détroit និង Saint-Louis នៅសហរដ្ឋអាម៉េរិក ជាដើម។ ចំណែកអង់គ្លេសវិញ កាន់កាប់ដែនដីតូចជាងបារាំង គឺដែនដី នៅតាមបណ្តោយឆ្នេរប៉ែកខាងកើតសហរដ្ឋអាម៉េរិក ដែលគេហៅថា ដែនដីអាណានិគមទាំង១៣ ហើយដែលក្រោយមកនឹងត្រូវក្លាយជារដ្ឋដំបូងបង្អស់ នៃសហរដ្ឋអាម៉េរិក។ ក៏ប៉ុន្តែ ដែនដីអាណានិគមអង់គ្លេសអស់ទាំងនេះ ថ្វីដ្បិតតែមានទំហំផ្ទៃដីតិច ប៉ុន្តែ មានប្រជាជនរស់នៅច្រើនជាងបារាំង ពោលគឺ ប្រមាណជា១លាននាក់ ធៀបទៅនឹង ដែនដីអាណានិគមរបស់បារាំង ដែលមានប្រជាជនតែប្រមាណជា១០ម៉ឺននាក់។ ដែនដីអាណានិគមបារាំងនៅអាម៉េរិក មានមនុស្សរស់នៅតិច គឺដោយសារតែប្រជាជនបារាំងភាគច្រើនមិនចង់ចាកចេញពីប្រទេសកំណើត ទៅតាំងទីលំនៅនៅលើដែនដីអាណានិគម។ រដ្ឋាភិបាលបារាំងវិញក៏មិនសូវជាយកចិត្តទុកដាក់លើដែនដីអាណានិគម ដូចជារដ្ឋាភិបាលអង់គ្លេសនោះដែរ។

### ៤.២.១-សង្គ្រាមបារាំង ឥណ្ឌា ឆ្នាំ១៧៥៦

នៅឆ្នាំ១៧៥៦ សង្គ្រាមដណ្តើមកាន់កាប់ដែនដីអាណានិគមបានផ្ទុះឡើង រវាងបារាំង និងអង់គ្លេស។ សង្គ្រាមនេះ ដែលភាគច្រើនជាសង្គ្រាមខាងទ័ពជើងទឹក បានអូសបន្លាយពេលដល់ឆ្នាំ១៧៦៣ ហើយត្រូវបានគេឱ្យឈ្មោះថា«សង្គ្រាម៧ឆ្នាំ»។ នៅអាម៉េរិក សង្គ្រាមនេះត្រូវបានគេឱ្យឈ្មោះថា សង្គ្រាមបារាំង-ឥណ្ឌា (French and Indian War) ពោលគឺសង្គ្រាមរវាង បារាំង ដែលមានពួកជនជាតិដើមឥណ្ឌាស្បែកក្រហមជាសម្ពន្ធមិត្ត ទល់នឹងអង់គ្លេស រួមជាមួយនឹងដែនដីអាណានិគមទាំង១៣។

ការប្រយុទ្ធរវាងអង់គ្លេស និងបារាំង ដើម្បីគ្រប់គ្រងអាម៉េរិកខាងជើង បានចាប់ផ្តើមឡើងនៅជ្រលងអូហៃយ៉ូ។ ពួកបារាំង បានកម្ចាត់ពួកឈ្មួញរកស៊ីរោមសត្វ ហើយនៅក្នុងឆ្នាំ១៧៥៤ បារាំងបានបង្កើតបន្ទាយនៅ ហ្វត ឌុកេស(Fort Duquesne) ដែលជាឧបសគ្គចំពោះអាណានិគមទាំង១៣ ក្នុងការពង្រីកឆ្ពោះទៅខាងលិច។ ចលនានេះបានគំរាមកំហែងដល់សុវត្ថិភាពរបស់វីជីនៀ(Virginia) និងផេនស៊ីលវានៀ។ កម្លាំងកងជីវពលរបស់វីជីនៀ គឺជាក្រុមស៊ីវិល ដែលបានហ្វឹកហាត់ជាទាហាន ដើម្បីធ្វើសង្គ្រាមក្នុងភាពបន្ទាន់ ស្ថិតនៅក្រោមបញ្ជាការរបស់មន្ត្រីវ័យក្មេង ឈ្មោះ ចច វ៉ាស៊ីនតោន (George Washingto) បានបើកការវាយប្រហារឆ្ពោះទៅកាន់ជ្រលងអូហៃយ៉ូ ក្នុងឆ្នាំ១៧៥៤ តែត្រូវទទួលបរាជ័យដោយកងកម្លាំងរបស់បារាំងបានកម្ចាត់វ៉ាស៊ីនតោន ចេញពីជ្រលងអូហៃយ៉ូ។ នៅឆ្នាំ១៧៥៥ ឧត្តមសេនីយ៍ អង់គ្លេស លោក Edward Braddock ត្រូវបានបញ្ជូនទៅ Ohio ដើម្បីដណ្តើមយកជ័យជម្នះពីបារាំង។ តែកងទ័ពរបស់ Braddock ត្រូវបានស្ទាក់វាយ និងសម្លាប់ដោយកងកម្លាំងជនជាតិដើម និងកម្លាំងរបស់បារាំង។

នៅឆ្នាំ១៧៥៦ បារាំង និងអង់គ្លេស បានប្រកាសសង្គ្រាមជាផ្លូវការប្រឆាំងគ្នាទៅវិញទៅមក។ ពេលនោះ កងកម្លាំងបារាំងនៅអាម៉េរិកខាងជើង ដឹកនាំដោយ Marquis de Montcalm ដែលដើមនៃសង្គ្រាមដណ្តើម ជ័យជម្នះនៅ Oswego and Fort William Henry។ ជោគជ័យខាងដំបូងរបស់បារាំង បានធ្វើឱ្យមេដឹកនាំ អង់គ្លេស William Pitt ផ្លាស់ប្តូរយុទ្ធសាស្ត្រ។ ការសន្និដ្ឋានរបស់ Pitt : សង្គ្រាមអាចចាញ់ ឬឈ្នះ នៅម៉េរិក ខាងជើង ហើយលោកបានរៀបចំគម្រោងដើម្បីលោមព័ទបន្ទាយដ៏សំខាន់របស់បារាំងនៅអាម៉េរិក ខាងជើង ដោយប្រើប្រាស់កងកម្លាំងអង់គ្លេស និងកងទ័ពអាណានិគម។ ក្នុងពេលនោះផងដែរអង់គ្លេសបានផ្តល់ជំនួយ ទៅឱ្យកងទ័ពដែលជាសត្រូវរបស់បារាំងនៅក្នុងទ្វីបអឺរ៉ុប លើសពីនេះទៅទៀត លោក Pitt បានបង្ហាញ នូវទេព កោសល្យ ដ៏ប៉ិនប្រសព្វ ក្នុងនាមជារដ្ឋមន្ត្រី ដឹកនាំយុទ្ធនាការបញ្ចុះបញ្ចូលប្រជាជននៅអាម៉េរិក ខាងជើង។

រដូវក្តៅ ឆ្នាំ១៧៥៨: អង់គ្លេសបានបើកការវាយប្រហារ និងឡោមព័ទ បន្ទាយ Louisbourg ហើយបន្ទាយនេះ ត្រូវបោះបង់ក្នុងខែ កក្កដា។ នៅចុងរដូវក្តៅអង់គ្លេស បើកការវាយប្រហារ ប្រឆាំងបារាំងនៅ New France។

រដូវក្តៅ ឆ្នាំ១៧៥៩: កងកម្លាំងអង់គ្លេស បានចូលទៅ St. Lawrence ហើយធ្វើការឡោមព័ទ Quebec។ កងទ័ព អង់គ្លេស ដែលស្ថិតនៅក្រោមបញ្ជាការ របស់លោក ជេម វូល្ហ (James Wolfe) បានឡើងគោកនៅពេលយប់ ភាគ ខាងក្រោមនៃតំបន់កេប៊ិក ហើយបានបោះទីតាំងនៅតាមច្រាំងថ្មចោទៗ នៅទីបំផុតទាហានរបស់អង់គ្លេស បានបង្ខំ ឱ្យបារាំងដែលស្ថិតនៅក្រោមការបញ្ជារបស់ ល្វី ម៉ុងកាល់ (Louis Montcalm) ចុះចាញ់សង្គ្រាម។

កងទ័ពបារាំងបានប្រមូលផ្តុំឡើងវិញ ហើយជោគជ័យនៅ Montreal ក្នុងឆ្នាំ១៧៦០។ ក្តីសង្ឃឹមរបស់ពួកគេគឺ រងចាំការមកដល់នៃកងទ័ពជំនួយនានិទាឃរដូវ ឆ្នាំ១៧៦០។ តែជាអកុសល កងនាវាអង់គ្លេសបានមកដល់មុន ដោយនាំមកនូវកងទ័ពជាច្រើនហើយឡោមព័ទ Montreal។ បារាំងបានបង្ខំចិត បោះបង Montreal នៅថ្ងៃ៨ កញ្ញា ១៧៦០។ សង្គ្រាមនៅអាម៉េរិក ខាងជើងត្រូវបានបញ្ចប់។

កត្តាដែលជាការកំណត់ជោគជ័យរបស់អង់គ្លេសនៅក្នុងសង្គ្រាមមានដូចជា៖

- ១៧៥៨-១៧៥៩ អង់គ្លេសទទួលបានជោគជ័យ ៖ មានលុយច្រើន មានកងទ័ពច្រើន មាននាវាចម្បាំង ដ៏មាន ឥទ្ធិពល
- នៅ New Franceឆ្នាំ១៧៥៩ ផលធៀប ការប្រើកម្លាំងប្រឈមគ្នាគឺ៖
  - នាវាអង់គ្លេស មាន៣ បារាំង ១
  - កងទ័ពអង់គ្លេស ៤ បារាំង ១
  - ប្រាក់ អង់គ្លេសមាន ១០ បារាំង ១។

សង្គ្រាមនេះត្រូវបានបញ្ចប់ជាមួយនឹងការចុះសន្ធិសញ្ញាសន្តិភាព នៅទីក្រុងប៉ារីស នៅឆ្នាំ១៧៦៣ ដោយបារាំងត្រូវបាត់បង់ដែនដីអាណានិគមស្ទើរតែទាំងអស់នៅកាណាដា ដែលត្រូវប្រគល់ទៅឱ្យអង់គ្លេស ក្នុង នោះរួមមានទាំងទឹកដី Québec ផងដែរ។ លើសពីនេះអង់គ្លេសទទួលបានផងដែរនូវទឹកដីទឹកដី អាណានិគម បារាំងដែលស្ថិតនៅខាងកើតទន្លេមីស៊ីស៊ីពី ព្រមទាំងទទួលពីអេស្ប៉ាញនូវទឹកដី ហ្វ័រីដា។ ចំណែកទឹកដី ល្វីសា ណារបស់បារាំងត្រូវប្រគល់ទៅឱ្យប្រទេសអេស្ប៉ាញ។ ចំពោះប្រទេសបារាំងវិញ អាចមានសិទ្ធិរក្សាបាន តែទឹក ដីបន្តិចបន្តួចប៉ុណ្ណោះ គឺកោះផលិតស្ករសនៅក្នុងកម្រងកោះការីបប៊ីន (Caribbean) និងការនេសាទនៅ កោះ សាំង ព្យែរ និង មីគីឡង់ (St Pierre et Miquelon)។

### ៤.២.២-សង្គ្រាមបដិវត្តន៍នៅអាម៉េរិក

អង់គ្លេសវិញ ថ្វីដ្បិតតែទទួលជ័យជម្នះលើបារាំង ហើយដណ្តើមកាន់កាប់ទឹកដីអាណានិគមយ៉ាងច្រើននៅអាម៉េរិក ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា ក៏ទទួលរងនូវការខូចខាតដោយសង្គ្រាមយ៉ាងធ្ងន់ធ្ងរដែរ។ ការគ្រប់គ្រងដែនដីដែលធ្លាប់ស្ថិតក្រោមអាណានិគមបារាំងក៏ជារឿងស្មុគស្មាញ ហើយទំនាក់ទំនងជាមួយជនជាតិឥណ្ឌាស្បែកក្រហម ដែលធ្លាប់ជាសម្ពន្ធមិត្តរបស់បារាំងក៏ចោទជាបញ្ហា។ ការខូចខាតផ្នែកសេដ្ឋកិច្ចដោយសារសង្គ្រាមមានទំហំធំធេង ដែលជាហេតុធ្វើឱ្យអង់គ្លេសស្ទើរតែនឹងត្រូវក្ស័យធន។

មិនយូរប៉ុន្មានក្រោយមក អង់គ្លេស ដែលទទួលជោគជ័យក្នុងសង្គ្រាមជាមួយបារាំង ក៏ត្រូវប្រឈមមុខនឹងសង្គ្រាមមួយថ្មីទៀត នៅអាម៉េរិក ខាងជើង ហើយលើកនេះ ជាសង្គ្រាមតទល់ជាមួយនឹងទឹកដីអាណានិគមរបស់អង់គ្លេសខ្លួនឯងផ្ទាល់ គឺសង្គ្រាមទាមទារឯករាជ្យរបស់អាម៉េរិក។

បន្ទាប់ពីជ័យជម្នះ ក្នុងសង្គ្រាមដណ្តើមអាណានិគមជាមួយបារាំង អង់គ្លេសត្រូវប្រឈមមុខនឹងបញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងរ ក៏បានសម្រេចដំឡើងពន្ធអាករ លើប្រជាជនអង់គ្លេស ដែលរស់នៅលើទឹកដីអាណានិគម នៅអាម៉េរិក ខាងជើង។ ចក្រភពអង់គ្លេសយល់ថា ប្រជាជននៅដែនដីអាណានិគមអាម៉េរិកខាងជើងត្រូវតែចូលរួមវិភាគទានច្រើន នៅក្នុងវិស័យការពារជាតិអង់គ្លេស ពីព្រោះពួកគេទទួលបានការការពារពីសំណាក់ទាហានអង់គ្លេស។ ក៏ប៉ុន្តែ អាណានិគមជនអង់គ្លេសនៅអាម៉េរិកវិញយល់ថា ពួកគេមិនមានសិទ្ធជ្រើសរើសតំណាងនៅក្នុងសភាអង់គ្លេសដូចពលរដ្ឋ ដទៃទៀត ដូច្នេះ មិនគួរមានកាតព្វកិច្ចបង់ពន្ធច្រើនបែបនេះទេ។ ពួកគេក៏បាននាំគ្នាងើបឡើងប្រឆាំងនឹងអាជ្ញាធរអង់គ្លេស ហើយចលនាប្រឆាំងនេះក៏បានរាលដាលកាន់តែខ្លាំង រហូតផ្ទុះជាអំពើហិង្សា នៅឆ្នាំ១៧៧០ នៅពេលដែលទាហានអង់គ្លេសបានបើកការបាញ់ប្រហារលើក្រុមប្រឆាំងនៅបូស្តុន បណ្តាលឱ្យមនុស្ស ៥នាក់បាត់បង់ជីវិត។

ចាប់ពីពេលនោះមក ចលនាប្រឆាំងនឹងរដ្ឋាភិបាលចក្រភពអង់គ្លេសក៏កើតមានកាន់តែខ្លាំង ហើយគិតត្រឹមឆ្នាំ១៧៧៤ ដែនដីអាណានិគមទាំង ១៣ នៅអាម៉េរិកខាងជើង ក៏បានរៀបចំបង្កើតជាសភា និងរដ្ឋាភិបាលនៅតាមតំបន់រៀងៗខ្លួន ហើយនៅខែកញ្ញា ឆ្នាំ១៧៧៤ តំណាងដែនដីអាណានិគមទាំង ១៣ បានជួបប្រជុំគ្នានៅ Philadelphia ដែលគេរាប់ថាជាកិច្ចប្រជុំនីតិកាលទី១នៃសភារួមរបស់ដែនដីអាណានិគម ទាំង ១៣ (Continental Congress)។ ក៏ប៉ុន្តែ នៅពេលនោះ អាម៉េរិក មិនទាន់ប្រកាសឯករាជ្យដាច់ចេញពីចក្រភពអង់គ្លេសនៅឡើយទេ។

នៅក្នុងកិច្ចប្រជុំនោះ វ៉ាស៊ីងតោន មានឱកាសជាលើកដំបូងក្នុងការប្រាស្រ័យទាក់ទងជាមួយបណ្តាអ្នកដឹកនាំរដ្ឋ ដែលស្ថិតក្រោមអាណានិគមដទៃទៀត។ សមាជិកទាំងនោះមានការស្ងើចសរសើរ ចំពោះគំនិតវិនិច្ឆ័យ និងការយល់ដឹងពីផ្នែកកងទ័ពរបស់គាត់ជាខ្លាំង។ វ៉ាស៊ីងតោន មិនបានធ្វើសេចក្តីថ្លែងការណ៍ ហើយក៏មិនត្រូវបានគេតែងតាំងឱ្យធ្វើការក្នុង គណៈកម្មការណាមួយដែរ។ តែលោកត្រូវធ្វើការបញ្ឈប់ការធ្វើ ពាណិជ្ជកម្មទាំងអស់ជាមួយអង់គ្លេស ពីបណ្តារដ្ឋក្រោមអាណានិគម។ ការធ្វើពហិការផ្នែកជំនួញ ត្រូវបានអនុម័ត ដោយសភានេះ បន្ទាប់មកសភានេះក៏ផ្អាកដំណើរការតែម្តង។

ចក្រភពអង់គ្លេសវិញ ឆ្លើយតបនឹងចលនាប្រឆាំងនៅអាម៉េរិកក៏បានចាត់វិធានការកាន់តែតឹងរ៉ឹង ព្រមទាំងបានបញ្ជូនទាហានកាន់តែច្រើនឱ្យទៅអាម៉េរិក ក្នុងគោលដៅពង្រឹងអំណាចរបស់ខ្លួន ទៅលើដែនដីអាណានិគម។ វិធានការរឹតតែតឹងរ៉ឹង ចលនាប្រឆាំងក៏រឹតតែកើនឡើង។ មិនយូរប៉ុន្មាន ចលនាប្រឆាំងនៅក្នុងដែនដីអាណានិគមនៅអាម៉េរិក ក៏បានក្លាយជាចលនា បះបោរប្រដាប់អាវុធ ហើយបានប៉ះប្រយុទ្ធជាមួយនឹង

ទាហានអង់គ្លេសជាលើកទី១ នៅ Massachusetts នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៧៧៥។ គឺថ្ងៃនោះហើយដែលគេចាត់ទុកថាជាថ្ងៃចាប់ផ្តើមនៃសង្គ្រាមឯករាជ្យ ឬសង្គ្រាមបដិវត្តន៍អាម៉េរិក ។ សមរភូមិសំខាន់ពីរនៅម៉ាសាជូសេត ក្នុងថ្ងៃទី១៩ ខែមេសា ឆ្នាំ១៧៧៥ គឺនៅ Lexington និង Concord។

នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៧៧៥ គណៈប្រតិភូមកពីដែនដីអាណានិគមទាំង១៣ ដោយក្នុងនោះរួមមាន Georges Washington, John Adams, Benjamin Franklin និង Thomas Jefferson បានបើកកិច្ចប្រជុំសភាជាថ្មីម្តងទៀត ហើយសម្រេចបង្កើតកងទ័ពរួម (Continental Army) ដោយមាន Georges Washington ជាអគ្គបញ្ជាការ ដើម្បីប្រយុទ្ធតទល់ជាមួយនឹងកងទ័ពនៃចក្រភពអង់គ្លេស។

នៅពាក់កណ្តាលឆ្នាំ១៧៧៦ នៅក្នុងពេលដែលសង្គ្រាមបដិវត្តន៍អាម៉េរិក កំពុងតែឆាបឆេះពេញបន្ទុកប្រជាជននៅក្នុងដែនដីអាណានិគមទាំង១៣ កាន់តែច្រើនឡើងបង្ហាញពីជំហរចង់បានឯករាជ្យដាច់ចេញពីចក្រភព អង់គ្លេសទាំងស្រុង។ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៧៧៦ សភានៃដែនដីអាណានិគមទាំង ១៣ (Continental Congress) ក៏បានអនុម័តសេចក្តីប្រកាសឯករាជ្យពីអង់គ្លេស។ គិតមកត្រឹមពេលនោះ ដែនដីអាណានិគមទាំង ១៣ ភាគច្រើនស្ថិតក្រោមការកាន់កាប់របស់កងទ័ពអាម៉េរិកក៏ប៉ុន្តែ អង់គ្លេស ដែលនៅតែមិនសុខចិត្តបោះបង់ដែនដីអាណានិគមរបស់ខ្លួន ក៏បានបញ្ជូននាវាចម្បាំង ព្រមទាំងទាហានកាន់តែច្រើនដើម្បីទៅវាយបង្ក្រាបទាហានអាម៉េរិក ដែលអង់គ្លេសចាត់ទុកថាជាក្រុមបះបោរ។

នៅដើមឆ្នាំ១៧៧៨ បារាំងដែលច្បាំងចាញ់អង់គ្លេសក្នុងសង្គ្រាមដណ្តើមដែនដីអាណានិគមអាម៉េរិកកាលពី១៥ឆ្នាំមុន មើលឃើញសន្ទុះនៃកម្លាំងទ័ពអាម៉េរិក ថាជាឱកាសល្អ ដើម្បីសងសឹកចំពោះអង់គ្លេស ក៏បានលូកដៃចូលអន្តរាគមន៍ជួយអាម៉េរិកក្នុងការច្បាំងជាមួយនឹងកងទ័ពអង់គ្លេស។ អង់គ្លេសក៏ប្រកាសសង្គ្រាមជាមួយបារាំង។ អេស្ប៉ាញ និងហូឡង់ ដែលជាសម្ពន្ធមិត្តរបស់បារាំងបាននាំគ្នាចូលមកជួយបារាំង ចំណែករដ្ឋខ្លះរបស់អាល្លឺម៉ង់បានចូលមកជួយអង់គ្លេស។ សង្គ្រាមឯករាជ្យអាម៉េរិកក៏បានរាលដាលទៅជាសង្គ្រាមអន្តរជាតិ ដែលអូសបន្លាយពេលរហូតដល់ឆ្នាំ១៧៨៣ ទើបបញ្ចប់តាមរយៈការចុះសន្ធិសញ្ញានៅទីក្រុងប៉ារីស ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៧៨៣។ នៅក្នុងសន្ធិសញ្ញានេះ អង់គ្លេសបានសុខចិត្តទទួលស្គាល់អាម៉េរិកថា ជាប្រទេសដែលមានឯករាជ្យពេញលេញ។

## ៤.៣-បដិវត្តន៍គហបតីនៅបារាំង

### ៤.៣.១-មូលហេតុនៃបដិវត្តន៍

នៅចុងសតវត្សទី១៨ ដោយសារតែការចំណាយយ៉ាងច្រើនសន្ធឹកសន្ធាប់ នៅក្នុងសង្គ្រាមដើម្បីជួយសហរដ្ឋអាម៉េរិកទាមទារឯករាជ្យពីអង់គ្លេសផង និងដោយសារតែការចាយវាយខ្ជះខ្ជាយរបស់ព្រះបាទល្វីទី១៦ផង បារាំងត្រូវប្រឈមមុខនឹងវិបត្តិហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរ រហូតស្ទើរតែត្រូវក្ស័យធន។

ស្របពេលជាមួយគ្នានេះការប្រែប្រួលអាកាសធាតុធ្វើឱ្យទិន្នផលកសិកម្មមានការធ្លាក់ចុះ ប្រជាពលរដ្ឋបារាំងរស់ក្នុងស្ថានភាពខ្វះអាហារ នំប៉័ងឡើងថ្លៃខ្ពស់។

វណ្ណៈទី៣ ពិសេសពួកគហបតីដែលមានធនធានស្តុកស្តម្ភ និងចំណេះវិជ្ជាខ្ពង់ខ្ពស់ក៏ដោយក៏ពួកនេះពុំមានសិទ្ធិចូលរួមក្នុងកិច្ចការនយោបាយរបស់ប្រទេសជាតិដូចវណ្ណៈទី១ និងទី២ឡើយ។ ដូច្នេះវណ្ណៈនេះបានទាមទារសិទ្ធិសេរីភាព និងសមភាពនៅក្នុងសង្គម។

#### ៤.៣.២-បដិវត្តន៍របស់ពួកតំណាងប្រជាជននៃវណ្ណៈទី៣ (ខែមិថុនា ១៧៨៩)

ស្តេច ល្វីទី១៦ បានកោះប្រជុំសភាទាំង៣ ដើម្បីអនុម័តគម្រោងដំឡើងពន្ធ និងបង្កើតពន្ធថ្មីៗដើម្បីបង្កើនចំណូលរដ្ឋ។ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៧៨៩ កិច្ចប្រជុំពេញអង្គនៃសភាទាំង៣ បានបើកធ្វើនៅ ព្រះបរមរាជវាំងវែរសៃ(Versailles) ជាយក្រុងប៉ារីស។ ការប្រជុំនេះកើតមានឡើងអាស្រ័យភាគីខាងស្តេចចង់ការពាររបបចាស់ ឯភាគីម្ខាងទៀត គឺប្រជាជនបារាំងទាំងឡាយទាមទារឱ្យមានការកែទម្រង់ប្រព័ន្ធបោះឆ្នោតពីការបោះឆ្នោតតាមសភា ទៅជាការបោះឆ្នោតដោយរាប់តាមចំនួនសមាជិកវិញ ពោលគឺ សមាជិកនីមួយៗត្រូវមានមួយសំឡេងស្មើៗគ្នា។ នៅក្នុងសុន្ទរកថារបស់ស្តេច ទ្រង់ពុំបានលើកសេចក្តីអះអាងសំខាន់ណាមួយក្នុងកំណែទម្រង់ទេ។ ដោយមានការខកចិត្ត ពួកសមាជិកសភានៃវណ្ណៈទី៣ ប្រកាសបង្កើត «**សភាជាតិ**» នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៧៨៩ ដោយប្រឆាំងផ្ទាល់ចំពោះស្តេច ដែលជាជំហានដំបូងនៃបដិវត្តន៍។ ពួកគេសន្យាថាបំបែកគ្នាលុះត្រាតែរដ្ឋធម្មនុញ្ញមួយលេចចេញរូបរាងឡើង។ ក្រោយមកសមាជិកសភានៃពួកបព្វជិត និងអភិជនបានចូលរួមប្រជុំគ្នាជាមួយវណ្ណៈទី៣ ដើម្បីបង្កើត«សភាធម្មនុញ្ញ»។

#### ៤.៣.៣-បដិវត្តន៍របស់ប្រជាជនទីក្រុងប៉ារីស (ខែកក្កដា ១៧៨៩)

របបរាជាធិបតេយ្យផ្តាច់ការ ដែលគ្រប់គ្រងដោយស្តេចល្វីទី១៦ បានប្រឈមមុខនឹងការបះបោរកាន់តែខ្លាំងឡើង។ នៅក្នុងទីក្រុងតម្លៃនំប៉័ងបានកើនឡើងខ្ពស់ ដោយការច្រូតកាត់ក្នុងឆ្នាំ១៧៨៨ បានផលតិច ហើយបន្តធ្លាក់ចុះនៅឆ្នាំបន្ទាប់ទៀត។ នៅទីក្រុងប៉ារីសថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៧៨៩ តម្លៃនំប៉័ងឡើងខ្ពស់បំផុត ដែលពុំធ្លាប់មានចាប់តាំងពីឆ្នាំ១៧០៩មក។ ម្យ៉ាងទៀតប្រជាជនព្រួយបារម្ភចំពោះការវាយបង្ក្រាបពីកងទ័ពស្តេច។

នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៧៨៩ ចលនាបដិវត្តន៍ប្រជាជនបាននាំគ្នាវាយលុកទៅលើគុកបាស្ទី (Bastille) ដែលក្រុមបដិវត្តន៍ចាត់ទុកថាជានិមិត្តរូបនៃអំណាចផ្តាច់ការរបស់ស្តេច។ គុកបាស្ទី ត្រូវបានចលនាបដិវត្តន៍វាយដណ្តើមយកបាន ហើយថ្ងៃទី១៤ ខែកក្កដា ត្រូវបានបារាំងចាត់ទុកជាថ្ងៃបុណ្យជាតិ រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។

#### ៤.៣.៤- បដិវត្តន៍ទីក្រុង និងជនបទ (ខែកក្កដា-សីហា ឆ្នាំ១៧៨៩)

ពេលផ្ទុះបដិវត្តន៍នៅទីក្រុងប៉ារីស សភាជាតិបានបង្កើតសាលាក្រុង និងកងការពារជាតិនៅតាមទីក្រុងនានា មានភារកិច្ចរក្សារបៀបរៀបរយពីការគំរាមកំហែងដោយសារតម្លៃខ្ពស់នៃគ្រាប់ធញ្ញជាតិ។

នៅតាមស្រុកស្រែមានការបះបោរយ៉ាងខ្លាំង។ ពួកកសិករ ប្រឆាំងចំពោះបំណុលពន្ធចាស់ៗ ទាំងឡាយ ហើយព្រួយបារម្ភចំពោះការឡើងថ្លៃនំប៉័ង ព្រមទាំងភ័យខ្លាចមានការរួមគំនិតក្បត់នៃពួកអភិជន។ ដូចនៅប៉ារីសដែរ ពួកកសិករដែលកាន់អាវុធបានចូលបំផ្លាញផ្ទះពួកសក្តិភូមិនានាហើយដុតបំផ្លាញបញ្ជី ផ្សេងៗស្តីពីកាតព្វកិច្ចសក្តិភូមិ។ ថ្ងៃទី៤ ខែសីហា ឆ្នាំ១៧៨៩ ដោយព្រួយបារម្ភចំពោះការបះបោរដ៏ធំនេះ ពួកអភិជន និងពួកបព្វជិតលុបចោលច្បាប់សក្តិភូមិនានា និងអាករទាំងឡាយ។ សកម្មភាពនេះ គឺ ជាចុងបញ្ចប់នៃរបបសក្តិភូមិនៅប្រទេសបារាំង។

#### ៤.៣.៥-ការផ្តួលរំលំរបបរាជានិយមនៅប្រទេសបារាំង

នៅឆ្នាំ១៧៨៩ ចលនាបដិវត្តន៍ប្រជាជនបានផ្តួលរំលំរបបរាជានិយមផ្តាច់ការ ហើយនាំប្រទេសបារាំងទៅរករបបនយោបាយថ្មីមួយ គឺរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ ព្រះមហាក្សត្របារាំង ព្រះបាទល្វីទី១៦ បានបង្ខំចិត្តទទួលយករបបនយោបាយថ្មីនេះ ដោយសារតែមានសម្ពាធពីចលនាបដិវត្តន៍តែប៉ុណ្ណោះ។ រីឯក្នុងចិត្តវិញ ព្រះអង្គនៅតែចង់ឱ្យបារាំងវិលត្រឡប់ទៅរករបបរាជានិយមផ្តាច់ការ ដូចកាលពីសម័យដើម។

នៅយប់មួយ ក្នុងខែមិថុនា ឆ្នាំ១៧៩១ ព្រះបាទល្វីទី១៦ ព្រមទាំងក្រុមគ្រួសារ ក៏បានលួចរត់គៀសព្រះកាយចេញពីព្រះបរមរាជវាំង ដើម្បីទៅស្វះស្វែងរកជំនួយពីស្តេចអាល្លឺម៉ង់។ ក៏ប៉ុន្តែ នៅតែប្រមាណជា ៣០ គីឡូម៉ែត្រពីព្រំដែនអាល្លឺម៉ង់ ព្រះអង្គត្រូវគេចាប់ខ្លួនបាន រួចហើយបញ្ជូនឱ្យត្រឡប់មកកាន់ទីក្រុង ប៉ារីសវិញ។

ចាប់ពីពេលនោះមក ប្រជាជនបារាំងបានបាត់បង់ទំនុកចិត្តលើព្រះមហាក្សត្រទាំងស្រុង ដោយពួកគេចាត់ទុកថា ការព្យាយាមរត់គៀសព្រះកាយទៅរកជំនួយពីបរទេស គឺជាទង្វើក្បត់ជាតិ។ ចលនាបដិវត្តន៍ប្រជាជនក៏បានចាប់កក្រើកឡើងវិញ ហើយមានសន្ទុះកាន់តែខ្លាំងក្លាជាងមុន ដោយពេលនោះ ពួកគេទាមទារឱ្យរំលាយរបបរាជានិយមចោលទាំងស្រុង ដើម្បីបង្កើតជារបបសាធារណរដ្ឋជំនួសវិញ។

នៅព្រឹកព្រលឹមថ្ងៃទី១០ ខែសីហា ឆ្នាំ១៧៩២ ក្រុមបដិវត្តន៍បានបើកការវាយលុកចូលទៅដល់ក្នុងព្រះបរមរាជវាំង ក្នុងក្រុងប៉ារីស (Les Tuileries )។ របបរាជានិយមត្រូវគេលុបបំបាត់ចោលទាំងស្រុង ហើយរបបសាធារណរដ្ឋក៏ត្រូវបានបង្កើតឡើង។ ព្រះបាទល្វីទី១៦ ត្រូវបានតុលាការបដិវត្តន៍កាត់ទោសប្រហារជីវិតដោយកាត់ក្បាល នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៧៩៣។ ការប្រហារជីវិតព្រះបាទល្វីទី១៦ ត្រូវបានធ្វើឡើងជាសាធារណៈ នៅកណ្តាលក្រុងប៉ារីស (នៅត្រង់ទីលានមួយ ដែលគេឱ្យឈ្មោះថា «ទីលានបដិវត្តន៍» ហើយបច្ចុប្បន្ន ត្រូវប្តូរឈ្មោះមកជា "Place de la Concorde" )។

ការផ្តួលរំលំរបបរាជានិយម និងប្រហារជីវិតស្តេចនៅបារាំង បានធ្វើឱ្យព្រះមហាក្សត្រនៅតាម បណ្តាប្រទេសផ្សេងៗ ទៀតក្នុងតំបន់ អឺរ៉ុបផ្ទុះកំហឹង ហើយនាំគ្នាលើកទ័ពវាយលុកមកលើរបបសាធារណរដ្ឋ បារាំង។ ពីខាងក្រៅ របបសាធារណរដ្ឋដែលទើបនឹងបង្កើតថ្មីត្រូវប្រឈមមុខនឹងការឈ្លានពាន ពីគ្រប់ទិស គឺអង់គ្លេស និងបែលហ្ស៊ិក ពីខាងជើង អាល្លឺម៉ង់ និងអូទ្រីសពីខាងកើត ហើយអេស្ប៉ាញ ពីខាងត្បូង។ ចំណែកនៅខាងក្នុងស្រុកវិញ សង្គ្រាមផ្ទៃក្នុងក៏បានឆាបឆេះយ៉ាងសន្ធោរសន្ធៅឡើងដែរ គឺសង្គ្រាមទល់នឹងក្រុមអ្នករាជានិយម។ ស្ថិតក្នុងស្ថានភាពចលាចលនេះ របបសាធារណរដ្ឋបារាំងបានដាក់ចេញនូវនយោបាយបែបផ្តាច់ការ និងឃោរឃៅមួយ ដែលនៅក្នុងប្រវត្តិសាស្ត្របារាំងគេបានដាក់ឈ្មោះថា « La Terreur »។ នៅក្នុងសម័យកាលនោះ រាល់អ្នកណាដែលប្រឆាំងនឹងរដ្ឋាភិបាល ត្រូវគេចាប់ខ្លួន និងសម្លាប់ចោល ដោយចោទថាជាអ្នកប្រឆាំងនឹងបដិវត្តន៍។ អ្នកដែលត្រូវចាប់ខ្លួន និងសម្លាប់ ពីបទប្រឆាំងនឹងបដិវត្តន៍នេះ មានទាំងអតីតមន្ត្រីក្នុងរបបចាស់ ប្រជាជនធម្មតា រហូតដល់ជួរថ្នាក់ដឹកនាំនៃរបបសាធារណរដ្ឋគ្នាឯង។ របបសាធារណរដ្ឋ ដែលកើតចេញពីបដិវត្តន៍ប្រឆាំងនឹងរបបផ្តាច់ការរបស់ស្តេច ក៏បានក្លាយខ្លួនទៅជារបបផ្តាច់ការថ្មីមួយទៀត។

របបផ្តាច់ការ និងឃោរឃៅនេះបានបិទបញ្ចប់ នៅខែកក្កដា ឆ្នាំ១៧៩៤ នៅក្រោយពេលដែលមេដឹកនាំដ៏មានអំណាចម្នាក់ ឈ្មោះ Robespierre ត្រូវបានចាប់ខ្លួន និងកាត់ទោសប្រហារជីវិត ដោយត្រូវគេយកទៅកាត់ក្បាល នៅត្រង់កន្លែង ដែលគេធ្លាប់កាត់ក្បាលស្តេចល្វីទី១៦ កាលពីជាង១ឆ្នាំមុន។ គិតជាសរុប មានមនុស្សប្រមាណជា ៥០ម៉ឺននាក់ត្រូវគេចាប់ដាក់ពន្ធនាគារ ហើយប្រមាណជា ១០ម៉ឺននាក់ត្រូវគេសម្លាប់ នៅក្រោមរបបសាធារណរដ្ឋផ្តាច់ការថ្មីនេះ។

ក្រោយពេលដែល Robespierre ត្រូវបានចាប់ខ្លួន និងប្រហារជីវិត បិទបញ្ចប់របបឃោរឃៅ ដែលគេហៅថា "La Terreur" រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានគេតាក់តែងឡើង ដើម្បីបង្កើតរបបដឹកនាំថ្មីមួយទៀត។ ក៏ប៉ុន្តែ ជម្លោះផ្ទៃក្នុង រវាងក្រុមអ្នកសាធារណរដ្ឋ និងអ្នករាជានិយម នៅតែបន្តកើតមាន ដែលជាហេតុបង្កឱ្យមានអស្ថិរភាពនយោបាយជាប្រចាំ។ ទិដ្ឋភាពនយោបាយបារាំង នៅពេលនោះ តែងតែប្រែប្រួលឥតឈប់ រវាងការបោះឆ្នោត និងរដ្ឋប្រហារយោធា ដែលតែងតែកើតមានជារឿយៗ។

ស្ថិតនៅក្នុងភាពច្របូកច្របល់នេះ គេឃើញមានឥស្សរជនម្នាក់ចាប់ផ្ដើមលេចមុខឡើង ហើយដែលក្រោយមកនឹងនាំមកនូវការផ្លាស់ប្ដូរដ៏ធំមួយ នៅក្នុងប្រវត្តិសាស្ត្របារាំង ក៏ដូចជា ប្រវត្តិសាស្ត្រអឺរ៉ុប។ ឥស្សរជននោះ គឺណាប៉ូឡេអុង បូណាប៉ាត ( Napoléon Bonaparte )។

ប៉ូឡេអុង កើតថ្ងៃទី១៥ ខែសីហា ឆ្នាំ១៧៦៩ នៅកោះ Corse ដែលជាអតីតកោះរបស់អ៊ីតាលី។ នៅឆ្នាំដែលណាប៉ូឡេអុងកើត កោះ Corse ទើបនឹងត្រូវបានអ៊ីតាលីកាត់មកឱ្យប្រទេសបារាំង។ នៅពេលដែលបដិវត្តន៍បារាំងផ្ទុះឡើង នៅឆ្នាំ១៧៨៩ ណាប៉ូឡេអុងទើបនឹងមានអាយុ២០ឆ្នាំ ហើយគ្រាន់តែជានាយទាហានថ្នាក់ទាបម្នាក់ ដែលទើបនឹងបញ្ចប់សាលានាយទាហាននៅប៉ារីស។ ក៏ប៉ុន្តែ នៅក្រោមរបបសាធារណរដ្ឋ ណាប៉ូឡេអុង ដែលមានស្នាដៃច្រើនក្នុងសមរភូមិ ក៏បានឡើងបុណ្យស័ក្តិជាបន្តបន្ទាប់។ នៅឆ្នាំ១៧៩៦ នៅពេលដែលរបបសាធារណរដ្ឋបារាំងកំពុងប្រឈមមុខនឹងការឈ្លានពានពីសំណាក់ កងទ័ពស្ដេចនៃបណ្ដាប្រទេសដែលនៅជុំវិញ ណាប៉ូឡេអុងត្រូវបានគេតែងតាំងជាឧត្តមសេនីយ៍ ហើយបានដឹកនាំទ័ពយកជ័យជម្នះ នៅតាមបណ្ដាសមរភូមិសំខាន់ៗជាច្រើន ជាពិសេស នៅប៉ែកខាងអ៊ីតាលី ដែលកងទ័ពរបស់ណាប៉ូឡេអុងវាយបំបាក់កងទ័ពអូទ្រីស រហូតធ្វើឱ្យអូទ្រីសត្រូវបង្ខំចិត្តចុះកិច្ចព្រមព្រៀងសន្តិភាព ជាមួយ បារាំង។ នៅឆ្នាំ១៧៩៩ នៅពេលដែលកងទ័ពបារាំងបានបង្ហាញនូវកម្លាំងគួរឱ្យស្ញប់ស្ញែងចំពោះសត្រូវពីខាងក្រៅនៅផ្ទៃក្នុង។ នៅប្រទេសបារាំង វិបត្តិនយោបាយតែងតែកើតមានជាអចិន្ត្រៃយ៍។ ស្ថិតក្នុងស្ថានភាពបែបនេះ ណាប៉ូឡេអុងដែលកំពុងគ្រប់គ្រងទ័ព ក្នុងប្រទេសអេហ្ស៊ីប ក៏បានធ្វើដំណើរវិលត្រឡប់មកកាន់ទីក្រុងប៉ារីស វិញ។ នៅខែវិច្ឆិកា ឆ្នាំ១៧៩៩ ណាប៉ូឡេអុងបានរៀបចំធ្វើរដ្ឋប្រហារទម្លាក់រដ្ឋាភិបាល ដណ្ដើមអំណាចយកមកកាន់កាប់។

របបដឹកនាំថ្មីនេះ មានរដ្ឋធម្មនុញ្ញ ដែលមានរូបភាពខាងក្រៅជារបបប្រជាធិបតេយ្យ ក៏ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្ដែង អំណាចទាំងអស់ស្ថិតក្នុងដៃរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ណាប៉ូឡេអុង។ ជាថ្មីម្ដងទៀត ប្រជាជនបារាំង ដែលខិតខំរើខ្លួនចេញពីរបបផ្ដាច់ការមួយ ប៉ុន្តែ តែងតែត្រូវធ្លាក់ចូលទៅក្នុងរបបផ្ដាច់ការថ្មីជាបន្តបន្ទាប់។ លើសពីនេះទៅទៀត នៅឆ្នាំ១៨០៤ ណាប៉ូឡេអុង បូណាប៉ាត ដែលអះអាងថាជាអ្នកការពាររបបសាធារណរដ្ឋ ក៏ប៉ុន្តែ ស្រាប់តែបានប្រកាសខ្លួនជាអធិរាជ។ ១៥ឆ្នាំ ក្រោយបដិវត្តន៍ទម្លាក់របបរាជានិយមផ្ដាច់ការ បារាំងបានវិលត្រឡប់ទៅរកការដឹកនាំតាមបែបរាជានិយមផ្ដាច់ការដូចពីមុនវិញ គឺចក្រភពបារាំងក្រោមអំណាចរបស់អធិរាជណាប៉ូឡេអុង[446]។

## ៥-បដិវត្តន៍ឧស្សាហកម្ម និងការផ្លាស់ប្ដូរសង្គមអឺរ៉ុប

### ៥.១-ការចាប់ផ្ដើមនៃបដិវត្តន៍ឧស្សាហកម្មនៅអង់គ្លេស

នៅក្នុងឆ្នាំ១៧០០ ដីស្រែចម្ការតូចៗបានគ្របដណ្ដប់នៅពាសពេញចក្រភពអង់គ្លេស។ ប៉ុន្តែក្រោយមកម្ចាស់កម្មសិទ្ធិដីធ្លី ដែលមានទ្រព្យសម្បត្តិស្ដុកស្ដម្ភនានា បានចាប់ផ្ដើមប្រមូលទិញដីស្រែចម្ការទាំងឡាយដែលប្រជាកសិករធ្លាប់ធ្វើកសិកម្ម។ ពួកម្ចាស់កម្មសិទ្ធិដីធ្លីធំៗបានអភិវឌ្ឍគួរឱ្យចាប់អារម្មណ៍នូវវិធីដាំដុះថ្មីៗរបស់ពួកគេ។ ការបង្កើតថ្មីនេះគឺស្ថិតនៅក្នុងចំណោមការធ្វើបដិវត្តន៍កសិកម្ម។

បន្ទាប់ពីទិញយកដីរបស់ពួកប្រជាកសិករ ពួកម្ចាស់កម្មសិទ្ធិដីធ្លីដែល មានទ្រព្យសម្បត្តិស្ដុកស្ដម្ភ បានហ៊ុមព័ទ្ធដីរបស់ពួកគេជាមួយនឹងរបង ឬបង្គោលឈើ។ ការបង្កើននូវទំហំដីរបស់ពួកគេ បានអនុញ្ញាតឱ្យពួកគេអាចដាំដុះលើផ្ទៃដីដ៏ធំមួយ។ នៅក្នុងផ្ទៃដីដាំដុះដ៏ធំនេះ ដែលគេហៅថា ការហ៊ុមព័ទ្ធដីធ្លី, ម្ចាស់កម្មសិទ្ធិដីធ្លី

[446] សេង ឌីណា (២០១៣) *ប្រវត្តិសាស្ត្រពិភពលោក* : ការចេញផ្សាយរបស់វិទ្យុបារាំងអន្តរជាតិ RFI អាទិត្យ 22 ធ្នូ 2013

បានសាកល្បងដាំដុះគ្រាប់ពូជដែលទទួលបានទិន្នផលច្រើន និងវិធីសាស្ត្រប្រមូលផលផ្សេងៗ ដើម្បីបង្កើនទិន្នផលគ្រាប់ធុញ្ញជាតិរបស់ពួកគេ។ ចលនានៃការហ៊ុមព័ទ្ធដីធ្លីនេះបានផ្តល់នូវលទ្ធផលពីរសំខាន់ៗ។ ទីមួយម្ចាស់កម្មសិទ្ធិដីធ្លីបាន សាកល្បងវិធីសាស្ត្រធ្វើកសិកម្មថ្មី។ ទីពីរម្ចាស់កម្មសិទ្ធិដីធ្លីធំៗបានជំរុញឱ្យ ប្រជាកសិករតូចតាចក្លាយជាអ្នកជួលដីដើម្បីធ្វើស្រែ ឬបោះបង់ការធ្វើស្រែរបស់ពួកគេ ហើយធ្វើដំណើរទៅកាន់ទីក្រុង។

នៅត្រឹមសតវត្សទី១៨ ប្រជាជនទូទៅនៅលើពិភពលោក ភាគច្រើនលើសលុបរស់នៅក្នុងភូមិតូចៗ នៅតាមទីជនបទ ហើយប្រកបរបរចិញ្ចឹមជីវិត ដោយការដាំដុះ ចិញ្ចឹមសត្វ ឬសកម្មភាពសិប្បកម្មផ្សេងទៀត។ ប្រជាជនបរិភោគចំណីអាហារ ដែលបានមកពីដំណាំដែលគេដាំដោយខ្លួនឯង ស្លៀកសម្លៀកបំពាក់ និងប្រើប្រាស់សម្ភារៈ ដែលគេផលិតដោយខ្លួនឯង ហើយសកម្មភាពទិញដូរកើតមានយ៉ាងតិចតួចបំផុត។

នៅពេលនោះអ្វីៗទាំងអស់ត្រូវធ្វើឡើងដោយដៃ ដោយកម្លាំងមនុស្ស ឬសត្វចិញ្ចឹម ដូចជា គោ ក្របី ឬសេះ ជាដើម ហើយសកម្មភាពផលិតភាគច្រើនធ្វើឡើងតែតាមផ្ទះជាលក្ខណៈគ្រួសារ ដែលផ្តល់ផលក្នុងកម្រិតទាប ប្រាក់ចំណូលតិចតួច ហើយប្រជាជនភាគច្រើនមានជីវភាពខ្សត់ខ្សោយ។ ប៉ុន្តែ នៅចុងសតវត្សទី១៨ ពិភពលោកបានស្គាល់នូវការវិវឌ្ឍដ៏សំខាន់បំផុតមួយ ដែលគេឱ្យឈ្មោះថា "បដិវត្តន៍ឧស្សាហកម្ម" ជាចំណុចរបត់នៃការផ្លាស់ប្តូររបៀបរស់នៅរបស់មនុស្សជាតិ ពីការពឹងផ្អែកជាចម្បងលើសកម្មភាពកសិកម្ម ទៅជាការប្រកបរបរចិញ្ចឹមជីវិត ដោយសកម្មភាពឧស្សាហកម្ម។

បដិវត្តន៍ឧស្សាហកម្មចាប់ផ្តើមចេញពីអង់គ្លេស ដោយសារកត្តាច្រើនយ៉ាង។ កត្តាសំខាន់ទីមួយ គឺវត្ថុធាតុដើម។ អង់គ្លេស គឺជាប្រទេសដែលសម្បូរទៅដោយរ៉ែធ្យូងថ្ម និងរ៉ែដែក ដែលជាវត្ថុធាតុដើមសំខាន់បំផុតក្នុងវិស័យឧស្សាហកម្ម។ លើសពីធនធានធម្មជាតិរបស់ពួកគេ, ចក្រភពអង់គ្លេសមានសេដ្ឋកិច្ចដ៏ធំមួយដើម្បីគាំទ្រដល់ឧស្សាហូបនីយកម្ម។ អ្នកជំនួញបានវិនិយោគនៅក្នុងរោងចក្រដែលបង្កើតថ្មី ប្រព័ន្ធធនាគារដែលមានការអភិវឌ្ឍកម្រិតខ្ពស់របស់ចក្រភពអង់គ្លេស នៅពេលនោះក៏បានចូលរួមចំណែកនៅក្នុងការបង្កើតឱ្យមានឧស្សាហូបនីយកម្មនៅក្នុងប្រទេសផងដែរ។ ប្រជាជនត្រូវបានលើកទឹកចិត្ត តាមរយៈការ ផ្តល់ប្រាក់កម្ចីដើម្បីវិនិយោគទៅលើម៉ាស៊ីនដែលទើបបង្កើតថ្មី និងពង្រីកប្រតិបត្តិការរបស់ពួកគេ។ ការកើនឡើងនូវ ពាណិជ្ជកម្មក្រៅប្រទេស, ភាពរុងរឿង នៃសេដ្ឋកិច្ច, និងបរិយាកាសនៃការរីកចម្រើនមួយ បាននាំទៅដល់ការកើនឡើងនូវតម្រូវការចំពោះមុខទំនិញ។

កត្តាសំខាន់ទីពីរ គឺចំណេះដឹង។ នៅក្នុងអំឡុងសតវត្សទី១៨ អង់គ្លេសមានអ្នកប្រាជ្ញល្បីៗជាច្រើន។ អ៊ីសាក់ ញូវតុន (Isaac Newton) ដែលជា អ្នកប្រាជ្ញមានឈ្មោះល្បីល្បាញបំផុតរហូតមកទល់នឹងពេលបច្ចុប្បន្ន នេះ គឺជាអ្នកប្រាជ្ញអង់គ្លេស។ ក្រៅពីញូវតុន អង់គ្លេសនៅមានអ្នកប្រាជ្ញជាច្រើនទៀត ជាពិសេសខាងផ្នែករូបវិទ្យា និងវិស្វកម្ម។ ចំណេះដឹងរបស់អ្នកប្រាជ្ញទាំងនេះបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការបង្កើតបច្ចេកវិទ្យាថ្មីៗជាច្រើន ដូចជា ការបង្កើនប្រសិទ្ធភាពក្នុងការប្រើថាមពលទឹក, ការប្រើធ្យូងថ្មជាប្រភពថាមពលជំនួសអុស, ការបង្កើតម៉ាស៊ីនដើរដោយចំហាយទឹក, បច្ចេកទេសក្នុងការផលិតដែកជាលក្ខណៈឧស្សាហកម្ម ព្រមទាំងបច្ចេកទេសខាងផ្នែកមេកានិក ក្នុងការបង្កើតគ្រឿងម៉ាស៊ីនផ្សេងទៀត សម្រាប់ប្រើក្នុងវិស័យផលិតកម្មជំនួសដោយការផលិតដោយដៃ។ ការផលិតដោយប្រើម៉ាស៊ីនទាំងនេះធ្វើឱ្យគេទទួលបានទិន្នផលច្រើន ជាងការផលិតដោយដៃរាប់រយ ឬរហូតដល់រាប់ពាន់ដង។

កត្តាដ៏សំខាន់មួយទៀតដែលនាំឱ្យមានបដិវត្តន៍ឧស្សាហកម្ម នៅអង់គ្លេស គឺកត្តានយោបាយ និងសង្គម។ ចាប់តាំងពីមានបដិវត្តន៍បង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ នៅចុងសតវត្សទី១៧ អង់គ្លេសគឺជាប្រទេស

មួយ ដែលមានស្ថិរភាពទាំងផ្នែកនយោបាយ និងសង្គម។ ម្យ៉ាងទៀត រដ្ឋាភិបាលអង់គ្លេសតែងតែប្រកាន់យកនូវនយោបាយបើកចំហក្នុងវិស័យ ឯកជន ដោយលើកទឹកចិត្តដល់អ្នកបង្កើតសហគ្រាសឯកជន និងអ្នកបង្កើតទ្រឹស្តី ឬបច្ចេកវិទ្យាថ្មីៗ ដែលអាចបង្កើនប្រសិទ្ធភាពក្នុងការផលិត។ លើសពីនេះទៅទៀត អង់គ្លេសនៅពេលនោះ គឺជាមហាអំណាច ដែលមានដែនដីអាណានិគមយ៉ាងធំធេង នៅទូទាំងពិភពលោក។ ដែនដីអាណានិគមទាំងនេះ គឺជាប្រភពវត្ថុធាតុដើមដ៏សំខាន់មួយផង ហើយវាក៏ជាទីផ្សារដ៏ចម្បងមួយដែរ សម្រាប់លក់ផលិតផលរបស់អង់គ្លេស។ នៅពេលដែលទីផ្សារកើនឡើង វាធ្វើឱ្យសហគ្រាសអង់គ្លេសកាន់តែនាំគ្នាខិតខំប្រឹងប្រែង ដើម្បីរកវិធីផលិតទំនិញឱ្យបានកាន់តែច្រើន និងកាន់តែលឿន។ទាំងអស់នេះហើយដែលនាំឱ្យ វិស័យឧស្សាហកម្មនៅអង់គ្លេសស្គាល់នូវភាព ជឿនលឿនជាងគេ នៅអំឡុងចុងសតវត្សទី១៨ និងដើម សតវត្សទី១៩។ នៅពេលនោះ រដ្ឋាភិបាលអង់គ្លេសបានព្យាយាមទប់ស្កាត់មិនឱ្យបច្ចេកវិទ្យា ឧស្សាហកម្មរបស់ខ្លួនត្រូវរីកសាយភាយទៅកាន់ប្រទេសផ្សេង។ ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងនេះត្រូវទទួលបរាជ័យ ដោយសារតែមានវិស្វករ ឬកម្មករជំនាញ ព្រមទាំងសហគ្រិនអង់គ្លេសខ្លះ បាននាំគ្នាធ្វើចំណាកស្រុក ដើម្បីទៅស្វែងរកឱកាសការងារ ឬឱកាសធ្វើជំនួញនៅបរទេស។

## ៥.២-ការរីកចម្រើននៃវិស័យវាយនភណ្ឌ

បដិវត្តន៍ឧស្សាហកម្មបានរីកសាយភាយចេញពីអង់គ្លេស ទៅកាន់ប្រទេសផ្សេងទៀតនៅអឺរ៉ុប ដោយចាប់ផ្តើមពីបែលហ្ស៊ិក បន្តទៅដល់បារាំង អាល្លឺម៉ង់ និងស៊ុយអែត ហើយបន្ទាប់មកទៀត ចេញពីអឺរ៉ុប ទៅដល់សហរដ្ឋអាម៉េរិក។

នៅត្រឹមពាក់កណ្តាលសតវត្សទី១៩ បដិវត្តន៍ឧស្សាហកម្មបានចាក់គ្រឹះយ៉ាងមាំ នៅទូទាំងតំបន់អឺរ៉ុបខាងលិច និងនៅឆ្នេរប៉ែកខាងកើតនៃសហរដ្ឋអាម៉េរិក។ វិស័យដែលមានការជឿនលឿនខ្លាំងជាងគេ នៅពេលនោះ គឺវិស័យវាយនភណ្ឌ ការផលិតដែក និងបច្ចេកវិទ្យាក្នុងការផលិតម៉ាស៊ីន ជាពិសេស ម៉ាស៊ីនដើរដោយចំហាយទឹក។ នៅតាមបណ្តាប្រទេស ដែលឆ្លងកាត់នូវបដិវត្តន៍ឧស្សាហកម្ម គេសង្កេតឃើញមានរោងចក្រថ្មីៗរីកដុះដាលដូចផ្សិតនៅគ្រប់ទីកន្លែង ហើយហេដ្ឋារចនាសម្ព័ន្ធខាងផ្នែកដឹកជញ្ជូនក៏មានការរីកចម្រើនមិនធ្លាប់មាន។

ឧស្សាហកម្មតម្បាញក្រណាត់រោមចៀម, ក្រណាត់ខ្សែន, និងក្រណាត់កប្បាសរបស់ចក្រភពអង់គ្លេសបានគ្របដណ្តប់នៅលើពិភពលោក។ ឧស្សាហកម្មនេះគឺជាការផ្លាស់ប្តូរជាលើកដំបូង។ ពាណិជ្ជករលក់សម្លៀកបំពាក់បានបង្កើនចំណូលរបស់ពួកគេដោយការបង្កើនសង្វាក់ផលិតកម្មរបស់អ្នករវៃ និងអ្នកតម្បាញដើម្បីផលិតសម្លៀកបំពាក់។

នៅក្នុងឆ្នាំ១៧៣៣ យន្តការីមួយរូបឈ្មោះ **ចន ខេ (John Kay)** បាន បង្កើតឧបករណ៍ត្រល់មួយដែលអាចរត់ទៅរត់មកបានដោយប្រើកង់របស់វា។ ឧបករណ៍ត្រល់នេះ ធ្វើឡើងពីបន្ទះ ឈើមានរូបរាងដូចជាទូកដែលគេភ្ជាប់សរសៃអំបោះជាមួយវា។ អ្នកតម្បាញអាចបង្កើនសង្វាក់ផលិតកម្មរបស់ពួកគេបានគុណនឹងពីរ។ ដោយសារតែអ្នករវៃមិនអាចរវៃទាន់ក្រុមអ្នកត្បាញដ៏លឿននេះ មានការផ្តល់រង្វាន់ជាសាច់ប្រាក់ដើម្បីទាក់ទាញការប្រគួតប្រជែងក្នុងការផលិតម៉ាស៊ីនរវៃដែលល្អប្រសើរមួយ។ នៅអំឡុងឆ្នាំ១៧៦៤ កម្មករតម្បាញមួយរូបឈ្មោះ **ជេម ហារគ្រេវ (James Hargreaves)** បានបង្កើតកង់បង្វិលមួយ ដោយលោកបានដាក់ឈ្មោះវាតាមឈ្មោះកូនស្រីរបស់លោក។ កង់បង្វិលជេននី**(Jenny)** របស់លោកបានអនុញ្ញាតឱ្យអ្នករវៃអាចរវៃសរសៃអំបោះចំនួន៨ ក្នុងពេលតែមួយ។

ដំបូងឡើយកម្មការតម្បាញប្រើប្រាស់ត្រល់ និងកង់បង្វិលជេននីដោយប្រើប្រាស់ដៃ។ បន្ទាប់មកលោក **រីឆាត អាករ៉ៃ** (Richard Arkwright : 1732-1792) បានបង្កើតម៉ាស៊ីនបង្វិលដោយប្រើទឹកនៅក្នុងឆ្នាំ១៧៦៩។ ម៉ាស៊ីននេះប្រើប្រាស់ចំហាយទឹកដើម្បីរុញកង់បង្វិល។ នៅក្នុងឆ្នាំ១៧៧៩ លោក **សាប៊ូអ៊ែល ក្រូមតុន** (Samuel Crompton) បានផ្គុំបញ្ចូលគ្នានូវកង់បង្វិលជេននីជាមួយនឹងម៉ាស៊ីនបង្វិលដោយប្រើទឹក ដើម្បីបង្កើតបានជារទេះរវៃមួយ។ រទេះរវៃបានធ្វើឱ្យសរសៃអំបោះកាន់តែរឹងមាំ, ស្អាត, និងត្រឹមត្រូវជាងម៉ាស៊ីនបង្វិលដំបូង។ កីតម្បាញដើរដោយចំហាយទឹក របស់លោក **អេដមុន ខារ៉ៃ** (Edmund Cartwright:1743-1823) បានបង្កើនល្បឿនក្នុងការត្បាញបន្ទាប់ពីការបង្កើតវាឡើងនៅក្នុងឆ្នាំ១៧៨៥។

ម៉ាស៊ីនបង្វិលដោយប្រើចំហាយទឹក, រទេះរវៃ, និងកីតម្បាញជាម៉ាស៊ីនដែលមានទំហំធំ និងមានតម្លៃថ្លៃ។ ម៉ាស៊ីនទាំងនេះបាននាំយកការងាររវៃ និងត្បាញចេញមកខាងក្រៅផ្ទះ។ ពាណិជ្ជករវាយនភណ្ឌមានទ្រព្យសម្បត្តិច្រើន បានរៀបចំម៉ាស៊ីនទាំងនេះនៅក្នុងអគារធំៗ ដែលគេហៅថារោងចក្រ។ រោងចក្រត្រូវការកម្លាំងចំហាយទឹក ដូច្នេះរោងចក្រដំបូងត្រូវបានគេស្ថាបនាឡើងនៅជិតទន្លេ និងស្ទឹង។



កង់បង្វិលជេននី**(Jenny)**



ម៉ាស៊ីនបង្វិលដោយប្រើទឹក:Arkwright’s Water Frame



រទេះរវៃ Crompton’s spinning Mule



Cartwright's Power Loom

ប្រភព៖ https://www.worldhistory.org/article/2183/the-textile-industry-in-the-british-industrial-rev/

### ៥.៣-ការរីកចម្រើននៃគមនាគមន៍ និងការដឹកជញ្ជូន

កាលពីមុន មនុស្សធ្វើដំណើរ ឬដឹកជញ្ជូនទំនិញ ពីកន្លែងមួយទៅកន្លែងមួយ ដោយថ្មើរជើង ឬដោយរទេះសេះ។ ការធ្វើដំណើរតាមផ្លូវទឹកវិញត្រូវធ្វើឡើងតាមទូកដោយប្រើក្ដោង ឬចែវ។ ប៉ុន្តែ បដិវត្តន៍ឧស្សាហកម្ម

បាននាំទៅរកការបង្កើតមធ្យោបាយដឹកជញ្ជូនថ្មី ដែលអាចដឹកទំនិញបានច្រើនបានលឿន និងក្នុងរយៈចម្ងាយឆ្ងាយជាងមុន។

នៅដើមសតវត្សទី១៩ វិស្វករអាមេរិក បានសាងសង់កប៉ាល់ពាណិជ្ជកម្មដើរដោយម៉ាស៊ីនប្រើចំហាយទឹកជាលើកដំបូង ហើយក្រោយមកទៀត នៅពាក់កណ្តាលសតវត្សទី១៩ កប៉ាល់ដើរដោយចំហាយទឹកបានក្លាយជាមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ មហាសមុទ្រអាត្លង់ទិក។

នៅដើមសតវត្សទី១៩នោះដែរ បច្ចេកវិទ្យានៃម៉ាស៊ីនដើរដោយចំហាយទឹកក៏ត្រូវបានវិស្វករយកទៅប្រើនៅក្នុងវិស័យដឹកជញ្ជូនតាមផ្លូវដែកផងដែរ តាមរយៈការផលិតក្បាលរថភ្លើងដើរដោយចំហាយទឹក។ នៅឆ្នាំ១៨៣០ ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវដែកត្រូវបានដាក់ឱ្យដំណើរការជាលើកដំបូង ដោយតភ្ជាប់ពីទីក្រុង Liverpool ទៅទីក្រុង Manchester។

ភាពជឿនលឿននៅក្នុងឧស្សាហកម្មវាយនភណ្ឌ បានជំរុញឱ្យឧស្សាហកម្មផ្សេងៗទៀតមានការរីកចម្រើន។ ការអភិវឌ្ឍដំបូងៗមួយចំនួនដូចជា ម៉ាស៊ីនប្រើចំហាយទឹក ក្នុងគោលបំណងស្វែងរកនូវធនធានដែលមានចំនួនច្រើន និងមានតម្លៃថោក។ នៅដើមឆ្នាំ១៧០៥ អ្នកដឹកឮងថ្មបានប្រើប្រាស់ម៉ាស៊ីនបូមដែលប្រើកម្លាំងចំហាយទឹកដើម្បីយកទឹកចេញពីអណ្តូងរ៉ែជ្រៅៗ។ ប៉ុន្តែប្រភេទនៃម៉ាស៊ីប្រើចំហាយទឹកដំបូងនេះត្រូវការឥន្ធនៈក្នុងបរិមាណដ៏ច្រើន ដែលធ្វើឱ្យមានការចំណាយច្រើនក្នុងការប្រើប្រាស់វា។

សំឡីកប្បាសរបស់អង់គ្លេស ត្រូវបានគេយកមកពីតំបន់ដាំដុះដំណាំកប្បាសនៅអាមេរិកខាងត្បូង នៅអំឡុងទសវត្សឆ្នាំ១៧៩០។ ការយកចេញនូវគ្រាប់ពីកប្បាសនៅជាការងារដ៏លំបាកមួយ។ នៅក្នុងឆ្នាំ១៧៩៣ អ្នកបង្កើតថ្មី ជនជាតិអាមេរិកមួយរូបឈ្មោះ អេលី វីតនី (Eli Whitney) បានបង្កើតម៉ាស៊ីនមួយដើម្បីបង្កើនល្បឿនការងារនេះ។ ម៉ាស៊ីនយកគ្រាប់កប្បាសចេញរបស់លោកបានបង្កើនល្បឿនយកគ្រាប់កប្បាសចេញបានទ្វេដង។ ផលិផលសំឡីកប្បាសរបស់អាមេរិកបានកើនឡើងពី១.៥ លានផោននៅក្នុងឆ្នាំ១៩៧០ រហូតដល់៨៥លានផោននៅក្នុងឆ្នាំ១៨១០។

នៅក្នុងឆ្នាំ១៧៦៥ លោក ជេម វ៉ាត(James Watt) បានស្វែងរកឃើញនូវវិធីមួយដើម្បីបង្កើតម៉ាស៊ីនចំហាយទឹកដើរលឿន និងមានប្រសិទ្ធភាពខ្ពស់ ខណៈពេលដែលប្រើប្រាស់ឥន្ទនៈតិចតួចប៉ុណ្ណោះ។ នៅក្នុងឆ្នាំ១៧៧៤ លោក វ៉ាត បានចូលរួមជាមួយនឹងអ្នកជំនួញមួយរូបឈ្មោះថា ម៉ាស៊ូ បូតុន (Thomas Boulton)។ លោក បូតុន គឺជាសហគ្រិនមួយរូប ដែលជាអ្នករៀបចំ, គ្រប់គ្រង, និងពិនិត្យមើលលើហានិភ័យនៃជំនួញមួយ។ លោកបានផ្តល់ប្រាក់ខែដល់លោក វ៉ាត និងបានលើកទឹកចិត្តឱ្យគាត់ស្ថាបនាម៉ាស៊ីនចំហាយទឹកដ៏ប្រសើរមួយ។

ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវទឹក៖ ចំហាយទឹកក៏អាចរុញច្រានទូកឱ្យទៅមុខបានផងដែរ។ អ្នកបង្កើតថ្មីជនជាតិអាមេរិកម្នាក់ឈ្មោះ រ៉ូបឺត ហ្វ៊ុតុន(**Robert Fulton**) បានកម្មង់ម៉ាស៊ីនចំហាយទឹករបស់លោក បូតុន និងលោក វ៉ាត។ លោកបានស្ថាបនានាវាប្រើចំហាយទឹកមួយដែលគេហៅថា ក្លឺមុន (***Clermont***) ដែលវាបានធ្វើដំណើរដោយជោគជ័យជាលើកដំបូងនៅក្នុងឆ្នាំ១៨០៧។ នាវា ក្លឺមុន ក្រោយមកបានដឹកជញ្ជូនអ្នកធ្វើដំណើរទៅមកនៅតាមដងទន្លេ ហុតសុន នៅញូវយ៉ក។

នៅក្នុងប្រទេសអង់គ្លេស ការដឹកជញ្ជូនតាមផ្លូវទឹកត្រូវបានអភិវឌ្ឍឡើងជាមួយនឹងការបង្កើតប្រព័ន្ធព្រែកជីកមួយ ឬគេហៅថា ប្រព័ន្ធផ្លូវទឹកដែលបង្កើតឡើងដោយមនុស្ស។ ត្រឹមពាក់កណ្តាលទសវត្សឆ្នាំ១៨០០ តាមរយៈព្រែកជីកប្រវែងប្រមាណ៤២៥០ ម៉ាយ វាបានជួយកាត់បន្ថយការចំណាយលើការដឹកជញ្ជូនទាំងវត្ថុធាតុដើម និងផលិតផលសម្រេច។

ប្រព័ន្ធដឹកជញ្ជូនផ្លូវគោក៖ ផ្លូវថ្នល់នៅចក្រភពអង់គ្លេសត្រូវបានអភិវឌ្ឍដូចជាផ្លូវទឹកដែរ។ ការរីកចម្រើននេះជាការប្រឹងប្រែងរបស់លោក ចន ម៉ាកអាដាំ(John McAdam) ដែលជាវិស្វករជនជាតិស្កុតលែន។ ចាប់ផ្តើមធ្វើការងារនៅដើមទសវត្សឆ្នាំ១៨០០ លោកបានចាក់លើខ្នងផ្លូវនូវដុំថ្មធំៗទ្រាបពីលើដីសម្រាប់ សម្ងួតទឹក។ នៅពីលើថ្មធំៗនេះ លោកបានចាក់ទ្រនាប់ថ្មតូចៗឱ្យស្មើ។ បើទោះបីជាស្ថិតនៅក្នុងរដូវភ្លៀងក៏ដោយរទេះកង់បួនអាចធ្វើដំណើរពីលើផ្លូវចាក់ថ្មថ្មីនេះ ដោយមិនជាប់ផុងឡើយ។

អ្នកវិនិយោគឯកជននានាបានបង្កើតក្រុមហ៊ុនដើម្បីស្ថាបនាផ្លូវថ្នល់ ហើយបន្ទាប់មកបានដំណើរការដើម្បីស្វែងរកប្រាក់ចំណេញ។ ប្រជាជនបានហៅផ្លូវថ្មីនេះថាផ្លូវយកលុយ ដោយសារតែអ្នកធ្វើដំណើរទាំងឡាយត្រូវឈប់នៅបញ្ជរបង់ប្រាក់ដើម្បីបង់ប្រាក់ថ្លៃឆ្លងកាត់ នៅពេលដែលយើងចង់ធ្វើដំណើរទៅមុខទៀត។

ម៉ាស៊ីនចំហាយទឹកបានបង្កើនអំណាចដល់រោងចក្រនានានៅអង់គ្លេស នាចុងទសវត្សឆ្នាំ១៧០០។ ម៉ាស៊ីនចំហាយទឹកមួយដែលមានកង់រត់លើផ្លូវដែក (ក្បាលអយស្ម័យយាន) បានជំរុញឱ្យឧស្សាហកម្មនៅអង់គ្លេសកាន់តែមានសន្ទុះខ្លាំងបន្ទាប់ពីឆ្នាំ១៨២០។

នៅក្នុងឆ្នាំ១៨០៤ វិស្វករជនជាតិអង់គ្លេសមួយរូបឈ្មោះ រីឆាត ត្រេវីស៊ីក (Richard Trevithick) បាន ១០តោនក្នុងរយៈ ចំងាយផ្លូវជិត១០ម៉ាយ នៅលើក្បាលឈ្នះការភ្នាល់មួយដែលមានទឹកប្រាក់រាប់ពាន់ដុល្លា។ លោកឈ្នះការភ្នាល់នេះតាមរយៈការដឹកជញ្ជូនដល់ចំនួនអយស្ម័យយានប្រើចំហាយទឹកមួយ។ ក្នុងដំណាក់កាលនោះវិស្វករអង់គ្លេសដទៃទៀត បានអភិវឌ្ឍក្បាលអយស្ម័យយានរបស់លោក ត្រេវីស៊ីក។ វិស្វករផ្លូវដែកដំបូងម្នាក់ នៅក្នុងចំណោមនោះគឺលោក ចច ស្តេហ្វិនសុន(George Stephenson)។ លោកទទួលបានកិត្តិនាមដ៏ល្បីល្បាញមួយតាមរយៈការស្ថាបនា ម៉ាស៊ីនចំនួនជាង២០ សម្រាប់ដំណើរការដឹករុករករ៉ែនៅ ភាគខាងជើងអង់គ្លេស។ នៅក្នុងឆ្នាំ១៨២១ លោក ស្តេហ្វិន សុន បានចាប់ផ្តើមធ្វើការលើគម្រោងផ្លូវដែកដំបូងបំផុតលើលោក។ ផ្លូវដែននេះមានប្រវែង២៧ ម៉ាយ ដោយចេញដំណើរពីតំបន់ធ្យូងថ្មយ៉កស៊ី ទៅកាន់កំពង់ផែស្តុកតុន នៅសមុទ្រខាងជើង។ នៅក្នុងឆ្នាំ១៨២៥ ផ្លូវដែកត្រូវបានគេដាក់ឱ្យដំណើរការ។ វាត្រូវបាន ប្រើប្រាស់ក្បាលអយស្ម័យយាន៤ ដែលលោក ស្តេហ្វិនសុន បានរចនានិងស្ថាបនាឡើង។

ព័ត៌មានអំពីភាពជោគជ័យនេះ បានរីករាលដាលយ៉ាងឆាប់រហ័សនៅពាសពេញចក្រភពអង់គ្លេស។ សហគ្រិននានានៅអង់គ្លេសភាគខាងជើងចង់បានផ្លូវដែកមួយខ្សែដើម្បីភ្ជាប់តំបន់កំពង់ផែលីវើភូល ជាមួយទីក្រុងមែនឆេស្ទ័រ។ ក្រោយមកផ្លូវដែកនេះត្រូវបានគេស្ថាបនាឡើង។ នៅក្នុងឆ្នាំ១៨២៩ ការវិនិច្ឆ័យត្រូវបានធ្វើឡើងដើម្បីជ្រើសរើសក្បាលអយស្ម័យយាន ដែលល្អបំផុតសម្រាប់ប្រើប្រាស់នៅលើផ្លូវដែកថ្មីនេះ។ មានក្បាលម៉ាស៊ីនអយស្ម័យយានចំនួន៥ បានចូលរួមនៅក្នុងការប្រកួតប្រជែងនេះ។ គ្មានក្បាលអយស្ម័យយានមួយណាអាចប្រជែងជាមួយ រ៉ុកកែត (*Rocket*) ដែលរចនាឡើងដោយលោក ស្តេហ្វិនសុន និងកូនរបស់លោកបានឡើយ។ ផ្សែងបានហុយចេញពីបំពង់ផ្សែងដ៏វែងរបស់ រ៉ុកកែត ហើយវាមានប៊ីស្តុងចំនួន២ នៅពីខាងមុខ ដោយកង់ខាងមុខគឺជាអ្នកអូសទូរថភ្លើងទាំងមូល។ ក្បាលអយស្ម័យយានអាចដឹកជញ្ជូនទំនិញបានទម្ងន់ រហូតដល់១៣តោន នៅក្នុងល្បឿនថ្មីមួយ គឺជាង ២៤ម៉ាយក្នុងមួយម៉ោង។ ផ្លូវដែក លីវើភូល-មែនឆេស្ទ័រ បានបើកដំណើរការ ជាផ្លូវការនៅក្នុងឆ្នាំ១៨៣០។ នេះគឺជាជោគជ័យដ៏ធំធេងមួយ។

ការបង្កើត និងធ្វើឱ្យប្រសើរឡើងនូវក្បាលអយស្ម័យយាន បានជះឥទ្ធិពលសំខាន់ៗយ៉ាងតិចចំនួន៤ ដល់ចក្រភពអង់គ្លេស។ ទី១ ផ្លូវដែកបានរុញច្រានឱ្យឧស្សាហកម្មរីកលូតលាស់ តាមរយៈការផ្តល់ឱ្យម្ចាស់សហគ្រាសនូវការដឹកជញ្ជូនវត្ថុធាតុដើម និងផលិតផលសម្រេចក្នុងតម្លៃថោកមួយ។ ទី២ បន្ទុះនៃផ្លូវដែក បាន

បង្កើតការងារថ្មីរាប់ម៉ឺនសម្រាប់កម្មករផ្លូវដែក និងកម្មករជីករ៉ែ។ ពួកកម្មករជីករ៉ែទាំងនេះបានផ្ដល់នូវដែកសម្រាប់ធ្វើផ្លូវ និងធ្យូងថ្មសម្រាប់ម៉ាស៊ីនប្រើចំហាយទឹក។ ទី៣ ផ្លូវដែកបានលើកកម្ពស់កសិកម្ម និងឧស្សាហកម្ម នេសាទរបស់អង់គ្លេស ដែលប្រជាកសិករអាចដឹកជញ្ជូនទំនិញរបស់ពួកគេទៅកាន់ទីក្រុង ឆ្ងាយៗ។ ចុងក្រោយតាមរយៈការផ្ដល់ភាពងាយស្រួលនៅក្នុងការធ្វើដំណើរ ផ្លូវដែកបានជំរុញឱ្យមនុស្សនៅ ទីជនបទធ្វើដំណើរទៅកាន់ទីក្រុងឆ្ងាយៗ ដើម្បីស្វែងរកការងារធ្វើ។ ជាមួយនោះផងដែរ ផ្លូវដែកក៏បាន ទាក់ទាញអ្នករស់នៅក្នុងទីក្រុងឱ្យទៅកំសាន្តនៅទីជនបទផងដែរ។ បដិវត្តឧស្សាហកម្មបាននាំមកនូវការផ្លាស់ប្ដូរជីវិតរស់នៅរបស់ប្រជាជនយ៉ាងខ្លាំង[447]។

នៅឆ្នាំ១៨៤៨ រថភ្លើងមានបំពង់ផ្សែង ហ្វ្រាំងខ្យល់ទប់ល្បឿនជួយរក្សាសុវត្ថិភាព កម្លាំងនិងល្បឿន ១០០Km/h។ ចាប់ពីឆ្នាំ១៨១៤ ដល់១៩៥០ នៅតំបន់អឺរ៉ុបខាងលិចគ្របដណ្ដប់ទៅដោយប្រព័ន្ធផ្លូវដែកណែនណាន់តាន់តាប់[448]។

**ផ្លូវអេយស្វ័យយានទី១** ដែលឆ្លងកាត់អាម៉េរិកអាចបណ្ដាលឱ្យមានកំណើនប្រជាជន និងអាចបង្ហាញឱ្យឃើញពីទឹកដីធំធេងនៅសហរដ្ឋអាម៉េរិក ១៨៦៨ នៅកាណាដា១៨៨៥ និងនៅរុស្ស៊ីនៅក្នុងឆ្នាំ១៩០៣[449]។

នាវានៅតាមដងទន្លេ និងសមុទ្ទទាំងឡាយកាន់តែរីកចម្រើនឡើងជាលំដាប់ បំពាក់ដោយឆ្នាំងចំហាយទឹក កង់ស្លាបរហាត់ បន្ទាប់មកជាស្លាបចក្រ។ នាវាទាំងនោះមានល្បឿនលឿន និងទៀងទាត់។ នាវាដែលប្រើដោយចំហាយទឹកនិងស្រោបដោយដែកថែបត្រូវបានចូលមកជំនួសនាវាដែលប្រើក្ដោង។ ព្រែកជីក «ស៊ុយអេ» ដែលបានបើកឱ្យប្រើប្រាស់ក្នុងឆ្នាំ១៨៦៩ និងព្រែកជីក «ប៉ាណាម៉ា» ដែលជីកហើយនៅ ឆ្នាំ១៩១៤ អាចកាត់បន្ថយចម្ងាយផ្លូវឱ្យខ្លី។ ជាលើកដំបូងដែលរថភ្លើងនិងនាវាដើរដោយចំហាយទឹក អាចដឹកជញ្ជូនបានយ៉ាងរហ័ស ចំណុះក៏ច្រើនក្នុងចម្ងាយដ៏ឆ្ងាយនិងក្នុងតម្លៃថោក។

ម៉ាស៊ីនផ្ទុះបង្កើតឡើងដោយជនជាតិអាល្លឺម៉ង់ ដែមឡឺរ និងបេន (Daimler and Benz) បង្ហាញមុនដំបូងពីរថយន្ត។ អ្នកស្ថាបនារថយន្ត ដូចជាលោក រីណូ (Renault) ប៊ុយហ្គាទី (Bugatti) និងឡឺវ៉ាស័រ (Le Vassor) បានប្រឈមមុខគ្នាក្នុងការប្រកួតប្រណាំងរថយន្ត ចំណែកឯលោក ដុនឡុប (Dunlop) បង្កើតសំបកកង់ឡាន។ នៅឆ្នាំ១៩០៣ លោក ហ្វ្រេរ៉ាយ (Frere Wright) ហោះហើរដោយប្រើគ្រឿងឧបករណ៍ធ្ងន់ជាងខ្យល់ ហើយលោក ប្លេរីយ៉ូ (Bleriot) ឆ្លងកាត់តំបន់ម៉ង់ (Manche) ដោយយន្តហោះនៅក្នុងឆ្នាំ១៩០៩។

ប្រព័ន្ធទូរគមនាគមន៍វិញក៏ស្គាល់នូវភាពជឿនលឿនដ៏គួរឱ្យកត់សម្គាល់ដែរ នៅក្នុងសម័យកាលបដិវត្តន៍ឧស្សាហកម្ម ជាពិសេស តាមរយៈការបង្កើតតេឡេក្រាហ្វ (Télégraphe) ដោយវិស្វករអង់គ្លេស នៅអំឡុងឆ្នាំ១៨៣០។

## ៥.៤-ការផ្លាស់ប្ដូរផ្នែកសង្គម

បើនិយាយខាងផ្នែកសង្គមវិញ បដិវត្តន៍ឧស្សាហកម្មបានធ្វើឱ្យប្រជាជន ដែលកាលពីមុនរស់នៅតាមទីជនបទ នាំគ្នាមករស់នៅប្រមូលផ្ដុំគ្នា នៅតាមទីក្រុង ដែលជាកន្លែងសម្បូររោងចក្រ និងសម្បូរការងារធ្វើ។ ការកើនឡើងនៃសមត្ថភាពផលិតបានធ្វើឱ្យថ្លៃសម្ភារៈប្រើប្រាស់ ជាពិសេស ក្រណាត់ និងសម្លៀកបំពាក់ មាន

[447] គួង គីនី, *ប្រវត្តិសាស្ត្រពិភពលោក*, ទំព័រ៤០៥។

[448] ក្រសួងអប់រំ យុវជន និង កីឡា, *សិក្សាសង្គម ថ្នាក់ទី១០* , ដ.ឯ.ម., ទំព័រ១០០។

[449] -ដ- ទំព័រ១០០។

ការធ្លាក់ចុះ។ ប្រជាជនទូទៅមានប្រាក់ចំណូលច្រើន និងមានជីវភាពធូរជារជាងមុន។ ប៉ុន្តែ ក្នុងពេលជាមួយគ្នា មានអ្នកខ្លះបានរិះគន់ថា បដិវត្តន៍ឧស្សាហកម្មក៏បានបង្កជាបញ្ហាយ៉ាងច្រើនផងដែរ ទាក់ទងនឹងលក្ខខណ្ឌការងាររបស់កម្មករ។ កម្មករត្រូវធ្វើចំណាកស្រុក ឃ្លាតឆ្ងាយពីក្រុមគ្រួសារ និងភូមិកំណើត ដើម្បីទៅធ្វើការនៅតាមទីក្រុង។ កម្មករនីមួយៗត្រូវធ្វើការពី១២ម៉ោង ទៅ១៤ម៉ោងក្នុងមួយថ្ងៃ ហើយរោងចក្រត្រូវបានសាងសង់ដោយមិនបានគិតគូរម៉ត់ចត់ អំពីសន្តិសុខ និងសុខមាលភាពរបស់កម្មករ។

នៅសហរដ្ឋអាម៉េរិកវិញ ការកើនឡើងនៃសកម្មភាពផលិតនៅក្នុងវិស័យវាយនភណ្ឌបានធ្វើឱ្យតម្រូវការកប្បាសមានការកើនឡើងខ្លាំង ហើយការទិញដូរទាសករស្បែកខ្មៅ ដើម្បីយកទៅធ្វើការក្នុងចម្ការកប្បាសក៏មានការកើនឡើងខ្លាំង។ បញ្ហាទាសករ ដែលធ្លាប់ជាបញ្ហាចម្រូងចម្រាសស្រាប់ ចាប់តាំងពីពេលកកើតសហរដ្ឋអាម៉េរិក ក៏បានក្លាយជាបញ្ហាកាន់តែធំ រហូតរាលដាលទៅជាសង្គ្រាមស៊ីវិល រវាងរដ្ឋរបស់អាម៉េរិក នៅឆ្នាំ១៨៦១[450]។

នៅត្រឹមឆ្នាំ១៨៦៩ រដ្ឋាភិបាលសហព័ន្ធអាម៉េរិក បានស្ថាបនាផ្លូវរថភ្លើងពីរខ្សែ។ ខ្សែទី១ មានឈ្មោះថា សហភាពប៉ាស៊ីហ្វិក និងខ្សែទី២មានឈ្មោះថា ប៉ាស៊ីហ្វិកកណ្តាល។ ការបង្កើតផ្លូវរថភ្លើងផ្តល់ផលប្រយោជន៍ជាច្រើនដូចជា ការដឹកជញ្ជូនអ្នកដំណើរ និងផលិតផលកសិកម្មទៅកាន់កំពង់ផែជាដើម។ ក្នុង រយៈពេលតែ ២៥ឆ្នាំ ទឹកដីសហរដ្ឋអាម៉េរិកនៅតំបន់ទំនាបកណ្តាល បានប្រែក្លាយពីតំបន់ព្រៃមកជាតំបន់ពាណិជ្ជកម្ម និងចម្ការដំណាំ។ ការអភិវឌ្ឍនេះបានដុតបំផ្លាញព្រៃឈើ និងសម្លាប់ជនជាតិស្បែកក្រហមយ៉ាងវង្វាលគ្មានត្រាប្រណី។ ការកាប់សម្លាប់ផ្តាច់ពូជនេះ បានធ្វើឱ្យពួកស្បែកក្រហមមានចំនួនកាន់តែតិចទៅៗ ស្ទើរផុតពូជនៅលើទឹកដីកំណើតរបស់ខ្លួន។

**សំណួររំឭកមេរៀន**

១-តើសង្គមសក្តិភូមិអឺរ៉ុបក្នុងមជ្ឈិមសម័យបែងចែកវណ្ណៈដូចម្តេច?

២-តើបុនសម័យចាប់កំណើតនៅប្រទេសណា? មូលហេតុអ្វី?

៣-ចូររៀបរាប់ពីការរីកចម្រើននៃវិទ្យាសាស្ត្រ និងទស្សនៃការគ្រប់គ្រង ដែលទទួលឥទ្ធិពលពីបុនសម័យ។

៤-តើការរុករកផ្លូវ និងដីថ្មីរបស់ពួកអឺរ៉ុប មានគោលបំណងអ្វីខ្លះ?

៥-តើបដិវត្តន៍គហបតីនៅអង់គ្លេសកើតឡើងដោយសារមូលហេតុអ្វីខ្លះ?តើបដិវត្តន៍នេះផ្តល់ផលវិបាកដូចម្តេច?

៦-ចូរពន្យល់ពីមូលហេតុ និងផលវិបាកនៃបដិវត្តន៍គហបតីនៅប្រទេសបារាំង ឆ្នាំ១៧៨៩។

៧-តើបដិវត្តន៍ឧស្សាហកម្មផ្តើមឡើងនៅប្រទេសណា? ដោយសារមូលហេតុអ្វីខ្លះ?

[450] សេង ឌីណា *ប្រវត្តិសាស្ត្រពិភពលោក* : ការចេញផ្សាយរបស់វិទ្យុបារាំងអន្តរជាតិ RFI អាទិត្យ 12 មករា 2014

# មេរៀនទី៣ ស្ថានភាពពិភពលោកមុនសង្គ្រាមលោកលើកទី១

## ១-ប្រទេសមហាអំណាចនៅត្រឹមដើមសតវត្សទី២០

### ១.១-ចក្រភពអង់គ្លេសមុនសង្គ្រាមលោកលើកទី១

អង់គ្លេសជាប្រទេសដែនកោះ (អឺរ៉ុបដែនទឹក)ដែលខណ្ឌចែកពីអឺរ៉ុបដីគោកដោយច្រកសមុទ្រម៉ង់ (Manche) ដែលមានចម្ងាយ៣២Km។ ទឹកដីអង់គ្លេសចែកជា៤គឺ ក្រង់ប្រីតាញ អេកូស ប្រទេសហ្កាល់ អៀរឡង់ខាងជើង។ ចក្រភពអង់គ្លេសមានទំហំទឹកដី២២៤ ០៤៦ km$^2$ និងមានប្រជាជនចំនួនប្រជាជន៥៨លាននាក់(២០០៦)[451]។

នៅមុនសង្គ្រាមលោកលើកទី១ ប្រទេសអង់គ្លេសបានរីកចម្រើនជាខ្លាំងក្នុងវិស័យៈ

- ❖ នយោបាយក្នុងប្រទេសដោយបាននិយមលទ្ធិប្រជាធិបតេយ្យទូលំទូលាយ
- ❖ នយោបាយសេដ្ឋកិច្ច អនុវត្តរបបប្តូរដោយសេរី
- ❖ នយោបាយអាណានិគមដោយបានពង្រីកទឹកដីចក្រភពឱ្យបានទូលាយ[452]
- ❖ មកដល់ត្រឹមដើមសតវត្សទី២០ អង់គ្លេសជាប្រទេសមហាអំណាចជើងទឹកទី១ ហើយប្រទេសនេះបានឈានចូលក្នុងបដិវត្តន៍ឧស្សាហកម្មមុនគេ។

#### ១.១.១-ការចម្រើនខាងលទ្ធិប្រជាធិបតេយ្យ

**ក-កំណែទម្រង់នយោបាយ**

ប្រទេសអង់គ្លេស បានប្រកាន់យកលទ្ធិរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញជាយូរយាណាស់មកហើយ ពោលគឺមិនមែនរាជានិយមផ្តាច់ការដូចនៅប្រទេសដទៃឡើយ។ តែនៅសម័យនោះលទ្ធិប្រជាធិបតេយ្យអង់គ្លេសមិនទាន់មានលក្ខណៈបរិសុទ្ធភ្លាមៗដែរពីព្រោះ ៖

-នៅសភាឡូតក៏ដូចជានៅសភាខំមូនដែរ ពុំមានតំណាងប្រជាពលរដ្ឋទូទៅពិតប្រាកដទេមានតែតំណាងពួកអ្នកមាន និងពួកអភិជន

-របៀបបោះឆ្នោតរើសតំណាងរាស្ត្រ ពុំមានលក្ខណៈដូចគ្នានៅគ្រប់មណ្ឌលទាំងអស់ក្នុងប្រទេសអង់គ្លេសទាំងមូលឡើយ

-គេពុំដែលបានរៀបចំមណ្ឌលបោះឆ្នោតឡើងវិញឡើយ។ មណ្ឌលខ្លះដែលប្រជាជនចាកចេញស្ទើរតែអស់ទៅហើយក៏នៅមានតំណាងរាស្ត្រដដែល ហើយមានមណ្ឌលខ្លះទៀតដែលពលរដ្ឋបានកើនចំនួនច្រើននៅតែមិនទាន់មានតំណាងរាស្ត្រ។

-នៅសម័យបោះឆ្នោតម្តងៗ មានអំពើពុករលួយជាច្រើន។ រីឯកិច្ចការរដ្ឋបាលទូទៅនៅប្រទេសអង់គ្លេសទៀតក៏ធ្លាក់ទៅក្នុងកណ្តាប់ដៃពួកអ្នកមាន និងអភិជនដែរ។

អាស្រ័យហេតុដូចមាននៅខាងលើនេះហើយ បានជាគេនាំគ្នាកែទម្រង់នយោបាយ។ កំណែទម្រង់សំខាន់ៗ បានធ្វើជាបីលើកគឺ នៅឆ្នាំ១៨៣២ម្តង នៅឆ្នាំ១៨៦៧ម្តង និងឆ្នាំ១៨៨៤-១៨៨៥ម្តងទៀត។ កំណែទម្រង់ទាំងអស់នេះបានញាំងប្រទេសអង់គ្លេសឱ្យស្គាល់លទ្ធិប្រជាធិបតេយ្យដ៏បរិសុទ្ធមួយ ដែលប្រទេសដទៃទៀតក្នុងលោកតែងយកធ្វើជាគំរូ[453]។

---

451 ក្រសួងអប់រំ យុវជន និងកីឡា, *ប្រវត្តិវិទ្យាថ្នាក់ទី១២,* គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, ឆ្នាំ២០១៥, ទំព័រ១២។

452 ក្រសួងអប់រំជាតិ, ប្រវត្តិវិទ្យាថ្នាក់ទី៣, ដ.ឯ.ម., ទំព័រ៣៣។

453 -ដ- ទំព័រ៣៤។

**ខ-លក្ខណៈនៃលទ្ធិប្រជាធិបតេយ្យអង់គ្លេស**

បន្ទាប់ពីកំណែទម្រង់នេះមកប្រជាពលរដ្ឋអង់គ្លេស មានសិទ្ធិបោះឆ្នោតជាសកល (ដល់ឆ្នាំ១៩១៨ ទើបស្ត្រីអង់គ្លេសមានសិទ្ធិបោះឆ្នោតដូចបុរស)។ ចំណែកឯរបៀបបោះឆ្នោតវិញក៏មានឯកភាពនៅគ្រប់មណ្ឌលទាំងអស់ក្នុងប្រទេសទាំងមូល។ លទ្ធិប្រជាធិបតេយ្យអង់គ្លេស មានទំនៀមទម្លាប់ជាមូលដ្ឋាន ពោលគឺជនជាតិអង់គ្លេសនិយមប្រតិបត្តិការផ្សេងៗ មុននឹងតាក់តែងច្បាប់។ លុះសង្កេតឃើញថា ទម្លាប់នេះជាការប្រសើរហើយ គេក៏រៀបចំច្បាប់សម្រួលទៅ។

នៅប្រទេសអង់គ្លេសព្រះមហាក្សត្រសោយរាជ្យសម្បត្តិ តែព្រះអង្គមិនគ្រប់គ្រងប្រទេសឡើយ បានសេចក្តីថាព្រះមហាក្សត្រនៃប្រទេសអង់គ្លេស មិនជ្រៀតជ្រែកកិច្ចការរបស់រដ្ឋាភិបាល ហើយមិនដែលជំទាស់នឹងសេចក្តីសម្រេចរបស់សភាឡើយ។ ទម្លាប់នេះត្រូវបានយកមកអនុវត្តយ៉ាងពេញលេញបំផុត ចាប់ពីរជ្ជកាលព្រះមហាក្សត្រីយានីវិចតូរីយ៉ា គឺតាំងពីឆ្នាំ១៨៣៧ដល់ឆ្នាំ១៩០១។ គេចាត់ទុករជ្ជកាលនេះថាជាសម័យកំពូលនៃប្រវត្តិសាស្ត្រអង់គ្លេស។


Queen Victoria (1837–1901)


**Benjamin Disraeli**
**(February–December 1868, 1874-1880)**


**William Ewart Gladstone**
**(1868–74,1880–85, February–July 1886 and 1892–94)**[1]

លទ្ធិប្រជាធិបតេយ្យអង់គ្លេស បានរីកសាយភាយទៅកាន់ប្រទេសដទៃទៀត ក៏ប៉ុន្តែអនុវត្តន៍លទ្ធិនេះនៅបណ្តាប្រទេសដទៃទៀតពុំបានជោគជ័យដូចនៅប្រទេសអង់គ្លេសឡើយ។ នៅសម័យជាមួយគ្នានោះនៅប្រទេសបារាំង គណៈរដ្ឋមន្ត្រីត្រូវចំណុះសភា។ ចំណែកនៅប្រទេសអង់គ្លេសវិញ គណៈរដ្ឋមន្ត្រីមាន សេរីភាព និងអំណាចជាច្រើនក្នុងការបំពេញបេសកកម្មរបស់ខ្លួន។ នៅប្រទេសអង់គ្លេស គេទម្លាប់ប្រគល់តំណែងនាយករដ្ឋមន្ត្រី ទៅឱ្យគណបក្សដែលឈ្នះឆ្នោតគឺគណបក្សណាដែលមានតំណាងរាស្ត្រភាគច្រើននៅក្នុងសភា។

ដូចនេះនៅប្រទេសអង់គ្លេស មិនសូវមានវិបត្តិគណៈរដ្ឋមន្ត្រីដូចនៅប្រទេសបារាំងឡើយ។ នៅសម័យមុនសង្គ្រាមលោកលើកទី១ប្រទេសអង់គ្លេសមានគណបក្សនយោបាយតែពីរគឺ **គណបក្សអភិរក្សនិយម** និង **គណបក្សសេរីភាព**។ នាយករដ្ឋមន្ត្រីពីររូប ដែលមានកិត្តិនាមជាងគេនៅសម័យនោះគឺលោក **ឌីស្រាកអែលី** មេដឹកនាំគណបក្សអភិរក្សនិយម និងលោក **ក្លាតស្តូន** មេដឹកនាំគណបក្សសេរីភាព។ វរជនទាំងពីររូបនេះសុទ្ធតែ

ជាអ្នកស្រឡាញ់ និងការពារលទ្ធិប្រជាធិបតេយ្យតែមានមតិខុសគ្នាក្នុងនយោបាយក្រៅប្រទេស៖លោកឌីស្រាកអែលី និយមអនុវត្តនយោបាយអាណានិគម ចំណែកលោកក្លាត់ស្តូន និយមសន្តិភាព។

ក្នុងតំណែងនាយករដ្ឋមន្ត្រីទាំងពីររូបនេះ ប្រទេសអង់គ្លេសមានកំណែទម្រង់នយោបាយយ៉ាងច្រើន។ លោក ក្លាតស្តូន នៅតែរក្សាទម្រង់បោះឆ្នោះជាសម្ងាត់។ នៅក្នុងសភាឆ្នាំ១៨៧០ មានការអនុម័តច្បាប់អប់រំ ជាលើកដំបូង ដែលបើកទូលាយឱ្យជនជាតិអង់គ្លេសគ្រប់ស្រទាប់ចូលរៀននៅកម្រិតបឋមសិក្សាទូទាំងប្រទេស។ នៅឆ្នាំ១៨៧១ មានការអនុម័ត លើច្បាប់សហជីពកម្មករទៀត។ បន្ទាប់មកលោក ឌីស្រាកអេលី បានឡើងជានាយករដ្ឋមន្ត្រីនៅឆ្នាំ១៨៧៤ លោកបានធ្វើកំណែទម្រង់ទៅលើច្បាប់សង្គមជាច្រើនដូចជា ច្បាប់ទទួលសិទ្ធិនិយោគជក និងនិយោគជិតជាដើម ដែលជាទីសង្ឃឹមដល់វណ្ណៈកម្មករអង់គ្លេស។

ក្នុងរយៈពេល៦០ឆ្នាំ នៃការកែទម្រង់នយោបាយ នៅក្នុងរជ្ជកាលម្ចាស់ក្សត្រីវិចតូរីយ៉ា ប្រទេសអង់គ្លេសបានឈានដល់លទ្ធិសភានិយមយ៉ាងពិតប្រាកដ។ ចាប់ពីឆ្នាំ១៨៣៥ មកសូម្បីតែការជ្រើសតាំងអាជ្ញាធរភូមិរហូតដល់ក្រុង ក៏ប្រព្រឹត្តទៅដោយការបោះឆ្នោតទាំងអស់។ ផ្នែកសេវាមុខងារសាធារណៈទាំងអស់ត្រូវបើកចំហសម្រាប់ប្រជាពលរដ្ឋអង់គ្លេសទូទៅ។ ប៉ុន្តែលុះដល់ឆ្នាំ១៨៦០ មានការគិតគូរពីសមត្ថភាពអ្នកដឹកនាំ គេក៏ជ្រើសរើសមន្ត្រីតាមបែបប្រណាំងប្រជែង។ ការកែទម្រង់ច្បាប់ទាន់ពេលវេលា ជាពិសេសការចែងអំពីសិទ្ធិខាងលើ ធ្វើឱ្យនយោបាយប្រទេសអង់គ្លេស មានភាពធូរស្រាល ដោយពុំមានចលនាប្រឆាំងណាមួយធ្វើឱ្យរង្គោះរង្គើដល់រដ្ឋាភិបាលអង់គ្លេស។ គួរកត់សម្គាល់ថាដំណើររីកចម្រើននៃលទ្ធិប្រជាធិបតេយ្យនៅប្រទេសអង់គ្លេសបានប្រព្រឹត្តទៅដោយសន្តិវិធីគឺដោយគ្មានការបង្ហូរឈាមបដិវត្តន៍ ឬរដ្ឋប្រហារឡើយ។

ពេលវេលានេះជាឱកាសដែលផ្តល់ឱ្យប្រទេសអង់គ្លេស ពង្រីកខឿនឧស្សាហកម្មសមស្របទៅនឹងទំហំទីផ្សារ អាណានិគមដ៏ធំធេង ដែលជុំរុញឱ្យប្រទេសអង់គ្លេសក្លាយជាមហាអំណាចសេដ្ឋកិច្ចទី១ នៅលើពិភពលោកមុនពេល ផ្ទុះសង្គ្រាមលោកលើកទី១។

### ១.១.២-ការចម្រើនខាងសេដ្ឋកិច្ច

ចាប់តាំងពីសតវត្សទី១៩ម្ល៉េះ អង់គ្លេស ជាមហាអំណាចមួយសំខាន់ក្នុងខាងវិស័យសេដ្ឋកិច្ចដោយប្រទេសនេះបានឈានចូលដល់ដំណាក់កាលបដិវត្តន៍ឧស្សាហកម្មមុនគេ និងទទួលបានដែនដីអាណានិគមយ៉ាងច្រើន។ សេដ្ឋកិច្ចអង់គ្លេស រឹតតែចម្រើនយ៉ាងឆាប់រហ័សថែមទៀតចាប់តាំងពីឆ្នាំ១៨៤៦ ដោយប្រទេសអង់គ្លេសបានប្រកាន់យក **លទ្ធិសេដ្ឋកិច្ចប្តូរដោយសេរី** គឺការបើកសិទ្ធិឱ្យដឹកនាំទំនិញចេញចូលដោយសេរី ដោយពុំតម្រូវឱ្យបង់ពន្ធទំនិញទាំងនោះ ឬក៏យកតែបន្តិចបន្តួច។ លោករីឆែតកុបឌឹង ( Richard cobden ) ដែលជាឧស្សាហករដ៏ល្បីឈ្មោះមួយរូប ជាអ្នកផ្តើមគំនិតណែនាំប្រទេសអង់គ្លេសឱ្យអនុវត្តលទ្ធិសេដ្ឋកិច្ចនេះ។ ដោយកសិកម្មអង់គ្លេសពុំអាចប្រណាំងប្រជែងជាមួយនឹងបរទេសបាន ពួកកសិករអង់គ្លេសបានប្រឆាំងរបបសេដ្ឋកិច្ចនេះជាខ្លាំងតែពុំបានសម្រេច ហើយចាប់ពីឆ្នាំ១៨៤៦ មកប្រទេសអង់គ្លេសក៏ចាប់អនុវត្តរបប សេដ្ឋកិច្ចប្តូរដោយសេរីតាមការណែនាំរបស់លោក។

**របបសេដ្ឋកិច្ចនេះបានផ្តល់ចំពោះប្រទេសអង់គ្លេសនូវផលវិបាកដ៏ប្រសើរដូចតទៅ៖**

- ជីវភាពរបស់ប្រជាពលរដ្ឋទូទៅបានធូរធា ដោយគ្រឿងឧបភោគបរិភោគបានចុះថ្លៃថោកជាខ្លាំង
- ឧស្សាហកម្មអង់គ្លេសបានរីកចម្រើនជាខ្លាំង ដោយវត្ថុធាតុដើមបានចូលទៅក្នុងប្រទេសអង់គ្លេសបានយ៉ាងងាយស្រួល
- ពាណិជ្ជកម្មក៏បានរីកចម្រើនដោយមានទីផ្សារច្រើន។

ប្រទេសជាច្រើនបានយកគម្រូតាមប្រទេសអង់គ្លេស។ ម្លោះហើយលទ្ធិសេដ្ឋកិច្ចនេះបានផ្តល់ ផលវិបាកអាក្រក់ខ្លះទៅលើប្រទេសអង់គ្លេសវិញដែរចាប់តាំងពីឆ្នាំ១៨៧៥ពីព្រោះៈ

- ➢ កសិកម្មអង់គ្លេស បានជួបប្រទះនឹងការវិបាកកាន់តែខ្លាំងឡើងទៀតដោយត្រូវប្រណាំងប្រជែងនឹងកសិកម្មបរទេស
- ➢ ពាណិជ្ជកម្មអង់គ្លេសក៏មានការពិបាកដែរ ដោយប្រទេសអង់គ្លេសត្រូវប្រណាំងប្រជែងជាមួយនឹងប្រទេសដទៃទៀតដែលបានចម្រើនលូតលាស់ដែរដូចជាសហរដ្ឋអាម៉េរិក និងប្រទេសអាល្លឺម៉ង់ជាដើម។[454]

នៅក្នុងសតវត្សទី១៩ ប្រជាជនអង់គ្លេសមានកំណើនយ៉ាងលឿន គឺនៅឆ្នាំ១៨០០ មានចំនួន ១១លាននាក់ បានកើនឡើងរហូតដល់៤៦លាននាក់នៅឆ្នាំ១៩១៤។ កំណើនប្រជាជន គឺជាឃ្លាំងនៃប្រភពធនធានមនុស្សសម្រាប់ជំរុញ វិស័យឧស្សាហកម្មឱ្យលឿន។ វិស័យនេះទាក់ទាញប្រជាជនឱ្យធ្វើបំលាស់ទីពីជនបទមកកាន់ទីក្រុងដែលជាមជ្ឈមណ្ឌលឧស្សាហកម្ម។ បដិវត្តន៍ឧស្សាហកម្មត្រូវផ្សារភ្ជាប់នឹងកត្តាមួយចំនួនដូចជាវិស័យនាវាចរ ភាពសម្បូរដោយប្រភពថាមពលក្រោមដីគឺធ្យូងថ្ម និងរ៉ែដែក។ អង់គ្លេសជាប្រទេសមហាអំណាចជើងទឹក ដែលមាននាវាដឹកជញ្ជូនច្រើនជាងគេបង្អស់ ទំនិញសម្រាប់ដោះដូរលើទីផ្សារអាណានិគមត្រូវស្តុកទុក នៅកំពង់ផែទីក្រុងឡុង ដែលជាកំពង់ផែសំខាន់ជាងគេនៅសម័យនោះ។

អង់គ្លេសសម្បូរដោយថាមពលធ្យូងថ្ម ដែលមានជាច្រើនកន្លែង ដែលធ្វើឱ្យថាមពលនេះមានតម្លៃថោក។ គេប្រើថាមពលធ្យូងថ្មសម្រាប់រំលាយដែក និងសម្រាប់ប្រើម៉ាស៊ីនចំហាយទឹក។ នៅឆ្នាំ១៨៦០ អង់គ្លេសបានប្រើធ្យូងថ្ម ៨០លានតោន ហើយចំនួននេះកើនដល់ ៣០០លានតោននៅឆ្នាំ១៩១៣។ ចំណែករ៉ែដែក នៅប្រទេសអង់គ្លេសក៏សម្បូរណាស់ដែរ។ បដិវត្តន៍ឧស្សាហកម្មជំរុញឱ្យមានការកសាងផ្លូវដែក បង្កើតប្រព័ន្ធធនាគារ និងបើកឱ្យមានការប្រណាំងប្រជែងខាងទីផ្សារ។ រីឯដែកថែបវិញក៏មានការរីកចម្រើនណាស់ដែរ តាមរយៈបច្ចេកទេស គឺអង់គ្លេសបានផលិតដែកថែបនាំមុខគេ។

នៅក្នុងរជ្ជកាលរបស់មហាក្សត្រី វ៉ិច តូរី (១៨៣៧-១៩០១) ជាជំណាក់កាលដែលអង់គ្លេស មានកម្លាំងដ៏ខ្លាំងក្លាលើគ្រប់វិស័យ ចំនួនប្រទេសដែលស្ថិតនៅក្នុងអាណានិគមអង់គ្លេសបានកើនឡើងយ៉ាងឆាប់រហ័ស រីឯវិស័យឧស្សាហកម្មមានកម្រិតថ្នាក់លេខ១ លើសកលលោកជាអចិន្ត្រៃយ៍។ ចក្រភពអង់គ្លេសបានផលិតជាច្រើននូវផលិតផលធ្យូងថ្ម និងវាយនភណ្ឌ ដែលមានចំនួនច្រើនលើសផលិតផល របស់ប្រទេសអឺរ៉ុបទាំងអស់សរុបចូលគ្នាទៅទៀត។ អង់គ្លេសបានគ្រប់គ្រងលើនាវាចរពាណិជ្ជកម្មជាងពាក់កណ្តាលនៃចំនួននាវាចរពាណិជ្ជកម្មពិភពលោក រីឯមូលនិធិរបស់អង់គ្លេសដែលដាក់ធ្វើវិនិយោគ នៅបរទេសមានចំនួនច្រើនលើសចំនួនមូលនិធិ សរុបសកលលោកទៅទៀត។ ប្រទេសអង់គ្លេស និងអាល្លឺម៉ង់ បានស្លដែកថែបស្មើនឹង ២/៣ នៃចំនួនសរុបលើសកលលោកនៅឆ្នាំ១៩០០[455]។

ឥទ្ធិពលបដិវត្តន៍ឧស្សាហកម្មនៅអង់គ្លេស បានរីកសាយទៅដល់ប្រទេសមួយចំនួនទៀតដូចជា អាល្លឺម៉ង់ បារាំង អ៊ីតាលី សហរដ្ឋអាម៉េរិក និងជប៉ុនជាដើម។ បដិវត្តន៍ឧស្សាហកម្មបង្កើតឱ្យមានការប្រណាំងប្រជែងខាងទីផ្សារ និងខាងបច្ចេកវិទ្យា ជាពិសេសប្រទេសអាល្លឺម៉ង់ជាប្រទេសដែលទទួលនូវបដិវត្តន៍ ឧស្សាហកម្ម

[454] ក្រសួងអប់រំជាតិ, *ប្រវត្តិវិទ្យាថ្នាក់ទី៣,* ជ.ឯ.ម., ទំព័រ៣៧។

[455] ដៀប សុផល, *ពិភពលោកសតវត្សទី២០ អឺរ៉ុប និងអាម៉េរិកខាងជើង*, ភ្នំពេញ, ឆ្នាំ២០០៤, ទំព័រ១៤។

ក្រោយគេ បានប្រណាំងប្រជែងជាមួយប្រទេសអង់គ្លេសខាងផ្នែកជើងទឹក។ ដើម្បីដណ្ដើមទីផ្សារនៅទ្វីបអាហ្វ្រិក អាល្លឺម៉ង់ និងអង់គ្លេស បានប្រណាំងប្រជែងខាងសព្វាវុធ និងហួតដល់បង្កើតនូវសង្គ្រាមលោកលើកទី១។

### ១.១.៣-ការចម្រើនខាងនយោបាយអាណានិគម

ប្រទេសអង់គ្លេសក៏ដូចជាមហាអំណាចដទៃទៀតនៅទ្វីអឺរ៉ុបដែរ បានខំពង្រឹងនយោបាយអាណានិគម របស់ខ្លួននៅមុនសង្គ្រាមលោកលើកទី១ដើម្បីឱ្យបានសម្រេច *គោលដៅបួនយ៉ាង* ដ៏សំខាន់គឺះ

- រកវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មអង់គ្លេស
- រកទីផ្សារសម្រាប់ទំនិញអង់គ្លេស
- តាំងមូលដ្ឋានសឹកអង់គ្លេសនៅបរទេស
- ពង្រីកកិត្យានុភាពអង់គ្លេសលើផ្ទៃរាបអន្តរជាតិ។[456]

នយោបាយអាណានិគមអង់គ្លេសច្រើនតែមានជោគជ័យជាងប្រទេសដទៃទៀត។ នៅមុនសង្គ្រាមលោក លើកទី១ស្រុកចំណុះអង់គ្លេសមានដូចតទៅះ

១-**នៅទ្វីបអាស៊ីះ** មានឥណ្ឌា ភូមា ម៉ាឡេស៊ី សិង្ហបុរី(Singapour) ចិន(ហុងកុងនិងភូមិភាគខ្លះនៃ ប្រទេសចិន) ស៊ីប(Chypre) អាដិន(Aden) អាហ្វហ្គានីស្ថាន(Afghanistan)

២-**នៅទ្វីបអាហ្វ្រិក ះ** មានអេហ្ស៊ីប (Egypte) នីហ្សេរីយ៉ា(Nigeria) អាហ្វ្រិកខាងកើត អាហ្វ្រិកខាងត្បូង

៣-**នៅទ្វីអូសេអានីះ** មាន ញូវហ្សេឡង់ និងអូស្ត្រាលី

៤-**នៅទ្វីបអឺរ៉ុប ះ** មានអៀឡង់ (IrLande)

៥-**នៅទ្វីបអាម៉េរិកះ** កាណាដា(Kanada)

នៅឆ្នាំ១៩១៤ស្រុកចំណុះអង់គ្លេសមានទំហំ ១/៤ នៃផ្ទៃដីពិភពលោក ហើយមានប្រជាជន១/៤នៃ ប្រជាជនពិភពលោក។

#### ១.១.៣.១-ទ្វីបអាស៊ី

**ប្រទេសឥណ្ឌាះ** ពួកអង់គ្លេសបានមកដល់ប្រទេសឥណ្ឌា ឆ្នាំ១៦០៨ តាមកប៉ាល់មួយគ្រឿងឈ្មោះអ៊ិចទ័រ (Hector) ដែលមានមេបញ្ជាការឈ្មោះ វិល្លៀមហាវគីន(William Hawkin)។ នៅប្រទេសឥណ្ឌា អង់គ្លេស បានធ្វើសង្គ្រាមជាមួយពួកព័រទុយហ្គាល់ ដើម្បីដណ្ដើមមូលដ្ឋានទ័ពឈ្មោះអូមូលនៅឆ្នាំ១៦២២។ ក្រោយមក ទៀតអង់គ្លេស បានធ្វើសង្គ្រាមជាមួយបារាំង ដើម្បីដណ្ដើមកាន់កាប់តំបន់បេងហ្គាល់ ដោយបារាំងទទួលបរាជ័យ។ អង់គ្លេសបានត្រួតត្រាឥណ្ឌាអស់៥រជ្ជកាលស្ដេច។ ស្ដេចនីមួយៗបានតែងតាំងអគ្គទេសាភិបាល ឬឧបរាជមួយ រូបដើម្បីសោយរាជ្យនៅប្រទេសឥណ្ឌា ដែលមានប្រជាជន ៣០០លាននាក់។ អគ្គទេសាភិបាលគង់នៅក្នុងរាជ វាំងមួយដ៏ល្អស្កឹមស្កៃ ដែលហែហមដោយបរិវារជាមន្ត្រីឥណ្ឌាចំនួន១០០០នាក់ ការពារដោយទាហានឥណ្ឌា ១០ពាន់នាក់។

ជនជាតិឥណ្ឌាគ្រប់រូបបង់ពន្ធឱ្យពួកអង់គ្លេសជាប្រាក់ បើកាលណាគ្មានប្រាក់ត្រូវខ្ចីបុលគេ។ ពួកអង់គ្លេស បានប្រមូលពន្ធពីជនជាតិឥណ្ឌា ដើម្បីចំណាយទៅលើពួកក្បាលម៉ាស៊ីនរដ្ឋបាល និងមុខងារសាធារណៈ។ អ្វីដែល ជាផលចំណេញរបស់អង់គ្លេស គឺការនាំចេញនូវផលិតផលកសិកម្ម មានតែ កប្បាស ផ្ទៃ និងអាភៀនសម្រាប់

[456] ក្រសួងអប់រំជាតិ, *ប្រវត្តិវិទ្យាថ្នាក់ទី៣*, ជ.ឯ.ម., ទំព័រ៣៧។

នាំចេញទៅកាន់ប្រទេសចិន និងទីផ្សារអឺរ៉ុបនៅសម័យបដិវត្តន៍ឧស្សាហកម្ម ហើយនាំចូលមកវិញនូវផលិតផលអឺរ៉ុបដែលមានគុណភាពអន់ និងតម្លៃថោកយកមកលក់ក្នុងតម្លៃខ្ពស់នៅក្នុងទីផ្សារប្រទេសឥណ្ឌា។ ការនាំចូលផលិតផលអឺរ៉ុប ដូចជាកំណាត់សំពត់ជាដើម បានធ្វើឱ្យប៉ះពាល់ដល់សិប្បករឥណ្ឌា និងធ្វើឱ្យ ប្រជាជនជាច្រើនបាត់បង់មុខរបរ។ ម្យ៉ាងទៀតអង់គ្លេស មិនហ៊ានអភិវឌ្ឍឧស្សាហកម្មខ្នាតធំនៅលើទឹកដីឥណ្ឌា ពីព្រោះខ្លាចមានការប្រណាំងប្រជែង ជាមួយឧស្សាហកម្ម អង់គ្លេស។

**ប្រទេសចិន៖** ក្រុមហ៊ុនឥណ្ឌាខាងកើតរបស់អង់គ្លេស ដែលធ្វើជំនួញអាភៀនធំជាងគេនៅលើ ពិភពលោក ពីព្រោះពួកគេបានបង្កើតចម្ការអាភៀនលើទឹកដីឥណ្ឌា។ ក្នុងមួយឆ្នាំៗមានអាភៀនរាប់សិបតោនដឹកតាមនាវាលក់នៅក្នុងទីផ្សារងងឹតរបស់ចិន។ ដោយសារលំហូរចូលអាភៀននេះ ធ្វើឱ្យអ្នកជក់ក្នុងប្រទេសចិនកើនឡើងរហូតដល់២លាននាក់។ អ្វីដែលធ្ងន់ធ្ងរជាង់នេះ គឺនៅក្រោយសង្គ្រាមអាភៀនលើកទី១ ចិននិងអង់គ្លេសចុះសន្ធិសញ្ញាវិសមភាពមួយឈ្មោះ ណានជីង ដែលតម្រូវឱ្យចិនបាត់បង់ដែនដីហុងកុងទាំងមូល ហើយក្លាយជាឃ្លាំងស្តុកអាភៀនរបស់អង់គ្លេស។ ប្រត្តិកម្មរបស់ អធិរាជចិនចំពោះការរីករាលដាលនៃ ថ្នាំញៀននេះ បណ្តាលឱ្យផ្ទុះសង្គ្រាមអាភៀនជាមួយអង់គ្លេសមួយលើកទៀតហៅថា សង្គ្រាមអាភៀន លើកទី២។ សង្គ្រាមនេះត្រូវបញ្ចប់ដោយសន្ធិសញ្ញា ទៀនសិន(Tien Tsin) ដែលតម្រូវឱ្យចិនបើក កំពង់ផែបន្ថែមចំនួន៦កន្លែងថែមទៀត។ អ្វីដែលសំខាន់ជាងនេះទៅទៀតសន្ធិសញ្ញានេះចាត់ទុក អាភៀន ជាទំនិញស្របច្បាប់ វាជាគ្រឿងធម្មតាដូចជាគ្រឿងឧបភោគបរិភោគដែរ។

**១.១.៣.២-ទ្វីបអាម៉េរិក**

ប្រទេសអង់គ្លេស បានគ្រប់គ្រងលំហសមុទ្ទជុំវិញពិភពលោក ដូចពាក្យស្លោកអាម៉េរិកនិយាយថា "អ្នកណាគ្រប់គ្រងសមុទ្ទបានគឺគ្រប់គ្រងពិភពលោក"។ នៅឆ្នាំ១៦៣០ ប្រទេសអង់គ្លេសបានដាក់ អាណានិគមលើរដ្ឋទាំង១៣ នៃទ្វីបអាម៉េរិក ដែលហៅថាអាម៉េរិកខាងជើង។ នៅលើទីផ្សារដ៏ធំនេះ អង់គ្លេសបានយកពន្ធគ្រប់យ៉ាងទៅលើប្រជាជនអាណានិគម។ ពន្ធដែលថ្លៃជាងគេគឺពន្ធតែ និងពន្ធតែម។ ពិសេសអង់គ្លេសបានរាំងខ្ទប់ការរីកដុះដាលសេដ្ឋកិច្ចប្រទេសអាណានិគម ដោយហាមមិនឱ្យបង្កើតរោងចក្រ និងដំណាំមួយចំនួនដូចជាតែជាដើម ព្រមទាំងហាមឃាតមិនឱ្យប្រជាជនទៅចាប់ដីថ្មីនៅភាគខាងលិចជួរភ្នំ អាប៉ាឡាស ព្រោះអង់គ្លេសត្រូវបាក់ស្បាត ដោយមកពីការខូចខាតពលទាហានជាច្រើន ពីសំណាក់ពួកស្បែកក្រហម ដែលរារាំងមិនឱ្យជនជាតិអឺរ៉ុបពង្រីកទឹកដីលើភូមិភាគរបស់ពួកគេ។ការបញ្ឈប់ការទន្ទ្រានដីនេះ ធ្វើឡើងតាមរយៈសន្ធិសញ្ញាមួយរវាងអង់គ្លេស និងពួកស្បែកក្រហម។

អ្វីដែលពួកអង់គ្លេសបានហាមឃាត់មិនឱ្យមានការផលិត ផលិតផលលើដែនដីអាណានិគមមកពីអង់គ្លេសមាន ការព្រួយបារម្ភខ្លាចក្រែងផលិតផលអស់ទាំងនោះប្រណាំងប្រជែង នឹងផលិតផលនាំចូលរបស់អង់គ្លេសធ្វើឱ្យខូចខាតដល់ផលប្រយោជន៍សេដ្ឋកិច្ច ជាពិសេសគឺការនាំឱ្យដួលរលំក្រុមហ៊ុនឥណ្ឌាខាងលិចរបស់ខ្លួន។

**១.១.៤-វិបត្តិនៅប្រទេសអៀរឡង់**

ប្រទេសអៀរឡង់ជាកោះមួយដែលស្ថិតនៅប៉ែកខាងជើងនៃប្រទេសអង់គ្លេស ហើយបានធ្លាក់ទៅក្នុងឥទ្ធិពលនៃប្រទេសនេះម្តងទៀត។ ជនជាតិអៀរឡង់បានបំផុសចលនាជាតិទាមទារឯករាជ្យពីចក្រភពអង់គ្លេសជាហេតុនាំឱ្យមានផលវិបាកឥតឈប់ឈររហូតដល់ឆ្នាំ១៩១៤។

## ទិបត្តិទាំងនោះមាន

### ក-វិបត្តិសាសនា

ប្រជាជនដែលរស់នៅក្នុងតំបន់អៀរឡង់ខាងជើង មានអៀរឡង់ អង់គ្លេស និងស្កុតឡែន។ ប្រជាជននៅទីនោះភាគច្រើនគឺជនជាតិអង់គ្លេស នងិស្កុតឡែន ដែលប្រកាន់សាសនា ប្រូតេស្តង់ ខុសពីជនជាតិ អៀរឡង់ដែលកាន់សាសនាកាតូលិក។ ជនជាតិអៀរឡង់មានសិទ្ធិបោះឆ្នោតរើសតំណាងរាស្ត្រ។ ប៉ុន្តែត្រូវដកសិទ្ធិនេះទៅវិញដោយជនជាតិអៀរឡង់ភាគច្រើនជាអ្នកកាន់គ្រិស្តសាសនាខាងនិកាយកាតូលិច។ ម្យ៉ាងទៀតជនជាតិអៀរឡង់ទាំងនោះត្រូវបង់ពន្ធសាសនា (dimo) ឱ្យទៅវិហារខាងជាតិអង់គ្លេស។ ដោយសារការតវ៉ាយ៉ាងម៉ឺងម៉ាត់របស់ជនជាតិអៀរឡង់ដែលមានលោក**អូខូណែល** (O'Connell) ជាអ្នកដឹកនាំរដ្ឋាភិបាលអង់គ្លេសបានសុខចិត្តៈ

- នៅឆ្នាំ១៨២៩លុបច្បាប់បំបាត់សិទ្ធិបោះឆ្នោតចំពោះជនជាតិអៀរឡង់ណា ដែលប្រកាន់គ្រិស្តសាសនាខាងនិកាយកាតូលិច។
- នៅឆ្នាំ១៨៥៩លុបច្បាប់បង្ខំពួកកាតូលិចអៀរឡង់ឱ្យបង់ពន្ធសាសនាឱ្យវិហារអង់គ្លេស[457]។

### ខ-បញ្ហាកសិកម្ម

ពីដើមដីស្រែចម្ការទាំងអស់ជាដីកម្មសិទ្ធិរបស់ជនជាតិអៀរឡង់។ លុះដលប្រទេសអៀរឡង់ត្រូវស្ថិតនៅក្រោមអំណាចអង់គ្លេស ដីស្រែចម្ការភាគច្រើននៅអៀរឡង់ ហើយជាពិសេសដីណាដែលមានដីជាតិល្អបានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ជនជាតិអង់គ្លេស ភាគច្រើនតែងទុកដីទាំងនោះឱ្យនៅទំនេរសម្រាប់ធ្វើជាកន្លែងបរបាញ់សត្វកំសាន្តជាហេតុនាំឱ្យមានទុរ្ភិក្សជាញឹកញាប់នៅប្រទេសអៀរឡង់ ដូចជាទុរ្ភិក្សនៃឆ្នាំ១៨៤៥អូសបន្លាយដល់ឆ្នាំ១៨៤៧ជាដើម ដែលបណ្តាលឱ្យមនុស្សស្លាប់អស់ប្រហែល៥០០០០០នាក់។ ហេតុការនេះបានធ្វើឱ្យប្រជាជនអៀរឡង់កៀសខ្លួនទៅកាន់ប្រទេសក្រៅ ជាពិសេសសហរដ្ឋអាម៉េរិក។

ក្រោយពីការណែនាំនៃលោក**ប៉ានែល***(Parnell)* ជនជាតិអៀរឡង់បានតវ៉ាសុំឱ្យជនជាតិអង់គ្លេសលែងដណ្តើមយកដីស្រែចម្ការពីជនជាតិអៀរឡង់តទៅទៀត ហើយបានសុំឱ្យជនជាតិអង់គ្លេសព្រមលក់ដីចម្ការទាំងនោះឱ្យទៅជនជាតិអៀរឡង់វិញ។ ដើម្បីឱ្យជនជាតិអៀរឡង់មានលុយកាក់សម្រាប់ទិញដីស្រែចម្ការទាំងនោះបាន រដ្ឋាភិបាលអង់គ្លេសបានអនុញ្ញាតឱ្យជនជាតិអៀរឡង់ខ្ចីប្រាក់បាន។ ប៉ុន្តែការទាមទារទាំងនេះពុំសូវបានលទ្ធផលទេ ដោយម្ចាស់កម្មសិទ្ធិអង់គ្លេសច្រើនពុំព្រមលះបង់ចោលបុព្វសិទ្ធិរបស់ខ្លួន។

### គ-បញ្ហានយោបាយ

បញ្ហានយោបាយទាក់ទង និងបញ្ហាសាសនា។ ប្រទេសអៀរឡង់មានរដ្ឋសភាដែរ តែមិនមានតំណាងជនជាតិអៀកឡង់ពិតប្រាកដទេ ពីព្រោះជនជាតិអៀរឡង់ភាគច្រើន បានបាត់បង់សិទ្ធិបោះឆ្នោតដោយរឿងសាសនា។ ដោយសារការតវ៉ាឥតឈប់ឈរ និងការប្រយុទ្ធខាងផ្លូវសឹកយ៉ាងស្វិតស្វាញរបស់ជនជាតិអៀរឡង់លោក ក្លាត់ស្តូន បានស្នើសភាអង់គ្លេសនៅឆ្នាំ១៨៨៤ ឱ្យទទួលស្គាល់ស្វ័យភាព (Home Rule) នៃប្រទេសអៀរឡង់តែមិនបានសម្រេចដូចបំណងទេ។

---

[457] ក្រសួងអប់រំជាតិ, *ប្រវត្តិវិទ្យាថ្នាក់ទី៣*, ជ.ឯ.ម, ទំព័រ៣៨។

នៅដើមសតវត្សទី២០ ស្ថានភាពនៅក្នុងប្រទេសអៀកឡង់ បានធ្លាក់ចូលក្នុងសភាពស្មុគស្មាញ។ បន្ទាប់ពីសភាអង់គ្លេស បានបដិសេធចោលគម្រោងច្បាប់ Homerule ពួកវណ្ណៈគហបតី បញ្ញវន្តអៀក ឡង់ បានធ្វើសេចក្តីសម្រេចចិត្តថា ត្រូវធ្វើការតស៊ូទាមទារ ឱ្យបានដាច់ខាតនៃនីតិក្រម Homerule និងសិទ្ធិឯករាជ្យដ៏ពេញលេញនៃបូរណភាពទឹកដីអៀរឡង់។ នៅឆ្នាំ១៩០៨ ពួកគេបានបង្កើតបក្ស ***ស៊ិនហ្វេរ*** នៅក្នុងភាសាអៀរឡង់មានន័យថា***យើងដោយខ្លួនឯង*** ដែលមានទិសដៅចម្បងគឺការបង្កើតរដ្ឋាភិបាលអៀរឡង់ និងឯកភាពសេដ្ឋកិច្ចអៀរឡង់។

ដើម្បីជៀសវាងការរាលដាលទំនាស់ នៅឆ្នាំ១៩១២ រដ្ឋាភិបាលបក្សសេរីនិយមបានដាក់ជូន សភានូវគម្រោងច្បាប់ Home Rule ។ នីតិក្រមស្តីពីការបង្កើតរដ្ឋាភិបាលអៀរឡង់ និងការជានាខុសត្រូវចំពោះស្ថាប័នរដ្ឋអំណាចមូលដ្ឋាន ប៉ុន្តែរដ្ឋអំណាចជាន់ខ្ពស់ស្ថិតនៅក្នុងអំណាចរបស់រាជអគ្គទេសាភិបាលអង់គ្លេស[458]។

លុះដល់ឆ្នាំ១៩១៤ ទើបប្រទេសអង់គ្លេសព្រមប្រគល់ស្វ័យភាពទៅឱ្យប្រទេសអៀរឡង់។ ប៉ុន្តែស្វ័យភាពនេះមានតែនៅលើក្រដាស់ទេពីព្រោះរហូតមកដល់ឆ្នាំ១៩២១ ទើបគេយកស្វ័យភាពនោះមកអនុវត្ត ឱ្យបានត្រឹមត្រូវ ពេញលេញបន្ទាប់ពីមានការបង្ហូរឈាម[459]។

## ១.២-ប្រទេសបារាំង

ប្រធានាធិបតីបារាងជ្រើសតាំងក្នុងរយៈពេល៧ឆ្នាំម្តង តាមរយៈការបោះឆ្នោតជាសកល (Universal suffrage)។ ប្រធានាធិបតីតែងតាំងនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី ដែលទទួលខុសត្រូវនៅចំពោះមុខសភា។ ប្រធានាធិបតីមានសិទ្ធិរំលាយសភាជាតិ (The National Assimbly) ឬក៏សួរយោបល់ទៅសភានៅក្នុងការពិភាក្សាតាក់តែងច្បាប់ទាំងឡាយ។

រដ្ឋប្រហារ បម្លាស់ប្តូរសង្គម ការបដិវត្តន៍ វិបត្តិនយោបាយ បាតុភូតទាំងនេះកើតមានជាប្រចាំនៅក្នុងប្រទេសបារាំង ចាប់តាំងពីសតវត្សទី១៩ និងដើមសតវត្សទី២០ ក្នុងបរិការណ៍នេះហើយទើបប្រវត្តិវិទូបានកត់សម្គាល់ថាប្រទេសបារាំងជាមហាអំណាចមួយដែលមានលក្ខណៈផុយស្រួយសម្រាប់បាតុភូតទាំងនេះហើយ។

### ១.២.១-បដិវត្តន៍ និងការបង្កើតរបបសាធារណរដ្ឋនៅបារាំង

នៅចុងសតវត្សទី១៨ ដោយសារតែការចំណាយយ៉ាងច្រើនសន្ធឹកសន្ធាប់ នៅក្នុងសង្គ្រាម ដើម្បីជួយសហរដ្ឋអាម៉េរិកទាមទារឯករាជ្យពីអង់គ្លេសផង និងដោយសារតែការចាយវាយខ្ជះខ្ជាយរបស់ព្រះបាទល្វីទី១៦ផង បារាំងត្រូវប្រឈមមុខនឹងបញ្ហាថវិកាដ៏ធ្ងន់ធ្ងរ រហូតស្ទើរតែត្រូវក្ស័យធន។

នៅចុងឆ្នាំ១៧៨៦ រដ្ឋាភិបាលបារាំងបានរៀបចំគម្រោងធ្វើកំណែទម្រង់ផ្នែកសារពើពន្ធ ដោយដំឡើងពន្ធ និងបង្កើតពន្ធថ្មីៗ ដើម្បីបង្កើនចំណូលរដ្ឋ។ ព្រះបាទល្វីទី១៦ ក៏បានកោះប្រជុំសភាទាំង៣ ដើម្បីអនុម័តគម្រោងដំឡើងពន្ធនេះ។ កិច្ចប្រជុំពេញអង្គនៃសភាទាំង៣ ដែលគេហៅថា "Les états-généraux" បានបើកធ្វើ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៧៨៩ នៅព្រះបរមរាជវាំង Versailles ជាយក្រុងប៉ារីស។ ក៏ប៉ុន្តែ នៅពេលបើកកិច្ចប្រជុំ បញ្ហាដ៏ចម្រូងចម្រាសមួយបានកើតឡើងរវាងសភាទាំង៣។ សភាតំណាងប្រជាជនធម្មតាបានទាមទារឱ្យធ្វើការកែប្រែប្រព័ន្ធបោះឆ្នោតជាមុន មុននឹងឈានទៅធ្វើការប្រជុំអនុម័តកំណែទម្រង់ស្នើឡើងដោយរដ្ឋាភិបាល។

---

[458] ដៀប សុផល, *ពិភពលោកសតវត្សទី២០ អឺរ៉ុប និងអាម៉េរិកខាងជើង*, ដ.ឯ.ម. ទំព័រ២០

[459] ក្រសួងអប់រំជាតិ, *ប្រវត្តិវិទ្យាថ្នាក់ទី៣*, ដ.ឯ.ម., ទំព័រ៣៩។

តាមទម្លាប់ គិតមកទល់នឹងពេលនោះ សភានីមួយៗ ត្រូវធ្វើការបោះឆ្នោតដាច់ៗ ពីគ្នាជាមុន ទើបធ្វើការអនុម័ត នៅក្នុងកិច្ចប្រជុំពេញអង្គ (états généraux) ជាក្រោយ។ នៅក្នុងកិច្ចប្រជុំពេញអង្គនៃសភាទាំង៣នេះ សភានីមួយៗមានមួយសំឡេងស្មើៗគ្នា ដែលមានន័យថា សភាតំណាងប្រជាជនធម្មតា ដែលតំណាងប្រជាជនរហូតដល់ទៅប្រមាណជា៩៨% នៅទូទាំងប្រទេស អាចនឹងក្លាយជាសំឡេងភាគតិច ប្រសិនបើសភាពីរផ្សេងទៀតរួបរួមគ្នា។ ដោយមើលឃើញថា របៀបបោះឆ្នោតបែបនេះមិនឆ្លុះបញ្ចាំងពីឆន្ទៈរាស្ត្រទូទៅ សមាជិកសភាតំណាងប្រជាជនក៏បានទាមទារឱ្យធ្វើការកែប្រែប្រព័ន្ធ បោះឆ្នោត ពីការបោះឆ្នោតតាមសភា ទៅជាការ បោះឆ្នោតដោយរាប់តាមចំនួនសមាជិកវិញ ពោលគឺ សមាជិកនីមួយៗត្រូវមានមួយសំឡេងស្មើៗគ្នា។ ក៏ប៉ុន្តែ សំណើនេះត្រូវបានច្រានចោលដោយសភាតំណាងវិហារកាតូលិក និងសភាតំណាងអ្នកមាន វណ្ណៈខ្ពង់ខ្ពស់។ ភាពចម្រូងចម្រាសជុំវិញនីតិវិធីក្នុងការបោះឆ្នោតនេះបានធ្វើឱ្យ កិច្ចប្រជុំពេញអង្គនៃសភាទាំង៣ត្រូវជាប់គាំង។ ជាងមួយខែក្រោយមក នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៧៨៩ សភាតំណាងប្រជាជន (tiers état) ដោយមានការចូលរួមពីសំណាក់សមាជិកមួយចំនួននៃសភាពីរផ្សេងទៀត ក៏បានប្រកាសបង្កើតជា "រដ្ឋសភា" (Assemblée nationale) ដែលជាសភាតំណាងប្រជាជនទូទាំងប្រទេស។ ព្រះមហាក្សត្រល្វីទី១៦ បានព្យាយាមរារាំងមិនឱ្យរដ្ឋសភាថ្មីនេះជួបប្រជុំគ្នា ដោយបានបិទសាលប្រជុំនៅក្នុងព្រះបរមរាជវាំង ក៏ប៉ុន្តែសមាជិករដ្ឋសភាបានទៅជួបប្រជុំគ្នានៅទីលានវាយកូនបាល់។ ព្រះមហាក្សត្របិទទីលានវាយកូនបាល់ រដ្ឋសភាក៏នាំគ្នាទៅប្រជុំ នៅក្នុងវិហារកាតូលិក។ ព្រះមហាក្សត្រក៏បានប្រមូល កម្លាំងទ័ព ដើម្បីត្រៀមបំបែកកិច្ចប្រជុំរបស់រដ្ឋសភា ក៏ប៉ុន្តែបានប្តូរព្រះទ័យឈប់ប្រើកម្លាំងទ័ពវិញ ក្រោយពីឃើញមានសមាជិកសភាតំណាងវិហារកាតូលិកកាន់តែច្រើនចូលរួមក្នុងរដ្ឋសភាថ្មីនេះ។

នៅទីបំផុត ដោយមិនអាចរារាំងកិច្ចប្រជុំរបស់រដ្ឋសភាថ្មីនេះបាន ព្រះបាទល្វីទី១៦ ក៏បានចេញបញ្ជាឱ្យសភាតំណាងវិហារកាតូលិក និងសភាតំណាងអ្នកមានវណ្ណៈខ្ពង់ខ្ពស់ចូលរួមប្រជុំក្នុងរដ្ឋសភាថ្មី ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញថ្មី។ នៅថ្ងៃទី៩ ខែកក្កដា រដ្ឋសភាថ្មីនេះក៏បានប្រកាសខ្លួនទៅជាសភាធម្មនុញ្ញ ហើយចាប់ផ្តើមជជែកអំពីការបង្កើតរបបនយោបាយថ្មីមួយ គឺរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

នៅក្នុងពេលដែលសភាធម្មនុញ្ញកំពុងតែប្រជុំតាក់តែងរដ្ឋធម្មនុញ្ញថ្មី មានហេតុការណ៍មួយចំនួនបានកើតឡើង ដែលជាដើមហេតុជំរុញឱ្យស្ថានការណ៍កាន់តែធ្លាក់ដុនដាប រហូតបង្កើតទៅជាចលនាបដិវត្តន៍ប្រជាជន។ ទាហានប្រមាណជា ២ម៉ឺននាក់ត្រូវបានព្រះបាទល្វីទី១៦ ចល័តចូលមកក្នុងក្រុងប៉ារីស ដែលជាហេតុធ្វើឱ្យបណ្តាជនមានការសង្ស័យខ្លាចព្រះអង្គប្រើកម្លាំងទ័ព បង្ក្រាបចលនាប្រឆាំងនៅរដ្ឋសភា។

ម្យ៉ាងទៀត នៅថ្ងៃទី១១ ខែកក្កដា ព្រះមហាក្សត្របានដកតំណែងរដ្ឋមន្ត្រីមួយចំនួន ដែលព្រះអង្គយល់ថា មានគំនិតគាំទ្របដិវត្តន៍។ ក្នុងចំណោមរដ្ឋមន្ត្រីដែលត្រូវដកតំណែងនោះ មានរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ដែលប្រជាជនបារាំងស្រឡាញ់ចូលចិត្ត។ ដឹងពីដំណឹងនេះ បណ្តាជននៅក្នុងក្រុងប៉ារីសក៏បាននាំគ្នាងើបឡើងបះបោរប្រឆាំងនឹង ព្រះបាទល្វីទី១៦។ ចលនាបដិវត្តន៍ ដែលកើតឡើងនៅក្នុងរដ្ឋសភា ក៏បាន រាលដាលទៅជាចលនាបដិវត្តន៍ប្រជាជន។ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៧៨៩ ចលនាបដិវត្តន៍ប្រជាជនបាននាំគ្នាវាយលុកទៅលើគុកមួយ ក្នុងក្រុងប៉ារីស គឺគុកឈ្មោះ Bastille ដែលក្រុមបដិវត្តន៍ចាត់ទុកថាជានិមិត្តរូបនៃអំណាចផ្តាច់ការរបស់ ស្តេច។ គុក Bastille ត្រូវបានចលនាបដិវត្តន៍វាយដណ្តើមយកបាន ហើយថ្ងៃទី១៤ ខែកក្កដា ត្រូវបានបារាំងចាត់ទុកជាថ្ងៃបុណ្យឯករាជ្យ រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។ ប្រឈមមុខនឹងចលនាបដិវត្តន៍

របស់ប្រជារាស្ត្រ ព្រះបាទល្វីទី១៦ ក៏បានសុខចិត្តដកកម្លាំងទ័ពចេញពីប៉ារីស ហើយតែងតាំងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុដ៏មានប្រជាប្រិយភាពឱ្យមក កាន់តំណែងវិញ។

នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៧៨៩ សភាជម្មនុញ្ញបារាំងបានអនុម័តសេចក្តីថ្លែងការណ៍ ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ដែលមានចែងជាអាទិ៍ អំពីការមានសិទ្ធិស្មើគ្នារវាងប្រជាពលរដ្ឋ និងការលុបចោលនូវវណ្ណៈសក្តិភូមិពីសម័យបុរាណ។ របបរាជានិយមផ្តាច់ការ ត្រូវបិទបញ្ចប់ជំនួសមកវិញដោយរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ ព្រះ បាទល្វីទី១៦ នៅតែកាន់អំណាចនីតិប្រតិបត្តិ ក៏ប៉ុន្តែ អំណាចរបស់ព្រះអង្គត្រូវកាត់បន្ថយ ដោយបង្វែរទៅឱ្យរដ្ឋសភា ដែលជាសភាតែមួយ តំណាងប្រជាជនទូទៅ ហើយលែងមានការបែងចែកទៅតាមវណ្ណៈ ដូចពីមុន។

អ្នកខ្លះគិតថា នេះគឺជាការបិទបញ្ចប់នៃបដិវត្តន៍ ក៏ប៉ុន្តែ នៅទីបំផុតទៅ វាគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ របបរាជានិយមអាស្រ័យធម្មនុញ្ញ ដែលទើបនឹងបង្កើតថ្មីត្រូវប្រឈមមុខនឹងអស្ថិរភាពឥតឈប់ឈរ។ ចលនាបដិវត្តន៍របស់ប្រជាជនបារាំងក៏បានកើតឡើងសាជាថ្មី។ ចលនាបដិវត្តន៍នេះមានសន្ទុះកាន់តែខ្លាំង រហូតឈានទៅរំលាយរបបរាជានិយមចោលទាំងស្រុង។ របបសាធារណរដ្ឋបារាំងត្រូវបានបង្កើតឡើង ហើយព្រះបាទល្វីទី១៦ ដែលជាអតីតព្រះមហាក្សត្រ ត្រូវបានតុលាការបដិវត្តន៍កាត់ទោសប្រហារជីវិត ដោយកាត់ក្បាលជាសាធារណៈ។[460]

### ក-សាធារណរដ្ឋទី១ និងទី២

សាធារណរដ្ឋទី១ ត្រូវបានបង្កើតឡើងបន្ទាប់ពីមានបដិវត្តន៍គហបតី នាឆ្នាំ១៧៨៩ ដល់ឆ្នាំ១៧៩៤។ នៅឆ្នាំ១៧៨៩ របបរាជានិយមផ្តាច់ការត្រូវបានផ្តួលរំលំ ហើយនៅឆ្នាំ១៧៩១ រដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័តប្រព័ន្ធដឹកនាំរដ្ឋថ្មី គឺរដ្ឋធម្មនុញ្ញរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ។ ក៏ប៉ុន្តែគម្រោងបង្កើតរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនេះត្រូវទទួលបរាជ័យ ព្រោះនៅពេលនោះក្នុងសភាមានការបែកបាក់គ្នារវាងពួកអភិជនដែលគាំទ្រដល់របបរាជានិយម ជាមួយពួកខាងឆ្វេង(អ្នកស្នេហាជាតិ) ប្រឆាំងរាជានិយម។ ទីបំផុតនៅ ឆ្នាំ ១៧៩២ របបសាធារណរដ្ឋទី១បារាំងត្រូវបានបង្កើតឡើង។

ដោយសារការប្រឈមមុខដាក់គ្នារវាងវណ្ណៈសង្គម អំពើពុករលួយ បក្សពួកនិយម ធ្វើឱ្យសាធារណរដ្ឋទី១បារាំង ជួបប្រទះ និងអស្ថិរភាពយ៉ាងខ្លាំង។ ទីបំផុតព្រះចៅអធិរាជណាប៉ូឡេអុងទី១ បានចូលកាន់អំណាច នៅឆ្នាំ១៧៩៩ ហើយបានបញ្ចប់ប្រព័ន្ធដឹកនាំសាធារណរដ្ឋនិយម ដោយឡើងសោយរាជ្យនៅ ឆ្នាំ ១៨០៤។

សាធារណរដ្ឋទី២ ត្រូវបានបង្កើតឡើងដោយសារលទ្ធផលនៃបដិវត្តន៍ខែកុម្ភៈ ឆ្នាំ១៨៤៨។ មហាជនបានបះបោរឡើង ជាពិសេសនៅក្នុងទីក្រុងប៉ារីស ដើម្បីផ្តួលរំលំរបបសក្តិភូមិរាជានិយមផ្តាច់ការ។ បដិវត្តន៍មានឥរិយាបថ ជាបដិវត្តិន៍គហបតីប្រជាធិបតេយ្យ។ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៨៤៨ នៅទីក្រុងប៉ារីស ក្រោយការផ្តួលរំលំរបបរាជានិយមផ្តាច់ការមក គេក៏បានប្រកាសបង្កើតប្រព័ន្ធដឹកនាំសាធារណរដ្ឋនិយម។ រដ្ឋធម្មនុញ្ញថ្មីត្រូវបាន អនុម័តនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៨៤៨ អនុលោមទៅតាមរដ្ឋធម្មនុញ្ញថ្មី សាធារណរដ្ឋទី២ ក៏ចាប់បដិសន្ធិឡើង។ បញ្ហាទំនាស់រវាងកម្លាំងនយោបាយសង្គមចេញពីវណ្ណៈផ្សេងៗ គ្នាបានកើតឡើង ជាពិសេស

[460] សេង ឌីណា **ប្រវត្តិសាស្ត្រពិភពលោក** ការផ្សាយរបស់វិទ្យុបារាំងអន្តរជាតិ RFI ថ្ងៃអាទិត្យ 15 ធ្នូ 2013

ក្នុងជួរ គហបតី អភិជន និងពួកអភិរក្សនិយមផ្សេងៗ បានធ្វើឱ្យស្ថានភាពសង្គមមានអស្ថិរភាពយ៉ាងខ្លាំង។ ជាមួយនឹងប្រព័ន្ធការិយាល័យនិយមដ៏ក្រាសឃ្មឹក បង្កើតឡើងដោយក្រុមពុករលួយ និងបក្សពួកនិយម ធ្វើឱ្យដំណើរការដឹកនាំសាធារណរដ្ឋទី២ ឈានដល់ដំណាក់កាលទ័លច្រក។ ការអនុម័តរដ្ឋធម្មនុញ្ញថ្មីឆ្នាំ១៨៥២ បានបញ្ចប់សាធារណរដ្ឋទី២ ហើយរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញត្រូវបានបង្កើតឡើង ព្រះចៅអធិរាជគឺណាប៉ូឡេអុងទី៣។

**ខ-សាធារណរដ្ឋទី៣**

នៅថ្ងៃទី៤ខែកញ្ញាឆ្នាំ១៨៧០ប្រទេសបារាំង បានផ្ទុះចេញជាការធ្វើបដិវត្តិន៍មួយ ដែលធ្វើឱ្យរបបរាជានិយមរបស់ព្រះចៅអធិរាជណាប៉ូលេអុងទី៣ត្រូវដួលរលំ។ ប្រទេសបារាំងបានប្រកាសជាសាធារណរដ្ឋទី៣ឡើង អ្នកដឹកនាំសំខាន់ៗរបស់ប្រទេសបារាំងដូចជាលោកហ្គំបេតតា (Gambetta) លោកហ្ស៊ុលហ្វាវ (Jules Favre) លោក ហ្ស៊ុលហ្វេរី (Jules Ferry) បានបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយឡើង ហើយដាក់ឈ្មោះថារដ្ឋាភិបាលការពារជាតិ ដែលមានលោកឧត្តមសេនីយ៍ត្រូស៊ូ (Trochu) ជាប្រធានាធិបតី។ ប៉ុន្តែរបបរដ្ឋាភិបាលការពារជាតិត្រូវជួបជាមួយឧបសគ្គជាច្រើនគឺ៖

១-សង្គ្រាមចេះតែបន្តរវាងប្រទេសបារាំង និងប្រទេសអាល្លឺម៉ង់។ ព្រះចៅណាប៉ូលេអុងទី៣បានបរាជ័យនៅចំពោះមុខកងទ័ពអាល្លឺម៉ង់នៅទីក្រុងសឺដង់ (Sedan) នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៧០ ដែលជាបុព្វហេតុធ្វើឱ្យមាន បដិវត្តិន៍ផ្ទុះឡើងនោះក៏ពុំអាចយកឈ្នះលើកងទ័ពអាល្លឺម៉ង់បាន ទើបសុខចិត្តចុះសន្ធិសញ្ញាសន្តិភាពជាមួយអាល្លឺម៉ង់នៅទីក្រុងហ្វ្រង់ហ្វ័រ (Francfort) នៅថ្ងៃទី២៨ខែមករាឆ្នាំ១៨៧១។

២-របបសាធារណៈរដ្ឋទី៣ ពោពេញទៅដោយទំនាស់ដោយសារការប្រឈមមុខដាក់គ្នា រវាងពួកសាធារណៈរដ្ឋនិយម និងពួករាជានិយម។ ប៉ុន្តែ នៅក្នុងសម័យប្រជុំសភាដែលប្រព្រឹត្តទៅទីក្រុងបូរដូ សភាបានប្រគល់តំណែងនាយករដ្ឋមន្ត្រីទៅឱ្យលោកជែរ (Ghier)។

៣-ឆ្លៀតពេលដែលស្ថានការណ៍ពុំនឹងនរ ក្រុមកម្មករនៅទីក្រុងបារីសបានរួបរួមគ្នាបង្កើតជាអង្គការបដិវត្តន៍មួយហៅថា សហព័ន្ធសាធារណៈរដ្ឋនៃកងទ័ពជាតិ ដែលដឹកនាំដោយ គណៈកម្មាធិការកណ្តាល។ អង្គការបដិវត្តន៍នេះមានគោលបំណងវាយរលំរដ្ឋអំណាចមូលធននិយមក្នុងប្រទេសបារាំង ហើយរៀបចំជារដ្ឋអំណាចរបស់វណ្ណៈកម្មករមួយឡើង។

ប្រវត្តិវិទូបានឱ្យឈ្មោះអង្គការនេះថា កុំមូនក្រុងប៉ារីស ឬសហគមន៍ទីក្រុងប៉ារីស។ លោកជែរ ដោយបានទទួលការយល់ព្រមពីរដ្ឋសភាជាតិ បានវាយបង្ក្រាបចលនានេះភ្លាមបង្កជាសង្គ្រាមស៊ីវិលបង្ហូរឈាមនៅ កណ្តាលទីក្រុងប៉ារីស។សង្គ្រាមនេះមានរយៈពេលចាប់ពីថ្ងៃទី២១ដល់ថ្ងៃទី២៧ខែឧសភា ឆ្នាំ១៨៧១។ សហគមន៍ទីក្រុងប៉ារីសត្រូវទទួលបរាជ័យ អ្នកចូលរួមត្រូវសម្លាប់ ដាក់ពន្ធនាគារ និងនិរទេសខ្លួន។ ក្រោយព្រឹត្តិការណ៍នេះមកលោកជែរបានខិតខំកសាងប្រទេសបារាំងឱ្យស្ថិតក្នុងសភាពស្ងប់ស្ងាត់មួយរយៈ ប៉ុន្តែវិបត្តិនៅតែមិនទាន់ដោះស្រាយនៅឡើយទេ។

នៅក្រោមការដឹកនាំរបស់លោកជែរ ប្រទេសបារាំងមានចំណុចល្អពីរគឺ ទី១ស្ថិរភាពខាងវិស័យហិរញ្ញវត្ថុ និងទី២កងទ័ពរបស់បារាំងបានត្រូវរៀបចំឱ្យទំនើបឡើង។ ប៉ុន្តែដោយពុំអាចដោះស្រាយបាននូវវិបត្តិនយោបាយបានលោកជែរ ក៏បានលាលែងពីមុខតំណែង នាខែឧសភា ឆ្នាំ១៨៧៣ ហើយលោកម៉ាក់ម៉ាអុង (Mac Mahon) បានឡើងកាន់តំណែងជំនួសវិញ។ លោកម៉ាក់ម៉ាអុង កាន់តំណែងមិនបានយូរប៉ុន្មាន

លោកក៏លាលែងពីតំណែងដែរ។ ក្នុងពេលនោះប្រទេសបារាំងពើបប្រទះនឹងការលំបាកធំៗដោយរួមមានកម្លាំងប្រឆាំងជាច្រើនដូចជា៖

– កម្លាំងគណបក្សរាជានិយម (Royalistes)

– គណបក្សកម្មករអន្តរជាតិបារាំង

– អង្គការសហជីពបដិវត្តិន៍

– អង្គការសហព័ន្ធទូទៅដើម្បីការងារ

បញ្ហាលំបាកសម្រាប់រដ្ឋាភិបាលប្រទេសបារាំង គឺត្រង់បញ្ហាដែលថាភាគច្រើននៃកម្លាំងប្រទេសមានទំនោរឆ្ពោះទៅរកលទ្ធិម៉ាកនិយម (Marxism)។ បញ្ហាទី២គំនិត និងទ្រឹស្តីប្លែកៗបានជ្រៀតចូលទៅក្នុងចលនាកម្មកររបស់បារាំង។ និយាយពីប្រទេសបារាំងពីឆ្នាំ១៩០៩ដល់ឆ្នាំ១៩១៤ ពោលតែក្នុងរយៈពេល៥ឆ្នាំបានជួបប្រទះនិងវិបត្តិគណរដ្ឋមន្ត្រីដល់ទៅ១០លើក។

រដ្ឋធម្មនុញ្ញសាធារណរដ្ឋទី១ ប្រកាសថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៧៩៣

រដ្ឋធម្មនុញ្ញសាធារណរដ្ឋទី២ ប្រកាសថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៨៤៨

រដ្ឋធម្មនុញ្ញសាធារណរដ្ឋទី៣ ប្រកាសថ្ងៃទី? ឆ្នាំ១៨៧៥?

រដ្ឋធម្មនុញ្ញសាធារណរដ្ឋទី៤ ប្រកាសថ្ងៃទី១៣ តុលា ១៩៤៦

រដ្ឋធម្មនុញ្ញសាធារណរដ្ឋទី៥ ប្រកាសបង្កើតថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៥៨

**គ-ដំណើរវិវត្តនៃសាធារណរដ្ឋទី៣ (១៨៧៩-១៩១៤)**

បន្ទាប់ពីបានទទួលជោគជ័យលើពួករាជានិយម អ្នកនិយមរបបសាធារណរដ្ឋបាក់បែកគ្នាជាពីរក្រុមទៅតាមទំនោរនយោបាយរៀងខ្លួន គឺក្រុមរ៉ាឌីកាល់ (Radical ) និងក្រុមឱកាសនិយម (Opportunste )។

ក្រុមរ៉ាឌីកាល់មានលោក ក្លេម៉ង់សូ (Clemenceau ) ជាអ្នកដឹកនាំមានបំណងធ្វើឱ្យកម្មវិធីសាធារណរដ្ឋសម្រេចបានទាំងស្រុង និងជាបន្ទាន់ទៀតផង។រីឯពួកឱកាសនិយមដែលមានលោក កំបែតា(Gambetta ) និងលោក ស៊ុលហ្វែរី (Jules Ferry ) ជាមេវិញនោះ ប្រាថ្នាសម្រេចកម្មវិធីមួយផ្នែកម្តងៗ ដោយសន្សឹមៗទៅតាមឱកាសដែលហុចឱ្យ។

**១.សាធារណរដ្ឋឱកាសនិយម(១៨៧៩-១៨៨៥ )**

ដោយក្រុមឱកាសនិយមមានគ្នាច្រើន នយោបាយសាធារណរដ្ឋបារាំងជំនាន់នោះក៏ត្រូវបានយោលទៅតាមកម្មវិធីនៃក្រុមនេះដែរ។

កិច្ចការកែទម្រង់ផ្សេងៗ ក៏ត្រូវរៀបចំធ្វើឡើងជាបន្តបន្ទាប់ដូចជា

– សម្រាល ឬលើកលែងចោលនូវទោសនយោបាយ

– បំបាត់លក្ខណៈសាសនាក្នុងសិក្សាធិកា

– បើកឱ្យរៀនសូត្រដោយឥតបង់ថ្លៃ និងដោយបង្ខំនៅបឋមសិក្សា

– បើកសេរីភាពក្នុងការប្រជុំ សេរីភាពសារពត៌មាន

– អនុញ្ញាតឱ្យបង្កើតសហជីព (Syndicat ) វិជ្ជាជីវៈ។

នៅឆ្នាំ ១៨៨៥ ក្រោយដែលគណៈរដ្ឋមន្ត្រីលោក ស៊ុលហ្វែរីដួលរលំទៅ ប្រទេសបារាំងក៏បានប្រទះនឹងវិបត្តិយ៉ាងធ្ងន់ធ្ងរ ជាហេតុនាំឱ្យមានការមិនសប្បាយចិត្ត ក្នុងមជ្ឈដ្ឋានមហាជន។ ក្រុមអ្នកប្រឆាំងនឹងនយោបាយសាធារណរដ្ឋនិយមសភាបានឆ្លៀតឱកាសនេះ ប៉ុនប៉ងវាយរំលំរបបនេះចោល។

## ២.ជ័យជម្នះនៃរបបសាធារណរដ្ឋ

ក្រុមអ្នកប្រឆាំងក៏បាននាំគ្នាពឹងផ្អែកលើលោក ប៊ូឡង់សេ ( Boulanger ) ដែលជាឧត្តមសេនីយប្រជាប្រិយមួយរូបនៅសម័យនោះដើម្បីរំលាយរបបថ្មីនេះ។

បន្ទាប់ពីត្រូវបណ្តេញចេញពីគណៈរដ្ឋមន្ត្រី (ខែឧសភា ឆ្នាំ ១៨៨៧) និងត្រូវដាក់ឱ្យចូលនិវត្តន៍មក (ខែមីនា ឆ្នាំ ១៨៨៨ ) លោក ប៊ូឡង់សេក៏បានបង្កើតគណបក្សសេរីនិយមប្រាថ្នារំលាយអង្គការសភាចោល និងរៀបចំធ្វើរដ្ឋធម្មនុញ្ញជាថ្មីដែលផ្តល់អំណាចពេញលេញមកឱ្យ លោក។ ការបោះឆ្នោតបំពេញកន្លែងក្នុងរដ្ឋសភាបានបញ្ជាក់ឱ្យដឹងថា លោក ប៊ូឡង់សេ មានប្រជាប្រិយភាពខ្លាំងក្លាណាស់។ ដូចនេះក្រុមប៊ូឡង់សេនិយម ដែលភាគច្រើនជាអ្នករាជានិយម បានបង្ខំឱ្យលោក ប៊ូឡង់សេធ្វើរដ្ឋប្រហារដណ្តើមអំណាច តែលោកពុំហ៊ាន។ ប្រឈមមុខនឹងស្ថានការណ៍ដ៏មានគ្រោះថ្នាក់នេះ អ្នកសាធារណរដ្ឋនិយមគ្រប់និន្នាការទាំងអស់បានរួបរួមកម្លាំងគ្នាទប់ទល់ នឹងក្រុមប៊ូឡង់សេនិយម ដើម្បីការពាររបបសាធារណរដ្ឋឱ្យរស់រានតទៅមុខ។ គេក៏បានសម្រេចធ្វើច្បាប់មិនអនុញ្ញាតឱ្យបុគ្គលម្នាក់អាចធ្វើជាតំណាងរាស្ត្រនៅច្រើនមណ្ឌលក្នុងពេលតែមួយ។ ម្យ៉ាងទៀតគេខំប្រមូលលេសគ្រប់យ៉ាងដើម្បីចោទលោក ប៊ូឡង់សេ ក្នុងបទបង្កការជ្រួលច្របល់ក្នុងរដ្ឋ។

លោក ប៊ូឡង់សេ ភ័យខ្លួន ក៏បានរត់ទៅក្រុងប្រ៊ុចសែល ( Bruxelles ) ក្នុងប្រទេសបែលស៊ិចបាត់ទៅ (ខែមេសា ឆ្នាំ១៨៨៩ )។ ចាប់ពីពេលនោះមក ប្រជាប្រិយភាពរបស់លោកបានធ្លាក់ចុះយ៉ាងខ្លាំងហើយគណបក្សប៊ូឡង់សេនិយមក៏ត្រូវបរាជ័យយ៉ាងធ្ងន់ក្នុងសម័យបោះឆ្នោតខែកញ្ញាឆ្នាំ១៨៨៩។ លទ្ធិប៊ូឡង់សេនិយមក៏រលាយបាត់ បរិយាកាសស្ងប់ស្ងាត់ក៏កើតមានឡើងវិញ តែគួរកត់សំគាល់ថាចាប់ពីពេលនោះមក ទស្សនៈរាជានិយមក៏លែងមានកម្លាំងជាអង្គការនយោបាយទៀតដែរ។ ផ្ទុយទៅវិញលទ្ធិសង្គមនិយមបានចាប់ផ្តើមចេញមុខជាកម្លាំងក្នុងផ្ទៃសភា។ ម្យ៉ាងទៀត ចលនាសហជីពក៏បានរីកលូតលាស់យ៉ាងលឿនផងដែរ។

## ៣.វិវត្តន៍ទៅរកនិន្នាការខាងឆ្វេង

ក្រោយពីបានសម្រេចនៅក្នុងនយោបាយសម្រុះសម្រួលអស់មួយរយៈពេល ប្រទេសបារាំងក៏បានផ្តើមអនុវត្តន៍នយោបាយជឿនលឿនមួយកម្រិតទៅមុខទៀត។

- បញ្ហាសាសនា: នៅឆ្នាំ១៩០៥ សភាបារាំងអនុម័តច្បាប់មួយដើម្បីផ្តាច់វិស័យសាសនាចេញពីអង្គការរដ្ឋ។ សាធារណរដ្ឋបារាំងត្រូវមានជំហរ ជាអព្យាក្រឹតក្នុងវិស័យសាសនា ពោលគឺបើកសេរីភាពពេញលេញខាងជំនឿជូនមហាជន។
- ជីវភាពនយោបាយ: ដោយគោរពតាមសេចក្តីសម្រេចរបស់សមាជអន្តរជាតិនៃបក្សសង្គមនិយម ដែលរៀបចំឡើងនៅក្រុងអាំស្ទែដាំ(ប្រទេសហូឡង់) ក្នុងឆ្នាំ១៩០៤ នោះ អ្នកសង្គមនិយមបារាំងមួយភាគក៏បានដកខ្លួនចេញពីប្លុកសាធារណរដ្ឋ ហើយរួមគ្នាបង្កើតជាគណបក្សសង្គមនិយមមួយដែលមានឈ្មោះថា គណបក្សកម្មករអន្តរជាតិផ្នែកបារាំង ( Section Francaise de I Interntionale Ouvrére : S.F.I.O ) ។

ដូច្នេះ គណបក្សគ្រប់និន្នាការដទៃទៀត ក៏បានប្រមូលគ្នារួមជាកម្លាំងមួយទប់នឹងគណបក្សថ្មីនោះ។ ក្រោយការបោះឆ្នោតឆ្នាំ១៩០៦ មកលោក ក្លឺម៉ង់សូ មេដឹកនាំក្រុមរ៉ាឌីកាល់បានឡើងកាន់អំណាចក្នុងរដ្ឋាភិបាលរហូតដល់ទៅដប់ដងក្នុងរយៈវេលាតែ៥ឆ្នាំប៉ុណ្ណោះ ( ១៩០៩-១៩១៤ )។

- បញ្ហាសង្គមៈ បានចោទខ្លាំងឡើងៗពីឆ្នាំ១៩០៦ ដល់ឆ្នាំ១៩១១។ សកម្មភាពរបស់សហជីពបដិវត្តន៍ដែលយកមធ្យោបាយកូដកម្មប្រើនោះ បានបង្ខំរដ្ឋាភិបាលឱ្យសើរើរៀបចំច្បាប់សង្គម ដើម្បីធ្វើឱ្យមានការធូរស្រាលខ្លះដល់វណ្ណៈកម្មករទូទៅ។

គេបានបង្កើតក្រសួងការងារមួយ (១៩០៦) ហើយសម្រេចឱ្យកម្មករសម្រាកថ្ងៃអាទិត្យ (១៩០៦) និងឱ្យមានសោធននិវត្តន៍ទៀតផង។ នៅពេលជាមួយគ្នានោះ មានរដ្ឋការក្នុងអង្គការខ្លះ ដូចជាគ្រូបង្រៀនជាដើម បានខំទាមទារសិទ្ធិបង្កើតសហជីពដែរ តែពុំបានសម្រេចដូចបំណងឡើយ។ នៅឆ្នាំ១៩១៤ រពើតរពើងក្នុងសង្គម និងទំនាស់នយោបាយក៏អន់ថយទៅវិញ។ ម្យ៉ាងទៀត ស្ថានការណ៍សេដ្ឋកិច្ចក៏បានរីកចម្រើនគ្រប់វិស័យជាលំដាប់ដែរ[461]។

### ១.២.២-នយោបាយក្រៅប្រទេស

នយោបាយការបរទេសរបស់ប្រទេសបារាំងនៅមុនសង្គ្រាមលោកលើកទី១ គឺជានយោបាយអាណានិគមនិយមហើយចាប់តាំងពីសតវត្សទី១៩មកប្រទេសនេះមានដែនដី អាណានិគមនិយមចំនួន១០ 000 000km$^2$ ដែលមានប្រជាជនចំនួនដល់ទៅ៥០ 000 000។ នយោបាយពង្រីងដែនដី អាណានិគមជាផលវិបាកនៃនយោបាយឧស្សាហូបនីយកម្មរបស់ប្រទេសមហាអំណាចទាំងឡាយ។

ដើម្បីរកវត្ថុធាតុដើម រកទីផ្សារ រកទីតាំងមូលដ្ឋានសឹកកងនាវាចរណ៍ប្រទេសមហាអំណាច តោងស្វែងរកដែនដីអាណានិគមឱ្យបានច្រើន។ នយោបាយអាណានិគមបារាំងត្រូវបានការទិទៀនរិះគន់ពីសំណាក់ប្រជាពលរដ្ឋបារាំងពិសេសពីគណបក្សសង្គមនិយម ម៉្យាងទៀតត្រូវប្រឈមទល់នឹងការវាតទីទឹកដីរបស់មហាអំណាចដ៏ទៃទៀតដូចជាចក្រភពអង់គ្លេសចក្រភពអាល្លឺម៉ង់។ ល។

#### ក-អាណានិគមបារាំងនៅឥណ្ឌូចិន

សហព័ន្ធឥណ្ឌូចិនរបស់បារាំង ជានយោបាយត្រួតត្រាប្រទេសទាំងបីនៅអាស៊ីអាគ្នេយ៍រួមមានប្រទេសវៀតណាម ប្រទេសកម្ពុជា និងប្រទេសឡាវ។ ដើម្បីវាតទីមកលើប្រទេសទាំងបីនេះមុនបង្អស់ប្រទេសបារាំងបានចូលមកកាន់កាប់ទីក្រុងទូរ៉ាន (Tourane) នៅក្នុងឆ្នាំ១៨៥៨ បន្ទាប់មកទៅកាន់កាប់ទឹកដី កូសាំងស៊ីន (Cochin chine) នៅឆ្នាំ១៨៦១ ហើយចូលមកកាន់កាប់ និងត្រួតត្រាពទីក្រុងហាណូយនៅ ឆ្នាំ១៨៧៣ ទីបំផុតបារាំងបានកាន់កាប់ប្រទេសវៀតណាមទាំងមូលនៅឆ្នាំ១៨៨៤ រីឯប្រទេសឡាវត្រូវធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់បារាំងនៅឆ្នាំ១៨៩៣ ប្រទេសកម្ពុជានៅឆ្នាំ១៨៦៣។ សហព័ន្ធឥណ្ឌូចិនស្ថិតនៅក្រោមការដឹកនាំរបស់ទេសាភិបាលបារាំងម្នាក់ ដែលមានទីស្នាក់ការនៅទីក្រុងព្រៃនគរ។

ក្រោយពេលមានជ័យជម្នះលើយួនហើយ លោកឧត្តមនាវី រីហ្គោ ដឺ ហ្សឺនូយី មានបញ្ហាពីរ ដែលត្រូវដោះស្រាយជាបន្ទាន់ ចិនមិនគោរពសន្ធិសញ្ញាសន្តិភាពឆ្នាំ១៨៥៨ និងយួនវាយយកតួរ៉ាន វិញកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៨៥៩។ ដោយគ្មានជំនួយទ័ពបន្ថែម លោកហាក់ដូចជាត្រូវទីក្រុងប៉ារីសបំភ្លេចចោល។ នៅចុងខែមេសា កងនាវាចម្បាំងបារាំង-អេស្ប៉ាញមួយក្រុម បានត្រឡប់ទៅបង្ក្រាបចិន នៅកង់តុង និងយួននៅតួរ៉ានដោយទុកមួយក្រុម ឱ្យនៅការពារព្រៃនគរក្រោមបញ្ជាការលោកវរសេនីយ៍ទោ ហ្សេរហ្គីលែរី (Jauréguilerry) និងក្រោយមកលោកនាវីឯក ដារីយែស៍ និងលោកវរសេនីយ៍ត្រី ម៉ាតាំង ដេ ប៉ាលីយែរ៍។ ថ្ងៃទី៨ ខែឧសភា ឆ្នាំ១៨៥៩ លោកឧត្តមនាវី ប៉ាស្ហ (Page) បានមកដល់ព្រៃនគរ ជំនួស បណ្តោះអាសន្ន

[461] ឃិន សុខ, ម៉ក់ ភឺន, ប៉ែន ណាវុឍ, ដ.ឯ.ម., ទំព័រ៨៩។

លោកឧត្តមនាវី ដឺ ហ្សឺនូយី។ លោកបានអញ្ជើញមន្ត្រីយួនមកចរចា សន្តិភាពតែបរាជ័យ។ លោកបានប្រកាសឱ្យប្រើកំពង់ផែព្រៃនគរ ក្រោមការការពាររបស់បារាំង។

នៅឆ្នាំ១៨៦២ អធិរាជ ទឺ ឌឹក មានបញ្ហាធំពីរត្រូវដោះស្រាយ។ នៅតុងកឹង ក្រុម ឡេ ភុង (Lé Phung) កំពុងរៀបចំបះបោរឡើងប្រឆាំងនឹងទីក្រុងវេ។ តាំងពីជំនាន់អធិរាជ យ៉ា ឡុង មកម្ល៉េះក្រុមនេះទុកយួនវេ ជាអ្នកឈ្លានពានយកប្រទេសគេ។ តាំងពីឆ្នាំ១៨៥៨ មកម្ល៉េះ ក្រុម ឡេ ភុង បានសុំឱ្យបារាំងជួយដោយយល់ព្រមដាក់ តុងកឹង ក្រោមអាណានិគមបារាំង។

នៅខាងត្បូង ទឺ ឌឹក គ្មានមធ្យោបាយអីប្រឆាំងនឹងបារាំងទេ។ ទឺ ឌឹក បានស្នើសុំសន្តិភាព និងបំពេញបំណងបារាំងទាំងស្រុង។ កប៉ាល់បារាំង ហ្វកបាំង បានទាញសណ្តោង កប៉ាល់យួនមួយ ដែលមាន គណប្រតិភូមួយក្រុម ក្រោមការដឹកនាំរបស់លោក ផាន ថិនយ៉ាង (Phan Thanh Giang ) រដ្ឋមន្ត្រី ពាណិជ្ជកម្ម និងយុត្តិធម៌ និងមានសមាជិក១៣៥នាក់ ពីទីក្រុងវេ មកដល់ព្រៃនគរ។ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៨៦២ សន្ធិសញ្ញាសន្តិភាពមួយ ត្រូវបានចុះហត្ថលេខា រវាងលោកឧត្តមនាវី បូណាដ៍ តំណាងអធិរាជបារាំង ណាប៉ូឡេអុងទី៣ និងលោក ផាន ថិនយ៉ាង តំណាងអធិរាជ ទឺ ឌឹក។ តាមសន្ធិសញ្ញានេះ ទឺ ឌឹក យល់ព្រម៖

- ប្រគល់ខេត្ត ចំនួនបីគឺ ខេត្តចង្វាត្រពាំង (Bién Hoa) តាឌិន (Gia Dinh) និង មេ ស(My Tho) ព្រមទាំងកោះត្រឡាច (Poulo Condor) ទៅឱ្យបារាំងធ្វើជាកម្មសិទ្ធិ។
- ផ្តល់សេរីភាពដល់អ្នកកាន់សាសនាកាតូលិក
- សងសោហ៊ុយសង្គ្រាមចំនួន២០លានហ្វ្រង់ដល់បារាំង

សន្ធិសញ្ញានេះក៏បានបើកសេរីភាពឱ្យបារាំងធ្វើជំនួញ ដោយប្រើប្រាស់កំពង់ផែយួនជាច្រើនមានជាអាទិ៍ តួរ៉ាន ព្រមទាំងហាមមិនឱ្យយួនប្រគល់ទឹកដីខ្លួនទៅឱ្យប្រទេសណាមួយ បើគ្មានការយល់ព្រមពីបារាំងទេ។ ពិធីប្តូរសច្ចាប័នត្រូវបានធ្វើឡើងយ៉ាងឱឡារិក នៅរាជវាំងអធិរាជ ទឺ ឌឹក នៅក្រុងវេ នាថ្ងៃទី១០ ខែមេសា ឆ្នាំ១៨៦៣[462]។

បន្ទាប់ពីគ្រប់គ្រងនៅកូសាំងស៊ីនរួចហើយ បារាំងបានរិះរកមធ្យោបាយដើម្បីវាយដណ្តើមកាន់កាប់ទឹកដីវៀតណាម ដែលនៅសេសសល់ជាបន្តទៀត។ នៅចុងឆ្នាំ១៨៧៣ កងទ័ពបារាំងបានចូលទៅដល់តុងកឹង។ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៨៧៣ កងទ័ពបារាំង បានបើកការវាយប្រហារបន្ទាយនៅហាណូយ និងនៅតំបន់នេះ ហើយក្នុងមួយរយៈពេលដ៏ខ្លី កងទ័ពបារាំងបានកាន់កាប់ស្ទើរទាំងស្រុងនូវតំបន់និងខេត្ត ដែលខ្លួនបានវាយលុយ។ តែដោយមានការប្រែប្រួលខ្លះៗកងទ័ពបារាំងត្រូវបានបញ្ជាឱ្យដកចេញអស់ពីហាណូយ។ នៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ១៨៧៤ សន្ធិសញ្ញាមួយត្រូវបានចុះហត្ថលេខានៅព្រៃនគរ រវាងលោកទេសាភិបាល ជាមួយលោក ឡេទ្វឹង តំណាងអធិរាជ ទឺ ឌឹក។

សន្ធិសញ្ញានេះបានចែងថា៖

- ❖ ចំពោះយួនអាណ្ណាម
    - ឱ្យបរទេសប្រើប្រាស់ទន្លេក្រហមដោយសេរី និងសន្យាកំចាត់ក្រុមចោរទង់ខ្មៅ ធ្វើឱ្យមានសន្តិសុខ នៅតាមឆ្នេរសមុទ្ទ និងតាមទន្លេក្រហម

[462] ត្រាំងធាត ប៊ុត, *វៀតណាម ឬស្រុកយួន*, ដ.ឯ.ម., ទំព័រ៨៣។

- ទទួលស្គាល់អធិបតេយ្យភាពបារាំងនៅកូសាំងស៊ីន សម្រួលនយោបាយការបរទេសឱ្យស្របតាមនយោបាយបារាំង (ឃ្លានេះចង់និយាយថា អាណ្ណាមត្រូវនៅក្រោមអាណាព្យាបាលបារាំង)
- ឱ្យបារាំងដាក់កុងស៊ុលនៅហាណូយ និងហាយផុង ដោយមានទាហាន១០០នាក់ ការពារ និងស្ថានទូតនៅក្រុងវេ។

❖ **ចំពោះភាគីបារាំង**

- ប្រគល់បន្ទាយប្រាការនៅហាណូយ ទៅឱ្យយួនវិញ និងដកទ័ពចេញពីទន្លេក្រហម
- លប់ចោលសំណងសេសសល់តាមសន្ធិសញ្ញាឆ្នាំ១៨៦២
- ទទួលស្គាល់អធិបតេយ្យភាពរបស់អាណ្ណាមលើតុងកឹង
- ទទួលការពារអាណ្ណាម ពីការវាយប្រហារពីសត្រូវនានា តាមការស្នើសុំពីរដ្ឋាភិបាលអាណ្ណាម

សន្ធិសញ្ញាខាងលើនេះគេឃើញថា ពុំត្រូវបានភាគីយួនគោរពនោះទេ គេឃើញភាគីយួនចូលទាក់ទងជាមួយនឹងក្រុមចិនទង់ខ្មៅ បញ្ឆេះកំហឹងអ្នកស្រុកតុងកឹង ឱ្យប្រឆាំងនឹងបារាំងទៅវិញ។ ក្រុមចិនទង់ខ្មៅបានដៃកាន់កាប់ទន្លេក្រហម បិទផ្លូវមិនឱ្យបរទេសចេញចូលធ្វើជំនួញ។ ដោយយកលេសថា ភាគីយួន មិនគោរពសន្ធិសញ្ញាឆ្នាំ១៨៧៤ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៨៨២ លោកទេសាភិបាល កូសាំងស៊ីន ឡឺ មៀរ៍ ដឺ វីឡែរ៍ បានបញ្ជូនកងនាវាមួយក្រុម ៥០០នាក់ទៅតុងកឹង ដឹកនាំដោយលោក វរសេនីយ៍ឯក អង់រី រីវីយែរ៍។ ដោយចរចាឱ្យយួនគោរពតាមសន្ធិសញ្ញាឆ្នាំ១៨៧៤ ពុំបានលទ្ធផលអ្វីនោះ លោក រីវីយែរ៍ នៅថ្ងៃទី២៥ ខែមេសា បានសម្រេចបើកការវាយលុយ និងកាន់កាប់តុងកឹង។

ការវាយលុកកាន់កាប់តុងកឹងពីសំណាក់បារាំងធ្វើឱ្យចិនពុំសប្បាយចិនឡើយ ដោយនៅថ្ងៃទី៦ ខែឧសភា រដ្ឋទូតចិននៅប៉ារីសបានទាមទារឱ្យបារាំងដកទ័ពចេញពីតុងកឹងវិញ។ នៅថ្ងៃទី៣០ ខែមិថុនា កងទ័ពចិន បានបញ្ជូនមកតុងកឹង តែដោយញញើតនឹងបារាំង ចិនថាដើម្បីកម្ចាត់ក្រុមចោរទង់ខ្មៅ។ កងទ័ពចិនបានជ្រៀតចូលរហូតដល់ជាយក្រុងហាណូយទៀតផង។ ពេលនោះបារាំងព្រមានវិញថា គេមិនអនុញ្ញាតឱ្យចិនជ្រៀតជ្រែកក្នុងនយោបាយគេនៅតុងកឹងឡើយ។ នៅចុងឆ្នាំ១៨៨២ លោកទេសាភិបាលដឺវីឡែរ៍ បានប្រកាសថា មិនអនុញ្ញាតឱ្យមានទាហានចិនម្នាក់នៅតុងកឹង ព្រមទាំងចាប់បញ្ជូនទៅកោះត្រឡាច នូវជនណាម្នាក់ចេញមុខប្រឆាំងនឹងបារាំង។

សង្គ្រាមរវាងបារាំង និងយួនអាណ្ណាម បានបន្តមួយរយៈពេល ហើយទីបំផុតដោយបារាំងមានកម្លាំងខ្លាំងក្លាជាង បានបង្ខំឱ្យអាណ្ណាមទទួលយកអាណាព្យាបាលបារាំង។ ដោយមិនអាចប្រកែកបាន អធិរាជហ៊ីប ហ៊ា(Hiép Hoa) បានយល់ព្រមទទួលយកសន្ធិសញ្ញាទីក្រុងវេ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៨៨៣។ សន្ធិសញ្ញានេះមានចែងដូចតទៅ៖

- អាណ្ណាមទទួលស្គាល់ និងយល់ព្រមទទួលអាណាព្យាបាលបារាំង (មាត្រា១)
- រដ្ឋាភិបាលអាណ្ណាម ដកទ័ពអស់ភ្លាមចេញពីតុងកឹង(មាត្រា៤)
- រដ្ឋាភិបាលអាណ្ណាម ប្រកាសបើកឱ្យគ្រប់ប្រទេសធ្វើជំនួញ (មាត្រា៧)
- បារាំងកាន់កាប់ផ្នែកគយទាំងស្រុង (មាត្រា១៩)
- បារាំងដាក់ប៉ុស្តិ៍តាមទន្លេក្រហម សម្រាប់ការពារសន្តិសុខ (មាត្រា២២)

- បារាំងសន្យាការពារអធិបតេយ្យភាពអាណ្ណាម តទល់ជាមួយសត្រូវពីខាងក្រៅ និងការបះបោរក្នុងប្រទេស។ បារាំងជាអ្នកដេញកម្ចាត់ក្រុមចោរទង់ខ្មៅឱ្យចេញអស់ពីតុងកឹង(មាត្រា២៣)...។

ទោះបីជាមានសន្ធិសញ្ញាខាងលើនេះយ៉ាងណាក៏ដោយ តែភាគីយួននៅតែមិនមានឆន្ទៈក្នុងការគោរពដូចសន្ធិសញ្ញាមុនៗដែរ។ ដោយកងទ័ពយួនមិនព្រមដកចេញពីតុងកឹង ហើយកងទ័ពចិន ដែលចូលមកតុងកឹងពីមុន ថាមកកម្ចាត់ពួកក្រុមចោរទង់ខ្មៅ បែរជាចូលរួមជាមួយក្រុមនោះ ព្រមទាំងយួនហើយធ្វើការប្រឆាំងនឹងបារាំង។ បារាំងពិតជាមានការពិបាកក្នុងការធ្វើសង្គ្រាម ព្រោះនៅទីតាំងនោះសុទ្ធតែព្រៃ ហើយសត្រូវរបស់ខ្លួនស្គាល់ទឹកដីច្បាស់លាស់ណាស់ តែទោះបីជាយ៉ាងនេះក៏ដោយ បារាំងមានបំណងយកតុងកឹងទាំងមូលឱ្យខាងតែបាន។ ដោយមានប្រៀបខាងកងទ័ព បារាំងបានធ្វើការកៀបសង្កត់ចិន ឱ្យដកទ័ពចេញពីតុងកឹង និងបញ្ចប់ជាស្ថាពរនូវភាពជាចំណុះរបស់យួនចំពោះខ្លួន ដោយបានចុះហត្ថលេខាលើសន្ធិសញ្ញាបណ្តោះអាសន្ន **ទៀងស៊ីន** ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៨៨៤។

ក្រោយពីមានសន្ធិសញ្ញាទៀងស៊ីនហើយ បារាំងចង់បញ្ជាក់ឱ្យច្បាស់ជាងមុន ពីអំណាចបារាំង នៅអាណ្ណាម ដែលរួមមានតុងកឹងផងដែរ។ បារាំងយកអំណាចទាំងអស់មកកាន់ផ្ទាល់ខ្លួន ទុកតែផ្នែក រដ្ឋបាលឱ្យយួនកាន តែនៅក្រោមការទទួលខុសត្រូវរបស់បារាំងទៀត មន្ត្រីណាហ៊ានជំទាស់បារាំងដកចេញភ្លាម។ សន្ធិសញ្ញាទៀងស៊ីន ជាស្ថាពរ រវាងបារាំង និងចិន ត្រូវបានចុះហត្ថលេខានៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៨៨៥។ សន្ធិសញ្ញា សន្តិភាព មិត្តភាព និងពាណិជ្ជកម្មនេះមានសារៈសំខាន់ណាស់ចំពោះអនាគត អាណ្ណាម គឺ ចិនអស់មានសិទ្ធិជាអធិរាជលើយួនទៀតហើយ។ ចិនបានទទួលស្គាល់អាណាព្យាបាល បារាំងលើអាណ្ណាមដែរ។ ទោះជាមានសន្ធិសញ្ញា ដែលពួកយួនអាណ្ណាមទទួលយកអំណាចបារាំងហើយក៏ដោយ ក៏គេមើលឃើញថាចលនាប្រឆាំងនៅតែកើតមានជាបន្តបន្ទាប់រវាងបារាំង ជាមួយយួន។ ដែលការបះបោរនេះធ្វើឱ្យទាំងទាហ៊ាន និងជនស៊ីវិលជាច្រើននាក់ស្លាប់បាត់បង់ជីវិត។ ចលនានេះកើតឡើងនៅចន្លោះ ឆ្នាំ១៨៨៥-១៨៨៩ ដែលមានឈ្មោះថាចលនា កឹង យឿង(Cán Vuong)។

**ខ-អាណានិគមបារាំងនៅទ្វីបអាហ្វ្រិក**

នៅឆ្នាំ១៨៨១ បារាំងបានវាយយកបានប្រទេស ទុយនីស៊ី ដាក់ក្រោមអាណាព្យបាលរបស់គេ។ បន្ទាប់ពីយកបានស៊ូដង់ កូតឌីវ័រ និងដាហូមេ គេកសាងបានអាហ្វ្រិកខាងលិចរបស់បារាំងមួយឡើង។

នៅឆ្នាំ១៨៩០ បារាំងបានកាន់កាប់កោះម៉ាដាកាស្កា(Madagascar) ក្រោយពីបានព្រមព្រៀងប្រគល់ សង់ស៊ីបា(Zanzibar) ទៅឱ្យអង់គ្លេស។ នៅលើកោះនេះបារាំង ត្រូវប្រើពេលយូរ ទើបអាចបង្ក្រាបចលនាតស៊ូ របស់អ្នកស្រុកបាន។ នៅដើមសតវត្សទី២០ បារាំងយកបានប្រទេសម៉ារុកទៀត។ គេប្រើល្បិចគាំទ្រ ព្រះចៅស៊ុលតង់ ជ្រែក រាជ្យមួយអង្គនាម មូឡៃហាភីត (Moulay Hafid) ដើម្បីបង្ខំប្រទេសនេះឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន[463]។

[463] ក្រសួងអប់រំជាតិ, *ប្រវត្តិវិទ្យាថ្នាក់ទី៣*, ដ.ឯ.ម., ទំព័រ៥១។

## ១.៣-ចក្រភពរុស្ស៊ី

### ១.៣.១-ប្រទេសរុស្ស៊ីមុនរជ្ជកាលព្រះចៅអាឡិចសង់ទី២

**ក-ចក្រភពរុស្ស៊ី**

មកដល់រជ្ជកាលព្រះចៅអាឡិចសង់ទី២ ទំហំនៃចក្រភពរុស្ស៊ីសឹងប្រហាក់ប្រហែលផ្ទៃដី នាសម័យសភាពសាធារណរដ្ឋសង្គមនិយមសូវៀត។ ចក្រភពនេះត្រូវបានបង្កើតឡើងនៃទឹកដីបុព្វបុរស រុស្ស៊ីផង និងដោយទឹកដីរបស់ប្រទេសដែលទើបទន្ទ្រានយកបាននៅអឺរ៉ុប និងអាស៊ីផង។

**ប្រទេសនៃជនជាតិរុស្ស៊ីមានបួនមណ្ឌល គឺ៖**

- **រុស្ស៊ីធំ** ៖ ជាប្រភពនៃចក្រភពរុស្ស៊ី ហើយជាទីតាំងនៃរាជធានីមូស្គូទៀតផង។ ប្រជារាស្ត្រនៃមណ្ឌលនេះស្ទើតែទាំងអស់ កាន់សាសនាអរតូដុក(Orthodoxe)។
- **រុស្ស៊ីតូច ៖** ដែលមានអ៊ុយក្រែន ជាតំបន់កសិកម្មដ៏សំខាន់នោះបានភ្ជាប់ទៅនឹងរុស្ស៊ីធំ ពីសតវត្ស ទី១៧-១៨។ ក្រុងគៀវ (Kiev) ដែលជាទីប្រជុំជននៃមណ្ឌលនេះ ត្រូវបាន ប្រជាជនចាត់ទុកជា សន្តបុរី។ ប្រជាជនរុស្ស៊ីតូចមួយភាគជាអ្នកកាន់សាសនាកាតូលិច។
- **រុស្ស៊ីស ៖** ជាអាណាខេត្តដែលមានជនរុស្ស៊ីរស់នៅ ប៉ុន្តែស្ថិតតែមុនឆ្នាំ១៧៩៣ ជាទឹកដី របស់រដ្ឋលីទុយអានី និងប៉ូឡូញ។ នៅមណ្ឌលនេះមានអ្នកកាន់សាសនាកាតូលិចដែរ។
- **រុស្ស៊ីខាងត្បូង ៖** ជាមណ្ឌលដែលទើបទន្ទ្រានយកបានពីចក្រភពអូតូម៉ង់ ។ ជនរុស្ស៊ី ដែលរស់នៅក្នុងតំបន់នេះ ច្រើនពូជពង្សពីជនកូសាក់(Cosaque) មក ។

**ភូមិភាគអឺរ៉ុបដែលបានភ្ជាប់មកក្នុងចក្រភពរុស្ស៊ី មាន៖**

- ប្រទេសដែលមាននៅតាមសមុទ្របាល់ទិច គឺ អេស្តូនី (Estonie) លីវ៉ូនី (Livonie) កូឡង់ (Courlande) ។
- ប្រទេសប៉ូឡូញ
- ប្រទេសលីទុយអានី
- មហាឌុសេផាំងឡង់ (Grand Duche de Finlande)
- បេសារ៉ាប៊ី (Bessarabie) ជាតំបន់ដែលមានជនជាតិរូម៉ាំង និងជនជាតិជ្វីហ្វរស់នៅ។

**ភូមិភាគអាស៊ីរុស្ស៊ី**

- ភាគខាងត្បូងនៃរាជាណាចក្រ ហ្សក់ដី (Georgie) ត្រូវបានបញ្ចូលជាទឹកដីរុស្ស៊ីក្នុងឆ្នាំ ១៨០១។
- តំបន់ស៊ីបេរី ទាំងមូល ក្នុងឆ្នាំ១៨៦០ គេបានសង់កំពង់ផែវ្ល៉ាឌីវ៉ូស្តុក (Vladivostock) ដើម្បីបើកតំបន់ស៊ីបេរីឱ្យមានទំនាក់ទំនងទៅមហាសមុទ្រប៉ាស៊ីហ្វិក។

**ខ-សង្គមរុស្ស៊ី**

សង្គមរុស្ស៊ីនៅពាក់កណ្តាលសតវត្សទី១៩ ចែកជាវណ្ណៈ អភិជន គហបតី និងអ្នកងារ។

- វណ្ណៈអភិជន ៖

អភិជនរុស្ស៊ីខ្លះមានដើមកំណើតជាក្សត្រនៃក្សត្របុរីនានាក្នុងចក្រភព និងខ្លះទៀតជាម្ចាស់ដីធំៗ ដែលតែងតាំងឡើងដោយព្រះចៅអធិរាជ។ អភិជនម្ចាស់ដីធំៗនៅតាមជនបទត្រូវបានតែងតាំងជា ស្តេចត្រាញ់ ដែលប្រកបដោយអំណាចខ្លាំងក្លាគ្រប់វិស័យ មានរដ្ឋបាល និងតុលាការជាដើម។

នៅសតវត្សទី១៩ នៅក្នុងចក្រភពរុស្ស៊ីទាំងមូល មានអភិជនប្រជា១០០០គ្រួសារ។ វណ្ណៈនេះ មានបុព្វសិទ្ធិគ្រប់យ៉ាងទាំងអស់ ដូចជាហួងហែងអង្គការធំៗសម្រាប់តែពួកគេ មានក្របខ័ណ្ឌនាយទាហាន និងមន្ត្រីជាន់ខ្ពស់ជាដើម។

❖ វណ្ណៈគហបតី ៖ មានពួកសិប្បករធំៗ និងអ្នកជំនួញធំៗ ។

❖ វណ្ណៈទាសករ ឬអ្នកងារ ៖ មានទាសកររដ្ឋ និងទាសកររបស់អភិជន។ អ្នកជា ប្រជាកសិករ ដែលគ្មានសិទ្ធិសេរីភាព ហើយរស់ដោយលំបាកតោកយ៉ាក ក្រោមការជិះជាន់ ការជំរិតគ្រប់បែបយ៉ាង ពីសំណាក់ ពួកអភិជន។ ក្រៅពីជាប់កំណែនបី ថ្ងៃក្នុងមួយសប្តាហ៍ សម្រប់ធ្វើស្រែចម្ការរបស់ពួកអភិជន ម្ចាស់ដី ពួកអ្នកងារត្រូវបង់អាករខ្លួន ត្រូវគេយកទៅធ្វើជាបាវបម្រើក្នុងផ្ទះ ឬធ្វើជាកម្មករ ជាប្រយោជអភិជន។

**គ-របបគ្រប់គ្រង**

ព្រះចៅអធិរាជ ឬត្សា(Tsar) កាន់អំណាច់ផ្តាច់ការ។ ព្រះអង្គជាប្រមុខលើអង្គការគ្រប់គ្រងទាំង អស់ក្នុងចក្រភព។ ព្រះចៅជាអ្នកបង្កើតច្បាប់សម្រាប់រដ្ឋ ដោយព្រះអង្គផ្ទាល់។

ព្រះចៅអធិរាជ តែងតាំងនាម៉ឺន មន្ត្រី និងនាយទាហានទាំងឡាយ ឬបណ្តេញចោលតាម ព្រះទ័យព្រះអង្គ។ ម្យ៉ាងទៀត ព្រះចៅអធិរាជទ្រង់ប្រើលទ្ធិផ្តាច់ការក្នុងវិស័យសាសនាទៀតផង។ រាជរដ្ឋាភិបាលរុស្ស៊ីពុំអនុញ្ញាតឱ្យប្រជារាស្ត្រគោរពសាសនាអ្វីក្រៅពីអរតូដុកឡើយ។

បន្ទាប់ពីចៅអធិរាជមក គេឃើញមានក្រុមជំនុំជាច្រើនជាន់ថ្នាក់ កាន់កាប់កិច្ចការគ្រប់គ្រងប្រទេស ។ សភាជាន់ខ្ពស់នៃអភិជន ជាអង្គការធំបំផុត និងមានអំណាចខ្ពស់បំផុត ដែលមានតួនាទីជា អង្គការនីតិបញ្ញត្តិផង ជានីតិប្រតិបត្តិផង និងជាតុលាការផង ហើយពិសេសទៅទៀតត្រូវត្រួតពិនិត្យ កិច្ចការទាំងអស់ក្នុងអង្គការរដ្ឋ។

### ១.៣.២-ប្រទេសរុស្ស៊ីក្នុងរជ្ជកាលព្រះចៅអាឡិចសង់ទី២ (១៨៥៥-១៨៨១)

**ក-ព្រះចៅអាឡិចសង់ទី២**

ព្រះអង្គជាបុត្ររបស់ព្រះចៅនីកូឡៃទី១។ ព្រះចៅអាឡិចសង់ទី២ បានធ្វើដំណើរទៅសិក្សានៅ បរទេសជាញឹកញាប់ ហើយទ្រង់មានព្រះទ័យទូលាយក្នុងការទទួលគំនិតថ្មីនានា។ ព្រះអង្គទ្រង់ជា អធិរាជដ៏ល្បីល្បាញក្នុងប្រវត្តិសាស្ត្ររុស្ស៊ី។ ព្រះអង្គបានបន្សល់ទុកស្នាព្រះសហ្គជាច្រើន តាមទង្វើកំណែទម្រង់ វិស័យនយោបាយ ពង្រីកទឹកដី និងវិស័យរុស្ស៊ីកម្មជាដើម។ នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៨៨១ ព្រះចៅអាឡិចសង់ទី២ ត្រូវបានគេលួចធ្វើគុត ក្នុងឱកាសដែលព្រះអង្គត្រឡប់ពីឡាយព្រះហស្តលេខា លើសេចក្តីសម្រេចបង្កើត រដ្ឋធម្មនុញ្ញសម្រាប់ប្រទេសជាតិ។

**ខ-កំណែទម្រង់សង្គម**

❖ ស្របនឹងគំនិតរបស់ទីប្រឹក្សា ព្រះចៅអាឡិចសង់ទី២ ឈ្វេងយល់ថា របបទាសភាព ពុំអាចធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើនបានឡើយ។ ព្រះអង្គបានសម្រេចបំបាត់របបនេះចោល ដោយរំដោះទាសភាពពីប្រព័ន្ធគ្រប់គ្រងរបស់ពួកអភិជន។ នៅខែកុម្ភៈ ឆ្នាំ១៨៦១ ព្រះអង្គបានបង្កើតច្បាប់ រំដោះអ្នកងារ ទូទៅ និងផ្តល់ដីស្រែចម្ការដល់អ្នកទាំងនោះសម្រាប់បង្កបង្កើនផល ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារទៀត ផង ។

❖ កំណែទម្រង់ផ្នែករដ្ឋបាល តុលាការ សិក្សាធិការ និងកទ័ព

ក្នុងវិស័យរដ្ឋបាល គោលការណ៍ស្វយ័តនៃកិច្ចចាត់ចែងត្រូវបានយកមកប្រើប្រាស់នៅគ្រប់ ឃុំ ស្រុក និងខេត្ត។ ម្យ៉ាងទៀត គេបានបង្កើតសភាតំបន់ឱ្យត្រួតត្រាមើលការខុសត្រូវ សាលារៀន ផ្ទះ ពេទ្យ និង សម្បត្តិសាធារណៈទូទៅ។

ចំពោះវិស័យតុលាការ គេបានរៀបចំឱ្យទៅជាអង្គការអចិន្ត្រៃយ៍ ដែលមានគ្រប់ឯកទេស ទាំងអស់។

នៅក្នុងវិស័យសិក្សាធិការ ព្រះចៅអាឡិចសង់ទី២ បានប្រកាសសេរីភាព តាំងពីបឋមសិក្សា រហូតដល់ ឧត្តមសិក្សា ។

ក្នុងវិស័យយោធាវិញ ព្រះអង្គបានបង្កើតសាលាយោធា ដែលសិក្សាក្បួនយុទ្ធសាស្ត្រជាក់ លាក់ដើម្បី កសាងកងទ័ពជាតិយ៉ាងទំនើបមួយ។

❖ នយោបាយរុស្ស៊ីកម្ម

ដើម្បីបញ្ចៀសការបះបោរ និងចលនារំដោះជាតិ ដែលនឹងកើតមានឡើងជាយថាហេតុ នោះ ព្រះចៅ អាឡិចសង់ទី២ បានធ្វើនយោបាយរុស្ស៊ីកម្ម រំលាយជាតិផ្សេងៗ ក្នុងចក្រភព ឱ្យទៅជាជាតិរុស្ស៊ីទាំងអស់។ ដើម្បីសម្រេចគោលបំណងនេះព្រះអង្គបានប្រើមធ្យោបាយបំបែកបំបាក់ផ្ទៃក្នុងនៃ ជាតិនីមួយៗ ដែលរស់នៅ ក្នុងចក្រភពរុស្ស៊ី។ នៅឆ្នាំ១៨៦៤ ព្រះអង្គបានធ្វើច្បាប់មួយ រឹបអូសដីស្រែ ចម្ការរបស់ជនប៉ូឡូញ ហើយយក មួយភាគប្រគល់ផ្ដាច់ឱ្យទៅកសិករអ្នកប្រវាស់ដី និងមួយភាគទៀត ទុកជាសម្បត្តិរដ្ឋរុស្ស៊ី។ បន្ទាប់មកព្រះចៅ អង្គនេះបានបញ្ជូនជនរុស្ស៊ីឱ្យទៅតាំងនិគមជនលើដីដែលរឹប អូសបាននោះ។ ក្រៅពីនេះ ព្រះអង្គបានបង្ខំឱ្យ ប្រើភាសារុស្ស៊ីជាផ្លូវការតាមរយៈការអប់រំនៅសាលារៀន ជាទូទៅ និងគ្រប់គ្រឹះស្ថានសាធារណៈទាំងឡាយ។ លើសពីនេះទៀតមានការរឹតបន្តឹងផ្នែកសិទ្ធិមនុស្ស បំបិទសេរីភាពខាងជំនឿសាសនា និងបង្ខំអ្នកស្រុកឱ្យកាន់ សាសនាអរតូដុកទាំងអស់។ ទ្រព្យសម្បត្តិ ដីធ្លីរបស់វត្តអារាម ដែលពុំមែនអរតូដុក ត្រូវដាក់ជាសម្បត្តិរដ្ឋ។ នយោបាយរុស្ស៊ីកម្ម បានធ្វើឱ្យស្ទើរគ្រប់ ជាតិសាសន៍ ទទួលរងគ្រោះ ហើយទឹកដីត្រូវបានភ្ជាប់មកក្នុងចក្រភព រុស្ស៊ី។

## ១.៣.៣-បដិវត្តន៍ឆ្នាំ១៩១៧

### ក-បដិវត្តន៍ខែកុម្ភៈ

នៅមុនសង្គ្រាមលោកលើកទី១ ប្រទេសភាគច្រើននៅទ្វីបអឺរ៉ុបរួមទាំងប្រទេសរុស្ស៊ីផងសុទ្ធតែជាប្រទេស កាន់របបរាជានិយម។ ប៉ុន្តែនៅក្រោយសង្គ្រាមលោកលើកទី១មកប្រទេសទាំងនោះក៏ប្តូររបបនយោបាយស្ទើរ តែទាំងស្រុង។ លោកវ្ល៉ាឌីមៀរ អ៊ីឡិចលេនីន ជាអ្នកដឹកនាំធ្វើបដិវត្តន៍ ផ្ដួលរំលំ ស្ដេចត្សារ និងជាអ្នកបង្កើត សង្គមនិយមនៅប្រទេសរុស្ស៊ី។ បានជាមានបដិវត្តន៍សង្គមនិយមរុស្ស៊ីកើតឡើងនៅខែតុលា១៩១៧ ពីព្រោះ នៅខែសីហា១៩១៤សង្គ្រាមលោកលើកទី១បានផ្ទុះឡើង ស្ដេចត្សារមានការព្រួយបារម្ភចំពោះផលប្រយោជន៍ បក្សពួករបស់ខ្លួនជាមួយពួកមូលធនបារាំង និងអង់គ្លេសបានជំរុញឱ្យប្រជាជនរុស្ស៊ី ធ្លាក់ចូលទៅក្នុងសង្គ្រាម រយៈពេល ៣ឆ្នាំ បានធ្វើឱ្យមនុស្សស្លាប់១.៥លាន់នាក់ និងរបួស៥លាននាក់។ សេដ្ឋកិច្ចជាតិត្រូវខ្ទេចខ្ទាំហើយ ស្រុតចុះយ៉ាងខ្លាំង។ ទុរ្ភិក្ស និងជំងឺកើតមានគ្រប់ទិសទី។ នៅសមរភូមិមុខ កងទ័ពរុស្ស៊ីបរាជ័យដោយខ្វះស្បៀង និងអាវុធ។ ចំណែកឯផលិតកម្មរបស់រុស្ស៊ីទទួលត្រឹមតែ១ភាគ៤នៃ តម្រូវការ។ នៅចំពោះមុខស្ថានភាពដ៏ អាក្រក់នេះមិនបានបង្អាក់អំពើពុករលួយ និងដំណើរការរស់នៅដ៏ ស្ដឹមស្ដៃនៃរាជវាំងស្ដេចត្សារទេ។ មានតែ ផ្លូវមួយទេដែលមហាជនត្រូវជ្រើសយកគឺការផ្ដួលរលំស្ដេចត្សារ។ នៅតាមទីក្រុងកម្មករងើបឡើងធ្វើកូដកម្ម នៅតាមជនបទកសិករបះបោរ និងទាហានបះបោរទៅតាមសមរភូមិ។ ការផ្ទុះនៃកម្លាំងបដិវត្តតែមួយមិនអាច

ដណ្ដើមជ័យជម្នះបានទេ  កត្តាកំណត់ជ័យជំនះគឺកម្លាំងដឹកនាំនៃវណ្ណៈអធនរុស្ស៊ីក្រោមការដឹកនាំរបស់បក្សបុលសេវិច។ នៅក្នុងឱកាសទិវាអន្តរជាតិថ្ងៃទី២៣កុម្ភៈ ១៩១៧ ត្រូវនឹង  ថ្ងៃ៨មីនា (ប្រតិទិនចាស់របស់រុស្ស៊ី) ក្រោមការដឹកនាំរបស់បក្សបុលសេវិចកម្មករនៃទីក្រុងបេត្រូកាត(រដ្ឋធានីប្រទេសរុស្ស៊ី  បច្ចុប្បន្នមានឈ្មោះថា លេនីនក្រាត)  បានធ្វើបាតុកម្មក្រោមពាក្យស្លោក(បំបាតទុរ្ភិក្ស បរាជ័យស្ដេចត្សារ)។ រដ្ឋាភិបាលបានប្រើកម្លាំងយោធា ៦០០០០នាក់ និងប៉ូលិសដើម្បីបំបែបចលនានេះ។  ថ្ងៃទី២៨ កុម្ភៈបដិវត្តន៍មានជ័យជម្នះដោយសារប៉ូលិសចូលដៃជាមួយនិងពួកបដិវត្តន៍។ ក្រោយបដិវត្តខែកុម្ភៈ រដ្ឋអំណាចពីរត្រូវតែងតាំងឡើងនៅក្នុងប្រទេស ទី១រដ្ឋាភិបាលបណ្ដោះអាសន្ន) ជារដ្ឋអំណាចរបស់វណ្ណៈគហបតី និងម្ចាស់ដីដែលកាន់កាប់ដោយអង្គការរដ្ឋ។ ទី២(សូវៀត) ជារដ្ឋអំណាចកម្មករនិងកសិករ។

គោលបំណងរបស់រដ្ឋាភិបាលបណ្ដោះអាសន្នគឺបន្តការធ្វើសង្គ្រាម  ហើយរៀបចំធ្វើការវាយលុកជាថ្មីទៀត។ ប៉ុន្តែអំណាចពិតប្រាកដ ស្ថិតក្នុងកណ្ដាប់ដៃពួកសូវៀត(Soviets: ក្រុមប្រឹក្សា)។ ពួកក្រុមប្រឹក្សាសូវៀតបានត្រូវរៀបចំបង្កើតឡើងនៅប៉េត្រូក្រាត តាំងពីថ្ងៃ២៧ កុម្ភៈម្លេះ ដែលមានសមាជិកជាកម្មករ និងទាហាន។ ក្រុមប្រឹក្សាសូវៀតបានរីកចម្រើនយ៉ាងឆាប់រហ័ស  ហើយរៀបចំឡើងតាមរយៈការបោះឆ្នោតជាសកល  ដើម្បីជ្រើសតាំងតំណាងដឹកនាំក្នុងក្រុមប្រឹក្សា។  រដ្ឋាភិបាលបណ្ដោះអាសន្នមានអំណាច  ប៉ុន្តែមិនអាចធ្វើអ្វីបានឡើយ បើគ្មានការអនុញ្ញាតពីក្រុមប្រឹក្សាសូវៀត។  ក្រុមប្រឹក្សាសូវៀតចង់បញ្ចប់សង្គ្រាម  និងចង់ឱ្យគេរៀបចំធ្វើការបែងចែកដីធ្លី។

**ខ-បដិវត្តន៍ខែតុលា**

នៅក្រោយបដិវត្តន៍ស្ថានភាពនយោបាយនៅប្រទេសរុស្ស៊ី មានភាពស្មុគស្មាញបំផុត។ មកដល់ចំណុចនេះពេលវិលត្រលប់ពីប្រទេសស្វីស នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩១៧ លេនីន បានទាយទុកមុននូវការឆ្លងកាត់បន្ទាប់ពីបដិវត្តន៍ប្រជាធិបតេយ្យគហបតី មកបដិវត្តន៍សង្គមនិយម។ គាត់បានលើកឡើងនូវបទបញ្ហាអំណាចទាំងស្រុងត្រូវស្ថិតនៅក្នុងកណ្ដាប់ដៃសូវៀត។  លេនីន បានធ្វើការវិភាគចំពោះស្ថានភាពនៅពេលនោះ ហើយដាក់ចេញនូវបញ្ហា"និក្ខេបបទខែមេសា" ដែលមានចំណុចបីសំខាន់គឺះ

-អំណាច់ទាំងស្រុងត្រូវស្ថិតក្នុងកណ្ដាប់ដៃក្រុមប្រឹក្សាសូវៀត

-ដីធ្លីត្រូវបែងចែកទៅឱ្យប្រជាជន

-កម្មករទាំងអស់ជាម្ចាស់រោងចក្រ

បទបញ្ហាទាំងនេះបានរីកសាយយ៉ាងឆាប់រហ័ស។  នៅខែកក្កដាពួកបុលសេវិច  ដែលជាអ្នកដឹកនាំចលនាប្រឆាំង រដ្ឋាភិបាលត្រូវបានគេដេញប្រហារយ៉ាងខ្លាំង។  ប៉ុន្តែអំឡុងខែសីហា រដ្ឋាភិបាល  បណ្ដោះអាសន្នបែរជាត្រូវការពួកបុលសេវិចវិញ  ដើម្បីធ្វើការតបតជាមួយពួកទ័ពស្ដាំនិយមដណ្ដើមអំណាច។  នៅខែកញ្ញាពួកបុលសេវិច គឺជាអ្នកដឹកនាំ ក្រុមប្រឹក្សាសូវៀត នៅប៉េត្រូក្រាត និងមូស្គូ។ លោកលេនីនគិតថានេះជាឱកាសល្អសម្រាប់ដណ្ដើមអំណាច  តាមរយៈការធ្វើកុប្បកម្ម  ព្រោះលក្ខណៈនេះនឹងផ្ដល់នូវភាពស្របច្បាប់មួយ  ដល់ពួកបុលសេវិច។  នៅរាត្រីថ្ងៃទី២៤  ទៅ២៥  ខែតុលា  ពួកគេបានកាន់កាប់វាំងសិសិររដូវ។

រដ្ឋាភិបាលបណ្តោះអាសន្នបានរត់គេចខ្លួន ហើយក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ត្រូវបានបង្កើតឡើង និងដឹកនាំដោយលេនីន[464]។

នៅខែតុលា ឆ្នាំ១៩១៧ (គិតតាមប្រតិទិនរុស្ស៊ី) បដិវត្តន៍ថ្មីមួយទៀតក៏បានកើតមានឡើង គឺបដិវត្តន៍កុម្មុយនិស្ត ដឹកនាំដោយលេនីន។ វ្លាឌីមៀរ លេនីន ដែលរស់នៅនិរទេសខ្លួនក្នុងប្រទេសស្វ៊ីស បានធ្វើដំណើរត្រឡប់មកក្នុងប្រទេសរុស្ស៊ីវិញ ប្រមាណជាមួយខែក្រោយបដិវត្តន៍ខែកុម្ភៈ។ នៅពេលមកដល់រុស្ស៊ីភ្លាម លេនីនចាប់ផ្តើមចេញមុខប្រឆាំងនឹងរដ្ឋាភិបាលបណ្តោះអាសន្ន ដែលកើតចេញពីបដិវត្តន៍ខែកុម្ភៈ។ លេនីនបានរិះគន់រដ្ឋាភិបាលបណ្តោះអាសន្ននេះថាជារដ្ឋាភិបាលដែលបន្តដឹកនាំដោយពួកវណ្ណៈសក្តិភូមិ ហើយបានទាមទារឱ្យបង្កើតរដ្ឋាភិបាលថ្មីមួយ ដែលដឹកនាំដោយផ្ទាល់ ដោយកងទ័ព កម្មករ និងកសិករ។

នៅថ្ងៃទី១០ ខែតុលា (តាមប្រតិទិនរបស់រុស្ស៊ី) គណៈមជ្ឈិមនៃបក្សកុម្មុយនិស្ត ដែលនៅពេលនោះមានឈ្មោះថា គណបក្សបុលឆេវិច (Bolchevique) ដឹកនាំដោយលេនីន បានសម្រេចបង្កើតចលនាតស៊ូប្រដាប់អាវុធ ដើម្បីផ្តួលរំលំរដ្ឋាភិបាល។ នៅយប់ថ្ងៃទី២៤ ឈានចូលដល់ថ្ងៃទី២៥ខែតុលា កងកម្លាំងប្រដាប់អាវុធរបស់ក្រុមបុលឆេវិច ដឹកនាំដោយឡេអុង ត្រុតស្គី (Léon Trotsky) បានសម្រុកចូលកាន់កាប់វិមានរដ្ឋាភិបាល នៅក្នុងទីក្រុងប៉េត្រូក្រាដ ដោយសឹងតែគ្មានការផ្ទុះអាវុធទាល់តែសោះ ដោយសារតែ នៅពេលនោះ កងកម្លាំងរដ្ឋាភិបាល បាននាំគ្នាដកខ្លួនថយមិនប្រយុទ្ធ។ រដ្ឋាភិបាល បណ្តោះអាសន្នត្រូវដួលរលំ។ រដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើង ហើយវ្លាឌីមៀរ លេនីន ក៏បានក្លាយទៅជាប្រមុខដឹកនាំប្រទេស កុម្មុយនិស្តដំបូងបង្អស់ នៃប្រវត្តិសាស្ត្ររបស់ពិភពលោក។

ព្រឹត្តិការណ៍ថ្ងៃទី២៥តុលា ឆ្នាំ១៩១៧ ត្រូវបានបក្សកុម្មុយនិស្តសូវៀតចាត់ទុកជាបដិវត្តន៍ (បដិវត្តន៍ខែតុលា) ក៏ប៉ុន្តែ មានអ្នកខ្លះទៀត ជាពិសេស អ្នកប្រឆាំងនឹងក្រុមបុលឆេវិច ចាត់ទុកហេតុការណ៍នេះថាជាការធ្វើរដ្ឋប្រហារ ដណ្តើមអំណាចដោយខុសច្បាប់។ ចលនាប្រឆាំងនឹងរដ្ឋាភិបាលកុម្មុយនិស្តរបស់ លេនីនក៏បានចាប់ផ្ទុះឡើង រហូតរាលដាលទៅជាសង្គ្រាមស៊ីវិល។ សង្គ្រាមស៊ីវិល ដែលបានបណ្តាលឱ្យមនុស្សប្រមាណជាជាង១លាននាក់ត្រូវបាត់បង់ជីវិត ដោយក្នុងនោះមានមួយផ្នែកជាកងកម្លាំងប្រដាប់អាវុធដែលស្លាប់ក្នុងសមរភូមិ និងមួយផ្នែកទៀតជាប្រជាជនធម្មតា ដែលត្រូវប៉ូលិសសម្ងាត់កុម្មុយនិស្តចាប់ខ្លួនយកមកធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់ចោល ដោយចោទថាជា "ខ្មាំង"។

នៅឆ្នាំ១៩២២ សង្គ្រាមស៊ីវិលត្រូវបញ្ចប់។ ក្រុមបុលឆេវិករបស់លេនីនជាអ្នកទទួលជោគជ័យ ហើយសហភាពសូវៀតក៏ត្រូវបានបង្កើតឡើង.

មហាសន្និបាតបក្សបុលសេវិចលើកទី៦បានប្រជុំដោយសម្ងាត់ រដ្ឋាភិបាលបណ្តោះអាសន្នត្រូវចាប់ខ្លួនទាំងអស់។ ពីខែវិច្ឆិកា ដល់កុម្ភៈ ឆ្នាំ១៩១៨ កម្លាំងបដិវត្តន៍បានធ្វើសកម្មភាពរាលដាលហើយទទួលបានជោគជ័យទូទាំងប្រទេស។ លេនីនបានហៅសម័យកាលនោះថា(ដំណើរជ័យជម្នះរបស់ពួកផ្តាច់ការអេធន និងរបស់រដ្ឋអំណាចសូវៀត)។

[464] .អធិការមធ្យមសិក្សា និងសាស្ត្រាចារ្យកម្ពុជាមួយក្រុម សហការជាមួយសាស្ត្រាចារ្យបារាំង **ប្រវត្តិវិទ្យា ថ្នាក់ទី១១ សម្រាប់សាស្ត្រាចារ្យទុតិយភូមិ**, មូលនិធិ ល័រ-កម្ពុជា, ២០០៥, ទំព័រ១១៣

# ១.៤-ចក្រភពអូទ្រីស-ហុងគ្រី

## ១.៤.១-ស្ថានភាពទូទៅ

ក្រោយពីសង្គ្រាមអូទ្រីស និងព្រូស៊ី ឆ្នាំ១៨៦៦ ស្ថានភាពអាណាចក្រមានលក្ខណៈដុនដាបបានបង្ខំឱ្យអូទ្រីសចុះហត្ថលេខា ស្តីអំពីការបង្រួបបង្រួមជាមួយនិងព្រះរាជាណាចក្រហុងគ្រី បង្កើតបានជារដ្ឋមួយយ៉ាងធំនៅទ្វីបអឺរ៉ុប។ តាមទំហំធំជាងរាជាណាចក្រអង់គ្លេស អ៊ីតាលី និងបារាំង។ នៅដើមសតវត្សទី២០ ទឹកដីអាណាចក្រអូទ្រីស-ហុងគ្រី បណ្តុំទៅដោយទឹកដីប្រទេសអូទ្រីស ហុងគ្រី ឆេកូស្លូវ៉ាគី ស្លូវេនី និងក្រូអាទី ទន្ទឹមនឹងនេះដែរទឹកដីមួយផ្នែកនៃទឹកដីរូម៉ានីបច្ចុប្បន្ន ទឹកដីអ៊ុយក្រែន ប៉ូឡូញ និងអ៊ីតាលី។ រាជធានីអូទ្រីសគឺទីក្រុង វៀន ដែលគេចាត់ទុកថាជាទីក្រុងបុរាណមានប្រជាជនរស់នៅច្រើន និងមានសម្បត្តិវប្បធម៌ខ្ពង់ខ្ពស់នៅក្នុងទ្វីបអឺរ៉ុប។ ហើយទន្ទឹមនឹងនេះដែរ រាជធានីប៊ុយដាប៉េស្ត និងទីក្រុងប្រាក គឺជាមជ្ឈមណ្ឌលឧស្សាហកម្មវប្បធម៌យ៉ាងសំខាន់របស់អាណាចក្រផងដែរ។

ភាពខុសគ្នារវាងអាណាចក្រអូទ្រីស-ហុងគ្រី ទៅនឹងប្រទេសដទៃទៀត នៅក្នុងអឺរ៉ុបខាងលិចអាណាចក្រអូទ្រីស-ហុងគ្រី បណ្តុំទៅដោយពហុសញ្ជាតិ ហើយគ្មានសញ្ជាតិណាមួយដែលមានចំនួនច្រើនលើសលប់លើគេសូម្បីតែ១/៤ នៃចំនួនប្រជាជនទាំងអស់បានទេ។ ជនជាតិអូទ្រីសមានចំនួនច្រើនជាងគេ (២៣.៥%) និងហុងគ្រី (១៩.១%)។ បន្ទាប់ពីនេះមានជនជាតិប៉ូឡូញ (១០%) ជនជាតិអ៊ុយក្រែន (៨%) ជនជាតិរ៉ូម៉ានី (៦.៥%) ក្រៅពីនេះមានស្លូវេនី អ៊ីតាលី អាល្លឺម៉ង់ ។ ល។ មានជនជាតិជាច្រើនរស់នៅក្នុងអាណាចក្រដោយបណ្តុំគ្នាដូចជាជនជាតិអូទ្រីស នៅលើទឹកដីអូទ្រីស ហុងគ្រីនៅលើទឹកដីហុងគ្រី ក្រូអាទីនៅលើទឹកដីក្រូអាទី ឆេកូនៅលើទឹកដីឆេកូ ប៉ូឡូញនិងអ៊ុយក្រែននៅលើទឹកដីហ្គាលីស៊ីន រ៉ូម៉ានី និងហុងគ្រី រស់នៅលើទឹកដីត្រង់ស៊ីលវ៉ានី។ ក្នុងតំបន់ជាច្រើនទៀតរស់នៅដោយចម្រុះជនជាតិ ។

ទន្ទឹមនឹងបញ្ហាចម្រុះជនជាតិ ជាមួយគ្នានេះក៏មានផងដែរនូវបញ្ហាសាសនាដូចមាន ពួកជនជាតិអូទ្រីស អ៊ីតាលី ប៉ូឡូញ និងក្រូអាទី ប្រកាន់សាសនាតូលិក ពួកជនជាតិឆែក និងអាល្លឺម៉ង់មានសាសនាប្រូតេស្តង់ ជនជាតិអ៊ុយក្រែន អូតាដក ។

ដោយយោងទៅតាមលក្ខន្តិកៈនៃកិច្ចព្រមព្រៀងឆ្នាំ១៨៦៧ រវាងអូទ្រីស និងហុងគ្រី អូទ្រីស-ហុងគ្រីត្រូវបានកំណត់ថាជា "ព្រះរាជាណាចក្រពីរបង្រួបបង្រួមគ្នាតែមួយ" រវាងប្រជាជនអូទ្រីស និងហុងគ្រី។ ព្រះចៅអធិរាជ អូទ្រីស ហ្វ្រង់អ៊ីយ៉ូសែហ្វ ក្នុងពេលតែមួយក៏ជាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រហុងគ្រី ដែរ។ ព្រះចៅអធិរាជមានសិទ្ធិបង្កើតច្បាប់ តែងតាំងគណរដ្ឋមន្ត្រី និងអគ្គមេបញ្ជាការ ជាន់ខ្ពស់កងទ័ពអូទ្រីស-ហុងគ្រី។ អូទ្រីស និងហុងគ្រីមានក្រសួងបីរួមគ្នា ក្រសួងការពារជាតិ ក្រសួងការបរទេស និងក្រសួង ហិរញ្ញវត្ថុ។ ពួកអូទ្រីស និងហុងគ្រីមានសភា និងរដ្ឋាភិបាលរៀងខ្លួន ដែលត្រូវបានកំណត់រៀបចំឡើង ដោយព្រះចៅអធិរាជ។

ការបោះឆ្នោតជាសកល ពុំមានទេនៅក្នុងរាជាណាចក្រអូទ្រីស-ហុងគ្រី។ អ្នកដែលមានសិទ្ធិបោះឆ្នោតគឺមានតែក្រុមអ្នកមានអភ័យឯកសិទ្ធិ និងមានសម្បត្តិទ្រព្យខ្ពង់ខ្ពស់នៅក្នុងសង្គម។ នៅក្នុងតំបន់ដែលមានបណ្តុំលសញ្ជាតិច្រើន (នៅក្រូអាទី ឆេកូហ្គាលីស៊ី ) បានបង្កើរដ្ឋធម្មនុញ្ញរបស់ខ្លួនមានសភា មូលដ្ឋាន និងស្ថាប័នដឹកនាំស្វយ័ត។ នៅក្នុងតំបន់ដូចនេះបានកំណត់ច្បាប់ទាក់ទងនឹងការសិក្សាក្នុងសាលាបឋមសិក្សាត្រូវបានប្រព្រឹត្តិទៅនៅក្នុងភាសារបស់ជនជាតិ ប៉ុន្តែច្បាប់នេះគេរំលោភជាញឹកញាប់។

នៅក្នុងស្ថានភាព ពហុសញ្ជាតិនិងសាសនាចម្រុះដូចនៅអាណាចក្រ អូទ្រីស-ហុងគ្រី តែងតែកើតឡើងនូវទំនាស់ ជាច្រើន គេសង្កេតឃើញថា មានការផ្ទុះឡើងនូវចលនាបះបោររបស់ជនជាតិជាញឹកញាប់ ។

រដ្ឋាភិបាលអូទ្រីស-ហុងគ្រីបានប្រឹងប្រែងកៀបសង្កត់បំបាត់ការតស៊ូរបស់ជនជាតិដើម្បីឯករាជ្យជាតិ។ ជាច្រើនលើកច្រើនសា គេបានរំសាយស្ថាប័ន និងរដ្ឋាភិបាលអំណាចមូលដ្ឋាន ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គេមិនអាចបញ្ឈប់ចលនាបះបោររបស់ជនជាតិបានដែរ។ នៅក្នុងអាណាចក្រទាំងមូលបានកើតឡើងនូវអង្គការស្របច្បាប់ និងក្រៅច្បាប់ជាច្រើន។

## ១.៤.២-ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចសង្គម

នៅលើវិស័យសេដ្ឋកិច្ច អាណាចក្រអូទ្រីស-ហុងគ្រី នៅមានភាពទន់ខ្សោយជាងមហាអំណាច ដទៃទៀត។ នៅតំបន់ដែលមានឧស្សាហកម្មជឿនលឿន ស្ថិតនៅតំបន់ភូមិភាគខាងលិចនៃអូទ្រីស ហុងគ្រី និងទឹកដីឆេកូ។ នៅទីនោះមានឧស្សាហកម្មធំៗ និងធនាគារ។ សហគ្រាសម៉ូណូប៉ូលចំនួនប្រាំមួយបានគ្រប់គ្រងផលិតផលលោហៈសឹងតែទាំងអស់ និង៩២%នៃផលិតផលដែកថែប។ សហគ្រាសដែកថែប"ស្កូដា" (skoda)នៅឆេកូ គឺជាសហគ្រាសឧស្សាហកម្មយោធាមួយក្នុងចំណោមសហគ្រាសធំៗនៅក្នុងទ្វីបអឺរ៉ុប។ នៅក្នុងតំបន់ ផ្សេងៗទៀតនៃអាណាចក្រអូទ្រីស-ហុងគ្រីមានឧស្សាហកម្មតូចធំៗជាច្រើនទៀត។ ហុងគ្រី ក្រូអាទី ហាលីស៊ី និងត្រង់ស៊ីវ៉ានី ជាតំបន់កសិកម្មដែលមានអភិជនម្ចាស់ដីធំៗ។ សឹងតែលើផ្ទៃដី ២/៣ ជាដី ធ្វើអាជីវកម្មនៅទីនោះជាកម្មសិទ្ធិរបស់ម្ចាស់ដីធំៗដែលមានរហូតដល់ទៅ ១០ពាន់ហិតាក្នុងម្នាក់ៗ។

លក្ខណៈពិសេសដែលសេដ្ឋកិច្ចរបស់អូទ្រីស-ហុងគ្រី បានទទួលឥទ្ធិពលយ៉ាងខ្លាំងពីសំណាក់ មូលធនរបស់បរទេស។ មុខសញ្ញាសំខាន់ៗ នៃឧស្សាហកម្មរបស់អូទ្រីស-ហុងគ្រី គឺជាផលិតផល លោហៈ សំណង់ម៉ាស៊ីន ប្រេងកាត អគ្គីសនីត្រូវបានទទួលបានការគាំទ្រហិរញ្ញវត្ថុពីសំណាក់សហគ្រាសពី ចក្រភព អាល្លឺម៉ង់ ឬមួយជាកម្មសិទ្ធិរបស់គេផ្ទាល់តែម្តង។ មូលនិធិរបស់បារាំងមាននៅទីនោះមានដូចជា នៅក្នុងសហគ្រាសគមនាគមន៍ ផ្លូវដែក ការជីកយករ៉ែ និងសហគ្រាសដែកថែបមួយចំនួន។

វណ្ណៈកម្មករនៅក្នុងអាណាចក្រអូទ្រីស-ហុងគ្រីមានចំនួនមិនច្រើនទេ។ ពួកគេបានបណ្តុំភាគ ច្រើននៅទីក្រុងនៃអូទ្រីស និងឆេកូ ហើយនិងនៅក្នុងប៊ុយតាប៉េស្តផងដែរ។ ទីក្រុងអាណាចក្រអូទ្រីស-ហុងគ្រី មានប្រជាជន២/៣រស់នៅក្នុងស្រុកស្រែចម្ការ ប្រកបរបបកសិកម្ម សិប្បកម្ម និងជំនួញតូចតាច។

## ១.៤.៣-វិបត្តិនៃអាណាចក្រអូទ្រីស-ហុងគ្រី

នៅដើមស.វ.ទី២០ អាណាចក្រអូទ្រីស-ហុងគ្រី បានជួបវិបត្តិយ៉ាងធ្ងន់ធ្ងរ ដែលធ្វើឱ្យមានការ បះបោរពីសំណាក់កម្មករ និងចលនាជាតិនិយម។ បន្ទាប់ពីបានបោះពុម្ព សេចក្តីប្រកាសរបស់ស្តេចត្សាររុស្ស៊ី ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩០៥ មក ដែលក្នុងនោះរក្សាបានសន្យាថានឹងបង្កើតឱ្យមានសេរីភាព ប្រជាធិបតេយ្យ ដែលនាំឱ្យមានឥទ្ធិពលយ៉ាងខ្លាំង ទៅលើកម្មករអូទ្រីស-ហុងគ្រី។ មេដឹកនាំបក្សសង្គម ប្រជាធិបតេយ្យអូទ្រីស ទាមទារឱ្យមានការអនុម័តច្បាប់បោះឆ្នោតជាសកល។ នៅដើមខែវិច្ឆិកា ឆ្នាំ១៩០៥ នៅទីក្រុងវៀន និងទីក្រុងប្រាកមក ក៏បានចេញធ្វើសេចក្តីសម្រេចចិត្តទទួលយកការទាមទាររបស់កម្មករ ហើយនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩០៥ បានប្រកាសស្តីពីការយល់ព្រមបង្កើតឱ្យមានការ បោះឆ្នោតជាសកល។

ចំណុចដ៏សំខាន់នៃជីវិតអាណាចក្រអូទ្រីស-ហុងគ្រីនៅពេលនោះ គឺទាក់ទងនឹងយោធាក្រៅប្រទេស។ ជុំវិញក្បាលម៉ាស៊ីនដឹកនាំជាពិសេស បក្សយោធានិយម ដែលមានមេដឹកនាំទៅរករបបយោធានិយមយ៉ាងខ្លាំង ហើយមានមុខងារជាអគ្គមេបញ្ជាការង និងជាអ្នកស្នងរាជ្យសម្បត្តិបន្តពីអធិរាជអូទ្រីស ព្រះអង្គម្ចាស់ហ្វ្រង់ហ្វ៊ែរឌីណង់ មានទិសដៅ នយោបាយចង់វាតទីនៅលើតំបន់បាល់កង់យ៉ាងខ្លាំង។ នៅខែតុលា ឆ្នាំ១៩០៨

រាជរដ្ឋាភិបាលបានធ្វើសេចក្ដីអំពីការភ្ជាប់បូស្នី និងហេស៊ែហ្គោវីនសែលជាអតីត អាណាខេត្តរបស់តួកគីមក នឹងអាណាចក្រអូទ្រីស-ហុងគ្រី នៅទីនោះប្រជាជនភាគច្រើន ជាជនជាតិស៊ែប និងក្រូអាទី។

ការភ្ជាប់បូស្នី និងហេស៊ែហ្គោវីន មកអាណាចក្រអូទ្រីស-ហុងគ្រី បានធ្វើឱ្យប្រជាជននៅក្នុង បណ្ដាខេត្តទាំងពីរនេះមានការក្ដៅក្រហាយយ៉ាងខ្លាំង ហើយរឹតតែធ្វើឱ្យតឹងតែងថែមទៀតនូវទំនាស់ រវាង អូទ្រីស-ហុងគ្រី និងស៊ែប៊ី។

## ១.៤.៤-វិបត្តិខែកក្កដា ឆ្នាំ១៩១៤

មុនឆ្នាំ១៩១៤ ទំនាស់រវាងប្លុកនយោបាយយោធារបស់ពួកមហាអំណាចអឺរ៉ុប គឺបក្សសម្ពន្ធត្រីភាគី និងសម្ពន្ធមិត្ត បានផ្ទុះឡើងដល់កម្រិតកំពូល។ តំបន់តឹងតែងជាពិសេសនៅឧបទ្វីបបាល់កង់។ ជុំវិញអ្នកដឹកនាំអូទ្រីស-ហុងគ្រី តាមការឱ្យដំបូន្មានពីសំណាក់អធិរាជចក្រភពអាល្លឺម៉ង់ បានសម្រេចចិត្តសំពងទៅលើស៊ែប៊ីមួយអន្លូងដើម្បីបង្ហាញកម្លាំងរបស់ខ្លួននៅតំបន់បាល់កង់។ បន្តិមកគេរកឃើញ លេសដើម្បីប្រកាសសង្គ្រាម។ កងទ័ពអូទ្រីស-ហុងគ្រី បានមកឈរជើងនៅក្បែរព្រំប្រទល់ និងស៊ែប៊ី។ មេដឹកនាំ"បក្សយោធានិយម" អូទ្រីសព្រះអង្គម្ចាស់ហ្វ្រង់ហ្វែឌីណង់ បានទៅធ្វើទស្សនកិច្ចក្នុងរដ្ឋធានីសារ៉ាយេវ៉ូរបស់បូស្នី។ សភាពការនេះបានដាស់អារម្មណ៍ស្នេហាជាតិយ៉ាងខ្លាំងក្នុងជួរយុវជនស៊ែប៊ី។ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩១៤ យុវជនជាតិនិយមស៊ែប៊ី ដែលមកពីអង្គការពាក់កណ្ដាលយោធា"ដៃខ្មៅ" បានចូលបាញ់ព្រះអង្គម្ចាស់ ហ្វ្រង់ហ្វែឌីណង់ នៅតាមដងវិថីមួយនៃសារ៉ាយេវ៉ូ។ សម្រាប់ពួកយោធានិយមអូទ្រីស-ហុងគ្រីបានលិចឡើង នូវ លេសដើម្បីកម្ទេចស៊ែប៊ី ប៉ុន្តែត្រូវបានរារាំងដោយត្សាររុស្ស៊ី។ អធិរាជចក្រភពអាល្លឺម៉ង់បានទទួលសំបុត្រពីអធិរាជអូទ្រីស-ហុងគ្រី។ រដ្ឋាភិបាលអាល្លឺម៉ង់ បានសន្យាជួយ ហើយបានបង្ខំសម្ពន្ធមិត្តរបស់ខ្លួនឱ្យ «បញ្ឈប់បញ្ហាជាមួយនិងស៊ែប៊ី»។ ថ្ងៃទី២៣ ខែកក្កដា អូទ្រីស-ហុងគ្រីបានដាក់កំហិតស៊ែប៊ីដែលមិនអាចបំពេញបាន ហើយដាក់ឱសានវាទដោយថោកទាបជាទីបំផុត។

រុស្ស៊ី ដែលពុំបានត្រៀមខ្លួនដើម្បីធ្វើសង្គ្រាម ដោយស្រួលបួលផងនោះបានឱ្យដំបូន្មានដល់រដ្ឋាភិបាលស៊ែប៊ី ឱ្យធ្វើការអត់ធ្មត់ជាអតិបរមានូវអ្វីដែលអាចធ្វើបាន។ យ៉ាងណាមិញអូទ្រីស-ហុងគ្រី និង អាល្លឺម៉ង់ មិនចង់ដោះស្រាយទំនាស់ដោយសន្តិវិធីនោះទេ។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩១៤ អូទ្រីស-ហុងគ្រីបានប្រកាសសង្គ្រាមជាមួយស៊ែប៊ី។ មុនដំបូងរុស្ស៊ី បានចូលរួមតែមួយផ្នែកប៉ុណ្ណោះ បន្ទាប់មក បានបញ្ជូនកងទ័ពមកសមរភូមិដោយពេញទំហឹងតែម្ដង។ អាល្លឺម៉ង់ឆ្លើយតបមកវិញ ដោយប្រកាស សង្គ្រាមជាមួយនិងរុស្ស៊ីនៅថ្ងៃទី១ និងទី៣ ខែសីហា ជាមួយបារាំង។ កងទ័ពអាល្លឺម៉ង់បានវាយលុកចូលប្រទេសបារាំង ដោយឆ្លងកាត់ប្រទេសប៊ែលហ្សិក ដែលជាប្រទេសអព្យាក្រិត។ ដោយការទាមទារឱ្យគោរពអព្យាក្រិតភាពប៊ែហ្សិក អង់គ្លេសបានទាមទារឱ្យអាល្លឺម៉ង់ ដកកងទ័ពចេញពីប្រទេសប៊ែលហ្សិក ដោយបានទទួលចម្លើយថ្ងៃទី៤ សីហា អង់គ្លេសបានប្រកាសសង្គ្រាមជាមួយអាល្លឺម៉ង់។ នៅលើសមរភូមិប្រយុទ្ធបានចាប់ផ្ដើមដោយប្រទេសមហាអំណាចអឺរ៉ុប ដោយបន្តិចម្ដងៗទាំងអស់ចូលរួម ៣៨ប្រទេស។ សង្គ្រាមបានក្លាយទៅជាសង្គ្រាមសកលលោក។

## ១.៥-ចក្រភពអាល្លឺម៉ង់

អាល្លឺម៉ង់ត្រូវបានប្រកាសជាចក្រភពនៅឆ្នាំ១៨៧១ នាវិមានវែរសៃ។ អាល្លឺម៉ង់ជាមហាអំណាចយោធាលើពិភពលោក និងជាប្រទេសមួយដែលមានអរិយធម៌ខ្ពង់ខ្ពស់ដែលជាមោទនភាពមួយរបស់ពួកគេ។ អាល្លឺម៉ង់ជាប្រទេសមហាអំណាចសេដ្ឋកិច្ចចុងក្រោយគេ បន្ទាប់ពីអង់គ្លេស បារាំង អាម៉េរិក។ ដូច្នេះដើម្បីរក ទីផ្សារបាន អាល្លឺម៉ង់ត្រូវពង្រឹងកងទ័ពទាំងជើងទឹក ទាំងជើងគោក ក្នុងគោលបំណងដណ្ដើមយកដែនដីអាណានិគម

ពីមហាអំណាចទាំងនោះ ស្របតាមទ្រឹស្តីរបស់ព្រះចៅអធិរាជគីយ៉ូមទី២ (William II) " អាល្លឺម៉ង់ត្រូវតែមានកន្លែងមួយនៅក្នុងភពព្រះអាទិត្យ " ។

### ១.៥.១-ស្ថាប័នរដ្ឋ

អាល្លឺម៉ង់ពីមុនជារដ្ឋតូចមួយ ប៉ុន្តែនៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៨៧១ នៅវិមានវែរសៃត្រូវបានប្រកាសជាចក្រភពអាល្លឺម៉ង់ដោយមានរដ្ឋសហព័ន្ធចំនួន២៥ជារដ្ឋអធិបតេយ្យ និងតំបន់ត្រួតត្រាមួយ ។

នៅពេលដែលរដ្ឋសហព័ន្ធទាំងអស់បានសម្រេចបង្កើតជាចក្រភពអាល្លឺម៉ង់ ដោយលើកព្រះចៅអធិរាជព្រុស ព្រះនាមគីយ៉ូមទី១(William I) ជាប្រមុខរដ្ឋដំបូងបង្អស់ ។

**ចក្រភពអាល្លឺម៉ង់មានសភាពីរគឺ**

- សភាប៊ុនដេស្រាត( Bundesrat) ជាសភាជាន់ខ្ពស់តំណាងឱ្យរដ្ឋអាល្លឺម៉ង់ទាំងអស់ សមាជិកជាប្រតិភូនៃប្រមុខរដ្ឋនីមួយៗ
- សភារ៉ៃស្តាក( Reichstag) ជាសភាជាន់ទាប មានសមាជិកជាតំណាងរាស្ត្រជ្រើសតាំងដោយការបោះឆ្នោតជាសកល ។

សភារ៉ៃស្តាកមាននាទីអនុម័តច្បាប់ តែត្រូវទទួលការយល់ព្រមពីសភាប៊ុនដេស្រាត ។ រដ្ឋសហព័ន្ធទាំងអស់មានរដ្ឋធម្មនុញ្ញរៀងៗខ្លួន ដែលមានព្រះចៅអធិរាជជាប្រមុខនៃ រដ្ឋាភិបាលដែលកាន់អំណាច នីតិប្រតិបត្តិ ហើយព្រះអង្គជាអ្នកជ្រើសតាំងអធិកាបតី ដែលទទួលខុសត្រូវខាងនយោបាយរដ្ឋ។

### ១.៥.២-រជ្ជកាលព្រះចៅអធិរាជគីយ៉ូមទី២

នៅឆ្នាំ១៨៨៨ ព្រះចៅអធិរាជគីយ៉ូមទី១សុគតទៅ រាជបុត្រព្រះនាម **ប្រេដេរិច**ទី៣សោយរាជ្យបន្តបានរយៈពេលតែ៣ខែ( ៩មីនា ដល់១៥មិថុនា១៨៨៨)ក៏សុគតទៅ។ ព្រះចៅអធិរាជគីយ៉ូមទី២ឡើង សោយរាជ្យតមក( ១៥មិថុនា១៨៨៨)។

កិច្ចការសំខាន់របស់ព្រះអង្គគឺបញ្ឈប់ប៊ីស្មាក់ពីមុខតំណែង ដោយទ្រាំមិនបានពីការមិនចេះទទួលយកការជំទាស់របស់អធិការរូបនេះ។ ម្យ៉ាងទៀតព្រះចៅអធិរាជ និងលោកអធិការបតីពុំដែលមាន យោបល់ស្របគ្នាឡើយ ចំពោះបញ្ហាធំៗខាងនយោបាយក្នុង និងក្រៅប្រទេស។

ព្រះចៅអធិរាជ គីយ៉ូមទី២ ទ្រង់យល់ថា បញ្ហាធំដែលជាអាយុជីវិតរបស់ប្រទេសអាល្លឺម៉ង់គឺ បញ្ហាវត្ថុធាតុដើម និងទីផ្សារសម្រាប់លក់ទំនិញ។ នៅឆ្នាំ១៨៩០ ប្រទេសអាឡឺម៉ង់មានអាណានិគមខ្លះ នៅក្នុងទ្វីបអាហ្វ្រិក ដូចជា តូគោ ( Togo )កាម៉ឺរូន ( Cameroun) អាហ្វ្រិកនិរតី និងអាហ្វ្រិកខាងត្បូង។ ក្រៅពីនេះ ប្រទេសអាល្លឺម៉ង់បានត្រួតត្រាលើកោះខ្លះនៅមហាសមុទ្ទប៉ាស៊ីហ្វិច និងដីសម្បទាននៅការចូវ ( Kioa-Tcheou ) ក្នុងប្រទេសចិនទៀត។ ប៉ុន្តែប្រទេសអាល្លឺម៉ង់ទទួលបានទឹកដីជាទីផ្សារ ដែលមានសភាពសេដ្ឋកិច្ចអន់ជាងទឹកដីដែលកាន់កាប់ដោយបារាំង និងអង់គ្លេស។ ដូនេះប្រទេសអាល្លឺម៉ង់ ក៏យកប្រទេសអស៊ីទួក (Asie Turque) ដាក់ជារដ្ឋអាណាព្យាបាល របស់ខ្លួនថែមទៀត ដោយបានសង់ផ្លូវរថភ្លើងភ្ជាប់ពី ទីក្រុងកុងស្តង់ទីណូប (Constantinople) ទៅឈូងសមុទ្ទពែក (Golse Persique) ផង។ ដើម្បីការពារផលប្រយោជន៍នយោបាយ និងសេដ្ឋកិច្ចរបស់ខ្លួន ប្រទេសអាល្លឺម៉ង់ ត្រូវតែខ្លាំងពូកែ។ កងនាវាចម្បាំងជាតិអាល្លឺម៉ង់ដែលមានឋានៈ លេខ២ក្នុងពិភពលោក ជាសមិទ្ធិកើតឡើងដោយ ស្នាព្រះហស្តព្រះចៅអធិរាជ ដោយធ្វើសហប្រតិបត្តិការពីលោក តៀ

ពិត (Tirpitz) ដែលជារដ្ឋមន្ត្រីអង់គ្លេស មានសេចក្តីបារម្ភខ្លាំង ហើយជំរុញប្រទេសនេះឱ្យកាន់តែ ខិតជិតប្រទេសបារាំងឡើង។

ក្នុងវិស័យវប្បធម៌ប្រទេសអាល្លឺម៉ង់ក៏នៅតែមានសារៈសំខាន់ខ្ពង់ខ្ពស់ដដែល។ ប្រទេសអាល្លឺម៉ង់ មានកវីនិពន្ធយ៉ាងជំនាញៗ មានទស្សនវិទូយ៉ាងសំខាន់ៗ ដូចជា នីត (Nietzschr) មានសិល្បករភ្លេងយ៉ាងល្បីៗ ដូចជា វ៉ាកន័រ (Wagner) និងស្ត្រៅ (Strauss) ។ ដោយមានមហិច្ឆតាអានុភាពជាក់ស្តែងរបស់ប្រទេសខ្លួនក្នុងវិស័យវប្បធម៌ សេដ្ឋកិច្ច និងយោធា ជនជាតិអាល្លឺម៉ង់ខ្លះយល់ថាប្រទេសរបស់ខ្លួនអាចគ្រប់គ្រង ពិភពលោកបាន ជាហេតុនាំឱ្យប្រជាជាតិដទៃមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ។

**១.៥.៣-រដ្ឋាភិបាលប៊ីស្មាក់** (Bismarck) **ឆ្នាំ១៨៧១-១៨៩០**

នៅក្នុងសភារ៉ៃស្តាកមានគណបក្សបីសំខាន់គឺ៖

**គណបក្សអភិរក្សនិយម** សមាជិកជាក្រុមម្ចាស់ដីធំៗ ចូលចិត្តរបបពាណិជ្ជកម្មឧបត្ថមនិយម។

**គណបក្សជាតិសេរី** សមាជិកជាឧស្សាហករ ពាណិជ្ជករ ចូលចិត្តរបបប្តូរដោយសេរី និងរបបនយោបាយសេរី។

**គណបក្សកាតូលិក** សមាជិកជាគណៈសង្ឃកាតូលិក ។

ពីឆ្នាំ១៨៧១ ដល់ឆ្នាំ១៨៧៨ ប៊ីស្មាក់ពឹងផ្អែកលើ បក្សជាតិសេរីដើម្បីប្រឆាំងនឹងបក្សកាតូលិក។ ក្រោយឆ្នាំ១៨៧៨ ប៊ីស្មាក់បានចូលរួមជាមួយនឹងបក្សអភិរក្សនិយម និងបក្សកាតូលិក ដើម្បីប្រឆាំងនឹងពួកសង្គមនិយមវិញ។ គាត់មិនដែលទុកចិត្តនឹងបក្សកាតូលិកឡើយ ដោយមើលឃើញមានបក្សពួករបស់ប្រទេសអូទ្រីស បក្សពួករបស់ជនប៉ូញឡូញ និងជនអាល់សាស-ឡូរ៉ែន។ ម្យ៉ាងទៀត បុព្វសិទ្ធិ របស់គណៈសង្ឃកាតូលិកប្រទេសព្រុសមានច្រើនណាស់។ គណៈសង្ឃកាតូលិកនេះសឹងតែមិននៅក្រោមអំណាចត្រួតត្រារបស់រដ្ឋាភិបាលសោះ ហើយមានសិទ្ធិកាន់កាប់បញ្ជីអត្រានុកូលដ្ឋាន និងគ្រប់គ្រងបឋមសិក្សាផង។

នៅឆ្នាំ១៨៧១ សភារ៉ៃស្តាក បានអម័តច្បាប់ជាវិធានការប្រឆាំងនឹងគណៈសង្ឃកាតូលិក។ អធិបតេយ្យនៃរដ្ឋត្រូវបានប្រកាសឡើង អាពាហ៍ពិពាហ៍ស៊ីវិលត្រូវដាក់ឱ្យអនុវត្តជាទូទៅ (កាលពីមុន គេរៀបអាពាហ៍ពិពាហ៍តែតាមផ្លូវសាសនា)។ សភាប្រទេសព្រុសបានប្រកាសបិទវិហារកាតូលិកជាច្រើន ព្រមទាំងដកសិទ្ធិគ្រប់គ្រងបឋមសិក្សាពីគណៈសង្ឃកាតូលិកទៀតផង។ មន្ត្រីសង្ឃទាំងឡាយត្រូវ តែងតាំងឡើងដោយរដ្ឋាភិបាល។ ប៉ុន្តែក្រោយសម្តេចប៉ាបពីទី៩ (Pei IX) សោយទីវង្គតទៅ (១៨៧៨) ប៊ីស្មាក់ចាប់ផ្តើមចរចាជាមួយនឹងសម្តេចប៉ាបថ្មីព្រះនាម លេអុងទី១៣ (Leon XIII) ហើយគណបក្សនេះ ក្លាយជាគណបក្សរស់រដ្ឋាភិបាល។ ការខិតជិតរបស់ប៊ីស្មាក់មករកគណបក្សកាតូលិកបានធ្វើឱ្យគាត់កាន់តែឃ្លាតពីគណបក្សជាតិសេរី។

ប៊ីស្មាក់ប្រកាន់យកនយោបាយឧបត្ថម្ភនិយមដើម្បីទ្រទ្រង់កសិកម្ម និងឧស្សាហកម្ម ជាហេតុធ្វើឱ្យប៊ីស្មាក់ត្រូវប្រឆាំងនឹងពួកសង្គមនិយមផងដែរ។ ប៉ុន្តែប៊ីស្មាក់បានសាកល្បងដោះស្រាយបញ្ហាកម្មករ ដើម្បីឱ្យកម្មករងាកទៅរករដ្ឋាភិបាល ដោយបានបង្កើតច្បាប់ធានារ៉ាប់រងអំពីជំងឺ និងហានិភ័យសង្គម។

រដ្ឋាភិបាលប៊ីស្មាក់បានធ្វើការកែទម្រង់ជាច្រើន។ នៅឆ្នាំ១៨៨១ ប៊ីស្មាក់បានប្រកាសចែងច្បាប់សិទ្ធិកម្មករដែលរងគ្រោះដោយចៃដន្យ ក្នុងពេលផលិតកម្ម ឬដោយសារជំងឺព្យាធិ។ នៅឆ្នាំ១៨៨៩បានអុម័តច្បាប់ស្តីពីម៉ោងពលកម្ម១១ម៉ោងក្នុងមួយថ្ងៃ និងបម្រាមមិនឱ្យកុមារអាយុតិចជាង១៣ឆ្នាំធ្វើការងារពលកម្ម។

ចាប់ពីដើមទសវត្សទី៨នៃសតវត្សទី១៩ នយោបាយក្រៅប្រទេសរបស់ប៊ីស្មាក់មានទិសដៅ ផ្តោតលើបញ្ហាអាណានិគមនិយម។

នៅឆ្នាំ១៨៨៨ ព្រះចៅអធិរាជគីយ៉ូមទី១បានចូលទីវង្គត ហើយចៅរបស់ព្រះអង្គគីយ៉ូមទី២បាន ឡើងសោយរាជ្យបន្ត តែព្រះអង្គមានទំនាស់ជាច្រើននឹងការគ្រប់គ្រងអំណាចអធិការបតីរបស់ប៊ីស្មាក់។

នៅឆ្នាំ១៨៩០ ប៊ីស្មាក់បានចុះចេញពីតំណែងអធិការបតី។ តែនយោបាយអនុត្តរភាពនិយមបាន រីកដុះដាលកាន់តែខ្លាំង។ ពួកអភិរក្សនិយម និងបក្សជាតិសេរីនិយម បានរួមគ្នាជាក្រុមឃោឍាបង្កើត សហភាពអាល្លឺម៉ង់( Pan Germany ) គោលនយោបាយ "Pan Germany" បានកំណត់ថាជនជាតិ អាល្លឺម៉ង់ គឺជាជនជាតិត្រូវតែមានឧត្តមភាពលើជនជាតិដទៃ ហេតុដូច្នេះជនជាតិអាល្លឺម៉ង់ត្រូវតែគ្រប់គ្រងលើជនជាតិទាំងអស់។ សហភាពអាល្លឺម៉ង់បានទាមទារឱ្យមានការកំណត់នយោបាយ យកប្រទេសដទៃ មកដាក់ក្រោមអំណាចរបស់ខ្លួនដោយប្រើកម្លាំងបាយ។ ដើម្បីសម្រេចនយោបាយនោះសហភាពអាល្លឺម៉ង់ ទាមទារឱ្យមានការពង្រីកកម្លាំងយោធាទាំងជើងគោក និងជើងទឹក ក្នុងបំណងធ្វើសង្គ្រាមនឹងប្រទេសដទៃទៀត។ គម្រោងរបស់សហភាពអាល្លឺម៉ង់ស្តីពីការឈ្លានពានរបស់ចក្រភព អាល្លឺម៉ង់មានមុខសញ្ញាពីរសំខាន់ៗ គឺទិសបស្ចិម និងទិសបូព៌ា។ មុខសញ្ញាខាងទិសបស្ចិមជាដំបូងត្រូវជួបនឹងចក្រភពអង់គ្លេស និងបារាំង គឺជុំវិញទំនាស់នៃការបែងចែកទឹកដីអាណានិគមនិយម។ ការវាយលុកទៅទិសបូព៌ាជាដំបូង គឺប្រឆាំងនឹងរុស្ស៊ី ដើម្បីវាតទីយកទឹកដីប្រកបទៅដោយជីជាតិ និងវាតទីយកមជ្ឈិមបូព៌ា។ ការឃោសនា របស់សហភាពអាល្លឺម៉ង់បានធ្វើឱ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងក្នុងជួររដ្ឋាភិបាល។ ការបំពាក់បំប៉ន និងពង្រីកកម្លាំងយោធាជាកត្តាចាំបាច់របស់ចក្រភព រីឯនយោបាយយោធានិយមគឺជាផុកទ្រីនរបស់ រដ្ឋាភិបាល។ បើគិតពីចុងសតវត្សទី១៩ រហូតដល់ឆ្នាំ ១៩១៣ រដ្ឋាភិបាលចក្រភពអាល្លឺម៉ង់បានចំណាយលើ យោធាប្រាំដង គឺស្មើនឹងពាក់កណ្តាលនៃការចំណាយទាំងស្រុងរបស់ថវិការជាតិ។

ចក្រភពអាល្លឺម៉ង់បានសង់នាវាចម្បាំងជាច្រើន រហូតមកដល់ឆ្នាំ១៩១៤ ជាប់ចំណាត់ថ្នាក់លេខ២ បន្ទាប់ពីចក្រភពអង់គ្លេស។

## ២-ការប្រណាំងប្រជែងខាងកម្លាំង សេដ្ឋកិច្ច និងអាណានិគម

### ២.១-ការប្រជែងផ្នែកយោធា

នៅចុងសតវត្សទី១៩ ដើមសតវត្សទី២០ ទំនាក់ទំនងអន្តរជាតិកាន់តែរង្គោះរង្គើខ្លាំងឡើងៗ ដែលឈានទៅរកការផ្ទុះសង្គ្រាមប្រកបដោយគ្រោះថ្នាក់ជាទីបំផុត។ នៅលើឆាកអន្តរជាតិបានលេចឡើងនូវកម្លាំងថ្មីៗ ដ៏ខ្លាំងក្លា។ រីឯនៅទ្វីបអឺរ៉ុបការបង្រួបបង្រួមប្រទេសអាល្លឺម៉ង់ និងអ៊ីតាលីមានកម្លាំងកាន់តែខ្លាំងឡើង។ ការលេចចេញនៃរូបរាងមហាអំណាចទាំងពីរនេះ នឹងប៉ះទង្គិចទៅលើចក្រភពអង់គ្លេស បារាំង រុស្ស៊ី អូទ្រីស-ហុងគ្រី និងមហាអំណាចផ្សេងៗ ទៀតដោយជៀសមិនរួចឡើយ។ រីឯនៅទ្វីបអាស៊ីវិញអ្នកដែលចង់មានតួនាទីនោះគឺជប៉ុន ដែលធ្វើឱ្យប៉ះទង្គិចនឹងផលប្រយោជន៍របស់រុស្ស៊ី អង់គ្លេស អាល្លឺម៉ង់ បារាំង និង សហរដ្ឋអាម៉េរិក។

ទំនាស់អន្តរជាតិត្រូវបានកំណត់ផ្សេងៗពីគ្នា អាស្រ័យទៅនឹងផលប្រយោជន៍របស់កំពូលមហាអំណាចចាស់និងថ្មី។ ការប៉ះទង្គិចគ្នាយ៉ាងខ្លាំងក្លាដោយសារតែការដណ្តើមប្រទេសអាណានិគម និងតំបន់ក្រោមឥទ្ធិពលដូចមានការគ្រប់គ្រងទៅលើផ្ទៃសមុទ្ទ និងនៅលើផ្ទៃដីគោក នៅក្នុងទំនាក់ទំនងយោធា។ ការវាតទីប្រឹងប្រែងវាយលុកដើម្បីពង្រីកទឹកដី បានឆ្លើយតបទៅនឹងទ្រឹស្តីជាតិនិយម Geopolitism ទ្រឹស្តីអំណាចយោធានិយម ជប៉ុន «មហាអំណាចអាស៊ី» ទ្រឹស្តីវាតទីរបស់ចក្រភពអង់គ្លេស។

ទំនាស់បានកើតឡើងចេញពី អាណាចក្រអូតូម៉ង់ ដែលលាតសន្ធឹងលើទឹកដីយ៉ាងធំធេងនៃតំបន់ភូមិភាគខាងជើងនៃទ្វីបអាហ្វ្រិក តំបន់មជ្ឈិមបូព៌ា តំបន់អឺរ៉ុបប៉ែកអាគ្នេយ៍ ហើយដែលក្លាយជាការបែងចែករវាងពួកប្រទេសចក្រពត្តិនិយម។

ទំនាស់បានកើតឡើងជាបន្តបន្ទាប់ដោយសារតែ ប្រទេសមហាអំណាចទាំងអស់គ្មានភាពចុះសម្រុងគ្នា យកកម្លាំងយោធាជាមធ្យោបាយសម្រាប់ដោះស្រាយបញ្ហាកិត្យានុភាព និងឥទ្ធិពលនៅក្នុងពិភពលោកដ៏ ធំធេងនេះ។ កិច្ចព្រមព្រៀងការយោគយល់ដោយបិទបាំង ឬដោយចំហជាឥរិយាបថការទូត និងជានយោបាយក្រៅប្រទេសរបស់រដ្ឋដែលជាការលាក់កំបាំង ឬជាការគំរាមកំហែងដោយចំហអាស្រ័យនឹងល្បែង នយោបាយ។

## ២.២-ការប្រជែងផ្នែកដែនដីអាណានិគម

នៅដំណាច់សតវត្សទី១៩ ពិភពលោកទាំងមូលត្រូវបានបែងចែកជាស្រេចរវាងមហាអំណាចទាំង៥ នៅលើពិភពលោក ប៉ុន្តែការបែងចែកនោះដូចជាមានភាពមិនស្មើគ្នាដែលនាំឱ្យមហាអំណាចមួយចំនួននៅក្នុងនោះមានភាពមិនពេញចិត្ត ព្រោះខ្លួនទទួលបានដែនដីអាណានិគមតិចជាងគេ។ តួយ៉ាងដូចជាប្រទេសអាល្លឺម៉ង់ ដែលទទួលបានដែនដីអាណានិគមតិចជាងអង់គ្លេស និងបារាំង។ លុះមកដល់ដើមសតវត្សទី២០ ទំនាស់រវាងមហាអំណាចអាណានិគមទាំងនោះកាន់តែមានសភាពខ្លាំងឡើង ពោលគឺនយោបាយរុករានយកប្រទេសដទៃមកធ្វើជាអាណនិគមរបស់ខ្លួន។

### ក.សង្គ្រាមអាម៉េរិក-អេស្ប៉ាញ

មុនពេលសង្គ្រាមរវាង សហរដ្ឋអាម៉េរិក ជាមួយអេស្ប៉ាញបានផ្ទុះឡើងតាំងពីឆ្នាំ ១៨៤៩ មកម្ល៉េះ សហរដ្ឋអាម៉េរិកបានធ្វើសំណើសុំទិញ កោះគុយបាពីអេស្ប៉ាញ ដោយបានឱ្យតម្លៃកោះនោះតម្លៃ ១០០លានដុល្លារសហរដ្ឋអាម៉េរិក។ អេស្ប៉ាញបានបដិសេធ ព្រោះមិនធ្លាប់មានប្រពៃណីលក់ប្រទេសអាណានិគមឡើយ។ បន្ទាប់មកនៅឆ្នាំ១៨៩៥ លើកោះគុយបាបានផ្ទុះឡើងនូវការបះបោរចុងក្រោយបង្អស់ប្រឆាំងនឹងអំណាចគ្រប់គ្រងរបស់អេស្ប៉ាញ។ សហរដ្ឋអាម៉េរិក បានគិតថាជាឱកាសល្អក្នុងការប្រើព្រឹត្តិការណ៍នេះធ្វើជាមធ្យោបាយលូកដៃបញ្ហាកោះគុយបាតាមរយៈការគាំទ្រចលនាបះបោរប្រឆាំងនឹងអេស្ប៉ាញ ទីបំផុតឈ្លានពានលើកោះគុយបាតែម្តង។ ដោយសារតែការផ្ទុះគ្រាប់បែកនៅលើនាវាចម្បាំងមេន សហរដ្ឋអាម៉េរិកបានយកលេសនេះវាយលុកទៅលើអេស្ប៉ាញ នាខែមេសា ឆ្នាំ១៨៩៨។ សហរដ្ឋអាម៉េរិកបានទទួលជ័យជម្នះយ៉ាងឆាប់រហ័សដោយបានវាយកម្ទេចកងទ័ពនាវាអេស្ប៉ាញ។ នៅពេលនោះកោះគុយបាក៏ទទួលបានឯករាជ្យពីប្រទេសអេស្ប៉ាញ ប៉ុន្តែបានក្លាយជាប្រទេសពាក់កណ្តាលអាណានិគមរបស់សហរដ្ឋអាម៉េរិកទៅវិញ។

ដូច្នេះសង្គ្រាមរវាងសហរដ្ឋអាម៉េរិក និងអេស្ប៉ាញបានចាប់ផ្តើមដំណាក់កាលថ្មី នៃប្រវត្តិសាស្ត្រនៃទំនាក់ទំនងអន្តរជាតិ និងជាសង្គ្រាមទីមួយដើម្បីបែងចែកពិភពលោក ប៉ុន្តែវាមិនមែនជាលើកចុងក្រោយនោះទេ។ ជ័យជម្នះរបស់សហរដ្ឋអាម៉េរិកទៅលើអេស្ប៉ាញបានផ្តល់លទ្ធភាពឱ្យសហរដ្ឋអាម៉េរិកបើកផ្លូវដើម្បីធ្វើការឈ្លានពានទៅលើភូមិភាគខាងត្បូងនៃអាម៉េរិកឡាទីន តំបន់បូព៌ា និងភូមិភាគអាស៊ីអាគ្នេយ៍ថែមទៀតផង។

### ខ-សង្គ្រាមរវាងចក្រភពអង់គ្លេស និងសាធារណរដ្ឋប៊ួរ

សង្គ្រាមមួយទៀតដែលទាក់ទងទៅនឹងការបែងចែកពិភពលោកគឺ ការពាក់ព័ន្ធរវាងអង់គ្លេសជាមួយនឹងសាធារណរដ្ឋប៊ួរទាំងពីរដែលស្ថិតនៅភូមិភាគខាងត្បូងនៃទ្វីបអាហ្វ្រិក។ សង្គ្រាមរវាងអង់គ្លេស និងប៊ួរ ចាប់ផ្តើមពីថ្ងៃទី១១ ខែតុលា ឆ្នាំ១៨៩៩ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩០២ គឺជាសង្គ្រាម ដែលមានទ្រង់ទ្រាយធំ ជាធម្មតាគេស្គាល់ថាជាសង្គ្រាមប៊ួរ។ មូលហេតុដែលអង់គ្លេសធ្វើ សង្គ្រាមនេះព្រោះអង់គ្លេស

ចង់បានផ្លូវឆ្លោះទៅរកឧស្សាហកម្មករុករករ៉ែមាសនៅតំបន់នោះ ក៏ដូចជាចង់បញ្ចូលរដ្ឋនោះឱ្យក្លាយជារដ្ឋសហព័ន្ធ នៃការគ្រប់គ្រងរបស់ខ្លួនផង។ ចក្រភពអង់គ្លេស បានបញ្ជូនកងទ័ពចំនួន ២៥០,០០០នាក់ ទៅប្រយុទ្ធនឹងកងទ័ពប៊ួរ (មានដើមកំណើតពីហូឡង់)។ នៅក្នុងការប្រយុទ្ធគ្នានោះ គេបានប្រើអាវុធយុទ្ធភណ្ឌទំនើបៗ ដែលជាគំរូដល់កងទ័ពលើពិភពលោក និងជាលើកទីមួយដែលកងទ័ពអង់គ្លេសបានប្រើកាំភ្លើងយន្ត។

ដោយសារកម្លាំងរបស់ គូសត្រូវទាំងពីរហាក់ដូចជាមានសភាពមិនស្មើគ្នាឡើយ ជាចុងក្រោយកងទ័ពប៊ួរ ត្រូវបានទទួលបរាជ័យ។ សាធារណរដ្ឋប៊ួរទាំងពីរត្រូវបានភ្ជាប់ជាដែនដីអាណានិគមរបស់អង់គ្លេស។ ការយោគយល់គ្នារវាងមហាអំណាចមេត្រូប៉ូលអង់គ្លេស និងពួកស្បែកសប៊ួរដោយជាប់ពាក់ព័ន្ធផងដែរទៅនឹងជនជាតិស្បែកខ្មៅនៅទីនោះបានបង្កើតសហភាពអាហ្វ្រិកខាងត្បូង។ នៅឆ្នាំ១៩១០ គេបានទទួលឋានៈជាសមាជិកដូមីណូនស្វ័យភាពក្នុងការដឹកនាំប្រទេសនោះ។

**គ-សង្គ្រាមរុស្ស៊ី-ជប៉ុន**

សង្គ្រាមរុស្ស៊ី-ជប៉ុនបានកើតឡើងនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩០៤ រហូតដល់ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩០៥ គឺជាសង្គ្រាមបែងចែកតំបន់អាណានិគមនៅក្នុងតំបន់ចុងបូព៌ាដោយរុស្ស៊ី មិនពេញចិត្តជាមួយជប៉ុនរឿងការចរចាការបែងចែកផលប្រយោជន៍នៅតំបន់ម៉ាន់ជូរី និងកូរ៉េ។ ដំបូងរុស្ស៊ីបានស្នើសុំផ្លូវទឹកទៅជប៉ុននៅក្នុងតំបន់នៃមហាសមុទ្រប៉ាស៊ីហ្វិកដើម្បីប្រើក្នុងវិស័យកងទ័ពជើងទឹក និងផ្នែកពាណិជ្ជកម្មរបស់រុស្ស៊ី ប៉ុន្តែការស្នើសុំរបស់រុស្ស៊ីនេះមិនបានសម្រេចទេ រហូតដល់មានជម្លោះដែលនាំឱ្យជប៉ុនជ្រើសរើសការធ្វើសង្គ្រាមដើម្បីទទួលបានការគ្រប់គ្រងឧបទ្វីបកូរ៉េ និងម៉ាន់ជូរី បន្ទាប់ពីការចរចាដោយសន្តិវិធីត្រូវបានបញ្ចប់។ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩០៤ ជប៉ុនបានប្រកាសសង្គ្រាមជាមួយរុស្ស៊ី ដោយឱ្យដំណឹងទៅរុស្ស៊ីមុនការធ្វើសង្គ្រាមត្រឹមតែ ៣ម៉ោងមុនប៉ុណ្ណោះ ហើយបានឡោមព័ទ្ធកងទ័ពជើងទឹករបស់រុស្ស៊ី និងតំបន់ភាគខាងកើតនៃប្រទេសរុស្ស៊ី។ ការធ្វើសង្គ្រាមលើកនេះធ្វើឱ្យព្រះរាជារបស់រុស្ស៊ី មានភាពភ្ញាក់ផ្អើលដែលសឹងតែមិនជឿថាជប៉ុនអាចធ្វើសង្គ្រាមដោយមិនមានការប្រកាសមុនជាផ្លូវការសោះឡើយ នៅពេលនោះជប៉ុនក៏បានតបទៅរុស្ស៊ីវិញ ដោយអាងថាកាលពី រុស្ស៊ីធ្វើសង្គ្រាមជាមួយ ស៊ុយអែតនៅឆ្នាំ១៨០៩ នៅពេលនោះរុស្ស៊ីក៏មិនបានប្រកាសសង្គ្រាមមុនដែរ ហើយនៅពេលនោះការធ្វើសង្គ្រាមរបស់រុស្ស៊ីក៏មិនបានខុសច្បាប់ឡើយ ហើយសង្គ្រាមក៏ចេះតែបន្តទៅមុខទៀត រហូតដល់មានការចូលរួមបីសំណាក់មហាអំណាចផ្សេងៗទៀតចូលមកជួយជប៉ុន។ នៅក្នុងសង្គ្រាមនេះអង់គ្លេស និងសហរដ្ឋអាម៉េរិកស្ថិតនៅក្នុងភាគីរបស់ជប៉ុន។ អង់គ្លេស និង សហរដ្ឋអាម៉េរិកបានខ្ចីដៃជប៉ុន ដើម្បីធ្វើឱ្យស្ដេចរុស្ស៊ីចុះទន់ខ្សោយ។ នៅឆ្នាំ១៩០២អង់គ្លេសបានចុះហត្ថលេខាចងសម្ពន្ធភាពជាមួយនឹងជប៉ុន រីឯសហរដ្ឋអាម៉េរិក បានជួយជប៉ុនដើម្បីបានចំណេញក្នុងការចុះហត្ថលេខាសន្តិភាពជាមួយរុស្ស៊ីនៅឆ្នាំ១៩០៥។ ជាលទ្ធផលជប៉ុនបានពង្រឹងគោលជំហររបស់ខ្លួននៅក្នុងភូមិភាគខាងត្បូងនៃតំបន់ម៉ាន់ជូរី និងបានបង្កបរិយាកាសដ៏ល្អទៀតផង។

នៅឆ្នាំ១៩១០ ជប៉ុនបានយកកូរ៉េដាក់ជាប្រទេសអាណានិគមរបស់ខ្លួន ហើយទៅថ្ងៃមុខទៀតនឹងឈានទៅយកតំបន់ភូមិភាគអាស៊ីអាគ្នេយ៍ទាំងអស់។ ផ្ទុយទៅវិញសហរដ្ឋអាម៉េរិកមិនត្រឹមតែមិនបានឃើញភាពចុះខ្សោយរបស់ស្ដេចរុស្ស៊ីទេ តែបែរជាទទួលត្រឡប់មកវិញនូវសត្រូវដ៏កាចសាហាវបំផុតនោះគឺ ជប៉ុន។

**ឃ-ចក្ខុវិស័យអាល្លឺម៉ង់នៅលើនយោបាយអាណានិគមនិយម**

នៅក្នុងដំណាក់កាលនៃសង្គ្រាមអង់គ្លេស-ប៊ួរ មេដឹកនាំរបស់អាល្លឺម៉ង់ បានលើកបដារបស់គីយ៉ូមទី២ គឺ«អនាគតរបស់យើងនៅលើទឹក»។ នៅឆ្នាំ១៩០០ នៅពេលដែលសភាពការណ៍ពិភពលោកកំពុងតែស្មុគ

ស្នាញរវាងសង្គ្រាម និងសន្តិភាព សភារ៉ៃស្តាកបានអនុម័តកម្មវិធីស្តីពីការប្រកួតប្រជែងសព្វាវុធនៅលើផ្ទៃសមុទ្ទ។ បញ្ហាសំខាន់នៅក្នុងកម្មវិធីនេះគឺយកជ័យជម្នះទៅលើម្ចាស់សមុទ្ទទីមួយគឺ ចក្រភពអង់គ្លេស។ មុនឆ្នាំ១៩១៥ អាល្លឺម៉ង់មាននាវាចម្បាំងគ្រប់ប្រភេទប្រហែល២០០គ្រឿង។ ដោយឆ្លើយតបទៅនឹងកម្មវិធីថ្មី អាល្លឺម៉ង់ និងចក្រភពអង់គ្លេសបានសម្រេចចិត្តសង់នាវាចម្បាំងថ្មីថែមទៀត។

ការប្រឆាំងគ្នារវាងអង់គ្លេស និងអាល្លឺម៉ង់បានលេចធ្លោឡើងនៅតំបន់មជ្ឈិមបូព៌ា។ ពួកមូលធន អាល្លឺម៉ង់ទាមទារពីរដ្ឋាភិបាលតួកគី នូវសេចក្តីសម្រេចចិត្តដ៏សំខាន់ គឺការជានាក្នុងការសាងសង់ផ្លូវដែកទៅកាន់តំបន់មជ្ឈិមបូព៌ា ដោយចេញពីបែរទ្បាំងឆ្លងកាត់បាកដាត រហូតដល់គុយវ៉ែត។ ទំនាស់រវាងអង់គ្លេស និងអាល្លឺម៉ង់បានធ្វើឱ្យមានបម្រែបម្រួលនយោបាយក្រៅប្រទេសរបស់អង់គ្លេសនៅទ្វីបអឺរ៉ុប។

## ២.៣-ការប្រជែងផ្នែកសេដ្ឋកិច្ច

មហាអំណាចនៅទ្វីបអឺរ៉ុបក្នុងឆ្នាំ១៩១៤ មានចំនួន៥ ធំជាងគេហើយជាអ្នកដឹកនាំនយោបាយពិភពលោកទាំងមូលផងដែរ ម៉្យាងទៀតមហាអំណាចទាំងនោះបានខិតខំពង្រីកឧស្សាហកម្មរៀងៗ ខ្លួនយ៉ាងខ្លាំងសម្បើម។ គេខំធ្វើឧស្សាហកម្មឱ្យបានលូតលាស់យ៉ាងឆាប់រហ័សដើម្បីយកល្បីឈ្មោះរៀងៗខ្លួនដូចជា៖

- នៅរុស្ស៊ី និងអូទ្រីស-ហុងគ្រី បានរៀបចំសេដ្ឋកិច្ចរបស់ខ្លួនឱ្យបានទាន់សម័យ ប៉ុន្តែប្រទេសទាំងពីរនេះហាក់ដូចជានៅមានឧស្សាហកម្មអន់ថយនៅឡើយ (រោងចក្រមានតិចតួចស្តួចស្តើង, ភាគច្រើនប្រជាជន ជាអ្នកស្រែចម្ការប្រកបរបរកសិកម្ម...) ប៉ុន្តែ នៅចុងសតវត្សទី១៩នេះប្រទេសទាំងពីរបានកែប្រែខ្លួនរហូតបានក្លាយជាប្រទេសក្នុងចំណោមមហាអំណាចទាំង៥ នៅអឺរ៉ុបមុនសង្គ្រាមលោកលើកទី១។
- សាធារណរដ្ឋបារាំងជាប្រទេសដែលប្រកបដោយឧស្សហកម្មទំនើប ហើយមានមធ្យោបាយដឹកនាំលូតលាស់ទាន់សម័យ រួមទាំងជាមហាអំណាចអាណានិគមមួយខ្លាំងពូកែដោយមានទឹកដីនៅឯនាយសមុទ្ទ ច្រើនគ្រប់ទ្វីប។ រីឯប្រាក់បារាំងទៀតសោតមានជំហររឹងប៉ឹងទុកជារូបិយប័ណ្ណអន្តរជាតិ ប៉ុន្តែកសិកម្មនៅបារាំងហាក់ដូចជានៅមានការវិវត្តយឺតយ៉ាវ។
- ចក្រភពអង់គ្លេសជាមហាអំណាចអាណានិគមមួយដែរ ហើយចក្រភពអង់គ្លេសក៏ជាមហាអំណាចលេខមួយខាងសេដ្ឋកិច្ចនៅទ្វីបអឺរ៉ុបផងដែរ។ ចក្រភពអង់គ្លេសមានឧស្សាហកម្មលូតលាស់ជាងគេ (មានឧស្សាហកម្មធ្យូងថ្ម ដែកថែបលេខ១នៅលើពិភពលោក) មិនត្រឹមតែប៉ុណ្ណោះចក្រភពអង់គ្លេសមានទឹកដីរណបប្រមាណ ៣១លានគីឡូម៉ែត្រក្រឡា ប៉ុន្តែលុះមកដល់ឆ្នាំ១៩១៤ អង់គ្លេសត្រូវបានទទួលការគំរាមកំហែងពីសំណាក់ចក្រភពអាល្លឺម៉ង់។
- ចក្រភពអាល្លឺម៉ង់នៅដើមសតវត្សទី២០ ជាប្រទេសមួយដែលមានប្រជាជនច្រើនជាងគេនៅទ្វីបអឺរ៉ុបប៉ែកខាងលិចជាប្រទេសប្រកបដោយភោគទ្រព្យធនធានជាច្រើន។ ពាណិជ្ជកម្ម និងឧស្សាហកម្មរបស់អាល្លឺម៉ង់តែងតែប្រកួតប្រជែងនឹងឧស្សាហកម្ម ពាណិជ្ជកម្មអង់គ្លេសជារឿយៗ ហើយទទួលបានជោគជ័យទៀតផង។ អាល្លឺម៉ង់ក៏ជាប្រទេសមួយដែលមានកងទ័ពច្រើន ប្រកបដោយយុទ្ធភណ្ឌយ៉ាងទំនើប ហើយអាល្លឺម៉ង់ក៏មានបំណងចង់ត្រួតត្រាបន្តទៅលើសមុទ្ទនានាថែមទៀតផងដែរ។

ដោយសារតែនៅអាល្លឺម៉ង់មានការលូតលាស់នៃផ្នែកឧស្សាហកម្ម និងពាណិជ្ជកម្មមានសន្ទុះលឿនណាស់ជាហេតុនាំឱ្យមហាអំណាចផ្សេងទៀតមានការព្រួយបារម្ភជានិច្ច។ នៅពេលនោះផងដែរពិភពលោកទាំងមូលគេបានប្រកួតប្រជែងគ្នាដណ្តើមទីផ្សារគ្នា ដណ្តើមសម្បទានអណ្តូងរ៉ែ និងផ្លូវរទេះភ្លើងជាដើម។ នៅពេលខ្លះទៀតរដ្ឋាភិបាលជួយការពារផលប្រយោជន៍របស់ជនជាតិគេដែលប្រកបដោយអាវុធយុទ្ធភណ្ឌយ៉ាងទំនើបៗក្នុងការ

ប្រកួតប្រជែងដណ្តើមគ្នានេះ ជាហេតុនាំឱ្យការប្រណាំងប្រជែងខាងវិស័យសេដ្ឋកិច្ចនេះ បានប្រែក្លាយទៅជាការប្រណាំងប្រជែងខាងនយោបាយទៀតផងដែលនាំឱ្យពិភពលោកឆ្ពោះទៅរកភ្លើងសង្គ្រាម។

## ៣-ការបង្កើតប្លុកយោធា

មកដល់ត្រឹមដើមសតវត្សទី២០ ទ្វីបអឺរូបបានលេចឡើងនូវសម្ពន្ធភាពយោធាជាច្រើន ក្នុងនោះយើងឃើញសម្ពន្ធភាពយោធាពីរធំគឺ សម្ពន្ធត្រីភាគី (មានអាល្លឺម៉ង់ អូទ្រីស-ហុងគ្រី និងអ៊ីតាលី) និងមួយទៀតគឺអនុសញ្ញាត្រីភាគី(បារាំង រុស្ស៊ី និងចក្រភពអង់គ្លេស)។

### ៣.១-ការបង្កើតសម្ពន្ធភាពរវាងអាល្លឺម៉ង់ អូទ្រីស-ហុងគ្រី និងអ៊ីតាលី

នាដើមសតវត្សទី២០ នៅទ្វីបអឺរ៉ុបបានកើតឡើងនូវសម្ពន្ធភាពយោធាសំខាន់ពីរ មានដូចជា ទីមួយគឺសម្ពន្ធភាពត្រីភាគី ដែលបានកើតឡើងបន្ទាប់ពីសង្គ្រាមបារាំង-ព្រុស។ លោកអធិការបេតីប៊ីស្មាក់ មានការព្រួយបារម្ភចំពោះស្ថានភាពនៅអាល្លឺម៉ង់ និងនៅអឺរ៉ុបប៉ែកកណ្តាល។ អ្នកដែលមានស្ថានភាពឆ្លើយតបទៅនឹងសេចក្តីតម្រូវការរបស់ប្រទេសអាល្លឺម៉ង់នោះគឺ ប្រទេសមហាអំណាចដែលនៅជិតខាងមានដូចជា អាណាចក្រអូទ្រីស-ហុងគ្រី និងអ៊ីតាលី ដែលមានទំនាស់យ៉ាងស្រួចស្រាល និងប្រទេសបារាំង។ ដូចនេះគេបានចាប់ផ្តើមបង្កើតសម្ពន្ធភាពត្រីភាគី អាល្លឺម៉ង់ អ៊ីតាលី អូទ្រីស-ហុងគ្រី។ នៅក្នុងការបង្កើតសម្ពន្ធភាពត្រីភាគី បារាំងបានមើលឃើញដល់ការគំរាមកំហែងយ៉ាងខ្លាំង។ បារាំងក៏បានសម្រេចចិត្តចងសម្ពន្ធភាពជាមួយរុស្ស៊ី ដើម្បីដោះស្រាយបញ្ហានេះសម្រាប់ទប់ទល់នឹងពួកសម្ពន្ធមិត្ត អាល្លឺម៉ង់ អ៊ីតាលី អូទ្រីស-ហុងគ្រី។ ប៉ុន្តែការបង្កើតសម្ពន្ធភាពនេះប្រព្រឹត្តទៅបានចាំបាច់បារាំងត្រូវលុបបំបាត់ទំនាស់ដែលកើតមានពីមុនរវាងបារាំង-រុស្ស៊ី នៅតំបន់ចុងបូព៌ា និងមជ្ឈិមបូព៌ា។ រុស្ស៊ី និងបារាំងបានចុះ ហត្ថលេខាសម្ពន្ធភាពស្តីពីកត្តិកាសញ្ញានយោបាយយោធា (១៨៩១-១៨៩៣)។ ដូច្នេះនៅចុងសតវត្សទី១៩ នៅទ្វីបអឺរ៉ុបបានបង្កើតប្លុកយោធាពីរគឺប្លុក«អាល្លឺម៉ង់-អ៊ីតាលី-អូទ្រីស-ហុងគ្រី» និង ប្លុក «បារាំង និងរុស្ស៊ី»។

### ៣.២- ការបង្កើតសម្ពន្ធភាពរវាងសាធារណរដ្ឋបារាំង ចក្រភពរុស្ស៊ី និងចក្រភពអង់គ្លេស

ចក្រភពអង់គ្លេសបានគិតថាចង់រក្សាស្ថានភាពកាត់ផ្តាច់ពីទ្វីបអឺរ៉ុប ហើយចង់លេងចន្លោះជំទាស់ដែលស្មៀតនេះអង់គ្លេសបានប្រើតាំងពីយូរណាស់មកហើយ។ ប៉ុន្តែបញ្ហាចំពោះមុខការថែរក្សាស្ថានភាពបែបនេះតទៅទៀតមិនបានយូរអង្វែងទេ។

នៅខែមេសា ឆ្នាំ១៩០៤ អង់គ្លេស និងបារាំងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅក្នុងឯកសារសម្ងាត់ស្តីពីការបែងចែកតំបន់អាណានិគម។ បារាំងបានសន្យាថា មិនពាក់ព័ន្ធនឹងនយោបាយអង់គ្លេសនៅក្នុងប្រទេសអេហ្ស៊ីបឡើយ។ រីឯអង់គ្លេសបានសុខចិត្តប្រគល់តួនាទីឱ្យបារាំងក្នុងការគ្រប់គ្រងម៉ារ៉ុក។ ចក្រភពអាល្លឺម៉ង់ក៏ចង់ចូលរួមក្នុងការបែងចែកដែរ ទើបព្រះចៅអធិរាជគីយូមទី២ បានធ្វើដំណើរកម្សាន្តតាមទូកក្តោងទៅកាន់កំពង់ផែម៉ារ៉ុកតង់ស៊ែរ ដែលជាកន្លែងវីលហ្គេមទី២ បានស្វាគមន៍ "ឯករាជ្យ" ដល់ស៊ុលតង់ម៉ារ៉ុកដែកធ្វើឱ្យមានការរំជើបរំជួលយ៉ាងខ្លាំង។ រាជរដ្ឋាភិបាលអង់គ្លេសថាដើម្បីបង្ខំឱ្យអាល្លឺម៉ង់កុំលូកដៃមិនមែនត្រូវការតែកម្លាំងទ័ពនាវាខ្លាំងក្លាតែមួយមុខប៉ុណ្ណោះទេ កម្លាំងជើងគោកក៏ត្រូវខ្លាំងក្លាដូចគ្នាដែរ។ នៅដើមឆ្នាំ១៩០៦ កិច្ចព្រមព្រៀងជាសម្ងាត់រវាងអង់គ្លេស និងបារាំងបានកំណត់ស្ថានភាពកិច្ចសហប្រតិបត្តិការវិស័យយោធាបារាំង-រុស្ស៊ីក៏បានពង្រឹងដែរ។

កិច្ចព្រមព្រៀងអង់គ្លេស-រុស្ស៊ី បានបន្ថែមនៅលើសម្ពន្ធភាព អង់គ្លេស-បារាំង និងរុស្ស៊ី-បារាំង ជាសម្ពន្ធភាពត្រីភាគី រុស្ស៊ី-បារាំង-អង់គ្លេស។ ដោយមានការគំរាមកំហែងពីសំណាក់អាល្លឺម៉ង់កាន់តែខ្លាំងឡើង នៅទីបំផុតអង់គ្លេសបានទទួលស្គាល់ថាគេត្រូវការសម្ពន្ធ រុស្ស៊ី-បារាំង-អង់គ្លេស។ ដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងត្រីភាគីបែបនេះ ជាដំបូងគេបានដោះស្រាយទំនាស់រវាង រុស្ស៊ី-អង់គ្លេស ជាបឋមនៅអាស៊ីកណ្ដាល និងនៅតំបន់មជ្ឈឹមបូព៌ា។ ថ្វីបើនៅចុងបូព៌ាបានដោះស្រាយរួចហើយក៏ដោយតែនៅទីបំផុតនឹងត្រូវទទួលការគំរាមកំហែងពីសំណាក់ជប៉ុនផងដែរ។ ចំណែកឯនៅមជ្ឈឹមបូព៌ាត្រូវដោះស្រាយទំនាស់ជាលក្ខណៈ ទ្វេភាគីដោយឈរលើគោលការណ៍យោគយល់គ្នា។ ផ្លូវដែកបែរឡាំង-បាកដាត-គុយវ៉ែត ត្រូវបានកសាងរួចអាល្លឺម៉ង់បានបន្តការដាក់មូលនិធិមកក្នុងតំបន់បូព៌ាទៀត។

នៅក្នុងទីក្រុងបានបន្តពិភាក្សាគ្នាថា «បើឃើញមានវត្តមានរុស្ស៊ី និងកុងស្តង់ទីណូប ប្រសើរជាងឃើញកាំភ្លើងធំអាល្លឺម៉ង់នៅក្នុងតំបន់ឈូងសមុទ្រពែរ្ស» ហេតុដូចនេះគេបានឱ្យតម្លៃកិច្ចព្រមព្រៀងរុស្ស៊ីក្នុងកម្រិតខ្ពស់ណាស់ នៅចំពោះមុខការគំរាមកំហែងអាល្លឺម៉ង់។ លទ្ធផលនៃកិច្ចព្រមព្រៀងថ្ងៃទី៣១ ខែសីហា ឆ្នាំ ១៩០៧ ត្រូវបានចុះហត្ថលេខាលើកតិកាសញ្ញា អង់គ្លេស-រុស្ស៊ី ស្តីពីតំបន់ក្រោមឥទ្ធិពលនៅប្រទេសអ៊ីរ៉ង់ ប្រទេសអាហ្វហ្គានីស្ថាន និងតំបន់ទីបេ។ កិច្ចព្រមព្រៀងអង់គ្លេស-រុស្ស៊ី ឆ្នាំ១៩០៧ បានបញ្ចប់គម្រោងបង្កើតសម្ពន្ធភាពត្រីភាគីដែលក្នុងនោះមានអង់គ្លេស-បារាំង-រុស្ស៊ី។

- សម្ពន្ធភាពត្រីភាគីមានអ៊ីតាលី អាល្លឺម៉ង់ និងអូទ្រីស-ហុងគ្រី ហើយក្រោយមកមានតួគី និងប៊ុលការី។
- អនុសញ្ញាត្រីភាគីមានបារាំង-រុស្ស៊ី-អង់គ្លេស ក្រោយមកមានជប៉ុន ប៉ទុយកាល់ សហរដ្ឋអាម៉េរិក និងប្រេស៊ីល។

សង្គ្រាមត្រូវតែផ្ទុះឡើងដោយជៀសមិនរួចនៅពេលដែលមានឃាតកម្មនៅទីក្រុងសារ៉ាសឺវ៉ូ នៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩១៤ ដែលបណ្ដាលឱ្យរជ្ជទាយាទនៃប្រទេសអូទ្រីស-ហុងគ្រី សុគត។ រុស្ស៊ីមិនសប្បាយចិត្តនៅពេលដែលឃើញពួកអូទ្រីស-ហុងគ្រី ចូលទៅកាន់តំបន់បាល់កង់។ ដូចនេះរុស្ស៊ីត្រូវគាំទ្រពួកស៊ែប៊ីឱ្យរើបម្រាស់ពីនឹមអូទ្រីស-ហុងគ្រី។

- ថ្ងៃទី២៨ ខែកក្កដា អូទ្រីសបានប្រកាសសង្គ្រាមជាមួយស៊ែបប៊ី។
- ថ្ងៃទី៣០ ខែកក្កដា រុស្ស៊ីបានចាប់ផ្ដើមកេណ្ឌទ័ព។
- ថ្ងៃទី៣១ ខែកក្កដា អាល្លឺម៉ង់បានព្រមានរុស្ស៊ីកុំឱ្យកេណ្ឌទ័ព។
- ថ្ងៃទី១ ខែសីហា អាល្លឺម៉ង់ និងបារាំងបានចាប់ផ្ដើមកេណ្ឌទ័ព ហើយអាល្លឺម៉ង់បានចាប់ផ្ដើមប្រកាសសង្គ្រាមប្រឆាំងនឹងរុស្ស៊ី។
- ថ្ងៃទី៣ ខែសីហា អាល្លឺម៉ង់ប្រកាសសង្គ្រាមជាមួយបារាំង។
- ថ្ងៃទី៤ ខែសីហា អាល្លឺម៉ង់បានរំលោភនៅលើអព្យាក្រិតបែលហ្ស៊ិក ដែលនាំឱ្យអង់គ្លេសមិនអាចនៅស្ងៀមក៏ប្រកាសសង្គ្រាមជាមួយអាល្លឺម៉ង់។

ដូចនេះស្ថានភាពកម្លាំងនៅទ្វីបអឺរ៉ុបត្រូវបានកំណត់រួចស្រេចហើយបន្ទាប់ពីនោះពិភពលោកកំពុងតែធ្វើដំណើរទៅកាន់មហន្តរាយនៃសង្គ្រាមលោក។

**សំណួររំលឹក**

១-តើប្រទេសណាខ្លះជាមហាអំណាចកំពូលលើពិភពលោកចុងសតវត្សទី១៩?
តើប្រទេសណាខ្លះជាមហាអំណាចចាស់ ហើយប្រទេសណាខ្លះជាមហាអំណាចថ្មី?
២-តើមូលហេតុអ្វីខ្លះ ដែលនាំឱ្យពិភពលោកមានភាពតានតឹងខ្លាំងនៅដើមសតវត្សទី២០?
៣-តើមូលហេតុអ្វីបានជាកើតមានសង្គ្រាមជប៉ុន-រុស្ស៊ីនៅដើមសតវត្សទី២០?
ចូរនិយាយពីលទ្ធផលនៃសង្គ្រាមនេះ។
៤-តើសង្គ្រាមអាមេរិកជាមួយអេស្ប៉ាញកើតឡើងដោយសារមូលហេតុអ្វី? តើសង្គ្រាមនេះផ្ដល់លទ្ធផលដូម្ដេច?
៥-ចូរពន្យល់ពីមូលហេតុនៃការបង្កើតសម្ពន្ធមិត្តធំទាំងពីរនៅអឺរ៉ុប នាចុងសតវត្សទី១៩ និងដើមសតវត្សទី២០។
៦-តើមកដល់ដើមសតវត្សទី២០ តើអង់គ្លេសជាមហាអំណាចផ្នែកអ្វីខ្លះ?
៧-តើអង់គ្លេស ដាក់អាណានិគមលើទឹកដីណាខ្លះ?
៨-ចូរនិយាយពីលក្ខណៈប្រជាធិបតេយ្យនៅចក្រភពអង់គ្លេស មុនសង្គ្រាមលោកលើកទី១។

# មេរៀនទី៤ ពិភពលោកជំណាក់កាលសង្គ្រាមលោកលើកទី១(១៩១៤-១៩១៨)

## ១-ព្រឹត្តិការណ៍សំខាន់ៗនាំទៅរកសង្គ្រាមលោកលើកទី១

នៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០ ប្រទេសមហាអំណាចធំៗ ដែលត្រួតត្រាពិភពលោកភាគច្រើនស្ថិតនៅក្នុងតំបន់អឺរ៉ុប។ ក្រៅពីនេះ សុទ្ធសឹងជាមហាអំណាចបន្ទាប់បន្សំ។

សហរដ្ឋអាម៉េរិក គឺជាមហាអំណាចមួយ ដែលទើបនឹងងើបមុខថ្មី ក៏ប៉ុន្តែជាមហាអំណាចខាងផ្នែកសេដ្ឋកិច្ច និងឧស្សាហកម្ម ហើយមិនទាន់មានកម្លាំងទ័ពខ្លាំងក្លាជាមហាអំណាចពិភពលោកនៅឡើយទេ។ ម្យ៉ាងទៀតសហរដ្ឋអាម៉េរិកនៅពេលនោះ ប្រកាន់យកនូវនយោបាយឯកានិយម និងគោលការណ៍មិនធ្វើអន្តរាគមន៍នៅក្រៅប្រទេស។ សហរដ្ឋអាម៉េរិក គិតថាខ្លួនមានសុវត្ថិភាពដោយសារមានមហា សមុទ្ទធំៗពីរនៅការពារទាំងសងខាងគឺ មហាសមុទ្ទប៉ាស៊ីហ្វិកនៅខាងលិច និងមហាសមុទ្ទអាត្លង់ទិកនៅខាងកើត ដូច្នេះហើយបានជាមិនសូវជាវវីរវល់នឹងកិច្ចការនៅក្រៅទ្វីបអាម៉េរិកប៉ុន្មាននោះទេ។

នៅអាស៊ីវិញ ជប៉ុនក៏ជាមហាអំណាចដែលទើបនឹងងើបមុខថ្មីមួយដែរ ប៉ុន្តែផ្ទុយពីសហរដ្ឋអាម៉េរិក ជប៉ុនបានបោះបង់ចោលនយោបាយឯកោនិយមរបស់ខ្លួន ហើយងាកមកចាប់យកនយោបាយអាណានិគមនិយមដូចជាបណ្តាប្រទេសមហាអំណាចនៅអឺរ៉ុបដែរ។ ក៏ប៉ុន្តែបើទោះជាយ៉ាងនេះក៏ដោយ ជប៉ុននៅពេលនោះ គ្រាន់តែជាមហាអំណាចក្នុងតំបន់អាស៊ីប៉ុណ្ណោះ ដោយនៅមិនទាន់មានកម្លាំងទ័ពខ្លាំងក្លា ជាមហាអំណាចពិភពលោកដូចជាបណ្តាប្រទេសនៅអឺរ៉ុបនោះទេ។ ដូចបានបញ្ជាក់នៅក្នុងមេរៀនមុនរួចមកហើយ ជប៉ុនក្លាយជាប្រទេសដ៏មានឥទ្ធិពលបន្ទាប់ពីទទួលបានជោគជ័យក្នុងសង្គ្រាមជាមួយ រុស្ស៊ី ឆ្នាំ១៩០៤-១៩០៥ មក តែក្នុងក្រសែភ្នែកមហាអំណាចអឺរ៉ុប ជប៉ុនគ្រាន់តែជាប្រទេសមហាអំណាចមួយនៅទ្វីបអាស៊ីតែប៉ុណ្ណោះ។

នៅអឺរ៉ុប គេឃើញមានមហាអំណាចធំៗចំនួន៥ ដែលប្រកួតប្រជែងគ្នា រហូតដល់ឈានទៅផ្ទុះជាសង្គ្រាមលោកលើកទី១គឺរួមមាន អង់គ្លេស បារាំង អាល្លឺម៉ង់ រុស្ស៊ី និងអូទ្រីស-ហុងគ្រី។ នៅក្នុងចំណោមប្រទេសទាំងនេះ មហាអំណាចធំជាងគេបំផុតគឺចក្រភពអង់គ្លេស ដែលនៅក្នុងចន្លោះសតវត្សទី១៩ ដល់ដើមសតវត្សទី២០ គឺជាមហាអំណាចពិភពលោកលំដាប់ទីមួយ ពោលគឺដូចទៅនឹងសហរដ្ឋអាម៉េរិកដែលជាមហាអំណាចពិភពលោក នៅក្នុងសតវត្សទី២០ និងដើមសតវត្សទី២១នេះដែរ។ ក៏ប៉ុន្តែនៅចុងសតវត្សទី១៩ មហាអំណាចថ្មីមួយ បានចាប់លេចមុខមកប្រជែងជាមួយនឹងចក្រភពអង់គ្លេស គឺអាល្លឺ-ម៉ង់។

ការប្រកួតប្រជែងគ្នា រវាងប្រទេសមហាអំណាចនៅអឺរ៉ុប ដែលបានកើតមានឡើងកាន់តែខ្លាំង ពីមួយថ្ងៃទៅមួយថ្ងៃ ក៏បានធ្វើឱ្យប្រទេសនីមួយៗខិតខំពង្រឹងកម្លាំងទ័ពរៀងៗខ្លួន ហើយការប្រណាំងប្រជែងផ្នែកសព្វាវុធបានកើតមានឡើងយ៉ាងពេញទំហឹង ជាពិសេស គឺការប្រណាំងប្រជែងសព្វាវុធខាងទ័ពជើងទឹក រវាងអាល្លឺម៉ង់ និងអង់គ្លេស។

ព្រមពេលជាមួយគ្នា នឹងការប្រណាំងប្រជែងខាងសព្វាវុធ មហាអំណាចនៅអឺរ៉ុប ក៏បានស្វះស្វែងចងសម្ពន្ធមិត្តនឹងគ្នាយ៉ាងប្រទាក់ក្រឡាផងដែរ។ សម្ពន្ធភាពទ្វេភាគី រវាងអាល្លឺម៉ង់ និងអូទ្រីស-ហុងគ្រី ត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៧៩ ហើយ៣ឆ្នាំក្រោយមក សម្ពន្ធភាពនេះបានក្លាយជាសម្ពន្ធភាពត្រីភាគី ក្រោយពីមានការចូលរួមពីសំណាក់អ៊ីតាលី។ ដើម្បីទប់ទល់នឹងអាល្លឺម៉ង់ និងសម្ពន្ធមិត្ត បារាំងក៏បានទៅបង្កើតសម្ពន្ធភាពជាមួយនឹងប្រទេសផ្សេងទៀតផងដែរ គឺសម្ពន្ធភាពបារាំង-រុស្ស៊ី នៅឆ្នាំ១៨៩៤ និងសម្ពន្ធភាព បារាំង-អង់គ្លេស នៅឆ្នាំ១៩០៤។ នៅឆ្នាំ១៩០៧ ក្រោយពីអង់គ្លេស និងរុស្ស៊ី បានចុះសន្ធិសញ្ញាបង្កើតសម្ពន្ធភាពនឹងគ្នា សម្ពន្ធភាពត្រីភាគី បារាំង-អង់គ្លេស-រុស្ស៊ី ក៏បានចាប់កំណើតឡើង។

## ១.១-សង្គ្រាមបារាំង-ព្រុស ១៨៧០

នៅមុនឆ្នាំ១៨៧០ អាល្លឺម៉ង់មិនទាន់ជាប្រទេសរួបរួមគ្នាមួយនៅឡើយទេ ដោយត្រូវបែងចែកជារដ្ឋដែលមានរចនាសម្ពន្ធដឹកនាំដាច់ៗពីគ្នា ដោយក្នុងចំណោមនោះ នគរព្រុស្ស៊ី (Prusse/ Prussia) គឺជានគរដែលមានទឹកដី និងកម្លាំងទ័ពខ្លាំងជាងគេ។ អូតូ វ៉ុន ប៊ីស្មាក់ (Otto von Bismarck) ដែលត្រូវបានព្រះមហាក្សត្រ Wilhelm ទី១ តែងតាំងឱ្យធ្វើជាអធិការបតី (នាយករដ្ឋមន្ត្រី) ព្រុស្ស៊ី នៅឆ្នាំ១៨៦២ គឺជាអ្នកនយោបាយអភិរក្សនិយម ដែលមានក្តីបំណងចង់ឃើញអាល្លឺម៉ង់រួបរួមគ្នា បង្កើតទៅជាមហាអំណាចដ៏ធំមួយ។ ដើម្បីសម្រេចតាមក្តីបំណងនេះប៊ីស្មាក់បានរកឃើញយុទ្ធសាស្ត្រមួយ គឺបង្កសង្គ្រាមជាមួយបារាំង ដែលជាគូសត្រូវរួមរបស់គ្រប់ដែនដីទាំងអស់របស់អាល្លឺម៉ង់។ ភាពជាសត្រូវដែលបានបន្សល់ទុកតាំងពីសម័យអធិរាជណាប៉ូឡេអុងទី១ (ណាប៉ូឡេអុង បូណាប៉ាត)។ ប៊ីស្មាក់ក៏បានគិតឃើញផងដែរថា ដើម្បីអាចដុតបញ្ឆេះចលនាជាតិនិយមអាល្លឺម៉ង់ឱ្យរួបរួមគ្នាច្បាំងនឹងបារាំងបាន ចាំបាច់ត្រូវតែឱ្យប្រជាជនអាល្លឺម៉ង់ទាំងអស់មើលឃើញថា បារាំង គឺជាអ្នកឈ្លានពានលើ អាល្លឺម៉ង់។

ប៊ីស្មាក់ក៏ចាប់ផ្តើមបង្ករឿងជាច្រើនជាមួយបារាំង រហូតធ្វើឱ្យអធិរាជណាប៉ូឡេអុងទី៣ (ល្វី ណាប៉ូឡេអុង) ប្រកាសសង្គ្រាមលើនគរព្រុស្ស៊ី នៅខែកក្កដា ឆ្នាំ១៨៧០ ហើយប៊ីស្មាក់ក៏បានប្រមែប្រមូលរដ្ឋទាំងអស់របស់អាល្លឺម៉ង់ឱ្យចងជាសម្ពន្ធភាព ដើម្បីទប់ទល់នឹងសកម្មភាពដែលប៊ីស្មាក់ហៅថាជា «ការឈ្លានពានរបស់បារាំង»។

កងទ័ពអាល្លឺម៉ង់បានយកឈ្នះបារាំងនៅឆ្នាំ១៨៧១ ហើយក្រោយពីទទួលបានជ័យជម្នះនេះអាល្លឺម៉ង់បានរួបរួមគ្នាបង្កើតជាចក្រភពមួយឡើង ក្រោមការដឹកនាំរបស់អធិរាជ Wilhelmទី១ និងដោយមាន អូតូ វ៉ុន ប៊ីស្មាក់ ជាអធិការបតី ពោលគឺជាប្រមុខរដ្ឋាភិបាល។

នៅពេលនោះ ចក្រភពអាល្លឺម៉ង់ គឺជាមហាអំណាចដ៏ធំមួយ ខាងផ្នែកសេដ្ឋកិច្ច និងឧស្សាហកម្ម ក៏ប៉ុន្តែអាល្លឺម៉ង់មានមហិច្ឆតាចង់បានអ្វីៗលើសពីនេះទៀត ដើម្បីអាចក្លាយជាមហាអំណាចស្មើមុខជាមួយនឹងមហាអំណាចផ្សេងទៀត ហើយអ្វីដែលមហាអំណាចផ្សេងមាន តែអាល្លឺម៉ង់មិនទាន់មាន គឺដែនដីអាណានិគម។

ចក្រភពអាល្លឺម៉ង់មានមហិច្ឆតាចង់ក្លាយជាមហាអំណាចអាណានិគម ដោយយល់ឃើញថា ការវាតទីពង្រីកដែនដីអាណានិគមអាចនឹងជួយឱ្យអាល្លឺម៉ង់ពង្រីកទីផ្សារ និងគ្រប់គ្រងធនធានធម្មជាតិបានកាន់តែ ច្រើនផង ព្រមទាំងធ្វើឱ្យអាល្លឺម៉ង់អាចក្លាយជាមហាអំណាចស្មើមុខនឹងមហាអំណាចអឺរ៉ុបផ្សេងទៀតផងដែរ។ អាល្លឺម៉ង់ក៏បានចាប់ផ្តើមដាក់ចេញនូវនយោបាយវាតទីពង្រីកដែនដីអាណានិគម ដោយផ្តោតជាពិសេសទៅលើតំបន់អាហ្វ្រិក និងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ការពង្រីកដែនដីអាណានិគម ដែលធ្វើឱ្យអាល្លឺម៉ង់ត្រូវមានវិវាទជាមួយនឹងមហាអំណាចអាណានិគមចាស់ផ្សេងៗមាន បារាំង និងអង់គ្លេស ជាដើម។

ផ្កាភ្លើងនៃសង្គ្រាមលោកលើកទី១បានចាប់ផ្តើមលេចឡើង តាំងពីឆ្នាំ១៨៧១ គឺចេញពីសង្គ្រាម រវាងអាល្លឺម៉ង់ និងបារាំង។ អាល្លឺម៉ង់ដែលឈ្នះសង្គ្រាមបានបង្រួបបង្រួមប្រទេសបង្កើតជាចក្រភពថ្មីមួយ ដែលមានមហិច្ឆតាចង់ក្លាយជាមហាអំណាចប្រជែងជាមួយនឹងមហាអំណាចផ្សេងទៀតនៅអឺរ៉ុប។ បារាំងវិញ ដែលចាញ់សង្គ្រាម ត្រូវបានអាល្លឺម៉ង់កាត់យកទឹកដីនៃតំបន់ Alsace-Laurraine យកទៅកាន់កាប់។ ប្រជាជនបារាំង ដែលទទួលរងនូវភាពអាម៉ាស់នឹងបរាជ័យផ្នែកយោធា និងម្យ៉ាងទៀតខឹងនឹងការបាត់បង់ទឹកដី ក៏បានចិញ្ចឹមចិត្តរង់ចាំតែឱកាស ដើម្បីសងសឹកនឹងអាល្លឺម៉ង់វិញ។ គំនុំគំគួន ការមិនទុកចិត្តគ្នា និងការប្រណាំងប្រជែងគ្នាដណ្តើមដែនដីអាណានិគម បានជំរុញឱ្យបណ្តាប្រទេសនៅអឺរ៉ុបនាំគ្នាខិតខំពង្រឹងកម្លាំងទ័ពរៀងៗ

ខ្លួនផង និងព្យាយាមចងសម្ពន្ធមិត្តយ៉ាងប្រទាក់ក្រឡាគ្នាផង ដើម្បីជាបង្អែកទុកបង្កាក្នុងករណីមានសង្គ្រាមផ្ទុះឡើង។ អាល្លឺម៉ង់បានបង្កើតជាសម្ពន្ធមិត្តជាមួយនឹងចក្រភព អូទ្រីស-ហុងគ្រី និងអ៊ីតាលី។ ចំណែកបារាំងបានទៅបង្កើតសម្ពន្ធភាពត្រីភាគីជាមួយចក្រភពរុស្ស៊ី និងចក្រភពអង់គ្លេស។

### ១.២-វិបត្តិនៅបូស្នី ឆ្នាំ១៩០៨-១៩០៩

នៅក្នុងពេលជាមួយគ្នានោះ បញ្ហានៅតំបន់បាល់កង់បានកើតឡើងកាន់តែខ្លាំង ក្រោយពីចក្រភពអូតូម៉ង់បានធ្លាក់ចុះដុនដាប ហើយបណ្តារដ្ឋដែលធ្លាប់ជាផ្នែកមួយនៃចក្រភពអូតូម៉ង់បាននាំគ្នា ប្រកាសឯករាជ្យជាបន្តបន្ទាប់។ ស្ថិតក្នុងស្ថានភាពបែបនេះ បណ្តាប្រទេសនៅក្នុង និងនៅក្បែរតំបន់បាល់កង់ បានប្រណាំងប្រជែងគ្នាដណ្តើមត្រួតត្រាប្រទេស ដែលជាអតីតដែនដីរបស់ចក្រភពអូតូម៉ង់។

នៅឆ្នាំ១៩០៨ ចក្រភពអូទ្រីស-ហុងគ្រី បានប្រកាសកាត់យកដែនដីបូស្នី ដែលជាអាណាខេត្តមួយរបស់ចក្រភពអូតូម៉ង់ មកធ្វើជាដែនដីរបស់ខ្លួន។ ទង្វើនេះបានបង្កឱ្យមានការតវ៉ាយ៉ាងខ្លាំងពីសំណាក់ស៊ែរប៊ីដែលមានព្រំដែនជាប់នឹងបូស្នី មានភាសា និងអម្បូរប្រជាជនដូចបូស្នី ហើយធ្លាប់ជាប្រទេសមួយក្នុង ចក្រភពអូតូម៉ង់ជាមួយ បូស្នី។ ចំណែករុស្ស៊ីវិញ ដែលជាសម្ពន្ធមិត្តរបស់ស៊ែរប៊ី ក៏បានចេញមុខតវ៉ានឹងការកាត់យកទឹកដីបូស្នី ដោយអូទ្រីសហុងគ្រីនេះដែរ។

វិបត្តិនៅបូស្នី បានធ្វើឱ្យជម្លោះ រវាងអូទ្រីសហុងគ្រី និងរុស្ស៊ី ឈានដល់ដំណាក់កាលមួយ ដែលមិនអាចផ្សះផ្សាគ្នាបាន ហើយជម្លោះនេះរាលដាលកាន់តែខ្លាំងឡើងថែមទៀត នៅពេលដែលសង្គ្រាម នៅតំបន់បាល់កង់ បានផ្ទុះឡើង នៅឆ្នាំ១៩១២ និងឆ្នាំ១៩១៣។

### ១.៣-សង្គ្រាមនៅបាល់កង់ ឆ្នាំ១៩១២-១៩១៣

នៅឆ្នាំ១៩១២ ពីរឆ្នាំមុនសង្គ្រាមលោកលើកទី១ ប្រទេសចំនួន៤ ដែលសុទ្ធតែធ្លាប់ជាអតីតដែនដីក្នុងចក្រភពអូតូម៉ង់ដូចគ្នា គឺ ស៊ែរប៊ី ក្រិក ម៉ុងតេណេហ្គ្រោ និងប៊ុលហ្គារី បានចងសម្ពន្ធភាពយោធានឹងគ្នា ដែលគេឱ្យឈ្មោះថា "«បក្សសម្ពន្ធបាល់កង់» ដើម្បីប្រយុទ្ធតទល់នឹងចក្រភពអូតូម៉ង់។ ក្នុងរយៈពេលតែប៉ុន្មានខែ ក្រុមបក្សសម្ពន្ធបាល់កង់ក៏បានយកជ័យជម្នះ ដោយបានដណ្តើមយកដែនដីជាច្រើនរបស់ចក្រភពអូតូម៉ង់មកកាន់កាប់។ ក៏ប៉ុន្តែមិនយូរប៉ុន្មានសង្គ្រាមមួយទៀតក៏បានផ្ទុះឡើង ដោយម្តងនេះ ជាសង្គ្រាមរវាងប្រទេសក្នុងបក្សសម្ពន្ធបាល់កង់គ្នាឯង គឺរវាងម្ខាង ប៊ុលហ្គារី និងម្ខាងទៀត ស៊ែរប៊ី និងក្រិក។ សង្គ្រាមនេះបានផ្ទុះឡើងដោយមកពីជម្លោះ ក្នុងការបែងចែកដែនដី ដែលពួកគេដណ្តើមបានពីចក្រភពអូតូម៉ង់។ ក្រោយពីសង្គ្រាមនៅបាល់កង់បានបញ្ចប់ទៅ នៅខែសីហា ឆ្នាំ១៩១៣ ស៊ែរប៊ីបានក្លាយជាប្រទេសដែលមានកម្លាំងយោធាខ្លាំងជាងគេបំផុត នៅក្នុងតំបន់បាល់កង់ ហើយតុល្យភាពអំណាច នៅបាល់កង់ ក៏បានផ្អៀងទៅរករុស្ស៊ី ដែលជាហេតុធ្វើឱ្យអូទ្រីសហុងគ្រីមិនសប្បាយចិត្ត ហើយមានគំនិតចង់ចាត់វិធានការគ្រប់យ៉ាង ដើម្បីទប់ស្កាត់ស៊ែរប៊ី កុំឱ្យបង្កើនអំណាចនៅបាល់កង់តទៅទៀត[465]។

សរុបមកនៅចុងសតវត្សទី១៩ និងឈានចូលសតវត្សទី២០ ពិភពលោកបានធ្លាក់ចូលទៅក្នុងស្ថានភាពតានតឹង ដែលពេលខ្លះស្ទើរតែមិនអាចដោះស្រាយដោយសន្តិវិធីបាន។ ទីបំផុតនៅឆ្នាំ១៩១៤ សង្គ្រាមបានផ្ទុះឡើងនៅទ្វីបអឺរ៉ុបដោយចៀសមិនរួចរវាងមហាអំណាចនានា ហើយសង្គ្រាមនេះជាសង្គ្រាម ដែលធំជាងគេនៅក្នុងប្រវត្តិសាស្ត្រសកលលោកត្រឹមទសវត្សរ៍ទី២នៃសតវត្សទី២០។ តើមានបុព្វហេតុអ្វីខ្លះដែលនាំឱ្យសង្គ្រាម

465. សេងឌីណា (២០១៤) **ប្រវត្តិសាស្ត្រពិភពលោក** : វិទ្យុបារាំងអន្តរជាតិ RFI ថ្ងៃទី១៦ មីនា ២០១៤

លោកលើកទី១ផ្ទុះឡើង? តើសង្គ្រាមនេះមានដំណើរប្រព្រឹត្តទៅយ៉ាងដូចម្តេច? សង្គ្រាមលោកលើកទី១ ផ្តល់ផលវិបាក និងបម្រែបម្រួលដូចម្តេចខ្លះចំពោះពិភពលោក?

## ២-បុព្វហេតុនៃសង្គ្រាម

ប្រទេសថ្មីទាំងឡាយ ដែលមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច បានធ្វើការរើបម្រាសយ៉ាងខ្លាំងដើម្បីស្វែងរកទីផ្សារនៅលើពិភពលោក ដែលសុទ្ធសឹងតែទឹកដីអាណានិគមរបស់ប្រទេសមហាអំណាចឧស្សាហកម្មនៅអឺរ៉ុប មានអង់គ្លេស និងបារាំងជាដើម។ មហាអំណាចថ្មីមាន អាម៉េរិក អាល្លឺម៉ង់ និងជប៉ុន ដែលកំពុងតែសម្លឹងមើលទីផ្សាររបស់អាណានិគមចាស់ៗ។ អាល្លឺម៉ង់ បានធ្វើឱ្យពួកអង់គ្លេសខាតចេញពីឧបទ្វីបបាល់កង់នៅមជ្ឈិមបូព៌ា ដែលសំបូរប្រេងកាត។ នៅបូព៌ាប្រទេសជប៉ុនបានបង្ហាញស្នាដៃលើកដំបូង ដែលនាំឱ្យមានការភ្ញាក់ផ្អើលគឺ សញ្ជ័យលើកងទ័ពជើងទឹករបស់រុស្ស៊ី នៅក្នុងឆ្នាំ១៩០៤-១៩០៥ ធ្វើឱ្យរុស្ស៊ី បាត់បង់ទីផ្សារទៅលើប្រទេសជប៉ុន។

មុនឆ្នាំ១៩១៤ ប្រទេសមហាអំណាចទាំងប្រាំមាន អង់គ្លេស បារាំង អាល្លឺម៉ង់ អូទ្រីស-ហុងគ្រី និងរុស្ស៊ី បានគ្រប់គ្រងទ្វីបអឺរ៉ុប។ នៅឆ្នាំ១៩១៤ សង្គ្រាមលោកលើកទី១ បានផ្ទុះឡើងនៅអឺរ៉ុប។ ទោះជាសម្ពន្ធមិត្តអឺរ៉ុប ជាបុព្វហេតុនៃសង្គ្រាមលោកលើកទី១ ក៏ដោយក៏មានកត្តារួមផ្សំជាច្រើនទៀតផងដែរដូចជាបញ្ហាជាតិនិយម យោធានិយម...។ បញ្ហាទាំងនេះបានផ្តុំបំប៉ោងនូវភាពតានតឹងឡើង។

### ២.១-បុព្វហេតុដោយប្រយោល

#### ក-ចក្រពត្តិនិយម ឬអាណានិគមនិយម

ចក្រពត្តិនិយមក៏ជាបុព្វហេតុមួយ ដែលបង្កឡើងនូវភាពតានតឹងក្នុងចំណោមប្រទេសមហាអំណាចដែលឈានទៅដល់សង្គ្រាម។ ចក្រពត្តិនិយម គឺជាបំណងប្រាថ្នារបស់ប្រជាជាតិនានាក្នុងការធ្វើអាណានិគមទៅលើគេ ហើយបង្កើតជាចក្រភព។ ប្រទេសនៅអឺរ៉ុបបានគ្រប់គ្រងអាណានិគមនៅលើពិភពលោកចាប់តាំងពីសតវត្សទី១៥ មកម្ល៉េះ។ ចាប់តាំងពីឆ្នាំ១៨៧០មក មានការប្រកួតប្រជែងគ្នាដណ្តើមដែនដីអាណានិគមដែលពីមុនពួកគេមានការចាប់អារម្មណ៍នោះ។ បារាំង និងអង់គ្លេស ហើយអាល្លឺម៉ង់ និងបារាំង ស្ទើរតែមានសង្គ្រាមនឹងគ្នាទៅហើយនៅក្នុងការប៉ះទង្គិចគ្នានៅដែនដីអាហ្វ្រិកខាងជើង។ អ៊ីតាលីមានការមិនសប្បាយចិត្តចំពោះបារាំង ពីព្រោះបារាំងរារាំងការធ្វើអាណានិគមរបស់អ៊ីតាលី។ ចំណែកឯអង់គ្លេស និងរុស្ស៊ី បានប៉ះទង្គិចគ្នាទៅលើបញ្ហាថា តើអ្នកណានឹងធ្វើការគ្រប់គ្រងនៅ Persia (អ៊ីរ៉ង់) ប៉ុន្តែពួកគេទាំងពីរមានការបារម្ភថាអាល្លឺម៉ង់ នឹងគ្រប់គ្រងលើទឹកដីនៅមជ្ឈិមបូព៌ា។ នៅពេលប្រទេសអឺរ៉ុបមានដែនដីអាណានិគមរៀងៗខ្លួនពួកគេមានការតាំងចិត្តក្នុងការជួយការពារប្រទេសអាណានិគមរបស់គេ នៅពេលដែលមានសង្គ្រាមកើតឡើង។

- **ការទទួលបានដែនដីអាណានិគមគឺដើម្បី ៖**
  - សន្តិសុខជាតិបន្ថែម
  - លើកតម្កើងកិត្យានុភាពជាតិ
  - ទទួលបានធនធានកម្រៗជាច្រើនផ្សេងទៀត
  - មានទីផ្សារសម្រាប់លក់ផលិតផលនានា

*សង្គ្រាមអាម៉េរិក-អេស្ប៉ាញ*

មុនពេលសង្គ្រាមរវាងសហរដ្ឋអាម៉េរិក និងអេស្ប៉ាញបានផ្ទុះឡើងតាំងពីឆ្នាំ១៨៤៩ មកម្ល៉េះ សហរដ្ឋអាម៉េរិកបានធ្វើសំណើសុំទិញ កោះគុយបាពីអេស្ប៉ាញដោយបានឱ្យតម្លៃកោះនោះតម្លៃ ១០០លានដុល្លារសហ

រដ្ឋអាម៉េរិក។ តែអេស្ប៉ាញបានបដិសេធ ព្រោះ មិនធ្លាប់មានប្រពៃណីលក់ប្រទេសអាណានិគមឡើយ។ បន្ទាប់មកនៅឆ្នាំ១៨៩៥ លើកោះគុយបាបានផ្ទុះឡើងនូវការបះបោរចុងក្រោយបង្អស់ប្រឆាំងនឹងអំណាចគ្រប់គ្រងរបស់អេស្ប៉ាញ។ សហរដ្ឋអាម៉េរិកបានគិតថា ជាឱកាសល្អក្នុងការប្រើព្រឹត្តិការណ៍នេះធ្វើជាមធ្យោបាយលូកដៃបញ្ហាកោះគុយបាតាម រយៈការគាំទ្រចលនាបះបោរប្រឆាំងនឹងអេស្ប៉ាញ ទីបំផុតឈ្លានពានលើកោះគុយបាតែ ម្តង។ ដោយសារតែការផ្ទុះគ្រាប់បែកនៅលើនាវាច្បាំង មេន សហរដ្ឋអាម៉េរិកបានយកលេសនេះវាយលុកទៅលើអេស្ប៉ាញ នាខែមេសា ឆ្នាំ១៨៩៨។ សហរដ្ឋអាម៉េរិកបានទទួលជ័យជម្នះយ៉ាងឆាប់រហ័ស ដោយបានវាយកម្ទេចកងទ័ពនាវាអេស្ប៉ាញ។ នៅពេលនោះកោះគុយបាក៏ទទួលបានឯករាជ្យពីប្រទេសអេស្ប៉ាញ ប៉ុន្តែបានក្លាយជាប្រទេសពាក់កណ្តាលអាណានិគមរបស់សហរដ្ឋអាម៉េរិកទៅវិញ។

ដូច្នេះសង្គ្រាមរវាងសហរដ្ឋអាម៉េរិក និងអេស្ប៉ាញបានចាប់ផ្តើមដំណាក់កាលថ្មីនៃប្រវត្តិសាស្ត្រនៃទំនាក់ទំនងអន្តរជាតិ និងជាសង្គ្រាមទីមួយដើម្បីបែងចែកពិភពលោក ប៉ុន្តែវាមិនមែនជាលើកចុងក្រោយនោះទេ។ ជ័យជម្នះរបស់សហរដ្ឋអាម៉េរិក ទៅលើអេស្ប៉ាញបានផ្តល់លទ្ធភាពឱ្យសហរដ្ឋអាម៉េរិកបើកផ្លូវដើម្បីធ្វើការឈ្លានពានទៅលើភូមិភាគខាងត្បូងនៃអាម៉េរិកឡាទីន តំបន់បូព៌ា និងភូមិភាគអាស៊ីអាគ្នេយ៍ថែមទៀតផង។

## សង្គ្រាមរវាងចក្រភពអង់គ្លេស និងសាធារណរដ្ឋប៊ួរ

សង្គ្រាមមួយទៀតដែលទាក់ទងទៅនឹងការបែងចែកពិភពលោកគឺ ការពាក់ព័ន្ធរវាងអង់គ្លេសជាមួយនឹងសាធារណរដ្ឋប៊ួរទាំងពីរដែលស្ថិតនៅភូមិភាគខាងត្បូងនៃទ្វីបអាហ្វ្រិក។ សង្គ្រាមរវាងអង់គ្លេស និងប៊ួរ ចាប់ផ្តើមពីថ្ងៃទី១១ ខែតុលា ឆ្នាំ១៨៩៩ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩០២ គឺជាសង្គ្រាមដែលមានទ្រង់ទ្រាយធំ ជាធម្មតាគេស្គាល់ថាជាសង្គ្រាមប៊ួរ។ មូលហេតុដែលអង់គ្លេសធ្វើសង្គ្រាមនេះព្រោះអង់គ្លេសចង់បានផ្លូវឆ្ពោះទៅរកឧស្សាហកម្មរុករករ៉ែមាសនៅតំបន់នោះ ក៏ដូចជាចង់បញ្ចូលរដ្ឋនោះឱ្យក្លាយជារដ្ឋសហព័ន្ធនៃការគ្រប់គ្រងរបស់ខ្លួនផង។ ចក្រភពអង់គ្លេស បានបញ្ជូនកងទ័ពចំនួន ២៥០,០០០នាក់ ទៅប្រយុទ្ធនឹងកងទ័ពប៊ួរ (មានដើមកំណើតពី ហូឡង់)។ នៅក្នុងការប្រយុទ្ធគ្នានោះ គេបានប្រើអាវុធយុទ្ធភណ្ឌទំនើបៗដែលជាគំរូដល់កងទ័ពលើពិភពលោក និងជាលើកទីមួយដែលកងទ័ពអង់គ្លេសបានប្រើកាំភ្លើងយន្ត។

ដោយសារកម្លាំងរបស់ គូសត្រូវទាំងពីរហាក់ដូចជាមានសភាពមិនស្មើគ្នាឡើយ ជាចុងក្រោយកងទ័ពប៊ួរត្រូវទទួលបរាជ័យ។ សាធារណរដ្ឋប៊ួរទាំងពីរត្រូវបានភ្ជាប់ជាអាណានិគមរបស់អង់គ្លេស។ ការឃោគយល់គ្នារវាងមហាអំណាចមេត្រូប៉ូលអង់គ្លេស និងពួកស្បែកសប៊ួរដោយជាប់ពាក់ព័ន្ធផងដែរទៅនឹងជនជាតិស្បែកខ្មៅនៅទីនោះបានបង្កើតសហភាពអាហ្វ្រិកខាងត្បូង។

## សង្គ្រាមរុស្ស៊ី-ជប៉ុន

សង្គ្រាមរុស្ស៊ី-ជប៉ុនបានកើតឡើងនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩០៤ រហូតដល់ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩០៥ គឺជាសង្គ្រាមបែងចែកតំបន់អាណានិគមនៅក្នុងតំបន់ចុងបូព៌ាដោយរុស្ស៊ី មិនពេញចិត្តជាមួយជប៉ុនរឿងការចរចាបែងចែកផលប្រយោជន៍នៅតំបន់ម៉ាន់ជូរី និងកូរ៉េ។ ដំបូងរុស្ស៊ី បានស្នើសុំផ្លូវទឹកទៅជប៉ុននៅក្នុងតំបន់នៃមហាសមុទ្រ ប៉ាស៊ីហ្វិកដើម្បីប្រើក្នុងវិស័យកងទ័ពជើងទឹក និងផ្នែកពាណិជ្ជកម្មរបស់រុស្ស៊ី ប៉ុន្តែការស្នើសុំរបស់រុស្ស៊ីនេះមិនបានសម្រេចទេ រហូតដល់មានជម្លោះដែលនាំឱ្យជប៉ុនជ្រើសរើសការធ្វើសង្គ្រាមដើម្បីទទួលបានការគ្រប់គ្រងឧបទ្វីបកូរ៉េ និងម៉ាន់ជូរី បន្ទាប់ពីការចរចាដោយសន្តិវិធីត្រូវបានបញ្ចប់។ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩០៤ ជប៉ុនបានប្រកាស សង្គ្រាមជាមួយរុស្ស៊ី ដោយឱ្យដំណឹងទៅរុស្ស៊ីមុនការធ្វើសង្គ្រាមត្រឹមតែ៣ម៉ោងមុនប៉ុណ្ណោះ ហើយបានឡោមព័ទ្ធកងទ័ពជើងទឹករបស់រុស្ស៊ី និងតំបន់ភាគខាងកើតនៃប្រទេសរុស្ស៊ី។ ការធ្វើ

សង្គ្រាមលើកនេះធ្វើឱ្យព្រះរាជារបស់រុស្ស៊ីមានភាពភ្ញាក់ផ្អើល ដែលសឹងតែមិនជឿថាជប៉ុនអាចធ្វើសង្គ្រាមដោយមិនមានការប្រកាសមុនជាផ្លូវការសោះឡើយ នៅពេលនោះជប៉ុនក៏បានតបទៅរុស្ស៊ីវិញដោយអាងថាកាលពីរុស្ស៊ីធ្វើសង្គ្រាមជាមួយស៊ុយអែតនៅឆ្នាំ ១៨០៩ នៅពេលនោះរុស្ស៊ីក៏មិនបានប្រកាសសង្គ្រាមមុនដែរ ហើយនៅពេលនោះការធ្វើសង្គ្រាមរបស់រុស្ស៊ីក៏មិនបានខុសច្បាប់ឡើយហើយសង្គ្រាមក៏ចេះតែបន្តទៅមុខទៀតរហូតដល់មានការចូលរួមពីសំណាក់មហាអំណាចផ្សេងៗទៀតចូលមកជួយជប៉ុន។ នៅក្នុងសង្គ្រាមនេះអង់គ្លេស និង សហរដ្ឋអាម៉េរិកស្ថិតនៅក្នុងភាគីរបស់ជប៉ុន។ អង់គ្លេស និង សហរដ្ឋអាម៉េរិកបានខ្ចីដៃជប៉ុន ដើម្បីធ្វើឱ្យស្តេចរុស្ស៊ីចុះទន់ខ្សោយ។ នៅឆ្នាំ១៩០២អង់គ្លេសបានចុះហត្ថលេខាចងសម្ពន្ធភាពជាមួយនឹងជប៉ុន រីឯសហរដ្ឋអាម៉េរិកបានជួយជប៉ុនដើម្បីបានចំណេញក្នុងការចុះហត្ថលេខាសន្តិភាពជាមួយរុស្ស៊ីនៅ ឆ្នាំ១៩០៥។ ជាលទ្ធផលជប៉ុន បានពង្រឹងគោលជំហររបស់ខ្លួននៅក្នុងភូមិភាគខាងត្បូងនៃតំបន់ម៉ាន់ជូរី និងបានបង្កបរិយាកាសដ៏ល្អទៀតផង។

**ខ-យោធានិយម**

យោធានិយម គឺជាបុព្វហេតុដែលបង្កឡើងឱ្យមានភាពតានតឹង និងការភ័យខ្លាចក្នុងចំណោមប្រទេសមហាអំណាចនៅអឺរ៉ុប។ អង់គ្លេសនៅពេលនោះ គឺជាចក្រភពដ៏ខ្លាំងក្លាមួយនៅក្នុងពិភពលោក ហើយក៏មានកងនាវាដ៏ខ្លាំងក្លាផងដែរ។ លោក Kaiser William II នៃប្រទេសអាល្លឺម៉ង់មានការច្រណែន និងស្អប់ខ្ពើមអង់គ្លេស ដោយសារអង់គ្លេសមានឧត្តមភាពខាងកងនាវាចរជាងខ្លួន។ គាត់បានពង្រីកកងនាវាអាល្លឺម៉ង់ ហើយបានកសាងនាវាចម្បាំងជាច្រើនគ្រឿង។ ចំណែកឯអង់គ្លេសវិញ ក៏ពង្រឹងកងនាវារបស់ខ្លួនផងដែរ ដោយបានកសាងនាវាជាច្រើនគ្រឿងថែមទៀត។ ពួកគេចាប់ផ្តើមរត់ប្រណាំងគ្នាខាងនាវាចម្បាំងទំនើបៗ ដែលជំរុញឱ្យមានភាពតានតឹងឡើងរវាងប្រទេសទាំងពីរនេះ។ ជម្លោះទាំងឡាយ ដែលកើតមាននៅអឺរ៉ុបទាំងមូលស្ថិតនៅក្នុងស្ថានភាព "សន្តិភាពប្រដាប់អាវុធ"។ លើសពីនេះទៅទៀត នៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០ បណ្តាប្រទេសមហាអំណាចផ្សេងៗ ទៀតក៏ពង្រឹងយោធារបស់ខ្លួនផងដែរ ដោយមានការបង្កើនចំណាយយ៉ាងច្រើនទៅលើវិស័យនេះ។ ចំនួនកងទ័ពប្រទេសនីមួយៗបានកើនឡើងយ៉ាងសន្ធឹកសន្ធាប់។

**ការប្រកួតប្រជែងផ្នែកយោធា**



## គ-សម្ពន្ធមិត្តនៅទ្វីបអឺរ៉ុប




សម្ពន្ធមិត្តអឺរ៉ុប ជាផ្នែកដ៏សំខាន់ក្នុងការចាប់ផ្ដើមសង្គ្រាមលោកលើកទី១។ បន្ទាប់ពីមានភាពតានតឹងដោយសារបញ្ហាជាតិនិយម ចក្រពត្តិនិយម និងយោធានិយម ពួកមហាអំណាចមានការបារម្ភពីការវាយប្រហារគ្នាទៅវិញទៅមក។ ដើម្បីទប់ទល់បញ្ហានេះ គេនាំគ្នាបង្កើតសម្ពន្ធមិត្តឡើង។ អាល្លឺម៉ង់ បានបង្កើតសម្ពន្ធមិត្តជាសម្ងាត់ជាមួយអូទ្រីស-ហុងគ្រី នៅឆ្នាំ១៨៧៩។ បីឆ្នាំក្រោយមក ប្រទេសអ៊ីតាលីបានចូលរួមក្នុងសម្ពន្ធភាពនេះ ដើម្បីបង្កើតជាសម្ពន្ធភាពត្រីភាគីពីព្រោះខ្លួនមានការធុញថប់ជាមួយបារាំង ដែលបានរារាំងផែនការធ្វើអាណានិគមរបស់ខ្លួននៅលើទ្វីបអាហ្វ្រិកខាងជើង។

ចំណែកមហាអំណាចផ្សេងទៀត មានការព្រួយបារម្ភកាន់តែខ្លាំងឡើងពីកម្លាំងរបស់សម្ពន្ធភាព ត្រីភាគីនេះ។ ប្រទេសអូទ្រីស-ហុងគ្រី និងអ៊ីតាលី ដោយជឿជាក់ថាពួកគេត្រូវការអាល្លឺម៉ង់ ក៏រួបរួមគ្នាជាសម្ពន្ធឡើង។ បារាំង និងរុស្ស៊ី បានព្រមព្រៀងគ្នាថានឹងជួយគ្នា ប្រសិនបើមានការវាយប្រហារណា មួយ។ អង់គ្លេសមានការព្រួយបារម្ភ ព្រោះខ្លួនគ្មានសម្ពន្ធភាព ជាមួយមហាអំណាចណាមួយឡើយ ប៉ុន្តែមិនបានត្រៀមខ្លួនធ្វើជាសម្ពន្ធមិត្តជាមួយអាល្លឺម៉ង់ទេ បន្ទាប់ពីមានសង្គ្រាម Boer មក។ នៅឆ្នាំ១៩០៤ បារាំង និងអង់គ្លេស បានត្រៀមខ្លួនក្នុងសង្គ្រាម ក្នុងការបំភ្លេចចោលនូវជម្លោះពីមុនៗរបស់ពួកគេ ហើយចាប់ផ្ដើមកិច្ចព្រមព្រៀងមួយ។ នៅទីបំផុតក្នុងឆ្នាំ១៩០៧ បារាំងបានប្រមូលផ្ដុំប្រជាជាតិទាំងបី ដើម្បីបង្កើតជាអនុសញ្ញាត្រីភាគី។

ប្រព័ន្ធសម្ពន្ធមិត្តនេះ គឺជាបុព្វហេតុដ៏ចម្បង ដែលធ្វើឱ្យផ្ទុះឡើងនូវសង្គ្រាមលោកលើកទី១។ ប្រសិនបើអាល្លឺម៉ង់មិនរួបរួមជាមួយអូទ្រីស-ហុងគ្រីទេ សង្គ្រាមប្រហែលជាអាចចៀសវាងបាន។ ឧទាហរណ៍ប្រសិនបើមានវិវាទកើតឡើងរវាងតែ អាល្លឺម៉ង់នឹងបារាំង ឬអង់គ្លេស នោះអឺរ៉ុបទាំងមូលនឹងមិនហក់ចូលក្នុងសង្គ្រាមឡើយ។ សង្គ្រាមលោកលើកទី១ បានរាលដាលដោយសារប្រព័ន្ធសម្ពន្ធភាពទាំងនេះ។

## ឃ-បុព្វហេតុជាតិនិយម

ជាតិនិយមក៏ជាបុព្វហេតុមួយទៀត ដែលបង្កឡើងនូវសង្គ្រាមលោកនេះដែរ។ ទ្រឹស្ដីជាតិនិយមបានប្រមូលផ្ដុំនូវមនុស្សម្នាទាំងឡាយដែលមានភាសា ប្រវត្តិសាស្ត្រ និងវប្បធម៌ដូចគ្នា។ អ្នកជាតិនិយមជឿជាក់ថាផលប្រយោជន៍របស់ខ្លួនសំខាន់ជាងជាតិសាសន៍ដទៃ។ ពួកគេមានមោទនភាពយ៉ាងខ្លាំងក្លាចំពោះជាតិរបស់ខ្លួន ហើយចង់ក្លាយជាជាតិសាសន៍ដែលមានជាងគេ ប្រសើរជាងគេ។ អារម្មណ៍ដ៏ខ្លាំងក្លានេះហើយ ដែលធ្វើឱ្យប្រជាជាតិនានាធ្វើការឈ្លានពានប្រទេសដ៏ទៃទៀត ហើយមិនមានការអត់ឱនឡើយ ប្រសិនបើជាតិរបស់ខ្លួនត្រូវមាក់ងាយពីជាតិដទៃនោះ។ ស្មារតីជាតិនិយមបានបញ្ចេះភាពតានតឹង ហើយមានឥទ្ធិពលដល់ការផ្ទុះឡើងនៃសង្គ្រាមលោកលើកទី១។

ជនជាតិស្លាវភាគច្រើនរស់នៅក្នុងតំបន់បាល់កង់ ក្នុងបណ្ដារដ្ឋប្រជាជាតិជាច្រើនដូចជា បូស្នី និង ស៊ែប៊ីបានលេចចេញនូវគំនិតជាតិនិយមរបស់ខ្លួន។ គំនិតជាតិនិយមរបស់ស៊ែបជំរុញឱ្យមានគំនិតបង្កើតរដ្ឋស៊ែបដ៏ធំទូលាយមួយ (ស៊ែប៊ី និងបូស្នី)។ អូទ្រីស-ហុងគ្រីត្រូវគំរាមដោយគំនិតនៃការបង្កើតរដ្ឋស៊ែបដ៏ធំទូលាយមួយនៅភាគខាងត្បូងព្រំដែនរបស់គេ។ នៅឆ្នាំ១៩០៨ អូទ្រីស-ហុងគ្រីបានភ្ជាប់ទឹកដីបូស្នី ពេល នោះ ជនជាតិស្លាវ

ជាច្រើនបានសម្រេចចិត្ត បង្កើតអង្គការសម្ងាត់ មួយដោយមានគោលបំណងបណ្ដេញ អូទ្រីស-ហុងគ្រីចេញពីបូស្នី។ ប្រជាជនរុស្ស៊ីមួយចំនួនគឺជាជនជាតិស្លាវ ដែលមានគំនិតការពារជាតិសាសន៍របស់គេក្នុងតំបន់បាល់កង់ ប្រឆាំងចំពោះការប៉ុនប៉ងរបស់ចក្រភពអូទ្រីស-ហុងគ្រី ដែលរារាំងការរីករាលដាលនៃគំនិតជាតិនិយមស៊ែប។

## ២.២-មូលហេតុដោយផ្ទាល់

ព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩១៤ ព្រះអង្គម្ចាស់ហ្វ្រង់ឌីណង់ (Franz Ferdinand) រជ្ជទាយាទរបស់ចក្រភពអូទ្រីស-ហុងគ្រី បានធ្វើដំណើរតាមរថភ្លើងមកដល់ទីក្រុងសារ៉ាយេវ៉ូ រដ្ឋធានីរបស់បូស្នី។ បូស្នី ដែលអូទ្រីស-ហុងគ្រី បានកាត់ពីចក្រភពអូតូម៉ង់មកធ្វើជាខេត្តរបស់ខ្លួន កាលពីឆ្នាំ១៩០៨ ក្រោមក្រសែភ្នែកក្ដៅក្រហាយរបស់ស៊ែរប៊ី។



ក្រុមយុវជនជាតិនិយមស៊ែប ៧នាក់ ដែលមាន ការជួយជ្រោមជ្រែងពីក្រុមភេរវជនស៊ែរប៊ី បានរៀបគម្រោងការ លបធ្វើឃាតព្រះអង្គម្ចាស់ ហ្វ្រង់ឌីណង់ ដោយបានពង្រាយគ្នានៅតាមបណ្ដោយផ្លូវ ដែលក្បួនរថយន្តរបស់ព្រះអង្គត្រូវឆ្លងកាត់។ ព្រះអង្គម្ចាស់ហ្វ្រង់ឌីណង់ ថ្វីដ្បិតតែដឹងថា ដំណើរទៅកាន់ទីក្រុង សារ៉ាយេវ៉ូ ជាដំណើរប្រកបដោយគ្រោះថ្នាក់ ក៏ប៉ុន្តែនៅតែជម្នះជិះក្នុងរថយន្តបើកដំបូល ដើម្បីចង់បង្ហាញពីភាពស្និទ្ធស្នាលដល់ប្រជារាស្ត្រនៅទីនោះ។ នៅម៉ោងប្រមាណជា១០ព្រឹក នៅពេលក្បួនរថយន្តរបស់ព្រះអង្គម្ចាស់ហ្វ្រង់ឌីណង់បើកមកដល់ ឃាតកម្នាក់ក៏បានគប់គ្រាប់បែកសំដៅទៅលើរថយន្តរបស់ព្រះអង្គ។ ក៏ប៉ុន្តែ គ្រាប់បែកបានធ្លាក់ខុសគោលដៅ ដោយផ្ទុះត្រូវ រថយន្តដែលបើកពីក្រោយ។ អ្នកបើកបរក៏បានបើករត់ ហើយនាំព្រះអង្គម្ចាស់ហ្វ្រង់ឌីណង់ ទៅកាន់សាលា ក្រុងសារ៉ាយេវ៉ូ។ ចំណែកឃាតករវិញ បានព្យាយាមសម្លាប់ខ្លួនឯង ក៏ប៉ុន្តែ មិនបានសម្រេច ហើយក៏ត្រូវប៉ូលិសចាប់ខ្លួនបាន។ នៅសាលាក្រុង ព្រះអង្គម្ចាស់ហ្វ្រង់ឌីណង់បានចូលរួមក្នុងពិធីផ្លូវការ ដែលបានគ្រោងទុកពីមុនជាធម្មតា ក៏ប៉ុន្តែ ក្រោយចប់ពិធី ព្រះអង្គបានសម្រេចលុបចោលកម្មវិធីដែលគ្រោងទុកផ្សេងទៀត ដើម្បីយាងទៅសួរសុខទុក្ខអ្នករបួស ដោយគ្រាប់បែកកាលពីព្រឹក ហើយដែលកំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យសារ៉ាយេវ៉ូ។

នៅតាមផ្លូវពីសាលាក្រុងទៅមន្ទីរពេទ្យ ព្រះអង្គម្ចាស់ហ្វ្រង់ឌីណង់ និងមហេសី គឺម្ចាស់ក្សត្រិយសូហ្វី (Sophie) ត្រូវបានឃាតកម្នាក់ទៀតបាញ់សម្លាប់។ ចក្រភពអូទ្រីស-ហុងគ្រីបានទម្លាក់ការទទួលខុសត្រូវនៃការធ្វើឃាត ព្រះអង្គម្ចាស់ហ្វ្រង់ឌីណង់ ទៅលើរដ្ឋាភិបាលស៊ែប៊ី។ អូទ្រីស-ហុងគ្រីក៏បានប្រកាសសង្គ្រាមលើស៊ែប៊ី ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩១៤។ ដោយសារតែការចងសម្ពន្ធមិត្តគ្នាយ៉ាងប្រទាក់ក្រឡា នៅក្នុងចំណោមប្រទេសមហាអំណាចនៅអឺរ៉ុប សង្គ្រាមទ្វេភាគី រវាងអូទ្រីស-ហុងគ្រី និងស៊ែប៊ី ក៏បានរាលដាលទៅដល់ប្រទេសមហាអំណាចអឺរ៉ុបផ្សេងទៀត រួមមាន អាល្លឺម៉ង់ រុស្ស៊ី បារាំង អង់គ្លេស និងអ៊ីតាលី។

ជារួមមក សង្គ្រាមលោកលើកទី១ ជាមហាសង្គ្រាមមួយដែលបង្កឡើងដោយលទ្ធិចក្រពត្តិនិយមដើម្បីយកទឹកដី និងតំបន់សេដ្ឋកិច្ចពិភពលោក ជាមហាសង្គ្រាមមួយក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិនាសតវត្សទី២០។




*រូបតុក្កតបង្ហាញពីសម្ពន្ធភាពដ៏ប្រទាក់ក្រឡា*

- ថ្ងៃទី២៨ កក្កដា ឆ្នាំ ១៩១៤ អូទ្រីសប្រកាសសង្គ្រាមជាមួយស៊ែប៊ី
- ថ្ងៃទី៣០ កក្កដា រុស្ស៊ីចាប់កេណ្ឌទ័ព
- ថ្ងៃទី៣១ ខែកក្កដា អាល្លឺម៉ង់ បានព្រមានរុស្ស៊ីកុំឱ្យកេណ្ឌទ័ព
- ថ្ងៃទី១ ខែសីហា អាល្លឺម៉ង់ និង បារាំងចាប់ផ្ដើមកេណ្ឌទ័ព។ អាល្លឺម៉ង់ចាប់ផ្ដើមប្រកាសសង្គ្រាមប្រឆាំងនិងប្រទេសរុស្ស៊ី។
- ថ្ងៃទី៣ សីហា អាល្លឺម៉ង់ ប្រកាសសង្គ្រាមជាមួយបារាំង
- ថ្ងៃទី៤ សីហា អាល្លឺម៉ង់បានរំលោភទៅលើអព្យាក្រឹត្យភាពបែលហ្ស៊ិក ដែលនាំឱ្យអង់គ្លេសមិនអាចនៅស្ងៀមក៏បានប្រកាសសង្គ្រាមជាមួយអាល្លឺម៉ង់។

ការហ៊ុមព័ទ្ធអាល្លឺម៉ង់ពីសំណាក់សម្ពន្ធមិត្ត បានបណ្ដាលឱ្យប្រទេសអាល្លឺម៉ង់ប្រើនាវាមុជទឹកជាលើកដំបូងធ្វើឱ្យនាវាជំនួញទាំងឡាយ ដែលមានទំនាក់ទំនងជាមួយទ្វីបអឺរ៉ុប មានការខូចខាតយ៉ាងធ្ងន់ធ្ងរ។ ការប្រើនាវាមុជទឹកនេះ ជំរុញឱ្យសហរដ្ឋអាមេរិកប្រកាសខ្លួនចូលក្នុងសង្គ្រាមនៅថ្ងៃទី៦ ខែមេសា ឆ្នាំ ១៩១៧ ដោយលោកប្រធានាធិបតី វិលសុន។

## ៣-ប្លុកដែលចូលរួមប្រយុទ្ធនៅក្នុងសង្គ្រាមលោកលើកទី១

សង្គ្រាមលោកលើកទី១ មានអាយុកាលរហូតដល់៤ឆ្នាំ បីខែ និង១៤ថ្ងៃ គិតពីខែកក្កដា ឆ្នាំ១៩១៤ ដល់ខែវិច្ឆិកា ឆ្នាំ១៩១៨ និងជាសង្គ្រាមដែលបានប្រមូលផ្ដុំមហាអំណាចដែលបែងចែកក្នុងប្លុកធំៗគឺ ៖

### ៣.១-អនុសញ្ញាត្រីភាគី

អនុសញ្ញាត្រីភាគីមានសាធារណរដ្ឋបារាំង ចក្រភពរុស្ស៊ី ចក្រភពអង់គ្លេស ក្រោយមកមាន ប្រទេសបែលហ្ស៊ិក ប្រទេសស៊ែប៊ី ប្រទេសក្រិក ប្រទេសរ៉ូម៉ានី ប្រទេសម៉ុងតេណេក្រូ ប្រទេសព័រទុយហ្គាល់ ប្រទេសអ៊ីតាលី( មុនពេលសង្គ្រាមលោកលើកទី១ផ្ទុះឡើងប្រទេសអ៊ីតាលីស្ថិតនៅក្នុងប្លុកជាមួយអាល្លឺម៉ង់ អូទ្រីស-

ហុងគ្រី ដែលបង្កើតឡើងតាំងពីឆ្នាំ១៨៨២ ក៏ប៉ុន្តែនៅពេលដែលសង្គ្រាមលោកផ្ទុះឡើង ប្រទេសនេះមិនបានចូលរួមខាងភាគីរបស់ខ្លួនទេ រហូតដល់ខែឧសភា ឆ្នាំ១៩១៥ ទើបអ៊ីតាលីចូលក្នុងសង្គ្រាមនៅខាង ភាគី អនុសញ្ញាត្រីភាគ) ប្រទេសជប៉ុន និងសហរដ្ឋអាម៉េរិក។ ប្លុកនេះ គេឱ្យឈ្មោះថាប្លុកសម្ពន្ធមិត្ត ។

**ការពាក់ព័ន្ធរបស់អាម៉េរិកក្នុងសង្គ្រាម**

អាម៉េរិកមិនចង់ពាក់ព័ន្ធក្នុងសង្គ្រាមឡើយ អាម៉េរិកបានស្ថិតនៅក្នុងភាពអាព្យាក្រឹត និងភាពឯកាជាយូរមកហើយ។ ប្រជាជនអាម៉េរិកជាច្រើន មិនចង់ចូលរួមនៅក្នុងជម្លោះ ឬសង្គ្រាមរបស់ប្រទេសខ្លួនទេ។

**ការលិចនាវា** បានបង្កើតភាពតានតឹងរវាងសហរដ្ឋអាម៉េរិក និងអាល្លឺម៉ង់ ប៉ុន្តែក៏មានកត្តាផ្សេងៗ ទៀតដែលពាក់ព័ន្ធផងដែរ។ ប្រធានាធិបតីអាម៉េរិក Woodrow Wilson បានជាប់ឆ្នោតម្តងទៀតនៅឆ្នាំ១៩១៨ ដោយប្រើពាក្យស្លោក(យើងត្រូវស្ថិតនៅក្រៅសង្គ្រាម)។ ទោះបីជាយ៉ាងណាក៏ដោយក៏ភាពតានតឹងកើនឡើងជាបន្តបន្ទាប់ នៅពេលដែលជនជាតិអាមេរិកត្រូវបានគេសម្លាប់នៅលើនាវានៅក្នុងដែនទឹកអឺរ៉ុប។

លើសពីនេះទៀតនៅឆ្នាំ១៩១៧ ភ្នាក់ងារស៊ើបអង្កេតសម្ងាត់របស់អង់គ្លេសបានចាប់បានតេឡេក្រាម Zimmerman។ នេះជាតេឡេក្រាមដែលផ្ញើដោយរដ្ឋមន្ត្រីការបរទេសអាល្លឺម៉ង់ទៅឱ្យឯកអគ្គរាជទូតអាល្លឺម៉ង់នៅម៉ិចស៊ីកូ។ នៅក្នុងតេឡេក្រាមនេះ អាល្លឺម៉ង់បានប្រគល់ឱ្យម៉ិចស៊ីកូនូវរដ្ឋ តិចសាស រដ្ឋ New Mexico និង Arizona។ អង់គ្លេសដែលបានផ្តាច់ទំនាក់ទំនងជាមួយអាល្លឺម៉ង់ ដោយសារតែការធ្វើសង្គ្រាមនាវាមុជទឹក គ្មានការស្រាកស្រាន្ត ពួកគេបានបញ្ចេញព័ត៌មាននេះ។

នៅត្រឹមខែមេសា ឆ្នាំ១៩១៧ នាវាអាម៉េរិកចំនួន ៥គ្រឿង ត្រូវបានបាញ់ពន្លេចដោយគ្មានការព្រមានជាមុន។ ប្រធានាធិបតី Wilson បានស្នើសុំការអនុម័តច្បាប់យល់ព្រមលើការប្រកាសសង្គ្រាម និងការអនុញ្ញាតឱ្យធ្វើសង្គ្រាម។ នៅខែឧសភា ច្បាប់បរិច្ចាកកិច្ចយោធាត្រូវអនុម័តហើយចាប់ផ្តើមកេណ្ឌយោធា។

មុនពេលសហរដ្ឋអាម៉េរិក ចូលរួមយ៉ាងពេញទំហឹងក្នុងសង្គ្រាម អាល្លឺម៉ង់បានធ្វើការវាយប្រហារយ៉ាងខ្លាំង ហើយបានរុញច្រានកម្លាំងសម្ពន្ធមិត្តឱ្យថយក្រោយ។ ឆ្លើយតបនឹងការរុញច្រានរបស់ អាល្លឺម៉ង់នេះ មេបញ្ជាការសម្ពន្ធមិត្តលោកឧត្តមសេនីយ៍ Foch ស្នើសុំកងទ័ព អាម៉េរិក ហើយបានរុញច្រានឱ្យពួកអាល្លឺម៉ង់ថយក្រោយវិញ។ មកដល់ខែកញ្ញា ទាហាន អាម៉េរិកប្រហែល៩ម៉ឺននាក់បានចូលរួមក្នុងសមរភូមិចុងក្រោយ រីឯទាហានអង់គ្លេសជ្រៀតចូលខ្សែសមរភូមិអាល្លឺម៉ង់នៅភាគខាងជើង។

## រុស្ស៊ីដកខ្លួនចេញពីសង្គ្រាម

នៅដើមឆ្នាំ១៩១៧ កម្មករនៅតាមបណ្តារោងចក្រ ក្នុងរាជធានីប៉េត្រូហ្គ្រាដ (បច្ចុប្បន្ន គឺទីក្រុង Saint Petersbourg) បាននាំគ្នាធ្វើកូដកម្ម និងបាតុកម្មជាបន្តបន្ទាប់ ហើយនៅថ្ងៃទី៨មីនា ឆ្នាំ១៩១៧ (បើគិតតាមប្រតិទិនរុស្ស៊ី គឺថ្ងៃទី២៣កុម្ភៈ) ពិធីជួបជុំ ដើម្បីអបអរទិវាសិទ្ធិនារីអន្តរជាតិ ក៏បានក្លាយទៅជាបាតុកម្មប្រឆាំងនឹងស្តេចត្សារ៍។ ប្រឈមមុខនឹងចលនាបះបោរនេះ នៅថ្ងៃទី១១មីនា ស្តេចត្សារ៍បានចេញបញ្ជាឱ្យកងទ័ពចេញធ្វើប្រតិបត្តិការជំនួស ប៉ូលិស ដើម្បីបង្ក្រាបបាតុកម្មប្រឆាំង។ ទាហានមួយចំនួនបាននាំគ្នាចេញបង្ក្រាបបាតុករតាមបញ្ជា ក៏ប៉ុន្តែ ទាហានមួយផ្នែកធំមិនស្តាប់បញ្ជាហើយបាននាំគ្នាផ្តាច់ខ្លួនទៅចុះចូលជាមួយក្រុមបះបោរ។

នៅក្រោយបដិវត្តន៍ខែកុម្ភៈ (តាមពិតខែមីនា បើគិតតាមប្រតិទិននៃឆ្នាំសកល) អំណាចនៅរុស្ស៊ីត្រូវស្ថិតក្រោមការគ្រប់គ្រងរួមគ្នា រវាងរដ្ឋាភិបាលបណ្តោះអាសន្ន និងសូវៀតប៉េត្រូក្រាដ ដែលនៅពេលនោះ មានទម្រង់ជាគណបក្សសង្គមនិយម។ក៏ប៉ុន្តែ ប៉ុន្មានខែក្រោយមក នៅខែតុលា ឆ្នាំ១៩១៧ (គិតតាមប្រតិទិនរុស្ស៊ី) បដិវត្តន៍ថ្មីមួយទៀតក៏បានកើតមានឡើងគឺបដិវត្តន៍កុម្មុយនីស្តដឹកនាំដោយលេនីន។

នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩១៧ (តាមប្រតិទិនចាស់ ត្រូវនឹងថ្ងៃទី ២៥ ខែតុលា) ពួកបុលសេវិកដឹកនាំដោយលេនីន បានដណ្តើមអំណាចពីរដ្ឋាភិបាលកេរីនស្គី ដែលបានបង្កើតឡើងបន្ទាប់ពីផ្តួលរំលំអំណាចស្តេចត្សារនៅក្នុងបដិវត្តន៍ខែកុម្ភៈ ឆ្នាំ១៩១៧។ រដ្ឋាភិបាលបុលសេវិកបានបោះពុម្ពសេចក្តីប្រកាស«អំពីសន្តិភាព» ដង្ហោយហៅឱ្យបណ្តាប្រទេសទាំងអស់បញ្ឈប់សង្គ្រាម ចរចាដើម្បីសន្តិភាព ដោយលើកគោលការណ៍គ្មានអ្នកណាចាញ់គ្មានអ្នកណាឈ្នះ។ បណ្តាប្រទេសសម្ពន្ធមិត្តបានបដិសេធ អ្នកដែលយល់ព្រមចុះហត្ថលេខាជាមួយនឹងរុស្ស៊ីមានតែចក្រភពអាល្លឺម៉ង់ទេ។ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩១៧ រវាងរុស្ស៊ី និងអាល្លឺម៉ង់បានចុះ ហត្ថលេខាសម្របសម្រួលដើម្បីសន្តិភាព។ រុស្ស៊ីបានដកខ្លួនចេញពីសង្គ្រាម កងទ័ពរុស្ស៊ីដែលឈរជើងនៅលើសមរភូមិអឺរ៉ុបបានវិលត្រឡប់មកមាតុភូមិវិញ។ អាល្លឺម៉ង់បានបន្តសង្គ្រាមជាមួយកងទ័ពសម្ពន្ធមិត្តដោយ គ្មានរុស្ស៊ី។

អាម៉េរិក ថ្វីដ្បិតតែមានទាហានតិច ក៏ប៉ុន្តែ មានសមត្ថភាពកេណ្ឌទ័ពបានរាប់លាននាក់ នៅក្នុងពេលដ៏ខ្លី។ ម្យ៉ាងទៀត នៅក្នុងពេលដែលទាហានអឺរ៉ុប ទាំងទាហានបារាំង និងអង់គ្លេស និងទាហានអាល្លឺម៉ង់សុទ្ធតែទទួលរងនូវការខូចខាតយ៉ាងធំធេងទាំងខាងផ្លូវកាយ និងផ្លូវចិត្ត ពីការវាយប្រយុទ្ធគ្នា ដោយគ្មានអ្នកឈ្នះ គ្មានអ្នកចាញ់ អស់រយៈពេលជាង៣ឆ្នាំមកហើយនោះទាហានអាម៉េរិកញគឺជាកម្លាំងថ្មី។

ដោយសារតែមានជំនួយពីកម្លាំងថ្មីនេះហើយ ទើបបារាំង និងអង់គ្លេសចាប់ផ្តើមមានប្រៀបលើសមរភូមិ។ នៅខែសីហា ឆ្នាំ១៩១៨ កងទ័ពសម្ពន្ធមិត្តក៏បានចាប់ផ្តើមបើកយុទ្ធនាការទ្រង់ទ្រាយធំ វាយរុញច្រានកងទ័ពអាល្លឺម៉ង់ឱ្យដកថយបន្តិចម្តងៗចេញពីប្រទេសបារាំង។ អាល្លឺម៉ង់ដែលទទួលបរាជ័យនៅស្ទើរតែគ្រប់សមរភូមិក៏សុខចិត្តចរចាសុំចុះចាញ់ ហើយចុះហត្ថលេខាលើបទឈប់បាញ់ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩១៨ មុននឹងឈានទៅចុះសន្ធិសញ្ញាសន្តិភាពនៅទីក្រុង Versailles (ប្រទេសបារាំង) ដើម្បីបញ្ចប់សង្គ្រាមលោកលើកទី១ ជាផ្លូវការ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩១៩។

### ៣.២-មហាអំណាចកណ្តាល (សម្ពន្ធត្រីភាគី)

សម្ពន្ធត្រីភាគីដែលមានប្រទេសអូទ្រីស-ហុងគ្រី ប្រទេសអាល្លឺម៉ង់បន្ទាប់មកមានការចូលជាសម្ពន្ធដែរ គឺប្រទេសប៊ុលហ្គារី និងប្រទេសតួកគី។ ប្លុកនេះ ប្រវត្តិវិទូឱ្យឈ្មោះថា ប្លុកមហាអំណាចកណ្តាល។

## ៤-ដំណើរប្រព្រឹត្តទៅនៃសង្គ្រាម

### ៤.១-ការវាយលុករបស់ក្រុមអាល្លឺម៉ង់

នៅថ្ងៃទី២៣ខែកក្កដា ឆ្នាំ១៩១៤ ក្រោយពីបានទទួលនូវការធានាពីអធិរាជអាល្លឺម៉ង់ ចក្រភព អូទ្រីស-ហុងគ្រីបានផ្ញើលិខិតផ្លូវការមួយ ដោយដាក់ឱសានវាទតែ៤៨ម៉ោងប៉ុណ្ណោះ ឱ្យស៊ែប៊ីបំពេញតាមលក្ខខណ្ឌ ១០ ចំណុច ដែលក្នុងចំណោមនោះ មានចំណុចខ្លះពិបាកនឹងបំពេញក្នុងរយៈពេលដ៏ខ្លីត្រឹម ៤៨ម៉ោង ហើយចំណុចខ្លះទៀត គឺជាលក្ខខណ្ឌ ដែលស៊ែប៊ី ក្នុងនាមជារដ្ឋអធិបតេយ្យ មិនអាចនឹងបំពេញតាមបាន។ តាមការពិត ការដាក់ឱសានវាទនេះ គ្រាន់តែជាការធ្វើ ដើម្បីបង្គ្រប់កិច្ចតែប៉ុណ្ណោះ។ អូទ្រីស-ហុងគ្រី បានសម្រេចចិត្តរួចទៅហើយថានឹងប្រកាសសង្គ្រាមទៅលើស៊ែប៊ី។

នៅថ្ងៃទី២៥ ខែកក្កដា រដ្ឋាភិបាលស៊ែប៊ីបានឆ្លើយតបទៅនឹងឱសានវាទរបស់អូទ្រីស-ហុងគ្រី ដោយបានសន្យាបំពេញតាមលក្ខខណ្ឌស្ទើរតែទាំងអស់ លើកលែងតែលក្ខខណ្ឌខ្លះ ដែលស៊ែប៊ីមិនអាចធ្វើតាមបាន ដោយសារតែវាធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យរបស់ស៊ែប៊ី។ ក៏ប៉ុន្តែ អូទ្រីស-ហុងគ្រីមិនសុខចិត្ត ក៏បានប្រកាសសង្គ្រាមលើស៊ែប៊ី នៅថ្ងៃទី២៨ខែកក្កដា ឆ្នាំ១៩១៤។

ដោយសារតែមានការចងសម្ពន្ធភាពប្រទាក់ក្រឡាគ្នាកាលពីមុនសង្គ្រាម ជម្លោះរវាងអូទ្រីស-ហុងគ្រី និងស៊ែប៊ី បានរាលដាលបន្តិចម្តងៗ ទៅកាន់ប្រទេសផ្សេងៗទៀត។ ក្រោយពីអូទ្រីស-ហុងគ្រីប្រកាសសង្គ្រាមលើស៊ែប៊ី ចក្រភពរុស្ស៊ីបានចាប់ផ្តើមកេណ្ឌកងទ័ព ដើម្បីត្រៀមចូលជួយស៊ែប៊ី ដែលជាសម្ពន្ធមិត្ត។ ឃើញបែបនេះ អាល្លឺម៉ង់ក៏បានចាប់ផ្តើមកេណ្ឌកងទ័ពរបស់ខ្លួនដែរ ហើយក្នុងពេលជាមួយគ្នា អាល្លឺម៉ង់បានប្រកាសដាក់ឱសានវាទ ១២ម៉ោង ឱ្យរុស្ស៊ីបញ្ឈប់ការត្រៀមខ្លួនធ្វើសង្គ្រាមជួយស៊ែប៊ី។ ដោយមិនបានទទួលចម្លើយវិជ្ជមានពីរុស្ស៊ី អាល្លឺម៉ង់ក៏បានប្រកាសសង្គ្រាមលើរុស្ស៊ី នៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩១៤។ អាល្លឺម៉ង់ក៏បានទាមទារផងដែរឱ្យបារាំងប្រកាសជំហរអព្យាក្រឹត ក្នុងសង្គ្រាម រវាងអាល្លឺម៉ង់ និងរុស្ស៊ី។ ក៏ប៉ុន្តែបារាំងបដិសេធ ដោយប្រាប់ទៅអាល្លឺម៉ង់វិញថា បារាំងនឹងធ្វើអ្វីៗ ដែលស្របនឹងផលប្រយោជន៍ជាតិរបស់បារាំង។ នៅថ្ងៃទី៣ ខែសីហា អាល្លឺម៉ង់ក៏បានប្រកាសសង្គ្រាមលើបារាំង ហើយមួយថ្ងៃក្រោយមក អង់គ្លេស ដែលជាសម្ពន្ធមិត្តរបស់បារាំង ក៏បានប្រកាសសង្គ្រាមលើអាល្លឺម៉ង់វិញដែរ។ ចំណែកប្រទេសជប៉ុន ដែលជាប់ក្នុងកិច្ចព្រមព្រៀងសម្ពន្ធភាពជាមួយអង់គ្លេស បានប្រកាសសង្គ្រាមលើអាល្លឺម៉ង់ និងអូទ្រីស-ហុងគ្រី នៅថ្ងៃទី២៣ និង២៥សីហា។

អាល្លឺម៉ង់បានចាប់ផ្តើមធ្វើសង្គ្រាម ដោយវាយលុកជាពីរមុខព្រួញ ក្នុងពេលតែមួយ គឺវាយលុកចូលឈ្លានពានប្រទេសបារាំង នៅទិសខាងលិច និងទប់ទល់នឹងកងទ័ពរបស់រុស្ស៊ីមកពីទិសខាងកើត។ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ១៩១៤ កងទ័ពអាល្លឺម៉ង់បានចាប់ផ្តើមវាយលុកចូលក្នុងប្រទេសបែលហ្ស៊ិក សំដៅចាក់ចុះមកប្រទេសបារាំង តាមទិសខាងជើង។ កងទ័ពបារាំងវិញបានចាប់ផ្តើមវាយលុកលើអាល្លឺម៉ង់ នៅទិសខាងកើត ក្នុងគោលដៅដណ្តើមយកតំបន់ Alsace-Laurraine ដែលអាល្លឺម៉ង់កាត់យកពីបារាំង កាលពីពេលបារាំងចាញ់សង្គ្រាម នៅឆ្នាំ១៨៧១។ ប៉ុន្តែ កងទ័ពបារាំងត្រូវកងទ័ពអាល្លឺម៉ង់វាយបកឱ្យដកថយក្រោយវិញ។ នៅខាងជើងឯនោះវិញ កងទ័ពអាល្លឺម៉ង់បានឆ្លងផុតបែលហ្ស៊ិក ហើយវាយលុកចូលក្នុងប្រទេសបារាំង សំដៅមកក្រុងប៉ារីស។ មកត្រឹមប្រមាណជា៧០គីឡូម៉ែត្រពីប៉ារីស កងទ័ពអាល្លឺម៉ង់ត្រូវបានកងទ័ពបារាំង ដែលពេលនោះមានជំនួយពីកងទ័ពអង់គ្លេស វាយទប់ជាប់លែងអាចរុលទៅមុខទៀតបាន។ នៅពេលនោះហើយដែល «សង្គ្រាមលេណដ្ឋាន» បានចាប់ផ្តើមឡើង ពោលគឺគូបដិបក្ខទាំងសងខាងបាននាំគ្នាជីកលេណដ្ឋានទល់មុខគ្នា ហើយធ្វើការវាយឆ្មក់ និងបាញ់ផ្លោងដាក់គ្នាចេញពីក្នុងលេណដ្ឋាន[466]។

ក្នុងដំណាក់កាលដំបូងនេះ ដោយមានជំនឿទុកចិត្តទៅលើគ្រឿងសព្វាវុធ និងកងកម្លាំងរបស់ខ្លួន អាល្លឺម៉ង់ បានបើកការវាយលុកយ៉ាងខ្លាំងក្លាទៅលើប្រទេសនានានៅក្នុងទ្វីបអឺរ៉ុបដោយសង្ឃឹមថា និងបានជ័យជម្នះយ៉ាងឆាប់ជាទីបំផុតនៅរណសិរ្សខាងលិច ដើម្បីបង្វិលកម្លាំងទ័ពទៅវាយលើរណសិរ្សខាងកើតវិញ។ ប៉ុន្តែគម្រោងការនេះត្រូវបរាជ័យដោយកងទ័ពអាល្លឺម៉ង់ត្រូវកងទ័ពបារាំងវាយស្កាត់នៅសមរភូមិ ម៉ាន នៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ១៩១៤។

❖ លទ្ធផលនៅរណសិរ្សខាងលិចនៅចុងឆ្នាំ១៩១៤

---

[466] សេង ឌីណា (២០១៤) *ប្រវត្តិសាស្ត្រពិភពលោក* : វិទ្យុបារាំង RFI ផ្សាយថ្ងៃទី២៣ មីនា ២០១៤

- កងទ័ពអាល្លឺម៉ង់វាយយកបានប្រទេសប៊ែលហ្សិកទាំងមូល
- កាន់កាប់ប្រទេសបារាំងមួយផ្នែក
- នៅរណសិរ្សខាងកើត វាយយកបានតំបន់ប៉ូឡូញមួយចំណែក។

## ៤.២-សង្គ្រាមនៅក្នុងលេណដ្ឋាន

នៅក្នុងដំណាក់កាលនេះ បញ្ហាសំខាន់គឺអាស្រ័យទៅដោយកម្លាំងទ័ព និងសម្ភារៈសឹក។ គូភាគីទាំងសងខាង បានប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ដោយរួមទាំងការ ប្រយុទ្ធនៅក្នុងលេណដ្ឋានផង។ លេណដ្ឋានដែលវែងជាងគេនៅក្នុងសង្គ្រាមលោកលើកទី១ គឺមានប្រវែង៧៨០គ.ម លាតសន្ធឹងពីសមុទ្រខាងជើងមកទល់ប្រទេសស្វីស។ នៅក្នុងអំឡុងឆ្នាំ១៩១៥ ដលឆ្នាំ១៩១៧ ការប្រយុទ្ធប្រយុទ្ធគ្នាមានសភាពឃោរឃៅជាទីបំផុត។ ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការរបស់កងទ័ពរដ្ឋាភិបាលប្រទេសដែលជាប់ដៃក្នុងសង្គ្រាម បានបង្វែរខឿនសេដ្ឋកិច្ច និងឧស្សាហកម្ម ទៅជាឧស្សាហកម្មយោធាទាំងអស់។ គេបានផលិតសម្ភារៈសឹកទំនើបៗ ដើម្បីបម្រើសេចក្តីត្រូវការក្នុងការធ្វើសឹកសង្គ្រាម។ គេបានផលលិតកាំភ្លើងយន្តគ្រប់ប្រភេទ គ្រាប់បែកដៃ អាវុធគីមី រថក្រោះ យន្តហោះចម្បាំង នាវាមុជទឹក កាំភ្លើងធំ...។

ចាប់ពីខែឧសភា ឆ្នាំ១៩១៥ ដល់ខែកញ្ញា ឆ្នាំ១៩១៦ កងទ័ពអាល្លឺម៉ង់បានចាប់ ផ្តើមវាយលុកជាទ្រង់ទ្រាយធំទៅប្រទេសរុស្ស៊ី។ នៅទីបំផុតកងទ័ពអាល្លឺម៉ង់បានកាន់កាប់ទឹកដី Gilicia, Poland និងLithuania។ កងទ័ពរុស្ស៊ីទទួលរងនូវការបាត់បង់ និងខូចខាតយ៉ាងធ្ងន់ធ្ងរដោយកងទ័ពប្រមាណជា ១,០០០,០០០នាក់ត្រូវបានស្លាប់។

នៅក្នុងដំណាក់កាលនេះ ការប្រយុទ្ធដ៏ធំជាងគេគឺការប្រយុទ្ធនៅវ៉ែរដង់ ក្នុងឆ្នាំ១៩១៦ ហើយដែលគូសត្រូវទាំងពីរបានបាញ់គ្នាទាំងយប់ទាំងថ្ងៃ អស់រយៈពេលជាច្រើនខែ។ ការប្រយុទ្ធនេះ បានចប់នៅខែធ្នូ ឆ្នាំ១៩១៦ ដែលធ្វើឱ្យកងទ័ពអាល្លឺម៉ង់ និងបារាំងបាត់បង់ជីវិតប្រមាណជា ៥០,០០០ នាក់។

## ៤.៣-ការវាយបករបស់ក្រុមសម្ពន្ធមិត្ត និងការចុះចាញ់របស់អាល្លឺម៉ង់

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩១៨ បដិវត្តន៍ប្រជាធិបតេយ្យបានចាប់ផ្តើមនៅអូទ្រីស-ហុងគ្រី។ ជាលទ្ធផលរបបរាជានិយមអូទ្រីស-ហុងគ្រីបានត្រូវដួលរលំ។ ចក្រភពអូទ្រីស-ហុងគ្រី ត្រូវបែងចែកជាពីរ គឺសាធារណរដ្ឋអូទ្រីស និងសាធារណរដ្ឋហុងគ្រី។ ចាប់ពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩១៨ រដ្ឋាភិបាលអូទ្រីសថ្មីបានចុះហត្ថលេខាបញ្ចប់សង្គ្រាមជាមួយនឹងប្រទេសសម្ពន្ធមិត្ត ក្នុងនាមចក្រភពអូទ្រីស-ហុងគ្រី។

រដ្ឋាភិបាលថ្មីរបស់អាល្លឺម៉ង់ ដែលបានបង្កើតឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩១៨ មានការចូលរួមពីសំណាក់ពួកសង្គមប្រជាធិបតេយ្យបានហុចដៃទៅរកសហរដ្ឋអាម៉េរិក ដើម្បីធ្វើការចរចាសន្តិភាព ឈរលើគោលការណ៍កម្មវិធីសន្តិភាព «១៤ចំណុច» របស់លោក វីលសុន (Woodrow Wilson)។ នៅក្នុងពេលជាមួយគ្នានេះដែរ អគ្គបញ្ជាការជាន់ខ្ពស់របស់កងទ័ពអាល្លឺម៉ង់ បានបញ្ជាឱ្យធ្វើការវាយលុកទ្រង់ទ្រាយធំលើផ្ទៃសមុទ្រ ក្នុងបំណងចង់បង្ហាញឱ្យឃើញថា កម្លាំងរបស់ខ្លួនមិនទាន់បាត់បង់នៅឡើយទេ។ នៅថ្ងៃទី៣០ ខែតុលា នាវាចម្បាំងរបស់អាល្លឺម៉ង់គ្រប់ធុនដែលសំចតនៅកំពង់ផែនៃទីក្រុងគីល បានទទួលបញ្ជាឱ្យធ្វើការវាយលុកទៅលើកងទ័ពនាវាចរសហរដ្ឋអាម៉េរិក។ នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩១៨ កងនាវាចរ កងទ័ព និងកម្មករអាល្លឺម៉ង់ចាប់ផ្តើមធ្វើការបះបោរ ដោយដណ្តើមគ្រប់គ្រងទីក្រុងគីល។ កងកម្លាំងបះបោរបានបង្កើត «ក្រុមប្រឹក្សា

តំណាងកម្មករនិងកងទ័ព»។ ក្រុមប្រឹក្សានេះ បានពង្រីកកម្លាំងរបស់ខ្លួនទៅកាន់ទីក្រុងជាច្រើនទៀត។ នៅថ្ងៃទី៩ ខែវិច្ឆិកា ការបះបោរបានផ្ទុះឡើងនៅកណ្ដាលរដ្ឋធានី បែរឡាំង។

នៅក្នុងស្ថានភាពបែបនេះគណៈប្រតិភូ របស់អាល្លឺម៉ង់បាន ប្រញាប់ប្រញាល់ទៅកាន់ទីតាំង មេបញ្ជាការអគ្គសេនាធិការយោធាកងទ័ពសម្ពន្ធមិត្ត ដែលស្ថិតក្រោមបញ្ជាការរបស់លោកសេនាប្រមុខ ហ្វែឌីណង់ ហ្វុក (Ferdinand Foch) ដើម្បីធ្វើការចរចាបញ្ចប់សង្គ្រាម។ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩១៨ នៅក្នុង ទូរថភ្លើងដែលជាទីបញ្ជាការរបស់សេនាប្រមុខហ្វុក ស្ថិតនៅក្នុងព្រៃកំព្យែង (Compiègne) នៅភាគខាងជើងបារាំង បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្សះផ្សាបញ្ចប់សង្គ្រាម។ អាល្លឺម៉ង់ត្រូវដកកងទ័ពចេញពីតំបន់ ដែលខ្លួនកាន់កាប់ដូចជាតំបន់ខាងលិចនៃទន្លេរ៉ាំង និងបញ្ជូននាវាចម្បាំងជាច្រើនគ្រឿង ព្រមទាំងអាវុធយុទ្ធភណ្ឌយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅឱ្យកងទ័ពសម្ពន្ធមិត្ត។ ការចុះហត្ថលេខានៅកំព្យែង បានបិទបញ្ចប់សង្គ្រាមលោកលើកទី១។

## ៥-សន្ធិសញ្ញាបញ្ចប់សង្គ្រាមលោកលើកទី១

សន្និសីទក្រុងប៉ារីស បានប្រព្រឹត្តទៅចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ១៩១៩ ដោយមានប្រទេសចំនួន៣២ ចូលរួម។ សេចក្ដីសម្រេចផ្សេងៗ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាចតុភាគី មានសហរដ្ឋអាម៉េរិក អង់គ្លេស អ៊ីតាលី និងបារាំង។ ក្រុមប្រឹក្សានេះ បានផ្ដោតទៅលើការបែងចែកផែនទីទ្វីបអឺរ៉ុប តាមឆន្ទៈ ប្រជាជន និងការបង្កើតសង្គមប្រជាជាតិដើម្បីរក្សាសន្តិភាព។ សន្ធិសញ្ញាវែរសៃ ត្រូវបានចុះហត្ថលេខាដោយប្រទេសអាល្លឺម៉ង់ នៅថ្ងៃទី២៨ខែមិថុនា ឆ្នាំ១៩១៩។ សន្ធិសញ្ញាផ្សេងទៀត ត្រូវបានចុះហត្ថលេខាដោយប្រទេសអូទ្រីស ហុងគ្រី តួកគី ប៊ុលហ្គារី ចាប់ពីខែកញ្ញា ឆ្នាំ ១៩១៩ ដល់ខែមិថុនា ឆ្នាំ១៩២០។ សន្ធិសញ្ញាវែរសៃ បានដាក់លក្ខខណ្ឌយ៉ាងច្រើនចំពោះប្រទេសអាល្លឺម៉ង់ ក្នុងនោះមានសំណង ចំពោះការខូចខាតនៃសង្គ្រាមជាប្រាក់ ការកាត់ផ្ដាច់ដែនដី និងការកម្រិតផ្នែកយោធា។

អាល្លឺម៉ង់ ត្រូវចំណាយចំពោះមហន្តរាយ ដែលបណ្ដាលមកពីសង្គ្រាម ដែលខ្លួនជាអ្នកបង្ក ឡើង។ កិច្ចព្រមព្រៀងវែរសៃ បានកំណត់ទំហំទឹកប្រាក់សំណងចំនួន១៣២ ពាន់លានម៉ាកមាស ដែលអាល្លឺម៉ង់ ត្រូវសង។ គេបង្កើតគណៈកម្មការបែងចែកទំហំទឹកប្រាក់នេះ ៥២% ត្រូវទទួលដោយ បារាំង២២% អង់គ្លេស១០% អ៊ីតាលី ៨% បែលហ្ស៊ិក[467]។

អាល្លឺម៉ង់មិនត្រូវបានអនុញ្ញាតឱ្យមានកងទ័ពនៅក្នុងតំបន់ Rhineland។ កងទ័ពពួកសម្ពន្ធមិត្តកាន់កាប់តំបន់ នេះរហូតដល់ឆ្នាំ១៩៣៥។

តំបន់ឧស្សាហកម្មសារ(Saar)នៅបន្តជារបស់អាល្លឺម៉ង់ ប៉ុន្តែគ្រប់គ្រងដោយសង្គមប្រជាតិរហូតដល់ឆ្នាំ១៩៣៥។
ផលប្រយោជន៍ផ្សេងៗនៃតំបន់នេះត្រូវប្រគល់ទៅឱ្យបារាំង




តំបន់ Alsace-Lorraine ត្រូវបានប្រគល់ទៅឱ្យបារាំងវិញ។

[467] ក្រសួងអប់រំ យុវជន និងកីឡា(២០១៤) ប្រវត្តិវិទ្យាថ្នាក់ទី១១: គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ទំព័រ៥៦

កិច្ចព្រមព្រៀងវែរសៃ បានហាមឃាត់មិនឱ្យអាល្លឺម៉ង់ មាននាវាមុជទឹក នាវាចម្បាំងលើទឹកធំៗ កងទ័ពរថក្រោះ កងទ័ពអាកាស និងកាំភ្លើងផ្លោងធុនធ្ងន់។ សេនាធិការយោធាអាល្លឺម៉ង់ ត្រូវរំលាយ ចោល។ កាតព្វកិច្ច និងបរិច្ចាកកិច្ចយោធា ត្រូវលុបបំបាត់ចោល។ កងទ័ពជើងគោកអាល្លឺម៉ង់ត្រូវមានចំនួនអតិបរិមា ១០០ ០០០នាក់ ដែលត្រូវបង្កើតដោយទាហានស្ម័គ្រចិត្ត។ ចំនួនកងទ័ពជើងទឹកអតិ បរិមា ១៥០០០នាក់។ សន្ធិសញ្ញាវែរសៃ បានបង្ខំឱ្យអាល្លឺម៉ង់ត្រូវបោះបង់នូវទឹកដីរបស់ខ្លួនកាន់កាប់ ទទួលខុសត្រូវចំពោះការបង្កសង្គ្រាម ប្រគល់តំបន់ Alsace- Lorraine ទៅឱ្យបារាំងវិញ។ ប្រគល់ឱ្យនូវការគ្រប់គ្រងតំបន់ធ្យូងថ្ម សារ (Saar) ទៅឱ្យសម្ពន្ធភាពប្រជាជាតិក្នុងរយៈពេល១៥ឆ្នាំ (បារាំងអ្នកទទួលយកផលប្រយោជន៍)។ លើសពីនេះទៀត កម្លាំងសម្ពន្ធមិត្រ ត្រូវកាន់កាប់ West Bank នៃទន្លេ Rhine ចំនួន១៥ឆ្នាំ ផងដែរ។ មិនត្រឹមតែប៉ុណ្ណោះទឹកដីមួយចំនួនទៀត ត្រូវប្រគល់ទៅឱ្យប្រទេសប៉ូឡូញ(ប៉ូស្នាញ់ តំបន់ខ្លះៗនៃព្រុស និងតំបន់ប៉ូម៉េរ៉ានី) បែលហ្ស៊ិក (អាយប៉ិច ម៉ាល់មេឌី និងម៉ូរ៉េនេ) ដាណឺម៉ាក់(តំបន់ស្លេស្វីកខាងជើង)។ បើប្រៀបធៀបទៅនឹងឆ្នាំ១៩១៤ ទឹកដីអាល្លឺម៉ង់បានរួញអស់មួយភាគប្រាំបីនៃផ្ទៃដីទាំងអស់។ ចំពោះដែនដីអាណានិគមអាល្លឺម៉ង់នៅឯនាយសមុទ្រ ក្នុងទ្វីបអាហ្វ្រិក និងនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ត្រូវបាត់បង់ទាំងអស់ផងដែរ។

### ៦-វិនាសកម្ម និងផលវិបាកនៃសង្គ្រាមលោកលើកទី១

សង្គ្រាមលោកលើកទី១ បានបំផ្លិចបំផ្លាញជីវិតមនុស្សទាំងកងទ័ព និងជនស៊ីវិលអស់ជាច្រើនក្នុងនោះ មានទាំងការខូចខាតសម្បត្តិវប្បធម៌ដ៏មានតម្លៃរបស់មនុស្សជាតិទៀតផង។ គិតជាសរុប សង្គ្រាមលោក លើកទី១ បានសម្លាប់ជីវិតមនុស្សប្រមាណ ១៧លាននាក់ ក្នុងនោះ មានទាហាន ១០លាននាក់ និងជនស៊ីវិល ៧លាននាក់។ ចំនួនអ្នករបួសវិញ មានរហូតដល់ទៅប្រមាណជា ២០លាននាក់។ ប្រទេសដែលទទួលរងការ ខូចខាតធ្ងន់ធ្ងរជាងគេ គឺអាល្លឺម៉ង់ និងបារាំង[468]។ ក្នុងនោះប្រទេសបារាំងមានចំនួនជាង ១.៣លាននាក់បានបាត់បង់ជីវិត។ ប្រទេសអាល្លឺម៉ង់ ជាង ១.៧ លាននាក់ ប្រទេសអូទ្រីស- ហុងគ្រីចំនួនជាង ១.២ នាក់ ប្រទេស បែលហ្ស៊ិក ៤ម៉ឺន៥ ពាន់នាក់ ប្រទេសអ៊ីតាលី ០.៦៥លាននាក់ ប្រទេស រ៉ូម៉ានី៧សែននាក់ សហរដ្ឋអាម៉េរិក ០.១២៦លាន ពាន់នាក់ ចក្រភពអង់គ្លេស ០.៩លាននាក់ ប្រទេស រុស្ស៊ី ១.៧ លាន នាក់ ប្រទេសស៊ែប៊ី ៤សែននាក់ និងប្រទេសតួកគី ចំនួន ៤សែននាក់។

| ប្រទេស | កងទ័ពចូលរួមក្នុងសង្គ្រាម | ស្លាប់ | របួស | បាត់ខ្លួន |
|---|---|---|---|---|
| អូទ្រីស-ហុងគ្រី | 7,800,000 | 1,200,000 | 3,620,000 | 2,200,000 |
| អង់គ្លេស | 8,904,000 | 908,000 | 2,090,000 | 129,000 |
| បារាំង | 8,410,000 | 1,357,800 | 4,266,000 | 537,000 |
| អាល្លឺម៉ង់ | 11,000,000 | 1,737,000 | 4,126,000 | 1,152,800 |
| អ៊ីតាលី | 5,615,000 | 650,000 | 947,000 | 600,000 |
| រុស្ស៊ី | 12,000,000 | 1,700,000 | 4,950,000 | 2,500,000 |
| អាម៉េរិក | 4,355,000 | 126,000 | 234,300 | 4,500 |

ក្រោយសង្គ្រាមស្ត្រីត្រូវបានលើកតម្កើងឱ្យមានភាពស្មើគ្នានឹងបុរស។ ជាក់ស្តែងនៅប្រទេសជាច្រើន ស្ត្រីទទួលបានសិទ្ធិក្នុងការបោះឆ្នោតនៅឆ្នាំ១៩១៨ (ប៉ូឡូញ អូទ្រីស ឆេកូស្លូវ៉ាគី ស៊ុយអែត កាណាដា...) ចំណែកនៅ

[468] សេង ឌីណា, *ប្រវត្តិសាស្ត្រពិភពលោក*, វិទ្យុបារាំង ផ្សាយថ្ងៃទី៤ ឧសភា ២០១៤។

សហរដ្ឋអាម៉េរិក វិញស្ត្រីបានចូលរួមបោះឆ្នោតជ្រើសរើសប្រធានាធិបតីជាលើកដំបូងនៅឆ្នាំ១៩២០[469]។ លើសពីនេះទៅទៀតនៅក្រោយសង្គ្រាមលោកលើកទី១ បានបញ្ចប់ ភាពស្មើគ្នារវាងពូជសាសន៍ និងវណ្ណៈនៅក្នុងសង្គមក៏ត្រូវបានលើកតម្កើងផងដែរ។

សង្គ្រាមបានធ្វើឱ្យខូចខាតសម្ភារៈយ៉ាងសន្ធឹកសន្ធាប់។ ទីក្រុងជាច្រើនបានក្លាយជាផេះផង់ស្ពានផ្លូវរថភ្លើង រោងចក្រជាច្រើនត្រូវខ្ទេចខ្ទី។ សង្គ្រាមបានធ្វើឱ្យខឿនសេដ្ឋកិច្ច ពិសេសឧស្សាហកម្ម កសិកម្ម និងហិរញ្ញវត្ថុ នៃបណ្ដាប្រទេសជាច្រើននៅទ្វីបអឺរ៉ុបត្រូវរង្គោះរង្គើជាហេតុធ្វើឱ្យប្រទេសទាំងនេះចុះក្រយ៉ាងធាប់បំផុត។ ម្យ៉ាងទៀត ប្រទេសជាប់ជម្លោះនីមួយៗសុទ្ធតែបាននាំគ្នាចំណាយលុយរាប់សិប ពាន់លានដុល្លារក្នុងការធ្វើសង្គ្រាម ហើយភាគច្រើនលុយទាំងនេះបានមកពីការខ្ចីបំណុល ទាំងនៅក្នុង និងក្រៅប្រទេស។ ក្រោយពីសង្គ្រាមបញ្ចប់ទៅ បំណុលអស់ទាំងនេះក៏ត្រូវដល់ពេលសងគេវិញ ហើយក្នុងពេលជាមួយគ្នា តម្រូវការចំណាយក៏មានច្រើន ដើម្បីស្ដារការខូចខាត ជាពិសេស ខាងផ្នែកហេដ្ឋារចនាសម្ពន្ធ ដែលត្រូវបំផ្លិចបំផ្លាញដោយសារសង្គ្រាម ចំណែកឯសេដ្ឋកិច្ចវិញក៏មិនមានកំណើន ដោយសារតែខ្វះខាតកម្លាំងពលកម្ម។

ប្រឈមមុខនឹងបញ្ហានេះ ប្រទេសនីមួយៗបាននាំគ្នាធ្វើការបោះពុម្ពលុយយ៉ាងច្រើនសន្ធឹកសន្ធាប់ដើម្បីយកមកបង្គ្រប់ការចំណាយ ដែលជាហេតុធ្វើឱ្យអត្រាអតិផរណាត្រូវកើនឡើងខ្ពស់កប់ពពក ជាពិសេសនៅអាល្លឺម៉ង់។ នៅអំឡុងចុងឆ្នាំ១៩២៣ លុយម៉ាក (Mark) របស់អាល្លឺម៉ង់បានធ្លាក់ថ្លៃដល់កម្រិតទាបបំផុតស្ទើរតែលែងមានតម្លៃអ្វីទាំងអស់ ពោលគឺ ជាង៤ពាន់ពាន់លានម៉ាក (៤ 000 000 000 000) ទើបដូរបានមួយដុល្លារអាម៉េរិក។ នៅក្នុងពេលដែលអឺរ៉ុបកំពុងប្រឈមមុខនឹងភាពចលាចលខាងផ្នែកសេដ្ឋកិច្ច និងរូបិយវត្ថុអាម៉េរិក ដែលបានផ្ដល់ប្រាក់កម្ចីរាប់ពាន់លានដុល្លារ ដល់បណ្ដាប្រទេសអឺរ៉ុប ដើម្បីយកទៅធ្វើសង្គ្រាម ក៏បានលេចមុខឡើងជាមហាអំណាចសេដ្ឋកិច្ចពិភពលោក។ មណ្ឌលហិរញ្ញវត្ថុពិភពលោកលែងស្ថិតនៅក្នុងទីក្រុងឡុងដ៍ ដូចជាពីពេលមុនទៀតហើយ ក៏ប៉ុន្តែ ទៅស្ថិតនៅឯទីក្រុងញូវយ៉ក សហរដ្ឋអាម៉េរិក ឯនោះវិញ[470]។

សង្គ្រាមលោកលើកទី១ បានបង្កឡើងឱ្យផ្ទុះជាបដិវត្តន៍ខែតុលានៅរុស្ស៊ីឆ្នាំ១៩១៧ ព្រឹត្តិការណ៍ទាំងនេះបានធ្វើឱ្យពិភពមូលធននិយម មានការរង្គោះរង្គើយ៉ាងខ្លាំង និងឈានចូលទៅក្នុងវិបត្តិមួយដ៏ជ្រាលជ្រៅជាទីបំផុត។



ការដួលរលំនៃអាណាចក្រអូទ្រីស-ហុងគ្រី នៅចុងបញ្ចប់នៃ

សង្គ្រាមលោកលើកទី១ក៏បានបង្កផលវិបាកខាងផ្នែកនយោបាយ យ៉ាងសម្បើមផងដែរ ដល់តំបន់អឺរ៉ុប។ របបរាជានិយមត្រូវដួលរលំជាបន្តបន្ទាប់ ដោយនាំយកទៅជាមួយនូវក្រុមគ្រួសាររាជវង្សធំៗ ដែលធ្លាប់តែគ្រប់គ្រងអឺរ៉ុបជាច្រើនតំណកន្លងមកហើយ។ ចក្រភពធំៗ នៅអឺរ៉ុប រួមមាន ចក្រភពអាល្លឺម៉ង់ អូទ្រីស-ហុងគ្រី រុស្ស៊ី និងអូតូម៉ង់ ត្រូវដួលរលំ ដោយបែកខ្ញែកគ្នាទៅជាប្រទេសតូចៗជាច្រើន ដូចជា ប្រទេសអូទ្រីស ហុងគ្រី ឆេកូស្លូវ៉ាគី ប្រទេសក្នុងអតីតយូហ្គោស្លាវី កើតចេញពីការដួលរលំនៃចក្រភពអូទ្រីស ហុងគ្រី ប្រទេសហ្វាំងឡង់ និងប្រទេសជុំវិញសមុទ្របាល់ទិក កើតចេញពីការដួលរលំនៃចក្រភពរុស្ស៊ី ចំណែក

[469] Women's_rights.htm#Suffrage.2C_the_right_to_vot។

[470] សេង ឪណា, *ប្រវត្តិសាស្ត្រពិភពលោក*, រិទ្យុបារាំងផ្សាយថ្ងៃទី៤ ឧសភា ២០១៤។

តួកគី និងបណ្តាប្រទេសជាច្រើនផ្សេងទៀត នៅក្នុងតំបន់មជ្ឈិមបូព៌ាសព្វថ្ងៃ កើតចេញពីការដួលរលំនៃចក្រភពអូតូម៉ង់។

នៅអាល្លឺម៉ង់ របបរាជានិយមរបស់ព្រះបាទ Wilhem II ត្រូវដួលរលំ ហើយបង្កើតទៅជារបបសាធារណរដ្ឋ ដែលគេឱ្យឈ្មោះថា សាធារណរដ្ឋវ៉ៃម៉ា (Weimar)។ តំបន់អាល់សាស់-ឡរ៉ែន (Alsace-Lorraine) ដែលអាល្លឺម៉ង់ដណ្តើមយកពីបារាំង កាលពីអំឡុងសង្គ្រាមអាល្លឺម៉ង់-បារាំង ឆ្នាំ១៨៧១ ត្រូវបានកាត់ប្រគល់ទៅឱ្យប្រទេសបារាំងវិញ។ លើសពីនេះទៅទៀត អាល្លឺម៉ង់ ដែលជាប្រទេសចាញ់សង្គ្រាម ត្រូវគេបង្ខំឱ្យសងការខូចខាត រហូតដល់ទៅជាង រាប់ពាន់លានដុល្លារ ដល់ប្រទេសដែលជាអ្នកឈ្នះសង្គ្រាម។ សន្ធិសញ្ញាសន្តិភាពក្រុង Versailles ក៏បានតម្រូវផងដែរឱ្យអាល្លឺម៉ង់កាត់បន្ថយចំនួនកងទ័ពឱ្យនៅយ៉ាង ច្រើនបំផុតត្រឹម ១០ម៉ឺននាក់ ហើយការផលិតគ្រឿងសព្វាវុធធុនធ្ងន់ ដូចជា រថក្រោះ យន្តហោះចម្បាំង និងនាវាចម្បាំងធំៗក៏ត្រូវបានហាមឃាត់។ ការដាក់កម្រិតបែបនេះ ត្រូវបានធ្វើឡើងក្នុងគោលដៅបញ្ចៀសកុំឱ្យមហិច្ចតាឈ្លានពានពង្រីកទឹកដីរបស់អាល្លឺម៉ង់ ត្រូវផ្ទុះឡើងវិញ ហើយបង្កទៅជាសង្គ្រាមសាជាថ្មីទៀត។

ក្រៅពីសន្ធិសញ្ញាវែរសៃ ដែលអាល្លឺម៉ង់ត្រូវចុះហត្ថលេខាក្រោយចាញ់សង្គ្រាមលោកលើកទី១នៅ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩១៩ សន្ធិសញ្ញាបំពេញបន្ថែមដែលបានរៀបចំរួមមាន៖

- សន្ធិសញ្ញាសាំងហ្សែម៉ាំង (Saint Germain)ជាមួយនឹងអូទ្រីសនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩១៩ ស្តីពីការបំបែកប្រទេសអូទ្រីសនិងហុងគ្រី ការដកយកដែនដីទីរ៉ុល (Tyrol)ទៅឱ្យប្រទេសអ៊ីតាលី ការទទួលស្គាល់ឯករាជភាពប៉ូឡូញ ឆេកូស្លូវ៉ាគី យូហ្គោស្លាវី ហុងគ្រី និងការកាត់បន្ថយទ័ពអូទ្រីសនៅត្រឹម៣០ពាន់នាក់ និងសងថ្លៃខូចខាតសង្គ្រាម។
- សន្ធិសញ្ញាណឺលី(Neuilly)ជាមួយប៊ុលហ្គារីនៅ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩១៩ ស្តីពីការកាត់ទឹកដីតំបន់ធ្រេរត្រាស់ (Thrace)ឱ្យទៅប្រទេសក្រិក។
- សន្ធិសញ្ញាទ្រីយ៉ាណុង (Trianon)ជាមួយនឹងហុងគ្រីនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩២០ ស្តីពីការបង្កើតរដ្ឋឆេកូស្លូវ៉ាគី កាត់ទឹកដីត្រង់ស៊ីលវ៉ានី(Transylvanie)ទៅឱ្យប្រទេសរ៉ូម៉ានី កាត់ទឹកដី បាណាត់ (Banat) ទៅឱ្យយូហ្គោស្លាវី។
- សន្ធិសញ្ញាក្រុងសែវ(Sèvres) ជាមួយប្រទេសតួកគី(អូតូម៉ង់)នៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩២០ ស្តីពីការត្រួតពិនិត្យជាអន្តរជាតិនៅលើតំបន់ច្រកចូលទាំងឡាយ ការរំលាយចក្រភពអូតូម៉ង់ ការបង្កើតរដ្ឋតួកគីដោយកំណត់កងទ័ពត្រឹម៥០ពាន់នាក់ និងការកាត់ផ្តាច់ទឹកដីមួយចំនួនទៀត។
- សន្ធិសញ្ញាឡូកាណូ(Locarno) ឆ្នាំ១៩២៥ ស្តីពីការដោះស្រាយបញ្ហាព្រំដែនប្រទេសអាល្លឺម៉ង់ជាមួយបារាំង និងបែលហ្ស៊ិក។

នៅក្នុងវិស័យនយោបាយនេះផងដែរយើងមើលឃើញថា សង្គ្រាមលោកលើកទី១ បានធ្វើឱ្យមានការលេចរូបរាងឡើងនូវរដ្ឋប្រជាជាតិថ្មីៗជាច្រើន និងមានការគូរព្រំដែនផងដែរ។ លើសពីនេះទៅទៀតនៅ ក្នុងពេលសង្គ្រាម ចលនាតស៊ូបះបោរប្រឆាំងនឹងសង្គ្រាមបានកើតឡើងនៅក្នុងប្រទេសជាច្រើន។ ក្នុងពេលជាមួយគ្នា ស្ថាប័នអន្តរជាតិដ៏ថ្មីស្រឡាងមួយក៏ត្រូវបានបង្កើតឡើងដែរ គឺសង្គមប្រជាជាតិ (League of Nations/Société des nations) ក្នុងបេសកកម្មធានាឱ្យបាននូវសុខសន្តិភាពនៅទូទាំងពិភពលោក[471]។

---

[471] សេង ឌីណា, *ប្រវត្តិសាស្ត្រពិភពលោក*, វិទ្យុបារាំង ផ្សាយថ្ងៃទី៤ ឧសភា ២០១៤។

**សង្គមប្រជាជាតិមានគោលបំណងជាមូលដ្ឋានពីរគឺៈ**

- ដើម្បីរក្សាសន្តិភាព តាមរយៈសកម្មភាពរួមរបស់សមាជិក។ បើមានជម្លោះ ត្រូវបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល និងសម្រុះសម្រួលដើម្បីដោះស្រាយ។ បើចាំបាច់អាចប្រើទណ្ឌកម្មសេដ្ឋកិច្ច និងយោធា។
- ជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យសេដ្ឋកិច្ច និងសង្គម។

***ការដួលរលំនៃសង្គមប្រជាជាតិ***

ហេតុផលជាច្រើនដែលធ្វើឱ្យអង្គការសង្គមប្រជាជាតិត្រូវរលំរលាយៈ

-ភាពទន់ខ្សោយនៃរចនាសម្ពន្ធគ្រប់គ្រងរបស់សង្គមប្រជាជាតិ

-គ្មានកងទ័ពសម្រាប់ពង្រឹងការអនុវត្តច្បាប់

-សហរដ្ឋអាម៉េរិក មិនបានចូលរួមជាសមាជិក

-ការយឺតយ៉ាវរបស់សូវៀតក្នុងការចូលរួម(ចូលក្នុងឆ្នាំ១៩៣៤)

-ការដកខ្លួនថយរបស់ប្លុកប្រទេសអាល្លឺម៉ង់ អ៊ីតាលី និងជប៉ុន

-ប្រទេសជាច្រើន បានចាប់ផ្តើមធ្វើកិច្ចព្រមព្រៀងជាមួយគ្នា នៅក្រៅរង្វង់សង្គមប្រជាជាតិ

-ប្រទេសមហាអំណាចមួយចំនួនធំ មិនគោរព តាមគោលការណ៍របស់សង្គមប្រជាជាតិ

-ការផ្ទុះឡើង និងរាលដាលនៃសង្គ្រាមលោកលើកទី២

**សង្គ្រាមលោកលើកទី១ បានធ្វើឱ្យពិភពលោកមានបម្រែបម្រួលជាច្រើនដូចជាៈ**

- នៅតាមប្រទេសស្ថិតនៅក្រោមអាណានិគម បានផ្ទុះឡើងនូវចលនាទាមទារឯករាជ្យ
- បម្រែបម្រួលភូមិសាស្ត្រនយោបាយ មានកើតឡើងនូវរដ្ឋថ្មីៗ ជាច្រើន ជាពិសេសនៅអឺរ៉ុប
- ប្រទេសឈ្នះសង្គ្រាមពង្រីកដែនដីអាណានិគម
- ប្រទេសចាញ់សង្គ្រាមបាត់បង់ដែនដីអាណានិគម
- ផ្ទុះឡើងនូវចលនាបដិវត្ត និងចលនាកុម្មុយនីស្ត នៅក្នុងបណ្តាប្រទេសជាច្រើន
- របបរាជានិយមរាជានិយមនៅអឺរ៉ុបជាច្រើនត្រូវដួលរលំ ដូចជានៅប្រទេសរុស្ស៊ី អាល្លឺម៉ង់ និងអូទ្រីស-ហុងគ្រី ជាដើម។
- សេដ្ឋកិច្ចនៅទ្វីបអឺរ៉ុបមានការធ្លាក់ចុះ ជាពិសេសអាម៉េរិកបានក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏ធំ
- ភាពគ្មានការងារធ្វើបានកើនឡើង
- វិបត្តិហិរញ្ញវត្ថុបានកើតឡើង អតិផរណាសង្គម
- ស្ត្រីត្រូវទទួលបានសិទ្ធិបោះឆ្នោត និងសមភាពជាមួយបុរសនៅក្នុងបណ្តាប្រទេសជាច្រើនជាបន្តបន្ទាប់។

**សំណួរត្រិះរិះ**

១-តើបុព្វហេតុអ្វីខ្លះដែលនាំឱ្យផ្ទុះសង្គ្រាមលោកលើកទី១ឡើង? ចូរពន្យល់។

២-តើមហាអំណាចដែលចូលរួមក្នុងសង្គ្រាមមានគោលបំណងដូចម្តេចខ្លះ?

៣-តើមូលហេតុអ្វីបានជាអាល្លឺម៉ង់ត្រូវធ្វើសង្គ្រាម តាមគម្រោងសង្គ្រាមផ្លេកបន្ទោរ?

៤-តើមូលហេតុអ្វីដែលធ្វើឱ្យប្រទេសអ៊ីតាលី ចាកចេញពីសម្ពន្ធមិត្តរបស់ខ្លួន ហើយមកចូលរួមសង្គ្រាមខាងភាគី បារាំង និងអង់គ្លេសវិញ?
៥-តើមូលហេតុអ្វីខ្លះដែលនាំឱ្យអាម៉េរិក ចូលរួមក្នុងសង្គ្រាមលោកលើកទី១?
៦-ចូរពន្យល់ពីមូលហេតុដែលនាំឱ្យរុស្ស៊ី ដកខ្លួនចេញពីសង្គ្រាមលោកលើកទី១?
៧-តើសន្ធិសញ្ញាក្រុងវែរសៃ បានដាក់ទណ្ឌកម្មដូចម្តេចខ្លះចំពោះប្រទេសអាល្លឺម៉ង់?
៨-តើសង្គ្រាមលោកលើកទី១ បានផ្តល់ផលវិបាកដូចម្តេចខ្លះចំពោះពិភពលោក?
៩-ចូរសរសេរសន្ធិសញ្ញាវែរសៃថ្មី ដើម្បីបញ្ចៀសពិភពលោកពីសង្គ្រាមសាជាថ្មីម្តងទៀត។

# មេរៀនទី៥ ពិភពលោកដំណាក់កាលសង្គ្រាមលោកលើកទី២(១៩៣៩-១៩៤៥)

សង្គ្រាមលោកលើកទី២ ជាជម្លោះប្រដាប់អាវុធដ៏ធំបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ដែលមានប្រទេសមហាអំណាចទាំងអស់ចូលរួម ហើយប្រទេសជាច្រើនលើពិភពលោកសុទ្ធតែពាក់ព័ន្ធនៅក្នុងសង្គ្រាមនេះ។ សង្គ្រាមលោកលើកទី២ ជាសង្គ្រាមដែលប្រើប្រាស់អាវុធបរមាណូដំបូងបំផុត សង្គ្រាមនេះបានបង្កវិនាសកម្មធ្ងន់ធ្ងរបំផុតចំពោះពិភពលោក។

សង្គ្រាមលោកលើកទី២ ឆ្នាំ១៩៣៩-១៩៤៥ បានធ្វើឱ្យមនុស្សជាតិស្គាល់ការខូចខាតឥតគណនា ស្គាល់នូវការឈឺចាប់ និងមរណៈយ៉ាងអាណោចអធមគឺជាលទ្ធផលនៃនយោបាយចង់ត្រួតត្រាពិភពលោកនៃពួកណាស៊ីអាល្លឺម៉ង់។ មហាអំណាចបស្ចិមប្រទេសសំខាន់ៗ មួយចំនួនពុំបានប្រកាន់ឥរិយាបថរបស់ខ្លួនឱ្យបានម៉ឺងម៉ាត់ដើម្បីទប់នយោបាយរបស់អ៊ីត្លែ។ ផ្ទុយទៅវិញមហាអំណាចទាំងនោះ ជាពិសេសពេលសន្និសីទក្រុងមុយនិចបានលើកទឹកចិត្តណាស៊ីអាល្លឺម៉ង់ ឱ្យរឹតតែខ្លាំងក្លាថែមទៀតជាហេតុធ្វើឱ្យសង្គ្រាមលោកលើកទី២ ផ្ទុះឡើង។

## ១-បុព្វហេតុនៃសង្គ្រាម

### ១.១-បុព្វហេតុនយោបាយ

សន្ធិសញ្ញាក្រុងវ៉ែរសៃ គឺជាសន្ធិសញ្ញាដែលអាល្លឺម៉ង់ទទួលយកលក្ខខណ្ឌនៃការបង្កឱ្យមានសង្គ្រាម លោកលើកទី១។ សន្ធិសញ្ញានេះបានដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរចំពោះប្រទេសអាល្លឺម៉ង ដែលជាហេតុធ្វើឱ្យ មេដឹកនាំអាល្លឺម៉ង់ក្រោយមកគិតថាសន្ធិសញ្ញានេះផ្តល់នូវភាពអយុត្តិធម៌ចំពោះខ្លួន។ ចំណែក ប្រទេសដែលឈ្នះសង្គ្រាមជាពិសេស ប្រទេសអង់គ្លេស និងបារាំង បានទទួលនូវផលប្រយោជន៍យ៉ាងច្រើន ជាពិសេសទទួលបាន សិទ្ធិកាន់កាប់ដែនដីនានា ដែលអតីតជាដែនដីរបស់ប្រទេសដែលចាញ់ សង្គ្រាម។ ផ្ទុយទៅវិញប្រទេសអ៊ីតាលី ជាប្រទេសមួយដែលឈ្នះសង្គ្រាមនឹងគេដែរ ហាក់បីដូចជាមិនសប្បាយចិត្ត ព្រោះខ្លួនមិនទទួលបាននូវអ្វីដែលខ្លួនចង់បានឡើយ។

តាមរយៈសន្ធិសញ្ញាវ៉ែរសៃ សង្គមប្រជាជាតិត្រូវបានបង្កើតឡើងក្នុងគោលបំណងរក្សាសន្តិភាព និងសន្តិសុខលើពិភពលោកទាំងមូល។ ក៏ប៉ុន្តែជាក់ស្តែង សង្គមប្រជាជាតិពិតជាទន់ខ្សោយ ពុំអាចដោះស្រាយបញ្ហាធំៗ នានាដោយប្រសិទ្ធភាពឡើយ។ ការរៀបចំសន្និសីទកាត់បន្ថយកងទ័ពរបស់សង្គមប្រជាជាតិ នៅឆ្នាំ១៩២៦ ត្រូវទទួលបរាជ័យដោយប្រទេសបារាំង និងអង់គ្លេស បដិសេធ មិនព្រមសហការជាមួយ។ លើសពីនេះទៅទៀត សន្និសីទក្រុងហ្សឺណែវ ស្តីពីកាត់បន្ថយកងទ័ពលើពិភពលោក (១៩៣២-១៩៣៤) ក៏ត្រូវបរាជ័យផងដែរ ដោយនៅពេលនោះ អាល្លឺម៉ង់ នៅតែបន្តការប្រកួតប្រជែងកងទ័ពជាមួយមហាអំណាចនានា ហើយអ៊ីត្លែរ បានដកខ្លួនពីសន្និសីទ និងដើចេញពីសង្គមប្រជាជាតិ។ បារាំងបានបដិសេធចំពោះការកំណត់ចំនួនកងទ័ពរបស់ខ្លួន ចំណែកចក្រភពអង់គ្លេស និងសហរដ្ឋអាម៉េរិកបានបដិសេធមិនព្រមប្រព្រឹត្តតាមអ្វីដែលស្នើសុំដោយបារាំង។

ដូចបានរៀបរាប់នៅក្នុងមេរៀន សង្គ្រាមលោកលើកទី១ មកហើយថា នៅក្រោយសង្គ្រាមលោកលើកទី១ ស្ថានភាពសង្គម និងនយោបាយនៅទ្វីបអឺរ៉ុបមានភាពច្របូកច្របល់យ៉ាងខ្លាំង។ ស្ថិតនៅក្នុងស្ថានភាពនោះ របបប្រជាធិបតេយ្យសេរី ដែលទើបនឹងចាប់កំណើតនៅក្នុងបណ្តារដ្ឋប្រជាជាតិថ្មីៗមួយចំនួននៅទន់ខ្សោយនៅឡើយនោះ ត្រូវប្រឈមមុខនឹងរបបកុម្មុយនីស្ត ដែលបានចាប់កំណើតដំបូងនៅប្រទេសរុស្ស៊ីក្នុង ឆ្នាំ១៩១៧

ហើយជះឥទ្ធិពលយ៉ាងខ្លាំងក្លាទៅកាន់តំបន់ទាំងនោះ។ ស្របពេលជាមួយគ្នានោះ ដោយឆ្លៀតឱកាស នៃវិបត្តិសេដ្ឋកិច្ច វិបត្តិសង្គម និងបញ្ហានយោបាយ របបផ្តាច់ការបានលេចរូបរាងឡើងនៅក្នុងប្រទេសអ៊ីតាលី គឺរបបហ្វាស៊ីសនិយម ដែលដឹកនាំដោយ ម៉ូសូលីនី។ ក្រោយមករបបផ្តាច់ការមួយទៀតដែលមាន លក្ខណៈដូចគ្នានេះដែរ បានលេចឡើងនៅប្រទេសអាល្លឺម៉ង់ គឺរបបណាស៊ីនិយម ដែលដឹកនាំដោយអ៊ីត្លែរ។ របបផ្តាច់ការខាងលើនេះបានចាប់ផ្តើមអនុវត្តនយោបាយឈ្លានពានទៅលើប្រទេសជិតខាងជាបន្តបន្ទាប់។ ស្ថិតនៅក្នុងកាលៈទេសៈ បែបនេះមហាអំណាចអឺរ៉ុប មានបារាំង និងអង់គ្លេស ហាក់បីដូចជាគ្មានវិធានការណ៍ណាមួយ ដែលមានប្រសិទ្ធភាពសម្រាប់រារាំងមហិច្ឆតារបស់មេដឹកនាំផ្តាច់ការទាំងនោះ។ លើសពីនេះទៅទៀតសង្គមប្រជាជាតិ ដែលជាស្ថាប័នរក្សាសន្តិភាព សន្តិសុខដ៏កំពូលនៅលើពិភពលោកពេលនោះក៏គ្មានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាពិភពលោកនានាពេលនោះផងដែរ។

ចំណែកនៅអាស៊ីវិញ យើងឃើញថាប្រទេសជប៉ុន ដែលត្រូវបានបណ្តេញចេញពីប្រទេសចិន តាមរយៈសន្និសីទវ៉ាស៊ីនតោន ដោយពុំសប្បាយចិត្តនោះ បានចាប់ផ្តើមស្តារស្ថានភាពរបស់ខ្លួនឡើងវិញ ហើយបានចាប់ផ្តើមនយោបាយឈ្លានពានទៅលើតំបន់ម៉ាន់ជូរីរបស់ប្រទេសចិននៅឆ្នាំ១៩៣១។

ចំណែកសហរដ្ឋអាម៉េរិក ដែលជាមហាអំណាចដ៏ធំនាពេលនោះ បានប្រកាន់នូវនយោបាយឯកានិយមដោយមិនខ្វាយខ្វល់អំពីបញ្ហាសន្តិភាពនៅទ្វីបអឺរ៉ុបឡើយ។ អ្វីដែលអាម៉េរិក បារម្ភនៅពេលនោះគឺ ការរីករាលដាលនៃលទ្ធិកុម្មុយនីស្ត ហើយនៅពេលនោះរបបផ្តាច់ការនៅប្រទេសអ៊ីតាលី និងអាល្លឺម៉ង់ ក៏មានទិសដៅប្រឆាំងកុម្មុយនីស្តផងដែរ។

មូលដ្ឋានគ្រឹះនៃនយោបាយអាល្លឺម៉ង់ គឺក្តោបក្តាប់ និងត្រួតត្រាលើពិភពលោកទាំងមូល ហើយបន្ទាប់មកទៀតគឺកម្ទេចរបបសង្គមនិយម ដែលទើបនឹងចាប់កំណើតនៅសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត។ ដោយផ្អែកលើមូលដ្ឋានស្នូលនេះ ក្រោយពីបានឡើងកាន់អំណាចជាម្ចាស់រដ្ឋអាល្លឺម៉ង់ទាំងមូលពេញលក្ខណៈហើយ អ៊ីត្លែរបានបង្កើតកម្មវិធីនយោបាយមួយសម្រាប់គណបក្សសង្គមជាតិនិយម ឬណាស៊ីដែលមានចំណុចសំខាន់ៗដូចតទៅ៖

- ធ្វើឱ្យជាតិសាសន៍អាល្លឺម៉ង់មានឈាមបរិសុទ្ធ ហើយខ្លាំងពូកែ
- បណ្តុះមនោសញ្ចេតនាស្នេហាសង្គម និងប្រពៃណីរបស់ជនជាតិអាល្លឺម៉ង់
- ប្រមូលផ្តុំជនជាតិអាល្លឺម៉ង់ទាំងអស់ឱ្យនៅតែជុំវិញតែអ្នកដឹកនាំម្នាក់មានឋានៈជានាយកដែលគេឱ្យឈ្មោះថា ភ្យូរ័រ( FÜHRER)
- ហែកសន្ធិសញ្ញាក្រុងវែរសៃដើម្បីសម្រេចនយោបាយត្រួតត្រាពិភពលោកទាំងមូល។

## ១.២-មូលហេតុសេដ្ឋកិច្ច

ក្រោយពីលិចលង់ពេលសង្គ្រាមបានបញ្ចប់មក នៅដើមទសវត្សឆ្នាំ១៩៣០ ស្ថានភាពសេដ្ឋកិច្ចអាល្លឺម៉ង់បានរីកលូតលាស់យ៉ាងឆាប់រហ័ស ហើយនៅមុនសង្គ្រាមប្រទេសអាល្លឺម៉ង់បានងើបឡើងជា មហាអំណាចសេដ្ឋកិច្ចយ៉ាងខ្លាំងនៅក្នុងចំណោមប្រទេសនៅអឺរ៉ុប។ នយោបាយរកទីផ្សារនៅគ្រប់ទិសទីលើពិភពលោកនេះសម្រាប់ទីផ្សារឧស្សាហកម្មជាការចាំបាច់ដល់ប្រទេសអាល្លឺម៉ង់។ ការប៉ុនប៉ងនៃចក្រពត្តិនិយមនៅ អាល្លឺម៉ង់ដើម្បីយកទីផ្សារពីមហាអំណាចចក្រពត្តិនិយមអង់គ្លេស បារាំង សហរដ្ឋអាម៉េរិកនៅអាស៊ី និងនៅ អាហ្វ្រិកបានជួបប្រទះនឹងការទប់ទល់វិញយ៉ាងស្វិតស្វាញពីមហាអំណាចខាងលើ។

គួររំឭកដែរថា នៅក្នុងឆ្នាំ១៩២៩ ពិភពលោកបានជួបនូវមហាវិបត្តិមួយដ៏ធំ ដែលផ្តើមចេញពី សហរដ្ឋអាម៉េរិក ហើយបន្តទៅដល់អឺរ៉ុប និងរីកសាយភាយស្ទើរតែពាសពេញពិភពលោក។ ឆក់ឱកាសនៃវិបត្តិនេះមេដឹកនាំផ្តាច់ការនៅប្រទេសអាល្លឺម៉ង់ បានឡើងកាន់អំណាចទាំងស្រុង។

## ១.៣-បុព្វហេតុជាតិនិយម

- លើកតម្កើងជាតិសាសន៍ខ្លួនឯង
- ធ្វើឱ្យជាតិសាសន៍អាល្លឺម៉ង់មានឈាមបរិសុទ្ធ ហើយខ្លាំងពូកែ
- បណ្តុះមនោសញ្ចេតនាស្នេហាសង្គម និងប្រពៃណីរបស់ជនជាតិអាល្លឺម៉ង់
- ទ្រឹស្តីជាតិនិយមរបស់ជប៉ុន គឺអាស៊ីសម្រាប់អាស៊ី (អាស៊ីសម្រាប់ជប៉ុន)

## ១.៤-បុព្វហេតុយោធា

ដើម្បីសម្រេចបំណងជាម្ចាស់ផែនដី និងការត្រួតត្រាពិភពលោកទាំងមូលរបស់ខ្លួនហើយដោយមានការផ្សំគំនិតពីមហាអំណាចចក្រពត្តិនៅបស្ចិមប្រទេសផង អ៊ីត្លែរបានស្តាបនាឧស្សាហកម្មសឹកមួយយ៉ាង ទូលំទូលាយ។ យោធាកម្មនៃសេដ្ឋកិច្ចមានលក្ខណៈប្រកបទៅដោយគ្រោះថ្នាក់ជាទីបំផុត ហើយកងទ័ព អាល្លឺម៉ង់តែក្នុងរយៈពេលដ៏ខ្លីប្រែក្លាយទៅជាកងទ័ពមួយយ៉ាងឃោរឃៅខ្លាំងពូកែ ប្រកបដោយយុទ្ធភណ្ឌ គ្រប់សព្វសារពើយ៉ាងទំនើបព្រមទាំងមានការហ្វឹកហ្វឺន និងវិន័យយ៉ាងតឹងរឹងជាងកងទ័ពនានាទាំងអស់នៅទ្វីបអឺរ៉ុប។

ដូចបានរៀបរាប់ខាងលើមកហើយ ថាសង្គមប្រជាជាតិពុំអាចរារាំងប្រទេសអាល្លឺម៉ង់ក្នុងការស្តាបនាវិស័យយោធាឡើងវិញបានឡើយ ហើយលើសពីនេះទៅទៀតសង្គមប្រជាជាតិក៏មិនអាចកំណត់ចំនួនកងទ័ពនៃមហាអំណាចអឺរ៉ុបបានដែរ។ មិនត្រឹមតែប៉ុណ្ណោះសង្គមប្រជាជាតិក៏គ្មានប្រសិទ្ធភាពផងដែរក្នុងការ ដោះស្រាយនូវ វិបត្តិធំៗ នាពេលនោះបានឡើយ ជាក់ស្តែងដូចជាការឈ្លានពានរបស់ជប៉ុនទៅលើប្រទេសចិន នៅឆ្នាំ១៩៣១ ការឈ្លានពានរបស់ប្រទេសអ៊ីតាលី ទៅលើប្រទេសអេត្យូពីនៅឆ្នាំ១៩៣៥ ជាដើម។

នៅដើមឆ្នាំ១៩៣៩ ក្រោយពីអាល្លឺម៉ង់បានចូលឈ្លានពានកាន់កាប់ប្រទេសអូទ្រីស និងឆេកូស្លូវ៉ាគី មហាអំណាចអឺរ៉ុប ដែលឈ្នះសង្គ្រាមលោកលើកទី១ គឺបារាំង និងអង់គ្លេស ក៏ចាប់ផ្តើមភ្ញាក់ដឹងខ្លួន ពីមហិច្ឆតាវាតទីនិយមរបស់អ៊ីត្លែរ។

គណៈរដ្ឋមន្ត្រីបារាំងបានប្រជុំសម្រេចគ្នាថា គេមិនអាចបន្តទុកបណ្តោយឱ្យអ៊ីត្លែរឈ្លានពានទៅលើប្រទេសណាមួយជាថ្មីទៀតនោះទេ។ ចំណែកនាយករដ្ឋមន្ត្រីអង់គ្លេសវិញ បានចេញមុខប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៣៩ ថាប្រសិនបើអាល្លឺម៉ង់ធ្វើការឈ្លានពានទៅលើប្រទេសតូចតាចណាមួយថ្មីទៀត អង់គ្លេសនឹងចេញមុខរារាំង ដោយប្រើគ្រប់អំណាចទាំងអស់ដែលខ្លួនមាន។ ការប្រកាសនេះ គឺជាសារព្រមានយ៉ាងច្បាស់ៗទៅដល់អ៊ីត្លែរថា សង្គ្រាមនឹងត្រូវផ្ទុះឡើង បើអ៊ីត្លែរនៅតែបន្តសកម្មភាពឈ្លានពានរបស់ខ្លួនតទៅទៀត។ ក៏ប៉ុន្តែ បើទោះបីជាមានការព្រមានបែបនេះក៏ដោយ អ៊ីត្លែរនៅតែមិនខ្វល់ ហើយចាប់ផ្តើមរៀបចំអនុវត្តផែនការរបស់ខ្លួន គឺចូលឈ្លានពានប្រទេសប៉ូឡូញ ដែលទឹកដីមួយផ្នែកធំ ធ្លាប់ជារបស់អាល្លឺម៉ង់ កាលពីមុនសង្គ្រាមលោកលើកទី១។

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៣៩ មួយសប្តាហ៍ក្រោយពីបានប្រកាសធានាការពារបែលហ្ស៊ិក ហូឡង់ និងស្វ៊ីស ពីការឈ្លានពានបារាំង និងអង់គ្លេស ក៏បានចេញសេចក្តីប្រកាសរួមគ្នាមួយធានាការពារឯករាជ្យប្រទេសប៉ូឡូញ។ ពីរសប្តាហ៍ក្រោយមកទៀត នៅថ្ងៃទី១៣ ខែមេសា បារាំង និងអង់គ្លេសបានប្រកាសធានាការពារ

ប្រទេសពីរទៀត គឺ រ៉ូមានី និងក្រិក ក្រោយពីម៉ូសូលីនី មេដឹកនាំអ៊ីតាលី បានយកតម្រាប់តាមអ៊ីត្លែរ ហើយចូលឈ្លានពានកាន់កាប់ប្រទេសអាល់បានី។

ទោះជាយ៉ាងណា វិបត្តិនៅប៉ូឡូញ នៅតែជាចំណុចក្តៅ ហើយបារាំង និងអង់គ្លេសក៏ព្យាយាមបញ្ចុះបញ្ចូលសហភាពសូវៀតមួយទៀត ឱ្យចូលរួមក្នុងកិច្ចព្រមព្រៀងការពារប៉ូឡូញ ដើម្បីឱ្យមានកម្លាំងកាន់តែច្រើន ទុកកម្លាអ៊ីត្លែរ។ ក៏ប៉ុន្តែ ការចូលរួមរបស់សហភាពសូវៀត នៅក្នុងកិច្ចព្រមព្រៀងការពារ ប៉ូឡូញនេះត្រូវប្រឈមមុខនឹងបញ្ហាស្មុគស្មាញ ដោយសារតែសូវៀតក៏ជាគូសត្រូវ ដែលចាំតែឱកាសលេបត្របាក់ទឹកដីរបស់ប៉ូឡូញដែរ ដែលជាហេតុធ្វើឱ្យ រដ្ឋាភិបាលប៉ូឡូញមិនទុកចិត្ត ខ្លាចសូវៀតទាមទារកាត់យកទឹកដីមួយផ្នែក នៅខាងកើត ប៉ូឡូញ ដើម្បីជាថ្នូរនឹងការចូលមកជួយទប់ទល់នឹងអ៊ីត្លែរ។ ហេតុដូច្នេះហើយបានជារដ្ឋាភិបាលប៉ូឡូញបានជំទាស់ដាច់ខាតមិនឱ្យ កងទ័ពសូវៀតចូលមកឈរជើងនៅលើទឹកដី របស់ខ្លួន។ ការចរចារវាងបារាំង និងអង់គ្លេស ជាមួយស្តាលីន ក៏ត្រូវទទួលបរាជ័យ នៅពាក់កណ្តាលឆ្នាំ១៩៣៩។

បារាំង និងអង់គ្លេស មិនអាចទាក់ទាញស្តាលីនឱ្យចូលរួមក្នុងកិច្ចព្រមព្រៀងការពារប្រទេស ប៉ូឡូញ ពីដៃអ៊ីត្លែរ ដោយសារតែមិនមានអ្វីឱ្យសូវៀតជាថ្នូរ។ អ៊ីត្លែរវិញ ខុសពីបារាំង និងអង់គ្លេស។

តាមការពិត នៅក្នុងពេលដែលស្តាលីនកំពុងចរចាជាមួយបារាំង និងអង់គ្លេស អ៊ីត្លែរក៏បានខ្នះខ្នែងយ៉ាងខ្លាំងដែរដើម្បីបញ្ចុះបញ្ចូល សូវៀត កុំឱ្យលូកដៃចូលធ្វើអន្តរាគមន៍រារាំង ការឈ្លាន ពានរបស់អាល្លឺម៉ង់ ទៅលើ ប៉ូឡូញ ហើយអ៊ីត្លែរមានកាដូដ៏ធំមួយជាថ្នូរមកវិញ គឺសន្យាឱ្យស្តាលីនកាត់យកទឹកដីមួយផ្នែកធំ នៅប៉ែកខាងកើត ប៉ូឡូញ។ ស្តាលីនយល់ព្រម ហើយនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៣៩ សូវៀតនិងអាល្លឺម៉ង់ក៏បានចុះកិច្ចព្រមព្រៀងមិនឈ្លានពានគ្នា ដោយនៅក្នុងនោះ មានខសម្ងាត់មួយចែងថា នៅក្នុងពេលមានសង្គ្រាមរវាងអាល្លឺម៉ង់ និងប៉ូឡូញ សូវៀតអាចកាត់យកទឹកដីប៉ែកខាងកើតប៉ូឡូញ ព្រមទាំងប្រទេស ៣ នៅជុំវិញសមុទ្ទបាល់ទិក គឺឡេតូនី លីទុយអានី និងអេស្តូនី យកទៅធ្វើជាទឹកដីរបស់ខ្លួន។ ជោគវាសនារបស់ប៉ូឡូញត្រូវបានកំណត់មិនមែនដោយព្រហ្មលិខិតទេ តែដោយកិច្ចព្រមព្រៀងអ៊ីត្លែរ-ស្តាលីន។



ផែនទីអឺរ៉ុប បង្ហាញពីការពង្រីកការគ្រប់គ្រងរបស់ណាស៊ីអាល្លឺម៉ង់នៅអឺរ៉ុបត្រឹមឆ្នាំ១៩៣៩

អ៊ីត្លែរបានរៀបចំផែនការឱ្យកងទ័ពអាល្លឺម៉ង់ វាយលុកទៅតាមពីរមុខសញ្ញាព្រមៗគ្នា ក្នុងគោលដៅចូលកាន់កាប់ទីក្រុងវ៉ាសូវីរបស់ប៉ូឡូញ។ ក៏ប៉ុន្តែ អ៊ីត្លែរ នៅត្រូវការលេសសមហេតុសមផលមួយ ដើម្បីអាចចូលឈ្លានពានប៉ូឡូញ។

នៅយប់ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៣៩ កងកុម្មង់ដូអាល្លឺម៉ង់ក្នុងឯកសណ្ឋានជាទាហានប៉ូឡូញ បានបើកការវាយប្រហារទៅលើទីតាំងមួយចំនួន នៅក្នុងទឹកដីអាល្លឺម៉ង់ ក្បែរព្រំដែនជាមួយប៉ូឡូញ។ អ៊ីត្លែរបានលេសថាប៉ូឡូញជាអ្នកវាយប្រហារលើអាល្លឺម៉ង់មុន ក៏បញ្ជូនទ័ពវាយលុកចូលឈ្លានពានប៉ូឡូញ នៅព្រឹកព្រលឹមថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៣៩។



រូបគ្គុកបង្ហាញពីបែងចែកទឹកដីប៉ូឡូញ រវាងអ៊ីត្លែរ និងស្តាលីន ខែសីហា ១៩៣៩

## ២-ដំណើរប្រព្រឹត្តទៅនៃសង្គ្រាម

នៅពេលដែលសង្គ្រាមលោកលើកទីផ្ទុះឡើងនៅឆ្នាំ១៩៣៩ ប្រទេសអាល្លឺម៉ង់ជាអ្នកឈ្លានពានគេ។ នៅខែមីនា ឆ្នាំ១៩៣៩ អ៊ីត្លែរ បានវាយកម្ទេចប្រទេសឆេកូស្លូវ៉ាគី នៅខែកញ្ញាឆ្នាំ១៩៣៩ អ៊ីត្លែរ បានវាយប្រហារ ប៉ូឡូញ ហើយនៅឆ្នាំ១៩៤១ អ៊ីត្លែរបានធ្វើសង្គ្រាមទន្រ្ទានកាន់កាប់ទឹកដីដ៏ធំជាមួយសហភាពសូវៀត។ នៅខែមិថុនាឆ្នាំ១៩៤០ ប្រទេសអ៊ីតាលី បានចូលរួមជាមួយ អាល្លឺម៉ង់ ហើយនៅខែធ្នូ ឆ្នាំ១៩៤១ ប្រទេសជប៉ុន បានចូលរួមផងដែរ។

សង្គ្រាមលោកទី២ ត្រូវបានប្រវត្តិវិទូបែងចែកជាពីរដំណាក់កាលៈ

❖ ដំណាក់កាលទី១

ចាប់ផ្តើមពីខែ កញ្ញា ឆ្នាំ១៩៣៩ ដល់ខែមិថុនា ឆ្នាំ១៩៤១ ដែលជាដំណាក់កាលវាយលុករបស់កងទ័ពណាស៊ីនិយមអាល្លឺម៉ង់ ដែលរួមគ្នាក្នុងកត្តិកាសញ្ញារ៉ូម បែរឡាំង តូក្យូ។

❖ ដំណាក់កាលទី២

ផ្តើមពីខែមិថុនា ឆ្នាំ១៩៤១ ដល់ខែសីហា ឆ្នាំ១៩៤៥ ដែលជាដំណាក់កាលសង្គ្រាមប្រឆាំងនឹងពួកផាស៊ីសនិយម រំដោះទឹកដីរួចឈានចូលដល់ទីបញ្ចប់ នៅពេលដែលកងទ័ពសម្ពន្ធមិត្តចូលរំដោះទីក្រុង បែរឡាំង។

នៅក្នុងមហាសង្គ្រាមលោកនេះមានកម្លាំងពីរ ដែលប្រឈមមុខដាក់គ្នាគឺកម្លាំងវាយលុក និងឈ្លានពាន ឬហៅថាមហាអំណាចកណ្តាល និងកម្លាំងមួយទៀតហៅថាកម្លាំងសម្ពន្ធមិត្ត។

កម្លាំងមហាអំណាចកណ្តាលរួមមាន អាល្លឺម៉ង់ អ៊ីតាលី និងប្រទេសជប៉ុន។ កម្លាំងសម្ពន្ធមិត្តរួមមាន សហរដ្ឋអាម៉េរិក ចក្រភពអង់គ្លេស បារាំង សហភាពសូវៀត អូស្រ្តាលី បែលហ្ស៊ិក ប្រេស៊ីល កាណាដា ចិន ដាណឺម៉ាក ក្រិក ហូឡង់ នូវែលស្ហេឡង់ ន័រវែស ប៉ូឡូញ អាហ្វ្រិចខាងត្បូង និងយូហ្គោស្លាវី។

## ២.១-ការចាប់ផ្តើមនៃសង្គ្រាម

*ចំណុចខាងក្រោមនេះជាការដកស្រង់ទាំងស្រុងពីប្រវត្តិសាស្ត្រពិភពលោក របស់ លោក សេង ឌីណា ដែលជាការផ្សាយរបស់វិទ្យុបារាំងអន្តរជាតិ ដែលមានខ្លឹមសារដូចតទៅ៖*

នៅយប់ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៣៩ កងកុម្មង់ដូអាល្លឺម៉ង់ក្នុងឯកសណ្ឋានជាទាហានប៉ូឡូញបាន បើកការ វាយប្រហារទៅលើទីតាំងមួយចំនួន នៅក្នុងទឹកដីអាល្លឺម៉ង់ ក្បែរព្រំដែនជាមួយប៉ូឡូញ។ អ៊ីត្លែរ បាន លេសថាប៉ូឡូញជាអ្នកវាយប្រហារលើអាល្លឺម៉ង់មុន ក៏បញ្ជូនទ័ពវាយលុកចូលឈ្លានពានប៉ូឡូញ នៅ ព្រឹកព្រលឹម ថ្ងៃទី១ ខែកញ្ញា។

នៅថ្ងៃទី៣ កញ្ញា ប្រទេសបារាំង និងអង់គ្លេសបានដាក់ឱសានវាទឱ្យអ៊ីត្លែរដកកងទ័ពចេញពី ប៉ូឡូញ។ នៅយប់ថ្ងៃដដែល ឱសានវាទត្រូវផុតកំណត់ អ៊ីត្លែរមិនដកទ័ព បារាំង និងអង់គ្លេស ក៏បានប្រកាសសង្គ្រាមលើ អាល្លឺម៉ង់ ហើយសង្គ្រាមលោកលើកទី២ ក៏បានចាប់ផ្ទុះឡើង។

ក៏ប៉ុន្តែ នៅពេលនោះ បារាំង និងអង់គ្លេស ថ្វីដ្បិតតែបានប្រកាសសង្គ្រាមលើអាល្លឺម៉ង់ តែមិនបានធ្វើ សកម្មភាពយោធាអ្វីធំដុំនោះទេ ដោយទុកឱ្យប៉ូឡូញ ប្រឈមមុខនឹងកងទ័ពរបស់អ៊ីត្លែរតែម្នាក់ឯង។ មិនតែ ប៉ុណ្ណោះ ប៉ូឡូញត្រូវប្រឈមមុខនឹងកងទ័ពរបស់ស្តាលីន ដែលបានវាយលុកចូលប៉ូឡូញពីទិសខាងកើត នៅ ថ្ងៃទី១៧ ខែកញ្ញា ស្របទៅតាមអ្វីដែលបានព្រមព្រៀងគ្នាជាមួយអ៊ីត្លែរ កាលពីខែសីហា ឆ្នាំ១៩៣៩។

នៅថ្ងៃទី៦តុលា កងទ័ពប៉ូឡូញត្រូវទទួលបរាជ័យទាំងស្រុង ហើយទឹកដីប៉ូឡូញត្រូវបានអ៊ីត្លែរ និង ស្តាលីន ពុះជាពីរចែកគ្នាកាន់កាប់មួយចំណែកម្នាក់។

ក្រោយពីទទួលជ័យជម្នះនៅប៉ូឡូញ ស្តាលីនបានងាកទៅវាយលុកចូលហ្វាំងឡង់ ចំណែកអ៊ីត្លែរវិញ បានបង្វែរកងទ័ពចេញពីប៉ូឡូញ មកទិសខាងលិច ដើម្បីត្រៀមតទល់ជាមួយបារាំង និងអង់គ្លេស។ នៅ សមរភូមិទិសខាងលិចនេះ ការវាយប្រយុទ្ធគ្នាបានកើតមានតែនៅទីសមុទ្រ រវាងនាវាចម្បាំងអាល្លឺម៉ង់ និង អង់គ្លេស ហើយជាថ្មីម្តងទៀត អាល្លឺម៉ង់បានប្រើតាក់ទិកដដែល ដូចកាលពីសង្គ្រាមលោកលើកទី១ គឺប្រើនាវា មុជទឹកបាញ់ពន្លិចនាវាដឹកទំនិញចេញចូលប្រទេសអង់គ្លេស។

រហូតដល់ជិតពាក់កណ្តាលឆ្នាំ១៩៤០ ទើបសមរភូមិជើងគោកទ្រង់ទ្រាយធំបានចាប់ផ្តើមឡើង ក្រោយ ពីទាហានអ៊ីត្លែរបានវាយលុកទៅលើន័រវែស ដាណឺម៉ាក បន្ទាប់មកទៅលើហូឡង់ និងបែលហ្ស៊ិក ហើយឆ្លង ចូលទៅក្នុងប្រទេសបារាំង នៅខែឧសភា ឆ្នាំ១៩៤០។

## ២.២-អាល្លឺម៉ង់ឈ្លានពានប្រទេសបារាំង

នៅពេលសង្គ្រាមលោកលើកទី២ ចាប់ផ្ទុះឡើង នៅខែកញ្ញា ឆ្នាំ១៩៣៩ បារាំង ថ្វីដ្បិតតែមានចំនួន ប្រជាជនតិចជាងអាល្លឺម៉ង់ដល់ទៅពីរដង ក៏ប៉ុន្តែ ប្រទេសទាំងពីរមានកម្លាំងទ័ពប្រហាក់ប្រហែលគ្នា។ ចំណុច ដែលខុសគ្នា ហើយដែលនាំឱ្យបារាំងត្រូវទទួលបរាជ័យ ធ្លាក់ក្រោមការកាន់កាប់របស់អ៊ីត្លែរ គឺយុទ្ធសាស្ត្រទ័ព។

យុទ្ធសាស្ត្រទ័ពរបស់បារាំង នៅពេលនោះ គឺពឹងផ្អែកខ្លាំងទៅលើខ្សែក្រវ៉ាត់ការពារ ដែលបារាំងបាន សង់នៅតាមបណ្តោយព្រំដែនជាមួយអាល្លឺម៉ង់ តាំងពីក្រោយសង្គ្រាមលោកលើកទី១។ ខ្សែក្រវ៉ាត់ការពារនេះ ត្រូវបានគេឱ្យឈ្មោះថា "Ligne Maginot" ដោយយកតាមឈ្មោះរបស់អតីតរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសង្គ្រាម របស់បារាំង ដែលជាអ្នកផ្តួចផ្តើមគំនិតសាងសង់ គឺលោក André Maginot។

បារាំងបានផ្តោតអាទិភាពខ្ពស់ និងចំណាយថវិកាការពារជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅលើការ សាងសង់ Ligne Maginot ដោយសារតែគិតថា វាគឺជាខ្សែក្រវ៉ាត់ការពារដ៏រឹងមាំបំផុត ដែលកងទ័ពអាល្លឺម៉ង់មិន

អាចឆ្លងកាត់បាន។ ជាការពិត នៅក្នុងយុទ្ធសាស្ត្រឈ្លានពានលើប្រទេសបារាំង មេទ័ពរបស់អ៊ីត្លែរក៏មិនបានព្យាយាមវាយលុកកាត់តាម Ligne Maginot ដ៏រឹងមាំនេះដែរ ប៉ុន្តែវាយលុកចូលតាមច្រកផ្សេង គឺកាត់តាមប្រទេសបែលហ្សិក ដែលមានព្រំដែនជាប់ជាមួយនឹងប្រទេសបារាំង ហើយដែលបារាំងមិនមានប្រព័ន្ធការពាររឹងមាំ ដោយសារតែនៅពេលនោះ បែលហ្សិកជាប្រទេសអព្យាក្រឹត ហើយមិនមែនជាគូសត្រូវរបស់បារាំង។

នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៤០ កងទ័ពអាល្លឺម៉ង់ បានបើកការវាយលុកចូលឈ្លានពានប្រទេសបីព្រមៗគ្នា គឺលុចសំបួ ហូឡង់ និងបែលហ្សិក ហើយ៣ថ្ងៃក្រោយមកទៀត កងទ័ពអាល្លឺម៉ង់ក៏បានវាយលុកឆ្លងពីបែលហ្សិកចូលមកដល់ប្រទេស បារាំង រួចហើយវាយបំបាក់កងទ័ពបារាំង នៅត្រង់ទន្លេ Meuse នៅក្រុង Sedan ក្បែរព្រំដែនបែលហ្សិក។

ប្រឈមមុខនឹង«សង្គ្រាមផ្លេកបន្ទោរ» របស់អាល្លឺម៉ង់ ទាហានបារាំងរាប់ម៉ឺននាក់ដែលឈរជើងនៅសមរភូមិទិសខាងជើង ក្បែរព្រំដែនបែលហ្សិក បាននាំគ្នាទម្លាក់អាវុធចុះចាញ់ ហើយសុខចិត្តក្លាយជាឈ្លើយសឹករបស់អាល្លឺម៉ង់។ ក៏ប៉ុន្តែ មិនមែនទាហានបារាំងទាំងអស់សុទ្ធតែសុខចិត្តទម្លាក់អាវុធចុះចាញ់នោះទេ។ នៅថ្ងៃទី១៧ ឧសភា ឧត្តមសេនីយ៍ Charles de Gaulle ដែលទើបនឹងត្រូវបានតែងតាំងឱ្យធ្វើជាមេបញ្ជាការកងពលរថក្រោះបារាំង បាននាំកងពលរបស់លោកចូលទៅវាយស្ទាក់បង្អាក់ដំណើរកងទ័ពអាល្លឺម៉ង់ ដើម្បីឱ្យកងទ័ពបារាំងមានពេលរៀបចំខ្សែត្រៀមការពារក្រុងប៉ារីស។ ក៏ប៉ុន្តែ កងរថក្រោះរបស់ Charles de Gaulle ក៏មិនអាចទប់ទល់នឹងកងរថក្រោះ Panzer របស់អាល្លឺម៉ង់បានយូរប៉ុន្មាននោះដែរ។

គិតត្រឹមចុងខែឧសភា ឆ្នាំ១៩៤០ ខ្សែត្រៀមបារាំង នៅប៉ែកខាងជើងប្រទេសត្រូវដួលរលំស្ទើរតែទាំងស្រុង ហើយអង់គ្លេស ដែលជាសម្ពន្ធមិត្តរបស់បារាំងក៏បានចាប់ផ្តើមជម្លៀសកងទ័ពរបស់ខ្លួន រួមជាមួយនឹងទាហានបារាំងជាង ១០ម៉ឺននាក់ ចេញតាមកប៉ាល់ ពី Dunkerque ឆ្ពោះទៅអង់គ្លេស។ នៅទិសខាងត្បូងឯណោះវិញ បារាំងក៏ត្រូវប្រឈមមុខនឹងសត្រូវមួយទៀត គឺអ៊ីតាលី ក្រោមការដឹកនាំរបស់មូសូលីនីសម្ពន្ធមិត្តរបស់អ៊ីត្លែរ ដែលបានប្រកាសសង្គ្រាមលើបារាំង នៅថ្ងៃទី១០មិថុនា។ នៅថ្ងៃទី១៤ មិថុនា ឆ្នាំ១៩៤០ កងទ័ពអាល្លឺម៉ង់បានវាយលុកចូលដល់ក្រុងប៉ារីស ចំណែករដ្ឋាភិបាលបារាំងបានភៀសខ្លួនចេញពីប៉ារីស ហើយទៅតាំងទីស្នាក់ការនៅទីក្រុង Bordeaux នៅខាងត្បូងឆៀងខាងលិចប្រទេសបារាំង។ ៣ថ្ងៃក្រោយការដួលរលំក្រុងប៉ារីស ដោយប្រឈមមុខនឹងបរាជ័យនេះ នាយករដ្ឋមន្ត្រីបារាំង Paul Reynaud បានចុះចេញពីតំណែង ហើយសេនាប្រមុខ Philippe Pétain ដែលជាឧបនាយករដ្ឋមន្ត្រី ត្រូវបានតែងតាំងឱ្យឡើងមកកាន់តំណែងជំនួសលោក Paul Reynaud។

គ្រាន់តែបានឡើងមកកាន់តំណែងជានាយករដ្ឋមន្ត្រីបារាំងភ្លាម សេនាប្រមុខ Pétain បានស្នើភ្លាមៗ ទៅអាល្លឺម៉ង់ ដើម្បីសុំចរចាចុះចាញ់សង្គ្រាម។ មួយថ្ងៃក្រោយមក គឺនៅថ្ងៃទី១៨ មិថុនា ឧត្តមសេនីយ៍ Charles de Gaulle ដែលទើបនឹងត្រូវបានតែងតាំងជាអនុរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសង្គ្រាម ហើយដែលកំពុងស្ថិតនៅក្នុងទីក្រុងឡុងដ៍ ក៏បានធ្វើសេចក្តីថ្លែងការណ៍មួយ តាមរយៈវិទ្យុ BBC ដោយបានរិះគន់សេចក្តីសម្រេចរបស់សេនាប្រមុខ Pétain ហើយបានអំពាវនាវឱ្យប្រជាជនបារាំងនាំគ្នាងើបឡើងកាន់អាវុធ ដើម្បីបន្តប្រឆាំងនឹងកងទ័ពអាល្លឺម៉ង់។ តាមរយៈសេចក្តីថ្លែងការណ៍នេះ ឧត្តមសេនីយ៍ Charles de Gaulle ត្រូវបានរដ្ឋាភិបាលរបស់លោក Pétain កាត់ទោសដោយកំបាំងមុខពីបទក្បត់ជាតិ ក៏ប៉ុន្តែចលនាតស៊ូបារាំងប្រឆាំងនឹងអាល្លឺម៉ង់ក៏បានចាប់កំណើតឡើងដែរ។




ផែនទី ប្រទេសបារាំងក្នុងសង្គ្រាមលោកលើកទី២ ដែលបង្ហាញពីការពុះចែកទឹកដីបារាំងជា ៣ផ្នែក៖ ពណ៌ក្រហមកាន់កាប់ដោយ អាល្លឺម៉ង់, ពណ៌បៃតងខ្ចីកាន់កាប់ដោយអ៊ីតាលី និងពណ៌ស្វាយកាន់កាប់ដោយរដ្ឋាភិបាលរបស់សេនាប្រមុខ Philippe Pétain

នៅថ្ងៃ ទី២២ មិថុនា រដ្ឋាភិបាលរបស់លោក Pétain បានចុះកិច្ចព្រមព្រៀងចុះចាញ់សង្គ្រាមជាមួយ អាល្លឺម៉ង់ ហើយតាមរយៈកិច្ចព្រមព្រៀងនេះ ទឹកដីបារាំងត្រូវបានពុះចែកជា ៣ចំណែក។ ទឹកដីពាក់កណ្ដាល នៅប៉ែកខាងជើងដោយរួមបញ្ចូលទាំងទីក្រុងប៉ារីសផង ត្រូវស្ថិតក្រោមការកាន់កាប់របស់ អាល្លឺម៉ង់។ មួយផ្នែក តូចនៅប៉ែកខាងត្បូងត្រូវស្ថិតក្រោមការកាន់កាប់របស់អ៊ីតាលី។ ចំណែកទឹកដីដែលនៅសេសសល់នៅ ប៉ែក កណ្ដាល គ្រប់គ្រងដោយរដ្ឋាភិបាលរបស់លោក Pétain ដែលបានទៅតាំងរដ្ឋធានី នៅទីក្រុង Vichy។

នៅលើក្រដាស រដ្ឋបារាំង ក្រោមការដឹកនាំរបស់លោក Pétain ត្រូវបានចាត់ទុកជារដ្ឋអធិបតេយ្យមួយ ក៏ប៉ុន្តែជាតុពិតជាក់ស្ដែង គឺជារដ្ឋាភិបាលរណបអាល្លឺម៉ង់សុទ្ធសាធ។ អ៊ីត្លែរបានតម្រូវឱ្យទ័ពជើងទឹកបារាំង ទាំងអស់ត្រូវរំសាយអាវុធ ចំណែកឯទ័ពជើងគោកវិញ មិនត្រូវឱ្យមានចំនួនលើសពី ១០ម៉ឺននាក់។ ចំណែក ទាហានបារាំងទាំងអស់ ដែលអាល្លឺម៉ង់បានចាប់ជាឈ្លើយសឹក ត្រូវបន្តជាប់ឃុំ នៅក្នុងប្រទេសអាល្លឺម៉ង់ ដោយ មិនអាចវិលត្រឡប់មកប្រទេសបារាំងបានវិញនោះទេ។ លើសពីនេះទៅទៀត រាល់ការចំណាយទាំងអស់របស់ កងទ័ពអាល្លឺម៉ង់ ដែលកាន់កាប់ទឹកដីពាក់កណ្ដាលប៉ែកខាងជើងប្រទេសបារាំង គឺត្រូវទទួលរ៉ាប់រងដោយថវិកាជាតិ បារាំង។

និយាយដោយខ្លី អ៊ីត្លែរចង់សង្កត់ក្បាលបារាំងឱ្យរាបដល់ដី ដើម្បីឱ្យបារាំងទទួលនូវភាពអាម៉ាស់ ដូចអ្វី ដែលអាល្លឺម៉ង់បានទទួលដោយសន្ធិសញ្ញាក្រុង Versailles នៅក្រោយសង្គ្រាមលោកលើកទី១។ តាមការពិត អ្វីដែលអ៊ីត្លែរបានដាក់លើបារាំង មានភាពធ្ងន់ធ្ងរជាងអ្វីដែលសន្ធិសញ្ញាក្រុង Versailles ដាក់លើអាល្លឺម៉ង់

ឆ្ងាយណាស់ ពីព្រោះថា អាល្លឺម៉ង់ក្រោយសង្គ្រាមលោកលើកទី១ យ៉ាងហោចណាស់ ក៏អាចរក្សាទឹកដីរបស់ខ្លួនបានទាំងមូល ដោយគ្មានកងទ័ពបរទេសគ្រប់គ្រង ហើយទាហានអាល្លឺម៉ង់ក៏មិនត្រូវបានគេចាប់ឃុំជាឈ្លើយសឹកនោះដែរ។

## ២.៣-អាល្លឺម៉ង់វាយប្រហារអង់គ្លេស

នៅពាក់កណ្តាលខែមិថុនា ឆ្នាំ១៩៤០ កងទ័ពរបស់អ៊ីត្លែរបានវាយចូលកាន់កាប់ក្រុងប៉ារីស ធ្វើឱ្យរដ្ឋាភិបាលបារាំង ដែលដឹកនាំដោយសេនាប្រមុខ Philippe Pétain ចរចាសុំចុះចាញ់ ហើយសុខចិត្តធ្វើជារដ្ឋវណបរបស់អាល្លឺម៉ង់។

បន្ទាប់ពីយកជ័យជម្នះលើបារាំងបានហើយ អ៊ីត្លែរក៏បានងាកទៅរកអង់គ្លេសវិញម្តង ដោយចង់យកទឹកដីប៉ែកខាងជើងរបស់បារាំងធ្វើជាមូលដ្ឋាន ក្នុងការវាយប្រហារលើអង់គ្លេស។

ក៏ប៉ុន្តែ អង់គ្លេសខុសពីបារាំងនៅត្រង់ថា ប្រទេសអង់គ្លេសគឺជាកោះ ដែលមានសមុទ្រជាខែលការពារ។ ដូច្នេះ បើសិនជាអ៊ីត្លែរចង់ចូលឈ្លានពានអង់គ្លេស គឺចាំបាច់ត្រូវតែបញ្ជូនកងទ័ពឆ្លងកាត់ច្រកសមុទ្រ English Channel (នៅចន្លោះអង់គ្លេស និងឆ្នេរប៉ែកខាងជើងប្រទេសបារាំង) ដែលជាមិនមែនជារឿងងាយស្រួលនោះទេ ដោយសារតែចក្រភពអង់គ្លេសនៅពេលនោះ គឺជាមហាអំណាចខាងទ័ពជើងទឹកដ៏ធំមួយ នៅលើពិភពលោក ចំណែកឯទ័ពជើងទឹករបស់អាល្លឺម៉ង់វិញកំពុងតែមានសភាពទន់ខ្សោយយ៉ាងខ្លាំង ក្រោយពីទទួលរងការខូចខាតយ៉ាងដំណំ នៅក្នុងប្រតិបត្តិការឈ្លានពានប្រទេសន័រវែស កាលពីខែមេសា ១៩៤០។

តាមការពិត អ៊ីត្លែរក៏មិនចង់ធ្វើសង្គ្រាមទល់នឹងចក្រភពអង់គ្លេសដែរ។ បើសិនជាអង់គ្លេសយល់ព្រមអ៊ីត្លែរ សប្បាយចិត្តនឹងចុះកិច្ចព្រមព្រៀងជាមួយអង់គ្លេស ដើម្បីចែកអំណាចគ្នា គឺអង់គ្លេសធ្វើជាមហាអំណាចជើងទឹក ចំណែកអាល្លឺម៉ង់ជាមហាអំណាចខាងជើងគោក។ នៅពាក់កណ្តាលខែកក្កដា ឆ្នាំ១៩៤០ អ៊ីត្លែរបានប្រកាសជាសាធារណៈស្នើឱ្យមានការចរចាបញ្ចប់សង្គ្រាមជាមួយអង់គ្លេស។ នៅពេលនោះ មានអ្នកនយោបាយ ព្រមទាំងសមាជិករាជវង្សមួយចំនួនរបស់អង់គ្លេសចង់ឱ្យអង់គ្លេសចរចា ជាមួយអ៊ីត្លែរ ដើម្បីបញ្ចៀសសង្គ្រាម។ ក៏ប៉ុន្តែ លោក Winston Churchill ដែលទើបនឹងឡើងមកកាន់តំណែងជានាយករដ្ឋមន្ត្រីអង់គ្លេស ជំនួសលោក Neville Chamberlain បានជាងពីរខែ បានប្រកាន់ជំហរយ៉ាងតឹងរ៉ឹងថា ក្នុងឋានៈជាមហាអំណាចដែលមានកិត្តិយស និងសម្ដីថ្លៃថ្នូរ អង់គ្លេសមិនអាចយកតែរួចខ្លួន ហើយសុខចិត្តឱ្យអ៊ីត្លែរកាន់កាប់ប្រទេសនៅអឺរ៉ុបដែនគោក ដែលជាសម្ពន្ធមិត្តរបស់អង់គ្លេស ហើយដែលអង់គ្លេសធ្លាប់បានចុះកិច្ចព្រមព្រៀងសន្យាថានឹងជួយការពារ នោះទេ។

ដោយមិនអាចបញ្ចុះបញ្ចូលអង់គ្លេសឱ្យចូលមកចរចាបញ្ចប់សង្គ្រាមនឹងគ្នាបាន អ៊ីត្លែរក៏បានដាក់បញ្ជាឱ្យទ័ពអាល្លឺម៉ង់ចាប់ផ្តើមអនុវត្តផែនការ ដែលបានរៀបចំទុកតាំងពីមុន គឺការបញ្ជូនទ័ពឆ្លងសមុទ្រ ដើម្បីចូលឈ្លានពានលើអង់គ្លេស។ ប្រតិបត្តិការ ដែលអ៊ីត្លែរដាក់ឈ្មោះថា «ប្រតិបត្តិការតោសមុទ្រ»(Operation Sea Lion)។ ប៉ុន្តែ ដើម្បីឱ្យ «តោសមុទ្រ» របស់អ៊ីត្លែរអាចឆ្លងទៅឈ្លានពានអង់គ្លេសបាន អាល្លឺម៉ង់ចាំបាច់ត្រូវតែធ្វើយ៉ាងណាគ្រប់គ្រងច្រកសមុទ្រ English Channel ឱ្យបានជាមុនសិន ហើយ ដោយសារតែនាវាចម្បាំងរបស់ អាល្លឺម៉ង់ភាគច្រើនត្រូវខូចខាតក្នុងប្រតិបត្តិការឈ្លានពានលើន័រវែស កាលពីប៉ុន្មានខែមុន អ៊ីត្លែរមានតែពឹងលើយន្តហោះចម្បាំង។

នៅខែកក្កដា ឆ្នាំ១៩៤០ អ៊ីត្លែរក៏បានបញ្ជាឱ្យកងទ័ពអាកាស អាល្លឺម៉ង់បើកប្រតិបត្តិការវាយ កម្ទេចទ័ពអាកាស ព្រមទាំងប្រព័ន្ធការពារឆ្នេរសមុទ្រអង់គ្លេស ដើម្បីគ្រប់គ្រងច្រកសមុទ្រ English Channel។ ក៏

ប៉ុន្តែ ខុសពីការរំពឹងទុករបស់អ៊ីត្លែរ កងទ័ពអាកាសរបស់អង់គ្លេសមិនងាយនឹងឱ្យអាល្លឺម៉ង់វាយបំបាក់បានងាយៗ នោះទេ។ តាមការពិត នៅក្នុងរយៈពេល ២សប្តាហ៍ដំបូង គឺពីពាក់កណ្តាលខែ ដល់ចុងខែកក្កដា គឺ អាល្លឺម៉ង់ទៅវិញទេ ដែលទទួលរងការខូចខាតច្រើនជាងអង់គ្លេស ដោយមានយន្តហោះរហូតដល់ទៅ ១៨០ គ្រឿងត្រូវអង់គ្លេសបាញ់ទម្លាក់ ក្នុងពេលដែលអង់គ្លេសត្រូវបាត់បង់យន្តហោះតែ ៧០គ្រឿង។ នៅខែកញ្ញា ឆ្នាំ ១៩៤០ ដោយមើលឃើញថា ដែនអាកាសក៏មិនអាចគ្រប់គ្រងបាន ហើយដែនទឹកក៏កាន់តែពិបាកនឹងយកប្រៀបលើអង់គ្លេសទៅទៀត អ៊ីត្លែរក៏បានសម្រេចលុបចោលគម្រោងបញ្ជូនកងទ័ពឱ្យឆ្លងសមុទ្រចូលទៅឈ្លានពានអង់គ្លេស។ ក៏ប៉ុន្តែ នៅពេលនោះ អ៊ីត្លែរមិនបានបញ្ឈប់ការវាយប្រហារតាមផ្លូវអាកាសទៅលើអង់គ្លេសនោះទេ។ ចាប់ពីថ្ងៃទី៧ ខែកញ្ញា អ៊ីត្លែរបានបង្វែរប្រតិបត្តិការទ័ពអាកាសពីការវាយបើកច្រកផ្លូវ ដើម្បីចូលឈ្លានពាន ទៅជាប្រតិបត្តិការទម្លាក់គ្រាប់បែកកម្ទេចទីក្រុងធំៗរបស់អង់គ្លេស វិញក្នុងគោលដៅធ្វើយ៉ាងណាបង្កការខូចខាតជាអតិបរមា ដើម្បីបង្ខំឱ្យអង់គ្លេសងាកមកចរចាបញ្ចប់សង្គ្រាម។

នៅក្នុងចន្លោះពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៤០ ដល់ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៤១ គ្រាប់បែកប្រមាណ ១០០តោន ត្រូវបានយន្តហោះអាល្លឺម៉ង់ទម្លាក់ទៅលើទីក្រុងធំៗចំនួន១៦ក្រុងរបស់អង់គ្លេស ជាពិសេស គឺទីក្រុងឡុងដ៍ ដោយបានបណ្តាលឱ្យជនស៊ីវិលអង់គ្លេសប្រមាណ៤ម៉ឺននាក់ត្រូវបាត់បង់ជីវិត អគាររោងចក្រព្រមទាំងផ្ទះសម្បែងរាប់លានខ្នងត្រូវទទួលរងនូវការបំផ្លិចបំផ្លាញ។ ប៉ុន្តែ ជាថ្មីម្តងទៀត ប្រតិបត្តិការទម្លាក់គ្រាប់បែកនេះក៏មិនបានសម្រេចទៅតាមគោលដៅដែល អ៊ីត្លែរចង់បាននោះដែរ ពីព្រោះថា វាមិនបានធ្វើឱ្យសេដ្ឋកិច្ចអង់គ្លេសត្រូវទទួលរងនូវការខូចខាតធ្ងន់ធ្ងរ ឬក៏ធ្វើឱ្យអង់គ្លេសបាក់ទឹកចិត្ត ហើយងាកមកចរចាបញ្ចប់សង្គ្រាមជាមួយអាល្លឺម៉ង់នោះទេ។

ផ្ទុយទៅវិញ ការទម្លាក់គ្រាប់បែកលើទីក្រុងឡុងដ៍ ដែលបានកម្ទេចផ្ទះសម្បែង ព្រមទាំងសម្លាប់ ប្រជាជនស៊ីវិលរាប់ម៉ឺននាក់ បានធ្វើឱ្យប្រជាជនអង់គ្លេសកាន់តែមានកំហឹងចំពោះអ៊ីត្លែរ ហើយនាំគ្នាគាំទ្រ រដ្ឋាភិបាល និងកងទ័ពអង់គ្លេសកាន់តែខ្លាំង ក្នុងការប្រយុទ្ធតទល់នឹងអាល្លឺម៉ង់។ បើនិយាយពីខាងផ្នែក សេដ្ឋកិច្ចវិញ ប្រតិបត្តិការទម្លាក់គ្រាប់បែកដោយឥតលោះថ្ងៃ នៅក្នុងរយៈពេល ៨ខែនេះ ក៏មិនបានធ្វើឱ្យសកម្មភាពផលិតកម្មរបស់អង់គ្លេសត្រូវធ្លាក់ចុះនោះដែរ។ វិស័យឧស្សាហកម្មយោធារបស់អង់គ្លេស មិនត្រឹមតែមិនធ្លាក់ចុះនោះទេ តែថែមទាំងកើនឡើងទៅវិញ។

លើសពីនេះទៅទៀត នៅដើមឆ្នាំ១៩៤១ អង់គ្លេសចាប់ផ្តើមទទួលបាននូវជំនួយផ្នែកយោធាពីប្រទេសដ៏សំខាន់មួយ គឺសហរដ្ឋអាម៉េរិក។ នៅខែមីនា ឆ្នាំ១៩៤១ សភាអាម៉េរិកបានអនុម័តច្បាប់មួយ (Lend-Lease Act) ដោយអនុញ្ញាតឱ្យប្រធានាធិបតីអាម៉េរិក គឺលោក Franklin Roosevelt បញ្ជូនគ្រឿងសព្វាវុធទៅជួយអង់គ្លេស ហើយខុសពីកាលសម័យសង្គ្រាមលោកលើកទី១ គ្រឿងសព្វាវុធអស់ទាំងនេះត្រូវបានផ្តល់ទៅឱ្យអង់គ្លេសក្នុងទ្រង់ទ្រាយជាជំនួយឥតសំណង។ ជំនួយយោធារបស់អាម៉េរិក បានធ្វើឱ្យអង់គ្លេសមានកម្លាំងកាន់តែខ្លាំង ក្នុងការប្រយុទ្ធតទល់នឹងអាល្លឺម៉ង់។ នៅទីចុងបញ្ចប់ អ៊ីត្លែរត្រូវប្រឈមមុខនឹងតថភាពមួយ គឺទឹកដីរបស់អង់គ្លេសជាដែនកោះដែលមិនអាចចូលឈ្លានពានបាន។ អ៊ីត្លែរក៏បានសម្រេចផ្អាកប្រតិបត្តិការយោធានៅអង់គ្លេស ហើយងាកទៅអឺរ៉ុបខាងកើតវិញម្តង ដោយចាប់ផ្តើមអនុវត្តគម្រោងការចូលឈ្លានពានសហភាពសូវៀត ដែលអ៊ីត្លែរធ្លាប់បានចុះកិច្ចព្រមព្រៀងមិនឈ្លានពានគ្នារួចទៅហើយ នៅមុនពេលចូលឈ្លានពានប៉ូឡូញ កាលពីឆ្នាំ១៩៣៩។

## ២.៤-អាល្លឺម៉ង់ឈ្លានពានសូវៀត

នៅពាក់កណ្តាលឆ្នាំ១៩៤១ ក្រោយពីទទួលបរាជ័យ មិនអាចឈ្លានពានកាន់កាប់ប្រទេសអង់គ្លេស ហើយក៏មិនអាចបង្ខំឱ្យអង់គ្លេសចូលមកចរចា ចែកអំណាចគ្នាគ្រប់គ្រង អឺរ៉ុបបាន អ៊ីត្លែរ ក៏បានផ្អាកសកម្មភាពយោធានៅអឺរ៉ុបខាងលិច ហើយងាកទៅរកអឺរ៉ុបខាងកើតវិញម្តង។ គោលដៅរបស់អ៊ីត្លែរ គឺចូលឈ្លានពានសហភាពសូវៀត។

តាមការពិត នៅមុនពេលសង្គ្រាមលោកលើក ទី២ ចាប់ផ្តើមផ្ទុះឡើង អ៊ីត្លែរ និងស្តាលីន បានព្រមព្រៀងសហការគ្នា និងបែងចែកដែនឥទ្ធិពលគ្នា តាមរយៈការចុះសន្ធិសញ្ញាមិនឈ្លានពានគ្នា កាលពីខែសីហា ឆ្នាំ១៩៣៩ ពោលគឺនៅតែប៉ុន្មានសប្តាហ៍ប៉ុណ្ណោះ មុនពេលអាល្លឺម៉ង់ចូលឈ្លានពានប៉ូឡូញ។ នៅខែកញ្ញា នៅពេលអ៊ីត្លែរបញ្ជូនទ័ពចូលឈ្លានពានប៉ូឡូញពីទិសខាងលិច កងទ័ពរបស់ស្តាលីនក៏វាយលុកមកលើប៉ូឡូញចូលតាមទិសខាងកើតដែរ ហើយប្រទេសប៉ូឡូញក៏ត្រូវបាន អ៊ីត្លែរ និងស្តាលីនពុះជាពីរចែកគ្នាកាន់កាប់។ បន្ទាប់ពីបានកាន់កាប់ប៉ូឡូញម្នាក់មួយចំណែកហើយ អ៊ីត្លែរបានបន្តធ្វើការឈ្លានពានអឺរ៉ុបដោយវាតទីទៅទិសខាងលិច គឺឈ្លានពានប្រទេសន័រវែស ដាណឺម៉ាក ហូឡង់ លុចសំបួ បែលហ្ស៊ិក បារាំង និងអង់គ្លេស (តែមិនបានសម្រេច)។ ចំណែកស្តាលីនវិញ វាតទីនៅទិសខាងកើត ដោយឈ្លានពានហ្វាំងឡង់ ប្រទេសបីនៅជុំវិញសមុទ្របាល់ទិក គឺលីទុយអានី ឡេតូនី និងអេស្តូនី ព្រមទាំងចូលកាន់កាប់ទឹកដីមួយផ្នែករបស់ប្រទេស រូម៉ានី។

បើពិនិត្យមើលជារួម នៅឆ្នាំដំបូងនៃសង្គ្រាមលោកលើកទី២ អាល្លឺម៉ង់ និងសហភាពសូវៀតមានទំនាក់ទំនងល្អនឹងគ្នា ទាំងខាងផ្នែកការទូត និងសេដ្ឋកិច្ច។ ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា អ៊ីត្លែរ និងស្តាលីនសំឡឹងមើលគ្នាទៅវិញទៅមកប្រកបដោយការមិនទុកចិត្តគ្នា ហើយម្ខាងៗ សុទ្ធតែនាំគ្នាត្រៀមជើងព្រួល រៀងៗខ្លួនដើម្បីត្រៀមធ្វើសង្គ្រាមនឹងគ្នា។ តាមការពិត នៅពេលដែលអាល្លឺម៉ង់ និងសហភាពសូវៀតចុះសន្ធិសញ្ញាមិនឈ្លានពានគ្នា អ្នកណាៗក៏មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដែរ ដោយសារតែគេមើលឃើញពីភាពជាសត្រូវនឹងគ្នារវាងគណបក្សណាហ្ស៊ីអាល្លឺម៉ង់ និងគណបក្សកុម្មុយនិស្តសូវៀត។ សម្រាប់អ៊ីត្លែរ ក្រុមបុលឆេវិកសូវៀតសុទ្ធតែជាក្រុមបម្រើផលប្រយោជន៍ឱ្យពួកជ្វីហ្វ។

ម្យ៉ាងទៀត នៅក្នុងសៀវភៅ Mein Kampf (ការតស៊ូរបស់ខ្ញុំ)ដែលអ៊ីត្លែរសរសេរកាលពីមុនពេលឡើងកាន់អំណាច អ៊ីត្លែរក៏បានបង្ហើបឱ្យដឹងផងដែរ អំពីគម្រោងចង់ឈ្លានពានកាន់កាប់ សហភាពសូវៀតដោយអ៊ីត្លែរលើកឡើងថា អាល្លឺម៉ង់ត្រូវការពង្រីកទឹកដី ដើម្បីឱ្យប្រជាជនរស់នៅផង និងដើម្បីទាញយកធនធានធម្មជាតិផង ហើយទឹកដីនេះ អាល្លឺម៉ង់ត្រូវពង្រីកទៅទិសខាងកើត។ ក្រោយៗមកទៀត នៅពេលបានឡើងកាន់អំណាច អ៊ីត្លែរបានបង្ហាញនូវចក្ខុវិស័យកាន់តែច្បាស់ថា ទៅថ្ងៃអនាគត អាល្លឺម៉ង់ប្រាកដជាចៀសមិនផុតនឹងចូលឈ្លានពានកាន់កាប់សហភាពសូវៀត នោះទេ ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា អ៊ីត្លែរក៏បានគិតទុកជាមុនផងដែរថា នៅក្នុងដំហានដំបូង អាល្លឺម៉ង់អាចសហការជាមួយសូវៀតជាបណ្តោះអាសន្ន ប្រសិនបើវាអាចផ្តល់ផលប្រយោជន៍ដល់អាល្លឺម៉ង់។

នៅចុងឆ្នាំ១៩៤០ អ៊ីត្លែរបានចេញបញ្ជាឱ្យមេទ័ពអាល្លឺម៉ង់រៀបចំគម្រោងការឈ្លានពាន សហភាពសូវៀត ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា អ៊ីត្លែរបានព្យាយាមទាក់ទាញស្តាលីនឱ្យចូលរួមក្នុងបក្សសម្ពន្ធត្រីភាគី រួមជាមួយនឹងអ៊ីតាលី និងជប៉ុន ដើម្បីបង្កើតជាបក្សសម្ពន្ធចតុភាគីអាល្លឺម៉ង់-អ៊ីតាលី-ជប៉ុន-សូវៀត។

ស្តាលីនក៏ដឹងអំពីចេតនារបស់អ៊ីត្លែរដែលចង់លេបយកទឹកដីសហភាពសូវៀតដែរ។ ក៏ប៉ុន្តែ ស្តាលីន គិតថា ការចូលក្នុងបក្សសម្ពន្ធជាមួយអ៊ីត្លែរយ៉ាងហោចណាស់ក៏អាចបញ្ចៀស សង្គ្រាមជាមួយអាល្លឺម៉ង់បាន មួយរយៈដែរ ដើម្បីទុកពេលឱ្យសូវៀតអាចពង្រឹងកម្លាំងទ័ពទុកទប់ទល់នឹងអ៊ីត្លែរ។ នៅខែវិច្ឆិកា ឆ្នាំ១៩៤០ ស្តាលីនក៏បានបញ្ជូនរដ្ឋមន្ត្រីក្រសួងការបរទេសឱ្យទៅចរចា ជាមួយអាល្លឺម៉ង់ អំពីការចូលក្នុងបក្សសម្ពន្ធអ៊ីត្លែរ។

នៅពេលបើកកិច្ចចរចា រដ្ឋមន្ត្រីការបរទេសអាល្លឺម៉ង់បានប្រាប់ទៅសមភាគីសូវៀតថា បើមើលទៅលើ ស្ថានភាពយោធាបច្ចុប្បន្ន បក្សសម្ពន្ធត្រីភាគីប្រាកដជានឹងទទួលជោគជ័យក្នុងសង្គ្រាមលោកលើកទី២នេះ គ្រាន់តែមិនដឹងថាតើជោគជ័យនេះនឹងមកដល់ឆាប់ប៉ុណ្ណាតែប៉ុណ្ណោះ។ ដូច្នេះ វាល្មមដល់ពេលដែលប្រទេស មហាអំណាចទាំង៤ (អាល្លឺម៉ង់ អ៊ីតាលី ជប៉ុន និងសហភាពសូវៀត) ត្រូវធ្វើការបែងចែកគ្នា ដើម្បីត្រួតត្រា ពិភពលោក។

នៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង ដែលអាល្លឺម៉ង់ដាក់លើតុចរចាជាមួយសហភាពសូវៀត ប្រទេស ទាំង៤ ត្រូវបន្តកាន់កាប់ទឹកដីដែលខ្លួនកំពុងកាន់កាប់បច្ចុប្បន្ន ហើយអាចធ្វើការឈ្លានពានវាតទីពង្រីកទឹកដី ទៅតាមទិសដៅរៀងៗខ្លួន គឺអាល្លឺម៉ង់ នៅអាហ្វ្រិកប៉ែកកណ្តាល អ៊ីតាលី នៅអាហ្វ្រិកខាងជើង និងខាងកើត ជប៉ុន នៅអាស៊ីអាគ្នេយ៍ ចំណែកសហភាពសូវៀត នៅតំបន់អាស៊ីកណ្តាលចាក់ចុះទៅទិសខាងត្បូងសំដៅទៅ មហាសមុទ្រឥណ្ឌា។ សំណើនេះមិនត្រូវបានសហភាពសូវៀតទទួលយកទាំងស្រុងនោះទេ ដោយស្តាលីនទាមទារឱ្យ អ៊ីត្លែរកំណត់ឱ្យបានច្បាស់លាស់ អំពីការបែងចែកដែនឥទ្ធិពល នៅក្នុងតំបន់អឺរ៉ុបខាងកើត ជាពិសេស ប្រទេសហ្វាំងឡង់ ប៊ុលហ្គារី និងរូម៉ានី ដែលអាល្លឺម៉ង់ និងសហភាពសូវៀតកំពុងតែប្រជែងគ្នាកាន់កាប់។ ស្តាលីន បានផ្ញើសេចក្តីព្រាងកិច្ចព្រមព្រៀងថ្មីមួយជាសំណើតបទៅ អ៊ីត្លែរវិញ ក៏ប៉ុន្តែ អ៊ីត្លែរមិនឆ្លើយតប ហើយការចរចា បង្កើតបក្សសម្ពន្ធចតុភាគីក៏ត្រូវជាប់គាំង។

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៤១ កងទ័ពអាល្លឺម៉ង់ក៏បានបើកការវាយលុកចូលឈ្លានពានសហភាព សូវៀត ក្នុងប្រតិបត្តិការដែលអាល្លឺម៉ង់ដាក់ឈ្មោះថា "Barbarossa"។ ការឈ្លានពានរបស់អាល្លឺម៉ង់ទៅលើ សហភាពសូវៀតនៅពេលនោះ ត្រូវបានគេចាត់ទុកថាជាប្រតិបត្តិការឈ្លានពានដ៏ធំបំផុត នៅក្នុងប្រវត្តិសឹក សង្គ្រាមពិភពលោក។ ទាហានអាល្លឺម៉ង់ជាង ៣លាននាក់ ចែកចេញជា ១៥០កងពលធំ អមដោយរថក្រោះ ជាង ៤ពាន់គ្រឿង យន្តហោះនិងឧទ្ធម្ភាគចក្រជិត ៥ពាន់គ្រឿង ព្រមទាំងកាំភ្លើងធំជាង ៧ពាន់ដើម បានបើក ការវាយលុកចូលទៅក្នុងទឹកដីសហភាពសូវៀត នៅក្នុងសមរភូមិ ដែលបើកមុខរហូតដល់ទៅជិត៣ពាន់គីឡូ ម៉ែត្រ។

នៅមួយខែដំបូង កងទ័ពអាល្លឺម៉ង់បានវាយលុកចូលយ៉ាងជ្រៅទៅក្នុងទឹកដីរុស្ស៊ី រហូតចូលទៅដល់ទ្វារ ក្រុងម៉ូស្គូ នៅដើមខែតុលា។ ក៏ប៉ុន្តែ មិនយូរប៉ុន្មាន រដូវត្រជាក់ក៏ឈានចូលមកដល់ ហើយកងទ័ពអាល្លឺម៉ង់ ដែលនៅឆ្ងាយពីមូលដ្ឋាន ហើយមិនមានសម្ភារៈគ្រប់គ្រាន់ ដើម្បីប្រឈមមុខនឹងអាកាសធាតុត្រជាក់នៃរដូវ រងារុស្ស៊ីក៏ចាប់ផ្តើម ធ្លាក់ចុះខ្សោយ ហើយត្រូវបានកងទ័ពរុស្ស៊ី ដែលជាម្ចាស់ស្រុកវាយទប់ជាប់មិនឱ្យចូលកាន់ កាប់ក្រុងម៉ូស្គូ បាន។

បន្ទាប់ពីបរាជ័យនៃប្រតិបត្តិការ«តោសមុទ្រ»(Sealion) នៅអង់គ្លេស ប្រតិបត្តិការ "Barbarrossa" បានក្លាយជាបរាជ័យដ៏ជូរចត់មួយទៀតរបស់អ៊ីត្លែរ នៅក្នុងសង្គ្រាមលោកលើកទី២។ ការឈ្លានពានលើ សហ ភាពសូវៀត ដែលអ៊ីត្លែររំពឹងថានឹងអាចទទួលជោគជ័យឆាប់ៗ បានក្លាយជាសង្គ្រាម ដែលអូសបន្លាយពេល រហូតដល់ទៅ៤ឆ្នាំ។ បរាជ័យនៃប្រតិបត្តិការ "Barbarrossa" នៅសហភាពសូវៀតបានធ្វើឱ្យអាល្លឺម៉ង់ ត្រូវ

ប្រឈមមុខនឹងសមរភូមិពីរ ទិសធំៗក្នុងពេលតែមួយ នៅពេលដែលកងកម្លាំងនៃចលនាតស៊ូបារាំង រួមជាមួយនឹងកងទ័ពអង់គ្លេស និងអាមេរិក ចាប់ផ្តើមវាយបកមកលើអ៊ីត្លែរវិញ នៅសមរភូមិអឺរ៉ុបខាងលិច។



ផែនទីទ្វីបអឺរ៉ុប ឆ្នាំ១៩៤២

## ២.៥- សង្គ្រាមលោកលើកទី២នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក

នៅពេល ដែលសង្គ្រាមលោកលើក ទី២ ចាប់ផ្តើមផ្ទុះឡើង នៅខែកញ្ញា ឆ្នាំ១៩៣៩ ភ្លើងសង្គ្រាមបានឆាបឆេះរួចទៅហើយ នៅក្នុងតំបន់អាស៊ី គឺសង្គ្រាមរវាងជប៉ុន និងចិន ដែលចាប់ផ្ទុះឡើង តាំងពីឆ្នាំ១៩៣៧។ នៅពេលដែលសង្គ្រាមលោកលើកទី២ចាប់ផ្ទុះឡើង នៅខែកញ្ញា ឆ្នាំ១៩៣៩ ទឹកដីមួយផ្នែកធំនៅប៉ែកខាងកើតប្រទេសចិនត្រូវបានកងទ័ពជប៉ុន ឈ្លាន ពានកាន់កាប់រួចទៅហើយ។ ចំណែកឯទឹកដីដែលនៅសេសសល់មួយចំណែកត្រូវកាន់កាប់ដោយរដ្ឋាភិបាលសាធារណរដ្ឋចិនរបស់លោក ចាង កាយចៀក និងមួយចំណែកតូចទៀតស្ថិតក្រោមការកាន់កាប់របស់ក្រុមកុម្មុយនីស្ត របស់ម៉ៅសេទុង។

នៅក្នុងឆ្នាំដំបូងៗ នៃសង្គ្រាមលោកលើកទី២ នៅពេលដែលអាល្លឺម៉ង់ អ៊ីតាលី និងសហភាពសូវៀត នាំគ្នាឈ្លានពានពង្រីកទឹកដី នៅក្នុងតំបន់អឺរ៉ុប អាស៊ីប៉ាស៊ីហ្វិកវិញ គឺជាដែនប្រមាញ់របស់ចក្រភពជប៉ុន ដែលស្ថិតក្នុងបក្សសម្ពន្ធត្រីភាគី អាល្លឺម៉ង់-អ៊ីតាលី-ជប៉ុន ហើយដែលបានចុះសន្ធិសញ្ញារក្សាអព្យាក្រឹតជាមួយសហភាពសូវៀត។

តាមពិត ជប៉ុនធ្លាប់ជាសម្ពន្ធមិត្តរបស់បារាំង អង់គ្លេស និងសហរដ្ឋអាមេរិក ច្បាំងទល់នឹងអាល្លឺម៉ង់ នៅក្នុងអំឡុងសង្គ្រាមលោកលើកទី១។ ហេតុដូច្នេះហើយបានជានៅក្រោយពេលឈ្នះសង្គ្រាមលោកលើកទី១ ប្រទេសមហាអំណាចអស់ទាំងនេះបើកដៃឱ្យជប៉ុនធ្វើភ្លៀងធ្វើផ្គរស្រេចនឹងចិត្ត នៅក្នុងប្រទេសចិន។ ក៏ប៉ុន្តែការទទួលបានសិទ្ធិកាន់កាប់ទឹកដីអាណានិគមនៅចិន និងនៅអាស៊ីប៉ាស៊ីហ្វិកនេះ មិនបានធ្វើឱ្យជប៉ុនស្កប់ចិត្តនោះទេ ដោយសារតែនៅពេលនោះ ជប៉ុនយល់ថាខ្លួនគឺជាចក្រភពមួយ ដែលគួរត្រូវបានប្រទេសមហាអំណាចទុកក្នុងកែវភ្នែកជាដៃគូ យុទ្ធសាស្ត្រស្មើមុខស្មើមាត់នឹងគ្នា តែប្រទេសមហាអំណាចបានទុកជប៉ុនត្រឹមតែជាដៃគូតូចតាចមួយប៉ុណ្ណោះ។ ហេតុដូច្នេះហើយបានជានៅក្នុងសង្គ្រាមលោកលើកទី២ ជប៉ុនងាកទៅចូល

រួមក្នុងបក្សសម្ពន្ធជាមួយអាល្លឺម៉ង់ ដែលជាអតីតគូសត្រូវ ហើយត្រូវប្រឈមមុខនឹងអតីតសម្ពន្ធមិត្តកាលពីសង្គ្រាមលោកលើកទី១ ទៅវិញ។

នៅខែកញ្ញា ឆ្នាំ១៩៤០ នៅក្រោយពេលដែលបារាំងត្រូវទទួលបរាជ័យ ស្ថិតក្រោមការកាន់កាប់របស់អាល្លឺម៉ង់ ហើយរដ្ឋាភិបាលថ្មីរបស់បារាំង ដែលដឹកនាំដោយសេនាប្រមុខ Philippe Pétain ក៏ត្រូវក្លាយជារដ្ឋាភិបាលរណបរបស់អ៊ីត្លែរ ដែរនោះ ជប៉ុនក៏បានចាប់ផ្ដើមបញ្ជូនទ័ពចូលឈ្លានតំបន់ឥណ្ឌូចិន ដែលជាដែនដីអាណានិគមរបស់បារាំង។ គោលដៅរបស់ជប៉ុន គឺកាត់ផ្ដាច់ផ្លូវដឹកជញ្ជូនស្បៀង ប្រេង និងសព្វាវុធ ពីកំពង់ផែហាយហ្វុងប្រទេសវៀតណាម កាត់តាមហាណូយ ចូលទៅក្នុងខេត្តយូណាន យកទៅផ្គត់ផ្គង់កម្លាំងទ័ពរបស់ចាង កាយចៀក និងម៉ៅសេទុង ដើម្បីច្បាំងទល់នឹងកងទ័ពជប៉ុន។ នៅថ្ងៃទី២២ កញ្ញា ១៩៤០ បារាំងបានសុខចិត្តឱ្យកងទ័ពជប៉ុនកាន់កាប់តំបន់តុងកឹង (ប៉ែកខាងជើងប្រទេស វៀតណាម ជាប់នឹងព្រំដែនចិន)។ ក៏ប៉ុន្តែ ជប៉ុនមិនសុខចិត្តទទួលយកត្រឹមតំបន់តុងកឹងនេះមួយទេ។ ចាប់ពីឆ្នាំ១៩៤១ កងទ័ពជប៉ុនក៏បានរាតទីកាន់កាប់ទីតាំងជាច្រើនផ្សេងទៀត នៅក្នុងតំបន់ឥណ្ឌូចិនទាំងមូល។ ប្រឈមមុខនឹងការរាតទីរបស់ជប៉ុននេះ សហរដ្ឋអាម៉េរិក ដោយមានការព្រមព្រៀងពីសំណាក់អង់គ្លេស ក៏បានសម្រេចដាក់ទណ្ឌកម្មសេដ្ឋកិច្ចលើជប៉ុន ហើយបានទាមទារឱ្យជប៉ុនដកខ្លួនចេញពីឥណ្ឌូចិន។ ទណ្ឌកម្មនេះបានធ្វើឱ្យជប៉ុនត្រូវទទួលរងនូវការខូចខាតយ៉ាងខ្លាំង ដោយត្រូវបាត់បង់ប្រភពផ្គត់ផ្គង់ប្រេងរហូតដល់ទៅ ៩០% និងបាត់បង់ចំណូលពីការដោះដូរពាណិជ្ជកម្មអន្តរជាតិ រហូតដល់ទៅ ៧៥%។

ប្រឈមមុខនឹងទណ្ឌកម្មសេដ្ឋកិច្ចនេះ គណៈរដ្ឋមន្ត្រីជប៉ុនបានបើកកិច្ចប្រជុំមួយ នៅខែកញ្ញា ឆ្នាំ១៩៤១ ក្រោមអធិបតីភាពរបស់អធិរាជហ៊ីរ៉ូហ៊ីតូ (Hirohito) ដើម្បីជជែកគ្នា អំពីជម្រើស៣៖ ទីមួយ ដកថយពីតំបន់ឥណ្ឌូចិនតាមការទាមទាររបស់អាម៉េរិក ទីពីរ ធ្វើការចរចាស្វែងរកសម្បទានពីអាម៉េរិកនិងទីបី បើកធ្វើសង្គ្រាមទល់នឹងអាម៉េរិកតែម្ដង។ នៅក្នុងកិច្ចប្រជុំនេះ ជប៉ុនក៏បានសម្រេចថានឹងធ្វើការចរចាជាមួយសហរដ្ឋអាម៉េរិក ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នាត្រូវចាប់ផ្ដើមរៀបចំទ័ពធ្វើសង្គ្រាម ប្រសិនបើការចរចាមិនបានសម្រេច។ មួយខែក្រោយមក នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៤១ ការផ្លាស់ប្ដូរដ៏សំខាន់មួយបានកើតឡើង នៅក្នុងជួររដ្ឋាភិបាលជប៉ុន ដោយលោក ហ៊ីដេគី តូចូ (Hideki Tojo) ឧត្ដមសេនីយ៍ និងជារដ្ឋមន្ត្រីកិច្ចការសង្គ្រាម ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី។ នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីថ្មីមួយទៀត នៅខែវិច្ឆិកា ហ៊ីដេគី តូចូ បានលើកឡើង នៅចំពោះមុខអធិរាជហ៊ីរ៉ូហ៊ីតូ ថា ប្រសិនបើជប៉ុនមិនឆក់ឱកាសល្អដែលខ្លួនមាននៅក្នុងដៃនៅពេលនេះទេ នៅក្នុងរយៈពេលពីរ ទៅបីឆ្នាំទៀត ជប៉ុនប្រាកដជានឹងក្លាយទៅជាប្រទេស តតិយលោក។

នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៤១ ជប៉ុនក៏បានសម្រេចថានឹងត្រូវធ្វើសង្គ្រាមទល់នឹងអាម៉េរិក ដោយកំណត់យកថ្ងៃទី៣០វិច្ឆិកា ជាថ្ងៃចុងក្រោយសម្រាប់ឱ្យមន្ត្រីទូតជប៉ុនចរចាស្វែងរកសម្បទានសមស្របមួយពីសហរដ្ឋអាម៉េរិក។ ក្នុងពេលជាមួយគ្នានោះ រដ្ឋាភិបាលជប៉ុនបានដាក់បញ្ជាឱ្យកងទ័ពជើងទឹកត្រៀមខ្លួនធ្វើដំណើរ ចេញពីបន្ទាយ នៅថ្ងៃទី២៥វិច្ឆិកា ដើម្បីសំដៅទៅបើកការវាយប្រហារលើសហរដ្ឋអាម៉េរិក។ ចំណែកឯកងទ័ពជប៉ុននៅក្នុងតំបន់ឥណ្ឌូចិនវិញត្រូវត្រៀមខ្លួន វាយលុកចូលប៉ែកខាងត្បូងប្រទេសថៃ ដើម្បីបើកផ្លូវចូលឈ្លានពានកាន់កាប់ដែនដីអាណានិគមរបស់អង់គ្លេសនៅ ម៉ាឡេស៊ី និងភូមា និងដែនដីអាណានិគមរបស់ហូឡង់នៅឥណ្ឌូណេស៊ី។

នៅក្នុងការរៀបចំផែនការធ្វើសង្គ្រាមនេះ ជប៉ុនមិនបានដឹងទេថា អាម៉េរិករកឃើញវិធីបំបែកកូដអានសារសម្ងាត់ឆ្លងឆ្លើយគ្នា រវាងរដ្ឋាភិបាលក្រុងតូក្យូ និងកងទ័ព ព្រមទាំងមន្ត្រីទូតជប៉ុននៅវ៉ាស៊ីងតោន។ តាមរយៈ

ការអានសារសម្ងាត់នេះ អាម៉េរិកដឹងថា ជប៉ុនបន្តចរចាក៏ពិតមែន ក៏ប៉ុន្តែ តាមពិតបានសម្រេចថានឹងធ្វើសង្គ្រាមជាមួយអាម៉េរិកទៅហើយ។ ហេតុដូច្នេះហើយបានជា នៅក្នុងការចរចា មន្ត្រីទូតអាម៉េរិក មិនត្រឹមតែមិនសុខចិត្តធ្វើសម្បទានទៅភាគីជប៉ុននោះទេ ក៏ប៉ុន្តែ នៅថ្ងៃទី២៦វិច្ឆិកា រដ្ឋមន្ត្រីក្រសួងការបរទេសអាម៉េរិកបានបន្ថែមការទាមទារកាន់តែច្រើនថែមទៀត ជាថ្នូរនឹងការដកទណ្ឌកម្មសេដ្ឋកិច្ចពីជប៉ុន។ អាម៉េរិក បានទាមទារឱ្យជប៉ុនដកទ័ពចេញទាំងពីតំបន់ឥណ្ឌូចិន និងពីប្រទេសចិនទាំងមូល ហើយត្រូវដកខ្លួនចេញពីបក្សសម្ពន្ធត្រីភាគីជាមួយអាល្លឺម៉ង់ និងអ៊ីតាលី។ ការទាមទារនេះបានធ្វើឱ្យហ៊ីដេគី តូចូ ផ្ទុះកំហឹងយ៉ាងខ្លាំង ហើយបានរៀបចំលិខិតមួយឱ្យឯកអគ្គរាជទូតជប៉ុនប្រចាំទីក្រុងវ៉ាស៊ីងតោន ប្រគល់ឱ្យរដ្ឋាភិបាល អាម៉េរិកនៅព្រឹកថ្ងៃទី៧ធ្នូ ដើម្បីជាការប្រកាសសង្គ្រាម។ នៅក្នុងពេលជាមួយគ្នានោះ កងទ័ពជប៉ុនបានចាប់ផ្តើមចេញដំណើរចេញពីបន្ទាយរៀងៗខ្លួនរួចទៅហើយ ដោយសំដៅទៅបើកការវាយប្រហារលើសហរដ្ឋអាម៉េរិក។

នៅពេលនោះ ថ្វីដ្បិតតែអាម៉េរិកអាចអានសារសម្ងាត់របស់ជប៉ុន ហើយដឹងថា ជប៉ុនកំពុងរៀបចំសកម្មភាពធ្វើសង្គ្រាម ក៏ប៉ុន្តែ ដោយសារតែ ហ៊ីដេគី តូចូ បានដាក់បញ្ជាយ៉ាងដាច់ណាត់មិនឱ្យកងទ័ពនិយាយទាក់ទងគ្នាអំពី សកម្មភាព ទីតាំង និងទិសដៅរបស់ពួកគេ អាម៉េរិកមិនបានដឹងថា តើជប៉ុនគ្រោងបើកការវាយប្រហារទៅលើទីតាំងណាពិតប្រាកដនោះទេ។ រហូតទាល់តែដល់ព្រឹកថ្ងៃទី៧ ខែធ្នូ ទើបអាម៉េរិកអាចដឹងច្បាស់នៅពេលដែលកងទ័ពជប៉ុនបើកការវាយប្រហារទៅលើមូលដ្ឋានទ័ពជើងទឹកអាម៉េរិកនៅPearl Harbor រដ្ឋហាវ៉ៃ។

## ២.៦-ជប៉ុនវាយប្រហារមូលដ្ឋានទ័ពជើងទឹកអាម៉េរិកនៅកោះហាវ៉ៃ

ជាងពីរឆ្នាំ ក្រោយពីសង្គ្រាមលោកលើកទី២បានផ្ទុះឡើង សហរដ្ឋអាម៉េរិកបានព្យាយាមរក្សានយោបាយឯកោនិយមរបស់ខ្លួន ដោយព្យាយាម មិនប្រឡូកខ្លួន ចូលទៅក្នុងសង្គ្រាម។ ក៏ប៉ុន្តែ ការប្រឈមមុខដាក់គ្នាជាមួយជប៉ុន នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ជាពិសេសនៅចិន និង អាស៊ីអាគ្នេយ៍ បានរុញសហរដ្ឋអាម៉េរិក ឱ្យខិតកាន់តែជិតមាត់ជ្រោះសង្គ្រាមពីមួយថ្ងៃទៅមួយថ្ងៃ។

នៅពាក់កណ្តាលឆ្នាំ១៩៤១ នៅក្រោយពេលដែលជប៉ុនចូលឈ្លានពានកាន់កាប់ឥណ្ឌូចិន ដែលពេលនោះ គឺជាដែនដីអាណានិគមរបស់បារាំង សហរដ្ឋអាម៉េរិកបានដាក់ទណ្ឌកម្មសេដ្ឋកិច្ចលើជប៉ុន ដែលធ្វើឱ្យជប៉ុនបាត់បង់ចំណូលយ៉ាងច្រើនសន្ធឹកសន្ធាប់ពីការដោះដូរពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងបាត់បង់ប្រភពផ្គត់ផ្គង់ប្រេងស្ទើរតែទាំងស្រុង។

ក្រោយពីបានចរចាជាមួយអាម៉េរិករាប់ខែតែគ្មានដំណោះស្រាយ នៅខែវិច្ឆិកា ឆ្នាំ១៩៤១ **ហ៊ីដេគី តូចូ** នាយករដ្ឋមន្ត្រីជប៉ុនក៏បានសម្រេចធ្វើសង្គ្រាមជាមួយអាម៉េរិក។ នៅថ្ងៃទី២៥ វិច្ឆិកា កងទ័ពជើងទឹកជប៉ុនបានចេញដំណើរពីបន្ទាយដើម្បីឆ្ពោះទៅបើកការវាយប្រហារលើសហរដ្ឋអាម៉េរិក។

សហរដ្ឋអាម៉េរិកដែលអាចបំបែកកូដលួចអានសារសម្ងាត់របស់ជប៉ុនបាន តាំងពីយូរមកហើយនោះ បានដឹងតាំងពីដើមខែវិច្ឆិកាថា ជប៉ុនកំពុងរៀបចំសកម្មភាពធ្វើសង្គ្រាមមកលើអាម៉េរិក ក៏ប៉ុន្តែមិនដឹងទេថា តើជប៉ុនគ្រោងបើកការវាយប្រហារទៅលើទីតាំងណាមួយពិតប្រាកដ។ ជប៉ុនវិញបានព្យាយាមលាក់ការណ៍យ៉ាងជិតបំផុត ពីព្រោះមេទ័ពជប៉ុនដឹងថា គន្លឹះនៃជោគជ័យ គឺការលួចវាយឆ្មក់ដោយមិនឱ្យអាម៉េរិកដឹងខ្លួនមុន។ ទិសដៅដែលជប៉ុនគ្រោងធ្វើការវាយប្រហារគឺមូលដ្ឋានទ័ពជើងទឹកអាម៉េរិកប្រចាំតំបន់ប៉ាស៊ីហ្វិកដែលមានទីតាំងនៅ Pearl Harbor ទឹកដីហាវ៉ៃ ចម្ងាយប្រមាណជាង៦០០០ គីឡូម៉ែត្រពីប្រទេសជប៉ុន។

នៅក្នុងយុទ្ធសាស្ត្រទ័ពរបស់ជប៉ុន ការកម្ទេចមូលដ្ឋានទ័ព Pearl Harbor គឺជាចំណុចគន្លឹះក្នុងការឈានទៅត្រួតត្រាមហាសមុទ្រប៉ាស៊ីហ្វិក ដើម្បីរារាំងអាម៉េរិកកុំឱ្យចូលមករំខានសកម្មភាពឈ្លានពានរបស់ជប៉ុន

នៅក្នុងតំបន់អាស៊ី។ តាមគម្រោងការណ៍របស់ជប៉ុន ក្រោយពីបើកការវាយប្រហារលើ Pearl Harbor បានសម្រេចហើយ កងទ័ពជប៉ុននឹងបើកការវាយប្រហារភ្លាមៗនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយឱ្យកងទ័ពជប៉ុនប្រចាំនៅតំបន់ឥណ្ឌូចិន បើកការវាយប្រហារចាក់ចូលតាមប្រទេសថៃ ដើម្បីចូលឈ្លានពានដែនដីអាណានិគមរបស់អង់គ្លេសនៅភូមានិងម៉ាឡេស៊ី ដែនដីអាណានិគមរបស់ហូឡង់នៅ ឥណ្ឌូណេស៊ីនិងប្រទេសហ្វីលីពីនដែលនៅពេលនោះស្ថិតនៅក្រោមអាណាព្យាបាលរបស់អាម៉េរិក។

មូលដ្ឋានទ័ពជើងទឹក Pearl Harbor ព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤១ ត្រូវជាថ្ងៃអាទិត្យ។ ដោយសារតែនៅពេលនោះ អាម៉េរិកមិនស្ថិតក្នុងស្ថានភាពសង្គ្រាម ទាហាននៅ Pearl Harbor ត្រូវបានអនុញ្ញាតឱ្យឈប់សម្រាកនៅថ្ងៃអាទិត្យ ដោយទុកតែមួយចំនួនតូចឱ្យនៅយាមប្រចាំការ។ ម៉ោង៧ព្រឹក ទាហានដែលប្រចាំការនៅមុខរ៉ាដាការពារដែនអាកាសហាវ៉ៃបានកត់សម្គាល់ឃើញយន្តហោះយ៉ាងច្រើនសន្ធឹកសន្ធាប់ ហោះក្នុងល្បឿនយ៉ាងលឿនពីទីសមុទ្ទ សំដៅមក Pearl Harbor។ ក៏ប៉ុន្តែ មេបញ្ជាការទទួលបន្ទុករ៉ាដាបានប្រាប់ថាកុំឱ្យមានការភ្ញាក់ផ្អើល ដោយគិតថា យន្តហោះដែលរ៉ាដាចាប់បាននេះ គឺជាយន្តហោះចម្បាំង ដែលគេបញ្ជូនពីអាម៉េរិកដីគោក ហើយដែលតាមគម្រោងនឹងត្រូវមកដល់ Pearl Harbor នៅថ្ងៃអាទិត្យនោះ។ ក៏ប៉ុន្តែ តាមពិតយន្តហោះអស់ទាំងនេះ គឺជាយន្តហោះចម្បាំងរបស់ជប៉ុន ដែលមានសរុបទាំងអស់ចំនួនជាង៤០០គ្រឿង ចែកចេញជាបីក្រុម ដោយហោះចេញពីនាវាផ្ទុកយន្តហោះចំនួន៦គ្រឿង អមទៅដោយនាវាចម្បាំងតូចធំ គិតជាសរុបចំនួនជិត៥០គ្រឿង សំដៅទៅធ្វើការវាយប្រហារលើ Pearl Harbor។ យន្តហោះចម្បាំងក្រុមទីមួយរបស់ជប៉ុន បានចាប់បើកការវាយប្រហារទៅលើ Pearl Harbor នៅម៉ោងប្រមាណជាជិត៨ព្រឹក បន្តកន្ទុយជាប់ៗគ្នាដោយក្រុមទី២ និងក្រុមទី៣ ដោយមិនឱ្យអាម៉េរិកមានពេលអាចតដៃទាន់។

៩០នាទីក្រោយមក ប្រតិបត្តិការវាយប្រហារលើ Pearl Harbor ត្រូវបញ្ចប់ ហើយកងទ័ពជប៉ុនក៏បានដកថយចេញទៅវិញ ដោយបន្សល់ទុកនូវការខូចខាតយ៉ាងធ្ងន់ធ្ងរបំផុតដល់កងទ័ពអាម៉េរិក។ គិតជាសរុបការវាយប្រហាររបស់ជប៉ុនទៅលើ Pearl Harbor បានបណ្តាលឱ្យអាម៉េរិកបាត់បង់នាវាចម្បាំងចំនួន១៨គ្រឿង យន្តហោះចម្បាំងជិត ៣០០គ្រឿង ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធយោធាជាច្រើនទៀត ហើយកាន់តែធ្ងន់ធ្ងរជាងនេះទៅទៀត គឺការបាត់បង់ជីវិតទាហានប្រមាណជិត ២៥០០នាក់ និង ១០០០នាក់ផ្សេងទៀតត្រូវរងរបួស។ ប៉ុន្តែ បើទោះបីជាយ៉ាងនេះក៏ដោយ ការវាយប្រហារទៅលើ Pearl Harbor ត្រូវបានគេចាត់ទុកថាជាបរាជ័យដ៏ធំមួយសម្រាប់ជប៉ុន។ បរាជ័យនៅក្នុងន័យថា ជប៉ុនមិនអាចកម្ទេចទ័ពជើងទឹកអាម៉េរិកប្រចាំមហាសមុទ្ទប៉ាស៊ីហ្វិកបានទាំងស្រុង ដូចការចង់បាន ដោយសារតែជប៉ុនមិនបានកម្ទេចឃ្លាំងស្តុកប្រេង និងអាវុធ ព្រមទាំងពាងជាងសម្រាប់ជួសជុលនាវានៅ Pearl Harbor។ ចំណែកឯនាវាចម្បាំងសំខាន់ៗរបស់អាម៉េរិក ជាពិសេស នាវាផ្ទុកយន្តហោះធំៗ ជាច្រើនគ្រឿង ក៏មិនស្ថិតនៅក្នុងបន្ទាយ នៅព្រឹកថ្ងៃអាទិត្យ ទី៧ធ្នូនោះ។

នៅទីបំផុតទៅ ការវាយប្រហារទៅលើ មូលដ្ឋានទ័ពនៅ Pearl Harbor មិនអាចធ្វើឱ្យជប៉ុនត្រួតត្រាមហាសមុទ្ទប៉ាស៊ីហ្វិកដូចដែលជប៉ុនរំពឹងទុកនោះទេ ប៉ុន្តែផ្ទុយទៅវិញ តាមរយៈការវាយប្រហារនេះ ជប៉ុនបាន «ដាស់យក្សឱ្យភ្ញាក់ពីដំណេក»។ ជាងពីរឆ្នាំក្រោយពីមានការប្រទាញប្រទង់គ្នានៅក្នុងចំណោមសាធារណមតិអាម៉េរិក ដែលអ្នកខ្លះចង់ឱ្យអាម៉េរិកចូលប្រឡូកក្នុងសង្គ្រាមដើម្បីជួយសម្ពន្ធមិត្ត ឯខ្លះទៀតទាមទារឱ្យអាម៉េរិករក្សាខ្លួន អព្យាក្រឹត ដើម្បីបញ្ចៀសខ្លួនពីសង្គ្រាម នៅទីបំផុតទៅ គឺចក្រភពជប៉ុន តាមរយៈការវាយប្រហារលើ Pearl Harbor ដែលបានទាញប្រជាជនអាម៉េរិក ឱ្យមូលមាត់គ្នាតែមួយ គឺមូលមាត់គ្នាក្នុងការធ្វើសង្គ្រាម។

នៅថ្ងៃទី៨ ខែធ្នូ មួយថ្ងៃក្រោយការវាយប្រហារលើ Pearl Harbor លោក Franklin Roosevelt ប្រធានាធិបតីអាមេរិកបានសុំឱ្យសភាពេញអង្គ (Congress) ប្រកាសសង្គ្រាមលើជប៉ុន។ សេចក្តីប្រកាសសង្គ្រាមដែលសភាអាមេរិកអនុម័តភ្លាមៗ នៅថ្ងៃនោះ។ ៣ថ្ងៃក្រោយមក អាល្លឺម៉ង់ និងអ៊ីតាលី ដែលស្ថិតក្នុងបក្សសម្ពន្ធត្រីភាគីជាមួយជប៉ុន ក៏បានប្រកាសសង្គ្រាមលើអាមេរិកវិញដែរ។ សហរដ្ឋអាមេរិកក៏បានឈានជើងចូលក្នុងសង្គ្រាមលោកលើកទី២ជាផ្លូវការ។

## ២.៧-ការពង្រីកឥទ្ធិពលជប៉ុននៅអាស៊ីអាគ្នេយ៍

គិតមកត្រឹមសម័យសង្គ្រាមលោកលើកទី២ តំបន់អាស៊ីអាគ្នេយ៍ស្ទើរតែទាំងមូលកំពុងស្ថិតនៅក្រោមអាណានិគមរបស់ មហាអំណាចលោកខាងលិច គឺតំបន់ឥណ្ឌូចិន (កម្ពុជា វៀតណាម និងឡាវ) ស្ថិតក្រោមអាណានិគមបារាំង ភូមា និងម៉ាឡេស៊ីស្ថិតក្រោមអាណានិគមអង់គ្លេស ឥណ្ឌូណេស៊ីស្ថិតក្រោមអាណានិគមហូឡង់ និងហ្វីលីពីនស្ថិតនៅក្រោមអាណាព្យាបាលរបស់សហរដ្ឋអាមេរិក។ លើកលែងតែប្រទេសថៃមួយចេញ ដែលបារាំង និងអង់គ្លេសបានព្រមព្រៀងគ្នាមិនយកមកដាក់ជាដែនអាណានិគម ដើម្បីទុកធ្វើជាតំបន់ទ្រនាប់។ ចាប់ពីចុងឆ្នាំ១៩៤០ នៅក្រោយពេលដែលបារាំងចាញ់សង្គ្រាមទល់នឹងអាល្លឺម៉ង់ ហើយរដ្ឋាភិបាលបារាំងដឹកនាំដោយសេនាប្រមុខ Philippe Pétain ត្រូវក្លាយជារដ្ឋាភិបាលរណបអ៊ីត្លែរ ជប៉ុន ដែលជាសម្ពន្ធមិត្តរបស់អាល្លឺម៉ង់ ក៏បានបញ្ជូនកងទ័ពរបស់ខ្លួនឱ្យចូលមកក្នុងតំបន់ឥណ្ឌូចិន។ នៅពេលនោះ ថ្វីដ្បិតតែឥណ្ឌូចិននៅមានឈ្មោះជាដែនអាណានិគមបារាំង ក៏ប៉ុន្តែ រដ្ឋាភិបាលបារាំងដែលធ្លាក់ចុះខ្សោយត្រូវបង្ខំចិត្តអនុញ្ញាតឱ្យ កងទ័ពជប៉ុនបោះមូលដ្ឋានទ័ពនៅក្នុងដែនអាណានិគមរបស់ខ្លួន។

ជប៉ុនចូលឈ្លានពានកាន់កាប់តំបន់ឥណ្ឌូចិន គឺក្នុងគោលដៅសំខាន់ពីរ៖ ទីមួយ ដើម្បីកាត់ផ្តាច់ផ្លូវនាំចូលគ្រឿងសព្វាវុធទៅចិនផង និងទីពីរ ដើម្បីទុកធ្វើជាមូលដ្ឋានឈានទៅឈ្លានពានដែនអាណានិគមរបស់លោក ខាងលិចផ្សេងទៀត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ក៏ប៉ុន្តែ សកម្មភាពឈ្លានពានរបស់ជប៉ុននៅឥណ្ឌូចិនត្រូវប្រឈមមុខនឹងឧបសគ្គដ៏ធំមួយ គឺការតវ៉ាជំទាស់ពីសំណាក់សហរដ្ឋអាមេរិក។ ក្រោយពីបានចរចាជាមួយអាមេរិកស្វែងរកដំណោះស្រាយមិនបាន ជប៉ុនក៏បានសម្រេចបើកការវាយប្រហារទៅលើមូលដ្ឋានទ័ពជើងទឹកអាមេរិក ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក គឺមូលដ្ឋានទ័ព Pearl Harbor នៅកោះហាវ៉ៃ។ គោលដៅរបស់ជប៉ុន គឺចង់គ្រួតត្រាមហាសមុទ្ទប៉ាស៊ីហ្វិក ដើម្បីរាំងអាមេរិកកុំឱ្យចូលមករំខានសកម្មភាពឈ្លានពានរបស់ជប៉ុននៅក្នុងតំបន់អាស៊ី ជាពិសេស តំបន់អាស៊ីអាគ្នេយ៍។ តាមគម្រោងការណ៍របស់ជប៉ុន ក្រោយពីវាយប្រហារលើ Pearl Harbor បានសម្រេចហើយ កងទ័ពជប៉ុននឹងបើកការវាយប្រហារភ្លាមៗ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយឱ្យកងទ័ពជប៉ុនប្រចាំនៅតំបន់ឥណ្ឌូចិន បើកការវាយប្រហារទៅលើប្រទេសថៃ ដើម្បីយកទឹកដីថៃធ្វើជាមូលដ្ឋានទ័ពក្នុងការឈ្លានពានបន្តទៅទិស ខាងលិច សំដៅទៅភូមា និងបន្ទាប់មកទៅឥណ្ឌា និងទៅទិសខាងត្បូង សំដៅទៅម៉ាឡេស៊ី និងឥណ្ឌូណេស៊ី។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤១ កងទ័ពជប៉ុនបានបើកការវាយប្រហារទៅលើមូលដ្ឋានទ័ពជើងទឹកអាមេរិក នៅ Pearl Harbor នៅកោះហាវ៉ៃ ហើយមួយថ្ងៃក្រោយមក ជប៉ុនក៏បានបញ្ជូនទ័ពចូលឈ្លានពានប៉ែកខាងត្បូងប្រទេសថៃ ទៅតាមការគ្រោងទុក។ រដ្ឋាភិបាលថៃ ដោយដឹងថាខ្លួនមិនមានកម្លាំងអាចទប់ទល់នឹងកងទ័ពជប៉ុន ក៏បានសុំចរចាឈប់បាញ់ភ្លាមៗ ដោយសុខចិត្តដាក់ខ្លួនជាប្រទេសសម្ពន្ធមិត្តរបស់ជប៉ុន ហើយបើកឱ្យកងទ័ពជប៉ុនប្រើប្រាស់ទឹកដីថៃ ដើម្បីធ្វើការវាយប្រហារទៅលើដែនអាណានិគមលោកខាងលិច។

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤១ ជប៉ុនបានប្រើមូលដ្ឋានទ័ពនៅប៉ែកខាងត្បូងប្រទេសថៃ បើកការវាយប្រហារទៅលើម៉ាឡេស៊ី ហើយក្នុងពេលជាមួយគ្នា បញ្ជូនទ័ពជើងទឹកមួយក្រុមផ្សេងទៀតឱ្យចូលឈ្លានពានហ្វីលីពីន។

ចក្រភពអង់គ្លេស ដែលជាប់ដៃក្នុងការច្បាំងទប់ទល់នឹងអ៊ីត្លែរនៅអឺរ៉ុបផង ហើយខ្ជីខ្ជា និងមើលស្រាលកម្លាំងទ័ពជប៉ុនផង បានបញ្ជូនទ័ពតិចតួចប៉ុណ្ណោះ ឱ្យមកពង្រឹងកម្លាំង នៅតាមដែនអាណានិគមនៅ អាស៊ីអាគ្នេយ៍។ ជាលទ្ធផល នៅក្នុងសមរភូមិនៅម៉ាឡេស៊ី កងទ័ពអង់គ្លេសមានចំនួនតិចជាងកងទ័ពជប៉ុនដល់ទៅពីរដង ហើយគ្រឿងសព្វាវុធក៏ចាញ់ប្រៀបជប៉ុនយ៉ាងឆ្ងាយផងដែរ។ ហេតុដូច្នេះហើយបានជាក្នុង រយៈពេលមិនដល់មួយសប្តាហ៍ផង កងទ័ពជប៉ុនបានវាយបំបាក់កងទ័ពអង់គ្លេសនិងសម្ពន្ធមិត្ត ដោយ ដណ្តើមកាន់កាប់បានទាំងស្រុង នូវតំបន់ប៉ែកខាងជើងប្រទេសម៉ាឡេស៊ី ហើយព្រមទាំងបានចាប់ផ្តើម បើកការឈ្លានពានក្នុងមុខព្រួញ ថ្មីផ្សេងទៀត គឺវាយប្រហារលើ ឥណ្ឌូណេស៊ី និងភូមា។ គិតត្រឹមពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៤២ ប្រទេស ម៉ាឡេស៊ីទាំងមូល ត្រូវធ្លាក់ក្រោមការកាន់កាប់របស់ជប៉ុន ហើយចក្រភពអង់គ្លេសត្រូវបាត់បង់មូលដ្ឋានទ័ពជើងទឹកដ៏សំខាន់មួយ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺមូលដ្ឋានទ័ពជើងទឹកនៅសិង្ហបុរី។ ប៉ុន្មានខែក្រោយមក ភូមា ដែលជាដែន អាណានិគមមួយទៀតរបស់អង់គ្លេស ក៏ត្រូវធ្លាក់ក្នុងដៃជប៉ុន ហើយសូម្បីតែឥណ្ឌា ដែលជាដែនអាណានិគមដ៏ធំបំផុតរបស់អង់គ្លេសនៅអាស៊ី ហើយដែលមានព្រំដែនជាប់នឹងភូមា ក៏ត្រូវប្រឈមមុខនឹងការឈ្លានពានរបស់ជប៉ុនផងដែរ។

នៅឥណ្ឌូណេស៊ីវិញ កងទ័ពហូឡង់ត្រូវទទួលបរាជ័យ ហើយសុខចិត្តប្រគល់ដែនអាណានិគម ឥណ្ឌូណេស៊ីទៅឱ្យជប៉ុនកាន់កាប់ នៅខែមីនា ឆ្នាំ១៩៤២។ ចំណែកកងទ័ពអាម៉េរិកវិញត្រូវបានកងទ័ពជប៉ុនវាយឱ្យដកថយចេញពី ហ្វីលីពីន នៅខែឧសភា។ គិតមកត្រឹមពាក់កណ្តាលឆ្នាំ១៩៤២ តំបន់អាស៊ីអាគ្នេយ៍ ស្ទើរតែទាំងមូល គឺកម្ពុជា វៀតណាម ឡាវ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ហ្វីលីពីន និងភូមាត្រូវធ្លាក់ក្រោមការកាន់កាប់របស់កងទ័ពជប៉ុន។ ចំណែកប្រទេសថៃវិញ ថ្វីដ្បិតតែមានឈ្មោះជាប្រទេសឯករាជ្យ ក៏ប៉ុន្តែ ក៏ត្រូវដាក់ខ្លួនជាប្រទេសរណបជប៉ុនផងដែរ។ បូកបន្ថែមជាមួយនឹងប្រទេសកូរ៉េ និងមួយផ្នែកនៃប្រទេសចិន គឺជាងពាក់កណ្តាលតំបន់អាស៊ី ដែលត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ចក្រភពជប៉ុន។ ប៉ុន្តែ អំណាចរបស់ជប៉ុននៅអាស៊ីនេះនឹងមិនស្ថិតស្ថេរបានយូរប៉ុន្មាននោះទេ។ មិនយូរប៉ុន្មានក្រោយមក កងទ័ពជើងទឹកអាម៉េរិក ដែលជប៉ុនកម្ទេចមិនអស់ នៅក្នុងប្រតិបត្តិការវាយប្រហារទៅលើ Pearl Harbor ក៏ត្រូវបានពង្រឹងឡើងវិញ ហើយយក្សដែលជប៉ុនដាស់ឱ្យភ្ញាក់ពីដំណេកក៏នឹងងើបមកជាន់ជប៉ុនវិញ។

## ២.៨-ការប្រែប្រួលនៃតុល្យភាពកម្លាំង

គិតត្រឹមឆ្នាំ១៩៤២ បក្សសម្ពន្ធអាល្លឺម៉ង់-អ៊ីតាលី-ជប៉ុនបានទទួលជោគជ័យជាបន្តបន្ទាប់ ស្ទើរតែគ្រប់សមរភូមិ ដោយបានដណ្តើមកាន់កាប់ទឹកដីភាគច្រើននៅទូទាំងពិភពលោក។ នៅអឺរ៉ុប អ៊ីត្លែរ ត្រួតត្រាទឹកដីស្ទើរតែពេញទ្វីបអឺរ៉ុបទាំងមូល ដោយរាប់ចាប់តាំងពីប្រទេសបារាំងនៅទិសខាងលិច រហូតទៅដល់តំបន់ សមុទ្របាល់ទិក និងទឹកដីមួយផ្នែករបស់សហភាពសូវៀត នៅទិសខាងកើត។ ចំណែកបណ្តាប្រទេសនៅអឺរ៉ុបប៉ែកខាងត្បូងជាប់សមុទ្រមេឌីទែរ៉ាណេ និងតំបន់បាល់កង់វិញ ត្រូវស្ថិតក្រោមការកាន់កាប់របស់អ៊ីតាលី។ នៅក្នុងតំបន់អាហ្វ្រិក ប្រទេសជាច្រើនដែលជាទឹកដីអាណានិគមរបស់អង់គ្លេសក៏ត្រូវបានអ៊ីតាលី និង អាល្លឺម៉ង់វាយដណ្តើមកាន់កាប់ផងដែរ។ នៅអាស៊ីវិញ ជប៉ុនកាន់កាប់កូរ៉េ ចិន និងតំបន់អាស៊ីអាគ្នេយ៍ រហូតទៅដល់ព្រំដែនឥណ្ឌា ដែលជាដែនអាណានិគមដ៏ធំមួយរបស់ចក្រភពអង់គ្លេស។

សកម្មភាពឈ្លានពានរបស់ជប៉ុននៅអាស៊ីអាគ្នេយ៍ និងតំបន់ប៉ាស៊ីហ្វិកបានចាប់ផ្តើមឡើង ក្រោយពីកងទ័ពជប៉ុនបានធ្វើការលបវាយប្រហារដោយជោគជ័យ ទៅលើមូលដ្ឋានទ័ពជើងទឹកអាម៉េរិក នៅ Pearl Harbor នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤១។ ការវាយប្រហារដែលធ្វើឱ្យប្រជាជនអាម៉េរិកដែលប្រទាញប្រទង់គ្នា រាប់ឆ្នាំមកហើយនោះ ចាប់ផ្តើមមូលគំនិតគ្នាតែមួយ ក្នុងការចូលខ្លួនក្នុងសង្គ្រាម។

អាម៉េរិកប្រកាសសង្គ្រាមលើជប៉ុន នៅថ្ងៃទី៨ធ្នូ ឆ្នាំ១៩៤១ ក៏ប៉ុន្តែ នៅពេលនោះ អាម៉េរិកនៅមិនទាន់អាចស្តារកម្លាំងទ័ពពីវិនាសកម្មនៅ Pearl Harbor បានពេញលេញនៅឡើយទេ។ ហេតុដូច្នេះហើយបានជានៅក្នុងរយៈពេល ៦ខែដំបូង គឺចាប់តាំងពីខែធ្នូ ឆ្នាំ១៩៤១ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៤២ កងទ័ពអាម៉េរិកត្រូវទទួលបរាជ័យជាបន្តបន្ទាប់ ដោយត្រូវជប៉ុនវាយដណ្តើមយកប្រទេសហ្វីលីពីន ព្រមទាំងកោះមួយចំនួន នៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ ក៏ប៉ុន្តែ អ្វីៗចាប់ផ្តើមប្រែប្រួល ចាប់ពីខែឧសភា ឆ្នាំ១៩៤២ ក្រោយពីអាម៉េរិករកវិធីបំបែកកូដ អាចលួចស្តាប់ការឆ្លើយឆ្លងគ្នា រវាងកងទ័ពជើងទឹកជប៉ុន ហើយអាចដឹងជាមុន អំពីគម្រោងការណ៍ និងចលនាទ័ពរបស់ជប៉ុន នៅក្នុងតំបន់មហាសមុទ្រប៉ាស៊ីហ្វិក។ នៅខែឧសភានោះ អាម៉េរិកដឹងថា ជប៉ុនកំពុងរៀបចំគម្រោងការណ៍វាយប្រហារទ្រង់ទ្រាយធំ ទៅលើកោះ Midway របស់អាម៉េរិក ដើម្បីព្យាយាមកម្ទេចនាវាផ្ទុកយន្តហោះរបស់អាម៉េរិក ដែលនៅសេសសល់ពីការវាយប្រហារលើ Pearl Harbor។

តាមគម្រោងការណ៍ ជប៉ុននឹងបើកការវាយប្រហារទៅលើ Midway នៅព្រឹកព្រលឹមថ្ងៃទី៤មិថុនា ដោយមិនឱ្យអាម៉េរិកដឹងខ្លួនជាមុន ពោលគឺប្រើតាក់ទិកដែលធ្លាប់ប្រើដោយជោគជ័យនៅ Pearl Harbor។ ក៏ប៉ុន្តែលើកនេះខុសពីកាលពីនៅ Pearl Harbor ពីព្រោះថា អាម៉េរិកបានដឹងទាំងអស់នូវគម្រោងការណ៍របស់ជប៉ុន ហើយបានរៀបចំអន្ទាក់ទុកជាស្រេច ដើម្បីចាំទទួលជប៉ុន។ នៅទីបំផុត គឺកងទ័ពជប៉ុនទៅវិញទេ ដែលដើរចូលក្នុងអន្ទាក់របស់អាម៉េរិកដោយមិនដឹងខ្លួន។

ជោគជ័យរបស់កងទ័ពអាម៉េរិកលើកងទ័ពជប៉ុន នៅ Midway នៅខែមិថុនា ឆ្នាំ១៩៤២ ត្រូវបានអ្នកប្រវត្តិសាស្ត្រទូទៅចាត់ទុកថាជាចំណុចរបត់ដ៏សំខាន់មួយ នៃតុល្យភាពកម្លាំង នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ក៏ដូចជា នៅក្នុងសង្គ្រាមលោកលើកទី២ទាំងមូល។ បរាជ័យនៅ Midway ធ្វើឱ្យកងទ័ពជើងទឹកជប៉ុនត្រូវទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ ដែលជប៉ុននឹកស្មានមិនដល់។ នាវាផ្ទុកយន្តហោះដ៏ខ្លាំងៗទាំង៤ របស់ជប៉ុនដែលនៅលើនោះមានយន្តហោះចម្បាំង ៣២២គ្រឿង និងទាហានជាង ៥ពាន់នាក់ ត្រូវកងទ័ពអាម៉េរិកបាញ់ពន្លិច។

ក្រោយពីទទួលបរាជ័យនៅ Midway កងទ័ពជើងទឹករបស់ជប៉ុន ដែលធ្លាក់ចុះខ្សោយបានបញ្ឈប់សកម្មភាពឈ្លានពាន នៅមហាសមុទ្រប៉ាស៊ីហ្វិក ហើយអាម៉េរិកក៏មានឱកាសពង្រឹងកងទ័ពរបស់ខ្លួនឡើងវិញ។ ចាប់ពីចុងឆ្នាំ១៩៤២ រហូតដល់ដើមឆ្នាំ១៩៤៣ កងទ័ពអាម៉េរិកបានយកជ័យជម្នះជាបន្តបន្ទាប់លើកងទ័ពជប៉ុន នៅក្នុងការវាយប្រយុទ្ធគ្នាដណ្តើមកោះក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ គិតត្រឹមពាក់កណ្តាលឆ្នាំ១៩៤៣ តុល្យភាពកម្លាំងនៅក្នុងតំបន់ប៉ាស៊ីហ្វិកទាំងមូលត្រូវផ្អៀងទៅខាងអាម៉េរិក ដែលបានវាយដណ្តើមកាន់កាប់កោះជាច្រើននៅក្បែរប្រទេសជប៉ុន ដើម្បីយកទុកធ្វើជាមូលដ្ឋាន ឈានទៅសម្រេចគោលដៅចុងក្រោយ គឺវាយលុកចូលឈ្លានពានទៅលើប្រទេសជប៉ុន។

នៅតំបន់អាហ្វ្រិកវិញ កងទ័ពអង់គ្លេស ដែលមានជំនួយពីកងទ័ពអាម៉េរិក និងកងកម្លាំងចលនាតស៊ូបារាំង ដឹកនាំដោយឧត្តមសេនីយ៍ Charles De Gaulle ក៏បានចាប់ផ្តើមយកប្រៀបលើកងទ័ពអ៊ីតាលី និងអាល្លឺម៉ង់ផងដែរ។ បណ្តាប្រទេសអាហ្វ្រិក ដែលស្ថិតក្រោមអាណានិគមបារាំង ហើយដែលពីមុនស្ថិតក្រោម

អំណាចរដ្ឋាភិបាលរណបអ៊ីត្លែររបស់សេនាប្រមុខ Philippe Pétain ត្រូវបានរដ្ឋាភិបាលនិរទេសរបស់ឧត្តមសេនីយ៍ Charles De Gaulle ដណ្តើមកាន់កាប់ម្តងមួយៗ។ គិតត្រឹមឆ្នាំ១៩៤៣ កងទ័ពអាម៉េរិក និងអង់គ្លេសវាយដណ្តើមកាន់កាប់តំបន់អាហ្វ្រិកខាងជើង ហើយគ្រប់គ្រងសមុទ្រមេឌីទែរ៉ាណេ ដើម្បីបើកផ្លូវឈានទៅវាយលុក រំដោះតំបន់អឺរ៉ុបពីដៃអ៊ីត្លែរ និងមូសូលីនី។

នៅខែមករា ឆ្នាំ១៩៤៣ លោក Franklin Roosevelt ប្រធានាធិបតីអាម៉េរិក លោក Winston Churchill នាយករដ្ឋមន្ត្រីអង់គ្លេស ឧត្តមសេនីយ៍ Charles De Gaulle មេដឹកនាំចលនាតស៊ូបារាំង និងឧត្តមសេនីយ៍ Henri Giraud មេទ័ពបារាំងប្រចាំតំបន់អាហ្វ្រិកខាងជើង បានបើកធ្វើសន្និសីទមួយ នៅក្នុងទីក្រុង Casablanca (ប្រទេសម៉ារ៉ុក) ដើម្បីជជែកគ្នាអំពីជំហានបន្ទាប់ ក្នុងសង្គ្រាមតទល់នឹងបក្សសម្ពន្ធ អាល្លឺម៉ង់-អ៊ីតាលី-ជប៉ុន។ នៅក្នុងសន្និសីទនេះ ប្រមុខដឹកនាំអាម៉េរិក អង់គ្លេស និងបារាំង បានព្រមព្រៀង គ្នាថា នឹងមិនមានប្រទេសណាមួយសុខចិត្តចូលទៅចរចាទទួលយកសំណើអ្វី ទាំងអស់ពីអ៊ីត្លែរ និងសម្ពន្ធមិត្ត ពោលគឺត្រូវបន្តរួមគ្នាធ្វើសង្គ្រាមរហូតដល់គូសត្រូវសុខចិត្តប្រកាស ចុះចាញ់ដោយគ្មានលក្ខខណ្ឌ។ ក៏ប៉ុន្តែ នៅក្នុងការជជែកគ្នានោះ អាម៉េរិក និងអង់គ្លេសមានការខ្វែងគំនិតគ្នាទៅលើយុទ្ធសាស្ត្រទ័ពនៅអឺរ៉ុប។

លោក Franklin Roosevelt ចង់ចូលរំដោះអឺរ៉ុប តាមរយៈការវាយលុកទៅលើកងទ័ពអាល្លឺម៉ង់ នៅខាងជើងប្រទេសបារាំង។ ចំណែកលោក Winston Churchill វិញ បានព្យាយាមបញ្ចុះបញ្ចូលលោក Franklin Roosevelt ថា កងទ័ពអាល្លឺម៉ង់នៅខាងជើងប្រទេសបារាំងមានទីតាំងរឹងមាំខ្លាំង ដែលពិបាកនឹងវាយបែក ហើយថា គេគួរតែធ្វើការវាយលុកចូលពីទិសខាងត្បូងវិញ គឺតាមរយៈការចូលឈ្លានពានអ៊ីតាលី ដែលជាចំណុចខ្សោយនៃខ្សែក្រវ៉ាត់ការពារតំបន់អឺរ៉ុប។

ចុងក្រោយ លោកប្រធានាធិបតីអាម៉េរិកក៏សុខចិត្តផ្អាកគម្រោងការណ៍វាយលុកចូល ខាងជើងប្រទេសបារាំង ហើយងាកទៅបើកប្រតិបត្តិការ ចូលឈ្លានពានប៉ែកខាងត្បូងប្រទេសអ៊ីតាលី វិញតាមសំណើរបស់លោកនាយករដ្ឋមន្ត្រីអង់គ្លេស។ ជាថ្នូរមកវិញ លោកWinston Churchill បានព្រមព្រៀងបញ្ជូនកងទ័ពអង់គ្លេសឱ្យទៅជួយអាម៉េរិកក្នុងការច្បាំងទល់នឹងជប៉ុន នៅអាស៊ីប៉ាស៊ីហ្វិក។

## ២.៩-ការដួលរលំនៃរបបមូសូលីនីនៅអ៊ីតាលី

ក្រោយពីបានវាយបណ្តេញកងទ័ពអាល្លឺម៉ង់ និងអ៊ីតាលី ចេញពីតំបន់អាហ្វ្រិកខាងជើង នៅចន្លោះចុងឆ្នាំ១៩៤២ និងដើមឆ្នាំ១៩៤៣ សហរដ្ឋអាម៉េរិក អង់គ្លេស និងប្រទេសសម្ពន្ធមិត្ត ក៏បានចាប់ផ្តើមរៀបចំយុទ្ធសាស្ត្រ ដើម្បីវាយលុកចូលរំដោះតំបន់អឺរ៉ុប និងឈានទៅសម្រេចគោលដៅចុងក្រោយ គឺយកជ័យជម្នះលើកងទ័ពរបស់អាល្លឺម៉ង់ណាហ្ស៊ី។ នៅពេលនោះ ក្រុមសម្ពន្ធមិត្តត្រូវប្រឈមមុខនឹងជម្រើសពីរៈ ទីមួយ គឺវាយលុកតាមច្រកសមុទ្រ អង់គ្លស(English Chhanel) ទៅលើកងទ័ពអាល្លឺម៉ង់ នៅប៉ែកខាងជើងប្រទេសបារាំង និងទីពីរ វាយលុកតាមសមុទ្រមេឌីទែរ៉ាណេ ទៅលើប្រទេសអ៊ីតាលី ដែលជាសម្ពន្ធមិត្តរបស់អ៊ីត្លែរ ហើយដែលនាយករដ្ឋមន្ត្រីអង់គ្លេស គឺលោក Winston Churchill ចាត់ទុកថាជាចំណុចខ្សោយនៃខ្សែក្រវ៉ាត់ការពារតំបន់អឺរ៉ុប។ ក្រោយពីមានការជជែកគ្នាយ៉ាងច្រើន ជាពិសេស រវាងអាម៉េរិក និងអង់គ្លេស នៅទីបំផុត ក្រុមសម្ពន្ធមិត្តក៏បានឯកភាពគ្នាទៅលើជម្រើសទីពីរ គឺវាយលុកចូលតាមប្រទេសអ៊ីតាលី ដោយបញ្ជូនកងទ័ពដែលភាគច្រើនកំពុងស្ថិតនៅក្នុងតំបន់មេឌីទែរ៉ាណេ ស្រាប់ ឱ្យចូលឈ្លានពានទៅលើតំបន់ស៊ីស៊ីល (Sicile) ដែលជាកោះស្ថិតនៅចុងខាងត្បូងបំផុតនៃប្រទេសអ៊ីតាលី។ មុននឹងបើកការវាយលុកទៅលើតំបន់ស៊ីស៊ីល អង់គ្លេសបានរៀបចំគម្រោងការណ៍សម្ងាត់ ដើម្បីបង្វែងដានបញ្ឆោតអ៊ីត្លែរ។

នៅខែមេសា ឆ្នាំ១៩៤៣ អង់គ្លេសបានយកសាកសពជនអនាថាម្នាក់ មកស្លៀកពាក់ក្លែងខ្លួនជាទាហានអង់គ្លេស ដោយដាក់ខ្នោះដៃភ្ជាប់ទៅនឹងវ៉ាលិសមួយ ដែលផ្ទុកពេញទៅដោយឯកសារសម្ងាត់ក្លែងក្លាយ រួចហើយយកទៅផ្តុងចោលនៅក្នុងសមុទ្រក្បែរឆ្នេរសមុទ្រអេស្ប៉ាញ ដែលនៅពេលនោះ មានឈ្មោះជាប្រទេសអព្យាក្រឹត តែលួចសហការដោយសម្ងាត់ជាមួយអាល្លឺម៉ង់។ នៅពេលដែលសាកសពទាហានអង់គ្លេសក្លែងក្លាយត្រូវបានគេប្រទះឃើញ ហើយស្រង់ចេញពីទឹក វ៉ាលិសផ្ទុកឯកសារសម្ងាត់ក្លែងក្លាយ ក៏ត្រូវបានអេស្ប៉ាញលួចបញ្ជូនបន្តទៅឱ្យភ្នាក់ងារចារកិច្ច អាល្លឺម៉ង់។ នៅក្នុងឯកសារសម្ងាត់ក្លែងក្លាយនេះមានសរសេររៀបរាប់លម្អិតអំពី គម្រោងការណ៍របស់កងទ័ពសម្ពន្ធមិត្ត ក្នុងការវាយលុកទៅលើ អ៊ីតាលី ក៏ប៉ុន្តែ ទិសដៅនៃការវាយលុក គឺ កោះ Corse និង Sardaigne ដែលស្ថិតនៅខាងលិចអ៊ីតាលី ឆ្ងាយពីតំបន់ស៊ីស៊ីល ដែលជាគោលដៅពិតប្រាកដ។ ដោយនឹកស្មានថា ឯកសារសម្ងាត់នេះ គឺជាឯកសារពិត អ៊ីត្លែរ និងមូសូលីនី ក៏បានបង្វែរកម្លាំងទ័ពភាគច្រើនឱ្យទៅចាំការពារកោះ Corse និង Sardaigne ដែលជាហេតុធ្វើឱ្យតំបន់ស៊ីស៊ីលត្រូវថយកម្លាំងការពារ។ នៅពេលដែលប្រតិបត្តិការវាយលុកលើតំបន់ស៊ីស៊ីលបានចាប់ផ្តើមឡើង អាល្លឺម៉ង់ទុកកងទ័ពតែ២កងពលប៉ុណ្ណោះ នៅស៊ីស៊ីល ដើម្បីជួយកងទ័ពអ៊ីតាលី។

ប្រតិបត្តិការវាយលុកទៅលើ តំបន់ស៊ីស៊ីលរបស់អ៊ីតាលី ដែលត្រូវបានគេឱ្យឈ្មោះសម្ងាត់ថា "ប្រតិបត្តិការ Husky" បានចាប់ផ្តើមឡើង នៅព្រឹកព្រលឹមថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៤៣ ដោយមានការចូលរួមពីកងទ័ពចំនួន១៥ម៉ឺននាក់ នាវាចម្បាំង ៣ពាន់គ្រឿង យន្តហោះចម្បាំង ៤ពាន់គ្រឿង ព្រមទាំងរថក្រោះ ជាច្រើនគ្រឿងផ្សេងទៀត។ គិតត្រឹមរសៀលថ្ងៃដដែលនោះ កងកម្លាំងសម្ពន្ធមិត្តទាំង ១៥ម៉ឺននាក់ ចែកចេញជា ៧កងពល គឺ ៣កងពលមកពីអាម៉េរិក ៣កងពលមកពីអង់គ្លេស និង១កងពលមកពីកាណាដា បានចូលទៅដល់តំបន់ឆ្នេរសមុទ្រប៉ែកខាងត្បូងតំបន់ស៊ីស៊ីល ដោយនាំទៅជាមួយនូវរថក្រោះប្រមាណ ៦០០គ្រឿង។ កងទ័ពសម្ពន្ធមិត្តក៏បានធ្វើការវាយលុករុលទៅមុខ ដោយជួបនឹងឧបសគ្គតិចតួចបំផុត ដោយសារតែនៅពេលនោះ កងទ័ពពូកែៗ របស់អាល្លឺម៉ង់ត្រូវបានគេបង្វែរទៅការពារទីតាំងផ្សេង ដោយសារចាញ់ឧបាយកលរបស់អង់គ្លេស។

តាមការពិត ប៉ុន្មានថ្ងៃក្រោយពីឃើញក្រុមសម្ពន្ធមិត្តបើកការវាយប្រហារទៅលើ តំបន់ស៊ីស៊ីល អ៊ីត្លែរនៅតែរក្សាកម្លាំងទ័ពនៅចាំការពារកោះ Corse និងកោះ Sardaigne ដោយមិនព្រមបង្វែរកម្លាំងឱ្យមកស៊ីស៊ីលវិញនោះទេ ដោយសារតែពេលនោះ អ៊ីត្លែរនៅតែជឿថា ឯកសារសម្ងាត់ដែលគេយកបានពីសាកសពទាហានអង់គ្លេស គឺជាឯកសារពិត ហើយនឹកស្មានថា ការណ៍ដែលក្រុមសម្ពន្ធមិត្តបើកការវាយប្រហារនៅតំបន់ស៊ីស៊ីល គ្រាន់តែជាការបង្វែងដានទៅវិញ។ ទម្រាំតែអ៊ីត្លែរ និងមូសូលីនីភ្ញាក់ដឹងខ្លួន កងកម្លាំងសម្ពន្ធមិត្តបានវាយដណ្តើមកាន់កាប់តំបន់ស៊ីស៊ីលបានស្ទើរតែទាំងស្រុង ហើយជំហានបន្ទាប់ គឺប្រទេសអ៊ីតាលីទាំងមូលដែលត្រូវប្រឈមមុខនឹងគ្រោះថ្នាក់។

បរាជ័យនៅស៊ីស៊ីលបានធ្វើឱ្យរបបហ្វាស៊ីសមូសូលីនីត្រូវធ្លាក់ដុនដាប ដោយត្រូវបាត់បង់នូវការគាំទ្រពីសំណាក់ប្រជាជន ព្រះមហាក្សត្រ និងមេដឹកនាំយោធាកំពូលៗរបស់អ៊ីតាលី ហើយនៅថ្ងៃទី២៤ ខែកក្កដា មូសូលីនីក៏ត្រូវគេដកតំណែង និងចាប់ឃុំខ្លួន ហើយតំណែងនាយករដ្ឋមន្ត្រីត្រូវបានព្រះមហាក្សត្រអ៊ីតាលីប្រគល់ទៅឱ្យសេនាប្រមុខព្យេត្រូ បាដូហ្គ្លីយ៉ូ (Pietro Badoglio) ដែលជាឥស្សរជនធ្លាប់តែមានជំហរប្រឆាំងនឹងការចងសម្ពន្ធមិត្តជាមួយ នឹងអ៊ីត្លែរ។ គ្រាន់តែបានឡើងអំណាចភ្លាម សេនាប្រមុខបាដូហ្គ្លីយ៉ូ ក៏បានចាប់ផ្តើមបើកការចរចាជាមួយអាម៉េរិក និងអង់គ្លេស ដើម្បីឈានទៅបញ្ចប់ សង្គ្រាម។ ក៏ប៉ុន្តែ ការចរចានេះត្រូវ

បានធ្វើឡើងដោយលាក់ការណ៍យ៉ាងសម្ងាត់បំផុត ដោយសារតែនៅពេលនោះ កងទ័ពរបស់អ៊ីត្លែរមានវត្តមានយ៉ាងច្រើនសន្ធឹកសន្ធាប់ពាសពេញក្នុងទឹកដីអ៊ីតាលី។

នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៤៣ អ៊ីតាលីបានចុះកិច្ចព្រមព្រៀងជាមួយក្រុមសម្ពន្ធមិត្ត ដោយសុខចិត្តចុះចាញ់សង្គ្រាម ហើយផ្តាច់ខ្លួនចេញពីបក្សសម្ពន្ធត្រីភាគីជាមួយអ៊ីត្លែរ។ ក៏ប៉ុន្តែ គ្រាន់តែកិច្ចព្រមព្រៀងនេះត្រូវបានប្រកាសជាសាធារណៈភ្លាម អាល្លឺម៉ង់ ដែលមានកងទ័ពនៅក្នុងប្រទេសអ៊ីតាលីស្រាប់ ក៏បានចាប់ ផ្តើមវាយដណ្តើមកាន់កាប់ទីតាំងទ័ពសំខាន់ៗរបស់ អ៊ីតាលី ហើយបន្ទាប់មកទៀត អ៊ីត្លែរបានបញ្ជូនកងកុម្ម៉ង់ដូមួយក្រុមឱ្យទៅរំដោះមូសូលីនីចេញពី ពន្ធនាគារ អ៊ីតាលី ដើម្បីយកទៅបន្តុបឱ្យធ្វើជាមេដឹកនាំរដ្ឋាភិបាលអាយ៉ងមួយ ដែលអ៊ីត្លែរបានរៀបចំឡើង នៅដែនដីប៉ែកខាងជើងអ៊ីតាលី។ ចាប់ពីពេលនោះមក អ៊ីតាលីជាប្រទេសដែលមានត្រឹមតែឈ្មោះប៉ុណ្ណោះ ក៏ប៉ុន្តែ ទឹកដីអ៊ីតាលីស្ទើរតែទាំងមូលត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ អ៊ីត្លែរ។ កងទ័ពសម្ពន្ធមិត្ត ដែលចង់ចូលកាន់កាប់ទឹកដីអ៊ីតាលី ក៏ត្រូវកងទ័ពអាល្លឺម៉ង់វាយស្ទាក់ជាប់នៅត្រឹមខ្សែត្រៀមខាងត្បូង ទីក្រុងរ៉ូម លែងអាចរុលទៅមុខទៀតបាន។ យុទ្ធសាស្ត្ររបស់ Winston Churchill ដែលចង់យកអ៊ីតាលីធ្វើជាច្រកផ្លូវ សំដៅទៅវាយលុករំដោះតំបន់អឺរ៉ុបពីដៃអ៊ីត្លែរត្រូវបរាជ័យ។ នៅខែមិថុនា ឆ្នាំ ១៩៤៤ ក្រុមសម្ពន្ធមិត្តក៏អនុវត្តជម្រើសយុទ្ធសាស្ត្រជំហានទីពីរ គឺការវាយលុកឆ្លងកាត់តាមច្រកសមុទ្រអង់គ្លេសទៅលើកងទ័ពអាល្លឺម៉ង់ នៅប៉ែកខាងជើងប្រទេសបារាំង។

### ២.១០-ដំណើរឆ្ពោះទៅរកជ័យជម្នះរបស់ក្រុមសម្ពន្ធមិត្ត លើអ៊ីត្លែរ

ការវាយលុកទៅលើតំបន់ឆ្នេរសមុទ្ទ Normandie ប៉ែកខាងជើងប្រទេសបារាំង នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៤៤ ត្រូវបានគេចាត់បញ្ចូលជាប្រតិបត្តិការវាយលុកចេញពីទីសមុទ្ទសំដៅឡើងគោកដ៏ធំបំផុតមួយ នៅក្នុងប្រវត្តិសាស្ត្រ។ វាគឺជាចំណុចចាប់ផ្តើម ដែលបើកផ្លូវឆ្ពោះទៅរកជ័យជម្នះរបស់ប្រទេសសម្ពន្ធមិត្តលើ អាល្លឺម៉ង់។ នៅឆ្នាំ១៩៤៤ សង្គ្រាមលោកលើកទី២បានឈានចូលដល់ឆ្នាំទី៥។ កាលពី៤ឆ្នាំមុន កងទ័ព អាល្លឺម៉ង់បានចូលឈ្លានពានកាន់កាប់តំបន់ប៉ែកខាងជើងប្រទេស បារាំង ហើយបានរៀបចំសាងសង់ខែលការពារយ៉ាងរឹងមាំ នៅតាមបណ្តោយឆ្នេរសមុទ្ទជាប់នឹងច្រកសមុទ្ទអង់គ្លេស និងមហាសមុទ្ទអាត្លង់ទិក ដើម្បីទុកទប់ទល់នឹងការវាយលុករបស់គូសត្រូវ។

នៅខែមករា ឆ្នាំ១៩៤៤ ឧត្តមសេនីយ៍អាម៉េរិក Dwight Eisenhower ត្រូវបានគេតែងតាំងឱ្យធ្វើជាអគ្គបញ្ជាការដឹកនាំប្រតិបត្តិការវាយលុកលើ Normandie ដែលគេឱ្យឈ្មោះសម្ងាត់ថា « Operation Overlord »។ ក្រោយពីបានចំណាយពេលជាច្រើនខែ ដើម្បីរៀបចំផែនការប្រយុទ្ធ ហាត់សម និងប្រើឧបាយកលបង្វែងដាន គូសត្រូវនៅល្ងាចថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៤៤ កងកម្លាំងសម្ពន្ធមិត្តចំនួនជាង ១៥ម៉ឺននាក់ មក ពីសហរដ្ឋអាម៉េរិក អង់គ្លេស និងកាណាដា បាននាំគ្នាធ្វើដំណើរតាមនាវាចម្បាំងចំនួនជាង ៥ពាន់គ្រឿង ចេញពីប្រទេសអង់គ្លេស សំដៅទៅប្រទេសបារាំង។ គោលដៅ គឺវាយលុកទៅលើទីតាំងចំនួន៥ នៅតាមបណ្តោយឆ្នេរសមុទ្ទប្រវែងប្រមាណ ៨០គីឡូម៉ែត្រ នៅតំបន់ Normandie។ ទីតាំងទាំង ៥នេះ ត្រូវបានគេឱ្យឈ្មោះសម្ងាត់ថា Sword, Juno, Gold, Utah និង Omaha។

នៅព្រឹកព្រលឹមថ្ងៃទី៦ មិថុនា នៅពេលដែលនាវាដឹកទ័ពសម្ពន្ធមិត្តធ្វើដំណើរជិតទៅដល់ឆ្នេរសមុទ្ទបារាំង នាវាចម្បាំង ព្រមទាំងយន្តហោះចម្បាំងជាង១ម៉ឺនគ្រឿង បានបើកការវាយប្រហារទៅលើទីតាំងអាល្លឺម៉ង់នៅតាមបណ្តោយឆ្នេរ ដើម្បីបើកផ្លូវឱ្យកងថ្មើរជើងចុះចត។ ចំណែកកងឆត្រយោងរាប់ពាន់នាក់ផ្សេងទៀតបានលោតឆត្រចុះពីខាងក្រោយ ខ្សែត្រៀមអាល្លឺម៉ង់ ដើម្បីកម្ទេចកាំភ្លើងធំ ព្រមទាំងវាយកាត់ផ្តាច់ផ្លូវកុំ

ឱ្យកងរថក្រោះអាល្លឺម៉ង់ធ្វើដំណើរ ទៅកាន់ឆ្នេរ។ នៅម៉ោង ៦ និង៣០នាទីព្រឹក ប្រតិបត្តិការទ័ពថ្មើរជើងសម្ពន្ធមិត្តបានចាប់ផ្ដើម ដោយកងទ័ពអង់គ្លេស និងកាណាដាបើកការវាយលុកទៅលើឆ្នេរ Sword, Juno និង Gold ចំណែកកងទ័ពអាម៉េរិកវាយលុកទៅលើឆ្នេរ Utah និង Omaha។ គិតត្រឹមល្ងាចថ្ងៃដដែលនោះ កងកម្លាំងសម្ពន្ធមិត្តបានវាយដណ្ដើមកាន់កាប់បានទាំងស្រុងនូវឆ្នេរ Normandie ក៏ប៉ុន្តែ ជោគជ័យនេះបានមកដោយត្រូវចំណាយអាយុជីវិតទាហានរហូតដល់ទៅប្រមាណជាង៤ពាន់នាក់ ក្នុងនោះគ្រាន់តែនៅឆ្នេរOmaha មួយមានទាហានអាម៉េរិកស្លាប់ រហូតដល់ទៅ ២ពាន់នាក់។

ជោគជ័យនៅ Normandie នៅថ្ងៃទី៦ មិថុនា គឺជាការបើកច្រកផ្លូវឱ្យប្រទេសសម្ពន្ធមិត្តបញ្ជូនទាហាន ព្រមទាំងអាវុធយុទ្ធភណ្ឌកាន់តែច្រើនចូលមកក្នុងប្រទេសបារាំង។ គិតត្រឹមចុងខែមិថុនា ទាហានសម្ពន្ធមិត្តរហូតដល់ទៅជាង១លាននាក់ ព្រមទាំងរថក្រោះ និងរថយន្តផ្សេងៗទៀតសរុបជាង ២០ម៉ឺនគ្រឿងត្រូវបានគេបញ្ជូនចូលមកប្រទេសបារាំងតាម Normandie ហើយបានវាយរុញច្រានកងទ័ពអាល្លឺម៉ង់ឱ្យដកថយចេញពីតំបន់ខាងជើងប្រទេស បារាំង នៅខែសីហា។

នៅក្នុងពេលជាមួយគ្នានោះ កងកម្លាំងនៃចលនាតស៊ូបារាំង រួមជាមួយនឹងកងកម្លាំងអាម៉េរិកបានបើកការវាយប្រហារពីសមុទ្រមេឌីទែរ៉ាណេ ទៅលើឆ្នេរសមុទ្រប៉ែកខាងត្បូងប្រទេសបារាំង ដោយអនុវត្តតាមយុទ្ធសាស្ត្រ ដែលគេប្រើនៅ Normandie។

នៅចុងខែសីហា កងពលធំរថក្រោះនៃចលនាតស៊ូបារាំង ដឹកនាំដោយឧត្តមសេនីយ៍ Philippe Leclerc ដោយមានជំនួយពីកងពលថ្មើរជើងរបស់អាម៉េរិក បានវាយលុកចូលរំដោះក្រុងប៉ារីស ពីការកាន់កាប់របស់កងទ័ពអាល្លឺម៉ង់។ ការរំដោះក្រុងប៉ារីស ដែលជានិមិត្តរូបនៃការរំដោះប្រទេសបារាំង ចេញពីនឹមត្រួតត្រារបស់អាល្លឺម៉ង់ ដែលបានចាប់ផ្ដើមឡើងតាំងពីពាក់កណ្ដាលឆ្នាំ១៩៤០។

នៅក្នុងរយៈពេលប៉ុន្មានខែបន្ទាប់ពីបានរំដោះប្រទេសបារាំង កងទ័ពសម្ពន្ធមិត្តក៏បានវាយលុកចូលឈ្លានពានប្រទេសអាល្លឺម៉ង់ពីទិស ខាងលិច ក្នុងពេលដែលកងទ័ពក្រហមរបស់សហភាពសូវៀតវាយលុកពីទិសខាងកើត។ នៅថ្ងៃទី២៥មេសា ឆ្នាំ១៩៤៥ កងទ័ពអាម៉េរិក និងកងទ័ពសហភាពសូវៀតបានជួបចាប់ដៃគ្នានៅត្រង់ទន្លេ Elbe ចម្ងាយប្រមាណជាង ១០០គីឡូម៉ែត្រខាងត្បូងទីក្រុងប៊ែរឡាំង។

នៅទីក្រុងប៊ែរឡាំង កងទ័ព និងរដ្ឋាភិបាលណាហ្ស៊ី ដែលទទួលរងនូវការទម្លាក់គ្រាប់បែកពីយន្តហោះអាម៉េរិក និង សម្ពន្ធមិត្ត ចាប់តាំងពីខែកុម្ភៈមកនោះ ត្រូវទទួលរងនូវការបាញ់ផ្លោងឥតដាច់ ពីសំណាក់កងទ័ពសូវៀត ដែលបានឡោមព័ទ្ធប៊ែរឡាំង ចាប់តាំងពីថ្ងៃទី២០មេសា។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៤៥ នៅពេលដែលកងទ័ពសូវៀតវាយលុកចូលទៅដល់ទីក្រុងប៊ែរឡាំង អ៊ីត្លែរក៏បានសម្លាប់ខ្លួនឯង ហើយជាងមួយសប្ដាហ៍ក្រោយមក រដ្ឋាភិបាលអាល្លឺម៉ង់បានសុខចិត្តចុះចាញ់សង្គ្រាមដោយឥតលក្ខខណ្ឌ។ សង្គ្រាមលោកលើកទី២ នៅក្នុងតំបន់អឺរ៉ុប ក៏ត្រូវបញ្ចប់។

## ២.១១-ការចុះចាញ់របស់ជប៉ុន



ការផ្ទុះគ្រាប់បែកនុយក្លេអ៊ែរនៅហ៊ីរ៉ូស៊ីម៉ា (ឆ្វេង) និងនៅណាហ្គាសាគី ថ្ងៃទី៦ និងទី៩ សីហា ឆ្នាំ១៩៤៥



Paul Tibbets
-23 February 1915
-1 November 2007 (aged 92)



Little Boy

| | |
|---|---|
| Designer | Los Alamos Laboratory |
| Specifications | |
| Weight | 9,700 pounds (4,400 kg) |
| Length | 10 feet (3.0 m) |
| Diameter | 28 inches (71 cm) |



Charles W. Sweeney
December 27, 1919
July 16, 2004 (aged 84)



Fat Man

| | |
|---|---|
| Designer | Los Alamos Laboratory |
| Specifications | |
| Weight | 10,300 pounds (4,670 kg) |
| Length | 128 inches (3.3 m) |
| Diameter | 60 inches (1.5 m) |

នៅដើមខែឧសភា ឆ្នាំ១៩៤៥ សង្គ្រាមលោកលើកទី២ នៅក្នុងតំបន់អឺរ៉ុបត្រូវបិទបញ្ចប់។ អាល្លឺម៉ង់ ត្រូវទទួលបរាជ័យ ដោយនាំទៅជាមួយនូវហ្វាស៊ីសអ៊ីតាលី ដោយមេដឹកនាំផ្តាច់ការអ៊ីតាលី បេនីតូ មូសូលីនី ត្រូវបានក្រុមបះបោរអ៊ីតាលីចាប់ខ្លួន និងបាញ់សម្លាប់ចោល នៅថ្ងៃទី២៨មេសា ចំណែកឯអ៊ីត្លែរវិញបានសម្លាប់ខ្លួនឯង នៅថ្ងៃទី៣០ មេសា។ នៅក្នុងចំណោមប្រទេសទាំង៣ នៅក្នុងបក្សសម្ពន្ធត្រីភាគី នៅសល់តែជប៉ុនមួយប៉ុណ្ណោះ ដែលនៅមិនទាន់ចុះចាញ់សង្គ្រាម។

នៅថ្ងៃទី១៧កក្កដា ឆ្នាំ១៩៤៥ ប្រមុខដឹកនាំអាម៉េរិក អង់គ្លេស និងសហភាពសូវៀត បានបើកធ្វើសន្និសីទមួយ នៅទីក្រុងប៉ុតស្តាំ (Potsdam) ក្បែរទីក្រុងបែរឡាំង ប្រទេសអាល្លឺម៉ង់។ ភាគីអាម៉េរិកតំណាងដោយ លោក Harry Truman ដែលទើបនឹងឡើងមកធ្វើជាប្រធានាធិបតីជំនួសលោក Franklin Roosevelt ដែលទទួលមរណភាពដោយជំងឺ កាលពីថ្ងៃទី១២មេសា ភាគីអង់គ្លេសតំណាងដោយនាយករដ្ឋមន្ត្រី ក្លេម៉ង់ អាតលី ហើយភាគីសហភាពសូវៀតតំណាងដោយលេខាបក្សកុម្មុយនីស្ត Joseph Staline។ សន្និសីទក្រុងប៉ុតស្តាំនេះផ្តោតជាចម្បងទៅលើបញ្ហាធំៗពីរ គឺការគ្រប់គ្រងតំបន់អឺរ៉ុប ក្រោយសម័យសង្គ្រាម និងការរួមកម្លាំងគ្នាធ្វើសង្គ្រាមប្រឆាំងជប៉ុន ដើម្បីឈានទៅបញ្ចប់សង្គ្រាមនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។

បើនិយាយពីរចនាសម្ពន្ធនៃបក្សសម្ពន្ធនៅក្នុងសង្គ្រាមលោកលើកទី២ គេត្រូវដឹងថា សហភាពសូវៀត មិនស្ថិតក្នុងចំណោមប្រទេសសម្ពន្ធមិត្តជាមួយអាម៉េរិក អង់គ្លេស និងបារាំងនោះទេ។ តាមការពិត នៅពេលសង្គ្រាមលោកលើកទី២ទើបនឹងចាប់ផ្តើមផ្ទុះឡើង ស្តាលីន និងអ៊ីត្លែរ ធ្លាប់សហការគ្នា ហើយស្តាលីនថែមទាំងធ្លាប់ធ្វើការចរចាជាមួយអ៊ីត្លែរ ដើម្បីចូលក្នុងបក្សសម្ពន្ធត្រីភាគីជាមួយអាល្លឺម៉ង់ អ៊ីតាលី និងជប៉ុនទៀតផង ប៉ុន្តែ ចរចាមិនបានសម្រេច ទើបអ៊ីត្លែរចូលឈ្លានពានសូវៀត នៅឆ្នាំ១៩៤១។

ទោះជាយ៉ាងណា នៅពេញក្នុងអំឡុងសង្គ្រាមលោកលើកទី២ សហភាពសូវៀត និងជប៉ុនបានរក្សាជំហរ អព្យាក្រឹតនឹងគ្នាទៅវិញទៅមក ស្របទៅតាមកិច្ចព្រមព្រៀង ដែលបានចុះ កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ ១៩៤១ ពោលគឺ ប្រទេសទាំងពីរនឹងមិនសហការគ្នា ដើម្បីធ្វើសង្គ្រាមទល់នឹងប្រទេសផ្សេង ហើយក៏មិនត្រូវសហការជាមួយប្រទេសផ្សេង ដើម្បីធ្វើសង្គ្រាមនឹងគ្នានោះដែរ។ ក៏ប៉ុន្តែ ក្រោយមក ស្តាលីនបានព្រមព្រៀងដោយសម្ងាត់ជាមួយអាម៉េរិកថា នឹងចូលធ្វើសង្គ្រាមទល់នឹងជប៉ុន នៅក្នុងតំបន់អាស៊ី ជាថ្នូរនឹងការណ៍ដែលអាម៉េរិក និងសម្ពន្ធមិត្តបើកការវាយប្រហារលើ អាល្លឺម៉ង់ នៅអឺរ៉ុបខាងលិច ដើម្បីបំបែកកម្លាំងទ័ពអាល្លឺម៉ង់ពីសូវៀត។

នៅក្នុងអំឡុងសន្និសីទនៅយ៉ាល់តា នៅខែកុម្ភៈ ឆ្នាំ១៩៤៥ ស្តាលីនធ្លាប់បានព្រមព្រៀងជាមួយលោក Franklin Roosevelt រួចទៅហើយថា កងទ័ពសូវៀតនឹងចាប់ផ្តើមបើកការវាយប្រហារលើជប៉ុន ក្រោយពីអាល្លឺម៉ង់ប្រកាសចុះចាញ់សង្គ្រាម ហើយនៅក្នុងសន្និសីទក្រុងប៉ុតស្តាំ ខែកក្កដា លោក Harry Truman បានបន្តទទូចឱ្យស្តាលីនចូលធ្វើសង្គ្រាមទល់នឹងជប៉ុន ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា លោកទើបនឹងបានទទួលដំណឹងពីសហរដ្ឋអាម៉េរិក អំពីជោគជ័យនៃការសាកល្បងអាវុធប្រភេទថ្មីមួយ ដែលពិភពលោកមិនធ្លាប់ស្គាល់ពីមុន ហើយដែលអាចធ្វើឱ្យជប៉ុនចុះចាញ់ដោយមិនចាំបាច់មានជំនួយពីសហភាពសូវៀត។ អាវុធប្រភេទថ្មីនោះ គឺគ្រាប់បែកនុយក្លេអ៊ែរ (គ្រាប់បែកបរមាណូ)។

សហរដ្ឋអាម៉េរិកបានរៀបចំបង្កើតគម្រោងផលិតអាវុធនុយក្លេអ៊ែរ តាំងពីឆ្នាំ១៩៤០ គឺតាំងពីពេលដែលសង្គ្រាមលោកលើកទី២ទើបនឹងចាប់ផ្ទុះឡើង ហើយអាម៉េរិកនៅមិនទាន់លូកដៃចូលក្នុងសង្គ្រាមនៅឡើយ។ គម្រោងផលិតអាវុធនុយក្លេអ៊ែរនេះមានឈ្មោះថា "The Mahnatan Project" ហើយត្រូវបាន អាម៉េរិក លាក់ការណ៍យ៉ាងសម្ងាត់បំផុត។

គ្រាប់បែកនុយក្លេអ៊ែរដំបូងបង្អស់នៅក្នុងប្រវត្តិសាស្ត្រ ត្រូវបានអាមេរិកធ្វើការសាកល្បងប្រកបដោយជោគជ័យ នៅព្រឹកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៤៥។ នៅពេលនោះ អាល្លឺម៉ង់បានចុះចាញ់សង្គ្រាមរួចទៅហើយ។ នៅសល់តែជប៉ុនមួយប៉ុណ្ណោះ ដែលនៅចចេសមិនព្រមចុះចាញ់។ ក៏ប៉ុន្តែ បើទោះបីជាមើលឃើញយ៉ាងច្បាស់ថា កងទ័ពជប៉ុនតែឯងប្រាកដជាមិនអាចទប់ទល់នឹងកងទ័ពអាម៉េរិក និងសម្ពន្ធមិត្តបានក៏ដោយ លោក Harry Truman នៅតែសម្រេចចិត្តប្រើអាវុធប្រល័យលោក ដែលទើបនឹងផលិតបាននេះ យកទៅវាយប្រហារលើជប៉ុន។

ហេតុផលធំបំផុតដែលជំរុញឱ្យលោក Harry Truman សម្រេចប្រើអាវុធនុយក្លេអ៊ែរលើជប៉ុន គឺដើម្បីបញ្ចប់សង្គ្រាមឱ្យបានឆាប់ ដោយមិនចាំបាច់បញ្ជូនកម្លាំងទ័ពជម្នតាឱ្យចូលឈ្លានពានប្រទេសជប៉ុន។ គម្រោងវាយលុកលើប្រទេសជប៉ុន ដែលនៅពេលនោះ ត្រូវបានមេទ័ពអាម៉េរិកព្យាករថាអាចនឹងបណ្តាលឱ្យទាហានអាម៉េរិកស្លាប់រហូតដល់ទៅ១លាននាក់ ដោយសារតែគេមើលឃើញពីភាពប្តូរផ្តាច់របស់ទាហានជប៉ុន នៅក្នុងសមរ

ភូមិមុនៗ ជាពិសេស នៅកោះអ៊ីវ៉ូជីម៉ា និងអូគីណាវ៉ា ដែលកងទ័ពជប៉ុន ថ្វីដ្បិតតែទទួលបរាជ័យ តែបានបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរបំផុតដល់កងទ័ពអាម៉េរិក។

ម្យ៉ាងទៀត លោកប្រធានាធិបតីអាម៉េរិក និងមន្ត្រីជំនិតៗមួយចំនួនផ្សេងទៀត យល់ថា ការវាយប្រហារលើជប៉ុនដោយប្រើអាវុធនុយក្លេអ៊ែរ ក្រៅពីអាចបញ្ចប់សង្គ្រាមបានឆាប់ ហើយបញ្ចៀសការបាត់បង់ជីវិតទាហានអាម៉េរិក វាក៏អាចនឹងបង្កើនឥទ្ធិពលរបស់អាម៉េរិកនៅលើពិភពលោកផងដែរ តាមរយៈបង្ហាញឱ្យគេឃើញ អំពីកម្លាំងដ៏អស្ចារ្យនៃអាវុធប្រល័យលោកនេះ។

ថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៤៥ វេលាម៉ោង ៨ និង១៥នាទីព្រឹក ម៉ោងក្នុងស្រុក គ្រាប់បែកនុយក្លេអ៊ែរទីមួយ (ដែលគេឱ្យឈ្មោះថា « Little Boy ») ត្រូវបានអាម៉េរិកទម្លាក់ពីលើយន្តហោះ ទៅលើទីក្រុងហ៊ីរ៉ូស៊ីម៉ា។ ៣ថ្ងៃក្រោយមក នៅថ្ងៃទី៩ សីហា អាម៉េរិកបានទម្លាក់គ្រាប់បែកនុយក្លេអ៊ែរមួយគ្រាប់ទៀត (ដែលគេឱ្យឈ្មោះថា « Fat Man ») ទៅលើទីក្រុងណាហ្គាសាគី។ការវាយប្រហារដោយគ្រាប់បែកនុយក្លេអ៊ែរទាំងពីរគ្រាប់នេះបានបណ្តាលឱ្យប្រជាជនជប៉ុនប្រមាណ ១២ម៉ឺននាក់ត្រូវស្លាប់ភ្លាមៗ (ដោយមិនទាន់រាប់អ្នកស្លាប់ក្រោយៗមកទៀត ដោយសារជាតុវិទ្យុសកម្ម) ហើយនៅថ្ងៃទី១៥ សីហា អធិរាជហ៊ីរ៉ូហ៊ីតូក៏បានប្រកាសចុះចាញ់សង្គ្រាមដោយឥតលក្ខខណ្ឌ។ កិច្ចព្រមព្រៀងចុះចាញ់សង្គ្រាមនេះត្រូវបានចុះហត្ថលេខាដោយជប៉ុន និងសហរដ្ឋអាម៉េរិក នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ ជាថ្ងៃដែលសង្គ្រាមលោកលើកទី២ត្រូវបញ្ចប់ជាផ្លូវការ។

### ៣-ផលវិបាកដែលបន្សល់ទុកដោយសង្គ្រាមលោកលើកទី២

នៅក្នុងតំបន់អឺរ៉ុប សង្គ្រាមលោកលើកទី២បានបញ្ចប់ នៅខែឧសភា ឆ្នាំ១៩៤៥ នៅក្រោយពេលដែលកងទ័ពសហភាពសូវៀត និងកងទ័ពសម្ពន្ធមិត្តលោកខាងលិចបានវាយកាន់កាប់ប្រទេសអាល្លឺម៉ង់ ហើយពុះដែនដីអាល្លឺម៉ង់ចែកគ្នាកាន់កាប់។ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកវិញ សង្គ្រាមបានបន្តរហូតដល់ខែសីហា ទើបអធិរាជជប៉ុនព្រមចុះចាញ់សង្គ្រាម ក្រោយពីអាម៉េរិកបានទម្លាក់គ្រាប់បែកនុយក្លេអ៊ែរលើទីក្រុង ហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី។

នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ កិច្ចព្រមព្រៀងចុះចាញ់សង្គ្រាមដោយឥតលក្ខខណ្ឌត្រូវបានជប៉ុនដែលតំណាងដោយរដ្ឋមន្ត្រីការបរទេស បានចុះហត្ថលេខានៅលើនាវាចម្បាំងអាម៉េរិក និងនៅចំពោះមុខមេទ័ពអាម៉េរិកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក។ សង្គ្រាមលោកលើកទី២ ដែលបានផ្ទុះឡើងកាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៣៩ ក៏ត្រូវបានបញ្ចប់ជាផ្លូវការ ក៏ប៉ុន្តែ សង្គ្រាមរយៈពេល ៦ឆ្នាំនេះ បានបន្សល់ទុកនូវការខូចខាតដ៏ធ្ងន់ធ្ងរបំផុតដល់មនុស្សជាតិ។

សង្គ្រាមលោកលើកទី២ត្រូវបានគេចាត់ទុកថាជាសង្គ្រាម ដែលបានសម្លាប់មនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់បំផុតនៅ ក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។ ចំនួនអ្នកស្លាប់នៅក្នុងសង្គ្រាមលោកលើកទី២ ត្រូវបានគេវាយតម្លៃផ្សេងៗគ្នា នៅក្នុងចន្លោះពី៤០លាន ទៅ ៧០លាននាក់ ដោយនៅក្នុងចំណោមនោះ មានជាងពាក់កណ្តាល គឺជាជនស៊ីវិល។

ប្រជាជនដែលទទួលរងគ្រោះធ្ងន់ធ្ងរជាងគេ គឺសហភាពសូវៀត និងចិន ដែលប្រទេសនីមួយៗ មានប្រជាជនប្រមាណ ពី១០លាន ទៅជិត២០លាននាក់ ត្រូវស្លាប់ដោយសង្គ្រាម ក្នុងនោះពាក់កណ្តាលគឺជាជនស៊ីវិល។ បើគិតតាមសមាមាត្រនៃចំនួនប្រជាជនសរុបវិញ ប៉ូឡូញ គឺជាប្រទេសដែលមានអត្រាស្លាប់ខ្ពស់ជាងគេ គឺរហូតដល់ទៅជិត ២០% ហើយក្នុងចំណោមប្រជាជនប៉ូឡូញទាំងជិត ៦លាននាក់ ដែលត្រូវស្លាប់ក្នុងសង្គ្រាមមានពាក់កណ្តាល ជាជនជាតិជ្វីហ្វដែលត្រូវទទួលរងការសម្លាប់រង្គាលពីសំណាក់របបណាហ្ស៊ីអ៊ីត្លែរ។

អាល្លឺម៉ង់ខ្លួនឯងផ្ទាល់ ដែលជាអ្នកដុតបញ្ឆេះសង្គ្រាម ក៏ទទួលរងនូវការខូចខាតមិនតិចនោះដែរ ដោយមានប្រជាជនស្លាប់រហូតដល់ទៅ៦លាននាក់ ប៉ុន្តែ អ្នកស្លាប់ភាគច្រើនលើសលុប គឺជាទាហាន។ ដូចគ្នាដែរចំពោះសម្ពន្ធមិត្តអ៊ីត្លែរនៅអាស៊ី គឺចក្រភពជប៉ុន ដែលមានទាហានស្លាប់ប្រមាណ២លាននាក់។ ជនរងគ្រោះស៊ីវិលមានប្រមាណជា៥០ម៉ឺននាក់ ក្នុងនោះមានប្រមាណជា១២ម៉ឺននាក់ ជាជនរងគ្រោះក្នុងការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរនៅ ហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី។

នៅឆ្នាំ១៩៤៦ ប៉ុន្មានខែក្រោយពីចប់សង្គ្រាមលោកលើកទី២ មេដឹកនាំនៃរបបណាហ្ស៊ីអាល្លឺម៉ង់ ត្រូវបានគេនាំយកទៅកាត់ទោស នៅក្នុងតុលាការយោធាអន្តរជាតិមួយ ដែលរៀបចំបង្កើតឡើងដោយប្រទេសមហាអំណាចដែលជាអ្នកឈ្នះសង្គ្រាម ហើយដែលមានទីតាំងនៅក្នុងទីក្រុងនូរ៉ាំប៊ែរ (Nuremberg)ប្រទេសអាល្លឺម៉ង់។ នៅឯទីក្រុងតូក្យូវិញ តុលាការយោធាអន្តរជាតិមួយទៀតក៏ត្រូវបានគេបង្កើតឡើងដែរ ដើម្បីជំនុំជម្រះលើបទឧក្រិដ្ឋ ដែលប្រព្រឹត្តដោយមេដឹកនាំ និងកងទ័ពជប៉ុន។

គិតជាសរុប មេដឹកនាំនយោបាយនិងយោធាកំពូលៗ ចំនួន២៣រូប នៃរបបណាហ្ស៊ីអាល្លឺម៉ង់ និងមេដឹកនាំកំពូលៗ ចំនួន២៨រូប នៃចក្រភពជប៉ុន ត្រូវបានគេនាំខ្លួនយកទៅជំនុំជម្រះដោយចោទប្រកាន់ពីបទ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជនជាប់ចោទភាគច្រើនត្រូវបានតុលាការកាត់ទោសប្រហារជីវិត ក្នុងនោះក៏រួមមានផងដែរ ហ៊ីដេគី តូចូ នាយករដ្ឋមន្ត្រីជប៉ុនក្នុងសម័យសង្គ្រាម។

ដំណើរការកាត់ទោសនៅតូក្យូ និងនូរ៉ាំប៊ែរ ត្រូវបានអ្នកខ្លះចាត់ទុកថាជាដំណើរការកាត់ទោស ដ៏សំខាន់បំផុតមួយ នៅក្នុងសតវត្សទី២០ ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា តុលាការអន្តរជាតិទាំងពីរនេះក៏ត្រូវទទួលរងនូវការរិះគន់មិនតិចដែរ ដោយសារតែគេយល់ថា វាជាដំណើរការកាត់ទោសដែលធ្វើឡើងដោយប្រទេសអ្នកឈ្នះសង្គ្រាម ទៅលើតែប្រទេសអ្នកចាញ់ ឬអាចនិយាយដោយសាមញ្ញថា«អ្នកឈ្នះជាស្តេច អ្នកចាញ់ជាចោរ»។ ទោះជាយ៉ាងណា ដំណើរការកាត់ទោសនៅតូក្យូ និងនូរ៉ាំប៊ែរ ថ្វីដ្បិតតែជាយុត្តិធម៌មិនគ្រប់ជ្រុងជ្រោយ ដោយការកាត់ទោសត្រូវធ្វើឡើងតែលើប្រទេសចាញ់សង្គ្រាម ក៏ប៉ុន្តែ វាជាជំហានដ៏សំខាន់មួយ ឆ្ពោះទៅកែលម្អច្បាប់អន្តរជាតិ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ។ ការស៊ើបអង្កេតនៅក្នុងដំណើរការកាត់ទោសនេះបានបើកកកាយនូវ ឧក្រិដ្ឋកម្មធំៗជាច្រើន ជាពិសេសឧក្រិដ្ឋកម្មប្រព្រឹត្តដោយពួកណាហ្ស៊ីអាល្លឺម៉ង់ទៅលើ ពួកជ្វីហ្វ។ ការបើកកកាយឧក្រិដ្ឋកម្ម ដែលនាំទៅរកការបង្កើតអនុសញ្ញាក្រុងហ្សឺណែវស្តីពីបទឧក្រិដ្ឋប្រល័យ ពូជសាសន៍ និងសេចក្តី ប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស នៅឆ្នាំ១៩៤៨។ ច្បាប់សង្គ្រាមក៏ត្រូវបានកែលម្អយ៉ាងច្រើនផងដែរ តាមរយៈការបង្កើតអនុសញ្ញាក្រុងហ្សឺណែវ នៅឆ្នាំ១៩៤៩។

សង្គ្រាមលោកលើកទី២បានបញ្ចប់នៅឆ្នាំ១៩៤៥ ក៏ប៉ុន្តែ បានបន្សល់ទុកនូវមរតកយ៉ាងច្រើនដល់ពិភពលោក នៅក្នុងរយៈពេលជាច្រើនទសវត្សរ៍ក្រោយៗមកទៀត។

ភាពខ្ទេចខ្ទាំដែលបង្កឡើងដោយសង្គ្រាមបានដាស់ស្មារតីសហគមន៍ អន្តរជាតិឱ្យយល់ពីសារៈសំខាន់នៃការបង្កើតយន្តការដោះស្រាយជម្លោះ ដោយសន្តិវិធីជាជាងការប្រើកម្លាំងទ័ព។ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៤៥ (ជាងមួយខែក្រោយពីចប់សង្គ្រាមលោកលើកទី២) អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើង ដោយមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់ប្រទេសចំនួន៥១ នៅទូទាំងពិភពលោក។

ការសម្លាប់រង្គាលជនជាតិជ្វីហ្វ នៅក្នុងសង្គ្រាមលោកលើកទី២ បាននាំទៅរកការបង្កើតរដ្ឋអ៊ីស្រាអែល នៅឆ្នាំ១៩៤៩ ហើយបង្កជាសង្គ្រាម និងជម្លោះរ៉ាំរ៉ៃនៅតំបន់ដើមបូព៌ារហូតមកទល់នឹងពេលបច្ចុប្បន្ន។ ការរីក

ដុះដាលនៃចលនាជាតិនិយម ក្នុងអំឡុងសង្គ្រាមបានបង្កើតឱ្យមានចលនាទាមទារឯករាជ្យ ឈានទៅលុបបំបាត់អាណានិគម នៅស្ទើរតែគ្រប់កន្លែងទូទាំងពិភពលោក។

មហាអំណាចអឺរ៉ុប រួមមាន អង់គ្លេស និងបារាំងត្រូវបាត់បង់ដែនដីអាណានិគមម្តងមួយៗ។ បូករួមទាំងការខូចខាតយ៉ាងខ្ទេចខ្ទាំបង្កឡើងដោយសង្គ្រាមផងនោះ អង់គ្លេស និងបារាំង ដែលធ្លាប់តែជាមហាអំណាចត្រួតត្រាពិភពលោកកាលពីមុនសង្គ្រាមក៏ ចាប់ផ្តើមធ្លាក់ចុះទន់ខ្សោយ ហើយមហាអំណាចជំនាន់ថ្មីក៏ចាប់ផ្តើមលេចមុខឡើង។

សហរដ្ឋអាម៉េរិក គឺជាប្រទេសដែលទទួលរងការខូចខាតដោយសង្គ្រាមតិចតួចជាងគេ បើប្រៀបធៀបនឹងប្រទេសមហាអំណាចផ្សេងៗទៀត។ ក្រៅពីនៅកោះហាវ៉ៃ និងបណ្តាកោះតូចៗ មួយចំនួន នៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ដែលទទួលរងការវាយប្រហារពីសំណាក់កងទ័ពជប៉ុន ទឹកដីរបស់អាម៉េរិក ដែលនៅដាច់ឆ្ងាយពីគេឯង ហើយមានមហាសមុទ្រពីរជារនាំងការពារ បានចៀសផុតទាំងស្រុងពីការវាយប្រហាររបស់ សត្រូវ។ រោងចក្រ សហគ្រាស ព្រមទាំងសកម្មភាពសេដ្ឋកិច្ចផ្សេងទៀត បន្តដំណើរការដោយគ្មានអាក់ខាន នៅពេញក្នុងអំឡុងសង្គ្រាម ហើយនៅក្រោយសង្គ្រាម ការរីកចម្រើននៃវិស័យឧស្សាហកម្ម ដែលមានទាំងនៅក្នុងវិស័យស៊ីវិល និងក្នុងវិស័យយោធា បានធ្វើឱ្យអាម៉េរិកក្លាយខ្លួនទៅជាមហាអំណាចសេដ្ឋកិច្ច និងយោធាដ៏ធំបំផុតនៅលើពិភពលោក។ ក៏ប៉ុន្តែ មិនយូរប៉ុន្មាន មហាអំណាចពិភពលោកថ្មីនេះ ត្រូវប្រឈមមុខនឹងមហាអំណាចដ៏ធំមួយទៀត ដែលជាអ្នកឈ្នះសង្គ្រាមលោកលើកទី២ដែរ គឺមហាអំណាចកុម្មុយនិស្តសហភាពសូវៀត។ សង្គ្រាមលោកលើកទី២បានបិទបញ្ចប់ សង្គ្រាមថ្មីមួយទៀតបានចាប់ផ្តើមឡើង គឺ "សង្គ្រាម ត្រជាក់"។

សរុបមកសង្គ្រាមលោកលើកទី២ បានធ្វើឱ្យពិភពលោកមានបម្រែបម្រួលជាច្រើនដូចជា ៖

- ភាពរុងរឿង និងវិបុលភាពក្នុងទ្វីបអឺរ៉ុប ត្រូវបានបញ្ចប់ ពីព្រោះសង្គ្រាមលោកលើកទី២ បានបំផ្លាញដល់ ឬសគល់នូវខឿនសេដ្ឋកិច្ច របស់ទ្វីបអឺរ៉ុប ដែលមាននៅមុនពេលសង្គ្រាម។
- សង្គ្រាមលោកលើកទី២បានធ្វើឱ្យអាម៉េរិក ក្លាយជាប្រទេសមហាអំណាចដ៏ធំនៅក្នុងពិភពលោក។
- នៅក្រោយសង្គ្រាមលោកលើកទី២ សហភាពសូវៀត បានឈានចូលទៅក្នុងរង្វង់នៃនយោបាយវាតទី និយម ហើយក៏បានប្រែក្លាយទៅជាមហាអំណាចពិភពលោក ប្រគួតប្រជែងជាមួយនឹងសហរដ្ឋអាម៉េរិកផងដែរ។
- សង្គ្រាមលោកលើកទី២បានជម្រុញឱ្យពិភពលោក ចូលទៅក្នុងដំណាក់កាលនៃសង្គ្រាមត្រជាក់ ដែលជាដំណាក់កាលពិភពលោកតែមួយ ប៉ុន្តែគ្រប់ដណ្តប់ទៅដោយប្រព័ន្ធលទ្ធិពីរបដិបក្សនឹងគ្នា។
- សង្គ្រាមលោកលើកទី២ បានធ្វើឱ្យពិភពលោកឈានចូលទៅក្នុងយុគសម័យ នៃអាវុធបរមាណូ (The Nuclear Age)
- សង្គ្រាមលោកបានធ្វើឱ្យផុសឡើងនូវលទ្ធិជាតិនិយម (The Nationalism) និងចលនាទាមទារឯករាជ្យ (The Independence movement) ក្នុងទ្វីបអាស៊ី អាហ្វ្រិក និងអាម៉េរិកឡាទីន។
- ការចាប់បដិសន្ធិនៃអង្គការអន្តរជាតិ និងរបៀបរបបពិភពលោកថ្មីមួយ[472]។
- សង្គ្រាមលោកលើកទី២ បានធ្វើឱ្យភូមិសាស្ត្រនយោបាយនៅលើពិភពលោកមានបម្រែបម្រួលជាខ្លាំងផងដែរ។

[472] ខៀវ ថរិកា, *ប្រវត្តិនៃទំនាក់ទំនងអន្តរជាតិ ពីឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន( ភាគ១), ឆ្នាំ១៩៩៧*, ទំព័រ៣។

## ៤-ដំណោះស្រាយសង្គ្រាម

### ៤.១-សន្និសីទតេអេរ៉ង់

ថ្ងៃ២៨វិច្ឆិកា ដល់ថ្ងៃ១ ខែធ្នូ ឆ្នាំ១៩៤៣នៃរដ្ឋាភិបាលបណ្តាប្រទេសទាំងបីបានជួបប្រជុំគ្នានៅតេអេរ៉ង់ រាជធានី នៃប្រទេសអ៊ីរ៉ង់ ដើម្បីរៀបចំផែនការដឹកនាំសង្គ្រាម (បើករណសិរ្សទីពីរនិងការរៀបចំពិភពលោកនៅក្រោយសង្គ្រាម)។បន្ទាប់ពីតវ៉ាគ្នាយ៉ាងតឹងតែងមករដ្ឋាភិបាលបណ្តាប្រទេសទាំងបីបានយល់ព្រមលើកិច្ចព្រមព្រៀងដែលមានខ្លឹមសារៈ

- ក្រោយសង្គ្រាមកគេនឹងប្រឹងប្រែងបង្កើនកិច្ចសហប្រតិបត្តិការរវាងបណ្តាប្រទេសជាសម្ពន្ធមិត្តតាមសមធម៌ និងភាពស្ថិតស្ថេរ ដើម្បីសន្តិភាព។
- សម្រេចលប់បំបាត់លទ្ធិ ណាហ្ស៊ីចោលទាំងស្រុង ដើម្បីឱ្យប្រជាជាអាល្លឺម៉ង់អាចស្ថាបនា ប្រទេសបែបប្រជាធិបតេយ្យ ឯករាជ្យ និងឯកភាព។

### ៤.២-សន្និសីទនៅយ៉ាល់តា (The Yalta Conference)

សន្និសីទយ៉ាល់តា ដែលបានប្រព្រឹត្តឡើង ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៤៥ ដោយ មេដឹកនាំនៃសហរដ្ឋអាម៉េរិក សហភាពសូវៀត និងចក្រភពអង់គ្លេស។ មេដឹកនាំនៃប្រទេសទាំងបីមាន លោកប្រធានាធិបតីសហរដ្ឋអាម៉េរិក ហ្វ្រង់គ្លីនរ៉ូស្វែល(Franklin Roosevelt) មេដឹកនាំសហភាពសូវៀត ចូស៊ែប ស្តាលីន(Joseph Staline) និងលោកនាយករដ្ឋមន្ត្រីអង់គ្លេស វិនស្តុន ឆឺឈីល(Winston Churchill)។

ប្រធានបទសំខាន់ៗ ត្រូវបានយកមកពិភាក្សានៅក្នុងសន្និសីទ ពិសេសទាក់ទងទៅនឹងបញ្ហាការគ្រប់គ្រងអាល្លឺម៉ង់ និងប៉ូឡូញក្រោយសង្គ្រាមលោកលើកទី២ ការសន្យាចូលរួមសង្គ្រាមរបស់សហភាពសូវៀតប្រឆាំងនឹងជប៉ុន ការរៀបគម្រោងបង្កើតអង្គការសហប្រជាជាតិជាដើម។

**បញ្ហាប្រទេសអាល្លឺម៉ង់ៈ**

សន្និសីទបានលើកជាសំណើថា នៅក្រោយសង្គ្រាមលោកលើកទី២ ប្រទេសអាល្លឺម៉ង់ត្រូវកាន់ កាប់ដោយកងទ័ពរបស់មហាអំណាចទាំងបី តាមរយៈការបែងចែកតំបន់ត្រួតត្រា។

**បញ្ហាប្រទេសប៉ូឡូញៈ**

ចំពោះប្រទេសប៉ូឡូញ គឺទាក់ទងទៅនឹងបញ្ហាថា តើសមាសភាពរបស់រដ្ឋាភិបាលណាមួយ ដែលនឹងត្រូវដឹកនាំ និងគ្រប់គ្រងប្រទេសនេះ ក្រោយសង្គ្រាមបញ្ចប់ទៅ។ មុនសង្គ្រាមលោកលើកទី២ បញ្ចប់ រដ្ឋាភិបាលប៉ូឡូញ មាននិន្នាការប្រឆាំងសូវៀត និងប្រឆាំងនឹងពួកកុម្មុយនីស្ត ហើយបានរត់គេចខ្លួនទៅនៅប្រទេសអង់គ្លេស នាទីក្រុងឡុង ក្នុងខណៈពេលដែលកងទ័ពណាស៊ីអាល្លឺម៉ង់ វាយចូលមកទីក្រុងវ៉ាសូវី (ប្រទេសប៉ូឡូញ)។ រដ្ឋាភិបាលនិរទេសនេះបានតាំងទីស្នាក់ការមួយ ដើម្បីរងចាំវិលត្រឡប់ មកកាន់អំណាចនៅក្នុងប្រទេសវិញ ពេលណាដែលសង្គ្រាមត្រូវបានបញ្ចប់។ ចំពោះអ្នកដឹកនាំប្រទេសលោកខាងលិច ទាំងលោករ៉ូស្វែល ទាំងលោកឆឺឈីល មានបំណងឱ្យរដ្ឋាភិបាលនិរទេសនេះ វិលត្រឡប់មករៀបចំរដ្ឋាភិបាលស្របច្បាប់មួយដែរ។ តែស្ថានការណ៍ផ្ទុយស្រឡះ ដោយពេលសង្គ្រាម ចប់ភ្លាម កងទ័ពក្រហមសូវៀតឈរជើងរួចជាស្រេចទៅហើយ នៅលើទឹកដីនៃប្រទេសប៉ូឡូញ។ បញ្ហាប្រទេសប៉ូឡូញក៏ចាប់ផ្តើមឡើង ពីព្រោះវាបង្ហាញឱ្យឃើញថា តើសមាសភាពណា ដែលត្រូវដឹកនាំប្រទេសប៉ូឡូញ ហើយអ្នកកំណត់បញ្ហានេះ មិនមែនមេដឹកនាំលោកខាងលិចទេ តែជាមេដឹកនារបស់ សូវៀត លោកស្តាលីន វិញទេ។ បញ្ហាប៉ូឡូញ ក៏បានផ្សារភ្ជាប់ទៅនឹងការប្រឈមមុខដាក់គ្នា រវាងប្លុក កុម្មុយនីស្ត និងប្លុកលោកសេរី។

**បញ្ហាប្រទេសជប៉ុន៖**

សន្និសីទទីក្រុងយ៉ាល់តា ទាក់ទងទៅនឹងការធ្វើសង្គ្រាម របស់សហរដ្ឋអាម៉េរិកនៅក្នុងប្រទេសជប៉ុន។ នៅក្នុងសន្និសីទនេះ សហភាពសូវៀត សន្យាចូលរួមអន្តរាគមន៍ប្រឆាំងនឹងជប៉ុន ឱ្យជប៉ុនបរាជ័យក្រោយពេល អាល្លឺម៉ង់ចុះចាញ់សង្គ្រាមបីខែ។ ការចូលរួមរបស់សហភាពសូវៀត ក្នុងលក្ខខណ្ឌ ដែលសូវៀត អាចចាប់យកមកវិញ នូវសិទ្ធិដែលប្រទេសរុស្ស៊ី បាត់បង់នៅក្នុងសង្គ្រាម ១៩០៥ មានដូចជា ការត្រួតពិនិត្យផ្លូវដែក តំបន់ម៉ាន់ជូរី នៃប្រទេសចិន ការត្រួតពិនិត្យមូលដ្ឋានសឹក នៅកំពង់ផែ ផត អាធ្ធរ(Port Arthur) ភាគខាងត្បូងនៃកោះសាខាលីន និងកោះគូរីល[473]។

**បញ្ហាការបង្កើតអង្គការសហប្រជាជាតិ ៖**

សន្និសីទក្រុងយ៉ាល់តា បានពិភាក្សាគ្នាយ៉ាងល្អិតល្អន់ ស្តីពីការបង្កើតអង្គការសហប្រជាជាតិ ដើម្បីជំនួសឱ្យសង្គមប្រជាជាតិ ដែលបានរលាយបាត់រូប នៅក្នុងសង្គ្រាមលោកលើកទី២នេះទៅហើយនោះ។ នៅក្នុងបញ្ហានេះ លោកប្រធានាធិបតីសហរដ្ឋអាម៉េរិក រ៉ូស្វែល បានរកឃើញនូវរូបមន្ត និងរចនាសម្ពន្ធថ្មីមួយសម្រាប់ដំណើរការអង្គការសហប្រជាជាតិ ដោយបានទទួលការយល់ព្រមឯកភាពពីលោកនាយករដ្ឋមន្ត្រីអង់គ្លេស ឆឺឈីល និងមេដឹកនាំសូវៀត លោក ស្តាលីន។ លោករ៉ូស្វែល មានជំនឿយ៉ាងមុតមាំ ថាអង្គការសហប្រជាជាតិ មិនអាចនឹងមានប្រសិទ្ធភាព បានឡើយ ប្រសិនបើគ្មានការចូលរួមពីសហរដ្ឋអាម៉េរិក និងសហភាពសូវៀត។

**៤.៣-សន្និសីទក្រុង ពតស្តាម**

សន្និសីទពតស្តាម បានចាប់ផ្តើមដំណើរការ ពីថ្ងៃទី១៧ កក្កដា ដល់ថ្ងៃទី២ សីហា ១៩៤៥ នៅក្នុងទីក្រុងពតស្តាម នៃប្រទេសអាល្លឺម៉ង់ ដែលស្ថិតនៅចម្ងាយ ២៤គ .ម ភាគនិរតីនៃទីក្រុងប៊ែរឡាំង។ សន្និសីទនេះរៀបចំដោយមហាអំណាចសម្ពន្ធមិត្តទាំងបី។ នៅក្នុងដំណាក់កាលនេះបញ្ហាផ្ទៃក្នុងនៃមហាអំណាចទាំងបី ដែលជាអ្នកដើរតួនាទី ក្នុងការដោះស្រាយបញ្ហាសន្តិភាពក្នុងទ្វីបអឺរ៉ុប មានការផ្លាស់ប្តូរច្រើន៖

-នៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៤៥ លោកប្រធានាធិបតីសហរដ្ឋអាម៉េរិក រ៉ូស្វែល ដែលជាអ្នក ប្រកាន់ខ្ជាប់នូវគំនិត រក្សាសាមគ្គីភាពសម្ពន្ធមិត្ត បានទទួលមរណភាព ហើយជំនួសដោយលោក ទ្រូម៉ាន (Truman) ដែលជាអ្នកនយោបាយអាម៉េរិកមួយរូប តែងតែមានគំនិតមន្ទិលសង្ស័យទៅលើសូវៀត។

-នៅក្នុងប្រទេសអង់គ្លេស លោកនាយករដ្ឋមន្ត្រី ឆឺឈីល បានត្រូវផ្លាស់ចេញពីមុខតំណែងតាមរយៈ ការបោះឆ្នោត ហើយអ្នកជាប់ឆ្នោតជំនួសរូបលោក គឺ ក្លេម៉ង់ អាត់លី (Clement Attlee)។

សន្និសីទនេះ មានទិសដៅ ប្រជុំស្តីពីការទម្លាក់អាវុធរបស់ ពួកណាស៊ីអាល្លឺម៉ង់ បង្កើតតំបន់ គ្មានកងទ័ពលើទឹកដីអាល្លឺម៉ង់ លុបបំបាក់គណបក្សណាស៊ី និងចាប់ពួកឧក្រិដ្ឋជនឈ្លោកសង្គ្រាម បញ្ជូនទៅតុលាការយោធាអន្តរជាតិ និងធ្វើការថ្កោលទោស។

នៅក្នុងការពិភាក្សាគ្នា អំពីព្រំប្រទល់ប្រទេសអាល្លឺម៉ង់ សមាជិកសន្និសីទបានមូលមតិគ្នា សម្រេចចិត្តដូចតទៅ ៖ ព្រំប្រទល់អាល្លឺម៉ង់-ប៉ូឡូញ ត្រូវកាត់តាមខ្សែបន្ទាត់តាមទន្លេអឌ័រ (Order) ប្រគល់តំបន់ព្រុសខាងកើតទៅសហភាពសូវៀត សព្វថ្ងៃជាតំបន់កាលីនីនក្រាដ(Kaliningrad)។

---

473 អ៊ុន រយ៉េត, *កម្រងព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រសាកលលោក*, បណ្ណាគារអង្គរ, ឆ្នាំ២០០៥, ទំព័រ៧៩។

ប្រទេសអាល្លឺម៉ង់ ត្រូវបានបែកចែកជាបួនតំបន់ ដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងពីសហភាព សូវៀត (តំបន់នេះក្រោយមកក្លាយជាសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់) សាធារណរដ្ឋបារាំង ចក្រភពអង់គ្លេស និងសហរដ្ឋអាម៉េរិក។ ចំណែកទីក្រុងបែរឡាំង ដែលកាន់កាប់ដោយសូវៀត តាំងពីមុនមកក៏សន្និសីទនេះ បានសម្រេចបែងចែកទៅជាតំបន់បួនដែលកាន់កាប់ដោយអង់គ្លេស បារាំង អាម៉េរិក និងសូវៀតដែរ។



ពីឆ្វេងទៅស្តាំ លោកនាយករដ្ឋមន្ត្រីអង់គ្លេស ក្លេម៉ង់ អាត់លី , លោកប្រធានាធិបតី ទ្រូម៉ាន់ និងលោកស្តាលី

**សំណួរត្រិះរិះ**

១-តើអ្វីខ្លះជាមូលហេតុដែលនាំឱ្យផ្ទុះសង្គ្រាមលោកលើកទី២ ?

២-តើមូលហេតុអ្វីខ្លះដែលធ្វើឱ្យបារាំងទទួលបរាជ័យចំពោះមុខកងទ័ពអាល្លឺម៉ង់នៅឆ្នាំ១៩៤០ ?

៣-តើកត្តាអ្វីខ្លះដែលធ្វើឱ្យអាល្លឺម៉ង់មិនអាចយកជ័យជម្នះលើអង់គ្លេសបាននៅឆ្នាំ១៩៤១ ?

៤-តើមូលហេតុអ្វីខ្លះ បានជាអាល្លឺម៉ង់សម្រេចចិត្តលើកទ័ពចូលលុកលុយសហភាពសូវៀតនាឆ្នាំ១៩៤១ ?

៥-ចូរពន្យល់ពីគោលនយោបាយជប៉ុនក្នុងការត្រួតត្រាអាស៊ីប៉ាស៊ីហ្វិក។

៦-តើសន្និសីទទីក្រុងយ៉ាល់តា មានទិសដៅសំខាន់ដូចម្តេចខ្លះ ? ចូរបកស្រាយ។

៧-តើសង្គ្រាមលោកលើកទី២ ផ្តល់ផលវិបាកដូចម្តេចខ្លះចំពោះពិភពលោកទាំងមូល ?

៨-ចូរវិភាគពីមូលហេតុដែលនាំឱ្យអាម៉េរិកសម្រេចប្រើប្រាស់គ្រាប់បែកបរមាណូដើម្បីប្រឆាំងជប៉ុន។

# មេរៀនទី៦ អង្គការសហប្រជាជាតិ (United Nation)

អង្គការសហប្រជាជាតិ បានចាប់កំណើតឡើងបន្ទាប់ពីសង្គ្រាមលោកលើកទី២ បានផុតរលត់ទៅ។ អង្គការនេះត្រូវបានបង្កើតជាផ្លូវការនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៥ នៅពេលដែលធម្មនុញ្ញនៃអង្គការនេះត្រូវបានផ្តល់សច្ចាប័នដោយសមាជិកស្ថាបនិកចំនួន៥១ (Republic of China, France, Union of Soviet Socialist Republics, United Kingdom of Great Britain and Northern Ireland, United States of America, Argentina, Brazil, Belarus, Chile, Cuba, Czechoslovakia, Denmark, Dominican Republic, Egypt, El Salvador, Haiti, Iran, Lebanon, Luxembourg, New Zealand, Nicaragua, Paraguay, Philippines, Poland, Saudi Arabia, Syria, Turkey, Ukraine, Yugoslavia, Australia, Belgium, Bolivia, Canada, Colombia, Costa Rica, Ecuador, Ethiopia, Greece, Guatemala, Honduras, India, Iraq, Liberia, Mexico, Netherlands, Norway, Panama, Peru, South Africa, Uruguay, and Venezuela)។

អង្គការសហប្រជាជាតិ មានតួនាទីយ៉ាងសំខាន់ក្នុងការរក្សាសន្តិភាព សន្តិសុខ និងជានាភាពរុងរឿងនៃមនុស្សជាតិទាំងមូល។

## ១-ការបង្កើតអង្គការសហប្រជាជាតិ

ពាក្យពេចន៍ដំបូងបង្អស់នៃ "**សហប្រជាជាតិ**" បានបន្លឺឱ្យដឹងឡើងតាមរយៈប្រធានាធិបតី សហរដ្ឋអាម៉េរិក លោក ហ្វ្រង់គ្លីន រ៉ូស្វែល (Franklin D. Roosevelt) ។ ពាក្យរបស់លោក បានលេចឡើងជាលើកដំបូងនៅក្នុង **សេចក្តីប្រកាសរបស់សហប្រជាជាតិ** (United Nations Declaration) នាថ្ងៃទី១ ខែមករា ឆ្នាំ១៩៤២។

**ការបង្កើតអង្គការសហប្រជាជាតិ ចេញជារូបរាងឡើងត្រូវឆ្លងកាត់ជាច្រើនដំណាក់កាល៖**

***ក.ដំណាក់កាលទី១* សេចក្តីប្រកាសនៅវិមាន ហ្សេម** (The Declaration of St James Palace)

នេះជាព្រឹត្តិការណ៍ នៅពេលដែលសង្គ្រាមលោកលើកទី២ កំពុងផ្ទុះឡើង។ រដ្ឋាភិបាលនិរទេសខ្លួនដែលមកពីប្រទេសក្រិក បែលស៊ិក ឆេកូស្លូវ៉ាគី លុចសំបួរ ហូឡង់ ន័រវែស ប៉ូឡូញ យូហ្គោស្លាវី និងតំណាងមកពីចក្រភពអង់គ្លេស កាណាដា អូទ្រីស ញូហ្សេឡែន អាហ្វ្រិកខាងត្បូង និងលោកឧត្តមសេនីយ៍ដឺហ្គោល នៃប្រទេសបារាំង បានមកជួបប្រជុំគ្នានៅទីក្រុងឡុងក្នុងវិមានហ្សេម។ បន្ទាប់ពីកិច្ចប្រជុំបណ្តាប្រមុខរដ្ឋទាំងនោះ បានចេញសេចក្តីថ្លែងការណ៍រួមមួយនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៤១ ក្នុងទិសដៅស្វះស្វែងរកសន្តិភាពសម្រាប់ទ្វីបអឺរ៉ុប។

***ខ.ដំណាក់កាលទី២* ការបង្កើតធម្មនុញ្ញអាត្លង់ទិក(The Atlantic Charter)៖**

បន្ទាប់ពីសេចក្តីប្រកាសវិមានហ្សេមរួចមក ព្រឹត្តិការណ៍សំខាន់មួយទៀត ដែលជាប្រភពកំណាក់កំណើតអង្គការសហប្រជាជាតិ គឺការអនុម័តនូវធម្មនុញ្ញអាត្លង់ទិក នាថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៤១។ ធម្មនុញ្ញនេះបានផ្តួចផ្តើមដោយមេដឹកនាំសំខាន់ពីររូបគឺ លោកវិនស្តុន ឆឺឈីល(Winston Churchill) នាយករដ្ឋមន្ត្រីអង់គ្លេស និងប្រធានាធិបតីអាម៉េរិក លោក ហ្វ្រង់គ្លីន រ៉ូស្វែល(Franklin Roosevelt) ដែលលោកទាំងពីរបានប្រជុំគ្នានៅលើនាវា ក្នុងមហាសមុទ្រអាត្លង់ទិក។

**គោលការណ៍នៃធម្មនុញ្ញអាត្លង់ទិក៖**

- ការប្រកាន់យកសិទ្ធិស្វ័យសម្រេចក្នុងដែនដីរៀងៗខ្លួន
- សិទ្ធិប្រជាពលរដ្ឋក្នុងការជ្រើសរើសទម្រង់រដ្ឋាភិបាល
- ជំរុញសមភាពក្នុងវិស័យពាណិជ្ជកម្ម
- សន្តិភាព និងសន្តិសុខ

- សេរីភាពខាងសមុទ្ទ
- លះបង់ចោលការប្រើកម្លាំង...។

***គ.ដំណាក់កាលទី៣ សេចក្តីប្រកាសសហប្រជាតិ*** **(The United Nations Declaration) ៖**

នេះជាព្រឹត្តិការណ៍សំខាន់ជាងគេ ដែលឈានទៅដល់ការបង្កើតអង្គការសហប្រជាជាតិ។ សេចក្តីប្រកាសរបស់សហប្រជាជាតិ បានចុះហត្ថលេខាដោយប្រធានាធិបតីអាម៉េរិក លោករ៉ូស្វែល នាយករដ្ឋមន្ត្រីអង់គ្លេស លោកឆឺឈីល តំណាងប្រទេសសូវៀតលោកម៉ាស៊ីម លីតវ៉ូណូវ (Maxim Litvinov) និងតំណាងប្រទេសចិនលោក ស៊ូង(Soong) នាថ្ងៃទី១ ខែមករា ឆ្នាំ១៩៤២។ សេចក្តីប្រកាសនេះ ក៏ត្រូវបានចុះហត្ថលេខាដោយបណ្តាអ្នកតំណាងមកពីប្រទេសចំនួន២០ទៀត[474]។

សេចក្តីប្រកាសសហប្រជាជាតិនេះ បានគូសបញ្ជាក់យ៉ាងច្បាស់ថា ចាំបាច់ត្រូវតែបង្កើតឡើងនូវអង្គការអន្តរជាតិមួយ ឈរលើគោលការស្មើភាព អធិបតេយ្យភាព របស់បណ្តារដ្ឋស្រឡាញ់សន្តិភាពទាំងអស់ មិនថាជារដ្ឋធំក្តី តូចក្តី ក្នុងគោលដៅជានា និងពង្រឹងសន្តិភាព និងសន្តិសុខ អន្តរជាតិ។

***ឃ.ដំណាក់កាលទី៤ សេចក្តីប្រកាសទីក្រុងមូស្គូ*** (Moscow Declaration) ៖

នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៤៣ តំណាងមកពីប្រទេសអង់គ្លេស សហរដ្ឋអាម៉េរិក សូវៀត និងចិន បានជួបប្រជុំគ្នានៅទីក្រុងមូស្គូ ហើយបានចុះហត្ថលេខាលើសេចក្តីប្រកាសមួយដែលគេហៅថា **សេចក្តីប្រកាសទីក្រុងមូស្គូ** ដែលក្នុងនោះបានបង្ហាញឱ្យឃើញពីការរួបរួមសកម្មភាពគ្នា ដើម្បីតស៊ូប្រឆាំងនឹងសត្រូវរួម។ ពិសេសជាងនេះទៅទៀត សេចក្តីប្រកាសបានបញ្ជាក់ថា ជាប្រការចាំបាច់ណាស់ និងបន្ទាន់ ដែលត្រូវតែបង្កើតអង្គការពិភពលោកមួយ(World Organization) ដែលផ្អែកលើគោលការណ៍ សមភាពនៃប្រជាជាតិនានា ហើយបើកទ្វារចំហ សម្រាប់ពលរដ្ឋទាំងអស់ក្នុងពិភពលោក ដើម្បីរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។

***ង.ដំណាក់កាលទី៥ សន្និសីទទីក្រុងតេអេរ៉ង់*** (Teheran Conference)

សេចក្តីប្រកាសទីក្រុងតេអេរ៉ង់ ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៤៣ ដោយមានការចូលរួមពីសហរដ្ឋអាម៉េរិក សហភាពសូវៀត និងចក្រភពអង់គ្លេស។ នៅក្នុងសន្និសីទនេះ តំណាងប្រទេសទាំងបី បានស្របគ្នាថា ជាការចាំបាច់ និងបន្ទាន់មួយដែលត្រូវបង្កើតអង្គការអន្តរជាតិមួចអាចមានសមត្ថភាព ថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។

***ច.ដំណាក់កាលទី៦ សន្និសីទទីក្រុងដុមបាតុងអ័ក*** (Dumbarton Oaks Conference)៖

នេះក៏ជាព្រឹត្តិការណ៍សំខាន់មួយដែរ នៅក្នុងការចាប់កំណើតអង្គការសហប្រជាជាតិ ។ សន្និសីទនេះធ្វើឡើងនៅក្នុងដំណាក់កាលទី២។ ដំណាក់កាលទី១ ចូលរួមដោយតំណាងមកពីប្រទេស សាធារណរដ្ឋចិន សូវៀត ចក្រភពអង់គ្លេស និងសហរដ្ឋអាម៉េរិក។ សេចក្តីសម្រេចរបស់អង្គសន្និសីទ គឺបាន កំណត់សមាសភាព មុខងារអង្គការសំខាន់ៗរបស់អង្គការសហប្រជាជាតិ។ នៅក្នុងសន្និសីទនេះ គេបានអនុម័តប្រសិទ្ធិនាមអង្គការនេះថា **អង្គការសហប្រជាជាតិ។** គេបានហៅសេចក្តីសម្រេចទីក្រុងដុមបាតុងអ័ក(ក្នុងរដ្ឋធានីវ៉ាស៊ីងតោន) ថាជាសំណើដុមបាតុងអ័ក (The Dumbarton Oaks Proposal)។ អង្គការសហប្រជាជាតិ ដែលនឹងត្រូវបង្កើតឡើងនេះឈរនៅលើធម្មនុញ្ញសហប្រជាជាតិ ដែលចេញមកពីទស្សនវិស័យ សំខាន់ៗនៃបណ្តារដ្ឋចូលរួម ក្នុងនោះបានយល់ស្របថា មុខងារចម្បងរបស់អង្គការសហប្រជាជាតិ គឺថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។

[474] នួន សុធិមន្ត, *ទំនាក់ទំនងអន្តរជាតិ*, ភ្នំពេញ, ឆ្នាំ២០០៧, ទំព័រ៩៩។

ប្រទេសដែលចូលរួមក្នុងអង្គការនេះ ត្រូវតែជារដ្ឋទាំងឡាយណា ដែលស្រឡាញ់សន្តិភាព។ យន្តការរបស់អង្គការសហប្រជាជាតិ នឹងរួមមានមហាសន្និបាត (General Assembly) ដែលប្រមូលផ្តុំរដ្ឋជាសមាជិក ក្រុមប្រឹក្សាសន្តិសុខ(Security Council) ដែលជាស្ថាប័នសម្រាប់ថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម(Economic and Social Council) លេខាធិការដ្ឋាន(Secretariat) និងតុលាការអន្តរជាតិ ហើយបញ្ហា ដែលនៅសេសសល់ តំណាងចូលរួមបានសម្រេចថា នឹងយកទៅពិភាក្សាជាចុងក្រោយនៅក្នុងសន្និសីទទីក្រុងសានហ្វ្រាន់ស៊ីស្កូ។

***ឆ.ដំណាក់កាលទី៧ សន្និសីទទីក្រុងយ៉ាល់តា*** (Yalta Conference) ៖

សន្និសីទយ៉ាល់តា ដែលបានប្រព្រឹត្តឡើង ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៤៥ ដោយមេដឹកនាំនៃសហរដ្ឋអាម៉េរិក សហភាពសូវៀត និងចក្រភពអង់គ្លេស។ មេដឹកនាំនៃប្រទេសទាំងបីមាន លោកប្រធានាធិបតីសហរដ្ឋអាម៉េរិក ហ្វ្រង់គ្លីនរ៉ូស្វែល(Franklin Roosevelt) មេដឹកនាំសូវៀតលោក ចូសេហ្វ ស្តាលីន(Joseph Staline) និងលោកនាយករដ្ឋមន្ត្រីអង់គ្លេស វិនស្តុន ឆឺឈីល (Winston Churchill)។ សន្និសីទនេះ បានបន្តពីសន្និសីទដុមបាតុងអ័ត នូវការរៀបចំធម្មនុញ្ញសហប្រជាជាតិ ដែលនឹងត្រូវយកទៅអនុម័ត នៅក្នុងសន្និសីទនាទីក្រុងសានហ្វ្រាន់ស៊ីស្កូ។

***ជ.ដំណាក់កាលទី៨ សន្និសីទទីក្រុងសានហ្វ្រាន់ស៊ីស្កូ*** (San Francisco Conference)៖

សន្និសីទសានហ្វ្រាន់ស៊ីស្កូ បានប្រព្រឹត្តឡើង ដែលដឹកនាំដោយលោក Lord Halifax និងបានអនុម័តទាំងស្រុងនូវធម្មនុញ្ញ និងលក្ខន្តិកៈនៃតុលាការអន្តរជាតិ និងការបង្កើតអង្គការសហប្រជាជាតិ ដែលមានរដ្ឋចំនួន៥១ បានចុះហត្ថលេខា។

សន្និសីទក្រុងសានហ្វ្រានស៊ីស្កូ បានប្រព្រឹត្តទៅពីថ្ងៃទី២៤ ខែមេសា ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៤៥ ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋានទាំងអស់ តំណាងឱ្យរដ្ឋនានា ដែលបានធ្វើការតស៊ូប្រឆាំងនឹងលទ្ធិហ្វាស៊ីសនិយម ក្រោមទិសស្លោកនៃពាក្យ "**សហប្រជាជាតិ**" ប្រឆាំងនឹងសត្រូវរួម។

## ២-គោលបំណង និងគោលការណ៍របស់អង្គការសហប្រជាជាតិ

ដោយធ្លាប់មានបទពិសោធន៍នៃភាពខ្វះខាតរបស់សង្គមប្រជាជាតិ តំណាងសហរដ្ឋអាម៉េរិក ចក្រភពអង់គ្លេស សហភាពសូវៀត និងប្រទេសចិន បានមករួមប្រជុំគ្នាបើកសន្និសីទអន្តរជាតិមួយនៅទីក្រុង ដុមបាតុងអ័ក(វ៉ាស៊ីនតោន)ដែលសន្និសីទនេះគេឱ្យឈ្មោះថាសន្និសីទចតុភាគី ប្រព្រឹត្តទៅពីខែ សីហា ដល់ខែកញ្ញា ឆ្នាំ១៩៤៤។

ធម្មនុញ្ញអង្គការសហប្រជាជាតិ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៤៥ និងចូលជាធរមាននៅថ្ងៃទី២៤ ខែតុលាឆ្នាំ១៩៤៥ ដោយមានការឱ្យសច្ចាប័នពីសំណាក់សមាជិកអចិន្ត្រៃយ៍ទាំង៥ របស់ក្រុមប្រឹក្សាសន្តិសុខ និងបណ្តាប្រទេសផ្សេងៗជាច្រើនទៀត ដែលបានចូលរួមក្នុងសន្និសីទនេះ។ ដូច្នេះពិភពលោកសម្រេចយកថ្ងៃទី២៤ តុលា ជាទិវាពិភពលោកនៃសហប្រជាជាតិ។

ស្ថាប័នផ្សេងៗរបស់អង្គការសហប្រជាជាតិ ដូចជាក្រុមប្រឹក្សាសន្តិសុខ ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម តុលាការអន្តរជាតិ បានបង្កើត និងអនុម័តក្នុងសម័យប្រជុំលើកទីមួយនៃមហាសន្និបាតអង្គការសហប្រជាជាតិ ដែលប្រព្រឹត្តទៅនៅទីក្រុងឡុងពីថ្ងៃទី១០ ខែមករា ដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៤៦[475]។

---

[475] នួន សុធិមន្ត, *ទំនាក់ទំនងអន្តរជាតិ*, ដ.ឯ.ម. ទំព័រ១០៣។

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៤៦ មហាសន្និបាត បានសម្រេចជ្រើសរើសយកទីស្នាក់ការនៅទីក្រុងញូយ៉ក សហរដ្ឋអាម៉េរិក។ សម័យប្រជុំលើកទី១នៃមហាសន្និបាតអង្គការសហប្រជាជាតិ ក៏បានជ្រើសតាំងលោកទ្រីវ លី(Trygve Lie) ជនជាតិ ន័រវែស ជាអគ្គលេខាធិការទី១ របស់អង្គការសហប្រជាជាតិ នាថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៤៦។

ធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលចូលជាធរមាននៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៥ ចែកចេញជា ១៩ជំពូក និង១១១មាត្រា។ ធម្មនុញ្ញនេះមានគោលបំណងសំខាន់បីគឺ[476]៖

- រួមរស់នៅក្នុងសន្តិភាព រួបរួមកម្លាំងគ្នាដើម្បីថែរក្សានូវសន្តិភាព និងសន្តិសុខអន្តរជាតិ។
- អនុវត្តិគោលការណ៍ច្បាប់ ដោយមិនប្រើប្រាស់កម្លាំងអាវុធ លើកលែងតែករណីចាំបាច់ ដើម្បីផលប្រយោជន៍រួម
- ពឹងផ្អែកលើស្ថាប័នអន្តរជាតិ ដើម្បីជួយឱ្យមានវឌ្ឍនភាពខាងវិស័យសេដ្ឋកិច្ច និងសង្គម ដល់ប្រជាពលរដ្ឋទាំងឡាយ។

***ខ្លឹមសារសំខាន់នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ៖***

- ជំពូក១៖ គោលបំណង និងគោលច្បាប់ មាត្រា១-២
- ជំពូក២៖ អំពីសមាជិកភាព មាត្រា ៣-៦
- ជំពូក៣៖ អំពីអង្គការ មាត្រា ៧-៨
- ជំពូក៤៖ អំពីមហាសន្និបាត មាត្រា ៩-២២
- ជំពូក៥៖ ក្រុមប្រឹក្សាសន្តិសុខ មាត្រា២៣-៣២
- ជំពូក៦៖ បទបញ្ញាខាងសន្តិវិធីចំពោះការខ្វែងយោបល់ មាត្រា ៣៣-៣៨
- ជំពូក៧៖ អំពីអំពើដែលគំរាមកំហែងដល់សន្តិភាព ការរំលោភដល់សន្តិភាព និងអំពើឈ្លានពាន មាត្រា ៣៩-៥១
- ជំពូក៨៖ កិច្ចព្រមព្រៀងតំបន់ ភូមិភាគ (Regional agreements) មាត្រា៥២-៥៤
- ជំពូក៩៖ សហប្រតិបត្តិការសេដ្ឋកិច្ច សង្គមអន្តរជាតិ(International Economic and Social Cooperation) មាត្រា ៥៥-៦0
- ជំពូក១០៖ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (Economic and Social Council) មាត្រា ៦១-៧២
- ជំពូក១១៖ សេចក្តីប្រកាសស្តីពីដែនដី មិនមែនស្វ័យភាព (Declaration regarding Non-self governing territories) មាត្រា ៧៣-៧៤
- ជំពូក១២៖ របៀបរបបជាអន្តរជាតិខាងការគ្រប់គ្រង (International trusteeship system) មាត្រា ៧៥-៨៥
- ជំពូក១៣៖ ក្រុមប្រឹក្សាភិបាល (Trusteeship Council) មាត្រា ៨៦-៩១
- ជំពូក១៤៖ តុលាការអន្តរជាតិ (International Council of Justice)មាត្រា ៩២-៩៦

[476] ក្រសួងអប់រំ យុវជន និងកីឡា, *ប្រវត្តិវិទ្យាថ្នាក់ទី១១*, គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, ឆ្នាំ២០១៤, ទំព័រ១១៥។

- ❖ ជំពូក១៥៖ លេខាធិការដ្ឋាន (Secretariat) មាត្រា ៩៧-១០១
- ❖ ជំពូក១៦៖ បទបញ្ញត្តិផ្សេងៗ មាត្រា១០២-១០៥
- ❖ ជំពូក១៧៖ អន្តរបញ្ញត្តិខាងសន្តិសុខ (Transitional Security Arrangements) មាត្រា ១០៦-១០៧
- ❖ ជំពូក១៨៖ ការធ្វើវិសោធនកម្ម(Amendments) មាត្រា ១០៨-១០៩
- ❖ ជំពូក១៩៖ ការផ្តល់សច្ចាប័ន និងការចុះហត្ថលេខា (Ratification and Signature) មាត្រា ១១០-១១១។

## ២.១-គោលបំណង

យោងតាមមាត្រា១ នៃធម្មនុញ្ញសហប្រជាជាតិ ដែលបានចែងអំពីគោលបំណងសំខាន់ៗទាំងឡាយរបស់អង្គការសហប្រជាជាតិក្នុងនោះគឺ៖

- ➢ ថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ហើយដើម្បីសម្រេចនូវគោលបំណងនេះ គឺត្រូវអនុវត្តវិធានការរួមគ្នាដ៏សក្តិសិទ្ធិដើម្បីការពារ និងបញ្ចៀសមិនឱ្យមានការគំរាមកំហែងមកលើសន្តិភាព និងបង្ក្រាបគ្រប់អំពើឈ្លានពាន ឬសកម្មភាពដែលធ្វើឱ្យបែកបាក់នូវសន្តិភាព តាមមធ្យោបាយសន្តិវិធី និងអនុលោកទៅតាមគោលការណ៍ច្បាប់ យុត្តិធម៌ និងនីតិវិធីអន្តរជាតិ។
- ➢ ពង្រឹងទំនាក់ទំនងជាមិត្តរវាងប្រជាជាតិទាំងឡាយ ដោយបង្កើតឡើងនៅលើការគោរពនូវគោលការណ៍សមភាពនៃសិទ្ធិរបស់ប្រជាពលរដ្ឋនិងសិទ្ធិសម្រេចដោយខ្លួនឯង(The Principle of Self Determination)។
- ➢ សម្រេចឱ្យបាននូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងគោលបំណងដោះស្រាយរាល់បញ្ហាជាអន្តរជាតិនានា ដែលទាក់ទងទៅនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច បញ្ញាជន ឬមនុស្សធម៌ ពង្រីកនិងលើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសម្រាប់មនុស្សគ្រប់រូបដោយគ្មានការបែងចែក ពូជសាសន៍ ភេទ ភាសា ឬសាសនាឡើយ។
- ➢ ជាទីប្រជុំមួយដើម្បីរួមកម្លាំងនៃប្រជាជាតិទាំងអស់ឆ្ពោះទៅរកគោលបំណងរួម។

## ២.២-គោលការណ៍នានារបស់អង្គការសហប្រជាជាតិ

គោលការណ៍សំខាន់ៗរបស់អង្គការសហប្រជាជាតិរួមមាន៖

➢ អង្គការសហប្រជាជាតិ បង្កើតឡើងតាមគោលការណ៍សមភាព ប្រកបដោយអធិបតេយ្យភាព នៃសមាជិកទាំងអស់។

➢ សមាជិកនៃអង្គការសហប្រជាជាតិ ត្រូវបំពេញដោយសុចរិត នូវកាតព្វកិច្ចដែលខ្លួនទទួលបន្ទុកតាមគោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិដែលមានមកហើយ ដើម្បីធានារ៉ាប់រងដល់ការអនុវត្តសិទ្ធិនិងអត្ថប្រយោជន៍ប្រកបដោយផ្លែផ្កា ដែលបណ្តាលមកពីគុណសម្បត្តិនៃសមាជិក។

➢ សមាជិកនៃអង្គការសហប្រជាជាតិ ត្រូវសម្រួលការខ្វែងយោបល់អន្តរជាតិតាមមធ្យោបាយសន្តិវិធី ដើម្បីធ្វើយ៉ាងណាឱ្យបានសន្តិភាព និងសន្តិសុខអន្តរជាតិព្រមទាំងយុត្តិធម៌ដោយមិនឱ្យធ្លាក់ទៅក្នុងគ្រោះថ្នាក់។

➢ សមាជិកនៃអង្គការសហប្រជាជាតិ ត្រូវឧបត្ថម្ភដោយពេញបន្ទុកដល់អង្គការនេះ ហើយជៀសវាងកុំឧបត្ថម្ភទៅរដ្ឋណាមួយ ដែលអង្គការសហប្រជាជាតិបានរឹតត្បិតទៅលើរដ្ឋនោះ។

➢ អង្គការសហប្រជាជាតិ ត្រូវធ្វើយ៉ាងណាឱ្យរដ្ឋ ដែលមិនមែនជាសមាជិកគោរពតាមគោលការណ៍ច្បាប់ខាងលើនេះជាចាំបាច់ ដើម្បីទ្រទ្រង់សន្តិភាព និងសន្តិសុខអន្តរជាតិ។

➢ មិនឱ្យមានបទបញ្ញត្តិណាមួយអនុញ្ញាតឱ្យអង្គការសហប្រជាជាតិ ធ្វើអន្តរាគមន៍ក្នុងរឿងដែលទាក់ទិនទៅក្នុងសមត្ថកិច្ចនៃរដ្ឋណាមួយ ឬបង្ខំរដ្ឋសមាជិកទាំងឡាយ ឱ្យដាក់រឿងតាមប្រភេទទៅក្នុងបរិបទ វិនិច្ឆ័យនៃបទបញ្ញាតាមគោលការណ៍ធម្មនុញ្ញ ក៏ប៉ុន្តែគោលការណ៍បែបនេះមិនប៉ះពាល់ការអនុវត្តអំណាច រឹតត្បិត ដែលមានកំណត់ក្នុងជំពូក៧ ឡើយ[477]។

## ៣-សមាជិកភាព

### ៣.១-លក្ខខណ្ឌសម្រាប់ការចូលជាសមាជិក

យោងតាមមាត្រ៤ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ រាល់បណ្តារដ្ឋផ្សេងៗអាចសុំចូលជាសមាជិកអង្គការសហប្រជាជាតិបាន លុះត្រាតែបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- ទាល់តែជារដ្ឋមួយពិតប្រាកដ( It must be a state )
- ជារដ្ឋនិយមសន្តិភាព( It must be peace-loving )
- រដ្ឋនោះត្រូវទទួលយកកាតព្វកិច្ចទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិ( It must accept the obligations of the Charter )
- អាចនឹងបំពេញបាន និងប្រុងប្រៀបនឹងបំពេញនូវកាតព្វកិច្ចទាំងនោះទៀតផង( It must be able to carry out these obligations )។

សមាជិកស្ថាបនិករបស់អង្គការសហប្រជាជាតិមានចំនួន៥១ប្រទេស ដែលជាប្រទេសចូលរួមក្នុងសន្និសីទទីក្រុងសានហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាម៉េរិក។ ធម្មនុញ្ញនេះត្រូវបានចុះហត្ថលេខាដោយប្រទេសចំនួន៥០ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៤៥ ដោយពេលនោះអវត្តមានតំណាងប្រទេសប៉ូឡូញ។ ប៉ូឡូញ បានចុះ ហត្ថលេខាលើធម្មនុញ្ញនេះក្រោយគេ គឺនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៤៥។ ធម្មនុញ្ញនេះត្រូវបានប្រទេសស្ថាបនិកទាំង៥១ ផ្តល់សច្ចាប័នរួចរាល់ និងចូលជាធរមាននៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៥។ ប្រទេសកម្ពុជា បានចូលជាសមាជិកអង្គការសហប្រជាជាតិនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ បន្ទាប់ពីទទួលបានឯករាជ្យពេញលេញពីប្រទេសបារាំង។ ក្នុងនាមជាសមាជិកនៃអង្គការសហប្រជាជាតិ ប្រទេសកម្ពុជាធ្លាប់បានដាក់ពាក្យបណ្តឹងទៅកាន់តុលាការអន្តរជាតិនៃទីក្រុងឡាអេ ឱ្យជួយដោះស្រាយវិវាទដោយប្រទេសថៃបានចូលកាន់កាប់ប្រាសាទព្រះវិហារ ចាប់តាំងពីឆ្នាំ១៩៥៤។ នៅថ្ងៃ១៥ ខែមិថុនា ឆ្នាំ១៩៦២ កម្ពុជាបានឈ្នះរឿងក្តីនេះនៅតុលាការក្រុងឡាអេ។

ក្នុងករណីប្រទេសចិន យើងឃើញថាមានភាពចម្រោងចម្រាសគ្នា បន្ទាប់ពីប្រទេសចិន ត្រូវបែកជាពីរនៅឆ្នាំ១៩៤៩ គឺសាធារណរដ្ឋប្រជាមានិតចិន( កុម្មុយនីស្ត ) និងសាធារណរដ្ឋចិន( ចិនជាតិនិយម )។ ពេលនោះកៅអីរបស់ចិន ត្រូវបានគេប្រគល់ទៅឱ្យ ចិនជាតិនិយម( កោះតៃវ៉ាន់ ) ជាអ្នកតំណាងឱ្យចិនទាំងមូល។ រហូតមកដល់ឆ្នាំ១៩៧១ ទើបមហាសន្និបាតអង្គការសហប្រជាជាតិ បានសម្រេចប្រគល់អសនៈនោះទៅឱ្យសាធារណរដ្ឋប្រជាមានិតចិន ជំនួសកោះតៃវ៉ាន់វិញ។ រហូតមកដល់បច្ចុប្បន្នតៃវ៉ាន់ ពុំត្រូវបានគេទទួលស្គាល់ជាសមាជិកអង្គការសហប្រជាជាតិឡើយ។

---

[477] ក្រសួងអប់រំ យុវជន និងកីឡា, *ប្រវត្តិវិទ្យាថ្នាក់ទី១១*, ដ.ឯ.ម.,ទំព័រ១១៦

អាល្លឺម៉ង់ខាងកើត និងអាល្លឺម៉ង់ខាងលិច មានអសនៈរៀងៗខ្លួន ចាប់តាំងពីឆ្នាំ១៩៧៣ រហូតដល់ ឆ្នាំ ១៩៩០ នៅពេលដែលអាល្លឺម៉ង់ត្រូវបានបង្រួបបង្រួមតែមួយឡើងវិញ ដោយអាល្លឺម៉ង់ខាងកើតសុខចិត្ត រំលាយរចនាសម្ពន្ធរបស់ខ្លួន។

**ការចូលជាសមាជិកអង្គការសហប្រជាជាតិមានពីរដំណាក់កាលៈ**

- សមាជិកសង្កេតការណ៍ (Observers)
- សមាជិកពេញសិទ្ធិ(Full member)

### ៣.២-ការដកខ្លួនចេញពីអង្គការសហប្រជាជាតិ

រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ អាចដកខ្លួនចេញពីអង្គការនេះវិញដោយសេរី ដោយគ្រាន់តែបង្ហាញពីហេតុផលនៃការដកខ្លួន របស់ខ្លួនតែប៉ុណ្ណោះ។ គោលការណ៍នេះ ពុំបានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិទេ ប៉ុន្តែវាកើតចេញពីសេចក្តីថ្លែងការណ៍បកស្រាយមួយ ដែលត្រូវបានទទួលការអនុម័ត នៅក្នុងសន្និសីទទីក្រុងសានហ្វ្រានស៊ីស្កូ។ ឧទាហរណ៍ ករណីប្រទេសឥណ្ឌូណេស៊ី បានដកខ្លួនចេញពីអង្គការសហប្រជាជាតិ នាឆ្នាំ១៩៦៥ ដោយចេតនា ដើម្បីបង្ហាញឱ្យឃើញនូវការមិនពេញចិត្តរបស់ខ្លួនចំពោះការដែលមហាសន្និបាត បានបោះឆ្នោតបញ្ចូលប្រទេសម៉ាឡេស៊ី ទៅក្នុងក្រុមប្រឹក្សាសន្តិសុខ ពីព្រោះពេលនោះ ប្រទេសឥណ្ឌូណេស៊ី និងប្រទេសម៉ាឡេស៊ី កំពុងកើតមានជម្លោះជាមួយគ្នា។

### ៣.៣-ការបណ្តេញសមាជិកចេញពីអង្គការសហប្រជាជាតិ

ការបណ្តេញចេញ អនុវត្តចំពោះរដ្ឋជាសមាជិកណាដែលប្រព្រឹត្តល្មើសផ្ទួនៗគ្នា ផ្ទុយពីគោលការណ៍ដែលមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ។ នីតិក្រមនៃការបណ្តេញចេញ ក៏ដូចជានីតិក្រមនៃការទទួលឱ្យចូលជាសមាជិកដែរ គឺក្រុមប្រឹក្សាសន្តិសុខ ស្នើទៅមហាសន្និបាត ឱ្យបណ្តេញចេញរដ្ឋណាមួយ ដែលប្រព្រឹត្តល្មើស ហើយមហាសន្និបាតជាអ្នកសម្រេចលើការបណ្តេញចេញ ឬមិនបណ្តេញចេញ។

## ៤-ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ និងតួនាទី

### ៤.១-ស្ថាប័នរបស់អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិមានស្ថាប័នសំខាន់ៗទាំងអស់ចំនួន៦ គឺ

- មហាសន្និបាត(General Assembly)
- ក្រុមប្រឹក្សាសន្តិសុខ(Security Council)
- ក្រុមប្រឹក្សាសេដ្ឋកិច្ច-សង្គម(Economic and Social Council)
- ក្រុមប្រឹក្សាភិបាល(Trusteeship Council)
- តុលាការអន្តរជាតិ(International Court of Justice)
- លេខាធិការដ្ឋាន(Secretariat)

## ៤.២-តួនាទី និងការងារនៃស្ថាប័ន របស់អង្គការសហប្រជាជាតិ

**ក-មហាសន្និបាត**

ជាស្ថាប័នមួយដ៏សំខាន់ ដែលមានសិទ្ធិសម្រេចកិច្ចការទាំងឡាយ។ សម័យប្រជុំរបស់អង្គការសហប្រជាជាតិចែកជាពីរគឺៈ

- សម័យប្រជុំប្រចាំឆ្នាំ ដំណើរការពីខែកញ្ញា ដល់ខែធ្នូ ជារៀងរាល់ឆ្នាំ

- សម័យប្រជុំវិសាមញ្ញ ប្រព្រឹត្តឡើងតាមការចាំបាច់ និងសំណូមពររបស់ក្រុមប្រឹក្សាសន្តិសុខ តាមសំឡេងភាគច្រើនរបស់រដ្ឋជាសមាជិក។

មុនពេលចាប់ផ្ដើមរបៀបវារៈសម័យប្រជុំ គេត្រូវជ្រើសតាំងប្រធាននៃមហាសន្និបាត និងអនុប្រធាន ២១រូបទៀត។ ការជ្រើសរើសប្រធានសម័យប្រជុំនេះ គេឆ្លាស់គ្នារៀងរាល់ឆ្នាំទៅតាមភូមិសាស្ត្រ ម្ដងអាស៊ី ម្ដងអឺរ៉ុប ម្ដងអាហ្វ្រិក ...។ អ្នកចូលរួមក្នុងសម័យប្រជុំនេះ អាចជាប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ឬក៏រដ្ឋមន្ត្រីក៏បាន។

នៅក្នុងសម័យប្រជុំ រដ្ឋមួយចំនួនបានរួមគ្នាជាក្រុម ជាតំបន់ ដើម្បីការពារផលប្រយោជន៍ និងនយោបាយរួមរបស់ពួកគេ។ ភាសាផ្លូវការដែលគេប្រើក្នុងមហាសន្និបាតរួមមាន ភាសាអង់គ្លេស បារាំង រុស្ស៊ី ចិន អារ៉ាប និងអេស្ប៉ាញ។

**ខ-ក្រុមប្រឹក្សាសន្តិសុខ**

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាស្ថាប័ននីតិប្រតិបត្តិ ដែលមានតួនាទីសំខាន់ក្នុងការពង្រឹងសន្តិភាព និងសន្តិសុខអន្តរជាតិ។ ពេលបង្កើតដំបូងក្រុមប្រឹក្សានេះមានសមាជិកចំនួន១១ ប្រទេស តែរហូតដល់ឆ្នាំ១៩៦៣ គេបានធ្វើវិសោធនកម្មអនុញ្ញាតឱ្យមានសមាជិកដល់ទៅ១៥ប្រទេស។ ក្នុងចំនោមសមាជិកទាំង១៥ប្រទេសនេះ ចែកចេញជាពីរប្រភេទគឺសមាជិកអចិន្ត្រៃយ៍ និងសមាជិកធម្មតា។ សមាជិកអចិន្ត្រៃយ៍មានមហាអំណាចទាំង៥គឺ អាម៉េរិក រុស្ស៊ី ចិន អង់គ្លេស និងបារាំង។ សមាជិកអចិន្ត្រៃយ៍ទាំង៥នេះមានសិទ្ធិវេតូ ជំទាស់មិនឱ្យក្រុមប្រឹក្សាសន្តិសុខអាចដំណើរការបាន នៅក្នុងដំណោះស្រាយណាមួយរបស់ ខ្លួន។ ចំណែកសមាជិកធម្មតា ឬសមាជិកមិនអចិន្ត្រៃយ៍ ទាំង១០ ត្រូវបានបោះឆ្នោតជ្រើសរើសដោយមហា សន្និបាតសម្រាប់រយៈពេល២ឆ្នាំម្ដង។ សមាជិកមិនអចិន្ត្រៃយ៍ ជាតំណាប្រទេសតាមតំបន់នានានៃពិភពលោក ដោយបែងចែកកៅអីទៅតាមរបៀបដូចខាងក្រោម៖

**អសនៈនៃសមាជិកមិនអចិន្ត្រៃយ៍ របស់ក្រុមប្រឹក្សាសន្តិសុខ បែងចែកដូចតទៅ៖**

- កៅអី៥ សម្រាប់រដ្ឋនៅអាស៊ី និងអាហ្វ្រិក
- កៅអី១ សម្រាប់រដ្ឋនៅអឺរ៉ុបខាងកើត
- កៅអី២ សម្រាប់រដ្ឋនៅអាម៉េរិកឡាទីន
- កៅអី២ សម្រាប់រដ្ឋនៅអឺរ៉ុបខាងលិច និងរដ្ឋដទៃទៀត

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ អាចអនុម័តសេចក្ដីសម្រេចបានដោយសំឡេងគាំទ្រ៩ ក្នុងចំណោមសមាជិកទាំងអស់១៥ប្រទេស ដែលក្នុងនោះសមាជិកអចិន្ត្រៃយ៍ត្រូវតែគាំទ្រទាំង៥សំឡេងជាឯកច្ឆ័ន្ទ។សមាជិកមិនអចិន្ត្រៃយ៍មាន Bolivia (2018), Egypt (2017), Ethiopia (2018), Italy (2017), Japan (2017), Kazakhstan (2018), Senegal (2017), Sweden (2018), Ukraine (2017) និង Uruguay (2017) [478]។ មុខងារសំខាន់នៃក្រុមប្រឹក្សាសន្តិសុខ៖

- ដោះស្រាយរាល់វិវាទរវាងរដ្ឋទាំងឡាយ ដែលជាសមាជិករបស់អង្គការសហប្រជាជាតិ
- រៀបចំផែនការកម្រិតគ្រឿងសព្វាវុធ
- ធ្វើអន្តរាគមន៍ក្នុងករណីមានការគំរាមកំហែងចំពោះសន្តិភាព ឬមានអំពើឈ្លានពាន
- សម្រេចប្រើកម្លាំងបង្ខំឱ្យអនុវត្តសាលក្រមរបស់តុលាការអន្តរជាតិ

[478] http://www.un.org/en/sc/members/.

ប្រសិនបើប្រទេសជាសមាជិកណាមួយ ដែលទាក់ទងនៅក្នុងរឿងជម្លោះ មិនព្រមអនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ក្រុមប្រឹក្សានេះនឹងចាត់វិធានការពីរយ៉ាងដូចខាងក្រោម៖

**១-ទណ្ឌកម្មមិនប្រើកម្លាំង**

ធ្វើការពិភាក្សាតាមផ្លូវទូត។

ដាក់ទណ្ឌកម្មសេដ្ឋកិច្ច មានការកាត់ផ្តាច់ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ បិទផ្លូវគោក ឬផ្លូវអាកាស ដែលនាំឱ្យប្រទេសនោះ មានវិបត្តិសេដ្ឋកិច្ច និងវិបត្តិសង្គម។

**២-ទណ្ឌកម្មដោយប្រើកម្លាំង**

មានការបញ្ជូនទ័ព(មួកខៀវ) ទៅហ៊ុមព័ទ្ធ ឬក៏បញ្ជូននាវាទៅក្នុងដែនទឹក ឬក៏បើកការវាយប្រហារតាមផ្លូវអាកាស ដើម្បីគាបសង្កត់ឱ្យប្រទេសនោះព្រមបន្ធន់តវិយាបថទទួលយកលក្ខខណ្ឌ ដែលក្រុមប្រឹក្សាសន្តិសុខ បានដាក់ឱ្យអនុវត្តតាម។ ដូចជាសង្គ្រាមនៅឈូងសមុទ្រពែក្ស ឆ្នាំ១៩៩១ របស់អង្គការសហប្រជាជាតិ ដើម្បីប្រឆាំងនឹងប្រទេសអ៊ីរ៉ាក់(Iraq) ដែលមិនព្រមដកទ័ពចេញពីប្រទេសកូវ៉ែត(Kuwait)។

**គ-ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម**

ជាយន្តការសម្រាប់ធ្វើការពិភាក្សា ជជែកដេញដោលទៅលើបញ្ហាដែលទាក់ទងទៅនឹងវិស័យសេដ្ឋកិច្ច និងសង្គមក្នុងក្របខ័ណ្ឌជាអន្តរជាតិ។ ពីមុនមានសមាជិក ចំនួន១៨ប្រទេសប៉ុណ្ណោះ ក្រោយមកមានចំនួន៥៤ប្រទេស។

**ឃ-ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលត្រូវបានបង្កើតឡើង ដើម្បីធ្វើសកម្មភាពជំរុញតំបន់១១កន្លែង ឱ្យទទួលបាន ស្វយ័តភាព និងឯករាជ្យ។ នៅឆ្នាំ១៩៩៤ ប្រទេសប៉ាលូ បានទទួលឯករាជ្យចុងក្រោយគេ (ប៉ាលូធ្លាប់ស្ថិតនៅក្រោមអាណាព្យាបាលរបស់សហរដ្ឋអាម៉េរិក) បន្ទាប់ពីនេះមកក្រុមប្រឹក្សាភិបាលបានបញ្ចប់សកម្មភាពរបស់ខ្លួន។

**ទឹកដីតំបន់ទាំង១១**

- កាមេរ៉ូន ក្រោមការគ្រប់គ្រងរបស់រដ្ឋបាលបារាំង
- កាមេរ៉ូន ក្រោមការគ្រប់គ្រងរបស់រដ្ឋបាលអង់គ្លេស
- ប៉ាពួញូគីនេ (Papua New Guinea)
- រូនដា-អ៊ូរ៉ានឌី( Ruanda-Urundi)
- តាំងហ្គានីយីកា(Tanganyika)
- តូហ្គោក្រោមរដ្ឋបាលបារាំង(Togoland under French administration) (French Togoland): Became independent as Togo in 1960.
- តូហ្គោក្រោមរដ្ឋបាលអង់គ្លេស (Togoland under British administration)
- សាម៉ៅខាងលិច (Western Samoa)
- ណឺរូ (Trust Territory of Nauru)
- សូម៉ាលី
- ប៉ាលូ

**ង-តុលាការអន្តរជាតិ**

តុលាការអន្តរជាតិ គឺជាអង្គការច្បាប់ដ៏សំខាន់មួយ របស់អង្គការសហប្រជាជាតិ មានទីស្នាក់ការនៅទីក្រុងឡាអេ ប្រទេសហូឡង់។ តុលាការអន្តរជាតិដំណើរការសកម្មភាពរបស់ខ្លួន ដោយផ្អែកលើលក្ខន្តិកៈ ដែលជាផ្នែកមួយមិនអាចកាត់ផ្តាច់ចេញបានពីធម្មនុញ្ញសហប្រជាជាតិ។ តុលាការមានសមាសភាពចៅក្រម ចំនួន ១៥រូប។ ចៅក្រមនីមួយៗត្រូវបានជ្រើសរើសតាមរយៈនៃការបោះឆ្នោត ហើយកាន់មុខតំណែងក្នុងអាណត្តិ៩ឆ្នាំ ប្រកបដោយឯករាជ្យភាព និងក្រមសីលធម៌ខ្ពស់បំផុត និងប្រកបដោយសមត្ថកិច្ចអន្តរជាតិ។ ចៅក្រមទាំងនេះមានសញ្ជាតិខុសៗគ្នា ត្រូវតែងតាំងឡើង តាមរយៈមហាសន្និបាតនៃអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសន្តិសុខ។ ចៅក្រមតុលាការអន្តរជាតិ គឺមិនអាចដកហូតចេញពីមុខងារបានឡើយ និងមានអភ័យឯកសិទ្ធិខាងការទូត។ សមាជិកតុលាការទាំងអស់ មុននឹងចូលបំពេញមុខងារត្រូវប្រកាសជាឱឡារិកថានឹងបំពេញមុខងាររបស់ខ្លួនដោយមិនលំអៀង និងប្រកបដោយសតិសម្បជញ្ញៈ។

**តុលាការអន្តរជាតិមានមុខងារពីរគឺ**

1. យោងតាមច្បាប់អន្តរជាតិ ដោះស្រាយវិវាទខាងផ្លូវច្បាប់ ដែលបណ្តារដ្ឋនានាបានស្នើឡើង។ តុលាការអន្តរជាតិដោះស្រាយវិវាទ រវាងប្រទេស និងប្រទេស។ រូបវន្តបុគ្គល និងនីតិបុគ្គល ពុំមានសិទ្ធិយករឿងវិវាទរបស់ខ្លួនទៅដោះស្រាយក្នុងតុលាការអន្តរជាតិបានឡើយ។
2. ផ្តល់មតិពិគ្រោះស្តីពីបញ្ហាផ្លូវច្បាប់ ដែលត្រូវបានដាក់ជូនដោយអង្គការ ឬទីភ្នាក់ងារអន្តរជាតិទាំងឡាយដែលមានសិទ្ធិត្រឹមត្រូវ។ ប៉ុន្តែ ការផ្តល់មតិយោបល់ មានលក្ខណៈគ្រាន់តែជាសំណូមពរស្នើ ឬជាការស្នើយោបល់ប៉ុណ្ណោះ ពុំមានតម្លៃជាការចាប់បង្ខំឡើយ។

ចាប់ពីថ្ងៃបដិសន្ធិមក តុលាការអន្តរជាតិបានដោះស្រាយទំនាស់ជាង៧០ករណីរួចមកហើយ (ដំណោះស្រាយបញ្ហាប្រាសាទព្រះវិហារ វិវាទខ្មែរ-ថៃ ត្រូវបានតុលាការអន្តរជាតិសម្រេច ដោយឱ្យភាគីខ្មែរ ជាអ្នកឈ្នះ)។ ដំណោះស្រាយទាំងនោះទាក់ទងនឹងបញ្ហាជាច្រើនៈ

- បញ្ហាជម្លោះព្រំប្រទល់ដែនដី និងព្រំដែនសមុទ្រអធិបតេយ្យភាពដែនដី
- ការមិនប្រើកម្លាំង
- ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃទៀត
- ទំនាក់ទំនងការទូត
- ការចាប់ជាចំណាប់ខ្មាំង
- សិទ្ធិសុំជ្រកកោន
- ជនជាតិ
- ភាពជាអាណាព្យាបាលស្របច្បាប់
- សិទ្ធិធ្វើដំណើរឆ្លងកាត់ និងសិទ្ធិខាងវិស័យសេដ្ឋកិច្ច

**ច-លេខាធិការដ្ឋាន**

ស្ថាប័ននេះទទួលបន្ទុកផ្នែករដ្ឋបាល នៃអង្គការសហប្រជាជាតិ មានអគ្គលេខាជាប្រធាន ដែលមាន អាណត្តិ៥ឆ្នាំ ជ្រើសតាំងដោយមហាសន្និបាត។ តំណែងជាអគ្គលេខាធិការនេះ សម្រាប់មនុស្សដែលមានសមត្ថភាពខ្ពស់ និងចាស់ទុំដោយមានបទពិសោធន៍នយោបាយ និងមាននិន្នាការមិនលំអៀងប្រកបដោយសីលធម៌ខ្ពស់។

អគ្គលេខាធិការអង្គការសហប្រជាជាតិមានតួនាទីសំខាន់បីគឺ៖ តួនាទីនយោបាយ តួនាទីការទូត និងតួនាទីកិច្ចការរដ្ឋបាល។

លេខាធិការដ្ឋាន ចែកចេញជាការិយាល័យសំខាន់ៗដូចជា៖ ការិយាល័យនីតិបញ្ញត្តិ ការិយាល័យរំលាយសព្វាវុធ ការិយាល័យប្រឹក្សាភិបាល និងការិយាល័យកិច្ចការសេដ្ឋកិច្ច។

ចាប់ពីពេលបង្កើតហូតមកដល់បច្ចុប្បន្ន អង្គការសហប្រជាជាតិមានអគ្គលេខាធិការ ចំនួន៩រូប


លោក ទ្រីវ លី


លោក ដាក់ហាំម៉ាសូល


លោក អ៊ូថាន់


លោក គៀតវាលហែម


លោក សាវីយេប៉េរ៉េដឺគូអេ


លោក ប៊ុត្រូសប៊ុត្រូសកា


លោក កូហ្វីអាននណាន


លោក បានគីមូន

**ក.លោក ទ្រីវ លី** Trygve Lie (1946-1952) លោកអគ្គលេខាធិការដំបូងបង្អស់ មានសញ្ជាតិន័រវែស (Norwegian) បានត្រូវតែងតាំងនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៤៦ អាណត្តិនេះត្រូវបញ្ចប់នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៥០ ហើយលោកត្រូវបានតែងតាំងបន្តរហូតដល់ឆ្នាំ១៩៥២។

**ខ.លោក ដាក់ហាំម៉ាសូល** Dag Hammarskjold (1953-1961)

លោកជាជនជាតិ ស៊ុយអែត (Swedish) ត្រូវតែងតាំងជាអគ្គលេខានៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៥៣ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៦១។

**គ.លោក អ៊ូថាន់**

លោកជាជនជាតិភូមា ត្រូវតែងតាំងជាអគ្គលេខានៃអង្គការសហប្រជាជាតិនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៦១ ដល់ថ្ងៃទី៣១ ខែធ្នូឆ្នាំ១៩៧១។ លោកអ៊ូថាន់ បានខិតខំបំពេញកាតព្វកិច្ចដើម្បីសន្តិភាពពិភពលោក ដូចជា៖

-វិបត្តិនៃកោះស៊ីស ដែលកើតឡើងរវាងប្រទេសតួកគី និងក្រិក។ ក្រុមប្រឹក្សាសន្តិសុខ បានបញ្ជូនទ័ព អង្គការសហប្រជាជាតិចូលទៅកោះនេះ ដើម្បីរារាំងកុំឱ្យមានជម្លោះរវាងប្រទេសទាំងពីរតទៅទៀត។

-វិបត្តិរវាងប៉ាគីស្ថាន និងឥណ្ឌា ក្នុងរឿងដែនដីកាស្មៀរ បណ្តាលឱ្យមានសង្គ្រាមអូសបន្លាយពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៧២។ ក្រុមប្រឹក្សាសន្តិសុខបានបញ្ជូនភ្នាក់ងារយោធាមួយក្រុម ដើម្បីត្រួតពិនិត្យមើលស្ថានភាពទ័ពរវាងឥណ្ឌា និងប៉ាគីស្ថាន នៅក្នុងដែនដីកាស្មៀរ។

**ឃ.លោក គៀត វលហែម** Kurt Waldheim( 1972-1981 )

លោកជាជនជាតិអូទ្រីស ត្រូវតែងតាំងជាអគ្គលេខានៃអង្គការសហប្រជាជាតិនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៨២ និងតែងតាំងជាអគ្គលេខានៅអាណត្តិទី២ នៅខែធ្នូ១៩៧៦ ហើយបញ្ចប់អាណត្តិនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៨១។

នៅឆ្នាំ១៩៧៣ លោកគៀត វាលហែម បានធ្វើការប្រឹងប្រែងនៅក្នុងជម្លោះរ៉ាំរ៉ៃរវាងអារ៉ាប និងអ៊ីស្រាអែល ដោយដាក់ពង្រាយកងទ័ពអង្គការសហប្រជាជាតិ។

**ង.លោក សាវីយេប៉េរេដឺគុអេឡា** SavierPerez de Cuellar( 1982-1991 )

លោកជាជនជាតិប៉េរូ ជ្រើសតាំងជាអគ្គលេខាចំនួន២អាណត្តិ។ នៅក្នុងអាណត្តិរបស់គាត់ អង្គការសហប្រជាជាតិបានខិតខំពន្លត់ភ្លើងសង្គ្រាមរវាង អ៊ីរ៉ាក់ និងអ៊ីរ៉ង់ ដែលបានផ្ទុះនៅឆ្នាំ១៩៨០ និងបានធ្វើអន្តរាគម ទៅក្នុងវិបត្តិកម្ពុជា ដោយជួយប្រឹងប្រែងឱ្យមានការបោះឆ្នោតថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ ដើម្បីនាំមកនូវសន្តិភាពជូនប្រទេសកម្ពុជាវិញ បន្ទាប់ពីសង្គ្រាមរ៉ាំរ៉ៃអស់រយៈពេល ៣ទសវត្សរ៍កន្លងមក។

**ច.លោកប៊ូត្រូសប៊ូត្រូសកាលី** Buotros Buotros Ghali( 1992-1997 )

លោកជាជនជាតិអេហ្ស៊ីប ជាប់ជាអគ្គលេខាអង្គការសហប្រជាជាតិ ឆ្នាំ១៩៩២-១៩៩៧។ លោកបានដោះស្រាយបញ្ហាពិភពលោកក្នុងរឿងតែមួយដូចជា វិបត្តិបន្តរវាងប៉ាឡេស្ទីន បញ្ហាសិទ្ធិមនុស្សនៅចិន និងនៅមីយ៉ាន់ម៉ា។ អង្គការសហប្រជាជាតិបានដាក់ពង្រាយកងទ័ពនៅកោះទីម័រ ខាងកើត ថែមទាំងជួយប្រទេសនេះ ឱ្យបានឯករាជ្យពីប្រទេសឥណ្ឌូណេស៊ី។

**ឆ.លោក កូហ្វីអាណាន់** Kofi Annan ( 1997-2006 )

លោកកូហ្វីអាណាន់ ជាជនជាតិកាណា បានជាប់ជាអគ្គលេខាធិការអង្គការសហប្រជាជាតិ២អាណត្តិ គឺអាណត្តិទី១ចាប់ពីខែវិច្ឆិកា ឆ្នាំ១៩៩៧-២០០២ និងអាណត្តិទី២ ឆ្នាំ២០០២-២០០៦។ លោកបានដោះ ស្រាយបញ្ហាកោះទីម័រឱ្យបានឯករាជ្យពីឥណ្ឌូណេស៊ី...។

**ជ.លោក បាន គីមូន** Ban Kimoon( 2007-2016 )

លោក ជាជនជាតិកូរ៉េ បានជាប់ជាអគ្គលេខា អង្គការសហប្រជាជាតិក្នុងអាណត្តិទី១ ពីឆ្នាំ២០០៧-២០១២។ លោកបានដោះស្រាយវិវាទថៃ នឹងកម្ពុជា ស្តីពីប្រាសាទព្រះវិហារខ្មែរ។ នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ នៅទីក្រុងកេបិច ប្រទេសកាណាដា អង្គកា UNESCO បានដាក់ប្រាសាទ

ព្រះវិហារខ្មែរជាសម្បត្តិបេតិកភណ្ឌពិភពលោក។ ពេលនោះថៃបានជំទាស់ ហើយថៃមទាំងលើកទ័ព ចូលឈ្លានពានខ្មែរជាទ្រង់ទ្រាយធំបីលើកគឺ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៨ និងនៅថ្ងសទី៣ ខែមេសា ឆ្នាំ២០០៩។

**៣.លោក អាន់តូនីញ៉ូ ហ្គាទ័ររេស** ( António Guterres ) ( 2017 -បច្ចុប្បន្ន )

**លោក អាន់តូនីញ៉ូ ហ្គាទ័ររេស** ជាជនជាតិព័រទុយហ្គាល់ ដែលជាប់ឆ្នោតចូលកាន់តំណែង ជំនួសលោក បានគីមូន កាលពីដើមឆ្នាំ២០១៧។

**សំណួរត្រិះរិះ**

១-តើគេបង្កើតអង្គការសហប្រជាជាតិឡើងដើម្បីអ្វី ?

២-តើអង្គការសហប្រជាជាតិមានស្ថាប័នសំខាន់ៗអ្វីខ្លះ ? ចូរនិយាយពីតួនាទីនៃស្ថាប័នទាំងនោះ។

៣-តើអង្គការសហប្រជាជាតិមានគោលការណ៍ដូចម្ដេចខ្លះ ?

៤-ប្រសិនបើមានប្រទេសណាមួយមិនអនុវត្តតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ តើក្រុមប្រឹក្សានេះមានវិធានការដូចម្ដេចខ្លះ ?

៥-តើលក្ខខណ្ឌដូចម្ដេចខ្លះទើបប្រទេសមួយអាចក្លាយជាសមាជិកអង្គការសហប្រជាជាតិបាន ?

# មេរៀនទី៧ ពិភពលោកដំណាក់កាលសង្គ្រាមត្រជាក់

## ១-និយមន័យ

### តើសង្គ្រាមត្រជាក់ជាអ្វី ?

សង្គ្រាមត្រជាក់គឺជាការប្រឈមមុខដាក់គ្នារវាងប្លុកលោកខាងលិច ដែលប្រកាន់យកលទ្ធិ សេរីនិយម (Liberalism) និងប្លុកលោកខាងកើត ដែលប្រកាន់យកលទ្ធិកុម្មុយនីស្ត (Communism)។ ការប្រឈមមុខរវាង ប្លុកទាំងពីរនេះ កើតមានក្នុងវិស័យមនោគមវិជ្ជា នយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម យោធា ការទូត និងទំនាក់ទំនងអន្តរជាតិ។ ប៉ុន្តែបើយើងពិនិត្យទៅលើកត្តាជាក់ស្តែងនៃប្រវត្តិសាស្ត្រ ការប្រឈមមុខរវាងលោកខាងកើត និងលោកខាងលិច ចាប់ផ្តើមមានតាំងពីឆ្នាំ១៩១៧ មកម្លេះ ពេលនៅក្រោយពេលដែលប្រទេសរុស្ស៊ី ផ្ទុះបដិវត្ត ផ្តួលរំលំ របបរាជានិយម និងបាន កសាងលទ្ធិសង្គមនិយម។ ចាប់ពីពេលនោះមកពិភពលោកក៏ចាប់ផ្តើមមាន ប្រព័ន្ធទ្រឹស្តីពីរ ដែលបដិបក្ខនឹងគ្នា គឺលទ្ធិមូលធននិយម និងលទ្ធិសង្គមនិយម[479]។

ការប្រឈមមុខដាក់គ្នា និងភាពបដិបក្ខនេះ បានផ្ទុះចេញឡើងក្នុងសភាពតានតឹង នៅក្រោយសង្គ្រាម លោកលើកទី២ ពោលគឺចាប់ពីឆ្នាំ១៩៤៧មក ជាដំណាក់កាលនៃស្ថានភាពនៃការបែកបាក់គ្នាយ៉ាងពិតប្រាកដ នៃសម្ពន្ធមិត្តក្នុងសង្គ្រាមលោកលើកទី២ គឺសហរដ្ឋអាមេរិក និងសហភាពសូវៀត។ សង្គ្រាមត្រជាក់ត្រូវបានបញ្ចប់នៅឆ្នាំ១៩៩១ ពេលដែលសហភាពសូវៀតដួលរលំ។

## ២-ការចាប់ផ្តើមនៃសង្គ្រាមត្រជាក់

**តើអ្វីខ្លះជាប្រភពនៃសង្គ្រាមត្រជាក់?** ខាងក្រោមនេះនឹងលើកឡើងអំពីប្រភពសំខាន់ៗ ដែលនាំទៅរកសង្គ្រាមត្រជាក់។ ព្រឹត្តិការណ៍ទាំងអស់នេះចាប់ផ្តើមឡើងនៅក្នុងដំណាក់កាលនៃសង្គ្រាមលោកលើកទី២។

### ២.១-មហាសម្ពន្ធភាព និងការវាតទី

**សហភាពសូវៀត៖** បានឈានចូលក្នុងសង្គ្រាមប្រឆាំងនឹងអាល្លឺម៉ង់ នៅខែមិថុនា ឆ្នាំ១៩៤១ គឺនៅពេល ដែលកងទ័ពអាល្លឺម៉ង់ ចូលលុកលុយសហភាពសូវៀត។ គួររំលឹកថា កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៣៩ អាល្លឺម៉ង់ និងសូវៀត បានចុះហត្ថលេខាលើកតិកាសញ្ញា អាល្លឺម៉ង់-សូវៀត ដែលជាកតិកាសញ្ញាមិនឈ្លានពានគ្នា និងអនុញ្ញាតឱ្យគេធ្វើការបែងចែកប្រទេសប៉ូឡូញ និងអនុញ្ញាតឱ្យ សូវៀតយកទឹកដីបណ្តាប្រទេសសមុទ្របាល់ទិក ជារបស់ខ្លួន[480]។

នៅក្រោយសង្គ្រាមលោកលើកទី២ គឺគេមើលឃើញថាសូវៀតបានពង្រីកនូវឥទ្ធិពលរបស់ខ្លួន៖

-នៅក្រោយសង្គ្រាមលោកលើកទី២ សូវៀតបានជួយជ្រោមជ្រែង បង្កើតជារដ្ឋរណប ដោយយករបៀបរបបសូវៀតភាវូបនីកម្មដូចជានៅ អាល់បានី ប៊ុលហ្គារី ហុងគ្រី ប៉ូឡូញ រ៉ូម៉ានី និងយូហ្គោស្លាវី។

---

[479] ខៀវ ថវិកា (១៩៩៧) **ប្រវត្តិនៃទំនាក់ទំនងអន្តរជាតិ ពីឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន** ភាគ១ ទំព័រ១

[480] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា (២០០០) **ឯកសារប្រវត្តិវិទ្យា សម្រាប់សាស្ត្រាចារ្យទុតិយភូមិ** ភ្នំពេញ ទំព័រទី១៨

-សូវៀតបានកាន់កាប់ទឹកដីអាល្លឺម៉ង់ខាងកើត ហើយរៀបចំជាសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់។

-សូវៀតបានជួយជ្រោមជ្រែងបង្កើត ជាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ។

-សូវៀតបានជួយបក្សកុម្មុយនីស្តចិនឱ្យកាន់អំណាចនាទីក្រុងប៉េកាំង ឆ្នាំ១៩៤៩

-សូវៀតបានជួយពួកវៀតណាមកុម្មុនីស្ត ឱ្យគ្រប់គ្រងវៀតណាមទាំងមូល[481]។

**សហរដ្ឋអាម៉េរិក៖** ចូលរួមធ្វើសង្គ្រាមនៅខែធ្នូ ឆ្នាំ១៩៤១ ក្រោយពេលដែលជប៉ុន បានវាយប្រហារទៅលើមូលដ្ឋានទ័ពអាម៉េរិកនៅពាលហាបួ(Pearl Harbour)។ សហរដ្ឋអាម៉េរិក សហភាពសូវៀត និងរាជាណាចក្ររួម បានរួបរួមគ្នាបង្កើតជាសម្ពន្ធភាពដ៏ធំមួយដើម្បីប្រឆាំងនឹងអាល្លឺម៉ង់ និងអ៊ីតាលី។

នៅឆ្នាំ១៩៤២ សហរដ្ឋអាម៉េរិក សហភាពសូវៀត និងរាជាណាចក្ររួម ព្រមទាំងបណ្ដាប្រទេស ២៣ផ្សេងទៀតបានចុះហត្ថលេខាជាមួយគ្នាលើសេចក្ដីថ្លែងការ សហប្រជាជាតិ អះអាងពីសិទ្ធិឯករាជ្យនៃប្រទេសនីមួយៗ និងការគោរពបូរណភាពដែនដី។

នៅឆ្នាំ១៩៤៣និង១៩៤៤ ពួកសម្ពន្ធមិត្តបានព្រមព្រៀងគ្នាដើម្បីធ្វើឱ្យអាល្លឺម៉ង់ចុះចាញ់សង្គ្រាម និងឱ្យសូវៀតធ្វើសង្គ្រាមប្រឆាំងជាមួយជប៉ុន ជាដើម។ ប៉ុន្តែ ចាប់ពីឆ្នាំ១៩៤៤ លោក ឆឺឈីល នាយករដ្ឋមន្ត្រីអង់គ្លេស ពុំទុកចិត្តស្តាលីន ដែលមានកងទ័ព កំពុងតែលុកលុយប្រទេសប៉ូឡូញ រ៉ូម៉ានី និងតម្រង់យ៉ាងលឿនឆ្ពោះទៅទិសខាងលិច។ សហរដ្ឋអាម៉េរិក និងពួកសម្ពន្ធមិត្ត ក្រោយពីធ្វើការវាយឡើងគោកនៅប្រទេសបារាំង ដើម្បីរំដោះប្រទេសនេះ ប៉ុន្តែការរុលទៅទិសខាងកើត ត្រូវជួបការលំបាកយ៉ាងខ្លាំង។ ក្នុងពេលនោះ ដោយផ្ទុយទៅនឹង សេចក្ដីថ្លែងការណ៍សហប្រជាជាតិ សហភាពសូវៀតបានបង្ខំឱ្យបណ្ដាប្រទេសដែលខ្លួនកាន់កាប់មាន ប៊ុលការី ហុងគ្រី រ៉ូម៉ានីប្រកាន់យករបបកុម្មុយនីស្ត។ ឆឺឈីល ចង់ជួបចរចាជាមួយស្តាលីន នៅមូស្គូ ដើម្បីធ្វើការបែងចែកទ្វីបអឺរ៉ុបជាតំបន់ ដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្លួន។

នៅយ៉ាល់តា ខែកុម្ភៈ ឆ្នាំ១៩៤៥ មានការជួបគ្នារវាងស្តាលីន រ៉ូស្វែល និងឆឺឈីល គេបានព្រមព្រៀងគ្នា លើចំណុចខ្លះៗ ដូចជាការកាន់កាប់ជាបណ្ដោះអាសន្នលើប្រទេសអាល្លឺម៉ង់ ប៉ុន្តែមានការខ្វែងគំនិតគ្នាកើតឡើង ជាពិសេសចំពោះករណីប្រទេសប៉ូឡូញ។ ប៉ូឡូញ មិនមែនជាប្រទេសដែលបរាជ័យក្នុងសង្គ្រាមទេ គឺជាប្រទេសមួយ ដែលបានតស៊ូប្រឆាំងនឹងពួក កាន់កាប់ដោយកម្លាំងយោធា។ ប៉ុន្តែប៉ូឡូញត្រូវបានរំដោះដោយសារកងទ័ពសូវៀត។ ប៉ូឡូញ មានរដ្ឋាភិបាលពីរ ដែលទាមទារអំណាចគ្រប់គ្រង គឺរដ្ឋាភិបាលម្ខាង ជារដ្ឋាភិបាលដែលនិរទេសទៅទីក្រុងឡុង តាំងពីឆ្នាំ១៩៣៩ គាំទ្រដោយអង់គ្លេស និងរដ្ឋាភិបាលម្ខាងទៀត ជារដ្ឋាភិបាលកុម្មុយនីស្ត តាំងនៅទីក្រុងវ៉ាសូវី គាំទ្រដោយសូវៀត។

លោករូស្វែល មិនចង់ឮគេនិយាយពីការបែងចែកទ្វីបអឺរ៉ុបទេ ហើយសេចក្ដីថ្លែងការណ៍ ចុងក្រោយនៅ យ៉ាល់តា បញ្ជាក់ថែមទៀតនូវសិទ្ធិនៃបណ្ដាប្រទេស ដែលបានរំដោះ ក្នុងការជ្រើសរើស រដ្ឋាភិបាលរបស់ខ្លួនដោយសេរី និងប្រជាធិបតេយ្យ។

---

[481] នួន សុធិមន្ត(២០០៧) **ទំនាក់ទំនងអន្តរជាតិ** ភ្នំពេញ ទំព័រ ១៣២

នៅខែកក្កដា ឆ្នាំ១៩៤៥ សន្និសីទចុងក្រោយរវាងពួកសម្ពន្ធមិត្ត បានប្រព្រឹត្តទៅនៅប៉ុតដាម។ លោក ទ្រូម៉ាន់ បានបង្ហាញនូវភាពម៉ឺងម៉ាត់ ចំពោះស្តាលីន គេមិនបានស្រុះស្រួលគ្នា លើបញ្ហាប៉ូឡូញទេ ហើយគេក៏មិនយល់ព្រមផងដែរ ចំពោះដោតវាសនាប្រទេសអាល្លឺម៉ង់ក្រោយពីការដណ្តើមយករួចមក។ ស្តាលីនបានធ្វើឱ្យឯកោ ចំពោះប្រទេសដែលខ្លួនកាន់កាប់ ដែលឆឺឈីល បានឱ្យឈ្មោះថា "វាំងដែក"។ ពួកលោកខាងលិច មិនចង់ឃើញប្រទេសទាំងឡាយនៅអឺរ៉ុបខាងកើត ស្ថិតក្រោមរបបកុម្មុនីស្តឡើយ ប៉ុន្តែគេមិនអាចធ្វើអ្វីបានឡើយ ដោយ សារវត្តមាននៃកងទ័ពសូវៀត (លើកលែងប្រទេសក្រិក និងប្រទេសយូហ្គោស្លាវី)។

ការពុះចែកទ្វីបអឺរ៉ុបជាពីរ មិនមែនជាឆន្ទៈ របស់ពួកលោកខាងលិចទេ។ ពួកលោកខាងលិច បានប្រឆាំង នឹងមហិច្ឆិតា របស់ស្តាលីន នៅមជ្ឈិមបូព៌ាៈ ស្តាលីនចង់ពង្រីកឥទ្ធិពលរបស់ខ្លួនទៅដល់សមុទ្រខ្មៅ ទៅប្រទេស តួកគី និងប្រទេសអៀរ៉ង់។

## ២.២-ការរលាយនៃមហាសម្ពន្ធភាព

### ហេតុអ្វីបានជាមហាសម្ពន្ធនេះត្រូវរលំរលាយ ?

### ក-បញ្ហានៅអាល្លឺម៉ង់

ពួកសម្ពន្ធមិត្តមានការទាស់ទែងខ្វែងគំនិត មិនយល់ស្របចំពោះ ការគ្រប់គ្រងអាល្លឺម៉ង់ ៖

ប្រទេសអាល្លឺម៉ង់ ត្រូវបែងចែកបណ្តោះអាសន្នជា ៤តំបន់ ត្រួតត្រាដោយយោធា រង់ចាំការសម្រេច ជាស្ថាពរ។ ប៉ុន្តែពួកសម្ពន្ធមិត្តមិនយល់ព្រមទៅលើអនាគតនៃប្រទេសអាល្លឺម៉ង់ ដែលត្រូវបាត់បង់ទឹកដីដល់ទៅ ១០០០០០ គីឡូម៉ែត្រក្រឡាដោយសារការរំកិលព្រំដែនរបស់ប៉ូឡូញនោះទេ ហើយព្រំដែនភាគខាងកើត របស់ប៉ូឡូញត្រូវបង្ខិតមកខាងលិចដោយសារសហភាពសូវៀតដណ្តើម យក។

រាជាណាចក្ររួម និងអាម៉េរិក មានបំណងចង់ឱ្យអាល្លឺម៉ង់កកើតឡើងវិញ ជារដ្ឋឯករាជ្យ និងសម្បូរសប្បាយ យ៉ាងឆាប់រហ័ស និងចង់ឱ្យអាល្លឺម៉ង់រួបរួមតែមួយ ហើយរៀបចំរដ្ឋាភិបាលមួយបែបប្រជាធិបតេយ្យសេរី។ បារាំងមានការព្រួយបារម្ភខ្លាច រីករាលដាលមកដល់ព្រំដែនរបស់ខ្លួន ហើយជំទាស់មិនឱ្យអាល្លឺម៉ង់រួបរួមតែមួយ។

សូវៀត ប្រាថ្នាប្រមូលយកភោគទ្រព្យនៅតាមតំបន់កាន់កាប់របស់ខ្លួនដូចជារោងចក្រ និងកម្លាំងពលកម្មទៅសហភាពសូវៀត ដើម្បីសងការខូចខាតដែលកើតឡើងដោយសារសង្គ្រាម។ ជាពិសេសនៅមុនការបោះឆ្នោត សូវៀតបានតែងតាំងជនកុម្មុយនីស្ត នៅតាមប៉ុស្តិ៍សំខាន់ៗជាច្រើន ពោលគឺសូវៀតប្រាថ្នាចង់ឱ្យអាល្លឺម៉ង់ក្លាយជាប្រទេសកុម្មុយនីស្ត។ ចំពោះពួកសម្ពន្ធមិត្តខាងលិចវិញចង់ឱ្យអាល្លឺម៉ង់ ជាប្រទេសប្រជាធិបតេយ្យសេរី ។ ជំហរទាំងនេះពុំអាចផ្សះផ្សាបានឡើយ។

### ខ-ការរីករាលដាលនៃលទ្ធិកុម្មុយនីស្តនៅអឺរ៉ុបខាងកើត

នៅក្នុងបណ្តាប្រទេសជាច្រើន ដែលបានត្រួតត្រាដោយសូវៀតបានរៀបចំបោះឆ្នោតនៅឆ្នាំ១៩៤៦ ក៏ប៉ុន្តែ ការបោះឆ្នោតនេះពុំមានលក្ខណៈសេរីនោះឡើយ ហើយពួកកុម្មុយនីស្តបានទទួលសំឡេងភាគច្រើន នៅតំបន់អាល្លឺម៉ង់ រ៉ូម៉ានី និងនៅ ប៊ុលការី ។ ពួកកុម្មុយនីស្ត បានស្ថាបនា របបប្រជាធិបតេយ្យ

ប្រជាមានិតដែលមានលក្ខណៈផ្តាច់ការអត់ធន មានផែនការកម្មខាងវិស័យសេដ្ឋកិច្ច និងសមូហកម្ម ហើយមានការកៀបសង្កត់លើសេរីភាព ក្នុងការបញ្ចេញមតិ។ កសិករភាគច្រើនបានទទួលផលដោយសារកំណែទម្រង់ដីធ្លី ពួកម្ចាស់ដីធំៗ នៅអឺរ៉ុបខាងកើតពេលមុនសង្គ្រាម ត្រូវរលាយបាត់អស់។

នៅពេលនោះមានប្រទេសពីរ គឺយូហ្គោស្លាវី និងអាល់បានី ដែលបានរំដោះជាតិ ដោយគ្មានអន្តរាគមន៍ ពីសំណាក់កងទ័ពក្រហម។ ការតស៊ូប្រឆាំងនឹងពួកណាស៊ី នៅប្រទេសយូហ្គោស្លាវី និងការតស៊ូប្រឆាំងនឹងអ៊ីតាលី របស់ពួកអាល់បានី មួយភាគធំបានរៀបចំឡើងដោយចលនាពួកកុម្មុយនីស្ត ដឹកនាំដោយលោកទីតូ( យូហ្គោស្លាវី) និងលោក អង់វែរហុតសា (អាល់បានី)។ នៅឆ្នាំ១៩៤៥ ប្រទេសទាំងពីរនេះបានប្រកាន់យករបបកុម្មុយនីស្ត តែឯករាជ្យពីសហភាពសូវៀត។ ពួកសម្ពន្ធមិត្ត មានការព្រួយបារម្ភ ដោយឃើញលទ្ធិកុម្មុយនីស្តមកកាន់តែជិតប្រទេសរបស់ខ្លួន។ នៅឆ្នាំ១៩៤៦ ប្រទេសឆេកូស្លូវ៉ាគី ក្រោមរដ្ឋាភិបាល លោក បេនេស(Benes) ប្រកាន់យករបបប្រជាធិបតេយ្យដដែល ដែលមានតាំងពីមុនសង្គ្រាមមកម្លេះ។ ប្រទេសឆេកូស្លូវ៉ាគី ចង់ធ្វើជាស្ពាន រវាងប្រជាធិបតេយ្យ ប្រជាមានិត អឺរ៉ុបខាងកើត និងប្រជាធិបតេយ្យអឺរ៉ុបខាងលិច។

នៅក្នុងដំណាក់កាលសង្គ្រាមលោកលើកទី២ នៅប្រទេសប៉ូឡូញ មានចលនាតស៊ូពីរក្រុម បានតស៊ូប្រឆាំងនឹងអាល្លឺម៉ង់។ ចលនាមួយក្រុមដែលមិនមែនជាពួកកុម្មុយនីស្ត គាំទ្រដោយពួកខាងលិច ចលនាមួយក្រុមទៀតជាចលនារបស់កុម្មុយនីស្ត គាំទ្រដោយពួកសូវៀត មានបំណងប្រាថ្នាតែងតាំងរដ្ឋាភិបាលកុម្មុយនីស្ត និងការពារមិនឱ្យរដ្ឋាភិបាលដែលភៀសខ្លួនទៅទីក្រុងឡុងដ៍ វិលត្រឡប់មកវិញ ឡើយ។ ការបោះឆ្នោតប្រព្រឹត្តទៅនៅឆ្នាំ១៩៤៧ ហើយអ្នកទទួលខុសត្រូវថ្មី នៃសាធារណរដ្ឋប៉ូឡូញឈ្មោះប៊ីយេរូត(Bierut) ត្រូវរណបស្តាលីនទាំងស្រុង។

វាំងដែក ដែលប្រកាសដោយឆឺឈីល នាថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៤៦ នៅកុលតុន(Fulton) ជាព្រំដែនមួយដែលមិនអាចឆ្លងកាត់បាន រវាងផ្នែកទាំងពីរនៃទ្វីបអឺរ៉ុប ដែលផ្ទុយគ្នាស្រឡះដោយរបបនយោបាយ និងសេដ្ឋកិច្ច។ គេបានឃ្លាតយ៉ាងឆ្ងាយពីសេចក្តីប្រកាសនៅយ៉ាល់តា។ មហាសម្ពន្ធភាពគ្មានអត្ថិភាពទៀតឡើយ។

## ២.៣-ការបង្កើតប្លុកលោកពីរ

### ក. ការបង្កើតប្លុកលោកខាងលិច៖

នៅឆ្នាំ១៩៤៧ ស្ថានភាពនៅទ្វីបអឺរ៉ុប មានសភាពស្មុគស្មាញយ៉ាងខ្លាំង។ ប្រទេសទាំងនោះជួបនូវវិបត្តិ យ៉ាងធ្ងន់ធ្ងរ ដូចជាវិបត្តិសេដ្ឋកិច្ច ជួបគ្រោះទុរ្ភិក្ស អតិផរណាជាដើម។ ចំណែកវិបត្តិនយោបាយវិញក៏មានសភាព ធ្ងន់ធ្ងរណាស់ដែរ បក្សកុម្មុយនីស្តនៅបារាំង និងអ៊ីតាលី ឆ្លៀតឱកាសពង្រីក ឥទ្ធិពលរបស់ខ្លួន។ ចំណែកនៅប្រទេសក្រិក សង្គ្រាមស៊ីវិលបានផ្ទុះឡើង ដោយចលនាកុម្មុយនីស្ត បានប្រឆាំងនឹងរបបរាជានិយម។ ឆ្លើយតបទៅនឹងសភាពការណ៍នេះ នៅឆ្នាំ១៩៤៧សហរដ្ឋអាម៉េរិកបានសម្រេចធ្វើទំនប់ទប់នឹងការរីករាលដាលនៃលទ្ធិកុម្មុយនីស្តនៅទ្វីបអឺរ៉ុប តាមរយៈសេចក្តីប្រកាសរបស់លោក **ហារី ទ្រូម៉ាន់** នៅក្នុងសមាជអាម៉េរិក ខែមីនា ឆ្នាំ១៩៤៧ ដោយលោកបានពន្យល់ថា«**ជាការចាំបាច់**

**បំផុតចំពោះសហរដ្ឋអាម៉េរិកដែលជាមហាអំណាចពិភពលោកដែលត្រូវតែប្រឆាំងនឹង មហិច្ឆតា របស់សហភាពសូវៀត។ ភារកិច្ចរបស់សហរដ្ឋអាម៉េរិកគឺត្រូវតែផ្តល់ជំនួយដល់ប្រជាជនសេរី ឱ្យចេះថែរក្សាសិទ្ធិសេរីភាពរបស់ខ្លួន អ្នកណាដែលសុំជំនួយពីអាម៉េរិក អ្នកនោះនឹងទទួលបានតាម សំណូមពរ»**[482]។

**ទ្រឹស្តីទ្រូម៉ាន់ ដែលបានលើកឡើងដោយលោកប្រធានាធិបតី ហារី ទ្រូម៉ាន់មានចំណុចសំខាន់ដូចជា៖**

- អនុវត្តនយោបាយទប់ទល់ និងរុញច្រាន
- លើកយកគោលការណ៍ ប្រឆាំងលទ្ធិកុម្មុយនីស្តនិយម បញ្ចូលទៅក្នុងគោលនយោបាយការបរទេស សហរដ្ឋអាម៉េរិក
- ស្នើឱ្យសភាអាម៉េរិក ផ្តល់ជំនួយជាបន្ទាន់ទៅប្រទេសក្រិក ដែលពួកកុម្មុយនីស្តកំពុងមានឥទ្ធិពល[483]។

ម្យ៉ាងទៀតលទ្ធិនេះត្រូវបានបំពេញបន្ថែមទៀតនៅវាង បីខែក្រោយមកដោយផែនការរបស់លោក **ម៉ារសាល់** នៅក្នុងសន្ទរកថា នៅហាវើត ថ្ងៃ០៥ មិថុនា១៩៤៧ ដែលលោកបានបញ្ជាក់ថា «**សកម្មភាពរបស់យើងគឺមិនសំដៅប្រឆាំងប្រទេសណាមួយឡើយ ឬក៏ប្រឆាំងនឹងមនោគមវិជ្ជាណាមួយឡើយ ប៉ុន្តែគឺជាការប្រឆាំងទៅនឹង ភាពស្រេកឃ្លាន ,ភាពទុគត ,ភាពវឹកវរនិងភាពអស់សង្ឃឹម ហើយគោលបំណងរបស់ផែនការនេះ គឺត្រូវតែធ្វើឱ្យសេដ្ឋកិច្ចពិភពលោកមានដំណើរការល្អឡើងវិញ និង អនុញ្ញាតឱ្យមានលក្ខខណ្ឌ នយោបាយ និង សង្គមកិច្ច លេចឡើងវិញបានប្រសើរ ក្នុងនោះ ស្ថាប័នសេរីអាចដំណើរការបាន**»[484]។

ផែនការម៉ារសាល់បានយល់ព្រមផ្តល់ជំនួយផ្នែកសេដ្ឋកិច្ចដល់គ្រប់បណ្តាប្រទេស ដែលបានស្នើសុំ ហើយក៏បានផ្តល់ទៅឱ្យសហភាពសូវៀត និងបណ្តាប្រទេសកុម្មុយនីស្តទាំងឡាយផងដែរ។ នៅខែមេសា ឆ្នាំ១៩៤៨ សភារបស់សហរដ្ឋអាម៉េរិក បានបោះឆ្នោតអនុម័តស្តីពីការបង្កើតកម្មវិធីកសាងទ្វីបអឺរ៉ុបឡើងវិញ ដែលជាច្បាប់មួយសម្រាប់ការអនុញ្ញាតផ្តល់ជំនួយរបស់សហរដ្ឋអាម៉េរិក តាមរូបមន្ត ១០ភាគរយនៃការខ្ចីបុល និង៩០ភាគរយតាមរយៈជំនួយ។ ប៉ុន្តែដើម្បីបែងចែកជំនួយនេះនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៤៨ គេបានបង្កើតយន្តការមួយ ដែលមានឈ្មោះថា អង្គការទ្វីបអឺរ៉ុបនៃកិច្ចសហប្រតិបត្តិការខាងវិស័យសេដ្ឋកិច្ច(Organization for European Economic Cooperation-OEEC)។ យន្តការនេះទទួលបន្ទុកខាងការបែងចែកជំនួយសហរដ្ឋអាម៉េរិក ដែលជាប្រការមួយបង្ហាញឱ្យឃើញថា ទ្វីបអឺរ៉ុប បានឈានចូលទៅដល់ដំណាក់កាលនៃកិច្ចសហប្រតិបត្តិការថ្មីមួយជាមួយនឹង សហរដ្ឋអាម៉េរិក។ នៅវាងឆ្នាំ១៩៤៨ ដល់១៩៥២ ជំនួយសហរដ្ឋអាម៉េរិក ក្នុងក្របខ័ណ្ឌនៃផែនការម៉ារសាល់ទៅឱ្យអឺរ៉ុប

[482] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា(២០០០) ឯកសារប្រវត្តិវិទ្យាសម្រាប់សាស្ត្រាចារ្យទុតិយភូមិ ភ្នំពេញ ទំព័រ២៣-២៥

[483] នួន សុធិមន្ត(២០០៧) **ទំនាក់ទំនងអន្តរជាតិ** ដ.ឯ.ម. ទំព័រ ១៣៣

[484] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា(២០០០) ដ.ឯ.ម.ទំព័រទី២៥

ខាងលិច មានប្រមាណជា ១៣ ពាន់លានដូល្លារ ដែលក្នុងនោះចំនួនទឹកប្រាក់ ៣,២ លានដូល្លារ ផ្តល់ទៅឱ្យរាជាណាចក្ររួម និង២,៧ លានដូល្លារ ទៅឱ្យប្រទេសបារាំង។

**ការបែងចែកជំនួយរបស់សហរដ្ឋអាមេរិក ទៅឱ្យបណ្តាប្រទេសសំខាន់ៗ នៅក្នុងទ្វីបអឺរ៉ុប**

(គិតជាលាន ដូល្លារ និងភាគរយ)[485]

| ប្រទេស | ចំនួនសរុប | គិតជាភាគរយ | ជំនួយ | ភាគរយ |
|---|---|---|---|---|
| **គ្រប់ប្រទេសទាំងអស់** | **១២ ៩៩២៥,** | **១០០** | **៩ ២៩០** | **១០០** |
| ប្រទេសបារាំង | ២ ៦២៩០, | ២០៣, | ២ ២១២១, | ២៣៨, |
| ប្រទេសអ៊ីតាលី | ១ ៤៣៤៦, | ១១០, | ១ ១៧៤៤, | ១២៦, |
| ប្រទេសប៉េអ៊ីបា | ១ ០៧៨៧, | ៨៣, | ៧៩៦៤, | ៨៦, |
| សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ | ១ ៣១៧៣, | ១០១, | ១ ០៧៨៧, | ១១៦, |
| រាជាណាចក្ររួម | ៣ ១៦៥៨, | ២៤៤, | ១ ៩៥៦៩, | ២១ |

កិច្ចសហប្រតិបត្តិការនេះបានបន្តដោយការចុះហត្ថលេខាលើសន្ធិសញ្ញាក្រុងប៉ារីស ឆ្នាំ១៩៥១ ដោយប្រទេស បារាំង អ៊ីតាលី បេណេលុច អាល្លឺម៉ង់ខាងលិច ក្នុងការបង្កើត**សហគមន៍អឺរ៉ុបផ្នែក ធ្យូងថ្ម និងដែកថែប** ដែលអនុញ្ញាតឱ្យធ្វើចរាចរដោយសេរី នូវផលិតផលទាំងនេះ ដើម្បីឱ្យសេដ្ឋកិច្ចក្នុងតំបន់នេះរស់ឡើងវិញ។




**ផែនទីប្រទេសនៅទ្វីបអឺរ៉ុបក្រោមការ ការពាររបស់ណាតូ និងរ៉ាស្ស៊ី ឆ្នាំ១៩៥៦**

ប្រភព: Judy Ling , Dr Aron Paul, Bi-Polarity & the Cold War, Hodder Education

[485] ខៀវ ថវិកា, *ប្រវត្តិនៃទំនាក់ទំនងអន្តរជាតិ ពីឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន*, ដ.ឯ.ម., ទំព័រ២២។

នៅឆ្នាំ១៩៥៧ បណ្ដាប្រទេសដដែលនេះបានចុះហត្ថលេខាលើសន្ធិសញ្ញាក្រុងរ៉ូម ក្នុងការបង្កើតសហគមន៍សេដ្ឋកិច្ចអឺរ៉ុបដើម្បីធ្វើឱ្យបណ្ដូរដោយសេរីកាន់តែរីកចម្រើនឡើង។ ជាការពិតផែនការម៉ាសាល់បាននាំឱ្យទ្វីបអឺរ៉ុបមានការបែងចែកជាពីរផ្នែកកាន់តែច្បាស់ឡើងៗដោយយើងមើលឃើញថា៖

-ចាប់តាំងពីឆ្នាំ១៩៤៧ មក អាម៉េរិក បានបង្កើនការកៀបសង្កត់របស់ខ្លួនកាន់ខ្លាំងឡើងនៅក្នុងវិស័យ នយោបាយ និងសេដ្ឋកិច្ច លើបណ្ដាប្រទេសខាងលិច ដែលបន្តិចក្រោយមក បានរួមគ្នាតែមួយនៅជុំវិញអាម៉េរិក។

-ឥឡូវ ផ្ទុយពីមុនសង្គ្រាម អាម៉េរិកបានសម្រេចចិត្តក្លាយទៅជា **អាវុធហត្ថនៃពិភពសេរី** និងធ្វើ**អន្តរាគមន៍**នៅពេលណាដែលគេវិនិច្ឆ័យថាជាការចាំបាច់។

-អាម៉េរិក មិនត្រឹមតែកាន់កាប់កន្លែងសំខាន់ៗក្នុងស្ថាប័នអន្តរជាតិទេ ប៉ុន្តែបានដាក់ប្រទេសមួយចំនួនធំ នៅក្រោមការការពារផ្នែកយោធារបស់ខ្លួន « **ឆត្របរមាណូ** » តាមរយៈសន្ធិសញ្ញាសំខាន់ៗដូចជា៖

- អូតង់ ( OTAN-NATO) (អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង) ១៩៤៩ ដែប្រមូលផ្ដុំកម្លាំងយោធារបស់បារាំង ក្រង់ប្រីតាញ បេណេលុច... ក្រោមបញ្ជាការ អាម៉េរិក។
- អង់ស៊ីស (ANZUS) ១៩៥១ អូស្ត្រាលី ញូសេឡង់
- អូតាស (OTASE–SEATO) ១៩៥៤ បារាំង ក្រង់ប្រីតាញ អូស្ត្រាលី ញូហ្សេឡែន ហ្វីលីពីន ថៃ ប៉ាគីស្ថាន
- បាដាត (BADART) ១៩៥៥ តួកគី អ៊ីរ៉ាក់ ប៉ាគីស្ថាន អ៊ីរ៉ង់ ក្រង់ប្រីតាញ

**អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង**

**(North Atlantic Treaty Organization= NATO)**

នៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៤៩ សហរដ្ឋអាម៉េរិក បានលើកជាគំនិតផ្ដួចផ្ដើមមួយដែលទាក់ទងទៅនឹងប្រព័ន្ធសន្តិសុខរួមមួយ (The Collective Security System) សម្រាប់ការពារអឺរ៉ុបខាងលិច និងតំបន់អាម៉េរិកខាងជើង។ អាចនិយាយបានថាសន្តិសុខរួមនេះជា«ដៃស្ដាំ» របស់ផែនការម៉ាសោល់ ដែលទាក់ទាញឱ្យអាម៉េរិកចាំបាច់ត្រូវតែការពារ និងរក្សាសម្ពន្ធមិត្តរបស់ខ្លួននៅក្នុងតំបន់អឺរ៉ុបខាងលិច។

អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង NATO ត្រូវបានចុះហត្ថលេខាបង្កើតឡើងនៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៤៩ នៅទីក្រុងវ៉ាស៊ីនតោន ដែលមានប្រទេសជាសមាជិកដំបូងដូចជា ប្រទេសប៊ែលស៊ិក កាណាដា ដាណឺម៉ាក សហរដ្ឋអាម៉េរិក បារាំង អង់គ្លេស អ៊ីស្លង់ អ៊ីតាលី ណរវែស ហូឡង់ លុចសំប៊ួរ និងព័រទុយហ្គាល់។ សន្ធិសញ្ញានេះធានាជាពិសេសដល់ពលរដ្ឋអឺរ៉ុប នូវការគាំទ្ររបស់សហរដ្ឋអាម៉េរិក ក្នុងករណីនៃការឈ្លានពាន។ ក្រោយមកប្រទេសផ្សេងៗបានចូលជាសមាជិកជាបន្ទាប់ដូចជា៖ តួកគី និងក្រិក នៅឆ្នាំ១៩៥២ សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់(អាល្លឺម៉ង់ខាងលិច) ១៩៥៥ និងប្រទេសអេស្ប៉ាញ ឆ្នាំ១៩៨២។ នៅឆ្នាំ១៩៩៩ ប្រទេសបីនៃអឺរ៉ុបខាងកើតគឺ ហុងគ្រី ប៉ូឡូញ និងសាធារណរដ្ឋឆេក ត្រូវបានធ្វើសមាហរណកម្មទៅក្នុង NATO។ ក្រុមប្រឹក្សាអចិន្ត្រៃយ៍របស់ NATO តាំងនៅទីក្រុងប្រ៊ុចសែល នៃប្រទេសបែលហ្ស៊ិក។

### ខ-ប្រតិកម្មរបស់សហភាពសូវៀតនិងការបង្កើតប្លុកលោកខាងកើត

ដើម្បីទប់ទល់នឹងផែនការម៉ារសាល់ លោកស្តាលីន បានធ្វើការកៀបសង្កត់លើបណ្តាប្រទេសនៅអឺរ៉ុបខាងកើតឱ្យទាត់ចោលផែនការម៉ារសាល់។

នៅខែកញ្ញា ១៩៤៧ លោក ជាណូវ ជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តសូវៀតទទួលបន្ទុកខាងឃោសនាការ បានបង្ហាញនូវទស្សនៈ **ជាណូវ** តាមរយៈសុន្ទរកថាដែលបញ្ជាក់ថា « នៅពេលណាដែលយើងកាន់តែឃ្លាតឆ្ងាយពីសង្គ្រាម ពេលនោះយើងនឹង ឃើញយ៉ាងពិតប្រាកដនូវការលេចឡើងនៃ ពួកចក្រពត្តិ និងពួកប្រឆាំងប្រជាធិបតេយ្យ និងក្រុមប្រឆាំងចក្រពត្តិ និង ក្រុមប្រជាធិបតេយ្យ[486]។ អាមេរិកជាកម្លាំងដឹកនាំយ៉ាងសំខាន់នៃពួក ចក្រពត្តិ ដោយមានជំនួយពីអង់គ្លេស បារាំង និង បណ្តាប្រទេសដែលមានអាណានិគម ដែលចំណុះ អាម៉េរិក ។ ចំណែកឯសហភាពសូវៀត និងបណ្តាប្រទេសដែលមិនចុះសម្រុងជាមួយចក្រពត្តិ ក៏ដូចជាចលនាកម្មករប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តជាបងប្អូនដែរគឺចាត់ចូលជាក្រុមមួយផ្សេងទៀត»។

ក្រោយពីមានលទ្ធិ**ជាណូវ** ពិភពលោកបានបែងចែកជាពីរក្រុមបដិបក្ខ ដែលមិនអាចផ្សះផ្សារគ្នាបានឡើយ ម្ខាងត្រូវតែកម្ទេចម្ខាងទៀត។ សហរដ្ឋអាម៉េរិក ត្រូវចាត់ចូលដូចជាក្រុមប្រឆាំងនឹងប្រជាធិបេតេយ្យ ហើយជាក្រុមចក្រពត្តិនិយម។

សេចក្តីប្រកាសនេះបានបន្តរហូតដល់មានការបង្កើត **ការិយាល័យកូមិនហ្វម** KOMINFORM ទទួលបន្ទុកការផ្សព្វផ្សាយ និងធ្វើទំនាក់ទំនងសកម្មភាពរបស់បណ្តារដ្ឋ ជាមួយបក្សកុម្មុយនីស្តក្នុងពិភពលោកទាំងមូល និងជាអ្នកថាតាមយុទ្ធសាស្ត្រដែលសម្រេចដោយមូស្គូ។ សម្រាប់ស្តាលីន វត្តមាននៃកងទ័ពក្រហម និងការតស៊ូ ផ្នែកមនោគមវិជ្ជាគឺជាមធ្យោបាយកៀបសង្កត់យ៉ាងមានប្រសិទ្ធភាព។

ចាប់ពីពេលនោះមក បណ្តាប្រទេសនៅអឺរ៉ុបខាងកើតណា ដែលរក្សា ឬ មានរដ្ឋាភិបាលមិនមែនកុម្មុយនីស្ត ត្រូវសូវៀតបង្ខំដោយកម្លាំងបាយឱ្យរដ្ឋាភិបាលនោះលាឈប់ពីតំណែង និងដាក់ជនកុម្មុយនីស្ត ជំនួសមកវិញ ដូចជា ប្រទេស ឆេកូស្លូវ៉ាគី ដែលលោក **បេនេស** (BENES ) ត្រូវជំនួសដោយ លោក ហ្គុត វ៉ល ( GOTT WALD ) ជាដើម។

នៅអឺរ៉ុបខាងកើតលោកស្តាលីនបានរៀបចំ ផែនការសេដ្ឋកិច្ច និងយោធា ប្រឈមនឹងលោកខាងលិច ដូចជា ៖

❖ **ខាងសេដ្ឋកិច្ច**

-នៅឆ្នាំ១៩៤៩ បង្កើតគណកម្មការជំនួយសេដ្ឋកិច្ចទៅវិញទៅមក (CMEA **1949–1991**) សម្រាប់ត្រួតពិនិត្យសេដ្ឋកិច្ចនៃបណ្តាប្រទេសនៅក្រោមឥទ្ធិពល សូវៀត។ បណ្តាប្រទេសនីមួយៗ ពុំមានសេរីភាពសេដ្ឋកិច្ចឡើយគឺត្រូវធ្វើផែនការកម្ម និងពិនិត្យដោយសូវៀត តម្រូវតាមសេចក្តីត្រូវការរបស់ខ្លួនដែលប្រទេសនីមួយៗត្រូវមានមុខជំនាញក្នុងគំរូផលិតផលឧស្សាហកម្ម ឬកសិកម្ម ៖

[486] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា, *ឯកសារប្រវត្តិវិទ្យា សម្រាប់សាស្ត្រាចារ្យទុតិយភូមិ*, ឆ្នាំ២០០០, ទំព័រទី២៩-៣០។

ឧ.អាល្លឺម៉ង់ ផលិតគ្រឿងម៉ាស៊ីន ហុងគ្រី ផលិតរថយន្ត ដឹកអ្នកដំណើរ រ៉ូម៉ានីផលិត ផលិតផលកសិកម្ម ។ល។ បណ្តាប្រទេសទាំងនេះ អាចធ្វើពាណិជ្ជកម្ម បានតែរវាងប្រទេសគ្នាឯង។ គឺប្លុក សេដ្ឋកិច្ចបិទយ៉ាងជិត។

❖ **ខាងយោធា:**

- ដើម្បីឆ្លើយតបនឹង អូតង់ សូវៀតបានបង្កើត កតិកាសញ្ញាវ៉ាសូវី (WARSAW) នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៥ ដែលប្រមូលផ្តុំកងទ័ពនៅបណ្តាប្រទេសអឺរ៉ុបខាងកើតទាំងអស់ស្ថិតក្រោមបញ្ជាការសូវៀត(ប្រទេសចូលរួម អាល់បានី ប៊ុលហ្គារី ហុងគ្រី ប៉ូឡូញ រ៉ូម៉ានី សហភាពសូវៀត ឆេកូស្លូវ៉ាគី និង អាល្លឺម៉ង់ខាងកើត)[487]។

-កងទ័ពវ៉ាសូវី មានកាតព្វកិច្ចចូលអន្តរាគមន៍នៅពេលណា នៅកន្លែងណា ដែលលទ្ធិសង្គមនិយមត្រូវគំរាមកំហែង។

-កតិកាសញ្ញាវ៉ាសូវី ក៏ដើម្បីការពារបណ្តាប្រទេសកុម្មុយនីស្តផងដែរ នៅពេលណាដែលពួកចក្រពត្តិឈ្លានពាន។

គ្រប់បណ្តាប្រទេសនៃក្រុមកុម្មុយនីស្ត បានចម្លងតាមគំរូរបស់សូវៀត និងអនុវត្តតាមបន្ទាត់នយោបាយ របស់សូវៀត។ គេគ្មានសេរីភាពក្នុងការកំណត់បន្ទាត់នយោបាយរបស់ខ្លួនឡើយ លើកលែងតែប្រទេសយូហ្គោស្លាវីមួយគត់។ នៅប្រទេសយូហ្គោស្លាវី ចាប់តាំងពីឆ្នាំ ១៩៤៥ មក លោកសេនាប្រមុខទីតូ បានរៀបចំរបបកុម្មុយនីស្តមួយ ដែលស្ថិតនៅក្រៅឥទ្ធិពលស្តាលីន។ គាត់ចង់បានសេរីភាពដោយខ្លួនឯង ក្នុងប្រទេសរបស់ខ្លួន។

ស្តាលីន បានចោតប្រកាន់លោកទីតូ ថាជាអ្នកងាកពីមាគ៌ារបស់បក្សខ្លួន បានន័យថាមិនដើរតាមមាគ៌ា ដែលកំណត់ដោយបក្សកុម្មុយនីស្តសូវៀត ហើយស្តាលីនខ្លាចមានការរាលដាល ឆ្លងទៅប្រទេសកុម្មុយនីស្តដទៃ ទៀត។ លោកទីតូ មិនព្រមចុះចាញ់ ហើយគឺជាការបែកបាក់ទាំងស្រុង នូវទំនាក់ទំនងរវាងយូហ្គោស្លាវី និង បណ្តាប្រទេសកុម្មុយនីស្តនៅអឺរ៉ុបផ្សេងទៀត។ ដូចគ្នានេះដែរ ទីតូក៏បានប្រកែកពុំព្រមចូលទៅក្នុងក្រុមលោក ខាងលិចដែរ។

ក្រោយមរណភាពរបស់លោកស្តាលីន នៅឆ្នាំ១៩៥៣ ស្ថានភាពបានប្រែប្រួល អគ្គលេខាថ្មីរបស់បក្ស កុម្មុយនីស្តសូវៀត លោក គ្រុតឆេវ បានជានានឹងគ្នាវិញជាមួយទីតូ នៅឆ្នាំ១៩៥៥។ នៅពេលនោះ កុម្មុយនីស្តនៅអឺរ៉ុបហាក់ដូចជារកឃើញនូវឯកភាព។ ផ្ទុយទៅវិញ ចាប់ពីទសវត្សរ៍ឆ្នាំ១៩៥០ ប្រទេសចិនកុម្មុយនីស្តរបស់ម៉ៅ សេទុងបានឃ្លាតឆ្ងាយពីឥទ្ធិពលរបស់សូវៀតទៅវិញ។

## ៣-វិបត្តិនានាក្នុងដំណាក់ដំបូងនៃសង្គ្រាមត្រជាក់

មកដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៥០ ពិភពលោកកាន់តែមានលក្ខណៈតានតឹងខ្លាំងឡើងៗ រកកលនឹងផ្ទុះសង្គ្រាមលោកសារជាថ្មីម្តងទៀត ដោយសារតែះ

-ក្រុមម្ខាងៗមានការប៉ុនប៉ងឈ្លានពានគ្នាទៅវិញទៅមក

[487] អ៊ុន យ៉េត, *សម្រង់ប្រវត្តិសាស្ត្រអាល្លឺម៉ង់ និងអតីតប្លុកសូវៀត (ភាគ១)*, ការផ្សាយឥន្ទ្រទេវី, ឆ្នាំ២០០៦, ទំព័រ១០២។

-ការប្រកួតប្រជែងផ្នែកសព្វាវុធ៖

- ១៩៤៥ អាម៉េរិក ផលិតដោយជោគជ័យនូវគ្រាប់បែកបរមាណូ
- ១៩៤៩ សូវៀត ផលិតបានគ្រាប់បែកបរមាណូ
- ១៩៥២ អាម៉េរិករកឃើញគ្រាប់បែកបរមាណូ អ៊ីដ្រូសែន
- ១៩៥៤ សូវៀតករកឃើញគ្រាប់បែកបរមាណូ អ៊ីដ្រូសែន
- ក្រុមម្ខាងៗ សុទ្ធតែមានរោងចក្រផលិតអាវុធបរមាណូ បន្ថែមលើកម្លាំងទ័ពដែលមានពីមុនមក ។

ដូចនេះភ្នក់ភ្លើងនៃសង្គ្រាមក៏បានឆាបឆេះឡើងហើយបង្កគ្រោះមហន្តរាយនិងវិបត្តិនានាយ៉ាងធ្ងន់ធ្ងរជាពិសេស នៅអឺរ៉ុប និង អាស៊ី ៖

### ៣.១-វិបត្តិនៅអាល្លឺម៉ង់

ហេតុអ្វីបានជាគេពោលថា បញ្ហានៅអាល្លឺម៉ង់ ជាបញ្ហាស្នូលនៃសង្គ្រាមត្រជាក់ ?

បញ្ហាអាល្លឺម៉ង់ ជាបញ្ហាដ៏ស្រួចស្រាល់មួយ ដែលធ្វើឱ្យពិភពលោកត្រូវរង្គោះរង្គើដោយសារការប្រជែងគ្នា និងការប្រឈមមុខដាក់គ្នា រវាងមហាអំណាចធំ២គឺសហរដ្ឋអាម៉េរិក និង សហភាពសូវៀត៖

❖ ***ការប្រជែងគ្នា៖***

-សន្និសីទយ៉ាល់តា និងពតស្តាំ បានបែងចែងប្រទេសអាល្លឺម៉ង់

- ផ្នែកខាងលិច មាន១១រដ្ឋ គ្រប់គ្រងដោយ អាម៉េរិក អង់គ្លេស និងបារាំង
- ផ្នែកខាងកើត មាន ៥រដ្ឋ គ្រប់គ្រងដោយ សហភាពសូវៀត

-ផែនការម៉ារសាល់: បង្កើតដោយ អាម៉េរិក នៅថ្ងៃ៥ មិថុនា១៩៤៧ មានទិសដៅ៖

- ស្តារទ្វីបអឺរ៉ុបឡើងវិញ
- ទប់ស្កាត់ការរីករាលដាលនៃលទ្ធិកុម្មុយនីស្ត

-សន្និសីទ ក្រុងឡុងដ៍ៈបង្កើតឡើង នៅខែមិថុនា១៩៤៨ ដោយអាម៉េរិក អង់គ្លេស និងបារាំង មានបំណងបង្រួបបង្រួមអាល្លឺម៉ង់ខាងលិចជាតំបន់តែមួយ និងឯកភាពខាងរូបិយវត្ថុជាសម្ងាត់ ។

**វាំងននដែក** បានបែងចែកទ្វីបអឺរ៉ុបជា២ប្លុកគឺខាងលិច និងខាងកើតដែលជានិមិត្តរូបនៃ**សង្គ្រាមត្រជាក់។**

## បញ្ហាប្រទេសអាល្លឺម៉ង់

ក្រោយសង្គ្រាមលោកលើកទី២ ប្រទេសអាល្លឺម៉ង់ត្រូវកាន់កាប់ដោយកងទ័ពសម្ពន្ធមិត្ត។ ប្រទេសនេះត្រូវបានបែងចែកជា៤តំបន់កាន់កាប់គឺ អង់គ្លេស បារាំង សហភាពសូវៀត និងសហរដ្ឋអាម៉េរិក។ សម័យកាលក្នុងសង្គ្រាមត្រជាក់ អាល្លឺម៉ង់គឺជាចំណុចក្តៅបំផុតពីឆ្នាំ១៩៤៨ ដល់ឆ្នាំ១៩៥៣។

យោងទៅតាមកិច្ចព្រមព្រៀងទីក្រុងយ៉ាល់តា កងទ័ពសម្ពន្ធមិត្តបានកាន់កាប់ប្រទេសអាល្លឺម៉ង់ដោយធ្វើការបែងចែកទៅតាមតំបន់។ មកដល់ខែសីហា ឆ្នាំ១៩៤៥ គេបានបង្កើតក្រុមប្រឹក្សាត្រួត ពិនិត្យលើកងទ័ពសម្ពន្ធមិត្តក្នុងឋានៈ ជាអង្គការជាន់ខ្ពស់សំរាប់ធ្វើការពិភាក្សាដោះស្រាយលើបញ្ហាផ្សេងៗ ដែលទាក់ទងនឹងវិស័យសេដ្ឋកិច្ច និងនយោបាយនៅក្នុងប្រទេសអាល្លឺម៉ង់ក្រោយសង្គ្រាមលោកលើក ទី២។

សភាពការណ៍ប្រែប្រួលដំបូងគឺតំបន់កាន់កាប់របស់បារាំង និងសូវៀតបានធ្វើអ្វីៗជារបៀបស្វយ័តដោយមិនសួរយោបល់ពីក្រុមប្រឹក្សាត្រួតពិនិត្យរបស់កងទ័ពសម្ពន្ធមិត្តឡើយ ជាពិសេសនោះតំបន់របស់សហភាពសូវៀតបានរៀបចំទម្រង់មូលដ្ឋានសេដ្ឋកិច្ចមួយ ដែលមានលក្ខណៈជាលិទ្ធិសង្គមនិយម ដូចជា កំណែទម្រង់ដីធ្លី ការធ្វើជាតូបនីយកម្ម។

ក្នុងអំឡុងពេលនៃការប្រារព្ធសន្និសីទរដ្ឋមន្រ្តីការបរទេសពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៤៧ មានភាពមិនចុះសម្រុងគ្នាមួយចំនួនដូចជា តំបន់សារ និងការរៀបចំសេដ្ឋកិច្ចក្នុងប្រទេសអាល្លឺម៉ង់របស់សហរដ្ឋអាម៉េរិកត្រូវជួបប្រទះរបបសេដ្ឋកិច្ចសង្គមនិយមដែលសូវៀតបានបង្កើត។

សង្គ្រាមត្រជាក់ កាន់តែរីកធំឡើងនៅក្នុងខែមីនា ឆ្នាំ១៩៤៨ នៅពេលក្រុមប្រឹក្សាត្រួតពិនិត្យសម្ពន្ធមិត្តត្រូវជួលរលំនិងអ្នកតំណាងសូវៀតចាកចេញពីប្រទេសអាល្លឺម៉ង់។ រហូតមកដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៤៨ នៅក្នុងតំបន់របស់លោកខាងលិចកាន់កាប់មានការកែទម្រង់រូបិយវត្ថុ ដែលជាដំណាក់កាលនៃការចាប់ផ្តើមមានសន្ទុះសេដ្ឋកិច្ចសាជាថ្មីឡើងវិញនៃអាល្លឺម៉ង់។ ឯក្នុងតំបន់របស់សូវៀតវិញ ក៏មានការកែទម្រង់រូបិយវត្ថុផងដែរ រហូតដល់មានយុទ្ធនាការឡោមព័ទ្ធទីក្រុងប៊ែរឡាំងពីខែមិថុនា ១៩៤៨ ដល់ខែឧសភា ១៩៤៩ តែត្រូវបរាជ័យ ព្រោះសហរដ្ឋអាម៉េរិក បានស្ថាបនាផ្លូវហោះហើរដើម្បីដឹកជញ្ជូនបំពេញតម្រូវការរបស់ទីក្រុង។ ពេលនោះការកាត់ផ្តាច់ទឹកដីជាពីរបានចាប់ផ្តើម ហើយបញ្ហាទឹកដីអាល្លឺម៉ង់ក៏ក្លាយជាបញ្ហារសើបមួយ នៃការប្រឈមមុខដាក់គ្នារវាងប្លុកខាងលិច និងសូវៀត។ ដោយមានការជួយឧបត្ថម្ភគាំទ្រពីសហរដ្ឋអាមេរិក អង់គ្លេស និងបារាំង សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ត្រូវបានបង្កើតនៅខែឧសភា ឆ្នាំ១៩៤៩។ ចាប់ពីពេលនោះមកប្រទេសនេះត្រូវពួកប្លុកខាងលិចចាត់ទុកជាប្រទេសស្របច្បាប់នៃប្រជាជាតិអាល្លឺម៉ង់ និងបានបញ្ចូលប្រទេសនេះ ក្នុងរង្វង់សកម្មភាពនយោបាយ យោធា និងសេដ្ឋកិច្ចរបស់លោកខាងលិចផង។ រីឯតំបន់កាន់កាប់របស់សហភាសូវៀតវិញក៏បានបង្កើតជា សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ នៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៤៩ ផងដែរ។ រហូតមកដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥២ នៅពេលដែលប្រទេសលោកខាងលិចរៀបចំគម្រោងការបញ្ចូលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នៅក្នុងសហគមន៍ការពារទ្វីបអឺរ៉ុប (The European community of defense) សហភាពសូវៀតបានលើកគោលការណ៍ដូចជា៖

- ត្រូវរៀបចំការបោះឆ្នោតដោយសេរីមួយនៅក្នុងប្រទេសអាល្លឺម៉ង់។
- កងកម្លាំងយោធាបរទេសត្រូវដកចេញពីទឹកដីអាល្លឺម៉ង់ឱ្យអស់
- អនុញ្ញាតឱ្យអតីតសមាជិកនៃគណបក្សណាស៊ី មានសិទ្ធិគ្រប់ៗគ្នា និងអនុញ្ញាតឱ្យប្រទេសអាល្លឺម៉ង់ មានសិទ្ធិរៀបចំកងទ័ពរបស់ខ្លួន ហើយសិទ្ធិមានកងទ័ពនេះត្រូវគោរពតាមលក្ខខណ្ឌពីរ គឺ(ទី១)អាល្លឺម៉ង់ត្រូវតែជាប្រទេសអព្យាក្រិត (ទី២)អាល្លឺម៉ង់មិនត្រូវចូលរួមក្នុងបក្សសម្ពន្ធយោធាណាមួយឡើយ។[488]

សំណើខាងលើរបស់សូវៀតត្រូវបដិសេធន៍ដោយលោក Adenauer ដែលជាមេដឹកនាំអាល្លឺម៉ង់ខាងលិច និងទទួលការជំទាស់ពីប្រទេសមហាអំណាចលោកខាងលិច។

នៅពេលនោះលោក Adenauer ដែលជាមេដឹកនាំអាល្លឺម៉ង់ខាងលិច បានជ្រើសយកផ្លូវ បំពាក់អាវុធឡើងវិញ និងបញ្ចូលប្រទេសអាល្លឺម៉ង់ខាងលិច ទៅក្នុងប្លុកសម្ពន្ធយោធា អូតង់តែម្តង[489]។

- នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៦០ សន្និសីទកំពូលនៅទីក្រុងបារីសស្តីពីបញ្ហាក្រុងបែរឡាំងត្រូវទទួលនូវភាពទាល់ច្រក ដែលជាហេតុមួយធ្វើឱ្យដំណោះស្រាយកាន់តែតានតឹងឡើង។
- ថ្ងៃទី១៣ សីហា ១៩៦១ ជញ្ជាំងបែរឡាំងត្រូវបានសាងសង់ដែលមានប្រវែង៤៣គ.ម. តាមខ្សែបន្ទាត់ព្រំដែននៃទឹកដីខាងកើតនិងខាងលិច(ប្រវែងព្រំដែនព័ទ្ធជុំវិញទីក្រុងបែរឡាំងខាងលិច មានប្រវែងសរុប១៥៥គម, ប្រវែងព្រំដែនរវាងបែរឡាំងខាងលិច ជាមួយអាល្លឺម៉ង់ខាងកើត ១១១,៩ គម និងប្រវែងព្រំដែនរវាងបែរឡាំងខាងលិច ជាមួយបែរឡាំងខាងកើត ៤៣.១គម)។

មកដល់ឆ្នាំ១៩៨៩ ទើបជញ្ជាំងបែរឡាំងត្រូវបានដួលរលំហើយនៅខែកក្កដា ឆ្នាំ១៩៩០ ទើបអាល្លឺម៉ង់ទាំងពីរមានការឯកភាពគ្នាក្នុងការបង្កើតរូបិយវត្ថុរួម និងបង្កើតពន្ធអាករ។ រហូតមកដល់ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៩០ ប្រទេសអាល្លឺម៉ង់ទាំងពីរធ្វើការបង្រួបបង្រួមទៅជាអាល្លឺម៉ង់តែមួយ ប៉ុន្តែបញ្ហានោះគឺ គម្លាតគ្នារវាង សេដ្ឋកិច្ចអាល្លឺម៉ង់ខាងលិច និងខាងកើតដែលប្រទេសនេះ ត្រូវដោះស្រាយនៅពេលបន្ទាប់។

## ៣.២-សង្គ្រាមស៊ីវិលនៅប្រទេសចិន និងវិបត្តិនៅតៃវ៉ាន់

នៅក្នុងពេលដែលប្រទេសចិន ទទួលការឈ្លានពានពីសំណាក់កងទ័ពជប៉ុន នៅទសវត្ស ឆ្នាំ១៩៣០ ភាគីជម្លោះទាំងពីរនៅក្នុងប្រទេសចិន បានរួមកម្លាំងគ្នាប្រឆាំងនឹងសត្រូវឈ្លានពាន រហូតទទួលបានជោគជ័យ។ ប៉ុន្តែក្រោយពេលសង្គ្រាមលោកលើកទី២ បានបញ្ចប់ទៅ សង្គ្រាមរវាងភាគីទាំងពីរបានចាប់ផ្តើមសារជាថ្មី។

ដូច្នេះនៅពេលដែលសង្គ្រាមលោកលើកទី២បានបញ្ចប់ នៅក្នុងប្រទេសចិនមានកម្លាំងពីរ ដែលនៅប្រឈមមុខដាក់គ្នាគឺកម្លាំងអ្នកជាតិនិយមចិន និងកម្លាំងពួកកុម្មុយនីស្តនិយម។ ក្រុមកុម្មុយនីស្ត

---

[488] ខៀវ ថវិកា, *ប្រវត្តិនៃទំនាក់ទំនងអន្តរជាតិ ពីឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន*, ទំព័រ១៥។

[489] ហើស សិរីធន, *សង្គ្រាមត្រជាក់*, រោងពុម្ពពន្លឺខ្មែរ, ឆ្នាំ២០១៤, ទំព័រ១១៤។

បានរៀបចំ និងចាត់តាំងចលនាសង្គ្រាមឈ្លប ក្រោមយុទ្ធសាស្ត្រពីរ ទីមួយធ្វើសង្គ្រាមឈ្លបប្រឆាំងនឹងរដ្ឋាភិបាលលោក ចាង ខៃចៀក និងទីពីរ ប្រឆាំងនឹងកងទ័ពជប៉ុន។

ចាប់ពីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៤៤ លោកឧត្តមសេនីយ ហ្សូរឡី (Patrick Hurley) បានទទួលជួបប្រាស្រ័យ ទាក់ទងជាមួយនឹងមេដឹកនាំកម្លាំងកុម្មុយនីស្ត ក្នុងប្រទេសចិន **ម៉ៅសេទុង** (Mao Tse Toung) នៅក្នុងតំបន់ យេណាន់ (Yenan) ។ បេសកកម្មរបស់លោក ហ្សូរឡី ធ្វើយ៉ាងណាដើម្បីឱ្យកម្លាំងប្រឈមមុខដាក់គ្នារវាងអ្នកជាតិនិយម និងពួកកុម្មុយនីស្ត បានបង្រួបបង្រួមគ្នា ហើយបន្ទាប់មកបង្កើតជារដ្ឋាភិបាលចម្រុះមួយ ដោយយោលទៅតាមគោលការណ៍របស់លោក **ស៊ុនយ៉ាតសេន** ប៉ុន្តែមានចំណុចមួយចំនួនដែលមិនស្របគ្នា ពោលមុនការបង្រួបបង្រួមនេះគឺថា រដ្ឋាភិបាលរបស់អ្នកជាតិនិយមត្រូវរំលាយចោលជាមុនសិន។ ចំណុចមួយទៀត មិនអាចយល់ព្រមទាល់តែសោះនូវការបញ្ចូលសមាសភាពពួកកុម្មុយនីស្តទៅក្នុងរដ្ឋាភិបាលចម្រុះនោះ។ អាស្រ័យដោយមានការខិតខំប្រឹងប្រែងរបស់លោក ឧសេនីយអាម៉េរិក ហ្សូរឡី កិច្ចចរចាមួយបានប្រព្រឹត្តទៅនៅតំបន់ **ជូន គីង (Tchoung King)** រវាងពួកុម្មុយនីស្ត ដែលដឹកនាំដោយជូ អេនឡាយ និងពួកអ្នកជាតិនិយម ដែលដឹកនាំដោយ រដ្ឋមន្ត្រីការបរទេសនៃគណបក្សគួមីងតាង លោក **ស៊ូង (Soong)** ប៉ុន្តែកិច្ចចរចានេះពុំបានទទួលលទ្ធផលអ្វីទេ ដោយរដ្ឋាភិបាលលោក ចាង ខៃចៀកបានបដិសេធចំពោះការបង្កើតរដ្ឋាភិបាលចម្រុះ និងសំណូមពរស្នើសុំរបស់ ពួកកុម្មុយនីស្ត ក្នុងការទាមទារឱ្យដោះលែងឈ្លើយសឹកនយោបាយ។

បរាជ័យនៃកិច្ចចរចាធ្វើឱ្យលោក ហ្សូរឡី តំណាងអាម៉េរិក កៀបសង្កត់មួយកម្រិតទៀត ទៅលើពួកកុម្មុយនីស្ត និងក្រុមអ្នកជាតិនិយមចិន ដោយស្នើឱ្យរដ្ឋាភិបាលអាម៉េរិក បញ្ឈប់ជំនួយទាំងគ្រឿងសព្វាវុធ ទាំងហិរញ្ញវត្ថុ។

នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៤៥ លោក ហ្សូរឡី បានជួបសន្ទនាជាមួយមេដឹកនាំសហភាពសូវៀត លោកស្តាលីន និងលោករដ្ឋមន្ត្រីការបរទេសម៉ូឡូតូវ នាទីក្រុងមូស្គូ ដែលនៅទីនោះតំណាងសហភាពសូវៀត បានប្រកាសឱ្យដឹងថា ខ្លួនមិនគាំទ្រចំពោះបក្សកុម្មុយនីស្តចិនឡើយ ពីព្រោះសហភាពសូវៀត គ្មានបំណងណាមួយចង់ឱ្យមានសង្គ្រាមស៊ីវិល នៅក្នុងប្រទេសចិនទេ។ នៅថ្ងៃទី១ ខែកក្កដា ១៩៤៥ កិច្ចចរចាជាថ្មីម្តងទៀតរវាង ពួកអ្នកជាតិនិយម និងពួកកុម្មុយនីស្ត បានដំណើរការនៅយេណាន់ ដែលពួកកុម្មុយនីស្តបានយកធ្វើជារដ្ឋធានី។ មកទល់នឹងថ្ងៃទី២៨ ខែសីហា ដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ ១៩៤៥ ម៉ៅសេទុង បានសុខចិត្តទទួលយល់ព្រមចុះហត្ថលេខាជាមួយគណៈបក្សគួរមីងតាង ។ តាមកិច្ចព្រមព្រៀងនេះគឺ លោកជៀងកៃចៀក នឹងកាន់តំណែងជាប្រមុខដឹកនាំ នៅក្នុងរដ្ឋាភិបាលនាពេលអនាគត ដោយយោលទៅតាមសមមាត្ររវាងភាគីទាំងសងខាង(គួរមីងតាង មានកងទ័ពចំនួន១០០ កងពលធំ ឯពួកកុម្មុយនីស្តមានមិនដល់២០កងពលធំផង)។ ប៉ុន្តែកិច្ចចរចានានា ត្រូវជួបប្រទះនឹងភាពចម្រូងចម្រាស ដោយសារស្ថានការណ៍នៅក្នុងតំបន់ម៉ាន់ជូរី ដែលបណ្តាលឱ្យផ្ទុះឡើងជាសង្គ្រាមស៊ីវិលជាថ្មីម្តងទៀត រវាងពួកកុម្មុយនីស្ត និងពួកអ្នកជាតិនិយម។ ដោយទទួលបរាជ័យ លោកហ្សូរឡី

បានស្នើលាលែងពីតំណែង។ លោកប្រធានាធិបតី អាម៉េរិក ទ្រូម៉ាន់ បានដាក់លោកម៉ារសាល់ មកជំនួស ក្នុងការដោះស្រាយបញ្ហានៅប្រទេសចិន។

ចាប់ពីរដូវក្ដៅ ឆ្នាំ១៩៤៦ ប្រទេសចិនបានពើបប្រទះនឹងភ្លើងសង្គ្រាមស៊ីវិល។ នៅឆ្នាំ១៩៤៧ កងទ័ពអ្នកជាតិនិយម បានទទួលជ័យជម្នះខ្លះៗ ទៅលើទ័ពកុម្មុយនីស្ត ដោយដណ្ដើមយកបានតំបន់យេណាន់ ដែលជារដ្ឋធានីរបស់ពួកកុម្មុយនីស្ត។ ប៉ុន្តែស្ថានការណ៍ត្រូវប្រែប្រួល ដោយសារនៅក្នុងប្រព័ន្ធគ្រប់គ្រងលោក ចាង ខៃចៀក ពោពេញទៅដោយអំពើពុករលួយ ដែលជាហេតុធ្វើឱ្យកម្លាំងកុម្មុយនីស្តមានប្រៀបជាងកម្លាំងអ្នកជាតិនិយម។

អាស្រ័យដោយកត្តានេះហើយ ទើបមកទល់ខែមករា ឆ្នាំ១៩៤៩ កងទ័ពក្រហមដណ្ដើមបានទីក្រុងប៉េកាំង និងវាយសម្រុកមកភាគខាងត្បូង ពេលនោះហើយ ដែលគណបក្សគួរមីងតាង ត្រូវរលាយ។ នៅដំណាច់ចុងឆ្នាំ១៩៤៩ កងទ័ពកុម្មុយនីស្ត បានកាន់កាប់តំបន់ស្ទើរតែទាំងអស់របស់ប្រទេសចិន។ រដ្ឋាភិបាល លោកជៀងកៃចៀក ក៏បានបង្ខំចិត្តទៅនៅកោះតៃវ៉ាន់។

នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩ សាធារណរដ្ឋប្រជាមានិតចិន បានត្រូវប្រកាសឡើងជាផ្លូវការ ដែលក្នុងពេលនោះលោកម៉ៅសេទុង កាន់តំណែងជាប្រធានាធិបតី ហើយលោកជូអេនឡាយ ជានាយករដ្ឋមន្ត្រី។

ចាប់តាំងពីលទ្ធិម៉ៅនិយមបានទទួលជោគជ័យនៅឆ្នាំ១៩៤៩ មក ប្រទេសចិន ក៏បានក្លាយទៅជាប្រទេសកុម្មុយនីស្ត (សាធារណៈរដ្ឋប្រជាមានិតចិន) មួយយ៉ាងធំក្នុងពិភពលោកដែលទទួលស្គាល់ភ្លាមៗដោយ សហភាពសូវៀតនិងបណ្ដាប្រទេសប្រជាធិបតេយ្យប្រជាមានិត រីឯសហរដ្ឋអាម៉េរិកវិញមិនទទួលស្គាល់ សាធារណៈរដ្ឋប្រជាមានិតចិន ដែលប្រកាសដោយម៉ៅសេទុងនោះទេ តែទទួលស្គាល់រដ្ឋាភិបាលជៀងកាយចៀកនៅ កោះតៃវ៉ាន់ ដែលជាពួកអ្នកជាតិនិយម[490] ចំណែកឯ អង់គ្លេសចង់ការពារហុងកុង។

ចាប់តាំងពីឆ្នាំ១៩៥០មក ប្រទេសចិនបានយកទីបេត៏ ដែលមានព្រំដែនជាប់នឹងឥណ្ឌាធ្វើជាឧបសម្ព័ន្ធរបស់ខ្លួនធ្វើឱ្យបណ្ដាប្រទេសលោកខាងលិចមានការព្រួយបារម្ភយ៉ាងខ្លាំង។

ម៉ៅសេទុង នៅតែព្យាយាមដណ្ដើមយកតៃវ៉ាន់ ដូចនេះ អាម៉េរិកបានគាំទ្រតៃវ៉ាន់ពេញទំហឹង ។

នៅឆ្នាំ១៩៥៤ ចិនបានទំលាក់គ្រាប់បែកទៅលើកោះតូចៗជាច្រើននៅជិតតៃវ៉ាន់ ដែលគ្រប់គ្រងដោយ ពួកជាតិនិយម ឯអាម៉េរិក បានគំរាមចិនថានឹងទំលាក់គ្រាប់បែកបរមាណូ ដូចនេះចិនប្រកាសវាយ តៃវ៉ាន់ដោយកម្លាំងទ័ព។

### ៣.៣-វិបត្តិ និងសង្គ្រាមនៅឧបទ្វីបកូរ៉េ

ស្ថានភាពនៅប្រទេសកូរ៉េមានលក្ខណៈប្រហាក់ប្រហែលគ្នានិងនៅអាល្លឺម៉ង់ដែរ។

---

[490] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា, ដ.ឯ.ម., ទំព័រ៤១។

បន្ទាប់ពីនៅក្រោមការត្រួតត្រារបស់ជប៉ុន នៅឆ្នាំ១៩៤៥ កូរ៉េបានបែងចែកជាពីរតំបន់កាន់កាប់ខណ្ឌដោយខ្សែស្របទី៣៨ ដឺក្រេខាងជើង ដែលភាគខាងជើង កាន់កាប់ដោយ សូវៀត និង ភាគខាងត្បូងកាន់កាប់ដោយអាម៉េរិក ។

នៅឆ្នាំ១៩៤៨តំបន់ទាំងពីរនេះបានប្រែក្លាយទៅជារដ្ឋពីរ[491]គឺ៖

- កូរ៉េខាងជើង៖ គឺជារដ្ឋប្រជាធិបតេយ្យ ប្រជាមានិត្យ មានរដ្ឋធានីនៅ ព្យុងយ៉ាង ដឹកនាំដោយ លោក គីម អ៊ីលស៊ុង ។
- កូរ៉េខាងត្បូង៖ជាសាធារណរដ្ឋ មានរដ្ឋធានីនៅ សេអ៊ូលដឹកនាំដោយ លោក ស៊ីន ម៉ានរី។

នៅខែមិថុនា ឆ្នាំ១៩៥០ កងទ័ពកូរ៉េខាងជើងដោយបានទទួលការគាំទ្រ ពីសូវៀត បានឆ្លងកាត់ខ្សែស្របទី៣៨$^{o}$ និងបានឆ្លងកាត់ទៅដល់ចុងខាងត្បូងបំផុតនៃឧបទ្វីបកូរ៉េ តែក្នុងរយៈពេល២ ឬ ៣ថ្ងៃប៉ុណ្ណោះដោយពុំបានប្រកាសសង្គ្រាមនោះទេ រីឯសហរដ្ឋអាម៉េរិកវិញក៏ពុំមានប្រតិកម្មអ្វីសោះឡើយ។

ភ្លាមៗ នោះអង្គការសហប្រជាជាតិបានកោះអញ្ជើញសមាជិករបស់ខ្លួនឱ្យជួយដល់កូរ៉េខាងត្បូង ប៉ុន្តែ សូវៀត មិនចូលរួម និង អវត្តមាននៅក្នុងការបោះឆ្នោត ដើម្បីលើកទ័ពជួយកូរ៉េ ។

មួយភាគធំនៃកងទ័ពសហប្រជាជាតិគឺជាកងទ័ពរបស់អាម៉េរិក ស្ថិតក្រោមបញ្ជាឧត្តម សេនីយ៍ ម៉ាក់ អាទួរ (MAC ARTHUR)។ នៅខែកញ្ញា១៩៥០ កងទ័ពសហប្រជាជាតិបានឡើងគោក រួចរុញច្រានកងទ័ពកូរ៉េខាងជើងហួសឆ្ងាយពីខ្សែស្របទី៣៨។ នៅចុងឆ្នាំ១៩៥០ ប្រទេសកូរ៉េខាងជើងត្រូវកងទ័ពសហប្រជាជាតិវាយដណ្តើមបានមួយភាគធំ។ កូរ៉េខាងជើងដោយទទួលបានជំនួយពីប្រទេសចិនក៏បានរុញច្រានកងទ័ពសហប្រជាជាតិ មកខាងត្បូងវិញយ៉ាងឆ្ងាយ។ ដោយសង្គ្រាមដែលមានលក្ខណៈស៊ីសាច់ហុតឈាម និងការលំបាកយ៉ាងខ្លាំង ម៉ាក់ អាទួរ មានបំណងប្រើអាវុធបរមាណូ ប៉ុន្តែ លោក ទ្រូម៉ាន់ មិនយល់ព្រមព្រោះខ្លាចអន្តរាគមន៍របស់សូវៀតដែលមាន អាវុធបរមាណូ ដែរ។ ក្នុងសង្គ្រាមនេះបានធ្វើឱ្យមនុស្សស្លាប់អស់២ ៣០០ ០០០នាក់ ដែល ៤/៥ ជាប្រជាជនស៊ីវិល[492]។ នៅឆ្នាំ១៩៥១ លោកឧត្តមសេនីយ៍ រីតវ៉េ (RIDGWAY) បានឡើងមកជំនួស លោក ម៉ាក់ អាទួរ ដែលបានធ្វើឱ្យសង្គ្រាមក្លាយទៅជាសង្គ្រាមទីតាំង និងឈានដល់ការចរចារយុទ្ធសន្តិភាព ដែលប្រព្រឹត្តទៅនៅប៉ានមុនជុន(PUN MUNJON) នៅខ្សែស្របទី៣៨$^{0}$ ហើយរហូតដល់ខែកក្កដា១៩៥៣គឺពីរ បីខែក្រោយមរណៈភាពរបស់ស្តាលីន ទើបមាន ការចុះហត្ថលេខាយុទ្ធសន្តិភាពនេះ។

**បញ្ហាប្រទេសកូរ៉េ**

ប្រទេសកូរ៉េបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជប៉ុន តាំងពីឆ្នាំ១៩១០។ ក្នុងសង្គ្រាមលោកលើកទី២ សហភាពសូវៀត និង សហរដ្ឋអាម៉េរិក បានរំដោះប្រទេសនេះចេញពីកណ្តាប់ដៃជប៉ុន ដោយសូវៀតឈរជើងនៅខាងជើង និងសហរដ្ឋអាម៉េរិកឈរជើងនៅភាគខាងត្បូងនៃប្រទេសកូរ៉េ។ ចាប់ពីខែ

---

[491] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា, *ឯកសារប្រវត្តិវិទ្យា សម្រាប់សាស្ត្រាចារ្យទុតិយភូមិ*, ដ.ឯ.ម., ទំព័រ៣៩។

[492] -ដ- ទំព័រ៤១។

មិថុនា ឆ្នាំ១៩៥០ ប្រទេសកូរ៉េបានក្លាយជាសមរភូមិប្រយុទ្ធរវាងប្លុកខាងលិច និងខាងកើតចំពេលដែលសង្គ្រាមត្រជាក់កំពុងពុះកញ្ជ្រោល។ ដើម្បីដោះស្រាយបញ្ហាប្រទេសកូរ៉េ ដំបូងគេបានបង្កើតគណកម្មាធិការចម្រុះរុស្ស៊ីអាម៉េរិក ក្នុងគោលបំណងរៀបចំ និងសម្រួល ឱ្យមានជារដ្ឋាភិបាលបណ្តោះអាសន្នមួយឡើង។ សហរដ្ឋអាម៉េរិកបានស្នើឱ្យមានការបោះឆ្នោតជាសកលនៅក្នុងតំបន់នីមួយៗតែសហភាពសូវៀតជំទាស់។ សហរដ្ឋអាម៉េរិកបានបញ្ចូលបញ្ហាប្រទេសកូរ៉េនៅក្នុងសម័យប្រជុំរបស់អង្គការសហប្រជាជាតិ ប៉ុន្តែត្រូវសហភាពសូវៀតជំទាស់ម្តងទៀត។ សម័យប្រជុំបានជំទាស់និងសហភាពសូវៀត។ អង្គការសហប្រជាជាតិ ក៏បានចេញសេចក្តីសំរេចបង្កើតគណកម្មាធិការបណ្តោះអាសន្ន របស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសកូរ៉េមួយឡើង។ គណកម្មាធិការមួយនេះមិនអាចសម្រេចការងារអ្វីជាដុំកំភួនឡើយ។ នៅតំបន់ភាគខាងត្បូងរបស់សហរដ្ឋអាម៉េរិក មានសមាគមជាតិដើម្បីធ្វើឱ្យសម្រេចយ៉ាងរហ័សនូវឯករាជ្យកូរ៉េដែលដឹកនាំដោយលោកស៊ុនម៉ាន់រី ត្រូវបានបង្កើតឡើង។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៤៨ ភាគខាងត្បូងបានដំណើរការបោះឆ្នោតហើយសមាគមរបស់លោក ស៊ុនម៉ាន់រី ទទួលសំឡេងភាគច្រើនហើយក៏បានបង្កើតរដ្ឋាភិបាលមួយឡើង។

ឯនៅភាគខាងជើង ដែលកងទ័ពសូវៀតឈរជើងក៏បានបង្កើតក្រុមប្រឹក្សាមួយឈ្មោះថា ក្រុមប្រឹក្សាកូរ៉េខាងជើងដឹកនាំដោយលោក គឹមអ៊ីលស៊ុង។ នៅខែឧសភា ឆ្នាំ១៩៤៨សភាប្រជាជនទូទាំងប្រទេសបានរៀបចំការបោះឆ្នោត។ មកដល់ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៤៨ សភានេះបានតែងតាំងរដ្ឋាភិបាលមួយ ដែលមានឈ្មោះថា រដ្ឋាភិបាល សាធារណរដ្ឋប្រជាមានិតកូរ៉េ។

ស្ថិតនៅចំពោះមុខសភាពការនេះ គណកម្មាធិការបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិបានលើកសំណើឱ្យសហគមអន្តរជាតិទទួលស្គាល់ទាំងប្រទេសកូរ៉េខាងជើង និងកូរ៉េខាងត្បូង។ បន្ទាប់មកគណកម្មាធិការនេះ បានប្តូរឈ្មោះទៅជាគណកម្មាធិការអចិន្ត្រៃរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសកូរ៉េនៅក្នុងខែធ្នូឆ្នាំ ១៩៤៨។

**សង្គ្រាមកូរ៉េ**

ដោយមើលឃើញអាម៉េរិក ខិតខំគ្រប់គ្រងតែនៅប្រទេសជប៉ុន កោះអូគីណាវ៉ា និងហ្វីលីពីន ហើយមិនច្បាស់ថាតើសហរដ្ឋអាម៉េរិក ពង្រឹងមកកោះតៃវ៉ាន់ កូរ៉េខាងត្បូងនិងអាស៊ីអាគ្នេយ៍ ឬ យ៉ាងណា និងដោយជឿជាក់ថាសហរដ្ឋអាម៉េរិក មិនមានបំណងការពារកូរ៉េខាងត្បូងនោះ សហភាព សូវៀត ក៏បានអនុញ្ញាតឱ្យកូរ៉េខាងជើងឈ្លានពានកូរ៉េខាងត្បូង។ កងទ័ពកូរ៉េខាងជើង បានកាន់កាប់លើកូរ៉េខាងត្បូងយ៉ាងរហ័ស តែត្រូវកងទ័ពអង្គការសហប្រជាជាតិ និងកូរ៉េខាងត្បូងបានវាយរុញច្រានឆ្ពោះទៅខាងជើងរហូតដល់ព្រំដែនចិន។ ដោយខ្លាចការដួលរលំនៃកូរ៉េខាងជើងនិងអាចបន្តការឈ្លានពានចិននោះ ម៉ៅបានបញ្ជូនកងទ័ពចិនចូលក្នុងកូរ៉េខាងជើង។ ជាលទ្ធផលកងកម្លាំងរបស់អង្គការសហប្រជាជាតិក៏ដកថយទៅខាងត្បូងវិញ។ ដោយវាយយកតាមដីគោកមិនអាចឈ្នះលើកងទ័ពចិនឧត្តមសេនីយ៍ម៉ាកអាធួរ បានធ្វើគម្រោងចង់ទម្លាក់គ្រាប់បែក និងបាញ់គ្រាប់មីស៊ីលលើមូលដ្ឋានទ័ពចិន តែបើធ្វើដូច្នោះវានឹង បណ្តាលឱ្យមានសង្គ្រាមជាមួយសូវៀតទៀតផង។

រដ្ឋាភិបាលទ្រូម៉ាន់បាននិយាយថា ផលប្រយោជន៍នៅអាស៊ីជីគោគ វាមិនមានតម្លៃគ្រប់គ្រាន់និងការវាយប្រថុយជាមួយសង្គ្រាមលោកលើកទី៣ឡើយ។ ដូច្នេះចិនមិនត្រូវបានទម្លាក់គ្រាប់បែកឡើយ ហើយលោកម៉ាកអាធូរត្រូវបានដកចេញពីមុខតំណែង ហើយយកលោក រីដវេ មកជំនួសវិញនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥១។ ក្រោយមកលោកម៉ាក់អាធួរត្រូវបានបាញ់សំលាប់នៅពេលគាត់តវ៉ាជាសាធារណៈនោះ។ រហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៥៣ កូរ៉េខាងជើងនិងខាងត្បូងបានចុះហត្ថលេខាលើយុទ្ធសាស្រ្តសន្តិភាព នៅប៉ាន់ម៉ុនជុន ដើម្បីបញ្ចប់សង្គ្រាម។

## ៤-សន្តិសហវិជ្ជមាន១៩៥៣-១៩៦២ និងការលេចឡើងនូវវិបត្តិនានា

### ៤.១-និយមន័យ

សន្តិសហវិជ្ជមានគឺជានយោបាយអត់ឱនឱ្យគ្នាទៅវិញទៅមករវាងប្លុកទាំងពីរ ដើម្បីចៀសវាងការប្រថុយប្រថាន ដែលអាចនាំពិភពលោកឆ្ពោះទៅរកក្តីវិនាសអន្តរាយដោយសារអាវុធមហាប្រល័យ (បរមាណូ)[493]។

នយោបាយនេះចាប់ផ្តើមធ្វើដោយលោក គ្រូតឆូវបន្ទាប់ពីមរណភាពរបស់ស្តាលីន។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មហាអំណាចទាំងពីរនៅតែមិនអាចលះបង់នូវមនោគមវិជ្ជារបស់ខ្លួនបានឡើយ គឺថាខាងសហភាពសូវៀត លោក គ្រូត ឆូវ ពុំបានបោះបង់នយោបាយពង្វាតលទ្ធិ កុម្មុយនីស្តក្នុងពិភពលោកទេ រីឯសហរដ្ឋអាម៉េរិកវិញក៏បានរិះរកគ្រប់មធ្យោបាយ ដើម្បីរាំងខ្ទប់នយោបាយពង្វាតលទ្ធិកុម្មុយនីស្តនៅគ្រប់ទិសទី។

### ៤.២-បុព្វហេតុខ្លះៗមុននឹងឈានដល់សន្តិសហវិជ្ជមាន

**ក-ការរត់ប្រណាំងផ្នែកសព្វាវុធ[494]**

- ❖ នៅឆ្នាំ១៩៤៥អាម៉េរិកផលិតបានគ្រាប់បែកបរមាណូ និងបានប្រើប្រាស់វាជាលើកទី១ នៅក្នុងការ ប្រឆាំងជប៉ុន ។
- ❖ នៅឆ្នាំ១៩៤៩ សហភាពសូវៀតផលិតបាន គ្រាប់បែកបរមាណូ និងបាន សាកល្បងវាជាលើកទី១
- ❖ ១៩៥២ សហរដ្ឋអាម៉េរិក ផលិតបានគ្រាប់បែកថ្មីដែលមានអនុភាពខ្លាំងជាងមុន គឺគ្រាប់បែកអ៊ីដ្រូសែន ។
- ❖ ១៩៥៣ សូវៀតក៏ផលិតបានគ្រាប់បែកអ៊ីដ្រូសែនដែរ។

**ខ-ការរត់ប្រណាំងផ្នែកអវកាស[495]**

- ❖ ១៩៥៧សូវៀតបានបង្ហោះផ្កាយរណបទី១របស់ខ្លួន ឈ្មោះ ស្ពុតនិក ទៅក្នុងទីអវកាសដោយជោគជ័យ។

---

[493] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា, *ឯកសារប្រវត្តិវិទ្យា សម្រាប់សាស្ត្រាចារ្យទុតិយភូមិ,* ដ.ឯ.ម., ទំព័រ៩០។

[494] -ដ- ទំព័រ៩១។

[495] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា, *ឯកសារប្រវត្តិវិទ្យា សម្រាប់សាស្ត្រាចារ្យទុតិយភូមិ,* ដ.ឯ.ម., ទំព័រ៩១-៩២។

- នៅឆ្នាំ១៩៦០អាម៉េរិកបានបង្កើតកម្មវិធីអវកាសលើកដំបូងរបស់ខ្លួនឈ្មោះ ណាសា
- ១៩៦១អ្នកអវកាសទី១ របស់សូវៀតឈ្មោះយូរីហ្គាការីន បានហោះចូលក្នុង លំហរ
- ១៩៦៩អ្នកអវកាសទី១របស់អាម៉េរិក ឈ្មោះលោកអាមស្ត្រង និងលោក អាល់ឌ្រីន បានចុះចតលើភពព្រះចន្ទ។

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៦៩ ម៉ោង ៩ និង៣២នាទីព្រឹក ម៉ោងនៅហ្វ្លរីដា សហរដ្ឋអាម៉េរិក (ត្រូវនឹងម៉ោង ១ និង៣២នាទីរសៀលម៉ោងសកល) រ៉ុកកែត Saturn V ត្រូវបានគេបាញ់បង្ហោះចេញពី Cape Canaveral...នៅពីលើរ៉ុកកែតនេះ គឺយានអវកាសនៃបេសកកម្មអាប៉ូឡូទី១១ ផ្ទុកអវកាសយានិកចំនួន៣រូប គឺ នៀល អាមស្ត្រង (Neil Armstrong) ជាមេបញ្ជាការ, ម៉ៃឃើល ខូលីនស៍ (Michael Collins) អ្នកបើកបរយានធំ (Command and Service Module) ដែលគេប្រសិទ្ធនាមឱ្យថា "Columbia" និង បើស អាល់ឌ្រីន (Buzz Aldrin) អ្នកបើកបរកូនយានសម្រាប់ចុះលើដីព្រះចន្ទ (Lunar Module) ដែលគេប្រសិទ្ធនាមឱ្យថា "Eagle"។២នាទី និង៤២វិនាទី ក្រោយពីត្រូវបាញ់ចេញពីដី កំណាត់ទី១ (First Stage) នៃរ៉ុកកែត Saturn V ត្រូវផ្ដាច់ចេញពីតួរ៉ុកកែត ហើយម៉ូទ័រនៃកំណាត់ទី២ (Second Stage) ក៏ចាប់ផ្ដើមដំណើរការបន្ត។ ៩នាទី និង៩វិនាទី កំណាត់ទី២ក៏បានផ្ដាច់ខ្លួនចេញដែរ ហើយកំណាត់ទី៣ (Third Stage) ជាអ្នកបន្តវេន នាំអាប៉ូឡូទី១១ ទៅដាក់ក្នុងគន្លងតារាវិថីជុំវិញភពផែនដី។

ក្រោយពីហោះបាន ២ម៉ោង និង ៤៤នាទី និងធ្វើដំណើរជុំវិញផែនដីបាន១ជុំកន្លះ កំណាត់ទី៣ នៃរ៉ុកកែត Saturn V ក៏បានចាប់ផ្ដើមបញ្ឆេះម៉ូទ័រឡើងសាជាថ្មីម្ដងទៀត ដើម្បីរុញយានអាប៉ូឡូទី១១ ឱ្យចេញពីគន្លងតារាវិថីនៃផែនដី ហើយធ្វើដំណើរសំដៅទៅកាន់ព្រះចន្ទ។ នៅថ្ងៃទី១៩ ខែកក្កដា ក្រោយពីបានចំណាយពេល ៣ថ្ងៃ ហោះកាត់ទីអវកាស ក្នុងចម្ងាយរហូតដល់ទៅជិត ៤០ម៉ឺនគីឡូម៉ែត្រ អាប៉ូឡូទី១១ ក៏បានធ្វើដំណើរមកដល់ព្រះចន្ទ ដោយពីដំបូងហោះហួសទៅដល់ខាងក្រោយព្រះចន្ទរួចហើយបន្ថយល្បឿន ដើម្បីអាចហោះចូលទៅក្នុងគន្លងតារាវិថីជុំវិញព្រះចន្ទ។ នៅថ្ងៃទី២០ ខែកក្កដា ក្រោយពីបានហោះជុំវិញព្រះចន្ទជាច្រើនជុំ រហូតអាចស្ថិតនៅក្នុងគន្លងតារាវិថីមួយដែលមានស្ថិរភាពទៅតាមការចង់បានរួចហើយ អវកាសយានិកពីររូប គឺ នៀល អាមស្ត្រង និងបើស អាល់ឌ្រីន ក៏បានចូលទៅក្នុង Lunar Module រួចហើយផ្ដាច់ខ្លួនចេញពីយានធំ សំដៅទៅចុះចតលើដីព្រះចន្ទ ចំណែកឯ ម៉ៃឃើល ខូលីនស៍ ស្ថិតនៅក្នុងយានធំ (Command and Service Module) ហោះចាំនៅខាងលើ ក្នុងតារាវិថីជុំវិញព្រះចន្ទ។

នៅម៉ោង ៨ និង១៧នាទីយប់ថ្ងៃទី២០កក្កដាម៉ោងសកល Lunar Module ក៏បានចុះចតដល់ដីព្រះចន្ទ នៅត្រង់តំបន់មួយ ដែលគេឱ្យឈ្មោះថា "Sea of Tranquility"។ ក្រោយពីបានសម្រាកនៅក្នុងយានប្រមាណជា ៣ម៉ោង អវកាសយានិកទាំង២រូបក៏បានចាប់ផ្ដើមរៀបចំខ្លួនចេញពីយាន ដោយ នៀល អាមស្ត្រង ជាអ្នកចេញមុន ចុះតាមជណ្ដើរយាន ហើយបានក្លាយជាមនុស្សដំបូងបង្អស់នៅក្នុងប្រវត្តិសាស្ត្រ ដែលបានឈានជើងជាន់លើដី ព្រះចន្ទ នៅម៉ោង ២ និង៥៦នាទីរំលងអធ្រាតឈាន

ចូលថ្ងៃទី២១កក្កដា។ លោក នៀល អាមស្រ្តង និងបើស អាល់ឌ្រីន បានចំណាយពេលនៅលើព្រះចន្ទ គិតជាសរុបចំនួន២១ម៉ោង និង ៣៦នាទី ដោយក្នុងនោះ មានមួយផ្នែកធំ គឺចំណាយពេលធ្វើការ និងសម្រាកនៅខាងក្នុងយាន ចំណែកឯជាង២ម៉ោងផ្សេងទៀត គឺធ្វើការនៅលើដីព្រះចន្ទ ដោយផ្ទាល់ ដើម្បីធ្វើពិសោធន៍ខាងវិទ្យាសាស្ត្រ ព្រមទាំងប្រមែប្រមូលយកថ្មព្រះចន្ទយក ត្រឡប់ទៅផែនដីវិញ ដើម្បីបន្តសិក្សាលម្អិតអំពីព្រះចន្ទ។ នៅម៉ោង៥ និង៥៤នាទីល្ងាចថ្ងៃទី២១ ខែកក្កដា នៀល អាមស្រ្តង និងបើស អាល់ឌ្រីន ក៏បានហោះចេញពីផ្ទៃដីព្រះចន្ទ ដោយប្រើផ្នែកខាងលើនៃកូនយាន Lunar Module។ តាមការពិត Lunar Module នេះ ត្រូវបានគេចែកចេញជាពីរផ្នែក គឺផ្នែកខាងក្រោម ដែលគេហៅថា "Descent Stage" ហើយដែលគេប្រើសម្រាប់ចុះចតលើព្រះចន្ទ និងក្រោយមកទៀតត្រូវប្រើជាទម្រ សម្រាប់បាញ់បង្ហោះផ្នែកខាងលើ ដែលគេហៅថា "Ascent Stage" ដើម្បីនាំអវកាសយានិក ចេញពីផ្ទៃដីព្រះចន្ទ ត្រឡប់ទៅកាន់យានធំវិញ ដែលកំពុងហោះនៅចាំខាងលើ ក្នុងគន្លងតារាវិថីជុំវិញព្រះចន្ទ។ ក្រោយពីបានហោះទៅតភ្ជាប់ជាមួយនឹងយានធំហើយ នៀល អាមស្រ្តង និងបើស អាល់ឌ្រីន បានផ្ទេរទៅកាន់យានធំរួចហើយ ផ្នែកចុងក្រោយនៃ Lunar Module នេះ ក៏ត្រូវបានគេផ្តាច់ចេញផងដែរ មុននឹងបញ្ឆេះម៉ូទ័រយានធំឱ្យចាកចេញពីគន្លងតារាវិថីជុំវិញ ព្រះចន្ទ ហោះសំដៅត្រឡប់មកកាន់ភពផែនដីវិញ ដោយត្រូវចំណាយពេល ៣ថ្ងៃ ដូចជាកាលពីពេលហោះពីផែនដីដែរ។ តាមការពិតទៅ យានធំ ឬ Command and Service Module នេះ ក៏ត្រូវគេចែកចេញជាពីរផងដែរ គឺ Service Module ដែលជាផ្នែកធំរាងជាស៊ីឡាំង ហើយដែលមានផ្ទុកប្រព័ន្ធម៉ាស៊ីនសម្រាប់ដំណើរការយាន និង Command Module ដែលជាផ្នែកតូចខាងមុខ ដែលមានរាង ជាសាជី ហើយដែលជាបន្ទប់បើកបរមានផ្ទុកអវកាសយានិកទាំង៣រូប។

នៅពេលដែលយានហោះជិតមកដល់ភពផែនដី Command Module និង Service Module ត្រូវបានគេផ្តាច់ចេញពីគ្នា ដោយទុកតែ Command Module មួយតែប៉ុណ្ណោះឱ្យហោះចុះមកផែនដី។ ក្រោយពីត្រូវបន្ថយល្បឿនដោយសារភាពកកិតនឹងបរិយាកាសភពផែនដីផង និងក្រោយមកទៀតដោយសារឆត្រយោងផង Command Module បានធ្លាក់ចុះទៅក្នុងមហាសមុទ្ទ ប៉ាស៊ីហ្វិក ដោយមាននាវាផ្ទុកយន្តហោះមួយគ្រឿងរបស់អាម៉េរិក នៅរង់ចាំជាស្រេចនៅក្បែរនោះ។

អវកាសយានិកទាំង ៣រូប នៃបេសកកម្ម អាប៉ូឡូទី១១បានវិលត្រឡប់មកដល់ផែនដីវិញដោយសុវត្ថិភាព ដោយនាំយកមកជាមួយនូវថ្មពីព្រះចន្ទប្រមាណជា ២២គីឡូក្រាម ដើម្បីទុកសិក្សា ក៏ប៉ុន្តែពួកគេក៏បានបន្សល់ទុកនូវរបស់ជាច្រើនផងដែរ នៅលើដីព្រះចន្ទ។ ក្រៅ ពីផ្នែកខាងក្រោមនៃកូនយាន Lunar Module គឺមានទង់ជាតិអាម៉េរិក , ថាសដែលមានចារនូវសាររបស់ប្រមុខដឹកនាំប្រទេសចំនួន ៧៣, ផ្លាកដែលមានហត្ថលេខារបស់ប្រធានាធិបតីអាម៉េរិក រីឆាដ និចសុន និងអវកាសយានិកអាប៉ូឡូទី ១១ទាំង៣រូប រួមជាមួយនឹងពាក្យដែលបង្ហាញថា មនុស្សជាតិបានមកចុះចតលើដីព្រះចន្ទក្នុងចេតនាសន្តិភាព ("Here men from the planet Earth first set foot upon the Moon. July 1969, A.D. We came in peace for all mankind.") ។

ក្រៅពីវត្ថុអនុស្សាវរីយ៍ផ្លូវការអស់ទាំងនេះ អវកាសយានិកអាប៉ូឡូទី១១ក៏បានបន្សល់ទុកនូវអនុស្សាវរីយ៍ជាលក្ខណៈផ្ទាល់ខ្លួនផងដែរ ដោយក្នុងនោះរួមមានស្លាកឈ្មោះអវកាសយានិកអាម៉េរិក ៣រូប ដែលត្រូវបាត់បង់ជីវិតនៅក្នុងបេសកកម្មអាប៉ូឡូទី១ (ឆ្នាំ១៩៦៧) និងជាពិសេសជាងនេះទៅទៀត នៀល អាមស្ត្រុង និងប៊ើស អាល់ឌ្រីន ក៏បានបន្សល់ទុកផងដែរនូវស្លាកឈ្មោះអវកាសយានិកសូវៀតពីររូប គឺ វ្ល៉ាឌីមៀរ កូម៉ារ៉ូវ (Vladimir Kormarov) ដែលបាត់បង់ជីវិតក្នុងបេសកកម្ម (ឆ្នាំ១៩៦៧) និង យូរី ហ្គាហ្គារីន (Yuri Gagarin) ដែលនៅតែជាប់ឈ្មោះថាជាមនុស្សដំបូងបង្អស់ ដែលបានហោះចេញទៅក្នុងទីអវកាស។

ការបន្សល់ទុកនូវស្លាកឈ្មោះអវកាសយានិកសូវៀត ដែលជាគូសត្រូវ នៅក្នុងពេលដែលសង្គ្រាមត្រជាក់កំពុងឆាបឆេះយ៉ាងសន្ធោសន្ធៅបែបនេះ គឺជាកាយវិការមួយបញ្ជាក់ថា សម្រាប់អវកាសយានិកអាប៉ូឡូ បើទោះបីជានៅលើដី មានការបែងចែកជាជាតិសាសន៍ ជាប្រទេស ដែលមានទៅដោយជម្លោះ និងការប្រជែងគ្នា ក៏ប៉ុន្តែ នៅក្នុងទីអវកាសវិញ ជោគជ័យនៅក្នុងការចុះចតលើដីព្រះចន្ទ វាគឺជាជោគជ័យរួមរបស់មនុស្សជាតិទាំងមូល។

### ៤.៣-ការលេចឡើងនូវវិបត្តិនានាដែលនាំពិភពលោកមកដល់សន្តិសហវិជ្ជមាន

### ក.បញ្ហាព្រែកជីកស៊ុយអេ

ព្រែកជីកស៊ុយអេ ស្ថិតនៅប្រទេសអេហ្ស៊ីប ជាប់នឹងសមុទ្រមេឌីទែរ៉ានេ ទៅសមុទ្រក្រហម។ ព្រែកជីកនេះនៅចន្លោះទីវាលរហោស្ថាននៃប្រទេសអារ៉ាប់ និងតំបន់ស៊ីណៃ(The Sinai Peninsula) ហើយមានតួនាទីមួយយ៉ាងសំខាន់នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មពិភពលោក។ គម្រោងសាងសង់ព្រែកជីកនេះ បានលើកឡើងដោយលោក **ហ្វែរឌីណង់ ដឺឡឺសេប** *(Ferdinand de Lesseps)* ហើយចាប់ផ្តើមពីថ្ងៃទី២៥ ខែមេសា ឆ្នាំ១៨៥៩ និងបានដាក់សម្ពោធឱ្យប្រើប្រាស់នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៨៦៩។ ប្រាក់ចំណាយទៅលើការសាងសង់មានចំនួន៤៣២,៨០៧,៨៨២ហ្វ្រង់។ ព្រែកជីកស៊ុយអេជាផ្លូវទឹកមួយដ៏សំខាន់ភ្ជាប់មហាសមុទ្រអាត្លង់ទិក និងមហាសមុទ្រឥណ្ឌា ហើយព្រែកជីកនេះមានអត្ថន័យសំខាន់ណាស់លើវិស័យដឹកជញ្ជូនទំនិញ នាវាចរណ៍ និងក្នុងវិស័យយុទ្ធសាស្ត្រ។ ព្រែកជីកនេះជាកន្លែងឆ្លងកាត់នាវាគ្រប់ប្រភេទ និងអាចជានាការចេញចូលនាវា ដែលមានចំណុះពី១៥០ ០០០តោនឡើងទៅ។ ព្រែកជីកនេះមានប្រវែង ១៦១គ.ម ជំរៅ ១៦.២ម ទទឹង ១២០ម។

ប្រឈមមុខទល់នឹងនយោបាយរបស់លោកណាស៊ែរ ដែលនយោបាយនេះ បានទទួលការលើកទឹកចិត្តពីសំណាក់សហភាពសូវៀត សហរដ្ឋអាម៉េរិកបានប្រើប្រាស់កតិកាសញ្ញាទីក្រុងបាដាតដើម្បីជាមធ្យោបាយទប់ទល់នឹងនយោបាយរបស់លោកណាស៊ែរ។ ប៉ុន្តែមានចំណុចមួយ ដែលទាក់ទងទៅនឹងបញ្ហាជំនួយរបស់សហរដ្ឋអាម៉េរិក គឺថាប្រទេសអេហ្ស៊ីបបានស្នើសុំជំនួយហិរញ្ញវត្ថុពីធនាគារពិភពលោក សម្រាប់យកមកកសាងទំនប់ទឹកនៅតំបន់ Aswan ក្នុងនោះក៏សុំពីសហរដ្ឋអាម៉េរិក និងប្រទេសអង់គ្លេសផងដែរ តែសំណើនេះត្រូវបានបដិសេធចោល។ ទាក់ទងទៅនឹងបញ្ហានេះ លោករដ្ឋ

មន្ត្រីការបរទេសសហរដ្ឋអាមេរិក បានប្រកាសឱ្យដឹងនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៦ ថាសហរដ្ឋអាមេរិក មិនយល់ព្រមក្នុងការផ្តល់ជំនួយទៅឱ្យប្រទេសអេហ្ស៊ីបឡើយ។

ការបដិសេធនេះ បានត្រូវធ្វើឡើងដោយផ្សារភ្ជាប់នឹងមូលហេតុពីរសំខាន់៖

- ទេសអេហ្ស៊ីប បានទទួលយល់ព្រមយកគ្រឿងសព្វាវុធទំនើបៗរបស់សហភាពសូវៀត និងរបស់ប្រទេសឆេកូស្លូវ៉ាគី ចូលមកក្នុងប្រទេសរបស់ខ្លួន។
- ដោយសារជំហររបស់លោកណាស៊ែរ នៅក្នុងសន្និសីទអន្តរជាតិ នៃចលនាមិនចូលបក្សសម្ព័ន្ធ ដែលលោកបានសហការ និងស្រុះស្រួលគ្នាជាមួយលោកទីតូ និងលោកនាយករដ្ឋមន្ត្រីឥណ្ឌានេរុ។

វិធានការរបស់សហរដ្ឋអាមេរិក បានជំរុញឱ្យលោកណាស៊ែរ ងាកទៅសុំជំនួយពីសូវៀត និងសម្រេចចិត្តអនុវត្តនយោបាយជាតូបនីយកម្មទៅលើព្រែកជីកស៊ុយអេ នៅថ្ងៃទី២៣ មិថុនា ១៩៥៦។ សេចក្តីសម្រេចនេះ ដំបូងបានប៉ះទង្គិចដល់ផលប្រយោជន៍របស់ប្រទេសបារាំង និងប្រទេសអង់គ្លេស ដែលជាញឹកញាប់ធ្វើសកម្មភាពនៅក្នុងព្រែកជីកនេះ។ ប្រការមួយទៀតគឺស្ថិតនៅក្នុងអនុសញ្ញា ឆ្នាំ ១៨៨៨ ស្តីពីព្រែកជីក ដែលចែងច្បាស់ថា ព្រែកជីកអាចបើកឱ្យប្រើប្រាស់ទាំងនៅក្នុងពេលមាន សន្តិភាព ក៏ដូចជាក្នុងពេលមានសង្គ្រាមដែរ ដើម្បីបម្រើដល់សេវាដឹកជញ្ជូននាវា បម្រើដល់ វិស័យពាណិជ្ជកម្ម ឬក៏សម្រាប់សកម្មភាពសឹកសង្គ្រាមដែរ។ ម្យ៉ាងទៀតការបិទព្រែកជីកស៊ុយអេ ក៏បានប៉ះពាល់ទៅលើការដឹកជញ្ជូនទំនិញតាមនាវា ទៅកាន់ប្រទេសអ៊ីស្រាអែល ដែលជាប្រទេស សម្ពន្ធមិត្តយ៉ាងជិតស្និទ្ធរបស់សហរដ្ឋអាមេរិកទៀតផង។

នៅយប់ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៥៦ កងទ័ពអ៊ីស្រាអែល ដោយឈ្លានពានទៅលើយុទ្ធសន្តិភាពរវាងប្រទេសអ៊ីស្រាអែល និងអេហ្ស៊ីប ដែលបានចុះហត្ថលេខា ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៤៩ បានបើកការវាយប្រហារទៅលើទឹកដីអេស៊ីប។ ថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៥៦ ប្រទេសអង់គ្លេស និងបារាំង ក៏បានបើកការវាយលុយទៅលើប្រទេសអេហ្ស៊ីប បង្កើតជាសង្គ្រាមមួយថ្មីទៀតនៅក្នុងតំបន់មជ្ឈិមបូព៌ាក្នុងដំណាក់នៃសង្គ្រាមត្រជាក់។ គោលបំណងរបស់ប្រទេសអង់គ្លេស និងបារាំង គឺធ្វើយ៉ាងណាឱ្យតំបន់ព្រែកជីក ស៊ុយអេ ស្ថិតនៅក្រោមការកាន់កាប់របស់ក្រុមហ៊ុនបរទេស។

នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៥៦ ប្រទេសបារាំង និងអង់គ្លេស បានប្រើសិទ្ធិវេតូ ជំទាស់ទៅនឹងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ដែលបានលើកឡើងតាមសំណើសហរដ្ឋអាមេរិក ឱ្យដកកងទ័ពអ៊ីស្រាអែលចេញពីខ្សែបន្ទាត់យុទ្ធសន្តិភាព។

នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៥៦ ក្នុងសភាពដ៏ធ្ងន់ធ្ងរបំផុតនោះ សហរដ្ឋអាមេរិក បានស្នើឱ្យមានការឈប់បាញ់គ្នាជាបន្ទាន់មួយ ហើយសេចក្តីសម្រេចនេះត្រូវបានបោះឆ្នោតអនុម័តដោយមានសំឡេងគាំទ្រ៦៤ និងសំឡេងប្រឆាំង ៥ (ប្រទេសអង់គ្លេស បារាំង អ៊ីស្រាអែល ប្រទេសអូស្ត្រាលី និងប្រទេសនូវែលសេឡង់) និងមានសំឡេងអនុប្បវាទចំនួន៦ (ក្នុងនោះមាន បែលស៊ិក និងកាណាដា)។ ប៉ុន្តែសេចក្តីសម្រេច និងការបោះឆ្នោតនៅក្នុងអង្គការសហប្រជាជាតិហាក់ដូចជាពុំបានរារាំងដល់កិច្ចប្រតិបត្តិ

ការយោធាអង់គ្លេស និងបារាំងឡើយ ហើយជាប្រការមួយ ដែលអាចឱ្យសហភាពសូវៀតលូកដៃចូលទៅក្នុងសង្គ្រាមក្នុងតំបន់នេះ។

នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៥៦ សហភាពសូវៀតបានប្រកាសឱ្យដឹងពីឱសានវាទមួយទៅកាន់ប្រទេសបារាំង អង់គ្លេស និងអ៊ីស្រាអែល។ លោកសេនាប្រមុខសូវៀត **ប៊ូលហ្គានីន** (Boulganine) បានបរិយាយថា ទង្វើរបស់ប្រទេសទាំងបីនេះ គឺជាសកម្មភាពឈ្លានពានមួយ ហើយលោកបានពោលពាក្យបញ្ឆិតបញ្ឆៀងទៀតថា ប្រសិនបើមិនបញ្ឈប់អំពើនេះទេ វាជាប្រការមួយដែលបើកលទ្ធភាពឱ្យសហភាពសូវៀត ប្រើប្រាស់នូវអាវុធទំនើបៗរបស់ខ្លួន ដើម្បីនឹងកម្ទេចកងទ័ពឈ្លានពានទាំងនោះ ពិសេសទៅទៀតសហភាពសូវៀត អាចនឹងប្រើកាំជ្រួចម៉ីស៊ីល ដើម្បីប្រឆាំងនឹងប្រទេសទាំងបីនេះ។

នៅក្នុងសហរដ្ឋអាមេរិក និងប្លុកសេរី ឱសានវាទរបស់សហភាពសូវៀត ផ្ញើទៅកាន់ប្រទេសទាំងបីនេះបានបង្កឡើងជាសេចក្តីភិតភ័យស្លន់ស្លោរមួយហើយក្នុងនោះ លោកប្រធានាធិបតីអាមេរិក លោក ហៃសិនហាវ៍ បានរៀបចំ និងចាត់ចែងកម្លាំងទ័ពបម្រុងជាស្រេចក្នុងលក្ខណៈប្រយ័ត្នប្រយែងបំផុត ហើយលោកបាននិយាយទូរស័ព្ទទៅកាន់លោករដ្ឋមន្ត្រីការបរទេសអង់គ្លេស **អង់តូនី អ៊ីដេន** ឱ្យបញ្ឈប់កិច្ចប្រតិបត្តិការយោធាជាបន្ទាន់។ ស្ថិតនៅចំពោះស្ថានភាពបែបនេះ នៅថ្ងៃទី៧ ខែវិច្ឆិកា ១៩៥៦ មហាសន្និបាទរបស់អង្គការសហប្រជាជាតិបានបោះឆ្នោតដោយសំឡេង៦៤គាំទ្រ និង១២អនុប្បវាទ ស្តីពីការបង្កើតឱ្យមានកងកម្លាំងអន្តរជាតិមួយរបស់អង្គការសហប្រជាជាតិ ដើម្បីយក ទៅឈរជើងជំនួសឱ្យកងទ័ពបារាំង និងអង់គ្លេស។ ជាលទ្ធផលប្រទេសអង់គ្លេស បារាំង ត្រូវបាក់មុខចំពោះដំណោះស្រាយនេះ។ ក្នុងពេលនោះគេមើលឃើញថា ទាំងអាមេរិក ទាំងសូវៀត ហាក់ដូចជាបានសម្រាលស្ថានការណ៍ដល់លោកប្រធានាធិបតីអេស៊ី លោកណាស៊ែរ។

សង្គ្រាមរវាងអេហ្ស៊ីប និងអ៊ីស្រាអែល បានធ្វើឱ្យជំនួយសហភាពសូវៀតហូរកាន់តែច្រើនមកក្នុងតំបន់នេះ ហើយសកម្មភាពជនកុម្មុយនីស្ត នៅក្នុងប្រទេសអេហ្ស៊ីប កាន់តែផុសផុលឡើងដែរ។ ទីបំផុតប្រទេសអេហ្ស៊ីប បានក្លាយទៅជាប្រទេសមួយ ដែលមានលក្ខណៈស្រដៀងគ្នាទៅតាមរបៀបរបបដឹកនាំ ប្រទេសកុម្មុយនីស្ត ដោយប្រកាន់យកការដឹកនាំគណបក្សតែមួយគឺសម្ពន្ធសង្គមនិយមអារ៉ាប់ដោយមានក្រុមប្រឹក្សាប្រជាជនមួយ ប្រមូលផ្តុំជាងពាក់កណ្តាល នៃចំនួនប្រជាពលករ កសិករ។

វិបត្តិព្រែកជីកស៊ុយអេ បានបំផ្លិចបំផ្លាញដល់ឫសគល់នូវលទ្ធិជាប្រពៃណីរបស់ប្រទេសបារាំង និងអង់គ្លេសនៅក្នុងតំបន់មជ្ឈិមបូព៌ា។ អន្តរាគមន៍ដោយយោធារបស់ប្រទេសទាំងពីរនេះ បានបង្ហាញឱ្យឃើញពីបំណងស្រោចស្រង់ ផលប្រយោជន៍ខាងសេដ្ឋកិច្ច និងយោធាក៏ដូចជាស្រោចស្រង់ លទ្ធិអាណានិគមនិយមរបស់ខ្លួននៅក្នុងតំបន់នេះដែរ។ ប៉ុន្តែផ្ទុយទៅវិញ អង់គ្លេស និងបារាំង ត្រូវបានបរាជ័យនៅក្នុងតំបន់មជ្ឈិមបូព៌ា។ ចំណែកឯលោក ណាស៊ែរវិញ បានក្លាយទៅជាជើងឯកសម្រាប់លទ្ធិជាតិនិយមអារ៉ាប់ និងជាជើងឯកខាងការបំបាក់នយោបាយអាណានិគមនិយម។ ចំពោះសូវៀតវិញឆ្លៀតឱកាសពីជម្លោះក្នុងតំបន់មជ្ឈិមបូព៌ា បានខិតខំធ្វើជាអ្នកការពារបណ្តាប្រទេសអារ៉ាប់ប្រឆាំងនឹងលទ្ធិចក្រពត្តិនិយម ហើយក៏បង្ហាញឱ្យសហគមន៍អន្តរជាតិមើលឃើញថា ក្រុងមូស្គូជាសម្ពន្ធមិត្តដ៏

សំខាន់មួយនៅក្នុងពិភពអារ៉ាប់ ហើយឥទ្ធិពលមិនមានតែចំពោះប្រទេសអេហ្ស៊ីបទេ តែក៏មានលើប្រទេសស៊ីរីផងដែរ[496]។

**ខ-វិបត្តិ នៅហុងគ្រី[497]**

នៅឆ្នាំ១៩៥៦ នៅទីក្រុង ប៊ុយ ដាបេស បានផ្ទុះឡើងនូវកុប្បកម្មមួយដើម្បីទាមទារសេរីភាពក្នុងការ ជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន។

ចលនានេះត្រូវបានសូវៀត ប្រើរថក្រោះបង្ក្រាបដើម្បីកុំឱ្យបណ្តាប្រទេសនៅអឺរ៉ុបខាងកើត ចាកចេញពី ពិភពកុម្មុយនីស្ត រីឯបណ្តាប្រទេសលោកខាងលិចវិញមិនបានចូលធ្វើអន្តរាគមឡើយ។

**គ-វិបត្តិនៅបែរឡាំង:[498]**

ដើម្បីបញ្ឈប់ការចាកចេញនៃប្រជាជនអាល្លឺម៉ង់ខាងកើតតាមក្រុងបែរឡាំងមក អាល្លឺម៉ង់ខាងលិចសហភាពសូវៀតបានស្ថាបនាជញ្ជាំងមួយខណ្ឌចែកក្រុងបែរឡាំងជាពីរផ្នែក។ ជញ្ជាំងនេះមានភាពរឹងមាំណាស់ ហើយមានប្រវែង ៤៣គ.ម ធ្វើពីបេតុង និងរាយលួសបន្លាយ៉ាងញឹក និងមានឆ្មាំការពារទាំងយប់ទាំងថ្ងៃ មិនអាចឆ្លងកាត់បានឡើយ។

ទោះបីជាពួកមហាអំណាចលោកខាងលិចមាន ការក្រេវក្រោធយ៉ាងណាក៏ដោយក៏គេមិនបានចូលធ្វើអន្តរាគមឡើយ ព្រោះខ្លាចផ្ទុះសង្គ្រាមនុយក្លេអ៊ែរ ។

**ឃ.វិបត្តិនៅគុយបា ឆ្នាំ១៩៦២**

ប្រទេសគុយបា គឺជាដែនកោះមួយ ដែលជាអតីតអាណានិគមរបស់ប្រទេសអេស្ប៉ាញ ហើយទទួលបានឯករាជ្យពីអេស្ប៉ាញនៅឆ្នាំ១៨៩៨។ នៅក្នុងពេលនោះប្រទេសគុយបា តែងតែទទួល ឥទ្ធិពលខាងវិស័យនយោបាយ និងសេដ្ឋកិច្ចពីសហរដ្ឋអាម៉េរិក ដូចជាមូលដ្ឋានដ៏សំខាន់មួយនៅ **ហ្គានតាណាម៉ូ(Guantanamo)**។ គុយបាជាប្រទេសមួយដែលក្រីក្រជាងគេនៅតំបន់អាម៉េរិកឡាទីន ប៉ុន្តែមក ដល់ឆ្នាំ១៩៥៩ សហរដ្ឋអាម៉េរិក បានដាក់ទុនវិនិយោគមកក្នុងប្រទេសនេះដល់ទៅមួយកោដិដុល្លារ អាម៉េរិកដោយសារប្រទេសគុយបា សម្បូរទៅដោយភោគផល និងធនធានកសិកម្ម។ នៅទីនេះពួកវិនិយោគទុនអាម៉េរិក បានកាន់កាប់ផលិតផលស្ករ ចំនួន៤០% និង៨០%នៃការនាំចេញ។ ជារួមអាចនិយាយបានថាមុនការបដិវត្តនៃប្រទេសគុយបា សហរដ្ឋអាម៉េរិកដើរតួនាទីធំណាស់ រហូតអ្នកការទូតអាម៉េរិកបង្ហើបឱ្យដឹងថា ឯកអគ្គរដ្ឋទូតអាម៉េរិក ប្រចាំនៅប្រទេសគុយបា មានអំណាចជាងប្រធានាធិបតី ប្រទេសគុយបាខ្លួនឯងទៅទៀត។ នៅមុនបដិវត្តន៍ ប្រទេសគុយបាជាប្រទេសមួយដែលស្ថិតនៅក្រោម ពាក់កណ្តាលអាណានិគមអាម៉េរិក។ ហេតុនេះហើយទើបបណ្តាលឱ្យផ្ទុះចេញជាចលនាកែទម្រង់ និងចលនា

[496] ខៀវ ថរិកា, *ប្រវត្តិនៃទំនាក់ទំនងអន្តរជាតិ ពីឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន*, ដ.ឯ.ម., ទំព័រ៩១។

[497] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា, *ឯកសារប្រវត្តិវិទ្យា សម្រាប់សាស្ត្រាចារ្យទុតិយភូមិ*, ដ.ឯ.ម., ទំព័រ៩៣។

[498] -ដ- ទំព័រ៩៣-៩៤។

ស្នេហាជាតិទាមទារឯករាជ្យពីសំណាក់ប្រជាពលរដ្ឋគុយបា ហើយក៏បានបង្កបង្កើតឱ្យមានជា លទ្ធិកាស្ត្រូនិយម ដែលមានប្រភពចេញមកពីគំនិតរបស់វិរៈបុរសទាមទារឯករាជ្យសញ្ជាតិគុយបា។

វិបត្តិនៅក្នុងប្រទេសគុយបា បានផ្ទុះឡើងដោយសារការប្រឈមមុខដាក់គ្នារវាងមហាអំណាចពីរ សហរដ្ឋអាម៉េរិក និងសូវៀត។ ប្រទេសគុយបាជាកម្រងកោះមួយនៃកម្រងកោះអង់ទីស្លិតនៅជិតសហរដ្ឋអាម៉េរិក។ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៩អ្នកកាន់អំណាចផ្តាច់ការ បាទីស្តា ដែលជាមិត្តរបស់អាម៉េរិកបានត្រូវផ្តួលរំលំដោយ ភីដែលកាស្ត្រូ។ នៅខែឧសភាឆ្នាំ១៩៥៩ លោកកាស្ត្រូ បានប្រកាសឱ្យដឹងពីការធ្វើកំណែទម្រង់ដីធ្លី ដែលប៉ះពាល់ដល់ដីធ្លីជាកម្មសិទ្ធិរបស់ក្រុមហ៊ុនអាម៉េរិក។ នៅខែកក្កដា ឆ្នាំ១៩៥៩ ប៉ូលិសគុយបា បានរកឃើញផែនការធ្វើរដ្ឋប្រហារមួយ ដែលរៀបចំឡើងដោយលោក ឌីយ៉ាស ឡង់(Diaz Lanz) ដែលជាមេបញ្ជាការ កងទ័ពគុយបា ហើយលោកក៏បានគេចខ្លួនទៅ អាម៉េរិក។ នៅខែសីហា ឆ្នាំ១៩៦០ លោកភីដែលកាស្ត្រូ បានធ្វើជាតូបនីយកម្មសហគ្រាស របស់សហរដ្ឋ អាម៉េរិក។ សហរដ្ឋអាម៉េរិកក៏បញ្ជាឱ្យធ្វើការហ៊ុមព័ទ្ធសេដ្ឋកិច្ចទៅលើគុយបា។ ពេលនោះ លោកភីដែលកាស្ត្រូត្រូវស្ថិតនៅ ក្នុងការបង្ខំចិត្តស្វែងរកសម្ពន្ធមិត្ត កុម្មុយនីស្ត ជាមួយសហភាពសូវៀត។ គុយបាជាបន្ទាកុម្មុយនីស្តក្នុងតំបន់ឥទ្ធិពលអាម៉េរិកមូលធននិយម។ លោកភីដែលកាស្ត្រូ និងមិត្តរបស់លោកគឺឆេគេវ៉ារ៉ា បានក្លាយជាគំរូមួយសម្រាប់អ្នកបដិវត្តន៍ប្រឆាំងនឹងអាម៉េរិក។ បរាជ័យនៃការឡើងគោករបស់ទ័ពអាម៉េរិក នៅឆកកូសុងបានពង្រឹងនូវកិត្យានុភាពរបស់គុយបា។




ប្រភព៖ Judy, L. and Dr Aron, P.(2017). Bi-Polarity & the Cold War: Hodder Education, ទំព័រ៩១

នៅថ្ងៃទី១ខែឧសភា ឆ្នាំ១៩៦១ លោកកាស្ត្រូ បានប្រកាសឱ្យដឹងថាប្រទេសរបស់លោកនឹងអនុម័តរដ្ឋធម្មនុញ្ញសង្គមនិយមនាពេលឆាប់ៗនេះ។ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៦១ លោកកាស្ត្រូតាមរយៈសន្ទរកថា របស់លោកបានប្រកាសឱ្យដឹងថាគណៈបក្សនេះនឹងប្រកាន់យកលិទ្ធិម៉ាក់លេនីននិមយ ទាំងស្រុង។ ដើម្បីសម្លុតប្រទេសគុយបា សហរដ្ឋអាម៉េរិកបានបង្កើតសកម្មភាពសមយុទ្ធយោធា នៅក្នុងតំបន់ការ៉ាអ៊ីបយ៉ាងខ្លាំងជាទីបំផុត។ នៅខែសីហា ឆ្នាំ១៩៦២ លោកគ្រុតឆេវ បានបញ្ជាឱ្យតាំងកាំជ្រួចសូវៀត នៅគុយបាដោយតម្រង់ទៅរកសហរដ្ឋអាម៉េរិក។ ជើងទ្រសម្រាប់បាញ់កាំជ្រួច បានត្រូវសង្កេតឃើញដោយយន្តហោះអាម៉េរិក។ វិបត្តិមីស៊ីលនៅក្នុងប្រទេសគុយបាគឺជាព្រឹត្តិការណ៍មួយដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រការទូត និងក្នុងទំនាក់ទំនងអន្តរជាតិសម័យកាលសង្គ្រាមត្រជាក់។

វិបត្តិនេះបានធ្វើឱ្យសហរដ្ឋអាម៉េរិក ប្រើប្រាស់នូវយុទ្ធវិធីការទូតតាមរយៈកម្លាំងយោធាផងនិង សម្បទានសន្តិភាពផង។ មិនតែប៉ុណ្ណោះវិបត្តិនេះបានធ្វើឱ្យមានសុពលភាពទៅដល់ យុទ្ធសាស្ត្រថ្មី របស់អ្នកដឹកនាំរបស់សហរដ្ឋអាម៉េរិក និងសូវៀត។

នៅចុងបញ្ចប់សហភាពសូវៀត បានយល់ព្រមដកមូលដ្ឋានតាំងកាំជ្រួចចេញពីគុយបាដូចនេះ វិបត្តិមីស៊ីលនេះត្រូវបានដោះស្រាយរួចរាល់នៅថ្ងៃទី២០ខែវិច្ឆកា ឆ្នាំ១៩៦២។

## ៥-ភាពធូរស្រាល ១៩៦៣-១៩៧៥

### ៥.១-ការចាប់ផ្តើមនៃភាពធូរស្រាល ១៩៦៣-១៩៦៨

ជាសម័យកាលកើតឡើងដោយចន្ទៈ នៃការចរចារវាងមហាអំណាចធំផុតលេខទាំងពីរ ដែល នៅពេលនោះ ពួកគេចង់ការពារផលប្រយោជន៍ជាតិរបស់ពួកគេ ក្នុងតំបន់រៀងខ្លួន ឱ្យបានល្អបំផុត តាម ដែលអាចធ្វើទៅបាន។

នៅបណ្តាប្រទេសអឺរ៉ុបខាងកើត និងប្រទេសចិន ក៏ដូចជាប្រទេសបារាំង និងបណ្តារប្រទេស នៅអាម៉េរិកឡាទីនដែរ មានប្រទេសខ្លះបានប្រានចោលនូវការត្រួតត្រារបស់អាម៉េរិក និងសូវៀត។

#### ៥.១.១-បុព្វហេតុ

- ការភ័យខ្លាចគ្រោះថ្នាក់ នៃមហន្តរាយនុយក្លេអ៊ែរ
- ប្រាក់ចំណាយលើសព្វាវុធយ៉ាងច្រើនសម្បើម
- មហាអំណាចទាំងពីរ ជួបការលំបាកផ្ទៃក្នុងជាច្រើន
- ការប្រណាំងប្រជែងរបស់ជប៉ុន និងអឺរ៉ុប
- ការអភិវឌ្ឍផ្នែកពាណិជ្ជកម្មអន្តរជាតិ
- ការលេចឡើងនៃតតិយលោក ហើយនិងការរីកចម្រើននៃគំនិត "មិនចូលបក្សសម្ពន្ធ" គឺមិនចូលខាងលិច និងមិនចូលខាងកើត។

#### ៥.១.២-លក្ខណៈពិសេស

មហាអំណាចទាំងពីរត្រូវបដិសេធគ្រប់អន្តរាគមន៍ផ្ទាល់ នៅក្នុងតំបន់ឥទ្ធិពលគូបដិបក្ខ។ មហា អំណាចទាំងពីរបានបែងចែកពិភពលោក។

ឧ.ទី១. នៅឆ្នាំ១៩៦៧ ពួកសូវៀតមិនធ្វើអន្តរាគមន៍ក្នុងសង្គ្រាម៦ថ្ងៃ ដើម្បីជួយសម្ពន្ធមិត្ត អេហ្ស៊ីប របស់គេ ប្រឆាំងនឹងអ៊ីស្រាអែល ដែលជាសម្ពន្ធមិត្តរបស់អាម៉េរិកឡើយ។

ឧទាហរណ៍ទី២ : នៅឆ្នាំ១៩៦៨ សហរដ្ឋអាម៉េរិកមិនធ្វើអន្តរាគម ក្នុងការលុកលុយចូល ប្រទេសឆេកូស្លូវ៉ាគី ដោយកងទ័ពកុម្មុយនីស្តនៃបក្សសម្ពន្ធវ៉ាសូវីឡើយហើយទុកឱ្យ«និទារដូវក្រុងប្រាក» ត្រូវបង្ក្រាប ថ្វីត្បិតតែមានចលនាសាធារណៈយ៉ាងទូលំទូលាយក៏ដោយ។

*នៅ ខែឧសភា ឆ្នាំ១៩៦៧ នៅក្នុងពេលដែលទំនាក់ទំនង រវាងអ៊ីស្រាអែល និងប្រទេសអារ៉ាប់ជិតខាងកំពុងតែស្ថិតក្នុងសភាពតានតឹងខ្លាំងស្រាប់អេហ្ស៊ីបបានទទួលព័ត៌មានខុសពីទីភ្នាក់ងារចោរកិច្ចសូវៀតថា អ៊ីស្រាអែលកំពុងប្រមូលកម្លាំងទ័ពយ៉ាងច្រើនសន្ធឹកសន្ធាប់ នៅក្បែរព្រំដែនស៊ីរី។ អេហ្ស៊ីប ដែលបានចុះសន្ធិសញ្ញាការពារជាតិជាមួយស៊ីរី ក៏បានប្រមូលកម្លាំងទ័ពឱ្យចូលមកក្បែរព្រំដែនអ៊ីស្រាអែល ព្រមទាំងបានបណ្ដេញកងកម្លាំងមួកខៀវរបស់អ.ស.បឱ្យចេញពីតំបន់ស៊ីណៃ និងហ្គាហ្សា។*

*នៅថ្ងៃទី៥ ខែមិថុនា សង្គ្រាមក៏បានផ្ទុះឡើង រវាងម្ខាងអ៊ីស្រាអែល និងម្ខាងទៀត អេហ្ស៊ីប ស៊ីរី និងហ្ស៊កដានី។ សង្គ្រាមអ៊ីស្រាអែល-អារ៉ាប់ លើកទី៣នេះមានរយៈពេលតែ ៦ថ្ងៃប៉ុណ្ណោះ។ ហេតុដូច្នេះហើយបានជាគេច្រើនហៅថា "សង្គ្រាម៦ថ្ងៃ"។ ជាថ្មីម្ដងទៀត គឺអ៊ីស្រាអែលជាអ្នកទទួលជោគជ័យ ដោយបានវាយដណ្ដើមកាន់កាប់ទឹកដីហ្គាហ្សា និង West Bank/Cisjordanie របស់ប៉ាឡេស្ទីន តំបន់ស៊ីណៃរបស់ អេហ្ស៊ីប និងតំបន់ខ្ពង់រាប Golan របស់ស៊ីរី។ និយាយជារួម អ៊ីស្រាអែលបានពង្រីកទឹកដីរបស់ខ្លួនមួយជាបី។ ក៏ប៉ុន្តែទឹកដីដែលអ៊ីស្រាអែលទើបនឹងដណ្ដើមកាន់កាប់ថ្មីនេះ មិនត្រូវបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិនោះទេ។ នៅថ្ងៃទី២២ វិច្ឆិកា ១៩៦៧ ក្រុមប្រឹក្សាសន្តិសុខអ.ស.បបានចេញសេចក្ដីសម្រេចមួយ (សេចក្ដីសម្រេចលេខ ២៤២) ទាមទារឱ្យអ៊ីស្រាអែលដកថយចេញពីដែនដី ដែលខ្លួនទើបនឹងដណ្ដើមកាន់កាប់ ក្នុងសង្គ្រាម ៦ថ្ងៃ ដោយវិលត្រឡប់ទៅកេបន្ទាត់ព្រំដែនចាស់ (បន្ទាត់បៃតង) ដែលកំណត់ដោយកិច្ចព្រមព្រៀងកាលពីឆ្នាំ១៩៤៩។ ជាថ្នូរមកវិញ ប្រទេសអារ៉ាប់ដែលជាប់ជម្លោះត្រូវចុះ សន្ធិសញ្ញាសន្តិភាពជាមួយនឹងអ៊ីស្រាអែល។*

### ៥.១.៣-ព្រឹត្តិការណ៍សំខាន់ៗនៃកិច្ចចរចា

ដើម្បីបង្កើតឱ្យមានទំនាក់ទំនងដោយផ្ទាល់រវាងអាម៉េរិក និងសូវៀត នៅថ្ងៃទី២០ ខែមិថុនាឆ្នាំ១៩៦៣ គេបានបង្កើតឧបករណ៍ទំនាក់ទំនងមួយដែលគេឱ្យឈ្មោះថា ទូរស័ព្ទក្រហម សម្រាប់ការចរចាដោយសម្ងាត់រវាងមេដឹកនាំទាំងពីរ។

នៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៦៣ មានការចុះហត្ថលេខាសន្ធិសញ្ញាក្រុងម៉ូស្គូ កិច្ចព្រមព្រៀងលើការបញ្ឈប់ការសាកល្បងនុយក្លេអ៊ែរ (បដិសេធដោយចិន និងបារាំង)។

ឆ្នាំ១៩៦៨ កិច្ចព្រមព្រៀងសាលទី១ ( Strategic Arms Limitation Talks =SALT I) លើការមិនធ្វើឱ្យរីកសាយអាវុធនុយក្លេអ៊ែរ។ កិច្ចព្រមព្រៀងសាល់ទី១ មានពីរផ្នែកសំខាន់ៗគឺ ៖ **ផ្នែកទី១** ហៅថាកិច្ចព្រមព្រៀងបណ្ដោះអាសន្ន **ផ្នែកទី២** ហៅថាសន្ធិសញ្ញា។ កិច្ចព្រមព្រៀងសាល់ទី១ នេះបានផ្ដោតទៅលើចំណុចសំខាន់ៗមួយចំនួន ដែលទាក់ទងទៅនឹងការកាត់បន្ថយគ្រឿងសព្វាវុធ ដូចជាការទប់ស្កាត់ និងបញ្ឈប់ការស្ថាបនាមូលដ្ឋានកាំជ្រួចមីស៊ីល ទាំងមីលស៊ីធុន ICMB ទាំងមីស៊ីលអន្តរទ្វីប និងប្រភេទមីស៊ីល SLBM។ (ICMB ជាប្រភេទកាំជ្រួចបាញ់បាន ចម្ងាយអន្តរទ្វីប បាញ់បានចម្ងាយ

ប្រវែងពី ៦៥០០ គីឡូម៉ែត្រ ទៅ ១២០០០ គីឡូម៉ែត្រដាក់តាំងនៅលើដី, SLBM ជាប្រភេទកាំជ្រួចផ្ទុកតាមនាវាមុជទឹក បាញ់បានចម្ងាយ៥០០ គ.ម ទៅ ៨០០០គ.ម)។

**សក្តានុពលយុទ្ធសាស្ត្ររវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត**[499]

| ឆ្នាំ | ICBM(USA) | SLBM(USA) | ICBM(URSS) | SLBM(URSS) |
|---|---|---|---|---|
| 1960 | 18 | 32 | 35 | - |
| 1965 | 854 | 496 | 270 | 120 |
| 1966 | 904 | 592 | 300 | 125 |
| 1967 | 1054 | 656 | 460 | 130 |
| 1968 | 1054 | 656 | 800 | 130 |
| 1969 | 1054 | 656 | 1050 | 160 |
| 1970 | 1054 | 656 | 1300 | 280 |
| 1971 | 1054 | 656 | 1510 | 440 |
| 1972 | 1054 | 656 | 1527 | 560 |
| 1973 | 1054 | 656 | 1527 | 628 |
| 1974 | 1054 | 656 | 1575 | 720 |
| 1975 | 1054 | 656 | 1618 | 784 |
| 1976 | 1054 | 656 | 1527 | 845 |
| 1977 | 1054 | 656 | 1477 | 909 |
| 1978 | 1054 | 656 | 1400 | 1015 |

## ៥.២-ការប្រឆាំងជំទាស់ផ្ទៃក្នុងប្លុក

### ៥.២.១-ប្លុកខាងកើត

**ប្រទេសចិន** ៖ ចាប់ពីឆ្នាំ១៩៦០ មកមានការប្រេះឆាទាំងស្រុង រវាងចិន និងសហភាពសូវៀត។ សាធារណរដ្ឋប្រជាមានិតចិន បដិសេធចុះហត្ថលេខាលើសន្ធិសញ្ញាក្រុងម៉ូស្គូ។ ប្រទេសចិនបដិសេធភាពធូរស្រាល ហើយបានសាកពិសោធគ្រាប់បែកបរមាណូរបស់ខ្លួននៅឆ្នាំ១៩៦៤។ ប្រទេសចិនទិតៀនចក្រពត្តិនិយមអាម៉េរិក និងសូវៀត។ ចិនចង់ដឹកនាំចលនាកុម្មុយនីស្តអន្តរជាតិ។ ចិនធ្វើសំណូមពរដល់ប្រទេសតតិយលោកឱ្យទទួលយកគំរូបែបម៉ៅនិយមដែលបង្កើតឡើងតាមរយៈបដិវត្តន៍វប្បធម៌ឆ្នាំ១៩៦៦។

**ការបះបោរនៅប្រទេសឆេកូស្លូវ៉ាគី ៖**

នៅឆ្នាំ១៩៦៨ លោកអាឡិចសង់ ឌុបសិក(Alexandre Dubcek) បានត្រូវជាប់ឆ្នោតជាមេដឹកនាំបក្សកុម្មុយនីស្តនៃប្រទេសឆេកូស្លូវ៉ាគី ។ លោកបានតវ៉ា នឹងរដ្ឋអំណាចសូវៀត ហើយចង់បាន

[499] ខៀវ ថវិកា, *ប្រវត្តិនៃទំនាក់ទំនងអន្តរជាតិ ពីឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន*, ដ.ឯ.ម., ទំព័រ១៨៣។

សេរីភាព និងសង្គមនិយម។ សហភាពសូវៀតខ្លាចមានការបះបោរបែបនេះ ឆ្លងរាលដាលទៅប្រទេសកុម្មុយនីស្តដទៃទៀត ក៏សាកល្បងធ្វើអន្តរាគមនៅខែសីហា ឆ្នាំ១៩៦៨។ រថក្រោះសូវៀតជាច្រើនបានចូលដល់ក្រុងប្រាក ហើយលោកឌុបសិក ត្រូវគេបង្ខំឱ្យចុះចេញពីតំណែង។ អន្តរាគមន៍របស់សហភាពសូវៀតនៅក្នុងប្រទេសឆេកូស្លូវ៉ាគី ឆ្លុះបញ្ចាំងឱ្យឃើញនូវវិបាកដូចខាងក្រោម៖

- អន្តរាគមន៍ គឺជាសញ្ញាមួយបង្ហាញដល់ប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើតកុំឱ្យយកគំរូតាមកំណែទម្រង់របស់មេដឹកនាំបក្សកុម្មុយនីស្តឆេកូស្លូវ៉ាគី
- ការកាច់បំបាក់ចលនានិទាឃរដូវនៃទីក្រុងប្រាក គឺជាទំនួលស្គាល់មួយនៃការអនុវត្តសកម្មភាពជាក់ស្តែងរបស់កតិកាវ៉ាសូវី នៅក្រោមរូបភាពអ្វីដែលហៅថា "ដើម្បីពង្រឹងកំពែង លទ្ធិសង្គមនិយម"។
- ជ័យជម្នះនេះជាជ័យជម្នះរបស់មេដឹកនាំសូវៀត ដែលបានប្រកាន់យកគំនិតប្រើកម្លាំងជាស្នូលរហូតដល់គេប្រសិទ្ធិនាមហៅថា ទ្រឹស្តីរបស់ប្រេសណេវ។
- អន្តរាគមន៍សូវៀតទៅក្នុងប្រទេសឆេកូស្លូវ៉ាគី ជាសញ្ញាមួយបង្ហាញឱ្យឃើញទៀតថាអធិបតេយ្យភាព របស់ប្រទេសសង្គមនិយមក្នុងប្លុកសូវៀត ត្រូវបានកំណត់រួចទៅហើយដោយក្រុងម៉ូស្គូ[500]។

### ៥.២.២-ប្លុកខាងលិច

**ប្រទេសបារាំង** ៖ នៅប្រទេសបារាំងលោកឧត្តមសេនីយ៍ដឺហ្គោល ចង់រំដោះប្រទេសខ្លួនឱ្យផុតពីឥទ្ធិពលអាម៉េរិក។ នៅឆ្នាំ១៩៦៤ ប្រទេសបារាំងបានផលិតអាវុធនុយក្លេអ៊ែរ។ នៅខែមីនាឆ្នាំ១៩៦៦ លោកដឺហ្គោលបានសម្រេចដកប្រទេសបារាំង ចេញពីបញ្ជាការ អូតង់ តែស្ថិតនៅក្នុងសម្ពន្ធភាពអាត្លង់តិកដដែល។ បារាំង បានទាមទារឱ្យយកមាសទៅជំនួសដុល្លារអាម៉េរិក ទុកដូចជាមូលដ្ឋានទូទាត់ហិរញ្ញវត្ថុ។ នៅឆ្នាំ១៩៦៦ លោកដឺហ្គោល បានថ្លែងនៅទីក្រុងភ្នំពេញសុំឱ្យអាម៉េរិកដកចេញពីឥណ្ឌូចិន។ នៅអឺរ៉ុប លោក ដឺហ្គោល សាកល្បងខិតចូលជិតម៉ូស្គូ និងធ្វើការសាកល្បងបញ្ឈប់អន្តរាគមន៍របស់សូវៀត ក្នុងប្រទេសឆេកូស្លូវ៉ាគី នៅឆ្នាំ១៩៦៨។ ថ្វីត្បិតតែគាត់មានបំណងប្រាថ្នាដូចនេះក៏ដោយ ក៏ប្រទេសបារាំង នៅតែស្ថិតក្នុងរង្វង់មូលធន និយម ដឹកនាំដោយ សហរដ្ឋអាម៉េរិកដដែល។

## ៥.៣-ដំណាក់កាលកំពូលនៃភាពធូរស្រាល (១៩៦៨-១៩៧៥)

មហាអំណាចទាំងពីរ បានបញ្ចៀសការប្រឈមមុខដាក់គ្នាដោយផ្ទាល់ ព្រោះខ្លាចផ្ទុះសង្គ្រាមនុយក្លេអ៊ែរ ដែលនឹងអាចធ្វើឱ្យវិនាស ពិភពលោកទាំងមូលបាន។ ទន្ទឹមនឹងនេះពួកគេទាំងពីរក៏បានចុះទន់ខ្សោយដែរ ដោយមានការធ្លាក់ចុះឥទ្ធិពលក្នុងប្លុកផ្ទាល់។

### ៥.៣.១-មហាអំណាចទាំងពីរ និងចិន

**ចិន និងសហភាពសូវៀត ៖**

[500] ខៀវ ថវិកា(១៩៩៧) **ប្រវត្តិនៃទំនាក់ទំនងអន្តរជាតិ ពីឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន** ភ្នំពេញ ទំព័រ១៧៦

នៅឆ្នាំ១៩៦៩ មានការប៉ះទង្គិចគ្នារវាងចិន និងសហភាពសូវៀត បានកើតឡើងនៅតាមបណ្តោយព្រំដែន។ ប្រទេសចិនបានចាត់ទុកសហភាពសូវៀត ដូចជា«សង្គមនិយមហ្វាស៊ីស» គ្រោះថ្នាក់ជាងចក្រពត្តិអាម៉េរិកទៅទៀត។

**ចិន និងសហរដ្ឋអាម៉េរិក ៖**

ការខិតចូលជិតគ្នារវាងចិនកុម្មុយនីស្ត និងអាម៉េរិក បង្កើតបានជាព្រឹត្តិការណ៍មួយដ៏សំខាន់ដែលស្តែងឡើងតាមរយៈសកម្មភាពដូចខាងក្រោម៖

- នៅឆ្នាំ១៩៧១ ទស្សនកិច្ចរបស់លោក គីស៊ីងគ័រ (Kissinger) រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាម៉េរិកនៅប៉េកាំង។
- នៅឆ្នាំ១៩៧១ ចិនកុម្មុយនីស្តចូលជាសមាជិក នៃអង្គការសហប្រជាជាតិ ជំនួសចិនជាតិនិយមតៃវ៉ាន់ និងចូលជាសមាជិកក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ។
- នៅឆ្នាំ១៩៧២ ការជួបគ្នារវាងលោក និច សុន (Nixon) និងលោកម៉ៅ សេទុង នៅប៉េកាំង។

### ៥.៣.២-កិច្ចព្រមព្រៀងសូវៀត អាម៉េរិក

កិច្ចព្រមព្រៀងរវាងអាម៉េរិក និងសូវៀត មានពីរចំណុចសំខាន់៖

- វិស័យយោធា ៖ ការព្រមព្រៀងលើការកាត់បន្ថយសព្វាវុធ
  - ឆ្នាំ១៩៦៨ សន្ធិសញ្ញា ហាមមានការរីកសាយអាវុធនុយក្លេអ៊ែរ
  - ឆ្នាំ១៩៦៨ កិច្ចព្រមព្រៀង SALT I
  - ឆ្នាំ១៩៧៣ ការបើកសន្និសីទ លើបញ្ហា សន្តិសុខ និងសហប្រតិបត្តិការក្នុងអឺរ៉ុប (CSCE) នៅ ហែលស៊ិនគី (HELSINKI)
- វិស័យសេដ្ឋកិច្ច ១៩៧២៖ ការលក់ស្រូវឱ្យសូវៀត និងកិច្ចសហប្រតិបត្តិការ

## ៦-សង្គ្រាមត្រជាក់ល្មម ១៩៧៥-១៩៨៥

ក្នុងរយៈកាលនេះមានភាពតានតឹងជាថ្មីទៀត រវាងសហរដ្ឋអាម៉េរិក និងសហភាពសូវៀត។ លោកប្រេសណេវ អ្នកដឹកនាំសហភាពសូវៀតបាននិយាយពីសង្គ្រាមត្រជាក់ល្មមនេះ។ វិបត្តិប្រេងកាត និងវិបត្តិសេដ្ឋកិច្ច បានប៉ះពាល់ដល់ពិភពបស្ចិមប្រទេស។ ចាប់ពីឆ្នាំ១៩៧៩ មក ភាពតានតឹងបានកើត មានជាថ្មីទៀត (បដិវត្ត អៀរ៉ង់ ការលុកលុយប្រទេសអាហ្វហ្គានីស្ថានដោយសហភាពសូវៀត)។

### ៦.១-ការដកថយរបស់អាម៉េរិក

សហរដ្ឋអាម៉េរិក បានចាញ់សង្គ្រាមនៅវៀតណាម ពលទាហានជាច្រើនត្រូវបានស្លាប់។ បាតុកម្មធំៗជាច្រើនប្រឆាំងនឹងអន្តរាគមអាម៉េរិកនៅវៀតណាម បានកើតឡើងនៅសហរដ្ឋអាម៉េរិក។ មេដឹកនាំសហរដ្ឋអាម៉េរិក បានលើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្ស។ នៅមជ្ឈិមបូព៌ា លោក ជីមី កាទ័រ (Jimmy Carter) លើកទឹកចិត្តដល់កិច្ចចរចា សន្តិភាពរវាង អេហ្ស៊ីបនិងអ៊ីស្រាអែល (សាដាត និង បេគីន

: Sadate និង Bégin) ដែលនាំទៅដល់កិច្ចព្រមព្រៀង «កំដាវីត» (Camp David) នៅឆ្នាំ១៩៧៨។ ពួកអ៊ីស្រាអែល បានយល់ព្រមប្រគល់តំបន់ ស៊ីណាអ៊ី ឱ្យអេហ្ស៊ីបវិញ ។

### ៦.២-ការរុលទៅមុខរបស់សហភាពសូវៀត

នៅពេលដែលការចរចាកំពុងតែប្រព្រឹត្តទៅ សហភាពសូវៀតក៏ចេះតែបន្តការពង្រីកឥទ្ធិពលរបស់ខ្លួននៅក្នុងពិភពលោកផងដែរ។

#### ៦.២.១-ការពង្រីកឥទ្ធិពលសូវៀតនៅអាស៊ី

នៅឆ្នាំ១៩៧៥ ប្រទេសវៀតណាម ត្រូវបង្រួបបង្រួម ហើយបានចុះហត្ថលេខាលើសន្ធិសញ្ញាសម្ពន្ធភាពជាមួយសហភាពសូវៀត។ ការលំបាកខាងវិស័យសេដ្ឋកិច្ច បានកើតមានឡើង ហើយប្រជាជនវៀតណាមខាងត្បូងជាច្រើនបានភៀសខ្លួនតាមទូកចេញពីវៀតណាមកុម្មុយនីស្ត។

នៅឆ្នាំ១៩៧៥ ប្រទេសឡាវក៏បានក្លាយជាប្រទេសកុម្មុយនីស្តផងដែរ។ ចំណែកនៅកម្ពុជា នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហម ដឹកនាំដោយប៉ុល ពត បានកាន់កាប់ទីក្រុងភ្នំពេញ។

ដោយសារមានការគាំទ្រពី សហភាពសូវៀត ប្រទេសវៀតណាមបានចូលធ្វើអន្តរាគម នៅប្រទេសកម្ពុជា ដែលធ្វើឱ្យរបបខ្មែរក្រហមត្រូវដួលរលំនៅឆ្នាំ១៩៧៩ ប៉ុន្តែពួកនេះបានបន្តការប្រយុទ្ធដោយទទួលជំនួយពីចិន។

នៅខែធ្នូឆ្នាំ១៩៧៩ សហភាពសូវៀតបានលើកទ័ពចូលលុកលុយ ប្រទេសអាហ្វហ្គានីស្ថាន ដើម្បីជួយដល់ជនកុម្មុយនីស្ត គឺលោក បាប្រាគ ការម៉ាល់។ ការបញ្ជូនកងទ័ពសូវៀតទៅកាន់ប្រទេសអាហ្វហ្គានីស្ថាន មានគោលដៅសំខាន់ពីរយ៉ាងគឺ៖

- ជាការអនុវត្តនូវទ្រឹស្តីយោធារបស់លោក លេអូនីដ ប្រេសណេវ និងដើម្បីបំពេញឱ្យទ្រឹស្តីមនោគមវិជ្ជា នៃលទ្ធិកុម្មុយនីស្តនិយម ដែលគេហៅថា "សាមគ្គីភាព វណ្ណៈអធន " ដែលធ្លាប់យកមកអនុវត្តជាច្រើនលើកច្រើនគ្រាមកហើយ នៅក្នុងប្លុកសង្គមនិយម។
- ជំហររបស់សហភាពសូវៀតនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន គឺដើម្បីឈោងឆ្ពោះទៅរកសកម្មភាពជាយុទ្ធសាស្ត្រមួយនៅក្នុងតំបន់ឈូងសមុទ្រពៃក្ស ដែលនៅតំបន់នោះមានសម្ពន្ធមិត្តរបស់សហរដ្ឋអាម៉េរិកគឺប្រទេសប៉ាគីស្ថាន និងប្រទេសអ៊ីរ៉ង់ ដែលកំពុងតែផ្ទុះ បដិវត្តន៍[501]។

វត្តមានរបស់កងទ័ពសូវៀតនៅអាហ្វហ្គានីស្ថាន ត្រូវបានសហគមន៍អន្តរជាតិ ចាត់ទុកជាអំពើឈ្លានពានមួយ ។ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨០ បញ្ហាប្រទេសអាហ្វហ្គានីស្ថាន ត្រូវបានសហគមន៍អន្តរជាតិយកមកពិភាក្សានៅក្នុងរបៀបវារៈ សម័យប្រជុំពេញអង្គរបស់អង្គការសហប្រជាជាតិ។ ការបោះឆ្នោតមួយត្រូវបានប្រព្រឹត្តឡើង ដើម្បីសម្រេចឱ្យកងទ័ពសូវៀតដកចេញពីអាហ្វហ្គានីស្ថាន លទ្ធផលគឺ១០៤ សំឡេងគាំទ្រ និង១៨សំឡេង ប្រឆាំង។

[501] ខៀវ ថវិកា, ប្រវត្តិនៃទំនាក់ទំនងអន្តរជាតិ ពីឆ្នាំ១៩៤៥ ដល់*បច្ចុប្បន្ន*, ដ.ឯ.ម., ទំព័រ២៣៥។

ព្រឹត្តិការណ៍នេះដែរ បានធ្វើឱ្យចលនាតស៊ូប្រឆាំងរីកដុះដាលនៅទូទាំងប្រទេស គួបផ្សំនិងគំនិតជាតិនិយម។ នៅក្នុងសង្គ្រាមឈ្លបរបស់អ្នកតស៊ូអាហ្វហ្គានីស្ថាន មានប្រទេសពីរដែលជួយឧបត្ថម្ភគាំទ្រដល់ចលនានេះគឺ ប្រទេសចិន និងសហរដ្ឋអាម៉េរិក។ ចំណែកឯប្រទេសប៉ាគីស្ថាន បានធ្វើជាមជ្ឈមណ្ឌលនៃជនភៀសខ្លួនអាហ្វហ្គានីស្ថានចំនួន៣០០ ០០០ នាក់ ដែលរត់គេចចេញពីរបបស្និទ្ធនឹងសូវៀត របស់លោកបាប្រាគ ការម៉ាល់។

## ៦.២.២-ការពង្រីកឥទ្ធិពលរបស់សូវៀតនៅអាហ្វ្រិក

ឆ្លៀតឱកាសពេលសង្គ្រាមក្នុងស្រុកនៅអាហ្វ្រិក សហភាពសូវៀតបានសាកល្បងតាំងឥទ្ធិពលរបស់ខ្លួន នៅលើទ្វីបនេះ។ ឧទាហរណ៍៖

- នៅអង់ហ្គោឡា សង្គ្រាមរំដោះជាតិចុងក្រោយត្រូវបានគាំទ្រ ដោយសហភាពសូវៀត
- នៅស៊ីមបាវេ ការឡើងកាន់អំណាចរបស់អ្នកម៉ាកនិយមឈ្មោះ មូកាបេ(Mugabé) ជាការជួយឧបត្ថម្ភរបស់សហភាពសូវៀត
- នៅអេត្យូពី ព្រះចៅអធិរាជ ហៃឡេ សេឡាស៊ីយេ (Haile Selassie) បានត្រូវផ្តួលរំលំដោយអ្នកម៉ាកនិយមម្នាក់ឈ្មោះ មេនស៊ីស្ទូ(Mengistu)
- នៅលីប៊ី លោក កាដាភី (Khadafi) ជាសម្ពន្ធមិត្តរបស់សូវៀត[502]។

## ៦.៣-លោករ៉ូណាល់ រីគែន(Ronald W. Reagan)ការវិលត្រឡប់របស់អាម៉េរិក

សហរដ្ឋអាម៉េរិកយល់ឃើញថា ភាពធូរស្រាលគ្រាន់តែជាឧបាយកលមួយប៉ុណ្ណោះ ព្រោះថាសហភាពសូវៀតឆ្លៀតឱកាសជានិច្ច ពីភាពធូរស្រាលជាមួយសហរដ្ឋអាម៉េរិក ដើម្បីពង្រីកមនោគមវិជ្ជាកុម្មុយនីស្ត ក្នុងពិភពលោក។ ពីឆ្នាំ ១៩៧៥ ដល់១៩៧៩ មនុស្សប្រហែល១០០លាននាក់បានធ្លាក់ចូលក្រោមឥទ្ធិពលសហភាពសូវៀត( នៅអាស៊ី អាម៉េរិកឡាទីន អាហ្វ្រិក)។

នៅឆ្នាំ១៩៨០ អាម៉េរិក ធ្វើពហិការ គឺមិនចូលរួមប្រកួតក្នុងកីឡាអូឡាំពិកនៅទីក្រុងម៉ូស្គូ។ នៅឆ្នាំ១៩៨០ នេះផងដែរសហរដ្ឋអាម៉េរិកបានបដិសេធការលក់គ្រាប់ធញ្ញជាតិ ឱ្យសហភាពសូវៀត។

នៅឆ្នាំ១៩៨១ លោក រីគែន បានសម្រេចអនុវត្តនយោបាយយ៉ាងម៉ឺងម៉ាត់បំផុត ប្រឆាំងនឹងសហភាពសូវៀត ដែលហៅថា "ចក្រភពបិសាច" (Axe of Evil) រាប់បញ្ចូលទាំងប្រទេសមួយចំនួន ដូចជាគុយបា និងអ៊ីរ៉ង់ជាដើម។ លោក រីគែន បានរៀបចំគម្រោងបង្កើតប្រព័ន្ធសង្គ្រាមផ្កាយ ប្រឆាំងនឹងគូបដិបក្ខ ដោយចំណាយថវិកាច្រើនឥតគណនា ព្រោះជាការទាមទារបច្ចេកវិទ្យាខ្ពស់បំផុត។ លោក រីគែន បានដាក់ពង្រាយកាំជ្រួចធុន ភើស៊ីង II លើទ្វីបអឺរ៉ុបដើម្បីប្រឆាំងនឹងកាំជ្រួចធុនទំនើប អេស អេស ២០ (SS 20) របស់សហភាពសូវៀត។ កងទ័ពរបស់សហរដ្ឋអាម៉េរិក បានបើកការវាយប្រហារឡើងកោះគ្រើណាដ ដែលគាំទ្រដោយគុយបា ក្នុងការបង្ហាញពីជំហរ របស់អាម៉េរិកតាមរយៈកម្លាំងយោធា[503]។

**វិបត្តិកាំជ្រួចមីស៊ីល នៅអឺរ៉ុប៖**

---

[502] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា, *ឯកសារប្រវត្តិវិទ្យា សម្រាប់សាស្ត្រាចារ្យទុតិយភូមិ,* ដ.ឯ.ម., ទំព័រ១១៤។

.[503],ក្រសួងអប់រំ យុវជន និងកីឡា, *ប្រវត្តិវិទ្យាថ្នាក់ទី១២,* គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, ឆ្នាំ២០១៥, ទំព័រ១០។

កាំជ្រួចមីស៊ីល អឺរ៉ុប គឺជាមីស៊ីល ដែលបាញ់បានរយៈខ្លី និងរយៈមធ្យម ស្ថិតនៅក្នុងទ្វីបអឺរ៉ុប ដាក់តាំងដោយមហាអំណាចទាំងពីរ (សហរដ្ឋអាម៉េរិក និងសូវៀត)។ នៅឆ្នាំ១៩៧៧ ប្រទេសអាល្លឺម៉ង់ខាងលិច បរិហារអំពីវត្តមានកាំជ្រួចថ្មីៗ របស់សូវៀត SS 20 នៅអឺរ៉ុបខាងកើត។ ប្រទេសអាល្លឺម៉ង់ខាងលិច យល់ថានេះជាការគំរាមកំហែងមួយ។ នៅឆ្នាំ១៩៨៣ សហរដ្ឋអាម៉េរិក បានតាំងកាំជ្រួច ភឺស៊ីង II នៅបណ្តាប្រទេសអឺរ៉ុបខាងលិច លើកលែងតែប្រទេសបារាំងដែលអាចបាញ់ដល់សហភាពសូវៀត។ នៅប្រទេសអាល្លឺម៉ង់ខាងលិច បាតុកម្មបានផ្ទុះឡើង ដើម្បីប្រឆាំងនឹងការតាំងកាំជ្រួចភឺស៊ីងនេះ។

នៅឆ្នាំ១៩៨៣ លោក រីគេន បានប្រកាសគម្រោងសង្គ្រាមផ្កាយ ៖ គឺការប្រើប្រាស់តារាវណប ក្នុងអវកាស ដើម្បីបង្វែមីស៊ីល។ គម្រោងនេះត្រូវចំណាយថវិកា យ៉ាងច្រើនសន្ធឹកសន្ធាប់ សហភាពសូវៀត មិនអាចធ្វើតាមសហរដ្ឋអាម៉េរិកបានទេ រីឯសហរដ្ឋអាម៉េរិកវិញ ក៏បានបោះបង់គម្រោងនេះចោលដែរ។ នេះជាការអនុវត្ត ជាបន្តទៅទៀតនូវការរត់ប្រណាំងសព្វាវុធ។ ប៉ុន្តែមហាអំណាចទាំងពីរ ត្រូវ ប្រឈមមុខនឹងបញ្ហាសេដ្ឋកិច្ច និងបញ្ហានៅក្នុងតំបន់របស់គេរៀងៗខ្លួន[504]។

## ៧-ទីបញ្ចប់នៃសង្គ្រាមត្រជាក់ និងការរលំរលាយនៃប្លុកសូវៀត

### ៧.១-នយោបាយកំណែទម្រង់របស់ហ្គោបាឆូវ

មកដល់ឆ្នាំ១៩៨៥ ពិភពលោកបានឈានចូលទៅដល់របត់ថ្មីមួយដែលគេបានកំណត់ថា សង្គ្រាមត្រជាក់ ហាក់ដូចជាឈានទៅរកទីបញ្ចប់ហើយ។ ជម្លោះនៅតាមតំបន់មួយចំនួនត្រូវបាន ដោះស្រាយ រួចឈានឆ្ពោះទៅរក មាគ៌ាលទ្ធិប្រជាធិបតេយ្យសម្រាប់ការសាងសង់ប្រទេសវិញ។ ទឹកដី អាល្លឺម៉ង់ដែលពុះបំបែកជាពីរចាប់តាំងពីក្រោយសង្គ្រាមលោកលើកទី២ ត្រូវបានបង្រួបបង្រួមគ្នាវិញ ជញ្ជាំងបែរឡាំងត្រូវរំលាយ កងទ័ពសូវៀត បានដកចេញពីប្រទេសអាហ្វហ្គានីស្ថាន សង្គ្រាមរវាងអ៊ីរ៉ាក់ អ៊ីរ៉ង់ បានបញ្ចប់ កងទ័ពវៀតណាមបានដកចេញពីប្រទេសកម្ពុជា ប្រទេសអាហ្វ្រិកខាងត្បូងបានប្រគល់ឯករាជ្យទៅឱ្យទឹកដីណាមីប៊ី។ នៅក្នុងវិស័យនុយក្លេអ៊ែរ ដោយអនុវត្តតាម សន្ធិសញ្ញាមិនរីកសាយអាវុធនុយក្លេអ៊ែរ មហាអំណាចបានជួបប្រជុំ ចរចាធ្វើការកាត់បន្ថយបរិមាណអាវុធបរមាណូ ដែលជាហេតុធ្វើឱ្យទំនាក់ទំនងរវាងលោកខាងលិច និងខាងកើតបានត្រូវកែលម្អឡើង[505]។

សភាពការណ៍អូសបន្លាយរហូតដល់ទសវត្សរ៍ឆ្នាំ១៩៧០ និង១៩៨០ វិបត្តិនៅសូវៀតបានឡើងដល់កម្រិតមួយខ្ពស់ ដែលលេចធ្លោជាងគេបំផុត គឺវិស័យកសិកម្មរបស់សូវៀត ជួបវិបត្តិដែលគួរឱ្យបារម្ភណ៍ជាទីបំផុត ដោយការខ្វះស្បៀង ពុំមានស្រូវសាឡី ខ្វះសាច់ ទឹកដោះ។ល។ ក្នុងបណ្តាឆ្នាំ១៩៦៥-១៩៦៧ និង១៩៧៥ ជាឆ្នាំដែលវិបត្តិកសិកម្មមានភាពធ្ងន់ធ្ងរបំផុត ដែលសូវៀតផលិតពុំបានអ្វីទាំងអស់។ ជារួមរាល់ឆ្នាំក្នុងសម័យកាលក្រោមការដឹកនាំរបស់ Brezhnev និង Andropov សូវៀតត្រូវចំណាយថវិកា ប្រមាណ៨កោដិដុល្លារអាម៉េរិក ដើម្បី ទិញស្រូវសាឡីពីអាម៉េរិក និងកាណាដា។ ពាក្យស្លោករបស់សង្គមនិយម ដែលតែងតែអះអាងថា "**សង្គមនិយមដាច់ខាតនឹងយក**

[504] សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា, *ឯកសារប្រវត្តិវិទ្យា សម្រាប់សាស្ត្រាចារ្យទុតិយភូមិ*, ដ.ឯ.ម., ទំព័រ១១៨។
[505] ខៀវ ថវិកា, *ប្រវត្តិនៃទំនាក់ទំនងអន្តរជាតិ ពីឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន*, ដ.ឯ.ម., ទំព័រ២៣៧។

**ឈ្នះលើមូលធននិយមដោយទិន្នផលពលកម្មក្នុងរបបសង្គមនិយម មានកម្រិតខ្ពស់ជាងរបបមូលធននិយម**" បានក្លាយទៅជាពាក្យស្លោក ដែលគ្មានន័យអ្វីទាំងអស់ទៅវិញ[506]។

ជាការពិតទឹកដីសហភាពសូវៀត មានវិសាលភាពដ៏មហិមា សំបូរទៅដោយសម្បត្តិធម្មជាតិ មានគ្រប់លក្ខណសម្បត្តិ ក្នុងការផ្តល់ផាសុកភាពឱ្យប្រជាពលរដ្ឋរបស់ខ្លួនបានយ៉ាងសមរម្យបំផុត។ ក៏ប៉ុន្តែដោយមាន របបនយោបាយកុម្មុយនីស្ត គួបផ្សំនឹងមហិច្ឆតានៅក្រោមរូបភាពជា «**កាតព្វកិច្ចអន្តរជាតិ**» «**លទ្ធិអធនអន្តរជាតិ**» និង «**ការគាំទ្រដល់ចលនាដំណើរការបដិវត្តន៍ពិភពលោក**» ផង បានធ្វើឱ្យសហភាពសូវៀត ជួបប្រទះទៅនឹងហេតុការណ៍ អកុសលខ្វះស្បៀងទាំងនេះ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ក្នុងចលនាកុម្មុយនីស្តអន្តរជាតិ មានបក្សកុម្មុយនីស្ត បក្សពលករ បក្សជាតិនិយម ដែលមាននិន្នាការសង្គមនិយមទាំងអស់ជាង ១៨០បក្ស។ ក្នុងនោះមានប្រទេស ដែលហៅថាសង្គមនិយម ឬមាននិន្នាការសង្គមនិយមនៅអឺរ៉ុប អាម៉េរិកឡាទីន អាស៊ី អាហ្វ្រិក ទាំងអស់២៤ ប្រទេស ដែលមានប្រជាជនសរុបប្រមាណ ១៧៨៣លាននាក់។ ប្រទេសសង្គមនិយមទាំងនេះទទួលបានជំនួយយ៉ាងសន្ធឹកសន្ធាប់ពីសហភាពសូវៀត។ ជំនួយដ៏សន្ធឹកសន្ធាប់នេះជាបច្ច័យដ៏ចម្បងមួយក្នុងការរួមចំណែកជំរុញសូវៀតឱ្យ ឆ្ពោះទៅកាន់ការរលំរលាយបានឆាប់ផងដែរ។

ប្រការមួយទៀត និងមានភាពធ្ងន់ធ្ងរក្នុងការរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចសូវៀតកាន់តែជួបវិបត្តិធ្ងន់ធ្ងរ ក្រោមការដឹកនាំរបស់ Brezhnev គឺមហិច្ឆតាចង់បានឧត្តមភាពខាងអាវុធយុទ្ធសាស្ត្រ ដោយការរត់ប្រណាំងសព្វាវុធជាមួយអាម៉េរិក អឺរ៉ុបខាងលិច ដែលចុងក្រោយនាំឱ្យសូវៀតរឹងស្ងួត និងធ្លាក់ចុះដោយឯងៗ។

នៅឆ្នាំ១៩៨៥ លោក មីខាអ៊ីល ហ្គោបាឆូវ (Mikhail Gorbachev) ឡើងកាន់តំណែងជាអគ្គលេខាបក្ស កុម្មុយនីស្ត បន្ទាប់ពីមរណភាពរបស់ Brezhnev , Andropov និង Chernenko។ ហ្គោបាឆូវ ធ្លាប់ស្ថិតនៅក្នុងជួរដឹកនាំរបស់បក្សកុម្មុយនីស្តសូវៀត ទើបគាត់យល់ច្បាស់អំពីការលំបាក និងភាពប្រឈមរបស់បក្សកុម្មុយនីស្ត ដែលកំពុងតទល់ នៅពេលនោះ។ ដើម្បីជម្នះឱ្យបាននូវផលវិបាកទាំងនោះ ហ្គោបាឆូវ បានដាក់ចេញនូវគោលនយោបាយពីរគឺ "Perestroika"(កែទម្រង់) និង "Glasnost"(តម្លាភាព)ឈានដល់ការបំបាត់ឫសគល់នៃវិបត្តិ និងស្តារប្រទេស និងសង្គមសូវៀតឡើងវិញ។ ការងារបរទេសក្នុងសម័យកំណែទម្រង់ គឺធ្វើយ៉ាងណាដើម្បីឆ្លងកាត់នូវដំណាក់កាលលំបាកដ៏ធ្ងន់ធ្ងរ របស់ប្រទេសជាតិ ហ្គោបាឆូវ យល់ឃើញថា មានតែនយោបាយការបរទេសសម្របសម្រួលមានភាពធូរស្រាលជាមួយ មហាអំណាចលើពិភពលោក ដែលជាហេតុមួយនាំដល់ការបន្ថយដល់ការរត់ប្រណាំងរបស់សូវៀត ធ្វើឱ្យប្រទេស ទាំងនេះមានជំនឿមកលើសូវៀត ដើម្បីផ្តល់វិញនូវឥណទាន ហើយយកឥណទានទាំងនោះមកដោះស្រាយបញ្ហា សេដ្ឋកិច្ចចំពោះមុខ។ ក្នុងការកាន់អំណាច ហ្គោបាឆូវ បានជ្រើសរើសយកសហការីដែលសកម្ម និងឈ្លាសវៃមកធ្វើការជាមួយរួមមាន លោក ចាកូវលីវ (Jakovliev) ទទួលបន្ទុកការងារបរទេស និងលោក ស្វេវ៉ាដណាដ្ស (Shevardnadze) ជា

[506] ហើស សិរីផន, *សង្គ្រាមត្រជាក់*, រោងពុម្ព ពន្លឺខ្មែរ, ឆ្នាំ២០១៤, ទំព័រ២៤៥។

រដ្ឋមន្ត្រីការបរទេស ព្រោះអ្នកទាំងពីរនេះជាស្ថាបនិកក្នុងការកសាងឡើងនូវមាគ៌ានយោបាយ Perestroika និង Glasnost ជាអ្នកយល់អំពីសភាពការណ៍លំបាកពិតប្រាកដរបស់សូវៀត និងជាអ្នកមានបំណងពិតប្រាកដ ចង់កែទម្រង់សូវៀតឱ្យចាកផុតពីវិបត្តិ។

ពីថ្ងៃទី២៥ ខែកុម្ភៈ ដល់ថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៨៦ នៅទីក្រុងមូស្គូ មហាសន្និបាតលើកទី២៧ របស់បក្សកុម្មុយនីស្តសហភាពសូវៀត បានប្រព្រឹត្តឡើង។ នៅក្នុងរបាយការណ៍របស់ហ្គោបាឆូវ បានធ្វើសេចក្តីអំពាវនាវ ឱ្យមានការកែទម្រង់សេដ្ឋកិច្ចទាំងស្រុងមួយ ហើយគណកម្មាធិការមជ្ឈិមបក្សបានអនុម័តលើលក្ខខន្តិកៈថ្មីរបស់បក្ស ដោយឈរលើគោលការណ៍ ពេរ៉េស្ត្រូយកា និងក្លាសណូស។ នយោបាយកែទម្រង់សំខាន់ៗរបស់ហ្គោបាឆូវបានផ្តោត ទៅលើកិច្ចការមួយចំនួន គ្របដណ្តប់ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច បញ្ញជន វប្បធម៌ មនោគមវិជ្ជា ដូចតទៅ៖

❖ ការកែទម្រង់នយោបាយ ត្រូវតែដើរមុនការកែទម្រង់សេដ្ឋកិច្ច។ ក្នុងនោះលោកបានធ្វើការកែតម្រូវ ទៅលើរដ្ឋធម្មនុញ្ញសហភាពសូវៀត បង្កើតឱ្យមានអំណាចប្រធានាធិបតី កែសម្រួលនូវជំពូក៦នៃរដ្ឋធម្មនុញ្ញស្តីពីតួនាទីដឹកនាំរបស់បក្សកុម្មុយនីស្តសហភាពសូវត។
❖ រៀបចំចាត់ចែងឡើងវិញ នៅក្នុងវិស័យពាណិជ្ជកម្មក្រៅប្រទេស។
❖ រៀបចំកំណែទម្រង់ទៅលើសហគ្រាស និងពង្រីកទីផ្សារអន្តរជាតិ
❖ អនុម័តច្បាប់ស្តីពីការងារពលកម្ម របស់បុគ្គលិក
❖ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៨៦លោក **អង់ដ្រេ សាខារ៉ូវ** (Andréi Sakharov)បានត្រូវដោះលែងឱ្យមាន សេរីភាពឡើងវិញ បន្ទាប់ពីត្រូវជាប់ឃុំក្នុងគេហដ្ឋាន របស់លោកអស់រយៈពេលដ៏យូរមក ពីបទរិះគន់ទៅលើរដ្ឋាភិបាលលោកប្រេសណេវ។

**នៅក្នុងនយោបាយការបរទេស**

- សហភាពសូវៀតមិនទាញយកផលប្រយោជន៍ពីការអនុវត្តជាក់ស្តែង នៃនយោបាយការបរទេសរបស់ខ្លួន ដើម្បីមកបំពេញផលប្រយោជន៍នៅក្នុងប្រទេសឡើយ ដោយក្នុងនោះមានៈ បន្ថយនូវថវិកាយោធា និងប្រកាន់យកនយោបាយកាត់បន្ថយគ្រឿងសព្វាវុធ និងនយោបាយត្រួតពិនិត្យអាវុធ។
- ដកទ័ពសូវៀត ដែលឈរជើងនៅបរទេស ដូចជានៅក្នុងប្រទេសអាហ្វហ្គានីស្ថាន និងក្នុងប្រទេសហុងគ្រី និងប្រទេសឆេកូស្លូវ៉ាគី។
- ធ្វើសម្បទាដោយសន្តិវិធីនៅក្នុងការដោះស្រាយជម្លោះនៅតាមតំបន់ ដូចជានៅតំបន់អាម៉េរិកកណ្តាល តំបន់អាស៊ីអាគ្នេយ៍ តំបន់អាហ្វ្រិក (ប្រទេសអង់ហ្គោឡា ប្រទេស ណាមីប៊ី) នៅក្នុងតំបន់មជ្ឈិមបូព៌ា (ប្រទេសអ៊ីរ៉ង់ ប្រទេសអ៊ីរ៉ាក់)។

ជំហានសំខាន់ក្នុងការងារការបរទេសរបស់ លោកហ្គោបាឆូវ គឺពិនិត្យ និងសម្រេចដកកងទ័ពសូវៀតទាំងអស់ចេញពីអាហ្វហ្គានីស្ថាន ដោយចាប់ផ្តើមពីខែមេសា ឆ្នាំ១៩៨៨ ដល់ដើមឆ្នាំ១៩៨៩។

ជោគជ័យមួយទៀតនៅក្នុងទំនាក់ទំនងអន្តរជាតិ គឺការរំសាយសញ្ញាវុធបានឈានដល់ការព្រមព្រៀងគ្នា យ៉ាងខ្ពស់រវាងប្រធានាធិបតីទាំងពីរ គឺ លោករីហ្គេន(Reagan) និងលោក ហ្គោបាឆូវ នាខែធ្នូ ឆ្នាំ១៩៨៧ នៅទីក្រុង វ៉ាស៊ីងតោន គឺការរំសាយចោលនូវបណ្តាកាំជ្រួចរយៈមធ្យម និងខ្លី។ បន្ទាប់មកនៅខែធ្នូ ឆ្នាំ១៩៨៩ ប្រធានាធិបតីទាំងពីររូបនេះ បានអះអាង និងប្រកាសយ៉ាងឱឡារិកនៅ Malte ថា **«សង្គ្រាមត្រជាក់បានចប់ជាស្ថាពរ»**។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះបានធ្វើឱ្យប្រជាជនលើសកលលោកសាទរ ដោយទទួលយកយ៉ាងសប្បាយរីករាយបំផុត។

ទន្ទឹមនឹងការប្រកាសខាងលើនេះ សភាពការណ៍នៃវិបត្តិសេដ្ឋកិច្ច នៅក្នុងប្រទេសសូវៀត កើនឡើងដល់ កម្រិតមួយខ្ពស់ ហើយចលនាប្រជាធិបតេយ្យ និងប្រជាជាតិបាន និងកំពុងរីកផុសផុល ទាំងនៅក្នុងប្រទេសសូវៀត ទាំងនៅក្នុងបណ្តាប្រទេសសង្គមនិយមអឺរ៉ុបខាងកើត[507]។

## ៧.២-ការដួលរលំរបបសង្គមនិយមនានា

នៅឆ្នាំ១៩៨៩ ចលនាបដិវត្តន៍ប្រជាជនបានផ្ទុះឡើងនៅក្នុងតំបន់អឺរ៉ុបខាងកើត រហូតធ្វើឱ្យរបបកុម្មុយនីស្តរណបសូវៀតត្រូវដួលរលំជាបន្តបន្ទាប់ រហូតធ្វើឱ្យប្លុកកុម្មុយនីស្តនៅអឺរ៉ុបខាងកើតត្រូវបាក់បែកខ្ចាត់ខ្ចាយស្ទើរតែអស់គ្មានសល់ ជំនួសមកវិញដោយរបបប្រជាធិបតេយ្យតាមបែបលោកខាងលិច។

នៅក្នុងប្រទេសប៉ូឡូញ ដោយពុំអាចទ្រទ្រង់បាននូវសភាពការណ៍ដ៏រីករវក្នុងស្រុកទើបនៅ ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៨៩ រដ្ឋាភិបាលប៉ូឡូញ បានសម្រេចបើកកិច្ចប្រជុំជាមួយនឹងសហជីពសាមគ្គីភាព។ ក្នុងកិច្ចប្រជុំនេះ ភាគីទាំងពីរបានព្រមព្រៀងគ្នា ក្នុងការរៀបចំបោះឆ្នោតជាសកល មានលក្ខណៈប្រជាធិបតេយ្យ និងសេរីនៅប៉ូឡូញដំបូង នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៨៩ បន្ទាប់ពីសង្គ្រាមលោកលើកទី២ចប់។ ក្នុងការបោះឆ្នោតនេះ សហជីពសាមគ្គី បានទទួលជ័យជម្នះយ៉ាងធំធេង ទើបនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៨៩ លោក Tadeusz Mazowieski មេធាវី និងជាមេដឹកនាំរបស់សហជីពសាមគ្គីភាពជាប់ឆ្នោតឡើងធ្វើជានាយករដ្ឋមន្ត្រី។ នេះជាលើកដំបូងក្នុងប្រវត្តិសាស្ត្រនៃប្រទេស កុម្មុយនីស្ត មានជួរថ្នាក់ដឹកនាំរដ្ឋាភិបាលមួយដែលពុំមែនជាជនកុម្មុយនីស្ត តែដឹកនាំកិច្ចការរបស់ប្រទេសជាតិ បើកផ្លូវឱ្យមានប្រជាធិបតេយ្យក្នុងប្រទេសប៉ូឡូញដោយឡែក និងក្នុងប្រទេសសង្គមនិយមអឺរ៉ុបខាងកើតនិយាយជារួម។

ចំពោះប្រទេសហុងគ្រីវិញ អាចជាប្រទេសកុម្មុយនីស្តមួយ ដែលមុនគេទទួលយករូបភាពជារបបពហុបក្ស នៅក្នុងប្លុកសង្គមនិយមនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៨៩។ មកដល់ថ្ងៃទី២ ខែឧសភា យោងតាមការព្រមព្រៀង Helsenki រដ្ឋាភិបាលហុងគ្រី បានចាប់ផ្តើមបំផ្លាញរនាំងដែក នៅតាមបណ្តោយព្រំដែនជាមួយនឹងប្រទេសអូទ្រីស ដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៨៩ រដ្ឋាភិបាលបាន

[507] ហើស សិរីធន, *សង្គ្រាមត្រជាក់*, ដ.ឯ.ម., ទំព័រ២៤៦។

សម្រេចបើកកិច្ចប្រជុំជាមួយនឹងគណបក្សប្រឆាំងហុងគ្រី បន្ទាប់មកក៏បានចាត់តាំងពិធីរំឭកខួបលោក Imre Nagy អតីតនាយករដ្ឋមន្ត្រីរបស់ហុងគ្រី ដែលត្រូវសម្លាប់នាឆ្នាំ១៩៥៨ បន្ទាប់ពីលោកបានដឹកនាំការបះបោរក្រោកឈរឡើងប្រឆាំងទៅនឹងការកាន់កាប់ជាយោធារបស់សូវៀត មកលើប្រទេសហុងគ្រីនាឆ្នាំ១៩៥៦។ ចាប់ពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៨៩ ព្រំដែនហុងគ្រី និងអូទ្រីស ត្រូវបានបើកជាចំហ និងសេរី ហើយជិតមួយខែក្រោយមក នៅថ្ងៃទី៧ ខែតុលាឆ្នាំ១៩៨៩ បក្សកុម្មុយនីស្តហុងគ្រី បានសម្រេចប្តូរឈ្មោះទៅជាបក្សសង្គមហុងគ្រីវិញ ដោយបានប្រកាសយ៉ាងឱឡារិកក្នុងការលុបចោល ជាស្ថាពរនូវគោលការណ៍ ប្រជាធិបតេយ្យប្រមូលផ្តុំ និងផ្តាច់ការអេធន។ ចុងក្រោយប្រទេសហុងគ្រីបានប្រកាសនូវឯករាជភាព ឥស្សរភាព និងសេរីពហុបក្សរបស់ប្រទេសខ្លួននៅចំពោះមុខសហគមន៍អន្តរជាតិ។

នៅអាល្លឺម៉ង់ខាងកើតវិញ សភាពការណ៍នយោបាយក្នុងសង្គមកាន់តែមានភាពច្របូកច្របល់បាត់ភាពម្ចាស់ការដឹកនាំ នៅចំពោះមុខហ្វូងបាតុកម្មរបស់មហាជនចេញពីគ្រប់ស្រទាប់វណ្ណៈក្នុងទូទាំងក្រុងធំៗ ដូចជា Berlin, Dresden, Leipzing។ល។ ស្រាប់តែនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៨៩ លោកអ៊ីរិច ហូនិចគឺ (Erich Honecker) អាយុ ៧៦ឆ្នាំ ដែលជាមេដឹកនាំបក្សដ៏កំពូលអភិរក្សក្នុងអង្គការបក្ស ត្រូវបានទម្លាក់ចេញពីតួនាទីជាអគ្គលេខាបក្ស របស់បក្សកុម្មុយនីស្តអាល្លឺម៉ង់ខាងកើត។ មកដល់ដើមខែកញ្ញា ឆ្នាំ១៩៨៩ នៅពេលដែលព្រំដែនហុងគ្រី អូទ្រីស ត្រូវបានបើកជាចំហដោយសេរីមកស្រាប់តែយុវជន ជំនាញការ កម្មករជំនាញ ជាច្រើនលួចរត់ឆ្លងដែន គ្រាន់តែក្នុង រយៈពេលមិនដល់មួយខែផង មានប្រជាជនអាល្លឺម៉ង់ខាងកើតប្រមាន ៨ម៉ឺននាក់បានរត់ទៅជ្រកកោននៅក្នុងអាល្លឺម៉ង់ ខាងលិច។ បន្ទាប់មកដល់ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៨៩ មានក្បួនបាតុកម្មមួយយ៉ាងធំ ដែលមានមនុស្សប្រមាណ ១ លាននាក់ចូលរួម ដោយហ្វូងបាតុករទាំងនេះបានស្រែកទាមទារឱ្យមានការបោះឆ្នោតដោយសេរី ពហុបក្ស រំសាយ ពួកប៉ូលិសសម្ងាត់ Stasi ឱ្យអស់ និងមានសេរីភាពសារព័ត៌មាន។ ក្បួនបាតុកម្មនេះបានធ្វើឱ្យជួរអ្នកដឹកនាំរបស់បក្សកុម្មុយនីស្ត និងសមាជិកក្នុងរដ្ឋាភិបាលរបស់អាល្លឺម៉ង់ខាងកើត ប្រកាសលាលែងចុះចេញពីតំណែងនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ដើម្បីបើកផ្លូវបង្កើតឡើងរដ្ឋាភិបាលចម្រុះមួយ រងចាំថ្ងៃបោះឆ្នោតជាសកល។ ប៉ុន្តែបន្ទាប់មកនៅថ្ងៃទី៩ ខែវិច្ឆិកា ក្រុមបាតុកម្មនេះនៅតែបន្តហើយហ្វូងមហាជនបាននាំគ្នាវាយកម្ទេចជញ្ជាំងប៊ែរឡាំង ដែលជាជញ្ជាំងបែងចែកបេះដូង ដួងព្រលឹងអាល្លឺម៉ង់ទៅជាពីរ។ ការរលំជញ្ជាំងប៊ែរឡាំង ជានិមិត្តសញ្ញាមួយបង្ហាញថា របបសង្គមនិយមចាប់រង្គោះរង្គើរមែនទែន។

នៅប៊ុលហ្គារីវិញ ដោយប្រទេសនេះទទួលឥទ្ធិលពលយ៉ាងខ្លាំងក្លាពីបណ្តាចលនាប្រជាធិបតេយ្យនៅក្នុងតំបន់មក ទើបនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៨៩ លោក ស៊ីវកូវ (Zhivkov) អាយុ៧៨ ឆ្នាំ ដែលជាអ្នកកាន់អំណាច យូរជាងគេបំផុងនៅប៊ុលហ្គារី (៣៥ឆ្នាំ) ត្រូវបានទម្លាក់ពីតំណែង ហើយអ្នកដែលបានឡើងជំនួសគាត់គឺលោក ពេតា ម្លាដេណូវ (Petar Mladenov ) បានប្រកាសនូវរបបពហុបក្សរៀបចំការបោះឆ្នោតដោយសេរី និងលុបបំបាត់ចោលនូវតួនាទី ដឹកនាំផ្តាច់មុខរបស់បក្សកុម្មុយនីស្តក្នុង

ប្រទេសប៊ុលហ្គារី។ ដោយមានវិធានការយ៉ាងវិជ្ជមានយ៉ាង ដូច្នេះ បានធ្វើឱ្យប្រទេស ប៊ុលហ្គារី គេចផុតពីការធ្វើបាតុកម្មធំៗ នៅក្នុងស្រុកដោយមហាជន។

ចំណែកសភាពការណ៍នៅក្នុងប្រទេស រ៉ូមានី (Romania) មានភាពស្មុគស្មាញ ដោយនៅឆ្នាំ ១៩៨៩ របបកុម្មុយនីស្តក្រោមការដឹកនាំរបស់ កឿកេសគូ (Ceaucescu) អាយុ ៧១ឆ្នាំ កាន់អំណាច ២៤ឆ្នាំ មើលទៅពីក្រៅបីដូចជាមានស្ថិរភាពរឹងមាំនៅឡើយ។ នៅចុងឆ្នាំ១៩៨៩ បាតុកម្មដ៏ធំមួយបានកើតឡើងនៅតំបន់ Timisoara (ភាគខាងលិចរ៉ូមានី)។ មូលហេតុដែលនាំឱ្យមានបាតុកម្មនេះ ដោយសារពួកប៉ូលិសសម្ងាត់បានចាប់ខ្លួន សង្ឃប្រូតេស្តង់ ជាតិ ហុងគ្រីមួយរូប។ ក្បួនបាតុកម្មនេះ ត្រូវក្រុមអង្គការប៉ូលិសសម្ងាត់ ប្រើប្រាស់រថក្រោះ កាំភ្លើងយកមក បង្ក្រាបលើក្រុមបាតុករយ៉ាងព្រៃផ្សៃឃោរឃៅបំផុត។ ការបង្ក្រាបមកលើក្បួនបាតុកម្មរបស់ប្រជាពលរដ្ឋ រ៉ូមានី យ៉ាងអមនុស្សធម៌ បានធ្វើឱ្យមានការផ្ទុះឡើងនូវបាតុកម្មជាច្រើននៅគ្រប់ខេត្ត-ក្រុង រួមទាំងរដ្ឋធានីប៊ូការេស្ត(Bucarest) ទៀតផង។ វិលត្រឡប់ពីអ៊ីរ៉ង់មកវិញ លោក កឿកេសគូ បានចាត់តាំងឱ្យមានការប្រជុំ មួយដែលមាន មនុស្សចូលរួម ប្រមាណ ២០០០០០នាក់។ គោលគំនិតចម្បងរបស់ កឿកេសគូ គឺយកការជួបប្រជុំនេះធ្វើជាលេស ដើម្បីថ្កោលទោសថាមានពួកហ្វាស៊ីស ប្រតិកិរិយា នៅពីក្រោយបាតុកម្មនៅ Timisoara ។ កំពុងនិយាយលើវេទិកាយ៉ាងធ្ងាញមាត់ ស្រាប់តែក្រុមមនុស្សក្នុងអង្គប្រជុំ កើតមានភាពចលាចល ជ្រួលច្របល់ ដោយមានក្រុមនិស្សិតរាប់ពាន់នាក់ ពោរពេញទៅដោយសេចក្តីក្លាហាន បានស្រែកខ្លាំងៗ ក្នុងអង្គប្រជុំថា**បរាជ័យជនផ្តាច់ការ កឿកេសគូ បរាជ័យពួកឃាតកសម្លាប់មនុស្សនៅ Timisoara ។** ឆ្លៀតឱកាសស្ថានភាពនៅក្នុងប្រទេស កំពុងជួបប្រទះទៅ នឹងការលំបាកដូច្នោះ ពួកសហការី អ្នកកាន់អំណាចជាមួយ កឿកេសគូ ស្រាប់តែក្រោកឈរឡើងធ្វើរដ្ឋប្រហារទម្លាក់កឿកេសគូ ក្នុងអង្គប្រជុំនេះ តែម្តង។ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៨៩ ជនកំណាច កឿកេសគូ និងប្រពន្ធបាន រត់គេចខ្លួន ហើយ រណសិរ្សស្រោចស្រង់ជាតិមួយត្រូវបានបង្កើតឡើងដោយជ្រើសតាំង លោក អ៊ីអន អ៊ីលលីស្គូ (Ion Illiescu) ឡើងកាន់អំណាច។ កងទ័ពបានសហការជាមួយមហាជនចូលរួមធ្វើបាតុកម្ម ដែលក្នុងពេលនោះ ពួក អង្គការប៉ូលិសសម្ងាត់ បន្តបាញ់សម្លាប់ប្រជាពលរដ្ឋធ្វើការប្រឆាំងតវ៉ា។ ថ្ងៃ២២ ខែធ្នូ ឆ្នាំ១៩៨៩ លោកកឿកេស្គូ និងប្រពន្ធ ត្រូវបាញ់សម្លាប់ចោល ដោយកងទ័ពជាតិរ៉ូមានី។ បដិវត្តន៍នៅរ៉ូមានី ពោរពេញទៅដោយឈាម និងទឹកភ្នែក មិនដូចបដិវត្តន៍នៅអឺរ៉ុបខាងកើតផ្សេងៗ ដែលសម្រេចបានដោយសន្តិវិធីឡើង។

នៅក្នុងប្រទេសឆេកូ ឯនោះវិញ ដោយទទួលសម្ពាធយ៉ាងខ្លាំងពីចលនាប្រជាធិបតេយ្យនៅក្នុងស្រុកដូច្នេះ ទើបនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ជួរដឹកនាំបក្សកុម្មុយនីស្តឆេកូ ទាំងអស់បានចុះចេញពីតំណែង ហើយមាន សមាជិកការិយាល័យនយោបាយ៧នាក់ ត្រូវបានបណ្តេញចេញពីអង្គការបក្ស។ ចុងក្រោយបដិវត្តន៍មហាជន ទទួលបានជោគជ័យលើពួកកុម្មុយនីស្ត ហើយរដ្ឋអំណាចត្រូវបានផ្ទេរមកឱ្យពួកប្រឆាំងសង្គមនិយមវិញ។ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៨៩ លោក វ៉ាខ្លាវ ហាវែល (Vaclav Havel) ដែលជាអ្នកទោសនយោបាយ របស់បក្សកុម្មុយនីស្ត ឆេកូ ត្រូវបានបោះឆ្នោតឱ្យធ្វើជាប្រធានាធិបតីនៃសាធារណរដ្ឋឆេកូ ចំពោះលោក អាឡិចសាន់ដឺ ឌូបកេក (Alexandre Dubcek) ដែលជាប្រធានដឹកនាំ

ចលនា **និទាឃរដូវ** Praha ត្រូវបានជ្រើសតាំងជាប្រធានរដ្ឋសភា ។ ចាប់ពី ពេលនោះមកឆេកូ បានក្លាយទៅជាប្រទេសប្រជាធិបតេយ្យសេរីពហុបក្សរហូតមក។

ចំណែក ប្រទេសម៉ង់ហ្គោលី និងប្រទេសអាល់បានី ក៏ប្រជាពលរដ្ឋចាប់ផ្ដើមក្រោកឈរឡើងបះបោរផ្ដួលរំលំរបបកុម្មុយនីស្តផ្ដាច់ការនៅក្នុងប្រទេសរបស់ខ្លួនផងដែរ។ សហព័ន្ធសង្គមនិយមយូហ្គោស្លាវី ក៏រងនូវការកៀបសង្កត់ សម្ពាធពីបណ្ដាចលនាជាតិនិយម និងប្រជាធិបតេយ្យដោយចាប់រលំរលាយជាបណ្ដើរៗ ហើយពិតមែនតែបានរំលំ យ៉ាងដូច្នេះ ក៏ពួកអភិរក្សនិយមខ្លះនៅក្នុងបក្សកុម្មុយនីស្តបន្តកាន់អំណាចរហូតដល់ថ្ងៃមានហេតុការណ៍ នៅសែប៊ី ជាឧទាហរណ៍ស្រាប់។ ក្រោយពីសហព័ន្ធយូហ្គោស្លាវី រលំរលាយមក សោកនាដកម្មមួយបានកើតឡើងនៅយូហ្គោស្លាវី គឺកើតសង្គ្រាមក្នុងស្រុក ហើយសង្គ្រាមនេះបានរីករាលដាលមកក្នុងតំបន់ បាល់កង់ (Balkan) រួមទាំងក្នុងទ្វីបអឺរ៉ុបទៀត ដែលជាឫសគល់កើតមកពីឥទ្ធិពលកុម្មុយនីស្តនិយម ដែលកើតមានរាប់សិបឆ្នាំនៅក្នុងតំបន់នេះ[508]។

នៅចំពោះមុខព្រឹត្តិការណ៍បដិវត្តន៍ ផ្ដួលរំលំរបបសង្គមនិយមក្នុងបណ្ដាប្រទេសនៅអឺរ៉ុបខាងកើតនាចុង ឆ្នាំ១៩៨៩ ក៏លោកហ្គោបាឆូវ និងដួរដឹកនាំរបស់បក្សកុម្មុយនីស្តសូវៀតរក្សាឥរិយាបថ មិនជ្រៀតជ្រែកធ្វើអន្តរាគមន៍ ឡើយ។ ការមិនធ្វើអន្តរាគមន៍មកលើហេតុការណ៍ទាំងនេះដូចកាលពីមុនដោយសូវៀតយល់ច្បាស់ថា សហភាព សូវៀតបាននឹងកំពុងស្ថិតនៅមាត់ជ្រោះវិបត្តិដ៏ធ្ងន់ធ្ងរ ដូច្នេះការធ្វើអន្តរាគមន៍ ជាយោធារបស់សូវៀត ចូលមក អឺរ៉ុប ខាងកើតម្ដងទៀត និងជំរុញសូវៀតកាន់តែផុងជ្រៅទៅៗ ហើយការធ្លាក់ផុងនេះជាឱកាសជួយសម្រួល និងបង្កលក្ខណៈសម្បត្តិឱ្យចលនាប្រជាធិបតេយ្យនៅក្នុងប្រទេសសូវៀតនៅពេលនោះ មានកម្លាំងរីកធំធាត់ និងមានឱកាសផ្ដួលរំលំរដ្ឋអំណាចសូវៀតតែម្ដង។

## ៧.៣-ការដួលរលំនៃសហភាពសូវៀត

នយោបាយ កំណែទម្រង់របស់លោកហ្គោបាឆូវ គឺជាកត្តាដ៏ធំមួយ ដែលជួយជំរុញឱ្យចលនាបដិវត្តន៍នេះបានទទួលជោគជ័យ។ ក៏ប៉ុន្តែ អ្វីដែលលោកហ្គោបាឆូវមិនបានរំពឹងទុកនោះ គឺបដិវត្តន៍ឆ្នាំ១៩៨៩នេះមិនមែនកើតមានឡើងតែនៅអឺរ៉ុបខាងកើតនោះទេ តែបានរាលដាលទៅដល់សហភាពសូវៀតខ្លួនឯងផ្ទាល់។ ដំណើរឆ្ពោះទៅរកការដួលរលំនៃសហភាពសូវៀត បានបានចាប់ផ្ដើមឡើងពីរដ្ឋជាប់នឹងសមុទ្របាល់ទិក គឺអេស្តូនី ឡេតូនី និងលីទុយអានី។ ប្រទេសទាំង ៣នេះធ្លាប់ជាប្រទេសឯករាជ្យ ក៏ប៉ុន្តែត្រូវបានសូវៀតកាត់យកមកដាក់ជាទឹកដីរបស់ខ្លួន តាមរយៈកិច្ចព្រមព្រៀង រវាងស្តាលីន និងហ៊ីត្លែរ នៅឆ្នាំ១៩៣៩។ ហេតុដូច្នេះហើយបានជាប្រជាជននៅក្នុងប្រទេសទាំង៣នេះ តែងតែចាត់ទុកខ្លួនឯងជាប្រទេសឯករាជ្យ តែស្ថិតក្រោមការកាន់កាប់ដោយខុសច្បាប់ពីសំណាក់សហភាពសូវៀត។

នៅខែសីហា ឆ្នាំ១៩៨៩ នៅក្នុងពេលដែលចលនាបដិវត្តន៍កំពុងតែផ្ទុះឡើងយ៉ាងពេញទំហឹងនៅអឺរ៉ុបខាងកើត ហើយឆ្លៀតក្នុងឱកាសខួប៥០ឆ្នាំ នៃកិច្ចព្រមព្រៀងស្តាលីន-ហ៊ីត្លែរឆ្នាំ១៩៣៩ (តាម

[508] ហើស សិរីធន, សង្គ្រាមត្រជាក់, ដ.ឯ.ម., ទំព័រ២៥៤។

ពិតគឺកិច្ចព្រមព្រៀងម៉ូឡូតូវ-រីបេនត្រុប ដោយយកតាមឈ្មោះរដ្ឋមន្ត្រីការបរទេស សូវៀត-អាល្លឺម៉ង់ ដែលជាអ្នកចុះហត្ថលេខា) ប្រជាជនអេស្តូនី ឡេតូនី និងលីទុយអានី ប្រមាណជា ១លាននាក់បាននាំគ្នាចេញធ្វើបាតុកម្ម ដើម្បីប្រឆាំងនឹងអ្វីដែលពួកគេហៅថាជាការកាន់កាប់ដោយខុសច្បាប់ របស់សូវៀត។ មួយឆ្នាំក្រោយមក ប្រទេសទាំងបីក៏បានប្រកាសផ្តាច់ខ្លួនជាប្រទេសឯករាជ្យ ពីសហភាព សូវៀត។

ការប្រកាស ផ្តាច់ខ្លួនរបស់ប្រទេសទាំង ៣នេះមិនត្រូវបានរដ្ឋាភិបាលសហព័ន្ធសូវៀតទទួលស្គាល់នោះទេ។ ទោះជាយ៉ាងនេះក៏ដោយ បណ្តារដ្ឋមួយចំនួនផ្សេងទៀតរួមមាន ហ្សកហ្ស៊ី, អ៊ុយក្រែន, អាមេនី និងម៉ុលដាវី ក៏បាននាំគ្នាប្រកាសផ្តាច់ខ្លួនពីសូវៀតជាបន្តបន្ទាប់ ដោយយកគំរូតាមប្រទេសនៅបាល់ទិក។ ចំណុចរបត់ដ៏សំខាន់ គឺការប្រកាសឯករាជ្យរបស់រុស្ស៊ី ដែលជារដ្ឋធំជាងគេ មានប្រជាជនច្រើនជាងគេ និងជាពិសេស មានអំណាចនយោបាយខ្លាំងជាងគេ នៅក្នុងសហភាពសូវៀត។ ការប្រកាសផ្តាច់ខ្លួនជារដ្ឋឯករាជ្យពីសភាពសូវៀតត្រូវបាន ចុះហត្ថលេខាដោយលោកប្រធានា ធិបតីរុស្ស៊ី បូរីស យែលស៊ីន នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩០។

ប្រឈមមុខនឹងចលនាផ្តាច់ខ្លួននៃបណ្តារដ្ឋសមាជិកទាំង ១៥ របស់សហភាពសូវៀត លោកហ្គោបាឆូវនៅតែប្រកាន់យកនូវនយោបាយដូចពីមុន គឺជ្រើសរើសយកការចរចា ជាជាងការប្រើកម្លាំងបង្រ្កាប។ នៅក្នុងការចរចានេះ លោកហ្គោបាឆូវបានលើកឡើងនូវសំណើកំណែទម្រង់ដ៏សំខាន់មួយ ដើម្បីផ្តល់អំណាចដល់រដ្ឋជាសមាជិក ក្នុងការចាត់ចែងកិច្ចការក្នុងរដ្ឋរបស់ខ្លួនស្ទើរតែដូចប្រទេស ឯករាជ្យ ក៏ប៉ុន្តែ ត្រូវស្ថិតនៅជារដ្ឋសមាជិកសហភាពសូវៀតដូចពីមុនដដែល។

ទោះជាយ៉ាងណា សំណើកំណែទម្រង់របស់លោកហ្គោបាឆូវនេះត្រូវប្រឈមមុខនឹងការប្រឆាំង ពីចរន្តធំៗ ពីរ។ រដ្ឋមួយចំនួន គឺ អេស្តូនី ឡេតូនី លីទុយអានី អាមេនី ហ្សកហ្ស៊ី និងម៉ុលដាវី ទាមទារដាច់ខាតចង់ផ្តាច់ខ្លួនជាប្រទេសឯករាជ្យដាច់ចេញទាំងស្រុងពី សហភាពសូវៀត។ ចំណែកឯក្រុមអ្នកនយោបាយប្រកាន់តឹងនៅក្នុងបក្សកុម្មុយនីស្តសូវៀត ដែលក្នុងចំណោមនោះក៏មានមន្ត្រីកាន់អំណាចធំៗ ជាច្រើនផងដែរ គឺរួមមាន អនុប្រធានាធិបតី នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិនិងប្រមុខក្រសួងចារកិច្ច(KGB)នាំគ្នាប្រឆាំងនឹងជំហរសម្រុះសម្រួលរបស់លោក ហ្គោបាឆូវ ដោយទាមទារឱ្យចាត់វិធានការក្តៅបង្រ្កាបទៅលើចលនាផ្តាច់ខ្លួន ដើម្បីរក្សាអំណាចសហភាពសូវៀតឱ្យនៅខ្លាំងដូចកាលពីមុន។ ដើម្បីសម្រេចតាមបំណងរបស់ខ្លួន ក្រុមនេះក៏បាននាំគ្នារៀបចំគម្រោងការណ៍ដើម្បីច្បាមយកអំណាចពីលោកហ្គោបាឆូវ តាមរយៈរដ្ឋប្រហារ។

ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩១ ក្រុមមេដឹកនាំរដ្ឋប្រហារបានបញ្ជូនមនុស្សពីម៉ូស្គូ ឱ្យទៅជួបលោកហ្គោបាឆូវដែលកំពុងសម្រាកលំហែរកាយនៅឯតំបន់គ្រីមេ ដោយបានទាមទារឱ្យលោកប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន ដើម្បីដាក់ពង្រាយកម្លាំងទ័ពទៅបង្រ្កាបក្រុមអ្នកទាមទារផ្តាច់ទឹកដី។ លោកហ្គោបាឆូវបដិសេធ ពួកមេដឹកនាំរដ្ឋប្រហារក៏បានចាប់លោកដាក់ឃុំនៅក្នុងផ្ទះ ដោយកាត់ផ្តាច់រាល់បណ្តាញទាក់ទងទៅពិភពខាងក្រៅ ហើយមួយថ្ងៃក្រោយមក មេដឹកនាំរដ្ឋប្រហារបានប្រកាសថា លោកហ្គោបាឆូវមានជំងឺ ហើយបានប្រគល់អំណាចទៅឱ្យគណៈកម្មាធិការមួយ ដែលមានសមាជិក ៨រូប ជា

អ្នកគ្រប់គ្រងជាបណ្តោះអាសន្ន ហើយក្នុងពេលជាមួយគ្នាគណៈកម្មាធិការនេះបានប្រកាសដាក់សហភាពសូវៀត ទាំងមូលឱ្យស្ថិតក្រោមច្បាប់អាជ្ញាសឹក ព្រមទាំងបញ្ជូនកម្លាំងឱ្យទៅបង្ក្រាបពួកអ្នកទាមទារផ្តាច់ខ្លួនជា រដ្ឋឯករាជ្យ។

មកត្រឹម ពេលនោះ អ្នកណាក៏ដឹងដែរថា អ្វីដែលកំពុងកើតឡើង គឺជារដ្ឋប្រហារទម្លាក់លោកហ្គោបាឆូវពីតំណែង។ ក៏ប៉ុន្តែ រដ្ឋប្រហារនេះមានអាយុកាលតែ៣ថ្ងៃប៉ុណ្ណោះ ក៏ត្រូវទទួលបរាជ័យទៅវិញ។ បរាជ័យនៃរដ្ឋប្រហារនេះកើតឡើងដោយសារតែមូលហេតុធំៗពីរ គឺការខ្វះគាំទ្រពីសំណាក់មន្ត្រីថ្នាក់ក្រោមទាំងនៅក្នុងជួរកងទ័ព និងក្នុងក្រសួងចារកិច្ច KGB ហើយកាន់តែសំខាន់ជាងនេះទៅទៀត គឺដោយសារតែក្រុមរដ្ឋប្រហារមិនអាចចាប់ខ្លួន លោក បូរីស យែលស៊ីន ប្រធានាធិបតីរុស្ស៊ី ដែលជារដ្ឋដ៏មានអំណាចបំផុតក្នុងសហភាពសូវៀត។

នៅថ្ងៃទី១៩សីហា លោកបូរីស យែលស៊ីន បានចេញមុខប្រកាសបដិសេធមិនទទួលស្គាល់មេដឹកនាំថ្មី ដែលកើតចេញពីអ្វី ដែលលោកហៅថាជារដ្ឋប្រហាររំលោភលើរដ្ឋធម្មនុញ្ញ ហើយលោកបានអំពាវនាវឱ្យប្រជាជន ព្រមទាំងកងកម្លាំងប្រដាប់អាវុធទាំងអស់ស្តាប់តាមតែបទបញ្ជាចេញដោយ រដ្ឋាភិបាលរបស់លោក។ សេចក្តីប្រកាសរបស់លោកបូរីស យែលស៊ីន បានទទួលនូវការគាំទ្រយ៉ាងច្រើនសន្ធឹកសន្ធាប់ពីសំណាក់ប្រជាជន ក៏ដូចជា ពីសំណាក់សហគមន៍អន្តរជាតិ ជាពិសេស ពីសំណាក់មេដឹកនាំប្រទេសមហាអំណាច ដូចជា លោកប៊ូស ប្រធានាធិបតីអាម៉េរិក លោកហ្វ្រង់ស័រ មីតេរ៉ង់ ប្រធានាធិបតីបារាំង លោកចន មេជ័រ នាយករដ្ឋមន្ត្រីអង់គ្លេស និងលោកអេលមូត កូល អធិកាបតីអាល្លឺម៉ង់។

នៅទីបំផុត មេដឹកនាំរដ្ឋប្រហារក៏ត្រូវបង្ខំចិត្តដោះលែងលោកហ្គោបាឆូវពីគ្រីមេ ឱ្យត្រឡប់មកកាន់អំណាចវិញ។ ក៏ប៉ុន្តែ ទោះជាត្រូវបរាជ័យក៏ដោយ រដ្ឋប្រហារនៅខែសីហា ឆ្នាំ១៩៩១នោះ បានធ្វើឱ្យអំណាចនយោបាយរបស់លោកហ្គោបាឆូវត្រូវធ្លាក់ចុះខ្សោយ យ៉ាងខ្លាំង ដោយលោកមានតែតំណែង ចំណែកឯអំណាចពិតប្រាកដត្រូវស្ថិតក្នុងដៃលោកបូរីស យែលស៊ីន។ នៅ៤ខែក្រោយរដ្ឋប្រហារ នៅថ្ងៃទី៨ខែធ្នូ រដ្ឋទាំង១៥ ក្នុងសហភាពសូវៀតក៏បានប្រកាសឯករាជ្យរៀងៗខ្លួន ហើយនៅថ្ងៃទី២៤ ខែធ្នូ រុស្ស៊ី ដោយមានការគាំទ្រពីអតីតរដ្ឋសូវៀតផ្សេងទៀត បានជូនដំណឹងទៅអ.ស.បថា ចាប់ពីពេលនោះទៅរុស្ស៊ីនឹងកាន់កាប់អាសនៈជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអ.ស.ប ជំនួសសហភាពសូវៀត។ មួយថ្ងៃក្រោយមក នៅថ្ងៃទី២៥ធ្នូ ដែលចំថ្ងៃបុណ្យណូអែល លោកហ្គោបាឆូវបានប្រកាសលាឈប់ពីមុខតំណែងជាប្រធានាធិបតីនៃសហភាពសូវៀត ហើយនៅថ្ងៃទី២៦ធ្នូ ទង់ក្រហម ដែលមានកណ្តៀវនិង




ប្រភព: Judy Ling , Dr Aron Paul, Bi-Polarity & the Cold

ញញួរត្រូវបានគេបង្គួតចុះពីវិមានក្រេមឡាំង ជំនួសមកវិញដោយទង់ជាតិរុស្ស៊ី[509]។ សហភាពសាធារណរដ្ឋសង្គមនិយម សូវៀត ដែលបានបង្កើតឡើងតាំងពីឆ្នាំ១៩២២ ក៏ត្រូវរំលាយជាផ្លូវការ ជំនួសមកវិញដោយប្រទេសឯករាជ្យចំនួន១៥គឺរុស្ស៊ី, អ៊ុយក្រែន, បេឡារុស, ហ្សកហ្ស៊ី, ម៉ុលដាវ៉ា, អាមេនី, អេស្តូនីឡេតូនី, លីទុយអានី, អាស៊ែបៃហ្សង់កាហ្សាក់ស្ថាន, អ៊ូសបេគីស្ថាន, តាហ្ស៊ីគីស្ថាន, កៀហ្ស៊ីស៊ីស្ថាន និងតួកម៉េនីស្ថាន។

## សំណួរត្រិះរិះ

១-តើសង្គ្រាមត្រជាក់ជាអ្វី? សង្គ្រាមនេះចាប់ផ្តើមឡើង និង បញ្ចប់នៅឆ្នាំណា? ដោយព្រឹត្តិការណ៍អ្វី?
២-តើមូលហេតុអ្វីខ្លះដែលនាំឱ្យកើតសង្គ្រាមត្រជាក់?
៣-តើសង្គ្រាមត្រជាក់ជះឥទ្ធិពលដូចម្តេចខ្លះដល់តំបន់ឥណ្ឌូចិន?
៤-តើនៅក្នុងដំណាក់កាលសង្គ្រាមត្រជាក់អាល្លឺម៉ង់ប្រឈមបញ្ហាធំៗអ្វីខ្លះ?
៥-តើសន្និសីទយ៉ាល់តាមានទិសដៅដូចម្តេចខ្លះ?
៦-ចូរពន្យល់ពីការបង្កើតបក្សសម្ពន្ធយោធាធំទាំងពីរនៅក្នុងសម័យសង្គ្រាមត្រជាក់។
៧-តើមូលហេតុអ្វីខ្លះដែលនាំឱ្យប្រទេសអាល្លឺម៉ង់ត្រូវបែងចែកជាពីរ?
៨-តើអាល្លឺម៉ង់បង្រួបបង្រួមតែមួយឡើងវិញនៅថ្ងៃខែឆ្នាំណា? ដោយសារមូលហេតុអ្វីខ្លះ?
៩-តើមូលហេតុអ្វីខ្លះដែលនាំឱ្យពួកកុម្មុយនីស្តអាចកាន់កាប់ប្រទេសចិនបាននៅឆ្នាំ១៩៤៩?
១០-ចូរពន្យល់ពីមូលហេតុការដួលរលំនៃរបបសង្គមនិយមនៅអឺរ៉ុបខាងកើតនាចុងទសវត្សរ៍ឆ្នាំ១៩៨០។
១១-តើមូលហេតុអ្វីដែលនាំឱ្យមានកំណែទម្រង់ពេរ៉េស្ត្រូយកានៅសូវៀតឆ្នាំ១៩៨៥? តើកំណែទម្រង់នេះផ្តោតលើចំណុចអ្វីខ្លះ?
១២-ចូរបកស្រាយពីមូលហេតុដែលនាំឱ្យសហភាពសូវៀតដួលរលំ?
១៣-តើកំណែទម្រង់ពេរ៉េស្ត្រូយកា ធ្វើឱ្យពិភពលោកមានការប្រែប្រួលដូចម្តេចខ្លះ?
១៤-តើការដួលរលំរបបសង្គមនិយមនៅអឺរ៉ុបខាងកើត បានផ្តល់ជាបច្ច័យអ្វីខ្លះដល់ការចរចាបញ្ចប់ជម្លោះនៅកម្ពុជានាចុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០?
១៥-តើមូលហេតុអ្វីខ្លះដែលធ្វើឱ្យទ្វីបអឺរ៉ុបត្រូវបែងចែកជាពីរនៅក្រោយសង្គ្រាមលោកលើកទី២?
១៦-តើសង្គ្រាមត្រជាក់ ជះឥទ្ធិពលដូចម្តេចខ្លះដល់កម្ពុជាក្នុងទសវត្សរ៍ឆ្នាំ១៩៧០?

[509] សូមមើល សេង ឌីណា *ប្រវត្តិសាស្ត្រពិភពលោក* ការផ្សាយរបស់វិទ្យុបារាំងអន្តរជាតិ ចុះផ្សាយនៅថ្ងៃ 21/02/2016

# ឯកសារយោង

## I-ឯកសារដើម

1. នរោត្តម សីហនុ រាជសារជូនជនរួមជាតិជ្រាបអំពីរាជសកម្មភាពដើម្បីឯករាជ្យបរិបូរណ៍ន កម្ពុជា នាទស្សវត្សរ៍១៩៤០-១៩៥០ ភ្នំពេញថ្ងៃទី១៤ តុលា ឆ្នាំ២០០៣

2. ប្រវត្តិសង្ខេបនៃព្រះរាជបេសកកម្មប្រយុទ្ធទាមទារឯករាជ្យសម្រាប់ប្រទេសកម្ពុជា ឆ្នាំ១៩៥៦

3. សុទ្ធ ប៉ូលីនសមាជចុងក្រោយនៃសង្គមរាស្ត្រនិយមនៅក្នុងអង្គរបុរីសំឡេងខ្មែរនៅបរទេស ឆ្នាំ?

4. ព្រះរាជសាសន៍ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ័ន្ម ព្រះចៅព្រះរាជអាចក្រកម្ពុជាទ្រង់ត្រាស់ទៅកាន់ប្រជាជាតិក្នុងកម្ពុជរដ្ឋ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៥៣

5. រាជកិច្ចលខ៦៣ ចេញផ្សាយថ្ងៃទី១៧ សីហា ឆ្នាំ១៩៦៨

6. រាជកិច្ចលេខ២១ ចេញផ្សាយថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៥៧

7. នយោបាយសេដ្ឋកិច្ចនៃសង្គមរាស្ត្រនិយម ឆ្នាំ?

8. រាជកិច្ចលេខ៥០ ចេញផ្សាយថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៦២

9. រាជវិចារណ៍ដើម្បីសម្រួលរដ្ឋធម្មនុញ្ញដែលព្រះមហាក្សត្រិយ៍ បានប្រោសប្រទានដល់ប្រជារាស្ត្រព្រះអង្គក្នុងឆ្នាំ១៩៤៧

10. រាជកិច្ចផ្សេងៗទៀតនៅបណ្ណសារដ្ឋានជាតិ

11. SPK ( 1980-1985 )

12. កាសែតកងទ័ព

13. កាសែតយុវជន

14. កាសែតកម្ពុជា ( ១៩៨៧,១៩៨៨ )

15. កាសែតសង្គមរាស្ត្រនិយម

16. ទស្សនាវដ្តីនៃយុវជន លេខ១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥៧

## II-ឯកសារស្នាដៃនិពន្ធ

### ក-ឯកសារជាភាសាខ្មែរ

1. កាសែតប្រជាជន( ១៩៩១ ) ហ៊ុន សែន ១៣ទសវត្សនៃដំណើរកម្ពុជា។

2. ក្រសួងអប់រំ យុវជន និង កីឡា (២០១៤) ប្រវត្តិវិទ្យា ថ្នាក់ទី៨ ភ្នំពេញ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ។

3. ក្រសួងអប់រំ យុវជន និង កីឡា (២០១៤) ប្រវត្តិវិទ្យា ថ្នាក់ទី១១ ភ្នំពេញ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ។

4. ក្រសួងអប់រំ យុវជន និង កីឡា (២០១៥) ប្រវត្តិវិទ្យា ថ្នាក់ទី១២ ភ្នំពេញ គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ។

5. ក្រសួងអប់រំជាតិ( ១៩៧៣ ) ខេមរយានកម្ម ( ប្រវត្តិវិទ្យាថ្នាក់ទី៣ ) ភ្នំពេញ ។

6. ក្រសួងអប់រំជាតិ(១៩៧៣) ខេមរយានកម្ម (ប្រវត្តិវិទ្យាថ្នាក់ទី៦) ភ្នំពេញ ។
7. ក្រុមការងារពិសេសរបស់រដ្ឋាភិបាល ៥-៦ កក្កដា? ១៩៩៧។
8. ខៀវ កាញារីទ្ធ (២០០៩) ធម្មនុញ្ញអាស៊ាន និងកិច្ចសហប្រតិបត្តិការ ភ្នំពេញ។
9. ខៀវ ថវិកា(១៩៩៧) ប្រវត្តិនៃទំនាក់ទំនងអន្តរជាតិ ពីឆ្នាំ១៩៤៥ ដល់បច្ចុប្បន្ន ភ្នំពេញ។
10. ខៀវ ថវិកា (២០០៦) សហគមន៍អន្តជាតិ ភ្នំពេញ។
11. ខៀន ធីរៈវិទ្យ និងសុណ័យ ភាសុខ (?) កម្ពុជាៈប្រវត្តិសាស្ត្រ សង្គម សេដ្ឋកិច្ច សន្តិសុខ នយោបាយ និងកិច្ចការបរទេស ប្រែសម្រួលដោយ ក្លែរុង អាមរៈតិស ទេព ទីណូ។
12. ខៀវសំផន(២០០២)ប្រវត្តិសាស្ត្រថ្មីៗនិងគោលជំហររបស់ខ្ញុំបន្តបន្ទាប់ បោះពុម្ពលើកទី២ភ្នំពេញ។
13. ខៀវ សំផន (២០០៧) ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ បោះពុម្ពផ្សាយដោយ សេវាបោះពុម្ពផ្សាយ រាហ៊ុ។
14. គង់ ថាន់ (២០០៩) រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ និងមាគ៌ាឆ្ពោះទៅរកសន្តិភាព រោងពុម្ពអង្គរ ភ្នំពេញ។
15. គឹម ជីអ៊ួយ(យាយ ទៀង) (២០០៩) អង្គការជានរណា ភាគ៣ បោះពុម្ពផ្សាយគេហដ្ឋានផ្សាយអក្សរា។
16. គួង គីនី (២០២២) ប្រវត្តិសាស្ត្រពិភពលោក ភ្នំពេញ។
17. ចាន់ ប៊ុន្នី (២០១២) ឯកសារទំនាក់ទំនងអន្តរជាតិ បង្រៀននៅCUS ។
18. ឆាយ សុផល (២០១៥) អំណាច និងរាជបល្ល័ង្កនៃមហាក្សត្រសៃអង្គដួង នរោត្តម ស៊ីសុវត្ថិ ភ្នំពេញ។
19. ឈុន ណារ៉េត (២០០៤) អាស៊ាន & ដំណើរសកលភាវូបនីយកម្ម ភ្នំពេញ។
20. ដេវិឌ ឆាឌល័រ (២០០៥) ប្រវត្តិសាស្ត្រខ្មែរ មជ្ឈមណ្ឌលខេមរសិក្សា។
21. ដៀប សុផល (២០០៣)សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដំណើរឆ្ពោះទៅកាន់សតវត្សទី២១
22. ដៀប សុផល(២០០៧) សង្គ្រាមនិងសន្តិភាពកម្ពុជា ភ្នំពេញ។
23. ដៀប សុផល (២០០៥) របបសង្គមរាស្ត្រនិយមពីមហាជ័យជំនះឈានដល់វិបត្តិ និងការដួលរលំ(១៩៥៥-១៩៧០)។
24. ឌី ខាំបូលី (២០០៧) ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញ។
25. ណាយ៉ាន់ ចាន់ដា (២០០៦) សត្រូវបងប្អូនឯង ប្រែសម្រួលដោយ ទេព ម៉េងឃាង មជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ពលើកទី១។
26. ត្រឹង ងា (១៩៧៣) ប្រវត្តិសាស្ត្រខ្មែរ ភ្នំពេញ។
27. ត្រាំងធាតប៊ុង(២០១៧) វៀតណាម ឬ ស្រុកយួន ភ្នំពេញ : គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ។
28. ទី សុផល, សហគមន៍អន្តរជាតិ និង ដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាពីឆ្នាំ ១៩៨១ ដល់ឆ្នាំ១៩៩១។

29. ទី សុផល(២០២៤) ប្រវត្តិវិទ្យា: ប្រវត្តិសាស្ត្រខ្មែរសង្ខេប។
30. ទីភ្នាក់ងារសារព័ត៌មាន ស.រ.អ( ? ) កម្រង ប្រវត្តិសាស្ត្រអាម៉េរិក។
31. នន សូហ្វិនស្គី (១៩៨៨) ប្រទេសសូវៀត បកប្រែសម្រួលដោយ យ៉ាវ ប៊ុនម៉េង និងលីខេង អង្គការបោះពុម្ពផ្សាយ ប្រូហ្គ្រេស្ស។
32. នរោត្តម សីហនុ (១៩៩៣) អនុស្សាវរីយ៍ផ្អែមល្ហែម និងជូរចត់។
33. នួន សុជិមន្ត (២០០៧) ទំនាក់ទំនងអន្តរជាតិ ភ្នំពេញ។
34. នួន សុជិមន្ត(២០០៥) សមាគមអាស៊ាន ភ្នំពេញ។
35. ប៊ិន យៀរនិន ( ? ) របបប៉ុល ពត ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ ប្រែសម្រួលដោយ ឡាយពុទ្ធា និងទីឃាយុ មជ្ឈមណ្ឌលឯកសារកម្ពុជា។
36. ប៉ែន សុវណ្ណ និងនាង វុធ (២០០២) ប៉ែន សុវណ្ណ ជីវប្រវត្តិសង្ខេប និងបុព្វហេតុជាតិមាតុភូមិកម្ពុជា វ៉ាស៊ីនតោន។
37. ប៊ុន ចន្ទម៉ុល (១៩៧៣) ចរិតខ្មែរ បោះពុម្ពលើកទី១នៅភ្នំពេញ។
38. ពុំ សុមុនីរៈ (១៩៩៦) តួនាទីសហគមន៍អន្តរជាតិ ក្នុងដំណោះស្រាយកម្ពុជា «សារណាបញ្ចប់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាកម្រិត២ មហាវិទ្យាល័យគរុកោសល្យភ្នំពេញ។
39. មីហេយេវ (១៩៨១) ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា បកប្រែដោយសាស្ត្រាចារ្យ ឡុងសៀម។
40. មិល្ដុន អូស្បន (២០០៩) ផ្ដើមឈ្វេងយល់ពីប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ : មជ្ឈមណ្ឌលខេមរសិក្សា។
41. រស់ ចន្ត្រាបុត្រា (១៩៩៣) ប្រែសម្រួលដោយទីឃាយុ ប៉ារីស។
42. វង់ សុធារ៉ា និងណុប សុខា (២០០៩) ប្រវត្តិសាស្ត្រកម្ពុជា ភ្នំពេញ។
43. វ៉ាន់ ឌីកាអុន ( ? ) ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគ១។
44. ស៊ន សំណាង (២០០៨) ប្រទេសកម្ពុជាក្នុងសតវត្សរ៍ទី១៩ ភ្នំពេញ។
45. ស៊ាង ប៉េងសែ (២០០៤) កូនខ្មែរចាំបាច់ត្រូវតែដឹង បារាំង។
46. សម្ដេចព្រះនរោត្តម សីហនុ និងប៊ែណាដ៍គ្រីស័រ (១៩៩០) សម្ដេចនរោត្តម សីហនុ រំលឹកប្រវត្តិរឿងដើមជាមួយថ្នាក់ដឹកនាំខ្លះនៅលើពិភពលោក Yohan Publicantion, Japan។
47. សមាគមអ្នកសារព័ត៌មាន(១៩៩៦) រាជរដ្ឋាភិបាលកម្ពុជា១៩៤៥-១៩៩៣។
48. សាស្ត្រាចារ្យកម្ពុជាសហការជាមួយ កាតេរីន ប៊ូសា (២០០០) ឯកសារប្រវត្តិវិទ្យាសម្រាប់សាស្ត្រា ចារ្យទុតិយភូមិ ភ្នំពេញ។
49. សុខ ទូច និងប៊ុន ធឿន(២០១៧) ទំនាក់ទំនងអន្តរជាតិ រវាងកម្ពុជា និងសហរដ្ឋអាម៉េរិក ចិន និងវៀតណាម។
50. សូ សាយ (១៩៧៣) កុម្មុយនីស្តឥណ្ឌូចិ ភ្នំពេញ។

51. សេង ឪណា (២០១៣) ប្រវត្តិសាស្ត្រពិភពលោក : វិទ្យុបារាំងអន្តរជាតិ RFI។
52. សេង ឪណា (២០១៤) ប្រវត្តិសាស្ត្រពិភពលោក : វិទ្យុបារាំងអន្តរជាតិ RFI។
53. សេង ឪណា (២០១៦) ប្រវត្តិសាស្ត្រពិភពលោក : វិទ្យុបារាំងអន្តរជាតិ RFI។
54. សេង ឪណា (២០១៧) ប្រវត្តិសាស្ត្រពិភពលោក : វិទ្យុបារាំងអន្តរជាតិ RFI។
55. សេង ប៊ុនធឿន (២០១៥) រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជា ភ្នំពេញ។
56. ស្តេហ្វិន ច.ម៉ូរី (២០០៨) ហេតុម្តេចវៀតណាមលុកចូលកម្ពុជា ប្រែសម្រួលដោយអូន វីរៈ។
57. សាំង ម៉ាក់សាង (១៩៧៣) កូសាំងស៊ីនជាដែនដីរបស់ខ្មែរត្រូវប្រគល់ឱ្យខ្មែរវិញ។
58. សៅ ឆាត (១៩៩៤) ឯកសារប្រវត្តិសាស្ត្រ វិបត្តិកម្ពុជា។
59. ហ្វ្រង់ ស្វ័តាន់ (២០០៨) ភូមិសាស្ត្រនយោបាយប្រទេសចិន បោះពុម្ពដោយវ៉េយំ ភ្នំពេញ។
60. ហ្វ្រង់ ស្វ័ប៉ុងសូដ៍ (២០០៤) ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា ភ្នំពេញ។
61. ហ៊ុន សែន (?) ១០ឆ្នាំ នៃដំណើរកម្ពុជា(១៩៧៩-១៩៨៩)។
62. ហ៊ិន ស៊ីថាន (?) នរណា...ជាឃាតករ។
63. ហើស សិរីធន(២០១៤) សង្គ្រាមត្រជាក់ ភ្នំពេញ : រោងពុម្ព ពន្លឺខ្មែរ។
64. ឡឹក សំអឿន (២០០៥) ខ្មែរអ្នកជាតិនិយម។
65. អ៊ី សេ្ស អ៊ីណូអេ (២០០៣) ស្ពានរវាងបេះដូងទាំងពីរមិត្តភាពមួយដែល នាំនូវសន្តិភាពសម្រាប់កម្ពុជា។
66. អ៊ុន គាក់ (?) កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជំលោះកម្ពុជា ឆ្នាំ១៩៩១។
67. អ៊ុន យ៉េត (២០០៥) កំរងព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រសាកលលោក។
68. អ៊ុន យ៉េត (២០០៦) សម្រង់ប្រវត្តិសាស្ត្រអាល្លឺម៉ង់ និងអតីតប្លុកសូវៀត ភាគ១ : ការផ្សាយឥន្ទ្រទេវី។
69. អ៊ុន សំអន ប្រធានាធិបតីនៃសហរដ្ឋអាម៉េរិក។
70. អាដេម៉ារ ឡឺក្លែរ (២០០៥) ប្រវត្តិសាស្ត្រកម្ពុជា។
71. ឥន សុផល (២០១១) កម្ពុជាក្នុងសង្គ្រាមវៀតណាម ១៩៥៤-១៩៧៥ ភ្នំពេញ។
72. ឥន សុផល (២០១១) កម្ពុជា ក្នុងសង្គ្រាមវៀតណាម ១៩៥៤-១៩៧៥ ភ្នំពេញ។

## ខ-ភាសាបរទេស

1. Bulletin Administratif du Camboge.(1940). Imprimerie du Protectorat, Phnom Penh.
2. David W.R.(2001). Political Transition in Cambodia 1991-1999: Curzon Press.
3. David, P.C.(1992). Brother Number One.
4. Evan, G.(2003). Cambodia after the Khmer Rouge, Inside the Politics of National Building: Yale University Press.
5. Judy, L. and Dr Aron, P.(2017). Bi-Polarity & the Cold War: Hodder Education
6. Judy, L. and Dr Aron, P.(2013). The World in Crisis: Pearson Education
7. Kenton C.(?). The United States and Cambodia 1870-1969 From curiosity to confrontation
8. Martin F. Herz.(?) A short History of Cambodia, From the days of Angkor to present. New York: by Frederic A. Praeger

9. Macalister, B.& Joseph, J. Z.(1998). Cambodia Confounds the Pease Makers 1979-1998: Connell University Press.
10. Marie, A. M.(1994). Cambodia a Shattered Society: University of California Press.
11. Norodom, S. (1973). La c.i.a contre le Cambodge. Paris
12. Norodom, S.(1972). My War with the CIA: Penguin Book.
13. Penny, E.(2007) Cambodge: The Cultivation of a Nation 1860– 1945: University of Wawai'i Press
14. Raoul, M.J.(1998). Cambodia Chronicles 1989-1991: White Lotus Publiccation.
15. Sorn, S.(1995). L'évolution de la société cambodgienne entre les deux guerres mondiales (1919-1939). Thèse de Doctorat d'Histoire: Université Paris 7.
16. Sorpong, P.(2000). Intervention &Change in Cambodia: Toward Democracy? Silkworm Books, Thailand.
17. Steven, L.R.(1992). The Vietnamese Army in Cambodia, 1978 -1990: Cornell University MA Thesis.